# ព្រះត្រៃបិដក

## ប្រែរួមនឹងព្រះអដ្ឋកថា

## ភាគ២៧

បាលីប្រែ ៥១ - ៥២

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

# មនោរថបូរណី អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# អង្គុត្តរនិកាយ

# តិកនិបាត ទុតិយភាគ

# ចតុក្កនិបាត តតិយភាគ

# ២៧

## បាលីប្រែ ៤១-៤២

*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ២៧
# សុត្តន្តបិដក ទុតិយបណ្ណាសក

## ព្រាហ្មណវគ្គ
### បឋមជនសូត្រទី ១

[ ៥៣ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង មានព្រាហ្មណ៍ ២ នាក់ ជរា មានវ័យចម្រើន ចាស់ មានវ័យកន្លង ចូលដល់បច្ឆិមវ័យតាំងពីកើតមក បាន ១២០ ឆ្នាំហើយ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលរាក់ទាក់ជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររាក់ទាក់ និងពាក្យគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះព្រាហ្មណ៍ទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន យើងខ្ញុំជាព្រាហ្មណ៍ជរា មានវ័យចម្រើនហើយ ចាស់កន្លងវ័យ ចូលដល់បច្ឆិមវ័យតាំងពីកើតមក បាន ១២០ ឆ្នាំហើយ តែយើងខ្ញុំទាំងនោះ មិនបានធ្វើសេចក្តីល្អ មិនបានធ្វើកុសល មិនបានធ្វើទីពឹង ដើម្បីការពារភ័យ សូមព្រះគោតមដ៏ចម្រើន ទូន្មានយើងខ្ញុំ សូមព្រះគោតមដ៏ចម្រើន ប្រៀនប្រដៅពួកយើងខ្ញុំ ដើម្បីប្រយោជន៍ ដើម្បីសុខដល់យើងខ្ញុំអស់កាលយូរ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា អើ អ្នកទាំង-

ឡាយ ជាព្រាហ្មណ៍ជរា មានវ័យចម្រើនហើយ ចាស់កន្លងវ័យ ចូលដល់បច្ឆិមវ័យ តាំងពីកើតមកបាន ១២០ ឆ្នាំហើយ តែថា អ្នកទាំងនោះ មិនបានធ្វើសេចក្តីល្អ មិនបានធ្វើកុសល មិនបានធ្វើទីពឹង ដើម្បីការពារភ័យ ម្នាលព្រាហ្មណ៍ទាំងឡាយ សត្វលោកនេះដែលជរា ព្យាធិ មរណៈបញ្ជូនតៗ គ្នា ម្នាលព្រាហ្មណ៍ទាំងឡាយ កាលបើសត្វលោកដែលជរា ព្យាធិ មរណៈបញ្ជូនតៗ គ្នាយ៉ាងនេះ សេចក្តីសង្រួមដោយកាយ សេចក្តីសង្រួមដោយវាចា សេចក្តីសង្រួមដោយចិត្តណា ពីឥឡូវនេះទៅ បុណ្យដែលកើតអំពីសេចក្តីសង្រួមនោះ ជាទីជ្រកកោនផង ជាទីពួនផង ជាទីពឹងផង ជាទីរឭកផង ជាទីសន្សឹមផង របស់បុគ្គលអ្នកទៅកាន់បរលោកនោះ ។

ជីវិត គឺអាយុមានប្រមាណតិច ដែលជរាបញ្ជូនតៗ គ្នា
ទីពឹងទាំងឡាយ មិនមានដល់បុគ្គល ដែលជរាបញ្ជូន
តៗ គ្នាទៅ កាលបើបុគ្គលឃើញភ័យក្នុងមរណៈនុ៎ះ គួរ
ធ្វើនូវបុណ្យទាំងឡាយ ដែលជាហេតុនាំមកនូវសេចក្តី
សុខ ។ សេចក្តីសង្រួមដោយកាយវាចាចិត្តណា តាំង
ពីឥឡូវនេះទៅ បុណ្យដែលកើតអំពីការសង្រួមនោះ
រមែងប្រព្រឹត្តទៅ ដើម្បីជាសុខដល់បុគ្គលដែលទៅ
កាន់បរលោកនោះ ( ព្រោះហេតុនោះ ) កាលបើ
បុគ្គលរស់នៅ គួរតែធ្វើបុណ្យ ។

# អដ្ឋកថា

# ទុតិយបណ្ណាសក

# ព្រាហ្មណវគ្គទី ១

## បឋមជនសូត្រ

[ ៥៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមជនសូត្រទី ១ នៃព្រាហ្មណវគ្គដូច្នេះ បទថា **ជិណ្ណា** បានដល់ គ្រាំគ្រាព្រោះជរា ។ បទថា **វុឌ្ឍា** បានដល់ ចម្រើនដោយវ័យ ។ បទថា **មហល្លកា** បានដល់ ព្រោះកើតមកយូរ ។ បទថា **អទ្ធគតា** បានដល់ កន្លងវ័យពាក់កណ្ដាលទៅហើយ ។ បទថា **វយោ អនុប្បត្តា** បានដល់ ឈានចូលបច្ឆិមវ័យ ។ បទថា **យេន ភគវា តេនុបសង្កមឹសុ** សេចក្ដីថា ព្រាហ្មណ៍ឃើញកូនប្រពន្ធមិនបដិបត្តិតាមពាក្យនៃខ្លួន គិតថា អញនឹងទៅគាល់ព្រះសមណគោតម ស្វែងរកផ្លូវដែលនាំចេញចាកទុក្ខ ដូច្នេះហើយ ទើបចូលទៅគាល់ ។

បទថា **មយមស្សុ ភោ គោតម ព្រាហ្មណា** សេចក្ដីថា ព្រាហ្មណ៍ទាំង ២ ប្រកាសភាពដែលខ្លួនជាព្រាហ្មណ៍ថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គទាំង ២ ជាព្រាហ្មណ៍ មិនមែនក្សត្រ មិនមែនអមាត្យ មិនមែនគហបតី ដូច្នេះហើយ ក្រាបទូលពាក្យជាដើមថា **ជិណ្ណា** គឺខ្ញុំព្រះអង្គចាស់ហើយ ដូច្នេះ ។ បទថា **អកតភីរុត្តាណា** ព្រាហ្មណ៍ទាំង ២ សម្ដែងថា ខ្ញុំព្រះអង្គទាំង ២ មិនទាន់បានធ្វើការការពារនូវភ័យ គឺការធ្វើការដែលជាទីពឹង

ជាទីអាស្រ័យ ។ បទថា **តត្ថ** ជានិបាត ចុះក្នុងអត្ថថា ដោយចំណែកតែមួយ ឬចុះក្នុងអត្ថថា ទទួល ។ ព្រះមានព្រះភាគទ្រង់សម្តែងដោយទីបំផុតដូចគ្នាថា អ្នកទាំងឡាយយ៉ាងនេះ សូម្បីតថាគតក៏ជានាដូចគ្នា ។ បទថា **ឧបនីយតិ** បានដល់ ត្រូវនាំចូលទៅ អធិប្បាយថា សត្វលោកនេះ ត្រូវជាតិនាំទៅកាន់ជរា ត្រូវជរានាំទៅកាន់ព្យាធិ ត្រូវព្យាធិនាំទៅកាន់មរណៈ ត្រូវមរណៈនាំទៅកាន់ជាតិទៀត ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ឧបនីយតិ** ដូច្នេះ ។

ឥឡូវនេះ ព្រោះហេតុដែលព្រាហ្មណ៍ទាំងនោះ សូម្បីបួសហើយ ក៏មិនអាចបំពេញវត្តឲ្យបរិបូណ៌បាន ព្រោះជាមនុស្សចាស់ ដូច្នោះ ព្រះមានព្រះភាគ កាលនឹងឲ្យព្រាហ្មណ៍ទាំង ២ នោះ តាំងនៅក្នុងសីល ៥ ទើបត្រាស់ថា **យោធ កាយេន សញ្ញមោ** ។ បណ្តាបទទាំងនោះ បទថា **កាយេន សញ្ញមោ** ឈ្មោះថា **កាយសញ្ញម** ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ ដោយបទថា **តំ តស្ស បេតស្ស** នេះ ព្រះមានព្រះភាគទ្រង់សម្តែងថា បុណ្យនោះ ឈ្មោះថា **តាណ** ព្រោះអត្ថថា ជាទីជ្រកកោននៃបុគ្គលដែលទៅកាន់បរលោក ។ ឈ្មោះថា **លេណ** ព្រោះអត្ថថា ជាទីពួនសម្ងំ ឈ្មោះថា **ទីប** ព្រោះអត្ថថា ជាទីពឹងពុំនាក់ ឈ្មោះថា **សរណៈ** ព្រោះអត្ថថា ជាទីពឹងអាស្រ័យ និងឈ្មោះថា **បរាយណៈ** ព្រោះអំណាចឲ្យគតិខ្ពស់ឡើងបាន ។ ព្រះគាថា មានអត្ថងាយយល់ហើយ ។ ព្រាហ្មណ៍ទាំងនោះដែលព្រះតថាគត ឲ្យសមាទានសីល ៥ យ៉ាងនេះហើយ រក្សាសីល ៥

ជរាបដល់អស់ជីវិត ហើយកើតក្នុងស្ថានសួគ៌ ។

អដ្ឋកថា បឋមជនសូត្រទី ១ ចប់

# សុត្តន្តបិដក

## ទុតិយជនសូត្រទី ២

[ ៥៤ ] គ្រានោះឯង ព្រាហ្មណ៍ ២ នាក់ជរា មានវ័យចម្រើនហើយ ចាស់កន្លងវ័យ ចូលដល់បច្ឆិមវ័យ តាំងពីកើតមកបាន ១២០ ឆ្នាំហើយ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគហើយ អង្គុយក្នុងទីដ៏សមគួរ ។ លុះព្រាហ្មណ៍ទាំងនោះអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន យើងជាព្រាហ្មណ៍ជរា មានវ័យចម្រើនហើយ ចាស់កន្លងវ័យហើយ ចូលដល់បច្ឆិមវ័យតាំងពីកើតមកបាន ១២០ ឆ្នាំហើយ តែយើងទាំងនោះ មិនបានធ្វើសេចក្តីល្អ មិនបានធ្វើកុសល មិនបានធ្វើទីពឹងការពារភ័យសោះ សូមព្រះគោតមដ៏ចម្រើន ទូន្មានយើងខ្ញុំព្រះអង្គ សូមព្រះគោតមដ៏ចម្រើន ប្រៀនប្រដៅយើងខ្ញុំព្រះអង្គ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់យើងខ្ញុំព្រះអង្គ អស់កាលដ៏យូរ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា អើអ្នកទាំងឡាយ ជាព្រាហ្មណ៍ជរា មានវ័យចម្រើនហើយ ចាស់កន្លងវ័យ ចូល

ដល់បច្ឆិមវ័យ តាំងពីកើតមកបាន ១២០ ឆ្នាំហើយ តែថា អ្នកទាំងនោះ មិនបានធ្វើសេចក្ដីល្អ មិនបានធ្វើកុសល មិនបានធ្វើទីពឹងការពារភ័យសោះ ម្នាលព្រាហ្មណ៍ទាំងឡាយ សត្វលោកនេះ ក្ដៅក្រហាយព្រោះជរា ព្យាធិ មរណៈ ម្នាលព្រាហ្មណ៍ទាំងឡាយ កាលបើសត្វលោកក្ដៅក្រហាយ ព្រោះជរា ព្យាធិ មរណៈយ៉ាងនេះហើយ សេចក្ដីសង្រួមដោយកាយ សេចក្ដីសង្រួមដោយវាចា សេចក្ដីសង្រួមដោយចិត្តណា តាំងពីឥឡូវនេះទៅ បុណ្យ ( ដែលកើតអំពីសេចក្ដីសង្រួម ) នោះ ជាទីជ្រកកោនផង ជាទីពួនផង ជាទីពឹងផង ជាទីរឭកផង ជាទីសង្ឃឹមផង របស់បុគ្គលដែលទៅកាន់បរលោកនោះ ។

កាលបើផ្ទះ ត្រូវភ្លើងឆេះ ជនម្ចាស់ផ្ទះតែងជញ្ជូនភាជន៍
ណា ចេញផុត ( អំពីផ្ទះ ) ឬទ្រព្យណា ក្នុងផ្ទះនោះ
( ដែលគេជញ្ជូនចេញហើយ ) ភ្លើងឆេះមិនបាន ទ្រព្យ
នោះ រមែងបានជាប្រយោជន៍របស់គេ យ៉ាងណា
សត្វលោកដែលត្រូវភ្លើង គឺជរា និងមរណៈឆាបឆេះ
គួរប្រញាប់ជញ្ជូនចេញឲ្យផុត ( អំពីផ្ទះ គឺរាងកាយ )
ដោយការឲ្យទាន ( ព្រោះថា ) ទានដែលគេឲ្យហើយ
ឈ្មោះថា បានជញ្ជូនដោយល្អ ក៏យ៉ាងនោះដែរ ។ ការ
សង្រួមដោយកាយ វាចា ចិត្តណា ពីឥឡូវនេះទៅ
បុណ្យ ( ដែលកើតមកអំពីការសង្រួម ) នោះ រមែង

កើតសុខដល់បុគ្គល ដែលទៅកាន់បរលោកហើយនោះ
ហេតុនោះ កាលបើបុគ្គលរស់នៅ គួរតែធ្វើបុណ្យ ។

# អដ្ឋកថា

## ទុតិយជនសូត្រ

[ ៥៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយជនសូត្រទី ២ ដូច្នេះ បទថា **ភាជនំ** បានដល់ កណ្ដុះណាមួយ ។ បទដ៏សេស គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងសូត្រទី ១ ។ល។

អដ្ឋកថាទុតិយជនសូត្រទី ២ ចប់

# សុត្តន្តបិដក

## ព្រាហ្មណសូត្រទី ៣

[ ៥៥ ] គ្រានោះឯង មានព្រាហ្មណ៍ម្នាក់ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ជាមួយនឹងព្រះដ៏មានព្រះភាគ ។បេ។ លុះព្រាហ្មណ៍នោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះអង្គតែងសម្តែងថា ធម៌ដែលបុគ្គលឃើញច្បាស់ដោយខ្លួនឯង ។ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលបុគ្គលឃើញច្បាស់ដោយខ្លួនឯង ឲ្យនូវផល មិនរង់ចាំកាល គួរហៅបុគ្គលដទៃឲ្យចូលមកមើលបាន គួរបង្អោនចូលមកទុកក្នុងចិត្តរបស់ខ្លួនបាន ដែលពួកអ្នកប្រាជ្ញ គប្បីឃើញចំពោះខ្លួន តើដោយហេតុដូចម្តេច ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បុគ្គលត្រេកអរដែលរាគៈគ្របសង្កត់ មានចិត្តប្រកាន់មាំ តែងគិតដើម្បីបៀតបៀនខ្លួនឯងខ្លះ គិតដើម្បីបៀតបៀនអ្នកដទៃខ្លះ គិតដើម្បីបៀតបៀនខ្លួនឯង និងអ្នកដទៃខ្លះ ក៏រមែងរងទុក្ខ ទោមនស្សដែលប្រព្រឹត្តទៅក្នុងចិត្ត ។ កាលបើលះបង់រាគៈហើយ បុគ្គលរមែងមិនគិត ដើម្បីបៀតបៀនខ្លួនឯងផង មិនគិតដើម្បីបៀតបៀនអ្នកដទៃផង មិនគិតដើម្បីបៀតបៀនខ្លួនឯង និងអ្នកដទៃផង រមែងមិនរងទុក្ខ ទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្ត ។ ម្នាលព្រាហ្មណ៍ យ៉ាងនេះឯងហើយ ឈ្មោះថា ធម៌ដែលបុគ្គលឃើញច្បាស់ ដោយខ្លួនឯង ... ម្នាលព្រាហ្មណ៍ បុគ្គលប្រទូស្ត ដែលទោសៈគ្របសង្កត់ មានចិត្តប្រកាន់មាំ តែង

គិតដើម្បីបៀតបៀនខ្លួនឯងខ្លះ គិតដើម្បីបៀតបៀនអ្នកដទៃខ្លះ គិតដើម្បីបៀតបៀនខ្លួនឯង និងអ្នកដទៃខ្លះ ក៏រមែងទទួលទុក្ខ ទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្ត ។ កាលបើលះទោសៈបានហើយ បុគ្គលតែងមិនគិត ដើម្បីបៀតបៀនខ្លួនឯងផង មិនគិតដើម្បីបៀតបៀនអ្នកដទៃផង មិនគិតដើម្បីបៀតបៀនខ្លួនឯង និងអ្នកដទៃផង រមែងមិនទទួលទុក្ខ ទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្ត ។ ម្នាលព្រាហ្មណ៍ យ៉ាងនេះហើយ ឈ្មោះថា ធម៌ដែលបុគ្គលឃើញច្បាស់ ដោយខ្លួនឯង ... ម្នាលព្រាហ្មណ៍ បុគ្គលវង្វេង ដែលមោហៈគ្របសង្កត់ មានចិត្តប្រកាន់មាំ តែងគិតដើម្បីបៀតបៀនខ្លួនឯងខ្លះ គិតដើម្បីបៀតបៀនអ្នកដទៃខ្លះ គិតដើម្បីបៀតបៀនខ្លួនឯង និងអ្នកដទៃខ្លះ ក៏រមែងទទួលទុក្ខ ទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្ត ។ កាលបើលះមោហៈហើយ បុគ្គលមិនគិតដើម្បីបៀតបៀនខ្លួនឯងផង មិនគិតដើម្បីបៀតបៀនអ្នកដទៃផង មិនគិតដើម្បីបៀតបៀនខ្លួនឯង និងអ្នកដទៃផង រមែងមិនទទួលទុក្ខ ទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្ត ។ ម្នាលព្រាហ្មណ៍ យ៉ាងនេះហើយ ឈ្មោះថា ធម៌ដែលបុគ្គលឃើញច្បាស់ដោយខ្លួនឯង ឲ្យនូវផល មិនរង់ចាំកាល គួរហៅបុគ្គលដទៃឲ្យចូលមកមើលបាន គួរបង្អោនចូលមកទុកក្នុងចិត្តរបស់ខ្លួនបាន ដែលវិញ្ញូជនគប្បីដឹងច្បាស់ដោយខ្លួនឯង ។ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។បេ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវសរណគមន៍ ស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមទៅ ។

# អដ្ឋកថា

## ព្រាហ្មណសូត្រ

[ ៥៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងព្រាហ្មណសូត្រទី ៣ ជាបន្ត បទថា **សម្មោទនីយំ** បានដល់ ឲ្យកើតការត្រេកអរនៃចិត្ត ។ បទថា **សារាណីយំ** បានដល់ ដែលសមគួរឲ្យរឭកដល់គ្នានិងគ្នា ។ បទថា **វីតិសារេត្វា** ប្រែថា កាលឲ្យរឭកដល់គ្នានិងគ្នារួចរាល់ហើយ ។ បទថា **កត្តាវតា** ប្រែថា ដោយហេតុប៉ុន្មានយ៉ាង ។

បទថា **សន្ទិដ្ឋិកោ ធម្មោ ហោតិ** សេចក្តីថា ជាធម៌ដែលគប្បីឃើញបានដោយខ្លួនឯង ។ បទថា **អកាលិកោ** សេចក្តីថា មិនឲ្យផលក្នុងកាលដទៃ ។ ដោយបទថា **ឯហិបស្សិកោ** នេះ ព្រាហ្មណ៍ទូលសួរដល់អាគមនីយបដិបទាថា ព្រះធម៌ដែលបុគ្គលបដិបត្តិ អាចចង្អុលបង្ហាញបានយ៉ាងនេះថា **ឯហិ បស្ស** ប្រែថា អ្នកចូរមកមើលចុះ ដូច្នេះ ។ បទថា **ឱបនយិកោ** សេចក្តីថា គប្បីបង្អោនចិត្តរបស់ខ្លួនចូលទៅរក ។ បទថា **បច្ចត្តំ វេទិតព្វោ** សេចក្តីថា គប្បីជ្រាបបានដោយខ្លួនឯងនោះឯង ។ បទថា **វិញ្ញូហិ** បានដល់ បណ្ឌិតទាំងឡាយ ។ បទថា **បរិយាទិន្នចិត្តោ** បានដល់ ជាអ្នកមានចិត្តដែលរាគៈកាន់យកហើយ ចាប់ហើយ និងបញ្ចោសអង្អែលហើយ ។ បទថា **ចេតេតិ** ប្រែថា គិត ។ ពាក្យដ៏សេស ក្នុងព្រះសូត្រ ងាយយល់ទាំងអស់ហើយ ។ តែក្នុងសូត្រនេះ ព្រាហ្មណ៍ទូលសួរដល់លោកុត្តរមគ្គ សូម្បីព្រះបរមសាស្តាក៏ត្រាស់លោកុត្តរមគ្គនោះដូចគ្នា ។ ព្រោះថា លោកុត្តរមគ្គនោះ

ឈ្មោះថា **សន្ទិដ្ឋ** ព្រោះត្រូវឃើញដោយខ្លួនឯង ដូច្នេះឯង ។

**អដ្ឋកថា ព្រាហ្មណសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## បរិព្វាជកសូត្រទី ៤

[ ៥៦ ] គ្រានោះឯង មានព្រាហ្មណ៍បរិព្វាជកម្នាក់ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ។បេ។ លុះព្រាហ្មណ៍បរិព្វាជកនោះ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះអង្គតែងសម្តែងថា ធម៌ដែលបុគ្គលឃើញច្បាស់ដោយខ្លួនឯង ។ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលបុគ្គលឃើញច្បាស់ដោយខ្លួនឯង ឲ្យនូវផលមិនរង់ចាំកាល គួរហៅបុគ្គលដទៃ ឲ្យចូលមកមើលបាន គួរបង្អោនចូលមកទុកក្នុងចិត្តរបស់ខ្លួន ដែលពួកវិញ្ញូជន គប្បីដឹងច្បាស់ដោយខ្លួនឯង តើដោយហេតុដូចម្តេច ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បុគ្គលត្រេកអរ ដែលរាគៈគ្របសង្កត់ មានចិត្តប្រកាន់មាំ រមែងគិតដើម្បីបៀតបៀនខ្លួនឯងខ្លះ គិតដើម្បីបៀតបៀនអ្នកដទៃខ្លះ គិតដើម្បីបៀតបៀនខ្លួនឯងនិងអ្នកដទៃខ្លះ ក៏រមែងទទួលទុក្ខ ទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្ត ។

កាលបើលះបង់រាគៈបានហើយ បុគ្គលរមែងមិនគិត ដើម្បីបៀតបៀនខ្លួនឯង ផង មិនគិតដើម្បីបៀតបៀនអ្នកដទៃផង មិនគិតដើម្បីបៀតបៀនខ្លួនឯង និង អ្នកដទៃផង រមែងមិនទទួលទុក្ខ ទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្ត ។ ម្នាល ព្រាហ្មណ៍ បុគ្គលត្រេកអរ ដែលរាគៈគ្របសង្កត់ មានចិត្តប្រកាន់មាំ រមែង ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ កាលបើលះបង់រាគៈហើយ បុគ្គលរមែងមិនប្រព្រឹត្តទុច្ចរិតដោយកាយ មិន ប្រព្រឹត្តទុច្ចរិតដោយវាចា មិនប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ ម្នាលព្រាហ្មណ៍ បុគ្គលត្រេកអរ ដែលរាគៈគ្របសង្កត់ មានចិត្តប្រកាន់មាំ រមែងមិនដឹងនូវ ប្រយោជន៍របស់ខ្លួនតាមពិតខ្លះ មិនដឹងនូវប្រយោជន៍របស់បុគ្គលដទៃតាម ពិតខ្លះ មិនដឹងនូវប្រយោជន៍ខ្លួនឯង និងអ្នកដទៃតាមពិតខ្លះ ។ កាលបើ លះបង់រាគៈបានហើយ បុគ្គលរមែងដឹងនូវប្រយោជន៍ របស់ខ្លួនតាមពិតផង ដឹងនូវប្រយោជន៍របស់អ្នកដទៃតាមពិតផង ដឹងនូវប្រយោជន៍របស់អ្នកដទៃ តាមពិតផង ដឹងនូវប្រយោជន៍ខ្លួន និងអ្នកដទៃតាមពិតផង ។ ម្នាលព្រាហ្មណ៍ យ៉ាងនេះឯងហើយ ឈ្មោះថា ធម៌ដែលបុគ្គលឃើញច្បាស់ ដោយខ្លួនឯង ... ម្នាលព្រាហ្មណ៍ បុគ្គលប្រទូស្ត ។បេ។ ម្នាលព្រាហ្មណ៍ បុគ្គលវង្វេងដែល មោហៈគ្របសង្កត់ មានចិត្តប្រកាន់មាំ រមែងគិតដើម្បីបៀតបៀនខ្លួនឯងខ្លះ គិតដើម្បីបៀតបៀនអ្នកដទៃខ្លះ គិតដើម្បីបៀតបៀនខ្លួនឯង និងអ្នកដទៃខ្លះ ក៏ រមែងទទួលទុក្ខ ទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្ត ។ កាលបើលះបង់ មោហៈបានហើយ បុគ្គលរមែងមិនគិត ដើម្បីបៀតបៀនខ្លួនឯងផង មិនគិត

ដើម្បីបៀតបៀនអ្នកដទៃផង មិនគិតដើម្បីបៀតបៀនខ្លួនឯង និងអ្នកដទៃផង រមែងមិនទទួលទុក្ខ ទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្ត ។ ម្នាលព្រាហ្មណ៍ បុគ្គលវង្វេងដែលមោហៈគ្របសង្កត់ មានចិត្តប្រកាន់មាំ រមែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ កាលបើលះមោហៈបានហើយ បុគ្គលរមែងមិនប្រព្រឹត្តទុច្ចរិតដោយកាយ មិនប្រព្រឹត្តទុច្ចរិតដោយវាចា មិនប្រព្រឹត្តទុច្ចរិតដោយចិត្ត ម្នាលព្រាហ្មណ៍ បុគ្គលវង្វេងដែលមោហៈគ្របសង្កត់ មានចិត្តប្រកាន់មាំ រមែងមិនដឹងនូវប្រយោជន៍របស់ខ្លួនតាមពិតខ្លះ មិនដឹងនូវប្រយោជន៍របស់បុគ្គលដទៃតាមពិតខ្លះ មិនដឹងនូវប្រយោជន៍ខ្លួនឯង និងអ្នកដទៃតាមពិតខ្លះ ។ កាលបើលះមោហៈបានហើយ បុគ្គលរមែងដឹងនូវប្រយោជន៍របស់ខ្លួនតាមពិតផង ដឹងនូវប្រយោជន៍អ្នកដទៃតាមពិតផង ដឹងនូវប្រយោជន៍ខ្លួន និងអ្នកដទៃតាមពិតផង ។ ម្នាលព្រាហ្មណ៍ យ៉ាងនេះឯង ឈ្មោះថា ធម៌ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ឲ្យនូវផល មិនរង់ចាំកាល គួរហៅបុគ្គលដទៃឲ្យចូលមកមើលបាន គួរបង្អោនចូលមកទុកក្នុងចិត្តរបស់ខ្លួនបាន ដែលពួកវិញ្ញូជន គប្បីដឹងច្បាស់ដោយខ្លួនឯង ។ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។បេ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គ ថាជាឧបាសក អ្នកដល់នូវសរណគមន៍ ស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមទៅ ។

# អដ្ឋកថា

## បរិព្វាជកសូត្រ

[ ៥៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបរិព្វាជកសូត្រទី ៤ ដូច្នេះ បទថា **ព្រាហ្មណបរិព្វាជកោ** បានដល់ បរិព្វាជកដែលជាព្រាហ្មណ៍ដោយកំណើត មិនមែនក្សត្រជាដើម ដោយកំណើតឡើយ ។ បទថា **អត្តត្ថម្បិ** សេចក្តីថា ប្រយោជន៍របស់ខ្លួន ទាំងក្នុងបច្ចុប្បន្ន និងសម្បរាយភព ដែលលាយឡំដោយលោកិយ និងលោកុត្តរ ។ល។

**អដ្ឋកថា បរិព្វាជកសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## និព្វុតសូត្រទី ៥

[ ៥៧ ] គ្រានោះឯង ព្រាហ្មណ៍ឈ្មោះជានុស្សោណិ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ។បេ។ លុះជានុស្សោណិព្រាហ្មណ៍អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះអង្គតែងសម្តែងថា ព្រះនិព្វានដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ព្រះនិព្វានជាធម្មជាត ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រះនិព្វានជាធម្មជាតដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួន

ឯង ឲ្យនូវផល មិនរង់ចាំកាល គួរហៅបុគ្គលដទៃឲ្យចូលមកមើលបាន គួរបង្អោនចូលមកទុកក្នុងចិត្តរបស់ខ្លួនបាន ដែលវិញ្ញូជនទាំងឡាយ គប្បីដឹងច្បាស់ដោយខ្លួនឯង តើដោយហេតុដូចម្តេច ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បុគ្គលត្រេកអរដែលរាគៈគ្របសង្កត់ មានចិត្តប្រកាន់មាំ រមែងគិតដើម្បីបៀតបៀនខ្លួនឯងខ្លះ គិតដើម្បីបៀតបៀនអ្នកដទៃខ្លះ គិតដើម្បីបៀតបៀនខ្លួនឯង និងអ្នកដទៃខ្លះ ក៏រមែងទទួលទុក្ខ ទោមនស្ស ប្រព្រឹត្តទៅក្នុងចិត្ត ។ កាលបើលះរាគៈបានហើយ បុគ្គលរមែងមិនគិតដើម្បីបៀតបៀនខ្លួនផង មិនគិតដើម្បីបៀតបៀនអ្នកដទៃផង មិនគិតដើម្បីបៀតបៀនខ្លួនឯង និងអ្នកដទៃផង រមែងមិនទទួលទុក្ខ ទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្ត ។ ម្នាលព្រាហ្មណ៍ យ៉ាងនេះឯងហើយ ព្រះនិព្វាន ឈ្មោះថា ជាធម្មជាតដែលបុគ្គលគប្បីឃើញច្បាស់ ដោយខ្លួនឯង ... ម្នាលព្រាហ្មណ៍ បុគ្គលប្រទុស្ត ។បេ។ ម្នាលព្រាហ្មណ៍ បុគ្គលវង្វេងដែលមោហៈគ្របសង្កត់ មានចិត្តប្រកាន់មាំ រមែងគិតដើម្បីបៀតបៀនខ្លួនឯងខ្លះ គិតដើម្បីបៀតបៀនអ្នកដទៃខ្លះ គិតដើម្បីបៀតបៀនខ្លួនឯង និងអ្នកដទៃខ្លះ ក៏រមែងទទួលទុក្ខ ទោមនស្សដែលប្រព្រឹត្តទៅក្នុងចិត្ត ។ កាលបើលះបង់មោហៈហើយ បុគ្គលរមែងមិនគិតដើម្បីបៀតបៀនខ្លួនផង មិនគិតដើម្បីបៀតបៀនអ្នកដទៃផង មិនគិតដើម្បីបៀតបៀនខ្លួនឯង និងអ្នកដទៃផង រមែងមិនទទួលទុក្ខ ទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្ត ។ ម្នាលព្រាហ្មណ៍ យ៉ាងនេះឯងហើយ ព្រះនិព្វាន ឈ្មោះថា ជាធម្មជាតដែលបុគ្គលគប្បីឃើញច្បាស់ ដោយខ្លួនឯង ... ម្នាល

ព្រាហ្មណ៍ បុគ្គលនេះ ទទួលនូវការអស់រាគៈឥតសេសសល់ ទទួលនូវការអស់ទោសៈឥតសេសសល់ ទទួលនូវការអស់មោហៈ ឥតសេសសល់ ។ ម្នាលព្រាហ្មណ៍ យ៉ាងនេះឯងហើយ ព្រះនិព្វាន ឈ្មោះថា ជាធម្មជាតដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ឲ្យនូវផលមិនរង់ចាំកាល គួរហៅបុគ្គលដទៃឲ្យចូលមកមើលបាន គួរបង្អោនចូលមកទុកក្នុងចិត្តរបស់ខ្លួន ដែលពួកវិញ្ញូជនគប្បីដឹងច្បាស់ដោយខ្លួនឯង ។ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។បេ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គ ថាជាឧបាសកអ្នកដល់នូវសរណគមន៍ ស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមទៅ ។

# អដ្ឋកថា

## និព្វុតសូត្រ

[ ៥៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិព្វុតសូត្រទី ៥ ដូចតទៅនេះ បទថា **អកាលិកំ** សេចក្តីថា មិនមែនគប្បីសម្រេចក្នុងកាលដទៃទេ ។ បទថា **ឱបនយិកំ** បានដល់ គួរចូលដល់ដោយបដិបទា ។l

**អដ្ឋកថានិព្វុតសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## បលោកសូត្រទី ៦

[ ៥៨ ] គ្រានោះឯង មានព្រាហ្មណ៍មហាសាលម្នាក់ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ។បេ។ លុះព្រាហ្មណ៍មហាសាលនោះ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គបានឮពាក្យនេះ អំពីពួកព្រាហ្មណ៍ជាន់មុន មានវ័យចម្រើន ចាស់ជាអាចារ្យតៗ គ្នាមកនិយាយថា កាលពីដើម លោកនេះ ពេញពាសដោយពួកមនុស្ស ហាក់ដូចជាអវិចិមហានរក ស្រុក និគម ជនបទ រាជធានី ( ជិតៗគ្នា ) ល្មមចម្ងាយមាន់ហើរដល់ ។ បពិត្រព្រះគោតមដ៏ចម្រើន ហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឲ្យពួកមនុស្ស ក្នុងកាលឥឡូវនេះ អស់ទៅ តិចទៅ ស្រុកទៅជាមិនមែនស្រុក និគមទៅជាមិនមែននិគម នគរទៅជាមិនមែននគរ ជនបទទៅជាមិនមែនជនបទ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពួកមនុស្សឥឡូវនេះ ត្រេកអរក្នុងអធម្មរាគៈ ត្រូវវិសម-លោភៈគ្របសង្កត់ ត្រូវមិច្ឆាធម្មរួបរឹត កាលបើមនុស្សទាំងនោះ ត្រេកអរក្នុងអធម្មរាគៈ ត្រូវវិសមលោភៈគ្របសង្កត់ ត្រូវមិច្ឆាធម្មរួបរឹតហើយ ក៏ចាប់យកសស្ត្រាដ៏មុត ផ្តាច់ជីវិតគ្នានិងគ្នា ហេតុនោះ បានជាពួកមនុស្សដ៏ច្រើនក៏ធ្វើមរណកាល ។ ម្នាលព្រាហ្មណ៍ នេះជាហេតុ នេះជាបច្ច័យ ដែលនាំពួកមនុស្សក្នុងកាលឥឡូវនេះ អស់ទៅ តិចទៅ ស្រុកទៅជាមិនមែនស្រុក និគមទៅជាមិនមែននិគម នគរទៅជាមិនមែននគរ ជនបទទៅជាមិនមែន

ជនបទ ។ ម្នាលព្រាហ្មណ៍ មួយទៀត ពួកមនុស្សឥឡូវនេះ ត្រេកអរក្នុងអធម្មរាគៈ ត្រូវវិសមលោភៈគ្របសង្កត់ ត្រូវមិច្ឆាធម៌របរឹត កាលបើពួកមនុស្សទាំងនោះ ត្រេកអរក្នុងអធម្មរាគៈ ត្រូវវិសមលោភៈគ្របសង្កត់ ត្រូវមិច្ឆាធម៌របរឹត ភ្លៀងក៏មិនបង្អុរនូវមេទឹកដោយប្រពៃ ហេតុនោះ បានជាកើតទុរ្ភិក្ស សម្ទូងមិនល្អ ក្រាស៊ី ស្កកស្គ៊ី ហេតុនោះ បានជាពួកមនុស្សដ៏ច្រើនធ្វើមរណកាល ។ ម្នាលព្រាហ្មណ៍ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យពួកមនុស្សឥឡូវនេះអស់ទៅ តិចទៅ ស្រុកទៅជាមិនមែនស្រុក និគមទៅជាមិនមែននិគម នគរទៅជាមិនមែននគរ ជនបទទៅជាមិនមែនជនបទ ។ ម្នាលព្រាហ្មណ៍ មួយទៀត ពួកមនុស្សឥឡូវនេះ ត្រេកអរក្នុងអធម្មរាគៈ ត្រូវវិសមលោភៈគ្របសង្កត់ ត្រូវមិច្ឆាធម៌របរឹត កាលបើពួកមនុស្សទាំងនោះត្រេកអរក្នុងអធម្មរាគៈ ត្រូវវិសមលោភៈគ្របសង្កត់ ត្រូវមិច្ឆាធម៌របរឹតហើយ យក្ខទាំងឡាយក៏លែងពួកអមនុស្សដ៏កាច ( ឲ្យចាប់ ) ហេតុនោះបានជាមនុស្សដ៏ច្រើន ធ្វើមរណកាល ។ ម្នាលព្រាហ្មណ៍ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យពួកមនុស្សឥឡូវនេះ អស់ទៅ តិចទៅ ស្រុកទៅជាមិនមែនស្រុក និគមទៅជាមិនមែននិគម នគរទៅជាមិនមែននគរ ជនបទទៅជាមិនមែនជនបទ ។ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។បេ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គ ថាជាឧបាសក អ្នកដល់នូវសរណគមន៍ ស្មើដោយជីវិតតាំងអំពីថ្ងៃនេះជាដើមទៅ ។

# អដ្ឋកថា

## បលោភសូត្រ

[ ៥៨ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងបលោភសូត្រទី ៦ ដូចតទៅនេះ បទថា* **អាចរិយាចរិយានំ** *សេចក្តីថា អាចារ្យទាំងឡាយក្តី អាចារ្យនៃអាចារ្យទាំងឡាយក្តី ។ បទថា* **អវីចិ មញ្ញេ ផុដ្ឋោ ហោតិ** *សេចក្តីថា ពេញទៅដោយមនុស្សទាំងឡាយ ដូចអវីចីមហានរកដែលសត្វពាល់ត្រូវហើយ គឺពេញទៅដោយពពួកសត្វនរកជានិច្ចនិរន្តរ ។ បទថា* **កុក្កុដសម្បាតិកា** *សេចក្តីថា ការហើរធ្លាក់របស់មាន់ ពោល គឺការដែលមាន់ហើរទៅអំពីដំបូលរបស់ផ្ទះមួយ ទៅធ្លាក់ត្រង់ដំបូលផ្ទះមួយទៀត មាននៅក្នុងភូមិទាំងនេះ ព្រោះហេតុនោះ ទើបផ្ទះទាំងនោះ ឈ្មោះថា* **កុក្កុដសម្បាតិក** *ប្រែថា មាននៅរយៈចម្ងាយមាន់ហើរធ្លាក់ ។ បាឋៈថា* **កុក្កុដសម្បាទិកា** *ក៏មាន អធិប្បាយថា ការធ្លាក់របស់មាន់ ពោល គឺការឈានដើរទៅរបស់មាន់អំពីចន្លោះភូមិទៅកាន់ចន្លោះភូមិ មាននៅក្នុងភូមិទាំងនោះ ។ បទទាំង ២ នេះ ព្រះមានព្រះភាគទ្រង់សម្តែងដល់ការនៅជាមួយគ្នាយ៉ាងកុះករនោះឯង ។ បទថា* **អធម្មរាគរត្តា** *សេចក្តីថា រាគៈ ជាអធម៌ដោយចំណែកមួយប៉ុណ្ណោះ តែរាគៈដែលកើតឡើងក្នុងបរិក្ខាររបស់ខ្លួន ទ្រង់មិនសំដៅយកថា ជាអធម្មរាគៈឡើយ រាគៈដែលកើតឡើងក្នុងបរិក្ខាររបស់អ្នកដទៃ ទើបទ្រង់បំណងយកថា ជាអធម្មរាគៈ ។*

*បទថា* **វិសមលោភាភិភូតា** *សេចក្តីថា ឈ្មោះថា លោភៈ នឹងមាន*

កាលស្មើមិនមាន ។ លោកៈនេះមិនស្មើដោយចំណែកមួយប៉ុណ្ណោះ តែកាលកើតឡើងក្នុងវត្ថុដែលខ្វះខាងហួងហែង ឈ្មោះថា **សមលោភ** ដែលកើតឡើងក្នុងវត្ថុដែលអ្នកដទៃហួងហែងប៉ុណ្ណោះ ទ្រង់បំណងយកថា **វិសមលោភ ។** បទថា **មិច្ឆាធម្មបរេតា** សេចក្តីថា ប្រកបដោយធម៌ចំណែកខុស ពោល គឺការសេពវត្ថុដែលមិនមែនវត្ថុ ។

បទថា **ទេវោ ន សម្មា ធារំ អនុប្បវេច្ឆតិ** សេចក្តីថា ភ្លៀងមិនធ្លាក់ក្នុងកាលដែលគួរធ្លាក់ ។ បទថា **ទុព្ភិក្ខំ** បានដល់ អាហាររកបានដោយក្រ ។ បទថា **ទុស្សស្សំ** សេចក្តីថា ឈ្មោះថា សម្លូងវិនាស ព្រោះសម្លូងច្រើនប្រភេទមិនចេញផ្លែ ។ បទថា **សេតដ្ឋិកំ** សេចក្តីថា កាលសម្លូងកំពុងចេញកួរ ពួកដង្កូវនាំគ្នាស៊ីត្រង់កួរស្រូវដែលចេញហើយ កួរស្រូវមានពណ៌ស មិនមានសាច់ ព្រោះត្រូវដង្កូវទាំងនោះរូងជញ្ជក់ ទ្រង់សំដៅយកស្រូវស្កកនោះ ទើបត្រាស់ថា **សេតដ្ឋិកំ** ដូច្នេះ ។ បទថា **សលាកាវុត្តំ** សេចក្តីថា សម្លូងដែលព្រោះហើយ ដុះត្រឹមតែដើមប៉ុណ្ណោះ អធិប្បាយថា មិនមានកួរ ។ បទថា **យក្ខា** បានដល់ យក្ខជាអធិបតី ។ បទថា **វាឡេ អមនុស្សេ ឱស្សជ្ជន្តិ** សេចក្តីថា លែងយក្ខកាចទៅក្នុងដែនដីមនុស្ស យក្ខទាំងនោះបានឱកាស រមែងធ្វើឲ្យមហាជនដល់នូវការអស់ជីវិត ។៚

**អដ្ឋកថាបលោភសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## វច្ឆសូត្រទី ៧

[ ៥៩ ] គ្រានោះឯង វច្ឆគោត្តបរិព្វាជក ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះវច្ឆគោត្តបរិព្វាជកអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គបានឮពាក្យនេះថា ព្រះសមណគោតមត្រាស់យ៉ាងនេះថា បុគ្គលគួរឲ្យទានដល់តថាគត មិនគួរឲ្យទានដល់ពួកជនដទៃឡើយ បុគ្គលគួរឲ្យទានដល់ពួកសាវកតថាគត មិនគួរឲ្យទានដល់ពួកសាវកគ្រូដទៃឡើយ ទានដែលបុគ្គលឲ្យដល់តថាគតហើយ មានផលច្រើន ទានដែលបុគ្គលឲ្យដល់ពួកជនដទៃ មិនមានផលច្រើនទេ ទានដែលបុគ្គលឲ្យដល់ពួកសាវកនៃតថាគត មានផលច្រើន ទានដែលបុគ្គលឲ្យដល់ពួកសាវករបស់គ្រូដទៃ មិនមានផលច្រើនទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ពួកជនណា និយាយយ៉ាងនេះថា ព្រះសមណគោតមត្រាស់យ៉ាងនេះថា បុគ្គលគួរឲ្យទានដល់តថាគតតែមួយយ៉ាង មិនគួរឲ្យទានដល់ពួកជនដទៃឡើយ បុគ្គលគួរឲ្យទានដល់ពួកសាវករបស់តថាគតតែមួយយ៉ាង មិនគួរឲ្យទានដល់ពួកសាវករបស់គ្រូដទៃឡើយ ទានដែលបុគ្គលឲ្យដល់តថាគត មានផលច្រើន ទានដែលបុគ្គលឲ្យដល់ពួកជនដទៃ មិនមានផលច្រើនទេ ទានដែលបុគ្គលឲ្យដល់ពួកសាវកតថាគត មានផលច្រើន ទានដែលបុគ្គលឲ្យ

ដល់ពួកសាវករបស់គ្រូដទៃ មិនមានផលច្រើនឡើយ ។ ពួកជនទាំងនោះ ឈ្មោះថា និយាយតាមពាក្យដែលព្រះគោតមដ៏ចម្រើនពោលហើយ មិននិយាយបន្តាច់ព្រះគោតមដ៏ចម្រើន ដោយពាក្យមិនពិត ទាំងឈ្មោះថាព្យាករនូវធម៌សមគួរដល់ធម៌ លំនាំនៃពាក្យ ប្រកបដោយហេតុនីមួយ មិនមកកាន់ឋានៈដែលគប្បីតិះដៀលទេឬ ព្រោះយើងមិនមានប្រាថ្នាដើម្បីនិយាយបន្តាច់ព្រះគោតមដ៏ចម្រើនទេ ។ ម្នាលវច្ឆៈ ពួកជនណា និយាយយ៉ាងនេះថា ព្រះសមណគោតមត្រាស់យ៉ាងនេះថា បុគ្គលត្រូវឲ្យទានដល់តថាគតតែមួយយ៉ាង ។បេ។ ទានដែលបុគ្គលឲ្យដល់ពួកសាវករបស់ពួកគ្រូដទៃ មិនមានផលច្រើនទេ ពួកជនទាំងនោះ ឈ្មោះថា មិននិយាយតាមពាក្យដែលតថាគតពោលហើយ មួយទៀត ពួកជនទាំងនោះ ឈ្មោះថា និយាយបន្តាច់តថាគតដោយពាក្យមិនទៀង មិនពិត ម្នាលវច្ឆៈ អ្នកណាហាមឃាត់បុគ្គលដទៃកំពុងឲ្យទាន អ្នកនោះឈ្មោះថា ធ្វើអន្តរាយដល់ជន ៣ នាក់ ឈ្មោះថាបៀតបៀនដល់ជន ៣ នាក់ ។ ដល់ជន ៣ នាក់ដូចម្តេច ។ គឺជាអ្នកធ្វើឲ្យអន្តរាយបុណ្យរបស់ទាយក ១ ធ្វើឲ្យអន្តរាយលាភរបស់បដិគ្គាហកទាំង-ឡាយ ១ គាស់រម្លើងគុណរបស់ខ្លួនផង កម្ចាត់គុណរបស់ខ្លួនផង ដែលមានក្នុងកាលមុន ១ ។ ម្នាលវច្ឆៈ អ្នកណាហាមឃាត់បុគ្គលដទៃកំពុងឲ្យទាន អ្នកនោះឈ្មោះថា ធ្វើអន្តរាយដល់ជនទាំង ៣ នាក់នេះ បៀតបៀនដល់ជនទាំង ៣ នាក់នេះ ។ ម្នាលវច្ឆៈ ចំណែកខាងតថាគតពោលយ៉ាងនេះថា សូម្បីពួកសត្វមានជីវិតណា ដែលនៅក្នុងអណ្តូងស្មោកគ្រោកក្តី រណ្តៅស្មោក

គ្រោកក្តី ជនណាចាក់នូវទឹកលាងចានក្តី ទឹកលាងឆ្នាំងក្តី ក្នុងទីស្មោកគ្រោកនោះ ដោយគិតថា ពួកសត្វណាមានក្នុងទីស្មោកគ្រោកនោះ សត្វទាំងនោះ ចូរញុំាងជីវិតឲ្យរស់នៅ ដោយកាកអាហារនោះចុះ ម្នាលវច្ឆៈ គ្រាន់តែប៉ុណ្ណឹងទេ តថាគតហៅថាហេតុជាទីមកនៃបុណ្យ ចាំបាច់ពោលទៅ ថ្វីដល់ពួកមនុស្ស ។ ម្នាលវច្ឆៈ តថាគតគ្រាន់តែពោលថា ទានដែលឲ្យដល់បុគ្គលមានសីល មានផលច្រើន ដល់បុគ្គលទ្រុស្តសីល មិនដូច្នោះទេ ។ ព្រោះបុគ្គលមានសីលនោះ លះអង្គ ៥ ប្រកបដោយអង្គ ៥ ។ លះអង្គ ៥ ដូចម្តេច ។ គឺជាអ្នកលះកាមច្ឆន្ទៈ ១ លះព្យាបាទ ១ លះថីនមិទ្ធៈ ១ លះឧទ្ធច្ចកុក្កុច្ចៈ ១ លះវិចិកិច្ឆា ១ ។ នេះ ឈ្មោះថា លះអង្គ ៥ ។ បុគ្គលប្រកបដោយអង្គ ៥ តើដូចម្តេច ។ គឺជាអ្នកប្រកបដោយសីលក្ខន្ធជាអសេក្ខៈ ១ ប្រកបដោយសមាធិក្ខន្ធជាអសេក្ខៈ ១ ប្រកបដោយបញ្ញាក្ខន្ធជាអសេក្ខៈ ១ ប្រកបដោយវិមុត្តិក្ខន្ធជាអសេក្ខៈ ១ ប្រកបដោយវិមុត្តិញាណទស្សនក្ខន្ធជាអសេក្ខៈ ១ ។ បុគ្គលប្រកបដោយអង្គទាំង ៥ នេះ ។ តថាគតពោលថា ទានដែលបុគ្គលឲ្យចំពោះបុគ្គលអ្នកលះអង្គ ៥ ប្រកបដោយអង្គ ៥ មានផលច្រើន ដោយប្រការដូច្នេះ ។

គោឈ្មោល កើតក្នុងពួកមេគោណាមួយ ទោះសម្បុរ
ខ្មៅក្តី សក្តី ក្រហមក្តី លឿងក្តី ពព្រុសក្តី មានរូបរាង
ស្រដៀងនឹងកូនរាក្តី ប្រផេះក្តី ដែលគេបង្ហាត់បានបត់
ជាគោសម្រាប់ដឹកនាំ បរិបូណ៌ដោយកម្លាំង មាន

សម្បុះល្អ គេទឹមគោនោះក្នុងរទេះ គេមិនបានគិតគូរ ដល់ពណ៌សម្បុរនៃគោនោះឡើយ យ៉ាងណាមិញ បុគ្គលល្អកើតក្នុងត្រកូលណាមួយ ទោះជាក្សត្រិយ៍ក្តី ព្រាហ្មណ៍ក្តី វេស្សៈក្តី សុទ្ទៈក្តី ចណ្ឌាលក្តី បុក្កុសៈក្តី ដែលបានទូន្មានចិត្តឲ្យប្រាសចាកកិលេស ស្ថិតនៅក្នុងធម៌ បរិបូណ៌ដោយសីល និយាយពាក្យសច្ចៈ មានចិត្តប្រកបដោយហិរិ លះជាតិ និងមរណៈ បរិបូណ៌ដោយព្រហ្មចារ្យ មានភារៈដាក់ចុះហើយ ប្រាសចាករាគៈ មានសោឡសកិច្ចធ្វើស្រេចហើយ មិនមានអាសវៈ ជាអ្នកដល់ត្រើយ នៃធម៌ទាំងអស់ មិនប្រកាន់មាំ ប្រាសចាកកម្តៅ គឺកិលេស ទានដែលបុគ្គលឲ្យហើយក្នុងខេត្តដែលប្រាសចាកធូលី មានរាគៈជាដើមនោះឯង ជាទានមានផលធំទូលាយ ក៏យ៉ាងនោះដែរ ។ ចំណែកខាងពួកបុគ្គលពាល អប្បប្រាជ្ញា មិនបានរៀនសូត្រ មិនស្គាល់ ( បុញ្ញក្ខេត្ត ) រមែងឲ្យទានខាងក្រៅ ( ពុទ្ធសាសនា ) មិនដែលចូលទៅជិតពួកសប្បុរស ។ បើពួកបុគ្គលណា ចូលទៅជិតពួកសប្បុរស ជាអ្នកមានប្រាជ្ញា សន្មតថា ជាអ្នកប្រាជ្ញ សទ្ធាជាឫសគល់ របស់ពួកបុគ្គលនោះ ស្ថិតនៅក្នុង

ព្រះសុគត បុគ្គលទាំងនោះ រមែងទៅកាន់ទេវលោក ឬក៏កើតក្នុងត្រកូល ( មានត្រកូលក្សត្រិយ៍ជាដើម ) នាលោកនេះ ជាពួកបណ្ឌិត សម្រេចនូវព្រះនិព្វានតាមលំដាប់ ។

# អដ្ឋកថា

## ជប្បសូត្រ

[ ៥៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងជប្បសូត្រទី ៧ ដូច្នេះ បទថា **មហប្ផលំ** ប្រែថា មានផលច្រើន ។ ក្នុងបទថា **ធម្មស្ស ច អនុធម្មំ ព្យាករោន្តិ** នេះ គប្បីជ្រាបអធិប្បាយដូចតទៅនេះថា វាចាដែលព្រះមានព្រះភាគត្រាស់ហើយ ឈ្មោះថា **ព្រះធម៌** ការត្រាស់បទបន្តបន្ទាប់ និងបទដែលត្រាស់ហើយ ឈ្មោះថា **អនុធម៌** ។

បទថា **សហធម្មិកោ** បានដល់ ព្រមដោយការណ៍ ព្រមដោយហេតុ ។ ការកាន់តាម គឺការអនុលោមតាម អធិប្បាយថា ការប្រព្រឹត្តតាមវាចា ឈ្មោះថា **វាទានុវាទ** ។ បទថា **គារយ្ហំ ឋានំ** បានដល់ ហេតុដែលគួរនិន្ទា ។ លោកអធិប្បាយថា ការអនុលោមតាមពាក្យដែលមានហេតុផល ដែលព្រះគោតមដ៏ចម្រើនត្រាស់ហើយ មិនគួរដល់ហេតុដែលគួរតិះដៀលណាមួយ

ឡើយ ។ ម្យ៉ាងទៀត ព្រាហ្មណ៍សួរថា ការអនុលោមតាមព្រឹត្តិការណ៍របស់វាទ: ដែលមានហេតុ ដែលបុគ្គលទាំងនោះពោលហើយ និងដល់ហេតុដែលគួរតិះដៀលណាមួយមិនមាន ។

បទថា **អន្តរាយករោ ហោតិ** សេចក្តីថា ធ្វើនូវអន្តរាយ គឺការវិនាស គឺឲ្យបានទួលសេចក្តីលំបាក បានដល់ ឲ្យកើតការក្តៅក្រហាយ ។ បទថា **ចារិបន្ថិកោ** បានដល់ ចោរដែលវាយគ្នាចាំប្លន់អ្នកដើរផ្លូវ ។ បទថា **ខតោ ច ហោតិ** បានដល់ ត្រូវជីក ដោយគាស់រម្លើងនូវគុណចោលទៅ ។ បទថា **ឧបហតោ** បានដល់ ត្រូវកម្ចាត់ដោយការទម្លាយនូវគុណ ។ បទថា **ចន្ទ-និកាយ** បានដល់ ក្នុងអណ្តូងភក់ដែលមិនស្អាត ។ បទថា **ឱឡិគ្គល្លេ** បានដល់ លូដែលមិនទាន់លាងភក់ ។ បទថា **សោ ច** បានដល់ ព្រះខីណា-ស្រព ដែលលោកពោលថា ជាអ្នកមានសីលនោះ ។ បទថា **សីលក្ខន្ធេន** ប្រែថា ដោយគំនរសីល ។ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ បច្ច-វេក្ខណញ្ញាណ ព្រះមានព្រះភាគត្រាស់ហៅថា វិមុត្តិញ្ញាណទស្សនៈ ក្នុងពាក្យថា **វិមុត្តិញ្ញាណទស្សនក្ខន្ធេន** នេះ ។ បច្ចវេក្ខណញ្ញាណនោះ ព្រះមានព្រះភាគត្រាស់ថា **អសេក្ខ** ព្រោះប្រព្រឹត្តទៅហើយដល់ព្រះអសេក្ខៈ ។ ញាណក្រៅអំពីនេះ សូម្បីខ្លួនឯង ក៏ជាអសេក្ខៈស្រាប់ហើយ ព្រោះសម្រេចហើយ ក្នុងទីបំផុតនៃសិក្ខា ។ ញាណទាំងនោះក៏ជាលោកុត្តរ បច្ចវេក្ខណ-ញ្ញាណជាលោកិយ ។

បទថា **រោហិណីសុ** បានដល់ មានពណ៌ក្រហម ។ បទថា **សរូបាសុ**

បានដល់ មានពណ៌ដូចកូនគោរបស់ខ្លួន ។ បទថា **បារេវតាសុ** បានដល់ មានពណ៌ដូចសត្វព្រាប ។ បទថា **ទន្តោ** បានដល់ អស់ព្យសន៍ហើយ ។ គោឈ្មោល ឈ្មោះថា **បុង្គវោ ។** បទថា **ធោរេយ្ហោ** បានដល់ គោបម្រើ ។ បទថា **កល្យាណជវនិក្កមោ** បានដល់ ប្រកបដោយបដិភាណល្អ គឺស្មោះត្រង់ ។ បទថា **នាស្ស វណ្ណំ បរិក្ខរេ** សេចក្តីថា មិនដាក់ចិត្តដល់ពណ៌រាងកាយនៃគោនោះ តែដាក់ចិត្តចំពោះការងារ គឺការប្រកបធុរៈរបស់គោប៉ុណ្ណោះ ។

បទថា **យស្មឹ កស្មិញ្ចិ ជាតិយេ** សេចក្តីថា កើតហើយក្នុងត្រកូលណាមួយ ។ បទថា **យាសុ កាសុចិ ឯតាសុ** បានដល់ ក្នុងកំណើតណាមួយ ញែកប្រភេទជាក្សត្រជាដើមទាំងនេះ ។ បទថា **ព្រហ្មចរិយស្ស កេវលី** សេចក្តីថា ប្រកបដោយការនៅចប់ព្រហ្មចរិយៈ អធិប្បាយថា ប្រកបដោយភាពជាអ្នកបរិបូណ៌ដោយព្រហ្មចរិយៈ ។ ព្រោះថា ព្រះខីណាស្រព ឈ្មោះថា ជាអ្នកប្រព្រឹត្តព្រហ្មចរិយៈទាំងមូល ដោយហេតុនោះ ទើបលោកពោលពាក្យនេះ ។

បទថា **បន្នភារោ** បានដល់ ដាក់នូវភារៈហើយ អធិប្បាយថា ដាក់នូវភារៈ គឺខន្ធភារៈ គឺកិលេសភារៈ គឺកាមគុណបានហើយ ។ បទថា **កតកិច្ចោ** គឺធ្វើកិច្ចដោយមគ្គទាំង ៤ ស្រេចហើយ ។ បទថា **បារគូ សព្វធម្មានំ** សេចក្តីថា បញ្ចក្ខន្ធ អាយតនៈ ១២ ធាតុ ១៨ ត្រាស់ហៅថា **សព្វធម្ម ។** ឈ្មោះថា **បារគូ** ព្រោះដល់នូវត្រើយ ៦ យ៉ាង គឺ **អភិញ្ញាបារំ**

ត្រើយ គឺអភិញ្ញា ១ **បរិញ្ញាបារំ** ត្រើយ គឺបរិញ្ញា ១ **បហានបារំ** ត្រើយ គឺបហាន ១ **ភាវនាបារំ** ត្រើយ គឺភាវនា ១ **សច្ឆិកិរិយាបារំ** ត្រើយ គឺសច្ឆិកិរិយា ១ **សមាបត្តិបារំ** ត្រើយ គឺសមាបត្តិ ១ ។ នៃសព្វធម៌នោះ ។ បទថា **អនុបាទាយ** បានដល់ មិនកាន់យក ។ បទថា **និព្វុតោ** បានដល់ វៀរចាកការក្តៅក្រហាយព្រោះកិលេស ។ បទថា **វិរជេ** បានដល់ វៀរចាកធូលី គឺរាគៈ ទោសៈ និងមោហៈ ។

បទថា **អវិជានន្តា** បានដល់ មិនដឹងបុញ្ញក្ខេត្ត ។ បទថា **ទុម្មេធា** បានដល់ មិនមានបញ្ញា ។ បទថា **អស្សុតាវិនោ** បានដល់ វៀរចាកការបានឮ ការវិនិច្ឆ័យ ទាក់ទងនឹងបុញ្ញក្ខេត្ត ។ បទថា **ពហិទ្ធា** បានដល់ ខាងក្រៅសាសនានេះ ។ បទថា **ន ហិ សន្តេ ឧបាសរេ** សេចក្តីថា មិនចូលទៅរកព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រពទាំងឡាយ ដែលជាឧត្តមបុរស ។ បទថា **ធីរសម្មតេ** បានដល់ បណ្ឌិតសរសើរហើយ លើកតម្កើងហើយ ។ បទថា **មូលជាតា បតិដ្ឋិតា** នេះ ទ្រង់សម្តែងដល់សទ្ធារបស់ព្រះសោតាបន្ន ។ បទថា **កុលេ វា ឥធ ជាយរេ** សេចក្តីថា ឬកើតក្នុងត្រកូលក្សត្រ ត្រកូលព្រាហ្មណ៍ ត្រកូលវេស្សៈ ក្នុងមនុស្សលោកនេះ ។ បុគ្គលនេះឯង ឈ្មោះថា មានកុលសម្បត្តិ ៣ ប្រការ ។ បទថា **អនុបុព្វេន និព្វានំ អធិគច្ឆន្តិ** សេចក្តីថា បំពេញគុណធម៌ទាំងនេះ គឺសីល សមាធិ បញ្ញាឲ្យបរិបូណ៌ រួចសម្រេចព្រះនិព្វានតាមលំដាប់ ដូច្នេះឯង ។

**អដ្ឋកថា ជប្បសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## តិកណ្ណសូត្រទី៨

[ ៦០ ] គ្រានោះឯង តិកណ្ណព្រាហ្មណ៍ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលសេចក្តីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យគួររីករាយ និងពាក្យគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះតិកណ្ណព្រាហ្មណ៍អង្គុយក្នុងទីសមគួរហើយ ក៏និយាយសរសើរព្រាហ្មណ៍ទាំងឡាយ អ្នកបានវិជ្ជា ៣ ចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគថា ពួកព្រាហ្មណ៍បានវិជ្ជា ៣ យ៉ាងនេះ ពួកព្រាហ្មណ៍បានវិជ្ជា ៣ ដូច្នេះ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ចុះពួកព្រាហ្មណ៍បញ្ញត្តព្រាហ្មណ៍អ្នកបានវិជ្ជា ៣ ដោយប្រការយ៉ាងណា ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រាហ្មណ៍ក្នុងលោកនេះ ជាឧភតោសុជាត ( មានជាតិល្អទាំងពីរខាង ) គឺអំពីមាតាផង អំពីបិតាផង កើតអំពីផ្ទៃដ៏បរិសុទ្ធស្អាត ដែលបុគ្គលមិនរង្កៀស មិនតិះដៀល ដោយពោលអំពីជាតិបានដរាបអំពីជួរជីតាគម្រប់ ៧ ជាអ្នករាយមន្ត ចេះចាំមន្ត ជាអ្នកដល់ត្រើយនៃត្រៃវេទ ព្រមទាំងគម្ពីរនិឃណ្ឌុ និងកេដុភៈ ព្រមទាំងអក្ខរប្បភេទ គឺសិក្ខា និងនិរុត្តិ មានគម្ពីរឥតិហាសៈជាគម្រប់ ៥ ជាអ្នកចេះបទ និងវេយ្យាករណ៍ ជាអ្នកមិនខ្វះថយ គឺស្ទាត់ជំនាញក្នុងលោកាយតសាស្ត្រ និងមហាបុរិសលក្ខណសាស្ត្រ ។ បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍បញ្ញត្តព្រាហ្មណ៍អ្នកបានវិជ្ជា ៣ យ៉ាងនេះឯង ។ ម្នាលព្រាហ្មណ៍ ពួកព្រាហ្មណ៍បញ្ញត្តព្រាហ្មណ៍អ្នកបានវិជ្ជា ៣ ដោយ

ខ្សែក ឯវិជ្ជា ៣ ក្នុងវិន័យរបស់អរិយៈដោយខ្សែក ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះវិជ្ជា ៣ ក្នុងវិន័យរបស់អរិយៈ តើដូចម្ដេច វិជ្ជា ៣ ក្នុងវិន័យរបស់អរិយៈយ៉ាងណា សូមព្រះគោតមដ៏ចម្រើន មេត្តាសម្ដែងធម៌យ៉ាងនោះដល់ខ្ញុំព្រះអង្គ ។ ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរប្រុងស្ដាប់ ប្រុងធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្ដែង ។ តិកណ្ណព្រាហ្មណ៍ទទួលស្ដាប់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគបានត្រាស់ដូច្នេះថា ម្នាលព្រាហ្មណ៍ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កនិងវិចារ មានបីតិ និងសុខកើតអំពីវិវេក សម្រេចសម្រាន្តនៅ ព្រោះស្ងប់វិតក្ក វិចារ ក៏ចូលដល់ទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្ដានខ្លួនប្រកបដោយសេចក្ដីជ្រះថ្លា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក វិចារមានតែបីតិ និងសុខកើតអំពីសមាធិ សម្រេចសម្រាន្តនៅ ព្រោះប្រាសចាកបីតិផង ជាអ្នកព្រងើយកន្តើយ មានសតិសម្បជញ្ញៈផង ទទួលសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយ តែងសរសើរបុគ្គលដែលបានតតិយជ្ឈាននោះថា ប្រកបដោយឧបេក្ខា មានស្មារតី មានកិរិយានៅជាសុខ ដូច្នេះព្រោះតតិយជ្ឈានណា ក៏ចូលកាន់តតិយជ្ឈាននោះ សម្រេចសម្រាន្តនៅព្រោះលះបង់សុខផង លះបង់ទុក្ខផង អស់សោមនស្ស ទោមនស្ស ក្នុងកាលមុនផង ក៏ចូលកាន់ចតុត្ថជ្ឈាន មានអារម្មណ៍មិនជាទុក្ខ មិនជាសុខមានសតិដ៏បរិសុទ្ធ ដោយឧបេក្ខា សម្រេចសម្រាន្តនៅ ។ កាលបើចិត្តតាំង

ខ្ជាប់ខ្ជួន បរិសុទ្ធស្អាត មិនមានកិលេស ប្រាសចាកឧបក្កិលេស ជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តមិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះក៏បង្អោនចិត្តទៅ ដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ភិក្ខុនោះរឭកឃើញនូវខន្ធ ដែលសត្វ អាស្រ័យនៅក្នុងកាលមុនជាច្រើនប្រការ គឺរឭកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជាតិខ្លះ ១០០០ ជាតិខ្លះ ១០០០០០ ជាតិ ខ្លះ រឭកអស់សំវដ្តកប្បជាច្រើន វិវដ្តកប្បជាច្រើន សំវដ្តវិវដ្តកប្បជាច្រើន ក៏បានថា អាត្មាអញបានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មាន គោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខ និងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណោះ លុះអាត្មាអញនោះ ច្យុតចាក អត្តភាពនោះហើយ ក៏បានទៅកើតក្នុងភពឯណោះ ដែលកើតក្នុងភពនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារ យ៉ាងនេះ បានទទួលសុខ និងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណោះ អាត្មាអញនោះ លុះច្យុតចាកអត្តភាពនោះហើយ ក៏បានមកកើតក្នុងភពនេះ ភិក្ខុនោះរឭកបាននូវខន្ធ ដែលខ្ជួននៅក្នុងកាលមុនជាច្រើនប្រការ ព្រមទាំង អាការ គឺសម្បុរ និងអាហារជាដើម ព្រមទាំងឧទ្ទេស គឺឈ្មោះ និងគោត្រ ដោយប្រការដូច្នេះ ។ នេះជាវិជ្ជាទី ១ ដែលភិក្ខុនោះបានសម្រេចហើយ អវិជ្ជាក៏បាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតបាត់ទៅ ពន្លឺក៏កើតឡើង ( ជាផល ) សមគួរដល់ភិក្ខុមិនមានសេចក្តីប្រមាទ មានសេចក្តីព្យាយាម ជាគ្រឿងដុត

កម្តៅកិលេស មានចិត្តបញ្ជូនទៅរកព្រះនិព្វាន ។ កាលបើចិត្តតាំងខ្ជាប់ខ្ជួន បរិសុទ្ធស្អាត មិនមានកិលេស ប្រាសចាកឧបក្កិលេស ជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តមិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះក៏បង្អោនចិត្តទៅដើម្បី សត្តានំ ចុតូបបាតញាណ ភិក្ខុនោះ មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងចក្ខុជារបស់មនុស្សធម្មតា រមែងឃើញពួកសត្វដែលកំពុងច្យុត ដែលកំពុងកើត ដឹងច្បាស់នូវពួកសត្វថោកទាប ឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួនថា អើហ្ន៎ ពួកសត្វនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលព្រះអរិយៈទាំងឡាយ ជាមិច្ឆាទិដ្ឋិ ប្រកាន់អំពើមិច្ឆាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក អើហ្ន៎ ឯពួកសត្វទាំងអម្បាលនេះ បានប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត មិនតិះដៀលព្រះអរិយៈទាំងឡាយ ជាសម្មាទិដ្ឋិ ប្រកាន់អំពើជាសម្មាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិ សួគ៌ទេវលោក ភិក្ខុនោះ មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងចក្ខុរបស់មនុស្សធម្មតា រមែងឃើញពួកសត្វ ដែលច្យុត ដែលកើត ក៏ដឹងច្បាស់នូវពួកសត្វថោកទាប ឧត្តម មានសម្បុរល្អ សម្បុរអាក្រក់ មានគតិល្អ គតិអាក្រក់ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ដោយប្រការដូច្នេះ ។ នេះជាវិជ្ជាទី ២ ដែលភិក្ខុនោះបានសម្រេចហើយ អវិជ្ជាបាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតបាត់ទៅ ពន្លឺក៏កើត

ឡើង ( ជាផល ) សមគួរដល់ភិក្ខុអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅរកព្រះនិព្វាន ។ កាលបើចិត្តតាំងខ្ជាប់ខ្ជួនបរិសុទ្ធផូរផង់ មិនមានកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនៃកម្ម ជាចិត្តមិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះ ក៏បង្អោនចិត្តទៅដើម្បីអាសវក្ខយញ្ញាណ ភិក្ខុនោះដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះជាសេចក្តីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាបដិបទានាំឲ្យបានដល់នូវសេចក្តីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាអាសវៈទាំងឡាយ ដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតអាសវៈ ដឹងច្បាស់តាមពិតថា នេះជាសេចក្តីរលត់អាសវៈ ដឹងច្បាស់តាមពិតថា នេះជាបដិបទា នាំឲ្យដល់នូវសេចក្តីរលត់អាសវៈ ។ កាលភិក្ខុនោះ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តក៏ផុតស្រឡះចាកកាមាសវៈផង ចិត្តក៏ផុតស្រឡះចាកភវាសវៈផង ចិត្តក៏ផុតស្រឡះចាកអវិជ្ជាសវៈផង កាលបើចិត្តផុតស្រឡះហើយ ញាណក៏កើតឡើងថា ចិត្តផុតស្រឡះហើយ ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តស្រេចហើយ សោឡសកិច្ចអាត្មាអញ បានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ នេះជាវិជ្ជាទី ៣ ដែលភិក្ខុនោះបានសម្រេចហើយ អវិជ្ជាបាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតបាត់ទៅ ពន្លឺក៏កើតឡើង ( ជាផល ) សមគួរដល់ភិក្ខុអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅរកព្រះ

និព្វាន ។

ចិត្តរបស់បុគ្គលណា មានសីលមិនខ្ចាស់ទាប មាន
ប្រាជ្ញាចាស់ក្លា អ្នកដុតកម្ដៅកិលេស ជាចិត្តដ៏ស្ងាត់
មានអារម្មណ៍តែមួយតាំងខ្ជាប់ខ្ជួន ( ដោយអារម្មណ៍ )
ពួកអ្នកប្រាជ្ញហៅបុគ្គលនោះ ថាជាអ្នកបន្ទោបង់នូវ
ងងឹត ជាអ្នកប្រាជ្ញ បានវិជ្ជា ៣ លះបង់មច្ចុ ជា
ប្រយោជន៍ដល់ទេវតា និងមនុស្ស លះបង់នូវបាបធម៌
ទាំងអស់ បរិបូណ៌ដោយវិជ្ជា ៣ មានកិរិយានៅដោយ
សេចក្ដីមិនភាន់ច្រឡំ ចាក់ធ្លុះនូវសច្ចៈទាំង ៤ ទ្រទ្រង់
នូវសរីរៈមានក្នុងទីបំផុត ពួកទេវតា និងមនុស្សតែង
នមស្ការព្រះគោតមនោះ ។ បុគ្គលណាដឹងនូវបុព្វេ-
និវាស ឃើញនូវសួគ៌ និងអបាយ មួយទៀត ជា
ខីណាសវមុនី ដល់នូវការអស់ទៅនៃជាតិ ដឹងហើយ
បានសម្រេចសម្រាន្តនៅដោយទីបំផុតនៃកិច្ច បានវិជ្ជា
៣ ដោយវិជ្ជា ៣ នុ៎ះ តថាគតហៅបុគ្គលអ្នកបានវិជ្ជា
៣ នោះ ថាជាព្រាហ្មណ៍ មិនមែនហៅបុគ្គលដទៃ
តាមពាក្យដែលគេធ្លាប់ហៅឡើយ ។

ម្នាលព្រាហ្មណ៍ វិជ្ជា ៣ ក្នុងវិន័យរបស់អរិយៈយ៉ាងនេះឯង ។ បពិត្រ
ព្រះគោតមដ៏ចម្រើន វិជ្ជា ៣ របស់ព្រាហ្មណ៍ទាំងឡាយ ដោយឡែក វិជ្ជា ៣

ក្នុងវិន័យរបស់អរិយៈ ដោយឡែក បពិត្រព្រះគោតមដ៏ចម្រើន តែថា វិជ្ជា ៣ របស់ព្រាហ្មណ៍ទាំងឡាយ មិនដល់នូវចំណែកទី ១៦ៗ ជងនៃវិជ្ជា ៣ ក្នុងវិន័យរបស់អរិយៈនេះទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។បេ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គ ថាជាឧបាសក អ្នកដល់សរណគមន៍ ស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមទៅ ។

# អដ្ឋកថា

## តិកណ្ណសូត្រ

[ ៦០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតិកណ្ណសូត្រទី ៨ ដូចតទៅនេះ បទថា **តិកណ្ណោ** ជាឈ្មោះរបស់ព្រាហ្មណ៍នោះ ។ បទថា **ឧបសង្កមិ** សេចក្តីថា ព្រាហ្មណ៍គិតថា បានឮថា ព្រះសមណគោតមជាបណ្ឌិត អញនឹងទៅសម្នាក់របស់លោក ដូច្នេះ បរិភោគអាហារព្រឹកហើយ មានមហាជនចោមរោម ចូលទៅគាល់ព្រះមានព្រះភាគ ។ បទថា **ភគវតោ សម្មុខា** សេចក្តីថា អង្គុយខាងមុខព្រះទសពល ។

បទថា **វណ្ណំ ភាសតិ** សេចក្តីថា សួរថា ព្រោះហេតុអ្វី ទើបពោលសរសើរ ឆ្លើយថា បានឮថា មុននេះ ព្រាហ្មណ៍នោះមិនធ្លាប់ទៅកាន់សម្នាក់របស់ព្រះទសពលឡើយ ទើបព្រាហ្មណ៍មានការគិតយ៉ាងនេះថា ធម្មតាព្រះ

សម្ពុទ្ធទាំងឡាយ ចូលគាល់បានលំបាក អញទូលមុនហើយ ទោះត្រាស់ ឬ មិនត្រាស់ក៏បាន បើទ្រង់មិនត្រាស់ពេលនោះ មនុស្សទាំងឡាយនឹងពោលថា អាត្មាអញជាអ្នកពោលក្នុងសមាគមយ៉ាងនេះថា ហេតុអ្វី ទើបអ្នកពោលក្នុងទីនេះ ព្រោះថា លោកមិនទៅកាន់សម្នាក់របស់ព្រះគោតម ហើយក៏មិនទាន់បានត្រឹមតែការត្រាស់ដែរ ព្រោះហេតុនោះ ព្រាហ្មណ៍កាលសម្គាល់ថា អញនឹងផុតពាក្យនិន្ទាទៅបាន ដោយឧបាយយ៉ាងនេះ ទើបទូលឡើង ព្រាហ្មណ៍ពោលសរសើរព្រាហ្មណ៍ទាំងឡាយក៏ពិត តែពោលដល់វិជ្ជា ៣ ដោយបំណងតែម្យ៉ាងថា អាត្មាអញនឹងសាកល្បងព្រះញាណរបស់ព្រះតថាគត ។

បទថា **ឯវម្បិ តេវិជ្ជា ព្រាហ្មណា** សេចក្តីថា ព្រាហ្មណ៍ដែលទ្រទ្រង់វិជ្ជា ៣ ជាបណ្ឌិតយ៉ាងនេះ គឺជាអ្នកប្រាជ្ញយ៉ាងនេះ ជាអ្នកឈ្លាសយ៉ាងនេះ ជាពហូសូតយ៉ាងនេះ ជាអ្នកមានប្រក្រតីពោលយ៉ាងនេះ អធិប្បាយថា ជាអ្នកបានទទួលសម្បត្តិយ៉ាងនេះ ។ បទថា **ឥតិបិ** ព្រះមានព្រះភាគទ្រង់សម្តែងការកំណត់អាការរបស់បណ្ឌិតជាដើម នៃព្រាហ្មណ៍ទាំងនោះ ។ ក្នុងសេចក្តីនេះ មានអធិប្បាយយ៉ាងនេះថា ជាបណ្ឌិតដោយហេតុមានប្រមាណប៉ុណ្ណោះ ។បេ។ ជាអ្នកបានទទួលសន្ទូត ដោយហេតុមានប្រមាណប៉ុណ្ណោះ ។

បទថា **យថា** ក្នុងបទថា **យថា កថំ បន ព្រាហ្មណា** នេះ ជាពាក្យសម្តែងហេតុ ។ បទថា **កថំ បន** ជាពាក្យសួរ ។ សេចក្តីនេះ សមដូចព្រះមានព្រះភាគត្រាស់ថា ម្នាលព្រាហ្មណ៍ ព្រាហ្មណ៍ទាំងឡាយបញ្ញត្តព្រាហ្មណ៍ដែលបានវិជ្ជា ៣ ដូចម្តេច ។ អ្នកចូរប្រាប់ហេតុដែលឲ្យស្គាល់ព្រាហ្មណ៍អ្នក

បានវិជ្ជា ៣ នោះ ។ ព្រាហ្មណ៍កាលបានស្តាប់ដូច្នោះហើយ ក្រោកអរថា ព្រះសម្មាសម្ពុទ្ធត្រាស់សួរក្នុងធម៌ដែលមានឋានៈល្មមដឹងបាន មិនមែនមានឋានៈដែលដឹងមិនបាន ទើបទូលពាក្យជាដើមថា **ឥធ ភោ គោតម** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **ឧភតោ** បានដល់ ទាំង ២ ចំណែក ។ បទថា **មាតិតោ ច បិតិតោ ច** សេចក្តីថា បុគ្គលណាមានមាតាជាព្រាហ្មណី មានជីដូនជាព្រាហ្មណី សូម្បីយាយទួតក៏ជាព្រាហ្មណី មានបិតាជាព្រាហ្មណ៍ ជីតាជាព្រាហ្មណ៍ សូម្បីតាទួតក៏ជាព្រាហ្មណ៍ បុគ្គលនោះ ឈ្មោះថា កើតល្អហើយទាំង ២ ចំណែក គឺទាំងខាងមាតា និងខាងបិតា ។

បទថា **សំសុទ្ធគ្គហណិកោ** សេចក្តីថា បុគ្គលណាមានទីបដិសន្ធិ គឺផ្ទៃរបស់មាតាបរិសុទ្ធហើយ បុគ្គលនោះ ឈ្មោះថា **សំសុទ្ធគ្គហណី** ។ តែក្នុងពាក្យថា **សមវេបាកិនិយា គហណិយា** នេះ ព្រះមានព្រះភាគត្រាស់ហៅថា ការកាន់យកតេជោធាតុដែលកើតអំពីកម្ម ។ ក្នុងពាក្យថា **យាវ សត្តមា បិតាមហយុគា** នេះ សេចក្តីថា បិតានៃបិតា ឈ្មោះថា **បិតាមហា** ។ យុគនៃជីតា ឈ្មោះថា **បិតាមហយុគ** ។ ប្រមាណនៃអាយុ លោកហៅថា **យុគ** ពាក្យថា **យុគ** នេះ គ្រាន់តែជាពាក្យហៅប៉ុណ្ណោះ តែដោយអត្ថ **បិតាមហា** នោះឯង ឈ្មោះថា **បិតាមហយុគ** ។ បុព្វបុរសទាំងអស់បន្ទាប់អំពីបិតាមហយុគចុះទៅ ក៏សំដៅយកដោយសព្ទថា **បិតាមហា** នោះឯង កាលបើដូច្នេះ បុគ្គលដែលឈ្មោះថា **សំសុទ្ធគ្គហណី** មានត្រឹម ៧ ជួរមនុស្សយ៉ាងតិច ។

ម្យ៉ាងទៀត ទ្រង់សម្តែងថា ព្រាហ្មណ៍ដែលជាឧភតោសុជាតិនោះ នឹងមិនត្រូវជំទាស់ ត្រូវតិះដៀលដោយការពោលអាងដល់ជាតិ ។ បទថា **អក្ខិត្តោ** សេចក្តីថា មិនត្រូវជំទាស់យ៉ាងនេះថា នៃអ្នកទាំងឡាយ ចូរនាំបុគ្គលនេះចេញទៅ បុគ្គលនេះមានប្រយោជន៍អ្វី ។ បទថា **អនុបក្កុដ្ឋោ** សេចក្តីថា មិនត្រូវតិះដៀល មិនធ្លាប់ត្រូវជេរ មិនធ្លាប់ត្រូវនិន្ទា សួរថា ព្រោះហេតុអ្វី ឆ្លើយថា ដោយការពោលអាងដល់ជាតិ អធិប្បាយថា ដោយការពោលបែបនេះថា បុគ្គលនេះជាតិថោកទាប ដោយប្រការនេះ ។

បទថា **អជ្ឈាយកោ** នេះ គប្បីជ្រាបអត្ថដូចតទៅនេះ ពាក្យនិន្ទាកើតឡើងដល់ព្រាហ្មណ៍ដែលវៀរចាកឈាន ក្នុងកាលបឋមកប្បយ៉ាងនេះថា នៃវាសេដ្ឋៈ និងភារទ្វាជៈ ឥឡូវនេះ ជនទាំងនេះ មិនសម្លឹង ឥឡូវនេះ ជនទាំងនេះ មិនសម្លឹងយ៉ាងនេះឯង អក្ខរៈថា **អជ្ឈាយកា អជ្ឈាយកា** គឺបុគ្គលមិនសម្លឹង សំដៅដល់អ្នករចនា និងអ្នកបង្រៀនគម្ពីរ ទើបឧប្បត្តិឡើងក្នុងលើកទី ៣ ។ តែក្នុងបច្ចុប្បន្ននេះ ព្រាហ្មណ៍ ឈ្មោះថា **អជ្ឈាយកោ** ព្រោះសិក្សាវេទនោះ មនុស្សទាំងឡាយពោលពាក្យសរសើរដោយអធិប្បាយនេះថា ព្រាហ្មណ៍ភាយមន្ត គឺវេទ ។ ព្រាហ្មណ៍ ឈ្មោះថា **មន្តធរោ** ព្រោះទ្រទ្រង់នូវមន្ត គឺវេទ ។ បទថា **តិណ្ណំ វេទានំ** បានដល់ ឥរុព្វេទ យជុវេទ និងសាមវេទ ។ ព្រាហ្មណ៍ ឈ្មោះថា **បារគូ** ព្រោះដល់នូវត្រើយដោយអំណាចនៃការទន្ទេញ គឺចងចាំបានហើយ ។

ត្រៃវេទ មួយអន្លើដោយនិឃណ្ឌុសាស្ត្រ និងកេដុភសាស្ត្រ ឈ្មោះថា

**សនិឃណ្ឌុកេដុភ** ។ បទថា **និឃណ្ឌុ** បានដល់ សាស្ត្រដែលចែកឈ្មោះវត្ថុផ្សេងៗ គឺសាស្ត្រាដែលពោលដោយឈ្មោះនៃដើមឈើជាដើម ។ បទថា **កេដុភំ** បានដល់ សាស្ត្រដែលកំណត់អាកប្បកិរិយា គឺសាស្ត្រាដែលឧបការៈដល់កវី ។ វេទ មួយអន្លើដោយប្រភេទនៃអក្ខរៈ ឈ្មោះថា **សាក្ខរប្បភេទ**។ សិក្ខា និងនិរុត្តិ ឈ្មោះថា **អក្ខរប្បភេទ** ។ បទថា **ឥតិហាសបញ្ចមានំ** សេចក្ដីថា វេទ ឈ្មោះថា មានឥតិហាសជាគម្រប់ ៥ ព្រោះមានឥតិហាសដែលប្រកបដោយពាក្យដូច្នេះថា **ឥតិ ហ អាស ឥតិ ហ អាស** ពោល គឺគម្ពីរបុរាណ ឬគម្ពីរពោលដោយវិជ្ជារបស់ក្សត្រ អ្នកចម្បាំងជាគម្រប់ ៥ ។ ដោយរាប់យកអាថព្វនវេទ ជាគម្រប់ ៤ នៃវេទទាំងនោះ ដែលមានឥតិហាសជាគម្រប់ ៥ ។ ឈ្មោះថា ដឹងបទ ដឹងវេយ្យាករណ៍ ព្រោះទ្រទ្រង់ចាំ គឺដឹងបទផង ព្យាករ គឺពាក្យអធិប្បាយតួបទដ៏សេសនោះផង ។

**វិតណ្ឌវាទសាស្ត្រ** ( រឿងកំប្លែង ) លោកហៅថា លោកាយតៈ ។ បទថា **មហាបុរិសលក្ខណំ** បានដល់ សាស្ត្រដែលមានបទកម្រងកែវប្រមាណ ១២០០០ គម្ពីរ ដែលសម្ដែងលក្ខណៈនៃមហាបុរស មានព្រះពុទ្ធជាដើម ឈ្មោះថា **ពុទ្ធមន្ត** ប្រមាណ ១៦០០០ បទគាថា មានការអាចជាហេតុឲ្យដឹងនូវការផ្សេងគ្នាដូច្នេះថា បុគ្គលប្រកបដោយលក្ខណៈនេះ ជាព្រះពុទ្ធ ដោយលក្ខណៈនេះ ជាព្រះបច្ចេកពុទ្ធ ដោយលក្ខណៈនេះ ជាអគ្គសាវកទាំង ២ ដោយលក្ខណៈនេះ ជាអសីតិមហាសាវក ដោយលក្ខណៈនេះ ជាពុទ្ធមាតា ដោយលក្ខណៈនេះ ជាពុទ្ធបិតា ដោយលក្ខណៈនេះ ជា

អគ្គឧបដ្ឋាក ដោយលក្ខណៈនេះ ជាអគ្គឧបដ្ឋាយិកា និងដោយលក្ខណៈនេះ ជាស្តេចចក្រពត្តិ ។

បទថា **អនវយោ** បានដល់ ជាអ្នកមិនខ្វះខាត គឺជាអ្នកបរិបូណ៌ក្នុងគម្ពីរលោកាយតៈ និងគម្ពីរមហាបុរិសលក្ខណៈទាំងនេះ មានពាក្យអធិប្បាយថា មិនមែនជាបុគ្គលថោកថយ ។ បុគ្គលមិនអាចចាំនូវសាស្រ្តាទាំងនោះបាន ដោយអធិប្បាយផង ដោយគម្ពីរផង បុគ្គលនោះ ឈ្មោះថា ជាអ្នកថោកថយ ម្យ៉ាងទៀត បទថា **អនវយោ** កាត់បទជា **អនុ អវយោ** ដោយអំណាចសន្ធិលុប ឧ អក្ខរៈចេញ គឺ **អនុ អវយោ** ទើបជា **អនវយោ** អធិប្បាយថា មានសិប្បៈបរិបូណ៌ ។

ព្រះមានព្រះភាគ ទ្រង់ឃើញព្រាហ្មណ៍នោះទូលអារាធនា ទ្រង់ដឹងថា ឥឡូវនេះ ជាកាលសមគួរដែលតថាគតនឹងពោលស្រាយប្រស្នានៃព្រាហ្មណ៍នោះ ទើបត្រាស់ពាក្យនេះថា **តេនហិ** ដូច្នេះ ។ បទថា **តេនហិ** នោះ មានអត្ថថា ព្រោះហេតុដែលអ្នកសំណូមពរតថាគត ដូច្នោះ អ្នកចូរស្តាប់ ។ បទថា **វិវិច្ចេវ កាមេហិ** ជាដើម បានអធិប្បាយយ៉ាងពិស្តារ ក្នុងគម្ពីរវិសុទ្ធិមគ្គហើយនោះឯង ។ តែក្នុងទីនេះ ពាក្យថា **វិវិច្ចេវ កាមេហិ** ជាដើម នេះគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ហើយ ដើម្បីសម្តែងដល់បដិបទាដែលជាបុព្វភាគរបស់វិជ្ជាទាំង ២ ។ បណ្តាវិជ្ជាទាំង ៣ នោះ កិច្ចពណ៌នាវិជ្ជាទាំង ២ ទៅតាមលំដាប់បទក្តី ន័យក្នុងការចម្រើនវិជ្ជាទាំង ២ ក្តី បានឲ្យពិស្តារហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គដូចគ្នា ។

# អធិប្បាយ វិជ្ជា ៣

*បទថា* **បឋមា វិជ្ជា** *សេចក្ដីថា វិជ្ជា ឈ្មោះថា* **បឋមា** *ព្រោះកើតឡើងដំបូង ។ ឈ្មោះថា* **វិជ្ជា** *ព្រោះអត្ថថា ធ្វើឲ្យជាក់ច្បាស់ហើយ ។ សួរថា ធ្វើអ្វីឲ្យជាក់ច្បាស់ ឆ្លើយថា ធ្វើខន្ធដែលធ្លាប់អាស្រ័យក្នុងជាតិមុនឲ្យជាក់ច្បាស់ ។ មោហៈដែលបិទបាំងបុព្វេនិវាសានុស្សតិញ្ញាណនោះ ព្រោះអត្ថថា ធ្វើបុព្វេនិវានុស្សតិញ្ញាណនោះឯងមិនឲ្យជាក់ច្បាស់ ត្រាស់ហៅថា អវិជ្ជា ។ បទថា* **តមោ** *សេចក្ដីថា មោហៈនោះឯង ហៅថា* **តម** *ព្រោះអត្ថថា ជាហេតុបិទបាំង ។ បទថា* **អាលោកោ** *សេចក្ដីថា វិជ្ជានោះឯង ត្រាស់ហៅថា* **អាលោក** *ព្រោះអត្ថថា ធ្វើនូវពន្លឺ ។ ក្នុងព្រះសូត្រនេះ បំណងយកថា បានសម្រេចវិជ្ជា ៣ ហើយ ។ ពាក្យដ៏សេស ជាពាក្យពោលសរសើរ ។ ក្នុងសេចក្ដីនេះ ប្រកបសេចក្ដីថា លោកបានសម្រេចវិជ្ជានេះហើយ លំដាប់នោះ អវិជ្ជា ក៏ឈ្មោះថា បុគ្គលសម្រេចវិជ្ជាហើយ កម្ចាត់ហើយ អធិប្បាយថា ឲ្យវិនាសហើយ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះវិជ្ជាកើតឡើងហើយ ។ ក្នុងបទទាំង ២ ក្រៅអំពីនេះ ក៏ន័យនេះឯង ។*

*បទថា* **យថា** *ក្នុងពាក្យថា* **យថា តំ** *នេះ ជាឧបមា ។ បទថា* **តំ** *ត្រឹមតែជានិបាត ។ ឈ្មោះថា មិនប្រមាទហើយ ព្រោះមិនខ្វះខាតសតិ ។ ឈ្មោះថា មានសេចក្ដីព្យាយាម ព្រោះមានសេចក្ដីព្យាយាមជាគ្រឿងដុតកម្ដៅកិលេស ឈ្មោះថា មានខ្លួនបញ្ជូនទៅហើយ ព្រោះមិនអាល័យ ជាប់ជំពាក់ក្នុងរាងកាយ និងជីវិត ។ លោកអធិប្បាយដូច្នេះថា បុគ្គលមិនប្រមាទ មានសេចក្ដីព្យាយាម បញ្ជូនចិត្តទៅហើយ អវិជ្ជានឹងវិនាសទៅ វិជ្ជានឹងកើតឡើង*

ការងងឹតនឹងបាត់ទៅ ពន្លឺគប្បីកើតឡើង យ៉ាងណា អវិជ្ជាក៏ដូច្នោះដូចគ្នា ឈ្មោះថា ព្រាហ្មណ៍នេះកម្ចាត់ហើយ វិជ្ជាកើតឡើងហើយ ងងឹត ឈ្មោះថា ត្រូវកម្ចាត់ហើយ ពន្លឺកើតឡើងហើយ ទើបព្រាហ្មណ៍នោះ បានទទួលផល ដែលសមគួរដល់ការប្រកបព្យាយាមនោះហើយ ដូច្នេះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងកថាពណ៌នា អំពីចុតូបបាតិញ្ញាណតទៅនេះ វិជ្ជា គឺទិព្វចក្ខុញ្ញាណ ឈ្មោះថា **វិជ្ជា** ការមិនដឹងដែលបិទបាំងចុតិ និងបដិសន្ធិនៃ សត្វទាំងឡាយ ឈ្មោះថា **អវិជ្ជា** ។ ពាក្យដ៏សេស មានន័យដូចពោល មកហើយនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងវិជ្ជាទី ៣ ដូចតទៅនេះ ក្នុងបទថា **សោ ឯវំ សមាហិតេ ចិត្តេ** គប្បីជ្រាបថា បានដល់ ចតុត្ថជ្ឈានចិត្តដែលជាបាទនៃ វិបស្សនា ។ បទថា **អាសវានំ ខយញ្ញាណាយ** សេចក្ដីថា ដើម្បីជា ប្រយោជន៍ដល់អរហត្តមគ្គញ្ញាណ ព្រោះអរហត្តមគ្គ លោកហៅថា ជាធម៌ អស់ទៅនូវអាសវៈទាំងឡាយ ព្រោះញ៉ាំងអាសវៈទាំងឡាយ ឲ្យវិនាស ។ អរហត្តមគ្គញ្ញាណ ក្នុងបទថា **អាសវានំ ខយញ្ញាណាយ** នោះ ហៅថា ឈ្មោះថា **ញាណ** ព្រោះទាក់ទងក្នុងអរហត្តមគ្គនោះ ។ បទថា **ចិត្តំ អភិ-និន្នាមេតិ** សេចក្ដីថា បង្អោនចិត្តទៅក្នុងវិបស្សនា ។ ក្នុងពាក្យថា **សោ ឥទំ ទុក្ខំ** ជាដើម គប្បីជ្រាបអត្ថយ៉ាងនេះថា បុគ្គលនោះរមែងដឹង គឺរមែងចាក់ធ្លុះ នូវទុក្ខសច្ចទាំងអស់តាមសេចក្ដីពិត ដោយការចាក់ធ្លុះលក្ខណៈ មួយអន្លើ ដោយកិច្ចថា ទុក្ខមានប្រមាណប៉ុណ្ណេះ មិនច្រើនជាងនេះឡើយ ទើងដឹង គឺ

ចាក់ធ្លុះនូវតណ្ហាដែលឲ្យកើតទុក្ខនោះថា នេះជាហេតុឲ្យកើតទុក្ខនោះតាមសេចក្ដីពិត ដោយការចាក់ធ្លុះលក្ខណៈ មួយអន្លើដោយកិច្ច ដឹង គឺចាក់ធ្លុះស្ថានទីណាដល់ហើយ ទុក្ខ និងសមុទយៈទាំង ២ នោះ រលត់ទៅក្នុងទីនោះ គឺនិព្វានដែលទុក្ខ និងសមុទយៈទាំង ២ នោះ មិនប្រព្រឹត្តទៅតាមសេចក្ដីពិត ដោយការចាក់ធ្លុះលក្ខណៈ ព្រមទាំងកិច្ចថា នេះជាការរម្ងត់ទុក្ខ នឹងដឹង គឺចាក់ធ្លុះអរិយមគ្គដែលឲ្យដល់និព្វាននោះតាមសេចក្ដីពិត ដោយការចាក់ធ្លុះលក្ខណៈ ព្រមទាំងកិច្ចថា នេះជាបដិបទាឲ្យដល់នូវការរលត់ទុក្ខ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងសច្ចៈទាំងឡាយ ដោយសរុបយ៉ាងនេះហើយ បន្ទាប់អំពីនេះ កាលនឹងសម្ដែងសច្ចៈទាំងឡាយដោយអម ដោយអំណាចនៃកិលេស ទើបត្រាស់ពាក្យថា **ឥមេ អាសវា** ដូច្នេះជាដើម ។

បទថា **តស្ស ឯវំ ជានតោ ឯវំ បស្សតោ** សេចក្ដីថា របស់ភិក្ខុនោះដែលជាអ្នកដឹង ជាអ្នកឃើញយ៉ាងនេះ ។ ព្រះមានព្រះភាគត្រាស់មគ្គដែលដល់ទីបំផុត មួយអន្លើដោយវិបស្សនាក្នុងទីនេះ ។ បទថា **កាមាសវា** ប្រែថា ចាកកាមាសវៈ ។ ដោយបទថា **ចិត្តំ វិមុច្ចតិ** ព្រះមានព្រះភាគទ្រង់សម្ដែងដល់មគ្គក្ខណៈ គឺខណៈចិត្តដែលសម្បយុត្តដោយមគ្គ អធិប្បាយថា ក្នុងខណៈនៃមគ្គចិត្ត ចិត្តកំពុងរួចផុត ។ ក្នុងខណៈនៃផលចិត្ត ចិត្តឈ្មោះថារួចផុតហើយ ។ ដោយបទថា **វិមុត្តស្មឹ វិមុត្តមិតិ ញាណំ** នេះ ព្រះមានព្រះភាគទ្រង់សម្ដែងបច្ចវេក្ខណញ្ញាណ ។ ដោយពាក្យទាំងឡាយថា **ខីណា ជាតិ** ជាដើម ទ្រង់សម្ដែងភូមិរបស់ព្រះខីណាស្រពនោះ ។ ព្រោះថា ព្រះ

ទីណាស្រពនោះ កាលពិចារណាដោយញាណនោះ រមែងជ្រាបអត្ថជាដើមថា ជាតិអស់ហើយ ដូច្នេះ ។

សួរថា ជាតិប្រភេទណានៃព្រះខីណាស្រពនោះអស់ទៅហើយ ហើយលោកដឹងថា ជាតិនោះអស់ទៅបានដូចម្ដេច ។

ឆ្លើយថា ជាដំបូង អតីតជាតិរបស់លោក មិនបានអស់ទៅហើយ ព្រោះអតីតជាតិនោះ អស់ទៅមុនហើយ ជាតិអនាគតក៏មិនអស់ ព្រោះមិនមានការព្យាយាមក្នុងអនាគត ជាតិបច្ចុប្បន្នក៏មិនទាន់អស់ ព្រោះជាតិបច្ចុប្បន្ននៅមាន តែជាតិណាដែលចែកប្រភេទជាខន្ធ ១ ខន្ធ ៤ និងខន្ធ ៥ គប្បីកើតឡើងក្នុងឯកវោការភព ចតុវោការភព និងបញ្ចវោការភព ព្រោះមិនបានអប់រំមគ្គ ជាតិនោះ ឈ្មោះថា អស់ទៅហើយ ដោយការដល់នូវការមិនកើតឡើងជាធម្មតា ព្រោះបានអប់រំមគ្គហើយ ។ កាលលោកពិចារណាកិលេសដែលលះបានហើយ ដោយមគ្គភាវនា កាលដឹងថា កម្ម ទោះបីមាន ក៏មិនតាក់តែងបដិសន្ធិតទៅ ព្រោះមិនមានកិលេស ដូច្នេះ ឈ្មោះថា ដឹងជាតិនោះ ។

បទថា **វុសិតំ** បានដល់ នៅចប់ហើយ គឺនៅចប់សព្វគ្រប់ហើយ អធិប្បាយថា ធ្វើសម្រេចអស់ហើយ ។ បទថា **ព្រហ្មចរិយំ** បានដល់ មគ្គព្រហ្មចរិយៈ ។ ព្រះសេក្ខៈ ៧ ពួក មួយអន្លើដោយកល្យាណបុថុជ្ជនទាំងឡាយ ឈ្មោះថា នៅប្រព្រឹត្តព្រហ្មចរិយៈនៅឡើយ ព្រះខីណាស្រពឈ្មោះថា មានព្រហ្មចរិយៈ នៅចប់ហើយ ព្រោះដូច្នោះ កាលលោកពិចារណាការនៅប្រព្រឹត្តព្រហ្មចរិយៈរបស់ខ្លួន រមែងដឹងច្បាស់ថា ព្រហ្មចរិយៈ អាត្មាអញនៅ

ចប់ហើយ ។ បទថា **កតំ ករណីយំ** អធិប្បាយថា កិច្ចទាំង ១៦ យ៉ាង ដោយអំណាចនៃការសម្រេចដោយបរិញ្ញាកិច្ច បហានកិច្ច សច្ឆិកិរិយាកិច្ច និង ភាវនាកិច្ច ដោយមគ្គទាំង ៤ ក្នុងសច្ចៈទាំង ៤ ដែលលោកឲ្យចប់សព្វគ្រប់ហើយ ។ ព្រោះថា កល្យាណបុថុជ្ជនជាដើម កំពុងធ្វើកិច្ចនោះ ឯព្រះខីណាស្រព ធ្វើកិច្ចស្រេចហើយ ព្រោះដូច្នោះ កាលលោកពិចារណាកិច្ចដែលខ្លួនត្រូវធ្វើ រមែងដឹងច្បាស់ថា កិច្ចដែលគួរធ្វើ អាត្មាអញធ្វើស្រេចហើយ ។ បទថា **ណាបរំ ឥត្ថត្តាយ** សេចក្តីថា លោករមែងដឹងច្បាស់ថា កិច្ច គឺការបំពេញមគ្គ ដើម្បីភាពយ៉ាងនេះទៀត គឺដើម្បីភាពជាកិច្ច ១៦ យ៉ាង ឬដើម្បីការអស់កិលេសយ៉ាងនេះ មិនមានដល់អាត្មាអញទៀតឡើយ ។

ម្យ៉ាងទៀត បទថា **ឥត្ថត្តាយ** សេចក្តីថា ដឹងច្បាស់ថា ការបន្តនៃខន្ធដទៃអំពីសភាពយ៉ាងនេះ គឺចាកការបន្តនៃខន្ធដែលមានក្នុងបច្ចុប្បន្ន មានប្រការយ៉ាងនេះ មិនមានដល់អាត្មាអញ បញ្ចក្ខន្ធទាំងដែលអញកំណត់ដឹងហើយនេះ កំពុងតាំងនៅឡើយ តែដូចជាដើមឈើដែលមានឫសដាច់ហើយ បញ្ចក្ខន្ធទាំងនោះ នឹងរលត់ទៅ ព្រោះវិញ្ញាណចុងក្រោយរលត់ ដូចអណ្តាតភ្លើងដែលមានកំញមអស់ ហើយរលត់ទៅ ដូច្នោះ ។ វិជ្ជា គឺអរហត្តមគ្គញាណ ឈ្មោះថា វិជ្ជាក្នុងទីនេះ ។ អវិជ្ជាដែលបិទបាំងអរិយសច្ច ៤ ឈ្មោះថា **អវិជ្ជា** ។ ពាក្យដ៏សេស មានន័យដូចពោលហើយ ។

បទថា **អនុច្ចាវចសីលស្ស** សេចក្តីថា បុគ្គលដែលមានសីល ពេលខ្លះសាបសូន្យ ពេលខ្លះចម្រើន ឈ្មោះថា មានសីលទំនាបៗ មានសីលទួលៗ

ឯព្រះវិញ្ញាស្រេត មានសីលចម្រើនដោយចំណែកមួយប៉ុណ្ណោះ ។ ព្រោះដូច្នោះ ទើបលោកឈ្មោះថា មានសីលមិនទំនាប មិនទួល ។ បទថា **វសីភូតំ** បានដល់ ដល់នូវការជំនាញ ។ បទថា **សុសមាហិតំ** បានដល់ តាំងដោយល្អ គឺតាំងទុកល្អហើយក្នុងអារម្មណ៍ ។ បទថា **ធីរំ** បានដល់ ជាអ្នកសម្បូរដោយបញ្ញាចងចាំ ។ បទថា **មច្ចុហាយិនំ** បានដល់ លះបង់មច្ចុរាជ ហើយតាំងនៅ ។ បទថា **សព្វប្បហាយិនំ** បានដល់ លះបាបធម៌ទាំងអស់ ហើយតាំងនៅ ។ បទថា **ពុទ្ធំ** បានដល់ ត្រាស់ដឹងសច្ចៈទាំង ៤ ។ បទថា **អន្តិមសារីរំ** សេចក្តីថា ទ្រទ្រង់នូវរាងកាយចុងក្រោយ ។ បទថា **តំ នមស្សន្តិ គោតមំ** សេចក្តីថា សាវករបស់ព្រះពុទ្ធទាំងឡាយ នមស្ការព្រះអង្គ ជាគោតមគោត្រ ។ម្យ៉ាងទៀត អធិប្បាយថា សាវករបស់ព្រះពុទ្ធព្រះនាមថាគោតម ក៏ឈ្មោះថា **គោតម** ទេវតា និងមនុស្សទាំងឡាយនមស្ការសាវកដែលឈ្មោះថា **គោតម** នោះ ។

បទថា **បុព្វេនិវាសំ** បានដល់ ខន្ធដែលនៅក្នុងជាតិមុនបន្តគ្នាមក ។ បទថា **យោ វេតិ** សេចក្តីថា បុគ្គលណាមិនវិនាស គឺមិនធ្លាក់ចុះ ។ បាឋៈថា **យោវេទិ** ដូច្នេះក៏មាន អធិប្បាយថា បុគ្គលណាបានដឹងហើយ គឺធ្វើវត្ថុដែលដឹងហើយ ឲ្យប្រាកដតាំងនៅ ។ បទថា **សគ្គាបាយញ្ច បស្សតិ** សេចក្តីថា បុគ្គលនោះ ឃើញសួគ៌ជាន់កាមាវចរ ៦ ព្រហ្មលោក ៩ និងអបាយ ៤ ។ បទថា **ជាតិក្ខយំ បត្តោ** សេចក្តីថា សម្រេចអរហត្តផល ។ បទថា **អភិញ្ញាវោសិតោ** សេចក្តីថា នៅដោយការអស់កិច្ច ព្រោះដឹង ។

មុនី គឺព្រះខីណាស្រព ដែលប្រកបភាពជាអ្នកដឹង ឈ្មោះថា **មុនី** ។ បទថា **ឃតាហិ** សេចក្តីថា ដោយញាណទាំងឡាយ មានបុព្វេនិវាសានុស្សតិញ្ញាណជាដើម ដែលទ្រង់សម្តែងហើយខាងដើម ។ បទថា **ឆាញ្ញំ លបិតលាបនំ** សេចក្តីថា តែតថាគតមិនហៅបុគ្គលដទៃ ដែលហៅតាមបែបអ្នកដទៃហៅថា **តេវិជ្ជោ** ថាជា **តេវិជ្ជោ** ឡើយ អធិប្បាយថា តថាគតហៅបុគ្គលដឹងដោយប្រចក្សដល់ខ្លួន ហើយប្រាប់វិជ្ជា ៣ ដល់អ្នកដទៃផង ថាជាអ្នកមានវិជ្ជា ៣ ។ បទថា **កលំ** ប្រែថា ចំណែក ។ បទថា **ឆាគ្ឃតិ** ប្រែថា មិនដល់ ។ ឥឡូវនេះ ព្រាហ្មណ៍ជ្រះថ្លាក្នុងព្រះពុទ្ធវចនៈ ហើយកាលសម្តែងអាការរបស់អ្នកជ្រះថ្លា ទើបបានពោលពាក្យជាដើមថា **អភិក្កន្តំ** ដូច្នេះ ៕

## អដ្ឋកថា តិកណ្ណសូត្រទី ៨ ចប់

# សុត្តន្តបិដក

## ជានុស្សោណិសូត្រទី ៩

[ ៦១ ] គ្រានោះឯង ជានុស្សោណិព្រាហ្មណ៍ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ។បេ។ លុះជានុស្សោណិព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន គ្រឿងបូជាក្តី មតកកត្តដែលឲ្យដោយសទ្ធាក្តី អាហារជាសម្រាប់ដែលគប្បីឲ្យដល់បុគ្គលដទៃក្តី ទេយ្យធម៌ គឺវត្ថុក្រៅពីនោះក្តី របស់បុគ្គលណា បុគ្គលនោះគួរឲ្យទានចំពោះព្រាហ្មណ៍ទាំងឡាយ អ្នកបានវិជ្ជា ៣ ដែរឬទេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ចុះពួកព្រាហ្មណ៍បញ្ញត្តព្រាហ្មណ៍អ្នកមានវិជ្ជា ៣ ដោយប្រការយ៉ាងណា ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រាហ្មណ៍ក្នុងលោកនេះ ជាឧភតោសុជាត ( មានជាតិល្អទាំងពីរខាង ) គឺខាងមាតា និងខាងបិតា កើតអំពីគភ៌ដ៏បរិសុទ្ធ មិនមានបុគ្គលរង្កៀស មិនមានគេតិះដៀលដោយពោលអំពីជាតិកំណើតបាន ដរាបអំពីជួរនៃជីតាគម្រប់ ៧ ស្វាធ្យាយទ្រទ្រង់នូវមន្ត ដល់ត្រើយនៃត្រៃវេទ ព្រមទាំងគម្ពីរនិឃណ្ឌុ និងកេដុភៈ ព្រមទាំងអក្ខរប្បភេទ គឺសិក្ខា និងនិរុត្តិ ដែលមានគម្ពីរឈ្មោះឥតិហាសៈជាគម្រប់ ៥ ជាអ្នកចេះបទ និងវេយ្យាករណ៍ ជាអ្នកស្ទាត់ជំនាញក្នុងលោកាយតសាស្ត្រ និងមហាបុរិសលក្ខណៈ ។ បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍បញ្ញត្តព្រាហ្មណ៍អ្នកបានវិជ្ជា ៣ យ៉ាងនេះឯង ។ ម្នាលព្រាហ្មណ៍ ពួកព្រាហ្មណ៍បញ្ញត្តព្រាហ្មណ៍អ្នកបានវិជ្ជា ៣ ដោយឡែក ឯវិជ្ជា ៣

ក្នុងវិន័យរបស់អរិយៈ ដោយឡែក ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះវិជ្ជា ៣ ក្នុងវិន័យរបស់អរិយៈ តើដូចម្តេច វិជ្ជា ៣ ក្នុងវិន័យរបស់អរិយៈយ៉ាងណា សូមព្រះគោតមដ៏ចម្រើន មេត្តាប្រោសសម្តែងធម៌ដល់ខ្ញុំព្រះអង្គយ៉ាងនោះ ។ ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ជានុស្សោណិព្រាហ្មណ៍ ទទួលស្តាប់ព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលព្រាហ្មណ៍ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ក៏ចូលចតុត្ថជ្ឈាន ។ កាលបើចិត្តតាំងខ្ជាប់ខ្ជួន បរិសុទ្ធស្អាត ឥតមានកិលេស ប្រាសចាកឧបក្កិលេស ជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះ ក៏បង្អោនចិត្តទៅ ដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ភិក្ខុនោះរឭកឃើញនូវបុព្វេនិវាសច្រើនប្រការ ។បេ។ នេះជាវិជ្ជាទី ១ ដែលភិក្ខុនោះបានសម្រេចហើយ អវិជ្ជាបាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតបាត់ទៅ ពន្លឺក៏កើតឡើង ( ជាផល ) សមគួរដល់ភិក្ខុអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅរកព្រះនិព្វាន ។ កាលបើចិត្តតាំងខ្ជាប់ បរិសុទ្ធស្អាត ឥតមានកិលេស ប្រាសចាកឧបក្កិលេស ជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះក៏បង្អោនចិត្តទៅដើម្បី សត្តានំ ចុតូបបាតញ្ញាណ ភិក្ខុនោះ មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់ចក្ខុជារបស់មនុស្សធម្មតា ឃើញពួកសត្វ ។បេ។ នេះជាវិជ្ជាទី ២ ដែលភិក្ខុនោះបានសម្រេចហើយ អវិជ្ជាបាត់ទៅ វិជ្ជាក៏កើត

ឡើង ធនឹតបាត់ទៅ ពន្លឺក៏កើតឡើង ( ជាផល ) សមគួរដល់ភិក្ខុអ្នកមិនមានសេចក្ដីប្រមាទ មានព្យាយាមជាគ្រឿងដុតកម្ដៅកិលេស មានចិត្តបញ្ជូនទៅរកព្រះនិព្វាន ។ កាលបើចិត្តតាំងខ្ជាប់ខ្ជួន បរិសុទ្ធស្អាត ឥតមានកិលេស ប្រាសចាកឧបក្កិលេស ជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះ ក៏បង្អោនចិត្តទៅដើម្បីអាសវក្ខយញ្ញាណ ភិក្ខុនោះដឹងច្បាស់តាមពិតថា នេះជាទុក្ខ ។បេ។ ដឹងច្បាស់តាមពិតថា នេះជាបដិបទានាំឲ្យដល់សេចក្ដីរលត់ទុក្ខ ។ ដឹងច្បាស់តាមពិតថា ទាំងអស់នេះជាអាសវៈ ។បេ។ ដឹងច្បាស់តាមពិតថា នេះជាបដិបទានាំឲ្យបានដល់សេចក្ដីរលត់អាសវៈ ។ កាលភិក្ខុនោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តក៏រួចស្រឡះចាកកាមាសវៈផង ចិត្តក៏រួចស្រឡះ ចាកភវាសវៈផង ចិត្តក៏រួចស្រឡះ ចាកអវិជ្ជាសវៈផង កាលចិត្តរួចស្រឡះហើយ ញាណកើតឡើងថា ចិត្តរួចស្រឡះហើយ ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញបានប្រព្រឹត្តស្រេចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ នេះជាវិជ្ជាទី ៣ ដែលភិក្ខុនោះបានសម្រេចហើយ អវិជ្ជាបាត់ទៅ វិជ្ជាក៏កើតឡើង ធនឹតបាត់ទៅ ពន្លឺក៏កើតឡើង ( ជាផល ) សមគួរដល់ភិក្ខុ អ្នកមិនមានសេចក្ដីប្រមាទ មានព្យាយាមជាគ្រឿងដុតកម្ដៅកិលេស មានចិត្តបញ្ជូនទៅរកព្រះនិព្វាន ។

បុគ្គលណា បរិបូណ៌ដោយសីល និងវត្ត មានចិត្តបញ្ជូន
ទៅរកព្រះនិព្វាន មានចិត្តតម្កល់មាំ ចិត្តរបស់បុគ្គល

ណា ស្គាត់ ប្រសើរឯក ខ្ជាប់ខ្ជួនប្រពៃ បុគ្គលណា
ដឹងនូវបុព្វេនិវាសផង ឃើញនូវសួគ៌ និងអបាយផង
មួយទៀត ដល់នូវការអស់ទៅនៃជាតិ បានដឹងច្បាស់
ហើយ សម្រេចសម្រាន្តនៅ ដោយទីបំផុតនៃកិច្ច ជា
ខីណាសវមុនិ អ្នកបានវិជ្ជា ៣ ដោយវិជ្ជា ៣ នុ៎ះ
តថាគតហៅបុគ្គលអ្នកបានវិជ្ជា ៣ នោះ ថាជាព្រាហ្មណ៍
មិនហៅបុគ្គលដទៃតាមពាក្យ ដែលគេធ្លាប់ពោលឡើយ។

ម្នាលព្រាហ្មណ៍ វិជ្ជា ៣ ក្នុងវិន័យរបស់អរិយៈ យ៉ាងនេះឯង ។ បពិត្រព្រះគោតមដ៏ចម្រើន វិជ្ជា ៣ របស់ពួកព្រាហ្មណ៍ដោយឡែក ឯវិជ្ជា ៣ ក្នុងវិន័យរបស់អរិយៈដោយឡែក បពិត្រព្រះគោតមដ៏ចម្រើន វិជ្ជា ៣ របស់ពួកព្រាហ្មណ៍ មិនដល់នូវចំណែកទី ១៦ៗ ផង នៃវិជ្ជា ៣ ក្នុងវិន័យរបស់អរិយៈនេះទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។បេ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គ ថាជាឧបាសក ដល់នូវសរណៈស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមទៅ ។

# អដ្ឋកថា

## ជានុស្សោណិសូត្រ

[ ៦១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងជានុស្សោណិសូត្រទី ៩ ដូចតទៅនេះ បទថា **យស្សស្ស** ស្មើគ្នានឹង **យស្ស** ភវេយ្យុំ ប្រែថា របស់បុគ្គលណាគប្បីមាន ។ ក្នុងបទថា **យញ្ញោ** ជាដើម អធិប្បាយថា ទេយ្យធម៌ ឈ្មោះថា **យញ្ញ** ព្រោះត្រូវបូជា ។ ពាក្យថា **យញ្ញ** នេះ ជាឈ្មោះនៃទេយ្យធម៌ ។ បទថា **សទ្ធំ** បានដល់ កត្តាហារដែលឧទ្ទិសដើម្បីអ្នកស្លាប់ ។ បទថា **ថាលិបាកោ** បានដល់ កត្តាហារដែលគប្បីឲ្យដល់បរិស័ទដទៃ ។ ឈ្មោះថា ទេយ្យធម៌គ្រប់យ៉ាងដែលសល់អំពីពោលហើយ ឈ្មោះថា **ទេយ្យធម្មំ** ។

បទថា **តេវិជ្ជេសុ ព្រាហ្មណេសុ ទានំ ទទេយ្យ** សេចក្ដីថា ទានទាំងអស់នេះ គួរឲ្យក្នុងបុគ្គលដែលមានវិជ្ជា ៣ ព្រះមានព្រះភាគទ្រង់សម្ដែងថា ព្រាហ្មណ៍អ្នកមានវិជ្ជា ៣ ប៉ុណ្ណោះ គួរបានទទួលទាន ។ បទដ៏សេស ក្នុងព្រះសូត្រនេះ មានន័យដូចពោលហើយខាងដើមនោះឯង ៕

**អដ្ឋកថាជានុស្សោណិសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## សង្គារវសូត្រទី ១០

[ ៦២ ] គ្រានោះឯង សង្គារវព្រាហ្មណ៍ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះសង្គារវព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន យើងទាំងឡាយ ឈ្មោះថាជាព្រាហ្មណ៍ បូជានូវយញ្ញខ្លួនឯងខ្លះ ប្រើគេឲ្យបូជាខ្លះ បពិត្រព្រះគោតមដ៏ចម្រើន ក្នុងជំណើរនោះ ព្រាហ្មណ៍ណា បូជាយញ្ញដោយខ្លួនឯងផង ព្រាហ្មណ៍ណា ប្រើគេឲ្យបូជាផង ព្រាហ្មណ៍ទាំងអស់នោះ ឈ្មោះថា ប្រតិបត្តិនូវសេចក្តីប្រតិបត្តិ ជាហេតុឲ្យកើតបុណ្យ ដែលប្រព្រឹត្តទៅក្នុងសរីរៈដ៏ច្រើន ព្រោះហេតុតែការបូជានេះ បពិត្រព្រះគោតមដ៏ចម្រើន ចំណែកខាងបុគ្គលណា ចេញចាកត្រកូលណាក្តី ចេញចាកផ្ទះណាក្តី ហើយបួសក្នុងសម្នាក់បុគ្គលមិនមានផ្ទះ ក៏ទូន្មានចំពោះខ្លួនមួយៗ រម្ងាប់ចំពោះខ្លួនមួយៗ រម្ងត់ទុក្ខចំពោះខ្លួនមួយៗ បុញ្ញប្បដិបទានេះ ប្រព្រឹត្តទៅក្នុងសរីរៈតែមួយ រមែងមានដល់បុគ្គលនោះយ៉ាងនេះ ព្រោះហេតុតែបព្វជ្ជានេះ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បើដូច្នោះ តថាគតនឹងត្រឡប់សួរជំណើរនោះចំពោះអ្នកវិញ អ្នកគាប់ចិត្តយ៉ាងណា គប្បីដោះស្រាយប្រស្នានោះ យ៉ាងនោះចុះ ។ ម្នាលព្រាហ្មណ៍ អ្នកសម្គាល់សេចក្តីនោះដូចម្តេច ព្រះតថាគតកើតឡើង

ក្នុងលោកនេះ ជាអរហន្តសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជា និងចរណៈ មានដំណើរល្អ ជ្រាបច្បាស់នូវត្រៃលោក មិនមានបុគ្គលដទៃប្រសើរជាង ជាសារថីទូន្មាននូវបុរស ដែលគួរទូន្មានបាន ជាគ្រូនៃទេវតា និងមនុស្សទាំង-ឡាយ ត្រាស់ដឹងនូវអរិយសច្ចទាំង ៤ លែងវិលមកកាន់ភពថ្មីទៀត ព្រះតថាគតនោះពោលយ៉ាងនេះថា នេះជាផ្លូវ នេះជាបដិបទា ក្នុងដំណើរនោះ ដូចតថាគតប្រតិបត្តិ បានធ្វើឲ្យជាក់ច្បាស់ នូវការចុះស៊ប់ កាន់ព្រហ្មចរិយៈដ៏ប្រសើរ ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង ទើបប្រកាសប្រាប់ ( សត្វដទៃ ) ថា អើអ្នកទាំងឡាយ ចូរមក អ្នកទាំងឡាយ ចូរប្រតិបត្តិធ្វើឲ្យជាក់ច្បាស់នូវការចុះស៊ប់កាន់ព្រហ្មចរិយៈដ៏ប្រសើរ ដោយប្រាជ្ញាខ្លួនឯង សម្រេចសម្រាន្តនៅយ៉ាងណា អ្នកទាំងឡាយ ចូរប្រតិបត្តិយ៉ាងនោះចុះ ។ ព្រះសាស្ដានេះតែងសម្ដែងធម៌ផង ពួកជនដទៃប្រតិបត្តិតាមបែបនោះផង ដោយប្រការដូច្នេះ ។ ការប្រមាណនៃសត្វទាំងឡាយនោះ មានរយដ៏ច្រើនផង មានពាន់ដ៏ច្រើនផង មានសែនដ៏ច្រើនផង ម្នាលព្រាហ្មណ៍ អ្នកសម្គាល់សេចក្ដីនោះដូចម្ដេច កាលបើហេតុមានយ៉ាងនេះ បុញ្ញប្បដិបទានេះ ឈ្មោះថា ប្រព្រឹត្តទៅក្នុងសរីរៈតែមួយ ឬប្រព្រឹត្តទៅក្នុងសរីរៈដ៏ច្រើន ព្រោះហេតុតែបព្វជ្ជាដោយប្រការដូច្នេះ ។ បពិត្រព្រះគោតមដ៏ចម្រើន កាលបើហេតុមានយ៉ាងនេះ បុញ្ញប្បដិបទានេះ ឈ្មោះថា ប្រព្រឹត្តទៅក្នុងសរីរៈដ៏ច្រើន ព្រោះហេតុតែបព្វជ្ជានេះ ដូច្នេះ ។ កាលបើព្រាហ្មណ៍និយាយយ៉ាងនេះហើយ ព្រះអានន្ទដ៏មានអាយុបាននិយាយនឹងសង្គារវព្រាហ្មណ៍ដូច្នេះថា ម្នាលព្រាហ្មណ៍ បណ្ដាបដិបទាទាំង ២ នេះ

អ្នកគាប់ចិត្តបដិបទាណាថា មានសេចក្ដីត្រូវការតិចផង មានការរៀបចំតិចផង មានផលច្រើនផង មានអានិសង្សច្រើនផង ។ កាលបើព្រះអានន្ទ និយាយយ៉ាងនេះហើយ សង្គារវព្រាហ្មណ៍ បាននិយាយនឹងព្រះអានន្ទដ៏មានអាយុដូច្នេះថា បុគ្គលដូចជាព្រះគោតមដ៏ចម្រើន និងព្រះអានន្ទដ៏ចម្រើនទាំងនេះ ខ្ញុំត្រូវបូជា ខ្ញុំត្រូវសរសើរ ។ ព្រះអានន្ទដ៏មានអាយុ បាននិយាយនឹងសង្គារវព្រាហ្មណ៍ជាគម្រប់ ២ ដងដូច្នេះថា ម្នាលព្រាហ្មណ៍ អាត្មាមិនសួរអ្នកថា ពួកបុគ្គលដូចម្ដេច ដែលអ្នកត្រូវបូជា ឬពួកបុគ្គលដូចម្ដេច ដែលអ្នកត្រូវសរសើរយ៉ាងនេះទេ ។ ម្នាលព្រាហ្មណ៍ អាត្មាសួរអ្នកយ៉ាងនេះថា ម្នាលព្រាហ្មណ៍ បណ្ដាបដិបទាទាំងពីរនេះ អ្នកគាប់ចិត្តបដិបទាណាថា មានសេចក្ដីត្រូវការតិចផង មានការរៀបចំតិចផង មានផលច្រើនផង មានអានិសង្សច្រើនផង ដូច្នេះទេតើ ។ សង្គារវព្រាហ្មណ៍ បាននិយាយនឹងព្រះអានន្ទដ៏មានអាយុជាគម្រប់ ២ ដង ដូច្នេះថា បុគ្គលដូចជាព្រះសមណគោតមដ៏ចម្រើន និងព្រះអានន្ទដ៏ចម្រើននេះ ខ្ញុំត្រូវបូជា ខ្ញុំត្រូវសរសើរ ។ ព្រះអានន្ទដ៏មានអាយុបាននិយាយនឹងសង្គារវព្រាហ្មណ៍ ជាគម្រប់ ៣ ដងដូច្នេះយ៉ាងនេះថា ម្នាលព្រាហ្មណ៍ អាត្មាមិនសួរអ្នកថា ពួកបុគ្គលដូចម្ដេច ដែលអ្នកត្រូវបូជា ឬពួកបុគ្គលដូចម្ដេច ដែលអ្នកត្រូវសរសើរទេ ។ ម្នាលព្រាហ្មណ៍ អាត្មាសួរអ្នកយ៉ាងនេះថា ម្នាលព្រាហ្មណ៍ បណ្ដាបដិបទាទាំងពីរនេះ អ្នកកាន់បដិបទាណា ថាមានសេចក្ដីត្រូវការតិចផង មានការរៀបចំតិចផង មានផលច្រើនផង មានអានិសង្សច្រើនផង ដូច្នេះទេតើ ។ សង្គារវព្រាហ្មណ៍ បាន

និយាយនឹងព្រះអានន្ទដ៏មានអាយុជាគម្រប់ ៣ ដងដូច្នេះថា បុគ្គលដូចជាព្រះគោតមដ៏ចម្រើន និងព្រះអានន្ទដ៏ចម្រើននេះ ខ្ញុំត្រូវបូជា ខ្ញុំត្រូវសរសើរ ។ លំដាប់នោះឯង ព្រះដ៏មានព្រះភាគមានសេចក្តីត្រិះរិះដូច្នេះថា សង្គារវព្រាហ្មណ៍ត្រូវអានន្ទសួរប្រស្នាប្រកបដោយហេតុ ដរាប ៣ ដងហើយ បន្ទប់មិនដោះស្រាយ បើដូច្នោះ មានតែតថាគតដោះស្រាយ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគត្រាស់នឹងសង្គារវព្រាហ្មណ៍ដូច្នេះថា ម្នាលព្រាហ្មណ៍ ថ្ងៃនេះ អន្តរាកថា ( ពាក្យពោលក្នុងចន្លោះ ឬរវាង ) ដូចម្តេច កើតឡើងដល់ពួកជនដែលអង្គុយប្រជុំគ្នា ក្នុងរាជបរិសទ្យ ក្នុងខាងក្នុងរាជបុរី ។ បពិត្រព្រះគោតមដ៏ចម្រើន ថ្ងៃនេះ ខាងក្នុងរាជបុរី អន្តរាកថានេះឯង កើតឡើងដល់ពួកជនដែលអង្គុយប្រជុំគ្នា ក្នុងរាជបរិសទ្យថា បានឮថា កាលពីដើម ពួកភិក្ខុមានប្រមាណតិច តែភិក្ខុអ្នកមានឧត្តរិមនុស្សធម៌ សម្តែងឥទ្ធិប្បាដិហារ្យបាន មានច្រើន ឥឡូវនេះ ពួកភិក្ខុមានច្រើនមែន តែភិក្ខុអ្នកមានឧត្តរិមនុស្សធម៌ សម្តែងឥទ្ធិប្បាដិហារ្យបាន មានប្រមាណតិចវិញ ។ បពិត្រព្រះគោតមដ៏ចម្រើន ថ្ងៃនេះ ខាងក្នុងរាជបុរី អន្តរាកថានេះ កើតឡើងដល់ពួកជនដែលអង្គុយប្រជុំគ្នាក្នុងរាជបរិសទ្យ ។ ម្នាលព្រាហ្មណ៍ បាដិហារ្យនេះមាន ៣ ។ បាដិហារ្យ ៣ ដូចម្តេច ។ គឺឥទ្ធិប្បាដិហារ្យ ១ អាទេសនាបាដិហារ្យ ១ អនុសាសនីបាដិហារ្យ ១ ។ ម្នាលព្រាហ្មណ៍ ឥទ្ធិប្បាដិហារ្យ តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះ ក្នុងលោកនេះ បានសម្រេចឫទ្ធិច្រើនប្រការ គឺមនុស្សម្នាក់ ធ្វើឲ្យទៅជាមនុស្សច្រើននាក់ក៏បាន មនុស្សច្រើននាក់ ធ្វើឲ្យ

ទៅជាមនុស្សម្នាក់វិញក៏បាន ដើរទៅ មិនជាប់ជំពាក់នឹងទីវាល ទីខាងក្រៅ ទីខាងក្រៅជញ្ជាំង ទីខាងក្រៅកំពែង ទីខាងក្រៅភ្នំ ហាក់ដូចជាដើរទៅក្នុងអាកាសក៏បាន ធ្វើនូវការងើបឡើង ឬមុជចុះក្នុងផែនដី ហាក់ដូចជាងើបឡើង ឬមុជចុះក្នុងទឹកក៏បាន ដើរលើទឹកមិនបែកធ្លាយ ហាក់ដូចជាដើរលើផែនដីក៏បាន ទៅឯអាកាសទាំងភ្នែន ហាក់ដូចជាសត្វស្លាបក៏បាន យកដៃទៅស្ទាបអង្អែល ចាប់ពាល់ព្រះចន្ទ្រ ព្រះអាទិត្យនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះក៏បាន ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោកក៏បាន ។ ម្នាលព្រាហ្មណ៍ នេះហៅថា ឥទ្ធិប្បាដិហារ្យ ។ ម្នាលព្រាហ្មណ៍ អាទេសនាបាដិហារ្យ តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះ ក្នុងលោកនេះ ទាយ ( ចិត្ត ) តាមនិមិត្តថា មនោរបស់អ្នកយ៉ាងនេះខ្លះ មនោរបស់អ្នកដោយប្រការដូច្នេះខ្លះ ចិត្តអ្នកដូច្នេះខ្លះ ។ បុគ្គលនោះ ទោះបីទាយច្រើន ហេតុដែលទាយដូច្នោះនោះ ក៏មិនក្លាត់ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនបាច់ទាយចិត្តតាមនិមិត្តទេ គ្រាន់តែឮសំឡេងពួកមនុស្ស ពួកអមនុស្ស និងពួកទេវតា ហើយក៏ទាយបានថា មនោរបស់អ្នក យ៉ាងនេះខ្លះ មនោរបស់អ្នកដោយប្រការដូច្នេះខ្លះ ចិត្តអ្នកដូច្នេះខ្លះ ។ បុគ្គលនោះ ទោះបីទាយច្រើន ហេតុដែលទាយដូច្នោះនោះ ក៏មិនក្លាត់ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនបាច់ទាយចិត្តតាមនិមិត្តទេ មិនបាច់ឮសំឡេង ពួកមនុស្ស ពួកអមនុស្ស និងពួកទេវតាហើយទាយទេ គ្រាន់តែឮស្សូរវិតក្ក វិចាររបស់បុគ្គលដែលត្រិះរិះ

ពិចារណា ក៏ទាយបានថា មនោរបស់អ្នក យ៉ាងនេះខ្លះ មនោរបស់អ្នក ដោយប្រការដូច្នេះខ្លះ គំនិតអ្នកដូច្នេះខ្លះ ។ បុគ្គលនោះ ទោះបីទាយច្រើន ហេតុដែលទាយដូច្នោះនោះ ក៏មិនក្លាត់ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនបាច់ទាយចិត្តតាមនិមិត្តទេ ទាំងមិនបាច់ស្តាប់សំឡេង ពួកមនុស្ស ពួកអមនុស្ស ពួកទេវតា ហើយទាយទេ ទាំងមិនបាច់ស្តាប់សូរវិតក្កវិចាររបស់មនុស្សដែលត្រិះរិះ ដែលពិចារណា ហើយទាយទេ ប៉ុន្តែថា កំណត់ដឹងចិត្តដោយចិត្តនៃបុគ្គល ដែលចូលសមាធិ មិនមានវិតក្ក មិនមានវិចារថា មនោសង្ខារទាំងឡាយ របស់បុគ្គលដ៏ចម្រើននេះ តាំងទុកហើយយ៉ាងណា បុគ្គលដ៏ចម្រើន នឹងត្រិះរិះនូវវិតក្កឈ្មោះឯណោះ អំពីលំដាប់នៃចិត្តនេះ ។ បុគ្គលនោះ ទោះបីទាយច្រើន ហេតុដែលទាយដូច្នោះនោះ ក៏មិនក្លាត់ ។ ម្នាលព្រាហ្មណ៍ នេះហៅថា អាទេសនាបាដិហារ្យ ។ ម្នាលព្រាហ្មណ៍ ចុះអនុសាសនីបាដិហារ្យ តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះ ក្នុងលោកនេះ ប្រៀនប្រដៅយ៉ាងនេះថា អ្នកទាំងឡាយ ត្រូវត្រិះរិះយ៉ាងនេះ កុំត្រិះរិះយ៉ាងនេះឡើយ ចូរធ្វើទុកក្នុងចិត្តយ៉ាងនេះ កុំធ្វើទុកក្នុងចិត្តយ៉ាងនេះឡើយ ចូរលះបង់នូវអំពើនេះចេញ ចូរឱបក្រសោបនូវអំពើនេះចុះ ។ ម្នាលព្រាហ្មណ៍ នេះហៅថា អនុសាសនីបាដិហារ្យ ។ ម្នាលព្រាហ្មណ៍ បាដិហារ្យមាន ៣ ប្រការនេះឯង ។ ម្នាលព្រាហ្មណ៍ បណ្តាបាដិហារ្យទាំង ៣ នេះ អ្នកគាប់ចិត្តបាដិហារ្យណាថា ល្អផង ឧត្តមផង ។ បពិត្រព្រះគោតមដ៏ចម្រើន បណ្តាបាដិហារ្យទាំងនោះ បាដិហារ្យដែលបុគ្គល

ពួកខ្លះ ក្នុងលោកនេះ បានសម្រេចឫទ្ធិ ច្រើនប្រការ ។បេ។ ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោក បពិត្រព្រះគោតមដ៏ចម្រើន បាដិហារ្យនេះ បុគ្គលណាធ្វើបាដិហារ្យនោះ បុគ្គលនោះឯង រមែងបាន បាដិហារ្យនោះ បុគ្គលណាធ្វើបាដិហារ្យនោះ បាដិហារ្យនោះ តែងមានដល់បុគ្គលនោះឯង ។ បពិត្រព្រះគោតមដ៏ចម្រើន បាដិហារ្យនេះ ប្រាកដដល់ខ្ញុំព្រះអង្គ បីដូចរូបភាពប្រកបដោយកលមាយា ។ បពិត្រព្រះគោតមដ៏ចម្រើន បាដិហារ្យណា ដែលបុគ្គលពួកខ្លះ ក្នុងលោកនេះ ទាយចិត្តតាមនិមិត្តបានថា មនោរបស់អ្នក យ៉ាងនេះខ្លះ មនោរបស់អ្នកដោយប្រការដូច្នេះខ្លះ ចិត្តរបស់អ្នកដូច្នេះខ្លះ ។ បុគ្គលនោះ ទោះបីទាយច្រើន ហេតុដែលទាយដូច្នោះនោះ ក៏មិនក្លាត់ ។ បពិត្រព្រះគោតមដ៏ចម្រើន មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនបាច់ទាយចិត្ត តាមនិមិត្តទេ គ្រាន់តែឮសំឡេងពួកមនុស្ស ពួកអមនុស្ស ឬពួកទេវតាហើយ ទាយបាន ... មិនបាច់ឮសំឡេងពួកមនុស្ស ពួកអមនុស្ស ឬពួកទេវតា ហើយទាយ គ្រាន់តែឮស្សូរវិតក្ក វិចាររបស់បុគ្គលកំពុងត្រិះរិះ កំពុងពិចារណា ហើយទាយត្រូវ ... មិនបាច់ឮស្សូរវិតក្ក វិចាររបស់បុគ្គលកំពុងត្រិះរិះ កំពុងពិចារណា ហើយទាយទេ គ្រាន់តែកំណត់ដឹងចិត្តដោយចិត្តរបស់អ្នកបានសមាធិ មិនមានវិតក្ក មិនមានវិចារថា មនោសង្ខារទាំងឡាយ របស់បុគ្គលដ៏ចម្រើននេះ តាំងទុកយ៉ាងណា បុគ្គលដ៏ចម្រើន នឹងត្រិះរិះនូវវិតក្កឈ្មោះឯណោះ តាមលំដាប់នៃចិត្តនេះ ។ បុគ្គលនោះ ទោះបីទាយច្រើន ហេតុដែលទាយដូច្នោះនោះ ក៏មិនក្លាត់ បពិត្រព្រះ

គោតមដ៏ចម្រើន បាដិហារ្យនេះ បុគ្គលណាបានធ្វើ បាដិហារ្យនោះ បុគ្គលនោះឯងបាននូវបាដិហារ្យនោះ បុគ្គលណា ធ្វើបាដិហារ្យនោះ បាដិហារ្យនោះរមែងមានដល់បុគ្គលនោះឯង ។ បពិត្រព្រះគោតមដ៏ចម្រើន បាដិហារ្យនេះប្រាកដដល់ខ្ញុំព្រះអង្គ បីដូចរូបភាពប្រកបដោយកលមាយា ។ បពិត្រព្រះគោតមដ៏ចម្រើន បាដិហារ្យណា ដែលបុគ្គលពួកខ្លះ ក្នុងលោកនេះ ប្រៀនប្រដៅយ៉ាងនេះថា អ្នកទាំងឡាយ ចូរត្រិះរិះយ៉ាងនេះ កុំត្រិះរិះយ៉ាងនេះឡើយ ចូរធ្វើទុកក្នុងចិត្តយ៉ាងនេះ កុំធ្វើទុកក្នុងចិត្តយ៉ាងនេះឡើយ ចូរលះបង់អំពើនេះចេញ ចូរប្រកបអំពើនេះវិញ ។ បពិត្រព្រះគោតមដ៏ចម្រើន បណ្ដាបាដិហារ្យទាំង ៣ នេះ ខ្ញុំព្រះអង្គគាប់ចិត្ត បាដិហារ្យនេះល្អផង ឧត្ដមផង ។ បពិត្រព្រះគោតមដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះគោតមដ៏ចម្រើន ចម្លែកណាស់ ពាក្យដែលព្រះគោតមដ៏ចម្រើន ទ្រង់សម្ដែងហើយនេះ ថាជាសុភាសិត យើងខ្ញុំចាំទុកនូវព្រះគោតមដ៏ចម្រើន ដែលប្រកបដោយបាដិហារ្យទាំង ៣ នេះ ព្រោះព្រះគោតមដ៏ចម្រើន បានសម្រេចឫទ្ធិច្រើនប្រការ ។បេ។ ប្រើអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោក ព្រោះព្រះគោតមដ៏ចម្រើន កំណត់ដឹងនូវចិត្តដោយចិត្តរបស់បុគ្គលអ្នកបានសមាធិ ឥតមានវិតក្កៈ ឥតមានវិចារថា មនោសង្ខារទាំងឡាយ ដែលបុគ្គលដ៏ចម្រើននេះតម្កល់ទុក បុគ្គលដ៏ចម្រើននេះ នឹងត្រិះរិះនូវវិតក្កឈ្មោះឯណោះ ក្នុងលំដាប់នៃចិត្តនេះ ដ្បិតព្រះគោតមដ៏ចម្រើន ប្រៀនប្រដៅយ៉ាងនេះថា អ្នកទាំងឡាយ ចូរត្រិះរិះយ៉ាងនេះ កុំត្រិះរិះយ៉ាងនេះឡើយ ចូរធ្វើទុកក្នុងចិត្តយ៉ាងនេះ កុំធ្វើ

ទុកក្នុងចិត្តយ៉ាងនេះឡើយ ចូរលះបង់អំពើនេះចេញ ចូរប្រកបអំពើនេះចុះ ។ ម្នាលព្រាហ្មណ៍ វាចាអែបនែបដែលអ្នកពោលហើយ ប៉ះត្រូវតថាគតដោយពិត មានតែតថាគតនឹងសម្តែងដល់អ្នក ម្នាលព្រាហ្មណ៍ ព្រោះតថាគតបានសម្រេចឫទ្ធច្រើនប្រការ ។បេ។ ប្រើអំណាចឲ្យប្រព្រឹត្តទៅ ដោយកាយដរាបដល់ព្រហ្មលោក ម្នាលព្រាហ្មណ៍ ព្រោះតថាគតកំណត់ដឹងនូវចិត្តដោយចិត្តរបស់បុគ្គលអ្នកបានសមាធិ ឥតមានវិតក្ក ឥតមានវិចារថា មនោសង្ខារទាំងឡាយ ដែលបុគ្គលដ៏ចម្រើននេះ បានតម្កល់ទុក បុគ្គលដ៏ចម្រើននេះ នឹងត្រិះរិះនូវវិតក្កឈ្មោះឯណោះ ក្នុងលំដាប់នៃចិត្តនេះ ម្នាលព្រាហ្មណ៍ ព្រោះតថាគតប្រៀនប្រដៅយ៉ាងនេះថា អ្នកទាំងឡាយ ចូរត្រិះរិះយ៉ាងនេះ កុំត្រិះរិះយ៉ាងនេះឡើយ ចូរធ្វើទុកក្នុងចិត្តយ៉ាងនេះ កុំធ្វើទុកក្នុងចិត្តយ៉ាងនេះឡើយ ចូរលះបង់អំពើនេះចេញ ចូរប្រកបអំពើនេះវិញ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះភិក្ខុអង្គណាមួយដទៃទៀត ដែលប្រកបដោយបាដិហារ្យទាំង ៣ នេះ លើកលែងតែព្រះគោតមដ៏ចម្រើនចេញ មានដែរឬ ។ ម្នាលព្រាហ្មណ៍ មិនមានត្រឹមមួយរយ មិនមានត្រឹម ២ រយ មិនមានត្រឹម ៣ រយ មិនមានត្រឹម ៤ រយ មិនមានត្រឹមតែ ៥ រយទេ ដែលពិតនោះ ភិក្ខុដែលប្រកបដោយបាដិហារ្យទាំង ៣ នេះ មានច្រើនណាស់ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះឥឡូវនេះ ពួកភិក្ខុទាំងនោះ នៅក្នុងទីណា ។ ម្នាលព្រាហ្មណ៍ នៅក្នុងពួកភិក្ខុនេះឯង ។ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ដូចជាគេ

ផ្ការរបស់ដែលផ្កាប់ ឬបើកបង្ហាញរបស់ដែលបិទបាំង ឬក៏ប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ពុំនោះដូចគេទ្រោលប្រទីបក្នុងទីងងឹត ឲ្យមនុស្សមានចក្ខុមើលឃើញរូបទាំងឡាយបាន យ៉ាងណា ធម៌ដែលព្រះគោតមដ៏ចម្រើន ប្រកាសហើយដោយអនេកបរិយាយ ក៏យ៉ាងនោះដែរ ខ្ញុំព្រះអង្គនុ៎ះ សូមដល់ព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីរឭក សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គ ថាជាឧបាសក អ្នកដល់សរណគមន៍ ជាទីពឹងស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមទៅ ។

ព្រាហ្មណវគ្គទី ១ ចប់

## ឧទ្ទាននៃព្រាហ្មណវគ្គនោះ គឺ

ពោលអំពីជន ២ លើក អំពីព្រាហ្មណ៍ ១ អំពីបរិព្វាជក
១ អំពីសេចក្តីរលត់ ១ អំពីសត្វលោកដែលជាប់ជំពាក់
ដោយអធម្មរាគៈជាដើម ១ អំពីសេចក្តីប្រាថ្នាដ៏ក្រៃលែង
១ អំពីព្រាហ្មណ៍ឈ្មោះតិកណ្ណៈ ១ អំពីព្រាហ្មណ៍ឈ្មោះ
ជាណុស្សោណិ ១ អំពីព្រាហ្មណ៍ឈ្មោះសង្គារវៈ ១ ។

# អដ្ឋកថា

## សង្គារវសូត្រ

[ ៦២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសង្គារវសូត្រទី ១០ ដូចតទៅនេះ បទថា **សំគារវោ** បានដល់ ព្រាហ្មណ៍អ្នកមើលថៃ និងធ្វើការជុសជួលរបស់បុរាណ ក្នុងក្រុងរាជគ្រឹះ មានឈ្មោះយ៉ាងនេះ ។ បទថា **ឧបសង្កមិ** សេចក្តីថា ព្រាហ្មណ៍បរិភោគអាហារព្រឹកហើយ មានមហាជនចោមរោម ចូលទៅគាល់ព្រះមានព្រះភាគ ។ បទថា **អស្សុ** ក្នុងពាក្យថា **មយមស្សុ** នេះ ត្រឹមតែជានិបាត គឺជាបទសម្តែងសេចក្តីនេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ ឈ្មោះថា ព្រាហ្មណ៍ ។

បទថា **យញ្ញំ យជាម** សេចក្តីថា ឈ្មោះថា យញ្ញប្រកបទៅដោយការសម្លាប់សត្វយ៉ាងនេះ មួយមុខ ៤ មួយមុខ ៨ មួយមុខ ១៦ មួយមុខ ៣២ មួយមុខ ៦៤ មួយមុខ ១០០ និងមួយមុខ ៥០០ មាននៅក្នុងលទ្ធិខាងក្រៅព្រះពុទ្ធសាសនា ។ ព្រះមានព្រះភាគ ទ្រង់សំដៅយកយញ្ញនោះឯង ។ បទថា **អនេកសារីរិកំ** បានដល់ ទាក់ទងដោយបុគ្គលច្រើន ។ បទថា **យមិទំ** ស្មើគ្នានឹង **យា ឯសា** ប្រែថា នេះ ។ បទថា **យញ្ញាធិករណំ** សេចក្តីថា មានការបូជាយញ្ញជាហេតុ និងមានការឲ្យអ្នកដទៃបូជាជាហេតុ សេចក្តីពិត បុញ្ញបដិបទាក្នុងទេយ្យធម៌តែម្យ៉ាង ដែលបុគ្គលឲ្យឯងក្តី ប្រើឲ្យអ្នកដទៃឲ្យក្តី ដល់បុគ្គលច្រើន សូម្បីក្នុងទេយ្យធម៌ច្រើនយ៉ាង ដែលបុគ្គលឲ្យឯងក្តី ប្រើអ្នកដទៃក្តី ដល់បុគ្គលមានចំនួនច្រើន ឈ្មោះថា ជាបដិបទា

ទាក់ទងដល់បុគ្គលច្រើន ។ ពាក្យនេះ ព្រះមានព្រះភាគត្រាស់សំដៅយក បុញ្ញបដិបទានោះ បុញ្ញបដិបទារបស់បុគ្គលដែលពោលថា ខ្ញុំបូជាអ្នក ខ្ញុំបូជាអ្នក ដូច្នេះក្តី បុគ្គលប្រើអ្នកដទៃថា អ្នកចូរបូជា អ្នកចូរបូជា ដូច្នេះក្តី ឈ្មោះថា ជាបដិបទាទាក់ទងដោយបុគ្គលច្រើនដូចគ្នា ។ ពាក្យនេះ ព្រះមានព្រះភាគត្រាស់សំដៅយកបុញ្ញបដិបទានោះ ។

បទថា **យស្ស វា តស្ស វា** ស្មើគ្នានឹង **យស្មា វា តស្មា វា** ប្រែថា អំពីត្រកូលណាៗ ក៏ដោយ ។ បទថា **ឯកមត្តានំ ទមេតិ** សេចក្តីថា ទូន្មានខ្លួនម្នាក់ឯង ដោយអំណាចនៃការទូន្មានឥន្ទ្រិយរបស់ខ្លួន ។ បទថា **ឯកមត្តានំ សមេតិ** សេចក្តីថា ស្ងប់ខ្លួនឯងម្នាក់ឯងនោះឯង ដោយការស្ងប់រាគៈជាដើមរបស់ខ្លួន ។ បទថា **បរិនិព្វាបេតិ** សេចក្តីថា បរិនិព្វានដោយការរម្ងត់ឥតសេសសល់នូវរាគៈជាដើមនោះឯង ។ បទថា **ឯវមស្សាយំ** សេចក្តីថា កាលបើដូច្នេះ រឿងការចេញបព្វជ្ជានេះ ក៏ស្មើគ្នានឹងបុញ្ញបដិបទានេះ ។ ព្រះសាស្តាទ្រង់ស្តាប់វាចារបស់ព្រាហ្មណ៍យ៉ាងនេះហើយ ទ្រង់ព្រះតម្រិះថា ព្រាហ្មណ៍នេះពោលដល់មហាយញ្ញ ដែលប្រកបដោយការសម្លាប់សត្វ ថាជាបុញ្ញបដិបទា ដែលទាក់ទងដោយបុគ្គលច្រើន តែពោលដល់បដិបទាដែលជាហេតុឲ្យកើតបុណ្យ មានបព្វជ្ជាជាបទដ្ឋានថា ជាបុញ្ញបដិបទាទាក់ទងដោយមនុស្សតែមួយ ព្រាហ្មណ៍នេះ មិនស្គាល់បដិបទាដែលទាក់ទងដោយបុគ្គលមួយឡើយ មិនស្គាល់បដិបទាដែលទាក់ទងដោយមនុស្សចំនួនច្រើនផងដែរ ណ្ហើយចុះ តថាគតនឹងសម្តែងបដិបទាដែលទាក់ទងដោយ

បុគ្គលម្នាក់ផង ទាក់ទងដោយបុគ្គលច្រើនផង ដល់ព្រាហ្មណ៍នេះ ដូច្នេះហើយ កាលទ្រង់ពង្រីកព្រះធម្មទេសនាចេញទៅទៀត ទើបត្រាស់ពាក្យជាដើមថា **តេនហិ ព្រាហ្មណ** ដូច្នេះ ។ បណ្តាបទ ទាំងនោះ បទថា **យថាតេ ខមេយ្យ** សេចក្តីថា អ្នកគាប់ចិត្តយ៉ាងណា ។ បទថា **ឥធ តថាគតោ លោកេ ឧប្បជ្ជតិ** បានឲ្យពិស្តារហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។

បទថា **ឯត្ថាយំ មគ្គោ** សេចក្តីថា មកចុះអ្នកទាំងឡាយ តថាគតនឹងប្រៀនប្រដៅ នេះជាផ្លូវ ។ បទថា **អយំ បដិបទា** នេះ ជាវេវចនៈនៃមគ្គនោះ ។ បទថា **យថា បដិបន្នោ** សេចក្តីថា ប្រព្រឹត្តទៅហើយដោយមគ្គណា ។ បទថា **អនុត្តរំ ព្រហ្មចរិយោគធំ** សេចក្តីថា ធម៌ដែលដល់ទីបំផុតមិនមានធម៌ដទៃក្រៃលែងជាង គឺព្រះនិព្វានដែលជាទីពឹងដ៏ឧត្តមរបស់ព្រហ្មចរិយៈ ពោល គឺអរហត្តមគ្គ ។ បទថា **ឥច្ចាយំ** កាត់បទជា **ឥតិ អយំ** ។

បទថា **អប្បត្ថតរា** សេចក្តីថា ជាបដិបទាដែលមិនត្រូវការការជួយស្រោចស្រង់ ឬមិនត្រូវការឧបករណ៍ច្រើន ។ បទថា **អប្បសមារម្ភតរា** សេចក្តីថា ជាបដិបទាដែលមិនមានការប្រណាំងប្រជែង ពោល គឺការកំណត់ដោយកាត់ផ្តាច់នូវកម្មរបស់បុគ្គលដ៏ច្រើន ។

បទថា **សេយ្យថាបិ ភវំ គោតមោ ភវញ្ចានន្ទោ ឯតេ មេ បុជ្ជា** សេចក្តីថា ព្រាហ្មណ៍ពោលពាក្យនោះ សំដៅដល់សេចក្តីនេះថា បុគ្គលដូចព្រះគោតម និងព្រះអានន្ទ ជាបុគ្គលដែលខ្ញុំព្រះអង្គបូជាហើយ បានដល់ពួកលោកនោះឯង គឺទាំង ២ អង្គ ដែលខ្ញុំបូជា និងសរសើរ ។ បានឮថា

ព្រាហ្មណ៍នោះ មានការគិតយ៉ាងនេះថា ព្រះអានន្ទត្រូវការឲ្យអញប៉ុណ្ណោះឆ្លើយប្រស្នានេះ តែបើអញសរសើរគុណរបស់ខ្លួន ឈ្មោះថា បុគ្គលនឹងមិនត្រេកអរមិនមាន ។ ព្រោះដូច្នោះ កាលព្រាហ្មណ៍មិនបំណងនឹងឆ្លើយប្រស្នា ទើបពោលយ៉ាងនេះបន្ទប់ទៅ ដោយអំណាចនៃការពោលសរសើរ ។ បទថា **ន ខោ ត្យាហំ** កាត់បទជា **ន ខោ តេ អហំ**។

បានឮថា ព្រះថេរៈគិតថា ព្រាហ្មណ៍នេះមិនបំណងនឹងឆ្លើយបញ្ហា ទើបពោលបន្ទប់សេចក្តី អញនឹងឲ្យព្រាហ្មណ៍នេះ ឆ្លើយបញ្ហានេះឲ្យបាន ព្រោះដូច្នោះ ទើបលោកពោលពាក្យយ៉ាងនេះ នឹងព្រាហ្មណ៍នោះ ។ បទថា **សហធម្មិកំ** ប្រែថា មានហេតុ ។ បទថា **សំសាទេតិ** ប្រែថា បន្ទប់ ។ បទថា **នោ វិស្សជ្ជេតិ** ប្រែថា មិនឆ្លើយតប ។ បទថា **យន្នូនាហំ បរិមោចេយ្យំ** សេចក្តីថា កុំបីដូច្នោះឡើយ តថាគតនឹងដោះជនទាំង ២ ឲ្យផុតការលំបាកចិត្ត ។ ព្រោះថា ព្រាហ្មណ៍កាលមិនឆ្លើយបញ្ហាដែលព្រះអានន្ទសួរ រមែងលំបាកចិត្ត ឯអានន្ទ កាលឲ្យព្រាហ្មណ៍ឆ្លើយមិនបាន ក៏លំបាកចិត្ត ដូច្នោះ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា តថាគតនឹងដោះជនទាំង ២ នេះ ចេញអំពីសេចក្តីលំបាកចិត្ត ទើបត្រាស់យ៉ាងនេះ ។ បទថា **កាន្វជ្ជ** កាត់បទជា **កា នុ អជ្ជ**។ បទថា **អន្តរាកថា ឧទបាទិ** សេចក្តីថា ព្រះមានព្រះភាគត្រាស់សួរថា ក្នុងរវាងការសន្ទនាដល់រឿងដទៃ មានរឿងអ្វីកើតឡើងខ្លះ ។ ព្រះសាស្តាត្រាស់យ៉ាងនេះ ដោយមានពុទ្ធបំណងថា បានឮថា គ្រានោះ ព្រះរាជវាំងមានកថា ប្រារព្ធបាដិហារ្យ ៣ កើតឡើង តថាគតនឹង

សួរសេចក្តីនោះ ។

លំដាប់នោះ ព្រាហ្មណ៍គិតថា ឥឡូវនេះ អាត្មាអញអាចពោលបាន កាលនឹងក្រាបទូលសេចក្តីដែលកើតឡើងក្នុងព្រះរាជវាំង ទើបពោលពាក្យជាដើមថា **អយំ ខ្វជ្ជ ភោ គោតម** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **អយំ ខ្វជ្ជ** កាត់បទជា **អយំ ខោ អជ្ជ** ។ បទថា **សុទំ** ក្នុងពាក្យថា **បុព្វេ សុទំ** ត្រឹមតែជានិបាត ។ បទថា **ឧត្តរិមនុស្សធម្មា** បានដល់ មនុស្សធម៌ជាន់ខ្ពស់ ពោល គឺកុសលកម្មបថ ១០ ។ ដោយបទថា **ឥទ្ធិប្បាដិហារិយំ ទស្សេសុំ** ព្រាហ្មណ៍ពោលសំដៅយកការហោះឡើងទៅលើអាកាស ដែលប្រព្រឹត្តទៅហើយយ៉ាងនេះ គឺភិក្ខុទាំងឡាយ កាលត្រាច់បិណ្ឌបាត ទៅក្តី ត្រឡប់ក្តី ហោះទៅដោយអាកាសទាំងអស់ ។ បទថា **ឯតរហិ បន ពហុតរា ច ភិក្ខុ** នេះ ព្រាហ្មណ៍ពោលយ៉ាងនេះតាមលទ្ធិថា កាលមុនភិក្ខុទាំងឡាយប្រហែលជាគិតថា ពួកយើងនឹងញុំាងបច្ច័យ ៤ ឲ្យកើតឡើង ទើបធ្វើយ៉ាងនេះ តែឥឡូវនេះ ដឹងថា បច្ច័យកើតឡើងហើយ ទើបបណ្តោយពោលឲ្យកន្លងទៅដោយមោហៈ និងការប្រមាទ ។

បទថា **បាដិហារិយានិ** បានដល់ បាដិហារិយ៍ដោយប្រាជ្ញាកម្ចាត់លទ្ធិដែលជាបដិបក្ខ ។ បទថា **ឥទ្ធិបាដិហារិយំ** សេចក្តីថា បាដិហារិយ៍ដោយអំណាចការសម្តែងឫទ្ធិ ឈ្មោះថា ឥទ្ធិបាដិហារិយ៍ ។ ក្នុងបាដិហារិយ៍ក្រៅអំពីនេះ ក៏មានន័យដូចគ្នា ។ ឯអធិប្បាយអំពីវិជ្ជា ៨ មានឥទ្ធិវិធិផ្សេងៗ ក្តី ការចម្រើនវិជ្ជា ៨ ក្តី មានពិស្តារហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។ បទថា

**និមិត្តេន អាទិសតិ** សេចក្តីថា ព្យាករថា ឈ្មោះថា វត្ថុនេះ នឹងមានដោយនិមិត្តដែលចូលមកហើយ ដោយនិមិត្តដែលចូលទៅហើយ ឬដោយនិមិត្តដែលកំពុងនៅ ។

ក្នុងរឿងនេះ មានរឿងជាបុគ្គលាធិដ្ឋានដូចតទៅ បានឮថា ព្រះរាជាមួយអង្គ ក្តាប់កែវមុក្តា ៣ ហើយត្រាស់សួរបុរោហិតថា លោកអាចារ្យ អ្វីនៅក្នុងដៃរបស់ខ្ញុំ ។ បុរោហិតក្រឡេកមើលខាងនោះ ខាងនេះ ពេលនោះមានតុកកែមួយរត់ទៅដោយតាំងចិត្តថា នឹងចាប់សត្វរុយ ក្នុងកាលចាប់ រុយក៏គេចទៅបាន ទើបគាត់ក្រាបទូលថា បពិត្រមហារាជ នុ៎ះជាកែវមុក្តា ព្រោះគាត់កាន់យកនិមិត្តរុយគេចទៅបាន ។ ព្រះរាជាត្រាស់សួរតទៅថា ត្រឹមត្រូវហើយ តែមានចំនួនប៉ុន្មាន ។ បុរោហិត សង្កេតមើលនិមិត្តទៀត ពេលនោះមាន់រងាវឡើង ៣ ដង ក្នុងទីមិនឆ្ងាយ ព្រាហ្មណ៍ក្រាបទូលថា បពិត្រមហារាជ មាន ៣ ។ បុគ្គលខ្លះ ព្យាករនិមិត្តដែលចូលមកហើយ ដូចពណ៌នាមកនេះ ។ សូម្បីនិមិត្តដែលចូលទៅហើយ និងកំពុងតាំងនៅ ក៏គប្បីជ្រាបការទាយ ដោយឧបាយនេះ ។

បទថា **ឯវម្បិ តេ មនោ** សេចក្តីថា ចិត្តរបស់អ្នកយ៉ាងនេះ គឺអាស្រ័យសោមនស្ស អាស្រ័យទោមនស្ស ឬប្រកបដោយកាមវិតក្កជាដើម ពាក្យទី ២ គឺ **ឥត្ថម្បិ តេ មនោ** ជាវេវចនៈនៃពាក្យថា **ឯវម្បិ តេ មនោ** នោះឯង ។ បទថា **ឥតិបិ តេ ចិត្តំ** សេចក្តីថា ចិត្តរបស់លោកប្រព្រឹត្តទៅដោយប្រការនេះ អធិប្បាយថា លោកកំពុងគិតដល់សេចក្តីនេះ និង

សេចក្តីនេះ ចិត្តប្រព្រឹត្តទៅហើយ ។ បទថា **ពហុម្បិ អាទិសតិ** សេចក្តីថា បើបុគ្គលនោះព្យាករច្រើនសោត ។ បទថា **តថេវ តំ ហោតិ** សេចក្តីថា រឿងផ្សេងៗ ដូចទាយនោះឯង ។ បទថា **អមនុស្សានំ** បានដល់អមនុស្ស មានយក្ខ និងបិសាចជាដើម ។ បទថា **ទេវតានំ** បានដល់ទេវតាទាំងឡាយ មានទេវតាជាន់ចាតុម្មហារាជជាដើម ។ បទថា **សទ្ទំ សុត្វា** សេចក្តីថា បានឮសំឡេងនៃបុគ្គលនោះកំពុងពោល ទើបព្យាករព្រោះដឹងចិត្តរបស់អ្នកដទៃ ។ បទថា **វិតក្កវិចារសទ្ទំ** សេចក្តីថា សំឡេងរបស់បុគ្គលដែលកំបាំង និងប្រមាទជាដើម មមើដល់វត្ថុដែលកើតឡើងដោយអំណាចនៃវិតក្ក និងវិចារ ។ បទថា **សុត្វា** បានដល់ បានឮសំឡេងនោះ អធិប្បាយថា ទាយនូវសំឡេងដែលកើតឡើង ដោយអំណាចអារម្មណ៍ដែលលោកកំពុងត្រិះរិះថា ចិត្តរបស់លោកយ៉ាងនេះ ។ ក្នុងសេចក្តីនោះមានរឿងជាសាធកដូចតទៅនេះ បានឮថា បុរសម្នាក់គិតថា អញនឹងទៅដោះស្រាយក្តីចេញអំពីស្រុក ទៅកាន់នគរតាំងអំពីទីដែលចេញដើរទៅ ក៏គិតថា ក្នុងសាលាអញនឹងធ្វើវត្ថុនេះ និងនិយាយពាក្យនេះដល់ព្រះរាជារាជអមាត្យហាក់ដូចជាទៅកាន់រាជត្រកូលហើយ ដូចគ្នានឹងបានឮចំពោះព្រះភក្ត្ររបស់ព្រះរាជាហើយ និងដូចកំពុងឲ្យការនៅជាមួយចៅក្រម បុរសម្នាក់បានឮសំឡេងនោះរបស់គាត់ដែលបន្ទឺទៅ ដោយវិតក្ក និងវិចារៈ ទើបសួរថា អ្នកទៅដោយរឿងអ្វី ។ បុរសនោះឆ្លើយថា ទៅដោះស្រាយក្តី ។ ទើបបុរសនោះពោលថា ទៅចុះ អ្នកនឹងមានជ័យជម្នះ ។ គាត់ទៅស្រាយក្តីហើយ ក៏

ជួបនូវជ័យជម្នះ ។

ព្រះថេរៈអ្នកបោលិយគាមមួយរូប ចូលទៅបិណ្ឌបាតក្នុងស្រុក ខណៈនោះ ទារិកាម្នាក់បញ្ជូនចិត្តទៅកាន់ទីដទៃ ទើបមិនឃើញលោកដើរចេញទៅ។ លោកឈរត្រង់ទ្វារផ្ទះ ហើយត្រឡប់ចេញទៅសម្លឹងមើល ឃើញទារិកានោះ ហើយបានដើរត្រិះរិះទៅ ហើយកាលដើរទៅ ក៏បានពោលថា នាងធ្វើអ្វីឬ ទើបមិនឃើញអាត្មា ។ បុរសម្នាក់ឈរនៅក្បែរបានឮហើយ ក៏ពោលឡើងថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ និមន្តទៅកាន់ស្រុកបោលិយគាមចុះ ។

បទថា **មនោសង្ខារា បណិហិតា** សេចក្តីថា ចិត្តសង្ខារដែលតាំងល្អហើយ ។ បទថា **វិតក្កេស្សតិ** សេចក្តីថា ដឹងច្បាស់ថា នឹងត្រិះរិះ គឺនឹងញុំាងចិត្តឲ្យប្រព្រឹត្តទៅ ។ កាលលោកដឹងច្បាស់ ឈ្មោះថា រមែងដឹងច្បាស់ដោយនិមិត្ត ដែលកន្លងមកនោះឯង ។ រមែងដឹងដោយនិមិត្ត ដែលជាចំណែកខាងដើម ។ រមែងដឹងដោយលើកចិត្តឡើងខាងក្នុងសមាបត្តិ ។

ក្នុងវេលាបរិកម្មកសិណទាំងនោះឯង ភិក្ខុដឹងថា ព្រះយោគាវចរនេះ ប្រារព្ធការចម្រើនកសិណ ដោយអាការណា នឹងញុំាងបឋមជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ឬសមាបត្តិ ៨ ឲ្យកើតឡើង ដោយអាការនោះ ឈ្មោះថា ដឹងដោយនិមិត្តដែលធ្លងមក ។

កាលប្រារព្ធសមថវិបស្សនាហើយ ភិក្ខុដឹង គឺដឹងថា ព្រះយោគាវចរនេះប្រារព្ធវិបស្សនាហើយ ដោយអាការណា នឹងញុំាងសោតាបត្តិមគ្គ ។បេ។ ឬអរហត្តមគ្គឲ្យកើតឡើង ដោយអាការនោះ ឈ្មោះថា ដឹងនិមិត្តដោយ

ចំណែកខាងដើម ។

ភិក្ខុដឹងថា មនោសង្ខាររបស់ព្រះយោគាវចរនេះ បានតម្កល់ល្អហើយ លោកនឹងត្រិះរិះវិតក្កនេះ ក្នុងលំដាប់នៃចិត្តឈ្មោះនេះ ដោយអាការណា សមាធិរបស់ព្រះយោគាវចរនេះ ដែលចេញចាកសមាបត្តិនេះហើយ ដែលជាហានភាគិយៈ គឺចំណែកនៃការលះ ដែលជាឋិតិភាគិយៈ គឺចំណែកនៃការតាំងនៅដែលជាវិសេសភាគិយៈ គឺជាចំណែកនៃគុណវិសេស ឬជានិព្វេធភាគិយៈ គឺចំណែកនៃការត្រាស់ដឹង នឹងមាន ឬការធ្វើឲ្យជាក់ច្បាស់ដោយអភិញ្ញា នឹងកើតឡើងដល់លោក ដោយអាការនោះ ឈ្មោះថា ដឹងដោយពិនិត្យមើលចិត្តខាងក្នុងសមាបត្តិ ។

បណ្ដាបទទាំងនោះ បុថុជ្ជនអ្នកបានចេតោបរិយញ្ញាណ រមែងដឹងចិត្តនៃបុថុជ្ជនផងគ្នា តែមិនដឹងចិត្តរបស់ព្រះអរិយៈឡើយ សូម្បីព្រះអរិយៈទាំងឡាយ ព្រះអរិយៈថ្នាក់ក្រោម រមែងមិនដឹងចិត្តរបស់ព្រះអរិយបុគ្គលថ្នាក់ខ្ពស់ តែព្រះអរិយបុគ្គលថ្នាក់ខ្ពស់ ដឹងចិត្តរបស់ព្រះអរិយបុគ្គលថ្នាក់ទាប ។ម្យ៉ាងទៀត បណ្ដាព្រះអរិយបុគ្គលទាំងនេះ ព្រះសោតាបន្នចូលសោតាបត្តិផលសមាបត្តិ ព្រះសកទាគាមី ... ព្រះអនាគាមី ... ព្រះអរហន្ត ចូលអរហត្តផលសមាបត្តិ ។ ព្រះអរិយបុគ្គលថ្នាក់ខ្ពស់ មិនចូលសមាបត្តិថ្នាក់ទាប ព្រោះថា សមាបត្តិថ្នាក់ទាបរបស់ព្រះអរិយបុគ្គលថ្នាក់ទាបទាំងនោះ ប្រព្រឹត្តទៅក្នុងព្រះអរិយបុគ្គលថ្នាក់ទាបទាំងនោះ ។ បទថា **តថេវ តំ ហោតិ** សេចក្ដីថា ពាក្យព្យាករនោះ រមែងដូចយ៉ាងនោះឯង ដោយចំណែកមួយ

ព្រោះពាក្យព្យាករដែលលោកដឹង ដោយអំណាចនៃចេតោបរិយញ្ញាណ ឈ្មោះថា ទៅជាដទៃមិនមាន គឺមិនខុសក្លាំងក្លាត់ ។

បទថា **ឯវំ វិតក្កេថ** សេចក្តីថា អ្នកទាំងឡាយចូរត្រិះរិះឲ្យនេក្ខម្មវិតក្ក ជាដើមប្រព្រឹត្តទៅយ៉ាងនេះ ។ បទថា **មា ឯវំ វិតក្កយិត្ថ** សេចក្តីថា អ្នកទាំងឡាយ កុំត្រិះរិះឲ្យកាមវិតក្កជាដើមប្រព្រឹត្តទៅយ៉ាងនេះ ។ បទថា **ឯវំ មនសិករោថ** សេចក្តីថា អ្នកទាំងឡាយ ចូរមនសិការដល់អនិច្ចសញ្ញា នោះឯង ឬសញ្ញាដទៃ ក្នុងបណ្តាទុក្ខសញ្ញាជាដើមយ៉ាងនេះ ។ បទថា **មា ឯវំ** សេចក្តីថា អ្នកទាំងឡាយ កុំដាក់ចិត្តដោយន័យជាដើមថា ទៀង ដូច្នេះ ។ បទថា **ឥទំ** សេចក្តីថា អ្នកទាំងឡាយ ចូរលះនូវតម្រេកក្នុងបញ្ចកាមគុណ នេះ ។ បទថា **ឥទំ បន ឧបសម្បជ្ជ** សេចក្តីថា អ្នកទាំងឡាយ គប្បីចូល ដល់ គឺសម្រេចលោកុត្តរធម៌ ចែកប្រភេទជាមគ្គ ៤ ផល ៤ នោះឯង បានដល់ ឲ្យសម្រេចហើយ ។

បទថា **មាយាសហធម្មរូបំ វិយ ខាយតិ** សេចក្តីថា រមែងប្រាកដ ដូចរូបដែលកើតអំពីហេតុដែលស្មើដោយមាយា ។ ពិតហើយ អ្នកលេងល្បិច រមែងសម្តែងកលបានច្រើនយ៉ាង គឺដួសទឹកមក ធ្វើឲ្យជាប្រេងក៏បាន ដួសប្រេងមក ធ្វើឲ្យទៅជាទឹកក៏បាន សូម្បីបាដិហារិយ៍នេះ ក៏បែបនោះដូចគ្នា ដូច្នេះ ។

ព្រាហ្មណ៍ពោលយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន សូម្បីបាដិហារ្យ ប្រាកដដល់ខ្ញុំព្រះអង្គដូចលេងកល សំដៅយកភាពដែលបាដិហារ្យដូចគ្នានឹង

វិជ្ជាចិន្តាមនីមន្ត ។ ព្រោះបុគ្គលដែលចេះចិន្តាមនីមន្តនេះ ឃើញបុគ្គលកំពុងដើរមកនោះឯង រមែងដឹងថា បុគ្គលនេះ ដើរត្រិះរិះរឿងនេះមក ម្យ៉ាងទៀត រមែងដឹងថា បុគ្គលនេះ ឈរត្រិះរិះរឿងឈ្មោះនេះ អង្គុយត្រិះរិះរឿងឈ្មោះនេះ ដេកត្រិះរិះរឿងឈ្មោះនេះ ដូច្នេះ ។

បទថា **អភិក្កន្តតរំ** បានដល់ ល្អជាង ។ បទថា **បណីតតរំ** បានដល់ ប្រណីតជាង ។ ក្នុងបទថា **ភវញ្ហិ គោតមោ អវិតក្កំ អវិចារំ** នេះ ព្រាហ្មណ៍មិនបានកាន់យកអាទេសនាបាដិហារ្យដ៏សេសថា ជាលទ្ធិខាងក្រៅព្រះពុទ្ធសាសនា ព្រាហ្មណ៍នោះ កាលពោលសរសើរព្រះតថាគត ទើបពោលសេចក្តីទាំងអស់នេះ ។ បទថា **អទ្ធា ខោ ត្យាហំ** សេចក្តីថា វាចានេះ អ្នកពោលត្រឹមត្រូវហើយ ដោយចំណែកមួយពិត ។ បទថា **អាសជ្ជ ឧប-នីយវាចា ភាសិតា** សេចក្តីថា វាចាដែលអ្នកពោលទីពឹងតថាគត អ្នកពោលត្រឹមត្រូវហើយ ។ បទថា **អបិច ត្យាហំ ព្យាករិស្សាមិ** សេចក្តីថា ទាំងតថាគតនឹងព្យាករដល់អ្នក ។ បទដ៏សេស មានអត្ថងាយយល់ទាំងអស់ហើយ ដូច្នេះឯង ។៚

**អដ្ឋកថាសង្គារវសូត្រទី ១០ ចប់**

**ព្រាហ្មណវគ្គទី ១ ចប់**

# សុត្តន្តបិដក

# មហាវគ្គ

## តិត្ថាយតនសូត្រទី ១

[ ៦៣ ] ម្នាលភិក្ខុទាំងឡាយ លទ្ធិនៃតិរ្ថិយ មាន ៣ យ៉ាង ដែលពួកបណ្ឌិតសាកសួររឿយៗ ដេញដោលរឿយៗ ប្រដៅរឿយៗ ប្រព្រឹត្តទៅតាមនូវបរម្បរាចារ្យ ហើយតាំងនៅក្នុងអកិរិយមតិ ។ លទ្ធិនៃតិរ្ថិយ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ពួកមួយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុរសបុគ្គលនេះទទួលនូវអារម្មណ៍ណាមួយ ជាសុខ ឬជាទុក្ខ ឬមិនមែនទុក្ខមិនមែនសុខ អារម្មណ៍ទាំងអស់នោះ ( ដែលបុគ្គលបានទទួលហើយ ) ព្រោះហេតុតែអំពើដែលគេបានធ្វើហើយក្នុងកាលមុន ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុរសបុគ្គលនេះ ទទួលនូវអារម្មណ៍ណាមួយ ជាសុខ ឬជាទុក្ខ ឬមិនមែនទុក្ខមិនមែនសុខ អារម្មណ៍ទាំងអស់នោះ ( ដែលបុគ្គលទទួលហើយ ) ព្រោះហេតុតែព្រះឥសូរបានតាក់តែងមក ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុរសបុគ្គលនេះ ទទួលនូវអារម្មណ៍ណាមួយ ជាសុខ ឬជាទុក្ខ ឬមិនមែនទុក្ខមិនមែនសុខ អារម្មណ៍ទាំងអស់នោះ ( ដែលបុគ្គលបានទទួលហើយ ) ព្រោះមិនមានហេតុ មិនមានបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសមណ-ព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាង

នេះថា បុរសបុគ្គលនេះទទួលនូវអារម្មណ៍ណាមួយ ជាសុខ ឬជាទុក្ខ ឬមិនមែនទុក្ខ មិនមែនសុខ អារម្មណ៍ទាំងអស់នោះ ( ដែលបុគ្គលបានទទួលហើយ ) ព្រោះហេតុតែអំពើដែលគេបានធ្វើហើយក្នុងកាលមុន តថាគតបានចូលទៅរកពួកសមណព្រាហ្មណ៍ទាំងនោះ ហើយពោលយ៉ាងនេះថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ ឮថា អ្នកទាំងឡាយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុរសបុគ្គលនោះ ទទួលនូវអារម្មណ៍ណាមួយ ជាសុខ ឬជាទុក្ខ ឬមិនមែនទុក្ខ មិនមែនសុខ អារម្មណ៍ទាំងអស់នោះ ( ដែលបុគ្គលបានទទួលហើយ ) ព្រោះហេតុតែអំពើដែលគេបានធ្វើហើយ ក្នុងកាលមុនពិតមែនឬ ។ បើសមណព្រាហ្មណ៍ទាំងនោះ ដែលតថាគតសួរយ៉ាងនេះហើយ ក៏ប្តេជ្ញាថា ព្រះករុណាព្រះអង្គ តថាគតក៏និយាយទៅនឹងពួកសមណ-ព្រាហ្មណ៍ទាំងនោះយ៉ាងនេះវិញថា បើដូច្នោះ អ្នកដ៏មានអាយុទាំងឡាយ នឹងប្រព្រឹត្តបាណាតិបាត ព្រោះហេតុតែអំពើដែលខ្លួនបានធ្វើហើយ ក្នុងកាលមុន នឹងប្រព្រឹត្តអទិន្នាទាន ព្រោះហេតុតែអំពើដែលខ្លួនបានធ្វើហើយ ក្នុងកាលមុន នឹងប្រព្រឹត្តអព្រហ្មចារ្យ ព្រោះហេតុតែអំពើដែលខ្លួនបានធ្វើហើយ ក្នុងកាលមុន នឹងប្រព្រឹត្តមុសាវាទ ព្រោះហេតុតែអំពើដែលខ្លួនបានធ្វើហើយ ក្នុងកាលមុន នឹងប្រព្រឹត្តបិសុណាវាចា ព្រោះហេតុតែអំពើដែលខ្លួនបានធ្វើហើយ ក្នុងកាលមុន នឹងប្រព្រឹត្តផរុសវាចា ព្រោះហេតុតែអំពើដែលខ្លួនបានធ្វើហើយ ក្នុងកាលមុន នឹងប្រព្រឹត្តសម្ផប្បលាបៈ ព្រោះហេតុតែអំពើដែលខ្លួនបានធ្វើហើយ ក្នុងកាលមុន នឹងជាអ្នកច្រើនដោយអភិជ្ឈា ព្រោះហេតុតែអំពើដែល

ខ្លួនបានធ្វើហើយ ក្នុងកាលមុន នឹងមានចិត្តព្យាបាទ ព្រោះហេតុតែអំពើដែលខ្លួនបានធ្វើហើយ ក្នុងកាលមុន នឹងជាមិច្ឆាទិដ្ឋិ ព្រោះហេតុតែអំពើដែលខ្លួនបានធ្វើហើយ ក្នុងកាលមុន ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នា ឬសេចក្តីព្យាយាមថា កិច្ចនេះ គួរធ្វើក្តី កិច្ចនេះ មិនគួរធ្វើក្តី មិនសម្រេចដល់ពួកបុគ្គលដែលប្រកាន់នូវអំពើដែលខ្លួនបានធ្វើហើយ ក្នុងកាលមុនថា មានសារៈទេ ។ កាលបើកិច្ចដែលគួរធ្វើ និងមិនគួរធ្វើ មិនប្រាកដដោយពិតដោយមាំមួនហើយ សមណវាទដែលប្រកបដោយហេតុចំពោះខ្លួន ក៏មិនសម្រេចដល់ពួកបុគ្គលដែលភាន់ភាំងសតិ និងមិនមានការរក្សាឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាវាទៈរបស់តថាគត ប្រកបដោយហេតុទី ១ ជាធម៌សង្កត់សង្កិនពួកសមណព្រាហ្មណ៍ទាំងនោះ ដែលមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណាមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុរសបុគ្គលនេះរមែងទទួលនូវអារម្មណ៍ណាមួយ ជាសុខ ឬជាទុក្ខ ឬមិនមែនទុក្ខ មិនមែនសុខ អារម្មណ៍ទាំងអស់នោះ ( ដែលបុគ្គលបានទទួលហើយ ) ព្រោះហេតុតែព្រះឥស្សូរបានតាក់តែងមក តថាគតចូលទៅរកសមណព្រាហ្មណ៍ទាំងនោះហើយ ពោលយ៉ាងនេះថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ ឮថាអ្នកទាំងឡាយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុរសបុគ្គលនេះទទួលនូវអារម្មណ៍ណាមួយ ជាសុខ ឬជាទុក្ខ ឬមិនមែនទុក្ខ មិនមែនសុខ អារម្មណ៍ទាំងអស់នោះ ( ដែលបុគ្គលបានទទួលហើយ ) ព្រោះហេតុតែព្រះ

ឥស្សរបានតាក់តែងមក ពិតឬ ។ បើតថាគតសួរយ៉ាងនេះហើយ សមណ-
ព្រាហ្មណ៍ទាំងនោះ ក៏ប្តេជ្ញាថា ព្រះករុណាព្រះអង្គ តថាគតក៏ពោលទៅនឹង
សមណព្រាហ្មណ៍ទាំងនោះ យ៉ាងនេះវិញថា បើដូច្នោះ អ្នកដ៏មានអាយុ
ទាំងឡាយ នឹងប្រព្រឹត្តបាណាតិបាត ព្រោះហេតុតែព្រះឥស្សរបានតាក់តែងមក
។បេ។ នឹងមានគំនិតយល់ខុស ព្រោះហេតុតែព្រះឥស្សរបានតាក់តែងមក ។
សេចក្តីប្រាថ្នា ឬសេចក្តីព្យាយាមថា កិច្ចនេះ គួរធ្វើក្តី កិច្ចនេះ មិនគួរធ្វើក្តី
មិនសម្រេចដល់ពួកបុគ្គលដែលប្រកាន់នូវសេចក្តីយល់ថា ព្រះឥស្សរអ្នកតាក់
តែងមកថា មានសារៈទេ ។ កាលបើកិច្ចគួរធ្វើ និងមិនគួរធ្វើ មិនប្រាកដ
ដោយពិត ដោយមាំមួនទេ សមណវាទដែលប្រកបដោយហេតុចំពោះខ្លួន
ក៏មិនសម្រេចដល់បុគ្គលដែលភ្លេចសតិ និងមិនមានការរក្សាឡើយ ។ ម្នាល
ភិក្ខុទាំងឡាយ នេះឯង ជាវាទៈរបស់តថាគតប្រកបដោយហេតុទី ២ ជាធម៌
សង្កត់សង្កិនពួកសមណព្រាហ្មណ៍ទាំងនោះ ដែលមានវាទៈយ៉ាងនេះ មានទិដ្ឋិ
យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួក
ព្រាហ្មណ៍ណាមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុរសបុគ្គលនេះទទួល
នូវអារម្មណ៍ណាមួយ ជាសុខ ឬជាទុក្ខ ឬមិនមែនទុក្ខមិនមែនសុខ អារម្មណ៍
ទាំងអស់នោះ ( ដែលបុគ្គលបានទទួលហើយ ) ព្រោះមិនមានហេតុ មិន
មានបច្ច័យ តថាគតក៏បានចូលទៅរកពួកសមណព្រាហ្មណ៍ទាំងនោះ ហើយ
ពោលយ៉ាងនេះថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ ឮថា អ្នកទាំងឡាយ
មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុរសបុគ្គលនេះ ទទួលនូវអារម្មណ៍

ណាមួយ ជាសុខ ឬជាទុក្ខ ឬមិនមែនទុក្ខ មិនមែនសុខ អារម្មណ៍ទាំងអស់នោះ ( ដែលបុគ្គលបានទទួលហើយ ) ព្រោះមិនមានហេតុ មិនមានបច្ច័យពិតឬ ។ បើតថាគតសួរយ៉ាងនេះហើយ សមណព្រាហ្មណ៍ទាំងនោះ ប្ដេជ្ញាព្រមថា ព្រះករុណាព្រះអង្គ តថាគតពោលទៅនឹងសមណព្រាហ្មណ៍ទាំងនោះយ៉ាងនេះវិញថា បើដូច្នោះ អ្នកដ៏មានអាយុទាំងឡាយ នឹងប្រព្រឹត្តបាណាតិបាត ព្រោះមិនមានហេតុ មិនមានបច្ច័យ ។បេ។ និងគំនិតយល់ខុស ព្រោះមិនមានហេតុ មិនមានបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីប្រាថ្នា ឬសេចក្ដីព្យាយាមថា កិច្ចនេះ គួរធ្វើក្ដី កិច្ចនេះ មិនគួរធ្វើក្ដី មិនសម្រេចដល់ពួកបុគ្គលដែលប្រកាន់នូវអំពើដែលមិនមានហេតុថាជាសារៈឡើយ ។ កាលបើកិច្ចដែលគួរធ្វើ និងមិនគួរធ្វើ មិនប្រាកដដោយពិត ដោយមាំមួនទេសមណវាទដែលប្រកបដោយហេតុចំពោះខ្លួន ក៏មិនសម្រេចដល់ពួកបុគ្គលដែលភ្លេចស្មារតី និងមិនមានការរក្សាឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាវាទៈរបស់តថាគត ប្រកបដោយហេតុទី ៣ ជាធម៌សង្កត់សង្កិនពួកសមណព្រាហ្មណ៍ទាំងនោះ ដែលមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ លទ្ធិនៃតិរ្ថិយទាំង ៣ យ៉ាងនេះឯងហើយ ដែលបណ្ឌិតសាកសួររឿយៗ ដេញដោលរឿយៗ ប្រដៅរឿយៗ ប្រព្រឹត្តតាមបរម្បរាចារ្យ តាំងនៅដោយអកិរិយមតិ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតបានសម្ដែងមកហើយនេះ ពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញ សង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបានឡើយ ។

ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតបានសម្តែងមកហើយ ពួកសមណ-ព្រាហ្មណ៍ ជាអ្នកប្រាជ្ញ សង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតបានសម្តែងហើយថា នេះធាតុ ៦ ពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ សង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបាន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតបានសម្តែងហើយថា នេះផស្សាយតនៈ ៦ ពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ សង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបាន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតបានសម្តែងហើយថា នេះមនោបវិចារ ១៨ ពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ សង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបាន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតបានសម្តែងហើយថា នេះអរិយសច្ច ៤ ពួក សមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ សង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបាន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតបានសម្តែងហើយថា នេះធាតុ ៦ ពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ សង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបាន ពាក្យនុ៎ះ តថាគតបានពោលដូច្នេះឯង ។ ពាក្យដែលតថាគតបានពោលហើយនុ៎ះ ព្រោះអា-ស្រ័យនូវហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ( ព្រោះអាស្រ័យ ) នូវធាតុ ៦ នេះ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ អាកាសធាតុ ១

វិញ្ញាណធាតុ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតបានសម្តែងហើយ ថា នេះធាតុ ៦ ពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ សង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបាន ពាក្យណាដែល តថាគតបានពោលដូច្នេះហើយ ពាក្យនុ៎ះ តថាគតបានពោលហើយ ព្រោះ អាស្រ័យនូវហេតុនេះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតបានសម្តែង ហើយថា នេះផស្សាយតនៈ ៦ ពួកសមណព្រាហ្មណ៍ សង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបាន ពាក្យនោះ តថាគតបានពោលហើយដូច្នេះឯង ។ ពាក្យដែលតថាគតបានពោលហើយនុ៎ះ ព្រោះអាស្រ័យនូវហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ( ព្រោះអាស្រ័យ ) នូវ ផស្សាយតនៈ ៦ នេះគឺ ផស្សាយតនៈ គឺចក្ខុ ១ ផស្សាយតនៈ គឺសោតៈ ១ ផស្សាយតនៈ គឺឃានៈ ១ ផស្សាយតនៈ គឺជិវ្ហា ១ ផស្សាយតនៈ គឺ កាយ ១ ផស្សាយតនៈ គឺមនោ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែល តថាគតបានសម្តែងហើយថា នេះផស្សាយតនៈ ៦ ពួកសមណព្រាហ្មណ៍ សង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិន បាន ពាក្យណាដែលតថាគតបានពោលហើយដូច្នេះ ពាក្យដែលតថាគតបាន ពោលហើយនុ៎ះ ព្រោះអាស្រ័យនូវហេតុនេះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ដែលតថាគតបានសម្តែងហើយថា នេះមនោបវិចារ ១៨ ពួកសមណ-ព្រាហ្មណ៍ សង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបាន ពាក្យនុ៎ះ តថាគតបានពោលហើយដូច្នេះឯង ។ ពាក្យដែល

តថាគត បានពោលហើយនុ៎ះ ព្រោះអាស្រ័យនូវហេតុអ្វី ។ ព្រោះឃើញនូវរូបដោយចក្ខុ ហើយពិចារណានូវរូប ដែលជាទីតាំងនៃសោមនស្ស ពិចារណានូវរូបដែលជាទីតាំងនៃទោមនស្ស ពិចារណានូវរូបដែលជាទីតាំងនៃឧបេក្ខា ឮសំឡេងដោយត្រចៀក ... ហិតក្លិនដោយច្រមុះ ... ជញ្ជក់នូវរសដោយអណ្តាត ... ពាល់ត្រូវនូវផោដ្ឋព្វៈដោយកាយ ... ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ពិចារណានូវធម្មារម្មណ៍ ដែលជាទីតាំងនៃសោមនស្ស ពិចារណានូវធម្មារម្មណ៍ដែលជាទីតាំងនៃទោមនស្ស ពិចារណានូវធម្មារម្មណ៍ដែលជាទីតាំងនៃឧបេក្ខា ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតបានសម្តែងហើយថា នេះមនោបវិចារ ១៨ ពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ សង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបាន ពាក្យណាដែលតថាគតបានពោលហើយដូច្នេះ ពាក្យដែលតថាគតបានពោលហើយនុ៎ះ ព្រោះអាស្រ័យនូវហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតបានសម្តែងហើយថា នេះអរិយសច្ច ៤ ពួកសមណព្រាហ្មណ៍ សង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបាន ពាក្យនុ៎ះ តថាគតបានពោលហើយដូច្នេះឯង ។ ពាក្យដែលតថាគតបានពោលហើយនុ៎ះ ព្រោះអាស្រ័យនូវហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ការចុះកាន់គភ៌ព្រោះអាស្រ័យនូវធាតុ កាលបើចុះកាន់គភ៌មាន នាមរូបក៏មាន កាលបើនាមរូបជាបច្ច័យមាន សឡាយតនៈក៏មាន កាលបើសឡាយតនៈជាបច្ច័យមាន ផស្សៈក៏មាន កាលបើផស្សៈជាបច្ច័យមាន វេទនាក៏មាន ។

ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលដឹងនូវអារម្មណ៍ ( ទាំងនោះ ) ទើបតថាគតបញ្ញត្តថា នេះជាទុក្ខ បញ្ញត្តថា នេះជាទុក្ខសមុទ័យ បញ្ញត្តថា នេះជាទុក្ខនិរោធ បញ្ញត្តថា នេះជាទុក្ខនិរោធគាមិនីបដិបទា ។ ម្នាលភិក្ខុទាំងឡាយ ទុក្ខអរិយសច្ច តើដូចម្តេច ។ គឺជាតិទុក្ខ ជរាទុក្ខ មរណទុក្ខ សោកទុក្ខ បរិទេវទុក្ខ ទុក្ខទុក្ខ ទោមនស្សទុក្ខ ឧបាយាសទុក្ខ អប្បិយេហិ សម្បយោគទុក្ខ បិយេហិ វិប្បយោគទុក្ខ យម្បិច្ឆំ ន លភតិ តម្បិទុក្ខំ សង្ខិត្តេន បញ្ចុបាទានក្ខន្ធទុក្ខ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខអរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ ទុក្ខសមុទយអរិសច្ច តើដូចម្តេច ។ គឺសង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈកើតមាន ព្រោះជាតិជាបច្ច័យ សេចក្តីសោកខ្សឹកខ្សួល ទុក្ខ ទោមនស្ស តានតឹងក៏កើតមានព្រម ។ សេចក្តីកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងមានយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខសមុទយអរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ ទុក្ខនិរោធអរិយសច្ច តើដូចម្តេច ។ សេចក្តីរលត់សង្ខារ ព្រោះវិនាស រលត់មិនមានសេសសល់នៃអវិជ្ជា សេចក្តីរលត់វិញ្ញាណ ព្រោះរលត់សង្ខារ សេចក្តីរលត់

នាមរូប ព្រោះរលត់វិញ្ញាណ សេចក្តីរលត់សឡាយតនៈ ព្រោះរលត់នាមរូប សេចក្តីរលត់ផស្សៈ ព្រោះរលត់សឡាយតនៈ សេចក្តីរលត់វេទនា ព្រោះរលត់ផស្សៈ សេចក្តីរលត់តណ្ហា ព្រោះរលត់វេទនា សេចក្តីរលត់ឧបាទាន ព្រោះរលត់តណ្ហា សេចក្តីរលត់ភព ព្រោះរលត់ឧបាទាន សេចក្តីរលត់ជាតិ ព្រោះរលត់ភព សេចក្តីចាស់ ស្លាប់រលត់ ព្រោះរលត់ជាតិ សេចក្តីសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងការចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏រលត់ទៅ ។ សេចក្តីរលត់នៃកងទុក្ខទាំងអស់នេះ តែងមានយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខនិរោធអរិយសច្ច ។ ម្នាលភិក្ខុទាំង-ឡាយ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច តើដូចម្តេច ។ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង គឺសម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មា-សមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខនិរោធគាមិនីបដិបទា-អរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតបានសម្តែងហើយថា នេះអរិយសច្ច ៤ ពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ សង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបាន ពាក្យណាដែលតថាគតពោលហើយដូច្នេះ ពាក្យនេះតថាគតពោលហើយ ព្រោះអាស្រ័យនូវហេតុនុ៎ះ ។

# អដ្ឋកថា

# មហាវគ្គទី ២

## តិត្ថាយតនសូត្រ

[ ៦៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតិត្ថាយតនសូត្រទី ១ នៃមហាវគ្គទី ២ ដូច្នេះថា អណ្តូងកើត ដូចជា **តិត្ថ** គឺកំពង់ ឬប្រភពកើតរបស់តិត្ថិយទាំងឡាយ ឈ្មោះថា **តិត្ថាយតន** ប្រែថា លទ្ធិតិត្ថិយ ។

ក្នុងបទថា **តិត្ថាយតនានិ** នោះ អ្នកសិក្សាគួរស្គាល់តិត្ថ គួរស្គាល់តិត្ថករ គឺមេលទ្ធិ គួរស្គាល់តិត្ថិយ និងគួរស្គាល់សាវករបស់តិត្ថិយជាមុន ។

ទិដ្ឋិ ៦២ ឈ្មោះថា តិត្ថ ។ បុគ្គលអ្នកឲ្យកើតទិដ្ឋិទាំង ៦២ នោះ ឈ្មោះថា **តិត្ថករ** ។ បុគ្គលដែលគាប់ចិត្តក្នុងទិដ្ឋិ ៦២ នោះ ឈ្មោះថា តិត្ថិយ ។ បុគ្គលឲ្យបច្ច័យដល់តិត្ថិយទាំងនោះ ឈ្មោះថា សាវករបស់តិត្ថិយ ។

បទថា **អាយតនំ** សេចក្តីថា ទីកើត ឈ្មោះថា អាយតនៈ ដូចក្នុងប្រយោគជាដើមថា **អស្សានំ កម្ពោជោ អាយតនំ** ដែនកម្ពោជៈជាទីកើតនៃសេះទាំងឡាយ **គុន្នំ ទក្ខិណាបថោ អាយតនំ** ទក្ខិណាជនបទ ជាទីកើតនៃគោទាំងឡាយ ។

ស្ថានទីសមោសរ ឈ្មោះថា អាយតនៈ ដូចក្នុងប្រយោគជាដើមថា

**មនោរមេ អាយតនេ សេវន្តិ នំ វិហង្គមា**
**ឆាយំ ឆាយត្ថិកា យន្តិ ផលត្ថា ផលភោជិនោ ។**

( ដើមឈើធំ ) ជាទីរីករាយចិត្ត ពួកសត្វដែលត្រូវការម្លប់
ក៏ទៅជ្រកម្លប់ ពួកសត្វដែលត្រូវការផ្លែ ក៏បរិភោគផ្លែ ។

ហេតុ ឈ្មោះថា អាយតនៈ ដូចក្នុងប្រយោគនេះថា **បញ្ចិមានិ ភិក្ខវេ វិមុត្តាយតនានិ** ម្នាលភិក្ខុទាំងឡាយ វិមុត្តាយតនៈ ( ហេតុជាគ្រឿងរួចចាកកិលេស ) នេះ មាន ៥ យ៉ាង ។

ក្នុងទីនេះ លោកសំដៅយកអាយតនៈទាំងអស់នោះ ។ ព្រោះថា មិច្ឆាទិដ្ឋិកបុគ្គលទាំងអស់ កាលកើតក៏កើតក្នុងឋានៈ ៣ នេះប៉ុណ្ណោះ កាលសង្គ្រោះចូល រមែងសង្គ្រោះចូល គឺប្រជុំចុះ ធ្លាក់ចុះក្នុងឋានៈ ៣ នេះដូចគ្នា ។ កាលបុគ្គលទាំងនោះជាមិច្ឆាទិដ្ឋិ ហេតុទាំង ៣ នេះឯង ឈ្មោះថា អាយតនៈ ព្រោះអត្ថជាដើមថា ដូចគ្នានឹងកំពង់ទឹក គឺជាទឹកដីដែលកើតឡើង ព្រោះហេតុនោះ ទើបឈ្មោះថា **តិត្ថាយតន** ។ ម្យ៉ាងទៀត ឈ្មោះថា **តិត្ថាយតន** ព្រោះអត្ថថា ជាប្រភពកើតនៃតិរ្ថិយទាំងឡាយ ដោយអត្ថនោះឯង ។

បទថា **សមនុយុញ្ជិយមានានិ** បានដល់ ត្រូវបណ្ឌិតសួរយ៉ាងនេះថា ទិដ្ឋិទាំងនោះ គឺអ្វី ។ បទថា **សមនុគ្គាហិយមានានិ** សេចក្តីថា ត្រូវសួរដោយល្អយ៉ាងនេះថា ទិដ្ឋិទាំងនោះកើតឡើងព្រោះហេតុអ្វី ។ បទថា **សមនុភាសិយមានានិ** សេចក្តីថា ត្រូវប្រាប់ដោយល្អយ៉ាងនេះថា អ្នកទាំងឡាយចូរលះបង់ទិដ្ឋិដ៏លាមកទាំងនោះចេញ ។ ម្យ៉ាងទៀត ទាំង ៣ បទនេះ គឺ **សមនុយុញ្ជិយមានានិ សមនុគ្គាហិយមានានិ សមនុភាសិយមានានិ** ជា

វេវចនៈនៃការសាកសួរ និងការសួរដូចគ្នា ដោយហេតុនោះ ទើបលោកពោលក្នុងអដ្ឋកថាថា បទថា **សមនុយុញ្ជតិ** ក្តី បទថា **សមនុគ្គាហតិ** ក្តី បទថា **សមនុភាសតិ** ក្តី នេះក៏ជាកាពតែមួយ មានអត្ថដូចគ្នាប៉ុណ្ណោះ មានចំណែកស្មើគ្នា កើតអំពីវត្ថុនោះដូចគ្នាតែម្យ៉ាងនោះឯង ។

បទថា **បរម្បិ គន្ត្វា** សេចក្តីថា ដល់នូវការបន្តណាមួយ ក្នុងបណ្តាការបន្តទាំង ៣ គឺ **អាចរិយបរម្បរា** គឺការបន្តអាចារ្យ ១ **លទ្ធិបរម្បរា** គឺការបន្តលទ្ធិ ១ **អត្តភាវបរម្បរា** គឺការបន្តអត្តភាព ១ ។ បទថា **អកិរិយាយ សណ្ឋហន្តិ** គឺតាំងនៅក្នុងឋានៈត្រឹមតែជាអកិរិយទិដ្ឋិ ។

តិត្ថាយតនៈទាំងនេះ ដែលប្រព្រឹត្តទៅយ៉ាងនេះ គឺអាចារ្យរបស់យើងទាំងឡាយ ជាបុព្វេកតវេទី គឺជាអ្នកមានវាទៈថា កម្មដែលធ្វើក្នុងជាតិមុនជាហេតុ បាចារ្យ គឺអាចារ្យនៃអាចារ្យរបស់យើងទាំងឡាយ ជាបុព្វេកតវាទី គឺយល់ថា ទីបំផុតអំពីកម្មចាស់ អាចរិយបាចារ្យ គឺអាចារ្យរបស់បាចារ្យនៃយើងទាំងឡាយ ជាបុព្វេកតវេទី អាចារ្យរបស់យើងទាំងឡាយ ជាឥស្សរ-និម្មានវាទី គឺមានវាទៈថា ការនិម្មិតរបស់ព្រះឥសូរជាហេតុ បាចារ្យនៃយើងទាំងឡាយជាឥស្សរនិម្មានវាទី អាចារ្យនៃបាចារ្យយើងទាំងឡាយ ជាឥស្សរ-និម្មានវាទី អាចារ្យរបស់យើងទាំងឡាយ ជាអហេតុកអបច្ចយវាទី គឺមានវាទៈថា មិនមានហេតុ មិនមានបច្ច័យ បាចារ្យនៃយើងទាំងឡាយ ជាអហេតុក-អបច្ចយវាទី បាចារ្យរបស់អាចារ្យនៃយើងទាំងឡាយ ជាអហេតុកអបច្ចយ-វាទី ឈ្មោះថា ប្រព្រឹត្តទៅតាមការបន្តអាចារ្យ ។

តិត្ថាយតនៈ ដែលប្រព្រឹត្តទៅយ៉ាងនេះ គឺអាចារ្យរបស់យើងទាំងឡាយ ជាបុព្វេកតលទ្ធិកបុគ្គល បាចារ្យរបស់យើងទាំងឡាយ ។បេ។ អាចារ្យរបស់បាចារ្យយើងទាំងឡាយ ជាអហេតុកបច្ចយលទ្ធិកបុគ្គល ឈ្មោះថា ប្រព្រឹត្តទៅតាមការបន្តលទ្ធិ ។

តិត្ថាយតនៈ ដែលប្រព្រឹត្តទៅយ៉ាងនេះ គឺអត្តភាពរបស់អាចារ្យនៃយើងទាំងឡាយ មានកម្មដែលធ្វើក្នុងជាតិមុនជាហេតុ អត្តភាពរបស់អាចារ្យនៃយើងទាំងឡាយ ។បេ។ អត្តភាពរបស់បាចារ្យនៃយើងទាំងឡាយ មិនមានហេតុ មិនមានបច្ច័យ ឈ្មោះថា ប្រព្រឹត្តទៅតាមការបន្តអត្តភាព ។

តិត្ថាយតនៈទាំងនោះ រមែងប្រព្រឹត្តទៅឆ្ងាយក្រៃលែងយ៉ាងនេះ រមែងតាំងនៅក្នុងឋានៈត្រឹមតែជាអកិរិយទិដ្ឋិនោះឯង ។ អ្នកសាង ឬអ្នកឲ្យសាងនៃមិច្ឆាទិដ្ឋិកបុគ្គលទាំងនោះ ក៏មិនប្រាកដ សូម្បីត្រឹមតែម្នាក់ ។

បទថា **បុរិសបុគ្គលោ** បានដល់ សត្វ ។ សេចក្តីពិត កាលព្រះមានព្រះភាគត្រាស់ថា បុរសក្តី ត្រាស់ថា បុគ្គលក្តី ជាការត្រាស់សំដៅដល់សត្វនោះឯង តែកថានេះ ចាត់ជាសម្មតិកថា ។ បុគ្គលណានឹងយល់បានយ៉ាងណា ក៏ត្រាស់ដល់បុគ្គលនោះយ៉ាងនោះ ។ បទថា **បដិសំវេទេតិ** សេចក្តីថា តែងស្គាល់សុខវេទនា ទុក្ខវេទនា ឬអទុក្ខមសុខវេទនា ដែលកើតឡើងក្នុងសន្តានរបស់ខ្លួន គឺធ្វើសុខវេទនា ទុក្ខវេទនា និងអទុក្ខសុខវេទនា ឲ្យខ្លួនដឹងច្បាស់ហើយ ឬរមែងសោយ ។

បទថា **បុព្វេកតហេតុ** ប្រែថា ព្រោះកម្មដែលខ្លួនធ្វើក្នុងជាតិមុនជាហេតុ

អធិប្បាយថា បុរសបុគ្គលសោយ ព្រោះកម្មដែលខ្លួនធ្វើក្នុងជាតិមុនជាបច្ច័យប៉ុណ្ណោះ ។ ដោយបទថា **បុព្វេកតហេតុ** នេះ មិច្ឆាទិដ្ឋិកបុគ្គលទាំងឡាយបដិសេធកម្មវេទនា គឺវេទនាដែលកើតអំពីកម្ម និងកិរិយវេទនា គឺវេទនាដែលកើតអំពីកិរិយា រមែងទទួលចំពោះតែវិបាកវេទនាម្យ៉ាងប៉ុណ្ណោះ ។

## អាពាធ ៨ យ៉ាង

ព្រះមានព្រះភាគត្រាស់រោគទាំង ៨ យ៉ាងនេះ គឺអាពាធកើតពីប្រមាត់កម្រើកជាសមុដ្ឋាន ១ អាពាធមានសេម្ហៈជាសមុដ្ឋាន ១ អាពាធមានខ្យល់ជាសមុដ្ឋាន ១ អាពាធកើតអំពីរោគប្រមាត់ រោគស្លេស្ម រោគខ្យល់មកប្រជុំគ្នា ១ អាពាធកើតអំពីផ្លាស់រដូវ ១ អាពាធកើតអំពីការបរិហាររាងកាយមិនត្រឹមត្រូវ ១ អាពាធកើតអំពីសេចក្ដីព្យាយាមធ្វើឲ្យកើតឡើង ១ អាពាធកើតអំពីវិបាកកម្ម ១ ក្នុងរោគទាំង ៨ យ៉ាងនោះ មិច្ឆាទិដ្ឋិកបុគ្គលបដិសេធរោគ ៧ យ៉ាងខាងដើមហើយ រមែងទទួលចំពោះតែរោគប្រភេទទី ៨ ប៉ុណ្ណោះ ។

ក្នុងបណ្ដាគំនរនៃកម្ម ៣ ប្រភេទ ដែលព្រះមានព្រះភាគត្រាស់ គឺទិដ្ឋធម្មវេទនីយកម្ម ១ ឧបបជ្ជវេទនីយកម្ម ១ អបរាបរិយាយវេទនីយកម្ម ១ មិច្ឆាទិដ្ឋិកបុគ្គលបដិសេធកម្ម ២ ប្រភេទខាងដើម ព្រមទទួលចំពោះតែអបរាបរិយាយវេទនីយកម្មប៉ុណ្ណោះ ។ ក្នុងគំនរវិបាក ៣ ប្រភេទ ដែលព្រះមានព្រះភាគត្រាស់ គឺទិដ្ឋធម្មវេទនីយវិបាក ១ ឧបបជ្ជវេទនីយវិបាក ១ អបរាបរិយាយវេទនីយវិបាក ១ មិច្ឆាទិដ្ឋិកបុគ្គលបដិសេធវិបាក ២ យ៉ាងខាងដើម

ព្រមទទួលចំពោះតែអបរបរិយាយវិបាកតែម្យ៉ាងប៉ុណ្ណោះ ។

ក្នុងគំនរចេតនា ៤ ប្រភេទ ព្រះមានព្រះភាគត្រាស់ គឺកុសលចេតនា ១ អកុសលចេតនា ១ វិបាកចេតនា ១ កិរិយាចេតនា ១ មិច្ឆាទិដ្ឋិកបុគ្គលបដិសេធចេតនា ៣ ប្រភេទ ទទួលចំពោះតែវិបាកចេតនាតែម្យ៉ាងប៉ុណ្ណោះ ។

បទថា **ឥស្សរនិម្មានហេតុ** ព្រោះការនិម្មិតរបស់ព្រះឥស្សរជាហេតុ ។ អធិប្បាយថា បុរសបុគ្គលសោយសុខវេទនា ទុក្ខវេទនា ឬអទុក្ខមសុខ-វេទនា ក៏ព្រោះត្រូវព្រះឥស្សរនិមិត្ត គឺបណ្ដាល ព្រោះថា មិច្ឆាទិដ្ឋិកបុគ្គលទាំងនោះ មានការយល់ដូច្នេះថា វេទនាទាំង ៣ នេះ បុរសបុគ្គលមិនអាចសោយបាន ព្រោះមានកម្មដែលខ្លួនធ្វើទុកក្នុងបច្ចុប្បន្នជាមូលខ្លះ ព្រោះបញ្ជារបស់អ្នកដទៃជាមូលខ្លះ ព្រោះកម្មដែលខ្លួនធ្វើក្នុងជាតិមុនខ្លះ ព្រោះមិនមានហេតុ មិនមានបច្ច័យ គឺដោយចៃដន្យខ្លះ តែបុរសបុគ្គលសោយវេទនាទាំងនេះបាន ព្រោះការនិម្មិតរបស់ព្រះឥស្សរជាហេតុតែម្យ៉ាង ។

មិច្ឆាទិដ្ឋិកបុគ្គលទាំងនេះ មានវាទៈយ៉ាងនេះ ទើបមិនព្រមទទួលភាគសូម្បី ១ ប្រភេទ ក្នុងបណ្ដាភាគ ៨ យ៉ាងដែលពោលហើយខាងដើមបដិសេធទាំងអស់ និងមិនព្រមទទួលកម្មប្រភេទណាមួយ ក្នុងបណ្ដាគំនរកម្ម ៣ ប្រភេទ វិបាកមួយប្រភេទ ក្នុងបណ្ដាគំនរវិបាក ៣ ប្រភេទ និងចេតនាមួយប្រភេទ ក្នុងបណ្ដាគំនរចេតនា ៤ ប្រភេទ ដែលពោលហើយខាងដើមបដិសេធទាំងអស់ ។

បទថា **អហេតុអប្បច្ចយា** បានដល់ វៀរចាកហេតុ និងបច្ច័យ ។

អធិប្បាយថា បុរសបុគ្គលសោយសុខវេទនា ទុក្ខវេទនា ឬអទុក្ខមសុខវេទនា ដោយមិនមានហេតុឡើយ ។ ព្រោះថា មិច្ឆាទិដ្ឋិកបុគ្គលទាំងនោះ មានការយល់ដូច្នេះថា វេទនាទាំង ៣ នេះ បុគ្គលណាមួយមិនអាចនឹងសោយបាន ព្រោះកម្មដែលខ្លួនធ្វើក្នុងបច្ចុប្បន្នជាមូលក៏មាន ព្រោះការបញ្ជារបស់អ្នកដទៃជាមូលក្តី ព្រោះកម្មដែលធ្វើក្នុងជាតិមុនក្តី ព្រោះការនិម្មិតនៃព្រះឥស្សរជាហេតុក្តី បុរសបុគ្គលសោយវេទនាទាំងនេះ ដោយមិនមានហេតុ មិនមានបច្ច័យឡើយ ។ មិច្ឆាទិដ្ឋិកបុគ្គលទាំងនោះ មានវាទៈយ៉ាងនេះ ទើបមិនព្រមទទួលហេតុទាំងឡាយដែលពោលហើយ ខាងដើម មានរោគជាដើមត្រឹមតែ ១ បដិសេធទាំងអស់ ។

ព្រះសាស្តា កាលទ្រង់លើកមាតិកាយ៉ាងនេះឡើងហើយ ឥឡូវនេះ ដើម្បីទ្រង់ចែកមាតិកានោះ ទើបត្រាស់ពាក្យថា **តត្រ ភិក្ខវេ** ជាដើម ។ បណ្តាបទទាំង នោះ បទថា **ឯវំ វទាមិ** ព្រះមានព្រះភាគទ្រង់សម្តែងថា តថាគតពោលយ៉ាងនេះ ក៏ដើម្បីតាំងលទ្ធិ ព្រោះថា ព្រះមានព្រះភាគ មិនតាំងលទ្ធិហើយ រមែងឈានចូលកាន់លទ្ធិអំពីលទ្ធិដែលត្រូវសង្កត់សង្កិន ។ មិច្ឆាទិដ្ឋិកបុគ្គលទាំងឡាយ ពោលពាក្យជាដើមថា ព្រះគោតមដ៏ចម្រើន យើងខ្ញុំទាំងឡាយ ពោលបុព្វេកតវាទឬ ។ តែកាលតាំងលទ្ធិហើយ មិច្ឆា-ទិដ្ឋិកបុគ្គលទាំងឡាយ ឈានចូលរកលទ្ធិមិនបាន ក៏នឹងត្រូវសង្កត់បាន ដោយងាយ ។ ព្រះមានព្រះភាគត្រាស់ថា **ឯវំ វទាមិ** ដល់មិច្ឆាទិដ្ឋិក-បុគ្គលទាំងនោះ ក៏ដើម្បីញ៉ាំងលទ្ធិឲ្យតាំងដោយប្រការដូច្នេះ ។

បទថា **តេនហាយស្មន្តោ** កាត់បទជា **តេនហិ អាយស្មន្តោ** មានពាក្យអធិប្បាយដូចម្ដេច ។ មានពាក្យអធិប្បាយថា បើសេចក្ដីនោះពិត បើដូច្នោះ តាមវាទៈអ្នកទាំងឡាយនោះ ។ បទថា **ចាណាតិចាតិនោ ភវិស្សន្តិ បុព្វេ កតហេតុ** សេចក្ដីថា បុរសបុគ្គលពួកណាម្នាក់ក្នុងលោក សម្លាប់សត្វ បុរសបុគ្គលទាំងនោះ នឹងជាបាណាតិបាត ព្រោះកម្មដែលធ្វើក្នុងជាតិមុនជាហេតុ ព្រោះហេតុអ្វី ព្រោះអ្នកទាំងឡាយមានលទ្ធិដូច្នេះថា បុគ្គលនោះអាចសោយកម្ម គឺបាណាតិបាត ព្រោះកម្មដែលខ្លួនធ្វើជាមូលក៏មិនមែន ព្រោះការបញ្ជារបស់អ្នកដទៃជាមូលក៏មិនមែន ព្រោះការនិម្មិតរបស់ព្រះឥស្វរជាហេតុក៏មិនមែន ព្រោះមិនមានហេតុ មិនមានបច្ច័យក៏មិនមែន បុគ្គលនោះសោយព្រោះកម្មដែលធ្វើក្នុងភពមុនជាហេតុប៉ុណ្ណោះ បុរសបុគ្គលជាបាណា-តិបាត ដោយអាការណា កាលវៀរចាកបាណាតិបាត ក៏នឹងវៀរដោយអាការនោះ គឺព្រោះកម្មដែលធ្វើក្នុងជាតិមុនជាហេតុដូចគ្នា ។ ព្រះមានព្រះភាគទ្រង់ចាប់លទ្ធិរបស់មិច្ឆាទិដ្ឋិកបុគ្គលទាំងនោះឯងបានហើយ ទើបទ្រង់សង្កត់សង្កិនមិច្ឆាទិដ្ឋិកបុគ្គលទាំងនោះ ដោយប្រការដូចពណ៌នាមក ដូច្នេះ គប្បីជ្រាបពាក្យពន្រឹកសេចក្ដីក្នុងបទថា **អធិដ្ឋានាយិនោ** ជាដើម ដោយន័យនេះ ។

បទថា **សារតោ បច្ចាគច្ឆតំ** បានដល់ ប្រកាន់មាំដោយភាពជាសារៈ ។ បទថា **ឆន្ទោ** បានដល់ កត្តុកម្យតាឆន្ទៈ គឺជាអ្នកពេញចិត្តដើម្បីធ្វើ ។ ក្នុងបទថា **ឥទំ វា ករណីយំ ឥទំ វា អករណីយំ** នេះ មានអធិប្បាយដូច្នេះថា មិនមានភាពជាបុគ្គលប្រាថ្នាដើម្បីធ្វើ ឬសេចក្ដីព្យាយាម

របស់បុរសចំពោះខ្លួន ដើម្បីធ្វើវត្ថុដែលគួរធ្វើ ដោយគិតថា វត្ថុនេះ គួរធ្វើ ឬមិនធ្វើវត្ថុដែលគួរធ្វើ ដោយគិតថា វត្ថុនេះមិនគួរធ្វើ ។ ម្យ៉ាងទៀត កាលឆន្ទៈ និងវាយាមៈមិនមាន ក៏មិនមានការគិតថា វត្ថុនេះ គួរធ្វើ វត្ថុនេះ មិនគួរធ្វើ ។ បទថា **ឥតិ ករណីយាករណីយេ ខោ បន សច្ចតោ ថេតតោ អនុបលព្ភិយមានេ** សេចក្តីថា កាលវត្ថុដែលគួរធ្វើ និងមិនគួរធ្វើមិនប្រាកដ គឺមិនបានដោយសេចក្តីពិត ដោយរបស់ពិតយ៉ាងនេះ ។ បើបុគ្គលគប្បីបានធ្វើវត្ថុដែលគួរធ្វើ គប្បីវៀរអំពីវត្ថុដែលមិនគួរធ្វើសោត វត្ថុដែលគួរធ្វើ និងមិនគួរធ្វើ បុគ្គលក៏គប្បីបានដោយភាពជារបស់មែន ដោយភាពជារបស់ពិត ។ តែព្រោះមិនបានទាំង ២ យ៉ាង យ៉ាងនេះ ដូច្នោះ កិច្ចដែលគួរធ្វើ និងមិនគួរនោះ ទើបបុគ្គលមិនបានដោយភាពជារបស់ពិត ដោយភាពជារបស់មែន គឺមិនបានវត្ថុដែលគួរធ្វើ និងមិនគួរធ្វើនោះ ដោយអាការយ៉ាងនេះ ។

បទថា **មុដ្ឋស្សតីនំ** បានដល់ មិនមានស្មារតី គឺបណ្តោយសតិទៅ ។ បទថា **អនារក្ខានំ វិហរតំ** បានដល់ ប្រាសចាកការរក្សាក្នុងទ្វារទាំង ៦ ។ បទថា **ន ហោតិ បច្ចត្តំ សហធម្មិកោ សមណវាទោ** សេចក្តីថា វាទៈថាជាសមណៈ ព្រមទាំងហេតុចំពោះខ្លួនថា យើងទាំងឡាយជាសមណៈ រមែងមិនមាន គឺមិនសម្រេចដល់អ្នកទាំងឡាយ ឬបុគ្គលដទៃដែលមានសភាពយ៉ាងនេះ ។ ព្រោះថា សមណៈទាំងឡាយ ក៏ជាអ្នកមានកម្មដែលធ្វើក្នុងជាតិមុនជាហេតុដូចគ្នា សូម្បីបុគ្គលមិនមែនជាសមណៈ ក៏ជាអ្នកមានកម្មធ្វើក្នុង

ជាតិមុនជាហេតុដូចគ្នា ។ បទថា **សហេតុកា** បានដល់ ព្រមទាំងហេតុ ។ បទថា **និគ្គហោ ហោតិ** បានដល់ ការសង្កត់សង្កិនរបស់តថាគតមាន ។ មិច្ឆាទិដ្ឋិកបុគ្គលទាំងនោះ ជាអ្នកត្រូវសង្កត់សង្កិនហើយ ។ កាលទ្រង់សង្កត់សង្កិនបុព្វេកតវាទីបុគ្គលយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សង្កត់សង្កិនឥស្សរនិម្មានវាទីបុគ្គល ទើបត្រាស់ពាក្យថា **តត្រ ភិក្ខវេ** ជាដើម ។ អត្ថនៃពាក្យនោះ គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងបុព្វេកតវាទ ក្នុងអហេតុកវាទក៏ដូចគ្នា ។

ព្រះមានព្រះភាគ ទ្រង់សម្តែងភាពដែលលទ្ធិតិរ្ថិយទាំងនេះ ទទេហើយយ៉ាងនេះ ព្រោះដល់នូវការបន្តគ្នា មកតាំងនៅក្នុងឋានៈជាអកិរិយទិដ្ឋិក្តី ភាពដែលលទ្ធិតិរ្ថិយទាំងនេះ មិនមែនគុណធម៌ជាគ្រឿងនាំចេញចាកទុក្ខក្តី ភាពដែលបុគ្គលកាន់យកក្នុងលទ្ធិតិរ្ថិយ ដូចសត្វតូចៗ បញ្ចេញសំឡេងយំដោយសម្គាល់ក្នុងភ្លើង ព្រោះដល់នូវភាពជាសភាវៈដូចគ្នានឹងការបុកអង្កាមមិនមានខ្លឹមសារក្តី ភាពដែលបុគ្គលមានលទ្ធិតិរ្ថិយនោះជាទិដ្ឋិ ឧបមាដូចជាផែងខ្វាក់ក្អែក ព្រោះមិនមានការឃើញអត្ថនៃលទ្ធិតិរ្ថិយខាងដើមក្តី កណ្តាលក្តី ទីខាងចុងក្តី ភាពដែលបុគ្គលកាន់យកលទ្ធិតិរ្ថិយទាំងនោះដោយហេតុត្រឹមសំឡេងប៉ុណ្ណោះ ហើយមានការឃើញថា ជាខ្លឹមសារ មានសភាពដូចគ្នានឹងទន្សាយ ដែលបានស្តាប់សំឡេងគួរខ្លាចរបស់ផ្លែព្នៅទុំដែលជ្រុះលើផែនដី ហើយរត់ទៅ ដោយសម្គាល់ថា ផែនដីស្រុតក្តី ឥឡូវនេះ ដើម្បីទ្រង់សម្តែងភាពដែលធម៌ទ្រង់សម្តែងជាធម៌មានខ្លឹមសារ និងធម៌

ជាគ្រឿងនាំចេញចាកទុក្ខ ទើបត្រាស់ថា **អយំ ខោ បន ភិក្ខវេ** ប្រែថា ម្នាលភិក្ខុទាំងឡាយ ឯធម៌ដែលតថាគតសម្ដែងនេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **អនិគ្គហិតោ** គឺមិនត្រូវអ្នកជំទែសង្កត់សង្កិន បានដល់ មិនមានបុគ្គលអាចសង្កត់សង្កិនបាន ។ បទថា **អសង្កិ-លិដ្ឋោ** គឺជាធម៌មិនសៅហ្មង បានដល់ បរិសុទ្ធ គឺដែលបុគ្គលគិតថា នឹងធ្វើធម៌នោះឲ្យសៅហ្មង ហើយប្រព្រឹត្ត ក៏មិនអាចធ្វើឲ្យទៅជាយ៉ាងនោះបាន ។ បទថា **អនុបវជ្ជោ** បានដល់ ផុតចាកការតិះដៀល ។ បទថា **អប្បដិក្កុដ្ឋោ** សេចក្ដីថា មិនត្រូវបដិសេធ ឬមិនត្រូវជំទាស់យ៉ាងនេះថា ប្រយោជន៍អ្វីដល់ធម៌នេះ អ្នកទាំងឡាយ ចូរនាំធម៌នេះទៅ ។ បទថា **វិញ្ញូហិ** បានដល់ បណ្ឌិតទាំងឡាយ ។ ព្រោះពាក្យពោលរបស់បុគ្គលដែលមិនមែនបណ្ឌិតពោលដោយមិនដឹង មិនជាប្រមាណ ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **វិញ្ញូហិ** ដូច្នេះ ។

ឥឡូវនេះ ដើម្បីនឹងសម្ដែងធម៌នោះ ទើបព្រះមានព្រះភាគតាំងបញ្ហាសួរថា **កតមោ ច ភិក្ខវេ** ហើយតាំងមាតិកាដោយន័យជាដើមថា **ឆយិមា ធាតុយោ** កាលទ្រង់សម្ដែងចែកតាមលំដាប់ ទើបត្រាស់ពាក្យជាដើមថា **ឆយិមា ធាតុយោ** ទៀត ។

បណ្ដាបទទាំងនោះ បទថា **ធាតុយោ** បានដល់ សភាវៈទាំងឡាយដោយអត្ថថា សភាវៈដែលប្រកាសដល់ការមិនមែនជីវៈ មិនមែនសត្វឈ្មោះថា អត្ថរបស់ធាតុ ។ បទថា **ផស្សាយតនានិ** បានដល់ ឈ្មោះថា

អាតយនៈ ព្រោះអត្ថថា ជាប្រភពកើតរបស់វិបាកផស្សៈទាំងឡាយ ។ បទថា **មនោបវិចារា** បានដល់ ការត្រាច់ទៅរបស់ចិត្តក្នុងឋានៈ ១៨ ដោយដើង គឺវិតក្ក និងវិចារ ។ បទថា **បឋវីធាតុ** បានដល់ ធាតុដែលតាំងមាំ ។ បទថា **អាបោធាតុ** បានដល់ ធាតុធ្វើកិច្ចផ្សារភ្ជាប់ ។ បទថា **តេជោធាតុ** បានដល់ ធាតុធ្វើកិច្ចឲ្យក្តៅ ។ បទថា **វាយោធាតុ** បានដល់ ធាតុធ្វើកិច្ចឲ្យកម្រើកញ័រ ។ បទថា **អាកាសធាតុ** បានដល់ ធាតុដែលពាល់ត្រូវមិនបាន ។ បទថា **វិញ្ញាណធាតុ** បានដល់ ធាតុធ្វើកិច្ចដឹងច្បាស់ ។

ធាតុកម្មដ្ឋាននេះ មកហើយយ៉ាងនេះ ។ ឯកម្មដ្ឋាននោះ ក្នុងទីមកដោយសង្ខេប គួរពោលដោយសង្ខេបផង ពោលដោយពិស្តារផង តែក្នុងទីដែលមកដោយពិស្តារ នឹងពោលដោយសង្ខេបមិនគួរ គួរពោលដោយពិស្តារប៉ុណ្ណោះ ឯក្នុងតិត្ថាយតនសូត្រនេះ កម្មដ្ឋាននេះមកហើយ ដោយអំណាចធាតុ ៦ ដោយសង្ខេប ។ នឹងពោលកម្មដ្ឋាននោះទាំង ២ យ៉ាង គឺដោយសង្ខេប និងដោយពិស្តារក៏គួរ ។

ព្រះយោគាវចរ កាលកំណត់កម្មដ្ឋាន ដោយអំណាចធាតុ ៦ ដោយសង្ខេប ក៏រមែងកំណត់យ៉ាងនេះ ។ រូបទាំងឡាយ ៤ គឺបឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ ចាត់ជាមហាភូតរូប អាកាសធាតុ ចាត់ជាឧបាទាយរូប កាលឃើញឧបាទាយរូបប្រភេទមួយ ឧបាទាយរូប ២៣ ដ៏សេសគប្បីកំណត់ថា ត្រូវឃើញដូចគ្នា ។

បទថា **វិញ្ញាណធាតុ** បានដល់ ចិត្ត ចិត្តនោះ បានដល់ វិញ្ញាណក្ខន្ធ

វេទនាដែលកើតរួមជាមួយវិញ្ញាណក្ខន្ធនោះ ឈ្មោះថា វេទនាក្ខន្ធ សញ្ញាដែលកើតរួមជាមួយវិញ្ញាណក្ខន្ធនោះ ឈ្មោះថា សញ្ញាក្ខន្ធ ផស្សៈ និងចេតនាដែលកើតរួមជាមួយវិញ្ញាណក្ខន្ធនោះ ឈ្មោះថា សង្ខារក្ខន្ធ ខន្ធទាំង ៤ ដូចពោលមកនេះ ឈ្មោះថា អរូបក្ខន្ធ ។ ម្យ៉ាងទៀត មហាភូតរូប ៤ និងរូបដែលអាស្រ័យមហាភូតរូប ៤ ឈ្មោះថា រូបក្ខន្ធ បណ្ដារូបក្ខន្ធ និងអរូបក្ខន្ធនោះ អរូបក្ខន្ធ ៤ ជានាម រូបក្ខន្ធ ជារូប ។ មានធម៌ ២ យ៉ាងប៉ុណ្ណោះ គឺ នាម ១ រូប ១ ។ មិនមានសត្វ ឬជីវៈ ក្រៅអំពីធម៌ ២ នោះឡើយ ។ គប្បីជ្រាបកម្មដ្ឋាន ដែលធ្វើឲ្យសម្រេចអរហត្តផល ដោយអំណាចធាតុ ៦ ដោយសង្ខេបរបស់ភិក្ខុមួយរូប ដូចពោលមកនេះ ។

ព្រះយោគាវចរ កាលកំណត់ដោយពិស្ដារ កាលកំណត់មហាភូតរូប ៤ ហើយ ទើបកំណត់ឧបាទាយរូប ២៣ តាមគន្លងនៃការកំណត់អាកាសធាតុតមក កាលកំណត់បច្ច័យនៃរូបទាំងនោះ ក៏ពិចារណាមើលមហាភូតរូប ៤ នោះឯងទៀត ហើយរួបរួមជាកោដ្ឋាស គឺ បណ្ដាមហាភូតរូប ៤ នោះ បឋវីធាតុមានអាការ ២០ អាបោធាតុមានអាការ ១២ តេជោធាតុមានអាការ ៤ វាយោធាតុមានអាការ ៦ រួមជាអាការ ៤២ បន្ថែមឧបាទាយរូប ២៣ ចូលទៅ ជារូប ៦៥ ព្រះយោគាវចរ ពិចារណាឃើញរូប ៦៥ នោះ និងរួមវត្ថុរូបចូល ជារូប ៦៦ ។

ឯវិញ្ញាណធាតុ បានដល់ ចិត្ត ៨១ ដោយជាលោកិយចិត្តទាំងអស់ ៨១ ឈ្មោះថា វិញ្ញាណក្ខន្ធ សូម្បីវេទនាជាដើមដែលកើតព្រមនឹងចិត្ត ៨១

នោះ ក៏មានចំនួនប៉ុណ្ណោះដូចគ្នា រួមសេចក្ដីថា វេទនា ៨១ ឈ្មោះថា វេទនាក្ខន្ធ សញ្ញា ៨១ ឈ្មោះថា សញ្ញាក្ខន្ធ ចេតនា ៨១ ឈ្មោះថា សង្ខារក្ខន្ធ រួមសេចក្ដីថា អរូបក្ខន្ធទាំង ៤ នេះ កាលកំណត់ដោយអំណាចធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ក៏បានដល់ធម្មាយតនៈ ៣២៤ ។

ធម៌ទាំងអស់ គឺអរូបធម៌ទាំងឡាយនេះ និងរូបធម៌ ៦៦ ដូចពោលមកនេះ កាលប្រមូលហើយ ក៏មានធម៌ ២ យ៉ាង គឺនាម ១ រូប ១ មិនមានសត្វ ឬជីវៈ ក្រៅអំពីធម៌ ២ យ៉ាងនោះឡើយ ។

ព្រះយោគាវចរ កាលកំណត់បញ្ចក្ខន្ធ ដោយជានាមរូបដូចពោលមកនេះ កាលស្វែងរកបច្ច័យរបស់នាមរូបទាំងនោះ ក៏ឃើញបច្ច័យយ៉ាងនេះ គឺព្រោះមានអវិជ្ជាជាបច្ច័យ ព្រោះមានតណ្ហាជាបច្ច័យ ព្រោះមានកម្មជាបច្ច័យ ព្រោះមានអាហារជាបច្ច័យ ហើយឆ្លងផុតសេចក្ដីសង្ស័យក្នុងកាលទាំង ៣ បាន គឺក្នុងអតីត នាមរូបនេះ ក៏ប្រព្រឹត្តទៅហើយ ដោយបច្ច័យទាំងនេះ សូម្បីក្នុងអនាគត ក៏នឹងប្រព្រឹត្តទៅដោយបច្ច័យទាំងនេះ សូម្បីក្នុងបច្ចុប្បន្ន ក៏ប្រព្រឹត្តទៅដោយបច្ច័យទាំងនេះដូចគ្នា បន្ទាប់អំពីនោះ ក៏បដិបត្តិទៅតាមលំដាប់ រហូតដល់បានសម្រេចអរហត្តផល ។ គប្បីជ្រាបកម្មដ្ឋានដែលជាហេតុឲ្យសម្រេចអរហត្តផល ដោយអំណាចធាតុ ៦ ដោយពិស្ដារដូចពោលមកនេះ ។

បទថា **ចក្ខុំ ឆសញ្ញាយតនំ** សេចក្ដីថា ចក្ខុ ឈ្មោះថា អាយតនៈ ព្រោះអត្ថថា ជាប្រភពកើត ដោយអត្ថថា ជាសមុដ្ឋាននៃផស្សៈ ៧ ដែលកើតព្រមជាមួយវិញ្ញាណ ៧ គឺចក្ខុវិញ្ញាណ ២ សម្បដិច្ឆន្នវិញ្ញាណ ២ សន្តីរណ-

វិញ្ញាណ ៣ ប្រៀបដូចវ៉ៃជាដើម ដែលជាប្រកពកើតនៃមាសជាដើម ។ ក្នុងបទថា **សោតំ ជស្សាយតនំ** ជាដើម ក៏ន័យនេះឯង ។

ឯក្នុងបទថា **មនោ ជស្សាយតនំ** នេះ គប្បីជ្រាបថា បានដល់វិបាកផស្សៈ ២២ កម្មដ្ឋាននេះ មកដោយអំណាចផស្សាយតនៈ ៦ ដូចពោលមកនេះ ។ កម្មដ្ឋាននោះគួរពោលទាំងដោយសង្ខេប និងដោយពិស្ដារ ។ ពោលដោយសង្ខេប ក្នុងអាយតនៈ ៦ នេះ អាយតនៈ ៥ ដំបូង ឈ្មោះថា ឧបាទាយរូប កាលឃើញអាយតនៈ៥នោះហើយ ក៏ឈ្មោះថាឃើញឧបាទាយរូបដ៏សេសផងដែរ ។ អាយតនៈទី ៦ គឺចិត្ត ជាវិញ្ញាណក្ខន្ធ ធម៌ ៣ ដ៏សេសមានវេទនាជាដើម ដែលកើតព្រមជាមួយវិញ្ញាណក្ខន្ធ ជាអរូបក្ខន្ធ ។ គប្បីជ្រាបកម្មដ្ឋានដែលជាហេតុ ឲ្យសម្រេចអរហត្តផល ដោយសង្ខេបផង ដោយពិស្ដារផង តាមន័យដូចពោលមកហើយខាងដើមនោះឯង ។

បទថា **ចក្ខុនា រូបំ ទិស្វា** សេចក្ដីថា ឃើញរូបដោយចក្ខុវិញ្ញាណ ។ បទថា **សោមនស្សដ្ឋានិយំ** បានដល់ ជាហេតុនៃសោមនស្ស ។ កិក្ខុកាលបញ្ជូនចិត្តទៅ ឈ្មោះថា ត្រាច់ទៅយ៉ាងជិតស្និទ្ធ ក្នុងបទថា **ឧបវិចរតិ** នេះ ក្នុងបទដ៏សេស ក៏មានន័យនេះឯង ។ ក្នុងបទថា **ចក្ខុនា រូបំ ទិស្វា** នេះ គប្បីជ្រាបថា រូប ទោះជាទីគួរប្រាថ្នាក្ដី មិនគួរប្រាថ្នាក្ដី ឃើញរូបណាហើយ សោមនស្សកើតឡើង រូបនោះ ឈ្មោះថា ជាទីតាំងនៃសោមនស្ស ។ ឃើញរូបណាហើយ ទោមនស្សកើតឡើង រូបនោះ ឈ្មោះថា ជាទីតាំងនៃទោមនស្ស ។ ឃើញរូបណាហើយ ឧបេក្ខាកើតឡើង រូបនោះ ឈ្មោះថា ជាទីតាំង

នៃឧបេក្ខា ។ សូម្បីក្នុងសំឡេងជាដើម ក៏មានន័យនេះឯង ។ កម្មដ្ឋាននេះមកហើយដោយសង្ខេប ដោយប្រការដូចពណ៌នាមក ដូច្នេះ ។ ឯកម្មដ្ឋាននោះ ក្នុងទីដែលមកហើយដោយសង្ខេប គួរពោលសង្ខេបផង ដោយពិស្តារផង ក្នុងទីដែលមកហើយដោយពិស្តារ មិនគួរពោលដោយសង្ខេប ។ តែក្នុងតិត្ថាយតនៈសូត្រនេះ កម្មដ្ឋាននេះមកហើយ ដោយអំណាចមនោបវិចារ ១៨ ដោយសង្ខេប ។ កម្មដ្ឋាននោះគួរពោលទាំងដោយសង្ខេប ទាំងដោយពិស្តារ ។

ក្នុងកម្មដ្ឋាននោះ ពោលដោយសង្ខេប រូប ៩ គឺចក្ខុ សោតៈ ឃានៈ ជិវ្ហា កាយ រូប សំឡេង ក្លិន រសជាឧបាទាយរូប កាលឃើញឧបាទាយរូបទាំង៩នោះហើយ ឧបាទាយរូបដ៏សេសក៏ឈ្មោះថា ឃើញផងដូចគ្នា។ ផោដ្ឋព្វៈ គឺមហាភូតរូប ៣ កាលឃើញមហាភូតរូបទាំង ៣ នោះហើយ មហាភូតរូបទី ៤ ក៏ឈ្មោះថា ឃើញដូចគ្នា ។ មនោ ជាវិញ្ញាណក្ខន្ធ ។ ធម៌ទាំងឡាយ មានវេទនាជាដើមដែលកើតព្រមជាមួយវិញ្ញាណក្ខន្ធនោះ ជាអរូបក្ខន្ធ ។ គប្បីជ្រាបកម្មដ្ឋានដែលជាហេតុឲ្យសម្រេចអរហត្តផលដោយសង្ខេប ទាំងដោយពិស្តារ តាមន័យដែលពោលហើយខាងដើមនោះឯង ។ បទថា **អរិយសច្ចានិ** បានដល់ សច្ចៈទាំងឡាយដែលធ្វើឲ្យជាព្រះអរិយៈ ឬ ដែលព្រះអរិយៈចាក់ធ្លុះហើយ ។ ក្នុងទីនេះ សេចក្តីសង្ខេបមានប្រមាណប៉ុណ្ណេះ ។ តែបើពោលដោយពិស្តារហើយ បទនេះ បានប្រកាសហើយក្នុងវិសុទ្ធិមគ្គ ។

សួរថា បទថា **ឆន្នំ ភិក្ខវេ ធាតូនំ** នេះ ព្រះមានព្រះភាគផ្តើមដើម្បីអ្វី ។ ឆ្លើយថា ដើម្បីឲ្យអ្នកដទៃយល់បានងាយ ។ ពិតហើយ ព្រះ

តថាគត បំណងនឹងត្រាស់បច្ចយវដ្តកៈ ១២ បទ ដល់បុគ្គលណា ក៏ទ្រង់សម្តែងវដ្តៈ គឺ ការឈានចុះកាន់គភ៌ដល់បុគ្គលនោះ ។ ព្រោះថា កាលទ្រង់សម្តែងវដ្តៈ គឺ ការឈានចុះកាន់គភ៌ហើយ ក៏ទ្រង់មានការងាយស្រួលដែលនឹងត្រាស់ឯង ទាំងដែលជាអ្នកទូន្មានអ្នកដទៃឲ្យដឹង ។ ទើបគួរជ្រាបថា ព្រះមានព្រះភាគ ទ្រង់ផ្តើមបទនេះដើម្បីទូន្មានអ្នកដទៃឲ្យដឹងបានងាយ ។

បណ្តាបទទាំងនោះ បទថា **ឆន្នំ ធាតូនំ** បានដល់ បឋវីធាតុជាដើមដែលពោលហើយខាងដើមនោះឯង ។ បទថា **ឧបាទាយ** ប្រែថា អាស្រ័យ ។ ដោយបទថា **ឧបាទាយ** នោះ ព្រះមានព្រះភាគទ្រង់សម្តែងត្រឹមតែបច្ច័យ មានពាក្យអធិប្បាយដូច្នេះថា ការឈានចុះកាន់គភ៌មាតាមានព្រោះធាតុ ៦ ជាបច្ច័យ ព្រោះធាតុ ៦ របស់សត្វដែលកើតក្នុងគភ៌នោះជាបច្ច័យ ។ សួរថា របស់មាតា ឬថា របស់បិតា ។ ឆ្លើយថា មិនមែនរបស់មាតា មិនមែនរបស់បិតា ព្រោះធាតុ ៦ របស់សត្វដែលបដិសន្ធិនោះឯងជាបច្ច័យ ទើបមានការឈានចុះកាន់គភ៌មាតា របស់សត្វដែលកើតក្នុងគភ៌ៗ ឈ្មោះថា **គព្ភសត្វ** នេះ មានប្រការផ្សេងៗ គឺគព្ភសត្វក្នុងនរក គព្ភសត្វក្នុងកំណើតតិរច្ឆាន គព្ភ-សត្វក្នុងកំណើតបិត្តិវិស័យ គព្ភសត្វក្នុងកំណើតមនុស្ស គព្ភសត្វក្នុងកំណើតទេវតា ។ តែក្នុងទីនេះ បំណងយកគព្ភសត្វក្នុងកំណើតមនុស្ស ។

បទថា **អវក្កន្តិ ហោតិ** សេចក្តីថា មានការឈានចុះ ការកើតឡើង ការប្រាកដ ។ សួរថា មានដូចម្តេច ។ ឆ្លើយថា មានព្រោះការប្រជុំព្រមនៃអង្គ ៣ សមដូចព្រះមានព្រះភាគត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ព្រោះ

ការប្រជុំព្រមនៃអង្គ ៣ ទើបមានការឈានចុះកាន់គភ៌មាតារបស់សត្វដែលកើតក្នុងគភ៌ ។ អង្គប្រកប ៣ ប្រការ គឺអ្វីខ្លះ ។

ម្នាលភិក្ខុទាំងឡាយ កិរិយាចុះចាប់បដិសន្ធិរបស់សត្វដែលកើតក្នុងផ្ទៃ ព្រោះប្រជុំហេតុ ៣ ប្រការ ។ ក្នុងសត្វលោកនេះ មាតាបិតាមកប្រជុំគ្នាហើយ តែមាតាជាស្រីមិនមានរដូវផង សត្វដែលគួរកើតក្នុងផ្ទៃនោះ ក៏មិនមានប្រាកដក្នុងឱកាសនោះផង កិរិយាចុះចាប់បដិសន្ធិរបស់សត្វដែលកើតក្នុងផ្ទៃ ក៏មិនទាន់មាននៅឡើយ ។ ក្នុងសត្វលោកនេះ មាតាបិតាមកប្រជុំគ្នាហើយផង មាតាជាស្រីមានរដូវផង តែសត្វដែលគួរកើត ក៏មិនមានប្រាកដក្នុងឱកាសនោះ កិរិយាចុះចាប់បដិសន្ធិរបស់សត្វដែលកើតក្នុងផ្ទៃ ក៏មិនទាន់មាននៅឡើយ ។ ម្នាលភិក្ខុទាំងឡាយ លុះតែកាលណា មាតាបិតាមកប្រជុំគ្នាផង មាតាជាស្រីមានរដូវផង សត្វដែលគួរកើតក៏មានប្រាកដក្នុងឱកាសនោះផង លុះប្រជុំហេតុទាំង ៣ ប្រការនេះឯង ទើបសត្វចុះចាប់បដិសន្ធិក្នុងផ្ទៃនៃមាតាបាន ។

បទថា **ឱក្កន្តិយា សតិ ឆាមរូបំ** សេចក្តីថា ក្នុងទីដែលត្រាស់ថា ព្រោះវិញ្ញាណជាបច្ច័យ ទើបមាននាមរូប ព្រះមានព្រះភាគទ្រង់សំដៅដល់ធម៌ ៣៣ ប្រការ គឺវត្ថុទសកៈ កាយទសកៈ ភាវទសកៈ និងអរូបក្ខន្ធ ៣ តែក្នុងទីដែលត្រាស់ថា កាលមានការឈានចុះ ទើបមាននាមរូប នេះគប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់សំដៅដល់ធម៌ ៣៤ ប្រការ ដែលកើតក្នុងបដិសន្ធិក្ខណៈនៃគព្ភសេយ្យកសត្វ ដោយទ្រង់បន្ថែមវិញ្ញាណក្ខន្ធចូលផង ។ ការ

ដែលសឡាយតនៈប្រាកដ ក្នុងកាលមាននាមរូប ភាពដែលផស្សៈប្រាកដ ក្នុងកាលមានសឡាយតនៈ ការដែលវេទនាប្រាកដ ក្នុងកាលមានផស្សៈ ព្រះមានព្រះភាគទ្រង់សម្តែងដោយបទទាំងឡាយជាដើមថា **នាមរូបប្បច្ចយា សឡាយតនំ** ដូចទ្រង់សម្តែងភាពដែលនាមរូបប្រាកដ ក្នុងកាលមានការឈានចុះកាន់គភ៌មាតាដោយបទថា **ឱក្កន្តិយា សតិ នាមរូបំ** ដូច្នោះ ។

ក្នុងបទថា **វេទិយមានស្ស** នេះ មានអធិប្បាយដូចតទៅនេះ អ្នកសោយវេទនាក្តី ស្គាល់វេទនាក្តី ហៅថា អ្នកសោយទាំងអស់ អធិប្បាយថា បុគ្គលកំពុងសោយ ឈ្មោះថា អ្នកសោយ ដូចក្នុងប្រយោគថា បពិត្រលោកដ៏ចម្រើន ខ្ញុំកំពុងសោយ ។ សូមសង្ឃចាំនូវខ្ញុំថា កំពុងសោយ បុគ្គលដឹង ឈ្មោះថា អ្នកសោយ ដូចក្នុងប្រយោគថា បុគ្គលកាលសោយសុខវេទនា ក៏ដឹងច្បាស់ថា អាត្មាអញកំពុងសោយសុខវេទនា ក្នុងទីនេះ ព្រះមានព្រះភាគក៏ទ្រង់បំណងយកបុគ្គលដែលដឹងនោះឯងថា ជាអ្នកសោយ ។

បទថា **ឥទំ ទុក្ខន្តិ បញ្ញាបេមិ** សេចក្តីថា តថាគតបញ្ញត្តថា នេះទុក្ខ ទុក្ខមានប៉ុណ្ណេះ មិនមានទុក្ខក្រៅអំពីនេះដល់សត្វដែលដឹងយ៉ាងនេះ គឺទូន្មានឲ្យបុគ្គលនោះដឹង បានដល់ ទូន្មានឲ្យបុគ្គលនោះជ្រាប ។ ក្នុងបទថា **អយំ ទុក្ខសមុទយោ** ជាដើម ក៏មានន័យនេះឯង ។ បណ្តាសច្ចៈ មានទុក្ខជាដើម ក្នុងសូត្រនោះ សន្និដ្ឋានកថាដូច្នេះ ក៏វៀរតណ្ហាចេញហើយ ខន្ធ ៥ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា ទុក្ខ តណ្ហាក្នុងកាលមុន ដែលជាហេតុឲ្យកើតទុក្ខនោះឯង ឈ្មោះថា ទុក្ខសមុទយៈ ការរម្ងត់សច្ចៈទាំង ២ នោះ

ដោយមិនកើតទៀត ឈ្មោះថា ទុក្ខនិរោធ អរិយមគ្គមានអង្គ ៨ ឈ្មោះថា ទុក្ខនិរោធគាមិនីបដិបទា ។

ព្រះមានព្រះភាគ កាលត្រាស់ថា កាលមានការឈានចុះ ទើបនាមរូបមាន ក៏ត្រាស់ដល់បុគ្គលអ្នកសោយ បុគ្គលអ្នកដឹងប៉ុណ្ណោះ កាលនឹងត្រាស់ថា ព្រោះមាននាមរូបជាបច្ច័យ ទើបសឡាយតនៈមាន ក៏ត្រាស់ដល់បុគ្គលដែលសោយប៉ុណ្ណោះ កាលនឹងត្រាស់ថា ព្រោះមានសឡាយតនៈជាបច្ច័យ ទើបផស្សៈមាន ក៏ត្រាស់ដល់បុគ្គលដែលសោយ បុគ្គលដែលដឹងប៉ុណ្ណោះ កាលនឹងត្រាស់ថា ព្រោះមានផស្សៈជាបច្ច័យ ទើបវេទនាមាន ក៏ត្រាស់ដល់បុគ្គលអ្នកសោយ អ្នកដឹងប៉ុណ្ណោះ កាលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឯតថាគតបញ្ញត្តថា នេះទុក្ខ ដល់បុគ្គលអ្នកសោយ ក៏ត្រាស់ដល់បុគ្គលអ្នកសោយ បុគ្គលអ្នកដឹងប៉ុណ្ណោះ កាលត្រាស់ថា តថាគតបញ្ញត្តថា នេះទុក្ខសមុទយៈ ក៏ត្រាស់ដល់អ្នកសោយ អ្នកដឹងប៉ុណ្ណោះ កាលត្រាស់ថា តថាគតបញ្ញត្តថា នេះទុក្ខនិរោធ ក៏ត្រាស់ដល់អ្នកសោយ អ្នកដឹងប៉ុណ្ណោះ កាលត្រាស់ថា តថាគតបញ្ញត្តថា នេះទុក្ខនិរោធគាមិនីបដិបទា ក៏ត្រាស់ដល់អ្នកសោយ អ្នកដឹងប៉ុណ្ណោះ ដោយប្រការដូចពណ៌នាមកនេះ ។

ឥឡូវនេះ កាលទ្រង់ពង្រីកសច្ចៈទាំងនោះតាមលំដាប់ឲ្យពិស្តារ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **កតមញ្ច ភិក្ខវេ** ជាដើម ។ ទុក្ខទាំងអស់នោះក្នុងពាក្យនោះ ខ្ញុំបានអធិប្បាយហើយ ដោយល្អិតល្អន់ គ្រប់ជ្រុងជ្រោយ ក្នុងវិសុទ្ធិមគ្គនោះឯង ។ គប្បីជ្រាបតាមន័យដែលពោល ក្នុងវិសុទ្ធិមគ្គនោះចុះ

ចំណែកដែលប្លែកគ្នាមានដូចតទៅនេះ បណ្តាអរិយសច្ចទាំងនោះ អរិយសច្ច គឺទុក្ខសមុទយៈ មកហើយតាមបែបនេះ គឺ **យាយំ តណ្ហា ពោនោព្ភវិកា** ក្នុងទីនេះមកហើយ ដោយអំណាចបច្ចយាការថា **អវិជ្ជាបច្ចយា សង្ខារា** ជាដើម ។ ម្យ៉ាងទៀត បណ្តាអរិយសច្ចទាំងនោះ អរិយសច្ច គឺទុក្ខនិរោធ មកហើយតាមបែបនេះ គឺ **យោ តស្សាយេវ តណ្ហាយ អសេសវិរាគ-និរោធោ** ក្នុងទីនេះ មកហើយដោយអំណាចការរលត់បច្ចយាការ គឺ **អវិជ្ជា-យត្វេវ អសេសវិរាគនិរោធា** ជាដើម ។ បណ្តាបទទាំងនោះ បទថា **អសេសវិរាគនិរោធា** សេចក្តីថា បទទាំង ២ នោះ គឺ **វិរាគ** និង **និរោធ** ជាវេវចនៈដល់គ្នានិងគ្នានោះឯង ព្រោះខ្វាក់ចោលមិនសេសសល់ និងព្រោះរលត់មិនសេសសល់ដូចគ្នា ។

បទថា **សង្ខារនិរោធោ** បានដល់ មានការរលត់សង្ខារទាំងឡាយ ដោយមិនកើតឡើងទៀត ។ ក្នុងបទដ៏សេស ក៏មានន័យនេះឯង ។ ម្យ៉ាងទៀត កិលេសទាំងឡាយ មានអវិជ្ជាជាដើម មកដល់ឋានៈណា រមែងរលត់ទៅ ឋានៈនោះ កាលពោលដោយអត្ថ ក៏គឺនិព្វាន ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយដោយបទទាំងនេះ ។ ពិតហើយ និព្វាន ព្រះមានព្រះភាគត្រាស់ដោយនាមថា ការរលត់ដោយឥតសេសសល់នៃធម៌ទាំងនោះយ៉ាងនេះ គឺ **អវិជ្ជានិរោធោ** ខ្វះ **សង្ខារនិរោធោ** ខ្វះ ។

បទថា **កេវលស្ស** ប្រែថា ទាំងអស់ ។ បទថា **ទុក្ខក្ខន្ធស្ស** គឺគំនរនៃវដ្តទុក្ខ ។ បទថា **និរោធោ ហោតិ** គឺមានការមិនប្រព្រឹត្តទៅ ។ ក្នុងបទ

ថា **និរោធោ ហោតិ** នោះ គប្បីជ្រាបថា ព្រោះហេតុដែលរលត់ឥតសេស សល់នៃកិលេសទាំងឡាយ មានអវិជ្ជាជាដើម ។ ហៅថា អាការដែល អស់ទៅនៃកិលេសទាំងឡាយ មានអវិជ្ជាជាដើម ថា អរហត្តផលខ្លះ ថា និព្វានខ្លះ ដូច្នោះ ។ ក្នុងទីនេះ ទើបព្រះមានព្រះភាគត្រាស់អរហត្តផល ក្នុងឋានៈ ១២ ដោយអំណាចការឃើញអាការដែលកិលេស មានអវិជ្ជាជា ដើមអស់ទៅហើយ និងត្រាស់និព្វានក្នុងឋានៈ ១២ ដូចគ្នា ។

ក្នុងបទថា **ឥទំ វុច្ចតិ** នេះ អធិប្បាយថា បទថា **ឥទំ** ព្រះមាន ព្រះភាគត្រាស់សំដៅយកនិព្វានតែម្យ៉ាង ក៏មិនមែន ។ បទថា **អដ្ឋង្គិកោ** ឈ្មោះថា មគ្គដទៃ ដែលផុតទៅអំពីអង្គ ៨ មិនមាន ។ ប្រៀបដូចកាល ពោលថា តន្ត្រីប្រកបដោយអង្គ ៥ ក៏ឈ្មោះថា ពោលថា តន្ត្រីមានត្រឹមអង្គ ៥ ប៉ុណ្ណោះ យ៉ាងណា ក្នុងទីនេះ ក៏ដូច្នោះដូចគ្នា គឺកាលព្រះមានព្រះភាគ ត្រាស់ថា មគ្គប្រកបដោយអង្គ ៨ ក៏គប្បីជ្រាបថា ឈ្មោះថា មគ្គមានអង្គ ៨ ប៉ុណ្ណោះ ។

បទថា **អនិគ្គហិតោ** គឺមិនសង្កត់សង្កិន ។ អធិប្បាយថា បុគ្គល កាលសង្កត់សង្កិនទូវធម៌ រមែងសម្តែងអរិយសច្ចបន្ថយចំនួនចុះខ្លះ បន្ថែម ចំនួនឡើងខ្លះ ផ្លាស់ប្តូរអរិយសច្ចនោះខ្លះ ។ សេចក្តីនោះ ដែលបុគ្គលណា ម្នាក់មិនអាចសម្តែងអរិសច្ច ៤ បន្ថយចំនួនចុះយ៉ាងនេះ គឺអរិយសច្ចទាំង- ឡាយ ៤ នេះ មិនមានមានត្រឹមតែ ២ ឬ ៣ ប៉ុណ្ណោះ មិនអាចបន្ថែមចំនួន ឡើងយ៉ាងនេះ គឺអរិយសច្ចមាន ៥ ឬអរិយសច្ចមាន ៦ មិនអាចនឹងសម្តែង

ផ្ទាស់ប្តូរថា អរិយសច្ចមិនមែន ៤ នេះ អរិយសច្ច ៤ ដទៃ ដូច្នោះ ទើប ធម៌នេះ ឈ្មោះថា មិនត្រូវសង្កត់សង្កិន ។ បទដ៏សេស ក្នុងទីគ្រប់អន្លើ មានអត្ថងាយយល់ទាំងអស់ហើយ ៚

**អដ្ឋកថា តិត្ថាយតនសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ភយសូត្រទី ២

[ ៦៤ ] ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនមិនចេះដឹង រមែងពោលថា អមាតាបុត្តិកភ័យ ( ភ័យដែលមាតាមិនបានឃើញបុត្រ បុត្រមិនបានឃើញមាតា ) នេះមាន ៣ យ៉ាង ។ ភ័យ ៣ យ៉ាងដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សម័យដែលមានកម្តៅភ្លើងធំតាំងឡើង ។ ម្នាលភិក្ខុទាំងឡាយ កាលបើកម្តៅភ្លើងធំតាំងឡើងហើយ អ្នកស្រុកក៏ក្តៅ អ្នកនិគមក៏ក្តៅ អ្នកនគរក៏ក្តៅ ដោយភ្លើងនោះ កាលបើអ្នកស្រុកក្តៅ អ្នកនិគមក្តៅ អ្នកនគរក្តៅ មាតាក៏មិនបានឃើញកូន ទាំងកូនក៏មិនបានឃើញមាតា ក្នុងកាលដែលអគ្គិភ័យកើតឡើងនោះ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង តែងពោលថា នេះជាអមាតាបុត្តិកភ័យទី ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សម័យដែលមហាមេឃតាំងឡើង គឺបង្អុរភ្លៀងឲ្យធ្លាក់ចុះ ។ ម្នាលភិក្ខុទាំងឡាយ

កាលបើមហាមេឃបង្អុរភ្លៀងធ្លាក់ចុះ អន្លង់ទឹកធំរមែងកើតព្រម កាលបើជំនន់ធំកើតព្រមហើយ អ្នកស្រុករមែងរសាត់ទៅ អ្នកនិគមរមែងរសាត់ទៅ អ្នកនគររមែងរសាត់ទៅដោយទឹកនោះ កាលបើអ្នកស្រុករសាត់ទៅ អ្នកនិគមរសាត់ទៅ អ្នកនគររសាត់ទៅ មាតាក៏មិនបានឃើញកូន ទាំងកូនក៏មិនបានឃើញមាតាក្នុងពេលដែលឧទកភ័យកើតឡើងនុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង រមែងពោលថា នេះជាអមាតាបុត្តិកភ័យទី ២ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត សម័យដែលមានអដវីសង្កោបភ័យ ( គឺសេចក្តីកម្រើកចោរក្នុងដងព្រៃ ) នោះ ពួកអ្នកជនបទ ក៏នាំគ្នាឡើងកាន់ចក្កយានបរទៅ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអដវីសង្កោបភ័យមានហើយ ពួកជនអ្នកជនបទនាំគ្នាឡើងកាន់ចក្កយានបរទៅ មាតាក៏មិនបានឃើញបុត្រ ទាំងបុត្រក៏មិនបានឃើញមាតា ក្នុងកាលដែលអដវីសង្កោបភ័យកើតឡើងនោះ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង តែងពោលថា នេះជាអមាតា-បុត្តិកភ័យទី ៣ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង តែងពោលថា អមាតាបុត្តិកភ័យមាន ៣ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង រមែងពោលនូវសមាតាបុត្តិកភ័យ ( ភ័យដែលមាតា និងបុត្រនៅឃើញគ្នាបាន ) ថាជាអមាតាបុត្តិកភ័យ ( ភ័យដែលមាតា និងបុត្រមិនបានឃើញគ្នា ) នេះ មាន ៣ យ៉ាង ។ ភ័យ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សម័យដែលមានកម្តៅភ្លើងធំតាំងឡើង ។ ម្នាលភិក្ខុទាំងឡាយ កាលបើកម្តៅភ្លើងធំតាំងឡើងហើយ អ្នកស្រុកក៏ក្តៅ អ្នកនិគម

ក៏ក្តៅ អ្នកនគរក៏ក្តៅដោយភ្លើងនោះ កាលបើអ្នកស្រុកក្តៅ អ្នកនិគមក្តៅ អ្នកនគរក្តៅ សម័យនោះ ជួនកាល មាតាបានឃើញបុត្រ បុត្រក៏បានឃើញមាតាខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង រមែងពោលនូវសមាតាបុត្តិកភ័យនេះ ថាជាអមាតាបុត្តិកភ័យទី ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សម័យដែលមានមហាមេឃបង្អុរភ្លៀង ។ ម្នាលភិក្ខុទាំងឡាយ កាលបើមហាមេឃបង្អុរភ្លៀងហើយ ជំនន់ធំក៏កើតឡើង កាលបើជំនន់ទឹកធំកើតហើយ ពួកអ្នកស្រុកក៏រសាត់ទៅ អ្នកនិគមក៏រសាត់ទៅ អ្នកនគរក៏រសាត់ទៅ ដោយទឹកនោះ កាលបើអ្នកស្រុករសាត់ទៅ អ្នកនិគមរសាត់ទៅ អ្នកនគរក៏រសាត់ទៅ សម័យនោះ ជួនកាល មាតាក៏បានឃើញបុត្រ បុត្រក៏បានឃើញមាតាខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង តែងពោលនូវសមាតាបុត្តិកភ័យនេះ ថាជាអមាតាបុត្តិកភ័យទី ២ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សម័យដែលមានអដវីសង្កោបភ័យ ពួកអ្នកជនបទក៏នាំគ្នាឡើងកាន់ចក្កយាន បរទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត កាលបើអដវីសង្កោបភ័យមានហើយ ពួកអ្នកជនបទ ក៏នាំគ្នាឡើងកាន់ចក្កយាន បរទៅ សម័យនោះ ជួនកាល មាតាបានឃើញបុត្រ បុត្រក៏បានឃើញមាតាខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង តែងពោលនូវសមាតាបុត្តិកភ័យនេះ ថាជាអមាតាបុត្តិកភ័យទី ៣ ។ ម្នាលភិក្ខុទាំង-ឡាយ បុថុជ្ជនអ្នកមិនចេះដឹង រមែងពោលនូវសមាតាបុត្តិកភ័យ ៣ យ៉ាងនេះឯង ថាជាអមាតាបុត្តិកភ័យ ។ ម្នាលភិក្ខុទាំងឡាយ អមាតាបុត្តិកភ័យ

នេះមាន ៣ យ៉ាង ។ អមាតាបុត្តិកភ័យ ៣ យ៉ាង តើដូចម្តេច ។ គឺជរា-ភ័យ ភ័យព្រោះជរា ១ ព្យាធិភ័យ ភ័យព្រោះព្យាធិ ១ មរណភ័យ ភ័យព្រោះមរណៈ ១ ។ ម្នាលភិក្ខុទាំងឡាយ មាតាមិនបានឃើញបុត្រ ដែលកំពុងជរាយ៉ាងនេះថា អាត្មាអញចាស់ សូមកុំឲ្យបុត្រអាត្មាអញចាស់ឡើយ ចំណែកខាងបុត្រក៏មិនបានឃើញមាតា ដែលកំពុងចាស់យ៉ាងនេះថា អាត្មាអញ សូមកុំឲ្យមាតារបស់អញចាស់ឡើយ ។ ម្នាលភិក្ខុទាំងឡាយ មាតាមិនបានឃើញបុត្រដែលកំពុងមានព្យាធិយ៉ាងនេះថា អាត្មាអញមានព្យាធិ សូមកុំឲ្យបុត្ររបស់អាត្មាអញមានព្យាធិឡើយ ចំណែកខាងបុត្រមិនបានឃើញមាតាដែលកំពុងមានព្យាធិយ៉ាងនេះថា អាត្មាអញមានព្យាធិ សូមកុំឲ្យមាតារបស់អាត្មាអញមានព្យាធិឡើយ ។ ម្នាលភិក្ខុទាំងឡាយ មាតាមិនបានឃើញបុត្រដែលស្លាប់យ៉ាងនេះថា អាត្មាអញរមែងស្លាប់ សូមកុំឲ្យបុត្ររបស់អញស្លាប់ឡើយ ចំណែកខាងបុត្រក៏មិនបានឃើញមាតា ដែលស្លាប់យ៉ាងនេះថា អាត្មាអញរមែងតែស្លាប់ សូមកុំឲ្យមាតារបស់អាត្មាអញស្លាប់ឡើយ ម្នាលភិក្ខុទាំងឡាយ អមាតាបុត្តិកភ័យមាន ៣ យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ មគ្គ និងបដិបទា រមែងប្រព្រឹត្តទៅដើម្បីលះបង់ ដើម្បីកន្លងបង់នូវសមាតា-បុត្តិកភ័យទាំង ៣ យ៉ាងនេះផង នូវអមាតាបុត្តិកភ័យទាំង ៣ យ៉ាងនេះផង ។ ម្នាលភិក្ខុទាំងឡាយ មគ្គ តើដូចម្តេច បដិបទា តើដូចម្តេច រមែងប្រព្រឹត្តទៅដើម្បីលះបង់ កន្លងបង់នូវសមាតាបុត្តិកភ័យទាំង ៣ យ៉ាងនេះបានផង នូវអមាតាបុត្តិកភ័យទាំង ៣ នេះបានផង ។ មគ្គដែលប្រកបដោយអង្គ ៨ ដ៏

ប្រសើរនេះឯង គឺសម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មា-កម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ហៅថា មគ្គ នេះហៅថា បដិបទា ប្រព្រឹត្តទៅដើម្បីលះបង់ ដើម្បីកន្លងបង់នូវសមាតាបុត្តិកភ័យទាំង ៣ យ៉ាង នេះផង នូវអមាតាបុត្តិកភ័យទាំង ៣ យ៉ាងនេះផង ។

# អដ្ឋកថា

## ភយសូត្រ

[ ៦៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងភយសូត្រទី ២ ដូចតទៅនេះ បទថា **អមាតាបុត្តិកានិ** សេចក្តីថា មាតា និងបុត្រ ឈ្មោះថា មាតា បុត្រ មាតា និងបុត្រ ឈ្មោះថា មិនមានក្នុងភ័យទាំងនេះ ដោយអំណាចការការពារនូវគ្នា និងគ្នាបាន ហេតុនោះ ទើបភ័យទាំងនេះ ឈ្មោះថា មិនមានមាតា និងបុត្រ ។ បទថា **យំ** គឺក្នុងសម័យណា ។ បទថា **តត្ថ មាតាបិ បុត្តំ ន បដិលភតិ** សេចក្តីថា កាលអគ្គិភ័យនោះកើតឡើងហើយ មាតាក៏មិនបានឃើញបុត្រ បុត្រក៏មិនបានឃើញមាតា ។

បទថា **ភយំ ហោតិ** សេចក្តីថា មានភ័យ គឺការតក់ស្លុតនៃចិត្ត ។ បទថា **អដវីសង្កោបោ** បានដល់ ការកម្រើករបស់ចោរដែលលាក់ខ្លួនក្នុង

ព្រៃជ្រៅ ។ ក្នុងបទថា **អដវី** នេះ គប្បីជ្រាបថា បានដល់ ចោរដែលលាក់ខ្លួននៅក្នុងព្រៃ ។ អធិប្បាយថា កាលណាចោរទាំងនោះចេញអំពីព្រៃ ចុះកាន់ជនបទ ដើរប្លន់ ទម្លាយគាមនិគម និងរាជធានី កាលនោះ ឈ្មោះថា មានការកម្រើករបស់ចោរនៅក្នុងព្រៃជ្រៅ ព្រះមានព្រះភាគទ្រង់សំដៅដល់ការកម្រើករបស់ចោរដែលនៅក្នុងព្រៃនោះ ទើបត្រាស់ពាក្យនេះថា **អដវី-សង្កោបោ** ។

ក្នុងបទថា **ចក្កសមារូឡ្ហា** នេះ អធិប្បាយថា វិលទៅទាំងចក្រ គឺឥរិយាបថទាំងចក្រ គឺយាន ។ ព្រោះថា កាលភ័យមកដល់ បុគ្គលពួកណាមានយាន បុគ្គលទាំងនោះ ក៏លើកទ្រព្យបរិក្ខាររបស់ខ្លួនឡើងយានទាំងនោះហើយបរទៅ បុគ្គលណាមិនមាន បុគ្គលនោះក៏ប្រើដងរែក ឬប្រើក្បាលទូលគេចចេញទៅ ។ មនុស្សទាំងនោះ ឈ្មោះថា ឡើងកាន់ចក្រ ។ បទថា **បរិយាយន្តិ** បានដល់ ទៅខាងនោះខាងនេះ ។ បទថា **កទាចិ** គឺក្នុងកាលខ្លះនោះឯង ។ បទថា **ករហចិ** ជាវេវចនៈនៃបទថា **កទាចិ** នោះឯង ។ បទថា **មាតាបិ បុត្តំ បដិលភតិ** សេចក្តីថា សូម្បីមាតាបានឃើញបុត្រដែលមក ដែលទៅ ឬពួនក្នុងទីមួយ ។ បទថា **ឧទកវាហកោ** គឺពេញស្ទឹង បទថា **មាតាបិ បុត្តំ បដិលភតិ** សេចក្តីថា កូនអណ្តែតទឹកជាប់លើក្បូន ឬផែ ក្នុងកាជនៈដី ឬលើកំណាត់ឈើ មាតាក៏បានឃើញ ។ ឬមាតាបានឃើញកូនហែលឆ្លងទៅ ដោយផុតភ័យហើយ ឈរនៅក្នុងផ្ទះ ឬក្នុងព្រៃ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងភ័យដែលមាតា និងបុត្រ មិនបាន

ជួបគ្នា ដែលទ្រង់បំណាំងយកការមក ដោយអមយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងភ័យដោយត្រង់ ទើបត្រាស់ពាក្យថា **តីណិមានិ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **ជរាភយំ** បានដល់ ភ័យដែលអាស្រ័យជរាកើតឡើង ។ ក្នុងភ័យ ២ យ៉ាងក្រៅពីនេះ ក៏មានន័យនេះឯង ។ សមដូចព្រះមានព្រះភាគត្រាស់ថា ភ័យ ហេតុដែលគួរភ័យ សេចក្តីខ្លាច សេចក្តីព្រឺរោម សេចក្តីតក់ស្លុតនៃចិត្ត ព្រោះអាស្រ័យជាតិ នេះហៅថា ភ័យព្រោះជាតិ ... ភ័យ ហេតុដែលគួរភ័យ សេចក្តីខ្លាច សេចក្តីព្រឺរោម សេចក្តីតក់ស្លុតនៃចិត្ត ព្រោះអាស្រ័យមរណៈ នេះហៅថា ភ័យព្រោះមរណៈ ។ បទដ៏សេស ក្នុងទីគ្រប់អន្លើ មានអត្ថងាយយល់ទាំងអស់ហើយ ។

## អដ្ឋកថា ភយសូត្រទី ២ ចប់

# សុត្តន្តបិដក

## វេនាគសូត្រទី ៣

[ ៦៥ ] សម័យមួយ ព្រះមានព្រះភាគ ទ្រង់ស្តេចទៅកាន់ចារិកក្នុងកោសលជនបទ មួយអន្លើដោយភិក្ខុសង្ឃជាច្រើនអង្គ ទ្រង់បានចូលទៅដល់ព្រាហ្មណគ្រាម ឈ្មោះវេនាគបុរី នៃកោសលជនបទ ។ ពួកព្រាហ្មណ៍ និងគហបតីអ្នកនៅក្នុងវេនាគបុរី បានឮច្បាស់នូវដំណឹងនោះហើយ ទើបប្រកាសសេចក្តីថា ម្នាលគ្នាយើង ឮថា ព្រះសមណគោតម ជាសក្យបុត្ត ចេញចាកសក្យត្រកូល ទៅទ្រង់ព្រះផ្នួសហើយ ស្តេចបានមកដល់វេនាគបុរី ។ កិត្តិសព្ទសរសើរព្រះគោតមដ៏ចម្រើននោះ ពីរោះ ឮខ្ទរខ្ទាយសុសសាយយ៉ាងនេះថា ព្រះដ៏មានព្រះភាគនោះ ទ្រង់ព្រះនាមថា អរហំ ថា សម្មាសម្ពុទ្ធោ ថា វិជ្ជាចរណសម្បន្នោ ថា សុគតោ ថា លោកវិទូ ថា អនុត្តរោ ថា បុរិសទម្មសារថិ ថា សត្ថា ទេវមនុស្សានំ ថា ពុទ្ធោ ថា ភគវា ព្រះអង្គបានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានចំពោះព្រះអង្គ ហើយញ៉ាំងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ញ៉ាំងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសឲ្យបានត្រាស់ដឹងផង ព្រះអង្គសម្តែងធម៌ពីរោះបទដើម ពីរោះបទកណ្តាល និងពីរោះបទខាងចុង ទ្រង់ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈដ៏បរិបូណ៌បរិសុទ្ធទាំងអស់ ក៏ដំណើរដែលបានឃើញ បានជួបនឹងព្រះអរហន្តទាំងឡាយមានសភាពយ៉ាងហ្នឹង ជាការប្រពៃពេក ។ លំដាប់

នោះឯង ព្រាហ្មណ៍ និងគហបតីអ្នកនៅក្នុងវេនាគបុរី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ពួកខ្លះក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ពួកខ្លះក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ពួកខ្លះអង្គុយក្នុងទីដ៏សមគួរ ប្រណម្យអញ្ជលីចំពោះព្រះដ៏មានព្រះភាគ ពួកខ្លះញុំាងនាម និងគោត្រឲ្យឮឡើង អង្គុយក្នុងទីសមគួរ ពួកខ្លះអង្គុយស្ងៀមក្នុងទីសមគួរ ។ ព្រាហ្មណ៍ជាវច្ឆគោត្រអ្នកនៅក្នុងវេនាគបុរី អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីអស្ចារ្យមិនធ្លាប់កើត ក៏កើតមាន បពិត្រព្រះគោតមដ៏ចម្រើន ឥន្ទ្រិយរបស់ព្រះគោតមដ៏ចម្រើន ជ្រះថ្លា ទាំងសម្បុរស្បែកក៏បរិសុទ្ធ ផូរផង់ដោយពិត បពិត្រព្រះគោតមដ៏ចម្រើន ប្រៀបដូចជាផ្លែពុទ្រាទុំក្នុងសរទកាល បរិសុទ្ធផូរផង់ យ៉ាងណាមិញ ឥន្ទ្រិយរបស់ព្រះគោតមដ៏ចម្រើន ជ្រះថ្លា ទាំងសម្បុរស្បែក ក៏បរិសុទ្ធផូរផង់យ៉ាងនោះដែរ ។ បពិត្រព្រះគោតមដ៏ចម្រើន មួយទៀត ប្រៀបដូចជាផ្លែត្នោតទុំ បរិសុទ្ធល្អជ្រុះចាកទង យ៉ាងណាមិញ ឥន្ទ្រិយរបស់ព្រះគោតមដ៏ចម្រើន ជ្រះថ្លា ទាំងសម្បុរស្បែក ក៏បរិសុទ្ធផូរផង់ យ៉ាងនោះដែរ ។ បពិត្រព្រះគោតមដ៏ចម្រើន មួយទៀត ដូចដុំមាសជម្ពូនទៈ ដែលកម្មារបុត្រអ្នកឈ្លាស ធ្វើបរិកម្មល្អទាំងរម្ងាយល្អហើយ តម្កល់ទុកលើសំពត់កម្ពល មានពណ៌លឿងទុំ រមែងភ្លឺផង ច្បាស់ផង រុងរឿងផង យ៉ាងណាមិញ ឥន្ទ្រិយរបស់ព្រះគោតមដ៏

ចម្រើន ជ្រះថ្លា ទាំងសម្បុរស្បែក ក៏បរិសុទ្ធ ផូរផង់ យ៉ាងនោះដែរ ។ បពិត្រព្រះគោតមដ៏ចម្រើន ឧច្ចាសយនៈ និងមហាសយនៈទាំងនោះមានដោយពិត គឺអាសន្ទិ ( អាសនៈដែលខ្ពស់ហួសប្រមាណ ) ១ បល្ល័ង្ក ( គ្រែដែលមានជើងវិចិត្រដោយរូបសត្វសាហាវ ) ១ គោណកៈ ( ព្រំដែលមានរោមវែងជាង ៤ ធ្នាប់ ) ១ ចិត្តិកា ( កម្រាលដែលគេធ្វើដោយរោមសត្វវិចិត្រដោយរតនៈ ) ១ បដិកា ( កម្រាលដែលមានពណ៌ស ធ្វើដោយរោមសត្វ ) ១ បដលិកា ( កម្រាលដែលធ្វើដោយរោមសត្វជាផ្កាចង្កោម ) ១ តូលិកា ( កម្រាលដែលញាត់ដោយសំឡី ) ១ វិកតិកា ( កម្រាលដែលធ្វើដោយរោមសត្វវិចិត្រដោយរូបសត្វមានសីហៈ និងខ្លាធំជាដើម ) ១ ឧទ្ធលោមី ( កម្រាលដែលធ្វើដោយរោមសត្វមានជាយទាំងពីរខាង ) ១ ឯកន្តលោមី ( កម្រាលដែលធ្វើដោយរោមសត្វមានជាយតែម្ខាង ) ១ កដ្ឋិស្សៈ ( កម្រាលដែលធ្វើដោយអំបោះលាយសូត្រ ដោតក្រងដោយរតនៈ ) ១ កោសេយ្យៈ ( កម្រាលដែលធ្វើដោយសូត្រដោតក្រងដោយរតនៈ ) ១ កុត្តកៈ ( កម្រាលដែលធ្វើដោយរោមសត្វល្មមពួកស្រីរបាំ ១០ នាក់ឈររាំបាន ) ១ ហត្ថត្ថរៈ ( កម្រាលសម្រាប់ក្រាលលើខ្នងដំរី ) ១ អស្សត្ថរៈ ( កម្រាលសម្រាប់ក្រាលលើខ្នងសេះ ) ១ រថត្ថរៈ ( កម្រាលសម្រាប់ក្រាលលើរថ ) ១ អជិនប្បវេណិ ( កម្រាលដែលគេធ្វើដោយស្បែកខ្លាឃ្មុំ ) ១ កាទលិមិគប្បវរប្បច្ចត្ថរណៈ ( កម្រាលដ៏ឧត្តមដែលធ្វើដោយស្បែកសត្វឈ្លូស ) ១ សឧត្តរច្ឆទៈ ( ទីដេកដែលមានពិតានក្រហម ) ១ ឧភតោលោហិតកុ-

បធាន: ( ខ្នើយមានពណ៌ក្រហមទាំងពីរខាង ) ១ ព្រះគោតមទ្រង់បាន តាមសេចក្តីប្រាថ្នា ទ្រង់បានដោយងាយ ទ្រង់បានដោយមិនលំបាក នូវឧច្చា-សយនៈ និងមហាសយនៈ មានសភាពយ៉ាងនេះដោយពិត ។ ព្រះដ៏មាន ព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ឧច្ចាសយនៈ និងមហាសយនៈទាំង នោះ គឺអាសន្ទិ ១ ... ឧកតោលោហិតកុបធានៈ ១ ពួកបព្វជិតបានដោយ លំបាក ប្រសិនបើបព្វជិតបានហើយ ក៏មិនគួរប្រើប្រាស់បានទេ ។ ម្នាល ព្រាហ្មណ៍ ឥឡូវនេះ តថាគតជាអ្នកបានតាមសេចក្តីប្រាថ្នា បានដោយងាយ បានដោយមិនលំបាក នូវឧច្ចាសយនៈ និងមហាសយនៈ ៣ យ៉ាងនេះឯង ។ ឧច្ចាសយនៈ និងមហាសយនៈ ៣ យ៉ាង តើដូចម្តេច ។ គឺឧច្ចាសយនៈ និងមហាសយនៈជាទិព្វ ១ ឧច្ចាសយនៈ និងមហាសយនៈជារបស់ព្រហ្ម ១ ឧច្ចាសយនៈ និងមហាសយនៈ ជារបស់អរិយៈ ១ ។ ម្នាលព្រាហ្មណ៍ ឥឡូវនេះ តថាគតបានតាមសេចក្តីប្រាថ្នា បានដោយងាយ បានដោយមិន លំបាក នូវឧច្ចាសយនៈ និងមហាសយនៈ ៣ យ៉ាងនេះឯង ។ បពិត្រព្រះ គោតមដ៏ចម្រើន ឥឡូវព្រះគោតមដ៏ចម្រើន បានតាមសេចក្តីប្រាថ្នា បាន ដោយងាយ បានដោយមិនលំបាកនូវឧច្ចាសយនៈ និងមហាសយនៈ ជា ទិព្វនោះ តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ ក្នុងទីឯណោះ តថាគតបានចូលទៅ អាស្រ័យនូវស្រុក ឬនិគមក្នុងបុព្វណ្ហសម័យ តថាគតស្លៀកស្បង់ប្រដាប់ បាត្រ និងចីវរចូលទៅកាន់ស្រុក និងនិគមនោះឯង ដើម្បីបិណ្ឌបាត កាល តថាគតត្រឡប់ពីបិណ្ឌបាតក្នុងបច្ឆាភត្ត ក៏ចូលទៅកាន់ព្រៃ តថាគតឯង ក៏

ប្រមូលយកស្មៅ ឬស្លឹកឈើទាំងនោះ ដែលមានក្នុងព្រៃនោះឲ្យនៅតែមួយ កន្លែង ហើយអង្គុយពែនភ្នែន តម្កល់កាយឲ្យត្រង់ តាំងសតិឆ្ពោះទៅកាន់ កម្មដ្ឋាន តថាគតនោះស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំង- ឡាយ ក៏ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្ក និងវិចារ មានបីតិ និង សុខដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ សម្រេចសម្រាន្តនៅ ព្រោះរម្ងាប់នូវ វិតក្ក វិចារ ក៏ចូលកាន់ទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តានខ្លួន ប្រកបដោយសេចក្តីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារ មានតែបីតិ និងសុខដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ក៏ សម្រេចសម្រាន្តនៅ ព្រោះនឿយណាយចាកបីតិផង ជាអ្នកប្រកបដោយ ឧបេក្ខាផង មានសតិ និងសម្បជញ្ញៈផង ទទួលនូវសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយ តែងសរសើរនូវបុគ្គលដែលបាននូវតតិយជ្ឈាននោះថា ប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះ បានដល់នូវតតិយជ្ឈាននោះ ទើបសម្រេចសម្រាន្តនៅ ព្រោះលះបង់នូវសុខ ផង លះបង់នូវទុក្ខផង ព្រោះអស់ទៅនៃសោមនស្ស និងទោមនស្សក្នុង កាលមុនផង ចូលកាន់ចតុត្ថជ្ឈាន ជាធម្មជាតមានអារម្មណ៍មិនមែនជាទុក្ខ មិនមែនជាសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ក៏សម្រេចសម្រាន្តនៅ ។ ម្នាលព្រាហ្មណ៍ បើតថាគតនោះចង្រ្កមមានសភាពយ៉ាងនេះ ទីចង្រ្កមជាទិព្វ នោះ រមែងមានដល់តថាគតក្នុងសម័យនោះ ម្នាលព្រាហ្មណ៍ បើតថាគត នោះឈរមានសភាពយ៉ាងនេះ ទីឈរជាទិព្វនោះ រមែងមានដល់តថាគតក្នុង

សម័យនោះ ម្នាលព្រាហ្មណ៍ បើតថាគតនោះ អង្គុយមានសភាពយ៉ាងនេះ ទីអង្គុយជាទិព្វនោះ រមែងមានដល់តថាគតក្នុងសម័យនោះ ម្នាលព្រាហ្មណ៍ បើតថាគតនោះសម្រេចនូវសំណិង មានសភាពយ៉ាងនេះ សំណិងដ៏ខ្ពស់ និងទីអង្គុយដ៏ប្រសើរជាទិព្វនោះ រមែងមានដល់តថាគតក្នុងសម័យនោះ ។ ម្នាលព្រាហ្មណ៍ ឥឡូវតថាគតជាអ្នកបានតាមសេចក្ដីប្រាថ្នា ជាអ្នកបានដោយងាយ បានដោយមិនលំបាកនូវសំណិងដ៏ខ្ពស់ និងទីអង្គុយដ៏ប្រសើរជាទិព្វនោះឯង ។ បពិត្រព្រះគោតមដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះគោតមដ៏ចម្រើន ចម្លែកណាស់ មានបុគ្គលណាដទៃ អាចនឹងបានតាមសេចក្ដីប្រាថ្នា បានដោយងាយ បានដោយមិនលំបាក នូវទីដេកដ៏ខ្ពស់ និងទីអង្គុយដ៏ប្រសើរ ជាទិព្វ មានសភាពយ៉ាងនេះបានឡើយ លើកលែងតែព្រះគោតមដ៏ចម្រើនចេញ ។ បពិត្រព្រះគោតមដ៏ចម្រើន ឥឡូវព្រះគោតមដ៏ចម្រើនទ្រង់បានតាមសេចក្ដីប្រាថ្នា បានដោយងាយ បានដោយមិនលំបាក នូវទីដេកដ៏ខ្ពស់ និងទីអង្គុយដ៏ប្រសើរ ជារបស់ព្រហ្មនោះ តើដូចម្ដេច ។ ម្នាលព្រាហ្មណ៍ ក្នុងទីឯណោះ តថាគតចូលទៅអាស្រ័យស្រុក ឬនិគមណា តថាគតស្លៀកស្បង់ ប្រដាប់ដោយបាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ស្រុក និងនិគមនោះឯង ដើម្បីបិណ្ឌបាត កាលតថាគតនោះត្រឡប់ពីបិណ្ឌបាត ក្នុងបច្ឆាភត្តហើយ ចូលទៅក្នុងជង់ព្រៃ តថាគតនោះបានប្រមូលនូវស្មៅ ឬស្លឹកឈើទាំងនោះ ដែលមានក្នុងជង់ព្រៃនោះ ឲ្យតម្កល់នៅមួយកន្លែង ហើយអង្គុយពែនភ្នែន តម្កល់កាយឲ្យត្រង់ ប្រុងសតិ

ឲ្យមានមុខឆ្ពោះទៅកាន់កម្មដ្ឋាន តថាគតនោះ មានចិត្តប្រកបដោយមេត្តាទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ និងទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹង គឺទិសតូចៗ មានចិត្តប្រកបដោយមេត្តា ជាចិត្តទូលាយ ដល់នូវសភាវៈធំ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ដោយអាការទាំងពួង ក្នុងទីទាំងពួង មានចិត្តប្រកបដោយករុណា ... មានចិត្តប្រកបដោយមុទិតា ... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ និងទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹង គឺទិសតូចៗ មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តទូលាយ ដល់នូវសភាវៈធំ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ដោយអាការទាំងពួង ក្នុងទីទាំងពួង ។ ម្នាលព្រាហ្មណ៍ បើតថាគតនោះចង្រ្កមយ៉ាងនេះ ជាទីចង្រ្កមដ៏ប្រសើរ រមែងមានដល់តថាគតក្នុងសម័យនោះ ម្នាលព្រាហ្មណ៍ បើតថាគតនោះឈរយ៉ាងនេះ ... អង្គុយ ... សម្រេចនូវសំណិង សំណិងដ៏ខ្ពស់ និងទីអង្គុយដ៏ប្រសើរ ជារបស់ព្រហ្មនោះ រមែងមានដល់តថាគតក្នុងសម័យនោះ ។ ម្នាលព្រាហ្មណ៍ តថាគតជាអ្នកបានតាមសេចក្តីប្រាថ្នា បានដោយងាយ បានដោយមិនលំបាក នូវសំណិងដ៏ខ្ពស់ និងទីអង្គុយដ៏ប្រសើរ ជារបស់ព្រហ្មនេះឯង ។ បពិត្រព្រះគោតមដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះគោតមដ៏ចម្រើន ចម្លែកណាស់ តើមានបុគ្គលដទៃឯណា នឹងបានតាមសេចក្តីប្រាថ្នា បានដោយងាយ បានដោយមិន

លំបាក នូវសំណិងដ៏ខ្ពស់ និងទីអង្គុយដ៏ប្រសើរ ជារបស់ព្រហ្ម មានសភាព យ៉ាងនេះ លើកលែងតែព្រះគោតមដ៏ចម្រើនចេញ ។ បពិត្រព្រះគោតមដ៏ចម្រើន ឥឡូវព្រះគោតមដ៏ចម្រើន បានតាមសេចក្តីប្រាថ្នា បានដោយងាយ បាន ដោយមិនលំបាក នូវសំណិងដ៏ខ្ពស់ និងទីអង្គុយដ៏ប្រសើរ ជារបស់អរិយៈ ដូចម្តេច ។ ម្នាលព្រាហ្មណ៍ ក្នុងទីឯណោះ តថាគតនោះ ចូលទៅអាស្រ័យ នូវស្រុក ឬនិគមណា តថាគតនោះស្លៀកស្បង់ ប្រដាប់ដោយបាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ស្រុក ឬនិគមនោះឯង ដើម្បីបិណ្ឌបាត កាល តថាគតនោះត្រឡប់ពីបិណ្ឌបាតក្នុងបច្ឆាភត្ត ចូលទៅកាន់ដងព្រៃ តថាគត នោះប្រមូលនូវស្មៅ ឬស្លឹកឈើទាំងនោះក្នុងដងព្រៃនោះឲ្យតាំងនៅក្នុងទី ១ ហើយអង្គុយពែនភ្នែន តម្កល់កាយឲ្យត្រង់ ប្រុងស្មារតីឆ្ពោះទៅកាន់កម្មដ្ឋាន តថាគតនោះដឹងយ៉ាងនេះថា រាគៈ តថាគតបានលះបង់ហើយ បានផ្តាច់ផ្តិល ឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ជាសភាវៈដល់នូវការសាបសូន្យ មានសភាពមិនកើតឡើងតទៅឡើយ ទោសៈ តថាគតបានលះបង់ហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បាន ធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ជាសភាវៈដល់នូវការសាប សូន្យមានសភាពមិនកើតឡើងតទៅ មោហៈតថាគត បានលះបង់ហើយ បាន ផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើម ត្នោត ជាសភាវៈដល់នូវការសាបសូន្យ មានសភាពមិនកើតឡើងតទៅ ឡើយ ។ ម្នាលព្រាហ្មណ៍ បើតថាគតនោះចង្ក្រម មានសភាពយ៉ាងនេះ ទី

ចង្ក្រមជារបស់អរិយៈនុ៎ះ រមែងមានដល់តថាគតក្នុងសម័យនោះ ម្នាលព្រាហ្មណ៍ បើតថាគតនោះឈរ មានសភាពយ៉ាងនេះ ... អង្គុយ ... សម្រេចនូវសំណិង សំណិងដ៏ខ្ពស់ និងទីអង្គុយដ៏ប្រសើរ ជារបស់អរិយៈនុ៎ះ រមែងមានដល់តថាគតក្នុងសម័យនោះ ។ ម្នាលព្រាហ្មណ៍ តថាគតជាអ្នកបានតាមសេចក្តីប្រាថ្នា បានដោយងាយ បានដោយមិនលំបាក នូវសំណិងដ៏ខ្ពស់ និងទីអង្គុយដ៏ប្រសើរ ជារបស់អរិយៈនេះឯង ។ បពិត្រព្រះគោតមដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះគោតមដ៏ចម្រើន ចម្លែកណាស់ តើមានបុគ្គលដទៃឯណា នឹងបានតាមសេចក្តីប្រាថ្នា បានដោយងាយ បានដោយមិនលំបាក នូវសំណិងដ៏ខ្ពស់ និងទីអង្គុយដ៏ប្រសើរ ជារបស់អរិយៈ មានសភាពយ៉ាងនេះ លើកលែងតែព្រះគោតមដ៏ចម្រើនចេញ ។ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ដូចជាបុគ្គលផ្ងាររបស់ដែលគេផ្កាប់ ឬបើករបស់ដែលគេបិទបាំង ពុំនោះក៏ដូចគេប្រាប់ផ្លូវដល់បុគ្គលអ្នកវង្វេងទិស ពុំនោះសោត ដូចគេទ្រោលបំភ្លឺប្រទីបប្រេងក្នុងទីងងឹត ឲ្យបុគ្គលអ្នកមានចក្ខុឃើញនូវរូបទាំងឡាយបាន យ៉ាងណាមិញ ធម៌ដែលព្រះគោតមដ៏ចម្រើនសម្តែងដោយអនេកបរិយាយ ក៏យ៉ាងនោះដែរ ។ យើងខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹង សូមព្រះគោតមដ៏ចម្រើន ទ្រង់ចាំទុកនូវយើងខ្ញុំព្រះអង្គ ថាជាឧបាសក ដល់នូវសរណៈ ស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមទៅ ។

# អដ្ឋកថា

## វេនាគសូត្រ

[ ៦៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវេនាគសូត្រទី ៣ ដូចតទៅនេះ បទថា **កោសលេសុ** បានដល់ ក្នុងជនបទដែលមានឈ្មោះយ៉ាងនោះ ។ បទថា **ចារិកំ ចរមានោ** បានដល់ ព្រះមានព្រះភាគទ្រង់មានព្រះពុទ្ធដំណើរទៅកាន់ផ្លូវឆ្ងាយ ។ ធម្មតាការយាងចារិករបស់ព្រះមានព្រះភាគមាន ២ យ៉ាង គឺការយាងចារិកដោយប្រញាប់ ១ ការយាងចារិកដោយមិនប្រញាប់ ១ ។ បណ្ដាការយាងចារិក ២ យ៉ាងនោះ ការដែលព្រះមានព្រះភាគ ទ្រង់ឃើញបុគ្គលដែលគួរណែនាំឲ្យដឹងបានក្នុងទីឆ្ងាយ ហើយទ្រង់ប្រញាប់ទៅដើម្បីប្រយោជន៍ក្នុងការទូន្មានបុគ្គលនោះឲ្យដឹង ឈ្មោះថា ទ្រង់ចារិកដោយប្រញាប់ ។ ការដែលទ្រង់ចារិកប្រញាប់នោះ គប្បីឃើញក្នុងវេលាដែលទ្រង់ទៅទទួលព្រះមហាកស្សបជាដើម ។ ចំណែកកាលដែលព្រះមានព្រះភាគកាលទ្រង់អនុគ្រោះលោកដោយពុទ្ធកិច្ច មានការត្រាច់បិណ្ឌបាតជាដើម យាងទៅតាមលំដាប់ស្រុក មួយថ្ងៃ ១ យោជន៍ ២ យោជន៍ ឈ្មោះថា ការយាងចារិកដោយមិនប្រញាប់ ។ ព្រះមានព្រះភាគ ទ្រង់សំដៅយកការចារិកដោយមិនប្រញាប់នេះ ទើបត្រាស់ពាក្យនេះថា **ចារិកញ្ចរមានោ** កថាពោលអំពីការយាងចារិក បានពោលហើយដោយពិស្ដារ ក្នុងអម្ពដ្ឋសុត្តវណ្ណនា ក្នុងអដ្ឋកថាទីឃនិកាយ ឈ្មោះសុមង្គលវិលាសិនី ។

បទថា **ព្រាហ្មណគាមោ** សេចក្ដីថា ស្រុកដែលព្រាហ្មណ៍ទាំងឡាយ

មកសមោសជាមួយគ្នាក្តី ស្រុកដែលព្រាហ្មណ៍ទាំងឡាយ មកបរិភោគក្តី ហៅថា ស្រុកព្រាហ្មណ៍ ។ ក្នុងទីនេះ ស្រុកដែលព្រាហ្មណ៍ទាំងឡាយមកលេងសមោស បំណងយកថា ជាស្រុកព្រាហ្មណ៍ ។ បទថា **តទវសរិ** គឺយាងទៅក្នុងស្រុកព្រាហ្មណ៍នោះ អធិប្បាយថា យាងដល់ហើយ ។ ឯការប្រថាប់ នៅមិនបានកំណត់ ក្នុងទីនេះ ។ ហេតុនោះ ទើបគួរជ្រាបថា ក្នុងទីមិនឆ្ងាយអំពីស្រុកព្រាហ្មណ៍នោះ មានដងព្រៃមួយ ដែលសមគួរដល់ព្រះពុទ្ធទាំងឡាយ ព្រះសាស្តាយាងទៅកាន់ដងព្រៃនោះ ។

បទថា **អស្សោសុំ** សេចក្តីថា ព្រាហ្មណ៍គហបតីទាំងឡាយស្តាប់ គឺបានចូលទៅ បានដល់ ដឹងតាមសំឡេងដែលបន្លឺចេញជាពាក្យពោលដល់សោតទ្វារ ។ សព្ទថា **ខោ** ត្រឹមតែជានិបាត ប្រើក្នុងអត្ថនៃអវធារណៈ គឺហាមសេចក្តីដទៃ ឬក្នុងអត្ថត្រឹមតែធ្វើបទឲ្យពេញ បណ្តាអត្ថ ២ យ៉ាងនោះ ដោយអត្ថអវធារណៈ គប្បីជ្រាបអត្ថដូច្នេះថា ព្រាហ្មណ៍គហបតីទាំងឡាយបានឮហើយនោះឯង ព្រាហ្មណ៍គហបតីទាំងនោះ មិនមានអន្តរាយនៃការស្តាប់ឡើយ ក្នុងបទបូរណៈ គឺការធ្វើបទឲ្យពេញ គប្បីជ្រាបត្រឹមតែជាការពីរោះរណ្តំនៃព្យញ្ជនៈប៉ុណ្ណោះ ។

ឥឡូវនេះ ដើម្បីប្រកាសអត្ថដែលព្រាហ្មណ៍គហបតីទាំងឡាយបានស្តាប់ហើយ ទើបព្រះសង្គីតិកាចារ្យពោលពាក្យថា **សមណោ ខលុ ភោ គោតមោ** ជាដើម ។ ក្នុងបទទាំងនោះ គប្បីជ្រាបថា បុគ្គលឈ្មោះថាជាសមណៈ ព្រោះមានបាបស្ងប់ហើយ ។ សព្ទថា **ខលុ** ត្រឹមតែជានិបាត

ប្រើក្នុងអត្ថថា បានស្តាប់តៗ មក ។ បទថា **ភោ** ត្រឹមតែជាព្រាហ្មណ៍គហបតីទាំងនោះហៅគ្នានិងគ្នា ។ បទថា **គោតមោ** ជាបទសម្តែងដល់ព្រះមានព្រះភាគ ដោយអំណាចគោត្រ ។ ហេតុនោះ ក្នុងបទថា **សមណោ ខលុ ភោ គោតមោ** នេះ គប្បីឃើញអត្ថយ៉ាងនេះថា បុគ្គលចម្រើនបានឮថា ព្រះសមណៈដែលជាគោតមគោត្រ ។ ឯបទថា **សក្យបុត្តោ** នេះ ជាបទសម្តែងដល់ត្រកូល ដែលខ្ពស់របស់ព្រះមានព្រះភាគ ។ បទថា **សក្យកុលា បព្វជិតោ** ជាបទសម្តែងថា ព្រះមានព្រះភាគទ្រង់យាងសាងព្រះផ្នួសដោយសទ្ធា ។ មានពាក្យអធិប្បាយថា ព្រះមានព្រះភាគមិនមានវិនាសណាមួយគ្របសង្កត់ឡើយ ទ្រង់លះត្រកូលនោះ ទាំងនៅមិនទាន់វិនាស ទ្រង់ព្រះផ្នួសដោយសទ្ធា ។

បទថា **តំ ខោ បន** ជាទុតិយាវិភត្តិ ប្រើក្នុងអត្ថបង្អុលប្រាប់ថា នេះយ៉ាងនេះ ។ អធិប្បាយថា របស់ព្រះគោតមដ៏ចម្រើននោះឯង ។ បទថា **កល្យាណោ** បានដល់ ប្រកបដោយគុណ មានពាក្យអធិប្បាយថា ប្រសើរបំផុត ។ បទថា **កិត្តិសទ្ទោ** បានដល់ មានកិត្តិនោះឯង ឬសំឡេងសរសើរ ។ បទថា **អព្ភុគ្គតោ** បានដល់ ល្បីរន្ទឺទៅដល់ទេវលោក ។ សួរថា កិត្តិសព្ទល្បីទៅ ដូចម្តេច ។ ឆ្លើយថា ល្បីទៅថា **ឥតិបិ សោ ភគវា ។បេ។ ពុទ្ធោ ភគវា ។** ក្នុងព្រះបាលីនោះ មានបទសម្ពន្ធដូច្នេះ ព្រះមានព្រះភាគនោះជាព្រះអរហន្ត ព្រោះហេតុនេះ ជាព្រះសម្មាសម្ពុទ្ធ ព្រោះហេតុនេះ ។បេ។ ជាភគវា ព្រោះហេតុនេះ មានពាក្យអធិប្បាយថា ព្រោះហេតុនេះផង ព្រោះ

*ហេតុនេះផង ។ ក្នុងព្រះពុទ្ធគុណនោះ លោកតាំងមាតិកា ដោយន័យជាដើម ថា ព្រះមានព្រះភាគអង្គនោះ គប្បីជ្រាបថា ជាព្រះអរហន្ត ដោយហេតុទាំងនេះ គឺព្រោះជាអ្នកឆ្ងាយចាកកិលេស ១ ព្រោះជាអ្នកទម្លាយបង់នូវសត្រូវទាំងឡាយ ១ ព្រោះទ្រង់កាច់បំបាក់នូវកាំទាំងឡាយ ១ ព្រោះទ្រង់ជាអ្នកគួរដល់បច្ច័យជាដើម ១ ព្រោះមិនធ្វើបាបក្នុងទីស្ងាត់ ១ ។*

*ដូច្នេះហើយ ពង្រីកបទទាំងនេះគ្រប់បទនោះឯង ឲ្យពិស្តារក្នុងពុទ្ធានុស្សតិនិទ្ទេស ក្នុងបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គ ។ អ្នកសិក្សាគប្បីកាន់យក សេចក្ដីពិស្ដាររបស់បទទាំងនោះ អំពីបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គនោះឯង ។*

*បទថា* **សោ ឥមំ លោកំ** *សេចក្ដីថា ព្រះគោតមដ៏ចម្រើននោះ ... លោកនេះ ។ តទៅនេះ នឹងសម្ដែងពាក្យដែលគប្បីពោល ។ បទថា* **សទេវកំ** *បានដល់ សត្វលោក ព្រមទាំងទេវតាទាំងឡាយ ឈ្មោះថា* **សទេវកំ** *សត្វលោក មួយអន្លើដោយមារ ឈ្មោះថា* **សមារកំ** *សត្វលោក ព្រមទាំងព្រហ្ម ឈ្មោះថា* **សព្រហ្មកំ** *ពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ឈ្មោះថា* **សស្សមណព្រាហ្មណី** *ពួកសត្វដែលឈ្មោះថា* **បជំ** *ព្រោះមានខ្លួនកើតអំពីទឹក ។ នូវបជានោះ ។ បជា ព្រមទាំងទេវតា និងមនុស្សទាំងឡាយ ឈ្មោះថា* **សទេវមនុស្សំ ។** *បណ្ដាពាក្យទាំងនោះ ពាក្យថា* **សទេវកំ** *គប្បីជ្រាបថា សំដៅដល់ទេវតាជាន់កាមាវចរ ៥ ដោយពាក្យថា* **សមារកំ** *គប្បីជ្រាបថា សំដៅដល់ទេវតាជាន់កាមាវចរទី ៦ ។ ដោយពាក្យថា* **សព្រហ្មកំ** *គប្បីជ្រាប*

ថា សំដៅដល់ព្រហ្ម ។ ដោយពាក្យថា **សស្សមណព្រាហ្មណឹ** គប្បីជ្រាបថា សំដៅដល់សមណព្រាហ្មណ៍ដែលជាសត្រូវរបស់ព្រះសាសនា និងសំដៅដល់សមណព្រាហ្មណ៍ ដែលមានបាបស្ងប់ហើយ ដែលបន្សាត់បាបហើយ ។ ដោយពាក្យថា **បជំ** គប្បីជ្រាបថា សំដៅដល់សត្វលោក ។ ពាក្យថា **សទេវមនុស្សំ** គប្បីជ្រាបថា សំដៅដល់សម្មតិទេព និងមនុស្សដ៏សេស ។ ក្នុងទីនេះ សត្វលោក ព្រមទាំងឱកាសលោក គប្បីជ្រាបថា លោកកាន់យកហើយដោយ ៣ បទ សត្វលោក គឺពួកសត្វ គប្បីជ្រាបថា លោកកាន់យកហើយដោយ ២ បទ ដូចពណ៌នាមក ដូច្នេះ ។

ម្យ៉ាងទៀត លោកជាន់អរូបាវចរ លោកកាន់យកហើយ ដោយសព្ទថា **សទេវកំ** លោកជាន់កាមាវចរ ៦ ជាន់ លោកកាន់យកហើយ ដោយសព្ទថា **សមារកំ** លោករបស់រូបព្រហ្ម លោកកាន់យកហើយ ដោយសព្ទថា **សព្រហ្មកំ** មនុស្សលោក ព្រមទាំងបរិស័ទ ៤ ឬសម្មតិទេព ឬសត្វលោកដ៏សេសទាំងអស់ លោកកាន់យកហើយ ដោយសព្ទថា **សស្សមណ-ព្រាហ្មណឹ** ជាដើម ។ ឯបុរាណាចារ្យទាំងឡាយពោលថា បទថា **សទេវកំ** បានដល់ លោកដ៏សេស ព្រមទាំងទេវតាទាំងឡាយ ។ បទថា **សមារកំ** បានដល់ លោកដ៏សេស ព្រមទាំងមារ ។ បទថា **សព្រហ្មកំ** បានដល់ លោកដ៏សេស ព្រមទាំងព្រហ្ម ដើម្បីប្រមូលសត្វដែលចូលដល់ភព ៣ ទាំងអស់ ក្នុង ៣ បទ ដោយ ៣ អាការ ហើយកំណត់កាន់យកទៀត ដោយ ២ បទ ទើបលោកពោលថា **សស្សមណព្រាហ្មណឹ បជំ សទេវ-**

**មនុស្សំ** ដូចពណ៌នាមកនេះ ។ លោកកំណត់កាន់យកជាតុ ៣ នោះឯង ដោយអាការនោះៗ ដោយ ៥ បទ យ៉ាងនេះឯង ។

បទថា **សយំ** ក្នុងពាក្យថា **សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ** សេចក្តីថា ដោយព្រះអង្គឯង គឺមិនមានអ្នកដទៃដឹកនាំ ។ បទថា **អភិញ្ញា** ប្រែថា ដោយអភិញ្ញា អធិប្បាយថា ទ្រង់ដឹងដោយព្រះញាណដ៏ក្រៃលែង ។ បទថា **សច្ឆិកត្វា** គឺទ្រង់ធ្វើឲ្យប្រចក្សច្បាស់ ។ លោកធ្វើការបដិសេធនូវការគិតដៅស្មានជាដើម ដោយបទថា **សច្ឆិកត្វា** នោះ ។ បទថា **បវេទេតិ** គឺទ្រង់ឲ្យដឹង បានដល់ ទ្រង់ឲ្យជ្រាប គឺទ្រង់ប្រកាស ។

បទថា **សោ ធម្មំ ទេសេតិ អាទិកល្យាណំ ។បេ។ បរិយោសាន-កល្យាណំ** សេចក្តីថា ព្រះមានព្រះភាគអង្គនោះ ទ្រង់អាស្រ័យព្រះករុណាក្នុងសត្វទាំងឡាយ ទោះបីទ្រង់វៀរព្រះធម្មទេសនាមួយគ្រា ហើយទ្រង់សម្តែងសេចក្តីសុខដែលកើតអំពីវិវេកដ៏កំពូល ។ ព្រះមានព្រះភាគ កាលទ្រង់សម្តែងសេចក្តីសុខ ដែលកើតអំពីវិវេកនោះ តិចខ្លះ ច្រើនខ្លះ ក៏ទ្រង់សម្តែងចំពោះប្រការ ដែលមានលម្អខាងដើម ជាដើមប៉ុណ្ណោះ មានពាក្យអធិប្បាយថា ទ្រង់សម្តែងធ្វើឲ្យល្អ បានដល់ មិនឲ្យមានទោសខាងដើមផង ទ្រង់ធ្វើឲ្យល្អ បានដល់ មិនឲ្យមានទោសត្រង់កណ្តាលផង ក្នុងទីបំផុតផង ។ ក្នុងសេចក្តីនោះ មានពាក្យអធិប្បាយថា ខាងដើម កណ្តាល និងទីបំផុតរបស់ទេសនា មានខាងដើម កណ្តាល និងទីបំផុតរបស់សាសនាក៏មាន ។ សម្រាប់ទេសនា ក្នុងគាថា ៤ បទ បទទី ១ ឈ្មោះថា ជាខាងដើម បទ

បន្ទាប់អំពីនោះ ឈ្មោះថា ជាកណ្តាល មួយបាទខាងចុង ឈ្មោះថា ជាទីបំផុត ។ សម្រាប់ព្រះសូត្រដែលមានអនុសន្ធិ ១ ពាក្យផ្តើមជាខាងដើម ពាក្យខាងចុងថា **ឥទមវោច** ជាទីបំផុត ចន្លោះពាក្យផ្តើម និងពាក្យចុងក្រោយ ជាកណ្តាល ។ សម្រាប់ព្រះសូត្រមានអនុសន្ធិច្រើន អនុសន្ធិដំបូងជាខាងដើម អនុសន្ធិខាងចុងជាទីបំផុត អនុសន្ធិ ១ ក្តី អនុសន្ធិ ២ ក្តី អនុសន្ធិច្រើនជាង ១ ឬ ២ ក្តី ត្រង់កណ្តាល ឈ្មោះថា កណ្តាលទាំងអស់ ។

សម្រាប់សាសនា គឺពាក្យប្រៀនប្រដៅ សីល សមាធិ និងវិបស្សនា ឈ្មោះថា ជាខាងដើម ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ថា ចុះអ្វីជាខាងដើមនៃកុសលទាំងឡាយ គឺសីលដ៏បរិសុទ្ធ ១ ទិដ្ឋិត្រង់ ១ ដូច្នេះ ។ ឯអរិយមគ្គ ដែលត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ មជ្ឈិមប្បដិបទា មិនប៉ះពាល់នូវធម៌អមខាងទាំង ២ នុ៎ះ ។ តថាគតបានត្រាស់ដឹងហើយ មាន ដូច្នេះ ។ ឈ្មោះថា ជាកណ្តាល ផល និងនិព្វាន ឈ្មោះថា ជាខាងចុង ផល លោកពោលថា ខាងចុង ដូចក្នុងប្រយោគនេះថា ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះឯង ចូរអ្នកប្រព្រឹត្តព្រហ្មចរិយៈ នុ៎ះជាត្រើយ នុ៎ះជាទីបំផុត ។ និព្វាន លោកពោលថា ជាទីផុត ដូចក្នុងប្រយោគថា ម្នាលអាវុសោវិសាខ ព្រោះព្រហ្មចរិយធម៌ ឈមទៅកាន់ព្រះនិព្វាន មានព្រះនិព្វានជាទីប្រព្រឹត្តទៅខាងមុខ មានព្រះនិព្វានជាទីបំផុត ។

ក្នុងទីនេះ លោកបំណងយកខាងដើម កណ្តាល និងទីបំផុតរបស់ទេសនា ព្រោះថា ព្រះមានព្រះភាគទ្រង់សម្តែងធម៌ ក៏ទ្រង់សម្តែងដល់សីល

ខាងដើម ទ្រង់សម្តែងមគ្គត្រង់កណ្តាល ហើយទ្រង់សម្តែងនិព្វានក្នុងទីបំផុត ។ ដោយហេតុនោះ ទើបព្រះសង្គីតិកាចារ្យពោលថា ព្រះមានព្រះភាគអង្គនោះ ទ្រង់សម្តែងលម្អនៃធម៌ខាងដើម ល្អត្រង់កណ្តាល និងល្អក្នុងទីបំផុត ។ ព្រោះដូច្នោះ ព្រះធម្មកថិករូបដទៃៗ កាលនឹងពោលធម៌

ក៏គប្បីសម្តែងសីលខាងដើម គប្បីសម្តែងមគ្គ ត្រង់
កណ្តាល គប្បីសម្តែងនិព្វានខាងចុង នេះឈ្មោះថា
ជាគោលដែលល្អរបស់ព្រះធម្មកថិក ។

បទថា **សាត្ថំ សព្យញ្ជនំ** សេចក្តីថា ទេសនារបស់ព្រះធម្មកថិករូបណា អាស្រ័យពណ៌នាដល់បបរ បាយ ស្ត្រី និងបុរសជាដើម ធម្មកថិកនោះ មិនឈ្មោះថា សម្តែងធម៌ដែលដល់ព្រមទៅដោយអត្ថ គឺប្រយោជន៍ តែព្រះមានព្រះភាគ ទ្រង់លះទេសនាបែបនោះចោល ទ្រង់សម្តែងទេសនាដែលអាស្រ័យសតិប្បដ្ឋាន ៤ ជាដើម ព្រោះដូច្នោះ ទើបព្រះសង្គីតិកាចារ្យពោលថា ទ្រង់សម្តែងធម៌ដែលដល់ព្រមដោយអត្ថ ។ ចំណែកទេសនារបស់ព្រះធម្មកថិករូបណា ប្រកបទៅដោយព្យញ្ជនៈប្រការមួយជាដើមខ្លះ មានព្យញ្ជនៈបាត់ទៅគ្រប់អង្គខ្លះ ចោលព្យញ្ជនៈទាំងអស់ និងនិគ្គហិតដែលជាព្យញ្ជនៈទៅទាំងអស់ខ្លះ ទេសនារបស់ធម្មកថិករូបនោះ ឈ្មោះថា មិនមានព្យញ្ជនៈ ព្រោះមានព្យញ្ជនៈមិនគ្រប់ ដូចភាសារបស់ពួកអ្នកព្រៃ មានពួកទមិឡ ពួកកិរាយតកៈ និងអ្នកយោនកៈជាដើម តែព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ ធ្វើព្យញ្ជនៈឲ្យបរិបូណ៌ ទ្រង់មិនលុបព្យញ្ជនៈទាំង ១០ ប្រភេទ

ដែលពោលយ៉ាងនេះថា

ការបេះក្នុងព្យញ្ជនៈ មាន ១០ ប្រការ គឺសិថិល ១ ធនិត ១ ទីឃៈ ១ រស្សៈ ១ លហុ ១ គរុ ១ និគ្គហិត ១ សម្ពន្ធ ១ វវត្ថិតៈ វិមុត្ត ១ ។

ព្រោះហេតុនោះ ទើបព្រះសង្គីតិកាចារ្យពោលថា ទ្រង់សម្តែងធម៌ដល់ព្រមទៅដោយព្យញ្ជនៈ ។

ពាក្យថា **កេវលំ** ក្នុងបទថា **កេវលបរិបុណ្ណំ** នេះ ជាពាក្យប្រើជំនួសពាក្យថា **សកលំ** សំដៅដល់ទាំងអស់ ។ បទថា **បរិបុណ្ណំ** សំដៅដល់មិនខ្វះ មិនលើស ។ មានពាក្យអធិប្បាយដូច្នេះថា ព្រះមានព្រះភាគទ្រង់សម្តែងធម៌បរិបូណ៌ទាំងអស់នោះឯង សូម្បីទេសនារឿងមួយដែលមិនបរិបូណ៌ ក៏មិនមាន ។ បទថា **បរិសុទ្ធំ** បានដល់ មិនមានឧបក្កិលេស អធិប្បាយថា ព្រះធម្មកថិករូបណាសម្តែងធម៌ដោយបំណងថា អញនឹងបានលាភ ឬសក្ការៈ ព្រោះអាស្រ័យធម្មទេសនានេះ ទេសនារបស់ធម្មកថិករូបនោះ ឈ្មោះថា មិនបរិសុទ្ធ តែព្រះមានព្រះភាគ ទ្រង់មិនប្រាថ្នាលោកាមិស ទ្រង់មានព្រះហឫទ័យទន់ភ្លន់ ដោយការផ្សាយប្រយោជន៍ ដោយការចម្រើនមេត្តា ទ្រង់សម្តែងធម៌ ដោយព្រះហឫទ័យដែលតាំងនៅក្នុងការលើកតម្កើង ដោយហេតុនោះ ទើបព្រះសង្គីតិកាចារ្យពោលថា ទ្រង់សម្តែងធម៌បរិសុទ្ធ ។ បទថា **ព្រហ្មចរិយំ** ក្នុងពាក្យថា **ព្រហ្មចរិយំ បកាសេតិ** នេះ បានដល់ សាសនា គឺពាក្យប្រៀនប្រដៅទាំងអស់ ដែលសង្គ្រោះចូលក្នុងត្រៃសិក្ខា ព្រោះហេតុ

នោះ ទើបព្រះសង្គីតិកាចារ្យពោលថា ទ្រង់ប្រកាសព្រហ្មចរិយៈ ។

គប្បីឃើញអត្ថក្នុងបទនេះ យ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ទ្រង់សម្ដែងលម្អខាងដើម ។ បេ ។ បរិសុទ្ធ និងកាលទ្រង់សម្ដែងយ៉ាងនេះ ឈ្មោះថា ទ្រង់ប្រកាសសាសនព្រហ្មចរិយៈទាំងមូល ដែលសង្គ្រោះចូលក្នុងត្រៃសិក្ខា ។ បទថា **ព្រហ្មចរិយំ** សេចក្ដីថា ចរិយាដែលឈ្មោះថាជាព្រហ្ម ព្រោះអត្ថថា ប្រសើរបំផុត ម្យ៉ាងទៀត មានពាក្យអធិប្បាយថា ចរិយារបស់បុគ្គលដែលប្រសើរទាំងឡាយ មានព្រះពុទ្ធជាដើម ឈ្មោះថា ព្រហ្មចរិយៈ ។

បទថា **សាធុ ខោ បន** សេចក្ដីថា ឯការឃើញព្រះអរហន្តទាំងឡាយជារបស់ល្អ ។ មានអធិប្បាយថា នាំប្រយោជន៍មកឲ្យ នាំសុខមកឲ្យ ។ បទថា **តថារូបានំ អរហតំ** សេចក្ដីថា ព្រះអរហន្តទាំងឡាយ ដូចព្រះគោតមដ៏ចម្រើន ជាបុគ្គលដែលឃើញបានដោយកម្រ ដោយប្រើពេលវេលាយូរអស់ច្រើនសែនកោដិកប្ប ទើបបានឃើញ មានសរីរៈធក់ទាញនូវចិត្ត ឆ្មៀលឆ្មាត់ដោយមហាបុរិសលក្ខណៈដ៏ល្អ ៣២ ប្រការ ប្រដាប់ដោយរតនៈ គឺអនុព្យញ្ជនៈ ៨០ ប្រការ ចោមរោមដោយព្រះរស្មី ផ្សាយចេញទៅប្រមាណមួយព្យាម គួរទស្សនា មិនមែនតិច មានក្រសែសំឡេងសម្ដែងធម៌ពីរោះក្រៃពេក រហូតគេថ្វាយព្រះនាមថា ជាព្រះអរហន្តក្នុងលោក ព្រោះបានសម្រេចគុណតាមសេចក្ដីពិត ។ បទថា **ទស្សនំ ហោតិ** សេចក្ដីថា គ្រាន់តែបើកភ្នែកមើលព្រះសរីរៈដោយសេចក្ដីជ្រះថ្លាជាដើម ក៏ជាការល្អ ព្រោះធ្វើអធ្យាស្រ័យយ៉ាងនេះថា បើព្រះពុទ្ធដូចព្រះគោតមដ៏ចម្រើន សម្ដែងធម៌ ដោយព្រះ

សូរសៀងដូចសំឡេងព្រហ្ម ដែលប្រកបដោយអង្គ ៨ យើងទាំងឡាយនឹងបានស្តាប់ត្រឹមតែមួយបទសោត ក៏ជាការល្អក្រៃលែងទៀតនោះឯង ។

បទថា **យេន ភគវា តេនុបសង្កមឹសុ** សេចក្តីថា អ្នកស្រុកវេនាគបុរៈទាំងឡាយ លះបង់នូវការងារគ្រប់យ៉ាង មានចិត្តត្រេកអរ ។ ក្នុងបទថា **អញ្ជលិម្បណាមេត្វា** នេះ មានអធិប្បាយថា ជនពួកណាចូលគ្នាបានទាំង ២ ចំណែក គឺទាំងខាងសម្មាទិដ្ឋិ និងមិច្ឆាទិដ្ឋិ ជនទាំងនោះគិតយ៉ាងនេះថា បើពួកមិច្ឆាទិដ្ឋិចោទសួរពួកយើងថា ព្រោះហេតុអ្វី ទើបអ្នកទាំងឡាយ ថ្វាយបង្គំព្រះសមណគោតម យើងទាំងឡាយនឹងឆ្លើយនឹងពួកមិច្ឆាទិដ្ឋិនោះថា ដោយហេតុត្រឹមតែធ្វើអញ្ជលី ក៏ចាត់ជាការថ្វាយបង្គំឬ បើពួកសម្មាទិដ្ឋិចោទពួកយើងថា ព្រោះហេតុអ្វី ទើបអ្នកទាំងឡាយ មិនក្រាបថ្វាយបង្គំព្រះមានព្រះភាគ យើងទាំងឡាយនឹងឆ្លើយថា ព្រោះក្បាលប៉ះផែនដីប៉ុណ្ណោះឬ ទើបចាត់ថាជាការថ្វាយបង្គំ ការលើកដៃប្រណម្យ ក៏ឈ្មោះថា ក្រាបថ្វាយបង្គំដូចគ្នា មិនមែនឬ ។

បទថា **ឆាមគោត្តំ** សេចក្តីថា អ្នកស្រុកវេនាគបុរៈទាំងឡាយ កាលពោលថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គឈ្មោះទត្តៈ ជាកូនរបស់អ្នកនោះ ឈ្មោះមិត្តៈ ជាកូនរបស់បុគ្គលនោះ មកក្នុងទីនេះ ដូច្នេះ ឈ្មោះថាប្រកាសឈ្មោះ កាលពោលថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គឈ្មោះវាសេដ្ឋៈ ខ្ញុំព្រះអង្គឈ្មោះកច្ចាយនៈ មកក្នុងទីនេះ ដូច្នេះ ឈ្មោះថា ប្រកាសគោត្រ ។

បានឮថា អ្នកវេនាគបុរៈទាំងនោះ ជាអ្នកក្រើក្រ ជាមនុស្សចាស់ ធ្វើយ៉ាងនោះ ក៏ដោយបំណងថា យើងទាំងឡាយ នឹងប្រាកដដោយអំណាចឈ្មោះ និងគោត្រ ក្នុងកណ្តាលបរិស័ទ ។ ឯអ្នកវេនាគបុរៈពួកណាអង្គុយស្ងៀម អ្នកវេនាគបុរៈទាំងនោះ ជាមនុស្សកំណាញ់ ជាមនុស្សល្ងង់ ។ បណ្តាជនទាំងនោះ ពួកអ្នកដែលកំណាញ់គិតថា កាលអញធ្វើការសន្ទនាប្រាស្រ័យពាក្យ ១ ពាក្យ ២ ព្រះគោតមក៏នឹងស្និទ្ធស្នាល បើមានការស្និទ្ធស្នាល មិនឲ្យកិច្ចាមួយវេក ១-២ វេក ក៏មិនសមគួរ ដូច្នេះ កាលដោះខ្លួនអំពីការសន្ទនាប្រាស្រ័យនោះ ទើបអង្គុយស្ងៀម ។ ពួកមនុស្សល្ងង់អង្គុយស្ងៀមមួយកន្លែង ដូចដុំដី ដែលគេគ្រវែង ព្រោះភាពដែលខ្លួនជាអ្នកមិនដឹង ។ បទថា **វេនាគបុរិកោ** បានដល់ អ្នកក្រុងវេនាគបុរី ។ បទថា **ឯតទវោច** សេចក្តីថា អ្នកក្រុងវេនាគបុរីសម្លឹងមើលព្រះសរីរៈរបស់ព្រះតថាគត តាំងអំពីចុងព្រះកេសា រហូតដល់ចុងព្រះបាទ ក៏ឃើញព្រះសរីរៈរបស់ព្រះតថាគត ប្រដាប់ដោយមហាបុរិសលក្ខណៈ ៣២ ប្រការ ដែលរុងរឿងដោយអនុព្យញ្ជនៈ ៨០ ចោមរោមដោយព្រះពុទ្ធរស្មី ៦ ពណ៌ ដែលផ្សាយចេញអំពីព្រះសរីរៈ ទៅកាន់ប្រទេសជុំវិញបាន ៨០ ហត្ថ ទើបកើតការភ្ញាក់ផ្អើលកាលពោលសរសើរគុណ ទើបបានពោលយ៉ាងនេះ គឺបានពោលពាក្យថា **អច្ឆរិយំ ភោ គោតម** ជាដើម ។

បណ្តាបទទាំងនោះ បទថា **យាវញ្ចិទំ** នេះ ជាពាក្យបង្អុលដល់ការកំណត់ មានប្រមាណក្រៃលែង ។ បទថា **យាវញ្ចិទំ** នោះ សម្ពន្ធចូលជា

មួយបទថា **វិប្បសន្នំ** ។ ឥន្ទ្រិយទាំងឡាយផូរផង់ដកបណា ឈ្មោះថា ផូរផង់ក្រៃលែង អធិប្បាយថា ផូរផង់ពន់ពេក ។ បទថា **ឥន្ទ្រិយានិ** បាន ដល់ ឥន្ទ្រិយ ៦ មានចក្ខុជាដើម កាលដែលឥន្ទ្រិយ ៦ នោះផូរផង់ បាន ប្រាកដហើយដល់វច្ឆគោត្តព្រាហ្មណ៍ ព្រោះបានឃើញភាពដែលឱកាស ដែល ឥន្ទ្រិយ ៥ តាំងនៅផូរផង់ ។ ព្រោះហេតុដែលការផូរផង់នោះ រមែងផូរផង់ ត្រង់ចិត្តនោះឯង ព្រោះសម្រាប់បុគ្គលដែលមានចិត្តមិនផូរផង់ ក៏នឹងមាន ឥន្ទ្រិយមិនផូរផង់ ដូច្នោះ សូម្បីការផូរផង់នៃឥន្ទ្រិយ ក៏បានប្រាកដដល់ ព្រាហ្មណ៍វច្ឆគោត្រនោះ ។ វច្ឆគោត្តព្រាហ្មណ៍បំណាងយកឥន្ទ្រិយ ៦ ផូរផង់ យ៉ាងនេះ ទើបពោលថា **វិប្បសន្នានិ ឥន្ទ្រិយានិ** ។

បទថា **បរិសុទ្ធោ** បានដល់ មិនមានមន្ទិល ។ បទថា **បរិយោទាតោ** បានដល់ ផូរផង់ ។ បទថា **សារទំ ពទរបណ្ឌុំ** បានដល់ ផ្លែពុទ្រាទុំ ដែល កើតក្នុងសរទកាល ពិតហើយ ផ្លែពុទ្រាទុំជោរនោះ ថ្លាផង ផូរផង់ផង ។ បទថា **តាលបក្កំ** បានដល់ ផ្លែត្នោតទុំ ។ បទថា **សម្បតិ ពន្ធនា បមុត្តំ** បានដល់ ផុតចាកទងក្នុងខណៈនោះឯង អធិប្បាយថា លើទីប្រមាណ ៤ ធ្នាប់ របស់ផ្លែត្នោតទុំនោះ ដែលបុគ្គលបេះចេញអំពីធ្នាយ ហើយផ្កាមុខលើ ដាក់ លើបន្ទះក្តារ រមែងប្រាកដជាពណ៌ស្រស់ថ្លា ផូរផង់ដល់បុគ្គលអ្នកសម្លឹងមើល វច្ឆគោត្តព្រាហ្មណ៍ សំដៅយកផ្លែត្នោតទុំនោះឯង ទើបពោលយ៉ាងនេះ ។

បទថា **នេក្ខំ ជម្ពោនទំ** បានដល់ ដុំមាសជម្ពូនទៈដែលមានពណ៌ ក្រហមរលោង ។ បទថា **ទក្ខកម្មារបុត្តសុបរិកម្មកតំ** បានដល់ ដែលកូន

ជាងមាសឈ្លាសវៃរចនាល្អហើយ ។ បទថា **ឧក្កាមុខេ សុកុសលសម្បហដ្ឋំ** សេចក្ដីថា មាសជម្ពូនទៈដែលជាងមាសមានថ្វីដៃ រម្ងាយក្នុងចង្ក្រានរបស់ជាងមាស ហើយខាត់យ៉ាងល្អដោយការវាយ ការជំពន្ធូត និងការរចនា អធិប្បាយថា ដុសខាត់ឲ្យបានល្អ ។ បទថា **បណ្ឌុកម្ពលេ និក្ខិត្តំ** សេចក្ដីថា ដែលនាយជាងមាសមានថ្វីដៃ ប្រើភ្លើងរោលខាត់ដោយចង្កូមខ្លាដំបង យកជ័រឈើលាប ហើយដាក់លើសំពត់កម្ពលក្រហម ។ បទថា **ភាសតេ** បានដល់ បញ្ចេញពន្លឺ ព្រោះមានពន្លឺកើតឯង ។ បទថា **តបតេ** បានដល់ មានពន្លឺ ព្រោះកម្ចាត់ការងងឹត ។ បទថា **វិរោចតិ** បានដល់ ផ្សាយទៅរុងរឿង អធិប្បាយថា ភ្លឺផ្លេកល្អពន់ពេក ។

ក្នុងបទថា **ឧច្ចាសយនមហាសយនានិ** នេះ មានអធិប្បាយដូចតទៅ ទីដេកខ្ពស់ហួសប្រមាណ ឈ្មោះថា **ឧច្ចាសយន** ទីដេកដែលជាអកប្បិយ-កណ្ឌ គឺរបស់ដែលមិនគួរដល់សមណៈ ទាំងបណ្ដាយ និងទទឹង ឈ្មោះថា **មហាសយនា** ។ ឥឡូវនេះ កាលសម្ដែងទីដែលខ្ពស់ និងទីដេកធំនោះ ទើបវច្ឆគោត្តព្រាហ្មណ៍ពោលពាក្យថា **សេយ្យថីទំ អាសន្ទិ** ជាដើម ។

ក្នុងពាក្យថា **អាសន្ទិ** ជាដើមនោះ មានអធិប្បាយដូចតទៅ ដែលឈ្មោះថា **អាសន្ទិ** បានដល់ អាសនៈ គឺទីអង្គុយធំពេក ដែលឈ្មោះថា **បល្លង្ក** បានដល់ បល្ល័ង្កដែលគេធ្វើដោយបិទរូបសត្វសាហាវត្រង់ជើង ។ ដែលឈ្មោះថា **គោណក** បានដល់ សំពត់កោជវៈផ្ទាំងធំដែលមានរោមវែង ។ បានឮថា រោមរបស់សំពត់កោជវៈផ្ទាំងធំនោះ វែងជាង ៤ ធ្នាប់ ។

ដែលឈ្មោះថា **ចិត្តិកា** បានដល់ គ្រឿងកម្រាលរោមចៀមវិចិត្រដោយរតនៈ ។ ដែលឈ្មោះថា **បដិកា** បានដល់ កម្រាលពណ៌ស ធ្វើអំពីរោមចៀម ។ ដែលឈ្មោះថា **បដលិកា** បានដល់ កម្រាលរោមចៀមមានផ្កាក្រាស់ ដែលហៅថា បន្ទះកន្ទួតព្រៃក៏មាន ។ ដែលឈ្មោះថា **តូលិកា** បានដល់ កម្រាលធ្វើអំពីសំឡីដែលញាត់ដោយសំឡីប្រភេទណាមួយ ក្នុងបណ្តាសំឡីទាំង ៣ ។ ដែលឈ្មោះថា **វិកតិកា** បានដល់ កម្រាលរោមចៀមដែលវិចិត្រដោយរូបរាជសីហ៍ និងខ្លាធំជាដើម ។ ដែលឈ្មោះថា **ឧទ្ធ-លោមី** បានដល់ កម្រាលរោមចៀមដែលមានជាយទាំងសងខាង ។ អាចារ្យពួកខ្លះពោលថា កម្រាលរោមចៀមដែលមានផ្កាផុសឡើងតែម្ខាង ។ ដែលឈ្មោះថា **ឯកន្តលោមី** បានដល់ កម្រាលរោមចៀមដែលមានជាយតែម្ខាង ។ អាចារ្យពួកខ្លះពោលថា កម្រាលរោមចៀមដែលមានផ្កាផុសឡើងទាំងសងខាង ។ ដែលឈ្មោះថា **កដ្ឋិស្សំ** បានដល់ កម្រាលដែលធ្វើអំពីសូត្រ ដេរភ្ជាប់ដោយរតនៈ ។ ដែលឈ្មោះថា **កោសេយ្យំ** បានដល់ កម្រាលដែលធ្វើអំពីសរសៃសូត្រ ដេរភ្ជាប់ដោយរតនៈដូចគ្នា ។ ដែលឈ្មោះថា **កុត្តកំ** បានដល់ កម្រាលរោមចៀម ទំហំអ្នករបាំ ១៦ នាក់ ឈររាំបាន ។ ដែលឈ្មោះថា **ហត្ថត្ថរំ** ជាដើម បានដល់ កម្រាលដែលក្រាលលើខ្នងដំរីជាដើម និងកម្រាលដែលធ្វើជារូបដំរីជាដើម ។ ដែលឈ្មោះថា **អជិនប្បវេណិ** បានដល់ កម្រាលដែលយកស្បែកខ្លាមកដេរដោយទំហំប៉ុនគ្រែ ។ បទដ៏សេសមានអត្ថដូចពោលហើយខាងដើមនោះឯង ។ បទថា **និកាមលាភី** ប្រែថា

ព្រះសមណគោតមដ៏ចម្រើន មានប្រក្រតីបានតាមប្រាថ្នា គឺមានប្រក្រតីបានទីដេកខ្ពស់ និងធំតាមដែលត្រូវការ ។ បទថា **អកិច្ឆលាភី** ប្រែថា មានប្រក្រតីបានដោយមិនលំបាក ។ បទថា **អកសិរលាភី** ប្រែថា មានប្រក្រតីបានទីដេកដ៏បរិបូណ៌ គឺមានប្រក្រតីបានទូវទីដេកធំ វច្ឆគោត្តព្រាហ្មណ៍ពោលសំដៅយកថា ព្រះសមណគោតមដ៏ចម្រើន ប្រហែលជាបានទីដេកដ៏ឱឡារនោះឯង បានឮថា ព្រាហ្មណ៍នេះធ្ងន់ក្នុងការដេក ។ គាត់ឃើញថា ឥន្ទ្រិយរបស់ព្រះមានព្រះភាគផូរផង់ជាដើម សម្គាល់ថា ព្រះសមណគោតមនេះអង្គុយ និងដេកលើទីដេកខ្ពស់ និងទីដេកធំបែបនេះដោយពិត ដោយហេតុនោះ ទើបឥន្ទ្រិយទាំងឡាយរបស់លោកផូរផង់ ទើបពណ៌សម្បុរបរិសុទ្ធទើបពោលសរសើរគុណរបស់សេនាសនៈនេះ ។

ក្នុងបទថា **លទ្ធា ច បន ឆ កប្បន្តិ** នេះ អធិប្បាយថា ព្រោះព្រះបាលីថា កម្រាលប្រភេទណាមួយប្រើបាន អធិប្បាយថា កម្រាលសូត្រសុទ្ធទោះក្រាលលើគ្រែក៏ប្រើបាន កម្រាលធ្វើសំពត់រោមសត្វជាដើម ទោះក្រាលដោយប្រើជាគ្រឿងកម្រាលផ្ទៃក៏ប្រើបាន ទោះកាត់ជើងរបស់អាសន្ទិ ហើយអង្គុយក៏បាន ទោះទម្លាយរូបសត្វសាហាវរបស់បល្ល័ង្ក ហើយអង្គុយក៏បាន ទោះហែកអាសនៈដែលញាត់សំឡី យកមកធ្វើជាខ្នើយក៏បាន ដូច្នេះ គ្រឿងកម្រាលទាំងនេះ ទើបគួរដោយវិធីដូចគ្នា តែព្រោះអាស្រ័យវត្ថុដែលជាអកប្បិយ កម្រាលទាំងអស់នោះឯង ព្រះមានព្រះភាគត្រាស់ថា មិនសមគួរ ។ បទថា **វនន្តំយេវ បចារយាមិ** សេចក្តីថា តថាគតចូលកាន់ព្រៃនោះឯង ។

បទថា **យនេវ** គឺ **យានិយេវ** ប្រែថា ទាំងឡាយណា ។ បទថា **បល្លង្កំ អាភុជិត្វា** គឺអង្គុយឲ្យអាសនៈ និងភ្លៅជិតគ្នា ដោយជុំវិញ ( អង្គុយពត់ភ្នែន ) ។ បទថា **ឧជុំ កាយំ បណិធាយ** គឺតាំងកាយឲ្យត្រង់ ឲ្យឆ្អឹងខ្នងទាំង ១៨ ត្រួតលើគ្នា ។ បទថា **បរិមុខំ សតឹ ឧបដ្ឋបេត្វា** សេចក្តីថា តម្កល់សតិឆ្ពោះទៅកាន់កម្មដ្ឋាន ឬ ធ្វើការកំណត់ដោយការនាំចេញចាកទុក្ខឲ្យប្រាកដ ។ សមដូចពាក្យដែលលោកពោលដូច្នេះថា សព្ទថា **បរិ** មានអត្ថថា កំណត់ សព្ទថា **មុខំ** មានអត្ថថា នាំចេញ សព្ទថា **សតិ** មានអត្ថថា តាំងមាំ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា តាំងសតិចំពោះមុខ ។ បទថា **ឧបសម្បជ្ជ វិហរាមិ** សេចក្តីថា តថាគតបាន គឺធ្វើឲ្យប្រចក្ស ។

បទថា **ឯវម្ភូតោ** សេចក្តីថា តថាគតជាអ្នកដល់ព្រមដោយឈានណាមួយ ក្នុងបណ្តាឈាន មានបឋមជ្ឈានជាដើមយ៉ាងនេះ ។ បទថា **ទិព្វោ មេ ឯសោ តស្មឹ សមយេ ចង្កមោ ហោតិ** សេចក្តីថា ឯការចង្ក្រមរបស់តថាគត តថាគតដែលចូលរូបជ្ឈាន ៤ ដើរចង្ក្រម ឈ្មោះថា ជាការចង្ក្រមទិព្វ កាលតថាគតចេញអំពីសមាបត្តិ ដើរចង្ក្រម ការចង្ក្រមនោះ ឈ្មោះថា ជាការចង្ក្រមទិព្វដូចគ្នា ។ ក្នុងឥរិយាបថទាំងឡាយ មានការឈរជាដើម ក៏មានន័យនេះឯង ។ ក្នុងការនៅ ២ យ៉ាងក្រៅអំពីនេះ ក៏ដូចគ្នា ។ បទថា **សោ ឯវំ បជានាមិ រាគោ មេ បហីនោ** សេចក្តីថា ព្រះមានព្រះភាគកាលទ្រង់សម្តែងរាគៈ ដែលលះបានហើយ ដោយអរហត្តមគ្គ ត្រង់មហាពោធិបល្ល័ង្កនោះឯង ទើបត្រាស់ថា **សោ ឯវំ បជានាមិ រាគោ មេ បហីនោ**

ដូច្នេះ ។ ក្នុងបទដ៏សេស ក៏មានន័យនេះឯង ។ ម្យ៉ាងទៀត សួរថា ដោយបទនេះ ជាការត្រាស់ដល់អ្វី ។ ឆ្លើយថា ព្រះមានព្រះភាគ ត្រាស់ដល់ការពិចារណា គឺបច្ចវេក្ខណញ្ញាណ ។ ព្រះមានព្រះភាគ ត្រាស់ដល់ផលសមាបត្តិ ដោយការពិចារណា ពិតហើយ ឥរិយាបថ មានការចង្ក្រមជាដើម របស់ព្រះអរិយៈ ដែលចូលផលសមាបត្តិក្តី ដែលចេញចាកសមាបត្តិក្តី ឈ្មោះថា ជាការចង្ក្រមរបស់ព្រះអរិយៈជាដើម ។ បទដ៏សេសក្នុងសូត្រនេះ ងាយយល់ទាំងអស់ហើយ ៕

**អដ្ឋកថា វេធាគសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## សរភសូត្រទី ៤

[ ៦៦ ] សម័យមួយ ព្រះដ៏មានព្រះភាគ គង់លើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង សរភបរិព្វាជក ( បួសក្នុងព្រះពុទ្ធសាសនា ) ទើបតែនឹង ( សឹក ) ចាកធម្មវិន័យនេះ បរិព្វាជកនោះក៏ពោលពាក្យយ៉ាងនេះ ក្នុងបរិសទ្យក្នុងក្រុងរាជគ្រឹះថា ធម៌របស់ពួកសមណសក្យបុត្តិយ៍ អញបានដឹងច្បាស់ហើយ លុះអាត្មាអញ បានដឹងច្បាស់នូវធម៌របស់ពួកសមណសក្យបុត្តិយ៍ហើយ ទើបអាត្មាអញ សឹកចាកធម្មវិន័យនោះយ៉ាងនេះ ។ លំដាប់

នោះឯង ភិក្ខុច្រើនរូប ស្លៀកស្បង់ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ។ ភិក្ខុទាំងនោះ បានស្តាប់នូវវាចា ដែលសរភបរិព្វាជកពោលក្នុងបរិសទ្យ ក្នុងក្រុងរាជគ្រឹះយ៉ាងនេះថា ធម៌ របស់ពួកសមណសក្យបុត្តិយ៍ អញបានដឹងច្បាស់ហើយ លុះអាត្មាអញដឹង ច្បាស់នូវធម៌របស់សមណសក្យបុត្តិយ៍ហើយ ទើបអាត្មាអញសឹកចាកធម្ម-វិន័យនេះ ។ លំដាប់នោះឯង ភិក្ខុទាំងនោះត្រាច់ទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ កាលត្រឡប់ពីបិណ្ឌបាតក្នុងបច្ឆាភត្ត ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះ ចូលទៅដល់ហើយ បានថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទី សមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូល ព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សរភបរិព្វាជក ទើបនឹង សឹកចាកធម្មវិន័យនេះ គាត់ក៏ពោលនូវពាក្យក្នុងបរិសទ្យ ក្នុងក្រុងរាជគ្រឹះ យ៉ាងនេះថា ធម៌របស់ពួកសមណសក្យបុត្តិយ៍ អញបានដឹងច្បាស់ហើយ លុះអាត្មាអញបានដឹងច្បាស់ធម៌ របស់ពួកសមណសក្យបុត្តិយ៍ហើយ ទើប អាត្មាអញសឹកចាកធម្មវិន័យនោះ យ៉ាងនេះ បពិត្រព្រះអង្គដ៏ចម្រើន សូម ព្រះដ៏មានព្រះភាគចូលទៅជួបនឹងសរភបរិព្វាជក ក្នុងបរិព្វាជការាម ក្បែរ ឆ្នេរស្ទឹងឈ្មោះសប្បិនី ដោយសេចក្តីអនុគ្រោះ ។ ព្រះដ៏មានព្រះភាគទ្រង់ ទទួលដោយតុណ្ហីភាព ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ចេញចាកទី សម្ងំ ក្នុងសាយណ្ហសម័យ ហើយចូលទៅជួបនឹងសរភបរិព្វាជក ក្នុងបរិព្វាជ-ការាម ក្បែរឆ្នេរស្ទឹងឈ្មោះសប្បិនី លុះចូលទៅដល់ហើយ ទ្រង់គង់លើ

អាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគគង់ហើយ បានត្រាស់ទៅនឹងសរភបរិព្វាជកដូច្នេះថា ម្នាលសរភៈ ឮថា អ្នកនិយាយយ៉ាងនេះថា ធម៌របស់ពួកសមណសក្យបុត្តិយ៍ អាត្មាអញបានដឹងច្បាស់ហើយ លុះអាត្មាអញ បានដឹងច្បាស់ធម៌របស់ពួកសមណសក្យបុត្តិយហើយ ទើបអាត្មាអញសឹកចាកធម្មវិន័យនោះយ៉ាងនេះ ពិតមែនឬ ។ កាលព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ សរភបរិព្វាជក ក៏នៅស្ងៀម ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទៅនឹងសរភបរិព្វាជកអស់វារៈ ២ ដងថា ម្នាលសរភៈ អ្នកចូរនិយាយទៅមើលថា ដូចម្តេច ធម៌របស់ពួកសមណសក្យបុត្តិយ៍ អ្នកបានដឹងហើយ ប្រសិនបើមិនទាន់គ្រប់គ្រាន់ដល់អ្នកទេ តថាគតនឹងបំពេញឲ្យ តែបើគ្រប់គ្រាន់ដល់អ្នកហើយ តថាគតនឹងអនុមោទនា ។ សរភបរិព្វាជកក៏ស្ងៀមអស់វារៈ ២ ដង ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទៅនឹងសរភបរិព្វាជកអស់វារៈ ៣ ដងទៀតថា ម្នាលសរភៈ ធម៌របស់ពួកសមណសក្យបុត្តិយ៍ មានតែតថាគតទើបឲ្យប្រាកដបានថា ម្នាលសរភៈ អ្នកចូរនិយាយទៅមើលថា ដូចម្តេច ធម៌របស់ពួកសមណសក្យបុត្តិយ៍ ដែលអ្នកបានដឹងហើយ ប្រសិនបើមិនទាន់គ្រប់គ្រាន់ដល់អ្នកទេ តថាគតនឹងបំពេញឲ្យ តែបើគ្រប់គ្រាន់ដល់អ្នកហើយ តថាគតនឹងអនុមោទនា ។ សរភបរិព្វាជកក៏ស្ងៀមអស់វារៈ ៣ ដង ។ លំដាប់នោះ បរិព្វាជកទាំងនោះ បាននិយាយទៅនឹងសរភបរិព្វាជកដូច្នេះថា ម្នាលអាវុសោសរភៈ អ្នកគប្បីសូមនូវវត្ថុណា ចំពោះព្រះសមណគោតម ឯព្រះសមណគោតម ទ្រង់បវារណាវត្ថុនោះឯងដល់អ្នក ម្នាល

អាវុសោសរភៈ អ្នកចូរនិយាយទៅមើលថា ដូចម្ដេច ធម៌របស់ពួកសមណ-សក្យបុត្តិយ៍អ្នកបានដឹងហើយ ប្រសិនបើមិនទាន់គ្រប់គ្រាន់ដល់អ្នកទេ ព្រះសមណគោតមនឹងបំពេញឲ្យ តែបើគ្រប់គ្រាន់ដល់អ្នកហើយ ព្រះសមណ-គោតមនឹងទទួលអនុមោទនា ។ កាលបរិព្វាជកទាំងនោះ និយាយយ៉ាងនេះហើយ សរភបរិព្វាជកក៏នៅស្ងៀម មានមុខសំយុងចុះ មានកឱនចុះ មានមុខជ្រប់ចុះ ស្រពោនមុខ រកនិយាយតបតមកវិញមិនរួច ឡើយក៏អង្គុយទៅ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា សរភបរិព្វាជកនៅស្ងៀម មានមុខសំយុងចុះ មានកឱនចុះ មានមុខជ្រប់ចុះ ស្រពោន មិននិយាយតបហើយ ក៏ទ្រង់ត្រាស់ទៅនឹងបរិព្វាជកទាំងនោះដូច្នេះថា ម្នាលបរិព្វាជកទាំង-ឡាយ បុគ្គលណា ពោលចំពោះតថាគតយ៉ាងនេះថា ធម៌ទាំងនេះដែលព្រះអង្គជាសម្មាសម្ពុទ្ធ គ្រាន់តែប្ដេជ្ញា មិនទាន់បានត្រាស់ដឹងទេ តថាគតគប្បីសាកសួរដេញដោល ឈ្លេចឈ្លីមែនទែន ចំពោះបុគ្គលនោះ ក្នុងពាក្យដែលតថាគត បានសម្ដែងហើយនោះ បុគ្គលនោះឯង កាលបើត្រូវតថាគតសាកសួរ ដេញដោល ឈ្លេចឈ្លីមែនទែនក៏ឥតមានហេតុ ឥតមានឱកាសគួរនឹងឲ្យបុគ្គលនោះ មិនដល់នូវឋានៈ ៣ ឋានៈណាមួយ គឺបំបិទពាក្យដទៃដោយពាក្យដទៃ ឬនាំពាក្យពីខាងក្រៅចេញ ១ បញ្ចេញនូវសេចក្ដីក្រោធផងនូវទោសៈផង នូវអាការមិនត្រេកអរផង ១ មានសភាពស្ងៀម មានមុខសំយុងចុះ មានកឱនចុះ មានមុខជ្រប់ចុះ ស្រពោន រកនិយាយតបតមកវិញមិនរួច នឹងអង្គុយនៅ ១ ដូចជាសរភបរិព្វាជក ។ ម្នាលបរិព្វាជកទាំង-

ឡាយ បុគ្គលណាគប្បីពោលចំពោះតថាគតយ៉ាងនេះថា អាសវៈទាំងនេះ ដែលព្រះអង្គជាខីណាសវៈគ្រាន់តែប្តេជ្ញា មិនទាន់បានអស់រលីងទេ តថាគតគប្បីសាកសួរ ដេញដោល ឈ្លេចឈ្លីមែនទែន ចំពោះបុគ្គលនោះ ក្នុងពាក្យដែលតថាគតសម្តែងហើយនោះ បុគ្គលនោះឯង កាលបើត្រូវតថាគតសាកសួរ ដេញដោល ឈ្លេចឈ្លីមែនទែន ក៏ឥតមានហេតុ ឥតមានឱកាស គួរនឹងឲ្យបុគ្គលនោះ មិនដល់នូវឋានៈ ៣ ឋានៈណាមួយ គឺបំបិទពាក្យដទៃដោយពាក្យដទៃ ឬនាំពាក្យខាងក្រៅចេញ ១ បញ្ចេញនូវសេចក្តីក្រោធផង នូវទោសៈផង នូវអាការមិនត្រេកអរផង ១ មានសភាពស្ងៀម មានមុខសំយុងចុះ មានកឱនចុះ មានមុខជ្រប់ចុះ ស្រពោន រកនិយាយតបតមកវិញមិនរួច នឹងអង្គុយនៅ ១ ដូចជាសរកបរិព្វាជក ។ ម្នាលបរិព្វាជកទាំង-ឡាយ បុគ្គលណា គប្បីពោលចំពោះ តថាគតយ៉ាងនេះថា ធម៌ គឺសច្ចៈ ៤ ដែលព្រះអង្គសម្តែងហើយ ដើម្បីប្រយោជន៍ដល់មគ្គ និងផលណា ធម៌នោះមិនប្រព្រឹត្តទៅ ដើម្បីឲ្យអស់ទៅនៃទុក្ខដោយប្រពៃដល់បុគ្គលអ្នកធ្វើ ដើម្បីមគ្គផលនោះទេ តថាគតគប្បីសាកសួរ ដេញដោល ឈ្លេចឈ្លីមែនទែន ចំពោះបុគ្គលនោះ ក្នុងធម៌ដែលតថាគតសម្តែងហើយ បុគ្គលនោះឯង កាលបើត្រូវតថាគតសាកសួរ ដេញដោល ឈ្លេចឈ្លី មែនទែន ក៏ឥតមានហេតុ ឥតមានឱកាស គួរនឹងឲ្យបុគ្គលនោះ មិនដល់នូវឋានៈ ៣ ឋានៈណាមួយ គឺបំបិទពាក្យដទៃដោយពាក្យដទៃ ឬនាំពាក្យខាងក្រៅចេញ ១ បញ្ចេញនូវសេចក្តីក្រោធផង នូវទោសៈផង នូវអាការមិនត្រេកអរផង ១ មានសភាព

ស្មៀម មានមុខសំយុងចុះ មានកឱនចុះ មានមុខជ្រប់ចុះ ស្រពោន រក និយាយតបតមកវិញមិនរួច នឹងអង្គុយនៅ ១ ដូចជាសរភបរិព្វាជក ។ លំដាប់នោះ ព្រះមានព្រះភាគបន្លឺនូវសីហនាទអស់វារៈ ៣ ដង ក្នុងបរិព្វា-ជការាម ជិតច្នេរស្ទឹងសប្បិនី ហើយហោះទៅកាន់វេហាស៍ ។ កាលដែលព្រះដ៏មានព្រះភាគ ទ្រង់និមន្តមិនយូរប៉ុន្មាន បរិព្វាជកទាំងនោះ ក៏និយាយចាក់ដោតទៅនឹងសរភបរិព្វាជកដោយជន្ទញ គឺសម្ដីដោយជុំវិញថា ម្នាលអាវុសោសរភៈ ប្រៀបដូចជាចចកចាស់ក្នុងព្រៃធំ គិតថា អញនឹងបន្លឺនូវសីហនាទ ហើយក៏បន្លឺនូវសំឡេងជាសំឡេងចចកដដែល បន្លឺនូវសំឡេងក៏នៅជាសំឡេងស្អួដដែល យ៉ាងណាមិញ ម្នាលអាវុសោសរភៈ អ្នកវៀរចាកព្រះសមណគោតមចេញ គិតថា អញនឹងបន្លឺនូវសីហនាទ ហើយក៏បន្លឺដូចជាសំឡេងរបស់ចចកដែលបន្លឺនូវសំឡេង ក៏នៅជាសំឡេងស្អួដដែល យ៉ាងនោះដែរ ។ ម្នាលអាវុសោសរភៈ ប្រៀបដូចជាមាន់ញីគិតថា អញនឹងរងាវឲ្យដូចជាមាន់ឈ្មោល ហើយក៏រងាវជាសំឡេងមាន់ញីដដែល យ៉ាងណាមិញ ម្នាលអាវុសោសរភៈ អ្នកវៀរចាកព្រះសមណគោតមចេញ គិតថា អញនឹងរងាវឲ្យដូចជាមាន់ឈ្មោល ហើយរងាវជាសំឡេងមាន់ញីដដែល យ៉ាងនោះដែរ ។ ម្នាលអាវុសោសរភៈ ប្រៀបដូចគោបា សម្គាល់នូវសំឡេង ដែលខ្លួនគប្បីបន្លឺឡើងដ៏ខ្លាំងក្នុងរោងគោ ដែលមិនមានគោបា យ៉ាងណាមិញ ម្នាលអាវុសោសរភៈ អ្នកវៀរចាកព្រះសមណគោតមចេញ ហើយ សម្គាល់នូវសំឡេង ដែលខ្លួនគប្បីបន្លឺឡើងខ្លាំង ក៏យ៉ាងនោះដែរ ។

លំដាប់នោះ បរិព្វាជកទាំងនោះ ពោលពាក្យចាក់ដោតចំពោះសរភបរិព្វាជក ដោយជន្ទួញ គឺពាក្យដោយជុំវិញ ។

# អដ្ឋកថា

## សរភសូត្រ

[ ៦៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសរភសូត្រទី ៤ ដូចតទៅនេះ បទថា **រាជគហេ** បានដល់ ក្នុងនគរមានឈ្មោះយ៉ាងនេះ ។ បទថា **គិជ្ឈកូដេ បព្វតេ** សេចក្តីថា ភ្នំនោះមានកំពូលដូចសត្វត្មាត ម្យ៉ាងទៀត ឈ្មោះថា គិជ្ឈកូដ ព្រោះសត្វត្មាតនៅលើកំពូលរបស់ភ្នំនោះ ។ ទ្រង់គង់ត្រង់ភ្នំគិជ្ឈ-កូដនោះ ។ ដោយបទថា **គិជ្ឈកូដេ** នេះ លោកសម្តែងដល់ទីប្រថាប់របស់ព្រះមានព្រះភាគ ដែលទ្រង់នៅប្រថាប់ ដោយយកក្រុងរាជគ្រឹះជាគោចរគាម ។ អធិប្បាយថា មហាជនសាងវិហារថ្វាយព្រះតថាគតលើភ្នំគិជ្ឈកូដ ដូច្នោះ ពាក្យថា **គិជ្ឈកូដវិហារោ** ទើបជាឈ្មោះរបស់វិហារនោះ ក្នុងសម័យនោះ បរិព្វាជក ឈ្មោះថា សរភៈនេះនៅក្នុងទីនោះ ដូច្នេះឯង ។

បទថា **សរភោ នាម បរិព្វាជកោ អចិរបក្កន្តោ ហោតិ** សេចក្តីថា បរិព្វាជកមានឈ្មោះយ៉ាងនេះថា សរភៈ បួសហើយក្នុងសាសនានេះ មិនយូរក៏ឃ្លាតចេញទៅ អធិប្បាយថា មិនយូរក៏សឹក ។ ពិតហើយ កាលព្រះសម្មា-

សម្ពុទ្ធទ្រង់កើតឡើងក្នុងលោក ពួកតិរ្ថិយនាំគ្នាសាបសូន្យលាភសក្ការៈ ។ លាភសក្ការៈជាច្រើនកើតឡើងដល់ព្រះរតនត្រ័យ ដូចព្រះធម្មសង្គាហកាចារ្យពោលថា សម័យនោះឯង ព្រះមានព្រះភាគ ជាបុគ្គលដែលជនទាំងឡាយធ្វើសក្ការៈ គោរព ឱនលំទោន បូជា កោតក្រែង ហើយជាអ្នកបានទទួលបរិក្ខារ គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានបច្ចយភេសជ្ជៈ ឯអន្យតិរ្ថិយ និងបរិព្វាជកទាំងឡាយ មិនមានបុគ្គលធ្វើសក្ការៈ គោរពរាប់អានបូជា និងធ្វើការកោតក្រែង មិនបានទទួលបរិក្ខារ គឺចីវរ បិណ្ឌបាតសេនាសនៈ និងគិលានបច្ច័យភេសជ្ជ ដូច្នេះ ។

អន្យតិរ្ថិយប្រមាណ ៥០០ នាក់នោះ ជាអ្នកវិនាសចាកលាភ និងសក្ការៈយ៉ាងនេះ ណាត់គ្នាប្រជុំក្នុងអារាមរបស់បរិព្វាជកមួយកន្លែង ពិភាក្សាគ្នាថា អ្នកដ៏ចម្រើនទាំងឡាយ ចាប់តាំងអំពីកាលដែលព្រះសមណគោតមកើតឡើងហើយ ពួកយើងក្លាយជាអ្នកសាបសូន្យចាកលាភសក្ការៈ អ្នកទាំងឡាយចូរ ពិចារណារកទោសរបស់ព្រះសមណគោតម និងសាវករបស់ព្រះសមណគោតមណាមួយ ពង្រីកទោសកំហុសចេញទៅ តិះដៀលពាក្យប្រៀនប្រដៅរបស់ព្រះសមណគោតមនោះ ហើយនឹងញុំាងលាភសក្ការៈឲ្យកើតឡើងដល់ពួកយើងទាំងឡាយ អន្យតិរ្ថិយទាំងនោះ កាលសម្លឹងមើលទោស បានពោលថា ពួកយើងមិនអាចនឹងមើលឃើញទោសរបស់ព្រះសមណគោតមក្នុងទី ៤ ស្ថាន គឺក្នុងទ្វារ ៣ និងអាជីវៈ ១ បានឡើយ អ្នកទាំងឡាយចូរលះឋានៈទាំង ៤ សិន ហើយសម្លឹងមើលឋានៈដទៃ ។ គ្រា

នោះ ក្នុងវាំងពួកតិរ្ថិយទាំងនោះ តិរ្ថិយម្នាក់ពោលឡើងយ៉ាងនេះថា ខ្ញុំមិនឃើញឧបាយដទៃ តែសមណៈទាំងនេះ ចុះប្រជុំគ្នារៀងរាល់កន្លះខែ បិទទ្វារ បិទបង្អួច មិនឲ្យសូម្បីតែសាមណេរចូលទៅ សូម្បីឧបដ្ឋាក ដែលជាអ្នកជិតស្និទ្ធ ក៏មិនបានឃើញ សមណៈទាំងនេះ រាយមាយាមន្ត ដែលធ្វើឲ្យមនុស្សវង្វេង ហើយធ្វើឲ្យមនុស្សត្រឡប់ចិត្ត ចុះចូលជាបក្ខពួក បើយើងទាំងឡាយអាចនាំយកមាយាមន្តដែលធ្វើឲ្យមនុស្សវង្វេងនោះមកបាន ដោយឧបាយនេះ លាភសក្ការៈដ៏ឱឡារ នឹងមានដល់ពួកយើង ។ សូម្បីតិរ្ថិយម្នាក់ទៀត ក៏បានក្រោកឡើងពោលយ៉ាងនោះដូចគ្នា ។ តិរ្ថិយទាំងអស់មានវាទៈតែមួយដូចគ្នា ។ បន្ទាប់ពីនោះ តិរ្ថិយទាំងអស់ពោលថា អ្នកណាអាចនាំយកមន្តនោះមកបាន ពួកយើងនឹងតែងតាំងឲ្យធ្វើជាប្រធាន ក្នុងលទ្ធិរបស់ពួកយើងទាំងឡាយ ។

លំដាប់នោះ ពួកតិរ្ថិយសួរគ្នា តាំងអំពីមនុស្សចុងក្រោយឡើងទៅថា អ្នកអាចទេ អ្នកអាចទេ កាលមនុស្សចំណែកច្រើនឆ្លើយថា ខ្ញុំមិនអាច ខ្ញុំមិនអាច ទើបនាំគ្នាសួរសេរកបរិព្វាជកថា នៃលោកអាចារ្យ លោកអាចារ្យអាចឬទេ គាត់ឆ្លើយថា ការនាំមាយាមន្តនេះមក មិនមែនជារឿងធ្ងន់ទេ បើពួកអ្នកគោរពតាមពាក្យសម្តីរបស់ខ្លួន តែងតាំងខ្ញុំឲ្យជាប្រធាននោះ ពួកតិរ្ថិយពោលថា កុំទើសទាល់ចិត្តឡើយលោកអាចារ្យ សូមលោកអាចារ្យនាំមន្តមកចុះ កាលធ្វើស្រេចហើយ ពួកខ្ញុំនឹងតែងតាំងឲ្យធ្វើជាប្រធានពិត ។ គាត់ពោលថា បុគ្គលនាំមាយាមន្តនោះមកបាន មិនមែនអាចនាំមកបានដោយការលួច ឬការប្លន់ តែត្រូវធ្វើជាបក្ខពួកជាមួយសាវ័ករបស់ព្រះគោតម គឺត្រូវថ្វាយបង្គំ

សាវករបស់ព្រះសមណគោតម ធ្វើវត្តបដិបត្តិ បរិភោគអាហារក្នុងបាត្រ របស់សាវកនៃព្រះសមណគោតមទាំងនោះ ទើបអាចនាំមកបាន កិរិយា របស់បុគ្គលដូច្នេះនោះ ពួកអ្នកពេញចិត្តឬ តិរ្ថិយទាំងឡាយឆ្លើយថា សូម លោកអាចារ្យធ្វើបែបណាមួយនាំមកប្រគល់ឲ្យពួកយើង ។ សរភបរិព្វាជក បានឲ្យសញ្ញាដល់បរិព្វាជកទាំងឡាយថា បើដូច្នោះ អ្នកទាំងឡាយឃើញខ្ញុំ ហើយ ត្រូវធ្វើដូចជាមិនឃើញ ហើយក្នុងថ្ងៃទី ២ ទើបក្រោកឡើងអំពី ព្រលឹម ចូលទៅកាន់មហាវិហារឈ្មោះគិជ្ឈកូដ ថ្វាយបង្គំភិក្ខុទាំងឡាយ ដែលខ្លួនឃើញហើយ ដោយបញ្ចង្គប្រតិស្ឋាន ភិក្ខុទាំងឡាយនិយាយគ្នាថា តិរ្ថិយដទៃរឹងត្អឹង គ្រោតគ្រាត តែតិរ្ថិយនេះ ប្រហែលជាអ្នកមានសទ្ធា មានសេចក្ដីជ្រះថ្លាហើយ ។ គាត់ពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ ទាំងឡាយបួសហើយ ក្នុងសម្នាក់ដ៏សមគួរនោះឯង ព្រោះដឹងល្អហើយ ឯខ្ញុំមិនបានពិចារណា ទើបសោត់ទៅខុសកំពង់ ទើបត្រាច់ទៅខុសទិសដៅ ដែលមិនបាននាំសត្វចេញចាកទុក្ខ ។ កាលគាត់ពោលយ៉ាងនេះហើយ ថ្វាយ បង្គំភិក្ខុគ្រប់រូបដែលខ្លួនឃើញហើយ ត្រៀមទឹកសម្រាប់ងូតជាដើម ធ្វើឈើ ស្ទន់ឲ្យជាកប្បិយ លាងជើង លាបប្រេង បានភត្តដែលសេសសល់ ហើយ បរិភោគ ។

ព្រះមហាថេរៈមួយរូប ឃើញគាត់ដោយទំនងនេះ ទើបពោលថា អ្នក មានសទ្ធាជ្រះថ្លាហើយ ម្ដេចមិនបួស គាត់ឆ្លើយថា បពិត្រលោកម្ចាស់ អ្នក ណាគេនឹងបំបួសខ្ញុំ ព្រោះពួកខ្ញុំប្រព្រឹត្តខ្លួនជាសត្រូវចំពោះលោកម្ចាស់ទាំង-

ឡាយ មកអស់កាលដ៏យូរ ។ ព្រះថេរៈពោលថា បើអ្នកបំណងនឹងបួស អាត្មាក៏នឹងបំបួស ហើយឲ្យគាត់បំពេញបព្វជ្ជា ។ រាប់អំពីវារៈដែលបួសហើយ បានធ្វើវត្តប្រតិបត្តិជានិច្ច ព្រះថេរៈពេញចិត្តក្នុងវត្តបដិបត្តិ មិនយូរប៉ុន្មាន ក៏ឲ្យឧបសម្បទា ។ ក្នុងថ្ងៃឧបសម្បទា លោកចូលកាន់រោងឧបោសថ មួយអន្លើដោយភិក្ខុទាំងឡាយ ឃើញភិក្ខុទាំងឡាយ លើកតម្កើងបាតិមោក្ខ ដោយឧស្សាហៈច្រើន ទើបគិតថា ភិក្ខុទាំងនេះរាយមាយាមន្ត ដែលធ្វើឲ្យមនុស្សវង្វេងហើយ ធ្វើឲ្យប្រែចិត្តចូលជាបក្ខពួក ។ ២-៣ ថ្ងៃទៀត ប៉ុណ្ណោះ អញនឹងសូត្របាន លោកទៅកាន់បរិវេណ ថ្វាយបង្គំព្រះឧបជ្ឈាយ៍ហើយ សាកសួរថា បពិត្រលោកម្ចាស់ ធម៌នេះ ឈ្មោះអ្វី ឧបជ្ឈាយ៍ឆ្លើយថា ឈ្មោះបាតិមោក្ខ ។ បពិត្រលោកម្ចាស់ បាតិមោក្ខនេះ ជាធម៌ដ៏ឧត្តមឬ ព្រះថេរៈពោលថា ត្រូវហើយ សិក្ខានេះទ្រទ្រង់ទុកបាននូវសាសនធម៌ទាំងអស់ សរភៈពោលថា បើធម្មសិក្ខានេះ ជាធម៌ឧត្តុង្គឧត្តមសោត ខ្ញុំនឹងរៀនយកធម្មសិក្ខានេះឯង ។ ព្រះថេរៈទទួលពាក្យថា រៀនចុះ ។ លោកកំពុងរៀន ជួបបរិព្វាជកទាំងឡាយ បរិព្វាជកសួរថា ដូចម្ដេចទៅហើយ លោកអាចារ្យ ទើបប្រាប់ថា ពួកអ្នកកុំគិតថ្វីឡើយ ២-៣ ថ្ងៃទៀត ខ្ញុំនឹងនាំទៅឲ្យ ។ មិនយូរក៏រៀនចប់ ហើយនិយាយនឹងឧបជ្ឈាយ៍ថា ធម្មសិក្ខានេះមានត្រឹមប៉ុណ្ណោះ ឬ ឬមានដទៃទៀត ។ ព្រះថេរៈឆ្លើយថា មានប៉ុណ្ណោះឯង ។ ក្នុងថ្ងៃស្អែក លោកស្លៀកដណ្ដប់តាមប្រក្រតី កាន់បាត្រតាមទំនងដែលធ្លាប់កាន់ ហើយចេញអំពីអារាមឈ្មោះគិជ្ឈកូដ ទៅកាន់អារាមរបស់បរិព្វាជកៗ ទាំងឡាយ

ឃើញហើយ នាំគ្នាចោមរោម សួរថា ដូចម្តេចទៅហើយ លោកអាចារ្យ ប្រហែលជាមិនអាចនាំមាយាមន្ត ដែលធ្វើឲ្យមនុស្សវង្វេងមកបានទេដឹង ។ គាត់ឆ្លើយថា កុំទើសទាល់ចិត្តឡើយ អាវុសោទាំងឡាយ មាយាមន្តដែលធ្វើឲ្យមនុស្សវង្វេង ខ្ញុំនាំមកបានហើយ តាំងអំពីនេះទៅ យើងទាំងឡាយ នឹងមានលាភសក្ការៈច្រើន អ្នកទាំងឡាយ ចូរសាមគ្គីគ្នា កុំឈ្លោះ កុំវិវាទគ្នា បរិព្វាជកទាំងឡាយពោលថា បពិត្រលោកអាចារ្យ បើលោករៀនបានមកហើយ ក៏ចូរប្រាប់មាយាមន្តដែលធ្វើឲ្យមនុស្សវង្វេងនោះដល់ពួកខ្ញុំផង ។ គាត់សូធ្យបាតិមោក្ខតាំងអំពីដើមដល់ចប់ ។ គ្រានោះ បរិព្វាជកទាំងឡាយនោះនិយាយគ្នាថា នែអ្នកដ៏ចម្រើនទាំងឡាយ មកពួកយើងនឹងចូលទៅក្នុងព្រះនគរ ពោលទោសរបស់ព្រះសមណគោតម កាលទ្វារក្រុងមិនទាន់បើក នាំគ្នាទៅជិតទ្វារ ចូលទៅមុនជនទាំងពួង ពេញផ្លូវដែលបើកហើយ ។ ពាក្យថា **សរភោ ឆាម បរិព្វាជកោ អចិរបក្កន្តោ ហោតិ** ដូច្នេះ លោកពោលដល់បរិព្វាជកនោះ ដែលលបគេចទៅទាំងភេទរបស់ខ្លួនយ៉ាងនេះ ។

ក្នុងថ្ងៃនោះ ព្រះមានព្រះភាគទ្រង់ប្រមើលមើលសត្វលោក ក្នុងវេលាជិតភ្លឺ បានឃើញហេតុនេះថា ថ្ងៃនេះ សរកបរិព្វាជកដើរទៅក្នុងព្រះនគរហើយធ្វើបកាសនីយកម្ម កាលគេពោលពាក្យតិះដៀលព្រះរតនត្រ័យ ឈ្មោះថា បាចទូវថ្នាំពិស ហើយទៅកាន់អារាមនៃបរិព្វាជក ឯតថាគត ក៏នឹងទៅក្នុងទីនោះដូចគ្នា បរិស័ទទាំង ៤ នឹងប្រជុំគ្នាក្នុងអារាមរបស់បរិព្វាជកនោះឯងក្នុងសមាគមនោះ មនុស្សប្រមាណ ៨៤០០០ នាក់ បានផឹកនូវទឹកអម្រឹត ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រិះរិះថា សរភបរិព្វាជក ចូរមានឱកាស ចូរប្រកាសទោសតាមពេញចិត្ត ហើយត្រាស់ហៅព្រះអានន្ទមកថា ម្នាលអានន្ទ អ្នកចូរទៅប្រាប់ភិក្ខុសង្ឃ ក្នុងមហាវិហារទាំង ១៨ កន្លែង ឲ្យទៅបិណ្ឌបាតជាមួយតថាគត ។ ព្រះអានន្ទបានបដិបត្តិដូច្នោះហើយ ។ ភិក្ខុទាំងឡាយ កាន់បាត្រ ចីវរ ចោមរោមព្រះតថាគត ហើយត្រាច់ទៅ ព្រះសាស្តាទ្រង់នាំភិក្ខុសង្ឃទៅបិណ្ឌបាតឯស្រុក ជិតព្រះនគរ ឯសរភបរិព្វាជកចូលទៅកាន់ព្រះនគរ មួយអន្លើដោយបរិព្វាជកទាំងឡាយ កាលដល់កណ្តាលពួកបរិស័ទ ទ្វារព្រះរាជវាំង ទ្វារផ្ទះអមាត្យ និងផ្លូវដែលមានមុំ ៤ ជាដើម បានប្រកាសថា ធម៌របស់ពួកសមណសក្យបុត្រទាំងឡាយ ខ្ញុំចេះអស់ហើយ ដូច្នេះជាដើម ក្នុងទីនោះៗ ។ ពាក្យជាដើមថា **សោ រាជគហេ បរិសតិ ឯវំ វាចំ ភាសតិ** នេះ លោកពោលសំដៅដល់ការពោលទោសនោះ ។ បណ្តាបទទាំងនោះ បទថា **អញ្ញាតោ** សរភបរិព្វាជកសម្តែងថា ធម៌របស់ពួកសមណសក្យបុត្រ ខ្ញុំដឹងហើយ គឺយល់ហើយ បានដល់ រៀនឲ្យជាក់ច្បាស់ហើយ ។ បទថា **អញ្ញាយ** ប្រែថា ដឹងហើយ ។ បទថា **អបក្កន្តោ** បានដល់ ចៀសចេញទៅទាំងដែលនៅទ្រទ្រង់ភេទនោះឯង ។ សរភបរិព្វាជកនោះកាលនឹងសម្តែងសេចក្តីនេះ ទើបពោលពាក្យយ៉ាងនេះថា បើសាសនារបស់ព្រះសមណគោតម នឹងមានសារៈអ្វីខ្លះហើយសោត ខ្ញុំក៏មិនចៀសចេញទៅ តែសាសនារបស់ព្រះសមណគោតមនោះ ឥតសារៈ មិនមានខ្លឹមសារ សមណៈទាំងឡាយរាយមាយាមន្ត ដែលធ្វើឲ្យមនុស្សវង្វេង ទើបបោក

បញ្ឆោតសត្វលោកបាន ។

បទថា **អថ ខោ សម្ពហុលា ភិក្ខូ** សេចក្ដីថា កាលនោះបរិព្វាជកនោះ ពោលយ៉ាងនេះ ភិក្ខុខាងអារញ្ញវាសី ៥០០ រូប មិនដឹងថា ព្រះសាស្ដាយាងទៅបិណ្ឌបាតក្នុងទីឈ្មោះនោះ ទើបចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ក្នុងគ្រាភិក្ខាចារ ។ ពាក្យថា **អថ ខោ សម្ពហុលា ភិក្ខូ** នេះ លោកពោលសំដៅភិក្ខុទាំងនោះ ។ បទថា **អស្សោសុំ** ប្រែថា បានឮហើយ ។ បទថា **យេន ភគវា តេនុបសង្កមិ** សេចក្ដីថា ចូលទៅដោយតាំងចិត្តថា ពួកយើងនឹងក្រាបទូលរឿងនេះដល់ព្រះទសពល ។ បទថា **សប្បិនិកា តីរំ** បានដល់ ច្រាំងស្ទឹង ដែលមានឈ្មោះយ៉ាងនេះថា សប្បិនិកា ។

បទថា **អធិវាសេសិ ភគវា តុណ្ហីភាវេន** អធិប្បាយថា ទ្រទ្រង់នូវខន្តីខាងក្នុង ទ្រង់ទទួលដោយចិត្តតែម្យ៉ាង ដោយទ្រង់មិនកម្រើកព្រះកាយនិងវាចា ។ ព្រះមានព្រះភាគ កាលទ្រង់ទទួលជ្រាបដោយតុណ្ហីភាពយ៉ាងនេះហើយ ទ្រង់ព្រះតម្រិះតទៅថា ថ្ងៃនេះ តថាគតកាលនឹងកាច់បំបាក់នូវវាទៈនៃសរភបរិព្វាជក គួរទៅម្នាក់ឯង ឬមានភិក្ខុសង្ឃចោមរោមទៅផងហ្ន៎ ។ គ្រានោះ ទ្រង់ដាក់ព្រះហឫទ័យដូច្នេះថា បើតថាគតមានភិក្ខុសង្ឃចោមរោមទៅមហាជននឹងពោលយ៉ាងនេះថា ព្រះសមណគោតមកាលនឹងចូលទៅកាន់ទីដែលលើកវាទៈ ក៏ចាំបាច់លើកគ្នីគ្នាទៅ ប្រើកម្លាំងរបស់បរិស័ទ កាច់វាទៈដែលកើតឡើងហើយ មិនឲ្យភាគីម្ខាងងើបក្បាលឡើងបានឡើយ កាលវាទៈកើត

ឡើងដល់តថាគតហើយ កិច្ច គឺការលើកភារៈដោយនាំអ្នកដទៃទៅផង មិនមានដល់តថាគតឡើយ តថាគតម្នាក់ឯងប៉ុណ្ណោះ ដែលនឹងទៅកាច់បំបាក់ភារៈនោះ ។ ការដែលតថាគតជាព្រះពុទ្ធ កាច់ភារៈដែលកើតឡើងដល់ខ្លួនក្នុងបច្ចុប្បន្ននេះ មិនជារបស់អស្ចារ្យឡើយ ក្នុងវេលាដែលតថាគតបំពេញពុទ្ធចរិយា អ្នកដទៃដែលអាចនាំធុរៈជំនួសតថាគត សូម្បីកាលកើតក្នុងអហេតុកបដិសន្ធិ មិនធ្លាប់មានឡើយ ។ ដើម្បីញុំាងសេចក្ដីនេះឲ្យជាក់ច្បាស់ គួរនាំកណ្ហជាតកមកសម្ដែង ដូច្នេះ

**យតោ យតោ គរុ ធុរំ យតោ គម្ភីរវត្តនិ**
**តទាស្សុ កណ្ហំ យុញ្ជន្តិ ស្វាស្សុ តំ**
**វហតេ ធុរំ។**

ធុរៈធ្ងន់ ក្នុងទីណាៗ ផ្លូវដ៏ជ្រៅក្នុងទីណា កាលនោះ
ឯង ពួកជននាំគ្នាទឹមគោឈ្មោះកណ្ហៈ គោឈ្មោះ
កណ្ហៈនោះ ក៏អូសនូវធុរៈដ៏ធ្ងន់នោះទៅបាន ។

# រឿងគោកាឡក

បានឮថា ក្នុងអតីត សម័យឈ្មួញរទេះម្នាក់ ស្នាក់នៅក្នុងផ្ទះរបស់ស្រីចាស់ម្នាក់ ។ គ្រានោះ មេគោមួយរបស់គាត់បានកើតកូនក្នុងពេលយប់ជាកូនគោឈ្មោលមួយ ។ ចាប់តាំងពីស្រីចាស់ឃើញកូនគោហើយ កើតសេចក្ដីស្រឡាញ់ដូចកូនបង្កើត ។ ក្នុងថ្ងៃស្អែកឡើង កូនរបស់ឈ្មួញរទេះពោលថា សូមលោកយាយទទួលថ្លៃឈ្នួលផ្ទះរបស់លោកយាយចុះ ។ ស្រី

ចាស់ពោលថា ខ្ញុំមិនត្រូវការរបស់ដទៃ សូមអ្នកឲ្យកូនគោនេះដល់ខ្ញុំចុះ ។ កូនឈ្មួញរទេះពោលថា សូមលោកយាយទទួលចុះ ។ ស្រីចាស់ទទួលកូនគោហើយ ឲ្យផឹកទឹកជោះ ឲ្យបបរ កត្ត និងស្មៅជាដើម ចិញ្ចឹមរក្សាហើយ ។ កូនគោចម្រើនធំធាត់ឡើង មានរូបរាងធាត់ សម្បូរដោយកម្លាំង និងសេចក្ដីព្យាយាមដល់ព្រមដោយអាចារ មានឈ្មោះថា កាឡក: ។ ក្នុងកាលបន្ទាប់មក កាលឈ្មួញរទេះម្នាក់ទៀត ធ្វើដំណើរមក មួយអន្លើដោយរទេះ ៥០០ កង់រទេះជាប់គក់ ក្នុងទីដែលមានទឹកជ្រោះ គាត់ព្យាយាមទឹមគោ ១០ ខ្ទះ ២០ ខ្ទះ ក៏មិនអាចទាញរទេះឡើងបាន ទើបចូលទៅរកគោកាឡក: ពោលថា នែបា ខ្ញុំនឹងឲ្យរង្វាន់ដល់អ្នក ចូរអ្នកទាញរទេះរបស់ខ្ញុំផងចុះ កាលពោលយ៉ាងនេះហើយ ក៏នាំគោកាឡក:នោះទៅ គិតថា គោដទៃ អាចអូសទឹមនាំទៅមួយអន្លើដោយរទេះនេះមិនមាន ទើបចងខ្សែត្រង់នឹមរទេះ ហើយទឹមគោកាឡក:នោះតែមួយ គោកាឡក:អូសរទេះនោះឡើងទៅដាក់លើគោក ។ នាំរទេះទាំង ៥០០ ឡើងទៅបានដោយទំនងនេះឯង ។ គោនោះនាំរទេះចុងក្រោយឡើងបានហើយ ឈ្មួញក៏ដោះចេញអំពីនឹម អើតក្បាលឡើង សម្ដែងអាការនឿយហត់ ។ ឈ្មួញរទេះគិតថា គោកាឡក:នេះ កាលអូសរទេះមានប្រមាណប៉ុណ្ណេះឡើងបាន មិនធ្លាប់ធ្វើយ៉ាងនេះ ប្រហែលគោនេះទារថ្លៃឈ្នួល ទើបខ្ចប់កហាបណ: ស្មើនឹងចំនួនរទេះ ខ្ចប់ប្រាក់ ៥០០ កហាបណ: ដាក់ត្រង់កគោនោះ ។ គោនោះមិនឲ្យអ្នកដទៃចូលជិត ដើរតម្រង់ទៅកាន់ផ្ទះនោះឯង ។ ស្រីចាស់ឃើញហើយ ក៏ស្រាយចេញ ដឹងថា ជាកហាបណ:

ទើបពោលថា នែកូន ហេតុអ្វី ទើបកូនធ្វើយ៉ាងនេះ ឯងយល់ថា ម៉ែរស់នៅបានដោយទ្រព្យដែលកូនធ្វើការ ហើយនាំមកឲ្យឬ ដូច្នេះហើយ លាងគោដោយទឹកក្ដៅ លាបខ្លួនដោយប្រេង ហើយពោលទូន្មានថា តទៅ កូនកុំធ្វើយ៉ាងនេះឡើយ ។ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា ក្នុងកាលដែលតថាគតបំពេញពុទ្ធចរិយា អ្នកដទៃ ឈ្មោះថា អាចនាំធុរៈជំនួសតថាគតដែលកើតហើយ ក្នុងអហេតុកបដិសន្ធិ មិនធ្លាប់មាន ដូច្នេះ ទ្រង់សំដៅដល់រឿងដែលពោលមកនេះឯង ទើបយាងទៅមួយព្រះអង្គឯង ។

កាលទ្រង់សម្ដែងរឿងនោះ ទើបលោកពោលពាក្យជាដើមថា **អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ** ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **បដិសល្លានា** សេចក្ដីថា ទ្រង់សង្រួមចិត្តចាកអារម្មណ៍គ្រោតគ្រាតទាំងឡាយ អធិប្បាយថា ចេញអំពីផលសមាបត្តិ ។ បទថា **តេនុប-សង្កមិ** សេចក្ដីថា កាលបរិព្វាជកទាំងឡាយ ធ្វើបកាសនីយកម្មពេញព្រះនគរ ហើយចេញចាកព្រះនគរ ទៅប្រជុំគ្នាត្រង់អារាមរបស់បរិព្វាជក អង្គុយសន្ទនាគ្នាដល់សីហនាទកថាយ៉ាងនេះថា បរិព្វាជកទាំងឡាយសួរថា នែសរភៈ បើព្រះគោតមយាងមកសោត អ្នកនឹងធ្វើដូចម្ដេច សរភបរិព្វាជកឆ្លើយថា ខ្ញុំនឹងធ្វើយ៉ាងនេះ គឺកាលព្រះសមណគោតមបន្លឺសីហនាទ ១ ខ្ញុំនឹងបន្លឺ ២ បើព្រះសមណគោតមបន្លឺ ២ ខ្ញុំនឹងបន្លឺ ៤ បើព្រះសមណគោតមបន្លឺ ៤ ខ្ញុំនឹងបន្លឺ ៥ បើព្រះសមណគោតមបន្លឺ ៥ ខ្ញុំនឹងបន្លឺ ១០ បើព្រះសមណ-គោតមបន្លឺ ១០ ខ្ញុំនឹងបន្លឺ ២០ បើព្រះសមណគោតមបន្លឺ ២០ ខ្ញុំនឹងបន្លឺ

៣០ បើព្រះសមណគោតមបន្ទឹ ៣០ ខ្ញុំនឹងបន្ទឹ ៤០ បើព្រះសមណគោតមបន្ទឹ ៤០ ខ្ញុំនឹងបន្ទឹ ៥០ បើព្រះសមណគោតមបន្ទឹ ៥០ ខ្ញុំនឹងបន្ទឹ ១០០ បើព្រះសមណគោតមបន្ទឹ ១០០ ខ្ញុំនឹងបន្ទឹ ១០០០ ដូច្នេះ ព្រះមានព្រះភាគយាងចូលទៅហើយ ។

ព្រះមានព្រះភាគ កាលយាងចូលទៅ ទ្រង់ស្បៀកសំពត់ ២ ជាន់ដែលគេជ្រលក់ល្អហើយ ទ្រង់ដណ្ដប់សុគតមហាចីវរ បានយាងចូលទៅមួយព្រះអង្គឯង ត្រង់កណ្ដាលព្រះនគរ ដូចព្រះរាជាប្រាសចាកពលនិករ ព្រោះផ្លូវទៅអារាមរបស់បរិព្វាជក ដែលនៅកណ្ដាលព្រះនគរ មិច្ឆាទិដ្ឋិកបុគ្គលទាំងឡាយឃើញហើយ នាំគ្នាតាមទៅដោយគិតថា បរិព្វាជកទាំងឡាយ នឹងធ្វើបកាសនីយកម្ម ប្រារព្ធទោសរបស់ព្រះសមណគោតម ប្រហែលជាទ្រង់យាងទៅដើម្បីឲ្យបរិព្វាជកទាំងនោះយល់ស្របតាម ។ ឯពួកសម្មាទិដ្ឋិកបុគ្គលក៏នាំគ្នាដើរតាមទៅ ដោយគិតថា ព្រះសម្មាសម្ពុទ្ធទ្រង់កាន់យកបាត្រ និងចីវរយាងទៅមួយព្រះអង្គឯងប៉ុណ្ណោះ ថ្ងៃនេះ ប្រហែលជាមានមហាធម្មសង្គ្រាមជាមួយសរភបរិព្វាជក ពួកយើងទាំងឡាយ ក៏នឹងរួមគ្នាធ្វើជាបន្ទាល់ក្នុងសមាគមនោះ ។ កាលមហាជនកំពុងមើលនោះឯង ព្រះបរមសាស្ដាយាងចូលទៅកាន់អារាមរបស់បរិព្វាជកហើយ ។

បរិព្វាជកទាំងឡាយ ឃើញព្រះឆព្វណ្ណរង្សីរបស់ព្រះសម្មាសម្ពុទ្ធជាដុំៗផ្សាយធ្លងដើម ប្រគាប និងមែកនៃដើមឈើទាំងឡាយ ទើបនាំគ្នាងៀងមើលដោយគិតថា ក្នុងថ្ងៃដទៃៗ មិនធ្លាប់មានឱភាសបែបនេះឡើយ នេះអ្វីហ្ន៎ ។

សរកបរិព្វាជកស្តាប់ពាក្យនោះហើយ ក៏ឱនមុខចុះ ដាក់ក្បាលក្នុងរវាងជើង ។ ក្នុងសម័យនោះ ព្រះមានព្រះភាគ កាលយាងចូលទៅកាន់អារាមនោះយ៉ាងនេះហើយ ទ្រង់ប្រថាប់គង់លើអាសនៈដែលគេក្រាលហើយ ពិតហើយ ព្រះតថាគតទ្រង់គួរដល់អាសនៈ ព្រោះទ្រង់កើតឡើងក្នុងត្រកូលខ្ពស់ លើផ្ទៃជម្ពូទ្វីប ។ ក្នុងទីគ្រប់កន្លែង គេតែងរៀបចំអាសនៈសម្រាប់ព្រះអង្គ ដោយចំពោះព្រះមានព្រះភាគ ប្រថាប់គង់លើពុទ្ធាសនៈ មានតម្លៃច្រើន ដែលគេក្រាលហើយយ៉ាងនេះ ។

បទថា **តេ បរិព្វាជកា សរភំ បរិព្វាជកំ ឯតទវោចុំ** សេចក្តីថា បានឮថា កាលព្រះសម្មាសម្ពុទ្ធត្រាស់ពាក្យមានប្រមាណប៉ុណ្ណេះ ជាមួយនឹងសរកបរិព្វាជកនោះឯង ភិក្ខុសង្ឃដែលតាមព្រះយុគលបាទរបស់ព្រះសាស្តា ក៏មកដល់អារាមរបស់បរិព្វាជក បរិស័ទទាំង ៤ ប្រជុំគ្នាហើយ ក្នុងបរិព្វា-ជការាមនោះឯង ។ លំដាប់នោះ បរិព្វាជកទាំងនោះគិតថា គួរអស្ចារ្យដែលព្រះសមណគោតមបានយាងមកកាន់សម្នាក់របស់ពួកយើង ដែលត្រាច់ទៅផ្សាយទោស ធ្វើបកាសនីយកម្មពេញផ្ទៃនគរ មកហើយ ជាបុគ្គលមានពៀរ ជាបច្ចាមិត្រ ជាសត្រូវ មិនត្រាស់ពាក្យដែលនាំឲ្យកើតនូវជម្លោះ វិវាទណាមួយ តែបែរជាត្រាស់មធុរកថា ហាក់បីដូចលាបដោយប្រេងដែលរម្ងាស់ហើយ ១០០ ដង ហាក់បីដូចឲ្យផឹកទឹកអម្រឹត ចាប់តាំងអំពីកាលដែលបានយាងមកហើយ ដូច្នេះហើយ ទើបបុគ្គលទាំងនោះ បានទូលពាក្យនេះ ស្របតាមព្រះសម្មាសម្ពុទ្ធ ។ បទថា **យាចេយ្យាសិ** សេចក្តីថា អ្នកគប្បីសូម គឺ

គប្បីប្រាថ្នា បានដល់ ត្រូវការ ។ បទថា **តុណ្ហីភូតោ** បានដល់ ជាអ្នកដល់នូវតុណ្ហីភាព ។ បទថា **មង្កុភូតោ** បានដល់ ដល់នូវការអស់តេជះ ។ បទថា **បត្តក្ខន្ធោ** បានដល់ មានកឱនចុះ ។ បទថា **អធោមុខោ** បានដល់ អន្ទយឈ្ងោកមុខ ។

បទថា **សម្មាសម្ពុទ្ធស្ស តេ បដិជានតោ** សេចក្តីថា ទ្រង់ប្តេជ្ញាយ៉ាងនេះថា តថាគតជាសម្មាសម្ពុទ្ធ ធម៌ទាំងពួង តថាគតត្រាស់ដឹងហើយ ។ បទថា **អនភិសម្ពុទ្ធា** សេចក្តីថា ឈ្មោះថាធម៌ទាំងនេះ ទ្រង់មិនបានត្រាស់ដឹងហើយ ។ បទថា **តត្ថ** បានដល់ ក្នុងធម៌ដែលទ្រង់សម្តែងទាំងនោះយ៉ាងនេះថា តថាគតមិនទាន់បានត្រាស់ដឹងហើយ ។

បទថា **អញ្ញេន វា អញ្ញំ បដិចរិស្សតិ** សេចក្តីថា បន្ទប់ដោយពាក្យណាមួយ ដោយពាក្យសម្តីមួយទៀត អធិប្បាយថា សួរមួយបែប ឆ្លើយផ្សេងមួយបែប ។ បទថា **ពហិទ្ធា កថំ អបនាមេស្សតិ** សេចក្តីថា នាំពាក្យសម្តីដទៃមកលុបលាងពាក្យដើម ។ បទថា **អប្បច្ចយំ** បានដល់ មិនត្រេកអរក្រៃលែង គឺអាការដែលមិនពេញចិត្ត ។ បទថា **ធាតុករិស្សតិ** បានដល់ នឹងធ្វើឲ្យប្រាកដ ។ ក្នុងបណ្តាឋានៈ ៣ យ៉ាងនោះ ត្រាស់ទោមនស្សដោយ **អប្បច្ចយ** សព្ទ ត្រាស់សេចក្តីក្រោធនោះឯងញែកប្រភេទជាសេចក្តីក្រោធយ៉ាងទន់ និងសេចក្តីក្រោធយ៉ាងខ្លាំងក្លា ដោយបទទាំង ២ ខាងដើម ។

ព្រះមានព្រះភាគ កាលទ្រង់បន្លឺសីហនាទ ដោយវេសារជ្ជករណធម៌ដំបូងយ៉ាងនេះហើយ កាលទ្រង់បន្លឺសីហនាទដោយវេសារជ្ជករណធម៌ទី ២

ជាដើមតទៅទៀត ទើបត្រាស់ពាក្យជាដើមថា **យោ ខោ មំ បរិព្វាជកា** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យស្ស ខោ បន តេ អត្ថាយ ធម្មោ ទេសិតោ** សេចក្ដីថា ចតុរារិយសច្ចធម៌ដែលទ្រង់សម្ដែងហើយ ដើម្បីជាប្រយោជន៍ដល់មគ្គ ឬផលណា ។ បទថា **សោ ន និយ្យាតិ** សេចក្ដីថា ធម៌នោះមិននាំទៅ គឺមិនចូលដល់ លោកអធិប្បាយថា មិនញុំាងប្រយោជន៍ឲ្យសម្រេច ។ បទថា **តក្ករស្ស** អធិប្បាយថា នៃបុគ្គលដែលធ្វើតាម គឺដែលបំពេញបដិបទា ។ បទថា **សម្មាទុក្ខក្ខយាយ** សេចក្ដីថា ដើម្បីការអស់ទៅនៃវដ្ដទុក្ខទាំងមូល ដោយហេតុ ដោយន័យ ដោយការណ៍ ។ម្យ៉ាងទៀត បទថា **យស្ស ខោ បន តេ អត្ថាយ ធម្មោ ទេសិតោ** សេចក្ដីថា ធម៌ដែលទ្រង់សម្ដែងដើម្បីជាប្រយោជន៍ណា គឺអសុភកម្មដ្ឋាន ដើម្បីជាប្រយោជន៍ដល់ការកម្ចាត់រាគៈ មេត្តាភាវនា ដើម្បីជាប្រយោជន៍ដល់ការកម្ចាត់ទោសៈ សច្ចធម៌ គឺមរណៈ ដើម្បីជាប្រយោជន៍ដល់ការកម្ចាត់មោហៈ អានាបានស្សតិ ដើម្បីជាប្រយោជន៍ដល់ការកម្ចាត់វិតក្ក ។ ក្នុងបទថា **សោ ន និយ្យាតិ តក្ករស្ស សម្មាទុក្ខក្ខយាយ** មានអធិប្បាយដូច្នេះ ធម៌នោះមិននាំទៅ គឺមិនចូលដល់ បានដល់ មិនញុំាងប្រយោជន៍ឲ្យសម្រេច ដើម្បីការអស់ទៅនៃវដ្ដទុក្ខដោយប្រពៃ គឺដោយហេតុ ដោយន័យ ដោយការណ៍ ដល់អ្នកបដិបត្តិធម៌នោះ តាមដែលទ្រង់សម្ដែង ។ បទថា **សេយ្យថាបិ សរភោ បរិព្វាជកោ** សេចក្ដីថា បុគ្គលនោះ នឹងអន្ទុយដូចសរភបរិព្វាជក

ដែលអង្គុយសុបសៅ អស់នូវបដិភាណ ដូច្នោះ ។

កាលព្រះតថាគត ទ្រង់បន្លឺសីហនាទដោយបទទាំង ៣ យ៉ាងនេះហើយ ទ្រង់សម្តែងធម៌ជាបរិវត្ត បរិស័ទប្រមាណ ៨៤០០០ ដែលប្រជុំគ្នាក្នុងទីនោះ បានផឹកនូវអមតៈ ។ ព្រះសាស្តាទ្រង់ជ្រាបថា បរិស័ទផឹកនូវអមតៈហើយ ទើបហោះឡើងកាន់អាកាស ចៀសចេញទៅ ។ ដើម្បីសម្តែងអត្ថនោះ ទើបលោកពោលពាក្យជាដើមថា **អថខោ ភគវា** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **សីហនាទំ** បានដល់ ការបន្លឺដ៏ប្រសើរ គឺការបន្លឺដោយមិនកោតខ្លាច បានដល់ បន្លឺមិនមានបុគ្គលប្រៀប ។ បទថា **វេហាសំ បក្កាមិ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ចូលចតុត្ថជ្ឈាន មានអភិញ្ញាជាបាទ ចេញអំពីឈាន ហើយ ទ្រង់អធិដ្ឋាន ហើយហោះឡើងកាន់អាកាស មួយអន្លើដោយភិក្ខុសង្ឃ កាលទ្រង់យាងទៅយ៉ាងនេះហើយ រំពេចនោះ ក៏បានយាងទៅប្រថាប់ឯភ្នំគិជ្ឈកូដមហាវិហារ ។ បទថា **វាចាយ សន្និតោទកេន** បានដល់ ចាក់ដោយវាចា ។ បទថា **សញ្ឈម្ភរឹ អកំសុ** សេចក្តីថា បរិព្វាជកទាំងឡាយ បានធ្វើការត្អោរ គឺពោលទ្រគោះមិនឈប់ឈរ អធិប្បាយថា និយាយចាក់ដោតខ្លាំងឡើង ។ បទថា **ព្រហារញ្ញេ** ប្រែថា ក្នុងព្រៃធំ ។ បទថា **សីហនាទំ នទិស្សាមិ** សេចក្តីថា ចចកចាស់ឃើញអាការរបស់រាជសីហ៍បន្លឺសីហនាទ ក៏គិតថា រាជសីហ៍នេះ ជាសត្វតិរច្ឆាន ឯអញក៏ជាសត្វតិរច្ឆាន រាជសីហ៍មានជើង ៤ អញក៏មានជើង ៤ អញក៏បន្លឺសីហនាទបានដូចគ្នា ។ ចចកចាស់មិនអាចបន្លឺសីហនាទចំពោះមុខរាជសីហ៍បាន រាជសីហ៍ចៀសចេញទៅរកអាហារ

តែឯង ក៏ផ្តើមបន្ទឺសីហនាទ ។ គ្រានោះ ចចកក៏បន្ទឺសំឡេងឆ្កែចចកនោះឯង ចេញទៅ ។ ដោយហេតុនោះ ទើបបរិព្វាជកពោលថា ស្រែកចេញមកជាសំឡេងចចកនោះឯង ។ បទថា **ភេរណ្ឌកំ** ជាវេវចនៈនៃបទថា **សិង្គាលក** នោះឯង ម្យ៉ាងទៀត លោកអធិប្បាយថា ស្រែកសំឡេងបែក បានដល់ ស្រែកសំឡេងចេញមកមិនគួរពេញចិត្ត ។ ដោយឧបមានេះថា **ឯវមេវ ខោ តុំ** បរិព្វាជកទាំងឡាយប្រៀបព្រះសាស្តាដូចរាជសីហ៍ ប្រៀបសរភបរិព្វាជកដូចចចក ។ បទថា **អម្ពកមទ្ទុរី** បានដល់ កូនមាន់ញី ។ បទថា **បុរិស្ស-ករវិកំ រវិស្សាមិ** សេចក្តីថា កូនមាន់ឃើញមាន់ធំរងាវ ក៏គិតថា មាន់នេះមានជើង ២ ស្លាប ២ សូម្បីអញក៏មានដូចគ្នា អញនឹងរងាវយ៉ាងនោះដែរ ដូច្នេះ វាមិនហ៊ានរងាវចំពោះមុខមាន់ធំ កាលមាន់ធំនោះចៀសចេញទៅហើយ ទើបរងាវ តែក៏រងាវជាសំឡេងមាន់ញីនោះឯង ។ ដោយហេតុនោះ ទើបលោកពោលថា **អម្ពកមទ្ទុរីរវិកំយេវ រវតិ** ដូច្នេះ ។

បទថា **ឧសភោ** បានដល់ គោឈ្មោល ។ បទថា **សុញ្ញាយ** សេចក្តីថា ទទេ គឺវៀរចាកគោឈ្មោលដែលចម្រើនបំផុត ។ បទថា **គម្ភីរំ ឆទិតព្វំ មញ្ញតិ** សេចក្តីថា រមែងសម្គាល់សំឡេងយំរបស់ខ្លួនថាជ្រៅ ដូចសំឡេងនៃគោឈ្មោលដ៏ប្រសើរ ។ បទដ៏សេស ក្នុងបទទាំងពួង ងាយយល់ហើយ ។

## អដ្ឋកថា សរភសូត្រទី ៤ ចប់

# សុត្តន្តបិដក

## កេសបុត្តសូត្រទី ៥

[ ៦៧ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់ស្តេចទៅកាន់ចារិក ក្នុងកោសលជនបទ ជាមួយនឹងភិក្ខុសង្ឃច្រើន ក៏បានទៅដល់និគមឈ្មោះកេសបុត្ររបស់ពួកក្សត្រិយ៍ ឈ្មោះកាលាមៈ ។ ពួកកាលាមក្សត្រិយ៍ នៅក្នុងកេសបុត្តនិគម បានឮដំណឹងហើយ ប្រកាសប្រាប់គ្នាថា ម្នាលគ្នាយើងដ៏ចម្រើន បានឮថា ព្រះសមណគោតម ជាសក្យបុត្រ ចេញពីសក្យត្រកូលបួសហើយ បានមកដល់កេសបុត្តនិគម កិត្តិសព្ទ សរសើរព្រះគោតមដ៏ចម្រើននោះឯង ពីរោះល្បីខ្ចរខ្ចាយយ៉ាងនេះថា ព្រះដ៏មានព្រះភាគអង្គនោះ ជាព្រះអរហន្ត ទ្រង់ត្រាស់ដឹងនូវធម៌ទាំងពួង ដោយព្រះអង្គឯង ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់មានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់ប្រសើរជាងសត្វលោក ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មាន ជាសាស្តាចារ្យ នៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ទ្រង់លែងវិលត្រឡប់មកកាន់ភពថ្មីទៀត ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយព្រះអង្គឯង នូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពពួកសត្វ ព្រមទាំងពួកសមណព្រាហ្មណ៍ និងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហើយអាចប្រកាសបាន ព្រះអង្គទ្រង់សម្តែងធម៌ ពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ព្រះអង្គប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈដ៏ពេញ បរិបូណ៌បរិសុទ្ធទាំងអស់

ក៏ដំណើរដែលបានឃើញ បានជួប នឹងព្រះអរហន្តទាំងឡាយ មានសភាព ដូច្នោះ ជាការប្រពៃពេកណាស់ ។ លំដាប់នោះ ពួកកាលាមក្សត្រិយ៍ នៅក្នុង កេសបុត្តនិគម បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ពួកខ្លះក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ពួកខ្លះក៏ធ្វើ សេចក្តីរីករាយជាមួយព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ពួកខ្លះប្រណម្យអញ្ជលី ចំពោះព្រះមានព្រះភាគ អង្គុយក្នុងទីសមគួរ ពួកខ្លះប្រកាសនាម និងគោត្ត អង្គុយក្នុងទីសមគួរ ពួកខ្លះអង្គុយស្ងៀម ក្នុងទីសមគួរ ។ លុះពួកកាលាម-ក្សត្រ ក្នុងកេសបុត្តនិគម អង្គុយក្នុងទីសមគួរហើយ ក៏បានក្រាបបង្គំទូល ព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន មានសមណព្រាហ្មណ៍ មួយពួក មកកាន់កេសបុត្តនិគម សមណព្រាហ្មណ៍ទាំងនោះ សម្តែងប្រកាស នូវវាទៈ គឺលទ្ធិរបស់ខ្លួនឯង បៀតបៀនមើលងាយបន្ទាប់បន្ថោនលើកទម្លាក់ នូវវាទៈរបស់បុគ្គលដទៃ បពិត្រព្រះអង្គដ៏ចម្រើន មានសមណព្រាហ្មណ៍ដទៃ មួយពួកទៀត មកកាន់កេសបុត្តនិគម សមណព្រាហ្មណ៍ទាំងនោះ ក៏សម្តែង ប្រកាសនូវវាទៈរបស់ខ្លួនឯង បៀតបៀនមើលងាយ បន្ទាប់បន្ថោន លើក ទម្លាក់នូវវាទៈរបស់បុគ្គលដទៃដែរ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងនោះ មានសេចក្តីងឿងឆ្ងល់ សង្ស័យពេកណាស់ ចុះបណ្តាសមណព្រាហ្មណ៍ដ៏ ចម្រើនទាំងនេះ អ្នកណានិយាយពិត អ្នកណានិយាយកុហក ។ ម្នាលកាលា-មក្សត្រិយ៍ គួរអ្នកទាំងឡាយងឿងឆ្ងល់ដែរ គួរសង្ស័យដែរ ព្រោះការងឿង

ឆ្ងល់ និងការសង្ស័យកើតឡើង ដល់អ្នកទាំងឡាយក្នុងទីនេះហើយ ។ ម្នាលកាលាមក្សត្រិយ៍ទាំងឡាយ អ្នកចូរមក អ្នកកុំប្រកាន់ដោយគ្រាន់តែឮតាមគ្នា កុំប្រកាន់តាមពាក្យបរម្បរា កុំប្រកាន់ដោយបានឮថាដូច្នេះ កុំប្រកាន់ដោយអាងក្បួនតម្រា កុំប្រកាន់តាមហេតុដែលត្រិះរិះ កុំប្រកាន់ដោយកាត់ជំរួយផ្សែផ្សំ កុំប្រកាន់ដោយគ្រាន់តែត្រិះរិះនូវអាការ កុំប្រកាន់ដោយសេចក្ដីពេញចិត្តតាមការពិនិត្យសមនឹងសេចក្ដីយល់ឃើញ កុំប្រកាន់ដោយយល់ថាមានសភាពគួរ ( ជឿ ) កុំប្រកាន់ដោយគិតថាសមណៈ ( នេះ ) ជាគ្រូរបស់យើង ម្នាលកាលាមក្សត្រិយ៍ កាលណាបើអ្នកទាំងឡាយ ដឹងដោយខ្លួនឯងថា ធម៌ទាំងនេះជាអកុសលធម៌ ទាំងនេះប្រកបដោយទោស ធម៌ទាំងនេះអ្នកប្រាជ្ញតិះដៀល ធម៌ទាំងនេះបុគ្គលបានសមាទានពេញលេញហើយ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខ ម្នាលកាលាមក្សត្រិយ៍ទាំងឡាយ ក្នុងកាលនោះ អ្នកទាំងឡាយ ត្រូវលះបង់ចោលចេញ ។ ម្នាលកាលាមក្សត្រិយ៍ អ្នកសម្គាល់នូវហេតុនោះដូចម្ដេច លោភៈកាលកើតឡើងក៏កើតឡើងក្នុងសន្ដានរបស់បុរស ដើម្បីជាប្រយោជន៍ ឬដើម្បីមិនជាប្រយោជន៍ទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ដើម្បីមិនជាប្រយោជន៍ទេ ។ ម្នាលកាលាមក្សត្រិយ៍ ចុះបុរសបុគ្គលនេះ ជាអ្នកល្មោភ ត្រូវសេចក្ដីលោភគ្របសង្កត់ មានចិត្តត្រូវសេចក្ដីលោភរួបរឹត រមែងសម្លាប់នូវសត្វមានជីវិតខ្លះ កាន់យកនូវទ្រព្យដែលបុគ្គលដទៃមិនបានឲ្យខ្លះ គប់រកនូវកិរិយាអ្នកដទៃខ្លះ និយាយកុហកខ្លះ ដឹកនាំបុគ្គលដទៃដើម្បីហេតុនោះខ្លះ ហេតុនេះ ប្រព្រឹត្តទៅ

ដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខអស់កាលដ៏អង្វែង ដល់បុគ្គលនោះឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងហ្នឹងហើយ ។ ម្នាលកាលាមក្សត្រិយ៍ អ្នកសម្គាល់ហេតុនោះដូចម្ដេច ទោសៈ កាលកើតឡើង ក៏កើតឡើងក្នុងសន្ដាននៃបុរស ដើម្បីជាប្រយោជន៍ ឬដើម្បីមិនជាប្រយោជន៍ទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ដើម្បីមិនជាប្រយោជន៍ទេ ។ ម្នាលកាលាមក្សត្រិយ៍ ចុះបុរសបុគ្គលនេះ ជាអ្នកប្រទូស្ត ត្រូវទោសៈគ្របសង្កត់ មានចិត្តត្រូវទោសៈរួបរឹត រមែងសម្លាប់នូវសត្វមានជីវិតខ្លះ រមែងកាន់យកទ្រព្យរបស់បុគ្គលដទៃ ដែលគេមិនបានឲ្យខ្លះ គប់រកនូវកិរិយាអ្នកដទៃខ្លះ និយាយកុហកខ្លះ ដឹកនាំបុគ្គលដទៃដើម្បីហេតុនោះខ្លះ ហេតុនេះ ប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខ អស់កាលជាអង្វែងដល់បុគ្គលនោះឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងហ្នឹងហើយ ។ ម្នាលកាលាមក្សត្រិយ៍ អ្នកសម្គាល់ហេតុនោះដូចម្ដេច មោហៈ កាលកើតឡើង ក៏កើតឡើងក្នុងសន្ដាននៃបុរស ដើម្បីជាប្រយោជន៍ ឬដើម្បីមិនជាប្រយោជន៍ទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ដើម្បីមិនជាប្រយោជន៍ទេ ។ ម្នាលកាលាមក្សត្រិយ៍ ចុះបុរសបុគ្គលនេះជាអ្នកវង្វេង ត្រូវមោហៈគ្របសង្កត់ មានចិត្តត្រូវមោហៈរួបរឹត រមែងសម្លាប់សត្វមានជីវិតខ្លះ កាន់យកទ្រព្យរបស់បុគ្គលដទៃដែលគេមិនបានឲ្យខ្លះ គប់រកនូវកិរិយាអ្នកដទៃខ្លះ និយាយកុហកខ្លះ បបួលបុគ្គលដទៃ ដើម្បីហេតុនោះខ្លះ ហេតុនេះ ប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខអស់កាលជាអង្វែង ដល់បុគ្គលនោះឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងហ្នឹងហើយ ។ ម្នាល

កាលាមក្សត្រិយ៍ អ្នកសម្គាល់ហេតុនោះ ដូចម្តេច ធម៌នេះជាកុសល ឬជាអកុសល ។ ជាអកុសល ព្រះអង្គ ។ ជាធម៌ប្រកបដោយទោស ឬមិនប្រកបដោយទោសទេ ។ ជាធម៌ប្រកបដោយទោស ព្រះអង្គ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល ឬអ្នកប្រាជ្ញសរសើរ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល ព្រះអង្គ ។ ធម៌ទាំងនេះ ដែលបុគ្គលសមាទានពេញលេញហើយ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ឬមិនប្រព្រឹត្តទៅទេ ឬក៏ក្នុងដំណើរនុ៎ះដូចម្តេចទៅវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងនេះដែលបុគ្គលសមាទានបរិបូណ៌ហើយ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ យើងខ្ញុំក៏យល់ក្នុងដំណើរនុ៎ះ ដូច្នោះដែរ ។ ម្នាលកាលាមក្សត្រិយ៍ តថាគតបានសម្តែងនូវហេតុនោះ ដូច្នេះហើយថា ម្នាលកាលាមក្សត្រិយ៍ អ្នកចូរមក អ្នកកុំប្រកាន់ដោយគ្រាន់តែឮតាមគ្នា កុំប្រកាន់តាមពាក្យបរម្បរា កុំប្រកាន់ដោយបានឮថាដូច្នេះ កុំប្រកាន់ដោយអាងក្បួនតម្រា កុំប្រកាន់តាមហេតុដែលត្រិះរិះ កុំប្រកាន់ដោយកាត់ដំរួយផ្សែផ្សំ កុំប្រកាន់ដោយគ្រាន់តែត្រិះរិះនូវអាការ កុំប្រកាន់ដោយសេចក្តីពេញចិត្តតាមការពិនិត្យ ថាសមនឹងសេចក្តីយល់ឃើញ កុំប្រកាន់ដោយយល់ថា មានសភាពគួរ ( ជឿ ) កុំប្រកាន់ដោយគិតថា សមណៈ ( នេះ ) ជាគ្រូរបស់យើង ម្នាលកាលាមក្សត្រិយ៍ កាលណាបើអ្នកដឹងដោយខ្លួនឯងថា ធម៌ទាំងនេះជាអកុសល ធម៌ទាំងនេះប្រកបដោយទោស ធម៌ទាំងនេះដែលអ្នកប្រាជ្ញតិះដៀល ធម៌ទាំងនេះដែលបុគ្គលសមាទានពេញលេញហើយ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍

ដើម្បីសេចក្ដីទុក្ខ ម្នាលកាលាមក្សត្រិយ៍ទាំងឡាយ ក្នុងកាលនោះអ្នកត្រូវលះបង់ចោលចេញ ពាក្យណាដែលតថាគតសម្ដែងហើយ ពាក្យនោះ តថាគតពោលហើយ ព្រោះអាស្រ័យនូវហេតុនេះ ដោយប្រការដូច្នេះ ។ ម្នាលកាលាមក្សត្រិយ៍ អ្នកចូរមក អ្នកកុំប្រកាន់ដោយគ្រាន់តែឮតាមគ្នា កុំប្រកាន់តាមពាក្យបរម្បរា កុំប្រកាន់ដោយបានឮថាដូច្នេះ កុំប្រកាន់ដោយអាងក្បួនតម្រា កុំប្រកាន់តាមហេតុដែលត្រិះរិះ កុំប្រកាន់ដោយកាត់ជំរួយផ្ទៃផ្ទំ កុំប្រកាន់ដោយគ្រាន់តែត្រិះរិះនូវអាការ កុំប្រកាន់ដោយសេចក្ដីពេញចិត្តតាមការពិនិត្យថា សមនឹងសេចក្ដីយល់ឃើញ កុំប្រកាន់ដោយយល់ថា មានសភាពគួរ ( ជឿ ) កុំប្រកាន់ដោយគិតថា សមណៈ ( នេះ ) ជាគ្រូរបស់យើង ម្នាលកាលាមក្សត្រិយ៍ កាលណាបើអ្នកដឹងដោយខ្លួនឯងថា ធម៌ទាំងនេះជាកុសល ធម៌ទាំងនេះមិនមានទោស ធម៌ទាំងនេះ ដែលអ្នកប្រាជ្ញសរសើរ ធម៌ទាំងនេះដែលបុគ្គលសមាទានពេញលេញហើយ ប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ម្នាលកាលាមក្សត្រិយ៍ ក្នុងកាលនោះ អ្នកទាំងឡាយចូរដល់នូវធម៌ទាំងនោះ ហើយនៅ ។ ម្នាលកាលាមក្សត្រិយ៍ អ្នកសម្គាល់ហេតុនោះដូចម្ដេច អលោភៈ កាលកើតឡើង ក៏កើតក្នុងសន្ដានរបស់បុរស ដើម្បីជាប្រយោជន៍ ឬមិនជាប្រយោជន៍ទេ ។ ដើម្បីជាប្រយោជន៍ ព្រះអង្គ ។ ម្នាលកាលាមក្សត្រិយ៍ ចុះបុរសបុគ្គលនេះ ជាអ្នកមិនល្មោភ មិនត្រូវសេចក្ដីលោភគ្របសង្កត់ មានចិត្តមិនត្រូវសេចក្ដីលោភរួបរឹត មិនសម្លាប់សត្វ មិនកាន់យកនូវទ្រព្យដែលគេមិនបានឲ្យ មិនគប់រកភរិយាអ្នកដទៃ មិននិយាយ

កុហក ទាំងមិនបានដឹកនាំអ្នកដទៃ ដើម្បីហេតុនោះ តើហេតុនេះ ប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលជាអង្វែង ដល់បុគ្គលនោះដែរឬ ។ យ៉ាងហ្នឹងហើយ ព្រះអង្គ ។ ម្នាលកាលាមក្សត្រិយ៍ អ្នកសម្គាល់ហេតុនោះដូចម្តេច អទោសៈ កាលកើតឡើង ក៏កើតឡើងក្នុងសន្តានរបស់បុរស ដើម្បីជាប្រយោជន៍ ឬដើម្បីមិនជាប្រយោជន៍ទេ ។ ដើម្បីជាប្រយោជន៍ ព្រះអង្គ ។ ម្នាលកាលាមក្សត្រិយ៍ ចុះបុរសបុគ្គលនេះ ជាអ្នកមិនប្រទូស្ត មិនត្រូវទោសៈគ្របសង្កត់ មានចិត្តមិនត្រូវទោសៈរួបរឹត មិនសម្លាប់សត្វ មិនកាន់យកនូវទ្រព្យដែលគេមិនបានឲ្យ មិនគប់រកកិរិយាអ្នកដទៃ មិននិយាយកុហក ទាំងមិនបានដឹកនាំបុគ្គលដទៃ ដើម្បីហេតុនោះ តើហេតុនេះប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលជាអង្វែង ដល់បុគ្គលនោះដែរឬ ។ យ៉ាងហ្នឹងហើយ ព្រះអង្គ ។ ម្នាលកាលាមក្សត្រិយ៍ អ្នកសម្គាល់ហេតុនោះដូចម្តេច អមោហៈ កាលកើតឡើង ក៏កើតឡើងក្នុងសន្តានរបស់បុរស ដើម្បីជាប្រយោជន៍ ឬដើម្បីមិនជាប្រយោជន៍ទេ ។ ដើម្បីជាប្រយោជន៍ ព្រះអង្គ ។ ម្នាលកាលាមក្សត្រិយ៍ ចុះបុរសបុគ្គលនេះ ជាអ្នកមិនវង្វេង មិនត្រូវមោហៈគ្របសង្កត់ មានចិត្តមិនត្រូវមោហៈរួបរឹត មិនសម្លាប់សត្វ មិនកាន់យកនូវទ្រព្យដែលគេមិនបានឲ្យ មិនគប់រកកិរិយាអ្នកដទៃ មិននិយាយកុហក ទាំងមិនដឹកនាំបុគ្គលដទៃដើម្បីហេតុនោះ តើហេតុនេះ ប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលអង្វែង ដល់បុគ្គលនោះដែរឬ ។ យ៉ាងហ្នឹងហើយ ព្រះអង្គ ។ ម្នាលកាលាមក្សត្រិយ៍

អ្នកសម្គាល់ហេតុនោះដូចម្តេច ធម៌នេះជាកុសល ឬអកុសល ។ ជាកុសល ព្រះអង្គ ។ ប្រកបដោយទោស ឬមិនប្រកបដោយទោសទេ ។ មិនប្រកបដោយទោសទេ ព្រះអង្គ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល ឬអ្នកប្រាជ្ញសរសើរ ។ ជាធម៌ដែលអ្នកប្រាជ្ញសរសើរ ព្រះអង្គ ។ ធម៌ដែលបុគ្គលសមាទានពេញលេញហើយ ប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ឬមិនប្រព្រឹត្តទៅទេ ឬក៏ក្នុងដំណើរនុ៎ះ ដូចម្តេចទៅវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលបុគ្គលសមាទានពេញលេញហើយ ប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ យើងខ្ញុំក៏យល់ក្នុងដំណើរនុ៎ះដូច្នោះដែរ ។ ម្នាលកាលាមក្សត្រិយ៍ តថាគតបានសម្តែងនូវហេតុនោះ ដូច្នេះហើយថា ម្នាលកាលាមក្សត្រិយ៍ អ្នកចូរមក អ្នកកុំប្រកាន់ដោយគ្រាន់តែឮតាមគ្នា អ្នកកុំប្រកាន់តាមពាក្យបរម្បរា អ្នកកុំប្រកាន់ដោយបានឮថាដូច្នេះ កុំប្រកាន់ដោយអាងក្បួនតម្រា កុំប្រកាន់តាមហេតុដែលត្រិះរិះ កុំប្រកាន់ដោយកាត់ជុំរួយផ្សំផ្សំ កុំប្រកាន់ដោយត្រិះរិះតាមអាការ កុំប្រកាន់ដោយសេចក្តីពេញចិត្តតាមការពិនិត្យថាសមនឹងសេចក្តីយល់ឃើញ កុំប្រកាន់ដោយយល់ថា មានសភាពគួរ ( ជឿ ) កុំប្រកាន់ដោយគិតថា សមណៈ ( នេះ ) ជាគ្រូរបស់យើង ម្នាលកាលាមក្សត្រិយ៍ កាលណាបើដឹងដោយខ្លួនឯងថា ធម៌នេះជាកុសល ធម៌នេះមិនប្រកបដោយទោស ធម៌នេះដែលអ្នកប្រាជ្ញសរសើរ ធម៌នេះដែលបុគ្គលសមាទានពេញលេញហើយ រមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ម្នាលកាលាមក្សត្រិយ៍ ក្នុងកាលនោះ អ្នកទាំង-

ឡាយ ចូរដល់នូវធម៌ទាំងនោះហើយនៅ ហេតុនោះ តថាគតបានពោលហើយ ដោយប្រការដូច្នេះ ពាក្យនុ៎ះ តថាគតបានពោលហើយ ព្រោះអាស្រ័យនូវហេតុនេះ ។ ម្នាលកាលាមក្សត្រិយ៍ អរិយសាវកនោះឯង មិនមានអភិជ្ឈា មិនមានព្យាបាទ មិនវង្វេង មានសម្បជញ្ញៈ មានសតិយ៉ាងនេះឯង មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅទិសខាងលើ ទិសខាងក្រោម ទិសទទឹង គឺទិសតូចៗ មានចិត្តប្រកបដោយមេត្តា ជាចិត្តទូលាយ ដល់នូវសភាវៈធំ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ដោយអាការទាំងពួង ក្នុងទីទាំងពួង មានចិត្តប្រកបដោយករុណា ... មានចិត្តប្រកបដោយមុទិតា ... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ និងទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹង គឺទិសតូចៗ មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តទូលាយ ដល់នូវសភាវៈធំ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ដោយអាការ ទាំងពួង ក្នុងទីទាំងពួង ។ ម្នាលកាលាមក្សត្រិយ៍ អរិយសាវកនោះឯង មិនមានចិត្តចងពៀរយ៉ាងនេះ មិនមានចិត្តព្យាបាទយ៉ាងនេះ មិនមានចិត្តសៅហ្មងយ៉ាងនេះ មានចិត្តស្អាតយ៉ាងនេះហើយ ជាអ្នកបាននូវអានិសង្ស ៤ យ៉ាងក្នុងបច្ចុប្បន្ន បើបរលោកមាន ផល និងវិបាកនៃអំពើទាំងឡាយ ដែលបុគ្គលធ្វើល្អ និងអាក្រក់ក៏មាន លុះអាត្មាអញទម្លាយរាងកាយ ស្លាប់ទៅនឹងទៅកើត

ក្នុងសុគតិសួគ៌ទេវលោក ដោយហេតុណា ហេតុនោះជាឋានៈ នេះជាអានិសង្សទី ១ ដែលអរិយសាវកនោះបានហើយ ។ បើបរលោកមិនមានផល និងវិបាកនៃអំពើដែលបុគ្គលធ្វើល្អ និងធ្វើអាក្រក់ ក៏មិនមាន អាត្មាអញរក្សានូវខ្លួនឲ្យជាបុគ្គលមិនមានពៀរ មិនមានព្យាបាទ មិនមានទុក្ខ មានតែសេចក្ដីសុខក្នុងបច្ចុប្បន្ននេះឯង នេះជាអានិសង្សទី ២ ដែលអរិយសាវកនោះបានហើយ ។ បើអំពើអាក្រក់ដែលបុគ្គលធ្វើហើយ ឈ្មោះថា បានធ្វើហើយ អញមិនដែលគិតនូវអំពើអាក្រក់របស់បុគ្គលណាមួយ សេចក្ដីទុក្ខនឹងពាល់ត្រូវនូវអាត្មាអញ ដែលមិនបានធ្វើនូវអំពើអាក្រក់អំពីទីណាបាន នេះជាអានិសង្សទី ៣ ដែលអរិយសាវកនោះបានហើយ ។ បើអំពើអាក្រក់ដែលបុគ្គលធ្វើហើយ ឈ្មោះថា មិនបានធ្វើ អាត្មាអញនឹងពិចារណាឃើញច្បាស់នូវខ្លួនដ៏បរិសុទ្ធ ដោយហេតុទាំងពីរ ក្នុងលោកនេះ នេះជាអានិសង្សទី ៤ ដែលអរិយសាវកនោះបានហើយ ។ ម្នាលកាលាមក្សត្រិយ៍ អរិយសាវកនោះឯង មិនមានចិត្តប្រកបដោយពៀរយ៉ាងនេះ មិនមានចិត្តព្យាបាទយ៉ាងនេះ មិនមានចិត្តសៅហ្មងយ៉ាងនេះ មានចិត្តបរិសុទ្ធយ៉ាងនេះ នេះជាអានិសង្ស ៤ យ៉ាង ដែលអរិយសាវកនោះបានក្នុងបច្ចុប្បន្ន ។ បពិត្រព្រះដ៏មានព្រះភាគ ហេតុនុ៎ះ យ៉ាងនេះឯង បពិត្រព្រះសុគត ហេតុនុ៎ះ យ៉ាងនេះឯង បពិត្រព្រះអង្គដ៏ចម្រើន អរិយសាវកនោះឯង មិនមានចិត្តប្រកបដោយពៀរយ៉ាងនេះ មិនមានចិត្តព្យាបាទយ៉ាងនេះ មិនមានចិត្តសៅហ្មងយ៉ាងនេះ មានចិត្តបរិសុទ្ធយ៉ាងនេះ ទើបអរិយសាវកនោះ បាននូវអានិសង្ស ៤ យ៉ាង ក្នុង

បច្ចុប្បន្ន បើបរលោកមាន ផល និងវិបាកនៃអំពើដែលបុគ្គលធ្វើល្អ និងធ្វើអាក្រក់ក៏មាន លុះអាត្មាអញ ទម្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងសុគតិសួគ៌ទេវលោក ដោយហេតុណា ហេតុនោះ ជាឋានៈ នេះជាអានិសង្ស ទី ១ ដែលអរិយសាវកនោះបានហើយ ។ បើបរលោកមិនមាន ផល និងវិបាកនៃអំពើដែលបុគ្គលធ្វើល្អ និងអាក្រក់ក៏មិនមាន អាត្មាអញនឹងរក្សាខ្លួនឲ្យជាបុគ្គលមិនមានពៀរ មិនមានព្យាបាទ មិនមានទុក្ខ មានតែសេចក្ដីសុខក្នុងបច្ចុប្បន្ននេះឯង នេះជាអានិសង្សទី ២ ដែលអរិយសាវកនោះបានហើយ ។ បើអំពើអាក្រក់ដែលបុគ្គលធ្វើហើយ ឈ្មោះថា បានធ្វើ អាត្មាអញមិនដែលគិតនូវអំពើអាក្រក់របស់បុគ្គលណាមួយឡើយ សេចក្ដីទុក្ខនឹងពាល់ត្រូវនូវអាត្មាអញដែលមិនធ្វើអំពើអាក្រក់អំពីទីណាបាន នេះជាអានិសង្សទី ៣ ដែលអរិយសាវកនោះបានហើយ ។ បើអំពើអាក្រក់ដែលបុគ្គលធ្វើហើយ ឈ្មោះថា មិនបានធ្វើ អាត្មាអញនឹងពិចារណាឃើញច្បាស់នូវខ្លួនដ៏បរិសុទ្ធ ដោយហេតុទាំង ២ ក្នុងលោកនេះ នេះជាអានិសង្សទី ៤ ដែលអរិយសាវកនោះបានហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន អរិយសាវកនោះឯង មិនមានចិត្តប្រកបដោយពៀរយ៉ាងនេះ មិនមានចិត្តព្យាបាទយ៉ាងនេះ មិនមានចិត្តសៅហ្មងយ៉ាងនេះ មានចិត្តបរិសុទ្ធយ៉ាងនេះ នេះជាអានិសង្ស ៤ យ៉ាង ដែលអរិយសាវកនោះបានក្នុងបច្ចុប្បន្ន ។ បពិត្រព្រះអង្គដ៏ចម្រើន ច្បាស់ពេកណាស់ ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គទាំងនេះ សូមដល់នូវព្រះដ៏មានព្រះភាគផង នូវព្រះធម៌ផង នូវព្រះសង្ឃផង ថាជាទីពឹង

បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ចាំទុកនូវយើងខ្ញុំព្រះអង្គ ថាជាឧបាសក ដល់នូវសរណៈស្មើដោយជីវិត តាំងអំពីថ្ងៃនេះ ជាដើមតទៅ ។

# អដ្ឋកថា

## កាលាមសូត្រ

[ ៦៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកាលាមសូត្រទី ៥ ដូចតទៅនេះ បទថា **កាលាមានំ និគមោ** បានដល់ និគមរបស់ពួកស្តេចឈ្មោះកាលាមៈ ។ បទថា **កេសបុត្តិយា** បានដល់ ដែលនៅក្នុងនិគមឈ្មោះកេសបុត្ត ។ បទថា **ឧបសង្កមឹសុ** សេចក្តីថា ឲ្យកាន់យកកេសជ្ជៈ មានសប្បិ នវនីតជាដើម និងទឹកបាន ៨ យ៉ាង ចូលទៅគាល់ ។ បទថា **សកំយេវ វាទំ ទីបេន្តិ** សេចក្តីថា ពោលលទ្ធិរបស់ខ្លួននោះឯង ។ បទថា **ជោតេន្តិ** បានដល់ ប្រកាស ។ បទថា **ខុំសេន្តិ** បានដល់ ពោលទ្រគោះបោះបោក ។ បទថា **វម្ភេន្តិ** បានដល់ ពោលមើលងាយ ។ បទថា **បរិភវន្តិ** បានដល់ ធ្វើឲ្យលាមក ។ បទថា **ឱបបក្ខឹ ករោន្តិ** បានដល់ ធ្វើការលុបលាង គឺលើកចោលទៅ ។ បទថា **អបរេបិ ភន្តេ** សេចក្តីថា បានឮមកថា ស្រុកនោះតាំងនៅមាត់ព្រៃ ព្រោះដូច្នោះ សមណព្រាហ្មណ៍ទាំងឡាយ ចូលព្រៃមកក្តី ចេញក្រោយក្តី ត្រូវស្នាក់ក្នុងស្រុកនោះ ។ បណ្តាព្រាហ្មណ៍ទាំងនោះ ព្រាហ្មណ៍

ដែលមកដល់មុន សម្ដែងលទ្ធិរបស់ខ្លួន ហើយចៀសចេញទៅ ពួកសមណ-ព្រាហ្មណ៍ដែលមកតាមក្រោយ ក៏សម្ដែងលទ្ធិរបស់ខ្លួនថា សមណព្រាហ្មណ៍ទាំងនោះ ចេះដឹងអ្វី ពួកគេទាំងនោះ ជាកូនសិស្សរបស់ពួកយើង រៀនសិប្បៈណាមួយក្នុងសម្នាក់របស់យើង ដូច្នេះហើយ ក៏ចៀសចេញទៅ ។ អ្នកកាលាមៈទាំងឡាយ មិនអាចច្បាស់លាស់ ក្នុងលទ្ធិមួយបាន ។ អ្នកស្រុកកាលាមៈទាំងនោះសម្ដែងសេចក្ដីនេះហើយ ទើបក្រាបទូលព្រះមានព្រះភាគយ៉ាងនេះហើយពោលពាក្យជាដើមថា **តេសំ នោ ភន្តេ** ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **ហោតេវ កង្ខា** សេចក្ដីថា ខ្ញុំព្រះអង្គទាំងឡាយ មានការសន្ទិះសង្ស័យពិតៗ ។ បទថា **វិចិកិច្ឆា** ជាវេវចនៈនៃ **កង្ខា** នោះឯង ។ បទថា **អលំ** ប្រែថា គួរហើយ ។

បទថា **មា អនុស្សវេន** បានដល់ កុំជឿដោយពាក្យតាមដែលបានស្ដាប់មក ។ បទថា **មា បរម្បរាយ** បានដល់ កុំជឿដោយពាក្យដែលនាំតៗ មក ។ បទថា **មា ឥតិកិរាយ** បានដល់ កុំជឿថា បានឮថាសេចក្ដីនេះយ៉ាងនេះ ។ បទថា **មា បិដកសម្បទានេន** បានដល់ កុំជឿថាសេចក្ដីនេះសមនឹងគម្រារបស់យើង ។ បទថា **មា តក្កហេតុ** បានដល់កុំជឿដោយការកាន់យកតាមការត្រិះរិះ ។ បទថា **មា នយហេតុ** បានដល់កុំជឿដោយការកាន់យកតាមន័យ ។ បទថា **មា អាការបរិវិតក្កេន** បានដល់ កុំជឿដោយការត្រិះរិះតាមហេតុការណ៍យ៉ាងនេះថា ហេតុនេះល្អ ។ បទថា **ទិដ្ឋិនិជ្ឈានក្ខន្តិយា** បានដល់ កុំជឿថា សេចក្ដីនេះ សមនឹងការយល់

ឃើញ ដែលពួកយើងពិនិត្យពិចារណា អត់ធន់ចំពោះការពិសោធ ទើបកាន់យក ។ បទថា **មា ភព្វរូបតាយ** បានដល់ កុំជឿដោយគិតថា ភិក្ខុនេះសមរម្យ គួរជឿពាក្យរបស់ភិក្ខុនេះបាន ។ បទថា **មា សមណោ នោ គរុ** បានដល់ កុំជឿថា សមណរូបនេះជាគ្រូរបស់អញ គួរជឿពាក្យរបស់សមណៈរូបនេះបាន ។

បទថា **សមត្តា** បានដល់ បរិបូណ៌ ។ បទថា **សមាទិន្នា** បានដល់ ដែលខ្ញុំកាន់យកហើយ គឺស្ទាបអង្អែលហើយ ។ បទថា **យំ តស្ស ហោតិ** សេចក្តីថា ហេតុណាមានដល់បុគ្គលនោះ ។ កុសលមូលទាំងឡាយ មានអលោភៈជាដើម គប្បីជ្រាបដោយអំណាចនៃធម៌ដែលជាបដិបក្ខចំពោះលោភៈជាដើម ។ ព្រះមានព្រះភាគ ត្រាស់បុព្វភាគនៃមេត្តា ដោយបទជាដើមថា **វិគតាភិជ្ឈោ** ដូច្នេះ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលត្រាស់កម្មដ្ឋាន មានមេត្តាជាដើម ទើបត្រាស់ពាក្យជាដើមថា **មេត្តាសហគតេន** ដូច្នេះ ។ បណ្តាបទទាំងនោះ បទណាគប្បីពោលដោយន័យរបស់កម្មដ្ឋានកថា និងភាវនាបធាន ឬដោយអដ្ឋកថានៃបាលី ពាក្យទាំងអស់នោះ ខ្ញុំបានពោលក្នុងគម្ពីរវិសុទ្ធិមគ្គនោះហើយ ។ បទថា **ឯវំ អវេរចិត្តោ** សេចក្តីថា ឈ្មោះថា មានចិត្តមិនមានពៀរ ព្រោះមិនមានពៀរ ដែលជាអកុសលផង បុគ្គលដែលជាពៀរផង ។ បទថា **អព្យាបជ្ឈចិត្តោ** សេចក្តីថា ឈ្មោះថា មានចិត្តមិនប្រកបដោយទុក្ខ ព្រោះមិនមានចិត្តអាក់អន់ ។ បទថា **អសង្កិលិដ្ឋចិត្តោ** សេចក្តីថា ឈ្មោះថា

បុគ្គលមានចិត្តមិនសៅហ្មង ព្រោះមិនមានកិលេស ។ បទថា **វិសុទ្ធចិត្តោ** អធិប្បាយថា ឈ្មោះថា មានចិត្តបរិសុទ្ធ ព្រោះមិនមានមន្ទិល គឺកិលេស ។ បទថា **តស្ស** បានដល់ ព្រះអរិយសាវកនោះ គឺបែបនោះ ។ បទថា **អស្សាសា** បានដល់ ជាទីអាស្រ័យ គឺជាទីពឹង ។

បទថា **សចេ ខោ បន អត្ថិ បរោ លោកោ** សេចក្តីថា បើឈ្មោះថា លោកដទៃក្រៅអំពីលោកនេះមានសោត ។ បទថា **ឋានមេតំ យេនាហំ កាយស្ស ភេទា ។បេ។ ឧបបជ្ជិស្សាមិ** សេចក្តីថា ការដែលយើងចូលដល់សុគតិសួគ៌ ក្រោយអំពីស្លាប់ហើយ ព្រោះកាយបែកធ្លាយទៅ ជាហេតុដែលមាន ដូច្នោះ ក្នុងគ្រប់បទគប្បីជ្រាបន័យដូចពណ៌នាមកនេះ ។ បទថា **អឃំ** ប្រែថា មិនមានទុក្ខ ។ បទថា **សុខី** ប្រែថា ដល់ហើយនូវសុខ ។ បទថា **ឧភយេនេវ វិសុទ្ធំ អត្តានំ សមនុបស្សាមិ** សេចក្តីថា តថាគតពិចារណាឃើញខ្លួនឯងជាបុគ្គលបរិសុទ្ធដោយហេតុទាំង ២ គឺតថាគតមិនធ្វើបាប ១ កាលបើបុគ្គលធ្វើបាបមាន តថាគតក៏មិនបានធ្វើ ១ ។ ពាក្យដ៏សេស ក្នុងបទទាំងពួងងាយយល់ទាំងអស់ហើយ ។៚

## អដ្ឋកថា កាលាមសូត្រទី ៥ ចប់

# សុត្តន្តបិដក

## សាឡ្ហសូត្រទី ៦

[ ៦៨ ] សម័យមួយ ព្រះនន្ទកៈដ៏មានអាយុ គង់ក្នុងប្រាសាទរបស់មិគារមាតាក្នុងវត្តបុព្វារាម ទៀបក្រុងសាវត្ថី ។ គ្រានោះ សាឡ្ហៈជាចៅរបស់មិគារសេដ្ឋី និងរោហនៈជាចៅរបស់បេខុណិយសេដ្ឋី នាំគ្នាចូលទៅរកព្រះនន្ទកៈដ៏មានអាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះនន្ទកៈដ៏មានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះសាឡ្ហៈជាចៅរបស់មិគារសេដ្ឋី អង្គុយនៅក្នុងទីសមគួរ ព្រះនន្ទកៈដ៏មានអាយុបានពោលដូច្នេះថា ម្នាលសាឡ្ហៈ និងរោហនៈ អ្នកទាំងឡាយ ចូរមក អ្នកទាំងឡាយ កុំប្រកាន់ដោយការឮតៗគ្នា កុំប្រកាន់តាមពាក្យបរម្បរា កុំប្រកាន់ដោយឮថាដូច្នេះ កុំប្រកាន់ដោយការអាងក្បួនតម្រា កុំប្រកាន់តាមហេតុដែលត្រិះរិះ កុំប្រកាន់ដោយកាត់ជំរុយផ្សំផ្សំ កុំប្រកាន់ដោយត្រិះរិះតាមអាការ កុំប្រកាន់ដោយសេចក្តីពេញចិត្តតាមការពិនិត្យថា សមនឹងសេចក្តីយល់ឃើញ កុំប្រកាន់ដោយយល់ថា មានសភាពគួរជឿ កុំប្រកាន់ដោយគិតថា សមណៈ ( នេះ ) ជាគ្រូរបស់យើងឡើយ ម្នាលសាឡ្ហៈ និងរោហនៈ កាលណាអ្នកទាំងឡាយដឹងដោយខ្លួនឯងថា ធម៌ទាំងអម្បាលនេះ ជាអកុសល ធម៌ទាំងអម្បាលនេះ ប្រកបដោយទោស ធម៌ទាំងអម្បាលនេះ ដែលអ្នកប្រាជ្ញតិះដៀល ធម៌ទាំងអម្បាលនេះ ដែលបុគ្គលបានសមាទានឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ម្នាលសាឡ្ហៈ និងរោហនៈ កាលណោះ

អ្នកទាំងឡាយត្រូវលះបោលចេញ ។ ម្នាលសាឡ្ហៈ និងរោហនៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច លោភៈ មានដែរឬ ។ សាឡ្ហៈ និងរោហនៈឆ្លើយថា មានដែរលោកម្ចាស់ ។ ម្នាលសាឡ្ហៈ និងរោហនៈ អាត្មាពោលសេចក្តីនុ៎ះថា លោភៈជាអភិជ្ឈា ។ ម្នាលសាឡ្ហៈ និងរោហនៈ បុគ្គលអ្នកល្មោភច្រើនដោយអភិជ្ឈានេះ រមែងសម្លាប់សត្វខ្លះ កាន់យករបស់ដែលគេមិនបានឲ្យខ្លះ ប្រព្រឹត្តខុសក្នុងកិរិយារបស់អ្នកដទៃខ្លះ ពោលពាក្យកុហកខ្លះ ដឹកនាំអ្នកដទៃដើម្បីអំពើដូច្នោះខ្លះ ដែលជាហេតុឲ្យប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ និងសេចក្តីទុក្ខអស់កាលជាយូរអង្វែងដល់បុគ្គលនោះ មែនឬ ។ មែនលោកម្ចាស់ ។ ម្នាលសាឡ្ហៈ និងរោហនៈ អ្នកសម្គាល់សេចក្តីនោះ ដូចម្តេច ទោសៈមានដែរឬ ។ មានដែរលោកម្ចាស់ ។ ម្នាលសាឡ្ហៈ និងរោហនៈ អាត្មាពោលសេចក្តីនុ៎ះថា ទោសៈជាព្យាបាទ ។ ម្នាលសាឡ្ហៈ និងរោហនៈ បុគ្គលអ្នកប្រទូស្ត មានចិត្តប្រកបដោយព្យាបាទនេះ តែងសម្លាប់សត្វខ្លះ កាន់យករបស់ដែលគេមិនបានឲ្យខ្លះ គប់រកនូវកិរិយារបស់អ្នកដទៃខ្លះ ពោលពាក្យកុហកខ្លះ ដឹកនាំអ្នកដទៃដើម្បីអំពើដូច្នោះខ្លះ ដែលជាហេតុឲ្យប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ និងសេចក្តីទុក្ខអស់កាលជាយូរអង្វែង ដល់បុគ្គលនេះ មែនឬ ។ មែនលោកម្ចាស់ ។ ម្នាលសាឡ្ហៈ និងរោហនៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច មោហៈ មានដែរឬទេ ។ មានដែរលោកម្ចាស់ ។ ម្នាលសាឡ្ហៈ និងរោហនៈ អាត្មាពោលសេចក្តីនុ៎ះថា មោហៈជាអវិជ្ជា ។ ម្នាលសាឡ្ហៈ និងរោហនៈ បុគ្គលអ្នកវង្វេង ប្រកបទៅដោយអវិជ្ជានេះ រមែង

សម្លាប់សត្វខ្លះ កាន់យករបស់ដែលគេមិនបានឲ្យខ្លះ គប់រកនូវកិរិយារបស់អ្នកដទៃខ្លះពោលពាក្យកុហកខ្លះ ដឹកនាំអ្នកដទៃដើម្បីអំពើដូច្នោះខ្លះ ដែលជាហេតុឲ្យប្រព្រឹត្តទៅ ដើម្បីអំពើមិនជាប្រយោជន៍ និងសេចក្តីទុក្ខ អស់កាលជាយូរអង្វែង ដល់បុគ្គលនោះ មែនឬ ។ មែនលោកម្ចាស់ ។ ម្នាលសាឡ្ហៈ និងរោហនៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច ធម៌ទាំងអម្បាលនេះជាកុសល ឬជាអកុសល ។ ជាអកុសល លោកម្ចាស់ ។ ប្រកបដោយទោសឬ មិនប្រកបដោយទោស ។ ប្រកបដោយទោសលោកម្ចាស់ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល ឬជាធម៌ដែលអ្នកប្រាជ្ញសរសើរ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល លោកម្ចាស់ ។ ជាធម៌ដែលបុគ្គលសមាទានឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ឬមិនមែនទេ ឬមួយក្នុងដំណើរនុ៎ះ មានប្រការដូចម្តេចទៅវិញ ។ បពិត្រព្រះករុណាដ៏ចម្រើន អកុសលធម៌ដែលបុគ្គលសមាទានឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ និងសេចក្តីទុក្ខមែន យើងខ្ញុំយល់យ៉ាងនេះដែរ ក្នុងដំណើរនុ៎ះ ។ ព្រះនន្ទកៈពោលថា ម្នាលសាឡ្ហៈ និងរោហនៈ យើងបានពោលនូវពាក្យណាដូច្នេះ យ៉ាងនេះថា ម្នាលសាឡ្ហៈ និងរោហនៈ អ្នកទាំងឡាយ ចូរមក អ្នកទាំងឡាយ កុំប្រកាន់ដោយការឮតៗ គ្នាកុំប្រកាន់តាមពាក្យបរម្បរា កុំប្រកាន់ដោយបានឮថាដូច្នេះ កុំប្រកាន់ដោយការអាងក្បួនតម្រា កុំប្រកាន់តាមហេតុដែលត្រិះរិះ កុំប្រកាន់ដោយកាត់ដំរូយផ្ទេផ្ទំ កុំប្រកាន់ដោយត្រិះរិះតាមអាការ កុំប្រកាន់ដោយសេចក្តីពេញចិត្តតាម

ការពិនិត្យថា សមនឹងសេចក្ដីយល់ឃើញ កុំប្រកាន់ដោយយល់ថា មានសភាពគួរជឿ កុំប្រកាន់ដោយគិតថាសមណៈ ( នេះ ) ជាគ្រូរបស់យើងដូច្នេះឡើយ ម្នាលសាឡ្ហៈ និងភេហនៈ កាលណាអ្នកទាំងឡាយដឹងដោយខ្លួនឯងថា ធម៌ទាំងអម្បាលនេះ ជាអកុសល ធម៌ទាំងអម្បាលនេះ ប្រកបដោយទោស ធម៌ទាំងអម្បាលនេះ ដែលអ្នកប្រាជ្ញតិះដៀល ធម៌ទាំងអម្បាលនេះ ដែលបុគ្គលសមាទានឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ និងសេចក្ដីទុក្ខ ម្នាលសាឡ្ហៈ និងភេហនៈ កាលណោះ អ្នកទាំងឡាយត្រូវលះចោលចេញ ពាក្យណា ដែលយើងពោលហើយដូច្នេះ ពាក្យនុ៎ះ យើងបានពោលហើយ ព្រោះអាស្រ័យហេតុនេះ ។ ម្នាលសាឡ្ហៈ និងភេហនៈ អ្នកទាំងឡាយចូរមក អ្នកទាំងឡាយ កុំប្រកាន់ដោយការឮតៗគ្នា កុំប្រកាន់តាមពាក្យបរម្បរា កុំប្រកាន់ដោយបានឮថា ដូច្នេះ កុំប្រកាន់ដោយការអាងក្បួនតម្រា កុំប្រកាន់តាមហេតុដែលត្រិះរិះ កុំប្រកាន់ដោយកាត់ដំរូយផ្សេងៗ កុំប្រកាន់ដោយត្រិះរិះតាមអាការ កុំប្រកាន់ដោយសេចក្ដីពេញចិត្តតាមការពិនិត្យថា សមនឹងសេចក្ដីយល់ឃើញ កុំប្រកាន់ដោយយល់ថាមានសភាពគួរជឿ កុំប្រកាន់ដោយគិតថា សមណៈ ( នេះ ) ជាគ្រូរបស់យើងឡើយ ម្នាលសាឡ្ហៈ និងភេហនៈ កាលណា អ្នកទាំងឡាយដឹងដោយខ្លួនឯងថា ធម៌ទាំងអម្បាលនេះ ជាកុសល ធម៌ទាំងអម្បាលនេះ មិនប្រកបដោយទោស ធម៌ទាំងអម្បាលនេះ ដែលអ្នកប្រាជ្ញសរសើរ ធម៌ទាំងអម្បាលនេះ ដែលបុគ្គលសមាទានឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅ

ដើម្បីជាប្រយោជន៍ និងសេចក្ដីសុខ ម្នាលសាឡ្ហៈ និងរោហនៈ កាលណោះ អ្នកទាំងឡាយ គួរចូលទៅសម្រេចសម្រាន្ត នៅចុះ ។ ម្នាលសាឡ្ហៈ និងរោហនៈ អ្នកសម្គាល់សេចក្ដីនោះដូចម្ដេច អលោភៈ មានដែរឬ ។ មានដែរ លោកម្ចាស់ ។ ម្នាលសាឡ្ហៈ និងរោហនៈ អាត្មាពោលសេចក្ដីនុ៎ះថា អលោភៈជាអនភិជ្ឈា ( សេចក្ដីមិនលោភ ) ម្នាលសាឡ្ហៈ និងរោហនៈ បុគ្គលអ្នកមិនល្មោភ មិនមានអភិជ្ឈានេះ រមែងមិនសម្លាប់សត្វ មិនកាន់យកនូវវត្ថុដែលគេមិនបានឲ្យ មិនគប់រកនូវកិរិយារបស់អ្នកដទៃ មិនពោលពាក្យកុហក ដឹកនាំអ្នកដទៃដើម្បីអំពើដូច្នោះ ដែលជាហេតុប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្ដីសុខ អស់កាលជាយូរអង្វែងដល់បុគ្គលនោះមែនឬ ។ មែនហើយ លោកម្ចាស់ ។ ម្នាលសាឡ្ហៈ និងរោហនៈ អ្នកសម្គាល់សេចក្ដីនោះដូចម្ដេច អទោសៈ មានដែរឬ ។ មានដែរ លោកម្ចាស់ ។ ម្នាលសាឡ្ហៈ និងរោហនៈ អាត្មាពោលសេចក្ដីនុ៎ះថា អទោសៈ ជាអព្យាបាទ ( សេចក្ដីមិនប្រទូស្ត ) ។ ម្នាលសាឡ្ហៈ និងរោហនៈ បុគ្គលអ្នកមិនប្រទូស្ត មានចិត្តមិនព្យាបាទនេះ រមែងមិនសម្លាប់សត្វ មិនកាន់យកនូវវត្ថុដែលគេមិនបានឲ្យ មិនគប់រកនូវកិរិយារបស់អ្នកដទៃ មិនពោលពាក្យកុហក ដឹកនាំអ្នកដទៃដើម្បីអំពើដូច្នោះ ដែលជាហេតុឲ្យប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្ដីសុខ អស់កាលជាយូរអង្វែងដល់បុគ្គលនោះមែនឬ ។ មែនហើយ លោកម្ចាស់ ។ ម្នាលសាឡ្ហៈ និងរោហនៈ អ្នកសម្គាល់សេចក្ដីនោះដូចម្ដេច អមោហៈ មានដែរឬ ។ មានដែរ លោកម្ចាស់ ។ ម្នាលសាឡ្ហៈ និងរោហនៈ

អាត្មាពោលសេចក្តីនោះថា អមោហៈ ជាវិជ្ជា ។ ម្នាលសាឡ្ហៈ និងរោហនៈ បុគ្គលអ្នកមិនវង្វេង ប្រកបដោយវិជ្ជានេះ រមែងមិនសម្លាប់សត្វ មិនកាន់យកនូវវត្ថុដែលគេមិនបានឲ្យ មិនគប់រកនូវកិរិយារបស់អ្នកដទៃ មិនពោលពាក្យកុហក ដឹកនាំអ្នកដទៃដើម្បីអំពើដូច្នោះ ដែលជាហេតុឲ្យប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្តីសុខ អស់កាលជាយូរអង្វែងដល់បុគ្គលនោះ មែនឬ ។ មែនហើយ លោកម្ចាស់ ។ ម្នាលសាឡ្ហៈ និងរោហនៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច ធម៌ទាំងអម្បាលនេះ ជាកុសល ឬជាអកុសល ។ ជាកុសល លោកម្ចាស់ ។ ប្រកបដោយទោស ឬមិនប្រកបដោយទោស ។ មិនប្រកបដោយទោសទេ លោកម្ចាស់ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល ឬជាធម៌ដែលអ្នកប្រាជ្ញសរសើរ ។ ជាធម៌ដែលអ្នកប្រាជ្ញសរសើរ លោកម្ចាស់ ។ ជាធម៌ដែលបុគ្គលសមាទានឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្តីសុខ ឬមិនមែនទេ ឬមួយក្នុងដំណើរនុ៎ះ មានប្រការដូចម្តេចទៅវិញ ។ បពិត្រព្រះករុណាដ៏ចម្រើន ធម៌ដែលបុគ្គលសមាទានឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ និងសេចក្តីសុខ យើងខ្ញុំក៏យល់យ៉ាងនេះដែរ ក្នុងដំណើរនុ៎ះ ។ ព្រះនន្ទកៈពោលថា ម្នាលសាឡ្ហៈ និងរោហនៈ យើងបានពោលនូវពាក្យណាដូច្នេះថា ម្នាលសាឡ្ហៈ និងរោហនៈ អ្នកទាំងឡាយចូលមក អ្នកទាំងឡាយ កុំប្រកាន់ដោយការឮតៗ គ្នា កុំប្រកាន់តាមពាក្យបរម្បរា កុំប្រកាន់ដោយបានឮថាដូច្នេះ កុំប្រកាន់ដោយការអាងក្បួនតម្រា កុំប្រកាន់តាមហេតុដែលត្រិះរិះ កុំប្រកាន់ដោយកាត់ជំរួយផ្សេងៗ

កុំប្រកាន់ដោយត្រិះរិះតាមអាការ កុំប្រកាន់ដោយសេចក្តីពេញចិត្តតាមការពិនិត្យថា សមនឹងសេចក្តីយល់ឃើញ កុំប្រកាន់ដោយយល់ថា មានសភាពគួរជឿ កុំប្រកាន់ដោយគិតថា សមណៈ ( នេះ ) ជាគ្រូរបស់យើងដូច្នេះឡើយ ម្នាលសាឡ្ហៈ និងរោហនៈ កាលណា អ្នកទាំងឡាយដឹងដោយខ្លួនឯងថា ធម៌ទាំងអម្បាលនេះ ជាកុសល ធម៌ទាំងអម្បាលនេះ ប្រកបដោយទោស ធម៌ទាំងអម្បាលនេះ ជាធម៌ដែលអ្នកប្រាជ្ញសរសើរ ធម៌ទាំងអម្បាលនេះ ដែលបុគ្គលសមាទានឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ និងសេចក្តីសុខ ម្នាលសាឡ្ហៈ និងរោហនៈ កាលណោះ អ្នកទាំងឡាយ គួរចូលទៅសម្រេចសម្រាន្ត នៅចុះ ពាក្យណា ដែលអាត្មាបានពោលហើយដូច្នេះ ពាក្យនុ៎ះ អាត្មាបានពោលទុកហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលសាឡ្ហៈ និងរោហនៈ អរិយសាវកនោះ ប្រាសចាកអភិជ្ឈា ប្រាសចាកព្យាបាទ ជាអ្នកមិនវង្វេង មានសម្បជញ្ញៈ មានសតិតម្កល់ខ្ជាប់យ៉ាងនេះហើយ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទោះទិសទី ២ ទី ៣ ទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ខាងក្រោម និងទិសទទឹង ផ្សាយទៅកាន់លោកទាំងអស់ ដោយប្រការទាំងពួង ក្នុងទីទាំងពួង ... មានចិត្តប្រកបដោយករុណា ។បេ។ មានចិត្តប្រកបដោយមុទិតា ។បេ។ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទោះទិសទី ២ ទី ៣ ទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តធំទូលាយ ដល់នូវសភាពជាធំ រកប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់ទិស

ខាងលើ ទិសខាងក្រោម និងទិសទទឹង ផ្សាយទៅកាន់លោកទាំងអស់ ដោយប្រការទាំងពួង ក្នុងទីទាំងពួង ។ ព្រះអរិយសាវកនោះ ដឹងច្បាស់ យ៉ាងនេះថា ទុក្ខសច្ចក៏មាន សមុទយសច្ចក៏មាន មគ្គសច្ចក៏មាន និរោធសច្ច ជាគ្រឿងរលាស់ចេញដ៏ក្រៃលែងនូវសញ្ញាក៏មាន ។ កាលព្រះអរិយសាវក នោះ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តរមែងរួចចាកកាមាសវៈផង ចិត្ត រមែងរួចចាកភវាសវៈផង ចិត្តរមែងរួចចាកអវិជ្ជាសវៈផង កាលបើចិត្តរួច ស្រឡះហើយ សេចក្ដីដឹងច្បាស់ ក៏កើតឡើងថា ចិត្តរួចផុតស្រឡះហើយ ដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបាននៅរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ព្រះអរិយសាវកនោះដឹង ច្បាស់យ៉ាងនេះថា លោភៈកើតមានដល់អាត្មាអញក្នុងកាលមុន ធម្មជាត នោះជាអកុសល ឥឡូវនេះ លោភៈនោះ មិនមានឡើយ ធម្មជាតនោះ ឈ្មោះថាជាកុសល ទោសៈកើតមានដល់អាត្មាអញក្នុងកាលមុន ... មោហៈ កើតមានដល់អាត្មាអញក្នុងកាលមុន ធម្មជាតនោះ ជាអកុសល ឥឡូវនេះ មោហៈនោះមិនមានឡើយ ធម្មជាតនោះ ឈ្មោះថា ជាកុសលដូច្នេះ ។ ព្រះ អរិយសាវកនោះ អស់សេចក្ដីស្រេកឃ្លាន ជាអ្នករលត់កិលេស មាន សេចក្ដីត្រជាក់ជាប្រក្រតី ទទួលនូវសេចក្ដីសុខ មានខ្លួនដ៏ប្រសើរ នៅក្នុង បច្ចុប្បន្ន ។

# អដ្ឋកថា

## សាឡ្ហសូត្រ

[ ៦៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសាឡ្ហសូត្រទី ៦ ដូចតទៅនេះ បទថា **មិគារនត្តា** ប្រែថា ជាចៅរបស់មិគារសេដ្ឋី ។ បទថា **បេខុណិយនត្តា** ប្រែថា ជាចៅរបស់បេខុណិយសេដ្ឋី ។ បទថា **ឧបសង្កមឹសុ** សេចក្ដីថា ចៅទាំង ២ បរិភោគអាហារព្រឹកហើយ មានទាសៈ និងកម្មករចោមរោម ចូលទៅរកហើយ ។ បានឮថា ពេលព្រឹកមុនអាហារ ត្រង់ផ្ទះនៃចៅសេដ្ឋី ទាំង ២ នោះតាំងប្រស្នា ១ តែមិនមានឱកាសដែលស្រាយបញ្ហានោះបាន ។ ជនទាំង ២ គិតថា អញនឹងស្ដាប់បញ្ហានោះ ទើបទៅកាន់សម្នាក់របស់ព្រះថេរៈ ថ្វាយបង្គំហើយ អង្គុយជាតុណ្ហីភាព ។

ព្រះថេរៈដឹងចិត្តរបស់បុគ្គលទាំងនោះថា ជនទាំងនោះមកដើម្បីស្ដាប់បញ្ហាដែលកើតក្នុងផ្ទះនោះ ដូច្នេះហើយ កាលផ្ដើមនិយាយគ្នាដល់បញ្ហានោះឯង ទើបពោលពាក្យជាដើមថា **ឯថ តុម្ហេ សាឡ្ហា** ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **អត្ថិ លោភោ** សេចក្ដីថា ព្រះនន្ទកត្ថេរសួរថា ឈ្មោះថា សេចក្ដីលោភ មានការចង់បានជាសភាវៈមានឬ ។ បទថា **អភិជ្ឈាតិ ខោ អហំ សាឡ្ហា ឯតមត្ថំ វទាមិ** សេចក្ដីថា ព្រះនន្ទកត្ថេរកាលសម្ដែងអត្ថនៃបញ្ហាដែលតាំងឡើង ទើបពោលថា ខ្ញុំនឹងពោលអត្ថនេះ ពោល គឺសេចក្ដីលោភ ថាជាអភិជ្ឈា ថាជាតណ្ហា ដូច្នេះ ។ គួរនាំន័យនេះទៅប្រើរាល់ៗ វារៈយ៉ាងនេះ ។

បទថា **សោ ឯវំ បជានាតិ** សេចក្តីថា ព្រះអរិយសាវកនោះចម្រើនព្រហ្មវិហារ ៤ តាំងនៅហើយ ចេញអំពីសមាបត្តិហើយ កាលផ្តើមវិបស្សនារមែងដឹងច្បាស់យ៉ាងនេះ ។ បទថា **អត្ថិ ឥទំ** សេចក្តីថា ព្រះអរិយសាវកនេះ កាលកំណត់ដឹងខន្ធបញ្ចកៈ ពោល គឺទុក្ខសច្ច ដោយអំណាចនៃនាមរូបថា ទុក្ខសច្ចមាន លោកហៅថា ដឹងយ៉ាងនេះថា វត្ថុនេះមាន ។ បទថា **ហីនំ** បានដល់ សមុទយសច្ច ។ បទថា **បណីតំ** បានដល់ មគ្គសច្ច ។ បទថា **ឥមស្ស សញ្ញាគតស្ស ឧត្តរឹ និស្សរណំ** សេចក្តីថា ព្រះនទ្ធកត្ថេរសម្តែងនិរោធសច្ច ដោយពាក្យនេះថា ធម្មតាការស្រុះចេញទៅយ៉ាងក្រៃលែងនៃសញ្ញា ពោល គឺវិបស្សនាសញ្ញានេះ ឈ្មោះថា និព្វាន និព្វាននោះមាន ។

បទថា **វិមុត្តស្មឹ វិមុត្តមិតិ ញាណំ** សេចក្តីថា មានបច្ចវេក្ខណញាណ ១៩ យ៉ាង បានពោលហើយ ។ បទថា **អហុ បុព្វេ លោភោ** សេចក្តីថា ការលោភរបស់អាត្មាអញមានហើយក្នុងកាលមុន ។ បទថា **តទហុ អកុសលំ** សេចក្តីថា នុ៎ះ បានឈ្មោះថា ជាអកុសល ម្យ៉ាងទៀត ឈ្មោះថា អកុសលមានហើយ ក្នុងកាលនោះ ។ បទថា **ឥច្ចេតំ កុសលំ** កាត់បទជា **ឥតិ ឯតំ កុសលំ** ប្រែថា យ៉ាងនេះជាកុសល ។ ព្រះនទ្ធកត្ថេរពោលសំដៅយកការមិនមាននៃអកុសលនោះឯង ថាជាកុសល គឺជាដែនក្សេម ។

បទថា **និច្ឆាតោ** ប្រែថា អស់តណ្ហា ។ បទថា **និព្វុតោ** សេចក្តីថា ឈ្មោះថា រលត់ហើយ ព្រោះមិនមានកិលេសដែលធ្វើនូវការក្តៅក្រហាយខាងក្នុង ។ បទថា **សីតិភូតោ** ប្រែថា ជាអ្នកត្រជាក់ហើយ ។ បទថា

**សុខប្បដិសំវេទី** បានដល់ ជាអ្នកសោយសុខតាមកាយ និងចិត្ត ។ បទថា **ព្រហ្មភូតេន** បានដល់ ជាអ្នកប្រសើរបំផុត ។ ពាក្យដ៏សេស ក្នុងបទទាំងពួងងាយយល់ទាំងអស់ហើយ ដូច្នេះ ។

**អដ្ឋកថា សាឡ្ហសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## កថាវត្ថុសូត្រទី ៧

[ ៦៩ ] ម្នាលភិក្ខុទាំងឡាយ កថាវត្ថុនេះមាន ៣ យ៉ាង ។ កថាវត្ថុ ៣ យ៉ាង ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គឺបុគ្គលពោលពាក្យប្រារព្ធហេតុជាអតីតកាលហើយពោលថា ហេតុជាអតីតកាលមានមកហើយយ៉ាងនេះ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលពោលពាក្យប្រារព្ធហេតុជាអនាគតកាលថា ហេតុជាអនាគតកាល នឹងមានយ៉ាងនេះ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលពោលពាក្យប្រារព្ធហេតុជាបច្ចុប្បន្នកាល ក្នុងកាលឥឡូវនេះថា ហេតុជាបច្ចុប្បន្នកាល ក្នុងកាលឥឡូវនេះយ៉ាងនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតគប្បីដឹង ស្គាល់បុគ្គលដោយការជួបប្រទះដោយពាក្យសម្តីថា នេះជាបុគ្គលដែលគួរសាកច្ឆា ឬមិនគួរសាកច្ឆា ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលនេះ កាលដែលត្រូវគេសួរប្រស្នាហើយ មិនព្យាករប្រស្នាដែលគេសួរ ព្យាករតែមួយ

ចំណែក ( តែម្តង ) មិនព្យាករដោយការចែករំលែកនូវប្រស្នាដែលគួរព្យាករ ដោយការចែករំលែក មិនព្យាករដោយការសួរតប ទៅវិញនូវប្រស្នាដែល គួរព្យាករ ដោយការសួរតបទៅវិញ មិនបញ្ឈប់នូវប្រស្នាដែលគួរបញ្ឈប់ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ បុគ្គលនេះឈ្មោះថា ជាបុគ្គលមិនគួរ សាកច្ឆា ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើបុគ្គលនេះ កាលដែលត្រូវគេសួរ ប្រស្នា ក៏ព្យាករប្រស្នាដែលគួរព្យាករដោយចំណែកមួយ តែមួយចំណែក ( ប៉ុណ្ណោះ ) ព្យាករដោយការចែករំលែកនូវប្រស្នាដែលគួរព្យាករ ដោយ ការចែករំលែក ព្យាករដោយការសួរតបទៅវិញ នូវប្រស្នាដែលគួរព្យាករ ដោយការសួរតបទៅវិញ បញ្ឈប់នូវប្រស្នាដែលគួរបញ្ឈប់ ម្នាលភិក្ខុទាំង-ឡាយ កាលបើយ៉ាងនេះ បុគ្គលនេះ ឈ្មោះថា ជាបុគ្គលគួរសាកច្ឆា ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតគប្បីដឹង ស្គាល់បុគ្គលដោយការចូលប្រទះដោយ ពាក្យសម្តីថា នេះជាបុគ្គលដែលគួរសាកច្ឆា ឬមិនគួរសាកច្ឆា ។ ម្នាលភិក្ខុ ទាំងឡាយ បើបុគ្គលនេះ ដែលត្រូវគេសួរប្រស្នាហើយ មិនតាំងនៅក្នុងឋានៈ ( ហេតុដែលកើតមាន ) និងអដ្ឋានៈ ( ហេតុដែលមិនកើតមាន ) មិនតាំង នៅក្នុងបរិកប្បៈ ( ការកំណត់សួរ និងឆ្លើយ ) មិនតាំងនៅក្នុងវាទៈដែល ខ្ញុំនចេះ មិនតាំងនៅក្នុងបដិបទា ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ បុគ្គលនេះ ឈ្មោះថា ជាបុគ្គលមិនគួរសាកច្ឆា ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើបុគ្គលនេះ កាលដែលត្រូវគេសួរប្រស្នាហើយ ក៏តាំងនៅក្នុងឋានៈ និងអឋានៈ តាំងនៅក្នុងបរិកប្បៈ តាំងនៅក្នុងវាទៈដែលខ្ញុំនចេះដឹង តាំងនៅ

ក្នុងបដិបទា ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ បុគ្គលនេះ ឈ្មោះថា ជាបុគ្គលគួរសាកច្ឆា ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតគប្បីដឹង ស្គាល់បុគ្គល ដោយការចូលប្រទះ ដោយពាក្យសម្តីថា នេះជាបុគ្គលគួរសាកច្ឆា ឬមិនគួរ សាកច្ឆាដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលនេះ កាលដែលត្រូវគេសួរ ប្រស្នាហើយ ក៏ពោលពាក្យបន្ទែបន្ទប់ ផ្តេសផ្តាស នាំយកសម្តីខាងក្រៅមក តំណាលធ្វើសេចក្តីក្រោធខឹង និងសេចក្តីតូចចិត្តឲ្យប្រាកដឡើង ម្នាលភិក្ខុ ទាំងឡាយ កាលបើយ៉ាងនេះ បុគ្គលនេះ ឈ្មោះថា ជាបុគ្គលមិនគួរសាកច្ឆា ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើបុគ្គលនេះ កាលដែលត្រូវគេសួរប្រស្នាហើយ មិនពោលពាក្យបន្ទែបន្ទប់ ផ្តេសផ្តាស មិននាំយកសម្តីខាងក្រៅមកតំណាល មិនធ្វើសេចក្តីក្រោធខឹង និងសេចក្តីតូចចិត្ត ឲ្យប្រាកដឡើង ម្នាលភិក្ខុទាំង-ឡាយ កាលបើយ៉ាងនេះ បុគ្គលនេះ ឈ្មោះថា ជាបុគ្គលគួរសាកច្ឆា ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតគប្បីដឹង ស្គាល់បុគ្គលដោយការចូលប្រទះ ដោយពាក្យសម្តីថា នេះជាបុគ្គលដែលគួរសាកច្ឆា ឬមិនគួរសាកច្ឆាដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើបុគ្គលនេះ កាលដែលត្រូវគេសួរប្រស្នាហើយ និយាយប៉ប៉ាច់ប៉ប៉ោច និយាយសន្តត់សន្ធិន និយាយសើចលេង ប្រុងចាប់ ថ្នាក់ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ បុគ្គលនេះ ឈ្មោះថា ជាបុគ្គល មិនគួរសាកច្ឆា ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើបុគ្គលនេះ កាលដែលត្រូវ គេសួរប្រស្នាហើយ មិននិយាយប៉ប៉ាច់ប៉ប៉ោច មិននិយាយសន្តត់សន្ធិន មិន និយាយសើចលេង មិនប្រុងចាប់ថ្នាក់ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាង

នេះ បុគ្គលនេះ ឈ្មោះថា ជាបុគ្គលគួរសោកច្ឆា ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតគប្បីដឹង ស្គាល់បុគ្គលដោយការចួបប្រទះ ដោយពាក្យសម្តីថា នេះជាបុគ្គលមានឧបនិស្ស័យ ឬមិនមានឧបនិស្ស័យ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលមិនផ្ទៀងត្រចៀកស្តាប់ ជាបុគ្គលមិនមានឧបនិស្ស័យ បុគ្គលដែលផ្ទៀងត្រចៀកស្តាប់ ជាបុគ្គលមានឧបនិស្ស័យ ។ បុគ្គលដែលមានឧបនិស្ស័យនោះ រមែងដឹងច្បាស់នូវធម៌មួយ រមែងកំណត់ដឹងនូវធម៌មួយ រមែងលះបង់នូវធម៌មួយ រមែងធ្វើឲ្យជាក់ច្បាស់នូវធម៌មួយ ។ កាលបុគ្គលនោះ ដឹងច្បាស់នូវធម៌មួយ កំណត់ដឹងនូវធម៌មួយ លះបង់នូវធម៌មួយ ធ្វើឲ្យជាក់ច្បាស់នូវធម៌មួយ រមែងពាល់ត្រូវនូវវិមុត្តិដោយប្រពៃបាន ។ ម្នាលភិក្ខុទាំងឡាយ ការនិយាយ ការប្រឹក្សាគ្នា ឧបនិស្ស័យ និងការផ្ទៀងត្រចៀកស្តាប់ សុទ្ធតែមានការរួចផុតនៃចិត្ត ព្រោះមិនប្រកាន់មាំ ទុំះជាប្រយោជន៍ ។

ជនទាំងឡាយណា និយាយ ( ទាំងកំហឹង ) ជាអ្នកប្រកាន់ខ្ជាប់ ជាអ្នកលើកតម្កើងខ្លួនពោលទាក់ទង ដល់អនរិយគុណ ជាអ្នកស្វែងរកកំហុសគ្នាទៅវិញទៅមក តែងត្រេកអរ ចំពោះពាក្យទុព្ភាសិត សេចក្តីភ្លាំងភ្លាត់ កាន់ប្រឡំនឹងការផ្ចាញ់សម្តីនៃគ្នានឹងគ្នា ឯអរិយជនមិនប្រព្រឹត្តការនិយាយដូច្នោះឡើយ ។ បើអរិយជនប្រាថ្នានឹងនិយាយ ក៏ជាអ្នកឈ្លាស ស្គាល់កាលនិយាយតែពាក្យសម្តីដែលប្រកបដោយធម៌ ជាសម្តីដែលអរិយជន

ធ្លាប់ប្រព្រឹត្តមកហើយ ជាអ្នកមានប្រាជ្ញា មិនក្រោធ មិនលើកខ្លួន មានចិត្ត ឥតមានមានះគ្របសង្កត់ ជាអ្នកមិនលើកកម្ពស់ ជាអ្នកមិនរួសរាន់ លោកជាអ្នកមិនមានឫស្យា និងសេចក្តីប្រកាន់ខ្លួន ដឹងពិតហើយ ទើបនិយាយ សម្តីដែលគេនិយាយត្រូវក៏អនុមោទនា កាលបើគេនិយាយខុស ក៏មិនដេញដោល មិនប្រុងប្រណាំងប្រជែង មិនអាងហេតុចាប់ខុសគេ មិននិយាយប៉ប៉ាច់ប៉ប៉ោច មិននិយាយសង្កត់សង្កិនគេ មិននិយាយបាតដៃជាខ្នងដៃ ។ ការប្រឹក្សាគ្នារបស់សប្បុរសទាំងឡាយតែងប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីសេចក្តីជ្រះថ្លា អរិយជនទាំងឡាយ តែងប្រឹក្សាគ្នាយ៉ាងនេះ នេះជាការប្រឹក្សានៃអរិយជនទាំងឡាយ បុគ្គលអ្នកមានបញ្ញា កាលបើដឹងសេចក្តីនុ៎ះច្បាស់ហើយ មិនគួរនិយាយប្រឹក្សាលើកតម្កើងតែខ្លួនឯងឡើយ ។

# អដ្ឋកថា

## កថាវត្ថុសូត្រ

[ ៦៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកថាវត្ថុសូត្រទី ៧ ដូចតទៅនេះ បទថា **កថាវត្ថូនិ** បានដល់ ហេតុដែលឲ្យកើតកថា អធិប្បាយថា ជាគ្រឹះ គឺជាទីតាំងនៃកថា ។ បទថា **អតីតំ វា ភិក្ខវេ អទ្ធានំ** សេចក្ដីថា កាលក្ដី ខន្ធក្ដី ឈ្មោះថា **អតីតទ្ធា** ក៏គួរ ។ ក្នុងអនាគត និងបច្ចុប្បន្ន ក៏មានន័យតែមួយដូចគ្នានេះ ។

ក្នុងបណ្ដាកាលទាំង ៣ នោះ កាលពោលដោយន័យនេះថា ព្រះសម្មាសម្ពុទ្ធព្រះនាមកស្សប ដែលមកហើយក្នុងអតីត ព្រះបាទក្រុងកាសីទ្រង់ព្រះនាមកិកិ បានជាអគ្គឧបដ្ឋាករបស់ព្រះអង្គ ទ្រង់មានព្រះជន្មាយុយឺនយូរ ដល់ទៅ ២០០០០ ឆ្នាំ ដូច្នេះ ឈ្មោះថា ពោលកថាប្រារព្ធអតីត ។

កាលពោលដោយន័យថា ព្រះពុទ្ធព្រះនាមមេត្តេយ្យ នឹងមានមកក្នុងអនាគត ព្រះរាជាព្រះនាមសង្ខ: ជាអគ្គឧបដ្ឋាករបស់ព្រះអង្គ ទ្រង់មានព្រះជន្មាយុ ៨០០០០ ឆ្នាំ ដូច្នេះ ឈ្មោះថា កថាពោលប្រារព្ធអនាគត ។

កាលពោលដោយន័យជាដើមថា ក្នុងបច្ចុប្បន្ននេះ ព្រះរាជាព្រះនាមយ៉ាងនោះជាធម្មិករាជ អង្គនោះក៏ជាធម្មិករាជ ដូច្នេះ ឈ្មោះថា កថាពោលប្រារព្ធបច្ចុប្បន្ន ។

បទថា **កថាសម្បយោគេន** បានដល់ ប្រកបគ្នា ។ បទថា **កច្ឆោ** ប្រែថា គួរពោល ។ បទថា **អកច្ឆោ** សេចក្ដីថា មិនគួរពោល គប្បីជ្រាប

វិនិច្ឆ័យក្នុងពាក្យថា **ឯកំសព្យាករណីយំ បញ្ហំ** ដូច្នេះ បុគ្គលត្រូវសួរថា ចក្ខុមិនទៀងឬ គួរឆ្លើយដោយចំណែកមួយថា ត្រូវហើយ ចក្ខុមិនទៀង ។ ក្នុងឥន្ទ្រិយទាំងឡាយ មានសោតៈជាដើមក៏មានន័យនេះដូចគ្នា នេះឈ្មោះថា ជាបញ្ហាដែលគប្បីឆ្លើយដោយចំណែកមួយ ។

តែបុគ្គលត្រូវសួរថា ចក្ខុ ឈ្មោះថា មិនទៀងឬ ក៏គួរញែកចម្លើយ យ៉ាងនេះថា មិនមែនចក្ខុតែម្យ៉ាងទេ ដែលមិនទៀង សូម្បីសោតៈក៏មិនទៀង ឃានៈក៏មិនទៀង នេះឈ្មោះថា ជាបញ្ហាដែលត្រូវញែកចម្លើយ ។

បុគ្គលត្រូវសួរថា សោតៈដូចគ្នានឹងចក្ខុ ចក្ខុដូចគ្នានឹងសោតៈ គួរសួរថា អ្នកសួរដោយបំណងយកអ្វី កាលបុគ្គលនោះឆ្លើយថា ខ្ញុំសួរសំដៅដល់ការឃើញ ហើយទើបឆ្លើយថា មិនដូចគ្នា តែកាលបុគ្គលនោះឆ្លើយថា ខ្ញុំសួរសំដៅដល់ការមិនទៀង ក៏គួរឆ្លើយថា ត្រឹមត្រូវហើយ នេះឈ្មោះថា ជាប្រស្នាដែលគប្បីត្រូវសាកសួរ ហើយទើបឆ្លើយ ។

តែបុគ្គលត្រូវសួរបញ្ហាជាដើមថា ជីវៈនោះ ជាសរីរៈនោះឬ គួរវៀរចាកការឆ្លើយ ដោយពោលថា សេចក្ដីនេះ ព្រះមានព្រះភាគទ្រង់មិនព្យាករ បញ្ហាបែបនេះ ជាបញ្ហាដែលមិនគួរព្យាករ នេះឈ្មោះថា ជាបញ្ហាដែលគួរវៀរចម្លើយ ។

បទថា **ឋានដ្ឋានេ ន សណ្ឋាតិ** សេចក្ដីថា មិនតាំងនៅក្នុងហេតុ ឬក្នុងវត្ថុដែលមិនមែនហេតុ ។ ក្នុងសេចក្ដីនោះ មានន័យដូច្នេះ សស្សតវាទីបុគ្គល ជាអ្នកដល់នូវលទ្ធិថា ស្ថិតស្ថេរ អាចសង្កត់សង្កិនឧច្ឆេទវាទីបុគ្គល

បុគ្គល ដែលកាន់យកថា ដាច់សូន្យ ដោយហេតុដែលសមគួរបាន ឧច្ឆេទ-វាទីបុគ្គល កាលត្រូវសង្កត់សង្កិន នឹងសម្ដែងភាពជាសស្សតវាទីបុគ្គលចេញមកថា ខ្ញុំពោលការដាច់សូន្យឬ បុគ្គលនោះ ឈ្មោះថា មិនអាចប្រាកដប្រជាក្នុងវាទៈរបស់ខ្លួនបាន កាលឧច្ឆេទវាទីបុគ្គលអាចសង្កត់សង្កិនយ៉ាងនេះ បុគ្គលនឹងក្លាយជាសស្សតវាទីបុគ្គលទៅ កាលបុគ្គលវាទីបុគ្គល ( បុគ្គលដែលមានលទ្ធិថាមានបុគ្គល ) អាច ( សង្កត់សង្កិន ) បុគ្គលនោះក៏ក្លាយជាសុញ្ញតវាទីបុគ្គល ( បុគ្គលដែលប្រកាន់ថា ដាច់សូន្យ ) កាលសុញ្ញត-វាទីបុគ្គលអាច ( សង្កត់សង្កិន ) បុគ្គលនោះក៏ក្លាយជាបុគ្គលវាទីបុគ្គល ដោយប្រការដូចពោលមកនេះ រមែងឈ្មោះថា មិនប្រាកដប្រជា ទាំងក្នុងឋានៈ អឋានៈ ។

ពាក្យថា **បរិកប្បេ ន សណ្ឋាតិ** នេះ បានទាំងក្នុងការសាកសួរបញ្ហា និងការឆ្លើយបញ្ហា ។ សួរថា សេចក្ដីនេះដូចម្ដេច ឆ្លើយថា បុគ្គលពួកខ្លះ អើតកបំណងនឹងសួរបញ្ហាថា អាត្មាអញនឹងសួរបញ្ហាបុគ្គលនោះមើល បុគ្គលម្នាក់ទៀតពោលថា អ្នកនឹងសាកសួរបញ្ហានេះឬ ដឹងថា បុគ្គលនោះដឹងហើយ ក៏ពោលថា មិនមែនសេចក្ដីនេះ ខ្ញុំសួរសេចក្ដីដទៃ ។ សូម្បីលោកត្រូវសួរបញ្ហា ក៏ហើបចង្កាបំណងនឹងឆ្លើយបញ្ហាថា ខ្ញុំនឹងឆ្លើយបញ្ហា ។ បុគ្គលត្រូវបុគ្គលម្នាក់ទៀតពោលថា អ្នកឆ្លើយបញ្ហានេះឬ ដឹងថា បុគ្គលនោះដឹងហើយ ក៏ពោលថា មិនមែនសេចក្ដីនេះ ខ្ញុំនឹងឆ្លើយសេចក្ដីដទៃ យ៉ាងនេះ ឈ្មោះថា មិនតាំងមាំនៅក្នុងប្រការដែលខ្លួនកំណត់ ។

បទថា **អញ្ញវាទេន ច សណ្ឋាតិ** សេចក្តីថា មិនតាំងមាំក្នុងវាទៈដែលដឹងហើយ គឺក្នុងវាទៈដែលជ្រាបហើយ ។ សួរថា សេចក្តីនេះដូចម្តេច ឆ្លើយថា បុគ្គលខ្វះសួរបញ្ហា បុគ្គលម្នាក់ទៀតពោលនឹងបុគ្គលនោះថា អ្នកសួរបញ្ហាត្រូវចិត្ត បញ្ហានេះ អ្នករៀនមកអំពីណា ។ បុគ្គលម្នាក់ទៀតសួរបញ្ហាតាមគន្លងដែលត្រូវសួរនោះឯង ញុំាងឲ្យកើតការច្ងល់ក្នុងពាក្យដល់បុគ្គលនោះថា ខ្ញុំសួរហើយ មិនត្រូវគន្លង ឬដូចម្តេច បុគ្គលម្នាក់ទៀតត្រូវសួរបញ្ហាហើយឆ្លើយបញ្ហា ។ បុគ្គលដទៃពោលនឹងបុគ្គលនោះថា អ្នកឆ្លើយបញ្ហាល្អហើយ អ្នករៀនបញ្ហាមកអំពីណា ធម្មតាអ្នកឆ្លើយបញ្ហា ត្រូវឆ្លើយយ៉ាងនេះ ។ ឯបុគ្គលម្នាក់ទៀត សូម្បីឆ្លើយបញ្ហាតាមគន្លងដែលត្រូវឆ្លើយនោះឯង តែងញុំាងឲ្យកើតសេចក្តីងឿងឆ្ងល់ក្នុងពាក្យ ដល់បុគ្គលនោះថា ខ្ញុំឆ្លើយទៅហើយ មិនត្រង់គន្លង ឬដូចម្តេច ។

បទថា **បដិបទាយ ច សណ្ឋាតិ** សេចក្តីថា មិនតាំងនៅក្នុងបដិបទា អធិប្បាយថា សួរក្នុងវត្ថុដែលមិនគួរសួរ ដោយមិនដឹងទំនៀម ។ ធម្មតាបញ្ហានេះ បុគ្គលដែលត្រូវគេសួរត្រង់លានចេតិយ មិនគួរឆ្លើយ ។ តាមផ្លូវភិក្ខាចារក្តី ក្នុងពេលត្រាច់ទៅបិណ្ឌបាតក្នុងស្រុកក្តី ក្នុងពេលអង្គុយលើអាសនៈសាលាក្តី ក្នុងពេលអង្គុយទទួលបបរ និងភត្តក្តី ក្នុងវេលាឆាន់ក្តី ក្នុងវេលាដើរផ្លូវទៅកាន់ទីសម្រាកពេលថ្ងៃក្តី ក៏មិនគួរឆ្លើយដូចគ្នា ។ តែក្នុងវេលាអង្គុយក្នុងទីសម្រាកពេលថ្ងៃ កាលបុគ្គលសូមឱកាសមុនសួរ ក៏គួរឆ្លើយ កាលមិនសូមឱកាស ហើយសួរ ក៏មិនគួរឆ្លើយ ។ បុគ្គលសួរដោយ

មិនដឹងទំនៀម នេះឈ្មោះថា មិនតាំងមាំក្នុងបដិបទា ។ បទថា **ឯវំ សន្តាយំ ភិក្ខវេ បុគ្គលោ អកច្ឆោ ហោតិ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ កាល ហេតុនេះមាន បុគ្គលនេះឈ្មោះថា មិនគួរឆ្លើយបញ្ហានេះ ។ បទថា **ឋានដ្ឋានេ សណ្ឋាតិ** សេចក្តីថា សស្សតវាទីបុគ្គលមានល្មមនឹងសង្កត់ឧច្ឆេទវាទី- បុគ្គល ។ ឧច្ឆេទវាទីបុគ្គល សូម្បីត្រូវសស្សតវាទីបុគ្គលសង្កត់សង្កិន ក៏ពោល អះអាងថា ខ្ញុំត្រូវពួកអ្នកសង្កត់សង្កិនអស់ ៧ ដង ក៏គង់ជាឧច្ឆេទវាទីនោះឯង ក្នុងសស្សតវាទីបុគ្គល បុគ្គលវាទីបុគ្គល និងសុញ្ញតវាទីបុគ្គល ក៏គប្បីនាំ ន័យទៅដោយន័យនេះឯង យ៉ាងនេះ ឈ្មោះថា តាំងមាំនៅក្នុងឋានៈ និង អឋានៈ ។

បទថា **បរិកប្បេ សណ្ឋាតិ** សេចក្តីថា បុគ្គលពួកខ្លះអើតកបំណងនឹង សួរបញ្ហាថា ខ្ញុំនឹងសួរបញ្ហា កាលត្រូវបុគ្គលនោះពោលថា អ្នកនឹងសួរបញ្ហា ឈ្មោះនេះឬ ក៏ឆ្លើយថា ត្រឹមត្រូវហើយ ខ្ញុំនឹងសួរបញ្ហានេះឯង សូម្បីលោក ត្រូវសួរបញ្ហា ក៏កម្រើកថ្គាមបំណងនឹងឆ្លើយបញ្ហាថា ខ្ញុំនឹងឆ្លើយបញ្ហា កាល ត្រូវសួរថា អ្នកនឹងឆ្លើយបញ្ហានេះឬ ក៏ពោលអះអាងថា ត្រឹមត្រូវហើយ ខ្ញុំនឹង ឆ្លើយបញ្ហានេះឯង យ៉ាងនេះ ឈ្មោះថា តាំងមាំនៅក្នុងប្រការដែលកំណត់ ។

បទថា **អញ្ញាវាទេ សណ្ឋាតិ** សេចក្តីថា បុគ្គលពួកខ្លះ សួរបញ្ហា ហើយ មានបុគ្គលពោលថា អ្នកសួរបញ្ហាល្អហើយ ធម្មតាអ្នកសួរបញ្ហាគួរ សួរយ៉ាងនេះ ដូច្នេះហើយ ក៏ទទួលមិនឲ្យកើតការឆ្ងល់ដល់អ្នកដទៃ ។ សូម្បីឆ្លើយបញ្ហាហើយ កាលមានបុគ្គលពោលថា អ្នកឆ្លើយបញ្ហាល្អហើយ

ធម្មតាអ្នកឆ្លើយបញ្ហា គួរឆ្លើយយ៉ាងនេះ ក៏ទទួលមិនឲ្យកើតការឆ្ងើងឆ្ងល់ ( យ៉ាងនេះ ឈ្មោះថា តាំងមាំនៅក្នុងវាទៈរបស់អ្នកដទៃ ) ។

បទថា **បដិបទាយ សណ្ឋាតិ** សេចក្ដីថា ភិក្ខុរបខ្លះ គេនិមន្តឲ្យអង្គុយក្នុងផ្ទះ ប្រគេនបបរ និងរបស់ទំពាជាដើម អង្គុយក្នុងចន្លោះ របួតស្រេចភត្តកិច្ច ទើបសួរបញ្ហា កាន់យកភេសជ្ជៈ មានសប្បិជាដើម ទឹកបាន ៨ យ៉ាង ឬសំពត់ជាគ្រឿងបិទបាំង កម្រងផ្កា និងគ្រឿងក្រអូបជាដើម ដើរទៅវិហារ ឲ្យនូវរបស់ទាំងនោះហើយ ចូលកាន់ទីសម្រាកពេលថ្ងៃ សូមឱកាសហើយ ទើបសួរបញ្ហា ពិតហើយ បុគ្គលសួរបញ្ហាដោយដឹងទំនៀមយ៉ាងនេះ ឈ្មោះថា តាំងមាំនៅក្នុងបដិបទា កាលឆ្លើយបញ្ហារបស់បុគ្គលនោះក៏គួរ ។

បទថា **អញ្ញេនញ្ញំ បដិចរតិ** សេចក្ដីថា បិទបាំងនូវពាក្យណាមួយដោយពាក្យមួយទៀត ឬត្រូវសួរបញ្ហាណាមួយ ទៅឆ្លើយបញ្ហាមួយទៀត ។ បទថា **ពហិទ្ធា កថំ អបនាមេតិ** សេចក្ដីថា កាលឆ្លងរឿងដំបូង ឈ្មោះថាពោលបញ្ចិតបញ្ចៀង គឺមិនត្រង់ទៅត្រង់មក ។ ក្នុងសេចក្ដីនោះ មានរឿងដូចតទៅនេះ

បានឮថា ភិក្ខុទាំងឡាយប្រជុំគ្នាហើយ ពោលនឹងភិក្ខុកំលោះមួយរូបថា អាវុសោ លោកត្រូវអាបត្តិឈ្មោះនេះ និងឈ្មោះនេះ ។ ភិក្ខុកំលោះឆ្លើយថា បពិត្រលោកដ៏ចម្រើន ខ្ញុំដើរទៅកាន់នាគទ្វីប ភិក្ខុទាំងឡាយពោលថា អាវុសោពួកខ្ញុំមិនដាក់ចិត្តក្នុងរឿងដែលអ្នកទៅកាន់នាគទ្វីប តែពួកខ្ញុំសួរលោកថា

លោកត្រូវអាបត្តិឬ ភិក្ខុកំលោះពោលថា បពិត្រលោកម្ចាស់ ខ្ញុំទៅនាគទ្វីប ហើយឆាន់ត្រី ភិក្ខុទាំងឡាយពោលថា អាវុសោ រឿងឆាន់ត្រីរបស់លោក មិនទាក់ទងនឹងពួកខ្ញុំ ឮថា លោកត្រូវអាបត្តិ ភិក្ខុកំលោះពោលថា ត្រីមិន សូវឆ្អិន ធ្វើឲ្យខ្ញុំមិនសប្បាយ ។ ភិក្ខុទាំងឡាយពោលថា អាវុសោ ទោះ លោកសប្បាយ ឬមិនសប្បាយ មិនទាក់ទងនឹងពួកខ្ញុំ តែលោកត្រូវអាបត្តិ ។ ភិក្ខុកំលោះពោលថា បពិត្រលោកម្ចាស់ ខ្ញុំមិនសប្បាយអស់កាលដែលនៅ ក្នុងនាគទ្វីបនោះ ។

ដោយរឿងតាមដែលពោលមកនេះ គប្បីជ្រាបថា ឈ្មោះថា រមែង ពោលបណ្តោះបណ្តោយទៅក្រៅរឿង ដោយការយករឿងដទៃមកពោលជួស ។

បទថា **អភិហរតិ** សេចក្តីថា ពោលប៉ប៉ាច់ប៉ប៉ោច ដោយនាំយក សូត្រនេះខ្លះ នោះខ្លះ ដូចព្រះតេបិដកតិស្សត្ថេរ ។ បានឮមកថា កាលមុន ភិក្ខុទាំងឡាយប្រជុំគ្នា ត្រង់លានមហាចេតិយ ធ្វើកិច្ចរបស់សង្ឃហើយ ឲ្យ ឱវាទដល់ភិក្ខុទាំងឡាយ ហើយសន្ទនា សាកសួរបញ្ហាដល់គ្នានិងគ្នា ក្នុងទី ប្រជុំនោះ ព្រះថេរៈរូបនេះទាញយកព្រះសូត្រមកអំពីគម្ពីរនោះៗ អំពីព្រះត្រៃ បិដកអស់មួយថ្ងៃ សូម្បីបញ្ហាតែមួយក៏មិនចប់ ។ បទថា **អភិមទ្ទតិ** សេចក្តី ថា ទាញហេតុមកពោលសង្កត់សង្កិន ។ បទថា **អនុបជគ្ឃតិ** សេចក្តីថា កាលភិក្ខុរូបដទៃសួរបញ្ហាក្តី ឆ្លើយបញ្ហាក្តី ទះដៃ សើចឡូឡា ដែលជាហេតុ ឲ្យកើតការងឿងឆ្ងល់ថា ខ្ញុំសួរបញ្ហាដែលអ្នកដទៃគេមិនសួរ ឬសួរបញ្ហា ដែលគេមិនឆ្លើយ ។ បទថា **ខលិតំ គណ្ហាតិ** សេចក្តីថា ចាប់យកសេចក្តី

ដែលពោលភ្ជាំងភ្ជាត់ទៅបន្តិចបន្តួច គឺត្រាប់លើកទោសថា សេចក្តីនេះ ត្រូវធ្វើយ៉ាងនេះ ក្នុងកាលពោលភ្ជាត់ ១ អក្ខរៈក្តី ១ បទក្តី ១ ព្យញ្ជនៈក្តី ។

បទថា **អនុបនិសោ** បានដល់ មានឧបនិស្ស័យ គឺមានបច្ច័យ ។ បទថា **ឱហិតសោ្តតោ** បានដល់ តាំងចិត្តស្តាប់ ។ បទថា **អភិជានាតិ ឯកំ ធម្មំ** សេចក្តីថា ដឹងក្រៃលែងនូវកុសលធម៌ណាមួយ គឺដឹងអរិយមគ្គ ។ បទថា **បរិជានាតិ ឯកំ ធម្មំ** សេចក្តីថា កំណត់ដឹងនូវទុក្ខសច្ចធម៌ណាមួយ ដោយតីរណបរិញ្ញា ។ បទថា **បជហាតិ ឯកំ ធម្មំ** សេចក្តីថា លះនូវធម៌ ១ គឺអកុសលធម៌ទាំងអស់ ។ បទថា **សច្ឆិករោតិ ឯកំ ធម្មំ** សេចក្តីថា ធ្វើនូវធម៌ណាមួយ គឺអរហត្តផលធម៌ ឬនិរោធនោះឯងឲ្យប្រចក្ស ។ បទថា **សម្មា វិមុត្តឹ ផុសតិ** សេចក្តីថា ពាល់ត្រូវវិមោក្ខ គឺអរហត្តផល ដោយការពាល់ត្រូវដោយញាណ ដោយប្រពៃ គឺដោយហេតុ ដោយន័យ ដោយការណ៍ ។ បទថា **ឯតទត្ថា ភិក្ខវេ កថា** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ កថាដែលតថាគតសម្តែងថា ដោយការពោលសន្ទនាប្រាស្រ័យគ្នា មានវិមុត្តិជាប្រយោជន៍ បានដល់ មានការរួចផុតនៃចិត្ត ព្រោះមិនប្រកាន់មាំ នេះជាគោល គឺជាទីតាំង ជាវត្ថុនៃកថានោះ គប្បីជ្រាបការប្រកបសេចក្តីក្នុងបទទាំងអស់ ដូចពណ៌នាមកនេះ ។ បទថា **ឯតទត្ថា មន្តនា** សេចក្តីថា ក្នុងបណ្តាបុគ្គលដែលសមគួរ និងមិនសមគួរ ការប្រឹក្សាជាមួយបុគ្គលដែលសមគួរនេះ មានវិមុត្តិនេះជាប្រយោជន៍ដូចគ្នា ។ បទថា **ឯតទត្ថា ឧបនិសា** សេចក្តីថា សូម្បីឧបនិស្ស័យដែលត្រាស់យ៉ាងនេះថា បុគ្គលផ្ទៀងនូវសោតៈ

ស្តាប់ ដែលមានឧបនិស្ស័យ មានវិមុត្តិនេះជាប្រយោជន៍ដូចគ្នា ។ បទថា **ឯតទត្ថំ សោតាវធានំ** សេចក្តីថា សូម្បីការផ្ទៀងសោតៈ ព្រមទាំងឧប-និស្ស័យរបស់បុគ្គលនោះ មានវិមុត្តិនេះជាប្រយោជន៍ដូចគ្នា ។ បទថា **អនុបាទា** ប្រែថា ព្រោះការមិនប្រកាន់មាំ ដោយឧបាទានទាំង ៤ ។ ការរួចផុត គឺអរហត្តផល ឈ្មោះថា ការរួចផុតនៃចិត្ត ។

ព្រោះថា ពាក្យទាំងអស់នេះ ត្រាស់ដើម្បីប្រយោជន៍ដល់អរហត្តផល ព្រោះដូច្នោះ កាលទ្រង់សរុបព្រះសូត្ររួមកំពូលដោយព្រះគាថាតទៅ ទើបត្រាស់ពាក្យជាដើមថា **យេ វិរុទ្ធា** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **វិរុទ្ធា** សេចក្តីថា ខុសគ្នាព្រោះក្រោធ ពោល គឺពិរោធ ។ បទថា **សល្លបន្តិ** បានដល់ ការចរចាប្រាស្រ័យគ្នា ។ បទថា **វិនិវិដ្ឋា** បានដល់ បុគ្គលប្រកាន់ខ្ជាប់ ។ បទថា **សមុស្សិតា** សេចក្តីថា លើកឡើងខ្ពស់ ដោយអំណាចមានះ ។ បទថា **អនរិយគុណមាសជ្ជ** សេចក្តីថា ពោលគុណកថាដែលមិនមែនបែបផែនរបស់ព្រះអរិយៈ ប៉ះខ្ទប់នូវគុណ អធិប្បាយថា ពោលកថាប៉ះខ្ទប់នូវគុណ គឺសេចក្តីល្អ ដែលឈ្មោះថា **អនរិយកថា** មិនមែនអរិយ-កថា ។ បទថា **អញ្ញោញ្ញវិវរេសិនោ** សេចក្តីថា ស្វែងរកឱកាស គឺកំហុសនៃគ្នានិងគ្នា ។ បទថា **ទុព្ភាសិតំ** បានដល់ ពោលមិនល្អ ។ បទថា **វិក្ខលិតំ** បានដល់ និយាយភ្លាត់បន្តិចបន្តួច ។ បទថា **លម្បមោហំ បរាជយំ** សេចក្តីថា ត្រេកអរនូវការភ្លាំងភ្លាត់ និងការឈ្នះចាញ់នៃគ្នានិងគ្នា ព្រោះមាត់រឹងបន្តិចបន្តួច ។ បទថា **អភិនន្ទន្តិ** ប្រែថា ត្រេកអរ ។ បទថា **នាចរេ** សេចក្តី

ថា មិនប្រព្រឹត្តទៅ គឺមិនពោល ។ បទថា **ធម្មដ្ឋប្បដិសំយុត្តា** សេចក្តីថា កថាដែលបុគ្គលតាំងនៅក្នុងធម្មសន្ទនាគ្នា ឈ្មោះថា ធម្មដ្ឋប្បដិសំយុត្តា ព្រោះតាំងនៅក្នុងធម៌ផង ប្រកបដោយធម៌ទាំងនោះផង ។ បទថា **អនុត្តិណ្ណេន មនសា** បានដល់ មានចិត្តមិនរាយមាយ ។ បទថា **អបឡាសោ** សេចក្តីថា មិនវាយឫកស្មើ ដោយការវាយស្មើ ដោយធ្វើជាគូប្រណាំងប្រជែង ។ បទថា **អសាហសោ** សេចក្តីថា មិនខ្លាំងក្លាដោយអំណាចសេចក្តីខ្លាំងក្លា គឺរាគៈ ទោសៈ និងមោហៈ ។ បទថា **អនុស្សុយ្យមានោ** បានដល់ មិនប្រណែន ។ បទថា **ទុត្ភដ្ឋេ នាប្បសាទយេ** សេចក្តីថា មិនរុករានព្រោះពាក្យដែលក្លាំងក្លាត់ ។ បទថា **ឧចារម្ភំ ន សិក្ខេយ្យ** សេចក្តីថា មិនដាក់ចិត្តនូវពាក្យតិះដៀលដែលមានលក្ខណៈហួសហេតុ ។ បទថា **ខលិតញ្ច ន គាហយេ** សេចក្តីថា វាចាដែលភ្លាត់មាត់បន្តិចបន្តួច មិនប្រកាន់ថា នេះជាការខុសរបស់អ្នក ។ បទថា **នាភិហារេ** បានដល់ មិននិយាយប៉ប៉ាច់ប៉ប៉ោច ។ បទថា **នាភិមទ្ទេ** បានដល់ មិននិយាយញាំញីដោយអាងហេតុណាមួយ ។l៚

**អដ្ឋកថាកថាវត្ថុសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## តិត្ថិយសូត្រទី ៨

[ ៧០ ] ម្នាលភិក្ខុទាំងឡាយ បើបរិព្វាជកជាអន្យតិរ្ថិយ គប្បីសួរ ( អ្នកទាំងឡាយ ) យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ធម៌ទាំងឡាយ អម្បាលនេះមាន ៣ យ៉ាង ។ ធម៌ទាំង ៣ យ៉ាង តើដូចម្តេច ។ គឺរាគៈ ១ ទោសៈ ១ មោហៈ ១ ។ ម្នាលអាវុសោទាំងឡាយ ធម៌មាន ៣ យ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ធម៌ទាំង ៣ យ៉ាងនេះ ប្លែកគ្នាដូចម្តេច មានអធិប្បាយដូចម្តេច មានសេចក្តីផ្សេងគ្នាដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កាលត្រូវគេសួរយ៉ាងនេះហើយ គប្បីព្យាករដូចម្តេច ដល់ពួកបរិព្វាជកជាអន្យតិរ្ថិយទាំងអម្បាលនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់យើងខ្ញុំព្រះអង្គ មានព្រះដ៏មានព្រះភាគជាទីតាំង មានព្រះដ៏មានព្រះភាគជាអ្នកណែនាំ មានព្រះដ៏មានព្រះភាគជាទីពឹង ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គ សូមព្រះរាជទានឱកាស សូមព្រះដ៏មានព្រះភាគបំភ្លឺសេចក្តីនៃភាសិតនុ៎ះឲ្យទាន ភិក្ខុទាំងឡាយបានស្តាប់ព្រះដ៏មានព្រះភាគហើយ នឹងចងចាំទុក ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងអម្បាលនោះទទួលព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បើពួកបរិព្វាជកជាអន្យតិរ្ថិយ គប្បីសួរយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ធម៌

ទាំងអម្បាលនេះ មាន ៣ យ៉ាង ។ ធម៌ ៣ យ៉ាង តើដូចម្ដេច ។ គឺរាគៈ ១ ទោសៈ ១ មោហៈ ១ ។ ម្នាលអាវុសោទាំងឡាយ ធម៌មាន ៣ យ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ធម៌ទាំង ៣ យ៉ាងនេះ ប្លែកគ្នាដូចម្ដេច មានអធិប្បាយដូចម្ដេច មានសេចក្ដីផ្សេងគ្នាដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ កាលអ្នកទាំងឡាយ ត្រូវគេសួរយ៉ាងនេះហើយ គប្បីដោះស្រាយដល់ពួកបរិព្វាជក ជាអន្យតិរ្ថិយអម្បាលនោះ យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ រាគៈមានទោសតិច ប៉ុន្តែក្រសាបរលាប ទោសៈមានទោសច្រើន ប៉ុន្តែឆាប់សាបរលាប មោហៈមានទោសច្រើនផង ក្រសាបរលាបផង ។ ម្នាលអាវុសោទាំងឡាយ ចុះអ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យរាគៈដែលមិនទាន់កើតឲ្យកើតឡើងក្ដី រាគៈដែលកើតឡើងហើយ ឲ្យរីងរឹតតែចម្រើនឡើងក្ដី ។ គួរដោះស្រាយថា សុភនិមិត្ត ( អារម្មណ៍ដែលល្អ ) ។ កាលបុគ្គលនោះ ធ្វើទុកក្នុងចិត្តនូវសុភនិមិត្ត ដោយមិនជាឧបាយនៃបញ្ញា រាគៈដែលមិនទាន់កើតឡើងក៏កើតឡើងផង រាគៈដែលកើតឡើងហើយ ក៏រីងរឹតតែចម្រើនច្រើនឡើងផង ។ ម្នាលអាវុសោទាំងឡាយ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យរាគៈដែលមិនទាន់កើតឡើងឲ្យកើតឡើងផង រាគៈដែលកើតឡើងហើយ ឲ្យរីងរឹតតែចម្រើនច្រើនឡើងផង ។ ម្នាលអាវុសោទាំងឡាយ ចុះអ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យទោសៈដែលមិនទាន់កើតឡើង ឲ្យកើតឡើងបានក្ដី ទោសៈដែលកើតឡើងហើយ ឲ្យរីងរឹតតែចម្រើនច្រើនឡើងក្ដី ។ គួរដោះស្រាយថា បដិឃនិមិត្ត ( អារម្មណ៍ដែលទាស់ចិត្ត ) ។ កាលបុគ្គលនោះ

ធ្វើទុកក្នុងចិត្តនូវបដិឃនិមិត្ត ដោយមិនជាឧបាយនៃបញ្ញា ទោសៈដែលមិនទាន់កើតឡើង ក៏កើតឡើងផង ទោសៈដែលកើតឡើងហើយ ក៏រឹងរឹតតែចម្រើនច្រើនឡើងផង ម្នាលអាវុសោទាំងឡាយ នេះជាហេតុ នេះជាបច្ច័យដែលនាំឲ្យទោសៈ ដែលមិនទាន់កើតឡើង ឲ្យកើតឡើងផង ទោសៈដែលកើតឡើងហើយ ឲ្យរឹងរឹតតែចម្រើនឡើងផង ។ ម្នាលអាវុសោទាំងឡាយ ចុះអ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យមោហៈដែលមិនទាន់កើតឡើង ឲ្យកើតឡើងក្តី មោហៈដែលកើតឡើងហើយ ឲ្យរឹងរឹតតែចម្រើនច្រើនឡើងក្តី ។ គួរដោះស្រាយថា អយោនិសោមនសិការ ( ការមិនធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ) ។ កាលបុគ្គលនោះ មិនធ្វើទុកក្នុងចិត្ត ដោយជាឧបាយនៃបញ្ញា មោហៈដែលមិនទាន់កើតឡើង ក៏កើតឡើងផង មោហៈដែលកើតឡើងហើយ ក៏រឹងរឹតតែចម្រើនច្រើនឡើងផង ។ ម្នាលអាវុសោទាំងឡាយ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យមោហៈដែលមិនទាន់កើតឡើង ឲ្យកើតឡើងផង មោហៈដែលកើតឡើងហើយ ក៏រឹងរឹតតែចម្រើនច្រើនឡើងផង ។ ម្នាលអាវុសោទាំងឡាយ ចុះអ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យរាគៈដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបានក្តី រាគៈដែលកើតឡើងហើយ ក៏លះបង់ចេញបានក្តី ។ គួរដោះស្រាយថា អសុភនិមិត្ត ( អារម្មណ៍ដែលមិនល្អ ) ។ កាលបុគ្គលនោះធ្វើទុកក្នុងចិត្ត នូវអសុភនិមិត្តដោយឧបាយនៃបញ្ញា រាគៈដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង រាគៈដែលកើតឡើងហើយ ក៏លះបង់ចេញបានផង ។ ម្នាលអាវុសោទាំងឡាយ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យ

រាគៈដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបានផង រាគៈដែលកើតឡើងហើយ ក៏លះបង់ចេញបានផង ។ ម្នាលអាវុសោទាំងឡាយ ចុះអ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យទោសៈដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងក្តី ទោសៈដែលកើតឡើងហើយ ក៏លះបង់ចេញបានក្តី ។ គួរដោះស្រាយថា មេត្តាចេតោវិមុត្តិ ( គ្រឿងរួចផុតនៃចិត្តដោយអំណាចមេត្តា ) ។ កាលបុគ្គលនោះ ធ្វើទុកក្នុងចិត្តនូវមេត្តាចេតោវិមុត្តិ ដោយឧបាយនៃបញ្ញា ទោសៈដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង ទោសៈដែលកើតឡើងហើយ ក៏លះបង់ចេញបានផង ។ ម្នាលអាវុសោទាំងឡាយ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យទោសៈដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងផង ទោសៈដែលកើតឡើងហើយ ក៏លះបង់ចេញបានផង ។ ម្នាលអាវុសោទាំងឡាយ អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យមោហៈដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងក្តី មោហៈដែលកើតឡើងហើយ ក៏លះបង់ចេញបានក្តី ។ គួរដោះស្រាយថា យោនិសោមនសិការ ( ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ) កាលបុគ្គលនោះធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា មោហៈដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង មោហៈដែលកើតឡើងហើយ ក៏លះបង់ចេញបានផង ។ ម្នាលអាវុសោទាំងឡាយ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យមោហៈដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងផង មោហៈដែលកើតឡើងហើយ ក៏លះបង់ចេញបានផង ។

# អដ្ឋកថា

## តិត្ថិយសូត្រ

[ ៧០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតិត្ថិយសូត្រទី ៨ ដូចតទៅនេះ បទថា **ភគវំមូលកា** សេចក្តីថា ធម៌ទាំងឡាយ ឈ្មោះថា **ភគវំមូលកា** ព្រោះមានព្រះមានព្រះភាគជាមូល ។ លោកអធិប្បាយដូចតទៅនេះ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌របស់ពួកខ្ញុំព្រះអង្គនេះ ដែលព្រះកស្សបសម្មាសម្ពុទ្ធកើតឡើងហើយក្នុងកាលមុន កាលទ្រង់បរិនិព្វានហើយ ឈ្មោះថា សមណៈ ឬព្រាហ្មណ៍ដទៃ អាចញុំាងធម៌ទាំងនេះឲ្យកើតឡើងក្នុងចន្លោះមួយពុទ្ធន្តរមិនមាន តែធម៌ទាំងនេះរបស់ខ្ញុំព្រះអង្គទាំងឡាយ ដែលព្រះមានព្រះភាគឲ្យកើតឡើងហើយ ខ្ញុំព្រះអង្គទាំងឡាយ នឹងដឹងទូទៅ គឺត្រាស់ដឹងធម៌ទាំងនេះបាន ដោយអាស្រ័យព្រះមានព្រះភាគ ព្រោះដូច្នោះ បពិត្រព្រះអង្គដ៏ចម្រើន ធម៌របស់ខ្ញុំព្រះអង្គទាំងឡាយ ឈ្មោះថា មានព្រះមានព្រះភាគជាមូល ដោយប្រការដូច្នេះ ។

បទថា **ភគវំនេត្តិកា** សេចក្តីថា ព្រះមានព្រះភាគទ្រង់ទូន្មាន គឺនាំចេញ គឺតាមណែនាំនូវធម៌ទាំងឡាយ បានដល់ ការតាំងឈ្មោះធម៌នីមួយៗ ហើយទ្រង់សម្តែងតាមសភាវៈ ព្រោះដូច្នោះ ទើបធម៌ទាំងឡាយ ឈ្មោះថា មានព្រះមានព្រះភាគជាអ្នកនាំ ។

បទថា **ភគវំ បដិសរណា** សេចក្តីថា ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ កាលមកកាន់គន្លងនៃព្រះសព្វញ្ញុតញ្ញាណ ឈ្មោះថា រមែងបង្កប់នៅក្នុង

ព្រះមានព្រះភាគ ព្រោះដូច្នោះ ទើបឈ្មោះថា **ភគវាបដិសរណា** ។ បទថា **បដិសរន្តិ** បានដល់ រួមទៅ គឺប្រជុំ ។ ន័យម្យ៉ាងទៀត ព្រះមានព្រះភាគ កាលទ្រង់តាំងឈ្មោះធម៌ ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ មួយប្រការៗ តាមសេចក្តីពិត ទើបទ្រង់រឭកដល់ធម៌ទាំងឡាយ ដោយអំណាចនៃការចាក់ធ្លុះរបស់ទ្រង់ ដែលប្រថាប់គង់នាមណ្ឌលពោធិព្រឹក្ស យ៉ាងនេះថា ផស្សៈ ហាក់ដូចជាមកទូលសួរយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គឈ្មោះអ្វី ។ ទ្រង់ត្រាស់ឆ្លើយថា អ្នកឈ្មោះផស្សៈ ព្រោះអត្ថថា ពាល់ត្រូវ ។ វេទនា ... សញ្ញា ... សង្ខារ ... វិញ្ញាណ ក៏ហាក់ដូចជាមកទូលសួរថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គឈ្មោះអ្វី ។ ត្រាស់ឆ្លើយថា អ្នកឈ្មោះថា វិញ្ញាណ ព្រោះអត្ថថា ដឹងច្បាស់ ព្រោះដូច្នោះ ទើបធម៌ទាំងឡាយ ឈ្មោះថា **ភគវាបដិសរណា** ។ បទថា **ភគវន្តំយេវ បដិភាតុ** សេចក្តីថា អត្ថនៃភាសិតនេះ ចូរប្រាកដដល់ព្រះមានព្រះភាគមួយអង្គចុះ អធិប្បាយថា សូមព្រះអង្គនោះឯង ត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គទាំងឡាយ ។

បទថា **ភគោ ខោ** បានដល់ ភគៈដែលប្រព្រឹត្តទៅហើយ ដោយអំណាចនៃសេចក្តីត្រេកអរ ។ បទថា **អប្បសាវជ្ជោ** សេចក្តីថា មានគោលដែលគួរតិះដៀលបន្តិចបន្តួច អធិប្បាយថា មានទោសតិចតួច ដោយទោសទាំង ២ ស្ថាន គឺដោយអំណាចនៃទោសដែលជាលោកវជ្ជៈ គឺទោសក្នុងបច្ចុប្បន្នខ្លះ ដោយទោសដែលជាវិបាកវជ្ជៈ គឺទោសក្នុងអនាគតខ្លះ ។ សេចក្តីនេះដូចម្តេច គឺមាតាបិតាឲ្យបង និងប្អូនជាដើមរៀបការជាមួយគ្នា ១ ឲ្យពួក

កូនរៀបចំរៀបការបងប្អូនរបស់កូន ១ ។ ភាគៈនេះមានទោសតិច ដោយជាលោកវជ្ជៈប៉ុណ្ណោះ ។ ឯភាគៈដែលមានទោសតិច ដោយជាវិបាកវជ្ជៈ យ៉ាងនេះ គឺឈ្មោះថា បដិសន្ធិក្នុងអបាយ ដែលមិនមានសទារសន្តោសជាមូល ។

បទថា **ឆន្នវិភាគី** សេចក្តីថា ភាគៈនេះ កាលប្រាសចាកទៅ ក៏ប្រាសចាកសន្សឹមៗ មិនរួចផុតទៅដោយរហ័ស ជាប់តាមបានយូរ ដូចសំពត់ដែលជ្រលក់ល្បងលាយដោយខ្លាញ់ ទើបទៅកាន់ភពដទៃ ២ ឬ ៣ ភព ដែលមិនផុតទៅ ព្រោះដូច្នោះ ទើបឈ្មោះថា **ឆន្នវិភាគី** គឺប្រាសចាកសន្សឹមៗ ក្នុងសេចក្តីនេះ មានរឿងនេះជាឧទាហរណ៍

# រឿង ស្រីសម្លាប់ប្តី

បានឮថា បុរសម្នាក់ប្រព្រឹត្តមិច្ឆាចារចំពោះកិរិយារបស់បងប្រុសខ្លួនឯង បានជាទីស្រឡាញ់របស់ស្រីនោះជាងប្តីរបស់ខ្លួន ។ នាងពោលជាមួយបុរសនោះថា កាលហេតុនេះប្រាកដហើយ ការនិន្ទាយ៉ាងធំនឹងមាន អ្នកចូរសម្លាប់បងប្រុសរបស់អ្នកចោល បុរសនោះសម្តុតស្រីនោះថា វិនាសចុះស្រីថោកទាប ហាងកុំពោលយ៉ាងនេះទៀត ។ នាងក៏នៅស្ងៀម កន្លងទៅ ២-៣ ថ្ងៃ ក៏ពោលទៀត ចិត្តរបស់បុរសនោះដល់នូវការរារែក បន្ទាប់អំពីនោះ ត្រូវនាងរំអុកដល់ទៅ ៣ ដង ទើបពោលថា ខ្ញុំនឹងធ្វើដូចម្តេចទើបបានឱកាស ។ លំដាប់នោះ នាងប្រាប់ឧបាយដល់បុរសនោះថា អ្នកចូរធ្វើតាមខ្ញុំប្រាប់ប៉ុណ្ណោះ ជិតស្រុកមហាកកុធៈ ត្រង់ទីនោះ មានកំពង់ទឹក អ្នកចូរកាន់យកកាំបិតធំដ៏មុត នៅត្រង់ទីនោះ បុរសបានធ្វើយ៉ាងនោះហើយ ឯបងប្រុសរបស់បុរសនោះ ធ្វើការក្នុងព្រៃស្រេចហើយ ត្រឡប់មកផ្ទះ នាងធ្វើហាក់ដូច

ជាមានចិត្តទន់ភ្លន់ចំពោះបុរសនោះ ពោលថា មកចុះ ខ្ញុំនឹងកក់សក់ឲ្យ ហើយមើលក្បាលរបស់បុរសនោះ ពោលថា ក្បាលរបស់បងស្មោកគ្រោក ហើយបញ្ជូនដុំកន្ទួតព្រៃឲ្យបុរសនោះ ប្រាប់ថា សូមបងទៅកក់សក់ត្រង់កំពង់ឈ្មោះនោះ ហើយត្រឡប់មក ។ បុរសទៅកាន់កំពង់តាមដែលនាងប្រាប់នោះឯង កក់សក់ដោយពពុះកន្ទួតព្រៃ ចុះងូតទឹកមុជក្បាលចុះហើយ ។ គ្រានោះ បុរសជាប្អូនចេញមកអំពីចន្លោះដើមឈើ កាប់បុរសនោះត្រង់ដងកឲ្យស្លាប់ ហើយត្រឡប់ទៅផ្ទះ ។

បងប្រុស កាលមិនអាចលះសេចក្តីស្នេហាក្នុងភរិយា ទើបទៅកើតជាពស់ខៀវធំក្នុងផ្ទះនោះឯង កាលភរិយានោះឈរក្តី អង្គុយក្តី ពស់នោះក៏ធ្លាក់ចុះត្រង់ខ្នងរបស់នាង ។ បន្ទាប់មក ទើបនាងឲ្យសម្លាប់ពស់នោះ ដោយយល់ថា ប្រហែលជាប្តីរបស់យើងជាពស់នោះ ។ ព្រោះការស្រឡាញ់ភរិយា ទើបពស់នោះកើតជាកូនឆ្កែក្នុងផ្ទះនោះទៀត តាំងអំពីពេលដែលឆ្កែដើរបាន ក៏រត់តាមក្រោយនាងទៅ សូម្បីនាងចូលព្រៃ ឆ្កែនោះក៏រត់តាមទៅដែរ មនុស្សទាំងឡាយឃើញនាងហើយ ក៏ពោលចំអកថា ព្រានសុនខចេញដំណើរហើយ តើទៅណា នាងក៏បញ្ជាឲ្យសម្លាប់ឆ្កែនោះទៀត ។

ឆ្កែនោះស្លាប់ហើយ ទៅកើតជាកូនគោក្នុងផ្ទះនោះទៀត ហើយដើរតាមក្រោយនាងទៅយ៉ាងនោះដូចគ្នា ។ ក្នុងគ្រានោះ មនុស្សទាំងឡាយឃើញគោនោះហើយ ក៏នាំគ្នាពោលចំអកថា នាងគោបាលចេញដំណើរហើយ តើគោទាំងឡាយទៅណាហ្ន៎ ។ នាងក៏បញ្ជាឲ្យសម្លាប់គោនោះ ក្នុងទីត្រង់នោះ ។

គ្រានោះ មិនអាចកាត់សេចក្ដីស្នេហាចំពោះនាងបាន វារៈទី ៤ កើតក្នុងផ្ទៃរបស់នាង ហើយរឭកជាតិបាន ទារកនោះដឹងថា ខ្លួនត្រូវនាងសម្លាប់មកអស់ ៤ ជាតិតាមលំដាប់ ហើយគិតថា អញកើតក្នុងពោះរបស់ស្រីដែលជាសត្រូវ មានសភាពយ៉ាងនេះ ។ រាប់តាំងអំពីនោះមក ក៏មិនព្រមឲ្យនាងយកដៃពាល់ត្រូវខ្លួនបាន បើនាងពាល់ត្រូវ ទារកក៏រើបម្រះស្រែកយំ ។ ពេលនោះ ជីតាប៉ុណ្ណោះដែលបីទារកនោះបាន ។ ក្នុងកាលតមក ទារកចម្រើនធំធាត់ហើយ ទើបជីតាពោលថា នែចៅ ហេតុអ្វី ទើបមិនព្រមឲ្យម្ដាយយកដៃប៉ះពាល់ បើម៉ែរបស់ចៅប៉ះពាល់ ចៅស្រែកយំដោយសំឡេងខ្លាំង ។ ទារកបានប្រាប់ការប្រព្រឹត្តទៅទាំងអស់នោះថា បុគ្គលនេះមិនមែនម្ដាយរបស់ខ្ញុំ តែជាសត្រូវ ។ ជីតាឱបទារកហើយ ទ្រហោយំ ពោលថា ឱ ! ចៅអើយ រឿងអ្វីពួកយើងត្រូវមកអាស្រ័យនៅក្នុងទីដូច្នេះ ហើយនាំគ្នាចេញអំពីផ្ទះ ទៅកាន់វិហារមួយ នាំគ្នាបួសក្នុងវិហារនោះ សម្រេចអរហត្តទាំង ២ នាក់ ។

បទថា **មហាសាវជ្ជោ** សេចក្ដីថា ឈ្មោះថា មានទោសច្រើនដោយហេតុ ២ គឺដោយអំណាចលោកវជ្ជៈ ១ ដោយអំណាចវិបាកវជ្ជៈ ១ ។ សេចក្ដីនេះ ដូចម្ដេច ។ គឺបុគ្គលដែលទោសៈប្រទូស្តហើយ រមែងប្រព្រឹត្តខុសក្នុងមាតាក៏បាន ក្នុងបិតាក៏បាន ក្នុងបងប្រុសប្អូនប្រុស បងស្រីប្អូនស្រីក៏បាន ក្នុងបព្វជិតក៏បាន ក្នុងទីគ្រប់អន្លើដែលផ្សាយទៅ បុគ្គលនោះនឹងបាននូវពាក្យនិន្ទាយ៉ាងធំថា បុគ្គលនេះ ប្រព្រឹត្តខុសក្នុងមាតាបិតា សូម្បីក្នុងបង

ប្រុសប្អូនប្រុស បងស្រីប្អូនស្រី សូម្បីក្នុងបព្វជិត ។ ទោសៈ ឈ្មោះថា មានទោសច្រើន ដោយអំណាចនៃទោសដែលជាលោកវជ្ជៈ ដូចពណ៌នាមកនេះ ។ តែបុគ្គលនោះនឹងបានសោយផលក្នុងនរកអស់កប្ប ដោយអនន្តរិយ-កម្ម ដែលខ្លួនធ្វើដោយអំណាចទោសៈ ។ ទោសៈ ឈ្មោះថា មានទោសច្រើន ដោយអំណាចនៃទោសដែលជាវិបាកវជ្ជៈ ដូចពណ៌នាមកនេះឯង ។

បទថា **ខិប្បវិរាគី** ប្រែថា ប្រាសចាករហ័ស អធិប្បាយថា បុគ្គលដែលត្រូវទោសៈប្រទូស្តហើយ ប្រព្រឹត្តខុសក្នុងមាតាបិតាក្តី ក្នុងចេតិយក្តី ក្នុងពោធិព្រឹក្សក្តី ក្នុងបព្វជិតក្តី បុគ្គលនោះសូមខមាទោសថា សូមលោកទាំង-ឡាយអត់ទោសដល់ខ្ញុំ ។ ព្រមគ្នានឹងការខមាទោស កម្មនោះ នឹងក្លាយជាប្រក្រតីមួយរំពេច ។

ចំណែកមោហៈមានទោសច្រើន ព្រោះហេតុ ២ ស្ថានដូចគ្នា សេចក្តីនេះ ដូចម្តេច គឺបុគ្គលដែលវង្វេងហើយព្រោះមោហៈ ប្រព្រឹត្តខុសក្នុងមាតាបិតាក្តី ក្នុងចេតិយក្តី ក្នុងពោធិព្រឹក្សក្តី ក្នុងបព្វជិតក្តី ហើយបានទទួលការតិះដៀល ក្នុងទីដែលខ្លួនទៅហើយ ។ មោហៈ ឈ្មោះថា មានទោសច្រើន ដោយអំណាចនៃទោសដែលជាលោកវជ្ជៈយ៉ាងនេះ ។ តែបុគ្គលនោះ នឹងសោយផលក្នុងនរកអស់កប្ប ព្រោះអនន្តរិយកម្មដែលគេធ្វើដោយអំណាចមោហៈ ។ មោហៈ ឈ្មោះថា មានទោសច្រើន ដោយអំណាចនៃទោសដែលជាវិបាកវជ្ជៈ ដូចពណ៌នាមកនេះឯង ។

បទថា **ទន្ធវិរាគី** ប្រែថា ប្រាសចាកសន្សឹមៗ អធិប្បាយថា កម្ម

ដែលវង្វេងព្រោះមោហៈធ្វើ នឹងផុតទៅសន្សឹមៗ ។ ឧបមាដូចស្បែកខ្លាឃ្មុំ ដែលគេសម្លាប់អស់ ៧ ដង ក៏មិនស យ៉ាងណា កម្មដែលបុគ្គលវង្វេង ហើយ ព្រោះមោហៈធ្វើ ក៏ដូច្នោះដូចគ្នា នឹងមិនផុតទៅរហ័ស គឺផុតសន្សឹមៗ ទៅ ដូច្នោះឯង ។ ពាក្យដ៏សេស ក្នុងព្រះសូត្រនេះ ងាយហើយ ៕៚

## អដ្ឋកថា តិត្ថិយសូត្រទី ៨ ចប់

# សុត្តន្តបិដក

## មូលសូត្រទី ៩

[ ៧១ ] ម្នាលភិក្ខុទាំងឡាយ អកុសលមូល ( ឫសគល់នៃអកុសល ) នេះមាន ៣ យ៉ាង ។ អកុសលមូល ៣ យ៉ាង តើដូចម្ដេច ។ គឺលោភៈជាអកុសលមូល ១ ទោសៈជាអកុសលមូល ១ មោហៈជាអកុសលមូល ១ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈណាជាតួលោភៈ សភាវៈនោះជាអកុសល បុគ្គលអ្នកល្មោភតែងសន្សំនូវកម្មណា ដោយកាយ វាចា ចិត្ត កម្មនោះក៏ជាអកុសលដែរ បុគ្គលអ្នកល្មោភត្រូវលោភៈគ្របសង្កត់ មានចិត្តត្រូវលោភៈរួបរឹត តែងរករឿង បន្ទុកទុក្ខដែលមិនមានពិតដល់អ្នកដទៃ ដោយការសម្លាប់ខ្លះ ដោយការចាប់ចងខ្លះ ដោយការបំផ្លាញខ្លះ ដោយការតិះដៀលខ្លះ ដោយការបំបរបង់ខ្លះ ដោយអាងកម្លាំងថា អាត្មាអញជាអ្នកមានកម្លាំងខ្លះ ដោយហេតុណា

ហេតុនោះ ហៅថា ជាអកុសល ។ អកុសលធម៌ទាំងឡាយដ៏លាមកជាច្រើន កើតអំពីលោភៈ មានលោភៈជាដើមហេតុ មានលោភៈជាប្រភព មានលោភៈជាបច្ច័យ ទាំងអម្បាលនេះ រមែងប្រជុំកើតព្រម ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈណាជាតួទោសៈ សភាវៈនោះ ក៏ជាអកុសល បុគ្គលអ្នកប្រទូស្តតែងសន្សំនូវកម្មណា ដោយកាយ វាចា ចិត្ត កម្មនោះ ក៏ជាអកុសលដែរ បុគ្គលអ្នកប្រទូស្ត ត្រូវទោសៈគ្របសង្កត់ មានចិត្តត្រូវទោសៈរួបរឹត តែងរករឿង បន្ទុកទុក្ខដែលមិនពិតដល់អ្នកដទៃ ដោយការសម្លាប់ខ្លះ ដោយការចាប់ចងខ្លះ ដោយការបំផ្លាញខ្លះ ដោយការតិះដៀលខ្លះ ដោយការបំបរបង់ខ្លះ ដោយអាងកម្លាំងថា អាត្មាអញជាអ្នកមានកម្លាំងខ្លះ ដោយហេតុណា ហេតុនោះ ហៅថា ជាអកុសល ។ អកុសលធម៌ទាំងឡាយដ៏លាមកជាច្រើន ដែលកើតអំពីទោសៈ មានទោសៈជាដើមហេតុ មានទោសៈជាប្រភព ( ជាដែនកើត ) មានទោសៈជាបច្ច័យ ទាំងអម្បាលនេះ រមែងប្រជុំកើតព្រម ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈណាជាតួមោហៈ សភាវៈនោះ ជាអកុសល បុគ្គលអ្នកវង្វេង តែងសន្សំនូវកម្មណា ដោយកាយ វាចា ចិត្ត កម្មនោះ ហៅថា ជាអកុសល បុគ្គលអ្នកវង្វេង ត្រូវមោហៈគ្របសង្កត់ មានចិត្តត្រូវមោហៈរួបរឹត តែងរករឿង បន្ទុកទុក្ខដែលមិនមានពិតដល់អ្នកដទៃ ដោយការសម្លាប់ខ្លះ ដោយការចាប់ចងខ្លះ ដោយការបំផ្លាញខ្លះ ដោយការតិះដៀលខ្លះ ដោយការបំបរបង់ចេញខ្លះ ដោយអាងកម្លាំងថា អាត្មាអញជាអ្នកមានកម្លាំងខ្លះ ដោយហេតុណា ហេតុនោះ ហៅថា

ជាអកុសល ។ អកុសលធម៌ទាំងឡាយ ដ៏លាមកជាច្រើន ដែលកើតអំពីមោហៈ មានមោហៈជាដើមហេតុ មានមោហៈជាប្រភព មានមោហៈជាបច្ច័យ ទាំងអម្បាលនេះ រមែងប្រជុំកើតព្រម ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពដូច្នេះនេះ ហៅថា អកាលវាទី ( និយាយក្នុងកាលមិនគួរ ) ខ្លះ អភូតវាទី ( និយាយពាក្យមិនពិត ) ខ្លះ អនត្ថវាទី ( និយាយពាក្យដែលមិនមានប្រយោជន៍ ) ខ្លះ អធម្មវាទី ( និយាយមិនត្រូវតាមធម៌ ) ខ្លះ អវិនយវាទី ( និយាយមិនត្រូវតាមវិន័យ ) ខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុដូចម្ដេច បានជាបុគ្គលមានសភាពយ៉ាងនេះ ហៅថា អកាលវាទីខ្លះ អភូតវាទីខ្លះ អនត្ថវាទីខ្លះ អធម្មវាទីខ្លះ អវិនយវាទីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពិតណាស់ ព្រោះថាបុគ្គលនេះ តែងបង្កទុក្ខដល់អ្នកដទៃ ដោយការសម្លាប់ខ្លះ ដោយការចាប់ចងខ្លះ ដោយការបំផ្លាញខ្លះ ដោយការតិះដៀលខ្លះ ដោយការបំបរបង់ខ្លះ ដោយអាងកម្លាំងថា អាត្មាអញជាអ្នកមានកម្លាំងខ្លះ តែកាលបើអ្នកដទៃហ៊ាននិយាយដោយសេចក្ដីពិត ក៏បដិសេធមិនព្រមទទួលដឹង កាលបើគេនិយាយដោយសេចក្ដីមិនពិត ក៏មិនធ្វើព្យាយាមដើម្បីដឹងនូវសេចក្ដីមិនពិតនោះថា ពាក្យនោះ មិនមែនទេដូច្នេះក្ដី ពាក្យនុ៎ះមិនពិតទេដូច្នេះក្ដី ព្រោះហេតុនោះ បុគ្គលមានសភាពយ៉ាងនេះ ហៅថា អកាលវាទីខ្លះ អភូតវាទីខ្លះ អនត្ថវាទីខ្លះ អធម្មវាទីខ្លះ អវិនយវាទីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងនេះ ត្រូវអកុសលធម៌ទាំង-ឡាយដ៏លាមក កើតអំពីលោភៈគ្របសង្កត់ មានចិត្តត្រូវអកុសលធម៌រួបរឹត

តែងនៅជាទុក្ខ ប្រកបដោយសេចក្ដីចង្អៀតចង្អល់ សេចក្ដីតានតឹង និង សេចក្ដីក្ដៅក្រហាយក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅ មានទុគ្គតិជាទីប្រាកដ ។ កើតអំពីទោសៈ ។បេ។ ត្រូវអកុសលធម៌ទាំងឡាយដ៏លាមក កើតអំពីមោហៈគ្របសង្កត់ មានចិត្តត្រូវអកុសលធម៌រួបរឹត តែងនៅជាទុក្ខ ប្រកបដោយសេចក្ដីចង្អៀតចង្អល់ សេចក្ដីតានតឹង និងសេចក្ដីក្ដៅក្រហាយក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅ មានទុគ្គតិជាទីប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ ដូចដើមសាលព្រឹក្ស ដើមធ្លឹក ឬដើមពន្រ្ទ ត្រូវវល្លិជ្រៃ ៣ ដើម រួបរឹតពីខាងលើ ព័ទ្ធព័ន្ធដោយជុំវិញ រមែងដល់នូវសេចក្ដីមិនចម្រើន ដល់នូវសេចក្ដីវិនាស ដល់នូវខូចខាត និងសេចក្ដីហិនហោច យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងនេះ ត្រូវអកុសលធម៌ទាំង-ឡាយដ៏លាមក តែងកើតអំពីលោភៈគ្របសង្កត់ មានចិត្តត្រូវអកុសលធម៌រួបរឹត តែងនៅជាទុក្ខ ប្រកបដោយសេចក្ដីចង្អៀតចង្អល់ សេចក្ដីតានតឹង និង សេចក្ដីក្ដៅក្រហាយក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅ មានទុគ្គតិជាទីប្រាកដ ។ កើតអំពីទោសៈ ។បេ។ ត្រូវអកុសលធម៌ទាំងឡាយដ៏លាមក តែងកើតអំពីមោហៈគ្របសង្កត់ មានចិត្តត្រូវអកុសលធម៌រួបរឹត តែងនៅជាទុក្ខ ប្រកបដោយសេចក្ដីចង្អៀតចង្អល់ សេចក្ដីតានតឹង និងសេចក្ដីក្ដៅក្រហាយក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅ មានទុគ្គតិជាទីប្រាកដ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ អកុសលមូលមាន ៣ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ កុសលមូល ( ឫសគល់នៃកុសល ) នេះមាន

៣ យ៉ាង ។ កុសលមូល ៣ យ៉ាង តើដូចម្តេច ។ គឺអលោភៈជាកុសលមូល ១ អទោសៈជាកុសលមូល ១ អមោហៈជាកុសលមូល ១ ។ ម្នាលភិក្ខុទាំងឡាយ ធម្មជាតណាជាអលោភៈ ធម្មជាតនោះ ជាកុសល បុគ្គលអ្នកមិនល្មោភតែងសន្សំនូវកម្មណា ដោយកាយ វាចា ចិត្ត កម្មនោះក៏ជាកុសល បុគ្គលអ្នកមិនល្មោភ ត្រូវលោភៈមិនគ្របសង្កត់ មានចិត្តត្រូវលោភៈមិនរួបរឹត មិនរករឿង បង្កទុក្ខដែលមិនមានពិតដល់អ្នកដទៃ ដោយការសម្លាប់ខ្លះ ដោយការចាប់ចងខ្លះ ដោយការបំផ្លាញខ្លះ ដោយការតិះដៀលខ្លះ ដោយការបំបរបង់ខ្លះ ដោយអាងកម្លាំងថា អាត្មាអញជាអ្នកមានកម្លាំងខ្លះ ដោយហេតុណា ហេតុនោះ ហៅថា ជាកុសល ។ កុសលធម៌ទាំងឡាយច្រើនប្រការ ដែលកើតអំពីអលោភៈ មានអលោភៈជាដើមហេតុ មានអលោភៈជាប្រភព មានអលោភៈជាបច្ច័យ ទាំងអម្បាលនេះ រមែងកើតព្រមដល់បុគ្គលនោះ ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ធម្មជាតណាជាអទោសៈ ធម្មជាតនោះជាកុសល បុគ្គលអ្នកមិនប្រទូស្ត តែងសន្សំនូវកម្មណាដោយកាយ វាចា ចិត្ត កម្មនោះក៏ជាកុសល បុគ្គលអ្នកមិនប្រទូស្ត ត្រូវទោសៈមិនគ្របសង្កត់ មានចិត្តត្រូវទោសៈមិនរួបរឹត មិនរករឿង បង្កទុក្ខដែលមិនមានពិតដល់អ្នកដទៃ ដោយការសម្លាប់ខ្លះ ដោយការចាប់ចងខ្លះ ដោយការបំផ្លាញខ្លះ ដោយការតិះដៀលខ្លះ ដោយការបំបរបង់ខ្លះ ដោយអាងកម្លាំងថា អាត្មាអញជាអ្នកមានកម្លាំងខ្លះ ដោយហេតុណា ហេតុនោះក៏ជាកុសល ។ កុសលធម៌ទាំងឡាយជាច្រើន ដែលកើតអំពីអទោសៈ មានអទោសៈជាដើមហេតុ មានអទោសៈ

ជាប្រភព មានអទោសៈជាបច្ច័យ ទាំងអម្បាលនេះ រមែងកើតព្រមដល់បុគ្គលនោះ ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ធម្មជាតណា ជាអមោហៈ ធម្មជាតនោះ ជាកុសល បុគ្គលអ្នកមិនវង្វេង តែងសន្សំនូវកម្មណាដោយកាយ វាចា ចិត្ត កម្មនោះ ក៏ជាកុសល បុគ្គលអ្នកមិនវង្វេង ត្រូវមោហៈមិនគ្របសង្កត់ មានចិត្តត្រូវមោហៈមិនរួបរឹត មិនបានរកឿន បង្កទុក្ខដែលមិនមានពិតដល់អ្នកដទៃ ដោយការសម្លាប់ខ្លះ ដោយការចាប់ចងខ្លះ ដោយការបំផ្លាញខ្លះ ដោយការតិះដៀលខ្លះ ដោយការបំបរបង់ខ្លះ ដោយអាងកម្លាំងថា អាត្មាអញជាអ្នកមានកម្លាំងខ្លះ ដោយហេតុណា ហេតុនោះក៏ជាកុសល ។ កុសលធម៌ទាំងឡាយច្រើន កើតអំពីអមោហៈ មានអមោហៈជាដើមហេតុ មានអមោហៈជាប្រភព មានអមោហៈជាបច្ច័យ ទាំងអម្បាលនេះ រមែងកើតព្រមដល់បុគ្គលនោះ ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលមានសភាពយ៉ាងនេះ ហៅថា កាលវាទី ( និយាយក្នុងកាលដែលគួរ ) ខ្លះ ភូតវាទី ( និយាយពាក្យពិត ) ខ្លះ អត្ថវាទី ( និយាយពាក្យដែលជាប្រយោជន៍ ) ខ្លះ ធម្មវាទី ( និយាយត្រូវតាមធម៌ ) ខ្លះ វិនយវាទី ( និយាយត្រូវតាមវិន័យ ) ខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុដូចម្ដេច បុគ្គលដែលមានសភាពដូច្នេះ ហៅថា កាលវាទីខ្លះ ភូតវាទីខ្លះ អត្ថវាទីខ្លះ ធម្មវាទីខ្លះ វិនយវាទីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពិតណាស់ព្រោះថា បុគ្គលនេះ មិនបង្កទុក្ខ ដែលមិនមានពិតដល់អ្នកដទៃ ដោយការសម្លាប់ខ្លះ ដោយការចាប់ចងខ្លះ ដោយការបំផ្លាញខ្លះ ដោយការតិះដៀលខ្លះ

ដោយការបំបរបង់ខ្លះ ដោយអាងកម្លាំងថា អាត្មាអញជាអ្នកមានកម្លាំងខ្លះ តែកាលបើអ្នកដទៃ និយាយដោយសេចក្តីពិត ក៏ទទួលរ៉ាប់រងមិនបដិសេធ កាលបើគេនិយាយដោយសេចក្តីមិនពិត ក៏ធ្វើសេចក្តីព្យាយាម ដើម្បីដឹងនូវសេចក្តីមិនពិតនោះថា ពាក្យនុ៎ះមិនមែនទេដូច្នេះក្តី ពាក្យនោះមិនពិតទេដូច្នេះក្តី ព្រោះហេតុនោះ បុគ្គលមានសភាពយ៉ាងនេះ ហៅថា កាលវាទីខ្លះ ភូតវាទីខ្លះ អត្ថវាទីខ្លះ ធម្មវាទីខ្លះ វិនយវាទីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតអំពីលោភៈ ដែលបុគ្គលមានសភាពយ៉ាងនេះលះបង់បានហើយ គាស់រម្លើងឫសគល់អស់ហើយ ធ្វើឲ្យដូចជាដើមត្នោតកំបុតក ធ្វើមិនឲ្យមានបែបភាព មានកិរិយាមិនកើតតទៅទៀតជាធម្មតា ( បុគ្គលមានសភាពយ៉ាងនេះ ) តែងនៅជាសុខ ឥតមានសេចក្តីចង្អៀតចង្អល់ ឥតមានសេចក្តីតានតឹង ឥតមានសេចក្តីក្តៅក្រហាយក្នុងបច្ចុប្បន្ន រមែងបរិ-និព្វានក្នុងបច្ចុប្បន្ន ។ ដែលកើតអំពីទោសៈ ។បេ។ អកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតអំពីមោហៈ បុគ្គលនោះលះបានហើយ គាស់រម្លើងឫសគល់អស់ហើយ ធ្វើឲ្យដូចជាដើមត្នោតកំបុតក ធ្វើមិនឲ្យមានបែបភាព មានកិរិយាមិនកើតតទៅទៀតជាធម្មតា បុគ្គលមានសភាពយ៉ាងនេះ តែងនៅជាសុខ ឥតមានសេចក្តីចង្អៀតចង្អល់ ឥតមានសេចក្តីតានតឹង ឥតមានសេចក្តីក្តៅក្រហាយក្នុងបច្ចុប្បន្ន រមែងបរិនិព្វានក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ ដូចដើមសាលព្រឹក្ស ដើមធ្នូក ឬដើមពន្រៃ ត្រូវព្នួរជ្រៃ ៣ ដើម រួបរឹតព័ទ្ធព័ន្ធដោយជុំវិញ ។ កាលណោះ មានបុរសកាន់ចប និងកញ្ជើដើរមក

បុរសនោះក៏កាប់ពួរជ្រៃត្រង់គល់ លុះកាប់គល់រួចហើយ ជីកគាស់ លុះជីកគាស់ហើយ ក៏ភើចយកឫសទាំងឡាយ ដោយហោចទៅ សូម្បីប៉ុនលំពង់ស្បូវក្លាំង ( ក៏មិនឲ្យសល់ ) បុរសនោះក៏កាត់ពួរជ្រៃនោះ ឲ្យជាកំណាត់តូចកំណាត់ធំ លុះកាត់ឲ្យជាកំណាត់តូចកំណាត់ធំរួចហើយ ក៏ពុះ លុះពុះរួចហើយ ក៏ធ្វើឲ្យជាចម្រៀកៗ លុះធ្វើឲ្យជាចម្រៀកៗ រួចហើយ ក៏ហាលខ្យល់ និងកម្តៅថ្ងៃឲ្យស្ងួត លុះហាលខ្យល់ និងកម្តៅថ្ងៃរួចហើយ ក៏ដុតដោយភ្លើង លុះដុតដោយភ្លើងរួចហើយ ក៏ធ្វើឲ្យជាធ្យូង លុះធ្វើឲ្យជាធ្យូងរួចហើយ ក៏បាចសាចទៅតាមខ្យល់ដ៏ខ្លាំង ឬបណ្តែតទៅតាមខ្សែទឹកស្ទឹង ដែលហូរខ្លាំង ម្នាលភិក្ខុទាំងឡាយ ពួរជ្រៃទាំងអម្បាលនោះ ដែលបុគ្គលនោះ គាស់រម្លើងឫសគល់អស់ហើយ ធ្វើឲ្យដូចជាដើមត្នោតកំបុតក ធ្វើមិនឲ្យមានបែបភាព មានកិរិយាមិនកើតតទៅទៀតជាធម្មតាយ៉ាងនេះ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតអំពីលោភៈ ដែលបុគ្គលមានសភាពយ៉ាងនេះ លះបានហើយ បានគាស់រម្លើងឫសគល់អស់ហើយ ធ្វើឲ្យដូចជាដើមត្នោតកំបុតក ធ្វើមិនឲ្យមានបែបភាព មានកិរិយាមិនកើតតទៅទៀតជាធម្មតា បុគ្គលមានសភាពយ៉ាងនេះ តែងនៅជាសុខ មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីតានតឹង មិនមានសេចក្តីក្តៅក្រហាយក្នុងបច្ចុប្បន្ន រមែងបរិនិព្វានក្នុងបច្ចុប្បន្ន ។ កើតអំពីទោសៈ ។បេ។ អកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតអំពីមោហៈ បុគ្គលនោះលះបានហើយ គាស់រម្លើងឫសគល់អស់ហើយ ធ្វើឲ្យដូចជាដើមត្នោតកំបុតក ធ្វើ

មិនឲ្យមានបែបកាព មានកិរិយាមិនកើតតទៅទៀតជាធម្មតា បុគ្គលមានសភាពយ៉ាងនេះ តែងនៅជាសុខ មិនមានសេចក្ដីចង្អៀតចង្អល់ មិនមានសេចក្ដីតានតឹង មិនមានសេចក្ដីក្ដៅក្រហាយក្នុងបច្ចុប្បន្ន រមែងបរិនិព្វានក្នុងបច្ចុប្បន្ន ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ កុសលមូលមាន ៣ យ៉ាងនោះឯង ។

# អដ្ឋកថា

## មូលសូត្រ

[ ៧១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមូលសូត្រទី ៩ ដូចតទៅនេះ ធម៌ដែលជាមូលនៃអកុសល ឈ្មោះថា អកុសលមូល ។ មួយវិញទៀត ធម៌នោះផង ជាមូលផង ព្រោះដូច្នោះ ទើបឈ្មោះថា អកុសលមូល ។ បទថា **យទបិ ភិក្ខវេ លោភោ** ស្មើគ្នានឹង **យោបិ ភិក្ខវេ លោភោ** ប្រែថា ម្នាលភិក្ខុទាំងឡាយ ការលោភណា ។ បទថា **តទបិ អកុសលមូលំ** សេចក្ដីថា ដោយការលោភនោះ ជាឫសគល់នៃអកុសល ឬជាតួអកុសលក៏បាន អធិប្បាយថា ក្នុងទីនេះ សូម្បីអកុសលនោះ សំដៅដល់អកុសលមូលនោះក៏គួរដូចគ្នា ក្នុងបទទាំងពួង គប្បីនាំន័យនេះទៅដោយឧបាយនេះ ។

បទថា **អភិសង្ខរោតិ** សេចក្ដីថា រមែងប្រមូល គឺបង្រួបបង្រួមមក

បានដល់ ធ្វើឲ្យជាគំនរ ។ បទថា **អសតា ទុក្ខំ ឧបទហតិ** សេចក្តីថា ញុំាងសេចក្តីទុក្ខ ដោយពោលទោសណាមួយ ដែលមិនពិតដល់បុគ្គលនោះ ដោយរឿងដែលមិនពិត គឺមិនមាន ។ បទថា **វធេន វា** ជាដើម ព្រះមានព្រះភាគត្រាស់ដើម្បីទ្រង់សម្តែងអាការដែលបុគ្គលបង្កនូវសេចក្តីទុក្ខឡើង ។

បណ្តាបទទាំងនោះ បទថា **ជានិយា** បានដល់ វិនាសទ្រព្យ ។ បទថា **បព្វាជនាយ** សេចក្តីថា បានដល់ ការបណ្តេញចេញអំពីស្រុក អំពីព្រៃ ឬអំពីរដ្ឋ ។ បទថា **ពលវម្ហិ** សេចក្តីថា ខ្ញុំជាបុគ្គលមានកម្លាំង ។ បទថា **ពលត្ថោ ឥតិបិ** សេចក្តីថា ពោលថា ខ្ញុំត្រូវការកម្លាំងក្តី ខ្ញុំនៅក្នុងកម្លាំងក្តី ។

បទថា **អកាលវាទី** សេចក្តីថា មិនពោលក្នុងវេលាដែលគួរពោល ឈ្មោះថា ពោលក្នុងកាលដែលមិនគួរ ។ បទថា **អភូតវាទី** សេចក្តីថា មិនពោលរឿងពិត ឈ្មោះថា ពោលរឿងមិនពិត ។ បទថា **អនត្ថវាទី** សេចក្តីថា មិនពោលរឿងដែលជាប្រយោជន៍ ឈ្មោះថា ពោលរឿងមិនជាប្រយោជន៍ ។ បទថា **អធម្មវាទី** សេចក្តីថា មិនពោលវត្ថុដែលជាធម៌ ឈ្មោះថា ពោលវត្ថុមិនជាធម៌ ។ បទថា **អវិនយវាទី** សេចក្តីថា មិនពោលវត្ថុដែលជាវិន័យ ឈ្មោះថា ពោលវត្ថុដែលមិនមែនវិន័យ ។ បទថា **តថាហាយំ** កាត់បទជា **តថា ហិ អយំ** ។ បទថា **ន អាតប្បំ ករោតិ តស្ស និព្ពេឋនាយ** សេចក្តីថា មិនធ្វើសេចក្តីព្យាយាមដើម្បីជាប្រយោជន៍ដល់ការស្រាយរឿងដែលមិនពិតនោះ ។ បទថា **ឥតិបេតំ អតច្ឆំ** សេចក្តីថា វត្ថុនេះមិនពិតដោយហេតុនេះ ។ ក្រៅអំពីនេះ ពាក្យថា **អភូតំ** ជាវេវចនៈ

នៃបទថា **អត្តច្ឆំ** នោះឯង ។

បទថា **ទុគ្គតិ ចាដិកង្ខា** សេចក្តីថា ទុគ្គតិដែលញែកប្រភេទជានរកជាដើម គប្បីសង្ឃឹមបាន អធិប្បាយថា ទុគ្គតិត្រូវជាចំណែករបស់បុគ្គលនោះពិតប្រាកដ គឺបុគ្គលនោះ នឹងត្រូវកើតក្នុងទុគ្គតិនោះ ។ បទថា **ឧទ្ធសោតោ** សេចក្តីថា ត្រូវពួរជ្រៃចាក់ស្រែះ គ្របដណ្តប់ហើយខាងលើ ។ បទថា **បរិយោនទ្ធោ** សេចក្តីថា ត្រូវពួរជ្រៃគ្របដណ្តប់ហើយដោយជុំវិញ ។

បទថា **អនយំ អាបជ្ជតិ** ប្រែថា ដល់នូវការមិនចម្រើនធំធាត់ ។ បទថា **ព្យសនំ អាបជ្ជតិ** ប្រែថា រមែងដល់នូវការវិនាស អធិប្បាយថា ក្នុងរដូវក្តៅ កាលផ្លៃជ្រៃទុំបែកចេញហើយ គ្រាប់ទាំងឡាយខ្ចាតធ្លាក់ទៅត្រង់គល់ជាដើម ក្នុងដើមឈើទាំងនោះ ត្រង់គល់ដើមឈើណា មានគ្រាប់ធ្លាក់ទៅ ៣ គ្រាប់ ក្នុងទិសទាំង ៣ កាលដើមឈើនោះត្រូវភ្លៀងក្នុងរដូវស្សា ពន្លក ៣ ដុះអំពីគ្រាប់ទាំង ៣ រួបរឹតដើមឈើនោះ បន្ទាប់អំពីនោះ រុក្ខ-ទេវតាជាដើម ក៏មិនអាចអាស្រ័យនៅតាមផ្លូវរបស់ខ្លួនបាន ពន្លកទាំង ៣ នោះដុះដាលឡើង ក្លាយជាវល្លិរួបរឹតដើមឈើនោះ រុំព័ទ្ធប្រគាប មែកតូចមែកធំទាំងអស់ រុំដើមឈើនោះជុំជិត ។ ដើមឈើនោះ ត្រូវវល្លិជ្រៃរួបរឹតដេរដាសទៅដោយពួរជ្រៃ ដ៏ធំក្រាស់ កាលភ្លៀងធ្លាក់ចុះមក ឬខ្យល់បក់ក៏បាក់រលំចុះក្នុងទីនោះៗ សល់តែដង្គត់ប៉ុណ្ណោះ ។ បទថា **ព្យសនំ អាបជ្ជតិ** នេះ ព្រះមានព្រះភាគត្រាស់សំដៅដល់ដើមឈើនោះ ។

ក្នុងបទថា **ឯវមេវ ខោ** នេះ មានការប្រៀបធៀបដូចតទៅនេះ សត្វលោក គប្បីឃើញដូចដើមឈើណាមួយ ក្នុងបណ្ដាដើមរាំងជាដើម អកុសលមូល ៣ គប្បីឃើញដូចពួរជ្រៃ ៣ ពួរ ។ កាលដែលលោភៈជាដើម មិនទាន់ជួបនូវទ្វារ គប្បីឃើញដូចការដែលវល្លិទាំងនោះ រុំព័ទ្ធដើមឈើឡើងទៅត្រង់ៗ មិនទាន់ដល់មែក ។ ក្នុងកាលដែលលោភៈជាដើមប្រព្រឹត្តទៅ ដោយអំណាចនៃទ្វារ គប្បីឃើញដូចពេលដែលវល្លិឡើងទៅតាមមែក ។ ពេលដែលលោភៈជាដើមគ្របដណ្ដប់ចិត្ត គប្បីឃើញដូចពេលដែលវល្លិគ្របដណ្ដប់ដើមឈើ ពេលដែលភិក្ខុត្រូវអាបត្តិតូចតាច ដោយអំណាចនៃកិលេសទាំងឡាយដែលមកជួបទ្វារហើយ គប្បីឃើញដូចពេលដែលមែកតូចៗ ជ្រុះចុះមក វេលាដែលភិក្ខុត្រូវគរុកាបត្តិ គប្បីឃើញដូចពេលដែលមែកឈើធំបាក់ធ្លាក់ ។ វេលាដែលភិក្ខុត្រូវអាបត្តិបារាជិក ហើយធ្លាក់ចុះទៅក្នុងអបាយទាំង ៤ តាមលំដាប់ គប្បីឃើញដូចពេលដែលដើមឈើរលំត្រង់ផែនដី ក្នុងកាលគល់ពុកផុយ ដោយអំណាចទឹក ដែលហូរចុះមកតាមជួរនៃវល្លិ ។

ចំណែកសុក្កបក្ខ គប្បីជ្រាបដោយផ្ទុយគ្នាតាមដែលពោលមកហើយ ។ តែក្នុងបទថា **ឯវមេវ ខោ** នេះ គប្បីជ្រាបការប្រៀបធៀបដូចតទៅនេះ សត្វលោកនេះ គប្បីឃើញដូចដើមឈើណាមួយ ក្នុងបណ្ដាដើមរាំងជាដើម ។ អកុសលមូលទាំង ៣ គប្បីឃើញដូចពួរជ្រៃ ៣ ។ ព្រះយោគាវចរគប្បីឃើញដូចបុរសដែលមកធ្វើវល្លិទាំងនោះមិនឲ្យប្រព្រឹត្តទៅ គឺជីកវល្លិចោល បញ្ញាគប្បីឃើញដូចចប ។ កម្លាំងនៃសទ្ធា គប្បីឃើញដូចកម្លាំងនៃចប ។ ការជីកដោយវិបស្សនា គប្បីឃើញដូចការជីកដោយចប ពេលដែលព្រះយោគីវចរ

ប្រើវិបស្សនាញាណ កាត់ឫសរបស់អវិជ្ជា គប្បីឃើញដូចការកាត់ឫសរបស់វល្លិដោយការជីក ។ ក្នុងពេលដែលព្រះយោគាវចរឃើញនាមរូប ដោយអំណាចនៃខន្ធ គប្បីឃើញដូចពេលដែលកាត់វល្លិឲ្យជាកំណាត់តូចធំ ។ គ្រាដែលព្រះយោគាវចរដកឡើងនូវកិលេសបានដោយមគ្គញ្ញាណ គប្បីឃើញដូចពេលដែលពុះយកវល្លិ វេលាដែលបញ្ចក្ខន្ធកំពុងតាំងនៅ គប្បីឃើញដូចពេលធ្វើវល្លិឲ្យទៅជាផេះ ។ ពេលដែលព្រះយោគាវចររម្ងត់ឧបាទិន្នកក្ខន្ធដោយការរម្ងត់មិនឲ្យមានបដិសន្ធិ ហើយមិនកាន់យកបដិសន្ធិក្នុងភពថ្មី គប្បីឃើញដូចពេលដែលបុរសបាចផេះទៅកាន់ទីដែលមានខ្យល់ធំ ធ្វើមិនឲ្យកើតទៀតដូច្នោះឯង ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគ ត្រាស់វដ្ដៈផង និងវិវដ្ដៈផង ៕

**អដ្ឋកថាមូលសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ឧបោសថសូត្រទី ១០

[ ៧២ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទរបស់មិគារមាតា ក្នុងវត្តបុព្វារាម ទៀបក្រុងសាវត្ថី ។ គ្រានោះ ថ្ងៃនោះ ជាថ្ងៃឧបោសថសីល នាងវិសាខាមិគារមាតា ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះ

ចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះនាងវិសាខាមិគារមាតា អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគបានត្រាស់ដូច្នេះថា ម្នាលនាងវិសាខា ចុះនាងមកពីណាទាំងថ្ងៃម៉្លេះ ។ នាងវិសាខាក្រាបបង្គំទូលថា ថ្ងៃនេះ ខ្ញុំម្ចាស់រក្សាឧបោសថ ព្រះអង្គ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលនាងវិសាខា ឧបោសថនេះមាន ៣ យ៉ាង ។ ឧបោសថ ៣ យ៉ាង តើដូចម្ដេច ។ គឺគោបាលកុបោសថ ( ឧបោសថរបស់គង្វាលគោ ) ១ និគន្ថុបោសថ ( ឧបោសថរបស់និគ្រន្ថ ) ១ អរិយុបោសថ ( ឧបោសថរបស់ព្រះអរិយៈ ) ១ ។ ម្នាលនាងវិសាខា ចុះគោបាលកុបោសថ តើដូចម្ដេច ។ ម្នាលនាងវិសាខា ដូចគង្វាលគោប្រគល់គោទាំងឡាយដល់អ្នកម្ចាស់គោ ក្នុងវេលាល្ងាច រួចហើយ គិតរំពឹងដូច្នេះថា ថ្ងៃនេះគោទាំងឡាយ ត្រាច់រកស៊ីក្នុងទីឯណោះៗ ផឹកទឹកក្នុងទីឯណោះៗ ស្អែកនេះគោទាំងឡាយ នឹងត្រាច់ទៅរកស៊ីក្នុងទីឯណោះៗ នឹងផឹកទឹកក្នុងទីឯណោះៗ យ៉ាងណាមិញ ។ ម្នាលនាងវិសាខា បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នករក្សាឧបោសថសីលហើយ គិតជញ្ជឹងដូច្នេះថា ក្នុងថ្ងៃនេះ អាត្មាអញបានទំពាស៊ីនូវខាទនីយៈនេះផងៗ អាត្មាអញបានបរិភោគនូវភោជនីយៈនេះផងៗ ស្អែកនេះ អាត្មាអញនឹងទំពាស៊ីនូវខាទនីយៈនេះផងៗ នឹងបរិភោគនូវខាទនីយៈនេះផងៗ បុគ្គលនោះ មានចិត្តប្រកបដោយអភិជ្ឈា តែងញុំាងថ្ងៃឲ្យប្រព្រឹត្តកន្លងទៅ ដោយលោភៈនោះ ក៏យ៉ាងនោះឯង ។ ម្នាលនាងវិសាខា យ៉ាងនេះឯង ឈ្មោះថា គោបាលកុបោសថ ។ ម្នាលនាងវិសាខា គោបាលកុ-

ឧបោសថ ដែលបុគ្គលរក្សាយ៉ាងនេះ ជាឧបោសថមិនមានផលច្រើន មិនមានអានិសង្សច្រើន មិនមានសេចក្តីរុងរឿងច្រើន មិនផ្សាយផលច្រើនទេ ។ ម្នាលនាងវិសាខា ចុះនិគណ្ឋុបោសថ តើដូចម្តេច ។ ម្នាលនាងវិសាខា មានពួកសមណៈ ហៅថា និគណ្ឋៈ សមណៈអម្បាលនោះ តែងដឹកនាំសាវកយ៉ាងនេះថា នែបុរសដ៏ចម្រើន អ្នកចូរមកអាយ សត្វទាំងឡាយណា មាននៅក្នុងទិសខាងកើត ខាងនាយពី ១០០ យោជន៍ទៅ អ្នកចូរដាក់អាជ្ញា ( សម្លាប់ ) សត្វអម្បាលនោះចុះ សត្វទាំងឡាយណា មាននៅក្នុងទិសខាងលិច ខាងនាយពី ១០០ យោជន៍ទៅ អ្នកចូរដាក់អាជ្ញាក្នុងសត្វអម្បាលនោះចុះ សត្វទាំងឡាយណា មាននៅក្នុងទិសខាងជើង ខាងនាយពី ១០០ យោជន៍ទៅ អ្នកចូរដាក់អាជ្ញាក្នុងសត្វអម្បាលនោះចុះ សត្វទាំងឡាយណា មាននៅក្នុងទិសខាងត្បូង ខាងនាយពី ១០០ យោជន៍ទៅ អ្នកចូរដាក់អាជ្ញាក្នុងសត្វអម្បាលនោះចុះ ។ ពួកនិគ្រណ្ឋ តែងដឹកនាំសាវកឲ្យអាណិតអនុគ្រោះចំពោះពួកសត្វខ្លះ តែងដឹកនាំសាវកមិនឲ្យអាណិត មិនឲ្យអនុគ្រោះចំពោះពួកសត្វខ្លះ ។ ក្នុងថ្ងៃឧបោសថនោះ គេតែងដឹកនាំសាវកយ៉ាងនេះថា នែបុរសដ៏ចម្រើន អ្នកចូរមកអាយ អ្នកចូរស្រាតសំពត់ឲ្យអស់ ហើយពោលយ៉ាងនេះថា អាត្មាអញមិនទាក់ទាមនឹងនរណាៗ ក្នុងទីណាៗ នឹងមានកង្វល់ក្នុងរបស់អ្វីៗ ក្នុងទីណាៗ ក៏មិនមានដល់អាត្មាអញឡើយ តែមាតាបិតារបស់គេក៏ដឹងថា នេះបុត្ររបស់អញ ទាំងខ្លួនគេក៏ដឹងថា នេះមាតាបិតារបស់អញ បុត្រភរិយារបស់គេ ក៏ដឹងថា នេះជាស្វាមីរបស់អញ ទាំងខ្លួនគេ

ក៏ដឹងថា នេះជាបុត្រភរិយារបស់អញ ពួកបុរសជាទាសកម្មកររបស់គេ ក៏ដឹងថា នេះជាម្ចាស់របស់អញ ទាំងខ្លួនគេ ក៏ដឹងថា នេះជាពួកបុរសដែលជាទាសកម្មកររបស់អញ ( សាវកទាំងនោះ ) ត្រូវគេដឹកនាំក្នុងសច្ចៈដូច្នេះ ក្នុងសម័យណា ( អ្នកដឹកនាំ ) ឈ្មោះថា ដឹកនាំក្នុងមុសាវាទ ក្នុងសម័យនោះ ។ តថាគតពោលថា ពាក្យដឹកនាំនេះជាពាក្យមុសាវាទរបស់គេ ។ លុះកន្លងរាត្រីនោះហើយ គេបរិភោគភោគៈទាំងអម្បាលនោះ ដែលម្ចាស់គេមិនបានឲ្យ ។ តថាគតពោលថា ការបរិភោគនេះជាអទិន្នាទានរបស់គេ ។ ម្នាលនាងវិសាខា យ៉ាងនេះឯង ឈ្មោះថា និគណ្ឋុបោសថ ។ ម្នាលនាងវិសាខា និគណ្ឋុបោសថ ដែលគេរក្សាយ៉ាងនេះ ជាឧបោសថមិនមានផលច្រើន មិនមានអានិសង្សច្រើន មិនមានសេចក្តីរុងរឿងច្រើន មិនផ្សាយផលច្រើនទេ ។ ម្នាលនាងវិសាខា ចុះអរិយុបោសថ តើដូចម្តេច ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បានដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវកក្នុងធម្មវិន័យនេះ តែងរឭករឿយៗ នូវព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ ព្រះអង្គមានដំណើរល្អ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាសារថី អ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជា

គ្រូនៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ កាលអរិយសាវកនោះ កំពុងរឭកនូវព្រះតថាគត ចិត្តរមែងជ្រះថ្លា សេចក្ដីរីករាយរមែងកើតឡើង ឧបក្កិ-លេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងនោះ អរិយសាវកនោះ ក៏លះបង់ចេញបាន ម្នាលនាងវិសាខា ដូចការជម្រះក្បាលដែលមិនស្អាត ឲ្យស្អាតបានដោយសេចក្ដីព្យាយាម ។ ម្នាលនាងវិសាខា ចុះការជម្រះក្បាលដែលមិនស្អាតឲ្យស្អាតបានដោយសេចក្ដីព្យាយាម តើដូចម្ដេច ។ ម្នាលនាងវិសាខា ការអាស្រ័យកាក ( កន្ទួតព្រៃ ) ផង អាស្រ័យដីផង អាស្រ័យទឹកផង អាស្រ័យសេចក្ដីព្យាយាមដ៏សមគួរដល់កិច្ចនោះ របស់បុរសផង ទើបធ្វើក្បាលដែលមិនស្អាត ឲ្យស្អាតបាន ដោយសេចក្ដីព្យាយាមយ៉ាងនេះ យ៉ាងណាមិញ ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាម ក៏យ៉ាងនោះដែរ ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់ដោយសេចក្ដីព្យាយាម តើដូចម្ដេច ។ ម្នាលនាងវិសាខា អរិយសាវកក្នុងធម្មវិន័យនេះ តែងរឭករឿយៗ នូវព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ កាលអរិយសាវកនោះ កំពុងរឭករឿយៗ នូវព្រះតថាគត ចិត្តរមែងជ្រះថ្លា សេចក្ដីរីករាយរមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះ ក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា អរិយសាវកនេះ ហៅថា រក្សា

ព្រហ្មុបោសថ ( ឧបោសថរបស់ព្រហ្ម ) នៅរួមនឹងព្រហ្ម ចិត្តរបស់គេប្រារព្ធចំពោះព្រហ្ម រមែងជ្រះថ្លា សេចក្តីរីករាយ រមែងកើតឡើង ឧបក្កិ-លេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមយ៉ាងនេះ ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មង រមែងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវកក្នុងធម្មវិន័យនេះ តែងរឭករឿយៗនូវព្រះធម៌ថា ព្រះធម៌ដែលព្រះដ៏មានព្រះភាគ ត្រាស់ប្រពៃហើយ ជាធម៌ដែលបុគ្គលប្រតិបត្តិគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរហៅអ្នកដទៃឲ្យចូលមកមើលបាន ជាធម៌គួរបង្អោនចូលមកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជន គប្បីដឹងចំពោះខ្លួន ។ កាលអរិយសាវកនោះកំពុងរឭកនូវព្រះធម៌ ចិត្តរមែងជ្រះថ្លា សេចក្តីរីករាយរមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា ដូចការជម្រះកាយដែលមិនស្អាត រមែងឲ្យស្អាតបាន ដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការជម្រះកាយដែលមិនស្អាត រមែងឲ្យស្អាតបាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា ការអាស្រ័យដុំលម្អិត សម្រាប់ជម្រះកាយផង អាស្រ័យលម្អិតសម្រាប់ងូតផង អាស្រ័យទឹកផង អាស្រ័យសេចក្តីព្យាយាមដ៏សមគួរ ដល់

កិច្ចនោះរបស់បុរសផង ទើបធ្វើការជម្រះកាយដែលមិនស្អាត ឲ្យស្អាតបាន ដោយសេចក្តីព្យាយាមយ៉ាងនេះ យ៉ាងណាមិញ ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមយ៉ាងនោះដែរ ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវក ក្នុងធម្មវិន័យនេះ តែងរឭករឿយៗ នូវព្រះធម៌ថា ព្រះធម៌ដែលព្រះដ៏មានព្រះភាគ ត្រាស់ទុកប្រពៃហើយ ។បេ។ ជាធម៌ដែលវិញ្ញូជនទាំងឡាយ គប្បីដឹងចំពោះខ្លួន ។ កាលអរិយសាវកនោះ កំពុងរឭកនូវព្រះធម៌ ចិត្តរមែងជ្រះថ្លា សេចក្តីរីករាយរមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះ ក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា អរិយសាវកនេះ ហៅថា រក្សាធម្មុបោសថ នៅរួមដោយធម៌ ចិត្តរបស់អរិយសាវកនោះ ប្រារព្ធចំពោះព្រះធម៌ រមែងជ្រះថ្លា សេចក្តីរីករាយក៏រមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះ ក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង រមែងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមយ៉ាងនេះ ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង រមែងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មង រមែងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមបាន តើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវក ក្នុងធម្មវិន័យនេះ តែងរឭករឿយៗ នូវព្រះសង្ឃថា ពួកសាវកនៃព្រះដ៏មាន

ព្រះភាគ ប្រតិបត្តិប្រពៃហើយ ពួកសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិត្រង់ហើយ ពួកសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិសមគួរហើយ គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា ពួកសាវកណា បើរាប់ជាគូនៃបុរសបាន ៤ គូ បើរាប់រៀងជាបុរសបុគ្គល មាន ៨ ពួក សាវកនៃព្រះដ៏មានព្រះភាគនុ៎ះ គួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលនាំមកអំពីចម្ងាយ ហើយបូជា គួរទទួលនូវអាគន្តុកទាន គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលីកម្ម ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។ កាលអរិយសាវកនោះ កំពុងរឭករឿយៗ នូវព្រះសង្ឃ ចិត្តរមែងជ្រះថ្លា សេចក្តីរីករាយ រមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយ-សាវកនោះ ក៏លះបង់បាន ។ ម្នាលនាងវិសាខា ដូចការធ្វើសំពត់ដែលមិនស្អាតឲ្យស្អាតបាន ដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការធ្វើសំពត់ដែលមិនស្អាតឲ្យស្អាតបាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា ព្រោះអាស្រ័យចំហាយផង អាស្រ័យទឹកក្បុងផង អាស្រ័យអាចម៌គោផង អាស្រ័យទឹកផង អាស្រ័យសេចក្តីព្យាយាមដ៏សមគួរ ដល់កិច្ចនោះរបស់បុរសផង ទើបធ្វើសំពត់ដែលមិនស្អាតឲ្យស្អាតបាន ដោយសេចក្តីព្យាយាមយ៉ាងនេះ យ៉ាងណាមិញ ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម ក៏យ៉ាងនោះឯង ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មង រមែងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវកក្នុងធម្មវិន័យនេះ

រមែងរឭករឿយៗ នូវព្រះសង្ឃថា ពួកសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិប្រពៃហើយ ... ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។ កាលព្រះអរិយសាវកនោះ កំពុងរឭករឿយៗ នូវព្រះសង្ឃ ចិត្តក៏ជ្រះថ្លា សេចក្តីរីករាយរមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្តឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះ ក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា អរិយសាវកនេះ ហៅថា រក្សាសង្ឃុបោសថ នៅរួមជាមួយនឹងព្រះសង្ឃ ចិត្តរបស់អរិយសាវកនោះ ប្រារព្ធចំពោះព្រះសង្ឃ រមែងជ្រះថ្លា សេចក្តីរីករាយរមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្តឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង រមែងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមយ៉ាងនេះឯង ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវកក្នុងធម្មវិន័យនេះ រឭករឿយៗ នូវសីលរបស់ខ្លួន ជាសីលមិនដាច់ មិនធ្លុះធ្លាយ មិនពព្រុស មិនពពាល ជាសីលអ្នកជា ជាសីលដែលវិញ្ញូជនសរសើរហើយ ជាសីលមិនប៉ះពាល់ដោយតណ្ហា និងទិដ្ឋិ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ កាលអរិយសាវកនោះ កំពុងរឭករឿយៗ នូវសីល ចិត្តក៏ជ្រះថ្លា សេចក្តីរីករាយរមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះ ក៏

លះបង់ចេញបាន ។ ម្នាលនាងវិសាខា ដូចការជុសខាត់កញ្ចក់ដែលមិនស្អាត ឲ្យស្អាតបាន ដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការជុសខាត់កញ្ចក់ដែលមិនស្អាត ឲ្យស្អាតបាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា ព្រោះអាស្រ័យប្រេងផង អាស្រ័យផេះផង អាស្រ័យប្រាសផង អាស្រ័យសេចក្តីព្យាយាមដ៏សមគួរ ដល់កិច្ចនោះ របស់បុរសផង ទើបជុសខាត់កញ្ចក់ដែលមិនស្អាតឲ្យស្អាតបាន ដោយសេចក្តីព្យាយាមយ៉ាងនេះ យ៉ាងណាមិញ ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម ក៏យ៉ាងនោះឯង ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវកក្នុងធម្មវិន័យនេះ រឭករឿយៗ នូវសីលរបស់ខ្លួន ដែលជាសីលមិនដាច់ មិនធ្លុះធ្លាយ ... ជាសីលប្រព្រឹត្តទៅ ដើម្បីសមាធិ ។ កាលអរិយសាវកនោះ កំពុងរឭករឿយៗនូវសីល ចិត្តក៏រមែងជ្រះថ្លា សេចក្តីរីករាយក៏កើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា អរិយសាវកនេះ ហៅថា រក្សាសីលុបោសថ នៅរួមដោយសីលមួយទៀត ចិត្តរបស់អរិយសាវកនោះ ប្រារព្ធចំពោះសីល ក៏ជ្រះថ្លា សេចក្តីរីករាយក៏រមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមយ៉ាងនេះឯង ។

ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវកក្នុងធម្មវិន័យនេះ រឭករឿយៗនូវទេវតាទាំងឡាយថា ពួកទេវតាជាន់ចាតុម្ម-ហារាជិក:ក៏មាន ពួកទេវតាជាន់តាវត្តិង្សក៏មាន ពួកទេវតាជាន់យាម:ក៏មាន ពួកទេវតាជាន់តុសិតក៏មាន ពួកទេវតាជាន់និម្មានរតីក៏មាន ពួកទេវតាជាន់បរនិម្មិតវសវត្តីក៏មាន ពួកទេវតាដែលរាប់បញ្ចូលក្នុងពួកព្រហ្មក៏មាន ពួកទេវតាជាន់ខ្ពស់ឡើងទៅទៀតក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយសទ្ធា មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើតក្នុងភពនោះ សទ្ធាមានសភាពដូច្នោះ របស់អាត្មាអញក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយសីល មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើតក្នុងភពនោះ សីលមានសភាពដូច្នោះ របស់អាត្មាអញក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយសុត: មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានមកកើតក្នុងភពនោះ សុត:មានសភាពដូច្នោះ របស់អាត្មាអញក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយចាគ: មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើតក្នុងភពនោះ ចាគ:មានសភាពដូច្នោះ របស់អាត្មាអញក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយបញ្ញា មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើតក្នុងភពនោះ បញ្ញាមានសភាពដូច្នោះ របស់

អាត្មាអញក៏មាន ។ កាលអរិយសាវកនោះ រឭករឿយៗ នូវសទ្ធា សីលៈ សុតៈ ចាគៈ បញ្ញា របស់ខ្លួន និងរបស់ទេវតាទាំងអម្បាលនោះ ចិត្តក៏ជ្រះថ្លា សេចក្តីរីករាយក៏កើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា ដូចការដុសខាត់មាស ដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការដុសខាត់មាសដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា ព្រោះអាស្រ័យបាវមាសផង អាស្រ័យដីប្រៃផង អាស្រ័យរង្គផង អាស្រ័យស្នប់ និងដង្កាប់ផង អាស្រ័យសេចក្តីព្យាយាមដ៏សមគួរដល់កិច្ចនោះ របស់បុរសផង ទើបដុសខាត់មាសដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមយ៉ាងនេះ យ៉ាងណាមិញ ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមក៏ដូច្នោះ យ៉ាងនោះឯង ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវកក្នុងធម្មវិន័យនេះ តែងរឭករឿយៗ នូវទេវតាថា ពួកទេវតាជាន់ចាតុម្មហារាជិកៈក៏មាន ពួកទេវតាជាន់តាវត្តិង្សក៏មាន ។បេ។ ពួកទេវតាដែលរាប់បញ្ចូលក្នុងពួកព្រហ្មក៏មាន ពួកទេវតាជាន់ខ្ពស់ឡើងទៅទៀតក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយសទ្ធា មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើតក្នុងភពនោះ សទ្ធាមានសភាពដូច្នោះ របស់អាត្មាអញក៏មាន ទេវតាទាំង

អម្បាលនោះ ប្រកបដោយសុតៈ ... ដោយចាគៈ ... ដោយបញ្ញា ... មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើតក្នុងភពនោះ បញ្ញាមានសភាពដូច្នោះ របស់អាត្មាអញក៏មាន ។ កាលអរិយសាវកនោះ រឭករឿយៗ នូវសទ្ធា សីលៈ សុតៈ ចាគៈ បញ្ញា របស់ខ្លួន និងរបស់ទេវតាទាំងនោះ ចិត្តក៏ជ្រះថ្លា សេចក្ដីរីករាយក៏កើតឡើង ឧបក្កិលេសទាំង-ឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះ ក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា អរិយសាវកនេះ ហៅថា ទេវតូ-បោសថ នៅរួមជាមួយនឹងពួកទេវតា មួយទៀត ចិត្តរបស់អរិយសាវកនោះ ប្រារព្ធទេវតា ក៏ជ្រះថ្លា សេចក្ដីរីករាយក៏កើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះ ក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាម យ៉ាងនេះឯង ។ ម្នាលនាងវិសាខា អរិយសាវកនោះ តែងពិចារណាឃើញដូច្នេះថា ព្រះអរហន្តទាំងឡាយ លះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្ដីខ្មាសបាប ប្រកបដោយសេចក្ដីអាណិត ជាអ្នកអនុគ្រោះដោយប្រយោជន៍ ចំពោះសព្វសត្វដែលមានជីវិត ដរាបដល់អស់ជីវិត ឯអាត្មាអញក្នុងថ្ងៃនេះ ក៏លះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានសស្ត្រាដាក់ចុះហើយ មានសេចក្ដីខ្មាសបាប ប្រកបដោយសេចក្ដីអាណិត ជាអ្នកអនុគ្រោះដោយប្រយោជន៍ ចំពោះសព្វសត្វ

ដែលមានជីវិត អស់យប់នេះ និងថ្ងៃនេះដែរ អាត្មាអញ ឈ្មោះថា ធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថឈ្មោះថា អាត្មាអញបានរក្សាផងដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយលះបង់អទិន្នាទាន វៀរចាកអទិន្នាទាន កាន់យកតែរបស់ដែលគេឲ្យ ប្រាថ្នាយកតែរបស់ដែលគេឲ្យ មានខ្លួនមិនលួច ស្អាតរហូតអស់ ១ ជីវិត អាត្មាអញក្នុងថ្ងៃនេះ ក៏លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន កាន់យកតែរបស់ដែលគេឲ្យ ប្រាថ្នាយកតែរបស់ដែលគេឲ្យ មានខ្លួនមិនលួច ស្អាតនៅអស់យប់នេះ និងថ្ងៃនេះដែរ អាត្មាអញ ឈ្មោះថា ធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថឈ្មោះថា អាត្មាអញបានរក្សាផងដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយ លះបង់អព្រហ្មចរិយៈ ជាព្រហ្មចារីបុគ្គល ជាអ្នកប្រព្រឹត្តឆ្ងាយចាក ( អព្រហ្មចរិយៈ ) វៀរចាកមេថុនដែលជាធម៌របស់អ្នកស្រុក អាត្មាអញក្នុងថ្ងៃនេះ ក៏លះបង់អព្រហ្មចរិយៈ ជាព្រហ្មចារីបុគ្គល ជាអ្នកប្រព្រឹត្តឆ្ងាយចាក ( អព្រហ្មចរិយៈ ) វៀរចាកមេថុន ដែលជាធម៌របស់អ្នកស្រុក អស់យប់នេះ និងថ្ងៃនេះដែរ អាត្មាអញ ឈ្មោះថា ធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថឈ្មោះថា អាត្មាអញបានរក្សាផងដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយលះបង់នូវមុសាវាទ វៀរចាកមុសាវាទ និយាយតែពាក្យពិត តភ្ជាប់តែពាក្យពិត មានពាក្យខ្ជាប់ខ្ជួន មានពាក្យគួរជឿ មិនពោលបង្កាច់សត្វលោក រហូតអស់មួយជីវិត អាត្មាអញក្នុងថ្ងៃនេះ ក៏លះបង់នូវមុសាវាទ វៀរចាកមុសាវាទ និយាយតែពាក្យពិត តភ្ជាប់តែពាក្យពិត មានពាក្យខ្ជាប់ខ្ជួន មានពាក្យគួរជឿ មិនពោល

បន្តាប់សត្វលោក អស់យប់នេះ និងថ្ងៃនេះដែរ អាត្មាអញឈ្មោះថា ធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថឈ្មោះថា អាត្មាអញរក្សាផង ដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយ លះបង់ការក្រេបផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ រហូតអស់មួយជីវិត ឯអាត្មាអញក្នុងថ្ងៃនេះ ក៏លះបង់ការក្រេបផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ វៀរចាកការក្រេបផឹកនូវទឹក ស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ អស់យប់នេះ និងថ្ងៃនេះដែរ អាត្មាអញឈ្មោះថា ធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថឈ្មោះថា អាត្មាអញបានរក្សាផង ដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយ បរិភោគភត្តតែម្តង វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគខុសកាល រហូតអស់មួយជីវិត អាត្មាអញក្នុងថ្ងៃនេះ ក៏បរិភោគភត្តតែម្តង វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគខុសកាល អស់យប់នេះ និងថ្ងៃនេះដែរ អាត្មាអញឈ្មោះថា ធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថឈ្មោះថា អាត្មាអញបានរក្សាផង ដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយ វៀរចាកការមើលនូវរបាំ និងការស្តាប់នូវចម្រៀង និងភ្លេងប្រគំ ដែលជាសត្រូវដល់កុសលធម៌ និងការទ្រទ្រង់ប្រដាប់ស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប គ្រឿងលាបផ្សេងៗ អាត្មាអញក្នុងថ្ងៃនេះ ក៏វៀរចាកការមើលរបាំ និងការស្តាប់ចម្រៀង និងភ្លេងប្រគំ ដែលជាសត្រូវដល់កុសលធម៌ និងការទ្រទ្រង់ប្រដាប់ស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប គ្រឿងលាប

ផ្សេងៗ អស់យប់នេះ និងថ្ងៃនេះដែរ អាត្មាអញ ឈ្មោះថា ធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថឈ្មោះថា អាត្មាអញបានរក្សាផង ដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយលះបង់ទីដេក ទីអង្គុយដ៏ខ្ពស់ និងទីដេក ទីអង្គុយដ៏ប្រសើរ វៀរស្រឡះចាកទីដេក ទីអង្គុយដ៏ខ្ពស់ និងទីដេក ទីអង្គុយដ៏ប្រសើរ សម្រេចទីដេកដ៏ទាបលើគ្រែក្តី លើកម្រាលស្មៅក្តី រហូតអស់មួយជីវិត អាត្មាអញក្នុងថ្ងៃនេះ ក៏លះបង់ទីដេកទីអង្គុយដ៏ខ្ពស់ និងទីដេកទីអង្គុយដ៏ប្រសើរ វៀរស្រឡះចាកទីដេក ទីអង្គុយដ៏ខ្ពស់ និងទីដេកទីអង្គុយដ៏ប្រសើរ សម្រេចទីដេកដ៏ទាប លើគ្រែក្តី លើកម្រាលស្មៅក្តី អស់យប់នេះ និងថ្ងៃនេះដែរ អាត្មាអញឈ្មោះថា ធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថឈ្មោះថា អាត្មាអញបានរក្សាផងដោយអង្គនេះឯង ។ ម្នាលនាងវិសាខា យ៉ាងនេះឈ្មោះថា អរិយុបោសថ ម្នាលនាងវិសាខា អរិយុបោសថដែលបុគ្គលរក្សាយ៉ាងនេះ តែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន ផ្សាយផលទៅច្រើន ។ មានផលច្រើនយ៉ាងណា មានអានិសង្សច្រើនយ៉ាងណា មានសេចក្តីរុងរឿងច្រើនយ៉ាងណា ផ្សាយផលទៅច្រើនយ៉ាងណា ។ ម្នាលនាងវិសាខា ប្រៀបដូចបុគ្គលណាមួយ គប្បីគ្រងរាជសម្បត្តិ ជាឥស្សរ-
ិយាធិបតីនៃមហាជនបទទាំង ១៦ នេះ ដែលមានរតនៈ ៧ ប្រការដ៏ច្រើន មហាជនបទទាំង ១៦ គឺអង្គៈ មគធៈ កាសី កោសលៈ វជ្ជី មល្លៈ ចេតីវង្សៈ កុរុ បញ្ចាលៈ មច្ឆៈ សុរៈ សេនៈ អស្សកៈ អវន្តី គន្ធារៈ កម្ពោជៈ រាជសម្បត្តិរបស់បុគ្គលនុ៎ះ មានតម្លៃមិនស្មើចំណិតទី ១៦ៗ លើក នៃឧបោ-

សថប្រកបដោយអង្គ ៨ ឡើយ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលនាងវិសាខា រាជសម្បត្តិជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្តីសុខទិព្វ ( ឃើញ ) ស្តើងស្តួចណាស់ ។ ម្នាលនាងវិសាខា ៥០ ឆ្នាំរបស់មនុស្ស ជាមួយយប់មួយថ្ងៃរបស់ពួកទេវតាជាន់ចាតុម្មហារាជិកៈ រាប់តាមរាត្រីនោះ ៣០ រាត្រីជាមួយខែ រាប់តាមខែនោះ ១២ ខែ ជាមួយឆ្នាំ រាប់តាមឆ្នាំនោះ ៥០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់ចាតុម្មហារាជិកៈ ។ ម្នាលនាងវិសាខា ហេតុនុ៎ះ រមែងមានប្រាកដ ត្រង់ពាក្យថា ស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ រក្សាឧបោសថប្រកបដោយអង្គ ៨ ហើយ លុះដល់រំលោងកាយស្លាប់ទៅ ទៅកើតរួមជាមួយនឹងពួកទេវតា ជាន់ចាតុម្មហារាជិកៈ។ ម្នាលនាងវិសាខា ដែលជារាជសម្បត្តិជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្តីសុខទិព្វ ( ឃើញ ) ស្តើងស្តួចនេះ តថាគតពោលសំដៅយកត្រង់ហេតុនុ៎ះឯង ។ ម្នាលនាងវិសាខា ១០០ ឆ្នាំរបស់មនុស្ស ជាមួយយប់មួយថ្ងៃរបស់ទេវតាជាន់តាវត្តិង្ស រាប់តាមរាត្រីនោះ ៣០ រាត្រី ជា ១ ខែ រាប់តាមខែនោះ ១២ ខែ ជា ១ ឆ្នាំ រាប់តាមឆ្នាំនោះ ១០០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់តាវត្តិង្ស ។ ម្នាលនាងវិសាខា ហេតុនុ៎ះ រមែងមានប្រាកដ ត្រង់ពាក្យថា ស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ រក្សាឧបោសថប្រកបដោយអង្គ ៨ ហើយ លុះដល់រំលោងកាយស្លាប់ទៅ ទៅកើតរួមជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ។ ម្នាលនាងវិសាខា ដែលថា រាជសម្បត្តិជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្តីសុខទិព្វ ( ឃើញ ) ស្តើងស្តួចនេះ តថាគតពោលសំដៅយកត្រង់

ហេតុនុ៎ះឯង ។ ម្នាលនាងវិសាខា ២០០ ឆ្នាំរបស់មនុស្ស ជាមួយយប់មួយថ្ងៃ របស់ពួកទេវតាជាន់យាមៈ រាប់តាមរាត្រីនោះ ៣០ រាត្រី ជា ១ ខែ រាប់តាមខែនោះ ១២ ខែ ជា ១ ឆ្នាំ រាប់តាមឆ្នាំនោះ ២០០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់យាមៈ ។ ម្នាលនាងវិសាខា ហេតុនុ៎ះរមែងមានប្រាកដ ត្រង់ពាក្យថា ស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ រក្សានូវឧបោសថប្រកបដោយអង្គ ៨ ហើយ លុះដល់រំលាយកាយស្លាប់ទៅ ទៅកើតរួមជាមួយនឹងពួកទេវតាជាន់យាមៈ ។ ម្នាលនាងវិសាខា ដែលថារាជសម្បត្តិជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្តីសុខទិព្វ ( ឃើញ ) ស្តើងស្តួចនេះ តថាគតពោលសំដៅយកត្រង់ហេតុនុ៎ះឯង ។ ម្នាលនាងវិសាខា ៤០០ ឆ្នាំរបស់មនុស្ស ជាមួយយប់មួយថ្ងៃ របស់ពួកទេវតាជាន់តុសិត រាប់តាមរាត្រីនោះ ៣០ រាត្រី ជា ១ ខែ រាប់តាមខែនោះ ១២ ខែ ជា ១ ឆ្នាំ រាប់តាមឆ្នាំនោះ ៤០០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់តុសិត ។ ម្នាលនាងវិសាខា ហេតុនុ៎ះ រមែងមានប្រាកដ ត្រង់ពាក្យថា ស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ រក្សានូវឧបោសថប្រកបដោយអង្គ ៨ ហើយ លុះដល់រំលាយកាយស្លាប់ទៅ ទៅកើតរួមជាមួយនឹងពួកទេវតាជាន់តុសិត ។ ម្នាលនាងវិសាខា ដែលថារាជសម្បត្តិជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្តីសុខទិព្វ ( ឃើញ ) ស្តើងស្តួចនេះ តថាគតពោលសំដៅយកត្រង់ហេតុនុ៎ះឯង ។ ម្នាលនាងវិសាខា ៨០០ ឆ្នាំរបស់មនុស្ស ជាមួយយប់មួយថ្ងៃរបស់ពួកទេវតា ជាន់និម្មានរតី រាប់តាមរាត្រីនោះ ៣០ រាត្រី ជា ១ ខែ រាប់តាមខែនោះ ១២ ខែ

ជា ១ ឆ្នាំ រាប់តាមឆ្នាំនោះ ៨០០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់និម្មានរតី ។ ម្នាលនាងវិសាខា ហេតុនុ៎ះ រមែងមានប្រាកដ ត្រង់ពាក្យថា ស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ រក្សានូវឧបោសថប្រកបដោយអង្គ ៨ ហើយ លុះដល់រំលាងកាយស្លាប់ទៅ ទៅកើតរួមជាមួយនឹងពួកទេវតាជាន់និម្មានរតី ។ ម្នាលនាងវិសាខា ដែលថារាជសម្បត្តិជារបស់មនុស្សប្រៀបធៀបនឹងសេចក្តីសុខទិព្វ ( ឃើញ ) ស្តើងស្តួចនេះ តថាគតពោលសំដៅយកត្រង់ហេតុនុ៎ះឯង ។ ម្នាលនាងវិសាខា ១៦០០ ឆ្នាំរបស់មនុស្សជាមួយយប់មួយថ្ងៃ របស់ពួកទេវតាជាន់បរនិម្មិតវសវត្តី រាប់តាមរាត្រីនោះ ៣០ រាត្រី ជា ១ ខែ រាប់តាមខែនោះ ១២ ខែ ជា ១ ឆ្នាំ រាប់តាមឆ្នាំនោះ ១៦០០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់បរនិម្មិតវសវត្តី ។ ម្នាលនាងវិសាខា ហេតុនុ៎ះ រមែងមានប្រាកដ ត្រង់ពាក្យថា ស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ រក្សានូវឧបោសថប្រកបដោយអង្គ ៨ ហើយ លុះដល់រំលាងកាយស្លាប់ទៅ ទៅកើតរួមជាមួយនឹងពួកទេវតាជាន់បរនិម្មិតវសវត្តី ។ ម្នាលនាងវិសាខា ដែលថារាជសម្បត្តិជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្តីសុខទិព្វ ( ឃើញ ) ស្តើងស្តួចនេះ តថាគតពោលសំដៅយកត្រង់ហេតុនុ៎ះឯង ។

បុរស ឬស្ត្រីមិនគប្បីសម្លាប់សត្វ ១ មិនគប្បីលួចយក
ទ្រព្យដែលម្ចាស់គេមិនបានឲ្យ ១ មិនគប្បីនិយាយ
កុហក ១ មិនគប្បីក្រេបផឹកនូវទឹកស្រវឹង ១ គប្បីវៀរ

ចាកមេថុន ដែលមិនមែនជាសេចក្តីប្រព្រឹត្តដ៏ប្រសើរ ១ មិនគប្បីបរិភោគភោជនក្នុងវេលារាត្រី និងភោជនក្នុងវេលាខុសកាល ១ មិនគប្បីទ្រទ្រង់កម្រងផ្កា មិនគប្បីប្រើប្រាស់គ្រឿងក្រអូប ១ គប្បីដេកលើគ្រែ ( ដែលត្រូវប្រមាណ ) ឬកម្រាលដែលក្រាលផ្ទាល់នឹងផែនដី ១ ។ ( បណ្ឌិតទាំងឡាយពោលសរសើរ ) ឧបោសថប្រកបដោយអង្គ ៨ នុ៎ះ ដែលព្រះពុទ្ធទ្រង់ដល់នូវទីបំផុតនៃទុក្ខ ទ្រង់ប្រកាសទុកហើយ ។ ព្រះចន្ទ្រ និងព្រះអាទិត្យទាំងពីរ មានរស្មីដ៏រុងរឿង ភ្លឺច្បុះ ផ្សាយចេញទៅ អស់ទីមានកំណត់ត្រឹមណា មួយទៀត ព្រះចន្ទ្រ និងព្រះអាទិត្យ មាននាទីកម្ចាត់បង់នូវងងឹត មានដំណើរទៅក្នុងអាកាស ចាំងពន្លឺសព្វទិស តែងបំភ្លឺក្នុងផ្ទៃមេឃ ទ្រព្យណាមួយ ដែលមាននៅក្នុងចន្លោះនុ៎ះ គឺកែវមុក្តា កែវមណី កែវពៃទូរ្យដ៏ល្អ មួយវិញទៀត ដែលហៅថាមាសសិង្គី មាសកាញ្ចនៈ មាសជាតរូប និងមាសហាដកៈ ទ្រព្យទាំងអម្បាលនោះ ( មានតម្លៃ ) មិនដល់នូវចំណិតទី ១៦ៗ លើកនៃឧបោសថ ប្រកបដោយអង្គ ៨ ឡើយ ដូចពួកផ្កាយទាំងអស់ ( ភ្លឺ ) មិនដល់ពន្លឺព្រះចន្ទ្រឡើយ ព្រោះហេតុនោះ ស្ត្រីបុរស

ដែលជាអ្នកមានសីល បានរក្សាឧបោសថ ប្រកបដោយ
អង្គ ៨ ធ្វើបុណ្យទាំងឡាយ ដែលមានសុខជាកម្រៃ ជា
អ្នកមិនត្រូវគេតិះដៀល តែងទៅកើតក្នុងស្ថានសួគ៌ ។

**មហាវគ្គទី ២ ចប់**

## ឧទ្ទាននៃមហាវគ្គនោះ គឺ

និយាយអំពីតិត្ថាយតនៈ ១ អំពីអមាតាបុត្តិកភ័យ ១ អំពីអ្នកស្រុកវេនាគបុរៈ ១ អំពីសរភបរិព្វាជក ១ អំពីអ្នកនិគមកេសបុត្ត ១ អំពីសាឡ្ហៈចៅរបស់មិគារ-សេដ្ឋី ១ អំពីកថាវត្ថុ ១ អំពីតិត្ថិយទាំងឡាយ ១ អំពីអកុសលមូល និងកុសលមូល ១ អំពីឧបោសថៈ ១ ។

# អដ្ឋកថា

## ឧបោសថសូត្រ

[ ៧២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧបោសថសូត្រទី ១០ ដូច្នេះ បទថា **តទហុបោសថេ** ស្មើគ្នានឹង **តស្មឹ អហុ ឧបោសថេ** គឺ **តំទិវសំ ឧបោសថេ** ប្រែថា ឧបោសថក្នុងថ្ងៃនោះ អធិប្បាយថា ក្នុងថ្ងៃនោះជាថ្ងៃបណ្ណរសីឧបោសថ ។ បទថា **ឧបសង្កមិ** សេចក្តីថា នាងវិសាខាអធិដ្ឋានអង្គឧបោសថ ហើយកាន់យកគ្រឿងក្រអូប និងផ្កាកម្រងជាដើម ចូលទៅគាល់ហើយ ។ បទថា **ហន្ទ** ជានិបាត ប្រើក្នុងអត្ថថា អញ្ជើញ ។ បទថា **ទិវា ទិវស្ស** សេចក្តីថា វេលាថ្ងៃត្រង់ ឈ្មោះថា ពេលថ្ងៃ បានដល់ ក្នុងពេលដែលព្រះអាទិត្យតាំងនៅត្រង់កណ្តាល ។ បទថា **កុតោ នុ ត្វំ អាគច្ឆសិ** សេចក្តីថា ព្រះមានព្រះភាគត្រាស់សួរថា អ្នកទៅធ្វើអ្វី ។

ឧបោសថប្រៀបដូចអ្នកស៊ីឈ្នួលចិញ្ចឹមគោ ព្រោះមានការត្រិះរិះថា មិនបរិសុទ្ធ ឈ្មោះថា គោបាលកឧបោសថ ។ ឧបោសថ គឺការរក្សារបស់និគ្រន្ថទាំងឡាយ ឈ្មោះថា និគណ្ឋឧបោសថ ។ ឧបោសថ គឺការរក្សារបស់ព្រះអរិយៈទាំងឡាយ ឈ្មោះថា អរិយឧបោសថ ដូច្នេះ ។ បទថា **សេយ្យថាបិ វិសាខេ** សេចក្តីថា ម្នាលនាងវិសាខា ប្រៀបដូច ... ។ បទថា **សាយណ្ហសមយេ សាមិកានំ គាវោ និយ្យាទេត្វា** សេចក្តីថា ពិតហើយ អ្នកចិញ្ចឹមគោ ទទួលគោមកចិញ្ចឹម ព្រោះតម្លៃឈ្នួល រាប់ថ្ងៃដោយកំណត់ថា ៥ ថ្ងៃ ១០ ថ្ងៃ កន្លះខែ ១ ខែ ៦ ខែ ឬ ១ ឆ្នាំ តែក្នុងព្រះសូត្រនេះ

ត្រាស់ពាក្យថា **គោបាលកុបោសថោ** ទ្រង់សំដៅដល់អ្នកចិញ្ចឹមគោ ព្រោះថ្លៃឈ្នួលរាប់ថ្ងៃ ។ បទថា **និយ្យាតេត្វា** សេចក្តីថា ប្រគល់ឲ្យ គឺពោលថា គោរបស់អ្នកមានចំនួនប៉ុណ្ណោះ ។ បទថា **ឥតិ បដិសញ្ចិក្ខតិ** សេចក្តីថា ទៅដល់ផ្ទះរបស់ខ្លួន បរិភោគអាហារហើយ ដេកលើគ្រែ ពិចារណាយ៉ាងនេះ ។ បទថា **អភិជ្ឈាសហគតេន** សេចក្តីថា សម្បយុត្តដោយតណ្ហា ។ បទថា **ឯវំ ខោ វិសាខេ គោបាលកុបោសថោ ហោតិ** សេចក្តីថា នេះជាអរិយ-ឧបោសថដូចគ្នា តែព្រោះមានវិតក្កមិនបរិសុទ្ធ ទើបនៅក្នុងឋានៈនៃគោបាលក-ឧបោសថប៉ុណ្ណោះ ។ បទថា **ន មហប្ផលោ** សេចក្តីថា មិនមានផលច្រើន ព្រោះផល គឺវិបាក ។ បទថា **ន មហានិសំសោ** សេចក្តីថា ឈ្មោះថា មិនមានអានិសង្សច្រើន ព្រោះអានិសង្ស គឺវិបាក ។ បទថា **ន មហាជុតិកោ** សេចក្តីថា មិនមានពន្លឺច្រើន ព្រោះពន្លឺ គឺវិបាក ។ បទថា **ន មហាវិប្ផារោ** សេចក្តីថា ឈ្មោះថា មិនផ្សាយទៅច្រើន ព្រោះការផ្សាយទៅនៃវិបាក មានមិនច្រើន ។

បទថា **សមណជាតិកា** បានដល់ ពួកសមណៈ ។ បទថា **បរំយោ-ជនសតំ** សេចក្តីថា ឆ្ងាយជាង ១០០ យោជន៍ គឺហួសអំពីនោះទៅ ។ បទថា **តេសុ ទណ្ឌំ និក្ខិបាហិ** សេចក្តីថា ដាក់ចុះនូវអាជ្ញា គឺជាអ្នកដាក់អាជ្ញាក្នុងសត្វទាំងឡាយនោះ ដែលនៅឆ្ងាយជាង ១០០ យោជន៍ទៅ ។

បទថា **នាហំ ក្វចិនិ កស្សចិ កិញ្ចនំ តស្មឹ** សេចក្តីថា អញមិនមានកង្វល់ចំពោះបុគ្គលដទៃក្នុងទីណាមួយ អធិប្បាយថា បលិពោធ ទ្រង់ត្រាស់

ហៅថា ការកន្សល់ អញជាអ្នកមិនមានកន្សល់ ។ បទថា **នត្ថិ មម កុចិនិ កិស្មិញ្ចិ កិញ្ចនំ នត្ថិ** សេចក្ដីថា តថាគតមិនមានកន្សល់ គឺមិនមានបលិពោធក្នុងវត្ថុណាមួយ គឺក្នុងបរិក្ខារណាមួយ ក្នុងទីណាមួយ គឺទាំងខាងក្នុង និងខាងក្រៅ មានអធិប្បាយថា តថាគតកាត់នូវការកន្សល់ដាច់ហើយ ។ បទថា **ភោគេ** បានដល់ គ្រឿងឧបភោគ និងបរិភោគ មានគ្រែ តាំង បបរ និងភត្តជាដើម ។ បទថា **អធិដ្ឋាយេវ បរិភុញ្ជតិ** សេចក្ដីថា ក្នុងថ្ងៃស្អែកឡើង កាលភិក្ខុដេកលើគ្រែក្ដី អង្គុយលើគ្រែក្ដី ហុតបបរក្ដី ឆាន់អាហារក្ដី ឈ្មោះថា បរិភោគភោគៈទាំងនោះ ដែលគេមិនបានឲ្យ ។

បទថា **ន មហប្ផលោ** ប្រែថា ឥតផល ។ ក្នុងបទថា **ន មហប្ផលោ** នេះ មានតែព្យញ្ជនៈប៉ុណ្ណោះដែលសល់ ចំណែកអត្ថមិនមានសល់ឡើយ ។ ព្រោះថា ឧបោសថរបស់បុគ្គលដែលរក្សាយ៉ាងនេះ មិនមានវិបាកដែលគួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្តត្រឹមតែបន្តិចបន្តួច ព្រោះដូច្នោះ និគណ្ឋ-ឧបោសថ គប្បីជ្រាបថា មិនមានផលឡើយ ។ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់ពាក្យនេះថា ចិត្តសៅហ្មងហើយ ។ ឆ្លើយថា ព្រោះថា ការដែលឧបោសថ ភិក្ខុមានចិត្តបរិសុទ្ធរក្សាហើយ មានផលច្រើន ឈ្មោះថា ទ្រង់អនុញ្ញាតហើយ ព្រោះទ្រង់សម្ដែងថា ឧបោសថដែលបុគ្គលមានចិត្តសៅហ្មង រក្សាហើយ រមែងមិនមានផលច្រើនឡើយ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគត្រាស់ពាក្យនេះ ដើម្បីសម្ដែង

កម្មដ្ឋានដែលជាហេតុឲ្យចិត្តបរិសុទ្ធ គឺកម្មដ្ឋានដែលជាហេតុជម្រះចិត្ត ។ បណ្តាបទទាំងនោះ បទថា **ឧបក្កមេន** សេចក្តីថា ដោយសេចក្តីព្យាយាមរបស់បុរសចំពោះខ្លួន ឬដោយឧបាយ ។

បទថា **តថាគតំ អនុស្សរតិ** សេចក្តីថា រឭកដល់ព្រះគុណរបស់ព្រះតថាគតដោយហេតុ ៨ ប្រការ ។ ក្នុងបទថា **តថាគតំ អនុស្សរតិ** នេះ លោកសង្គ្រោះយកព្រះពុទ្ធគុណទាំងអស់ ។ ដែលជាលោកិយផង លោកុត្តរផង ដោយពាក្យថា **ឥតិបិ សោ ភគវា** ដែលពន្រឹកសេចក្តីចេញទៅថា ព្រោះសីលនេះ ព្រះមានព្រះភាគអង្គនោះ ព្រោះសមាធិនេះ ព្រះមានព្រះភាគអង្គនោះ ទ្រង់សម្តែងព្រះគុណដែលជាចំណែកទ្រង់ប៉ុណ្ណោះ ដោយបទជាដើមថា **អរហំ** ដូច្នេះ ។ បទថា **តថាគតំ អនុស្សរតោ ចិត្តំ បសីទតិ** សេចក្តីថា កាលបុគ្គលរឭកដល់ព្រះគុណរបស់ព្រះតថាគត ដែលជាលោកិយផង លោកុត្តរផង ចិត្តប្បាទរមែងផូរផង់ ។

នីវរណៈទាំង ៥ ឈ្មោះថា **ឧបក្កិលិដ្ឋស្ស ចិត្តស្ស** កាកកន្ទួតព្រៃឈ្មោះថា **កក្ក** ។ បទថា **តជ្ជំ វាយាមំ** សេចក្តីថា សេចក្តីព្យាយាមដើម្បីប្រោះព្រំដុសខាត់ និងលាងដោយដុំដែលកើតអំពីកាកកន្ទួតព្រៃនោះ ដែលសមគួរដល់កាកកន្ទួតព្រៃនោះ ។

បទថា **បរិយោទបនា ហោតិ** សេចក្តីថា រមែងជាការធ្វើនូវការស្អាត ។ ពិតហើយ ព្រះមានព្រះភាគត្រាស់យ៉ាងនេះ ដោយពុទ្ធបំណងថា បើប្រដាប់គ្រឿងអលង្ការលើក្បាលដែលស្មោកគ្រោក លេងនក្ខត្តឫក្ស ក៏មិន

ស្អាត តែបើប្រដាប់គ្រឿងអលង្ការលើក្បាលដែលស្អាត លេងនក្ខត្តឫក្ស រមែងស្អាត យ៉ាងណា ឧបោសថដែលមានចិត្តសៅហ្មង អធិដ្ឋានអដ្ឋឧបោសថ ហើយរក្សា នឹងមិនមានផលច្រើន តែឧបោសថដែលបុគ្គលមានចិត្តស្អាត អធិដ្ឋានអដ្ឋឧបោសថ ហើយរក្សា រមែងមានផលច្រើនដូច្នោះដូចគ្នាដូច្នេះ ។

បទថា **ព្រហ្មុបោសថំ ឧបវសតិ** សេចក្តីថា ព្រះសម្មាសម្ពុទ្ធ បុគ្គលតែងហៅថា ព្រះព្រហ្ម ឧបោសថនេះ ឈ្មោះថា **ព្រហ្មឧបោសថ** ដោយសមាទាននៃការរឭកដល់គុណរបស់ព្រហ្មនោះ រក្សាព្រហ្មឧបោសថនោះ ។ បទថា **ព្រហ្មុនា សទ្ធឹ សំវសតិ** សេចក្តីថា គប់រកជាមួយព្រះសម្មាសម្ពុទ្ធ ។ បទថា **ព្រហ្មញ្ចស្ស អារព្ភ** សេចក្តីថា ប្រារព្ធព្រះសម្មាសម្ពុទ្ធ ។ បទថា **ធម្មំ អនុស្សរតិ** សេចក្តីថា រឭកដល់លោកុត្តរធម៌ ព្រមដោយពុទ្ធវចនៈ ។ បទថា **សោត្តឹ** បានដល់ កម្ទេចថ្មដែលបុគ្គលជួបក្នុងដែនកុរុ ។ មនុស្សទាំងឡាយ ផ្សំល័ខចូលជាមួយកម្ទេចថ្មដែលជួបក្នុងដែនកុរុ សួនជាគ្រាប់ផ្គាំ បោះរន្ធហើយ យកអំបោះដោត ចាប់ខ្សែកម្រងកូនផ្គាំទាំងសងខាង ហើយត្រដុសខ្លួន ។ បទថា **សោត្តិញ្ច បដិច្ច** នេះ ព្រះមានព្រះភាគត្រាស់សំដៅយកកម្រងផ្គាំនោះ ។ បទថា **ចុណ្ណំ** បានដល់ លម្អិតដែលប្រើក្នុងពេលងូតទឹក ។ បទថា **តជ្ជំ វាយាមំ** បានដល់ សេចក្តីព្យាយាមដែលសមនឹងកិច្ចនោះ មានការលាប ដុចខាត់ និងលាងជម្រះជាដើម ។ បទថា **ធម្មុបោសថំ** សេចក្តីថា ឧបោសថនេះ ព្រះមានព្រះភាគត្រាស់ហៅថា ធម្មឧបោសថ ព្រោះប្រារព្ធនវលោកុត្តរធម៌ មួយអន្លើជាមួយពុទ្ធវចនៈ ហើយ

រក្សា ។ អ្នកសិក្សាគួរដាក់បទថា **បរិយោទបនា** នេះជាគោល ហើយប្រកប សេចក្តីដោយន័យមុននោះឯង ។

បទថា **សង្ឃំ អនុស្សរតិ** សេចក្តីថា រឭកដល់គុណរបស់ព្រះអរិយ-បុគ្គល ៨ ពួក ។ បទថា **សញ្ញំ បដិច្ច** សេចក្តីថា អាស្រ័យកម្តៅដែលដាក់ឲ្យក្តៅ ដោយលើកដាក់លើជើងក្រាន ស្ងោរ ២-៣ អំពុះ ។ បាឋៈថា **ឩស្មំ** ដូច្នេះក៏មាន ។ អត្ថក៏តែមួយដូចគ្នានោះឯង ។ បទថា **ទីរំ** បានដល់ ផេះ ។ បទថា **គោមយំ** បានដល់ លាមកគោ ឬលាមកពពែ ។ ក្នុងបទថា **បរិយោទបនា** នេះ គប្បីប្រកបអត្ថដោយន័យមុននោះឯង ។ បទថា **សង្ឃុ-ទោសថំ** សេចក្តីថា ឧបោសថនេះ ត្រាស់ហៅថា **សង្ឃុទោសថ** ព្រោះប្រារព្ធគុណរបស់ព្រះអរិយបុគ្គល ៨ ពួក ហើយទើបរក្សា ។ បទថា **សីលានិ** សេចក្តីថា ជាគ្រហស្ថ ក៏រឭកដល់សីលរបស់គ្រហស្ថ ជាបព្វជិតក៏រឭកដល់សីលរបស់បព្វជិត ។ អធិប្បាយរបស់បទថា **អខណ្ឌានិ** ( សីលមិនដាច់ ) ជាដើម ខ្ញុំបានឲ្យពិស្តារហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។

បទថា **វាលណ្ឌុកំ** បានដល់ ប្រាសដែលធ្វើដោយរោមកន្ទុយសេះ ឬសម្បកធ្មៃជាដើម ។ បទថា **តជ្ជំ វាយាមំ** បានដល់ ការដែលយកប្រេងលាប គិតថា ប្រែះសើមទូទៅ ចាក់ផេះចូលទៅ ហើយព្យាយាមយកប្រាសដុស ។ អ្នកសិក្សាគួរប្រកបសេចក្តីយ៉ាងនេះ ដោយទាញបទថា **បរិយោ-ទបនា** នេះ ជាគោលដូចតទៅនេះ

រាងកាយ ទោះបីតាក់តែងគ្រឿងអលង្ការហើយ កាលកញ្ចក់សម្រាប់

ធុះមិនថា សម្លឹងមើលក៏មិនស្អាត កាលកញ្ចក់ស្អាត ទើបស្អាត យ៉ាងណា ឧបោសថដែលបុគ្គលរក្សាហើយ ក៏ដូច្នោះដូចគ្នា កាលចិត្តសៅហ្មង ក៏មិនមានផលច្រើន កាលចិត្តបរិសុទ្ធ ទើបមានផលច្រើន ដូច្នេះឯង ។ បទថា **សីលុបោសថំ** សេចក្ដីថា ឧបោសថដែលបុគ្គលរក្សាដោយអំណាចការរឭកដល់សីលរបស់ខ្លួន ឈ្មោះថា **សីលុបោសថ** ។ បទថា **សីលេន សទ្ធឹ** សេចក្ដីថា មួយអន្លើដោយសីល ៥ សីល ១០ របស់ខ្លួន ។ បទថា **សីលំ អារព្ភ** សេចក្ដីថា ប្រារព្ធសីល ៥ ផង សីល ១០ ផង ។

បទថា **ទេវតា អនុស្សរតិ** សេចក្ដីថា រឭកដល់គុណ គឺសទ្ធាជាដើមរបស់ខ្លួន ដោយតាំងទេវតាក្នុងឋានៈជាបន្ទាល់ ។ បទថា **ឧក្កំ** ប្រែថា ចង្រ្កាន ។ បទថា **លោណំ** បានដល់ ដីប្រៃ ។ បទថា **គេរុកំ** បានដល់ លម្អិតពណ៌ ( រង្គ ) ។ បទថា **នាឡិកសណ្ឌាសំ** បានដល់ ស្នប់ដែលធ្វើដោយដើមបបុស និងដង្កាប់សម្រាប់កៀប ។ បទថា **តជ្ជំ វាយាមំ** បានដល់ ព្យាយាមដ៏សមគួរ មានការដាក់ចុះក្នុងចង្រ្កាន ការសប់ និងការប្រើដង្កាប់ក្ដឹះជាដើម អ្នកសិក្សាគួរដាក់បទថា **បរិយោទបនា** នេះ ជាគោល ហើយប្រកបសេចក្ដីដោយន័យមុននោះឯង ព្រោះថា បុគ្គលតែងខ្លួនដោយគ្រឿងប្រដាប់ដែលធ្វើដោយមាសសៅហ្មង លេងនក្ខត្តឫក្ស រមែងមិនស្អាត តែបើតែងខ្លួនដោយគ្រឿងអលង្ការដែលធ្វើដោយមាសបរិសុទ្ធ លេងនក្ខត្តឫក្ស ទើបស្អាត យ៉ាងណា បុគ្គលមានចិត្តសៅហ្មង ក៏ដូច្នោះដូចគ្នា ឧបោសថរមែងមិនមានផលច្រើន ឯបុគ្គលមានចិត្តបរិសុទ្ធ ទើបមានផល

ច្រើន ។ បទថា **ទេវតូបោសថំ** សេចក្ដីថា ឧបោសថដែលបុគ្គលរឭកដល់គុណធម៌របស់ខ្លួន ដោយតាំងទេវតាក្នុងឋានៈជាបន្ទាល់ ហើយរក្សា ឈ្មោះថា **ទេវតាឧបោសថ** ។ ពាក្យដ៏សេស ដែលគួរពោលដល់ក្នុងកម្មដ្ឋាន មានពុទ្ធានុស្សតិជាដើមទាំងអស់នេះ ខ្ញុំបានពោលហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។

បទថា **បាណាតិបាតំ** បានដល់ ការសម្លាប់សត្វ ។ បទថា **បហាយ** សេចក្ដីថា លះនូវការទ្រុស្តសីល ពោល គឺចេតនាដែលជាហេតុសម្លាប់សត្វនោះ ។ បទថា **បដិវិរតា** សេចក្ដីថា វៀរ គឺវៀរចាកភាពជាអ្នកទ្រុស្តសីលនោះ តាំងអំពីពេលដែលលះបានហើយ ។

បទថា **និហិតទណ្ឌា និហិតសត្ថា** អធិប្បាយថា ឈ្មោះថា បោលនូវដំបងផង សស្ត្រាផង ព្រោះមិនកាន់ដំបង ឬសស្ត្រា ប្រព្រឹត្តទៅ ដើម្បីសម្លាប់អ្នកដទៃ ។ វៀរដំបងចេញហើយ ឧបករណ៍ដ៏សេសទាំងអស់ គប្បីជ្រាបថា ឈ្មោះថា សស្ត្រា ក្នុងបទថា **និហិតទណ្ឌា និហិតសត្ថា** នេះ ព្រោះញ៉ាំងជីវិតសត្វទាំងឡាយឲ្យវិនាស ។ ចំណែកភិក្ខុកាន់ឈើច្រត់មនុស្សចាស់ កាំបិតកាត់ឈើស្ទន់ ឬកន្ត្រៃ មិនមែនដើម្បីសម្លាប់អ្នកដទៃ ព្រោះដូច្នោះ ភិក្ខុនោះ ឈ្មោះថា ដាក់ចុះនូវដំបងហើយ ដាក់ចុះនូវសស្ត្រាហើយដូចគ្នា ។ បទថា **លជ្ជី** សេចក្ដីថា ប្រកបដោយការខ្មាស មានការរង្កៀសបាបជាលក្ខណៈ ។ បទថា **ទយាបន្នា** សេចក្ដីថា ដល់នូវការអាណិត គឺភាពជាអ្នកមានមេត្តាចិត្ត ។ បទថា **សព្វបាណភូតហិតានុកម្បី** សេចក្ដី

ថា អនុគ្រោះសត្វមានជីវិតទាំងពួងដោយប្រយោជន៍ អធិប្បាយថា មានចិត្តឧបការៈពួកសត្វមានជីវិតទាំងពួង ព្រោះជាអ្នកមានចិត្តអាណិតអាសូរនោះឯង ។

បទថា **អហាយ្យជ្ជ** កាត់បទជា **អហាំបិ អជ្ជ** ។ បទថា **ឥមិនាបិ អង្គេន** បានដល់ ដោយអង្គគុណនេះ ។ បទថា **អរហតំ អនុករោមិ** សេចក្តីថា កាលដើរតាមក្រោយបុគ្គលដែលដើរទៅខាងមុខ ឈ្មោះថា ដើរតាម យ៉ាងណា សូម្បីអាត្មាអញក៏ដូច្នោះ កាលបំពេញគុណនេះខាងក្រោយដែលព្រះអរហន្តទាំងឡាយបំពេញមកអំពីមុន ឈ្មោះថា ចម្រើនស្នាមតាមព្រះអរហន្តទាំងនោះ ។ បទថា **ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតិ** សេចក្តីថា ការដែលអាត្មាអញធ្វើយ៉ាងនេះ ឈ្មោះថា ចម្រើនស្នាមតាមព្រះអរហន្តផង និងឈ្មោះថា ចូលធ្វើឧបោសថផង ។

ការកាន់យកវត្ថុដែលម្ចាស់ទ្រព្យមិនបានឲ្យ គឺដែលអ្នកដទៃហួងហែងឈ្មោះថា អទិន្នាទាន អធិប្បាយថា បានដល់ ការលួច គឺការងាររបស់ចោរ ឈ្មោះថា **ទិន្នាទាយី** ព្រោះកាន់យកចំពោះតែរបស់ដែលគេឲ្យ ។ ឈ្មោះថា **ទិន្នបាដិកង្ខី** ព្រោះសង្ឃឹមក្នុងចិត្តចំពោះរបស់ដែលគេឲ្យ ។ ឈ្មោះថា **ថេន** ព្រោះលួច ឈ្មោះថា **អថេន** ព្រោះមិនលួច ។ ឈ្មោះថា **សុចិភូតេន** ព្រោះមិនលួចនោះឯង ។ បទថា **អត្តនា** បានដល់ មានអត្តភាព លោកអធិប្បាយថា ធ្វើអត្តភាពដែលមិនលួច ឲ្យស្អាត ។

បទថា **អព្រហ្មចរិយំ** បានដល់ ការប្រព្រឹត្តមិនប្រសើរ ។ ឈ្មោះថា

**ព្រហ្មចារី** *ព្រោះប្រព្រឹត្តធម៌ដ៏ប្រសើរ គឺអាចារដ៏ឧត្តម ។ បទថា* **អាចារី** *សេចក្តីថា ឈ្មោះថា មានអាចារអាក្រក់ ព្រោះមិនប្រព្រឹត្តធម៌ដ៏ប្រសើរ ។ បទថា* **មេថុនា** *បានដល់ អសទ្ធម្ម ដែលដល់នូវការរាប់ថា មេថុន ព្រោះសេពដោយធម៌ ដែលបានឈ្មោះថា មេថុន ព្រោះដូចគ្នានឹងកិលេសដែលជោមរោមចិត្ត គឺរាគៈ ។ បទថា* **គាមធម្មា** *បានដល់ ធម៌របស់អ្នកស្រុក ។*

*បទថា* **មុសាវាទា** *សេចក្តីថា ចាកការពោលឡេះឡោះ គឺពោលពាក្យឥតប្រយោជន៍ ។ ឈ្មោះថា* **សច្ចវាទី** *ព្រោះពោលតាមសេចក្តីពិត ។ ឈ្មោះថា* **សច្ចសន្ធា** *ព្រោះបន្តសច្ចៈដោយសច្ចៈ អធិប្បាយថា មិនពោលកុហកក្នុងចន្លោះៗ ព្រោះថា បុគ្គលណា ជួនកាលក៏ពោលកុហក ជួនកាលក៏ពោលពិត បុគ្គលនោះឈ្មោះថា មិនបន្តសច្ចៈដោយសច្ចៈឡើយ ព្រោះមានមុសាវាទមករាំង ។ ព្រោះដូច្នោះ ទើបបុគ្គលនោះមិនឈ្មោះថា មានសច្ចៈតជាប់គ្នា ។ តែបុគ្គលទាំងនេះមិនដូច្នោះឡើយ បន្តសត្យដោយពាក្យសត្យតែម្យ៉ាង ដោយមិនព្រមពោលកុហក ព្រោះហេតុនៃជីវិត ព្រោះដូច្នោះ ទើបឈ្មោះថា មានសច្ចៈតជាប់គ្នា ។ បទថា* **ថេតា** *ប្រែថា មាំទាំ អធិប្បាយថា មានពាក្យមាំទាំ បុគ្គលម្នាក់ជាអ្នកមិនមានពាក្យមាំទាំ ដូចការជ្រលក់សំពត់ដោយរមៀត ដូចបង្គោលដែលបោះលើគំនរអង្កាម និងដូចត្រឡាចដែលលើខ្នងសេះ តែបុគ្គលម្នាក់ទៀត មានពាក្យមាំទាំ ដូចស្នាមគំនូសលើផែនដី និងដូចសសរឥន្ទខីល ទោះបីយកដាវកាត់ក្បាល ក៏មិនព្រមពោលពាក្យបែកជា ២ ។ បុគ្គលនេះឈ្មោះថា* **ថេត** *គឺមានពាក្យមាំទាំ ។ បទថា*

**បច្ចយិកា** បានដល់ ទុកចិត្តបាន អធិប្បាយថា កាន់យកបាន ។ ព្រោះបុគ្គលពួកខ្លះជឿមិនបាន គឺកាលត្រូវគេសួរថា ពាក្យនេះ នរណាពោល លុះឆ្លើយថា បុគ្គលនោះពោល ក៏ដល់នូវភាពជាបុគ្គលដែលគេគប្បីពោលថា កុំជឿពាក្យរបស់វា តែបុគ្គលម្នាក់ពោលគួរជឿបាន កាលត្រូវសួរថា ពាក្យនេះអ្នកណាពោល លុះឆ្លើយថា បុគ្គលនោះពោល ក៏ដល់នូវការទទួលថា បើបុគ្គលនោះពោល សេចក្ដីនេះ ក៏កាន់យកជាប្រមាណបាន ។ ឥឡូវនេះមិនមានប្រការដែលនឹងត្រូវទាក់ទង ពាក្យនេះ យ៉ាងនេះ យ៉ាងនេះ ។ បុគ្គលនេះ ហៅថា ជាបុគ្គលដែលទុកចិត្តបាន ។ បទថា **អវិសំវាទកោ លោកស្ស** អធិប្បាយថា មិនពោលបោកបញ្ឆោតលោក ព្រោះពោលតែពាក្យពិតប៉ុណ្ណោះ ។ ហេតុនៃការប្រមាទ ពោល គឺចេតនាក្នុងការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ឈ្មោះថា **សុរាមេរយមជ្ជប្បមាទដ្ឋាន** ។

បទថា **ឯកភត្តិកា** សេចក្ដីថា អាហារមាន ២ ពេល គឺអាហារដែលត្រូវទទួលទានក្នុងវេលាព្រឹក ១ អាហារដែលត្រូវទទួលទានក្នុងពេលល្ងាច ១ បណ្ដាអាហារទាំង ២ យ៉ាងនោះ អាហារដែលទទួលទានក្នុងវេលាព្រឹក កំណត់ដោយកាលខាងក្នុងថ្ងៃត្រង់ អាហារដែលបរិភោគក្នុងពេលល្ងាច ក្រៅអំពីនេះ កំណត់ដោយពេលអំពីហួសថ្ងៃត្រង់ទៅ រហូតដល់ថ្ងៃរះ ។ ព្រោះដូច្នោះ ក្នុង វេលាខាងក្នុងថ្ងៃត្រង់ ទោះបីបរិភោគ ១០ ដង ក៏ឈ្មោះថាមានការទទួលទានអាហារមួយដងនោះឯង ។ ព្រះមានព្រះភាគត្រាស់ថា **ឯក-ភត្តិកា** សំដៅដល់ ការបរិភោគអាហារខាងក្នុងពេលថ្ងៃត្រង់ ការទទួលទាន

អាហារក្នុងពេលយប់ ឈ្មោះថា **រត្តិ** បុគ្គលវៀរចាកការទទួលទានអាហារក្នុងពេលយប់នោះ ព្រោះដូច្នោះ ទើបឈ្មោះថា **រត្តូបរតោ** ។ កាលទទួលទានអាហារហួសពីថ្ងៃត្រង់ទៅ រហូតដល់ព្រះអាទិត្យលិច ឈ្មោះថា ការទទួលទានអាហារក្នុងវេលាវិកាល បុគ្គល ឈ្មោះថា វៀរចាកវិកាលភោជន ព្រោះវៀរចាកការទទួលទានអាហារ ក្នុងវេលាវិកាលនោះ ។

ការមើលដែលឈ្មោះថា ជាសត្រូវ គឺជាសត្រូវ ព្រោះអនុលោមតាមពាក្យប្រៀនប្រដៅមិនបាន ព្រោះដូច្នោះ ទើបឈ្មោះថា **វិសូកទស្សនំ** គឺការប្រៀនរាំ ការប្រគំ ការដេញដំ កូតផ្លុំ ដោយអំណាចនៃការរាំដោយខ្លួនឯង និងដោយឲ្យអ្នកដទៃរាំជាដើម ហើយការរាំជាដើមដែលប្រព្រឹត្តទៅហើយដោយហោច សូម្បីដោយអំណាចនៃការរាំរបស់សត្វក្ងោកជាដើម ដែលជាសត្រូវ ព្រោះដូច្នោះ ទើបឈ្មោះថា **នច្ចគីត វាទិត វិសូកទស្សនំ**។ ការប្រកបដោយការរាំជាដើម ដោយខ្លួនឯងក្តី ការឲ្យអ្នកដទៃប្រកបក្តី ការមើលការរាំជាដើម ដែលបុគ្គលប្រកបហើយក្តី មិនគួរដល់ភិក្ខុ និងភិក្ខុនីឡើយ ។

ក្នុងបណ្តាមាលាជាដើម ផ្កាណាមួយ ឈ្មោះថា **មាលា** ។ គន្ធជាតិណាមួយ ឈ្មោះថា **គន្ធ**។ គ្រឿងលាប ឈ្មោះថា **វិលេបនំ**។ ក្នុងបណ្តាវត្ថុទាំងនោះ កាលប្រដាប់ ឈ្មោះថា **ធារណា**។ កាលបន្ថែមចំណែកដែលខ្វះខាត ឈ្មោះថា **តាក់តែង**។ កាលត្រេកអរដោយគ្រឿងក្រអូបក្តី ដោយគ្រឿងលាបក្តី ឈ្មោះថា **មណ្ឌនំ** ។ ការត្រេកអរដោយគ្រឿងក្រអូបក្តី ដោយគ្រឿងលាបក្តី ឈ្មោះថា **វិភូសនំ**។ ហេតុព្រះមានព្រះភាគត្រាស់ថា

**ឋាន:** អធិប្បាយថា ព្រោះដូច្នោះ មហាជនធ្វើនូវការទ្រទ្រង់នូវផ្កាជាដើមនោះដោយចេតនា គឺភាពជាអ្នកទ្រុស្តសីលឯណា ព្រះអរហន្តទាំងឡាយ ជាអ្នកវៀរចាកទុស្សីលចេតនានោះ ។

ទីអង្គុយ ទីដេក លើសប្រមាណ ហៅថា **ឧច្ចាសយន** ។ កម្រាលដែលជាអកប្បិយ: ឈ្មោះថា **មហាសយន** អធិប្បាយថា ព្រះអរហន្តទាំងឡាយ ជាអ្នកវៀរចាកទីអង្គុយ ទីដេកខ្ពស់ និងទីអង្គុយ ទីដេកធំនោះ ។ បទថា **កីវមហប្ផលោ** សេចក្តីថា មានផលច្រើនប៉ុនណា ។ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

បទថា **បហូតសត្តរតនានំ** សេចក្តីថា ប្រកបដោយរតនៈ ពោល គឺកែវច្រើន អធិប្បាយថា ពង្រាបផ្ទៃជម្ពូទ្វីបទាំងមូលឲ្យដូចផ្ទៃស្គរ ហើយចាក់រតនៈទាំង ៧ កម្ពស់ស្មើចង្កេះ ។ **ឥស្សរិយាធិបច្ចំ** សេចក្តីថា សោយរាជ-សម្បត្តិជាធំ ឬជាអធិបតី ដោយភាពជាឥស្សរៈផង ដោយភាពជាអធបិតីផង មិនមែនជាធំ ឬជាអធិបតី ដោយភាពជាព្រះរាជាដែលធូន់ព្រះហឫទ័យ ។ ឈ្មោះថា សោយឥស្សរិយាធិបតី ព្រោះមិនមានអាជ្ញាកម្មដែលខ្វាំងក្លាដូច្នេះក៏មាន ។ បទថា **រជ្ជំ ការេយ្យ** បានដល់ សោយចក្រពត្តិ-រាជសម្បត្តិបែបនេះ ។

ពាក្យថា **អង្គានំ** ជាដើម ជាឈ្មោះនៃជនបទទាំងនោះ ។ បទថា **កលំ នាគ្ឃតិ សោឡសឹ** សេចក្តីថា ចែកបុណ្យនៃការរក្សាឧបោសថអស់ថ្ងៃ និងយប់មួយជា ១៦ ចម្រៀកហើយ ចក្រពត្តិរាជសម្បត្តិ គង់មាន

តម្លៃមិនដល់មួយចម្រៀកអំពីចំណែក ១៦ នោះ អធិប្បាយថា ផលវិបាក នៃចំណែកទី ១៦ របស់ឧបោសថមួយយប់ ច្រើនជាងចក្រពត្តិរាជសម្បត្តិ របស់ស្តេចចក្រពត្តិនោះ ។ បទថា **កាមំ** បានដល់ បន្តិចបន្តួច ។ បទថា **អព្រហ្មចរិយា** បានដល់ ចាកការប្រព្រឹត្តដែលមិនប្រសើរ ។ បទថា **រត្តឹ ន ភុញ្ជេយ្យ វិកាលភោជនំ** សេចក្តីថា កាលរក្សាឧបោសថ មិនគួរបរិភោគ អាហារក្នុងពេលយប់ និងអាហារក្នុងពេលថ្ងៃ ដែលជាពេលវិកាល ។ បទ ថា **មញ្ចេ ឆមាយំ វ សយេថ សន្ថតេ** អធិប្បាយថា គួរដេកលើគ្រែ ដែលជាកប្បិយ ដែលមានជើងកម្ពស់ ១ ហត្ថក្តាប់ ឬផ្ទៃដែលគេចាក់ដោយ បាយអជាដើម ឬលើសន្ថត ដែលគេក្រាលដោយស្មៅ ស្លឹកឈើ ឬចំបើង ជាដើម ។ បទថា **ឯតញ្ហិ អដ្ឋង្គិកមាហុបោសថំ** សេចក្តីថា អ្នកប្រាជ្ញ ហៅឧបោសថដែលបុគ្គលមិនល្មើស ក្នុងបាណាតិបាតជាដើម បុគ្គលនោះ រក្សាហើយយ៉ាងនេះ ថាជាឧបោសថប្រកបដោយអង្គ ៨ ព្រោះប្រកបដោយ អង្គ ៨ ប្រការ ។

ឯបុគ្គលដែលរក្សាឧបោសថប្រកបដោយអង្គ ៨ នោះ គិតថា ស្អែក នេះ អាត្មាអញនឹងរក្សាឧបោសថ ហើយគួរត្រួតពិនិត្យការងារដែលត្រូវ ចាត់ចែង មានអាហារជាដើមថា អាត្មាអញត្រូវធ្វើយ៉ាងនេះ យ៉ាងនេះ ក្នុង ថ្ងៃនេះឯង ។ ក្នុងថ្ងៃឧបោសថ គួរបន្ទឹវាចា សមាទានអង្គឧបោសថ ក្នុង សម្នាក់របស់ភិក្ខុ ភិក្ខុនី ឧបាសក ឬឧបាសិកាដែលដឹងលក្ខណៈនៃសីល ១០ អំពីព្រលឹម ។

ចំណែកបុគ្គលមិនចេះបាលី គួរអធិដ្ឋានថា **ពុទ្ធប្បញ្ញត្តំ ឧបោសថំ**

**អធិដ្ឋាមិ** ប្រែថា ខ្ញុំសូមអធិដ្ឋានអង្គឧបោសថ ដែលព្រះពុទ្ធទ្រង់បញ្ញត្ត ហើយ ។ កាលរកបុគ្គលដទៃមិនបាន ក៏គួរអធិដ្ឋានដោយខ្លួនឯង ។ ឯការបន្ទឹវាចា គួរធ្វើដោយពិត ។

បុគ្គលរក្សាឧបោសថ មិនគប្បីពិចារណាការងារដែលទាក់ទងដោយការខ្វះខាតរបស់អ្នកដទៃ ជាអ្នកពិចារណាដល់ផល បាននូវផល មិនគួរបណ្តោយពេលវេលាឲ្យកន្លងទៅឡើយ ។ ចំណែកបុគ្គលបានអាហារក្នុងផ្ទះហើយ គួរបរិភោគដូចភិក្ខុដែលបានអាហារប្រចាំ ហើយផ្គោះទៅវិហារស្តាប់ធម៌ ឬមនសិការអារម្មណ៍កម្មដ្ឋាន ៣៨ ប្រការណាមួយ ។

បទថា **សុទស្សនា** បានដល់ យើញបានច្បាស់ល្អ ។ បទថា **ឱភាសយំ** បានដល់ ពន្លឺ ។ បទថា **អនុបរិយន្តិ** ប្រែថា គោចរទៅ ។ បទថា **យាវតា** បានដល់ ចុះកាន់ទីប្រមាណប៉ុនណា ។ បទថា **អន្តលិក្ខគា** បានដល់ អណ្តែតទៅកាន់អាកាស ។ បទថា **បភាសន្តិ** ប្រែថា ពន្លឺ គឺបញ្ចេញរស្មី ។ បទថា **ទិសា វិរោចនា** បានដល់ បញ្ចេញពន្លឺទៅក្នុងទិសទាំងពួង ។ ន័យម្យ៉ាងទៀត បទថា **បភាសន្តិ** ប្រែថា ភ្លឺស្វាងទៅគ្រប់ទិស ។ បទថា **វិរោចនា** ស្មើគ្នានឹង **វិរោចមានា** ប្រែថា ពន្លឺ ។

បទថា **វេឡុរិយំ** សេចក្តីថា ព្រះមានព្រះភាគទោះត្រាស់បទថា **មណី** ហើយ ក៏ទ្រង់សម្តែងដល់ភាពជាកែវមណីដោយកំណើតដោយបទថា **វេឡុរិយំ** នេះ ។ ដ្បិតថា កែវពៃទូរ្យដែលមានពណ៌ដូចឫស្សី ដែលកើតបានមួយឆ្នាំឈ្មោះថា កែវមណីដោយកំណើត ។ ព្រះមានព្រះភាគត្រាស់យ៉ាងនេះ ទ្រង់

សំដៅដល់កែវមណីដោយកំណើតនោះ ។ បទថា **ភទ្ទកំ** ស្មើគ្នានឹង **លទ្ធកំ** ប្រែថា ល្អាត ។ បទថា **សិង្គីសុវណ្ណំ** បានដល់ មាសដែលដុះឡើង មានសណ្ឋានដូចស្នែងគោ ។ បទថា **កាកញ្ចនំ** បានដល់ មាសដែលកើតអំពីភ្នំ គឺមាសដែលកើតលើកំពូលភ្នំ ។ បទថា **ជាតរូបំ** បានដល់ មាសដែលមានពណ៌ដូចព្រះឆវីវណ្ណរបស់ព្រះសាស្តា ។ បទថា **ហដកំ** បានដល់ មាសដែលស្រមោចពាំមក ។ បទថា **នានុភវន្តិ** ប្រែថា មិនទាន់ដល់ ។ បទថា **ចន្ទប្បភា** ជាបឋមាវិភត្តិ ចុះក្នុងអត្ថនៃឆដ្ឋីវិភត្តិ អធិប្បាយថា មិនដល់ចំណែកទី ១៦ នៃពន្លឺព្រះចន្ទ ។ បទថា **ឧបវស្សុពោសថំ** បានដល់ រក្សាឧបោសថ ។ បទថា **សុខុន្ទ្រយានិ** បានដល់ មានសុខជាផល គឺសោយសេចក្តីសុខ ។ បទថា **សគ្គមុបេន្តិ ឋានំ** បានដល់ ចូលដល់ឋានៈ ពោលគឺស្ថានសួគ៌ អធិប្បាយថា មិនមានបុគ្គលណាតិះដៀល រមែងកើតក្នុងទេវលោក ។ ពាក្យដ៏សេស ដែលមិនបានពោលក្នុងចន្លោះៗ ក្នុងព្រះសូត្រនេះ គប្បីជ្រាបដោយទំនងដែលពោលហើយនោះឯង ។ ០ ។

## អដ្ឋកថាឧបោសថសូត្រទី ១០ ចប់

## មហាវគ្គទី ២ ចប់

# សុត្តន្តបិដក
# អានិសង្សវគ្គទី ៣

## ឆន្នសូត្រទី ១

[ ៧៣ ] *សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ឆន្នបរិព្វាជក ចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ពោលរាក់ទាក់ជាមួយនឹងព្រះអានន្ទដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររាក់ទាក់ និងពាក្យគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះឆន្នបរិព្វាជកអង្គុយក្នុងទីសមគួរហើយ ក៏និយាយនឹងព្រះអានន្ទដ៏មានអាយុដូច្នេះថា នែអាវុសោអានន្ទ លោកបញ្ញត្តការលះបង់រាគៈ បញ្ញត្តការលះបង់ទោសៈ បញ្ញត្តការលះបង់មោហៈ ។ ម្នាលអាវុសោ យើងសោត ក៏បញ្ញត្តការលះបង់រាគៈ បញ្ញត្តការលះបង់ទោសៈ បញ្ញត្តការលះបង់មោហៈដែរ ។ ម្នាលអាវុសោ តែថា លោកឃើញទោសក្នុងរាគៈដូចម្តេច បានជាបញ្ញត្តការលះបង់រាគៈ ឃើញទោសក្នុងទោសៈដូចម្តេច បានជាបញ្ញត្តការលះបង់ទោសៈ ឃើញទោសក្នុងមោហៈដូចម្តេច បានជាបញ្ញត្តការលះបង់មោហៈ ។ ម្នាលអាវុសោ បុគ្គលអ្នកត្រេកត្រអាល ត្រូវរាគៈគ្របសង្កត់ មានចិត្តត្រូវរាគៈរួបរឹត រមែងគិតដើម្បីបៀតបៀនខ្លួនឯងខ្លះ គិតដើម្បីបៀតបៀនអ្នកដទៃខ្លះ គិតដើម្បីបៀតបៀនទាំងពីរខាងខ្លះ រមែងទទួលទុក្ខ ទោមនស្ស ប្រព្រឹត្តទៅក្នុងចិត្តខ្លះ កាលលះបង់រាគៈបានហើយ*

បុគ្គលរមែងមិនគិតដើម្បីបៀតបៀនខ្លួនឯង មិនគិតដើម្បីបៀតបៀនអ្នកដទៃ មិនគិតដើម្បីបៀតបៀនទាំងពីរខាង មិនទទួលទុក្ខ ទោមនស្ស ប្រព្រឹត្តទៅក្នុងចិត្ត ។ ម្នាលអាវុសោ បុគ្គលអ្នកត្រេកត្រអាល ត្រូវរាគៈគ្របសង្កត់ មានចិត្តត្រូវរាគៈរួបរឹត រមែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត កាលបើលះរាគៈបានហើយ បុគ្គលរមែងមិនប្រព្រឹត្តទុច្ចរិតដោយកាយ មិនប្រព្រឹត្តទុច្ចរិតដោយវាចា មិនប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ ម្នាលអាវុសោ បុគ្គលអ្នកត្រេកត្រអាល ត្រូវរាគៈគ្របសង្កត់ មានចិត្តត្រូវរាគៈរួបរឹត រមែងមិនដឹងច្បាស់នូវប្រយោជន៍ របស់ខ្លួនតាមពិតខ្លះ មិនដឹងច្បាស់នូវប្រយោជន៍ របស់បុគ្គលដទៃតាមពិតខ្លះ មិនដឹងច្បាស់នូវប្រយោជន៍ទាំងពីរខាងតាមពិតខ្លះ កាលបើលះបង់រាគៈបានហើយ បុគ្គលរមែងដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនតាមពិតផង ដឹងច្បាស់នូវប្រយោជន៍បុគ្គលដទៃតាមពិតផង ដឹងច្បាស់នូវប្រយោជន៍ទាំងពីរខាងតាមពិតផង ។ ម្នាលអាវុសោ រាគៈជាគ្រឿងធ្វើឲ្យងងឹត ធ្វើឲ្យដូចជាគ្មានចក្ខុ ធ្វើឲ្យគ្មានញាណ ឲ្យរលត់បញ្ញា ជាប៉ែកខាងសេចក្តីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វានទេ ។ ម្នាលអាវុសោ បុគ្គលអ្នកប្រទូស្ត ។បេ។ ម្នាលអាវុសោ បុគ្គលអ្នកវង្វេង ត្រូវសេចក្តីវង្វេងគ្របសង្កត់ មានចិត្តត្រូវសេចក្តីវង្វេងរួបរឹត រមែងគិតដើម្បីបៀតបៀនខ្លួនខ្លះ គិតដើម្បីបៀតបៀនអ្នកដទៃខ្លះ គិតដើម្បីបៀតបៀនទាំងពីរខាងខ្លះ តែងទទួលទុក្ខ ទោមនស្ស ប្រព្រឹត្តទៅក្នុងចិត្តខ្លះ កាលបើលះមោហៈបានហើយ បុគ្គលរមែងមិនគិតដើម្បីបៀតបៀនខ្លួន មិន

គិតដើម្បីបៀតបៀនអ្នកដទៃ មិនគិតដើម្បីបៀតបៀនទាំងពីរខាង មិនទទួលទុក្ខទោមនស្សប្រព្រឹត្តទៅក្នុងចិត្ត ។ ម្នាលអាវុសោ បុគ្គលអ្នកវង្វេង ត្រូវមោហៈគ្របសង្កត់ មានចិត្តត្រូវមោហៈរួបរឹត រមែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត កាលបើលះបង់មោហៈបានហើយ បុគ្គលរមែងមិនប្រព្រឹត្តទុច្ចរិតដោយកាយ មិនប្រព្រឹត្តទុច្ចរិតដោយវាចា មិនប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ ម្នាលអាវុសោ បុគ្គលអ្នកវង្វេង ត្រូវមោហៈគ្របសង្កត់ មានចិត្តត្រូវមោហៈរួបរឹត រមែងមិនដឹងច្បាស់នូវប្រយោជន៍ខ្លួនតាមពិតខ្លះ មិនដឹងច្បាស់នូវប្រយោជន៍អ្នកដទៃតាមពិតខ្លះ មិនដឹងច្បាស់នូវប្រយោជន៍ទាំងពីរខាងតាមពិតខ្លះ កាលបើលះមោហៈបានហើយ បុគ្គលរមែងដឹងច្បាស់នូវប្រយោជន៍ខ្លួនតាមពិតផង ដឹងច្បាស់នូវប្រយោជន៍អ្នកដទៃតាមពិតផង ដឹងច្បាស់នូវប្រយោជន៍ទាំងពីរខាងតាមពិតផង ។ ម្នាលអាវុសោ មោហៈជាគ្រឿងធ្វើឲ្យងងឹត ធ្វើឲ្យដូចជាគ្មានចក្ខុ ធ្វើឲ្យគ្មានញាណ ឲ្យរលត់បញ្ញា ជាប៉ែកខាងសេចក្តីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វានទេ ។ ម្នាលអាវុសោ យើងឃើញទោសក្នុងរាគៈនេះឯងហើយ ទើបបញ្ញត្តនូវការលះបង់រាគៈ ឃើញទោសក្នុងទោសៈនេះហើយ ទើបបញ្ញត្តនូវការលះទោសៈ ឃើញទោសក្នុងមោហៈនេះហើយ ទើបបញ្ញត្តនូវការលះមោហៈ ។ ម្នាលអាវុសោ ចុះផ្លូវប្រតិបត្តិដើម្បីលះរាគៈ ទោសៈ មោហៈនុ៎ះ មានដែរឬទេ ។ ម្នាលអាវុសោ ផ្លូវប្រតិបត្តិដើម្បីលះរាគៈ ទោសៈ មោហៈនុ៎ះមាន ។ ម្នាលអាវុសោ ចុះផ្លូវប្រតិបត្តិដើម្បីលះរាគៈ ទោសៈ

មោហៈនុ៎ះ តើដូចម្ដេច ។ ផ្លូវប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង គឺ សេចក្ដីឃើញត្រូវ ១ សេចក្ដីត្រិះរិះត្រូវ ១ វាចាត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ ការព្យាយាមត្រូវ ១ ការរឭកត្រូវ ១ ការតម្កល់ចិត្តមាំត្រូវ ១ ។ ម្នាលអាវុសោ នេះឯងជាផ្លូវប្រតិបត្តិដើម្បីលះរាគៈ ទោសៈ មោហៈនុ៎ះ ។ ម្នាលអាវុសោ ផ្លូវប្រតិបត្តិដើម្បីលះរាគៈ ទោសៈ មោហៈនុ៎ះ ជាផ្លូវប្រសើរល្អហើយ ។ ម្នាលអាវុសោអានន្ទ ហេតុនុ៎ះគួរ តែកុំធ្វេសប្រហែសឡើយ ។

# អដ្ឋកថា

# អានន្ទវគ្គទី ៣

## អដ្ឋកថា ឆន្នសូត្រ

[ ៧៣ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងឆន្នសូត្រទី ១ នៃវគ្គទី ៣ ដូច្នេះ បទថា* **ឆន្នោ** *បានដល់ បរិព្វាជកដែលមានសំពត់បិទបាំងរាងកាយ មានឈ្មោះយ៉ាងនេះ ។ បទថា* **តុម្ហេបិ អាវុសោ** *សេចក្តីថា ឆន្នបរិព្វាជក សួរថា នៃអាវុសោ ពួកយើងបញ្ញត្តការលះកិលេស មានរាគៈជាដើមយ៉ាងណា សូម្បីលោកទាំងឡាយ ក៏បញ្ញត្តយ៉ាងនោះឬ ។ លំដាប់នោះ ព្រះថេរៈគិតថា បរិព្វាជកនេះពោលនឹងពួកយើងថា យើងទាំងឡាយបញ្ញត្តការលះរាគៈជាដើម តែការបញ្ញត្តិការលះរាគៈជាដើមនេះ មិនមានក្នុងលទ្ធិខាងក្រៅ ដូច្នេះ ទើបពោលពាក្យថា* **មយំ ខោ អាវុសោ** *ដូច្នេះជាដើម ។ សព្ទថា* **ខោ** *ក្នុងពាក្យថា* **មយំ ខោ អាវុសោ** *នោះ ត្រឹមតែជានិបាត ប្រើក្នុងអត្ថថា ហាម អធិប្បាយថា ពួកយើងប៉ុណ្ណោះបញ្ញត្ត ។ លំដាប់នោះ បរិព្វាជកគិតថា ព្រះថេរៈនេះ កាលកាត់លទ្ធិខាងក្រៅចេញទៅ ទើបពោលថា ពួកយើងប៉ុណ្ណោះ សមណៈទាំងនេះឃើញទោសអ្វីហ្ន៎ ទើបញ្ញត្តការលះរាគៈជាដើមទាំងនេះ ។ គ្រានោះ ឆន្នបរិព្វាជក កាលនឹងសាកសួរព្រះថេរៈ ទើបពោលពាក្យជាដើមថា* **កឹ បន តុម្ហេ** *ដូច្នេះ ។*

*ព្រះថេរៈកាលព្យាករដល់បុគ្គលនោះ ទើបពោលពាក្យជាដើមថា* **រត្តោ**

ខោ **អាវុសោ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **អត្តត្ថំ** សេចក្តីថា ប្រយោជន៍របស់ខ្លួនក្នុងបច្ចុប្បន្ន និងសម្បរាយភព ទាំងដែលជាលោកិយ និងលោកុត្តរ ។ ក្នុងប្រយោជន៍របស់អ្នកដទៃ និងប្រយោជន៍ទាំង ២ ក៏មានន័យនេះដូចគ្នា ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អន្ធករណោ** ជាដើម រាគៈ ឈ្មោះថា **អន្ធករណោ** ព្រោះធ្វើបុគ្គលដែលមានរាគៈកើតឡើងឲ្យខ្វាក់ ដោយឃាត់ការដឹង ការឃើញតាមសេចក្តីពិត ។ ឈ្មោះថា **អចក្ខុករណោ** ព្រោះមិនធ្វើឲ្យកើតបញ្ញាចក្ខុ ។ ឈ្មោះថា **អញ្ញាណករណោ** ព្រោះមិនធ្វើឲ្យកើតញាណ ។ ឈ្មោះថា **បញ្ញានិរោធិកោ** ព្រោះបញ្ញាទាំង ៣ យ៉ាងនេះ គឺកម្មស្សកតប្បញ្ញា ឈានប្បញ្ញា និងវិបស្សនាបញ្ញារលត់ទៅ ដោយមិនធ្វើឲ្យប្រព្រឹត្តទៅ ។ ឈ្មោះថា **វិឃាតបក្ខិកោ** ព្រោះប្រព្រឹត្តទៅក្នុងចំណែកនៃការក្តៅក្រហាយ ពោល គឺទុក្ខ ព្រោះឲ្យផលមិនគួរប្រាថ្នាប៉ុណ្ណោះ ។ ឈ្មោះថា **អនិព្វានសំវត្តនិកោ** ព្រោះមិនញុាំងការរម្ងត់កិលេស ឲ្យប្រព្រឹត្តទៅ ។ បទថា **អលំ ច បនាវុសោ អានន្ទ អប្បមាទាយ** សេចក្តីថា ឆន្នបរិព្វាជកអនុមោទនាដោយពាក្យរបស់ព្រះថេរៈថា បពិត្រព្រះអានន្ទដ៏មានអាយុ បើបដិបទាបែបនេះមានសោត ក៏គប្បីគ្រប់គ្រាន់ សមគួរដើម្បីអ្នកទាំងឡាយមិនប្រមាទ អ្នកទាំងឡាយចូរបំពេញការមិនប្រមាទចុះ ដូច្នេះហើយ ចៀសចេញទៅ ។ ក្នុងព្រះសូត្រនេះ ព្រះអានន្ទត្ថេរពោលដល់អរិយមគ្គដែលលាយដោយលោកុត្តរ ។ ពាក្យដ៏សេស ក្នុងព្រះសូត្រនេះ មានអត្ថងាយយល់ទាំងអស់ហើយ ដូច្នេះ ។ ។

# សុត្តន្តបិដក

## អាជីវកសូត្រទី ២

[ ៧៤ ] សម័យមួយ ព្រះអានន្ទដ៏មានអាយុ គង់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ គ្រានោះ គហបតិជាសាវករបស់អាជីវកម្នាក់ចូលទៅរក ព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះ គហបតិជាសាវកអាជីវកនោះ អង្គុយក្នុងទីសមគួរហើយ សួរព្រះអានន្ទដ៏មាន អាយុដូច្នេះថា បពិត្រអានន្ទដ៏ចម្រើន(យើងទាំងពីរនាក់) អ្នកណាសម្តែងធម៌ ត្រូវ ពួកអ្នកណាឈ្មោះថា ប្រតិបត្តិត្រូវក្នុងលោក ពួកអ្នកណា ឈ្មោះថា ដើរត្រូវក្នុងលោក ។ ម្នាលគហបតី បើដូច្នោះ អាត្មានឹងត្រឡប់សួរទៅអ្នក ក្នុងហេតុនុ៎ះវិញ បើហេតុនោះគួរដល់អ្នកយ៉ាងណា ត្រូវអ្នកដោះស្រាយហេតុ នោះ យ៉ាងនោះចុះ ។ ម្នាលគហបតី អ្នកសម្គាល់ហេតុនោះដូចម្តេច ពួក បុគ្គលណា សម្តែងធម៌ដើម្បីលះរាគៈ សម្តែងធម៌ដើម្បីលះទោសៈ សម្តែង ធម៌ដើម្បីលះមោហៈ អ្នកទាំងនោះ ឈ្មោះថា សម្តែងធម៌ត្រូវឬទេ ឬថា អ្នក មានសេចក្តីយល់ដូចម្តេច ក្នុងដំណើរនោះ ។ បពិត្រអានន្ទដ៏ចម្រើន ពួក បុគ្គលណា សម្តែងធម៌ដើម្បីលះរាគៈ សម្តែងធម៌ដើម្បីលះទោសៈ សម្តែងធម៌ ដើម្បីលះមោហៈ បុគ្គលទាំងនោះ ឈ្មោះថា សម្តែងធម៌ត្រូវហើយ ខ្ញុំមាន សេចក្តីយល់ក្នុងដំណើរនុ៎ះ យ៉ាងនេះដែរ ។ ម្នាលគហបតី អ្នកសម្គាល់ហេតុ នោះដូចម្តេច ពួកបុគ្គលណា ប្រតិបត្តិដើម្បីលះរាគៈ ប្រតិបត្តិដើម្បីលះ ទោសៈ ប្រតិបត្តិដើម្បីលះមោហៈ ពួកបុគ្គលនោះឈ្មោះថា ប្រតិបត្តិត្រូវក្នុង

លោកឬទេ ឬថា អ្នកមានសេចក្តីយល់ក្នុងដំណើរនុ៎ះ ដូចម្តេច ។ បពិត្រអានន្ទដ៏ចម្រើន ពួកបុគ្គលណា ប្រតិបត្តិដើម្បីលះរាគៈ ប្រតិបត្តិដើម្បីលះទោសៈ ប្រតិបត្តិដើម្បីលះមោហៈ ពួកបុគ្គលនោះ ឈ្មោះថា ប្រតិបត្តិត្រូវក្នុងលោក ខ្ញុំមានសេចក្តីយល់យ៉ាងនេះ ក្នុងដំណើរនុ៎ះ ។ ម្នាលគហបតីអ្នកសម្គាល់ហេតុនោះដូចម្តេច ពួកបុគ្គលណាបានលះរាគៈហើយ បានរម្លើងឫសគល់ចោលហើយ ធ្វើមិនឲ្យដុះទៀតបាន ដូចជាត្នោតកំបុតក ធ្វើឲ្យវិនាស មិនឲ្យកើតឡើងតទៅទៀតជាធម្មតា ពួកបុគ្គលណាលះទោសៈហើយ ។បេ។ ពួកបុគ្គលណាលះមោហៈហើយ បានរម្លើងឫសគល់ចោលហើយ ធ្វើមិនឲ្យដុះទៀតបាន ដូចជាត្នោតកំបុតក ធ្វើឲ្យវិនាស មិនឲ្យកើតឡើងតទៅទៀតជាធម្មតា ពួកបុគ្គលនោះ ឈ្មោះថា ដើរត្រូវហើយក្នុងលោកឬទេ ឬក៏អ្នកមានសេចក្តីយល់ដូចម្តេច ក្នុងដំណើរនុ៎ះ ។ បពិត្រលោកដ៏ចម្រើន ពួកបុគ្គលណាលះរាគៈហើយ បានរម្លើងឫសគល់ចោលហើយ ធ្វើមិនឲ្យដុះទៀតបាន ដូចជាត្នោតកំបុតក ធ្វើឲ្យវិនាស មិនឲ្យកើតឡើងតទៅទៀតជាធម្មតា ពួកបុគ្គលណាលះទោសៈហើយ ។បេ។ ពួកបុគ្គលណា លះមោហៈហើយ បានរម្លើងឫសគល់ចោលហើយ ធ្វើមិនឲ្យដុះទៀតបាន ដូចជាត្នោតកំបុតក ធ្វើឲ្យវិនាស មិនឲ្យកើតឡើងតទៅទៀតជាធម្មតា ពួកបុគ្គលនោះឈ្មោះថា ដើរត្រូវក្នុងលោកហើយ ខ្ញុំមានសេចក្តីយល់យ៉ាងនេះ ក្នុងដំណើរនោះ ។ ម្នាលគហបតី អ្នកបានដោះស្រាយហើយយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ពួកបុគ្គលណា សម្តែងធម៌ដើម្បីលះរាគៈ សម្តែងធម៌ដើម្បីលះ

ទោសៈ សម្តែងធម៌ដើម្បីលះមោហៈ បុគ្គលនោះ ឈ្មោះថា សម្តែងត្រូវហើយ ។ អ្នកបានដោះស្រាយហើយ យ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ពួកបុគ្គលណាបានប្រតិបត្តិដើម្បីលះរាគៈ ប្រតិបត្តិដើម្បីលះទោសៈ ប្រតិបត្តិដើម្បីលះមោហៈ បុគ្គលទាំងនោះ ឈ្មោះថា ប្រតិបត្តិត្រូវក្នុងលោក ។ អ្នកបានដោះស្រាយហើយយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ពួកបុគ្គលណាបានលះរាគៈហើយ បានរម្លើងឫសគល់ចោលហើយ ធ្វើមិនឲ្យដុះទៀតបាន ដូចជាត្នោតកំបុតក ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតតទៅទៀតជាធម្មតា ពួកបុគ្គលណា បានលះទោសៈហើយ ។បេ។ ពួកបុគ្គលណា បានលះមោហៈហើយ បានរម្លើងឫសគល់ចោលហើយ ធ្វើមិនឲ្យដុះទៀតបាន ដូចជាត្នោតកំបុតក ធ្វើឲ្យវិនាស មិនឲ្យកើតតទៅទៀតជាធម្មតា ពួកបុគ្គលនោះ ឈ្មោះថា ដើរត្រូវក្នុងលោក ។ បពិត្រលោកដ៏ចម្រើន អស្ចារ្យណាស់ បពិត្រលោកដ៏ចម្រើន ចម្លែកណាស់ ឈ្មោះថា មិនមានការលើកតម្កើងតែធម៌ខ្លួនផង មិនមានការបន្ទះបន្ទាប់ធម៌បុគ្គលដទៃផង សម្តែងធម៌ត្រង់តាមតែហេតុ និយាយចំពោះតែសេចក្តី ទាំងមិនទាញមករកតែប៉ែកខាងខ្លួនផង ។ បពិត្រអានន្ទដ៏ចម្រើន លោក ( ហ្នឹងហើយ ) សម្តែងធម៌ដើម្បីលះរាគៈ សម្តែងធម៌ដើម្បីលះទោសៈ សម្តែងធម៌ដើម្បីលះមោហៈ លោកសម្តែងធម៌ត្រូវហើយ បពិត្រអានន្ទដ៏ចម្រើន លោកប្រតិបត្តិដើម្បីលះរាគៈ ប្រតិបត្តិដើម្បីលះទោសៈ ប្រតិបត្តិដើម្បីលះមោហៈ ប្រតិបត្តិត្រូវហើយក្នុងលោក បពិត្រអានន្ទដ៏ចម្រើន លោកបានលះរាគៈហើយ បានរម្លើងឫសគល់ចោលហើយ

ធ្វើមិនឲ្យដុះទៀតបាន ដូចជាត្នោតកំបុតក ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតតទៅទៀតជាធម្មតា លោកបានលះទោសៈហើយ ។បេ។ លោកបានលះមោហៈហើយ បានរម្លើងឫសគល់ចោលហើយ ធ្វើមិនដុះទៀតបាន ដូចជាត្នោតកំបុតក ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតតទៅទៀតជាធម្មតា លោកឈ្មោះថាដើរត្រូវក្នុងលោក ។ បពិត្រលោកដ៏ចម្រើន ពីរោះណាស់ បពិត្រលោកដ៏ចម្រើន ពីរោះណាស់ ។ បពិត្រលោកដ៏ចម្រើន ដូចគេផ្ងាររបស់ដែលផ្កាប់ ឬបើកបង្ហាញរបស់ដែលកំបាំង ពុំនោះ ដូចគេប្រាប់ផ្លូវដល់មនុស្សអ្នកវង្វេង ពុំនោះសោត ដូចគេទ្រោលប្រទីបប្រេងក្នុងទីងងឹត ដោយគិតថា មនុស្សអ្នកមានភ្នែក រមែងមើលឃើញរូបទាំងឡាយ យ៉ាងណាមិញ ធម៌ដែលលោកម្ចាស់អានន្ទបានសម្តែងហើយ ដោយអនេកបរិយាយយ៉ាងនេះ ក៏យ៉ាងនោះដែរ ។ បពិត្រអានន្ទដ៏ចម្រើន ខ្ញុំនោះ ដល់នូវព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីរឭក សូមលោកម្ចាស់អានន្ទ ចាំទុកនូវខ្ញុំព្រះករុណា ជាឧបាសកអ្នកដល់នូវសរណៈ ស្មើដោយជីវិត ចាប់ដើមពីថ្ងៃនេះតទៅ ។

# អដ្ឋកថា

## អាជីវកសូត្រ

[ ៧៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអាជីវកសូត្រទី ២ ដូចតទៅនេះ បទថា **តេនហិ គហបតិ** សេចក្តីថា បានឮថា ព្រះថេរៈគិតថា អាជីវកនេះ កាលមកក្នុងទីនេះ ក៏មិនបានបំណងនឹងមកដើម្បីចង់ដឹង តែមកដើម្បីពិសោធ អញនឹងឆ្លើយបញ្ហាដែលព្រាហ្មណ៍នេះសួរហើយ ដោយការសាកសួរនេះឯង ព្រះថេរៈបំណងនឹងឲ្យព្រាហ្មណ៍នោះឆ្លើយបញ្ហានោះខ្លួនឯង ដោយឧបាយនេះ ទើបពោលពាក្យជាដើមថា **តេនហិ** ដូច្នេះ ។

ក្នុងពាក្យថា **តេនហិ** ជាដើមនោះ សព្ទថា **តេនហិ** ជាការអាងដល់ហេតុ ។ អធិប្បាយថា ព្រោះហេតុដែលអ្នកសួរយ៉ាងនេះ ទើបខ្ញុំសូមសាកសួរអ្នកក្នុងសេចក្តីនេះ ។ បទថា **កេសន្នោ** សេចក្តីថា ដល់បុគ្គលណាហ្ន៎ ។ បទថា **សធម្មុក្កំសនា** សេចក្តីថា លើកលទ្ធិរបស់ខ្លួនតាំងឡើង ។ បទថា **បរធម្មាបសាទនា** សេចក្តីថា មិនទ្រគោះបោះបោក សង្កត់ ចាក់ដោតក្នុងលទ្ធិរបស់អ្នកដទៃ ។ បទថា **អាយតនេវ ធម្មទេសនា** សេចក្តីថា សម្តែងធម៌មានហេតុ ។ បទថា **អត្ថោ ច វុត្តោ** សេចក្តីថា នឹងចង្អុលបង្ហាញអត្ថនៃបញ្ហាដែលខ្ញុំសួរហើយ ។ បទថា **អត្តា ច អនុបនីតោ** សេចក្តីថា មិនអួតអាងខ្លួនយ៉ាងនេះថា ពួកយើងយ៉ាងនេះ បាឋៈថា **នុបនីតោ** ដូច្នេះក៏មាន ៕

អដ្ឋកថា អាជីវកសូត្រទី ២ ចប់

# សុត្តន្តបិដក

## មហានាមសក្កសូត្រទី ៣

[ ៧៥ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ជិតក្រុងកបិលពស្តុ ក្នុងដែនសក្កៈ ។ សម័យនោះឯង ព្រះដ៏មានព្រះភាគទ្រង់ស្បើយអំពីជំងឺ ទើបតែនឹងស្បើយអំពីជំងឺ មិនទាន់យូរប៉ុន្មាន ។ គ្រានោះ មហានាមសក្កៈ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់ក្នុងទីសមគួរ ។ លុះមហានាមសក្កៈ គង់ក្នុងទីសមគួរហើយ ក៏ក្រាបថ្វាយបង្គំទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គដឹងច្បាស់នូវធម៌ ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងអស់កាលជាយូរហើយ យ៉ាងនេះថា ញាណមានដល់បុគ្គលដែលមានចិត្តតម្កល់ខ្ជាប់ មិនមានដល់បុគ្គលដែលមានចិត្តមិនតម្កល់ខ្ជាប់ទេ ។ បពិត្រព្រះអង្គដ៏ចម្រើន សមាធិកើតមុន ញាណកើតក្រោយ ឬក៏ញាណកើតមុន សមាធិកើតក្រោយ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុមានសេចក្តីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគទ្រង់ស្បើយអំពីជំងឺ ទើបតែនឹងស្បើយអំពីជំងឺ មិនទាន់យូរប៉ុន្មាន ស្រាប់តែមហានាមសក្កៈនេះ សួរប្រស្នាដ៏ជ្រៅក្រៃពេក ចំពោះព្រះដ៏មានព្រះភាគ បើដូច្នោះ គួរតែអាត្មាអញនាំមហានាមសក្កៈ ទៅក្នុងទីសមគួរ ហើយសម្តែងធម៌ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ ក៏ចាប់ព្រះពាហានៃមហានាមសក្កៈ នាំទៅក្នុងទីសមគួរ ហើយនិយាយនឹងមហានាមសក្កៈដូច្នេះថា បពិត្រព្រះមហានាម សេក្ខសីល

ក៏ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយ អសេក្ខសីល ក៏ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយ សេក្ខសមាធិ ក៏ព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ អសេក្ខសមាធិ ក៏ព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ សេក្ខប្បញ្ញា ក៏ព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ អសេក្ខប្បញ្ញា ក៏ព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយដែរ ។ បពិត្រមហានាម ចុះសេក្ខសីល តើដូចម្តេច ។ បពិត្រមហានាម ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។បេ។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ បពិត្រមហានាម នេះហៅថា សេក្ខសីល ។ បពិត្រមហានាម ចុះសេក្ខសមាធិ តើដូចម្តេច ។ បពិត្រមហានាម ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់ចតុត្ថជ្ឈាន សម្រេចសម្រាន្តនៅ ។ បពិត្រមហានាម នេះហៅថា សេក្ខសមាធិ ។ បពិត្រមហានាម ចុះសេក្ខប្បញ្ញា តើដូចម្តេច ។ បពិត្រមហានាម ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ។បេ។ ដឹងច្បាស់តាមពិតថា នេះជាបដិបទាដំណើរទៅកាន់ទីរម្ងត់ទុក្ខ ។ បពិត្រមហានាម នេះហៅថា សេក្ខប្បញ្ញា ។ បពិត្រមហានាម អរិយសាវកនោះ អ្នកបរិបូណ៌ដោយសីលយ៉ាងនេះ បរិបូណ៌ដោយសមាធិយ៉ាងនេះ បរិបូណ៌ដោយបញ្ញាយ៉ាងនេះ រមែងធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ក្រៃលែងដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។ បពិត្រមហានាម សេក្ខសីល ក៏ព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ អសេក្ខសីល ក៏ព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ សេក្ខសមាធិ ក៏ព្រះដ៏មានព្រះភាគ

ទ្រង់សម្តែងហើយ អសេក្ខសមាធិ ក៏ព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ សេក្ខប្បញ្ញា ក៏ព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ អសេក្ខប្បញ្ញា ក៏ព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ យ៉ាងនេះឯង ។

# អដ្ឋកថា

## មហានាមសក្កសូត្រ

[ ៧៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសក្កសូត្រទី ៣ ដូចតទៅនេះ បទថា **គិលានា វុដ្ឋិតោ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ជាអំពីជំងឺ ។ បទថា **គេលញ្ញា** សេចក្តីថា ទើបតែនឹងជាអំពីជំងឺ ។ បទថា **ឧបសង្កមិ** សេចក្តីថា ព្រះបាទមហានាមសក្យៈ ទ្រង់សោយព្រះក្រយាហារពេលព្រឹកហើយ ទ្រង់កាន់យកកម្រងផ្កា និងគ្រឿងក្រអូបជាដើម មានបរិវារជាច្រើនចោមរោមហើយចូលទៅគាល់ព្រះមានព្រះភាគ ។

ដោយបទថា **ពាហាយំ គហេត្វា** គប្បីជ្រាបសេចក្តីថា ព្រះអានន្ទមិនបានចាប់ព្រះពាហារបស់ព្រះបាទមហានាមទាញមក តែក្រោកឡើងអំពីអាសនៈដែលអង្គុយ ហើយតម្រង់ទៅរកទ្រង់ ប្រើម្រាមដៃប៉ះត្រង់ពាហាខាងស្តាំ ហើយនាំចេញទៅក្នុងចំណែកម្ខាង ព្រះអានន្ទត្រេកាលប្រាប់សីលសមាធិ និងបញ្ញា ដែលជារបស់ព្រះសេក្ខៈទាំង ៧ ពួក ដោយន័យជាដើម

ថា នែមហានាម ព្រះមានព្រះភាគត្រាស់សីល ដែលជាសេក្ខៈក៏មាន ដូច្នេះ ហើយកាលនឹងប្រាប់សីល សមាធិ បញ្ញា របស់អសេក្ខៈ ដោយអំណាចអរហត្តផលជាទីបំផុត ទើបសម្តែងថា វិបស្សនាញាណដែលជាសេក្ខៈ និងផលញាណ ដែលជាអសេក្ខៈ កើតឡើងខាងក្រោយសមាធិដែលជាសេក្ខៈ និងផលសមាធិដែលជាអសេក្ខៈ កើតឡើងខាងក្រោយវិបស្សនាដែលជាសេក្ខៈ ដូច្នេះ ឯសមាធិដែលជាសម្បយុត្តធម៌ គប្បីជ្រាបថា កើតឡើងមិនមុន មិនក្រោយ ។ល។

**អដ្ឋកថាមហានាមសក្កសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## និគណ្ឋនាដសូត្រទី ៤

[ ៧៦ ] សម័យមួយ ព្រះអានន្ទដ៏មានអាយុគង់នៅក្នុងកូដាគារសាលា នាព្រៃមហាវន ជិតក្រុងវេសាលី ។ គ្រានោះ ស្តេចលិច្ឆវិនាមអភ័យ និងស្តេចលិច្ឆវិនាមបណ្ឌិតកុមារកៈ ចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះអានន្ទដ៏មានអាយុ ហើយគង់ក្នុងទីសមគួរ ។ លុះស្តេចលិច្ឆវិនាមអភ័យអង្គុយក្នុងទីសមគួរហើយ ក៏សួរព្រះអានន្ទដ៏មានអាយុ ដូច្នេះថា បពិត្រអានន្ទដ៏ចម្រើន និគណ្ឋនាដបុត្រជាសព្វញ្ញូ

ឃើញសព្វ តែងប្តេជ្ញានូវញាណទស្សនៈ ( សព្វញ្ញុតញ្ញាណ ) មិនមានសេសសល់ថា អាត្មាអញទោះដើរក្តី ឈរក្តី ដេកលក់ក្តី ភ្ញាក់ឡើងក្តី ញាណទស្សនៈតាំងឡើង ឥតចន្លោះរាល់ពេល ។ និគណ្ឋនាដបុត្រនោះតែងបញ្ញត្តនូវកិច្ច ធ្វើឲ្យអស់ទៅនៃកម្មចាស់ទាំងឡាយ ដោយតបធម៌ បញ្ញត្តនូវការសម្លាប់បច្ច័យ ព្រោះមិនធ្វើកម្មថ្មីទាំងឡាយ ការអស់ទុក្ខ ព្រោះអស់កម្ម ការអស់វេទនា ព្រោះអស់ទុក្ខ ទុក្ខទាំងពួងនឹងសាបរលាបទៅព្រោះអស់វេទនា ដោយប្រការដូច្នេះឯង ការកន្លងនូវ ( វដ្តទុក្ខ ) ដោយវិសុទ្ធិដែលត្រូវឃើញចំពោះខ្លួន ជាគ្រឿងធ្វើឲ្យកិលេសសាបរលាបទុំះយ៉ាងនេះ ។ បពិត្រអានន្ទដ៏ចម្រើន ចុះព្រះដ៏មានព្រះភាគ ទ្រង់សម្តែងដូចម្តេច ក្នុងសាសនានេះ ។ ម្នាលអភ័យ និជ្ជរាវិសុទ្ធិ ( វិសុទ្ធិជាគ្រឿងធ្វើកិលេសឲ្យសាបរលាប ) ទាំង ៣ នេះ ដែលព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសម្តែងហើយដោយប្រពៃ ដើម្បីសេចក្តីស្អាតនៃសត្វទាំងឡាយ ដើម្បីកន្លងនូវសោកនិងខ្សឹកខ្សួលទាំងឡាយ ដើម្បីរលត់ទៅនៃទុក្ខ និងទោមនស្សទាំងឡាយ ដើម្បីត្រាស់ដឹងនូវមគ្គ ដែលប្រកបដោយវិបស្សនា ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ និជ្ជរាវិសុទ្ធិទាំង ៣ តើដូចម្តេច ។ ម្នាលអភ័យ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។បេ។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ភិក្ខុនោះមិនធ្វើកម្មថ្មីផង បានពាល់ត្រូវរឿយៗ នូវកម្មចាស់ហើយ ធ្វើឲ្យអស់ទៅផង ព្រោះវិសុទ្ធិជាធម្មជាតដែលបុគ្គលគប្បីឃើញដោយខ្លួនឯង ជាគ្រឿងធ្វើ

កិលេសឲ្យសាបរលាប ឲ្យនូវផលមិនរង់ចាំកាល គួរដើម្បីបង្ហាញឲ្យចូលមកមើលបាន គួរបង្អោនចូលមកទុកក្នុងខ្លួនបាន ជាធម្មជាតដែលអ្នកប្រាជ្ញទាំងឡាយ គប្បីដឹងច្បាស់ចំពោះខ្លួន ។ ម្នាលអភ័យ ភិក្ខុនោះបរិបូរណ៍ដោយសីលយ៉ាងនេះ ក៏ស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់ចតុត្ថជ្ឈានសម្រេចសម្រាន្តនៅ ។ ភិក្ខុនោះមិនធ្វើកម្មថ្មីផង ពាល់ត្រូវរឿយៗ នូវកម្មចាស់ហើយ ធ្វើឲ្យអស់ទៅផង ព្រោះវិសុទ្ធិជាធម្មជាតដែលបុគ្គលគប្បីឃើញដោយខ្លួនឯង ជាគ្រឿងធ្វើកិលេសឲ្យសាបរលាប ឲ្យនូវផលមិនរង់ចាំកាល គួរដើម្បីបង្ហាញឲ្យចូលមកមើលបាន គួរបង្អោនចូលមកទុកក្នុងខ្លួនបាន ជាធម្មជាតដែលអ្នកប្រាជ្ញទាំងឡាយ គប្បីដឹងច្បាស់ចំពោះខ្លួន ។ ម្នាលអភ័យ ភិក្ខុនោះ បរិបូរណ៍ដោយសីលយ៉ាងនេះ បរិបូរណ៍ដោយសមាធិយ៉ាងនេះ រមែងធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ក្រៃលែង ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។ ភិក្ខុនោះ មិនធ្វើកម្មថ្មីផង ពាល់ត្រូវរឿយៗ នូវកម្មចាស់ហើយ ធ្វើឲ្យអស់ទៅផង ព្រោះវិសុទ្ធិជាធម្មជាតដែលបុគ្គលគប្បីឃើញដោយខ្លួនឯង ជាគ្រឿងធ្វើកិលេសឲ្យសាបរលាប ឲ្យនូវផលមិនរង់ចាំកាល គួរដើម្បីបង្ហាញឲ្យចូលមកមើលបាន គួរបង្អោនចូលមកទុកក្នុងខ្លួនបាន ជាធម្មជាតដែលអ្នកប្រាជ្ញទាំងឡាយ គប្បីដឹងច្បាស់ចំពោះខ្លួន ។ ម្នាលអភ័យ នេះឯងនិជ្ជរវិសុទ្ធិទាំង ៣ ដែលព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសម្តែងហើយដោយប្រពៃ ដើម្បីសេចក្តី

ស្មារតីរបស់សត្វទាំងឡាយ ដើម្បីកន្លងនូវសោក និងខ្សឹកខ្សួលទាំងឡាយ ដើម្បីរលត់ទុក្ខ និងទោមនស្សទាំងឡាយ ដើម្បីត្រាស់ដឹងនូវមគ្គប្រកបដោយវិបស្សនា ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ កាលបើព្រះអានន្ទដ៏មានអាយុ សម្ដែងយ៉ាងនេះហើយ ស្ដេចលិច្ឆវិនាមបណ្ឌិតកុមារកៈ ក៏និយាយនឹងស្ដេចលិច្ឆវិនាមអភ័យដូច្នេះថា នែអភ័យជាសម្លាញ់ ចុះហេតុអ្វី បានជាអ្នកមិនអនុមោទនាសុភាសិតរបស់ព្រះអានន្ទដ៏មានអាយុ ដោយសុភាសិត ។ នែសម្លាញ់ ថ្វីក៏ខ្ញុំមិនអនុមោទនាសុភាសិតរបស់ព្រះអានន្ទដ៏មានអាយុដោយសុភាសិត ។ អ្នកណាមិនអនុមោទនានូវសុភាសិតរបស់ព្រះអានន្ទដ៏មានអាយុដោយសុភាសិតទេ ក្បាលរបស់អ្នកនោះ មុខជាធ្លាក់ចុះមិនខាន ។

# អដ្ឋកថា

## និគណ្ឋនាដសូត្រ

[ ៧៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិគណ្ឋសូត្រទី ៤ ដូចតទៅនេះ បទថា **កូដាគារសាលាយំ** បានដល់ ព្រះគន្ធកុដិដែលគេដាក់ជហ្វា ២ មានដំបូលដូចហង្សពែនពង្ស ។ បទថា **អបរិសេសំ ញាណទស្សនំ បដិជានាតិ** សេចក្ដីថា ដឹងច្បាស់នូវញាណទស្សនៈគ្រប់យ៉ាង សូម្បីត្រឹមតែតិចតួច ។ បទថា **សតតំ សមិតំ** សេចក្ដីថា អស់កាលគ្រប់កាល គឺជានិច្ចនិរន្តរ ។

បទថា **ញាណទស្សនំ បច្ចុប្បដ្ឋិតំ** នេះ និគណ្ឋនាដបុត្រសម្តែងថា សព្វញ្ញុតញ្ញាណ ប្រាកដហើយដល់ខ្ញុំ ។ បទថា **បុរាណានំ កម្មានំ** បាន ដល់ កម្មដែលប្រមូលមក ។ បទថា **តបសា ព្យន្តីភាវំ** បានដល់ ធ្វើឲ្យ កិលេសអស់ទៅ ដោយតបៈដែលធ្វើបានដោយលំបាក ។ បទថា **នវានំ កម្មានំ** បានដល់ កម្មដែលគប្បីប្រមូលមកក្នុងបច្ចុប្បន្ន ។ បទថា **អករណា** សេចក្តីថា ព្រោះមិនប្រមូលមក ។ ដោយបទថា **សេតុឃាតំ** និគណ្ឋ-នាដបុត្រពោលដល់ការកាត់ផ្លូវដើរ គឺទម្លាយបច្ច័យ ។ បទថា **កម្មក្ខយា ទុក្ខក្ខយោ** បានដល់ ការអស់វដ្តទុក្ខ ព្រោះកម្មវដ្តៈអស់ទៅ ។ បទថា **ទុក្ខក្ខយា វេទនាក្ខយោ** បានដល់ ការអស់វេទនា ព្រោះវដ្តទុក្ខអស់ទៅ អធិប្បាយថា កាលវដ្តទុក្ខអស់ទៅ សូម្បីការវិលនៃវេទនា ក៏ឈ្មោះថា អស់ទៅហើយដូចគ្នា ។ បទថា **វេទនាក្ខយា សព្វំ ទុក្ខំ និជ្ជិណ្ណំ ភវិស្សតិ** សេចក្តីថា វដ្តទុក្ខទាំងមូល នឹងវិនាសទៅដោយមិនសេសសល់ ព្រោះវេទនាអស់ទៅ ។ បទថា **សន្ទិដ្ឋិកាយ** សេចក្តីថា ដែលគប្បីឃើញឯង គឺឃើញប្រចក្ស ។ បទថា **និជ្ជរាយ វិសុទ្ធិយា** សេចក្តីថា ឈ្មោះថា **និជ្ជរាយ** ព្រោះជាបដិបទានៃការវិនាសទៅរបស់កិលេស ឬព្រោះកិលេសទាំងឡាយវិនាសទៅ ដោយឥតមានសល់ ឈ្មោះថា បរិសុទ្ធ ព្រោះញុំាងសត្វទាំង-ឡាយឲ្យដល់នូវសេចក្តីបរិសុទ្ធ ព្រោះដូច្នោះ ទើបឈ្មោះថា **និជ្ជរាវិសុទ្ធិ** ។ បទថា **សមតិក្កមោ ហោតិ** សេចក្តីថា ស្ងប់រម្ងាប់នូវវដ្តទុក្ខទាំងមូលនឹងមាន ។ បទថា **ឥធ ភន្តេ ភគវា កិមាហ** សេចក្តីថា និគណ្ឋនាដបុត្រសួរ

ថា បពិត្រព្រះអង្គដ៏ចម្រើន សម្រាប់បដិបទានេះ ព្រះមានព្រះភាគត្រាស់ដូចម្តេច គឺទ្រង់បញ្ញត្តបដិបទា នៃការអស់ទៅនៃកិលេសនេះដូចម្តេច ឬបញ្ញត្តតាមបែបដទៃ ។

បទថា **ជានតា** សេចក្តីថា ដឹងដោយអាណាវរណញ្ញាណ ។ បទថា **បស្សតា** សេចក្តីថា ឃើញដោយសមន្តចក្ខុ ។ បទថា **វិសុទ្ធិយា** សេចក្តីថា ដើម្បីឲ្យដល់នូវភាពបរិសុទ្ធ ។ បទថា **សមតិក្កមាយ** សេចក្តីថា ដើម្បីឲ្យដល់នូវការរួចផុត ។ បទថា **អដ្ឋង្គមាយ** សេចក្តីថា ដើម្បីឲ្យដល់នូវការអស្តង្គត ។ បទថា **ញាយស្ស អធិគមាយ** សេចក្តីថា ដើម្បីជាប្រយោជន៍ដល់ការសម្រេចមគ្គ មួយអន្លើដោយវិបស្សនា ។ បទថា **និព្វានស្ស សច្ឆិកិរិយាយ** សេចក្តីថា ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានដែលមិនមានបច្ច័យ ។ បទថា **នវញ្ច កម្មំ ន ករោតិ** សេចក្តីថា មិនប្រមូលកម្មថ្មីមក ។ បទថា **បុរាណញ្ច កម្មំ** បានដល់ កម្មដែលប្រមូលមកហើយក្នុងកាលមុន ។ បទថា **ផុស្ស ផុស្ស ព្យន្តីករោតិ** សេចក្តីថា ជួបនូវកម្មចាស់ហើយ ក៏ធ្វើឲ្យអស់ទៅ អធិប្បាយថា ប៉ះនូវផស្សៈដែលជាវិបាកហើយធ្វើកម្មនោះឲ្យអស់ទៅ ។ បទថា **សន្ទិដ្ឋិកា** សេចក្តីថា ដែលបុគ្គលគប្បីឃើញឯង ។ បទថា **អកាលិកា** សេចក្តីថា មិនធ្វើកិច្ចក្នុងកាលដទៃ ។ បទថា **ឯហិបស្សិកា** សេចក្តីថា គួរចង្អុលឲ្យឃើញយ៉ាងនេះថា អ្នកចូរមើលចុះ ។ បទថា **ឱបនយិកា** សេចក្តីថា គួរក្នុងការបង្អោនចូលមក គឺសមគួរដល់ធម៌ ដែលខ្លួនគួរជាប់ជំពាក់ ។ បទថា **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ**

សេចក្តីថា ដែលបណ្ឌិតទាំងឡាយគប្បីដឹងបាន ក្នុងសន្តានរបស់ខ្លួននោះឯង តែពាលជនទាំងឡាយដឹងបានលំបាក ដូច្នោះ មគ្គ ២ ផល ២ ព្រះមានព្រះភាគត្រាស់ហើយ ដោយអំណាចនៃសីល ព្រោះថា ព្រះសោតាបន្ន និងព្រះសកទាគាមីជាអ្នកធ្វើឲ្យបរិបូរណ៍ក្នុងសីល ។ ចំណែកមគ្គ ៣ ផល ៣ ត្រាស់ហើយដោយសមាធិសម្បត្តិជាដើមថា **វិវិច្ចេវ កាមេហិ** ព្រោះស្ងាត់ហើយចាកកាមទាំងឡាយនោះឯង ព្រោះអរិយសាវកថ្នាក់អនាគាមិបុគ្គល ព្រះមានព្រះភាគត្រាស់ថា ជាអ្នកធ្វើឲ្យបរិបូរណ៍ក្នុងសមាធិ ។

ដោយពាក្យជាដើមថា **អាសវានំ ខយា** ទ្រង់ត្រាស់សំដៅដល់អរហត្តផល ។ សីល និងសមាធិប្រភេទខ្លះ ដែលសម្បយុត្តដោយអរហត្តផល ទ្រង់បំណងយកហើយក្នុងព្រះសូត្រនេះ តែកាលទ្រង់សម្តែងដល់បដិបទាដោយអំណាចនៃសីល និងសមាធិតែមួយប្រភេទ ទើបទ្រង់សម្តែងបែបផែនជាផ្នែកៗ ដូច្នេះឯង ៕

## អដ្ឋកថា និគណ្ឋនាដសូត្រទី ៤ ចប់

# សុត្តន្តបិដក

## សមាទបកសូត្រទី ៨

[ ៧៧ ] គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរដូច្នេះថា ម្នាលអានន្ទ អ្នកទាំងឡាយគប្បីអនុគ្រោះអ្នកណា ឬថា ពួកជនណាដែលជាមិត្រក្តី អាមាត្យក្តី ញាតិក្តី សាលោហិតក្តី គប្បីសម្គាល់នូវពាក្យដែលត្រូវស្តាប់ ម្នាលអានន្ទ ជនទាំងនោះ អ្នកទាំងឡាយ គួរណែនាំ គួរឲ្យនៅ គួរឲ្យតាំងនៅក្នុងឋានៈ ៣ យ៉ាង ។ ឋានៈ ៣ យ៉ាងនេះ តើដូចម្តេច ។ គឺគួរណែនាំ គួរឲ្យនៅ គួរឲ្យតាំងនៅក្នុងសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ បរិបូរណ៍ដោយវិជ្ជា និងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវត្រៃលោក ប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ជាសារថីទូន្មាននូវបុរស ជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ច ៤ ទ្រង់ខ្ជាក់ចោលនូវត្រៃភព លែងវិលត្រឡប់មកកើតទៀត ១ គួរណែនាំ គួរឲ្យនៅ គួរឲ្យតាំងនៅក្នុងសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះធម៌ថា ធម៌ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយដោយប្រពៃ ជាធម៌ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ឲ្យនូវផលមិនរង់ចាំកាល គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន គួរបង្អោនចូលមកទុកក្នុងខ្លួន អ្នកប្រាជ្ញ

ទាំងឡាយគប្បីដឹងច្បាស់ចំពោះខ្លួន ១ គួរណែនាំ គួរឲ្យនៅ គួរឲ្យតាំងនៅ ក្នុងសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះសង្ឃថា ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិដោយប្រពៃ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិដោយត្រង់ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិគួរដល់សាមីចិកម្ម ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគនុ៎ះ រាប់ជាគូនៃបុរសមាន ៤ គូ បើរាប់រៀងជាបុរសបុគ្គលមាន ៨ ពួក លោកគួរទទួលនូវរបស់ដែលគេរៀបទទួលភ្ញៀវ គួរទទួលនូវរបស់ដែលគេនាំមកបូជា គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តរបស់សត្វលោកដ៏ប្រសើរបំផុត ។ ម្នាលអានន្ទ សេចក្តីប្រែប្រួល មានចំពោះតែមហាភូតរូប ៤ គឺបឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ ឯសេចក្តីប្រែប្រួលរបស់អរិយសាវក ដែលប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះពុទ្ធ មិនមានសោះឡើយ ។ នេះជាសេចក្តីប្រែប្រួលក្នុងហេតុនោះ ។ ម្នាលអានន្ទ ពាក្យថា អរិយសាវកនោះ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះពុទ្ធ ហើយ មុខជានឹងទៅកើតក្នុងនរកក្តី កំណើតតិរច្ឆានក្តី ប្រេតវិស័យក្តី ដូច្នេះ នុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអានន្ទ សេចក្តីប្រែប្រួល មានចំពោះតែមហាភូតរូប ៤ គឺបឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ ឯសេចក្តីប្រែប្រួល ។បេ។ ក្នុងព្រះធម៌ មិនគប្បីមានឡើយ សេចក្តីប្រែប្រួលមិនមានដល់អរិយសាវក ដែលប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះសង្ឃ

សោះទេ ។ នេះជាសេចក្ដីប្រែប្រួលក្នុងហេតុនោះ ។ ម្នាលអានន្ទ ពាក្យថា អរិយសាវកដែលប្រកបដោយ សេចក្ដីជ្រះថ្លា មិនកម្រើកក្នុងព្រះសង្ឃនោះ មុខជានឹងទៅកើតក្នុងនរកក្ដី កំណើតតិរច្ឆានក្ដី ប្រេតវិស័យក្ដី ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអានន្ទ អ្នកទាំងឡាយ គប្បីអនុគ្រោះអ្នកណា ឬថា អ្នកណាជាមិត្រក្ដី អាមាត្យក្ដី ញាតិក្ដី សាលោហិតក្ដី គប្បីសម្គាល់នូវពាក្យដែលត្រូវស្ដាប់ ម្នាលអានន្ទ ជនទាំងនោះ អ្នកទាំងឡាយ គួរណែនាំ គួរឲ្យនៅ គួរឲ្យតាំងនៅក្នុងឋានៈ ៣ យ៉ាងនេះ ។

# អដ្ឋកថា

## សមាទបកសូត្រ

[ ៧៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសមាទបកសូត្រទី ៥ ដូចតទៅនេះ បទថា **អមច្ចា** បានដល់ អមាត្យដែលមានចិត្តល្អ ។ បទថា **ញាតិ** បានដល់ ញាតិខាងជីដូនជីតា ។ បទថា **សាលោហិតា** បានដល់ ដែលរួមខ្សែលោហិត មានបងប្រុស ប្អូនប្រុស បងស្រី ប្អូនស្រីជាដើម ។ បទថា **អវេច្ចប្បសាទេ** សេចក្ដីថា មានការជ្រះថ្លាដែលមិនញាប់ញ័រ ដែលកើតឡើង ដោយឈមចុះដល់គុណទាំងឡាយ ។

បទថា **អញ្ញថត្តំ** បានដល់ ភាពដទៃចាកសេចក្ដីពិត គប្បីជ្រាបវិនិច្ឆ័យ

ក្នុងបទថា **បឋវីធាតុយា** ជាដើមដូចតទៅនេះ បឋវីធាតុដែលជាធាតុមានអាការរឹង ក្នុងកោដ្ឋាស ២០ យ៉ាង អាបោធាតុដែលជាទឹក ជាធាតុប្រមូលផ្តុំក្នុងកោដ្ឋាស ១២ យ៉ាង តេជោធាតុ ដែលជាធាតុដុតពោលក្នុងកោដ្ឋាស ៤ យ៉ាង វាយោធាតុ ជាធាតុកម្រើកក្នុងកោដ្ឋាស ៦ យ៉ាង ទាំងអស់នេះ គប្បីមានភាពប្រែប្រួលទៅ ។

ដោយបទថា **ឯ ត្វេវ** ព្រះអានន្ទសម្តែងថា ពិតហើយ មហាភូតរូបទាំង ៤ នេះ គប្បីមានភាពជទៃទៅបាន ព្រោះដល់នូវភាពជាអញ្ញមញ្ញ-ប្បច្ច័យ តែសម្រាប់ព្រះអរិយសាវក មិនមានភាពជទៃទៅបានទេ ។

ក្នុងព្រះសូត្រនេះ បទថា **អញ្ញថត្តំ** បានដល់ ភាពជទៃដោយការជ្រះថ្លា និងភាពជទៃដោយគតិ ព្រោះថា ទាំង ២ យ៉ាងនោះ មិនមានដល់អរិយសាវក មានតែភាពជទៃដោយសភាវៈ អធិប្បាយថា ព្រះអរិយសាវកដែលជាមនុស្សកើតជាទេវតាក៏មាន កើតជាព្រហ្មក៏មាន តែការជ្រះថ្លារបស់ព្រះអរិយសាវកនោះ មិនកាត់ផ្តាច់ គឺមិនប្រែប្រួលក្នុងអន្តរភពផង មិនដល់នូវភាពជទៃដោយគតិ ពោល គឺអបាយគតិផង សូម្បីព្រះបរមសាស្តា កាលទ្រង់សម្តែងសេចក្តីនោះឯង ទើបត្រាស់ពាក្យជាដើមថា **តត្រិទំ អញ្ញថត្តំ** ដូច្នេះ ។ ពាក្យដ៏សេស ក្នុងព្រះសូត្រនេះ ងាយយល់ទាំងអស់ហើយ ។

**អដ្ឋកថា សមាទបកសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ភវសូត្រទី ៦

[ ៧៨ ] គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគទ្រង់សម្តែងថា ភព ភព ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថា ភពតើដោយហេតុដូចម្តេច ។ ម្នាលអានន្ទ បើកម្មដែលឲ្យផល ( សម្រេច ) ក្នុងកាមធាតុមិនមានហើយ កាមភពគប្បីមានប្រាកដដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុថា កម្មជាស្រែ វិញ្ញាណជាពូជ តណ្ហាជាទឹក វិញ្ញាណរបស់ពួកសត្វ ដែលមានអវិជ្ជាជាទំនប់ មានតណ្ហាជាគ្រឿងព័ន្ធព័ទ្ធ តម្កល់នៅស៊ប់ហើយក្នុងធាតុដ៏ថោកទាប គឺកាមធាតុ ការកើតចំពោះក្នុងភពថ្មីតទៅទៀត រមែងមានយ៉ាងនេះ ។ ម្នាលអានន្ទ បើកម្មដែលឲ្យផលក្នុងរូបធាតុមិនមានហើយ រូបភពគប្បីមានប្រាកដដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុថា កម្មជាស្រែ វិញ្ញាណជាពូជ តណ្ហាជាទឹក អភិសង្ខារវិញ្ញាណរបស់ពួកសត្វ ដែលមានអវិជ្ជាជាទំនប់ មានតណ្ហាជាគ្រឿងព័ន្ធព័ទ្ធ រមែងតម្កល់នៅស៊ប់ក្នុងធាតុជាន់កណ្តាល គឺរូបធាតុ ការកើតចំពោះក្នុងភពថ្មីតទៅទៀត រមែងមានយ៉ាងនេះ ។ ម្នាលអានន្ទ បើកម្មដែលឲ្យផលក្នុងអរូបធាតុ មិនមាន

ហើយ អរូបភពគប្បីមានប្រាកដដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុថា កម្មជាស្រែ វិញ្ញាណជាពូជ តណ្ហាជាទឹក ទើបអភិសង្ខារវិញ្ញាណរបស់ពួកសត្វ ដែលមានអវិជ្ជាជាទំនប់ មានតណ្ហាជាគ្រឿងព័ន្ធព័ទ្ធ រមែងតម្កល់នៅក្នុងធាតុជាន់ខ្ពស់ គឺអរូបធាតុ ការកើតចំពោះក្នុងភពថ្មីតទៅទៀត រមែងមានយ៉ាងនេះ ។ ម្នាលអានន្ទ ភពរមែងមានយ៉ាងនេះឯង ។

# អដ្ឋកថា

## នវសូត្រ

[ ៧៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនវសូត្រទី ៦ ដូចតទៅនេះ បទថា **កាមធាតុវេបក្កំ** បានដល់ កម្មដែលឲ្យផលចាកកាមធាតុ ។ បទថា **កាមភវោ** បានដល់ ឧប្បត្តិភពក្នុងកាមធាតុ ។ បទថា **កម្មំ ខេត្តំ** សេចក្តីថា កុសលកម្ម និងអកុសលកម្ម ឈ្មោះថា ជាស្រែ ព្រោះអត្ថថា ជាទីដុះឡើងនៃវិបាកក្ខន្ធ ។ បទថា **វិញ្ញាណំ ពីជំ** សេចក្តីថា វិញ្ញាណដែលមានអភិសង្ខារជាបច្ច័យ ដែលកើតព្រមគ្នា ឈ្មោះថា ពូជ ព្រោះអត្ថថា ជាហេតុដុះឡើង ។ បទថា **តណ្ហា ស្នេហោ** សេចក្តីថា តណ្ហា ឈ្មោះថា ទឹក ព្រោះដោយអំណាចនៃការសង្គ្រោះ និងចម្រើនឡើង ។

បទថា **អវិជ្ជា នីវរណានំ** សេចក្តីថា ដែលអវិជ្ជាពាំងហើយ ។ បទថា **តណ្ហាសញ្ញោជនានំ** សេចក្តីថា បុគ្គលដែលត្រូវចំណង គឺតណ្ហារួបរឹត ។ បទថា **ហីនាយ ធាតុយា** បានដល់ ក្នុងកាមធាតុ ។ បទថា **វិញ្ញាណំ បតិដ្ឋិតំ** សេចក្តីថា វិញ្ញាណដែលមានអភិសង្ខារជាបច្ច័យតាំងមាំហើយ ។ បទថា **មជ្ឈិមាយ ធាតុយា** បានដល់ ក្នុងរូបធាតុ ។ បទថា **បណីតាយ ធាតុយា** បានដល់ ក្នុងអរូបធាតុ ។ ពាក្យដ៏សេស ក្នុងសូត្រនេះ ងាយយល់ទាំងអស់ហើយ ដូច្នេះ ។ល។

**អដ្ឋកថា នវសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## ភវសូត្រទី ៧

[ ៧៩ ] គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ភព ភព ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន

ដែលហៅថា ភព តើដោយហេតុដូចម្ដេច ។ ម្នាលអានន្ទ បើកម្មដែលឲ្យផលក្នុងកាមធាតុ មិនមានហើយ កាមភពគប្បីមានប្រាកដដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុថា កម្មជាស្រែ វិញ្ញាណជាពូជ តណ្ហាជាទឹក ចេតនា និងសេចក្ដីប្រាថ្នារបស់ពួកសត្វដែលមានអវិជ្ជាជាទំនប់ មានតណ្ហាជាគ្រឿងព័ន្ធព័ទ្ធ រមែងតម្កល់នៅស៊ប់ក្នុងធាតុដ៏ថោកទាប គឺកាមធាតុ ការកើតចំពោះក្នុងភពថ្មីតទៅទៀត រមែងមានយ៉ាងនេះ ។ ម្នាលអានន្ទ បើកម្មដែលឲ្យផលក្នុងរូបធាតុ មិនមានហើយ រូបភពគប្បីមានប្រាកដដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុថា កម្មជាស្រែ វិញ្ញាណជាពូជ តណ្ហាជាទឹក ចេតនា និងសេចក្ដីប្រាថ្នារបស់ពួកសត្វ ដែលមានអវិជ្ជាជាទំនប់ មានតណ្ហាជាគ្រឿងព័ន្ធព័ទ្ធ រមែងតម្កល់នៅស៊ប់ក្នុងធាតុជាន់កណ្ដាល គឺរូបធាតុ ការកើតចំពោះក្នុងភពថ្មីតទៅទៀត រមែងមានយ៉ាងនេះ ។ ម្នាលអានន្ទ បើកម្មដែលឲ្យផលក្នុងអរូបធាតុ មិនមានហើយ អរូបភពគប្បីមានប្រាកដដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុថា កម្មជាស្រែ វិញ្ញាណជាពូជ តណ្ហាជាទឹក ចេតនា និងសេចក្ដីប្រាថ្នារបស់ពួកសត្វ ដែលមានអវិជ្ជាជាទំនប់ មានតណ្ហាជាគ្រឿងព័ន្ធព័ទ្ធ រមែងតម្កល់នៅស៊ប់ក្នុងធាតុជាន់ខ្ពស់ គឺអរូបធាតុ ការកើតចំពោះក្នុងភពថ្មីតទៅទៀត រមែងមានយ៉ាងនេះ ម្នាលអានន្ទ ភព រមែងមានយ៉ាងនេះឯង ។

# អដ្ឋកថា

## ភវសូត្រ

[ ៧៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងភវសូត្រទី ៧ ដូចតទៅនេះ ចេតនាជាហេតុធ្វើកម្ម ឈ្មោះថា **ចេតនា** ។ ការប្រាថ្នាដែលនឹងធ្វើកម្ម ឈ្មោះថា **បត្ថនា**។ ពាក្យដ៏សេស មានអត្ថដូចនឹងសូត្រមុនទាំងអស់នោះឯង ។ល។

**អដ្ឋកថាភវសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## សីលព្វតសូត្រទី ៨

[ ៨០ ] គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរដូច្នេះថា ម្នាលអានន្ទ សីល និងវត្ត ជីវិតព្រហ្មចារ្យ និងការបម្រើ ដោយយល់ថា មានខ្លឹមទាំងអស់ សុទ្ធតែមានផលឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងសេចក្ដីនុ៎ះមិនគួរព្យាករដោយចំណែកតែម្យ៉ាងទេ ។ ម្នាលអានន្ទ បើដូច្នោះ ចូរអ្នកចែកសេចក្ដីទៅមើល ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលសេពនូវសីលវត្ត ជីវិត ព្រហ្មចារ្យ និងការបម្រើ

ដោយយល់ថា មានទ្វីមណា អកុសលធម៌ទាំងឡាយចម្រើនឡើង កុសលធម៌ទាំងឡាយវិនាសទៅ សីលវត្ត ជីវិត ព្រហ្មចារ្យ និងការបម្រើ ដោយយល់ថា មានទ្វីម មានសភាពយ៉ាងនេះ ឈ្មោះថា ឥតផលទេ ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលសេពនូវសីលវត្ត ជីវិត ព្រហ្មចារ្យ និងការបម្រើ ដោយយល់ថា មានទ្វីមណា អកុសលធម៌ទាំងឡាយវិនាសទៅ កុសលធម៌ទាំងឡាយចម្រើនឡើង សីលវត្ត ជីវិត ព្រហ្មចារ្យ និងការបម្រើ ដោយយល់ថា មានទ្វីម មានសភាពយ៉ាងនេះ ទើបឈ្មោះថា មានផល ។ លុះព្រះអានន្ទដ៏មានអាយុ ក្រាបទូលពាក្យនេះហើយ ព្រះសាស្តាក៏ទ្រង់គាប់ព្រះហឫទ័យ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុដឹងថា ព្រះសាស្តារបស់អាត្មាអញ គាប់ព្រះហឫទ័យហើយ ក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ រួចហើយ ចេញទៅ ។ កាលដែលព្រះអានន្ទដ៏មានអាយុចេញទៅ មិនយូរប៉ុន្មាន ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អានន្ទជាសេក្ខបុគ្គល ប៉ុន្តែ បុគ្គលដែលត្រឹមស្មើដោយបញ្ញារបស់អានន្ទនុ៎ះ មិនងាយនឹងរកបានទេ ។

# អដ្ឋកថា

## សីលព្វតសូត្រ

[ ៨០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសីលព្វតសូត្រទី ៨ ដូចតទៅនេះ បទថា **សីលព្វតំ** បានដល់ សីល និងវត្ត ។ បទថា **ជីវិតំ** បានដល់ សេចក្ដីព្យាយាមរបស់បុគ្គលធ្វើកម្ម ដែលធ្វើបានដោយលំបាក ។ បទថា **ព្រហ្ម-ចរិយំ** បានដល់ ការនៅប្រព្រឹត្តព្រហ្មចរិយៈ ។ បទថា **ឧបដ្ឋានសារំ** សេចក្ដីថា សីលជាដើមនេះ ឈ្មោះថា ជាសារៈ ព្រោះធម៌ជាគ្រឿងប្រាកដ អធិប្បាយថា ប្រាកដយ៉ាងនេះថា សីលជាដើមនេះ ជាខ្លឹមសារ សីលជាដើមនេះ ជារបស់ប្រសើរ សីលជាដើមនេះ ជាហេតុឲ្យសម្រេច ។ ព្រះមានព្រះភាគត្រាស់សួរថា សីលជាដើមនេះ ជារបស់មានអានិសង្ស គឺមានសេចក្ដីចម្រើន ដោយបទថា **សផលំ** ដូច្នេះ ។ បទថា **ន ខ្វេត្ថ ភន្តេ ឯកំសេន** សេចក្ដីថា ព្រះអានន្ទឆ្លើយថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងសេចក្ដីនេះ មិនគួរព្យាករដោយចំណែកមួយឡើយ ។ បទថា **ឧបដ្ឋានសារំ សេវតោ** សេចក្ដីថា កាលសេពសីលជាដើម ដែលជាសារៈ គឺជាគ្រឿងប្រាកដយ៉ាងនេះថា សីលជាដើមនេះ ជាសារៈ ជាវត្ថុប្រសើរ ជាហេតុឲ្យសម្រេច ។

បទថា **អផលំ** សេចក្ដីថា មិនមានផល ដោយផលដែលត្រូវការ ។ ដោយចម្លើយមានប្រមាណប៉ុណ្ណេះ ឈ្មោះថា កាន់យកលទ្ធិខាងក្រៅដ៏សេសទាំងអស់ វៀរការបួសរបស់កម្មវាទីបុគ្គល និងកិរិយវាទីបុគ្គល ។ បទថា

**សផលំ** បានដល់ មានផល គឺមានអានិសង្ស ដោយផលដែលត្រូវបំណាំង ដោយចម្លើយ មានប្រមាណប៉ុណ្ណោះ ឈ្មោះថា កាន់យកបព្វជ្ជារបស់កម្មវាទីបុគ្គល និងកិរិយវាទីបុគ្គលទាំងអស់ តាំងអំពីដើមពុទ្ធសាសនានេះ ។ ដោយបទថា **ន ច បនស្ស សុលភរូបោ សមសមោ បញ្ញាយ** នេះ ព្រះមានព្រះភាគត្រង់សម្តែងថា ដែលតាំងនៅក្នុងសេក្ខភូមិ ឆ្លើយបញ្ហាបាន យ៉ាងនេះ ដែលស្មើដោយបញ្ញានៃអានន្ទនោះ មិនមែនរកបានងាយឡើយ ។ ធម៌ ឈ្មោះថា សេក្ខភូមិ ព្រះមានព្រះភាគត្រាស់ហើយ ក្នុងព្រះសូត្រនេះ ៕

**អដ្ឋកថា សីលព្វតសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## គន្ធសូត្រទី ៩

[ ៨១ ] គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្លិននៃគន្ធជាត ដែលផ្សាយទៅកាន់ទីបណ្តោយខ្យល់បាន ទៅច្រាសខ្យល់មិនបាន នេះមាន ៣ យ៉ាង ។ គន្ធជាត ៣ យ៉ាង តើដូចម្តេច ។ គឺក្លិនឫស ១

ក្លិនខ្លឹម ១ ក្លិនផ្កា ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្លិនគន្ធជាតទាំង ៣ នេះឯង ផ្សាយទៅបានតែទីបណ្តោយខ្យល់ ទៅច្រាសខ្យល់មិនបានទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្រែងមានក្លិនគន្ធជាតអ្វី ដែលផ្សាយទៅបណ្តោយខ្យល់ក៏បាន ផ្សាយទៅច្រាសខ្យល់ក៏បាន ផ្សាយទៅទាំងបណ្តោយខ្យល់ និងច្រាសខ្យល់ក៏បាន មានដែរឬទេ ។ ម្នាលអានន្ទ ក្លិនគន្ធជាតដែលផ្សាយទៅបណ្តោយខ្យល់ក៏បាន ទៅច្រាសខ្យល់ក៏បាន ទៅបណ្តោយខ្យល់ និងច្រាសខ្យល់ក៏បាន មានដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះគន្ធជាតដែលផ្សាយទៅបណ្តោយខ្យល់ក៏បាន ច្រាសខ្យល់ក៏បាន ទាំងបណ្តោយខ្យល់ និងច្រាសខ្យល់ក៏បាន តើដូចម្តេច ។ ម្នាលអានន្ទ ក្នុងលោកនេះ ស្ត្រីក្តី បុរសក្តី ក្នុងស្រុក ឬនិគមណា បានដល់ព្រះពុទ្ធជាទីពឹង បានដល់ព្រះធម៌ជាទីពឹង បានដល់ព្រះសង្ឃជាទីពឹង វៀរចាកការសម្លាប់សត្វ វៀរចាកការលួចលាក់កាន់យកវត្ថុដែលគេមិនបានឲ្យ វៀរចាកការប្រព្រឹត្តខុសក្នុងកាម វៀរចាកការនិយាយកុហក វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ជាអ្នកមានសីល មានធម៌ល្អ មានចិត្តប្រាសចាកសេចក្តីកំណាញ់ជាមន្ទិល នៅគ្រប់គ្រងផ្ទះ ជាអ្នកមានទានបរិច្ចាគហើយ មានដៃលាងស្អាតហើយ ជាអ្នកត្រេកអរក្នុងការលះ ជាអ្នកគួរគេសូមបាន ត្រេកអរក្នុងការឲ្យ និងការចែករំលែក សមណព្រាហ្មណ៍ក្នុងទិសទាំងឡាយ រមែងសរសើរបុគ្គលនោះថា ស្ត្រីក្តី បុរសក្តី ក្នុងស្រុក ឬនិគមឈ្មោះឯណោះ ដល់ព្រះពុទ្ធជាទីពឹង ដល់ព្រះធម៌ជាទីពឹង ដល់ព្រះសង្ឃជាទីពឹង វៀរចាកការ

សម្លាប់សត្វ វៀរចាកការលួចយកវត្ថុ ដែលគេមិនបានឲ្យ វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ វៀរចាកការនិយាយកុហក វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ជាអ្នកមានសីល មានធម៌ល្អ មានចិត្តប្រាសចាកសេចក្តីកំណាញ់ជាមន្ទិល នៅគ្រប់គ្រងផ្ទះ មានទានបរិច្ចាគហើយ មានដៃលាងស្អាតហើយ ជាអ្នកត្រេកអរក្នុងការលះ គួរគេសូមបាន ត្រេកអរក្នុងការចែករំលែកទាន ។ សូម្បីពួកទេវតាក៏តែងសរសើរបុគ្គលនោះថា ស្រ្តីក្តី បុរសក្តី ក្នុងស្រុក ឬនិគមឈ្មោះឯណោះ ជាអ្នកដល់ព្រះពុទ្ធជាទីរឭក ។បេ។ គួរគេសូមបាន ត្រេកអរក្នុងការចែករំលែកទាន ។ ម្នាលអានន្ទ ក្លិននៃគន្ធជាតនេះឯង ទើបផ្សាយទៅបណ្តោយខ្យល់ក៏បាន ច្រាសខ្យល់ក៏បាន ទាំងបណ្តោយខ្យល់ ទាំងច្រាសខ្យល់ក៏បាន ។

ក្លិនផ្កាផ្សាយទៅច្រាសខ្យល់ មិនបានទេ ទោះ ( ក្លិន )
ខ្លឹមចន្ទន៍ ក្រស្នា និងម្លិះលា ក៏ផ្សាយទៅច្រាសខ្យល់
មិនបានដែរ មានតែក្លិនរបស់សប្បុរសទាំងឡាយ ទើប
ផ្សាយទៅច្រាសខ្យល់បាន សប្បុរសរមែងផ្សព្វផ្សាយ
ទៅកាន់ទិសទាំងពួង ។

# អដ្ឋកថា

## គន្ធសូត្រ

[ ៨១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងគន្ធសូត្រទី ៩ ដូចតទៅនេះ បទថា **ឯកមន្តំ** សេចក្តីថា ក្នុងពេលក្រោយកត្តាហារ ព្រះអានន្ទត្រឡប់អំពីបិណ្ឌបាត សម្តែងវត្តចំពោះព្រះទសពលហើយ ទៅកាន់ទីសម្រាកពេលថ្ងៃរបស់ខ្លួន ហើយគិតថា ក្នុងលោកនេះ មានឈើឫសក្រអូប ឈើខ្លឹមក្រអូប ឈើផ្កាក្រអូប តែក្លិនទាំង ៣ យ៉ាងនេះ រមែងផ្សាយទៅតាមខ្យល់ប៉ុណ្ណោះ មិនផ្សាយទៅច្រាសខ្យល់ឡើយ មានក្លិនអ្វីផ្សាយទៅកាន់ទីច្រាសខ្យល់បានដែរឬហ្ន៎ ដូច្នេះហើយ ព្រោះហេតុដែលលោកទទួលពរ គឺការចូលទៅគាល់ក្នុងវេលាដែលកើតសេចក្តីសង្ស័យ ក្នុងកាលដែលទទួលពរ ៨ ប្រការនោះឯង រំពេចនោះ ទើបចេញអំពីទីសម្រាកពេលថ្ងៃ ទៅកាន់សម្នាក់របស់ព្រះសាស្តា ថ្វាយបង្គំហើយ អង្គុយក្នុងចំណែកម្ខាង ដើម្បីបន្ទោបង់នូវការសង្ស័យដែលកើតឡើង ទើបបានក្រាបទូលពាក្យនេះ គឺពាក្យជាដើមថា **តីណិមានិ ភន្តេ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **គន្ធជាតានិ** បានដល់ របស់ក្រអូបដោយកំណើតទាំងឡាយ ។ បទថា **មូលគន្ធោ** បានដល់ក្លិនដែលតាំងនៅក្នុងឫស ឬឫសដែលសម្បូរដោយក្លិននោះឯង ឈ្មោះថា **មូលគន្ធោ** ព្រោះថា ក្លិនរបស់ឫសនោះ រមែងផ្សាយទៅតាមខ្យល់ តែក្លិនរបស់ក្លិននោះមិនមាន ។ សូម្បីក្នុងក្លិនខ្លឹម និងក្លិនឫស ក៏មានន័យនេះដូចគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អត្ថានន្ទ គន្ធជាតំ** នេះដូចតទៅ ការ

ដល់នូវសារណៈជាដើម ឈ្មោះថា ជាក្លិន ព្រោះដូចគ្នានឹងក្លិនដែលផ្សាយទៅគ្រប់ទិស ដោយអំណាចនៃការពោលសរសើរគុណក្លិនទាំងនោះ មានបុគ្គលជាទីតាំង ឈ្មោះថា **គន្ធជាត។** បទថា **គន្ធោ គច្ឆតិ** សេចក្តីថា ផ្សាយទៅដោយអំណាចនៃការពោលសរសើរ ។ បទថា **សីលវា** បានដល់ មានសីលជាសីល ៥ ឬសីល ១០ ។ បទថា **កល្យាណធម្មោ** សេចក្តីថា មានកល្យាណធម៌ គឺមានធម៌ដែលល្អ ដោយសីលធម៌នោះឯង ។ អធិប្បាយនៃពាក្យជាដើមថា **វិគតមលមច្ឆេរេន** ជាដើម បានឲ្យពិស្តារហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។ បទថា **ទិសាសុ** បានដល់ ក្នុងទិសធំ ៤ ក្នុងទិសតូច ៤ ។ បទថា **សមណព្រាហ្មណា** បានដល់ សមណព្រាហ្មណ៍ដែលស្ងប់បាប និងបន្សាត់បាបហើយ ។ បទថា **ន បុប្ផគន្ធោ បដិវាតមេតិ** សេចក្តីថា ក្លិននៃផ្កាម្លិះជាដើម មិនផ្សាយទៅច្រាសខ្យល់ ។ បទថា **ន ចន្ទនំ តគរមល្លិកា វា** មានអធិប្បាយថា សូម្បីក្លិនរបស់ចន្ទន៍ក្រស្នា និងក្លាំពាក់ក៏ផ្សាយទៅច្រាសខ្យល់មិនបាន ។ ពិតហើយ អ្នកប្រាជ្ញទាំងឡាយពោលថា ក្នុងទេវលោក ក៏គង់មានផ្កាម្លិះដែលរីកហើយដូចគ្នា ក្នុងថ្ងៃដែលផ្កាម្លិះនោះរីកហើយ ក្លិនក៏ផ្សាយទៅបានរាប់រយយោជន៍ តែក្លិននោះក៏មិនអាចផ្សាយទៅច្រាសខ្យល់បាន សូម្បីត្រឹមតែ ១ ធ្នាប់ ឬត្រឹមតែ ១ ហត្ថ ។ បទថា **សតញ្ច គន្ធោ បដិវាតមេតិ** សេចក្តីថា ចំណែកក្លិន មានសីលគុណជាដើមរបស់សប្បុរសទាំងឡាយ គឺបណ្ឌិតទាំងឡាយ បានដល់ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះពុទ្ធសាវកទាំងឡាយ រមែងផ្សាយទៅច្រាសខ្យល់បាន។ បទថា **សព្វា**

**ទិសា សប្បុរិសោ បវាយតិ** សេចក្តីថា សប្បុរស គឺបណ្ឌិត រមែងផ្សាយទៅគ្រប់ទិស ដោយក្លិន គឺគុណ មានសីលជាដើម ។ អធិប្បាយថា មានក្លិនផ្សាយទៅគ្រប់ទិស ។ល។

**អដ្ឋកថា គន្ធសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ចូឡនីសូត្រទី ១០

[ ៨២ ] គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រនៃព្រះដ៏មានព្រះភាគ បានទទួលចំពោះព្រះភក្ត្រនៃព្រះដ៏មានព្រះភាគយ៉ាងនេះថា ម្នាលអានន្ទ ភិក្ខុឈ្មោះអភិភូ ជាសាវករបស់ព្រះពុទ្ធសិខី ស្ថិតនៅឯព្រហ្មលោក បានញុំាងលោកធាតុទាំង ១០០០ ឲ្យបានដឹងច្បាស់ ដោយសំឡេងបាន ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះដ៏មានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធ អាចញុំាងលោកធាតុមានប្រមាណត្រឹមណា ឲ្យដឹងច្បាស់ដោយសំឡេងបាន ម្នាលអានន្ទ អភិភូនោះជាសាវក ឯព្រះតថាគត

ទាំងឡាយ មានអានុភាពប្រមាណមិនបានទេ ។ ព្រះអានន្ទដ៏មានអាយុក្រាប
បង្គំទូលសួរព្រះដ៏មានព្រះភាគជាគម្រប់ ២ ដងដូច្នេះថា បពិត្រព្រះអង្គដ៏
ចម្រើន ខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ យ៉ាងនេះថា
ម្នាលអានន្ទ ភិក្ខុឈ្មោះអភិភូ ជាសាវករបស់ព្រះពុទ្ធសិខី ស្ថិតនៅឯព្រហ្ម-
លោក ញុំាងលោកធាតុ ១០០០ ឲ្យដឹងច្បាស់ដោយសំឡេងបាន បពិត្រ
ព្រះអង្គដ៏ចម្រើន ចុះព្រះដ៏មានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធ អាចញុំាង
លោកធាតុមានប្រមាណត្រឹមណា ឲ្យដឹងច្បាស់ដោយសំឡេងបាន ។ ម្នាល
អានន្ទ អភិភូនោះជាសាវក ឯព្រះតថាគតទាំងឡាយ មានអានុភាពប្រមាណ
មិនបានទេ ។ ព្រះអានន្ទដ៏មានអាយុ ក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគ
ជាគម្រប់ ៣ ដង ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានស្តាប់
ចំពោះព្រះភក្ត្រព្រះមានព្រះភាគ បានទទួលចំពោះព្រះភក្ត្រ ព្រះមានព្រះភាគ
យ៉ាងនេះថា ម្នាលអានន្ទ ភិក្ខុឈ្មោះអភិភូ ជាសាវករបស់ព្រះពុទ្ធសិខី ស្ថិត
នៅឯព្រហ្មលោក ញុំាងលោកធាតុ ១០០០ ឲ្យដឹងច្បាស់ ដោយសំឡេង
បាន បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ
អាចញុំាងលោកធាតុមានប្រមាណត្រឹមណា ឲ្យដឹងច្បាស់ដោយសំឡេងបាន ។
ម្នាលអានន្ទ លោកធាតុតូច ១០០០ អ្នកបានស្តាប់ហើយ ។ បពិត្រព្រះដ៏
មានព្រះភាគ ជាកាលគួរនឹងសម្តែងរឿងនុ៎ះហើយ ។ បពិត្រព្រះសុគត ជា
កាលគួរនឹងសម្តែងរឿងនុ៎ះហើយ ព្រោះថា ព្រះដ៏មានព្រះភាគសម្តែងធម៌
ណា ភិក្ខុទាំងឡាយបានស្តាប់ព្រះដ៏មានព្រះភាគហើយ នឹងចាំទុកនូវធម៌នោះ ។

ម្នាលអានន្ទ បើដូច្នោះ អ្នកចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែងប្រាប់ ។ ព្រះអានន្ទដ៏មានអាយុ បានទទួលស្តាប់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលអានន្ទ ព្រះចន្ទ្រ និងព្រះអាទិត្យដ៏រុងរឿងគោចរទៅបំភ្លឺទិសទាំងឡាយ បានត្រឹមណា ត្រឹមណោះ ជាលោកមួយ ( ត្រូវកំណត់យកលោកនោះ ) ១០០០ ក្នុងលោកដែលកំណត់ ១០០០ ជងនោះ មានព្រះចន្ទ្រ ១០០០ ព្រះអាទិត្យ ១០០០ ស្តេចភ្នំសិនេរុ ១០០០ ជម្ពូទ្វីប ១០០០ អមរគោយានទ្វីប ១០០០ ឧត្តរកុរុទ្វីប ១០០០ បុព្វវិទេហទ្វីប ១០០០ មហាសមុទ្រ ៤០០០ មហារាជ ( លោកបាល ) ៤០០០ ស្ថានចាតុម្មហារាជិកៈ ១០០០ ស្ថានតាវត្តិង្ស ១០០០ ស្ថានយាមៈ ១០០០ ស្ថានតុសិត ១០០០ ស្ថាននិម្មានរតី ១០០០ ស្ថានបរនិម្មិតវសវត្តី ១០០០ ព្រហ្មលោក ១០០០ ។ ម្នាលអានន្ទ នេះហៅថា សហស្សីចូឡនិកាលោកធាតុ ( លោកធាតុតូច ) ។ ម្នាលអានន្ទ សហស្សីចូឡនិកាលោកធាតុកំណត់ត្រឹមណា ត្រឹមណោះ ទុកជាលោកមួយ ( លោកនោះកំណត់ ) ១០០០ ជង ម្នាលអានន្ទ នេះហៅថា ទ្វិសហស្សីមជ្ឈិមិកាលោកធាតុ ។ ម្នាលអានន្ទ ទ្វិសហស្សីមជ្ឈិមិកាលោកធាតុត្រឹមណា ត្រឹមណោះជាលោកធាតុមួយ ( លោកនោះកំណត់ ) ១០០០ ជង ម្នាលអានន្ទ នេះហៅថា តិសហស្សីមហាសហស្សីលោកធាតុ ។ ម្នាលអានន្ទ កាលបើតថាគតប្រាថ្នា គប្បីញុំាងតិសហស្សីមហាសហស្សីលោកធាតុឲ្យដឹងច្បាស់ដោយសំឡេងបាន ឬថាគប្បីប្រាថ្នាដល់ត្រឹមណាក៏បាន ។ បពិត្រព្រះអង្គ

ដ៏ចម្រើន ចុះព្រះដ៏មានព្រះភាគគប្បីញ៉ាំងតិសហស្សីមហាសហស្សីលោកធាតុឲ្យដឹងច្បាស់ដោយសំឡេងបាន ឬថាគប្បីប្រាថ្នាដល់ត្រឹមណាក៏បាន តើដូចម្តេច ។ ម្នាលអានន្ទ ក្នុងលោកនេះ តថាគតផ្សាយរស្មីទៅកាន់តិសហស្សី-មហាសហស្សីលោកធាតុ កាលណាពួកសត្វទាំងនោះ ស្គាល់ច្បាស់នូវពន្លឺនោះបានក្នុងកាលនោះ តថាគតគប្បីធ្វើនូវសំឡេងឲ្យគឹកកង ញ៉ាំងសំឡេងឲ្យលាន់ឮ ម្នាលអានន្ទ តថាគតគប្បីញ៉ាំងតិសហស្សីមហាសហស្សីលោក-ធាតុ ឲ្យដឹងច្បាស់ដោយសំឡេងបាន ឬថាគប្បីប្រាថ្នាដល់ណាក៏បាន យ៉ាងនេះឯង ។ កាលបើព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះអានន្ទដ៏មានអាយុបានក្រាបទូលយ៉ាងនេះថា ឱ ជាលាភរបស់ខ្ញុំព្រះអង្គហើយ ខ្ញុំព្រះអង្គឈ្មោះថា បានល្អហើយ ព្រោះថា ព្រះសាស្តារបស់ខ្ញុំព្រះអង្គមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ។ កាលបើព្រះអានន្ទដ៏មានអាយុនិយាយយ៉ាងនេះហើយ ព្រះឧទាយិដ៏មានអាយុ ក៏និយាយតបនឹងព្រះអានន្ទដ៏មានអាយុដូច្នេះថា ម្នាលអាវុសោអានន្ទ ប្រសិនបើព្រះសាស្តារបស់អ្នកមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ តើអ្នកនឹងបានអ្វីក្នុងដំណើរនុ៎ះ ។ កាលបើព្រះឧទាយិដ៏មានអាយុ និយាយយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងព្រះឧទាយិដ៏មានអាយុ ដូច្នេះថា ម្នាលឧទាយិ អ្នកកុំនិយាយយ៉ាងនេះឡើយ ម្នាលឧទាយិ បើអានន្ទមិនទាន់ប្រាសចាករាគៈយ៉ាងនេះហើយ គប្បីធ្វើមរណកាលដោយចិត្តជ្រះថ្លានោះ អានន្ទ គប្បីសោយទេវរជ្ជសម្បត្តិ ក្នុងទេវលោក ៧ ដង សោយមហារជ្ជសម្បត្តិក្នុង

ជម្ពូទ្វីបនេះ ៧ ដង ម្នាលឧទាយិ តែថា អានន្ទនឹងបរិនិព្វានក្នុងអត្តភាព ជាបច្ចុប្បន្ននេះ ។

### អានន្ទវគ្គទី ៣ ចប់

## ឧទ្ទាននៃអានន្ទវគ្គនោះ គឺ

រឿងឆន្នបរិព្វាជក ១ សូត្រ អាជីវកសាវក ១ សូត្រ មហានាមសក្កៈ ១ សូត្រ និគ្គណ្ឋនាដបុត្រ ១ សូត្រ ការដឹកនាំឲ្យល្អ ១ សូត្រ កម្មប្តី ១ សូត្រ រឿងភព មានដូចគ្នានោះ ១ សូត្រ សីលវត្ត ១ សូត្រ ក្លិន ១ សូត្រ ចូឡនិកាលោកធាតុ ១ សូត្រ ។

# អដ្ឋកថា

## ចូឡ្បណីសូត្រ

[ ៨២ ] ក្នុងសូត្រទី ១០ មានអត្ថដែលត្រូវលើកឡើង ២ យ៉ាង គឺការលើកអត្ថ ដែលទាក់ទងនឹងអត្ថុប្បត្តិហេតុ ១ ដែលទាក់ទងដោយអំណាចការសួរ ១ ។ បើមានពាក្យសួរថា ក្នុងការកើតឡើងនៃអត្ថដូចម្ដេច ព្រះមានព្រះភាគត្រាស់ឆ្លើយពាក្យសួររបស់បុគ្គលណា ។ ឆ្លើយថា ក្នុងការកើតឡើងនៃអត្ថរបស់អរុណវតីសូត្រ ព្រះមានព្រះភាគ ទ្រង់ត្រាស់ឆ្លើយសំណួររបស់ព្រះអានន្ទ ។ សួរថា អរុណវតីសូត្រ បុគ្គលណាពោល ឆ្លើយថា ព្រះពុទ្ធ ២ ព្រះអង្គ គឺព្រះពុទ្ធសិខី និងព្រះសាស្ដានៃយើងត្រាស់ ។

ពន្រឹកសេចក្ដីថា រាប់តាំងអំពីកប្បនេះថយក្រោយទៅ ក្នុងកប្បទី ៣១ ត្រង់អរុណវតីនគរ ព្រះមានព្រះភាគព្រះនាមថាសិខី ទ្រង់បដិសន្ធិក្នុងគព្ភទររបស់ព្រះមហេសី ឈ្មោះបភាវតីរបស់ព្រះបាទអរុណវតៈ កាលព្រះញាណចាស់ក្លាហើយ ទ្រង់ចេញមហាភិនេស្រ្កម៍ ត្រាស់ដឹងសព្វញ្ញុតញ្ញាណត្រង់មណ្ឌលមហាពោធិ៍ ប្រកាសធម្មចក្រដ៏ប្រសើរ ទ្រង់អាស្រ័យអរុណវតីនគរប្រថាប់នៅ ថ្ងៃមួយ ពេលព្រឹក ទ្រង់បដិបត្តិសរីរកិច្ចហើយ មានភិក្ខុសង្ឃជាច្រើនជាបរិវារ ទ្រង់ព្រះតម្រិះថា តថាគតនឹងចូលទៅបិណ្ឌបាត ក្នុងអរុណវតីនគរ ហើយយាងទៅប្រថាប់ឈរត្រង់ខ្លោងទ្វារវិហារ ទ្រង់ហៅអគ្គសាវកព្រះនាមថា អភិភូមកហើយ ត្រាស់ថា ម្នាលភិក្ខុ បើទៅបិណ្ឌបាតកាន់អរុណវតីនគរ នៅពេលព្រឹកពេក ល្ហើយចុះ យើងទាំងឡាយ នឹងទៅ

កាន់ព្រហ្មលោកណាមួយសិន ដូច្នេះ ។

សមដូចដែលទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនោះ ព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ បានត្រាស់ហៅភិក្ខុឈ្មោះអភិភូថា ម្នាលព្រាហ្មណ៍ មក យើងនឹងចូលទៅកាន់ព្រហ្មលោកណាមួយ ទម្រាំដល់ពេលភត្ត ។ ម្នាលភិក្ខុទាំងឡាយ អភិភូភិក្ខុ ទទួលព្រះពុទ្ធដីកាព្រះសិខីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធថា ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំង-ឡាយ ក្នុងកាលនោះ ព្រះសិខីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ និងអភិភូភិក្ខុ ក៏បាត់អំពីអរុណវតីរាជធានី ទៅប្រាកដក្នុងព្រហ្មលោកនោះ ។ ហើយមហា-ព្រហ្មក្នុងព្រហ្មលោកនោះ បានឃើញព្រះសម្មាសម្ពុទ្ធ ហើយត្រេកអរ ទើបធ្វើការទទួល បានក្រាលអាសនៈព្រហ្មថ្វាយ ឯព្រះថេរៈ ព្រហ្មទាំងឡាយក៏នាំគ្នាក្រាលអាសនៈដែលសមគួរថ្វាយ ។ ព្រះមានព្រះភាគ ទ្រង់ប្រថាប់គង់លើអាសនៈ ដែលគេក្រាលថ្វាយហើយ ព្រះថេរៈក៏គង់លើអាសនៈ ដែលគេក្រាលដើម្បីខ្លួន ។ ឯមហាព្រហ្មក៏ថ្វាយបង្គំព្រះទសពល ហើយអង្គុយក្នុងចំណែកម្ខាង ។

ម្នាលភិក្ខុទាំងឡាយ ក្នុងលំដាប់នោះ ព្រះសិខីមានព្រះភាគអរហន្ត-សម្មាសម្ពុទ្ធត្រាស់នឹងអភិភូភិក្ខុថា ម្នាលព្រាហ្មណ៍ អ្នកចូរសម្តែងនូវធម្មីកថាដល់ព្រហ្មផង ដល់បរិសទ្យរបស់ព្រហ្មផង ដល់អ្នកបម្រើរបស់ព្រហ្មផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះអភិភូ ទទួលព្រះពុទ្ធដីកាព្រះសិខីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធថា ព្រះករុណាព្រះអង្គ ហើយញុំាងព្រហ្មផង ញុំាងបរិសទ្យ

របស់ព្រហ្មផង ញុំាងអ្នកបម្រើរបស់ព្រហ្មផង ... ។ ហើយកាលព្រះថេរៈសម្តែងធម៌ ព្រហ្មទាំងឡាយលើកទោសថា អស់កាលយូរហើយ ពួកខ្ញុំបានឃើញព្រះបរមសាស្តា យាងមកកាន់ព្រហ្មលោក តែភិក្ខុនេះ រារាំងព្រះសាស្តា ប្រុងប្រៀបសម្តែងធម្មកថាខ្លួនឯង ។

ព្រះសាស្តាទ្រង់ជ្រាបថា ពួកព្រហ្មទាំងនោះមិនពេញចិត្ត ទើបត្រាស់នឹងអភិភូភិក្ខុដូច្នេះថា ម្នាលព្រាហ្មណ៍ ព្រហ្ម ព្រហ្មបរិស័ទ និងព្រហ្មបារិសជ្ជា នាំគ្នាពោលទោសរបស់អ្នក បើដូច្នោះ ចូរអ្នកធ្វើឲ្យព្រហ្មទាំងនោះសង្វេគពន់ប្រមាណចុះ ។ ព្រះថេរៈទទួលព្រះពុទ្ធតម្រាស់ហើយ ធ្វើឫទ្ធិច្រើនប្រការ កាលញុំាងលោកធាតុ ១០០០ ឲ្យឮច្បាស់ដោយសំឡេង ទើបពោល ២ គាថាថា **អារព្ភថ និក្ខមថ** ប្រែថា ចូរផ្តើមចុះ ចូរព្យាយាមចុះអ្នកទាំងឡាយ ដូច្នេះជាដើម ។

សួរថា ព្រះថេរៈធ្វើដូចម្តេច ទើបឲ្យលោកធាតុទាំង ១០០០ ជ្រាបច្បាស់បាន ឆ្លើយថា ព្រះថេរៈចូលនីលកសិណហើយ ផ្សាយងងឹតអន្ធការទៅគ្រប់ទិសទាំងពួង បន្ទាប់អំពីនោះ កាលសត្វទាំងឡាយកើតការត្រិះរិះឡើងថា នេះជាងងឹតអន្ធការអ្វីហ្ន៎ ទើបសម្តែងពន្លឺ ។ កាលពួកសត្វទាំងនោះគិតថា នេះពន្លឺអ្វីហ្ន៎ ទើបបង្ហាញខ្លួនឲ្យឃើញ ទើបទេវតា និងមនុស្សទាំងឡាយ ក្នុងពាន់ចក្រវាលទាំងឡាយ នាំគ្នាឈរផ្គងអញ្ជលីនមស្ការព្រះថេរៈនោះឯង ។ ព្រះថេរៈអធិដ្ឋានថា ចូរមហាជនបានឮសំឡេងរបស់អញដែលសម្តែងធម៌ ដូច្នេះហើយ បានពោលគាថាទាំងនេះ ទេវតា និងមនុស្ស

ទាំងឡាយ បានឮសំឡេងរបស់ព្រះថេរៈ ដូចអន្ទាយសម្ដែងធម៌ក្នុងកណ្ដាលបរិស័ទដែលដល់ព្រមហើយ សូម្បីអត្ថក៏ប្រាកដច្បាស់ដល់ទេវតា និងមនុស្សទាំងនោះ ។

គ្រានោះឯង ព្រះមានព្រះភាគ បានយាងត្រឡប់មកកាន់អរុណវតីនគរមួយអន្លើដោយព្រះថេរៈ ទ្រង់យាងបិណ្ឌបាត ទ្រង់ត្រឡប់អំពីបិណ្ឌបាត ខាងក្រោយភត្តហើយ ត្រាស់សួរភិក្ខុសង្ឃថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយបានឮទេនូវសំឡេងរបស់អភិភូភិក្ខុ ដែលឈរពោលគាថាលើព្រហ្មលោក ភិក្ខុទាំងនោះទទួលថា បានឮ ព្រះអង្គ ។ កាលប្រកាសសេចក្ដីដែលខ្លួនបានឮទើបបានលើកយកទាំង ២ គាថាមកជាភស្តុតាង ។ ព្រះសាស្ដាទ្រង់ប្រទានសាធុការថា សាធុ សាធុ ហើយផ្ដើមសម្ដែងព្រះធម្មទេសនា ព្រះសូត្រនេះដែលព្រះមានព្រះភាគសិខីត្រាស់ក្នុងកប្បទី ៣១ រាប់អំពីកប្បនេះថយក្រោយទៅ ដោយប្រការដូចពណ៌នាមកនេះ ។

ចំណែកព្រះមានព្រះភាគនៃយើងទាំងឡាយ ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណហើយ ទ្រង់ប្រកាសព្រះធម្មចក្រដ៏បវរ ចូលទៅអាស្រ័យព្រះនគរសាវត្ថី ហើយនៅប្រថាប់ក្នុងវត្តជេតពនមហាវិហារ ក្នុងខែជេស្ឋ បានត្រាស់ហៅភិក្ខុទាំងឡាយមក ហើយទ្រង់ផ្ដើមសម្ដែងព្រះសូត្រ ឈ្មោះថា អរុណវតីនេះ ។ ព្រះអានន្ទឈរធ្វើការបក់ផ្លិតនោះឯង រៀនព្រះសូត្រទាំងអស់ តាំងអំពីដើមដល់ចប់ មិនឲ្យជ្រុះធ្លាក់សូម្បីតែ ១ ព្យញ្ជនៈ ក្នុងថ្ងៃស្អែកឡើងលោកត្រឡប់អំពីបិណ្ឌបាត សម្ដែងវត្តចំពោះព្រះទសពលហើយ ត្រឡប់ទៅ

កាន់ទីសម្រាកពេលថ្ងៃរបស់ខ្លួន កាលសទ្ធិវិហារិក និងអន្តេវាសិកទាំងឡាយ សម្តែងវត្តហើយ ចៀសចេញទៅ អង្គុយពិចារណាដល់អរុណវតីសូត្រ ដែលព្រះមានព្រះភាគត្រាស់ហើយក្នុងថ្ងៃម្សិលមិញ ។ កាលនោះ ព្រះសូត្រទាំងអស់ បានប្រាកដជាក់ច្បាស់ដល់ព្រះអានន្ទ ។

ព្រះអានន្ទត្ថេរគិតថា អគ្គសាវករបស់ព្រះមានព្រះភាគ ព្រះនាមសិខី ឈរលើព្រហ្មលោក បញ្ចេញរស្មីចេញអំពីសរីរៈ កម្ចាត់ងងឹតអន្ធការក្នុងចក្រវាល ១០០០ ហើយសម្តែងធម្មកថា ឲ្យទេវតា និងមនុស្សបានឮសំឡេងរបស់ខ្លួន ពាក្យដូចពោលមកនេះ ព្រះបរមសាស្តាត្រាស់ហើយ កាលអំពីម្សិលមិញ វិស័យរបស់សាវកមានអានុភាពបែបនេះ ឯព្រះសម្មាសម្ពុទ្ធទ្រង់បំពេញបារមី ១០ ហើយសម្រេចព្រះសព្វញ្ញុតញ្ញាណ និងបន្ទឺព្រះសូរសៀងបានឆ្ងាយប៉ុនណាហ្ន៎ ដើម្បីបន្ទោបង់សេចក្តីសង្ស័យ ដែលកើតហើយយ៉ាងនេះ រំពេចនោះឯង ទើបចូលទៅគាល់ព្រះមានព្រះភាគ ហើយទូលសួរសេចក្តីនោះ ។ ដើម្បីសម្តែងសេចក្តីនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលពាក្យថា **អថខោ អាយស្មា អានន្ទោ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **សម្មុខា** សេចក្តីថា ព្រះសូត្រនេះ ខ្ញុំអានន្ទឈរចំពោះព្រះភក្ត្រស្តាប់ហើយ មិនមែនស្តាប់ដោយបានឮតាមគ្នាមក គឺមិនបានស្តាប់ដោយតអំពីទូត ព្រះអានន្ទត្ថេរពោលយ៉ាងនេះ ដោយមានបំណងដូចអធិប្បាយមកនេះឯង ។

បទថា **កីវតកំ បហោតិ សរេន វិញ្ញាបេតុំ** សេចក្តីថា ព្រះមានព្រះភាគទ្រង់កម្ចាត់ងងឹតអន្ធការដោយព្រះរស្មី ដែលបញ្ចេញចេញអំពីព្រះ

វរកាយ ហើយបន្លឺសំឡេងទៅបានឆ្ងាយប៉ុនណា ។

ព្រះមានព្រះភាគ ត្រាស់ពាក្យនេះថា **សាវកោ សោ អានន្ទ អប្បមេយ្យា តថាគតា** ដោយមានព្រះពុទ្ធបំណងដូច្នេះថា ម្នាលអានន្ទ អ្នកពោលអ្វីយ៉ាងនេះ សាវកតាំងនៅក្នុងញាណចំពោះ ចំណែកព្រះតថាគតទ្រង់បំពេញបារមី ១០ ហើយទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណ មានព្រះញាណប្រមាណមិនបាន ។ ភិក្ខុនោះ ពោលអ្វីយ៉ាងនេះ ដូចយកចុងក្រចកឆ្កឹះធូលីឡើងមកប្រៀបជាមួយធូលីក្នុងផ្ទៃមហាប្រឹថពី ព្រោះវិស័យនៃសាវកទាំងឡាយក៏ជាចំណែកមួយ របស់ព្រះពុទ្ធទាំងឡាយក៏ជាចំណែកមួយ ធម៌ជាគោចរនៃសាវកទាំងឡាយក៏ជាចំណែកមួយ របស់ព្រះពុទ្ធទាំងឡាយក៏ជាចំណែកមួយ កម្លាំងរបស់ព្រះសាវកទាំងឡាយក៏ជាចំណែកមួយ របស់ព្រះពុទ្ធទាំងឡាយក៏ជាចំណែកមួយ ។ ព្រះមានព្រះភាគ កាលត្រាស់ភាពដែលព្រះពុទ្ធទាំងឡាយមានអានុភាពមិនមានប្រមាណ ដោយមានព្រះពុទ្ធបំណងដូចពណ៌នាមកនេះ ហើយទ្រង់តុណ្ហីភាព ។ សូម្បីព្រះថេរៈក៏ទូលសួរជាលើកទី ២ ។ ព្រះបរមសាស្តាកាលទ្រង់សម្តែងថា អានន្ទ អ្នកពោលអ្វីយ៉ាងនេះ ប្រៀបដូចយកប្រហោងនៃដើមត្នោតទៅប្រៀបនឹងអាកាស ដែលធំល្វឹងល្វើយមិនមានទីបំផុត និងដូចយកសត្វត្រចៀកកម្ម ទៅប្រៀបធៀបនឹងស្តេចគ្រុឌ ដែលហើរបានមួយថ្ងៃ ១៥០ យោជន៍ និងដូចយកទឹកក្នុងប្រមោយដំរីទៅប្រៀបធៀបនឹងទឹកក្នុងមហាគង្គា ដូចគ្នានឹងយកទឹកក្នុងរណ្តៅទំហំ ៨ ហត្ថទៅប្រៀបធៀបនឹងស្រះទាំង ៧ ដូចគ្នានឹងយកមនុស្សដែលមានទ្រព្យត្រឹមតែ

អន្តរប្រមាណមួយនាឡិ ទៅប្រៀបធៀបនឹងស្តេចចក្រពត្តិ និងដូចបិសាចប្រឡាក់ធូលីទៅ ប្រៀបធៀបនឹងសក្កទេវរាជ និងដូចយកពន្លឺនៃអំពិលអំពែក ទៅប្រៀបធៀបនឹងពន្លឺនៃព្រះអាទិត្យ ដូច្នេះហើយ ត្រាស់នូវភាពដែលព្រះពុទ្ធទាំងឡាយ មានអានុភាពប្រមាណមិនបានជាលើកទី ២ ហើយទ្រង់តុណ្ហីភាព ។ លំដាប់នោះ ព្រះថេរៈគិតថា ព្រះសាស្តាដែលអញទូលសួរហើយ មិនបានត្រាស់ឆ្លើយឡើយ អញទូលសួរអស់ ៣ ដង ហើយនឹងឲ្យព្រះសាស្តាបន្លឺពុទ្ធសីហនាទ ដូច្នេះ ទើបទូលជាលើកទី ៣ ដើម្បីសម្តែងដល់ការទូលសូមជាលើកទី ៣ នោះ ទើបលោកពោលពាក្យជាដើមថា **តតិយម្បិ ខោ** ។

លំដាប់នោះ ព្រះមានព្រះភាគ ដើម្បីទ្រង់ឆ្លើយបញ្ហារបស់ព្រះអានន្ទ ទើបត្រាស់ពាក្យជាដើមថា **សុតា តេ អានន្ទ** ដូច្នេះ ព្រះថេរៈគិតថា ព្រះបរមសាស្តា ត្រាស់ពាក្យមានប្រមាណប៉ុណ្ណេះ ប៉ុណ្ណោះ ដល់ខ្ញុំថា អានន្ទ លោកធាតុ ១០០០ តិចតួចណាស់ អ្នកបានស្តាប់ហើយ មិនមែនឬ ហើយទ្រង់តុណ្ហីភាព តទៅនេះ ព្រះពុទ្ធទ្រង់បន្លឺពុទ្ធសីហនាទ ដូច្នេះ ។ កាលទូលសូមព្រះបរមសាស្តា ទើបបានក្រាបទូលពាក្យជាដើមថា **ឯតស្ស ភគវា កាលោ** ដូច្នេះ ។

ឯព្រះមានព្រះភាគ ត្រាស់ពាក្យជាដើមថា **តេនហានន្ទ** ដូច្នេះ ដើម្បីត្រាស់កថាយ៉ាងពិស្តារដល់ព្រះអានន្ទ ។ បណ្តាបទទាំងនោះ បទថា **យាវតា** សេចក្តីថា អស់ទីមានប្រមាណប៉ុនណា ។ ព្រះចន្ទផង ព្រះអាទិត្យផង ឈ្មោះ

ថា **ចន្ទិមសុរិយា** ។ បទថា **បរិហរន្តិ** ប្រែថា គោចរទៅ ។ បទថា **ទិសា ភន្តិ** បានដល់ បញ្ចេញពន្លឺទៅគ្រប់ទិស ។ បទថា **វិរោចនា** ប្រែថា រុងរឿង ។ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ទ្រង់សម្តែងចក្រវាល ដោយកំណត់មួយចក្រវាល ។ ឥឡូវនេះ កាលទ្រង់សម្តែងចក្រវាល ១០០០ គុណនឹង ១០០០ ទើបត្រាស់ថា **តាវ សហស្សា លោកោ** ដូច្នេះ ។ បទថា **តស្មឹ សហស្សធា លោកេ** សេចក្តីថា ក្នុងពាន់នៃចក្រវាលនោះ ។ បទថា **សហស្សំ ចាតុម្មហារាជិកានំ** បានដល់ ទេវលោកចាតុម្មហារាជិកា ១០០០ ព្រោះហេតុក្នុងចក្រវាល មានមហារាជជាប្រចាំ មួយចក្រវាល ៤ មួយចក្រវាល ៤ ដូច្នោះ ទើបត្រាស់ថា **ចត្តារិ មហារាជសហស្សានិ** ដូច្នេះ ។ ក្នុងគ្រប់ៗ បទ គប្បីជ្រាបអត្ថដោយឧបាយនេះ ។ បទថា **ចូឡនិកា** ប្រែថា លោកធាតុខ្នាតតូច ។ នេះជាវិស័យរបស់សាវកទាំងឡាយ សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ ទ្រង់នាំលោកធាតុខ្នាតតូចនេះមកសម្តែង ។ ឆ្លើយថា ដើម្បីទ្រង់សម្តែងដល់ការកំណត់លោកធាតុខ្នាតកណ្តាល ។ បទថា **យាវតា** ប្រែថា មានប្រមាណប៉ុនណា ។ បទថា **តាវ សហស្សធា** សេចក្តីថា ដោយចំណែកត្រឹម ១០០០ នោះ ។

ដោយបទថា **ទ្វិសហស្សី មជ្ឈិមិកា លោកធាតុ** នេះ ទ្រង់សម្តែងថា លោកធាតុនេះមានចំនួន ២០០០ មានចក្រវាលមួយសែនជាប្រមាណ ដោយ ១០០០ ដោយមួយពាន់ចំណែកគុណនឹងចក្រវាល ១០០០ ឈ្មោះថា លោកធាតុខ្នាតកណ្តាល មិនមែនវិស័យរបស់សាវកទាំងឡាយ ជាវិស័យរបស់ព្រះ

*ពុទ្ធប៉ុណ្ណោះ ។ ព្រោះថា ក្នុងទីមានប្រមាណប៉ុណ្ណោះ ព្រះតថាគតទាំងឡាយ ទ្រង់អាចបញ្ចេញព្រះរស្មីអំពីពុទ្ធសរីរៈ កម្ចាត់នូវងងឹតអន្ធការ ហើយឲ្យមនុស្ស និងទេវតាទាំងឡាយបានឮនូវព្រះសូរសៀង ។ ឈ្មោះថា ជាតិក្ខេត្ត របស់ព្រះពុទ្ធទាំងឡាយ ទ្រង់សម្តែងហើយ ដោយពាក្យមានប្រមាណប៉ុណ្ណោះ ។ អធិប្បាយថា ក្នុងភពចុងក្រោយរបស់ព្រះពោធិសត្វទាំងឡាយ ក្នុងថ្ងៃដែលទ្រង់ចុតិចាកទេវលោក បដិសន្ធិក្នុងគភ៌របស់ព្រះពុទ្ធមាតា ១ ក្នុងថ្ងៃប្រសូតចាកព្រះគភ៌ ១ ក្នុងថ្ងៃចេញបួស ១ ក្នុងថ្ងៃត្រាស់ដឹង ១ ក្នុងថ្ងៃទ្រង់សម្តែងធម្មចក្រ ១ ក្នុងថ្ងៃទ្រង់ដាក់អាយុសង្ខារ ១ និងក្នុងថ្ងៃបរិនិព្វាន ១ ស្ថានទីមានប្រមាណប៉ុណ្ណោះ គឺលោកធាតុខាងកណ្តាលតែងញាប់ញ័រ ។*

*បទថា* **តិសហស្សី មហាសហស្សី** *សេចក្តីថា ឈ្មោះថា* **តិសហស្សី** *ព្រោះតាំងអំពីចំនួន ១០០០ យក ១០០០ គុណនឹង ៣ ដង ។ លោកធាតុដែលគុណដោយច្រើនពាន់ ព្រោះតាំង ១០០០ យក ១០០០ គុណ តាំងលោកធាតុខាងកណ្តាល យក ១០០០ គុណ ព្រោះដូច្នោះ ទើបឈ្មោះថា* **មហាសហស្សី** ។ *ដោយពាក្យមានប្រមាណប៉ុណ្ណោះ ឈ្មោះថា ទ្រង់សម្តែងលោក មានសែនកោដិចក្រវាលជាប្រមាណ ។ ព្រះមានព្រះភាគ កាលមានពុទ្ធបំណង ទ្រង់បញ្ចេញព្រះរស្មីចេញអំពីព្រះពុទ្ធសរីរៈ កម្ចាត់ងងឹតអន្ធការ ឲ្យទេវតា និងមនុស្សទាំងឡាយបានឮសំឡេង ក្នុងស្ថានទីប៉ុណ្ណោះ ។ ឯព្រះគណកបុត្តតិស្សត្ថេរពោលយ៉ាងនេះថា* **តិសហស្សីលោកធាតុ** និង **មហាសហស្សីលោកធាតុ** *មានប្រមាណយ៉ាងនេះ ព្រោះប្រមាណនេះ ជាទីតាំង*

នៃការបរិហារដោយវាចា ជាមូលនៃការស្វាធ្យាយរបស់អាចារ្យទាំងឡាយ តែស្ថានទីដែលឈ្មោះថា **តិសហស្សី លោកធាតុ** និង **មហាសហស្សី លោកធាតុ** មានប្រមាណមួយលានកោដិចក្រវាល ។ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ព្រះមានព្រះភាគទ្រង់សម្តែងខេត្តដែលឈ្មោះថា អាណាខេត្តហើយ ព្រោះក្នុងរវាងនេះ អាណា គឺអំណាចរបស់អាដានា-ដិយបរិត្ត ឥសិគិលិបរិត្ត ធជគ្គបរិត្ត ពោជ្ឈង្គបរិត្ត ខន្ធបរិត្ត មោរបរិត្ត មេត្តាបរិត្ត និងរតនបរិត្ត តែងផ្សាយទៅដល់ ។

បទថា **យាវតា វា បន អាកង្ខេយ្យ** សេចក្តីថា ទ្រង់ប្រាថ្នាទីមានប្រមាណប៉ុនណា ដោយពាក្យនេះ ទ្រង់សម្តែងដល់វិសយក្ខេត្ត ព្រោះតាមធម្មតាវិសយក្ខេត្តរបស់ព្រះពុទ្ធទាំងឡាយ មិនមានកំណត់ប្រមាណ ។ ក្នុងសេចក្តីនេះ វិសយក្ខេត្តរបស់ព្រះពុទ្ធទាំងឡាយ មិនមានកំណត់ប្រមាណនោះឯង បុរាណាចារ្យទាំងឡាយ នាំឧបមាមកអាងដូចតទៅនេះ បើមានបុគ្គលណាម្នាក់ យកគ្រាប់ស្ពៃទៅគរឲ្យពេញសែនកោដិចក្រវាល ទល់គ្នានឹងព្រហ្មលោក ដាក់គ្រាប់ស្ពៃទៅក្នុងចក្រវាល មួយចក្រវាល ១ គ្រាប់ក្នុងទិសបូព៌សោត គ្រាប់ស្ពៃទាំងអស់នោះ គប្បីដល់នូវការអស់ទៅមុន តែចក្រវាលក្នុងទិសបូព៌ មិនទាន់អស់ទៅឡើយ ក្នុងចក្រវាលទិសទក្សិណជាដើម ក៏មានន័យដូចគ្នា ។

ក្នុងវិសយក្ខេត្តនោះ ឈ្មោះថា វត្ថុដែលមិនជាវិស័យរបស់ព្រះពុទ្ធទាំងឡាយ មិនមានឡើយ ។ កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ

ព្រះថេរៈគិតថា ព្រះសាស្តាត្រាស់យ៉ាងនេះថា ម្នាលអានន្ទ កាលតថាគត ប្រាថ្នា គប្បីញ៉ាំងលោកធាតុឈ្មោះតិសហស្សី និងមហាសហស្សី ឲ្យបានឮសំឡេងតាមដែលតថាគតប្រាថ្នា ដូច្នេះ ឯលោកធាតុមិនស្មើគ្នា ចក្រវាលមិនមានទីបំផុត ព្រះអាទិត្យរះឡើង ១ ថ្ងៃត្រង់ ១ លិចចុះ ១ បឋមយាមមានក្នុងទី ១ មជ្ឈិមយាមមានក្នុងទី ១ បច្ឆិមយាមក៏មានក្នុងទី ១ ។ សត្វទាំងឡាយខ្វល់ខ្វាយក្នុងការងារ ដាក់ចិត្តក្នុងការលេង ស្វែងរកអាហារ ព្រោះដូច្នោះ សត្វទាំងឡាយ រមែងរាយមាយ និងប្រមាទ ដោយហេតុនោះៗយ៉ាងនេះ ព្រះបរមសាស្តានឹងញ៉ាំងសត្វទាំងឡាយនោះ ឲ្យបានឮព្រះសូរសៀងបានដូចម្តេចហ្ន៎ ដូច្នេះ ។ ព្រះអានន្ទត្ថេរ កាលគិតយ៉ាងនេះហើយ កាលនឹងទូលសួរព្រះតថាគត ដើម្បីបន្ទោបង់សេចក្តីសង្ស័យ ទើបក្រាបទូលពាក្យជាដើមថា **យថាកថំ បន** ដូច្នេះ ។

លំដាប់នោះ ព្រះបរមសាស្តាកាលទ្រង់ព្យាករដល់ព្រះអានន្ទត្ថេរ ទើបត្រាស់ពាក្យជាដើមថា **ឥធានន្ទ តថាគតោ** ដូច្នេះ ។ បណ្តាបទទាំងនោះបទថា **ឱភាសេន ផរេយ្យ** សេចក្តីថា ផ្សាយទៅដោយរស្មីនៃព្រះសរីរៈ ។ សួរថា ឱភាសនោះកាលផ្សាយទៅ គប្បីធ្វើអាការយ៉ាងណា ។ ឆ្លើយថា ទីណាមានព្រះអាទិត្យប្រាកដ ទីនោះទ្រង់ក៏ធ្វើឲ្យព្រះអាទិត្យលិចដោយអានុភាពរបស់ព្រះអង្គ តែទីណាព្រះអាទិត្យមិនប្រាកដ ទីនោះ ទ្រង់ធ្វើឲ្យព្រះអាទិត្យប្រាកដ ឃើញ ស្ថិតនៅត្រង់កណ្តាលអាកាស បន្ទាប់អំពីនោះ ក្នុងទីណាព្រះអាទិត្យប្រាកដ ក្នុងទីនោះ មនុស្សទាំងឡាយ ក៏គប្បីកើតការរិតក្កថា ព្រះ

អាទិត្យប្រាកដមិនយូរនេះឯង តែព្រះអាទិត្យនោះ ក៏លិចទៅអម្បាញ់មិញនេះឯង នេះប្រហែលជាការបណ្ដាលរបស់នាគ របស់ភូត របស់យក្ខ ឬរបស់ទេវតាអង្គណាមួយ ក្នុងទីណា ព្រះអាទិត្យមិនប្រាកដ ក្នុងទីនោះ មនុស្សទាំងឡាយ នឹងកើតបរិវិតក្កថា ព្រះអាទិត្យទើបតែលិចអម្បាញ់មិញនេះឯង ព្រះអាទិត្យមួយនេះរះឡើងភ្លាមទៀត នេះប្រហែលជាការបណ្ដាលរបស់នាគ ភូត យក្ខ និងរបស់ទេវតាអង្គណាមួយ ឬយ៉ាងណាហ្ន៎ បន្ទាប់អំពីនោះ កាលមនុស្សទាំងឡាយពិចារណាដល់ពន្លឺ និងការងងឹត ហើយនាំគ្នាស្វែងរកហេតុផល ដោយគិតថា នេះមានអ្វីជាបច្ច័យហ្ន៎ ព្រះបរមសាស្ដាទ្រង់ចូលនីលកសិណ ផ្សាយងងឹតឲ្យក្រាស់ទៅ ។

សួរថា ព្រោះហេតុអ្វី ។ ព្រោះទ្រង់ផ្សាយទៅ ដើម្បីសត្វទាំងឡាយដែលខ្វល់ខ្វាយប្រកបការងារជាដើមនោះ កើតនូវការតក់ស្លុត ។ លំដាប់នោះព្រះបរមសាស្ដាទ្រង់ជ្រាបថា សត្វទាំងនោះដល់នូវការតក់ស្លុតហើយ ទ្រង់ក៏ចូលឱកាសកសិណសមាបត្តិ ទ្រង់បញ្ចេញព្រះពុទ្ធរស្មីជាពណ៌ស ទ្រង់បណ្ដាលឲ្យទីគ្រប់អន្លើ មានពន្លឺតែមួយ ដោយការបញ្ចេញព្រះរស្មីតែម្យ៉ាងប៉ុណ្ណោះ ដូចវេលាដែលព្រះចន្ទ និងព្រះអាទិត្យរះឡើងព្រមគ្នា ១០០០ ដួង ហើយទ្រង់បញ្ចេញឱកាសនោះ ដោយចំណែកនៃព្រះវរកាយ មានប្រមាណប៉ុនគ្រាប់ល្ង ។ បើបុគ្គលណាបណ្ដាលផែនដីទូទាំងចក្រវាល ឲ្យជាចង្កៀង បណ្ដាលទឹកក្នុងមហាសមុទ្រ ឲ្យជាប្រេង បណ្ដាលភ្នំសិនេរុឲ្យជាប្រឆេះ ដុតលើភ្នំសិនេរុដទៃបាន បុគ្គលនោះ អាចធ្វើឲ្យភ្លឺក្នុងចក្រវាលមួយប៉ុណ្ណោះ មិន

អាចធ្វើទីប្រមាណត្រឹមមួយធ្នាប់ លើសអំពីនោះឲ្យភ្លឺបានឡើយ ។ ឯព្រះតថាគតទ្រង់បញ្ចេញព្រះឱភាស ដោយប្រទេសនៃព្រះសរីរៈប្រមាណប៉ុនគ្រាប់ល្ង គប្បីធ្វើឲ្យលោកធាតុតិសហស្សី និងមហាសហស្សី ឬក្រៃលែងជាងនោះ ឲ្យមានពន្លឺដូចគ្នាបាន ព្រោះថា គុណរបស់ព្រះពុទ្ធមានច្រើនយ៉ាងនេះ ដូច្នេះ ។

បទថា **តំ អាលោកំ សញ្ជានេយ្យុំ** សេចក្តីថា មនុស្សទាំងឡាយឃើញពន្លឺនោះហើយ គិតថា ព្រះអាទិត្យរះឡើងហើយ ងងឹតដ៏ក្រាស់ក៏បាត់ទៅ ព្រោះបុគ្គលណា ឥឡូវនេះ បុគ្គលនោះ ឈរបណ្តាលឲ្យកើតពន្លឺឡើងហើយ ឱ ! អស្ចារ្យពិត អច្ឆរិយបុរស ដូច្នេះហើយ ឈរផ្គងអញ្ជលី ។ បទថា **សទ្ទមនុស្សាវេយ្យ** សេចក្តីថា ព្រះតថាគតញ៉ាំងទេវតា និងមនុស្សទាំងឡាយឲ្យជាក់ចិត្តស្តាប់សំឡេងព្រះធម្មកថា ។ ពិតហើយ បុគ្គលណាបណ្តាលចក្រវាលមួយឲ្យជាស្គរ បណ្តាលមហាប្រឹថពីឲ្យជាស្បែកពាស បណ្តាលភ្នំព្រះសិនេរុឲ្យជាអន្ទូង ហើយទុកលើភ្នំសិនេរុមួយដទៃ ហើយវាយ បុគ្គលនោះ នឹងឲ្យមនុស្សទាំងឡាយបានឮសំឡេងនោះ តែក្នុងចក្រវាលមួយប៉ុណ្ណោះ មិនអាចឲ្យសំឡេងនោះ ហួសទៅខាងមុខ សូម្បីត្រឹមមួយធ្នាប់បានឡើយ ។ ចំណែកព្រះតថាគត ប្រថាប់គង់លើបល្ល័ង្ក ឬតាំង ទ្រង់ញ៉ាំងលោកធាតុតិសហស្សី និងមហាសហស្សី ឬក្រៃលែងជាងនោះ ឲ្យបានឮព្រះសូរសៀងបាន ព្រះតថាគតទ្រង់មានអានុភាពច្រើនយ៉ាងនេះ ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគសម្តែងវិសយក្ខេត្តនោះឯង ដោយទីមាន

ប្រមាណប៉ុណ្ណេះ ដោយប្រការដូចពោលមកនេះ ។

ព្រោះបានស្ដាប់ពុទ្ធសីហនាទនេះ ព្រះថេរៈបានកើតបីតិមានកម្លាំងឡើងខាងក្នុង កាលបន្លឺឧទាន ដោយអំណាចនៃបីតិ ទើបពោលពាក្យជាដើមថា **លាភា វត មេ** ជាលាភរបស់អញហ្ន៎ ដូច្នេះ បណ្ដាបទទាំងនោះ បទថា **យស្ស មេ សត្ថា ឯវំ មហិទ្ធិកោ** សេចក្ដីថា ការបានព្រះសាស្ដាដែលមានឫទ្ធិច្រើនយ៉ាងនេះ របស់អាត្មាអញ ដែលមានសាស្ដាមានឫទ្ធិច្រើនយ៉ាងនេះ ជាលាភផង ជារបស់ដែលបានមកដោយល្អផង ម្យ៉ាងទៀត ព្រះអានន្ទពោលយ៉ាងនេះ សំដៅដល់ថា ការដែលអាត្មាអញមានឱកាសកាន់បាត្រនិងចីវររបស់ព្រះសាស្ដាបែបនេះ ហើយទៅក្ដី មានឱកាសគក់ប្រដាប់ព្រះបាទក្ដី មានឱកាសថ្វាយទឹកលុបព្រះភក្ត្រ និងទឹកស្រង់ក្ដី មានឱកាសបោសបរិវេណព្រះគន្ធកុដិក្ដី មានឱកាសទូលសួរបញ្ហាតាមសង្ស័យ ដែលកើតឡើងហើយក្ដី បានស្ដាប់ធម្មកថាដ៏ពីរោះក្ដី ទាំងអស់នេះ ជាលាភផង ជារបស់ដែលបានមកដោយល្អផង ដូច្នេះ ។ ក្នុងព្រះសូត្រនេះ អ្នកសិក្សាគប្បីជ្រាបភាពដែលព្រះមានព្រះភាគ ជាអ្នកមានឫទ្ធិច្រើន ព្រោះទ្រង់មានឫទ្ធិពោល គឺការធ្វើផងផឹតឲ្យភ្លឺ ធ្វើទេវតា និងមនុស្សឲ្យបានឮព្រះសូរសៀងដ៏ច្រើន ។ ព្រះមានព្រះភាគ មានអានុភាពច្រើន ដោយឫទ្ធិទាំងនោះឯងផ្សាយទៅរឿយៗ ។

បទថា **ឧទាយិ** បានដល់ លោឡុទាយិត្ថេរ ។ បានឮថា ព្រះលោឡុទាយី ចងព្យាបាទក្នុងព្រះថេរៈដោយការប្រាថ្នាដែលតាំងក្នុងកាលមុន

ព្រោះដូច្នោះ ឥឡូវនេះ លុះបានឱកាស ទើបធ្វើការកាច់បំបាក់នូវសេចក្តីជ្រះថ្លារបស់ព្រះថេរៈ ពោលយ៉ាងនេះ ដូចរម្ងត់អណ្តាតប្រទីបដែលកំពុងឆេះ ក្នុងវេលាចប់ពុទ្ធសីហនាទនេះ ដូចយកដំបងវាយគោកំពុងដើរទៅ និងដូចផ្កាប់ថាសដែលមានអាហារពេញ ដូច្នោះ ។ បទថា **ឯវំ វុត្តេ ភគវា** សេចក្តីថា កាលព្រះឧទាយិត្ថេរ ពោលយ៉ាងនេះហើយ ព្រះមានព្រះភាគ កាលទ្រង់ហាមព្រះឧទាយិត្ថេរចាកពាក្យនោះ ទើបត្រាស់ពាក្យថា **មា ហេវំ ឧទាយិ** កុំពោលយ៉ាងនោះឡើយ ឧទាយិ ដូច្នេះ ។ ដូចបុរសដែលប្រាថ្នាប្រយោជន៍ ឈរនៅក្នុងចំណែកម្ខាង ពោលហើយពោលទៀត ជាមួយនឹងបុរសដែលឈរញៀរចំប្រប់ត្រង់មាត់ជ្រោះថា ចូរមកផ្លូវនេះ ចូរមកផ្លូវនេះ ដូច្នេះ ។

បទថា **មហារជ្ជំ** បានដល់ ចក្រពត្តិរាជសម្បត្តិ ។ សួរថា ព្រះសាស្តា ទ្រង់បានធ្វើអានិសង្សដ៏ធំកន្លង នៃសេចក្តីជ្រះថ្លាដែលកើតឡើង ព្រោះព្រះធម្មទេសនាដល់សាវកមួយរូប មិនមានកំណត់មិនមែនឬ ហេតុអ្វីទើបទ្រង់កំណត់អានិសង្សនៃការជ្រះថ្លា ដែលកើតឡើងដល់ព្រះអានន្ទនេះ ព្រោះប្រារព្ធពុទ្ធសីហនាទ ។ ឆ្លើយថា ព្រោះអរិយសាវក មានអត្តភាព មានប្រមាណប៉ុណ្ណោះជាប្រមាណ ។ ព្រោះថា ព្រះសោតាបន្ន សូម្បីមានបញ្ញាមិនរហ័ស បានអត្តភាពក្នុងទេវតា និងមនុស្សទាំងឡាយ ៧ ដងប៉ុណ្ណោះ ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់កំណត់គតិរបស់ព្រះអានន្ទនោះ ទើបបានត្រាស់យ៉ាងនេះ ។ បទថា **ទិដ្ឋេវ ធម្មេ** សេចក្តីថា តាំងនៅក្នុង

អត្ថភាពនេះប៉ុណ្ណោះ ។ បទថា **បរិ និព្វាយិស្សតិ** សេចក្ដីថា នឹងបរិនិព្វានដោយ **អបច្ចយបរិនិព្វាន**។

ព្រះមានព្រះភាគ ទ្រង់កាន់យកកំពូលដោយព្រះនិព្វាន ហើយទ្រង់ញ៉ាំងសីហនាទសូត្រនេះឲ្យចប់ ដោយប្រការដូចពណ៌នាមក ដូច្នេះឯង ៕

**អដ្ឋកថាចូឡនីសូត្រទី ១០ ចប់**

**អានន្ទវគ្គទី ៣ ចប់**

# សុត្តន្តបិដក

## សមណវគ្គទី ៨

### សមណសូត្រទី ១

[ ៨៣ ] ម្នាលភិក្ខុទាំងឡាយ សមណកិច្ចរបស់សមណៈនេះ មាន ៣ យ៉ាង ។ កិច្ច ៣ យ៉ាង តើដូចម្តេច ។ គឺការសមាទាននូវអធិសីលសិក្ខា ១ ការសមាទាននូវអធិចិត្តសិក្ខា ១ ការសមាទាននូវអធិប្បញ្ញាសិក្ខា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាសមណកិច្ចរបស់សមណៈ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះថា យើងនឹងមានសេចក្តីប៉ុនប៉ងឲ្យណាស់ ក្នុងការសមាទាននូវអធិសីលសិក្ខា យើងនឹងមានសេចក្តីប៉ុនប៉ងឲ្យណាស់ ក្នុងការសមាទាននូវអធិចិត្តសិក្ខា យើងនឹងមានសេចក្តីប៉ុនប៉ងឲ្យណាស់ ក្នុងការសមាទាននូវអធិប្បញ្ញាសិក្ខា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។

# អដ្ឋកថា

# សមណវគ្គទី ៤

## សមណសូត្រ

[ ៨៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសមណសូត្រទី ១ នៃសមណវគ្គទី ៤ ដូចតទៅ បទថា **សមណស្ស** ប្រែថា ដែលជារបស់សមណៈ ។ បទថា **សមណករណីយានិ** ប្រែថា កិច្ចដែលសមណៈគប្បីធ្វើ ។ ក្នុងបទថា **អធិសីលសិក្ខាសមាទានំ** ជាដើម មានអធិប្បាយថា ការកាន់យក ហៅថា **សមាទានំ** ការសមាទាន ការកាន់យក ការបំពេញអធិសីលសិក្ខា ឈ្មោះថា **អធិសីលសិក្ខាសមាទានំ ។** ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

ម្យ៉ាងទៀត ក្នុងទីនេះ គប្បីជ្រាបការចែកដូច្នេះថា សីល អធិសីល ចិត្ត អធិចិត្ត បញ្ញា អធិប្បញ្ញា ក្នុងការចែកនោះ សីល ៥ ឈ្មោះថា សីល សីល ១០ ឈ្មោះថា អធិសីល ព្រោះប្រៀបធៀបនឹងសីល ៥ នោះ បរិសុទ្ធិសីល ៤ ឈ្មោះថា អធិសីល ព្រោះប្រៀបធៀបនឹងសីល ១០ នោះ ម្យ៉ាងទៀត លោកិយសីលទាំងអស់ ចាត់ជាសីល លោកុត្តរសីល ចាត់ជាអធិសីល អធិសីលនោះឯង ហៅថា សិក្ខា ព្រោះត្រូវសិក្សា ។ ឯកាមាវចរចិត្ត ឈ្មោះថា ចិត្ត រូបាវចរចិត្ត ឈ្មោះថា អធិចិត្ត ព្រោះប្រៀបធៀបនឹងកាមាវចរចិត្តនោះ អរូបាវចរចិត្ត ឈ្មោះថា អធិចិត្ត ព្រោះប្រៀបធៀបនឹងរូបាវចរចិត្តនោះ ម្យ៉ាងទៀត លោកិយចិត្តទាំងអស់ ចាត់ជាចិត្ត

លោកុត្តរចិត្ត ចាត់ជាអធិចិត្ត ក្នុងបញ្ញាក៏មានន័យដូចគ្នានេះឯង ។ បទថា **តស្មា** សេចក្តីថា ព្រោះហេតុដែលកិច្ច ដែលសមណៈគប្បីធ្វើទាំង ៣ នេះ ។ បទថា **តិព្វោ** បានដល់ ក្រាស់ ។ បទថា **ឆន្ទោ** បានដល់ ការពេញចិត្តក្នុងកុសល គឺភាពជាអ្នកត្រូវការធ្វើ ។

សិក្ខាទាំង ៣ ដែលជាលោកិយ និងលោកុត្តរ ព្រះមានព្រះភាគត្រាស់ក្នុងសូត្រនេះ ដោយប្រការដូចពណ៌នាមក ដូច្នេះឯង ៕

**អដ្ឋកថាសមណសូត្រទី ១ ចប់**

# សុត្តន្តបិដក

## គទ្រភសូត្រទី ២

[ ៨៤ ] ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចលាជាប់តាមហ្វូងគោអំពីក្រោយៗ ថា អញជាគោដែរ អញជាគោដែរ ។ តែសម្បុរលានោះ មិនមែនដូចជាសម្បុររបស់ពួកគោទេ សម្រែកបែបលានោះ ក៏មិនដូចពួកគោទេ ស្នាមជើងបែបលានោះ ក៏មិនដូចពួកគោទេ ។ លានោះ ជាប់តាមហ្វូងគោអំពីក្រោយៗ ថា អញជាគោដែរ អញជាគោដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពួកខ្លះ ក្នុងសាសនានេះ ជាប់តាមភិក្ខុសង្ឃអំពីក្រោយៗ ថា អាត្មាអញជាភិក្ខុដែរ អាត្មាអញជាភិក្ខុដែរ ។ តែសេចក្តីប៉ុនប៉ងបែបនោះ របស់ភិក្ខុនោះ

មិនមានក្នុងការសមាទាននូវអធិសីលសិក្ខា ដូចជាពួកភិក្ខុដទៃទេ សេចក្តីប៉ុនប៉ងបែបនោះ មិនមានក្នុងការសមាទាននូវអធិចិត្តសិក្ខា ដូចជាពួកភិក្ខុដទៃទេ សេចក្តីប៉ុនប៉ងបែបនោះ មិនមានក្នុងការសមាទាននូវអធិប្បញ្ញាសិក្ខា ដូចជាពួកភិក្ខុដទៃទេ ។ ភិក្ខុនោះ គ្រាន់តែជាប់តាមភិក្ខុសង្ឃអំពីក្រោយៗ ថា អាត្មាអញជាភិក្ខុដែរ អាត្មាអញជាភិក្ខុដែរប៉ុណ្ណោះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា យើងនឹងមានសេចក្តីប៉ុនប៉ងឲ្យណាស់ ក្នុងការសមាទាននូវអធិសីលសិក្ខា យើងនឹងមានសេចក្តីប៉ុនប៉ងឲ្យណាស់ ក្នុងការសមាទាននូវអធិចិត្តសិក្ខា យើងនឹងមានសេចក្តីប៉ុនប៉ងឲ្យណាស់ ក្នុងការសមាទាននូវអធិប្បញ្ញាសិក្ខា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។

# អដ្ឋកថា

## គទ្រភសូត្រ

[ ៨៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងគទ្រភសូត្រទី ២ ដូចតទៅនេះ បទថា **បិដ្ឋិតោ បិដ្ឋិតោ** ប្រែថា ខាងក្រោយៗ ។ បទថា **អហម្បិ អម្ពា អហម្បិ អម្ពា** សេចក្តីថា មេគោស្រែកថា **អហម្បិ អម្ពា** លាក៏ស្រែកថា **អហម្បិ គាវី** ដូច្នោះ ។ បទថា **សេយ្យថាបិ គុន្នំ** សេចក្តីថា របស់មេគោទាំងឡាយ

យ៉ាងណា ពិតហើយ គោទាំងឡាយមានពណ៌ ខ្មៅខ្លះ មានពណ៌ក្រហមខ្លះ មានពណ៌សជាដើមខ្លះ តែលាមិនមានពណ៌ដូច្នោះ ពណ៌យ៉ាងណា សំឡេងក្តី ស្នាមជើងក្តី ក៏ដូចគ្នាដូច្នោះឯង ។

បទដ៏សេស មានអត្ថងាយយល់ទាំងអស់ហើយ ក្នុងសូត្រនេះ ព្រះមានព្រះភាគក៏ត្រាស់សិក្ខា ៣ លាយឡំគ្នានោះឯង ។៚

**អដ្ឋកថា គទ្រភសូត្រទី ២ ចប់**

# សុត្តន្តបិដក

## ខេត្តសូត្រទី ៣

[ ៨៥ ] ម្នាលភិក្ខុទាំងឡាយ កិច្ចដែលត្រូវធ្វើមុនរបស់គហបតីអ្នកភ្ជួរនេះមាន ៣ យ៉ាង ។ កិច្ច ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គហបតីអ្នកភ្ជួរក្នុងលោកនេះ មុនដំបូងត្រូវភ្ជួររាស់ស្រែឲ្យល្អ លុះភ្ជួររាស់ស្រែឲ្យល្អដំបូងហើយ ក៏សាបព្រោះពូជតាមកាលដ៏គួរ លុះសាបព្រោះពូជ ក្នុងកាលដ៏គួរហើយ ក៏បញ្ចូលទឹកខ្លះ បញ្ចេញទឹកខ្លះ តាមសម័យដ៏គួរ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាកិច្ចដែលត្រូវធ្វើមុនរបស់គហបតីអ្នកភ្ជួរ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ បុព្វកិច្ចរបស់ភិក្ខុនេះ ក៏មាន ៣ យ៉ាងដូច្នោះដែរ ។ កិច្ច ៣ យ៉ាង តើដូចម្តេច ។ គឺការសមាទានទូវអធិសីលសិក្ខា ១ ការសមាទាន

នូវអធិចិត្តសិក្ខា ១ ការសមាទាននូវអធិប្បញ្ញាសិក្ខា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាបុព្វកិច្ច ៣ យ៉ាងរបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះថា យើងនឹងមានសេចក្តីប៉ុនប៉ងឲ្យណាស់ ក្នុងការសមាទាននូវអធិសីលសិក្ខា យើងនឹងមានសេចក្តីប៉ុនប៉ងឲ្យណាស់ ក្នុងការសមាទាននូវអធិចិត្តសិក្ខា យើងនឹងមានសេចក្តីប៉ុនប៉ងឲ្យណាស់ ក្នុងការសមាទាននូវអធិប្បញ្ញាសិក្ខា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។

# អដ្ឋកថា

## ខេត្តសូត្រ

[ ៨៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងខេត្តសូត្រទី ៣ ដូចតទៅនេះ បទថា **បដិកច្ចេវ** ប្រែថា មុននោះឯង ។ បទថា **សុកដ្ឋំ ករោតិ** សេចក្តីថា អ្នកស្រែធ្វើស្រែឲ្យជាការភ្ជួរល្អហើយដោយនង្គ័ល ។ បទថា **សុមតិកតំ** សេចក្តីថា ធ្វើស្រែឲ្យមានផ្ទៃដីរៀបរយ គឺរាបស្មើ ។ បទថា **កាលេន** បានដល់ តាមកាលដែលគួរព្រោះ ។ បទដ៏សេសងាយយល់ទាំងអស់ហើយ ក្នុងសូត្រនេះ ព្រះមានព្រះភាគក៏ត្រាស់សិក្ខា ៣ លាយឡំគ្នានោះឯង ៕

**អដ្ឋកថា ខេត្តសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## វជ្ជិបុត្តសូត្រទី ៤

[ ៨៦ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារសាលា នាព្រៃមហាវ័ន ជិតក្រុងវេសាលី ។ គ្រានោះ វជ្ជិបុត្តកភិក្ខុមួយរូប ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះវជ្ជិបុត្តកភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សិក្ខាបទ ១៥០ ដែលសម្រេចហើយនេះ មកកាន់ឧទ្ទេសរាល់កន្លះខែ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនអាចនឹងសិក្សា ក្នុងសិក្ខាបទទាំងនុ៎ះបានទេ ។ ម្នាលភិក្ខុ ចុះអ្នកអាចសិក្សាក្នុងសិក្ខា ៣ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ បានឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គអាចនឹងសិក្សាក្នុងសិក្ខា ៣ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។ ម្នាលភិក្ខុ បើដូច្នោះ ក្នុងសាសនានេះ អ្នកចូរសិក្សាក្នុងសិក្ខា ៣ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ចុះ ម្នាលភិក្ខុ កាលណាបើអ្នកនឹងសិក្សានូវអធិសីលផង សិក្សានូវអធិចិត្តផង សិក្សានូវអធិប្បញ្ញាផង កាលបើអ្នកកំពុងសិក្សានូវអធិសីលផង សិក្សានូវអធិចិត្តផង សិក្សានូវអធិប្បញ្ញាផង អ្នកគង់នឹងបានលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈ ( មិនខាន ) ព្រោះតែការលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈ អ្នកនោះនឹងមិនធ្វើអំពើដែលជាអកុសល ទាំងមិនសេពនូវ

អំពើដែលលាមក ។ លុះសម័យតមក ភិក្ខុនោះក៏សិក្សាអធិសីលផង សិក្សាអធិចិត្តផង សិក្សាអធិប្បញ្ញាផង ។ កាលភិក្ខុនោះកំពុងសិក្សាអធិសីលផង សិក្សាអធិចិត្តផង សិក្សាអធិប្បញ្ញាផង ភិក្ខុនោះក៏បានលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈ ព្រោះតែការលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈ ភិក្ខុនោះ មិនបានធ្វើអំពើដែលជាអកុសល ទាំងមិនបានសេពនូវអំពើដែលលាមកឡើយ ។

# អដ្ឋកថា

## វជ្ជិបុត្តសូត្រ

[ ៨៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវជ្ជីបុត្តសូត្រទី ៤ ដូចតទៅនេះ បទថា **វជ្ជិបុត្តកោ** បានដល់ កូនរបស់រាជត្រកូលវជ្ជី ។ បទថា **ទិយឌ្ឍសិក្ខាបទសតំ** បានដល់ សិក្ខាបទ ១៥០ ។ ភិក្ខុវជ្ជីបុត្រសំដៅយកសិក្ខាបទដែលទ្រង់បញ្ញត្តក្នុងសម័យនោះ ទើបពោលពាក្យនេះថា **ទិយឌ្ឍសិក្ខាបទសតំ** ។ បានឮថា ភិក្ខុនោះដល់ព្រមដោយអាជ្ជវធម៌ ជាអ្នកមាននិស្ស័យស្មោះត្រង់ មិនវេចវេរ ដូច្នោះ ទើបលោកគិតថា អាត្មាអញអាចរក្សាសិក្ខាបទចំនួនប៉ុណ្ណោះបានឬទេ ដូច្នេះហើយ ក្រាបទូលឲ្យព្រះសាស្តាទ្រង់ជ្រាប ។ បទថា **សក្កោមហំ** កាត់បទជា **សក្កោមិ អហំ** ប្រែថា ខ្ញុំអាច ។

បានឮថា ភិក្ខុនោះ សម្គាល់ថា កាលអាត្មាអញសិក្សាក្នុងសិក្ខាបទចំនួនប៉ុណ្ណោះបាន ក៏មិនធុនចិត្តដែលនឹងសិក្សាក្នុងត្រៃសិក្ខា ទើបក្រាបទូលយ៉ាងនោះ ។ លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់លើកសិក្ខា ២ ទៀត ក្នុងលំដាប់ដែលខ្ពស់ឡើង ដល់ភិក្ខុដែលមិនអាចសិក្សាក្នុងសិក្ខា ១ ទើបត្រាស់ពាក្យថា **តស្មា តិហ ត្វំ ភិក្ខុ** ជាដើម ប្រៀបដូចបុគ្គលចងបាច់ស្មៅ ១០០ បាច់ ដាក់លើក្បាលរបស់បុគ្គលដែលមិនអាចលើកបាច់ស្មៅ ៥០ ឡើងបាន ដូច្នោះ ។

បានឮថា ក្នុងកោហាណជនបទ អ្នកជនបទម្នាក់ ឈ្មោះឧត្តរៈ នៅក្នុងកេរបាសាណវិហារ សម័យតមក ភិក្ខុកំលោះទាំងឡាយ ពោលនឹងបុរសនោះថា ឧត្តរៈ រោងភ្លើងត្រូវភ្លៀងលិចស្រោច សូមអ្នកធ្វើស្មៅឲ្យសមគួរហើយឲ្យចុះ ដូច្នេះ ហើយនាំបុរសនោះទៅព្រៃ ចងបាច់ស្មៅដែលឧត្តរៈនោះប្រូតហើយ ឲ្យជាបាច់ៗ ហើយពោលថា នែឧត្តរៈ អ្នកអាចទូលស្មៅ ៥០ បាច់បានឬទេ ។ ឧត្តរៈនោះពោលថា ខ្ញុំមិនអាចទេ លោកម្ចាស់ ។ ភិក្ខុកំលោះសួរថា ចុះបើ ៨០ បាច់ អ្នកអាចឬទេ បុរសនោះឆ្លើយថា មិនអាចទេ លោកម្ចាស់ ។ ភិក្ខុកំលោះសួរថា ចុះ ១០០ បាច់ ដែលចងរួមគ្នាតែមួយ អ្នកអាចឬទេ ឧត្តរៈឆ្លើយថា ខ្ញុំនឹងទូលទៅបាន លោកម្ចាស់ ទើបភិក្ខុទាំងឡាយចងបាច់ស្មៅ ១០០ ចូលគ្នា ហើយលើកដាក់លើក្បាលបុរសនោះ ។ ឧត្តរៈនោះលើកឡើងហើយ អត់ធ្មត់ក្នុងចិត្ត ទៅទម្លាក់ក្បែររោងភ្លើង ។ គ្រានោះ ទើបភិក្ខុទាំងឡាយពោលថា តើហត់ឬទេឧត្តរៈ ។ នាយ

ឧត្តរៈឆ្លើយថា ហត់ណាស់លោកម្ចាស់ ពួកភិក្ខុកំលោះបោកបញ្ឆោតខ្ញុំ ខ្ញុំមិនអាចទូលបាច់ស្មៅ ១០០ នេះបានទេ តែលោកប្រាប់ថា អ្នកចូរទូលទៅ តែ ៥០ បាច់ទេ ភិក្ខុទាំងឡាយពោលថា មែនហើយឧត្តរៈ ពួកភិក្ខុកំលោះបោកអ្នក គប្បីជ្រាបឧបមេយ្យនេះយ៉ាងនោះ ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់សិក្ខា ៣ លាយឡំគ្នា ៕

## អដ្ឋកថា វជ្ជិបុត្តសូត្រទី ៤ ចប់

# សុត្តន្តបិដក

## បឋមសេក្ខសូត្រទី ៥

[ ៨៧ ] គ្រានោះ ភិក្ខុមួយរូបចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគទ្រង់សម្ដែងថា ភិក្ខុជាសេក្ខៈ សេក្ខៈ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាសេក្ខៈ តើដោយហេតុដូចម្ដេច ។ ម្នាលភិក្ខុ ព្រោះតែភិក្ខុនៅសិក្សា ហេតុនោះ បានជាតថាគតហៅថា សេក្ខៈ ។ នៅសិក្សាអ្វី ។ ម្នាលភិក្ខុ នៅសិក្សាអធិសីលផង នៅសិក្សាអធិចិត្តផង នៅសិក្សាអធិប្បញ្ញាផង ហេតុនោះ បានជាតថាគតហៅថា

សេក្ខៈ ។

មគ្គញ្ញាណជាបឋម ក្នុងការអស់ទៅនៃកិលេស រមែង
កើតឡើង ដល់សេក្ខបុគ្គល នៅកំពុងសិក្សា ជាអ្នក
ប្រតិបត្តិនូវផ្លូវដ៏ត្រង់ អរហត្តផល តែងកើតឡើង
ជាលំដាប់ អំពីមគ្គញ្ញាណទី ៤ នោះ តពីនោះទៅ
បច្ចវេក្ខណញ្ញាណ ក្នុងការអស់ទៅនៃសំយោជនៈក្នុង
ភព រមែងមានដល់បុគ្គល ដែលមានចិត្តរួចស្រឡះ
ហើយ ដោយអរហត្តផលវិមុត្តិ ជាតាទិបុគ្គល ( អ្នក
មិនញាប់ញ័រដោយលោកធម៌ ) ថា ការរួចស្រឡះ
របស់អាត្មាអញ មិនបានកម្រើកឡើយ ។

# អដ្ឋកថា

## បឋមសេក្ខសូត្រ

[ ៨៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមសេក្ខសូត្រទី ៥ ដូចតទៅ បទថា **ឧជុមគ្គានុសារិនោ** សេចក្ដីថា អរិយមគ្គ ហៅថា **ឧជុមគ្គ** សេក្ខបុគ្គលរឭកដល់ គឺប្រព្រឹត្តទៅកាន់ផ្លូវត្រង់នោះ ។ បទថា **ខយស្មឹ បឋមំ ញាណំ** សេចក្ដីថា មគ្គញ្ញាណនោះឯងកើតឡើងមុន ។ ពិតហើយ មគ្គ ឈ្មោះថា **ខយ** នៃកិលេសទាំងឡាយ ព្រោះផុតក័យចាកកិលេស ញាណដែលសម្ប-

យុត្តដោយមគ្គនោះ ឈ្មោះថា **១យញ្ញាណ** ។ បទថា **តតោ អញ្ញា អនន្តរា** សេចក្តីថា បញ្ញាជាគ្រឿងដឹងទូទៅ រមែងកើតឡើងបន្ទាប់អំពីមគ្គញាណទី ៤ នោះ អធិប្បាយថា អរហត្តផល រមែងកើតឡើង ។ បទថា **អញ្ញាវិមុត្តស្ស** បានដល់ រួចផុតហើយ ដោយវិមុត្តិ គឺអរហត្តផល ។ បទថា **ញាណំ វេ ហោតិ** បានដល់ មានបច្ចវេក្ខណញ្ញាណ ។

ព្រះមានព្រះភាគត្រាស់សេក្ខបុគ្គល ៧ ពួកក្នុងសូត្រផង ក្នុងគាថាទាំងឡាយផង តែទ្រង់សម្តែងព្រះខីណាស្រពក្នុងទីបញ្ចប់ ។៚

**អដ្ឋកថា បឋមសេក្ខសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ទុតិយសេក្ខសូត្រទី ៦

[ ៨៨ ] ម្នាលភិក្ខុទាំងឡាយ សិក្ខាបទ ១៥០ ដែលសម្រេចហើយនេះ តែងមកកាន់ឧទ្ទេស រាល់កន្លះខែ ដែលជាទីសិក្សារបស់ពួកកុលបុត្រអ្នកប្រាថ្នានូវប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ សិក្ខានេះមាន ៣ ដែលជាទីប្រជុំចុះរបស់សិក្ខាបទ ១៥០ ទាំងអស់នុ៎ះ ។ សិក្ខា ៣ តើដូចម្តេច ។ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងសិក្ខា ៣ ដែលជាទីប្រជុំចុះរបស់សិក្ខាបទទាំងអស់នុ៎ះ ។ ម្នាលភិក្ខុទាំង-

ឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ធ្វើល្មមប្រមាណក្នុងសមាធិ ធ្វើល្មមប្រមាណក្នុងបញ្ញា ភិក្ខុនោះនៅត្រូវសិក្ខាបទតូច និងតូចបន្ទាប់ទាំងនោះខ្លះ នៅចេញចាក ( អាបត្តិ ) ខ្លះ ។ ហេតុនោះនឹងទៅជាអ្វី ។ ម្នាលភិក្ខុទាំងឡាយ តថាគតនៅតែមិនឲ្យឈ្មោះថា ជាអភព្វក្នុងការត្រូវអាបត្តិ ហើយចេញចាកអាបត្តិទាំះទេ ។ ពួកសិក្ខាបទណា ជាខាងដើមនៃមគ្គព្រហ្មចារ្យ សមគួរដល់មគ្គព្រហ្មចារ្យទី ៤ ភិក្ខុនោះ ជាអ្នកមានសីលជាប់មិនដាច់ផង មានសីលតាំងនៅផង សមាទានសិក្សាក្នុងសិក្ខាបទទាំងនោះ ។ ភិក្ខុនោះនៅតែបានសោតៈ ព្រោះការអស់សំយោជនៈ ៣ មានសភាពជាអ្នកមិនបានធ្លាក់ចុះក្នុងអបាយ ជាអ្នកទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល ធ្វើល្មមប្រមាណក្នុងសមាធិ ធ្វើល្មមប្រមាណក្នុងបញ្ញា ភិក្ខុនោះ នៅតែត្រូវសិក្ខាបទតូច និងតូចដោយលំដាប់ខ្លះ ចេញចាកខ្លះ ។ ហេតុនោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតនៅតែមិនឲ្យឈ្មោះថា ជាអភព្វ ក្នុងការត្រូវ និងការចេញទាំះទេ ។ ពួកសិក្ខាបទណាជាខាងដើមនៃមគ្គព្រហ្មចារ្យ សមគួរដល់មគ្គព្រហ្មចារ្យ ឲ្យតែភិក្ខុនោះមានសីលខ្ជាប់ខ្ជួនផង មានសីលស្ថិតស្ថេរផង សមាទានសិក្សាក្នុងសិក្ខាបទទាំងនោះ ។ ភិក្ខុនោះនៅតែបានជាសកទាគាមី ព្រោះអស់សញ្ញោជនៈ ៣ ព្រោះតែស្រាលស្តើងរាគៈ ទោសៈ មោហៈ មកកាន់លោកនេះម្តងទៀតក៏ធ្វើនូវទីបំផុតទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល

ធ្វើឲ្យបរិបូណ៌ក្នុងសមាធិ ធ្វើល្មមប្រមាណក្នុងបញ្ញា ភិក្ខុនោះ នៅតែត្រូវសិក្ខាបទតូច និងតូចបន្ទាប់នោះខ្លះ ចេញចាកខ្លះ ។ ហេតុនោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតនៅតែមិនឲ្យឈ្មោះថាជាអភព្វ ព្រោះការត្រូវ និងការចេញចាកនុ៎ះទេ ។ ពួកសិក្ខាបទណាជាខាងដើមនៃមគ្គព្រហ្មចារ្យ សមគួរដល់មគ្គព្រហ្មចារ្យ ភិក្ខុនោះមានសីលខ្ជាប់ខ្ជួនផង មានសីលស្ថិតស្ថេរផង សមាទានសិក្សាក្នុងសិក្ខាបទទាំងនោះ ។ ភិក្ខុនោះជាឱបបាតិកៈ ព្រោះអស់សំយោជនៈ ជាចំណែកខាងក្រោម ៥ បរិនិព្វាន ក្នុងស្ថានសុទ្ធាវាសនោះទៀងតែមិនត្រឡប់ មកពីលោកនោះវិញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល ធ្វើឲ្យបរិបូណ៌ក្នុងសមាធិ ធ្វើឲ្យបរិបូណ៌ក្នុងបញ្ញា ភិក្ខុនោះនៅតែត្រូវសិក្ខាបទតូច និងតូចបន្ទាប់នោះខ្លះ ចេញចាកខ្លះ ។ ហេតុនោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតនៅតែមិនទាន់ឲ្យឈ្មោះថាជាអភព្វ ព្រោះការត្រូវ និងការចេញចាកនុ៎ះទេ ។ ពួកសិក្ខាបទណាជាខាងដើមនៃមគ្គព្រហ្មចារ្យ សមគួរដល់មគ្គព្រហ្មចារ្យ ភិក្ខុនោះមានសីលខ្ជាប់ខ្ជួនផង មានសីលស្ថិតស្ថេរផង សមាទានសិក្សាក្នុងសិក្ខាបទទាំងនោះ ។ ភិក្ខុនោះនៅតែធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ក្រៃលែងខ្លួនឯងក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកធ្វើបានដោយអន្ទើរមែងសម្រេចមគ្គផលដោយអន្ទើ បុគ្គលជាអ្នកធ្វើឲ្យបរិបូណ៌ រមែងសម្រេចមគ្គផលបរិបូណ៌ ម្នាលភិក្ខុទាំងឡាយ តថាគតនៅតែសម្តែងថា សិក្ខាបទ

ទាំងឡាយ មិនមែនឥតអំពើឡើយ ។

# អដ្ឋកថា

## ទុតិយសេក្ខសូត្រ

[ ៨៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយសេក្ខសូត្រទី ៦ ដូចតទៅនេះ បទថា **អត្ថកាមា** បានដល់ កុលបុត្រទាំងឡាយដែលសង្ឃឹមប្រយោជន៍ដល់ខ្លួន ។ បទថា **យត្ថេតំ សព្ពំ សមោធានំ គច្ឆតិ** សេចក្តីថា សិក្ខាបទទាំង ១៥០ នេះ ដល់នូវការសង្គ្រោះចូលក្នុងសិក្ខាបទពួកណា ។ បទថា **បរិបូរការី ហោតិ** សេចក្តីថា កិក្ខុដែលជាអ្នកមានប្រក្រតីធ្វើឲ្យបរិបូណ៌ ។ បទថា **មត្តសោការី** សេចក្តីថា ជាអ្នកមានប្រក្រតីធ្វើល្មមប្រមាណ អធិប្បាយថា មិនអាចធ្វើបានទាំងអស់ ។ បទថា **ខុទ្ទានុខុទ្ទកានិ** បានដល់ សិក្ខាបទដ៏សេស វៀរបារាជិក ៤ ។ ម្យ៉ាងទៀត ក្នុងបទថា **ខុទ្ទានុខុទ្ទកានិ** នោះ អធិប្បាយថា សង្ឃាទិសេស ឈ្មោះថា ខុទ្ទកសិក្ខាបទ ថុល្លច្ច័យ ឈ្មោះថា អនុខុទ្ទកសិក្ខាបទ ម្យ៉ាងទៀត ថុល្លច្ច័យ ឈ្មោះថា ខុទ្ទកសិក្ខាបទ បាចិត្តិយៈ ឈ្មោះថា អនុខុទ្ទកសិក្ខាបទ ។ ម្យ៉ាងទៀត បាចិត្តិយៈ ឈ្មោះថា ខុទ្ទកសិក្ខាបទ បាដិទេសនីយៈ ទុក្កដ និងទុព្ភាសិត ឈ្មោះថា អនុខុទ្ទកសិក្ខាបទ ។ តែអាចារ្យអ្នកជំនាញក្នុងអង្គុត្តរមហានិកាយ ពោលថា សិក្ខាបទដ៏សេសទាំង

អស់ វៀរបារាជិក ៤ ឈ្មោះថា ខុទ្ទកានុខុទ្ទកសិក្ខាបទ ។

ក្នុងបទថា **តានិ អាបជ្ជតិបិ វុដ្ឋាតិបិ** នេះ មានអធិប្បាយថា ព្រះ-ទីណាស្រពមិនត្រូវអាបត្តិ ដែលជាលោកវជ្ជៈឡើយ តែត្រូវអាបត្តិដែលជាបណ្ណត្តិវជ្ជៈ កាលត្រូវក៏ត្រូវដោយផ្លូវកាយខ្លះ ផ្លូវវាចាខ្លះ ផ្លូវចិត្តខ្លះ គឺកាលត្រូវផ្លូវកាយ ក៏ត្រូវកុដិការសិក្ខាបទ សហសេយ្យកសិក្ខាបទជាដើម កាលត្រូវផ្លូវវាចា ក៏ត្រូវសញ្ចរិត្តសិក្ខាបទ និងបទសោធម្មសិក្ខាបទជាដើម កាលត្រូវអាបត្តិផ្លូវចិត្ត ក៏ត្រូវព្រោះទទួលរូបិយៈ ។ ក្នុងបទដ៏សេសក៏មានន័យនេះឯង ។ បទថា **ន ហិ មេត្ថ ភិក្ខវេ អភព្វតា វុត្តា** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ក្នុងទីនេះ តថាគតមិនបានពោលថា ព្រះអរិយបុគ្គល មិនគួរទាំងក្នុងការត្រូវ និងការចេញចាកអាបត្តិបែបនេះ ។

បទថា **អាទិព្រហ្មចរិយកានិ** សេចក្តីថា សិក្ខាបទដែលជាមហាសីល ៤ ដែលជាខាងដើមនៃមគ្គព្រហ្មចរិយៈ ។ បទថា **ព្រហ្មចរិយសារុប្បានិ** សេចក្តីថា សិក្ខាបទដែលជាមហាសីលនោះឯង ព្រោះសមគួរ គឺសមគួរដល់មគ្គព្រហ្មចរិយៈទី ៤ ។ បទថា **តត្ថ** បានដល់ ក្នុងសិក្ខាបទទាំងនោះ ។

បទថា **ធុវសីលោ** ប្រែថា ជាអ្នកមានសីលជាប្រចាំ ។ បទថា **ឋិត-សីលោ** ប្រែថា ដែលមានសីលមាំទាំ ។ បទថា **សោតាបន្នោ** បានដល់ បុគ្គលចូលដល់ផលដោយមគ្គ ដែលហៅថា **សោត** ។ បទថា **អវិនិបាត-ធម្មោ** បានដល់ មានការមិនធ្លាក់ទៅក្នុងអបាយ ៤ ជាសភាវៈ ។ បទថា **និយតោ** បានដល់ បុគ្គលទៀងដោយគុណធម៌ជាគ្រឿងកំណត់ គឺសោតា-

បត្តិមគ្គ ។ បទថា **សម្ពោធិបរាយនោ** បានដល់ មានបញ្ញាជាគ្រឿងត្រាស់ដឹងព្រម គឺមគ្គ ៣ ខាងលើ ដែលប្រព្រឹត្តទៅខាងមុខ ។

បទថា **តនុត្តា** ប្រែថា ព្រោះកិលេសទាំងឡាយស្រាលស្តើង ។ អធិប្បាយថា កិលេសទាំងឡាយ មានរាគៈជាដើម របស់ព្រះសកទាគាមីស្រាលស្តើង មិនក្រាស់ ប្រៀបដូចស្រទាប់ពពក និងប្រៀបដូចស្លាបរុយ ។

បទថា **ឱរម្ភាគិយានំ** បានដល់ ប្រព្រឹត្តទៅក្នុងចំណែកទាប ។ បទថា **សញ្ញោជនានំ** បានដល់ សំយោជនៈ ។ បទថា **បរិក្ខយា** ប្រែថា ព្រោះការអស់ទៅ ។ បទថា **ឱបបាតិកោ ហោតិ** បានដល់ ជាអ្នកកើតឡើង ។ បទថា **តត្ថ បរិនិព្វាយី** បានដល់ មានការមិនចុះមកកើតក្នុងភពជាន់ទាប នឹងបរិនិព្វានក្នុងភពជាន់ខ្ពស់នោះឯង ។ បទថា **អនាវត្តិធម្មោ** បានដល់ មានការមិនវិលត្រឡប់មកទៀតជាធម្មតា ដោយអំណាចកំណើតនិងគតិ ។

ក្នុងបទថា **បទេសំ បទេសការី** ជាដើម មានអធិប្បាយថា ព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមី ឈ្មោះថា ជាបុគ្គលមានប្រក្រតីធ្វើបានដោយចំណែកខ្លះ គឺព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគមីនោះ ធ្វើត្រៃសិក្ខាឲ្យសម្បូរបានដោយចំណែកខ្លះប៉ុណ្ណោះ ចំណែកព្រះអរហន្ត ឈ្មោះថា ជាអ្នកមានប្រក្រតីធ្វើឲ្យបរិបូណ៌ គឺព្រះអរហន្តនោះធ្វើត្រៃសិក្ខាឲ្យសម្បូរបានបរិបូណ៌នោះឯង ។ បទថា **អវញ្ឈានិ** គឺមិនទទេ អធិប្បាយថា មានផល មានអានិសង្ស ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគ

ក៏ត្រាស់សិក្ខា ៣ លាយឡំគ្នា ។

## អដ្ឋកថា ទុតិយសេក្ខសូត្រទី ៦ ចប់

# សុត្តន្តបិដក

## តតិយសេក្ខសូត្រទី ៧

[ ៨៩ ] ម្នាលភិក្ខុទាំងឡាយ សិក្ខាបទ ១៥០ ដែលសម្រេចហើយនេះ តែងមកកាន់ឧទ្ទេស រាល់កន្លះខែ ដែលជាទីសិក្សារបស់ពួកកុលបុត្រអ្នកប្រាថ្នានូវប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ សិក្ខានេះមាន ៣ ដែលជាទីប្រជុំចុះរបស់សិក្ខាបទទាំងអស់នុ៎ះ ។ សិក្ខា ៣ តើអ្វីខ្លះ ។ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងសិក្ខា ៣ ដែលជាទីប្រជុំចុះ នៃសិក្ខាបទទាំងអស់នុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីល ធ្វើល្មមប្រមាណក្នុងសមាធិ ភិក្ខុនោះនៅតែត្រូវសិក្ខាបទតូច និងតូចបន្ទាប់នោះខ្លះ ចេញចាកខ្លះ ។ ហេតុនោះតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនទាន់ឲ្យឈ្មោះថា ជាអភព្វក្នុងហេតុនុ៎ះទេ ។ ពួកសិក្ខាបទណា ជាខាងដើមនៃមគ្គព្រហ្មចារ្យ សមគួរដល់មគ្គព្រហ្មចារ្យ ឲ្យតែភិក្ខុនោះមានសីលទៀងទាត់ ស្ថិតស្ថេរ សមាទានសិក្សាក្នុងសិក្ខាបទទាំងនោះ ។ ភិក្ខុនោះ គង់បានជាសត្តក្ខត្តុបរមៈ ព្រោះការអស់រលីង

នៃសញ្ញោជនៈ ៣ ត្រាច់រង្គាត់អន្ទោលទៅ ក្នុងទេវលោក និងមនុស្សលោក យ៉ាងច្រើនត្រឹម ៧ ជាតិ ក៏ធ្វើនូវទីបំផុតទុក្ខបាន ។ ភិក្ខុនោះជាកោលង្កោលៈ ព្រោះអស់សញ្ញោជនៈ ៣ ត្រាច់រង្គាត់ អន្ទោលទៅកាន់ត្រកូល ២ ឬ ៣ ក៏ធ្វើនូវទីបំផុតទុក្ខបាន ។ ភិក្ខុនោះជាឯកពីជី ព្រោះអស់សញ្ញោជនៈ ៣ កើតក្នុងភពជារបស់មនុស្សតែម្តងប៉ុណ្ណោះ ក៏ធ្វើនូវទីបំផុតទុក្ខបាន ។ ភិក្ខុនោះជាសកទាគាមី ព្រោះអស់សំយោជនៈ ៣ ព្រោះស្រាលស្តើងរាគៈ ទោសៈ មោហៈ មកកាន់លោកនេះតែម្តងទៀត ក៏ធ្វើនូវទីបំផុតទុក្ខបាន ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល ធ្វើឲ្យបរិបូណ៌ក្នុងសមាធិ ធ្វើល្មមប្រមាណក្នុងបញ្ញា ភិក្ខុនោះ នៅត្រូវសិក្ខាបទតូចនិងតូចបន្ទាប់ខ្លះ ចេញចាកខ្លះ ។ ហេតុនោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ តថាគតមិនទាន់ឲ្យឈ្មោះថា ជាអភព្វក្នុងហេតុនុ៎ះទេ ។ ពួកសិក្ខាបទណា ជាខាងដើមនៃមគ្គព្រហ្មចារ្យ សមគួរដល់មគ្គព្រហ្មចារ្យ ភិក្ខុនោះមានសីលទៀងទាត់ ស្ថិតស្ថេរ សមាទានសិក្សាក្នុងសិក្ខាបទទាំងនោះ ។ ភិក្ខុនោះជាឧទ្ធំសោតអកនិដ្ឋគាមី ព្រោះអស់សញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។ ភិក្ខុនោះជាសសង្ខារបរិនិព្វាយី ព្រោះអស់សញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។ ភិក្ខុនោះ ជាអសង្ខារបរិនិព្វាយី ព្រោះអស់សញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។ ភិក្ខុនោះ ជាឧបហច្ចបរិនិព្វាយី ព្រោះអស់សញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។ ភិក្ខុនោះ ជាអន្តរាបរិនិព្វាយី ព្រោះអស់សញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនា

នេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល ធ្វើឲ្យបរិបូណ៌ក្នុងសមាធិ ធ្វើឲ្យបរិបូណ៌ក្នុងបញ្ញា ភិក្ខុនោះនៅត្រូវសិក្ខាបទតូច និងតូចបន្ទាប់ទាំងនោះខ្លះ ចេញចាកខ្លះ ។ ហេតុនោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនទាន់ឲ្យឈ្មោះថាជាអភព្វក្នុងហេតុនុ៎ះទេ ។ ពួកសិក្ខាបទណា ជាខាងដើមនៃមគ្គព្រហ្មចារ្យ សមគួរដល់មគ្គព្រហ្មចារ្យ ឲ្យតែភិក្ខុនោះមានសីលខ្ជាប់ខ្ជួន មានសីលស្ថិតស្ថេរ សមាទានសិក្សាក្នុងសិក្ខាបទទាំងនោះ ។ ភិក្ខុនោះ គង់បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ក្រៃលែងខ្លួនឯងក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកធ្វើបានដោយអន្លើ រមែងញ៉ាំងមគ្គផលដោយអន្លើឲ្យសម្រេច បុគ្គលអ្នកធ្វើឲ្យបរិបូណ៌ រមែងញ៉ាំងមគ្គផលឲ្យសម្រេចបានបរិបូណ៌ ដោយប្រការដូច្នេះឯង ម្នាលភិក្ខុទាំងឡាយ តថាគតនៅតែសម្តែងថា សិក្ខាបទទាំងឡាយ មិនមែនឥតអំពើទេ ។

# អដ្ឋកថា

## តតិយសេក្ខសូត្រ

[ ៨៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតតិយសេក្ខសូត្រទី ៧ ដូចតទៅនេះ បទថា **កោលង្កោលោ** បានដល់ ព្រះសោតាបន្ន ទៅអំពីត្រកូលកាន់ត្រកូល ។ ក្នុងបទថា **កុលំ** នេះ លោកបំណាងយកភព ព្រោះហេតុនោះ ក្នុងបទថា **ទ្វេ**

**ទ្វេ តីណិ វា កុលានិ** នេះ គប្បីជ្រាបអត្ថថា ២-៣ ភព ។ ពិតហើយ ព្រះសោតាបន្ននេះ រមែងអន្ទោលទៅ ២-៣ ភព ឬយ៉ាងខ្ពស់បំផុត ក៏ ៦ ភព ព្រោះហេតុនោះ គប្បីឃើញវិកប្ប គឺគោលកំណត់ក្នុងបទនេះយ៉ាងនេះថា ២ ភពក៏មាន ៣ ភពក៏មាន ៤ ភពក៏មាន ៥ ភពក៏មាន ៦ ភពក៏មាន ។

បទថា **ឯកពីជី** មានវិគ្គហៈថា ពូជរបស់ភព ១ ប៉ុណ្ណោះរបស់ព្រះអរិយៈនេះមាន ហេតុនោះ ទើបព្រះអរិយៈនេះ ឈ្មោះថា **ឯកពីជី** ។

ក្នុងបទថា **ឧទ្ធំសោតោ** ជាដើម អធិប្បាយថា ព្រះអនាគាមីប្រភេទឧទ្ធំសោតោអកនិដ្ឋគាមី មានក្រសែទៅខាងលើ និងទៅដល់អកនិដ្ឋភពក៏មាន ១ ព្រះអនាគាមីប្រភេទឧទ្ធំសោតោនអកនិដ្ឋគាមី មានក្រសែខាងលើ តែទៅមិនដល់អកនិដ្ឋភពក៏មាន ១ ព្រះអនាគាមីប្រភេទនឧទ្ធំសោតោអកនិដ្ឋគាមី មិនមានក្រសែខាងលើ តែទៅដល់អនិដ្ឋភពក៏មាន ព្រះអនាគាមីប្រភេទអនុទ្ធំសោតោអកនិដ្ឋគាមី មិនមានក្រសែខាងលើ និងទៅមិនដល់អកនិដ្ឋភពក៏មាន ១ ។

បណ្ដាព្រះអនាគាមី ៤ ពួកនោះ ព្រះអនាគាមីណា បានសម្រេចអនាគាមិផល ក្នុងលោកនេះហើយ កើតក្នុងជាន់សុទ្ធាវាស មានជាន់អវិហាជាដើម តាំងនៅក្នុងជាន់អវិហានោះ ដរាបដល់អស់អាយុហើយ ក៏កើតក្នុងជាន់សុទ្ធាវាសខ្ពស់ឡើងៗ រហូតដល់សុទ្ធាវាសជាន់អកនិដ្ឋ ព្រះអនាគាមីនេះ ឈ្មោះថា **ឧទ្ធំសោតោអកនិដ្ឋគាមី** ។ ចំណែកព្រះអនាគាមីណា កើតក្នុងសុទ្ធាវាសជាន់អវិហាជាដើម តែមិនបរិនិព្វានក្នុងសុទ្ធាវាសនោះ

ទៅបរិនិព្វានក្នុងព្រហ្មលោកខ្ពស់ឡើងៗ ដោយមិនទាន់ដល់សុទ្ធាវាសជាន់អកនិដ្ឋ ព្រះអនាគាមីនេះ ឈ្មោះថា **ឧទ្ធំសោតោឧអកនិដ្ឋគាមី** ។

ព្រះអនាគាមីណា ចុតិអំពីលោកនេះហើយ ទៅកើតក្នុងសុទ្ធាវាសជាន់អកនិដ្ឋនោះឯង ព្រះអនាគាមីនេះ ឈ្មោះថា **ឧឧទ្ធំសោតោអកនិដ្ឋគាមី** ។

ចំណែកព្រះអនាគាមីណា កើតក្នុងសុទ្ធាវាសជាន់ណាមួយ ក្នុងបណ្តាសុទ្ធាវាស ៤ មានអវិហាជាដើម ហើយបរិនិព្វានក្នុងសុទ្ធាវាសជាន់នោះឯង ព្រះអនាគាមីនេះ ឈ្មោះថា **អនុទ្ធំសោតោឧអកនិដ្ឋគាមី** ។

ចំណែកព្រះអនាគាមី ដែលកើតក្នុងព្រហ្មលោកជាន់ណាមួយ ហើយសម្រេចអរហត្តផល ដោយចិត្តដែលជាសសង្ខារ និងជាសម្បយោគ ព្រះអនាគាមីនេះ ឈ្មោះថា **សសង្ខារបរិនិព្វាយី** ។

ព្រះអនាគាមីសម្រេចអរហត្តផលដោយចិត្ត ដែលជាអសង្ខារ ដែលជាអសម្បយោគ ព្រះអនាគាមីនេះ ឈ្មោះថា **អសង្ខារបរិនិព្វាយី** ។

ព្រះអនាគាមីណា កើតក្នុងសុទ្ធាវាសជាន់អវិហា ដែលមានអាយុ ១ ពាន់កប្ប ធ្វងផុតទៅបាន ១០០ កប្បដំបូង ក៏សម្រេចអរហត្តផល ព្រះអនាគាមីនេះ ឈ្មោះថា **ឧបហច្ចបរិនិព្វាយី** ។

ក្នុងសុទ្ធាវាសជាន់អតប្បាជាដើម ក៏មានន័យនេះឯង ។ បទថា **អន្តរា-បរិនិព្វាយី** សេចក្តីថា ព្រះអនាគាមីណាអាយុមិនទាន់ហួសពាក់កណ្តាល ក៏បរិនិព្វាន ព្រះអនាគាមីនោះ មាន ៣ ប្រភេទ គឺលំដាប់ដំបូង ព្រះអនាគាមីណាមួយ កើតក្នុងសុទ្ធាវាសជាន់អវិហាដែលមានអាយុ ១០០០ កប្បហើយ

ក៏សម្រេចអរហត្តផល ក្នុងថ្ងៃដែលកើតនោះឯង បើមិនបានសម្រេចអរហត្តផល ក្នុងថ្ងៃដែលខ្លួនកើត តែបានសម្រេចក្នុងទីបំផុត ១០០ កប្បដំបូង អនាគាមីនេះ ឈ្មោះថា **អន្តរាបរិនិព្វាយីប្រភេទទី ១ ។**

ព្រះអនាគាមីមួយអង្គទៀត មិនអាចសម្រេចអរហត្តផលបានយ៉ាងនោះ តែសម្រេចក្នុងទីបំផុត ២០០ កប្ប ព្រះអនាគាមីនេះ ឈ្មោះថា **អន្តរាបរិនិព្វាយីប្រភេទទី ២ ។**

ព្រះអនាគាមីមួយរូបទៀត ក្នុងទីបំផុត ២០០ កប្បយ៉ាងនោះ ក៏មិនអាចសម្រេចអរហត្តផលបាន តែបានសម្រេចក្នុងទីបំផុត ៤០០ កប្ប ព្រះអនាគាមីនេះ ឈ្មោះថា **អន្តរាបរិនិព្វាយីប្រភេទទី ៣ ។** បទដ៏សេស មានន័យដូចពោលហើយនោះឯង ។

ម្យ៉ាងទៀត អ្នកសិក្សាគប្បីតាំងនៅក្នុងឋានៈនេះ ហើយពោលដល់ព្រះសោតាបន្ន ២៤ ពួក ព្រះសកទាគាមី ១២ ពួក ព្រះអនាគាមី ៤៨ ពួក និងព្រះអរហន្ត ១២ ពួក ។ អធិប្បាយថា ក្នុងសាសនានេះ មានធុរៈ ២ គឺ សទ្ធាធុរៈ ១ បញ្ញាធុរៈ ១ មានបដិបទា ៤ មានទុក្ខាបដិបទាទន្ធាភិញ្ញាជាដើម ។

ក្នុងសទ្ធាធុរៈ និងបញ្ញាធុរៈនោះ ព្រះសោតាបន្នបុគ្គលរូបណាមួយទាញយកដោយសទ្ធាធុរៈ រហូតបានសម្រេចសោតាបត្តិផល កើតក្នុងភពមួយ រួចធ្វើទីបំផុតទុក្ខបាន ព្រះសោតាបន្នបុគ្គលនេះ ចាត់ជាឯកពីជីប្រភេទ ១ ព្រះសោតាបន្នបុគ្គលប្រភេទឯកពីជីនោះ មាន ៤ ប្រភេទ ដោយអំណាចបដិបទា ។ ព្រះសោតាបន្នបុគ្គលប្រភេទឯកពីជី ជាអ្នកទាញយកដោយ

សទ្ធាធុរៈនេះ យ៉ាងណា សូម្បីបុគ្គលដែលទាញយកដោយបញ្ញាធុរៈ ក៏ដូច្នោះ រួមជាព្រះសោតាបន្នបុគ្គល ប្រភេទឯកពីជីមាន ៨ ។ ព្រះសោតាបន្នប្រភេទកោលង្កោលៈ និងព្រះសោតាបន្ន ប្រភេទសត្តក្ខត្តុបរមៈ ក៏ដូចគ្នា គឺមួយប្រភេទមាន ៨ រួមជាព្រះសោតាបន្ន ២៤ ពួក ។

ក្នុងវិមោក្ខទាំង ៣ ព្រះសកទាគាមិបុគ្គលដែលជាអ្នកដល់នូវភូមិរបស់ព្រះសកទាគាមី ក៏មាន ៤ ដោយអំណាចបដិបទា ៤ ។

ម្យ៉ាងទៀត ព្រះសកទាគាមិបុគ្គលដែលសម្រេចភូមិរបស់ព្រះសកទា-គាមី ដោយអនិមិត្តវិមោក្ខ ក៏មាន ៤ ដែលសម្រេចភូមិរបស់សកទាគាមី ដោយអំណាចអប្បណិហិតវិមោក្ខ ក៏មាន ៤ រួមជាព្រះសកទាគាមី ១២ ប្រភេទ ។

ឯក្នុងព្រហ្មលោកជាន់អវិហា ព្រះអនាគាមី មាន ៥ គឺព្រះអនាគាមីប្រភេទអន្តរាបរិនិព្វាយី មាន ៣ ព្រះអនាគាមីដែលជាឧបហច្ចបរិនិព្វាយី មាន ១ ព្រះអនាគាមីដែលជាឧទ្ធំសោតោអកនិដ្ឋគាមី មាន ១ ព្រះអនាគាមីទាំងនោះ បែកជា ១០ គឺព្រះអនាគាមីប្រភេទអសង្ខារបរិនិព្វាយី មាន ៥ ព្រះអនាគាមីប្រភេទសសង្ខារបរិនិព្វាយី មាន ៥ ។ ក្នុងសុទ្ធាវាសជាន់អតប្បាជាដើម ក៏មានចំនួនស្មើគ្នា តែក្នុងសុទ្ធាវាសជាន់អកនិដ្ឋ ព្រះអនាគាមីប្រភេទឧទ្ធំសោតោមិនមាន ព្រោះដូច្នោះ ទើបក្នុងសុទ្ធាវាសជាន់អនិដ្ឋនោះ មានព្រះអនាគាមី ៨ គឺព្រះអនាគាមីដែលជាសសង្ខារបរិនិព្វាយី ៤ ព្រះអនាគាមីដែលជាអសង្ខារបរិនិព្វាយី ៤ រួមជាព្រះអនាគាមី ៤៨ ។ ព្រះ

អរហន្ត គប្បីជ្រាបថា មាន ១២ ដូចព្រះសកទាគាមីដែរ ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគ ក៏ត្រាស់សិក្ខា ៣ លាយគ្នា ៗ។

## អដ្ឋកថា តតិយសេក្ខសូត្រទី ៧ ចប់

# សុត្តន្តបិដក

## ចតុត្ថសេក្ខសូត្រទី ៨

[ ៩០ ] ម្នាលភិក្ខុទាំងឡាយ សិក្ខាបទ ១៥០ ដែលសម្រេចហើយនេះ មកកាន់ឧទ្ទេស រាល់កន្លះខែ ដែលជាទីសិក្សារបស់កុលបុត្រអ្នកប្រាថ្នាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ សិក្ខានេះមាន ៣ ដែលជាទីប្រជុំរបស់សិក្ខាបទទាំងអស់នុ៎ះ ។ សិក្ខា ៣ តើដូចម្ដេចខ្លះ ។ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងសិក្ខា ៣ ដែលជាទីប្រជុំនៃសិក្ខាបទទាំងអស់នុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល ធ្វើឲ្យបរិបូណ៌ក្នុងសមាធិ ធ្វើឲ្យបរិបូណ៌ក្នុងបញ្ញា ភិក្ខុនោះ នៅតែត្រូវសិក្ខាបទតូច និងតូចបន្ទាប់ទាំងនោះខ្លះ ចេញចាកខ្លះ ។ ហេតុនោះ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនទាន់ឲ្យឈ្មោះថាជាអភព្វក្នុងហេតុនុ៎ះទេ ។ ពួកសិក្ខាបទណា ជាខាងដើមនៃមគ្គព្រហ្មចារ្យ សមគួរដល់មគ្គព្រហ្មចារ្យ ឲ្យតែភិក្ខុមានសីលខ្ជាប់ខ្ជួន មានសីលស្ថិតស្ថេរ សមាទាន

សិក្សាក្នុងសិក្ខាបទទាំងនោះ ។ ភិក្ខុនោះ គង់ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ក្រៃលែងខ្លួនឯង ក្នុងបច្ចុប្បន្ន ។ ទោះបីមិនទាន់សម្រេច មិនទាន់ចាក់ធ្លុះនូវអរហត្តផលនោះទេ គង់បានសម្រេចភាពជាអន្តរាបរិនិព្វាយី ព្រោះអស់សញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។ បើទុកជាមិនទាន់សម្រេច មិនទាន់ចាក់ធ្លុះនូវអន្តរាបរិនិព្វាយីនោះទេ គង់បានសម្រេចភាពជាឧបហច្ចបរិ-និព្វាយី ព្រោះអស់សញ្ញោជនៈជាចំណែកខាងក្រោម ៥ ។ ឬថា បើមិនទាន់សម្រេច មិនទាន់ចាក់ធ្លុះនូវឧបហច្ចបរិនិព្វាយីនោះទេ គង់បានសម្រេចភាពជាអសង្ខារបរិនិព្វាយី ព្រោះអស់សញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។ ពុំនោះសោត បើមិនទាន់សម្រេច មិនទាន់ចាក់ធ្លុះនូវអសង្ខារបរិនិព្វាយីនោះទេ គង់បានសម្រេចភាពជាសសង្ខារបរិនិព្វាយី ព្រោះអស់សញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។ ទោះបីមិនទាន់សម្រេច មិនទាន់ចាក់ធ្លុះនូវសសង្ខារបរិនិព្វាយីនោះទេ គង់បានសម្រេចភាពជាឧទ្ធំសោតអកនិដ្ឋគាមី ព្រោះអស់សញ្ញោជនៈជាចំណែកខាងក្រោម ៥ ។ កាលបើមិនទាន់សម្រេច មិនទាន់ចាក់ធ្លុះនូវឧទ្ធំសោតអកនិដ្ឋគាមីនោះទេ គង់តែបានសម្រេចភាពជាសកទាគាមី ព្រោះអស់សញ្ញោជនៈ ៣ ព្រោះស្រាលស្តើងរាគៈ ទោសៈ មោហៈ មកកាន់លោកនេះត្រឹមតែម្តង ក៏ធ្វើនូវទីបំផុតទុក្ខបាន ។ កាលបើមិនទាន់សម្រេច មិនទាន់ចាក់ធ្លុះនូវសកទាគាមិផលនោះទេ ដោយហោចទៅ គង់បានសម្រេចភាពជាឯកពីជីសោតៈ ព្រោះអស់សញ្ញោជនៈ ៣ កើត

ក្នុងភពជារបស់មនុស្សតែម្តងប៉ុណ្ណោះ ក៏ធ្វើនូវទីបំផុតនៃទុក្ខបាន ។ ឬក៏មិនទាន់សម្រេច មិនទាន់ចាក់ធ្លុះនូវឯកពីជីនោះទេ គង់បានសម្រេចភាពជាកោលង្កោលៈ ព្រោះអស់សញ្ញោជនៈ ៣ ត្រាច់រង្គាត់អន្ទោលទៅកាន់ត្រកូល ២ ឬ ៣ ក៏ធ្វើនូវទីបំផុតទុក្ខបាន ។ ពុំនោះសោត កាលបើមិនទាន់សម្រេច មិនទាន់ចាក់ធ្លុះនូវកោលង្កោលៈនោះទេ គង់បានសម្រេចភាពជាសត្តក្ខត្តុបរមៈ ព្រោះអស់សញ្ញោជនៈ ៣ ត្រាច់រង្គាត់ អន្ទោលទៅក្នុងទេវលោក និងមនុស្សលោកយ៉ាងច្រើនត្រឹម ៧ ជាតិ ក៏ធ្វើនូវទីបំផុតទុក្ខបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកធ្វើឲ្យបរិបូណ៌ រមែងសម្រេចមគ្គផលបរិបូណ៌ បុគ្គលអ្នកធ្វើបានដោយអន្ទើ រមែងសម្រេចមគ្គផលដោយអន្ទើ ដោយប្រការដូច្នេះឯង ម្នាលភិក្ខុទាំងឡាយ តថាគតនៅតែសម្តែងថា សិក្ខាបទទាំងឡាយ មិនមែនឥតអំពើទេ ។

# អដ្ឋកថា

## ចតុត្ថសេក្ខសូត្រ

[ ៩០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចតុត្ថសេក្ខសូត្រទី ៨ ដូចតទៅនេះ បទថា **តំ វា បន អនភិសម្ភវំ អប្បដិវិជ្ឈំ** សេចក្តីថា ព្រះអនាគាមីមិនទាន់សម្រេច គឺមិនទាន់ចាក់ធ្លុះអរហត្តផលនោះ ។ អ្នកសិក្សា គប្បីជ្រាប

អត្ថក្នុងទីគ្រប់អន្លើ មានពាក្យថា **តំ វា បន អនភិសម្ភាវំ អប្បដិវិជ្ឈំ** ដោយន័យនេះ ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់សិក្ខា ៣ លាយឡំគ្នានោះឯង ។l

**អដ្ឋកថា ចតុត្ថសេក្ខសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## បឋមសិក្ខាសូត្រទី ៩

[ ៩១ ] ម្នាលភិក្ខុទាំងឡាយ សិក្ខានេះមាន ៣ ។ សិក្ខា ៣ តើដូចម្តេច ។ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។ ម្នាលភិក្ខុទាំងឡាយ អធិសីលសិក្ខា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។បេ។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អធិសីលសិក្ខា ។ ម្នាលភិក្ខុទាំងឡាយ អធិចិត្តសិក្ខា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាម ។បេ។ បានដល់ចតុត្ថជ្ឈាន សម្រេចសម្រាន្តនៅ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អធិចិត្តសិក្ខា ។ ម្នាលភិក្ខុទាំងឡាយ អធិប្បញ្ញាសិក្ខា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ។បេ។ ដឹងច្បាស់តាមពិតថា នេះបដិបទាជា

ដំណើរទៅកាន់ទីរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អធិប្បញ្ញា-សិក្ខា ។ ម្នាលភិក្ខុទាំងឡាយ នេះឯងសិក្ខា ៣ ។

# អដ្ឋកថា

## បឋមសិក្ខាសូត្រ

[ ៩១ ] ក្នុងបឋមសិក្ខាសូត្រទី ៩ មានអត្ថងាយយល់ទាំងអស់ហើយ ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគក៏ត្រាស់សិក្ខា ៣ លាយឡំគ្នាដែរ ៕

### អដ្ឋកថាបឋមសិក្ខាសូត្រទី ៩ ចប់

# សុត្តន្តបិដក

## ទុតិយសិក្ខាសូត្រទី ១០

[ ៩២ ] ម្នាលភិក្ខុទាំងឡាយ សិក្ខានេះមាន ៣ ។ សិក្ខា ៣ តើដូចម្តេច ។ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។ ម្នាលភិក្ខុទាំងឡាយ អធិសីលសិក្ខា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុង

សាសនានេះ ជាអ្នកមានសីល ។បេ។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អធិសីលសិក្ខា ។ ម្នាលភិក្ខុទាំងឡាយ អធិចិត្តសិក្ខា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់ចតុត្ថជ្ឈាន សម្រេចសម្រាន្តនៅ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អធិចិត្តសិក្ខា ។ ម្នាលភិក្ខុទាំងឡាយ អធិប្បញ្ញាសិក្ខា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាខ្លួនឯងដ៏ក្រៃលែង ក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អធិប្បញ្ញាសិក្ខា ។ ម្នាលភិក្ខុទាំងឡាយ នេះឯង សិក្ខា ៣ ។

បុគ្គលមានព្យាយាម មានកម្លាំង មានប្រាជ្ញា ជាគ្រឿងទ្រទ្រង់ មានឈាន មានស្មារតី មានឥន្ទ្រិយគ្រប់គ្រង គួរប្រព្រឹត្តនូវអធិសីលផង អធិចិត្តផង អធិប្បញ្ញាផង បុគ្គល ( សិក្សាក្នុងសិក្ខា ៣ ) ក្នុងកាលមុនយ៉ាងណា ក្នុងកាលក្រោយក៏យ៉ាងនោះ ក្រោយយ៉ាងណា មុនក៏យ៉ាងនោះ ( ឃើញ ) កាយខាងក្រោម ( ដោយអំណាចនៃអសុភ ) យ៉ាងណា ឃើញកាយខាងលើក៏យ៉ាងនោះ កាយខាងលើយ៉ាងណា ខាងក្រោមក៏យ៉ាងនោះ ( សិក្សាក្នុងសិក្ខា ៣ ) ក្នុងវេលាថ្ងៃយ៉ាង

*ណា ក្នុងវេលាយប់ក៏យ៉ាងនោះ ក្នុងវេលាយប់យ៉ាងណា ក្នុងវេលាថ្ងៃក៏យ៉ាងនោះដែរ គប្បីគ្របសង្កត់ ( នូវអារម្មណ៍ទាំងឡាយ ) គ្រប់ទិសដោយអប្បមាណ-សមាធិ គឺសមាធិប្រកបដោយអរហត្តមគ្គ ។ ពួកព្រះអរិយៈ តែងសរសើរបុគ្គលជាសេក្ខៈ អ្នកប្រតិបត្តិថាជាអ្នកមានសេចក្ដីប្រព្រឹត្តដ៏បរិសុទ្ធ សរសើរបុគ្គលអ្នកត្រាស់ដឹងអរិយសច្ច ៤ ក្នុងលោកនេះ ថាជាអ្នកមានប្រាជ្ញា ដល់នូវទីបំផុតនៃសេចក្ដីប្រតិបត្តិ ។ ការរួចស្រឡះនៃចិត្តរបស់បុគ្គល ដែលមានសេចក្ដីរួចស្រឡះ ព្រោះអស់តណ្ហា ដោយសេចក្ដីរលត់វិញ្ញាណដូចជាការរលត់ទៅនៃប្រទីប ជាគ្រឿងបំភ្លឺ ។*

# អដ្ឋកថា

## ទុតិយសិក្ខាសូត្រ

*[ ៩២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយសិក្ខាសូត្រទី ១០ ដូចតទៅនេះ ក្នុងបទថា* **អាសវានំ ខយា** *នេះ មានអធិប្បាយថា អរហត្តមគ្គ ឈ្មោះថា អធិប្បញ្ញាសិក្ខា ។ ចំណែកផលមិនគួរពោលថា សិក្ខា ព្រោះកើតឡើងដល់បុគ្គលដែលបានសិក្សាសិក្ខាហើយ ។*

បទថា **យថា បុរេ តថា បច្ឆា** សេចក្តីថា ខាងដើមលោកសិក្សាក្នុងសិក្ខា ៣ ខាងក្រោយក៏សិក្សាយ៉ាងនោះដូចគ្នា ។ ក្នុងបទទី ២ ក៏មានន័យនេះឯង ។ បទថា **យថា អធោ តថា ឧទ្ធំ** សេចក្តីថា លោកពិចារណាឃើញកាយខាងក្រោម ដោយអំណាចអសុភ យ៉ាងណា ពិចារណាឃើញកាយខាងលើ យ៉ាងនោះដូចគ្នា ។ ក្នុងបទទី ២ ក៏មានន័យនេះដូចគ្នា ។ បទថា **យថា ទិវា តថា រត្តឹ** សេចក្តីថា ក្នុងពេលថ្ងៃ លោកសិក្សាសិក្ខា ៣ ក្នុងពេលយប់ ក៏សិក្សាយ៉ាងនោះដូចគ្នា ។ បទថា **អភិភុយ្យ ទិសា សព្វា** សេចក្តីថា គ្របសង្កត់ទិសទាំងពួង គឺគ្របសង្កត់ដោយអំណាចនៃអារម្មណ៍ ។ បទថា **អប្បមាណសមាធិនា** គឺដោយសមាធិដែលសម្បយុត្តដោយអរហត្តមគ្គ ។ បទថា **សេក្ខំ** បានដល់ អ្នកដែលនៅសិក្សានៅឡើយ គឺនៅមានកិច្ចដែលត្រូវធ្វើ ។ បទថា **បដិបទំ** បានដល់ អ្នកបដិបត្តិ ។ បទថា **សំសុទ្ធចារិនំ** បានដល់ បុគ្គលមានចរណៈបរិសុទ្ធល្អ គឺមានសីលបរិសុទ្ធ ។ បទថា **សម្ពុទ្ធំ** បានដល់ អ្នកត្រាស់ដឹងសច្ចៈ ៤ ។ បទថា **ធីរំ បដិបទន្តគុំ** សេចក្តីថា អ្នកប្រាជ្ញ គឺជាអ្នកដល់ព្រមដោយបញ្ញាជាគ្រឿងចងចាំ ដោយអំណាចនៃបញ្ញា ដែលទ្រទ្រង់ចាំក្នុងខន្ធ ធាតុ និងអាយតនៈ ជាអ្នកដល់នូវទីបំផុតនៃវត្តបដិបត្តិ ។

បទថា **វិញ្ញាណស្ស** បានដល់ នៃចរិមកវិញ្ញាណ គឺចិត្តដួងចុងក្រោយ ។ បទថា **តណ្ហក្ខយវិមុត្តិនោ** បានដល់ ជាអ្នកប្រកបដោយអរហត្តផលវិមុត្តិ ពោល គឺការរួចផុត ព្រោះអស់តណ្ហា ។ បទថា **បជ្ជោតស្សេវ និព្វានំ**

ដោយអត្ថថា ប្រៀបដូចការរលត់ទៅរបស់ប្រទីប ។ បទថា **វិមោក្ខោ ហោតិ ចេតសោ** សេចក្តីថា ការរួចផុត គឺការផុត បានដល់ ភាវៈ គឺការមិនប្រព្រឹត្តទៅនៃចិត្តមាន ។ អធិប្បាយថា ការរួចផុតទៅនៃចិត្តដែលប្រៀបដូចការរលត់ទៅនៃប្រទីប រមែងមានដល់ព្រះខីណាស្រពដែលរួចផុត ព្រោះអស់តណ្ហា ព្រោះចរិមកវិញ្ញាណរលត់ទៅ ស្ថានទីដែលព្រះខីណាស្រពទៅក៏មិនប្រាកដ លោកជាអ្នកចូលដល់នូវភាព ជាបុគ្គលដែលមិនមានការបញ្ញត្ត ។ល។

**អដ្ឋកថាទុតិយសិក្ខាសូត្រទី ១០ ចប់**

# សុត្តន្តបិដក

## បំកធាសូត្រទី ១១

[ ៩៣ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់ស្តេចទៅកាន់ចារិក ក្នុងដែនកោសល ជាមួយនឹងភិក្ខុសង្ឃច្រើនរូប បានដល់និគមឈ្មោះបង្កធា របស់ដែនកោសល ។ បានឮថា សម័យនោះ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងបង្កធានិគមរបស់ដែនកោសល ។ សម័យនោះ ភិក្ខុឈ្មោះកស្សបគោត្រ ជាចៅអាវាសក្នុងបង្កធានិគម ។ បានឮថា ក្នុងទីនោះ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់ពួកភិក្ខុឲ្យឃើញច្បាស់ ឲ្យកាន់តាម ឲ្យអាចហ៊ាន ឲ្យ

រីករាយ ដោយធម្មីកថា ដ៏ប្រកបដោយសិក្ខាបទ ។ គ្រាកាលដែលព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ពួកភិក្ខុឲ្យឃើញច្បាស់ ឲ្យកាន់តាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ដ៏ប្រកបដោយសិក្ខាបទហើយ ភិក្ខុកស្សបគោត្រ មានសេចក្តីមិនអត់ទ្រាំ មិនត្រេកអរថា សមណៈនេះដូចជាដុសខាត់ជ្រុលពេក ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងបង្កធានិគម តាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ក៏ទ្រង់ត្រាច់ចារិកទៅកាន់ក្រុងរាជគ្រឹះ កាលទ្រង់ត្រាច់ចារិកដោយលំដាប់ ក៏បានដល់ក្រុងរាជគ្រឹះនោះ ។ បានឮថា ក្នុងទីនោះ ព្រះមានព្រះភាគទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ កាលដែលព្រះមានព្រះភាគ ទ្រង់ស្តេចចេញទៅមិនយូរប៉ុន្មាន ភិក្ខុកស្សបគោត្រមានសេចក្តីក្តៅក្រហាយ ស្តាយក្រោយថា មិនជាលាភរបស់អាត្មាអញ អាត្មាអញឈ្មោះថាឥតលាភ អាត្មាអញឈ្មោះថាបានទាស់ហើយ អាត្មាអញមិនមែនបានស្រួលទេ ព្រោះថា កាលដែលព្រះដ៏មានព្រះភាគទ្រង់ពន្យល់ពួកភិក្ខុឲ្យឃើញច្បាស់ ឲ្យកាន់តាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាដ៏ប្រកបដោយសិក្ខាបទហើយ អាត្មាអញមានសេចក្តីមិនអត់ទ្រាំ មិនត្រេកអរថា សមណៈនេះ ដូចជាដុសខាត់ជ្រុលពេក បើដូច្នោះ គួរតែអាត្មាអញចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ត្រូវសម្តែងទោសតាមទោសក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ។ លំដាប់នោះ ភិក្ខុកស្សបគោត្រ រៀបទុកដាក់សេនាសនៈហើយ ក៏ប្រដាប់បាត្រ និងចីវររួចចេញទៅកាន់ក្រុងរាជគ្រឹះ បានចូលទៅគាល់ព្រះដ៏មានព្រះភាគឯភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ

នោះ ដោយលំដាប់ លុះចូលទៅហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុកស្សបគោត្រ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងបង្កធានិគម របស់ដែនកោសល ។ ក្នុងទីនោះ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់ពួកភិក្ខុឲ្យឃើញច្បាស់ ឲ្យកាន់តាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ដ៏ប្រកបដោយសិក្ខាបទ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ពួកភិក្ខុឲ្យឃើញច្បាស់ ឲ្យកាន់តាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ដ៏ប្រកបដោយសិក្ខាបទ ខ្ញុំព្រះអង្គអ្នកមានសេចក្តីមិនអត់ទ្រាំ មិនត្រេកអរថា សមណៈនេះដូចជាជុសខាត់ជ្រុលពេក គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងបង្កធានិគម តាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ទ្រង់ត្រាច់ចារិកមកកាន់ក្រុងរាជគ្រឹះ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលព្រះដ៏មានព្រះភាគ ទ្រង់ស្តេចចេញមកមិនយូរប៉ុន្មាន ខ្ញុំព្រះអង្គកើតសេចក្តីក្តៅក្រហាយ ស្តាយក្រោយថា មិនជាលាភរបស់អាត្មាអញហើយ អាត្មាអញឈ្មោះថាឥតលាភ អាត្មាអញបានទាស់ហើយ អាត្មាអញមិនមែនបានល្អទេ ព្រោះថា ព្រះដ៏មានព្រះភាគទ្រង់ពន្យល់ពួកភិក្ខុ ឲ្យឃើញច្បាស់ ឲ្យកាន់តាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ដ៏ប្រកបដោយសិក្ខាបទហើយ អាត្មាអញមានសេចក្តីមិនអត់ទ្រាំ មិនត្រេកអរថា សមណៈនេះដូចជាជុសខាត់ជ្រុលពេក បើដូច្នោះគួរអាត្មាអញ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ត្រូវ

សម្ដែងទោសតាមទោស ក្នុងសម្នាក់ព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន ទោសបានប្រព្រឹត្តកន្លងហើយនូវខ្ញុំព្រះអង្គ ជាមនុស្សពាលយ៉ាងណា វង្វេងយ៉ាងណា មិនឈ្លាសវៃយ៉ាងណា ព្រោះថា ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ពួកភិក្ខុឲ្យឃើញច្បាស់ ឲ្យកាន់តាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ដ៏ប្រកបដោយសិក្ខាបទហើយ ខ្ញុំព្រះអង្គមានសេចក្ដីមិនអត់ទ្រាំ មិនត្រេកអរថា សមណៈនេះ ដូចជាដុសខាត់ជ្រុលពេក បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទ្រង់ទទួលអត់ទោសតាមទោស ដល់ខ្ញុំព្រះអង្គនោះ ដើម្បីសេចក្ដីសង្រួមតទៅ ។ អើ កស្សបៈ ទោសប្រព្រឹត្តកន្លងហើយនូវអ្នកដែលជាមនុស្សពាលយ៉ាងណា វង្វេងយ៉ាងណា មិនឈ្លាសវៃយ៉ាងណា អ្នកមិនមានសេចក្ដីអត់ទ្រាំ មិនមានសេចក្ដីត្រេកអរនឹងតថាគត កាលដែលពន្យល់ពួកភិក្ខុឲ្យឃើញច្បាស់ ឲ្យកាន់តាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ដ៏ប្រកបដោយសិក្ខាបទថា សមណៈនេះ ដូចជាដុសខាត់ជ្រុលពេក ម្នាលកស្សបៈ កាលបើអ្នកឃើញទោសតាមទោស ហើយត្រឡប់ធ្វើសមគួរតាមធម៌ តថាគតទទួលអត់ទោសនោះដល់អ្នក ម្នាលកស្សបៈ បុគ្គលណាឃើញទោសតាមទោស ហើយត្រឡប់ធ្វើសមគួរតាមធម៌ ដល់នូវសេចក្ដីសង្រួមតទៅ នេះជាសេចក្ដីចម្រើនក្នុងវិន័យរបស់អរិយៈ ។ ម្នាលកស្សបៈ បើទុកជាភិក្ខុជាថេរៈ មិនចូលចិត្តនឹងការសិក្សា មិនសរសើរគុណនៃកិរិយាសមាទាននូវការសិក្សា មិនបបួលពួកភិក្ខុដទៃ ដែលមិនចូលចិត្តនឹងការសិក្សានោះឲ្យសិក្សា មិនសរសើរគុណពួកភិក្ខុដទៃ ដែលចូលចិត្តនឹងការ

សិក្ខានោះ ឲ្យពិតមែនតាមកាល ម្នាលកស្សបៈ តថាគតមិនសរសើរភិក្ខុជាថេរៈមានសភាពដូច្នេះទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះក្រែងពួកភិក្ខុដទៃសេពគប់ភិក្ខុជាថេរៈនោះ ដោយចូលចិត្តថា ព្រះជាគ្រូទ្រង់សរសើរភិក្ខុជាថេរៈនោះ ពួកភិក្ខុជាអ្នកសេពគប់នឹងភិក្ខុជាថេរៈនោះ រមែងប្រព្រឹត្តតាមទិដ្ឋិរបស់ភិក្ខុជាថេរៈនោះ អំពើនោះ ប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលដ៏វែង ដល់ពួកភិក្ខុដែលប្រព្រឹត្តតាមទិដ្ឋិនោះ ម្នាលកស្សបៈ ព្រោះហេតុនោះហើយ បានជាតថាគតមិនសរសើរភិក្ខុជាថេរៈមានសភាពដូច្នេះ ។ ម្នាលកស្សបៈ បើទុកជាភិក្ខុជាកណ្តាល ។បេ។ ម្នាលកស្សបៈ បើទុកជាភិក្ខុនវៈ តែមិនចូលចិត្តនឹងការសិក្សា មិនសរសើរគុណនៃកិរិយាសមាទាននូវការសិក្សា មិនបបួលពួកភិក្ខុដទៃ ដែលមិនចូលចិត្តនឹងការសិក្សានោះ ឲ្យសិក្សា មិនសរសើរគុណរបស់ពួកភិក្ខុដទៃដែលចូលចិត្តនឹងការសិក្សាឲ្យទៀងពិតតាមកាលគួរ ម្នាលកស្សបៈ តថាគតមិនសរសើរភិក្ខុនវៈបែបនោះទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថាពួកភិក្ខុដទៃសេពគប់ពួកភិក្ខុនវៈនោះដោយគិតថា ព្រះជាគ្រូទ្រង់សរសើរគុណភិក្ខុនោះ ពួកភិក្ខុអ្នកសេពគប់ភិក្ខុនវៈនោះ ប្រព្រឹត្តទៅតាមទិដ្ឋិភិក្ខុនោះ អំពើនោះប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលដ៏វែងដល់ពួកភិក្ខុដែលប្រព្រឹត្តតាមទិដ្ឋិនោះ ម្នាលកស្សបៈ ព្រោះហេតុនោះ បានជាតថាគតមិនសរសើរគុណរបស់ភិក្ខុនវៈ មានសភាពដូច្នេះទេ ។ ម្នាលកស្សបៈ បើភិក្ខុជាថេរៈអ្នកមានប្រាថ្នានូវការសិក្សា សរសើរគុណនៃកិរិយាសមាទាន

នូវការសិក្សា តែងបបួលពួកភិក្ខុដទៃ ដែលមិនប្រាថ្នានូវការសិក្សានោះ ឲ្យសិក្សា សរសើរគុណរបស់ពួកភិក្ខុដទៃ ដែលប្រាថ្នានូវការសិក្សាពិតមែនតាមកាល ម្នាលកស្សបៈ តថាគតសរសើរគុណភិក្ខុជាថេរៈ មានសភាពដូច្នេះ ។ ហេតុនោះ តើដូចម្ដេច ។ ព្រោះពួកភិក្ខុដទៃ សេពគប់នូវភិក្ខុជាថេរៈនោះ ដោយគិតថា ព្រះជាគ្រូទ្រង់សរសើរគុណភិក្ខុនោះ ពួកភិក្ខុនោះតែងប្រព្រឹត្តតាមទិដ្ឋិរបស់ភិក្ខុជាថេរៈ ដែលខ្លួនសេពគប់នោះ អំពើរបស់ពួកភិក្ខុដែលប្រព្រឹត្តតាមទិដ្ឋិ របស់ភិក្ខុជាថេរៈនោះ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខអស់កាលដ៏វែង ម្នាលកស្សបៈ ព្រោះហេតុនោះ តថាគតសរសើរគុណរបស់ភិក្ខុជាថេរៈមានសភាព ដូច្នេះ ។ ម្នាលកស្សបៈ បើភិក្ខុជាកណ្ដាល ។បេ។ ម្នាលកស្សបៈ បើភិក្ខុខ្ចី ជាអ្នកមានប្រាថ្នានូវការសិក្សា ជាអ្នកសរសើរគុណនៃកិរិយាសមាទាននូវការសិក្សា បបួលពួកភិក្ខុដទៃ ដែលមិនមានប្រាថ្នានូវការសិក្សានោះឲ្យសិក្សាផង សរសើរគុណរបស់ភិក្ខុដទៃ ដែលប្រាថ្នាការសិក្សាពិតមែន តាមកាលដ៏គួរផង ម្នាលកស្សបៈ តថាគតសរសើរគុណរបស់ភិក្ខុខ្ចី មានសភាពដូច្នេះ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះពួកភិក្ខុដទៃ សេពគប់នឹងភិក្ខុខ្ចីនោះដោយគិតថា ព្រះជាគ្រូទ្រង់សរសើរគុណរបស់ភិក្ខុនោះ ពួកភិក្ខុនោះរមែងប្រព្រឹត្តតាមទិដ្ឋិរបស់ភិក្ខុដែលខ្លួនសេពគប់នោះ អំពើរបស់ពួកភិក្ខុដែលប្រព្រឹត្តតាមទិដ្ឋិរបស់ពួកភិក្ខុខ្ចីនោះ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខអស់កាលដ៏វែង ម្នាលកស្សបៈ ព្រោះហេតុនោះ ទើបតថាគតសរសើរគុណរបស់ភិក្ខុខ្ចី

មានសភាពដូច្នេះ ។

សមណវគ្គទី ៤ ចប់

## ឧទ្ទាននៃសមណវគ្គនោះ គឺ

សមណកិច្ច ១ សូត្រ សត្វលា ១ សូត្រ ស្រែ ១ សូត្រ វជ្ជិបុត្តកៈ ១ សូត្រ សេក្ខបុគ្គល ១ សូត្រ ភិក្ខុបំពេញសិក្សា ៣ សូត្រ សិក្ខា ២ សូត្រ រឿងបង្កធានិគម ១ សូត្រ ។

# អដ្ឋកថា

## បំកធាសូត្រ

[ ៩៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបំកធាសូត្រទី ១១ ដូចតទៅនេះ បទថា **បំកធា នាម កោសលានំ និគមោ** សេចក្តីថា និគមក្នុងកោសលរដ្ឋ ដែលមានឈ្មោះយ៉ាងនេះថា **បំកធា** ។ បទថា **អាវាសិកោ** សេចក្តីថា ភិក្ខុម្ចាស់អាវាស សាងអាវាសថ្មីៗ ឡើង ទំនុកបម្រុងរក្សាអាវាសចាស់ៗ ។ បទថា **សិក្ខាបទបដិសំយុត្តាយ** បានដល់ បដិសំយុត្តដោយបទ ពោល គឺសិក្ខា អធិប្បាយថា ប្រកបដោយសិក្ខា ៣ ។ បទថា **សន្ទស្សេតិ** បានដល់ ទ្រង់ឲ្យភិក្ខុទាំងឡាយឃើញដូចនៅចំពោះមុខ ។ បទថា **សមាទបេតិ**

បានដល់ ឲ្យភិក្ខុទាំងឡាយកាន់យក ។ បទថា **សមុត្តេជេតិ** គឺឲ្យភិក្ខុទាំង-ឡាយអាចហ៊ាន ។ បទថា **សម្បហំសេតិ** គឺត្រាស់សរសើរ ធ្វើភិក្ខុទាំង-ឡាយឲ្យផូរផង់ដោយគុណ ដែលបានខ្ជួនហើយ ។ បទថា **អធិសល្លេខិតេ** បានដល់ សមណៈនេះរមែងជុសខាត់ពន់ពេក អធិប្បាយថា សមណៈនេះរមែងពោលធម៌ដែលល្អិតៗ ធ្វើឲ្យល្អិតល្អន់ពន់ពេក ។

បទថា **អច្ចយោ** គឺកំហុស ។ បទថា **មំ អច្ចគមា** គឺកន្លងល្មើសនូវខ្ញុំ បានដល់ សង្កត់សង្កិនខ្ញុំប្រព្រឹត្តទៅ ។ បទថា **អហុទេវ អក្ខន្តិ** សេចក្ដីថា ការមិនអត់ធន់ មានហើយនោះឯង ។ បទថា **អហុ អប្បច្ចយោ** សេចក្ដីថា អាការមិនត្រេកអរមានហើយ ។ បទថា **បដិគ្គណ្ហាតុ** សេចក្ដីថា សូមព្រះមានព្រះភាគអត់ទោស ។ បទថា **អាយតឹ សំវរាយ** គឺដើម្បីប្រយោជន៍ដល់ការសង្រួមក្នុងអនាគត អធិប្បាយថា ដើម្បីមិនធ្វើនូវកំហុសគឺទោស បានដល់ការភ្លាំងភ្លាត់បែបនេះទៀត ។ បទថា **តគ្ឃ** ជានិបាតដោយចំណែកមួយ ។

បទថា **យថាធម្មំ បដិករោសិ** គឺធម៌តាំងនៅដោយប្រការណា លោកក៏ធ្វើដោយប្រការនោះ មានពាក្យអធិប្បាយថា ឲ្យអត់ទោស ។ បទថា **តំ តេ មយំ បដិគ្គណ្ហាម** សេចក្ដីថា យើងទាំងឡាយរមែងអត់ទោសនោះឲ្យអ្នក ។ បទថា **វុឌ្ឍិ ហេសា កស្សប អរិយស្ស វិនយេ** សេចក្ដីថា ម្នាលកស្សប នេះឈ្មោះថា ជាការចម្រើនក្នុងសាសនារបស់ព្រះសម្ពុទ្ធ ។ សួរថា ការចម្រើនដូចម្ដេច ឆ្លើយថា ការឃើញទោសថាជាទោស ហើយ

*សម្ដែងតាមធម៌ ដល់នូវការសង្រួមតទៅ ។ ព្រះមានព្រះភាគ កាលទ្រង់ធ្វើទេសនាឲ្យជាបុគ្គលាធិដ្ឋាន ទើបត្រាស់ថា* **យោ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោតិ អាយតឹ សំវរំ អាបជ្ជតិ** *ប្រែថា បុគ្គលណា ឃើញទោសដោយភាពជាទោស សម្ដែងទោសតាមទំនៀម ដល់នូវការសង្រួមតទៅ ដូច្នេះ ។*

*បទថា* **ន សិក្ខាកាមោ** *សេចក្ដីថា ភិក្ខុមិនត្រូវការ គឺមិនប្រាថ្នា បាន ដល់ មិនយកចិត្តទុកដាក់ចំពោះសិក្ខា ៣ ។ បទថា* **សិក្ខាសមាទានស្ស** *គឺ នៃការបំពេញសិក្ខាឲ្យបរិបូណ៌ ។ បទថា* **ន វណ្ណវាទី** *គឺមិនពោលគុណ ។ បទថា* **កាលេន** *គឺដោយកាលដ៏សមគួរ ។ បទដ៏សេសក្នុងសូត្រនេះ មាន អត្ថងាយយល់ទាំងអស់ហើយ ។*

**អដ្ឋកថាបំកធាសូត្រទី ១១ ចប់**

**សមណវគ្គទី ៤ ចប់**

# សុត្តន្តបិដក

# លោណផលវគ្គទី ៥

## អច្ចាយិកសូត្រទី ១

[ ៩៤ ] ម្នាលភិក្ខុទាំងឡាយ ករណីយកិច្ច ប្រព្រឹត្តទៅយ៉ាងរួសរាន់ របស់កសិករគហបតី ( គហបតីអ្នកភ្ជួររាស់ ) នេះមាន ៣ យ៉ាង ។ ករណីយកិច្ច ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កសិករគហបតី ក្នុងលោកនេះ ភ្ជួររាស់ស្រែឲ្យរាប ឲ្យល្អិតល្អយ៉ាងប្រញាប់ ១ លុះភ្ជួររាស់ស្រែរាបល្អិតល្អ យ៉ាងប្រញាប់ហើយ ក៏ព្រោះពូជយ៉ាងប្រញាប់ ១ លុះព្រោះពូជយ៉ាងប្រញាប់ហើយ ក៏បញ្ចូលទឹកខ្លះ បញ្ចេញទឹកខ្លះយ៉ាងប្រញាប់ ១ ។ ម្នាលភិក្ខុទាំងឡាយ ករណីយកិច្ចយ៉ាងរួសរាន់ របស់កសិករគហបតី មាន ៣ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ កសិករគហបតីនោះ មិនមានឫទ្ធិ មិនមានអានុភាព ( បង្គាប់បញ្ជា ) ស្រូវនោះថា សូមឲ្យស្រូវទាំងឡាយ របស់អាត្មាអញលូតលាស់ក្នុងថ្ងៃនេះ មានបង្កើមក្នុងថ្ងៃស្អែក ទុំក្នុងថ្ងៃខានស្អែក ដូច្នេះបានឡើយ ម្នាលភិក្ខុទាំងឡាយ លុះតែដល់វេលា ទើបស្រូវទាំងនោះ របស់កសិករគហបតីនោះ ផ្លាស់រដូវហើយ ក៏លូតលាស់ មានបង្កើមទុំបាន ។ ម្នាលភិក្ខុទាំងឡាយ ករណីយកិច្ចប្រព្រឹត្តទៅយ៉ាងរួសរាន់របស់ភិក្ខុនេះ ក៏មាន ៣ យ៉ាង យ៉ាងនោះដែរ ។ ករណីយកិច្ច ៣ យ៉ាង តើដូចម្តេច ។ គឺសមាទាននូវអធិសីលសិក្ខា ១ សមាទាននូវអធិចិត្តសិក្ខា ១ សមាទាននូវអធិប្បញ្ញា-

សិក្ខា ១ ។ ម្នាលភិក្ខុទាំងឡាយ ករណីយកិច្ចប្រព្រឹត្តទៅយ៉ាងរួសរាន់របស់ភិក្ខុមាន ៣ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះមិនមានឫទ្ធិ មិនមានអានុភាព ( បង្គាប់បញ្ជា ) ចិត្តនោះថា សូមឲ្យចិត្តរបស់អាត្មាអញ ផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ក្នុងថ្ងៃនេះ ឬថ្ងៃស្អែក ឬក៏ថ្ងៃខានស្អែក ដូច្នេះបានឡើយ ម្នាលភិក្ខុទាំងឡាយ លុះតែដល់វេលាហើយទើបចិត្តរបស់ភិក្ខុនោះ ដែលសិក្សានូវអធិសីលផង សិក្សានូវអធិចិត្តផង សិក្សានូវអធិប្បញ្ញាផង ផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំបាន ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយត្រូវសិក្សាយ៉ាងនេះថា ពួកយើងនឹងជាបុគ្គលមានឆន្ទៈយ៉ាងក្លៀវក្លា ក្នុងការសមាទាននូវអធិសីលសិក្ខា ពួកយើងនឹងជាបុគ្គលមានឆន្ទៈយ៉ាងក្លៀវក្លា ក្នុងការសមាទាននូវអធិចិត្តសិក្ខា ពួកយើងនឹងជាបុគ្គលមានឆន្ទៈយ៉ាងក្លៀវក្លា ក្នុងការសមាទាននូវអធិប្បញ្ញាសិក្ខា ដូច្នេះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសិក្សាយ៉ាងនេះចុះ ។

# អដ្ឋកថា

# លោណផលវគ្គទី ៥

## អច្ចាយិកសូត្រ

[ ៩៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអច្ចាយិកសូត្រទី ១ នៃលោណផលវគ្គទី ៥ ដូចតទៅ បទថា **អច្ចាយិកានិ** ប្រែថា ប្រញាប់ប្រញាល់ ។ បទថា **ករណីយានិ** ប្រែថា កិច្ចដែលត្រូវធ្វើយ៉ាងពិត ធុរៈណាមិនត្រូវធ្វើដោយពិតប្រាកដ ធុរៈនោះ ហៅថា កិច្ច ធុរៈដែលត្រូវធ្វើពិតប្រាកដ ឈ្មោះថា ករណី ។ បទថា **សីឃសីឃំ** ប្រែថា ដោយរហ័ស ។ បទថា **តំ** ក្នុងពាក្យថា **តស្ស ខោ តំ** នេះ ត្រឹមតែជានិបាត ។ បទថា **នត្ថិ សា ឥទ្ធិ វា អានុភាវោ វា** សេចក្ដីថា ឫទ្ធិនោះ ឬអានុភាពនោះមិនមាន ។

បទថា **ឧត្តរស្វេ** បានដល់ ក្នុងថ្ងៃទី ៣ គឺក្នុងថ្ងៃម្សិលមិញ ។ បទថា **ឧតុបរិណាមីនិ** បានដល់ ធញ្ញជាតិទាំងឡាយ បានទូវការផ្លាស់ប្ដូររដូវ ។ បទថា **ជាយន្តិបិ** បានដល់ មានពន្លកពណ៌សដុះចេញក្នុងថ្ងៃទី ៣ កាលគ្រប់ ៧ ថ្ងៃ ពន្លកក៏ប្រែជាមានពណ៌ខៀវ ។ បទថា **គព្ភិនីបិ ហោន្តិ** សេចក្ដីថា ដល់វេលាមួយខែកន្លះ ក៏មានបង្កើម ។ បទថា **បចន្តិបិ** សេចក្ដីថា ដល់ពេល ៣ ខែ ក៏ទុំ ។

ឥឡូវនេះ ព្រោះហេតុដែលព្រះពុទ្ធទាំងឡាយ មិនត្រូវការដោយគហបតី ឬដោយសន្ទូង តែទ្រង់នាំឧបមានោះមក ក៏ដើម្បីសម្ដែងបុគ្គល ឬអត្ថដែល

*សមគួរនឹងទេសនានោះក្នុងសាសនា ដូច្នោះ កាលទ្រង់សម្ដែងអត្ថដែលទ្រង់បំណងនឹងសម្ដែងដែលជាហេតុឲ្យនាំឧបមានោះមក ទើបត្រាស់ពាក្យថា* **ឯកមេវ ខោ** *ជាដើម ។ សូត្រនេះ កាលពោលដោយអត្ថងាយយល់ទាំងអស់ហើយ ។ សិក្ខា ព្រះមានព្រះភាគ ក៏ត្រាស់លាយគ្នាក្នុងសូត្រនេះ ៗ៙*

**អដ្ឋកថា អច្ចាយិកសូត្រទី ១ ចប់**

# សុត្តន្តបិដក
## វិវេកសូត្រទី២

*[ ៩៥ ] ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកជាអន្យតិរ្ថិយ រមែងបញ្ញត្តនូវសេចក្ដីស្ងប់ស្ងាត់ ៣ យ៉ាងនេះ ។ សេចក្ដីស្ងប់ស្ងាត់ ៣ យ៉ាង តើដូចម្ដេច ។ គឺសេចក្ដីស្ងប់ស្ងាត់ចាកកិលេស ដែលកើតឡើង ព្រោះអាស្រ័យចីវរ ១ សេចក្ដីស្ងប់ស្ងាត់ចាកកិលេស ដែលកើតឡើង ព្រោះអាស្រ័យបិណ្ឌបាត ១ សេចក្ដីស្ងប់ស្ងាត់ចាកកិលេស ដែលកើតឡើង ព្រោះអាស្រ័យសេនាសនៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកជាអន្យតិរ្ថិយ តែងបញ្ញត្តនូវហេតុនេះ ក្នុងសេចក្ដីស្ងប់ស្ងាត់ចាកកិលេសដែលកើតឡើង ព្រោះអាស្រ័យចីវរនោះ គឺ ទ្រទ្រង់សំពត់សម្បកធ្មៃខ្លះ ទ្រទ្រង់សំពត់ដែលត្បាញលាយគ្នាខ្លះ ទ្រទ្រង់សំពត់ដែលបកចេញអំពីសាកសពខ្លះ ទ្រទ្រង់សំពត់បំសុកូលខ្លះ ទ្រទ្រង់*

សំពត់ដែលធ្វើដោយសម្បកឈើខ្លះ ទ្រទ្រង់ស្បែកខ្លាឃ្មុំខ្លះ ទ្រទ្រង់ស្បែកខ្លាទាំងក្រចកខ្លះ ទ្រទ្រង់សំពត់ដែលក្រងដោយស្បូវខ្លះ ទ្រទ្រង់សំពត់ដែលក្រងដោយសម្បកក្រចៅខ្លះ ទ្រទ្រង់សំពត់ដែលក្រងដោយចម្រៀកក្តារខ្លះ ទ្រទ្រង់សំពត់កម្ពលដែលត្បាញដោយសក់មនុស្សខ្លះ ទ្រទ្រង់សំពត់កម្ពលដែលត្បាញដោយរោមកន្ទុយសេះខ្លះ ទ្រទ្រង់សំពត់ដែលក្រងដោយស្លាបមៀមខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកជាអន្យតិរ្ថិយ តែងបញ្ញត្តនូវហេតុនេះឯង ក្នុងសេចក្តីស្ងប់ស្ងាត់ចាកកិលេស ដែលកើតឡើង ព្រោះអាស្រ័យចីវរ ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកជាអន្យតិរ្ថិយ តែងបញ្ញត្តនូវហេតុនេះឯង ក្នុងសេចក្តីស្ងប់ស្ងាត់ចាកកិលេស ដែលកើតឡើង ព្រោះអាស្រ័យបិណ្ឌបាតនោះ គឺជាអ្នកមានបន្លែស្រស់ជាអាហារខ្លះ មានអង្ករស្រងែជាអាហារខ្លះ មានស្គួយជាអាហារខ្លះ មានកម្ទេច ( ចំនៀរ ) ស្បែកជាអាហារខ្លះ មានស្លែ ឬសារាយជាអាហារខ្លះ មានកន្ទក់ជាអាហារខ្លះ មានបាយក្តាំងជាអាហារខ្លះ មានម្សៅជាអាហារខ្លះ មានស្មៅជាអាហារខ្លះ មានអាចម៍គោជាអាហារខ្លះ មានមើមឈើ និងផ្លែឈើព្រៃជាអាហារខ្លះ បរិភោគតែផ្លែឈើដែលជ្រុះស្រាប់ ចម្អែតអាត្មា ។ ម្នាលភិក្ខុទាំងឡាយ បរិព្វាជកជាអន្យតិរ្ថិយតែងបញ្ញត្តនូវហេតុនេះឯង ក្នុងសេចក្តីស្ងប់ស្ងាត់ ចាកកិលេសដែលកើតឡើង ព្រោះអាស្រ័យបិណ្ឌបាត ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកជាអន្យតិរ្ថិយ តែងបញ្ញត្តនូវហេតុនេះ ក្នុងសេចក្តីស្ងប់ស្ងាត់ចាកកិលេសដែលកើតឡើង ព្រោះអាស្រ័យសេនាសនៈនោះ គឺព្រៃម្ងប់ឈើ ព្រៃ

ស្មសាន ព្រៃធំ ទីវាល គំនរចំបើង ពេងទីលាន ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកជាអន្យតិ្ថិយ តែងបញ្ញត្តនូវហេតុនេះឯង ក្នុងសេចក្តីស្ងប់ស្ងាត់ ចាកកិលេសដែលកើតឡើង ព្រោះអាស្រ័យសេនាសនៈ ។ ម្នាលភិក្ខុទាំង-ឡាយ ពួកបរិព្វាជកជាអន្យតិ្ថិយ តែងបញ្ញត្តនូវសេចក្តីស្ងប់ស្ងាត់មាន ៣ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចំណែកសេចក្តីស្ងប់ស្ងាត់របស់ភិក្ខុ ក្នុងធម្មវិន័យនេះ ក៏មាន ៣ យ៉ាងនេះដែរ ។ សេចក្តីស្ងប់ស្ងាត់ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គឺភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល លះបង់ការទ្រុស្តសីល ស្ងប់ស្ងាត់ចាកការទ្រុស្តសីល ១ ជាអ្នកឃើញត្រូវ លះបង់ការឃើញខុស ស្ងប់ស្ងាត់ចាកការឃើញខុសនោះ ១ ជាខីណាស្រព លះបង់អាសវៈ ស្ងប់ស្ងាត់ចាកអាសវៈនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលណាភិក្ខុជាអ្នកមានសីល លះបង់ការទ្រុស្តសីល ស្ងប់ស្ងាត់ចាកការទ្រុស្តសីលនោះ ជាអ្នកឃើញត្រូវ លះបង់ការឃើញខុស ស្ងប់ស្ងាត់ចាកការឃើញខុសនោះ ជាខីណាស្រព លះបង់អាសវៈ ស្ងប់ស្ងាត់ចាកអាសវៈហើយ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ភិក្ខុនេះ ជាអ្នកដល់នូវការប្រសើរបំផុត ដល់នូវខ្លឹមសារបរិសុទ្ធ តាំងនៅស៊ប់ ក្នុងធម៌មានខ្លឹម ។ ម្នាលភិក្ខុទាំងឡាយ ដូចជាស្រែស្រូវសាលីដ៏បរិបូណ៌របស់កស្សកគហបតី ។ កស្សកគហបតី ត្រូវព្រោះស្រូវនោះយ៉ាងប្រញាប់ លុះព្រោះរួចយ៉ាងប្រញាប់ហើយ ត្រូវច្រូតយ៉ាងប្រញាប់ លុះច្រូតយ៉ាងប្រញាប់ហើយ ត្រូវដឹកនាំជញ្ជូនដាក់លានយ៉ាងប្រញាប់ លុះជញ្ជូនដាក់លានយ៉ាងប្រញាប់ហើយ ត្រូវគរជាគំនរ

យ៉ាងប្រញាប់ លុះគរជាគំនរយ៉ាងប្រញាប់ហើយ ត្រូវបែន ឬបញ្ចូនយ៉ាងប្រញាប់ លុះបែនឬបញ្ជូនយ៉ាងប្រញាប់ហើយ ត្រូវជជុះចំបើងយ៉ាងប្រញាប់ លុះជជុះចំបើងយ៉ាងប្រញាប់ហើយ ត្រូវរាស់កម្ទេច ឬកំញូមយ៉ាងប្រញាប់ លុះរាស់កម្ទេច ឬកំញូមយ៉ាងប្រញាប់ហើយ ត្រូវរោយយ៉ាងប្រញាប់ លុះរោយយ៉ាងប្រញាប់ហើយ ត្រូវជញ្ជូនដាក់ជង្រុកយ៉ាងប្រញាប់ លុះជញ្ជូនដាក់ជង្រុកយ៉ាងប្រញាប់ហើយ ត្រូវបុកយ៉ាងប្រញាប់ លុះបុកយ៉ាងប្រញាប់ហើយ ត្រូវអុំយកអង្កាមចេញយ៉ាងប្រញាប់ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ ស្រូវរបស់កស្សកគហបតីនោះ រមែងដល់នូវការប្រសើរបំផុតដល់នូវខ្លឹមសារដ៏បរិសុទ្ធ តាំងនៅស៊ប់ ក្នុងខ្លឹមសារ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសីល លះបង់នូវការទ្រុស្តសីល ស្ងប់ស្ងាត់ចាកការទ្រុស្តសីលនោះផង ជាអ្នកឃើញត្រូវ លះបង់នូវការឃើញខុស ស្ងប់ស្ងាត់ចាកការឃើញខុសនោះផង ជាខីណាស្រព លះបង់អាសវៈ ស្ងប់ស្ងាត់ចាកអាសវៈនោះផង ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ភិក្ខុនេះជាអ្នកដល់នូវការប្រសើរបំផុត ដល់នូវខ្លឹមសារ បរិសុទ្ធ តាំងនៅស៊ប់ ក្នុងធម៌មានខ្លឹមសារ ក៏យ៉ាងនោះដែរ ។

# អដ្ឋកថា

## វិវិត្តសូត្រ

[ ៩៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវិវិត្តសូត្រទី ២ ដូចតទៅនេះ បទថា **ចីវរបវិវេកំ** បានដល់ ការស្ងាត់ចាកកិលេស ដែលកើតឡើង ព្រោះអាស្រ័យចីវរ ។ ក្នុងបទដ៏សេស ក៏មានន័យតែមួយដូចគ្នានោះឯង ។ បទថា **សាណានិ** បានដល់ សំពត់ដែលត្បាញដោយសម្បកធ្មៃ ។ បទថា **មសាណានិ** បានដល់ សំពត់មានសាច់លាយឡំគ្នា ។ បទថា **ឆវទុស្សានិ** បានដល់ សំពត់ដែលចោលអំពីសរីរៈរបស់មនុស្សស្លាប់ ឬសំពត់ដែលធ្វើដោយស្មៅឯរកៈជាដើម ។ បទថា **បំសុកូលានិ** បានដល់ សំពត់មិនមានជាយដែលចោលលើផែនដី ។ បទថា **តិរីដកានិ** បានដល់ សំពត់សម្បកឈើ ។ បទថា **អជិនានិ** បានដល់ ស្បែកខ្លាដំបង ។ បទថា **អជិនក្ខិបំ** បានដល់ ស្បែកខ្លាដំបងនោះឯង ដែលវះត្រង់កណ្តាល អាចារ្យពួកខ្លះពោលថា **សហាខុរកំ** ស្បែកខ្លាទាំងក្រចក ដូច្នេះក៏មាន ។ បទថា **កុសចីរំ** បានដល់ ចីវរដែលត្បាញដោយស្បូវភ្លាំង ។ ក្នុងសំពត់ដែលក្រងដោយស្គារ និងសំពត់សម្បកឈើ ក៏មានន័យនេះឯង ។ បទថា **កេសកម្ពលំ** បានដល់ សំពត់កម្ពល ដែលធ្វើដោយសក់មនុស្ស ។ បទថា **វាលកម្ពលំ** បានដល់ សំពត់កម្ពលដែលធ្វើដោយកន្ទុយសេះជាដើម ។ បទថា **ឧលូកបក្ខិកំ** បានដល់ សំពត់ដែលធ្វើដោយស្លាបមៀម ។

បទថា **សាកភក្ខា** បានដល់ មានបន្លែស្រស់ជាភក្ខា ។ បទថា

**សាមាកភត្តា** បានដល់ មានស្រូវស្មៅជាភិក្ខា ។ ក្នុងបទថា **និវារ** ជាដើម វីហិជាតិដែលដុះឡើងឯងក្នុងព្រៃ ឈ្មោះថា **និវារ** គឺស្រូវ ។ បទថា **ទទ្ទុលំ** បានដល់ ចម្រៀកសាច់ដែលពួកជាងស្បែកចៀរស្បែក ហើយគរ ។ ជ័រក្តី សារាយក្តី ជ័រឈើ មានជ័រកណិការជាដើមក្តី ហៅថា **ហដ** ។ បទថា **កណំ** ប្រែថា កន្ទក់ ។ បទថា **អាចាមោ** បានដល់ បាយក្តាំងដែលជាប់ត្រង់ឆ្នាំង តាបសទាំងឡាយ ក៏នាំយកបាយក្តាំងនោះ ដែលគេបោះចោលហើយទំពាស៊ី ។ អាចារ្យពួកខ្លះពោលថា **ឱទនកញ្ជិយំ** ដូច្នេះក៏មាន ។ ល្ងបុកជាដើមប្រាកដជាក់ច្បាស់ហើយ ។ បទថា **បវត្តផលភោជី** បានដល់ មានប្រក្រតីបរិភោគផ្លែឈើដែលជ្រុះឯង ។ បទថា **កុសាគារំ** បានដល់ រោងអង្គាម ។

បទថា **សីលវា** បានដល់ ប្រកបដោយបារិសុទ្ធិសីល ៤ ។ បទថា **ទុស្សីលព្យស្ស បហីនំ ហោតិ** សេចក្តីថា ការទ្រុស្តសីល ៥ ឈ្មោះថា ភិក្ខុនោះលះបានហើយ ។ បទថា **សម្មាទិដ្ឋិកោ** បានដល់ ជាអ្នកមានទិដ្ឋិតាមសេចក្តីពិត ។ បទថា **មិច្ឆាទិដ្ឋិ** បានដល់ ជាអ្នកមានទិដ្ឋិមិនប្រព្រឹត្តទៅតាមសេចក្តីពិត ។ បទថា **អាសវា** បានដល់ អាសវៈ ៤ ។ បទថា **អគ្គប្បត្តោ** បានដល់ ដល់នូវកំពូលនៃសីល ។ បទថា **សារប្បត្តោ** បានដល់ ដល់នូវសីលសារៈ ។ បទថា **សុទ្ធោ** ប្រែថា បរិសុទ្ធ ។ បទថា **សារេ បតិដ្ឋិតោ** បានដល់ តាំងមាំនៅក្នុងសារធម៌ គឺសីល សមាធិ និងបញ្ញា ។

បទថា **សេយ្យថាបិ** ស្មើគ្នានឹង **យថា នាម** ប្រែថា ( ឈ្មោះយ៉ាង

ណា ) ។ បទថា **សម្បន្នំ** គឺបរិបូណ៌ បានដល់ ពេញដោយស្រូវសាលីទុំ ។ បទថា **សង្ឃរាបេយ្យ** បានដល់ អ្នកស្រែគប្បីឲ្យដញ្ជូនមក ។ បទថា **ឧព្ពូ-ហាបេយ្យ** បានដល់ គប្បីឲ្យនាំមកកាន់លាន ។ បទថា **ភុសិកំ** ប្រែថា អង្កាម ។ បទថា **កោដ្ដាបេយ្យ** បានដល់ គប្បីឲ្យចាក់ចូលទៅក្នុងត្បាល់ ហើយយកអង្រែបុក ។ បទថា **អគ្គប្បត្តានិ** បានដល់ ធញ្ញជាតិទាំងឡាយ ដល់នូវភាពជាបាយល្អ ។ ក្នុងបទថា **សារប្បត្តានិ** ជាដើម ក៏មានន័យនេះឯង ។ ឯបទដ៏សេស មានអត្ថងាយយល់ទាំងអស់ហើយ ។

ឯពាក្យណាដែលត្រាស់ក្នុងសូត្រនេះថា ការទ្រុស្តសីល ភិក្ខុនោះលះបានហើយ ហើយមិច្ឆាទិដ្ឋិ ភិក្ខុនោះក៏លះបានហើយ ដូច្នេះ ពាក្យនោះគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់សំដៅយកការទ្រុស្តសីល និងមិច្ឆាទិដ្ឋិដែលភិក្ខុលះបានហើយ ដោយសោតាបត្តិមគ្គ ។៙

## អដ្ឋកថាវិត្តសូត្រទី ២ ចប់

# សុត្តន្តបិដក

## សរទសូត្រទី ៣

[ ៩៦ ] ម្នាលភិក្ខុទាំងឡាយ ដូចជាព្រះអាទិត្យស្វាងស្រឡះចាកពពក ពួជ៏អាកាស ដែលមានវលាហកៈប្រាសទៅឆ្ងាយ ក្នុងសរទសម័យ ហើយក៏កម្ចាត់បង់នូវងងឹត ដែលនៅឯអាកាសទាំងអស់ រមែងភ្លឺត្រចះត្រចង់ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលណា ធម្មចក្ខុដែលប្រាសចាកធូលី ប្រាសចាកមន្ទិល បានកើតឡើងដល់អរិយសាវកហើយ ម្នាលភិក្ខុទាំងឡាយ ទើបអរិយសាវកលះបង់នូវសញ្ញោជនៈ ៣ ប្រការ គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ ជាមួយនឹងការកើតឡើងនៃទស្សនៈ លុះកាលជាខាងក្រោយមកទៀត ក៏រើចេញចាកធម៌ ២ យ៉ាង គឺអភិជ្ឈា ១ ព្យាបាទ ១ ។ អរិយសាវកនោះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏ដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្ក និងវិចារ មានបីតិ និងសុខកើតអំពីសេចក្ដីស្ងាត់ សម្រេចសម្រាន្តនៅ ។ ម្នាលភិក្ខុទាំងឡាយ បើអរិយសាវកធ្វើកាលកិរិយាក្នុងសម័យនោះ អរិយសាវកនោះរមែងមិនប្រកបដោយសញ្ញោជនៈ ដែលនាំឲ្យមកកាន់លោកនេះទៀតឡើយ ។

# អដ្ឋកថា

## សរទសូត្រ

[ ៩៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសរទសូត្រទី ៣ ដូចតទៅនេះ បទថា **វិទ្ធេ** គឺភ្លឺច្បាស់ ព្រោះប្រាសចាកពពក ។ បទថា **ទេវេ** គឺអាកាស ។ បទថា **អភិវិហច្ច** គឺកម្ចាត់ ។ បទថា **យទា** គឺក្នុងកាលណា ។ បទថា **វិរជំ** គឺប្រាសចាកធូលី មានរាគៈជាដើម ដែលឈ្មោះថា ប្រាសចាកមន្ទិល ព្រោះមន្ទិលទាំងនោះឯងប្រាសទៅហើយ ។ បទថា **ធម្មចក្ខុំ** បានដល់ ចក្ខុ គឺសោតាបត្តិមគ្គ ដែលកំណត់ធម៌ គឺសច្ចៈ ៤ ។ បទថា **នត្ថិ តំ សញ្ញោជនំ** សេចក្ដីថា ព្រះអរិយសាវកនោះ មិនមានសំយោជនៈ ២ យ៉ាង គឺអភិជ្ឈា និងព្យាបាទ ។ ម្យ៉ាងទៀត ក្នុងសូត្រក្រៅអំពីនេះ លោកពោលថា មិនមាន ក៏ព្រោះមិនអាចនាំមកកាន់លោកនេះបានទៀត ។ ពិតហើយ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់សំដៅដល់ព្រះអនាគាមី ៕ល៕

**អដ្ឋកថា សរទសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## បរិសាសូត្រទី ៤

[ ៩៧ ] ម្នាលភិក្ខុទាំងឡាយ បរិសទ្យនេះមាន ៣ ពួក ។ បរិសទ្យ ៣ ពួក តើដូចម្តេច ។ គឺអគ្គវតីបរិសទ្យ ( បរិសទ្យមានគុណប្រសើរបំផុត ) ១ វគ្គបរិសទ្យ ( បរិសទ្យជាពួក ) ១ សមគ្គបរិសទ្យ ( បរិសទ្យមានសេចក្តីព្រមព្រៀងគ្នា ) ១ ។ ម្នាលភិក្ខុទាំងឡាយ អគ្គវតីបរិសទ្យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានពួកភិក្ខុជាថេរៈ ក្នុងបរិសទ្យណា មិនល្មោភ ( ក្នុងបច្ច័យ ) មិនបន្ធូរបន្ថយ ( ក្នុងត្រៃសិក្ខា ) ដាក់ចុះនូវធុរៈ ក្នុងទីទាប គឺនីវរណៈទាំង ៥ មានការស្ទុះទៅក្នុងសេចក្តីស្ងប់ស្ងាត់ជាប្រធាន ប្រារព្ធព្យាយាមដើម្បីដល់នូវធម៌ ដែលមិនទាន់ដល់ ដើម្បីបាននូវធម៌ដែលមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលមិនទាន់ធ្វើឲ្យជាក់ច្បាស់ ពួកជនជាខាងក្រោយ រមែងដល់នូវទិដ្ឋានុគតិនៃភិក្ខុជាថេរៈទាំងនោះ ឯពួកបរិសទ្យនោះ ក៏មិនបានល្មោភក្នុងបច្ច័យ មិនបានបន្ធូរបន្ថយក្នុងត្រៃសិក្ខា ដាក់ចុះនូវធុរៈ ក្នុងទីទាប មានការស្ទុះទៅ ក្នុងសេចក្តីស្ងប់ជាប្រធាន ប្រារព្ធព្យាយាមដើម្បីដល់នូវធម៌ដែលមិនទាន់ដល់ ដើម្បីបាននូវធម៌ដែលមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលមិនទាន់ធ្វើឲ្យជាក់ច្បាស់ដែរ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ហៅថា អគ្គវតីបរិសទ្យ ។ ម្នាលភិក្ខុទាំងឡាយ វគ្គបរិសទ្យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ពួកភិក្ខុបរិសទ្យណា ជាអ្នកបង្កហេតុ បង្កជម្លោះ ទាស់ទែងគ្នា ចាក់

ដោតគ្នាទៅវិញទៅមក ដោយលំពែង គឺមាត់ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថា វគ្គបរិសទ្យ ។ ម្នាលភិក្ខុទាំងឡាយ សមគ្គបរិសទ្យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ពួកភិក្ខុបរិសទ្យណា ព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា មានសភាពដូចជាទឹកដោះ លាយដោយទឹក មើលគ្នាទៅវិញទៅមក ដោយចក្ខុជាទីស្រឡាញ់ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថា សមគ្គបរិសទ្យ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងវេលាណា ពួកភិក្ខុមានសេចក្តីព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា មានសភាពដូចទឹកដោះ លាយដោយទឹក មើលគ្នាទៅវិញទៅមក ដោយចក្ខុជាទីស្រឡាញ់ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុរមែងបានបុណ្យដ៏ច្រើន ក្នុងវេលានោះ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុរមែងនៅដោយព្រហ្មវិហារធម៌ ក្នុងវេលានោះ កាលបើភិក្ខុមានចិត្តរីករាយ ដោយមុទិតាចេតោវិមុត្តិហើយ បីតិក៏កើតឡើង កាលបើភិក្ខុមានចិត្តប្រកបដោយបីតិ កាយក៏ស្ងប់រម្ងាប់ លុះភិក្ខុមានកាយស្ងប់រម្ងាប់ហើយ ក៏ទទួលនូវសេចក្តីសុខ កាលបើភិក្ខុបានទទួលនូវសុខហើយ ទើបចិត្តតាំងមាំក្នុងអារម្មណ៍បាន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាភ្លៀងដែលមានគ្រាប់ដ៏ធំៗ បង្អុរចុះមកលើភ្នំ ទឹកភ្លៀងនោះ រមែងហូរទៅកាន់ទំនាប បំពេញជ្រោះភ្នំ អូរ និងប្រឡាយ លុះជ្រោះភ្នំ អូរ និងប្រឡាយពេញហើយ ក៏បំពេញបឹងតូចៗ លុះបឹងតូចៗ ពេញហើយ ក៏បំពេញបឹងធំៗ លុះបឹងធំៗ ពេញហើយ ក៏បំពេញស្ទឹងតូចៗ លុះស្ទឹងតូចៗ ពេញហើយ ក៏បំពេញស្ទឹងធំៗ លុះស្ទឹងធំៗ ពេញហើយ ក៏បំពេញសមុទ្រ យ៉ាងណាមិញ ម្នាលភិក្ខុ

ទាំងឡាយ ក្នុងវេលាណា ពួកភិក្ខុមានសេចក្តីព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា មានសភាពដូចជាទឹកដោះ លាយដោយទឹក មើលគ្នាទៅវិញទៅមក ដោយចក្ខុជាទីស្រឡាញ់ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុរមែងបាននូវបុណ្យដ៏ច្រើន ក្នុងវេលានោះ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុរមែងនៅដោយព្រហ្មវិហារធម៌ ក្នុងវេលានោះ កាលបើភិក្ខុមានចិត្តរីករាយ ដោយមុទិតា-ចេតោវិមុត្តិហើយ បីតិក៏កើតឡើង កាលបើភិក្ខុមានចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ លុះភិក្ខុមានកាយស្ងប់រម្ងាប់ហើយ ក៏ទទួលនូវសុខ កាលបើភិក្ខុបានទទួលសុខហើយ ចិត្តក៏តាំងមាំបាន ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ បរិសទ្យមាន ៣ ពួក នេះឯង ។

# អដ្ឋកថា

## បរិសាសូត្រ

[ ៩៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបរិសាសូត្រទី ៤ ដូចតទៅនេះ បទថា **ន ពាហុលិកា ហោន្តិ** សេចក្តីថា មិនជាអ្នកច្រើនដោយបច្ច័យ ។ បទថា **ន សាថលិកា** គឺមិនទទួលសិក្ខា ៣ ធ្វើឲ្យធូរថយ ។ បទថា **ឱក្កមនេ និក្ខិត្តធុរា** សេចក្តីថា នីវរណៈ ៥ ហៅថា ឱក្កមនៈ ព្រោះអត្ថថា ធ្វើឲ្យធ្លាក់ចុះ គឺភិក្ខុដែលជាថេរៈ បោះបង់នូវធុរៈក្នុងនីវរណៈ ដែលធ្វើឲ្យធ្លាក់

ចុះទាំងនោះ ។ បទថា **បវិវេកេ បុព្វង្គមា** សេចក្ដីថា ជាប្រធានក្នុងវិវេក ៣ យ៉ាង គឺកាយវិវេក ចិត្តវិវេក និងឧបធិវិវេក ។ បទថា **វីរិយំ អារភន្តិ** បានដល់ ផ្ដើមសេចក្ដីព្យាយាមទាំង ២ យ៉ាង ។ បទថា **អប្បត្តស្ស** បានដល់ មិនសម្រេចគុណវិសេស ពោល គឺឈាន វិបស្សនា មគ្គ និង ផល ។ ក្នុងបទដ៏សេស ក៏មានន័យនេះឯង ។

បទថា **បច្ឆិមា ជនតា** បានដល់ ប្រជុំជនខាងក្រោយ មានសទ្ធិវិហារិក និងអន្តេវាសិកជាដើម ។ បទថា **ទិដ្ឋានុគតឹ អាបជ្ជតិ** សេចក្ដីថា ធ្វើតាមឧបជ្ឈាយ៍ និងអាចារ្យបានធ្វើមកហើយ ។ ប្រជុំជនខាងក្រោយ ឈ្មោះថា ដល់នូវការដើរទៅតាមវត្តដែលប្រជុំជននោះ បានឃើញមកហើយ ក្នុងឧបជ្ឈាយ៍ និងអាចារ្យ ។ បទថា **អយំ វុច្ចតិ ភិក្ខវេ អគ្គវតី បរិសា** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះ ហៅថា បរិស័ទដែលមានតែ មនុស្សល្អ ។

បទថា **ភណ្ឌនជាតា** ប្រែថា កើតនូវជម្លោះ ។ បទថា **កលហជាតា** ប្រែថា កើតនូវការទាស់ទែងគ្នា ចំណែកខាងដើមនៃ **ភណ្ឌនជាតា** ឈ្មោះថា **កលហជាតា** ក្នុងសូត្រនេះ ។ ការកន្ទងល្មើសដោយអំណាច ចាប់ដៃគ្នាជាដើម ឈ្មោះថា **កលហ** ។ បទថា **វិវាទាបន្នា** បានដល់ ដល់នូវការវាយតប់គ្នា ។ បទថា **មុខសត្តីហិ** សេចក្ដីថា វាចាដែលគ្រោតគ្រាត ហៅថា លំពែង គឺមាត់ ព្រោះអត្ថថា ចាក់ទម្លុះនូវគុណ គឺភិក្ខុទាំងឡាយ ចាក់ទម្លុះគ្នានិងគ្នាដោយលំពែង គឺមាត់ទាំងនោះ ។ បទថា **វិតុទន្តា វិហរន្តិ**

គឺចាក់គ្នានិងគ្នា ។

បទថា **សមគ្គា** ប្រែថា ព្រមព្រៀងគ្នា ។ បទថា **សម្មោទមានា** បានដល់ មានការត្រេកអរប្រព្រឹត្តទៅព្រម ។ បទថា **ខីរោទកីភូតា** បានដល់ ចូលគ្នាបានដូចទឹក និងទឹកដោះ ។ បទថា **បិយចក្ខូហិ** បានដល់ ដោយមេត្តាចក្ខុ ដែលស្ងប់ត្រជាក់ ។

បទថា **បីតិ ជាយតិ** បានដល់ បីតិ ៥ ប្រភេទកើតឡើង ។ បទថា **កាយោ បស្សម្ភតិ** សេចក្តីថា នាមកាយក្តី រូបកាយក្តី ដែលប្រាសចាកការក្រវល់ក្រវាយ ។ បទថា **បស្សទ្ធកាយោ** បានដល់ មានកាយមិនរសាប់រសល់ ។ បទថា **សុខំ វេទិយតិ** បានដល់ សោយសុខទាំងកាយ និងចិត្ត ។ បទថា **សមាធិយតិ** សេចក្តីថា ចិត្តរបស់ភិក្ខុដែលមានសេចក្តីសុខ រមែងតាំងមាំនៅក្នុងអារម្មណ៍ ។ បទថា **ថុល្លផុសិតកេ** បានដល់ ភ្លៀងដែលមានតំណក់ធំ ។ ក្នុងបទថា **បព្វតកន្ទរបទរសាខា** នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ដែលឈ្មោះថា **កន្ទរ** បានដល់ ចំណែកមួយរបស់ភ្នំ ដែលត្រូវទឹកឈ្មោះថា **កំ** ប្រោះហើយ គឺទម្លាយហើយ ដែលសត្វលោកហៅថា **និតម្ពខ្វះ ឆទីនិកុញ្ជ ខ្វះ** ។ ដែលឈ្មោះថា **បទរ** បានដល់ បទេសដែលបែកក្រហែង ក្នុងកាលភ្លៀងមិនធ្លាក់អស់កន្លះខែ ។ ដែលឈ្មោះថា **សាខា** បានដល់ ប្រឡាយតូចសម្រាប់នាំទឹកទៅកាន់អូរ ។ ដែលឈ្មោះថា **កុសោព្ភា** បានដល់ អូរ និងប្រឡាយ ។ ដែលឈ្មោះថា **មហាសោព្ភា** បានដល់ បឹង ។ ដែលឈ្មោះថា **កុន្នទិយោ** បានដល់ ស្ទឹងតូច ។ ដែលឈ្មោះថា **មហា-**

ឆក្ខិយោ បានដល់ ស្ទឹងធំ មានស្ទឹងគង្គា និងស្ទឹងយមុនាជាដើម ។ល។

## អដ្ឋកថា បរិសាសូត្រទី ៤ ចប់

# សុត្តន្តបិដក

## បឋមអាជានីយសូត្រទី ៥

[ ៩៨ ] ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អរបស់ព្រះរាជាដែលប្រកបដោយអង្គ ៣ ជាសេះគួរដល់ព្រះរាជា ជាសេះព្រះរាជទ្រព្យដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជា ។ ប្រកបដោយអង្គ ៣ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អរបស់ព្រះរាជាក្នុងលោកនេះ ជាសេះបរិបូណ៌ដោយសម្បុរ ១ បរិបូណ៌ដោយកម្លាំង ១ បរិបូណ៌ដោយសម្ទុះ ១ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អ របស់ព្រះរាជាដែលប្រកបដោយអង្គ ៣ នេះឯង ជាសេះគួរដល់ព្រះរាជា ជាសេះព្រះរាជទ្រព្យ ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយធម៌ ៣ យ៉ាង ជាអ្នកគួរទទួលនូវរបស់ដែលគេនាំមកបូជា គួរទទួលនូវរបស់ដែលគេបម្រុងទទួលភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរបំផុតរបស់សត្វលោក ក៏យ៉ាងនោះដែរ ។ ប្រកបដោយធម៌ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកបរិបូណ៌ដោយសម្បុរ

១ បរិបូណ៌ដោយកម្លាំង ១ បរិបូណ៌ដោយសម្មុះ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុដែលបរិបូណ៌ដោយសម្បុរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីលសង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈ និងគោចរ ជាអ្នកឃើញនូវភ័យ ក្នុងទោសសូម្បីយ៉ាងតូច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយសម្បុរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយកម្លាំង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រារព្ធព្យាយាម ដើម្បីលះពួកធម៌ជាអកុសល ដើម្បីញុំាងពួកធម៌ជាកុសលឲ្យបរិបូណ៌ ជាអ្នកមានកម្លាំង មានសេចក្តីសង្វាតយ៉ាងមាំ មិនដាក់ចុះនូវធុរៈក្នុងកុសលធម៌ទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយកម្លាំង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយសម្មុះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះជាទីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយសម្មុះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាងនេះឯង ទើបជាអ្នកគួរទទួលនូវរបស់ដែលគេនាំមកបូជា គួរទទួលនូវរបស់ដែលគេបម្រុងទទួលភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរបំផុតរបស់សត្វលោក ។

# អដ្ឋកថា

## បឋមអាជានីយសូត្រ

[ ៩៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមអាជានីយសូត្រទី ៥ ដូចតទៅនេះ បទថា **អង្គេហិ** គឺដោយអង្គគុណទាំងឡាយ ។ បទថា **រាជារហោ** គឺ ( សេះអាជានេយ្យ ) សមគួរ បានដល់ សមគួរដល់ព្រះរាជា ។ បទថា **រាជភោគ្គោ** គឺជាសេះរបស់ព្រះរាជា ។ បទថា **រញ្ញោ អង្គំ** បានដល់ ដល់នូវការរាប់ថា ជាអង្គអវយវៈរបស់ព្រះរាជា ព្រោះមានជើងមុខ និងជើងក្រោយជាដើមសមសួន ។ បទថា **វណ្ណសម្បន្នោ** បានដល់ ដល់ព្រមដោយពណ៌កាំងកាយ ។ បទថា **ពលសម្បន្នោ** បានដល់ សម្បូរដោយកម្លាំងកាយ ។ បទថា **ជវសម្បន្នោ** បានដល់ ដល់ព្រមដោយសម្ទុះ ។

បទថា **អាហុនេយ្យោ** បានដល់ ជាអ្នកសមគួរទទួលបិណ្ឌបាត ពោល គឺរបស់ដែលគេនាំមកបូជា ។ បទថា **បាហុនេយ្យោ** បានដល់ ជាអ្នកសមគួរទទួលភត្តដែលគេរៀបចំទុកទទួលភ្ញៀវ ។ បទថា **ទក្ខិណេយ្យោ** បានដល់ ជាអ្នកសមគួរដល់ទក្ខិណា ពោល គឺរបស់ដែលគេប្រគេនដោយសទ្ធា ដោយអំណាចទានវត្ថុ ១០ យ៉ាង ។ បទថា **អញ្ជលិករណីយោ** បានដល់ ជាអ្នកសមគួរដល់ការផ្គងអញ្ជលី ។ បទថា **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** បានដល់ ជាទីដុះដាលនៃបុណ្យសត្វលោកទាំងអស់ មិនមានទីដទៃស្មើ ។

បទថា **វណ្ណសម្បន្នោ** បានដល់ ដល់ព្រមដោយវណ្ណៈ គឺគុណ ។

បទថា **ពលសម្បន្នោ** បានដល់ សម្បូរដោយកម្លាំងវិរិយៈ ។ បទថា **ជវ-សម្បន្នោ** បានដល់ ដល់ព្រមដោយកម្លាំងញាណ ។ បទថា **ថាមវា** បានដល់ ដល់ព្រមដោយកម្លាំងនៃញាណ ។ បទថា **ឧឡារបរក្កមោ** បានដល់ មានការព្យាយាមមាំទាំ ។ បទថា **អនិក្ខិត្តធុរោ** បានដល់ មិនដាក់ធុរៈ គឺបដិបត្តិទៅដោយគិតយ៉ាងនេះថា អញមិនសម្រេចអរហត្តផលដែលជាផលដ៏ប្រសើរហើយ នឹងមិនដាក់ធុរៈ គឺសេចក្តីព្យាយាម ។

ក្នុងសូត្រនេះ សោតាបត្តិមគ្គ ព្រះមានព្រះភាគត្រាស់ដោយអំណាចសច្ចៈ ៤ និងដោយការដល់ព្រមដោយសម្មុះនៃញាណ ត្រាស់ហើយដោយសោតាបត្តិមគ្គ ដូច្នេះ ៕

**អដ្ឋកថា បឋមអាជានីយសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ទុតិយអាជានីយសូត្រទី៦

[ ៩៩ ] ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អរបស់ព្រះរាជាដែលប្រកបដោយអង្គ ៣ ជាសេះគួរដល់ព្រះរាជា ជាសេះព្រះរាជទ្រព្យ ដល់នូវការរាប់ថាជាអង្គនៃព្រះរាជា ។ ប្រកបដោយអង្គ ៣ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អរបស់ព្រះរាជាក្នុងលោកនេះ ជាសេះបរិបូណ៌

ដោយសម្បុរ ១ បរិបូណ៌ដោយកម្លាំង ១ បរិបូណ៌ដោយសម្ផុះ ១ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អរបស់ព្រះរាជាដែលប្រកបដោយអង្គ ៣ យ៉ាងនេះឯង ទើបជាសេះគួរដល់ព្រះរាជា ជាសេះព្រះរាជទ្រព្យ ដល់នូវការរាប់ថាជាអង្គនៃព្រះរាជា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយធម៌ ៣ យ៉ាង ជាអ្នកគួរទទួលនូវរបស់ដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរបំផុតរបស់សត្វលោក ក៏យ៉ាងនោះដែរ ។ ប្រកបដោយធម៌ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកបរិបូណ៌ដោយសម្បុរ ១ បរិបូណ៌ដោយកម្លាំង ១ បរិបូណ៌ដោយសម្ផុះ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយសម្បុរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។បេ។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយសម្បុរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយកម្លាំង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រារព្ធព្យាយាម ។បេ។ មិនដាក់ធុរៈក្នុងកុសលធម៌ទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយកម្លាំងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិបូណ៌ដោយសម្ផុះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានជាឱបបាតិកៈ ( ក្នុងសុទ្ធាវាស ) ព្រោះអស់សញ្ញោជនៈ ៥ ជាចំណែកខាងក្រោមហើយ បរិនិព្វានក្នុងសុទ្ធាវាសនោះ មានសភាពមិនត្រឡប់ចាកលោកនេះវិញឡើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយសម្ផុះ យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាងនេះឯង ទើបជាអ្នកគួរទទួលនូវរបស់ដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរបំផុតរបស់សត្វលោក ។

# អដ្ឋកថា

## ទុតិយអាជានីយសូត្រ

[ ៩៩ ] សូត្រទី ៦ មគ្គ ៣ ផល ៣ ព្រះមានព្រះភាគត្រាស់ហើយ និងភាពជាអ្នកដល់ព្រមដោយសម្មុះនៃញាណ ព្រះមានព្រះភាគ ក៏ត្រាស់ហើយ ដោយមគ្គ ៣ ផល ៣ ។៚

### អដ្ឋកថា ទុតិយអាជានីយសូត្រទី ៦ ចប់

# សុត្តន្តបិដក

## តតិយអាជានីយសូត្រទី ៧

[ ១០០ ] ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អ របស់ព្រះរាជា ដែលប្រកបដោយអង្គ ៣ ជាសេះគួរដល់ព្រះរាជា ជាសេះព្រះរាជទ្រព្យ ដល់

នូវការរាប់ថាជាអង្គរបស់ព្រះរាជា ។ ប្រកបដោយអង្គ ៣ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អ របស់ព្រះរាជាក្នុងលោកនេះ ជាសេះបរិបូណ៌ដោយសម្បុរ ១ បរិបូណ៌ដោយកម្លាំង ១ បរិបូណ៌ដោយសម្ទុះ ១ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អរបស់ព្រះរាជា ដែលប្រកបដោយអង្គ ៣ នេះឯង ទើបជាសេះគួរដល់ព្រះរាជា ជាសេះព្រះរាជទ្រព្យ ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយធម៌ ៣ យ៉ាង ជាអ្នកគួរទទួលនូវរបស់ដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរបំផុតរបស់សត្វលោក ក៏យ៉ាងនោះដែរ ។ ប្រកបដោយធម៌ ៣ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកបរិបូណ៌ដោយសម្បុរ ១ បរិបូណ៌ដោយកម្លាំង ១ បរិបូណ៌ដោយសម្ទុះ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិបូណ៌ដោយសម្បុរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។បេ។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបរិបូណ៌ដោយសម្បុរ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិបូណ៌ដោយកម្លាំង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រារព្ធព្យាយាម ។បេ។ មិនដាក់ធុរៈក្នុងកុសលធម៌ទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបរិបូណ៌ដោយកម្លាំងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិបូណ៌ដោយសម្ទុះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈ

ទាំងឡាយដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង ក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តនៅ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបរិបូណ៌ដោយសម្មុះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយធម៌ ៣ យ៉ាងនេះឯង ជាអ្នកគួរទទួលនូវរបស់ដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរបំផុត របស់សត្វលោក ។

# អដ្ឋកថា

## តតិយអាជានីយសូត្រ

[ ១០០ ] សូត្រទី ៧ អរហត្តផល ព្រះមានព្រះភាគត្រាស់ហើយ មគ្គកិច្ច ព្រះមានព្រះភាគត្រាស់ហើយ ដោយអរហត្តផលនោះឯង ។ ចំណែកផល មិនគួរហៅថា ធរៈ ព្រោះកើតឡើងបានដោយ ធរៈ ដែលស្មុះទៅហើយ ។ល។

### អដ្ឋកថាតតិយអាជានីយសូត្រទី ៧ ចប់

# សុត្តន្តបិដក

## នវសូត្រទី ៨

[ ១០១ ] ម្នាលភិក្ខុទាំងឡាយ សំពត់ដែលត្បាញដោយសម្បកឈើ ទោះបីថ្មី មានពណ៌អាក្រក់ មានសម្ផស្សអាក្រក់ ទាំងមានតម្លៃក៏តិច ម្នាលភិក្ខុទាំងឡាយ សំពត់សម្បកឈើ ទោះបីជំនំ មានពណ៌អាក្រក់ មានសម្ផស្សអាក្រក់ ទាំងមានតម្លៃក៏តិច ម្នាលភិក្ខុទាំងឡាយ សំពត់សម្បកឈើ ទោះបីចាស់ មានពណ៌អាក្រក់ មានសម្ផស្សអាក្រក់ ទាំងមានតម្លៃក៏តិច ។ ម្នាលភិក្ខុទាំងឡាយ ពួកជនរមែងធ្វើនូវសំពត់សម្បកឈើដ៏ចាស់នោះ ឲ្យជាសំពត់សម្រាប់ជូតឆ្នាំង ឬចោលលើគំនរសំរាម ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុខ្ចីវស្សា ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ក៏យ៉ាងនោះដែរ បានជាតថាគតពោលយ៉ាងនេះ ព្រោះភិក្ខុនោះមានសម្បុរ គឺគុណអាក្រក់ ម្នាលភិក្ខុទាំងឡាយ សំពត់សម្បកឈើនោះ មានពណ៌អាក្រក់យ៉ាងណា តថាគតពោលនូវបុគ្គលនេះ ក៏យ៉ាងនោះដែរ ។ បើពួកជនណា សេពគប់ ចូលទៅអង្គុយជិត ក៏ដល់នូវទិដ្ឋានុគតិ គឺយកបុគ្គលនោះជាបែបយ៉ាង ការសេពគប់ជាដើមនោះ របស់ជនទាំងនោះ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ អស់កាលជាយូរអង្វែង បានជាតថាគតពោលយ៉ាងនេះ ព្រោះភិក្ខុនោះមានសម្ផស្សអាក្រក់ ម្នាលភិក្ខុទាំងឡាយ សំពត់សម្បកឈើ មានសម្ផស្សអាក្រក់ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏យ៉ាងនោះដែរ ។ បើបុគ្គលនោះ ទទួលចីវរបិណ្ឌបាត

សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខាររបស់ពួកជនណា ការទទួលនោះ មិនមានផលច្រើន មិនមានអានិសង្សច្រើន ដល់ពួកជននោះឡើយ បានជាតថាគតពោលយ៉ាងនេះ ព្រោះបុគ្គលនោះមានតម្លៃតិច ម្នាលភិក្ខុទាំង-ឡាយ សំពត់សម្បកឈើនោះ មានតម្លៃតិចយ៉ាងណា តថាគតពោលនូវបុគ្គលនោះ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុជាកណ្តាល ។បេ។ ម្នាលភិក្ខុទាំងឡាយ ទោះបីភិក្ខុជាថេរៈ ជាអ្នកទ្រុស្តសីលមានធម៌ដ៏លាមក ( ក៏យ៉ាងនោះដែរ ) បានជាតថាគតពោលយ៉ាងនេះ ព្រោះភិក្ខុនោះមានសម្បុរ គឺគុណអាក្រក់ ម្នាលភិក្ខុទាំងឡាយ សំពត់សម្បកឈើនោះ មានពណ៌អាក្រក់យ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏យ៉ាងនោះដែរ ។ បើពួកជនណា សេពគប់ ចូលទៅអង្គុយជិតដល់នូវទិដ្ឋានុគតិ គឺយកបុគ្គលនោះជាបែបយ៉ាង ការសេពគប់ជាដើមនោះរបស់បុគ្គលទាំងនោះ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលជាយូរអង្វែង បានជាតថាគតពោលយ៉ាងនេះ ព្រោះបុគ្គលនោះមានសម្ផស្សអាក្រក់ ម្នាលភិក្ខុទាំងឡាយ សំពត់សម្បកឈើនោះ មានសម្ផស្សអាក្រក់ យ៉ាងណាមិញ តថាគតពោលនូវបុគ្គលនេះ ក៏យ៉ាងនោះដែរ ។ បើបុគ្គលនោះ ទទួលចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយ-ភេសជ្ជបរិក្ខាររបស់ពួកជនណា ការទទួលនោះ មិនមានផលច្រើន មិនមានអានិសង្សច្រើន ដល់ពួកជននោះឡើយ បានជាតថាគតពោលយ៉ាងនេះ ព្រោះបុគ្គលនោះមានតម្លៃតិច ម្នាលភិក្ខុទាំងឡាយ សំពត់សម្បកឈើនោះមាន

តម្លៃតិច យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោល នូវបុគ្គលនេះ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុជាថេរៈនេះមានសភាពយ៉ាងនេះ ពោលក្នុងកណ្ដាលជំនុំសង្ឃ ពួកភិក្ខុបាននិយាយទៅនឹងភិក្ខុជាថេរៈនោះយ៉ាងនេះថា ប្រយោជន៍អ្វី ដោយពាក្យដែលលោកជាភិក្ខុល្ងង់មិនឈ្លាសនិយាយហើយ ទាំងខ្លួនលោក ក៏ចេះបានត្រឹមតែពាក្យដែលខ្លួនត្រូវនិយាយ ( ប៉ុណ្ណោះទេ ) ។ ភិក្ខុជាថេរៈនោះ ក៏ក្រោធខឹង អាក់អន់ចិត្ត សង្ឃបោះបង់ខ្លួនចោលដោយវាចាយ៉ាងណា ក៏បញ្ចេញវាចាយ៉ាងនោះ ដូចគេចោលសំពត់សម្បកឈើនោះលើគំនរសំរាម ។ ម្នាលភិក្ខុទាំងឡាយ សំពត់កាសិកទោះថ្មីមានពណ៌ល្អ មានសម្ផស្សក៏ស្រួល ទាំងមានតម្លៃក៏ច្រើន ម្នាលភិក្ខុទាំងឡាយ សំពត់កាសិក ទោះជំនំ មានពណ៌ល្អ មានសម្ផស្សក៏ស្រួល ទាំងមានតម្លៃក៏ច្រើន ម្នាលភិក្ខុទាំងឡាយ សំពត់កាសិក ទោះចាស់ មានពណ៌ល្អ មានសម្ផស្សក៏ស្រួល ទាំងមានតម្លៃក៏ច្រើន ។ ម្នាលភិក្ខុទាំងឡាយ សំពត់កាសិក បើទុកជាចាស់ ក៏ពួកជនរមែងធ្វើនូវសំពត់នោះ ឲ្យជាសំពត់សម្រាប់រុំកែវ ឬដាក់ចុះក្នុងខ្លួច សម្រាប់ដាក់គ្រឿងក្រអូបដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុខ្ទិវស្សា បើជាអ្នកមានសីល មានធម៌ដ៏ល្អ ក៏យ៉ាងនោះដែរ បានជាតថាគតពោលយ៉ាងនេះ ព្រោះភិក្ខុនោះ មានសម្បុរ គឺគុណដ៏ល្អ ម្នាលភិក្ខុទាំងឡាយ សំពត់កាសិកនោះ មានពណ៌ល្អយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏យ៉ាងនោះដែរ ។ បើជនពួកណា សេពគប់ចូលទៅអង្គុយជិត ដល់នូវទិដ្ឋានុគតិ គឺយកបុគ្គលនោះជា

បែបយ៉ាង ការសេពគប់ជាដើមនោះ របស់បុគ្គលនោះ រមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខអស់កាលជាយូរអង្វែង បានជាតថាគត ពោលយ៉ាងនេះ ព្រោះបុគ្គលនោះ មានសម្ផស្សស្រួល ម្នាលភិក្ខុទាំងឡាយ សំពត់កាសិកនោះ មានសម្ផស្សស្រួលយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏យ៉ាងនោះដែរ ។ ប្រសិនបើបុគ្គលនោះ ទទួល ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារបស់ជនពួក ណា ការទទួលនោះ រមែងមានផលច្រើន មានអានិសង្សច្រើនដល់ពួកជន ទាំងនោះ បានជាតថាគតពោលយ៉ាងនេះ ព្រោះបុគ្គលនោះមានតម្លៃច្រើន ម្នាលភិក្ខុទាំងឡាយ សំពត់កាសិកនោះ មានតម្លៃច្រើនយ៉ាងណាមិញ ម្នាល ភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនោះ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុ ទាំងឡាយ ទោះភិក្ខុជាកណ្ដាល ។បេ។ ម្នាលភិក្ខុទាំងឡាយ ទោះភិក្ខុជាថេរៈ ជាអ្នកមានសីល មានកល្យាណធម៌ ( ក៏យ៉ាងនោះដែរ ) បានជាតថាគត ពោលយ៉ាងនេះ ព្រោះភិក្ខុនោះមានសម្បុរ គឺគុណដ៏ល្អ ម្នាលភិក្ខុទាំងឡាយ សំពត់កាសិកនោះ មានពណ៌ល្អ យ៉ាងណាមិញ តថាគតពោលនូវបុគ្គលនេះ ក៏យ៉ាងនោះដែរ ។ បើជនពួកណា សេពគប់ ចូលទៅអង្គុយជិត ដល់នូវ ទិដ្ឋានុគតិ គឺយកបុគ្គលនោះជាបែបយ៉ាង ការសេពគប់ជាដើមនោះ របស់ បុគ្គលនោះ រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខអស់កាល ជាយូរអង្វែង បានជាតថាគតពោលយ៉ាងនេះ ព្រោះបុគ្គលនោះ មានសម្ផស្ស ស្រួល ម្នាលភិក្ខុទាំងឡាយ សំពត់កាសិកនោះ មានសម្ផស្សស្រួលយ៉ាងណា

មិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះក៏យ៉ាងនោះដែរ ។ ប្រសិនបើបុគ្គលនោះទទួលចីវរ បិណ្ឌបាតសេនាសនៈ និងគិលានប្បច្ចយ-ភេសជ្ជបរិក្ខាររបស់ពួកជនណា ការទទួលនោះ រមែងមានផលច្រើន មានអានិសង្សច្រើន ដល់ពួកជននោះ បានជាតថាគតពោលយ៉ាងនេះ ព្រោះបុគ្គលនោះមានតម្លៃច្រើន ម្នាលភិក្ខុទាំងឡាយ សំពត់កាសិកនោះ មានតម្លៃច្រើនយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុជាថេរៈនេះ មានសភាពយ៉ាងនេះ ពោលក្នុងកណ្តាលជំនុំសង្ឃ ពួកភិក្ខុបាននិយាយគ្នាចំពោះព្រះថេរៈនោះយ៉ាងនេះថា សូមលោកដ៏មានអាយុទាំងឡាយ កុំមាត់ខ្លាំង ភិក្ខុជាថេរៈកំពុងសម្តែងធម៌ និងវិន័យ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយ ត្រូវសិក្សាយ៉ាងនេះថា ពួកយើងឧបមាដូចជាកាសិកពស្ត្រ មិនមែនឧបមាដូចជាសំពត់សម្បកឈើទេ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសិក្សាយ៉ាងនេះឯង ។

# អដ្ឋកថា

## នវសូត្រ

[ ១០១ ] *សំពត់ដែលត្រាស់ថាថ្មីព្រោះអាស្រ័យការធ្វើ ។ សំពត់ដែលធ្វើអំពីធ្មៃ ឈ្មោះថា* **ធោត្តកោ** *។ សំពត់ដែលឈ្មោះថា* **មជ្ឈិមោ** *បានដល់ សំពត់ពាក់កណ្តាលចាស់ ពាក់កណ្តាលថ្មី ព្រោះការប្រើប្រាស់ ។ សំពត់ដែលឈ្មោះថា* **ជិណ្ណោ** *បានដល់ សំពត់ចាស់ព្រោះប្រើប្រាស់ ។ បទថា* **ឧក្កលិបរិមជ្ជនំ** *បានដល់ ជាសំពត់ជូតថ្នាំងបាយ ។ បទថា* **ទុស្សីលោ** *បានដល់ មិនមានសីល ។ បទថា* **ទុព្វណ្ណតាយ** *បានដល់ ព្រោះជាបុគ្គលមានពណ៌សម្បុរថោកថយ ព្រោះមិនមានពណ៌ គឺគុណ ។ បទថា* **ទិដ្ឋានុគតឹ អាបជ្ជន្តិ** *បានដល់ ភិក្ខុទាំងឡាយនាំគ្នាធ្វើតាមលំអាន ដែលភិក្ខុនោះធ្វើហើយ ។ បទថា* **ន មហប្ផលំ ហោតិ** *សេចក្តីថា មិនមានផលច្រើនដោយផល គឺវិបាក ។ បទថា* **ន មហានិសំសំ** *សេចក្តីថា មិនមានអានិសង្សច្រើន ដោយអានិសង្ស គឺវិបាក ។ បទថា* **អប្បគ្ឃតាយ** *បានដល់ ព្រោះការទទួលនោះ មានតម្លៃតិច ដោយតម្លៃ គឺវិបាក ។ បទថា* **កាសិកំ វត្ថំ** *បានដល់ សំពត់ដែលត្បាញដោយអំបោះដែលធ្វើអំពីសំឡី ។ ឯសំពត់ប្រភេទនោះកើតឡើង ចំពោះក្នុងដែនកាសី ។*

*បទដ៏សេស ងាយយល់ទាំងអស់ហើយ ។ ចំណែកសីលក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់លាយគ្នានោះឯង ។៙*

**អដ្ឋកថា នវសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## លោណកសូត្រទី ៩

[ ១០២ ] ម្នាលភិក្ខុទាំងឡាយ បើបុគ្គលណា និយាយយ៉ាងនេះថា បុរសនេះធ្វើអំពើយ៉ាងណាៗ រមែងទទួលនូវផលនៃអំពើយ៉ាងនោះៗ ម្នាលភិក្ខុទាំងឡាយ កាលបើហេតុយ៉ាងនេះមានហើយ ការនៅប្រព្រឹត្តព្រហ្មចរិយៈក៏មិនមានឱកាស ដើម្បីធ្វើឲ្យផុតទុក្ខដោយប្រពៃក៏មិនប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលណា និយាយយ៉ាងនេះថា បុរសនេះធ្វើអំពើដែលគួរទទួលផលយ៉ាងណាៗ រមែងទទួលនូវផលនៃអំពើនោះយ៉ាងនោះ ។ ម្នាលភិក្ខុទាំងឡាយ កាលបើហេតុយ៉ាងនេះមាន ការនៅប្រព្រឹត្តព្រហ្មចរិយៈក៏មានឱកាសដើម្បីធ្វើឲ្យផុតទុក្ខ ដោយប្រពៃក៏ប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ បានធ្វើបាបកម្ម សូម្បីត្រឹមតែបន្តិចបន្តួចហើយ ( បាបកម្មនោះ ) រមែងនាំបុគ្គលនោះ ទៅកាន់នរក ។ ម្នាលភិក្ខុទាំងឡាយមួយទៀត បាបកម្មត្រឹមតែបន្តិច ប្រហែលគ្នានឹងបាបកម្មមុននោះដែរ ដែលបុគ្គលពួកខ្លះ ក្នុងលោកនេះ ធ្វើហើយ ជាកម្មត្រូវទទួលផលក្នុងបច្ចុប្បន្ន ឯកម្មតិចតួចស្តួចស្តើងមិនប្រាកដ គឺថាមិនបានឲ្យផលក្នុងអត្តភាពជាគម្រប់ពីរទេ ( លុះណា ) តែកម្មច្រើន ទើបប្រាកដ គឺថាឲ្យផលក្នុងអត្តភាពជាគម្រប់ពីរបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលបែបណា ដែលបានធ្វើបាបកម្ម សូម្បីត្រឹមតែបន្តិចហើយ ( បាបកម្មនោះ ) នាំបុគ្គលនោះចូលទៅកាន់នរក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនបានចម្រើនកាយ

មិនបានចម្រើនសីល មិនបានចម្រើនសមាធិចិត្ត មិនបានចម្រើនវិបស្សនា-បញ្ញា មានគុណដ៏ស្ដួចស្ដើង មានគុណក្នុងខ្លួនដ៏តិច មានការនៅជាទុក្ខ ព្រោះផលតិច ម្នាលភិក្ខុទាំងឡាយ បុគ្គលបែបយ៉ាងនេះ ដែលបានធ្វើបាប-កម្ម សូម្បីត្រឹមតែបន្តិចហើយ ( បាបកម្មនោះ ) នាំបុគ្គលនោះ ចូលទៅកាន់នរកបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលបែបណា ដែលបានធ្វើបាបកម្ម សូម្បីត្រឹមតែបន្តិច ប្រហែលគ្នានឹងបាបកម្មមុននោះដែរ ហើយទទួលផល ក្នុងបច្ចុប្បន្ន ឯកម្មតិចតួចស្ដួចស្ដើង មិនប្រាកដ គឺថា មិនបានឲ្យផល ក្នុងអត្តភាពជាគម្រប់ពីរ ( លុះណា ) តែកម្មច្រើន ទើបប្រាកដ គឺថា ឲ្យផលបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកបានចម្រើនកាយ បានចម្រើនសីល បានចម្រើនសមាធិចិត្ត បានចម្រើនវិបស្សនាបញ្ញា មានគុណដ៏ច្រើន មានគុណក្នុងខ្លួនច្រើន មានការនៅដោយមិនមានរាគា-ទិក្កិលេស ម្នាលភិក្ខុទាំងឡាយ បុគ្គលបែបយ៉ាងនេះ ដែលបានធ្វើបាប-កម្មត្រឹមតែបន្តិច ប្រហែលគ្នានឹងបាបកម្មមុននោះហើយ ត្រូវទទួលផលក្នុងបច្ចុប្បន្ន ឯកម្មតិចតួចស្ដួចស្ដើងមិនប្រាកដ គឺថា មិនឲ្យផលក្នុងអត្តភាពជាគម្រប់ពីរ ( លុះណា ) តែកម្មច្រើន ទើបប្រាកដ គឺថា ឲ្យផលបាន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសបង់ដុំអំបិលមួយគ្រាប់ក្នុងផ្តិលទឹកយ៉ាងតូច ។ ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយ សម្គាល់នូវហេតុនោះដូចម្ដេច ទឹកក្នុងផ្តិលយ៉ាងតូចនោះ គួរជាទឹកប្រៃសព្វ ដោយអំបិលមួយគ្រាប់ប៉ុណ្ណោះដែរឬ ។ យ៉ាងហ្នឹងហើយ ព្រះអង្គ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏

ចម្រើន ព្រោះទឹកក្នុងផ្តិលនោះមានប្រមាណតិច ទឹកនោះជាទឹកប្រែសព្វដោយអំបិលមួយគ្រាប់ប៉ុណ្ណោះបាន យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសបង់អំបិលមួយគ្រាប់ក្នុងទន្លេគង្គា ។ ម្នាលភិក្ខុទាំងឡាយ តើអ្នកទាំងឡាយ សម្គាល់នូវហេតុនោះដូចម្តេច ទន្លេគង្គានោះគួរប្រែសព្វ ដោយអំបិលមួយគ្រាប់ប៉ុណ្ណោះដែរ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះក្នុងទន្លេគង្គាឯណោះ មានគំនរទឹកច្រើន គំនរទឹកយ៉ាងធំនោះមិនគួរប្រែសព្វ ដោយអំបិលមួយគ្រាប់ប៉ុណ្ណោះបាន យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះបានធ្វើបាបកម្ម សូម្បីត្រឹមតែបន្តិចបន្តួចហើយ ( បាបកម្មនោះ ) នាំបុគ្គលនោះ ចូលទៅកាន់នរក ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀតបុគ្គលពួកខ្លះ ក្នុងលោកនេះ បានធ្វើបាបកម្មត្រឹមតែបន្តិចបន្តួច ប្រហែលគ្នានឹងបាបកម្មមុននោះដែរ ហើយត្រូវទទួលផលក្នុងបច្ចុប្បន្ន ឯកម្មមានប្រមាណតិចមិនប្រាកដ ( លុះណា ) តែកម្មច្រើន ទើបប្រាកដក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលបែបណាដែលបានធ្វើបាបកម្មសូម្បីត្រឹមតែបន្តិចបន្តួចហើយ ( បាបកម្មនោះ ) នាំបុគ្គលនោះចូលទៅកាន់នរក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនមានចម្រើនសមាធិចិត្ត មិនបានចម្រើនវិបស្សនាបញ្ញា មានគុណស្តួចស្តើង មានគុណក្នុងខ្លួនតិច មានការនៅជាទុក្ខ ព្រោះផលតិច ម្នាលភិក្ខុទាំងឡាយ បុគ្គលបែបនេះឯង ដែលបានធ្វើបាបកម្ម សូម្បីត្រឹមតែ

បន្តិចបន្តួចហើយ ( បាបកម្មនោះ ) នាំបុគ្គលនោះចូលទៅកាន់នរក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលបែបណា ដែលបានធ្វើបាបកម្ម ត្រឹមតែបន្តិចបន្តួចប្រហែលគ្នានឹងបាបកម្មមុននោះដែរ ហើយត្រូវទទួលផលក្នុងបច្ចុប្បន្ន ឯកម្មតិចតួច រមែងមិនប្រាកដ ( លុះណា ) តែកម្មច្រើនទើបប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកបានចម្រើនកាយ បានចម្រើនសីល បានចម្រើនសមាធិចិត្ត បានចម្រើនវិបស្សនាបញ្ញា មានគុណច្រើន មានគុណក្នុងខ្លួនច្រើន មានការនៅដោយមិនមានរាគាទិក្កិលេសទេ ម្នាលភិក្ខុទាំងឡាយ បុគ្គលបែបយ៉ាងនេះឯង បានធ្វើបាបកម្មត្រឹមតែបន្តិចបន្តួចប្រហែលគ្នានឹងបាបកម្មមុននោះដែរ ហើយត្រូវទទួលផលក្នុងបច្ចុប្បន្ន ឯកម្មតិចតួច រមែងមិនប្រាកដ ( លុះណា ) តែកម្មច្រើនទើបប្រាកដ គឺឲ្យផលបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាប់ចំណង ព្រោះកន្លះកហាបណៈខ្លះ ជាប់ចំណងព្រោះមួយកហាបណៈខ្លះ ជាប់ចំណងព្រោះកហាបណៈ ១០០ ខ្លះ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត បុគ្គលពួកខ្លះក្នុងលោកនេះ មិនជាប់ចំណង ព្រោះកន្លះកហាបណៈខ្លះ មិនជាប់ចំណងព្រោះកហាបណៈមួយខ្លះ មិនជាប់ចំណង ព្រោះកហាបណៈ ១០០ ខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងណា រមែងជាប់ចំណង ព្រោះកន្លះកហាបណៈខ្លះ ជាប់ចំណង ព្រោះកហាបណៈមួយខ្លះ ជាប់ចំណង ព្រោះកហាបណៈ ១០០ ខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះជាអ្នកក្រីក្រឥតទីពំនាក់ មានគ្រឿងប្រើប្រាស់តិច ម្នាលភិក្ខុទាំងឡាយ បុគ្គល

មានសភាពយ៉ាងនេះ រមែងជាប់ចំណង ព្រោះកន្ទះកហាបណៈខ្លះ ជាប់ចំណងព្រោះកហាបណៈមួយខ្លះ ជាប់ចំណងព្រោះកហាបណៈ ១០០ ខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងណា មិនជាប់ចំណង ព្រោះកន្ទះកហាបណៈខ្លះ មិនជាប់ចំណងព្រោះកហាបណៈមួយខ្លះ មិនជាប់ចំណងព្រោះកហាបណៈ ១០០ ខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានគ្រឿងប្រើប្រាស់ច្រើន ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងនេះ រមែងមិនជាប់ចំណង ព្រោះកន្ទះកហាបណៈខ្លះ មិនជាប់ចំណង ព្រោះកហាបណៈមួយខ្លះ មិនជាប់ចំណង ព្រោះកហាបណៈ ១០០ ខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ បានធ្វើបាបកម្ម សូម្បីត្រឹមតែបន្តិចបន្តួចហើយ ( បាបកម្មនោះ ) រមែងនាំបុគ្គលនោះចូលទៅកាន់នរក ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ បានធ្វើបាបកម្មត្រឹមតែបន្តិចបន្តួច ប្រហែលនឹងបាបកម្មមុននោះដែរ ហើយគួរទទួលផលក្នុងបច្ចុប្បន្នឯកម្មតិចតួច មិនប្រាកដទេ ( លុះណា ) តែកម្មច្រើនទើបប្រាកដបាន ។បេ។ ម្នាលភិក្ខុទាំងឡាយ ដូចជាជនពួកខ្លះ ជាអ្នកម្ចាស់ចៀម ឬជាអ្នកសម្លាប់ចៀម ល្មមដើម្បីសម្លាប់ក្តី ចងក្តី ដុតក្តី ធ្វើកិច្ចគួរតាមការក្តី នូវជនអ្នកយកចៀម ដែលខ្លួនមិនបានឲ្យ ជនពួកខ្លះ មិនល្មមដើម្បីសម្លាប់ក្តី ចងក្តី ដុតក្តី ធ្វើកិច្ចគួរតាមការក្តី នូវជនអ្នកយកចៀម ដែលខ្លួនមិនបានឲ្យ ។ ម្នាលភិក្ខុទាំងឡាយ ជនមានសភាពយ៉ាងណាដែលជាម្ចាស់ចៀម ឬជាអ្នកសម្លាប់ចៀម

ល្មមដើម្បីសម្លាប់ក្តី ចងក្តី ដុតក្តី ធ្វើកិច្ចគួរតាមការក្តី នូវជនអ្នកយកចៀមដែលខ្លួនមិនបានឲ្យ ។ ម្នាលភិក្ខុទាំងឡាយ ជនពួកខ្លះ ក្នុងលោកនេះ ជាអ្នកក្រីក្រ ឥតទីពឹងពំនាក់ មានគ្រឿងប្រើប្រាស់តិច ម្នាលភិក្ខុទាំងឡាយ ជនមានសភាពយ៉ាងនេះ ដែលម្ចាស់ចៀម ឬអ្នកសម្លាប់ចៀម ល្មមដើម្បីសម្លាប់ក្តី ចងក្តី ដុតក្តី ធ្វើកិច្ចគួរតាមការក្តី នូវជនអ្នកយកចៀមដែលខ្លួនមិនបានឲ្យ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងណា ដែលជាម្ចាស់ចៀម ឬជាអ្នកសម្លាប់ចៀម មិនល្មមដើម្បីសម្លាប់ក្តី ចងក្តី ដុតក្តី ធ្វើកិច្ចគួរតាមការក្តី នូវជនអ្នកយកចៀម ដែលខ្លួនមិនបានឲ្យ ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ទោះស្តេចក្តី អាមាត្យធំរបស់ស្តេចក្តី ជាអ្នកស្តុកស្តម្ភមានទ្រព្យច្រើន មានគ្រឿងប្រើប្រាស់ច្រើន ម្នាលភិក្ខុទាំង-ឡាយ បុគ្គលមានសភាពយ៉ាងនេះ ដែលជាម្ចាស់ចៀម ឬជាអ្នកសម្លាប់ចៀម មិនល្មមដើម្បីសម្លាប់ក្តី ចងក្តី ដុតក្តី ធ្វើកិច្ចគួរតាមការក្តី នូវជនអ្នកយកចៀម ដែលខ្លួនមិនបានឲ្យដោយពិត អ្នកដែលគេលួចចៀម រមែងសំពះអង្វរអ្នកលួចចៀមនោះថា បពិត្រលោកអ្នកនិទុក្ខ សូមលោកឲ្យចៀមឬតម្លៃចៀមមកខ្ញុំ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ បានធ្វើបាបកម្ម សូម្បីត្រឹមតែបន្តិចបន្តួចហើយ ( បាបកម្មនោះ ) នាំបុគ្គលនោះ ចូលទៅកាន់នរក ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ បានធ្វើបាបកម្ម ត្រឹមតែបន្តិចបន្តួចប្រហែលគ្នានឹងបាបកម្មមុននោះដែរ ហើយគួរទទួលផលក្នុងបច្ចុប្បន្ន ឯបាបកម្ម

តិចតួច មិនប្រាកដ ( លុះណា ) បាបកម្មច្រើន ទើបប្រាកដបាន ។បេ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលណា និយាយយ៉ាងនេះថា បុរសនេះធ្វើកម្ម យ៉ាងណាៗ រមែងទទួលផលកម្មនោះយ៉ាងនោះៗ ម្នាលភិក្ខុទាំងឡាយ កាល បើហេតុយ៉ាងនេះមាន ការប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនមានឱកាសដើម្បីធ្វើ ឲ្យផុតទុក្ខដោយប្រពៃក៏មិនប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បើបុគ្គល ណា និយាយយ៉ាងនេះថា បុរសនេះធ្វើកម្មដែលខ្លួនត្រូវដឹងបាន យ៉ាងណាៗ ក៏រមែងទទួលយកនូវផលរបស់កម្មនោះ យ៉ាងនោះៗ ឯង ម្នាលភិក្ខុទាំងឡាយ កាលបើហេតុយ៉ាងនេះមាន ការប្រព្រឹត្តព្រហ្មចរិយៈក៏មាន ឱកាសដើម្បីធ្វើ ឲ្យផុតទុក្ខ ដោយប្រពៃក៏ប្រាកដ ។

# អដ្ឋកថា

## លោណកសូត្រ

[ ១០២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងលោណកសូត្រទី ៩ ដូចតទៅនេះ បទថា **យថា យថាយំ** កាត់បទជា **យថា យថា អយំ** ។ បទថា **តថា តថា តំ** បានដល់ **តថា តថា តំ កម្មំ** មានអធិប្បាយដូច្នេះថា បុគ្គលណា គប្បីពោលយ៉ាងនេះថា បុគ្គលធ្វើកម្មដោយប្រការណាមួយ ក៏នឹងសោយ វិបាកនៃកម្មនោះ ដោយប្រការនោះៗ ព្រោះថា បុគ្គលមិនអាចមិនសោយ

វិបាករបស់កម្មដែលធ្វើហើយ ព្រោះដូច្នោះ បុគ្គលធ្វើកម្មប៉ុនណា ក៏នឹងសោយវិបាករបស់កម្មប៉ុណ្ណោះនោះឯង ។ បទថា **ឯវំ សន្តំ** គឺ **ឯវំ សន្តេ** ប្រែថា បើដូច្នេះ ។ បទថា **ព្រហ្មចរិយវាសោ ន ហោតិ** សេចក្ដីថា ឧបបជ្ជវេទនីយកម្មណា ដែលធ្វើមុនការធ្វើមគ្គឲ្យកើតមាន ព្រោះឧបបជ្ជវេទនីយកម្មនោះ ដែលខ្លួននឹងត្រូវសោយដោយពិត ព្រហ្មចរិយៈសូម្បីនៅចប់ហើយ ក៏ឈ្មោះថា មិននៅឡើយ ។ បទថា **ឱកាសោ ន បញ្ញាយតិ សម្មាទុក្ខស្ស អន្តកិរិយាយ** សេចក្ដីថា ព្រោះកាលបើដូច្នេះ ការប្រមូលមកនូវកម្ម និងការសោយផលរបស់កម្មគង់មាន ដូច្នោះ ឱកាសនៃការធ្វើទីបំផុតនៃវដ្តទុក្ខ ដោយហេតុ ដោយន័យ ឈ្មោះថា មិនប្រាកដ ។ បទថា **យថា យថា វេទនីយំ** បានដល់ ដែលខ្លួនគប្បីសោយ ដោយអាការណាមួយ ។ បទថា **តថា តថាស្ស វិបាកំ បដិសំវេទិយតិ** សេចក្ដីថា សោយវិបាកនៃកម្ម នោះដោយអាការនោះៗ ។

មានពាក្យអធិប្បាយដូច្នេះថា ក្នុងជវនចិត្តទាំង ៧ កម្មក្នុងជវនចិត្តទី ១ នោះ កាលមានបច្ច័យ ក៏បានវារៈដែលនឹងឲ្យផលក្លាម កម្មនោះ ចាត់ជាទិដ្ឋធម្មវេទនីយកម្ម កាលមិនមានបច្ច័យ ក៏ឈ្មោះថា ជាអហោសិកម្ម ឯកម្មក្នុងជវនចិត្តទី ៧ យ៉ាងណា កម្មនោះ កាលមានបច្ច័យ ក៏ជាឧបបជ្ជវេទនីយកម្ម កាលមិនមានបច្ច័យ ក៏ឈ្មោះថា ជាអហោសិកម្ម និងកម្មក្នុងជវនចិត្តទាំង ៥ ក្នុងកណ្ដាល កម្មនោះ ឈ្មោះថា អបរាបរិវេទនីយកម្ម ដរាបស្មើគ្នាដែលនៅអន្ទោលទៅក្នុងសង្សារវដ្ត បុរសបុគ្គលដែលធ្វើកម្មនោះ គប្បី

សោយបានដោយអាការណាៗ ក្នុងបណ្តាអាការទាំងនេះ ក៏នឹងសោយវិបាករបស់កម្មនោះ ដោយអាការនោះៗ ។ ពិតហើយ លោកពោលក្នុងអដ្ឋកថាថា កម្មដែលបានវារៈឲ្យផលហើយប៉ុណ្ណោះ ឈ្មោះថា **យថាវេទនីយកម្ម** ។ បទថា **ឯវំ សន្តំ ភិក្ខវេ ព្រហ្មចរិយវាសោ ហោតិ** សេចក្តីថា ពាក្យដែលពោលថា ឈ្មោះថា មានការនៅព្រហ្មចរិយៈ ដែលធ្វើកម្មឲ្យអស់ទៅ ព្រោះកម្មដែលត្រូវធ្វើឲ្យអស់ទៅនៅមាន ដូច្នេះ ឈ្មោះថា ពោលល្អហើយនោះឯង ។

បទថា **ឱកាសោ បញ្ញាយតិ សម្មាទុក្ខស្ស អន្តកិរិយាយ** សេចក្តីថា ព្រោះហេតុដែលកាលបើដូច្នេះ ក៏មិនកើតវដ្តទុក្ខតទៅក្នុងភពនោះៗ ព្រោះអភិសង្ខារវិញ្ញាណរលត់ទៅដោយមគ្គនោះៗ ដូច្នោះ ឱកាសនៃការធ្វើទីបំផុតនៃទុក្ខដោយល្អ ទើបប្រាកដ ។

ឥឡូវនេះ កាលទ្រង់សម្តែងសភាវៈនៃយថាវេទនីយកម្មនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **ឥធ ភិក្ខវេ ឯកច្ចស្ស** ជាដើម ។ បណ្តាបទទាំងនោះ បទថា **អប្បមត្តកំ** បានដល់ បរិត្តកម្ម គឺកម្មតិចតួច កម្មស្រាល កម្មតូចតាច កម្មលាមក ។ បទថា **តាទិសំយេវ** បានដល់ វិបាកដែលឃើញសមគ្នានឹងកម្មនោះឯង ។ បទថា **ទិដ្ឋធម្មវេទនីយំ** សេចក្តីថា ក្នុងកម្មនោះឯងមាន អធិប្បាយថា កម្មដែលគប្បីឲ្យផល កាលបានវារៈដែលនឹងឲ្យផលក្នុងបច្ចុប្បន្ន ក៏ក្លាយជាទិដ្ឋធម្មវេទនីយកម្ម ។ បទថា **ណាណុបិ ខាយតិ** សេចក្តីថា មិនប្រាកដបន្តិចបន្តួចក្នុងអត្តភាពទី ២ អធិប្បាយថា មិនឲ្យផល

ត្រឹមតែតិចតួចក្នុងអត្តភាពទី ២ ។ បទថា **ឝហុនេវ** សេចក្ដីថា ចំណែកកម្ម ដែលច្រើន នឹងឲ្យផលបានដូចម្ដេច ។

បុថុជ្ជន វៀរចាកភាវនា ចម្រើនសតិប្បដ្ឋានក្នុងកាយ ជាអ្នកមានប្រក្រតីទៅកាន់វដ្ដៈ ព្រះមានព្រះភាគទ្រង់សម្ដែងដោយបទថា **អភាវិត-កាយោ** ជាដើម ។ បទថា **បរិត្តោ** បានដល់ មានគុណតិចតួច ។ បទថា **អប្បាតុមោ** សេចក្ដីថា អត្តភាព ហៅថា **អាតុម** បុថុជ្ជន ឈ្មោះថា មានអត្តភាពតូចតាចដោយពិត ព្រោះកាលអត្តភាពនោះធំ តែក៏មានគុណតិចតួច ។ បទថា **អប្បទុក្ខវិហារី** សេចក្ដីថា មានប្រក្រតីនៅជាទុក្ខ ដោយវិបាកបន្តិចបន្តួច ។ ព្រះខីណាស្រព ព្រះមានព្រះភាគទ្រង់សម្ដែងដោយបទថា **ភាវិត-កាយោ** ជាដើម ។ អធិប្បាយថា ព្រះខីណាស្រពនោះ ឈ្មោះថា មានកាយអប់រំហើយ ដោយភាវនា ពោល គឺកាយានុបស្សនា ឬឈ្មោះថា មានកាយអប់រំហើយ ព្រោះចម្រើនកាយានុបស្សនា ។ បទថា **ភាវិតសីលោ** ប្រែថា ចម្រើននូវសីល ។ ក្នុងបទដ៏សេស ក៏មានន័យនេះឯង ។

ម្យ៉ាងទៀត ព្រះខីណាស្រព ឈ្មោះថា មានកាយអប់រំហើយ ដោយអប់រំបញ្ចទ្វារ ។ ព្រះមានព្រះភាគត្រាស់ដល់ឥន្ទ្រិយសំវរសីល ដោយបទថា **ភាវិតកាយោ** នេះ ត្រាស់សីល ៣ ដ៏សេស ដោយបទថា **ភាវិតសីលោ** នេះ ។ បទថា **អបរិត្តោ** គឺមានគុណមិនមែនតិចតួច ។ បទថា **មហាត្តា** គឺព្រះខីណាស្រព ឈ្មោះថា មានអត្តភាពធំ សូម្បីមានរាងកាយតូច តែមានគុណច្រើន ។ បទថា **អប្បមាណវិហារី** នេះ ជាឈ្មោះរបស់ព្រះខីណាស្រព

ដោយពិត អធិប្បាយថា ព្រះខីណាស្រពនោះ ឈ្មោះថា **អប្បមាណវិហារី** គឺមានប្រក្រតីនៅដោយគុណធម៌ មិនមានប្រមាណ ព្រោះមិនមានកិលេស មានរាគៈជាដើម ធ្វើឲ្យមានប្រមាណ ។ បទថា **បរិត្តេ** ប្រែថា បន្តិចបន្តួច ។ បទថា **ឧទកមល្លកេ** ប្រែថា ក្នុងផ្តិលទឹក ។

បទថា **ឱរព្ភិកោ** ប្រែថា ម្ចាស់របស់ចៀម ។ បទថា **ឱរព្ភឃាតកោ** ប្រែថា អ្នកសម្លាប់ចៀម ។ បទថា **ជាបេតុំ វា** បានដល់ ដើម្បីឲ្យសាបសូន្យ ដោយការវិនាសទ្រព្យ ។ បាឋៈថា **ឈាបេតុំ** ដូច្នេះក៏មាន អត្ថក៏តែម្យ៉ាងដូចគ្នានោះឯង ។ បទថា **យថាបច្ចយំ វា កាតុំ** សេចក្តីថា ដើម្បីធ្វើឲ្យបានតាមប្រាថ្នា ។ បទថា **ឱរព្ភធនំ** បានដល់ តម្លៃខ្លួនចៀម ។ ម្ចាស់របស់ចៀម ឬអ្នកសម្លាប់ចៀមនោះ បើប្រាថ្នាក៏ឲ្យតម្លៃចៀមនោះ បើមិនប្រាថ្នា ក៏ឲ្យចាប់កអូសចេញទៅ ។

បទដ៏សេស គប្បីជ្រាបតាមន័យដែលពោលហើយនោះឯង តែព្រះមានព្រះភាគត្រាស់វដ្តៈ និងវិវដ្តៈក្នុងសូត្រនេះឯង ។៙

**អដ្ឋកថាលោណកសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## សង្ឃសូត្រទី ១០

[ ១០៣ ] ម្នាលភិក្ខុទាំងឡាយ ខ្សាច់លាយដោយអាចម៍ដី ក្បៀនលាយដោយក្រួស ជាឧបក្កិលេសយ៉ាងគ្រោតគ្រាត របស់មាស ក៏មានមេជាងអ្នកលាងអាចម៍ដីក្តី កូនជាងអ្នកលាងអាចម៍ដីក្តី រោយរាយមាសនោះចុះក្នុងស្នូកហើយ លាងជម្រះជម្រះដេញកម្ចាត់ចេញ ( នូវមន្ទិល ) ត្រាតែធ្វើមាសនោះឲ្យអស់មន្ទិល ឲ្យបាត់មន្ទិលចេញបាន ក្រួសយ៉ាងល្អិតៗ ខ្សាច់យ៉ាងធំៗ ជាឧបក្កិលេស ( មន្ទិល ) យ៉ាងកណ្តាលរបស់មាស មេជាងអ្នកលាងអាចម៍ដីក្តី កូនជាងអ្នកលាងអាចម៍ដីក្តី រមែងលាងជម្រះដេញកម្ចាត់ចេញនូវមន្ទិលនោះ ត្រាតែធ្វើមាសនោះ ឲ្យអស់មន្ទិល ឲ្យបាត់មន្ទិលចេញបាន ដីខ្សាច់យ៉ាងល្អិត ជារបស់មានពណ៌ខ្មៅ ជាឧបក្កិលេសយ៉ាងល្អិត របស់មាស ក៏មាស មេជាងអ្នកលាងអាចម៍ដីក្តី កូនជាងអ្នកលាងអាចម៍ដីក្តី លាងជម្រះដេញកម្ចាត់ចេញនូវមន្ទិលនោះ ត្រាតែធ្វើមាសនោះ ឲ្យអស់មន្ទិល ឲ្យបាត់មន្ទិលចេញបាន តអំពីនោះ នឹងសល់នៅតែមាសសុទ្ធ ជាងមាសក្តី កូនជាងមាសក្តី ដាក់មាសនោះចុះក្នុងបាវហើយ ទើបសប់រម្លាយដេញសាច់ ។ មាសនោះដែលមិនបានសប់រម្លាយដេញសាច់ មិនបានកម្ចាត់មន្ទិលចេញ មិនបាននាំមន្ទិលចេញហើយ មិនទៅជាមាសទន់ផង មិនទៅជាមាសគួរដល់ការងារផង មិនទៅជាមាសមានពន្លឺផ្លេកផង ទៅជាមាសស្រួយ មិនគួរដល់ការងារ ដោយប្រពៃផង ។ ម្នាលភិក្ខុទាំងឡាយ សម័យគួរនោះគឺសម័យ

ដែលជាធមាស ឬក្អួនជាធមាស សប់រម្ងាយដេញសាច់មាស នោះដែលបាន សប់រម្ងាយដេញសាច់ កម្ចាត់មន្ទិលចេញ នាំមន្ទិលចេញហើយ រមែងទៅជាមាសទន់ផង គួរដល់ការងារផង មានពន្លឺភ្លឺផ្លេកផង មិនទៅជាមាសស្រួយផង គួរដល់ការងារដោយប្រពៃផង ជាងប្រាថ្នាគ្រឿងប្រដាប់ប្លែកៗ ឯណាៗ ទោះជាជំពារមាសក្តី កុណ្ឌលក្តី គ្រឿងប្រដាប់កក្តី កម្រងមាសក្តី រមែងសម្រេចតាមត្រូវការនោះបានទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ជាឧបក្កិលេសយ៉ាងគ្រោតគ្រាត របស់ភិក្ខុដែលប្រកបរឿយៗ នូវអធិចិត្ត ក៏មានយ៉ាងនោះដែរ ។ ភិក្ខុអ្នកបរិបូណ៌ដោយសមាធិចិត្ត ប្រកបដោយជាតិជាអ្នកប្រាជ្ញ រមែងលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស នូវឧបក្កិលេសនោះចេញ ឲ្យតាំងនៅមិនបាន ត្រាតែធ្វើចិត្តនោះ ឲ្យអស់មន្ទិល ឲ្យបាត់មន្ទិលចេញ ។ កាមវិតក្ក ព្យាបាទវិតក្ក វិហឹសាវិតក្ក ជាឧបក្កិលេសយ៉ាងកណ្តាល របស់ភិក្ខុអ្នកប្រកបនូវអធិចិត្ត ។ ភិក្ខុអ្នកបរិបូណ៌ដោយសមាធិចិត្ត ប្រកបដោយជាតិជាអ្នកប្រាជ្ញ រមែងលះបង់ បន្ទោបង់ ធ្វើឲ្យវិនាសនូវឧបក្កិលេសនោះចេញ ឲ្យតាំងនៅមិនបាន ត្រាតែធ្វើចិត្តនោះ ឲ្យអស់មន្ទិល ឲ្យបាត់មន្ទិលចេញ ។ ញាតិវិតក្ក ( សេចក្តីត្រិះរិះអំពីញាតិ ) ជនបទវិតក្ក ( សេចក្តីត្រិះរិះអំពីជនបទ ) អនវញ្ញត្តិប្បដិសំយុត្តវិតក្ក ( សេចក្តីត្រិះរិះប្រកបដោយការមិនចង់ឲ្យគេមើលងាយ ) ជាឧបក្កិលេសយ៉ាងល្អិត របស់ភិក្ខុ អ្នកប្រកបនូវអធិចិត្ត ។ ភិក្ខុអ្នកបរិបូណ៌ដោយសមាធិចិត្ត ប្រកបដោយជាតិ ជាអ្នកប្រាជ្ញ រមែងលះបង់ បន្ទោបង់ ធ្វើឲ្យវិនាសនូវឧបក្កិលេស

នោះចេញ ឲ្យតាំងនៅមិនបាន ត្រាតែធ្វើចិត្តនោះ ឲ្យអស់មន្ទិល ឲ្យបាត់មន្ទិលចេញ ។ លំដាប់តពីនោះ នឹងនៅសល់តែធម្មវិតក្ក ( សេចក្តីត្រិះរិះនូវធម៌ ) ប៉ុណ្ណោះ ។ សមាធិនោះមិនបានរម្ងាប់ មិនបានខ្ពង់ខ្ពស់ មិនបាននូវការស្ងប់កិលេស មិនបានដល់នូវភាពជាចិត្តប្រសើរឯក មិនបានសង្កត់សង្កិនរាំង ( កិលេសដោយព្យាយាម ) ប្រកបដោយសង្ខារ ។ ម្នាលភិក្ខុទាំងឡាយ សម័យនោះ ចិត្តក៏ស្ងប់ស្ងៀមនៅក្នុងសន្តាន មានសភាពជាចិត្តប្រសើរឯក ហើយតាំងនៅមាំ ។ សមាធិនោះក៏បានរម្ងាប់ខ្ពង់ខ្ពស់ ស្ងប់កិលេស ដល់នូវភាពជាចិត្តប្រសើរឯក សង្កត់សង្កិនរាំង ( កិលេសដោយព្យាយាម ) មិនប្រកបដោយសង្ខារ មួយទៀត បុគ្គលបង្អោនចិត្តទៅដើម្បីធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាណាៗ កាលបើហេតុមាន រមែងគួរដល់នូវភាពគួរជាបន្ទាល់ ក្នុងធម៌នោះៗ ព្រោះធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាៗ បុគ្គលនោះបើប្រាថ្នាថា សូមឲ្យអាត្មាអញ ទទួលនូវការតាក់តែងឫទ្ធិច្រើនប្រការ គឺអាត្មាអញតែម្នាក់ឯង ធ្វើឲ្យទៅជាមនុស្សច្រើននាក់ គ្នាច្រើននាក់ឲ្យទៅជាម្នាក់ ធ្វើនូវទីកំបាំងឲ្យទៅជាទីវាល ធ្វើនូវទីវាលឲ្យទៅជាទីកំបាំង ដើរទម្លុះទៅក្រៅជញ្ជាំង ក្រៅកំពែង ក្រៅភ្នំបាន មិនមានទើសទាល់ដូចជាដើរទៅក្នុងទីវាល ធ្វើនូវការមុជចុះ និងងើបឡើង ក្នុងផែនដី ដូចជាមុជងើបក្នុងទឹក ដើរទៅលើទឹក មិនបែកធ្លាយទឹក ដូចជាដើរទៅលើផែនដី អណ្តែតទៅឯអាកាសទាំងភ្នែនបាន ដូចជាសត្វស្លាប ចាប់ស្ទាបអង្អែលព្រះចន្ទ្រ និងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាព

ច្រើនយ៉ាងនេះដោយដៃ ញុំាងអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោក កាលបើហេតុមាន រមែងដល់នូវភាពគួរជាបន្ទាល់ ក្នុងការតាក់តែងឫទ្ធិនោះៗ ។ បើបុគ្គលនោះ ប្រាថ្នាថា សូមឲ្យអាត្មាអញមានសោតធាតុ ដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងសោតធាតុ របស់មនុស្សធម្មតា ហើយឮនូវសំឡេងទាំងពីរ គឺសំឡេងទិព្វ ១ សំឡេងរបស់មនុស្ស ១ ដែលមាននៅក្នុងទីឆ្ងាយ និងទីជិត កាលបើហេតុមាន រមែងដល់នូវភាពគួរជាបន្ទាល់ ក្នុងការឮនូវសំឡេងនោះៗ ។ បើបុគ្គលនោះប្រាថ្នាថា សូមឲ្យអាត្មាអញ កំណត់ដឹងច្បាស់នូវចិត្តសត្វទាំងឡាយដទៃ បុគ្គលទាំងឡាយដទៃ ដោយកិច្ច ( របស់ខ្លួន ) បាន ចិត្តប្រកបដោយរាគៈក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ចិត្តដែលប្រាសចាករាគៈហើយក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈហើយ ចិត្តដែលប្រកបដោយទោសៈក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ ចិត្តដែលប្រាសចាកទោសៈហើយក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈហើយ ចិត្តដែលប្រកបដោយមោហៈក្តី អាត្មាក៏ដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ចិត្តដែលប្រាសចាកមោហៈហើយក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈហើយ ចិត្តដែលរួញថយក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តរួញថយ ចិត្តដែលរាយមាយក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តរាយមាយ ចិត្តដែលជាមហគ្គតៈ ( ចិត្តដល់នូវភាពជាធំ ) ក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តជាមហគ្គតៈ ចិត្តដែលជាអមហគ្គតៈ ( ចិត្តមិនបានដល់នូវភាពជាធំ ) ក្តី អាត្មាអញដឹងច្បាស់ថា

ចិត្តជាអមហគ្គតៈ ចិត្តដែលមានចិត្តដទៃក្រៃលែងជាង ( កាមាវចរៈ ) ក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តមានចិត្តដទៃក្រៃលែងជាង ចិត្តដែលមិនមានចិត្តដទៃក្រៃលែងជាង ( រូបាវចរ និងអរូបាវចរ ) ក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តមិនមានចិត្តដទៃក្រៃលែងជាង ចិត្តដែលតាំងមាំក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តតាំងមាំ ចិត្តដែលមិនបានតាំងមាំក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តមិនបានតាំងមាំ ចិត្តដែលរួចស្រឡះហើយក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តរួចស្រឡះហើយ ចិត្តដែលមិនរួចស្រឡះក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តមិនទាន់រួចស្រឡះ កាលបើហេតុមាន រមែងដល់នូវភាពជាបន្ទាល់ក្នុងការដឹងនោះៗ ។ បើបុគ្គលនោះប្រាថ្នាថា សូមឲ្យអាត្មាអញឃើញនូវបុព្វេនិវាសជាច្រើនប្រការ គឺរឭកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជាតិខ្លះ ១ ពាន់ជាតិខ្លះ ១ សែនជាតិខ្លះ សំវដ្តកប្ប ( កប្បវិនាស ) ខ្លះ វិវដ្តកប្ប ( កប្បដែលចម្រើន ) ខ្លះ សំវដ្តវិវដ្តកប្ប ( កប្បវិនាស និងកប្បចម្រើន ) ខ្លះ ថា អាត្មាអញបានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខ និងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះអាត្មាអញច្យុតចាកភពនោះហើយ បានទៅកើតក្នុងភពឯណោះ ដែលអាត្មាអញបានកើតក្នុងភពនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខ និងទុក្ខយ៉ាងនេះ មាន

កំណត់អាយុត្រឹមប៉ុណ្ណោះ លុះអាត្មាអញបានច្យុតចាកភពនោះហើយ ក៏បាន មកកើតក្នុងភពនេះ សូមឲ្យអាត្មាអញរឭកឃើញនូវបុព្វេនិវាសជាច្រើនប្រការ ព្រមទាំងអាការ គឺសម្បុរ និងអាហារជាដើម ព្រមទាំងឧទ្ទេស គឺឈ្មោះ និង គោត្រកូល ដោយប្រការដូច្នេះឯង កាលបើហេតុមាន រមែងដល់នូវភាពគួរ ជាបន្ទាល់ក្នុងការរឭកឃើញនោះៗ ។ បើបុគ្គលនោះប្រាថ្នាថា សូមឲ្យអាត្មា អញមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធស្អាត កន្លងបង់នូវចក្ខុជារបស់មនុស្សធម្មតា បានឃើញនូវសត្វទាំងឡាយ ដែលច្យុត ដែលកើតឡើង ថោកទាប និងឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់ នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួនថា អើហ្ន៎ សត្វពួកនេះ ប្រកប ដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នក តិះដៀលនូវព្រះអរិយៈទាំងឡាយ ជាមិច្ឆាទិដ្ឋិ កាន់យកនូវអំពើជាមិច្ឆាទិដ្ឋិ សត្វពួកនោះ លុះទម្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក អើហ្ន៎ ចំណែកឯសត្វពួកនេះប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀលនូវ ព្រះអរិយៈទាំងឡាយ ជាសម្មាទិដ្ឋិ កាន់យកនូវអំពើជាសម្មាទិដ្ឋិ សត្វពួក នោះ លុះទម្លាយរាងកាយស្លាប់ទៅ រមែងចូលទៅកាន់លោក គឺសុគតិសួគ៌ សូមឲ្យអាត្មាអញ មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុជារបស់ មនុស្សធម្មតា ឃើញនូវសត្វទាំងឡាយ ដែលច្យុត ដែលកើត ជាសត្វថោក ថយ និងឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់

ដឹងច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ដោយប្រការដូច្នេះ កាលបើហេតុមាន រមែងដល់នូវភាពគួរជាបន្ទាល់ ក្នុងការដឹង និងការឃើញ នោះៗ ។ បើបុគ្គលនោះប្រាថ្នាថា សូមឲ្យអាត្មាអញបានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅ នៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន ហើយ សម្រេចសម្រាន្តនៅ កាលបើហេតុមាន រមែងដល់នូវភាពគួរជាបន្ទាល់ ក្នុង ការសម្រេចនោះៗ ។

# អដ្ឋកថា

## សង្ឃសូត្រ

[ ១០៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសង្ឃសូត្រទី ១០ ដូចតទៅនេះ បទថា **ធោវតិ** ប្រែថា លាង ។ បទថា **សន្ធោវតិ** ប្រែថា លាងដោយល្អ គឺ លាងហើយលាងទៀត ។ បទថា **និទ្ធោវតិ** ប្រែថា លាងដោយមិនមាន មន្ទិលសេសសល់ ។ បទថា **អនិទ្ធន្តំ** គឺមិនទាន់បានរម្លាយ ។ បទថា **អនិន្នីតកសាវំ** គឺមិនទាន់បានជញ្ជមន្ទិល ។ បទថា **បភង្គុ** បានដល់ មានការបែកធ្លាយទៅជាសភាវៈ ។ រៀរមាសដែលរម្លាយហើយ គ្រាន់តែ យកកណ្តាប់ដៃដំក៏បែក ។ បទថា **បដ្ឋកាយ** បានដល់ ដើម្បីឲ្យមាសទៅជា

បន្ទះ ។ បទថា **គីវេយ្យកេ** បានដល់ គ្រឿងប្រដាប់ក ។ បទថា **អធិចិត្តំ** បានដល់ ចិត្តដែលអប់រំដោយសមថៈ និងវិបស្សនា ។ បទថា **អនុយុត្តស្ស** បានដល់ ចម្រើន ។ បទថា **សចេតសោ** បានដល់ សម្បូរដោយចិត្ត ។ បទថា **ធម្មជាតិកោ** បានដល់ ជាបណ្ឌិតដោយខ្នើត ។ ក្នុងវិតក្កទាំងឡាយ មានកាមវិតក្កជាដើម មានអធិប្បាយថា វិតក្កដែលប្រារព្ធកាមកើតឡើង ឈ្មោះថា **កាមវិតក្កោ** ។ វិតក្កដែលសម្បយុត្តដោយព្យាបាទ ឈ្មោះថា **ព្យាបាទវិតក្កោ** ដែលសម្បយុតដោយវិហិង្សា ឈ្មោះថា **វិហិង្សាវិតក្កោ** ។

ក្នុងវិតក្កទាំងឡាយ មានញាតិវិតក្កជាដើម មានអធិប្បាយថា វិតក្កដែលប្រារព្ធញាតិកើតឡើង ដោយន័យជាដើមថា ញាតិរបស់យើងទាំងឡាយជាច្រើន ជាអ្នកមានបុណ្យ ឈ្មោះថា **ញាតិវិតក្ក** ។ វិតក្កដែលអាស្រ័យផ្ទះដែលប្រារព្ធជនបទកើតឡើង ដោយន័យជាដើមថា ជនបទនោះផុតភ័យ រកភិក្ខាបានងាយ ឈ្មោះថា **ជនបទវិតក្ក** ។

បទថា **ន បណីតោ** គឺមិនគួរជាទីត្រេកអរ ។ បទថា **ន បដិប្បស្សទ្ធលទ្ធោ** គឺមិនបាននូវសេចក្តីរម្ងាប់កិលេស ។ បទថា **ន ឯកោទិភាវាធិគតោ** គឺមិនដល់នូវភាពជាសមាធិ ។ បទថា **សសង្ខារនិគ្គយ្ហវារិតវតោ** បានដល់ សង្កត់ គឺរារាំងកិលេសដោយសសង្ខារដែលជាសម្បយោគ មិនមែនកើតឡើងក្នុងទីបំផុត ដែលកិលេសទាំងឡាយ ត្រូវកាត់ផ្តាច់ទៅ តែកើតឡើងហាមនូវកិលេសទាំងឡាយ ។

ក្នុងបទថា **ហោតិ សោ ភិក្ខវេ សមយោ** នេះ មានអធិប្បាយថា ដែល

ឈ្មោះថា សម័យ បានដល់ កាលដែលជាសប្បាយ ៥ គឺឧតុសប្បាយ ១ អាហារសប្បាយ ១ សេនាសនៈសប្បាយ ១ បុគ្គលសប្បាយ ១ និងធម្មស្សវនៈសប្បាយ ១ ។ បទថា **យន្តំ ចិត្តំ** បានដល់ ក្នុងសម័យណា វិបស្សនាចិត្តនោះ ។ បទថា **អជ្ឈត្តំយេវ សន្តិដ្ឋតិ** បានដល់ តាំងនៅក្នុងខ្លួននោះឯង ឯវិស័យនៃអារម្មណ៍ដែលទៀង ឈ្មោះថា **អជ្ឈត្ត** ក្នុងទីនេះ សូម្បីអារម្មណ៍ខាងក្នុងក៏គួរ ។ មានពាក្យអធិប្បាយថា វិបស្សនាចិត្តលះអារម្មណ៍ច្រើន ហើយតាំងមាំនៅក្នុងអារម្មណ៍តែមួយ គឺក្នុងអារម្មណ៍ គឺព្រះនិព្វានប៉ុណ្ណោះ ។ បទថា **សន្និសីទតិ** បានដល់ ស្ងប់ដោយល្អ ។ បទថា **ឯកោទិភោតិ ហោតិ** បានដល់ ជាចិត្តមានអារម្មណ៍តែមួយដ៏លើស ។ បទថា **សមាធិយតិ** បានដល់ តាំងមាំដោយល្អ ។

បទថា **សន្តោ** ជាដើម អធិប្បាយថា សមាធិ ឈ្មោះថា ស្ងប់ ព្រោះការស្ងប់រម្ងាប់កិលេសដែលជាសត្រូវ ។ សមាធិ ឈ្មោះថា ប្រណីត ព្រោះអត្ថថា ឆ្អែតស្កប់ស្កល់ ។ សមាធិ ឈ្មោះថា បាននូវការស្ងប់រម្ងាប់ ព្រោះបាននូវការស្ងប់រម្ងាប់កិលេស ។ សមាធិ ឈ្មោះថា ដល់នូវភាពជាធម៌ឯកផុសឡើង ព្រោះដល់នូវធម្មជាតដែលមានអារម្មណ៍ ១ ដ៏លើស ។ សមាធិដែលឈ្មោះថា មិនត្រូវសង្កត់សង្កិន គឺរាំងកិលេសទាំងឡាយ ហើយត្រូវហាមដោយសប្បយោគ ព្រោះកើតឡើងក្នុងទីបំផុតដែលកិលេសទាំងឡាយត្រូវកាត់ផ្ដាច់ទៅ ព្រោះហេតុនោះ ទើបឈ្មោះថា មិនត្រូវសសង្ខារសង្កត់សង្កិន រាំរាំង ។ ភិក្ខុនេះ ឈ្មោះថា ធ្វើចិត្តឲ្យវិលត្រឡប់ ហើយសម្រេច

អរហត្តផល ដោយហេតុមានប្រមាណប៉ុណ្ណេះ ។

ឥឡូវនេះ កាលទ្រង់សម្ដែងការបាក់ជុះ ដោយអភិញ្ញារបស់ភិក្ខុនោះ ដែលជាព្រះខីណាស្រព ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **យស្ស យស្ស** ច ជាដើម ។ បណ្ដាបទទាំងនោះ បទថា **អភិញ្ញា សច្ឆិករណីយស្ស** បានដល់ ដែលគួរធ្វើឲ្យប្រចក្សដោយក្រៃលែង ។ បទថា **សតិ សតិ អាយតនេ** សេចក្ដីថា កាលអាយតនៈ ពោល គឺបុព្វហេតុ និងប្រភេទនៃឈានជាដើម ដែលគប្បីបានក្នុងកាល ឥឡូវនេះ មាន គឺកាលហេតុមានកថាពណ៌នាអំពីអភិញ្ញានេះរបស់ព្រះខីណាស្រពនោះ គប្បីជ្រាបដោយពិស្ដារតាមន័យដែលពោលហើយ ក្នុងវិសុទ្ធិមគ្គនោះឯង ។ ឯបទថា **អាសវានំ ខយា** ជាដើម ក្នុងសូត្រនេះ គប្បីជ្រាបថា បានត្រាស់ហើយដោយអំណាចផលសមាបត្តិ ៕

**អដ្ឋកថា សង្ឃសូត្រទី ១០ ចប់**

# សុត្តន្តបិដក

## សមុគ្គតសូត្រទី ១១

[ ១០៤ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រកបនូវអធិចិត្តហើយ ត្រូវធ្វើទុកក្នុងចិត្តនូវនិមិត្ត ៣ យ៉ាង ក្នុងកាលដ៏គួរ គឺត្រូវធ្វើទុកក្នុងចិត្តនូវសមាធិ-

និមិត្ត ក្នុងកាលដ៏គួរ ១ ត្រូវធ្វើទុកក្នុងចិត្តនូវបគ្គាហនិមិត្ត ក្នុងកាលដ៏គួរ ១ ត្រូវធ្វើទុកក្នុងចិត្ត នូវឧបេក្ខានិមិត្ត ក្នុងកាលដ៏គួរ ១ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកប្រកបរឿយៗ នូវអធិចិត្ត គប្បីធ្វើទុកក្នុងចិត្តនូវសមាធិនិមិត្តតែមួយចំណែក ហេតុនោះ គប្បីនាំចិត្តឲ្យប្រព្រឹត្តទៅដើម្បីសេចក្ដីខ្ជិលច្រអូស ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកប្រកបរឿយៗ នូវអធិចិត្ត គប្បីធ្វើទុកក្នុងចិត្តនូវបគ្គាហនិមិត្តតែមួយចំណែក ហេតុនោះ គប្បីនាំចិត្តឲ្យប្រព្រឹត្តទៅ ដើម្បីសេចក្ដីរាយមាយ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកប្រកបរឿយៗ នូវអធិចិត្ត គប្បីធ្វើទុកក្នុងចិត្តនូវឧបេក្ខានិមិត្ត តែមួយចំណែក ហេតុនោះ គប្បីនាំចិត្តមិនឲ្យតាំងមាំដោយប្រពៃ ដើម្បីការអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ កាលណា ភិក្ខុអ្នកប្រកបនូវអធិចិត្ត រមែងធ្វើទុកក្នុងចិត្តនូវសមាធិនិមិត្ត ក្នុងកាលដ៏គួរ ធ្វើទុកក្នុងចិត្តនូវបគ្គាហនិមិត្ត ក្នុងកាលដ៏គួរ ធ្វើទុកក្នុងចិត្តនូវឧបេក្ខានិមិត្ត ក្នុងកាលដ៏គួរ ទើបចិត្តនោះក៏ទន់ គួរដល់ការនាកម្ម ជាចិត្តភ្លឺផ្លេក មិនរឹង តាំងមាំដោយប្រពៃ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយបាន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាជាងមាសក្ដី កូនសិស្សជាងមាសក្ដី ចាត់ចែងបាវ លុះចាត់ចែងបាវរួចហើយ ក៏ដុតមាត់បាវ កាលដុតមាត់បាវ ក៏យកដង្កៀបចៀបមាសដាក់ក្នុងមាត់បាវ ហើយសប់ក្នុងកាលដ៏គួរ បំព្រំទឹកក្នុងកាលដ៏គួរ សម្លឹងមើលក្នុងកាលដ៏គួរ ។ ម្នាលភិក្ខុទាំង-ឡាយ បើជាងមាសក្ដី កូនសិស្សជាងមាសក្ដី គប្បីសប់តែមាសនោះមួយចំណែក នោះជាហេតុធ្វើឲ្យមាសឆេះរលួយទៅ ។ ម្នាលភិក្ខុទាំងឡាយ បើ

ជាងមាសក្តី កូនសិស្សជាងមាសក្តី បំពុំតែមាសនោះ ដោយទឹកមួយចំណែក នោះជាហេតុធ្វើមាសឲ្យត្រជាក់ ។ ម្នាលភិក្ខុទាំងឡាយ បើជាងមាសក្តី កូនសិស្សជាងមាសក្តី សម្លឹងមើលតែមាសនោះមួយចំណែក នោះជាហេតុធ្វើមិនឲ្យមាសឆ្អិនសព្វសាច់បាន ។ ម្នាលភិក្ខុទាំងឡាយ កាលណាជាងមាសក្តី កូនសិស្សជាងមាសក្តី សប់មាសនោះ ក្នុងកាលដ៏គួរ បំពុំដោយទឹក ក្នុងកាលដ៏គួរ សម្លឹងមើលក្នុងកាលដ៏គួរហើយ ទើបមាសនោះទៅជាមាសទន់ គួរដល់ការងារ ជាមាសមានសម្បុរភ្លឺផ្លេក មិនស្រួយ គួរបង្អោនទៅ ដើម្បីការងារ ដោយប្រពៃផង បើគេប្រាថ្នាគ្រឿងប្រដាប់ប្លែកៗណាៗ ទោះជាជំបារមាសក្តី កុណ្ឌលក្តី គ្រឿងប្រដាប់កក្តី កម្រងមាសក្តី រមែងសម្រេចប្រយោជន៍នោះៗ បាន ( យ៉ាងណាមិញ ) ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុអ្នកប្រកបរឿយៗ នូវអធិចិត្ត ត្រូវធ្វើទុកក្នុងចិត្តនូវនិមិត្ត ៣ យ៉ាង ក្នុងកាលដ៏គួរ គឺត្រូវធ្វើទុកក្នុងចិត្តនូវសមាធិនិមិត្ត ក្នុងកាលដ៏គួរ ១ ត្រូវធ្វើទុកក្នុងចិត្តនូវបគ្គាហនិមិត្ត ក្នុងកាលដ៏គួរ ១ ត្រូវធ្វើទុកក្នុងចិត្តនូវឧបេក្ខានិមិត្តក្នុងកាលដ៏គួរ ១ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកប្រកបនូវអធិចិត្ត គប្បីធ្វើទុកក្នុងចិត្តនូវសមាធិនិមិត្ត តែមួយចំណែក ហេតុនោះ គប្បីនាំចិត្តឲ្យប្រព្រឹត្តទៅ ដើម្បីសេចក្តីខ្ជិលប្រអូស ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រកបរឿយៗ នូវអធិចិត្ត គប្បីធ្វើទុកក្នុងចិត្តនូវបគ្គាហ-និមិត្ត តែមួយចំណែក ហេតុនោះ គប្បីនាំចិត្តឲ្យប្រព្រឹត្តទៅ ដើម្បីសេចក្តីរាយមាយ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកប្រកបរឿយៗ នូវអធិចិត្ត គប្បី

ធ្វើទុកក្នុងចិត្តនូវឧបេក្ខានិមិត្ត តែមួយចំណែក ហេតុនោះ គប្បីនាំចិត្តមិនឲ្យតាំងមាំដោយប្រពៃ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ លុះណាតែភិក្ខុអ្នកប្រកបរឿយៗ នូវអធិចិត្ត ធ្វើទុកក្នុងចិត្តនូវសមាធិនិមិត្ត ក្នុងកាលដ៏គួរ ធ្វើទុកក្នុងចិត្តនូវបគ្គាហនិមិត្ត ក្នុងកាលដ៏គួរ ធ្វើទុកក្នុងចិត្តនូវឧបេក្ខានិមិត្ត ក្នុងកាលដ៏គួរ ទើបចិត្តនោះ រមែងទៅជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តភ្លឺថ្លេក មិនរឹង តាំងមាំដោយប្រពៃ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយ បុគ្គលបង្អោនទៅនូវចិត្ត ដើម្បីធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមណាៗ កាលបើហេតុមាន រមែងដល់នូវភាពគួរជាបន្ទាល់ក្នុងធម៌នោះៗ ដើម្បីធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម ។ បើបុគ្គលនោះប្រាថ្នាថា សូមឲ្យអាត្មាអញបានចំពោះនូវការតាក់តែងឫទ្ធិជាច្រើនប្រការ ។បេ។ សូមឲ្យអាត្មាអញអស់អាសវៈ ... ធ្វើឲ្យជាក់ច្បាស់ សម្រេចសម្រាន្តនៅ កាលបើហេតុមាន ( បុគ្គលនោះ ) រមែងដល់នូវភាពគួរជាបន្ទាល់ក្នុងគុណនោះៗ មិនខាន ។

លោណផលវគ្គទី ៥ ចប់

## ឧទ្ទាននៃលោណផលវគ្គនោះ គឺ

និយាយពីកិច្ច ដែលត្រូវធ្វើយ៉ាងរួសរាន់ ១ ការស្ងប់ស្ងាត់ ១ ធម្មចក្ខុកើតឡើងដូចព្រះអាទិត្យ ក្នុងសារទសម័យ ១ បរិសទ្យ ៣ ពួក ១ ភិក្ខុប្រកបដោយធម៌

៣ ដូចសេះអាជានេយ្យមាន ៣ លើក ១ បាបកម្ម ដូចជាអំបិល ១ គុណសម្បត្តិដ៏ខ្ពង់ខ្ពស់របស់ភិក្ខុសង្ឃ ១ ។

បណ្ណាសកទី ២ ចប់

# អដ្ឋកថា

## សមុគ្គតសូត្រ

[ ១០៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសមុគ្គតសូត្រទី ១១ ដូចតទៅនេះ បទថា **អធិចិត្ត** បានដល់ ចិត្តក្នុងសមថៈ និងវិបស្សនានោះឯង ។ បទថា **តីណិ និមិត្តានិ** បានដល់ ហេតុ ៣ ។ បទថា **កាលេន កាលំ** បានដល់ ក្នុងកាលដ៏សមគួរ អធិប្បាយថា អស់កាលដ៏សមគួរ ។ ក្នុងបទថា **កាលេន កាលំ សមាធិនិមិត្តំ មនសិការាតព្វំ** ជាដើម មានអធិប្បាយថា ភិក្ខុគប្បីកំណត់កាលនោះៗ ហើយ មនសិការដល់ឯកគ្គតាក្នុងកាលដែលចិត្តប្រកបដោយឯកគ្គតា ។

ព្រោះថា ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់ឯកគ្គតាថា ជាសមាធិនិមិត្ត ។ ក្នុងបទថា **សមាធិនិមិត្តំ** នោះ មានអត្ថនៃពាក្យដូច្នេះ និមិត្ត គឺសមាធិ ឈ្មោះថា សមាធិនិមិត្ត ។ ក្នុងបទ ២ ដ៏សេស ក៏មានន័យនេះឯង ។ បទថា **បគ្គាហោ** គឺការផ្គងចិត្ត ជាឈ្មោះរបស់វីរិយៈ ។ បទថា **ឧបេក្ខា**

ជាឈ្មោះនៃមជ្ឈត្តការៈ ។ ព្រោះដូច្នោះ ភិក្ខុគប្បីមនសិការដល់វិរិយៈ ក្នុងកាលដ៏សមគួរដល់វិរិយៈ ។ គប្បីតាំងនៅក្នុងមជ្ឈត្តការៈ ក្នុងកាលដ៏សមគួរដល់មជ្ឈត្តការៈនោះឯង ។ បទថា **ឋានេ ចិត្តំ សោ សមាទហេយ្យ** សេចក្តីថា ហេតុដែលធ្វើឲ្យចិត្តនោះតាំងនៅក្នុងការៈ គឺការខ្ជិលច្រអូសមាន ។ ក្នុងហេតុក្រៅអំពីនោះ ក៏មានន័យនេះឯង ។ ក្នុងបទថា **ឧបេក្ខានិមិត្តំ យោ មនសិការេយ្យ** នេះ មានអត្ថដូច្នេះថា ភិក្ខុគប្បីសម្លឹងមើលនូវការវាងវៃនៃញាណដោយមជ្ឈត្តការៈ ។ បទថា **អាសវានំ ខយាយ** បានដល់ ដើម្បីជាប្រយោជន៍ដល់អរហត្តផល ។ បទថា **ឧក្កំ ពន្ធេយ្យ** បានដល់ គប្បីត្រៀមអំបែងដាក់ផ្សង ។ បទថា **អាលិម្បេយ្យ** សេចក្តីថា គប្បីដាក់ផ្សងទៅក្នុងអំបែងនោះ ហើយដុតភ្លើង ប្រើស្នប់សប់ឲ្យភ្លើងឆេះ ។ បទថា **ឧក្កាមុខេ បក្ខិបេយ្យ** សេចក្តីថា គប្បីចាប់ផ្សង ហើយដាក់លើផ្សង ឬក្នុងស្នប់ ។ បទថា **អជ្ឈុបេក្ខតិ** បានដល់ ពិចារណាមើលថា កម្តៅបានហើយ ។ បទថា **សម្មា សមាធិយតិ អាសវានំ ខយាយ** បានដល់ ចិត្តតាំងមាំដោយប្រពៃ ដើម្បីជាប្រយោជន៍ដល់អរហត្តផល ។ ភិក្ខុចម្រើនវិបស្សនា ហើយសម្រេចអរហត្តផល ព្រះមានព្រះភាគទ្រង់សម្តែងហើយដោយហេតុមាន ប្រមាណប៉ុណ្ណេះ ។

ឥឡូវនេះ កាលទ្រង់សម្តែងបដិបទាជាហេតុឲ្យសម្រេចអភិញ្ញារបស់ព្រះខីណាស្រពនោះ ទើបត្រាស់ពាក្យថា **យស្ស យស្ស ច** ជាដើម ពាក្យ

*នោះ គប្បីជ្រាបតាមន័យដែលពោលហើយខាងដើមនោះឯង ។*

**អដ្ឋកថា សមុគ្គតសូត្រទី ១១ ចប់**

**លោណផលវគ្គទី ៥ ចប់**

**ទុតិយបណ្ណាសកៈ ចប់**

# សុត្តន្តបិដក

# តតិយបណ្ណាសក

# សម្ពោធិវគ្គទី ១

## បុព្វសូត្រទី១

[ ១០៥ ] ម្នាលភិក្ខុទាំងឡាយ កាលមុននឹងត្រាស់ដឹង តថាគតនៅជាពោធិសត្វ មិនទាន់ត្រាស់ដឹងនៅឡើយ មានសេចក្តីត្រិះរិះដូច្នេះថា អានិសង្សដូចម្តេច ទោសដូចម្តេច ការរលាស់ខ្លួនចេញដូចម្តេចក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា សភាវៈណាកើតឡើង ព្រោះអាស្រ័យសេចក្តីសុខ សោមនស្សក្នុងលោក សភាវៈនេះឈ្មោះថា ជាអានិសង្សក្នុងលោក សភាវៈណាមិនទៀងជាទុក្ខ មានសេចក្តីប្រែប្រួលទៅជាធម្មតា សភាវៈនេះ ឈ្មោះថា ជាទោសក្នុងលោក សភាវៈណាជាគ្រឿងបន្ទោបង់នូវឆន្ទរាគ ជាគ្រឿងលះបង់នូវឆន្ទរាគ ក្នុងលោក សភាវៈនេះ ឈ្មោះថា ជាការរលាស់ខ្លួនចេញ ក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ តថាគតនៅមិនទាន់ត្រាស់ដឹងតាមពិត នូវអានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ខ្លួនចេញចាកលោក ថាជាការរលាស់ខ្លួនចេញផង យ៉ាងនេះត្រឹមណា ម្នាលភិក្ខុទាំងឡាយ តថាគតក៏មិនប្តេជ្ញាថាជាអ្នកត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណ-

ព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសត្រឹមណោះ ។ ម្នាល ភិក្ខុទាំងឡាយ លុះតែតថាគតបានត្រាស់ដឹងតាមពិតនូវអានិសង្សថាជាអានិ-សង្សផង នូវទោសថាជាទោសផង នូវការរលាស់ខ្លួនចេញចាកលោកថាជាការរលាស់ខ្លួនចេញផង យ៉ាងនេះក្នុងកាលណា ម្នាលភិក្ខុទាំងឡាយ ទើបតថាគតប្តេជ្ញាថាជាអ្នកត្រាស់ដឹង នូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ក្នុងកាលណោះ ។ ទាំងការដឹង និងការឃើញ ក៏កើតឡើងដល់តថាគតថា ការរួចស្រឡះរបស់តថាគតមិនកម្រើកទេ ជាតិនេះជាទីបំផុត ឥឡូវនេះ ភពថ្មីទៀតមិនមានឡើយ ។

# អដ្ឋកថា

# តតិយបណ្ណាសក

# សម្ពោធិវគ្គទី ១

## បុព្វសូត្រ

[ ១០៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបុព្វសូត្រទី ១ នៃតតិយបណ្ណាសកៈ ដូចតទៅនេះ ក្នុងបទថា **បុព្វេវ សម្ពោធា** បានដល់ ក្នុងកាលមុនអំពីត្រាស់ដឹង លោកអធិប្បាយថា ក្នុងវេលាដទៃ គឺមុនពេលអរិយមគ្គកើតឡើងនោះឯង ។ បទថា **អនភិសម្ពុទ្ធស្ស** បានដល់ មិនទាន់ចាក់ធ្លុះអរិយសច្ច ៤ ។ បទថា **ពោធិសត្តស្សេវ សតោ** សេចក្ដីថា កាលសត្វដែលត្រាស់ដឹងនោះឯង គឺផ្ដើមនឹងសម្រេចសម្មាសម្ពោធិញ្ញាណមាន ឬជាអ្នកជាប់ជំពាក់ក្នុងពោធិញ្ញាណមាន ។ ព្រោះថា ព្រះសម្មាសម្ពុទ្ធនៃយើង ចាប់តាំងអំពីកាលអភិនីហារសម្រេចហើយ ដោយសមោធានធម៌ ៨ ប្រការ ទៀបបាទមូលរបស់ព្រះមានព្រះភាគព្រះនាមទីបង្ករ ដែលទ្រង់យាងមកហើយយ៉ាងនោះ ជាអ្នកជាប់ គឺជាប់ជំពាក់ក្នុងពោធិញ្ញាណ ទ្រង់ព្រះតម្រិះថា អាត្មាអញត្រូវសម្រេចព្រះពោធិញ្ញាណនេះ ហើយទ្រង់មិនលះនូវសេចក្ដីព្យាយាម ដើម្បីសម្រេចព្រះពោធិញ្ញាណនោះឯងយាងមកហើយ ព្រោះដូច្នោះ ទើបហៅថា ព្រះពោធិសត្វ ។

បទថា **កោ នុ ខោ** គឺ **កតមោ នុ ខោ** ប្រែថា អ្វីហ្ន៎ ។ សន្ធារ-

លោក ឈ្មោះថា **លោក** ។ បទថា **អស្សាទោ** បានដល់ ជាអ្នកមានការត្រេកអរ ។ បទថា **អាទីនវោ** បានដល់ មានការមិនគួរស្រស់ថ្លា ។ បទថា **តស្ស មយ្ហំ** សេចក្តីថា កាលតថាគតជាប់ជំពាក់ក្នុងពោធិញ្ញាណយ៉ាងនេះមាន ។ បទថា **ឆន្ទរាគប្បដិវិនយោ ឆន្ទរាគប្បហានំ** សេចក្តីថា ព្រោះថា ឆន្ទរាគៈ ដល់នូវការប្រាសទៅ គឺលះបាន ព្រោះប្រារព្ធ គឺអាស្រ័យព្រះនិព្វាន ព្រោះដូច្នោះ ទើបព្រះនិព្វាន ហៅថា **ឆន្ទរាគវិនយោ** គឺនាំឆន្ទរាគៈចេញទៅ **ឆន្ទរាគប្បហានំ** គឺប្រហាររាគៈបាន ។ បទថា **ឥទំ លោកនិស្សរណំ** សេចក្តីថា ព្រះនិព្វាននេះ លោកហៅថា **លោកនិស្សរណំ** គឺស្ទុះចេញទៅអំពីលោក ព្រោះរលាស់ចេញទៅហើយចាកលោក ។ បទថា **យាវកីវំ** សេចក្តីថា អស់កាល មានប្រមាណប៉ុនណា ។ បទថា **អព្ភញ្ញាសឹ** សេចក្តីថា បានដឹងហើយ ដោយអរិយមគ្គញ្ញាណដ៏ប្រសើរក្រៃលែង ។ ដោយបទទាំង ២ នេះថា **ញាណញ្ច បន មេ ទស្សនំ** ព្រះមានព្រះភាគត្រាស់សំដៅដល់បច្ចវេក្ខណញ្ញាណ ។ បទដ៏សេស ក្នុងព្រះសូត្រនេះងាយយល់ទាំងអស់ហើយ ៕

## អដ្ឋកថា បុព្វសូត្រទី ១ ចប់

# សុត្តន្តបិដក

## មនុស្សសូត្រទី ២

[ ១០៦ ] ម្នាលភិក្ខុទាំងឡាយ តថាគតត្រាច់ស្វែងរកអានិសង្សរបស់លោក សភាវៈណាជាអានិសង្សក្នុងលោក តថាគតក៏បានជួបប្រទះនូវសភាវៈនោះ អានិសង្សទាំងអម្បាលម៉ានក្នុងលោក អានិសង្សនោះ តថាគតឃើញច្បាស់ហើយដោយប្រាជ្ញា ។ ម្នាលភិក្ខុទាំងឡាយ តថាគតត្រាច់ស្វែងរកទោសរបស់លោក សភាវៈឯណាជាទោសក្នុងលោក តថាគតក៏បានជួបប្រទះនូវសភាវៈនោះ ទោសទាំងអម្បាលម៉ានក្នុងលោក ទោសនោះ តថាគតឃើញច្បាស់ហើយ ដោយប្រាជ្ញា ។ ម្នាលភិក្ខុទាំងឡាយ តថាគតត្រាច់ស្វែងរកនូវការរលាស់ខ្លួនចេញចាកលោក ធម្មជាតណាជាការរលាស់ខ្លួនចេញក្នុងលោក តថាគតក៏បានជួបប្រទះធម្មជាតនោះ ការរលាស់ខ្លួនចេញទាំងអម្បាលម៉ានក្នុងលោក ការរលាស់ខ្លួនចេញនោះ តថាគតក៏បានឃើញច្បាស់ហើយ ដោយប្រាជ្ញា ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនទាន់ត្រាស់ដឹងតាមពិតនូវអានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ខ្លួនចេញចាកលោកថាជាការរលាស់ខ្លួនចេញផង ដរាបណា ម្នាលភិក្ខុទាំងឡាយ តថាគតក៏មិនទាន់ប្ដេជ្ញាថាជាអ្នកត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ លុះតែតថាគត បានត្រាស់ដឹង

តាមពិតនូវអានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ខ្លួនចេញចាកលោកថា ជាការរលាស់ខ្លួនចេញផង ក្នុងកាលណា ម្នាលភិក្ខុទាំងឡាយ ទើបតថាគតប្តេជ្ញាថាជាអ្នកត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសក្នុងកាលនោះ ។ ទាំងការដឹង និងការឃើញ ក៏កើតឡើងដល់តថាគតថា ការរួចស្រឡះរបស់តថាគតមិនកម្រើកទេ ជាតិនេះ ជាទីបំផុត ឥឡូវនេះ ភពថ្មីទៀត មិនមានឡើយ ។

# អដ្ឋកថា

## មនុស្សសូត្រ

[ ១០៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមនុស្សសូត្រទី ២ ដូចតទៅនេះ បទថា **អស្សាទបរិយេសនំ អចរឹ** សេចក្តីថា មិនអន្ទោលទៅដើម្បីជាប្រយោជន៍ដល់ការស្វែងរកអស្សាទ ។ សួរថា បានអន្ទោលទៅចាប់តាំងពីកាលណា ។ ឆ្លើយថា អន្ទោលទៅតាំងអំពីសុមេធតាបស ។ បទថា **បញ្ញាយ** បានដល់មគ្គប្បញ្ញា មួយអន្លើដោយវិបស្សនា ។ បទថា **សុទិដ្ឋោ** បានដល់ ចាក់ធ្លុះហើយដោយល្អ គប្បីជ្រាបអត្ថក្នុងបទទាំងអស់ដោយឧបាយនេះ ៕

**អដ្ឋកថាមនុស្សសូត្រទី ២ ចប់**

# សុត្តន្តបិដក

## អស្សាទសូត្រទី ៣

[ ១០៧ ] ម្នាលភិក្ខុទាំងឡាយ បើអានិសង្សនុ៎ះ មិនមានក្នុងលោក ពួក សត្វក៏មិនគប្បីត្រេកត្រអាលនិងអានិសង្សនេះក្នុងលោកដែរ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែអានិសង្សមាននៅក្នុងលោក ពួកសត្វទើបត្រេក-ត្រអាលក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ បើទោសក្នុងលោកមិនមានទេ ពួកសត្វក៏មិនគប្បីនឿយណាយនឹងទោសនេះក្នុងលោកដែរ ម្នាលភិក្ខុទាំង-ឡាយ ព្រោះហេតុតែទោសមាននៅក្នុងលោក ទើបពួកសត្វនឿយណាយក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ បើការរលាស់ខ្លួនចេញនុ៎ះ មិនមានក្នុងលោកទេ ពួកសត្វក៏មិនគប្បីរលាស់ខ្លួននេះចេញចាកលោកបានដែរ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែការរលាស់ខ្លួនចេញ មាននៅក្នុងលោក ទើបពួកសត្វរលាស់ខ្លួនចេញចាកលោកបាន ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមិនទាន់ដឹងច្បាស់តាមពិតនូវអានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ខ្លួនចេញចាកលោកថាជាការរលាស់ខ្លួនចេញផង ដរាបណា ម្នាលភិក្ខុទាំងឡាយ សត្វមិនទាន់ប្រាសចេញ មិនទាន់គេចចេញ មិនទាន់រួចផុតស្រឡះចាកលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ចាកពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស មានចិត្តមិនទាន់ប្រាសចាកព្រំដែនដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ លុះតែពួកសត្វដឹងច្បាស់តាមពិតនូវអានិសង្សថាជាអានិសង្សផង

នូវទោសថាជាទោសផង នូវការរលាស់ខ្លួនចេញចាកលោកថាជាការរលាស់ខ្លួនចេញផង ក្នុងកាលណា ម្នាលភិក្ខុទាំងឡាយ ពួកសត្វទើបប្រាសចេញគេចចេញរួចផុតស្រឡះចាកលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ចាកពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស មានចិត្តប្រាសចាកព្រំដែនក្នុងកាលនោះ ។

# អដ្ឋកថា

## អស្សាទសូត្រ

ក្នុងអស្សាទសូត្រទី ៣ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាអស្សាទសូត្រទី ៣ ចប់

# សុត្តន្តបិដក

## សមណសូត្រទី ៤

[ ១០៨ ] ម្នាលភិក្ខុទាំងឡាយ ពួកសមណៈ ឬព្រាហ្មណ៍ណាមួយមិនដឹងច្បាស់តាមពិតនូវអានិសង្សថា ជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ខ្លួនចេញចាកលោកថា ជាការរលាស់ខ្លួនចេញផង ម្នាលភិក្ខុ

ឡាយ ពួកសមណៈ ឬព្រាហ្មណ៍ទាំងនោះ តថាគតមិនសន្មតថា ជាសមណៈក្នុងពួកសមណៈ មិនសន្មតថាជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ទេ ដ្បិតថា អ្នកដ៏មានអាយុទាំងនោះ មិនទាន់ធ្វើឲ្យជាក់ច្បាស់នូវប្រយោជន៍ ជារបស់សមណៈផង នូវប្រយោជន៍ជារបស់ព្រាហ្មណ៍ផង ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ននេះ ។ ម្នាលភិក្ខុទាំងឡាយ លុះតែពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ដឹងច្បាស់តាមពិត នូវអានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ខ្លួនចេញចាកលោកថាជាការរលាស់ខ្លួនចេញផង ម្នាលភិក្ខុទាំងឡាយ ពួកសមណៈ ឬព្រាហ្មណ៍ទាំងនោះ តថាគតសន្មតថាជាសមណៈក្នុងពួកសមណៈ សន្មតថាជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ ដ្បិតថាអ្នកដ៏មានអាយុទាំងនោះ ធ្វើឲ្យជាក់ច្បាស់នូវប្រយោជន៍ជារបស់សមណៈផង នូវប្រយោជន៍ជារបស់ព្រាហ្មណ៍ផង ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ ។

## អដ្ឋកថា

## សមណសូត្រ

[ ១០៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសមណសូត្រទី ៤ ដូចតទៅនេះ បទថា **សាមញ្ញត្ថំ** បានដល់ អរិយផលទាំង ៤ យ៉ាង ។ បទក្រៅអំពីនេះ ជាវេវចនៈនៃបទថា **សាមញ្ញត្ថំ** ទាំងអស់ ។ មួយយ៉ាងទៀត ឈ្មោះថា មគ្គ ៤

ព្រោះអត្ថថាជាសមណៈ ឈ្មោះថា ផល ៤ ព្រោះអត្ថថាជាព្រហ្ម ។ ក្នុងព្រះសូត្រទាំង ៤ នេះ ព្រះមានព្រះភាគត្រាស់ដល់ខន្ធលោកតែម្យ៉ាង ។

អដ្ឋកថាសមណសូត្រទី ៤ ចប់

# សុត្តន្តបិដក

## រោណសូត្រទី៥

[ ១០៩ ] ម្នាលភិក្ខុទាំងឡាយ ការច្រៀងទុកដូចជាការយំ ក្នុងអរិយវិន័យ ម្នាលភិក្ខុទាំងឡាយ ការរាំទុកដូចជាការឆ្កួត ក្នុងអរិយវិន័យ ម្នាលភិក្ខុទាំងឡាយ ការសើចក្អាកក្អាយ បញ្ចេញធ្មេញឲ្យកន្លងហួសវេលា ទុកដូចជាល្បែងក្មេង ក្នុងអរិយវិន័យ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរបំបាក់ស្ពាន ក្នុងការច្រៀង ចូរបំបាក់ស្ពានក្នុងការរាំចេញ កាលអ្នកទាំងឡាយ មានសេចក្តីរីករាយ ក្នុងហេតុ ( ណាមួយ ) គ្រាន់តែសម្តែងអាការញញឹមប៉ុណ្ណោះ ល្មមហើយ ។

# អដ្ឋកថា

## ភោណសូត្រ

[ ១០៩ ] សូត្រទី ៥ ខ្ញុំលើករឿងឡើងសម្តែងតាមអត្ថុប្បត្តិហេតុ ។ សួរថា រឿងកាំកើតឡើងដូចម្តេច ។ ឆ្លើយថា រឿងកើតឡើងក្នុងអនាចាររបស់ឆព្វគ្គិយទាំងឡាយ ។ បានឮថា ឆព្វគ្គិយទាំងនោះច្រៀង រាំ សើចគ្រាប់ទៅ ។ ភិក្ខុទាំងឡាយនាំគ្នាក្រាបទូលព្រះទសពល ព្រះបរមសាស្តាត្រាស់ហៅឆព្វគ្គិយទាំងនោះមក ហើយទ្រង់ប្រារព្ធសូត្រនេះ ដើម្បីពុទ្ធបំណាងប្រៀនប្រដៅភិក្ខុទាំងនោះ ។

បណ្តាបទទាំងនោះ បទថា **រុណ្ណំ** ប្រែថា ការយំ ។ បទថា **ឧម្មត្តកំ** បានដល់ កិរិយារបស់មនុស្សឆ្កួត ។ បទថា **កោមារិកំ** បានដល់ រឿងដែលក្មេងៗ ត្រូវធ្វើ ។ បទថា **ឧន្តាវិធំសកហាសិតំ** បានដល់ ការសើចព្រោះសំឡេងខ្លាំងរបស់បុគ្គលអ្នកបញ្ចេញធ្មេញ ហើយទះដៃ ។ បទថា **សេតុឃាតោ គីតេ** ព្រះមានព្រះភាគទ្រង់សម្តែងថា ការកាត់នូវបច្ច័យក្នុងការប្រគំរបស់អ្នកទាំងឡាយ ចូរស្ទះទុកសិន អ្នកទាំងឡាយ ចូរលះនូវការប្រគំ ព្រមទាំងហេតុ ។ សូម្បីក្នុងការរាំ ក៏មានន័យនេះដូចគ្នា ។

បទថា **អលំ** ប្រែថា គួរហើយ ។ ហេតុ ត្រាស់ហៅថា ធម៌ ក្នុងបទនេះថា **ធម្មប្បមោទិតានំ សតំ** កាលមនុស្សទាំងឡាយត្រេកអរ រីករាយដោយហេតុណាមួយ ។ បទថា **សិតំ សិតមត្តាយ** មានអធិប្បាយថា កាលមានហេតុដែលត្រូវសើច ការសើចដែលអ្នកធ្វើត្រឹមតែញញឹម គឺដើម្បី

សម្តែងត្រឹមតែអាការត្រេកអរឲ្យឃើញចុងធ្មេញប៉ុណ្ណោះ ក៏គប់គ្រាន់សម្រាប់អ្នកទាំងឡាយ ។ល។

អដ្ឋកថា រោណសូត្រទី ៥ ចប់

# សុត្តន្តបិដក

## អតិត្តសូត្រទី ៦

[ ១១០ ] ម្នាលភិក្ខុទាំងឡាយ ការសេពចំពោះធម៌ ៣ យ៉ាងមិនចេះឆ្អែតឆ្អន់ទេ ។ ៣ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ គឺសេពនូវការដេកលក់ មិនចេះឆ្អែត ១ ម្នាលភិក្ខុទាំងឡាយ ការសេពគ្រឿងផឹក គឺសុរា និងមេរ័យ មិនចេះឆ្អែត ១ ម្នាលភិក្ខុទាំងឡាយ ការសេពចំពោះការប្រកបដោយមេថុនធម្ម មិនចេះឆ្អែត ១ ។ ម្នាលភិក្ខុទាំងឡាយ ការសេពចំពោះធម៌ ៣ យ៉ាងនេះ មិនចេះឆ្អែតឡើយ ។

# អដ្ឋកថា

## អតិត្តសូត្រ

[ ១១០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអតិត្តសូត្រទី ៦ ដូចតទៅនេះ បទថា **សុប្បស្ស** បានដល់ ការដេកលក់ ។ បទថា **បដិសេវនាយ នត្ថិ តិត្តិ** សេចក្ដីថា ទោះសេពប៉ុនណា ក៏ពេញចិត្តត្រឹមប៉ុណ្ណោះ ព្រោះដូច្នោះ ទើបឈ្មោះថា ការឆ្អែតមិនមាន ។ ក្នុងបទទាំង ២ ដ៏សេស ក៏មានន័យដូចគ្នា ។ បើទឹកក្នុងមហាសមុទ្រក្លាយជាស្រា អ្នកលេងសុរា កើតជាត្រី កាលកំពុងហែលក្ដី ដេកក្ដី ក្នុងទឹកនោះ ឈ្មោះថា ការឆ្អែតក៏មិនគប្បីមាន ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់ដល់វដ្ដៈតែម្យ៉ាង ៕

**អដ្ឋកថា អតិត្តសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## បឋមកូដសូត្រទី ៧

[ ១១១ ] គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយក៏អង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលគហបតី កាលបើចិត្តដែលបុគ្គល

មិនបានរក្សាហើយ កាយកម្មក៏ឈ្មោះថា មិនបានរក្សាផង វចីកម្មក៏ឈ្មោះថា មិនបានរក្សាផង មនោកម្មក៏ឈ្មោះថា មិនបានរក្សាផងដែរ ។ កាលបុគ្គលនោះ មិនរក្សាកាយកម្ម មិនរក្សាវចីកម្ម មិនរក្សាមនោកម្ម កាយកម្មឈ្មោះថា ជោក វចីកម្ម ក៏ឈ្មោះថា ជោក មនោកម្មក៏ឈ្មោះថា ជោក ( ដោយរាគាទិក្កិលេស ) ។ កាលបុគ្គលនោះ មានកាយកម្មជោក មានវចីកម្មជោក មានមនោកម្មជោក ដោយរាគាទិក្កិលេសហើយ កាយកម្មក៏ឈ្មោះថា ស្អុយផង វចីកម្មក៏ឈ្មោះថា ស្អុយផង មនោកម្មក៏ឈ្មោះថា ស្អុយផងដែរ ។ កាលបុគ្គលនោះ មានកាយកម្មស្អុយ មានវចីកម្មស្អុយ មានមនោកម្មស្អុយហើយ មរណៈ ( បុគ្គលនោះ ) មិនល្អទេ កាលកិរិយាក៏មិនល្អទេ ។ ម្នាលគហបតី ដូចជាផ្ទះមានកំពូល ដែលបុគ្គលប្រក់មិនជិត កំពូលក៏រក្សាទុកមិនបាន បន្ទង់ក៏រក្សាទុកមិនបាន ជញ្ជាំងក៏រក្សាទុកមិនបាន កំពូលក៏ទទឹកជោក បន្ទង់ក៏ទទឹកជោក ជញ្ជាំងក៏ទទឹកជោក កំពូលក៏ពុក បន្ទង់ក៏ពុក ជញ្ជាំងក៏ពុក យ៉ាងណា ម្នាលគហបតី កាលបើចិត្តដែលបុគ្គលមិនរក្សាហើយ ។បេ។ មរណៈក៏មិនល្អទេ កាលកិរិយាក៏មិនល្អទេ យ៉ាងនោះដែរ ។ ម្នាលគហបតី កាលបើចិត្តដែលបុគ្គលរក្សាហើយ កាយកម្មក៏ឈ្មោះថា បានរក្សា វចីកម្មក៏ឈ្មោះថា បានរក្សា មនោកម្មក៏ឈ្មោះថា បានរក្សាដែរ កាលបុគ្គលនោះ រក្សាកាយកម្ម រក្សាវចីកម្ម រក្សាមនោកម្ម កាយកម្មក៏ឈ្មោះថា មិនជោក វចីកម្មក៏ឈ្មោះថា មិនជោក មនោកម្មក៏ឈ្មោះថា មិនជោក ដោយរាគាទិក្កិលេស ។ កាលបុគ្គលនោះ មានកាយកម្មមិនជោក មានវចីកម្មមិនជោក មានមនោកម្ម

មិនជោក ដោយរាគាទិក្កិលេសហើយ កាយកម្ម ( របស់បុគ្គលនោះ ) ក៏មិនស្អុយ វចីកម្មក៏មិនស្អុយ មនោកម្មក៏មិនស្អុយដែរ ។ កាលបុគ្គលនោះ មានកាយកម្មមិនស្អុយ មានវចីកម្មមិនស្អុយ មានមនោកម្មមិនស្អុយ មរណៈ ( របស់បុគ្គលនោះ ) ក៏ល្អ កាលកិរិយាក៏ល្អ ។ ម្នាលគហបតី ដូចជាផ្ទះមានកំពូល ដែលបុគ្គលប្រក់ជិតល្អហើយ កំពូលក៏រក្សាទុកបាន បង្កង់ក៏រក្សាទុកបាន ជញ្ជាំងក៏រក្សាទុកបាន កំពូលក៏មិនទទឹកជោក បង្កង់ក៏មិនទទឹកជោក ជញ្ជាំងក៏មិនទទឹកជោក កំពូលក៏មិនពុក បង្កង់ក៏មិនពុក ជញ្ជាំងក៏មិនពុក យ៉ាងណា ម្នាលគហបតី កាលបើចិត្តដែលបុគ្គលរក្សាហើយ ។បេ។ មរណៈក៏ល្អ កាលកិរិយាក៏ល្អ យ៉ាងនោះដែរ ។

# អដ្ឋកថា

## បឋមកូដសូត្រ

[ ១១១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមកូដសូត្រទី ៧ ដូចតទៅនេះ បទថា **អវស្សុតំ ហោតិ** ប្រែថា រមែងសើម ។ បទថា **ន ភទ្ទកំ មរណំ ហោតិ** សេចក្តីថា ការស្លាប់ក្តី អ្នកក៏មិនបាន ព្រោះកម្មទាំង ៣ ជាបច្ច័យនៃបដិសន្ធិក្នុងអបាយ ។ បទថា **កាលកិរិយា** ជាវេវចនៈនៃបទថា **មរណំ** នោះឯង ។ គប្បីជ្រាបវិនិច្ឆ័យក្នុងធម៌ជាចំណែកសុក្កបក្ខដូចតទៅនេះ ការ

ស្តាប់ល្អ ដែលអ្នកបានហើយ ព្រោះកម្មទាំង ៣ ជាបច្ច័យនៃបដិសន្ធិក្នុងសុគតិ តែការស្តាប់នោះ ប្រើបានសម្រាប់ព្រះអរិយសាវកទាំង ៣ ពួក មានព្រះសោតាបន្នជាដើម ដោយចំណែកមួយប៉ុណ្ណោះ ។ បទដ៏សេស ក្នុងព្រះសូត្រនេះ ងាយយល់អស់ហើយ ។៚

**អដ្ឋកថាបឋមកូដសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ទុតិយកូដសូត្រទី ៨

[ ១១២ ] គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយក៏អង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលគហបតី កាលបើចិត្តព្យាបាទហើយ កាយកម្មក៏ព្យាបាទតាមដែរ វចីកម្មក៏ព្យាបាទតាមដែរ មនោកម្មក៏ព្យាបាទតាមដែរ ។ កាលបុគ្គលនោះ មានកាយកម្មប្រកបដោយព្យាបាទ មានវចីកម្មប្រកបដោយព្យាបាទ មានមនោកម្មប្រកបដោយព្យាបាទហើយ មរណៈ ( របស់បុគ្គលនោះ ) ក៏មិនល្អទេ កាលកិរិយាក៏មិនល្អទេ ។ ម្នាលគហបតី ដូចជាផ្ទះមានកំពូល ដែលបុគ្គលប្រក់មិនជិត កំពូលក៏ខូចផង បង្កង់ក៏ខូចផង ជញ្ជាំងក៏ខូចផង ម្នាលគហបតី កាលបើចិត្តព្យាបាទហើយ ។បេ។ មរណៈក៏

មិនល្អ កាលកិរិយាក៏មិនល្អ ដូច្នោះដែរ ។ ម្នាលគហបតី កាលបើចិត្តមិនព្យាបាទហើយ កាយកម្មក៏មិនព្យាបាទតាម វចីកម្មក៏មិនព្យាបាទតាម មនោ-កម្មក៏មិនព្យាបាទតាម ។ កាលបុគ្គលនោះ មានកាយកម្មមិនប្រកបដោយព្យាបាទ មានវចីកម្មមិនប្រកបដោយព្យាបាទ មានមនោកម្មមិនប្រកបដោយព្យាបាទហើយ មរណៈក៏ល្អ កាលកិរិយាក៏ល្អ ។ ម្នាលគហបតី ដូចជាផ្ទះមានកំពូល ដែលបុគ្គលប្រក់ជិត កំពូលក៏មិនខូចផង បន្ទង់ក៏មិនខូចផង ជញ្ជាំងក៏មិនខូចផង ម្នាលគហបតី កាលបើចិត្តមិនព្យាបាទហើយ ។បេ។ មរណៈក៏ល្អ កាលកិរិយាក៏ល្អ ដូច្នោះដែរ ។

# អដ្ឋកថា

## ទុតិយកូដសូត្រ

[ ១១២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយកូដសូត្រទី ៨ ដូចតទៅនេះ បទថា **ព្យាបន្នំ** បានដល់ ចិត្តដែលលះប្រក្រតីភាព ហើយតាំងនៅ ។ បទដ៏សេស មានន័យដូចពោលហើយ ក្នុងសូត្រមុននោះឯង ។៙

**អដ្ឋកថា ទុតិយកូដសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## បឋមនិទានសូត្រទី ៩

[ ១១៣ ] ម្នាលភិក្ខុទាំងឡាយ ហេតុនេះមាន ៣ យ៉ាង នៃការកើតឡើងនៃកម្ម ។ ហេតុ ៣ យ៉ាង ដូចម្ដេចខ្លះ ។ គឺលោភៈជាហេតុនៃការកើតឡើងនៃកម្ម ១ ទោសៈជាហេតុនៃការកើតឡើងនៃកម្ម ១ មោហៈជាហេតុនៃការកើតឡើងនៃកម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ កម្មណាសម្រេចមកអំពីលោភៈ កើតមកអំពីលោភៈ មានលោភៈជាហេតុ មានលោភៈជាដែនកើត កម្មនោះជាអកុសល កម្មនោះប្រកបដោយទោស កម្មនោះមានទុក្ខជាវិបាក កម្មនោះប្រព្រឹត្តទៅ ដើម្បីកើតឡើងនៃកម្ម កម្មនោះមិនប្រព្រឹត្តទៅ ដើម្បីរលត់ទៅនៃកម្ម ។ ម្នាលភិក្ខុទាំងឡាយ កម្មណាសម្រេចមកអំពីទោសៈ កើតមកអំពីទោសៈ មានទោសៈជាហេតុ មានទោសៈជាដែនកើត កម្មនោះជាអកុសល កម្មនោះប្រកបដោយទោស កម្មនោះមានទុក្ខជាវិបាក កម្មនោះប្រព្រឹត្តទៅ ដើម្បីកើតឡើងនៃកម្ម កម្មនោះ មិនប្រព្រឹត្តទៅ ដើម្បីរលត់ទៅនៃកម្ម ។ ម្នាលភិក្ខុទាំងឡាយ កម្មណាសម្រេចមកអំពីមោហៈ កើតមកអំពីមោហៈ មានមោហៈជាហេតុ មានមោហៈជាដែនកើត កម្មនោះ ជាអកុសល កម្មនោះប្រកបដោយទោស កម្មនោះមានទុក្ខជាវិបាក កម្មនោះ ប្រព្រឹត្តទៅ ដើម្បីកើតឡើងនៃកម្ម កម្មនោះ មិនប្រព្រឹត្តទៅ ដើម្បីរលត់ទៅនៃកម្ម ។ ម្នាលភិក្ខុទាំងឡាយ ហេតុ ៣ យ៉ាងនេះឯង ដើម្បីកើតឡើងនៃកម្ម ។ ម្នាលភិក្ខុទាំងឡាយ ហេតុ ៣ យ៉ាងនេះ ដើម្បីកើតឡើងនៃកម្ម ។ ហេតុ ៣ យ៉ាងដូចម្ដេចខ្លះ ។ គឺ

អលោភៈជាហេតុនៃការកើតឡើងនៃកម្ម ១ អទោសៈជាហេតុនៃការកើតឡើងនៃកម្ម ១ អមោហៈជាហេតុនៃការកើតឡើងនៃកម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ កម្មណាសម្រេចមកអំពីអលោភៈ កើតមកអំពីអលោភៈ មានអលោភៈជាហេតុ មានអលោភៈជាដែនកើត កម្មនោះជាកុសល កម្មនោះឥតទោស កម្មនោះមានសុខជាវិបាក កម្មនោះប្រព្រឹត្តទៅ ដើម្បីរលត់ទៅនៃកម្ម កម្មនោះមិនប្រព្រឹត្តទៅ ដើម្បីកើតឡើងនៃកម្ម ។ ម្នាលភិក្ខុទាំងឡាយ កម្មណាសម្រេចមកអំពីអទោសៈ កើតមកអំពីអទោសៈ មានអទោសៈជាហេតុ មានអទោសៈជាដែនកើត កម្មនោះជាកុសល កម្មនោះឥតទោស កម្មនោះមានសុខជាវិបាក កម្មនោះ ប្រព្រឹត្តទៅ ដើម្បីរលត់ទៅនៃកម្ម កម្មនោះមិនប្រព្រឹត្តទៅ ដើម្បីកើតឡើងនៃកម្ម ។ ម្នាលភិក្ខុទាំងឡាយ កម្មណាសម្រេចមកអំពីអមោហៈ កើតមកអំពីអមោហៈ មានអមោហៈជាហេតុ មានអមោហៈជាដែនកើត កម្មនោះជាកុសល កម្មនោះឥតទោស កម្មនោះមានសុខជាវិបាក កម្មនោះប្រព្រឹត្តទៅ ដើម្បីរលត់ទៅនៃកម្ម កម្មនោះមិនប្រព្រឹត្តទៅ ដើម្បីកើតឡើងនៃកម្ម ។ ម្នាលភិក្ខុទាំងឡាយ ហេតុ ៣ យ៉ាងនេះឯង ដើម្បីកើតឡើងនៃកម្ម ។

# អដ្ឋកថា

## បឋមនិទានសូត្រ

[ ១១៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមនិទានសូត្រទី ៩ ដូចតទៅនេះ បទថា **និទានានិ** បានដល់ ហេតុទាំងឡាយ ។ បទថា **កម្មានំ សមុទយាយ** សេចក្ដីថា ដើម្បីជាប្រយោជន៍ដល់ការធ្វើការប្រមូលមកនូវកម្ម ដែលជាវដ្ដគាមី ។ បទថា **លោភប្បកតំ** សេចក្ដីថា ធ្វើដោយការលោភ ។ បទថា **សាវជ្ជំ** ប្រែថា មានទោស ។ បទថា **តំ កម្មំ កម្មសមុទយាយ សំវត្តតិ** សេចក្ដីថា កម្មនោះ រមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ដល់ការធ្វើ ការប្រមូលមកនូវកម្មសមុទយៈ គឺហេតុឲ្យកើតកម្មដទៃដែលជាហេតុវដ្ដគាមី ។ បទថា **ន តំ កម្មំ កម្មនិរោធាយ** សេចក្ដីថា តែកម្មនោះមិនប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ដល់ការរម្ងត់វដ្ដគាមិកម្ម ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុងកម្មចំណែកសដូចតទៅនេះ បទថា **កម្មានំ សមុទាយាយ** សេចក្ដីថា ដើម្បីជាប្រយោជន៍ដល់ការកើតឡើងនៃវដ្ដគាមិកម្ម ។ បទទាំងពួង គប្បីជ្រាបដោយន័យនេះ ៕

**អដ្ឋកថា បឋមនិទានសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ទុតិយនិទានសូត្រទី ១០

[ ១១៤ ] ម្នាលភិក្ខុទាំងឡាយ ហេតុ ៣ យ៉ាងនេះ ដើម្បីកើតឡើងនៃកម្ម ។ ៣ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីគាប់ចិត្តកើតឡើង ព្រោះប្រារព្ធនូវធម៌ជាទីតាំងនៃឆន្ទរាគជាអតីត ១ ម្នាលភិក្ខុទាំងឡាយ សេចក្តីគាប់ចិត្តកើតឡើង ព្រោះប្រារព្ធនូវធម៌ ជាទីតាំងនៃឆន្ទរាគជាអនាគត ១ ម្នាលភិក្ខុទាំងឡាយ សេចក្តីគាប់ចិត្តកើតឡើង ព្រោះប្រារព្ធនូវធម៌ ជាទីតាំងនៃឆន្ទរាគជាបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីគាប់ចិត្តកើតឡើងព្រោះប្រារព្ធនូវធម៌ជាទីតាំងនៃឆន្ទរាគ ជាអតីត ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានចិត្តត្រិះរិះរឿយៗ ពិចារណារឿយៗ ព្រោះប្រារព្ធនូវធម៌ជាទីតាំងនៃឆន្ទរាគជាអតីត ។ កាលបុគ្គលនោះ មានចិត្តត្រិះរិះរឿយៗ ពិចារណារឿយៗ ប្រារព្ធនូវធម៌ជាទីតាំងនៃឆន្ទរាគ ជាអតីត សេចក្តីគាប់ចិត្តក៏កើតឡើង បុគ្គលនោះ លុះមានសេចក្តីគាប់ចិត្តកើតឡើងហើយ តែងប្រកបដោយធម៌ទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវចិត្តដែលប្រកបដោយរាគៈថា ជាសញ្ញោជនៈ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា សេចក្តីគាប់ចិត្តកើតឡើង ព្រោះប្រារព្ធនូវធម៌ជាទីតាំងនៃឆន្ទរាគជាអតីត ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីគាប់ចិត្តកើតឡើង ព្រោះប្រារព្ធនូវធម៌ជាទីតាំងនៃឆន្ទរាគជាអនាគត ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានចិត្តត្រិះរិះរឿយៗ ពិចារណារឿយៗ ព្រោះប្រារព្ធនូវធម៌ ជាទីតាំងនៃ

ធន្ធរាគ ជាអនាគត ។ កាលបុគ្គលនោះ មានចិត្តត្រិះរិះរឿយៗ ពិចារណារឿយៗ ព្រោះប្រារព្ធនូវធម៌ជាទីតាំងនៃធន្ធរាគជាអនាគត សេចក្តីគាប់ចិត្តក៏កើតឡើង បុគ្គលនោះលុះមានសេចក្តីគាប់ចិត្តកើតឡើងហើយ តែងប្រកបដោយធម៌ទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវចិត្តដែលប្រកបដោយរាគៈថាជាសញ្ញោជនៈ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះ ឈ្មោះថា សេចក្តីគាប់ចិត្តកើតឡើង ព្រោះប្រារព្ធនូវធម៌ ជាទីតាំងនៃធន្ធរាគ ជាអនាគត ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីគាប់ចិត្តកើតឡើង ព្រោះប្រារព្ធនូវធម៌ជាទីតាំងនៃធន្ធរាគ ជាបច្ចុប្បន្ន ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលមានចិត្តត្រិះរិះរឿយៗ ពិចារណារឿយៗ ព្រោះប្រារព្ធនូវធម៌ ជាទីតាំងនៃធន្ធរាគ ជាបច្ចុប្បន្ន ។ កាលបុគ្គលនោះ មានចិត្តត្រិះរិះរឿយៗ ពិចារណារឿយៗ ព្រោះប្រារព្ធនូវធម៌ ជាទីតាំងនៃធន្ធរាគ ជាបច្ចុប្បន្ន សេចក្តីគាប់ចិត្តក៏កើតឡើង បុគ្គលនោះ លុះមានសេចក្តីគាប់ចិត្តកើតឡើងហើយ តែងប្រកបដោយធម៌ទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវចិត្តដែលប្រកបដោយរាគៈថា ជាសញ្ញោជនៈ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះ ឈ្មោះថា សេចក្តីគាប់ចិត្តកើតឡើង ព្រោះប្រារព្ធនូវធម៌ ជាទីតាំងនៃធន្ធរាគ ជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ ទាំងនេះជាហេតុ ៣ យ៉ាង នៃការកើតឡើងនៃកម្ម ។ ម្នាលភិក្ខុទាំងឡាយ ហេតុ ៣ យ៉ាងនេះ ដើម្បីកើតឡើងនៃកម្ម ។ ៣ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីគាប់ចិត្តមិនកើតឡើង ព្រោះប្រារព្ធធម៌ជាទីតាំងនៃធន្ធរាគជាអតីត ១ ម្នាល

ភិក្ខុទាំងឡាយ សេចក្តីគាប់ចិត្តមិនកើតឡើង ព្រោះប្រារព្ធធម៌ ជាទីតាំងនៃឆន្ទរាគជាអនាគត ១ ម្នាលភិក្ខុទាំងឡាយ សេចក្តីគាប់ចិត្តមិនកើតឡើង ព្រោះប្រារព្ធធម៌ ជាទីតាំងនៃឆន្ទរាគជាបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីគាប់ចិត្តមិនកើតឡើង ព្រោះប្រារព្ធធម៌ ជាទីតាំងនៃឆន្ទរាគជាអតីត ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដឹងច្បាស់នូវវិបាក នៃធម៌ទាំងឡាយ ជាទីតាំងនៃឆន្ទរាគជាអតីតតទៅ លុះដឹងនូវវិបាកតទៅហើយ ក៏លះបង់វិបាកនោះ លុះលះបង់វិបាកនោះហើយ ទើបមានចិត្តនឿយណាយ ហើយចាក់ធ្លុះឃើញច្បាស់ដោយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា សេចក្តីគាប់ចិត្តមិនកើតឡើង ព្រោះប្រារព្ធធម៌ ជាទីតាំងនៃឆន្ទរាគជាអតីត ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីគាប់ចិត្តមិនកើតឡើង ព្រោះប្រារព្ធធម៌ ជាទីតាំងនៃឆន្ទរាគជាអនាគត ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដឹងច្បាស់នូវវិបាកនៃធម៌ទាំងឡាយ ជាទីតាំងនៃឆន្ទរាគជាអនាគតតទៅ លុះដឹងច្បាស់នូវវិបាកតទៅហើយ ក៏លះបង់នូវវិបាកនោះ លុះលះបង់វិបាកនោះហើយ ទើបមានចិត្តនឿយណាយ ហើយចាក់ធ្លុះឃើញច្បាស់ដោយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា សេចក្តីគាប់ចិត្តមិនកើតឡើង ព្រោះប្រារព្ធធម៌ ជាទីតាំងនៃឆន្ទរាគជាអនាគត ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីគាប់ចិត្តមិនកើតឡើង ព្រោះប្រារព្ធធម៌ជាទីតាំងនៃឆន្ទរាគជាបច្ចុប្បន្ន ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដឹងច្បាស់ នូវវិបាកនៃធម៌ទាំងឡាយ ជាទីតាំងនៃឆន្ទរាគជាបច្ចុប្បន្នតទៅ លុះដឹងច្បាស់នូវវិបាកតទៅហើយ ក៏លះបង់នូវវិបាក

នោះ លុះលះបង់វិបាកនោះហើយ ទើបមានចិត្តនឿយណាយ ហើយចាក់ធ្លុះឃើញច្បាស់ដោយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា សេចក្តីគាប់ចិត្តមិនកើតឡើង ព្រោះប្រារព្ធធម៌ ជាទីតាំងនៃឆន្ទរាគជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ ហេតុទាំង ៣ យ៉ាងនេះឯង ដើម្បីកើតឡើងនៃកម្ម ។

សម្មោធិវគ្គទី ១ ចប់

## ឧទ្ទាននៃសម្មោធិវគ្គនោះគឺ

និយាយអំពីកាលមុនត្រាស់ដឹង ១ អំពីអានិសង្សជាដើម
ក្នុងមនុស្ស ១ អំពីសមណព្រាហ្មណ៍ ១ អំពីសេចក្តី
យំស្រែកមួយទៀត ជាគម្រប់ប្រាំ ១ អំពីការសេពមិន
ចេះឆ្អែត ១ អំពីផ្ទះមានកំពូលមានពីរលើក ១ អំពី
ហេតុដទៃទៀត មានពីរលើក ១ ។

# អដ្ឋកថា

## ទុតិយនិទានសូត្រ

[ ១១៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយនិទានសូត្រទី ១០ ដូចតទៅនេះ បទថា **កម្មានំ** បានដល់ កម្មដែលជាវដ្តគាមីនោះឯង ។ បទថា **ឆន្ទរាគដ្ឋានិយេ** សេចក្តីថា ជាហេតុនៃឆន្ទរាគៈ ។ បទថា **អារព្ភ** បានដល់

អាស្រ័យ គឺសំដៅយកចំពោះ ។ បទថា **ធង្ក្ខោ** បានដល់ ការពេញចិត្ត ដោយអំណាចនៃតណ្ហា ។ បទថា **យោ ចេតសោ សារាគោ** សេចក្តីថា តម្រេក គឺសេចក្តីត្រេកអរនៃចិត្ត ភាពដែលចិត្តត្រេកអរហើយ យ៉ាងណា ការត្រេកអរនៃចិត្តនេះ តថាគតពោលថា ជាសំយោជនៈ គឺជាគ្រឿងចង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងធម៌ចំណែកសដូចតទៅនេះ បទថា **កម្មានំ** បាន ដល់ កម្មដែលជាវិវដ្តគាមី ។ បទថា **តទភិនិវដ្ដេតិ** សេចក្តីថា ឲ្យធម៌ដែល ជាទីតាំងនៃរាគៈជាដើម និងវិបាករបស់ធម៌នោះវិលត្រឡប់ចំពោះ គឺកាល ណាបុគ្គលនោះដឹង គឺយល់ក្នុងវិបាកដោយជាទីតាំងនៃធន្ទរាគៈជាដើម កាល នោះ បុគ្គលនោះ នឹងញុំាងធម៌នោះផង ដោយវិបាកនោះផង ឲ្យវិលត្រឡប់ ចំពោះ ។ម្យ៉ាងទៀត ដោយបទនេះ ទ្រង់ត្រាស់វិបស្សនាហើយ ដោយ បទថា **តទភិនិវដ្ដេត្វា** នេះ ត្រាស់មគ្គ ។ តែដោយបទថា **ចេតសា អភិ-វិរាជេត្វា** នេះ ត្រាស់មគ្គតែម្យ៉ាង ។ បទថា **បញ្ញាយ អតិវិជ្ឈ បស្សតិ** សេចក្តីថា ឃើញធ្លុះទូលំទូលាយ ដោយមគ្គប្បញ្ញាយ មួយអន្លើដោយ វិបស្សនា ។ ក្នុងបទទាំងអស់គប្បីជ្រាបយ៉ាងនេះ ក្នុងព្រះសូត្រនេះ ត្រាស់ វដ្តៈផង វិវដ្តៈផង ដូច្នេះឯង ។៚

**អដ្ឋកថា ទុតិយនិទានសូត្រទី ១០ ចប់**

**សម្ពោធិវគ្គទី ១ ចប់**

# សុត្តន្តបិដក

# អាចាយិកវគ្គទី ២

## អាចាយិកសូត្រទី ១

[ ១១៥ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ តែងទៅកាន់អបាយ ទៅកាន់នរក ព្រោះមិនលះបង់អំពើអាក្រក់នេះ ។ បុគ្គល ៣ ពួក ដូចម្តេចខ្លះ ។ គឺបុគ្គលណា មិនមែនជាព្រហ្មចារ្យ តែប្តេជ្ញាថាខ្លួនជាព្រហ្មចារ្យ ១ បុគ្គលណាចោទបុគ្គលជាព្រហ្មចារ្យ បរិសុទ្ធ ជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ដោយអព្រហ្មចរិយធម៌មិនមានមូល ១ បុគ្គលណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ទោសក្នុងកាមទាំងឡាយមិនមាន បុគ្គលនោះ ក៏ដល់នូវសេចក្តីស្រេកឃ្លានក្នុងកាមទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៣ ពួកនេះ តែងទៅកាន់អបាយ ទៅកាន់នរក ព្រោះមិនលះបង់អំពើអាក្រក់នេះ ។

# អដ្ឋកថា

# អាបាយិកវគ្គទី ២

## អាបាយិកសូត្រ

[ ១១៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអាបាយិកសូត្រទី ១ នៃអាបាយិកវគ្គ ដូចតទៅនេះ សត្វទាំងឡាយ ឈ្មោះថា **អាបាយិកា** ព្រោះទៅកាន់អបាយ ។ សត្វទាំងឡាយ ឈ្មោះថា **នេរយិកា** ព្រោះទៅកាន់នរក ។ បទថា **អព្រហ្មចារី** នេះ សេចក្តីថា មិនលះកម្មអាក្រក់ទាំង ៣ មានការប្តេជ្ញាខ្លួនថា ជាព្រហ្មចារីជាដើម ។ បទថា **ព្រហ្មចារិប្បដិញ្ញោ** បានដល់ ដែលប្រព្រឹត្តព្រហ្មចរិយៈក្លែងក្លាយ ម្យ៉ាងទៀត បានដល់បុគ្គលដែលប្តេជ្ញាយ៉ាងនេះថា ខ្ញុំក៏ជាព្រហ្មចារី ដោយមិនលះអាកប្បកិរិយារបស់ពួកគេ ។ បទថា **អនុទ្ធំសេតិ** សេចក្តីថា ជេរ គឺបរិភាស បានដល់ តិះដៀល ។ បទថា **នត្ថិ កាមេសុ ទោសោ** សេចក្តីថា បុគ្គលសេពកិលេសកាម និងវត្ថុកាមមិនមានទោស ។ បទថា **ចាតព្យតំ** សេចក្តីថា ភាពជាអ្នកត្រូវផឹក គឺភាពជាអ្នកត្រូវបរិភោគ បានដល់ ភាពជាអ្នកត្រូវផឹកស៊ី ដូចការផឹកទឹករបស់បុគ្គលអ្នកស្រេកទឹក ដោយចិត្តប្រាសចាកសេចក្តីរង្កៀស ។ ក្នុងព្រះសូត្រនេះ ត្រាស់វដ្តទុក្ខតែម្យ៉ាង ៚

**អដ្ឋកថា អាបាយិកសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ទុល្លភសូត្រទី ២

[ ១១៦ ] ម្នាលភិក្ខុទាំងឡាយ សេចក្តីកើតប្រាកដនៃបុគ្គល ៣ ពួក រកបានដោយក្រក្នុងលោក ។ បុគ្គល ៣ ពួក ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំង-ឡាយ សេចក្តីកើតប្រាកដនៃព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ រកបានដោយក្រក្នុងលោក ១ បុគ្គលអ្នកសំដែងធម្មវិន័យ ដែលព្រះតថាគតសំដែងហើយ រកបានដោយក្រក្នុងលោក ១ បុគ្គលជាកតញ្ញូកតវេទី រកបានដោយក្រក្នុងលោក ១ ។ ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃបុគ្គល ៣ ពួកនេះ រកបានដោយក្រក្នុងលោក ។

# អដ្ឋកថា

## ទុល្លភសូត្រ

[ ១១៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុល្លភសូត្រទី ២ ដូចតទៅនេះ បទថា **កតញ្ញូ កតវេទី** បានដល់ បុគ្គលដឹងកម្មដែលអ្នកធ្វើដល់ខ្លួនថា បុគ្គលនេះធ្វើគុណនេះដល់អញ ដូច្នេះហើយ ធ្វើការតបស្នងឲ្យអ្នកដទៃដឹង គឺឲ្យប្រាកដ ។

**អដ្ឋកថា ទុល្លភសូត្រទី ២ ចប់**

# សុត្តន្តបិដក

## អប្បមេយ្យសូត្រទី ៣

[ ១១៧ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ រមែងមានទៅក្នុងលោក ។ បុគ្គល ៣ ពួក ដូចម្តេចខ្លះ ។ គឺសុប្បមេយ្យបុគ្គល ( បុគ្គលដែលគេប្រមាណដោយងាយ ) ១ ទុប្បមេយ្យបុគ្គល ( បុគ្គលដែលគេប្រមាណដោយក្រ ) ១ អប្បមេយ្យបុគ្គល ( បុគ្គលដែលគេប្រមាណមិនបាន ) ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសុប្បមេយ្យបុគ្គល ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកលើកកម្ពស់ ឆ្មើងឆ្មៃ រពើតរពើង មាត់រឹង និយាយប៉ប៉ាច់ប៉ប៉ោច ភ្លេចស្មារតី មិនដឹងខ្លួន មានចិត្តមិននឹងធឹង មានចិត្តប្រែប្រួល មានឥន្ទ្រិយបើកចំហ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សុប្បមេយ្យបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ចុះទុប្បមេយ្យបុគ្គល ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកមិនលើកកម្ពស់ មិនឆ្មើងឆ្មៃ មិនរពើតរពើង មិនមានមាត់រឹង មិននិយាយប៉ប៉ាច់ប៉ប៉ោច តម្កល់ស្មារតី ដឹងខ្លួន មានចិត្តនឹងធឹង មានចិត្តមានអារម្មណ៍តែមួយ សង្រួមឥន្ទ្រិយល្អ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុប្បមេយ្យបុគ្គល ។ ម្នាលភិក្ខុទាំង-ឡាយ ចុះអប្បមេយ្យបុគ្គល ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គឺបានដល់ភិក្ខុជាអរហំខីណាស្រព ក្នុងធម្មវិន័យនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អប្បមេយ្យបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះឯង រមែងមានទៅក្នុងលោក ។

# អដ្ឋកថា

## អប្បមេយ្យសូត្រ

[ ១១៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអប្បមេយ្យសូត្រទី ៣ ដូចតទៅនេះ បុគ្គលឈ្មោះថា **សុប្បមេយ្យោ** ព្រោះប្រមាណបានដោយងាយ ។ ឈ្មោះថា **ទុប្បមេយ្យោ** ព្រោះប្រមាណបានដោយលំបាក ។ ឈ្មោះថា **អប្បមេយ្យោ** ព្រោះប្រមាណមិនបាន ។ បទថា **ឧន្នឡោ** បានដល់ បុគ្គលដែលដូចជាដើមបបុសដែលហុយឡើង អធិប្បាយថា លើកមានះដែលឥតសារៈឡើង ។ បទថា **ចបលោ** បានដល់ ប្រកបដោយការញាប់ញ័រ មានការតាក់តែងបាត្រជាដើម ។ បទថា **មុខរោ** បានដល់ បុគ្គលមាត់រឹង ។ បទថា **វិកិណ្ណវាចោ** បានដល់ ជាអ្នកមិនសង្រួមក្នុងពាក្យសម្ដី ។ បទថា **អសមាហិតោ** បានដល់ ដែលមិនមានចិត្តជាសមាធិ ។ បទថា **វិព្ភន្តចិត្តោ** បានដល់ មានចិត្តភ្ញាក់ផ្អើល ដូចមេគោ និងម្រឹគព្រៃដែលជាសត្វភ្ញាក់ផ្អើល ។ បទថា **បាកតិន្ទ្រិយោ** បានដល់ ដែលមានឥន្ទ្រិយបើកចំហ ។ បទដ៏សេសក្នុងសូត្រនេះ ងាយយល់ទាំងអស់ហើយ ដូច្នេះ ។

### អដ្ឋកថាអប្បមេយ្យសូត្រទី ៣ ចប់

# សុត្តន្តបិដក

## អានេញ្ជសូត្រទី ៤

[ ១១៨ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៣ ពួក ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ព្រោះកន្លងបង់នូវរូបសញ្ញា ដោយប្រការទាំងពួង ព្រោះរលត់នូវបដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយបរិកម្មថា អាកាសមិនមានទីបំផុត ដូច្នេះ ។ បុគ្គលនោះ ត្រេកអរនឹងឈាននោះ ប្រាថ្នានូវឈាននោះ ដល់នូវសេចក្តីត្រេកអរនឹងឈាននោះ ស្ថិតនៅក្នុងឈាននោះ សម្រាកក្នុងឈាននោះ សម្រេចសម្រាន្ត នៅដោយច្រើន ក្នុងឈាននោះ មិនសាបសូន្យ ( ចាកឈាននោះ ) កាលធ្វើមរណកាល ក៏ទៅកើតជាមួយនឹងពួកទេវតា ដែលកើតក្នុងជាន់អាកាសានញ្ចាយតនៈ ។ ម្នាលភិក្ខុទាំងឡាយ ប្រមាណអាយុរបស់ពួកទេវតាដែលកើតក្នុងជាន់អាកាសានញ្ចាយតនៈ កំណត់ពីរហ្មឺនកប្ប ( ២០០០០ កប្ប ) ។ បុថុជ្ជនដែលឋិតនៅក្នុងភពនោះ ដរាបដល់អស់អាយុ គឺកំណត់អស់អាយុទាំងអស់ ដែលជាប្រមាណអាយុនៃទេវតាទាំងនោះ ហើយក៏ទៅកើតក្នុងនរកខ្លះ ទៅកើតក្នុងកំណើតតិរច្ឆានខ្លះ ទៅកើតក្នុងបិត្តិវិស័យខ្លះ ។ ចំណែកខាងសាវករបស់ព្រះដ៏មានព្រះភាគ ដែលឋិតនៅក្នុងភពនោះ ដរាបដល់អស់អាយុ គឺថា កំណត់អស់អាយុទាំងអស់ ដែលជាប្រមាណអាយុរបស់ពួកទេវតាទាំងនោះ ហើយក៏បរិនិព្វានក្នុងភពនោះឯង ។ ម្នាលភិក្ខុ

ទាំងឡាយ នេះជាសេចក្តីប្លែក នេះជាសេចក្តីអធិប្បាយ នេះជាអំពើផ្សេងៗ គ្នា នៃអរិយសាវកអ្នកចេះដឹង និងបុថុជ្ជនអ្នកមិនចេះដឹង កាលបើនៅមាន គតិភព និងឧបបត្តិភពនៅឡើយ ។ ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត បុគ្គលពួកមួយ ក្នុងលោកនេះ កន្លងបង់នូវអាកាសានញ្ចាយតនជ្ឈាន ដោយ ប្រការទាំងពួង ចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វិញ្ញាណ មិនមានទីបំផុតដូច្នេះ បុគ្គលនោះ ត្រេកអរនឹងឈាននោះ ប្រាថ្នានូវឈាន នោះ ដល់នូវសេចក្តីត្រេកអរដោយឈាននោះ ឋិតនៅក្នុងឈាននោះ សម្រាក នៅក្នុងឈាននោះ សម្រេចសម្រាន្តនៅដោយច្រើនក្នុងឈាននោះ មិនសាប សូន្យ ( ចាកឈាននោះ ) កាលធ្វើមរណកាលទៅ ក៏ទៅកើតជាមួយនឹង ទេវតា ដែលកើតក្នុងជាន់វិញ្ញាណញ្ចាយតនៈ ។ ម្នាលភិក្ខុទាំងឡាយ ប្រមាណ អាយុនៃពួកទេវតា ដែលកើតក្នុងជាន់វិញ្ញាណញ្ចាយតនៈ កំណត់បួនហ្មឺនកប្ប ( ៤០០០០ កប្ប ) ។ បុថុជ្ជនដែលឋិតនៅក្នុងភពនោះ ដរាបដល់អស់ អាយុ គឺថា កំណត់អស់អាយុទាំងអស់ ដែលជាប្រមាណអាយុនៃពួកទេវតា ទាំងនោះហើយ ទៅកើតក្នុងនរកខ្លះ ទៅកើតក្នុងកំណើតតិរច្ឆានខ្លះ ទៅកើត ក្នុងបិត្តិវិស័យខ្លះ ។ ចំណែកសាវករបស់ព្រះដ៏មានព្រះភាគ ឋិតនៅក្នុងភព នោះ ដរាបដល់អស់អាយុ គឺកំណត់អស់អាយុទាំងអស់ ដែលជាប្រមាណ អាយុនៃពួកទេវតាទាំងនោះ ហើយក៏បរិនិព្វានក្នុងភពនោះឯង ។ ម្នាលភិក្ខុ ទាំងឡាយ នេះជាសេចក្តីប្លែក នេះជាសេចក្តីអធិប្បាយ នេះជាអំពើផ្សេងៗ គ្នា នៃអរិយសាវកអ្នកចេះដឹង និងបុថុជ្ជនអ្នកមិនចេះដឹង កាលបើគតិភព

និងឧបបត្តិកពមាននៅឡើយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពួកមួយ ក្នុងលោកនេះ កន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈានដោយ ប្រការទាំងពួង ហើយចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយបរិកម្មថា អ្វីតិចតួចមិនមាន ដូច្នេះ ។ បុគ្គលនោះ ត្រេកអរនឹងឈាននោះ ប្រាថ្នាឈាននោះ ដល់នូវសេចក្តីត្រេកអរដោយឈាននោះ ឋិតនៅក្នុងឈាននោះ សម្រាកនៅក្នុងឈាននោះ សម្រេចសម្រាន្តនៅដោយច្រើនក្នុងឈាននោះ មិនសាបសូន្យ (ចាកឈាននោះ ) កាលធ្វើមរណកាលទៅ រមែងទៅកើតជាមួយនឹងពួកទេវតាដែលកើតក្នុងជាន់អាកិញ្ចញ្ញាយតនៈ ។ ម្នាលភិក្ខុទាំងឡាយ ប្រមាណអាយុនៃពួកទេវតា ដែលកើតក្នុងជាន់អាកិញ្ចញ្ញាយតនៈ កំណត់ប្រាំមួយហ្មឺនកប្ប ( ៦០០០០ កប្ប ) ។ បុថុជ្ជនឋិតនៅក្នុងភពនោះ ដរាបដល់អស់អាយុ គឺថា កំណត់អស់អាយុទាំងអស់ ដែលប្រមាណអាយុនៃពួកទេវតាទាំងនោះ ហើយក៏ទៅកើតក្នុងនរកខ្លះ ទៅកើតក្នុងកំណើតតិរច្ឆានខ្លះ ទៅកើតក្នុងបិត្តិវិស័យខ្លះ ។ ចំណែកខាងសាវករបស់ព្រះដ៏មានព្រះភាគវិញ ឋិតនៅក្នុងភពនោះ ដរាបដល់អស់អាយុ គឺថា កំណត់អស់អាយុទាំងអស់ ដែលជាប្រមាណអាយុនៃពួកទេវតាទាំងនោះ ហើយក៏បរិនិព្វានក្នុងភពនោះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាសេចក្តីប្លែក នេះជាសេចក្តីអធិប្បាយ នេះជាអំពើផ្សេងៗ នៃអរិយសាវកអ្នកចេះដឹង និងបុថុជ្ជនអ្នកមិនចេះដឹង កាលបើគតិភព និងឧបបត្តិកពមាននៅឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៣ ពួកនេះ រមែងមាននៅក្នុងលោក ។

# អដ្ឋកថា

## អានេញ្ជសូត្រ

[ ១១៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអានេញ្ជសូត្រទី ៤ ដូចតទៅនេះ បទថា **តទធិមុត្តោ** បានដល់ គាប់ចិត្តក្នុងឈានទោះ ។ បទថា **តំ និកាមេតិ** បានដល់ ប្រាថ្នាឈានទោះឯង ។ បទថា **តេន ច វិត្តឹ អាបជ្ជតិ** បានដល់ ដល់នូវការត្រេកអរដោយឈានទោះ ។ បទថា **តត្ថ ឋិតោ** បានដល់ តាំងនៅក្នុងឈានទោះ ។ បទថា **តទធិមុត្តោ** បានដល់ បង្អោនចិត្តទៅក្នុងឈានទោះឯង ។ បទថា **តព្វហុលវិហារី** បានដល់ នៅជាមួយឈានទោះ ដោយចំណែកច្រើន ។ បទថា **សហាព្យតំ ឧបបជ្ជតិ** បានដល់ ចូលដល់នូវភាពជាសម្លាញ់ អធិប្បាយថា រមែងកើតក្នុងទេវលោកនេះ ។ ពាក្យជាដើមថា **និរយម្បិ គច្ឆតិ** ព្រះមានព្រះភាគត្រាស់សំដៅដល់ការទៅនរកទោះ ដោយអំណាចនៃបរិយាយដទៃ ព្រោះមិនផុតអំពីនរកជាដើមទៅបាន ព្រោះថា បុគ្គលមិនមានអកុសលកម្ម ដែលមានកម្លាំងច្រើនជាឧបចារជ្ឈាន ដែលជាហេតុឲ្យកើតក្នុងអបាយជាប់តគ្នា ។ បទថា **ភគវតោ បន សាវកោ** បានដល់ សាវកអង្គណាមួយ បណ្តាសាវកដែលជាព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមីទាំងឡាយ ។ បទថា **តស្មឹយេវ ភវេ** បានដល់ ក្នុងអរូបភពទោះឯង ។ បទថា **បរិនិព្វាយតិ** សេចក្តីថា នឹងបរិនិព្វានដោយអប្បច្ចយបរិនិព្វាន ។ សេចក្តីព្យាយាមជាគ្រឿងប្រកបយ៉ាងក្រៃលែង ឈ្មោះថា **អធិប្បាយសោ** ពាក្យដ៏សេស ក្នុងព្រះសូត្រនេះ គប្បីជ្រាបតាម

ន័យដែលពោលមកហើយនោះឯង ។ម្យ៉ាងទៀត ក្នុងព្រះសូត្រនេះ ឈាន ដែលជាហេតុឲ្យកើតឡើង ព្រះមានព្រះភាគត្រាស់សម្រាប់បុថុជ្ជន សម្រាប់ព្រះអរិយសាវ័ក ត្រាស់ទាំងការដែលជាហេតុឲ្យកើតនោះឯង ទាំងឈាន ដែលជាបាទនៃវិបស្សនាផងដែរ ។៚

អដ្ឋកថា អានេញ្ជសូត្រទី ៤ ចប់

# សុត្តន្តបិដក

## អយសូត្រទី ៥

[ ១១៩ ] ម្នាលភិក្ខុទាំងឡាយ វិបត្តិទាំងឡាយនេះ មាន ៣ យ៉ាង ។ វិបត្តិ ៣ យ៉ាង ដូចម្តេចខ្លះ ។ គឺសីលវិបត្តិ ១ ចិត្តវិបត្តិ ១ ទិដ្ឋិវិបត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសីលវិបត្តិ ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាម ពោលពាក្យកុហក ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់ ពោលពាក្យឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សីលវិបត្តិ ។ ម្នាលភិក្ខុទាំងឡាយ ចុះចិត្តវិបត្តិ ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ច្រើនដោយអភិជ្ឈា មានចិត្តព្យាបាទ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ចិត្តវិបត្តិ ។ ម្នាលភិក្ខុទាំងឡាយ ចុះទិដ្ឋិវិបត្តិ ដូចម្តេច ។ ម្នាលភិក្ខុ

ទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាមិច្ឆាទិដ្ឋិ មានសេចក្តីយល់វិបរិតថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាធំមិនមានផល ការបូជាតូច មិនមានផល ផលវិបាកនៃកម្ម ដែលបុគ្គលធ្វើល្អ និងអាក្រក់មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន មាតាមិនមាន បិតាមិនមាន ពួកសត្វជាឱបបាតិកៈមិនមាន ពួកសមណព្រាហ្មណ៍ជាអ្នកព្រមព្រៀងគ្នាប្រតិបត្តិប្រពៃ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសក្នុងលោកក៏មិនមាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទិដ្ឋិវិបត្តិ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែសីលវិបត្តិ បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរកក៏មាន ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែចិត្តវិបត្តិ បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរកក៏មាន ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែទិដ្ឋិ-វិបត្តិ បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរកក៏មាន ។ ម្នាលភិក្ខុទាំងឡាយ វិបត្តិមាន ៣ យ៉ាងប៉ុណ្ណេះ ។ ម្នាលភិក្ខុទាំងឡាយ សម្បទានេះមាន ៣ យ៉ាង ។ សម្បទា ៣ យ៉ាង ដូចម្តេចខ្លះ ។ គឺសីលសម្បទា ១ ចិត្តសម្បទា ១ ទិដ្ឋិ-សម្បទា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសីលសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាក

បិសុណាវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ ។ ម្នាលភិក្ខុទាំង-ឡាយ នេះហៅថា សីលសម្បទា ។ ម្នាលភិក្ខុទាំងឡាយ ចុះចិត្តសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ មិនច្រើន ដោយអភិជ្ឈា មានចិត្តមិនព្យាបាទ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ចិត្ត-សម្បទា ។ ម្នាលភិក្ខុទាំងឡាយ ចុះទិដ្ឋិសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាសម្មាទិដ្ឋិ មានសេចក្តីយល់មិនវិបរិតថា ទានដែលបុគ្គលឲ្យហើយមានផល ការបូជាធំមានផល ការបូជាតូចមានផល ផលវិបាកនៃកម្មដែលសត្វធ្វើល្អ និងអាក្រក់មាន លោកនេះក៏មាន លោកខាងមុខក៏មាន មាតាមាន បិតាមាន ពួកសត្វជាឱបបាតិកៈមាន ពួកសមណព្រាហ្មណ៍ជាអ្នកព្រមព្រៀងគ្នា ប្រតិបត្តិប្រពៃ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងហើយប្រកាសក្នុងលោកក៏មាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទិដ្ឋិ-សម្បទា ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែសីលសម្បទា បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងលោក គឺសុគតិ និងស្ថានសួគ៌ក៏មាន ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែចិត្តសម្បទា បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងលោក គឺសុគតិ និងស្ថានសួគ៌ក៏មាន ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែទិដ្ឋិសម្បទា បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅកើតក្នុងលោក គឺសុគតិ និងស្ថានសួគ៌ក៏មាន ។ ម្នាលភិក្ខុទាំង-

ឡាយ សម្បទាមាន ៣ យ៉ាងប៉ុណ្ណេះ ។

# អដ្ឋកថា

## អយសូត្រ

[ ១១៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអយសូត្រទី ៥ ដូចតទៅនេះ បទថា **សីលវិបត្តិ** បានដល់ អាការដែលសីលវិបត្តិ ។ ក្នុងដំសេសក៏មានន័យនេះ ឯង ។ ដោយបទថា **នត្ថិ ទិន្នំ** ព្រះមានព្រះភាគ ត្រាស់សំដៅយកភាព ទានដែលឲ្យហើយ មិនមានផល ។ ការបូជាតូច ហៅថា **យិដ្ឋំ** ។ លោក-សក្ការៈដែលសម្បូរ ទ្រង់បំណងយកថាជា **ហុតំ** ។ មិច្ឆាទិដ្ឋិកបុគ្គល បដិសេធ **យិដ្ឋំ** និង **ហុតំ** ទាំង ២ នោះថា មិនមានផល ។ បទថា **សុកដទុក្កដានំ** បានដល់ កម្មដែលធ្វើល្អ និងធ្វើអាក្រក់ អធិប្បាយថា បាន ដល់ កុសលកម្ម និងអកុសលកម្ម ។ ដោយបទថា **ផលវិបាកោ** មិច្ឆា-ទិដ្ឋិកបុគ្គលពោលវត្ថុដែលហៅថា ផល ឬវិបាកថា មិនមាន ។

បទថា **នត្ថិ អយំ លោកោ** សេចក្តីថា លោកនេះមិនមានសម្រាប់ បុគ្គលដែលតាំងនៅក្នុងលោកខាងមុខ ។ បទថា **នត្ថិ បរោ លោកោ** សេចក្តី ថា លោកខាងមុខមិនមានសម្រាប់បុគ្គលដែលតាំងនៅក្នុងលោកនេះ ។ មិច្ឆា-ទិដ្ឋិកបុគ្គលសម្តែងថា សត្វទាំងអស់ស្លាប់ហើយ រមែងដាច់សូន្យក្នុងលោក

នោះៗ ឯង ។ ដោយបទថា **ឆត្ថិ មាតា ឆត្ថិ បិតា** មិច្ឆាទិដ្ឋិបុគ្គលពោល ដោយអំណាចបដិបត្តិប្រពៃ និងបដិបត្តិខុសក្នុងមាតាបិតាទាំងនោះថា មិនមានផល ។ បទថា **ឆត្ថិ សត្តា ឱបបាតិកា** សេចក្តីថា ឈ្មោះថា សត្វដែលចុតិហើយ កើតមិនមាន ភាពបរិបូណ៌ ឈ្មោះថា **សម្បទា** ភាពដែលសីលបរិបូណ៌មិនខ្វះខាត ឈ្មោះថា **សីលសម្បទា**ៗ ក្នុងបទទាំង ២ ដ៏សេសក៏មានន័យនេះដូចគ្នា ។ បទថា **អត្ថិ ទិន្នំ** ជាដើម អ្នកសិក្សាគប្បីកាន់យកដោយន័យដែលផ្ទុយគ្នា តាមដែលពោលមកហើយ ៕

**អដ្ឋកថា អយសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## អបណ្ណកសូត្រទី ៦

[ ១២០ ] ម្នាលភិក្ខុទាំងឡាយ វិបត្តិនេះមាន ៣ យ៉ាង ។ វិបត្តិ ៣ យ៉ាងដូចម្តេចខ្លះ ។ គឺសីលវិបត្តិ ១ ចិត្តវិបត្តិ ១ ទិដ្ឋិវិបត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសីលវិបត្តិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។បេ។ ពោលពាក្យឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សីលវិបត្តិ ។ ម្នាលភិក្ខុទាំងឡាយ ចុះចិត្តវិបត្តិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ច្រើនដោយ

អភិជ្ឈា មានចិត្តប្រកបដោយព្យាបាទ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ចិត្តវិបត្តិ ។ ម្នាលភិក្ខុទាំងឡាយ ចុះទិដ្ឋិវិបត្តិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាមិច្ឆាទិដ្ឋិ មានសេចក្តីយល់វិបរិតថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាធំ មិនមានផល ។បេ។ ពួកសមណព្រាហ្មណ៍ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសក្នុងលោកក៏មិនមាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទិដ្ឋិវិបត្តិ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែសីលវិបត្តិ បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ក៏មាន ព្រោះហេតុតែចិត្តវិបត្តិ ... ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែទិដ្ឋិវិបត្តិ បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចកូនបាសកា មានជ្រុង ៦ ដែលបុគ្គលបោះទៅលើ ( ធ្លាក់ចុះមក ) តាំងនៅដោយជ្រុងណាៗ រមែងឋិតនៅនឹង ( ដោយជ្រុងនោះៗ ) ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែសីលវិបត្តិ បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ក៏មាន ព្រោះហេតុតែចិត្តវិបត្តិក៏មាន ... ព្រោះហេតុតែទិដ្ឋិវិបត្តិ បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរកក៏មាន យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ វិបត្តិមាន ៣ យ៉ាងប៉ុណ្ណេះ ។ ម្នាលភិក្ខុទាំងឡាយ

សម្បទានេះ មាន ៣ យ៉ាង ។ សម្បទា ៣ យ៉ាង ដូចម្ដេចខ្លះ ។ គឺសីល-សម្បទា ១ ចិត្តសម្បទា ១ ទិដ្ឋិសម្បទា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសីលសម្បទា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ វៀរចាកបាណាតិបាត ។បេ។ វៀរចាកសម្ផប្បលាបៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សីលសម្បទា ។ ម្នាលភិក្ខុទាំងឡាយ ចុះចិត្ត-សម្បទា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ មិនច្រើនដោយអភិជ្ឈា មានចិត្តមិនព្យាបាទ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ចិត្តសម្បទា ។ ម្នាលភិក្ខុទាំងឡាយ ចុះទិដ្ឋិសម្បទា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាសម្មាទិដ្ឋិ មានសេចក្ដីយល់មិនវិបរិតថា ទានដែលបុគ្គលឲ្យ មានផល ការបូជាធំ មានផល ។បេ។ ពួកសមណព្រាហ្មណ៍ដែលធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយប្រកាសក្នុងលោកក៏មាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទិដ្ឋិសម្បទា ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែសីលសម្បទា បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងលោក គឺសុគតិ និងស្ថានសួគ៌ក៏មាន ព្រោះហេតុតែចិត្តសម្បទា ... ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែទិដ្ឋិសម្បទា បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងលោក គឺសុគតិ និងស្ថានសួគ៌ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចកូនបាសកាមានជ្រុង ៦ ដែលបុគ្គលបោះទៅលើ ( ធ្លាក់ចុះមក ) តាំងនៅដោយជ្រុង

*ណាៗ រមែងឋិតនៅនឹង ( ដោយជ្រុងនោះៗ ) ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែសីលសម្បទា បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងលោក គឺសុគតិ និងស្ថានសួគ៌ក៏មាន ព្រោះហេតុតែចិត្តសម្បទា ... ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែទិដ្ឋិសម្បទា បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងលោក គឺសុគតិ និងស្ថានសួគ៌ ក៏មាន ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ សម្បទាមាន ៣ យ៉ាងប៉ុណ្ណេះ ។*

# អដ្ឋកថា

## អបណ្ណកសូត្រ

*[ ១២០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអបណ្ណកសូត្រទី ៦ ដូចតទៅនេះ បទថា* **អបណ្ណកោ មណិ** *បានដល់ កូនបាសកាដែលប្រកបដោយជ្រុង ៦ ។ បទថា* **សុគតឹ សគ្គំ** *បានដល់ លោក គឺស្ថានសួគ៌ ក្នុងបណ្តាសួគ៌ ៦ ជាន់ មានជាន់ចាតុម្មហារាជជាដើមណាមួយ ។ ក្នុងព្រះសូត្រនេះ ត្រាស់ធម៌ទាំង ២ ប្រការ គឺសីល និងសម្មាទិដ្ឋិលាយឡំគ្នា ។*

**អដ្ឋកថា អបណ្ណកសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## កម្មន្តសូត្រទី ៧

[ ១២១ ] ម្នាលភិក្ខុទាំងឡាយ វិបត្តិនេះមាន ៣ យ៉ាង ។ វិបត្តិ ៣ យ៉ាង ដូចម្ដេចខ្លះ ។ គឺកម្មន្តវិបត្តិ ១ អាជីវវិបត្តិ ១ ទិដ្ឋិវិបត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មន្តវិបត្តិ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។បេ។ ជាអ្នកពោលពាក្យឥតប្រ-យោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មន្តវិបត្តិ ។ ម្នាលភិក្ខុទាំង-ឡាយ ចុះអាជីវវិបត្តិ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកចិញ្ចឹមជីវិតខុស សម្រេចការរស់នៅ ដោយការចិញ្ចឹមជីវិតខុស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាជីវវិបត្តិ ។ ម្នាលភិក្ខុទាំង-ឡាយ ចុះទិដ្ឋិវិបត្តិ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាមិច្ឆាទិដ្ឋិ មានសេចក្ដីយល់វិបរិតថា ទានដែលបុគ្គលឲ្យហើយមិនមានផល ការបូជាធំ មិនមានផល ។បេ។ ពួកសមណព្រាហ្មណ៍ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខដោយប្រាជ្ញាដ៏ឧត្ដម ដោយខ្លួនឯងហើយប្រកាសក្នុងលោក ក៏មិនមាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទិដ្ឋិ-វិបត្តិ ។ ម្នាលភិក្ខុទាំងឡាយ វិបត្តិមាន ៣ យ៉ាងប៉ុណ្ណេះ ។ ម្នាលភិក្ខុទាំងឡាយ សម្បទានេះ មាន ៣ យ៉ាង ។ សម្បទា ៣ យ៉ាង ដូចម្ដេចខ្លះ ។ គឺកម្មន្តសម្បទា ១ អាជីវសម្បទា ១ ទិដ្ឋិសម្បទា ១ ។ ម្នាលភិក្ខុទាំងឡាយ កម្មន្តសម្បទា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោក

នេះ ជាអ្នកវៀរចាកការសម្លាប់សត្វ ។បេ។ ជាអ្នកវៀរចាកការពោលពាក្យឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មន្តសម្បទា ។ ម្នាលភិក្ខុទាំងឡាយ ចុះអាជីវសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកចិញ្ចឹមជីវិតត្រូវ សម្រេចការរស់នៅ ដោយការចិញ្ចឹមជីវិតត្រូវ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាជីវសម្បទា ។ ម្នាលភិក្ខុទាំងឡាយ ចុះទិដ្ឋិសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាសម្មាទិដ្ឋិ មានសេចក្តីយល់មិនវិបរិតថា ទានដែលបុគ្គលឲ្យហើយ មានផល ការបូជាធំ មានផល ។បេ។ ពួកសមណព្រាហ្មណ៍ ដែលធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយប្រកាសក្នុងលោកនេះក៏មាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទិដ្ឋិសម្បទា ។ ម្នាលភិក្ខុទាំងឡាយ សម្បទាមាន ៣ យ៉ាងប៉ុណ្ណេះ ។

# អដ្ឋកថា

## កម្មន្តសូត្រ

ក្នុងកម្មន្តសូត្រទី ៧ មានអត្ថងាយយល់ហើយ ។៚

អដ្ឋកថាកម្មន្តសូត្រទី ៧ ចប់

# សុត្តន្តបិដក

## បឋមសោចេយ្យសូត្រទី ៨

[ ១២២ ] ម្នាលភិក្ខុទាំងឡាយ ការស្អាតនេះ មាន ៣ យ៉ាង ។ ការស្អាត ៣ យ៉ាង ដូចម្តេចខ្លះ ។ គឺស្អាតកាយ ១ ស្អាតវាចា ១ ស្អាតចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះការស្អាតកាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកវៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យគេ វៀរចាកការប្រព្រឹត្តខុសក្នុងកាម ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្អាតកាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះការស្អាតវាចា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ វៀរចាកការពោលពាក្យកុហក វៀរចាកការពោលពាក្យញុះញង់ វៀរចាកការពោលពាក្យអាក្រក់ វៀរចាកការពោលពាក្យឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្អាតវាចា ។ ម្នាលភិក្ខុទាំងឡាយ ចុះការស្អាតចិត្ត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកមិនច្រើនដោយអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មាទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្អាតចិត្ត ។ ម្នាលភិក្ខុទាំងឡាយ ការស្អាតមាន ៣ យ៉ាងប៉ុណ្ណោះ ។

# អដ្ឋកថា

## បឋមសោចេយ្យសូត្រ

[ ១២២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមសោចេយ្យសូត្រទី ៨ ដូចតទៅ

*នេះ ការស្អាត ឈ្មោះថា* **សោចេយ្យំ** ។ *ការស្អាតក្នុងកាយទ្វារ ឈ្មោះថា* **កាយសោចេយ្យំ** ។ *ក្នុងបទទាំង ២ ដ៏សេស ក៏មានន័យនេះឯង ។ ក្នុងសូត្រទាំងឡាយ ៤ នេះ តាមលំដាប់ ព្រះមានព្រះភាគត្រាស់បដិបទាសម្រាប់អ្នកគ្រប់គ្រងផ្ទះហើយ ។ សូម្បីព្រះអរិយបុគ្គលដែលជាសោតាបន្ននិងព្រះសកទាគាមីក៏ប្រើបាន ។*

**អដ្ឋកថា បឋមសោចេយ្យសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## ទុតិយសោចេយ្យសូត្រទី ៩

[ ១២៣ ] ម្នាលភិក្ខុទាំងឡាយ ការស្អាតនេះ មាន ៣ យ៉ាង ។ ការស្អាតមាន ៣ យ៉ាង ដូចម្តេចខ្លះ ។ គឺការស្អាតកាយ ១ ស្អាតវាចា ១ ស្អាតចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះការស្អាតកាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ វៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យគេ វៀរចាកកិរិយាប្រព្រឹត្តមិនប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្អាតកាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះការស្អាតវាចា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកវៀរចាកការពោលពាក្យកុហក វៀរចាកការពោលពាក្យញុះញង់ វៀរចាកការពោលពាក្យអាក្រក់ វៀរចាកការពោលពាក្យឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្អាតវាចា ។ ម្នាលភិក្ខុទាំងឡាយ ចុះការស្អាតចិត្ត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទោះកាមច្ឆន្ទៈមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា កាមច្ឆន្ទៈមាននៅក្នុងខ្លួនអាត្មាអញ ទោះកាមច្ឆន្ទៈមិនមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា កាមច្ឆន្ទៈមិនមាននៅក្នុងខ្លួនអាត្មាអញ ។ មួយទៀត កិរិយាកើតឡើងនៃកាមច្ឆន្ទៈ ដែលមិនទាន់កើតឡើងដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់នូវកាមច្ឆន្ទៈដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាមិនកើតតទៅទៀតនៃកាមច្ឆន្ទៈដែលលះបង់បានហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ទោះព្យាបាទមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា ព្យាបាទមាននៅក្នុងខ្លួនអាត្មាអញ

ទោះ ព្យាបាទមិនមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា ព្យាបាទមិនមាននៅក្នុងខ្លួនអាត្មាអញ ។ មួយទៀត កិរិយាកើតឡើងនៃព្យាបាទ ដែលមិនទាន់កើតឡើងដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់ព្យាបាទដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាមិនកើតតទៅទៀត នៃព្យាបាទដែលលះបង់ហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ទោះថីនមិទ្ធៈ មាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា ថីនមិទ្ធៈមាននៅក្នុងខ្លួនអាត្មាអញ ទោះថីនមិទ្ធៈមិនមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា ថីនមិទ្ធៈមិនមាននៅក្នុងខ្លួនអាត្មាអញ ។ មួយទៀត កិរិយាកើតឡើងនៃថីន-មិទ្ធៈ ដែលមិនទាន់កើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់នូវថីនមិទ្ធៈ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាមិនកើតតទៅទៀតនៃថីនមិទ្ធៈ ដែលលះបង់ហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ទោះឧទ្ធច្ចកុក្កុច្ចៈមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចៈមាននៅក្នុងខ្លួនអាត្មាអញ ទោះឧទ្ធច្ច-កុក្កុច្ចៈមិនមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចៈមិនមាននៅក្នុងខ្លួនអាត្មាអញ ។ មួយទៀត កិរិយាកើតឡើងនៃឧទ្ធច្ចកុក្កុច្ចៈ ដែលមិនទាន់កើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់នូវឧទ្ធច្ច-កុក្កុច្ចៈដែលកើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាមិនកើតតទៅទៀតនៃឧទ្ធច្ចកុក្កុច្ចៈ ដែលលះបង់ហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ។ ទោះវិចិកិច្ឆាមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា

វិចិកិច្ឆាមាននៅក្នុងខ្លួនអាត្មាអញ ទោះវិចិកិច្ឆាមិនមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា វិចិកិច្ឆាមិនមាននៅក្នុងខ្លួនអាត្មាអញ ។ មួយទៀត កិរិយាកើតឡើងនៃវិចិកិច្ឆាដែលមិនទាន់កើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់វិចិកិច្ឆាដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាមិនកើតតទៅទៀតនៃវិចិកិច្ឆា ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាមិនកើតតទៅទៀតនៃវិចិកិច្ឆាដែលលះបង់ហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្អាតចិត្ត ។ ម្នាលភិក្ខុទាំងឡាយ ការស្អាតមាន ៣ យ៉ាងប៉ុណ្ណេះ ។

> អ្នកប្រាជ្ញទាំងឡាយ ពោលចំពោះបុគ្គល អ្នកស្អាតកាយ ស្អាតវាចា ស្អាតចិត្ត មិនមានអាសវៈ ជាអ្នកស្អាត បរិបូណ៌ដោយការស្អាត ថាជាបុគ្គលមានបាបលាងជ្រះហើយ ។

# អដ្ឋកថា

## ទុតិយសោចេយ្យសូត្រ

[ ១២៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយសោចេយ្យសូត្រទី ៩ ដូចតទៅនេះ បទថា **អជ្ឈត្តំ** បានដល់ ដែលប្រព្រឹត្តទៅខាងក្នុងពិតប្រាកដ ។ នីវរណៈ គឺកាមច្ឆន្ទៈ ឈ្មោះថា **កាមច្ឆន្ទោ ។** ក្នុងនីវរណៈ មានព្យាបាទជាដើម ក៏មានន័យនេះដូចគ្នា ។ ពាក្យដ៏សេសក្នុងព្រះសូត្រនេះ មានន័យដូចពោលហើយខាងដើមនោះឯង ។ ឯក្នុងគាថា បទថា **កាយសុចិំ** បានដល់ ការស្អាតក្នុងកាយទ្វារ ឬការស្អាតផ្លូវកាយ ។ ក្នុងបទទាំង ២ ដ៏សេសក៏មានន័យដូចគ្នា ។ បទថា **និន្ហាតបាបកំ** សេចក្តីថា លាង គឺជម្រះបាបទាំងអស់ ហើយតាំងនៅ ។ ដោយសូត្រនេះផង ដោយគាថាផង ព្រះមានព្រះភាគត្រាស់ដល់ព្រះខីណាស្រពតែម្យ៉ាង ដូច្នេះឯង ៕

**អដ្ឋកថា ទុតិយសោចេយ្យសូត្រទី៩ ចប់**

# សុត្តន្តបិដក

## មោនេយ្យសូត្រទី ១០

[ ១២៤ ] ម្នាលភិក្ខុទាំងឡាយ ភាពជាអ្នកប្រាជ្ញនេះ មាន ៣ យ៉ាង ។ ៣ យ៉ាង គឺអ្វីខ្លះ ។ គឺភាពជាអ្នកប្រាជ្ញផ្លូវកាយ ១ ភាពជាអ្នកប្រាជ្ញផ្លូវវាចា ១ ភាពជាអ្នកប្រាជ្ញផ្លូវចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភាពជាអ្នកប្រាជ្ញផ្លូវកាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ វៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យគេ វៀរចាកការប្រព្រឹត្តមិនប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភាពជាអ្នកប្រាជ្ញផ្លូវកាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះភាពជាអ្នកប្រាជ្ញផ្លូវវាចា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ វៀរចាកការពោលពាក្យកុហក វៀរចាកការពោលពាក្យញុះញង់ វៀរចាកការពោលពាក្យអាក្រក់ វៀរចាកការពោលពាក្យឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភាពជាអ្នកប្រាជ្ញផ្លូវវាចា ។ ម្នាលភិក្ខុទាំងឡាយ ចុះភាពជាអ្នកប្រាជ្ញផ្លូវចិត្ត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ សម្រេចសម្រាន្តនៅ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភាពជាអ្នកប្រាជ្ញផ្លូវចិត្ត ។ ម្នាលភិក្ខុទាំងឡាយ ភាពជាអ្នកប្រាជ្ញមាន ៣ យ៉ាងប៉ុណ្ណេះ ។

អ្នកប្រាជ្ញទាំងឡាយ ពោលចំពោះបុគ្គល ដែលជាអ្នក
ប្រាជ្ញផ្លូវកាយ ផ្លូវវាចា ផ្លូវចិត្ត មិនមានអាសវៈ

ជាអ្នកប្រាជ្ញ បរិបូណ៌ដោយភាពជាអ្នកប្រាជ្ញ ថាជាអ្នកមានបាប លះបង់អស់ហើយ ។

**អាបាយិកវគ្គទី ២ ចប់**

## ឧទ្ទាននៃអាបាយិកវគ្គនោះគឺ

ពោលអំពីបុគ្គលទៅកាន់អបាយ ១ អំពីបុគ្គលរកបានដោយក្រ ១ អំពីអប្បមេយ្យបុគ្គលជាដើម ១ អំពីបុគ្គលបានអរូបជ្ឈាន មិនញាប់ញ័រ ១ អំពីវិបត្តិមានសេចក្តីប្រៀបដោយបាសកា មានជ្រុងប្រាំមួយ ១ អំពីកម្មន្តវិបត្តិជាដើម ១ អំពីការស្អាតមានពីរលើក ១ អំពីភាពជាអ្នកប្រាជ្ញ ១ ។

# អដ្ឋកថា

## មោនេយ្យសូត្រ

[ ១២៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមោនេយ្យសូត្រទី ១០ ដូចតទៅនេះ ភាពជាមុនី ឈ្មោះថា **មោនេយ្យ** ។ ភាពជាមុនី គឺភាពជាសាធុជន បានដល់ភាពដែលជាបណ្ឌិតក្នុងកាយទ្វារ ឈ្មោះថា **កាយមោនេយ្យំ** ។ ក្នុងបទទាំង ២ ដ៏សេស ក៏មានន័យដូចគ្នា ។ បទថា **ឥធំ វុច្ចតិ ភិក្ខវេ កាយមោនេយ្យំ**

សេចក្តីថា ពិតហើយ ការលះកាយទុច្ចរិត ៣ យ៉ាងនេះ ឈ្មោះថា កាយ-មោនេយ្យ ។ មួយយ៉ាងទៀត សូម្បីកាយសុចរិត ៣ យ៉ាង ក៏ឈ្មោះថា **កាយ-មោនេយ្យំ** ។ ញាណដែលមានកាយជាអារម្មណ៍ ឈ្មោះថា **កាយ-មោនេយ្យំ** ដូចគ្នា ។ ការកំណត់ដឹងកាយ ឈ្មោះថា **កាយមោនេយ្យំ** ។ មគ្គដែលសហគតៈដោយបរិញ្ញា ឈ្មោះថា **កាយមោនេយ្យំ** ។ ការលះឆន្ទរាគៈផ្លូវកាយ ឈ្មោះថា **កាយមោនេយ្យំ** ។ ការរម្ងាប់កាយសង្ខារនិងការចូលចតុត្ថជ្ឈាន ក៏ឈ្មោះថា **កាយមោនេយ្យំ** ក្នុងវចីមោនេយ្យក៏មានន័យនេះដូចគ្នា ។ ឯក្នុងវចីមោនេយ្យ និងមនោមោនេយ្យនេះ មានការប្លែកផ្សេងគ្នាដូចតទៅនេះ ក្នុងទីនោះ គប្បីជ្រាបការចូលទុតិយជ្ឈាន គឺការរម្ងាប់វចីសង្ខារថាជាវចីមោនេយ្យ ដូចការចូលចតុត្ថជ្ឈានក្នុងទីនេះ ។ កាលជ្រាបអត្ថក្នុងមនោមោនេយ្យដោយន័យនេះហើយ ក៏គួរជ្រាបការចូលសញ្ញា-វេទយិតនិរោធ គឺការរម្ងាប់ចិត្តសង្ខារ ឈ្មោះថា **មនោមោនេយ្យ** ។

បទថា **កាយមុនឹ** បានដល់ បុគ្គលដឹង គឺបុគ្គលឧត្តម បានដល់បរិសុទ្ធក្នុងកាយទ្វារ ឬបុគ្គលដឹងផ្លូវកាយ ។ ក្នុងបទទាំង ២ ដ៏សេស ក៏មានន័យដូចគ្នា ។ បទថា **សព្វប្បហាយិនំ** បានដល់ ព្រះខីណាស្រព ។ ព្រោះថា ព្រះខីណាស្រព ឈ្មោះថា **សព្វប្បហាយី** គឺអ្នកលះបង់បានទាំងអស់ ដូច្នេះ ។ល។

អដ្ឋកថា មោនេយ្យសូត្រទី ១០ ចប់

អាចាយិកវគ្គទី ២ ចប់

# សុត្តន្តបិដក

## កុសិនារវគ្គទី ៣

### កុសិនារសូត្រទី ១

[ ១២៥ ] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងដងព្រៃឈ្មោះពលិហរណៈ ជិតក្រុងកុសិនារា ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅនៅអាស្រ័យនឹងស្រុក ឬនិគមណាមួយ ។ ឯគហបតី ឬគហបតិបុត្រ ចូលទៅរកភិក្ខុនោះនិមន្តដោយភត្ត ដើម្បីឆាន់ក្នុងថ្ងៃស្អែក ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលចង់ឆាន់ ក៏ទទួលនិមន្ត ។ លុះកន្លងរាត្រីនោះទៅ ភិក្ខុនោះស្លៀកស្បង់ប្រដាប់បាត្រ និងចីវរក្នុងវេលាព្រឹក រួចចូលទៅកាន់លំនៅគហបតី ឬគហបតិបុត្រនោះ លុះចូលទៅដល់ហើយ អង្គុយលើអាសនៈដែលគេក្រាលបម្រុងទុក ។ គហបតី ឬគហបតិបុត្រនោះ ក៏និមន្តភិក្ខុនោះ ឲ្យឆាន់ឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ដោយដៃខ្លួនឯង ។ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ប្រពៃណាស់ហ្ន៎ គហបតី ឬគហបតិបុត្រនេះ និមន្តអញឲ្យឆាន់ឆ្អែតស្កប់ស្កល់ ដោយខាទនីយ-ភោជនីយាហារដ៏ផ្ចិតផ្ចង់ ដោយដៃខ្លួនឯង ។ ភិក្ខុនោះ ក៏គិតយ៉ាងនេះទៀតថា ធ្វើម្ដេចហ្ន៎ នឹង

បានគហបតី ឬ គហបតិបុត្រនេះ និមន្តអញឲ្យឆាន់ឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់មានទំនងយ៉ាងនេះ ដោយដៃខ្លួនឯងតទៅទៀតអេះ ។ ភិក្ខុនោះ មានចិត្តផ្តេកផ្តួល ជ្រុលជ្រប់ ល្មោភ ជាអ្នកមិនឃើញទោស មិនមានបញ្ញាជាគ្រឿងរលាស់ខ្លួនចេញ បរិភោគនូវបិណ្ឌបាតនោះ ។ ភិក្ខុនោះ រមែងត្រិះរិះនូវកាមវិតក្កផង ត្រិះរិះនូវព្យាបាទវិតក្កផង ត្រិះរិះនូវវិហឹសាវិតក្កផង ក្នុងបិណ្ឌបាតនោះ ។ ម្នាលភិក្ខុទាំងឡាយ ទានដែលទាយកឲ្យហើយ ដល់ភិក្ខុមានសភាពយ៉ាងនេះ តថាគតមិនហៅថា ជាទានមានផលច្រើនទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះភិក្ខុមានសេចក្តីប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ចូលទៅនៅអាស្រ័យនឹងស្រុក ឬនិគមណាមួយ ។ ឯគហបតី ឬគហបតិបុត្រចូលទៅរកភិក្ខុនោះ និមន្តដោយភត្ត ដើម្បីឆាន់ក្នុងថ្ងៃស្អែក ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលចង់ឆាន់ក៏ទទួលនិមន្ត ។ លុះកន្លងរាត្រីនោះទៅ ភិក្ខុនោះស្លៀកស្បង់ប្រដាប់បាត្រ និងចីវរក្នុងវេលាព្រឹក រួចចូលទៅកាន់លំនៅនៃគហបតី ឬបគហបតិបុត្រនោះ លុះចូលទៅដល់ហើយ អង្គុយលើអាសនៈដែលគេក្រាលបម្រុងទុក ។ គហបតី ឬគហបតិបុត្រនោះ ក៏និមន្តភិក្ខុនោះឲ្យឆាន់ឆ្អែតស្កប់ស្កល់ ដោយខាទនីយ-ភោជនីយាហារដ៏ផ្ចិតផ្ចង់ ដោយដៃខ្លួនឯង ។ ភិក្ខុនោះ មិនមានសេចក្តីត្រិះរិះយ៉ាងនេះថា ប្រពៃណាស់ហ្ន៎ គហបតី ឬគហបតិបុត្រនេះនិមន្តអញឲ្យឆាន់ឆ្អែតស្កប់ស្កល់ ដោយខាទនីយ-ភោជនីយាហារដ៏ផ្ចិតផ្ចង់ ដោយដៃខ្លួនឯង ។ ទាំងមិនមានសេចក្តីត្រិះរិះ

យ៉ាងនេះថា ធ្វើម្តេចហ្ន៎ នឹងបានគហបតី ឬគហបតិបុត្រនេះ និមន្តអញឲ្យឆ្អែតស្កប់ស្កល់ ដោយខាទនីយ-ភោជនីយាហារ ដ៏ផ្ចិតផ្ចង់មានទំនងដូច្នេះ ដោយដៃខ្លួនឯង តទៅទៀតឡើយ ។ ភិក្ខុនោះមិនផ្តេកផ្តួល មិនជ្រុលជ្រប់ មិនល្មោភ ជាអ្នកឃើញទោស មានប្រាជ្ញាជាគ្រឿងរលាស់ខ្លួនចេញ បរិភោគនូវបិណ្ឌបាតនោះ ។ ភិក្ខុនោះ រមែងត្រិះរិះនូវនេក្ខម្មវិតក្កផង ត្រិះរិះនូវអព្យាបាទវិតក្កផង ត្រិះរិះនូវអវិហឹសាវិតក្កផង ក្នុងបិណ្ឌបាតនោះ ។ ម្នាលភិក្ខុទាំងឡាយ ទានដែលទាយកឲ្យហើយ ដល់ភិក្ខុមានសភាពយ៉ាងនេះ ទើបតថាគតហៅថា ជាទានមានផលច្រើន ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះភិក្ខុមិនមានសេចក្តីប្រមាទ ។

# អដ្ឋកថា

## កុសិនារវគ្គទី ៣

### អដ្ឋកថាកុសិនារសូត្រ

[ ១២៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកុសិនារសូត្រទី ១ នៃកុសិនារវគ្គទី ៣ ដូចតទៅ បទថា **កុសិនារាយំ** បានដល់ ក្នុងព្រះនគរដែលមានឈ្មោះយ៉ាងនេះ ។ បទថា **ពលិហរណេ វនសណ្ឌេ** បានដល់ ក្នុងដងព្រៃដែលមានឈ្មោះយ៉ាងនេះ ។ បានឮថា មនុស្សទាំងឡាយនាំពលីកម្មទៅ ដើម្បីពលីកម្មដល់ភូតក្នុងដងព្រៃនោះ ព្រោះដូច្នោះ ទើបដងព្រៃនោះជនទាំងឡាយហៅថា **ពលិហរណា** ។ បទថា **អាកង្ខមានោ** បានដល់ ប្រាថ្នា ។ បទថា **សហត្ថា** បានដល់ ដោយដៃរបស់ខ្លួន ។ បទថា **សម្បវារេតិ** សេចក្ដីថា ឃាត់ដោយវាចាថា ល្មមហើយ ល្មមហើយ និងដោយការរាដៃ ។

បទថា **សាធុ វត មាយំ** សេចក្ដីថា ល្អពិតហ្ន៎ គហបតី ឬបុត្តគហបតីនេះ អង្កាសអាត្មាអញឲ្យឆ្អែតស្កប់ស្កល់ ។ បទថា **គធិតោ** សេចក្ដីថា ជាប់ចិត្តដោយការត្រេកអរ ដោយអំណាចតណ្ហា ។ បទថា **មុច្ឆិតោ** បានដល់ ងប់ជ្រប់ហើយ ដោយអំណាចការងប់ជ្រប់នៃតណ្ហានោះឯង ។ បទថា **អជ្ឈោបន្នោ** សេចក្ដីថា លេបចូលទៅឲ្យសម្រេច ដោយអំណាចតណ្ហា ។ បទថា **និស្សរណបញ្ញោ** សេចក្ដីថា ភិក្ខុដែលលះឆន្ទរាគៈហើយ ឆាន់ភត្តដោយទាញចេញអំពីការជាប់ក្នុងរស ទើបឈ្មោះថាជាអ្នកមានបញ្ញា

*ជាគ្រឿងរលាស់ចេញ ភិក្ខុនេះ មិនដូច្នោះឡើយ លោកនៅមានឆន្ទរាគៈ ឆាន់អាហារ ព្រោះដូច្នោះ ទើបឈ្មោះថា* **និស្សរណាប្បញ្ញោ** *។ ធម៌ក្នុងសុក្កបក្ខ បណ្ឌិតគប្បីជ្រាបដោយផ្ទុយពីបរិយាយ ដូចពោលហើយ ។ម្យ៉ាងទៀត ក្នុងព្រះសូត្រនេះ គប្បីជ្រាបថា ទ្រង់ត្រាស់នេក្ខម្មវិតក្កជាដើមលាយឡំគ្នា ដូច្នេះ ។៚*

## អដ្ឋកថា កុសិនារសូត្រទី ១ ចប់

# សុត្តន្តបិដក

## ភណ្ឌនសូត្រទី ២

[ ១២៦ ] ម្នាលភិក្ខុទាំងឡាយ ក្នុងទិសណា ភិក្ខុទាំងឡាយបង្កហេតុបង្កជម្លោះ ទាស់ទែងគ្នា ចាក់ដោតគ្នា ទៅវិញទៅមក ដោយលំពែង គឺមាត់ ម្នាលភិក្ខុទាំងឡាយ ទិសនោះ មិនជាទីសប្បាយដល់តថាគត ដើម្បីធ្វើទុកក្នុងចិត្ត មិនបាច់និយាយដល់ការដើរទៅឡើយ តថាគតចូលចិត្តក្នុងការណ៍នោះថា អ្នកដ៏មានអាយុទាំងឡាយនោះ បានលះបង់នូវធម៌ ៣ យ៉ាង បានធ្វើរឿយៗ នូវធម៌ ៣ យ៉ាង ដោយពិតប្រាកដ ។ ចុះភិក្ខុនោះលះបង់នូវធម៌ ៣ យ៉ាង គឺអ្វីខ្លះ ។ គឺនេក្ខម្មវិតក្ក ១ អព្យាបាទវិតក្ក ១ អវិហឹសាវិតក្ក ១ ។ ភិក្ខុទាំងនោះ លះបង់ធម៌ ៣ យ៉ាងនេះឯង ។ ចុះភិក្ខុទាំងនោះបានធ្វើរឿយៗ នូវធម៌ ៣ យ៉ាង គឺអ្វីខ្លះ ។ គឺកាមវិតក្ក ១ ព្យាបាទវិតក្ក ១ វិហឹសាវិតក្ក ១ ។ ភិក្ខុទាំងនោះ បានធ្វើរឿយៗ នូវធម៌ ៣ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងទិសណា ភិក្ខុទាំងឡាយ បង្កហេតុ បង្កជម្លោះ ទាស់ទែងគ្នា ចាក់ដោតគ្នាទៅវិញទៅមកដោយលំពែង គឺមាត់ ម្នាលភិក្ខុទាំងឡាយ ទិសនេះ មិនជាទីសប្បាយដល់តថាគត ដើម្បីធ្វើទុកក្នុងចិត្តទេ មិនចាំបាច់និយាយដល់ការដើរទៅឡើយ តថាគតចូលចិត្តក្នុងការណ៍នោះថា អ្នកដ៏មានអាយុទាំងនោះ បានលះបង់នូវធម៌ ៣ យ៉ាងនេះឯង បានធ្វើឲ្យរឿយៗ នូវធម៌ ៣ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងទិសណា ភិក្ខុទាំងឡាយ ព្រមព្រៀងគ្នា រីករាយនឹងគ្នា មិនទាស់ទែងគ្នា ដូចទឹកដោះស្រស់លាយដោយទឹក

មើលគ្នាត្រង់ដោយចក្ខុជាទីស្រឡាញ់ ម្នាលភិក្ខុទាំងឡាយ ទិសនុ៎ះ ជាទីសប្បាយដល់តថាគតដើម្បីដើរទៅ មិនបាច់និយាយដល់ការធ្វើទុកក្នុងចិត្តឡើយ តថាគតចូលចិត្តក្នុងការណ៍នោះថា អ្នកដ៏មានអាយុទាំងនោះ បានលះបង់នូវធម៌ ៣ យ៉ាង បានធ្វើឲ្យរឿយៗ នូវធម៌ ៣ យ៉ាងដោយពិតប្រាកដ ។ អ្នកដ៏មានអាយុទាំងនោះ បានលះបង់ធម៌ ៣ យ៉ាង គឺអ្វីខ្លះ ។ គឺកាមវិតក្ក ១ ព្យាបាទវិតក្ក ១ វិហឹសាវិតក្ក ១ ។ ភិក្ខុទាំងនោះ បានលះបង់ធម៌ ៣ យ៉ាងនេះឯង ។ ចុះភិក្ខុទាំងនោះ បានធ្វើឲ្យរឿយៗ នូវធម៌ ៣ យ៉ាងគឺអ្វីខ្លះ ។ គឺនេក្ខម្មវិតក្ក ១ អព្យាបាទវិតក្ក ១ អវិហឹសាវិតក្ក ១ ។ អ្នកទាំងនោះបានធ្វើរឿយៗ នូវធម៌ ៣ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងទិសណា ភិក្ខុទាំងឡាយ ព្រមព្រៀងគ្នា រីករាយនឹងគ្នា មិនទាស់ទែងគ្នា ដូចទឹកដោះស្រស់លាយដោយទឹក មើលគ្នាត្រង់ដោយចក្ខុជាទីស្រឡាញ់ ម្នាលភិក្ខុទាំងឡាយ ទិសនុ៎ះ ជាទីសប្បាយដល់តថាគត ដើម្បីដើរទៅ មិនបាច់និយាយដល់ការធ្វើទុកក្នុងចិត្តឡើយ តថាគតចូលចិត្តក្នុងការណ៍នោះថា អ្នកដ៏មានអាយុទាំងនោះ បានលះបង់នូវធម៌ ៣ យ៉ាងនេះឯង បានធ្វើឲ្យរឿយៗ នូវធម៌ ៣ យ៉ាងនេះឯង ដោយពិតប្រាកដ ។

# អដ្ឋកថា

## កណ្ហសូត្រ

[ ១២៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកណ្ហសូត្រទី ២ ដូចតទៅនេះ បទថា **បជហិសុ** ប្រែថា រមែងលះបាន ។ បទថា **ពហុលមកំសុ** បានដល់ធ្វើរឿយៗ ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់វិតក្ក ៣ នេះលាយឡំគ្នាទៅ ។

អដ្ឋកថា កណ្ហសូត្រទី ២ ចប់

# សុត្តន្តបិដក

## គោតមចេតិយសូត្រទី ៣

[ ១២៧ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងគោតមកចេតិយ ជិតក្រុងវេសាលី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតសម្តែងធម៌ ដើម្បីឲ្យចេះដឹង មិនមែនដើម្បីមិនឲ្យចេះដឹងទេ ម្នាលភិក្ខុទាំងឡាយ តថាគតសម្តែងធម៌សមតាមហេតុ មិនមែនមិនសមតាមហេតុទេ ម្នាលភិក្ខុទាំងឡាយ តថាគតសម្តែង

ធម៌ប្រកបដោយសេចក្ដីអស្ចារ្យ មិនមែនមិនប្រកបដោយសេចក្ដីអស្ចារ្យទេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើតថាគតនោះសម្ដែងធម៌ ដើម្បីឲ្យចេះដឹង មិនមែនដើម្បីមិនឲ្យចេះដឹង សម្ដែងធម៌សមតាមហេតុ មិនមែនមិនសមតាមហេតុ សម្ដែងធម៌ប្រកបដោយសេចក្ដីអស្ចារ្យ មិនមែនមិនប្រកបដោយសេចក្ដីអស្ចារ្យ អ្នកទាំងឡាយ គួរធ្វើតាមឱវាទ គួរធ្វើតាមអនុសាសនី ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អ្នកទាំងឡាយ គួរត្រេកអរ គួរពេញចិត្ត គួររីករាយ ( ចំពោះគុណព្រះរតនត្រ័យ ) ថា ព្រះដ៏មានព្រះភាគ ជាព្រះសម្មាសម្ពុទ្ធ ព្រះធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងហើយដោយប្រពៃ ព្រះសង្ឃប្រតិបត្តិដោយប្រពៃ ។ លុះព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអររីករាយចំពោះភាសិត របស់ព្រះដ៏មានព្រះភាគ ។ ក៏កាលដែលព្រះដ៏មានព្រះភាគសម្ដែងនូវវេយ្យាករណ៍នេះចប់ហើយ លោកធាតុទាំង ១ ពាន់ ក៏កក្រើករញ្ជួយ ។

# អដ្ឋកថា

## គោតមចេតិយសូត្រ

[ ១២៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងគោតមចេតិយសូត្រទី ៣ ដូចតទៅនេះ បទថា **គោតមកេ ចេតិយេ** បានដល់ ក្នុងទីអាស្រ័យ គឺទេវស្ថាននៃ

គោតមកយក្ខ អធិប្បាយថា ក្នុងបឋមពោធិកាល ដោយច្រើន ព្រះតថាគត ប្រថាប់នៅត្រង់ទេវាល័យប៉ុណ្ណោះ អស់កាល ២០ វស្សាយ៉ាងនេះ គឺជួនកាល ត្រង់ចាបាលចេតិយ ជួនកាល ត្រង់សារន្ទទចេតិយ ជួនកាល ត្រង់ពហុបុត្តកចេតិយ ជួនកាល ត្រង់សត្តម្ពចេតិយ ។ តែក្នុងពេលនេះ ទ្រង់អាស្រ័យក្រុងវេសាលីប្រថាប់នៅហើយ ក្នុងទេវស្ថានរបស់គោតមកយក្ខ ។ ដោយហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលថា **គោតមកេ ចេតិយេ** ដូច្នេះ ។

បទថា **ឯតទវោច** នេះ សេចក្តីថា ព្រះមានព្រះភាគបានត្រាស់ពាក្យនេះ គឺព្រះសូត្រមានពាក្យជាដើមថា **អភិញ្ញាយាហំ** ដូច្នេះ ។ ក្នុងការកើតឡើងនៃអត្ថរបស់សូត្រនេះ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ហើយ ។ សួរថា ក្នុងអត្ថុប្បត្តិហេតុដូចម្តេច ឆ្លើយថា ក្នុងអត្ថុប្បត្តិហេតុនៃមូលបរិយាយសូត្រ ។

បានឮថា ព្រាហ្មណបព្វជិតជាច្រើនស្រវឹងក្នុងការចេះដឹង ព្រោះអាស្រ័យពុទ្ធវចនៈដែលធ្លាប់រៀនហើយ មិនព្រមទៅសាលាស្តាប់ធម៌ ដោយគិតថា ព្រះសម្មាសម្ពុទ្ធ កាលត្រាស់ ក៏ត្រាស់ពាក្យដែលពួកយើងចេះហើយប៉ុណ្ណោះ មិនត្រាស់ពាក្យដែលពួកយើងមិនទាន់ចេះ ដូច្នេះ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនោះដល់ព្រះតថាគតហើយ ព្រះសាស្តាត្រាស់ឲ្យហៅភិក្ខុទាំងនោះមក ទ្រង់កាន់យកមុខបញ្ហា គឺការទទួលផ្ទាល់មាត់របស់ភិក្ខុទាំងនោះ ហើយទ្រង់សម្តែងមូលបរិយាយសូត្រ ភិក្ខុទាំងនោះ មិនបាន

ឃើញទីមកទីទៅរបស់ព្រះធម្មទេសនាឡើយ កាលមិនឃើញ ក៏នាំគ្នាគិតថា ព្រះសម្មាសម្ពុទ្ធគង់យល់ក្នុងព្រះហឫទ័យថា ធម្មកថារបស់តថាគត រមែងនាំសត្វចេញទៅចាកទុក្ខ ទើបត្រាស់ព្រះធម្មទេសនាដែលចាំរត់ព្រះឱស្ឋប៉ុណ្ណោះ ព្រះសាស្តាទ្រង់ដឹងចិត្តនៃភិក្ខុទាំងនោះហើយ ទើបទ្រង់ផ្តើមព្រះសូត្រនេះ ។

បណ្តាបទទាំងនោះ បទថា **អភិញ្ញាយ** សេចក្តីថា ដឹង គឺចាក់ធ្លុះ ធ្វើឲ្យប្រចក្សថា ធម៌ទាំងនេះ គឺខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ឥន្ទ្រិយ ២២ អរិយសច្ច ៤ ហេតុ ៩ ផស្សៈ ៧ វេទនា ៧ ចេតនា ៧ សញ្ញា ៧ ចិត្ត ៧ ។ ម្យ៉ាងទៀត អធិប្បាយថា ដឹង គឺចាក់ធ្លុះ បានដល់ ធ្វើឲ្យជាក់ច្បាស់នោះឯង នូវធម៌នោះៗ ដោយន័យជាដើមថា សតិប្បដ្ឋាន ៤ នេះ ដូច្នេះ ។ បទថា **សនិទានំ** សេចក្តីថា តថាគតពោលធម៌ មួយអន្លើដោយបច្ច័យនោះឯង មិនមែនមិនមានបច្ច័យ ។ បទថា **សប្បាដិហារិយំ** សេចក្តីថា តថាគតពោលធម៌ មានបាដិហារ្យនោះឯង ព្រោះកម្ចាត់សត្រូវបាន មិនមែនមិនមានបាដិហារ្យ ។ បទថា **អលញ្ច បន វោ** សេចក្តីថា ឱវាទានុសាសនី គួរដល់អ្នកទាំងឡាយ ។ បទថា **តុដ្ឋិយា** មានអធិប្បាយថា គួរនោះឯង ដើម្បីធ្វើឲ្យត្រេកអរដល់អ្នកទាំងឡាយដែលរឭកដល់រឿយៗនូវរតនៈទាំង ៣ ដោយព្រះគុណថា ព្រះមានព្រះភាគជាអ្នកត្រាស់ដឹងប្រពៃ ដោយព្រះអង្គឯង ព្រះធម៌ ក៏ព្រះមានព្រះភាគត្រាស់ល្អហើយ ព្រះសង្ឃជាអ្នកបដិបត្តិល្អហើយ ដូច្នេះ ក្នុងបទទាំង ២ ដ៏សេស ក៏មានន័យនេះឯង ។

បទថា **អកម្បិត្ថ** បានដល់ បានកម្រើកញាប់ញ័រហើយ ដោយអាការ ៦ យ៉ាង អធិប្បាយថា ការញាប់ញ័រនៃប្រឹថពីបែបនេះ មានហើយត្រង់ពោធិមណ្ឌល បានឮថា កាលព្រះពោធិសត្វឡើងកាន់ពោធិមណ្ឌលទិសខាងត្បូង ផ្នែកខាងត្បូង ខាងក្រោម បានប្រាកដដូចស្រុតដល់អវីចីមហានរក ដោយទិសខាងលើ ដូចលើកឡើងទល់ភវគ្គព្រហ្ម ទិសខាងលិចស្រុតទៅ ដូចធ្លាក់ទៅដល់អវីចីមហានរក ទិសខាងកើត ដូចលើកឡើង ទល់គ្នានឹងភវគ្គព្រហ្ម ទិសខាងជើង ផ្នែកខាងក្រោម ហាក់ដូចស្រុតចុះ ទល់គ្នានឹងអវីចី-មហានរក ទិសខាងត្បូង ក៏ហាក់ដូចជាលើកឡើងទល់គ្នានឹងភវគ្គព្រហ្ម ទិសខាងកើត ផ្នែកខាងក្រោម ដូចស្រុតចុះដល់អវីចីមហានរក ទិសខាងលិចហាក់ដូចលើកឡើងដល់ភវគ្គព្រហ្ម សូម្បីពោធិព្រឹក្សខាងក្រោម ហាក់ដូចជាស្រុតដល់អវីចីមហានរកក្នុងគ្រាតែមួយ ខាងលើ ហាក់ដូចជាផុសឡើងទល់គ្នានឹងភវគ្គព្រហ្មដូចគ្នា ។ ក្នុងថ្ងៃនោះ មហាប្រឹថពី ក្នុងពាន់នៃចក្រវាល បានញាប់ញ័រហើយ ដោយអាការ ៦ យ៉ាង ដូចពណ៌នាមក ដូច្នេះ ។

**អដ្ឋកថា គោតមចេតិយសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ភរណ្ឌុសូត្រទី ៨

[ ១២៨ ] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់ស្ដេចទៅកាន់ចារិកក្នុងកោសលជនបទ ក៏ស្ដេចទៅដល់ក្រុងកបិលពស្ដុ ។ មហានាមសក្យរាជបានជ្រាបថា ព្រះដ៏មានព្រះភាគ ទ្រង់ស្ដេចមកដល់ក្រុងកបិលពស្ដុហើយ ។ លំដាប់នោះ មហានាមសក្យរាជ ស្ដេចចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចប្រថាប់ក្នុងទីសមគួរ ។ លុះមហានាមសក្យរាជ ប្រថាប់ក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា បពិត្រមហានាម សូមទ្រង់ស្ដេចទៅពិនិត្យមើលលំនៅក្នុងក្រុងកបិលពស្ដុ ដែលជាទីគួរតថាគតនៅអស់មួយយប់ក្នុងថ្ងៃនេះ ។ មហានាមសក្យរាជ ទទួលព្រះតម្រាស់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយស្ដេចយាងក្រឡឹងមើលក្រុងកបិលពស្ដុទាំងមូល ក៏មិនបានឃើញលំនៅក្នុងក្រុងកបិលពស្ដុ ដែលជាទីគួរព្រះដ៏មានព្រះភាគគង់នៅ អស់មួយយប់បាន ។ វេលានោះ មហានាមសក្យរាជ ទ្រង់ស្ដេចត្រឡប់ចូលមកគាល់ព្រះដ៏មានព្រះភាគវិញ លុះចូលមកដល់ហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន លំនៅក្នុងក្រុងកបិលពស្ដុ ដែលជាទីគួរព្រះអង្គគង់នៅអស់មួយយប់ ក្នុងថ្ងៃនេះមិនមានទេ បពិត្រព្រះអង្គដ៏ចម្រើន តាបសឈ្មោះភរណ្ឌុកាលាមៈនេះ ជាសព្រហ្មចារីបុគ្គលជាន់ចាស់របស់ព្រះអង្គ សូមព្រះអង្គគង់នៅក្នុងអាស្រមរបស់តាបសនោះ អស់មួយយប់ក្នុងថ្ងៃនេះចុះ ។ ព្រះសម្ពុទ្ធត្រាស់ថា បពិត្រមហានាម សូមទ្រង់ស្ដេច

ទៅឲ្យក្រាលកម្រាលចុះ ។ មហានាមសក្យរាជ បានទទួលព្រះតម្រាស់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយស្តេចចូលទៅឯអាស្រមរបស់ភរណ្ឌុកាលាមតាបស លុះស្តេចចូលទៅដល់ហើយ ក៏ឲ្យក្រាលកម្រាលលើគ្រែតូចដ៏សមគួរ ហើយឲ្យតម្កល់ទឹកទុកដើម្បីលាងព្រះបាទ រួចស្តេចត្រឡប់ចូលមកគាល់ព្រះដ៏មានព្រះភាគវិញ លុះចូលមកដល់ហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន កម្រាលក្រាលហើយ ទឹកសម្រាប់លាងព្រះបាទតម្កល់ទុកហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ជ្រាបនូវកាលដ៏គួរនឹងស្តេចក្នុងកាលឥឡូវនេះចុះ ។ គ្រានោះឯង ព្រះដ៏មានព្រះភាគ ស្តេចចូលទៅឯអាស្រមរបស់ភរណ្ឌុ-កាលាមតាបស លុះស្តេចចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលបម្រុងទុក លុះព្រះដ៏មានព្រះភាគគង់ហើយ ក៏លាងជូតព្រះបាទទាំងគូ ។ លំដាប់នោះ មហានាមសក្យរាជ ទ្រង់មានព្រះរាជតម្រិះដូច្នេះថា ថ្ងៃនេះជាកាលមិនគួរនឹងចូលទៅគាល់ព្រះដ៏មានព្រះភាគទេ ព្រោះព្រះដ៏មានព្រះភាគកំពុងនឿយព្រះកាយ ឥឡូវអាត្មាអញ ចាំចូលទៅគាល់ព្រះដ៏មានព្រះភាគក្នុងថ្ងៃស្អែកវិញចុះ មហានាមសក្យរាជក៏ថ្វាយបង្គំលាព្រះដ៏មានព្រះភាគធ្វើប្រទក្សិណ ហើយស្តេចចេញទៅ ។ លំដាប់នោះ មហានាមសក្យរាជ លុះកន្លងរាត្រីនោះទៅ ក៏ស្តេចចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះស្តេចចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចប្រថាប់ក្នុងទីសមគួរ ។ លុះមហានាមសក្យរាជប្រថាប់ក្នុងទីសមគួរហើយ ទើបព្រះដ៏មានព្រះភាគ

ទ្រង់ត្រាស់ដូច្នេះថា បពិត្រមហានាម សាស្តា ៣ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ សាស្តា ៣ ពួក ដូចម្តេចខ្លះ ។ បពិត្រមហានាម សាស្តាពួកខ្លះ ក្នុងលោកនេះ បញ្ញត្តការកំនត់នូវកាម គឺបឋមជ្ឈាន មិនបញ្ញត្តការកំនត់នូវរូប គឺអរូបាវចរសមាបត្តិ មិនបញ្ញត្តការកំនត់នូវវេទនា គឺនិព្វាន ។ បពិត្រមហានាម មួយទៀត សាស្តាពួកខ្លះ ក្នុងលោកនេះ បញ្ញត្តការកំនត់នូវកាមផង បញ្ញត្តការកំនត់នូវរូបផង តែមិនបញ្ញត្តការកំនត់នូវវេទនា ។ បពិត្រមហានាម មួយវិញទៀត សាស្តាពួកខ្លះ ក្នុងលោកនេះ បញ្ញត្តការកំនត់នូវកាមផង បញ្ញត្តការកំនត់នូវរូបផង បញ្ញត្តការកំនត់នូវវេទនាផង ។ បពិត្រមហានាម សាស្តា ៣ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។ បពិត្រមហានាម ចុះសាស្តា ៣ ពួកនេះ មានសេចក្តីយល់ដូចគ្នា ឬមានសេចក្តីយល់ផ្សេងគ្នា ។ កាលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរយ៉ាងនេះ ភរណ្ឌុកាលាមតាបស បានបង្គាប់មហានាមសក្យរាជដូច្នេះថា បពិត្រមហានាម សូមមហាបពិត្រមានព្រះរាជឱង្ការថា មានសេចក្តីយល់ដូចគ្នា ។ កាលភរណ្ឌុកាលាមតាបសនិយាយយ៉ាងនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងមហានាមសក្យរាជដូច្នេះថា បពិត្រមហានាម សូមទ្រង់មានព្រះរាជឱង្ការថា មានសេចក្តីយល់ផ្សេងគ្នាដូច្នេះវិញ ។ ភរណ្ឌុកាលាមតាបស បានបង្គាប់មហានាមសក្យរាជអស់ ២ ដងថា បពិត្រមហានាម សូមមហាបពិត្រមានព្រះរាជឱង្ការថា មានសេចក្តីយល់ដូចគ្នា ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងមហានាមសក្យរាជអស់ ២ ដងទៀតថា បពិត្រមហានាម សូមទ្រង់មាន

ព្រះរាជឱង្ការថា មានសេចក្ដីយល់ផ្សេងគ្នាដូច្នេះវិញ ។ ភរណ្ឌុកាលាមតាបស បានបង្គាប់មហានាមសក្យរាជអស់ ៣ ដងថា បពិត្រមហានាម សូមមហាបពិត្រ មានព្រះរាជឱង្ការថា មានសេចក្ដីយល់ដូចគ្នា ។ ព្រះដ៏មានព្រះភាគបានត្រាស់នឹងមហានាមសក្យរាជអស់ ៣ ដងទៀតថា បពិត្រមហានាម សូមទ្រង់មានព្រះរាជឱង្ការថា មានសេចក្ដីយល់ផ្សេងគ្នាដូច្នេះវិញ ។ លំដាប់នោះ ភរណ្ឌុកាលាមតាបសមានសេចក្ដីត្រិះរិះដូច្នេះថា មិនសមបើព្រះសមណគោតមមិនជ្រះថ្លានឹងអញអស់ ៣ ដង ក្នុងទីចំពោះព្រះភក្ត្រមហានាមសក្យរាជ ដែលមានសក្តិធំសោះ បើដូច្នោះ អញគួរដើរចេញអំពីក្រុងកបិលពស្ដុ ។ លំដាប់នោះ ភរណ្ឌុកាលាមតាបស ក៏ចេញអំពីកបិលពស្ដុ គឺចេញទៅតែម្ដង មិនបានត្រឡប់មកក្រោយវិញឡើយ ។

# អដ្ឋកថា

## ភរណ្ឌុសូត្រ

[ ១២៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងភរណ្ឌុសូត្រទី ៤ ដូចតទៅនេះ បទថា **កោសលកប្បំ** បានដល់ ក្នុងទិសជុំវិញ ។ បទថា **អាហិណ្ឌន្តោ** បានដល់ ទ្រង់ត្រាច់ទៅ ។ បទថា **ឆ អទ្ទស** សេចក្ដីថា ព្រោះហេតុអ្វី ទើបព្រះបាទមហានាមសក្យៈទ្រង់បានជួប ។ បានឮថា ភរណ្ឌុកាលាមតាបសនេះទំពាធាន់

*បិណ្ឌបាតដ៏ប្រសើរស្តេចសក្យៈទាំងឡាយត្រាច់ទៅ ។ ព្រះមានព្រះភាគទ្រង់ជ្រាបថា ក្នុងកាលដែលទ្រង់យាងដល់លំនៅរបស់តាបសនោះ ព្រះធម្មទេសនាមួយកណ្ឌនឹងកើតឡើង ទើបទ្រង់អធិដ្ឋានមិនឲ្យទីសម្រាកដទៃប្រាកដ ព្រោះដូច្នោះ ទើបសក្យមហានាមមិនឃើញ ។*

*បទថា* **បុរាណសព្រហ្មចារី** *បានដល់ ធ្លាប់ជាអ្នករួមប្រព្រឹត្តព្រហ្មចរិយៈជាមួយគ្នាមកអំពីមុន បានឮថា ភរណ្ឌុកាឡាមតាបសនោះ បាននៅក្នុងអាស្រមនោះ ក្នុងសម័យអាឡារតាបសកាលាមគោត្រ ។ ព្រះធម្មសង្គាហកាចារ្យពោលសំដៅដល់តាបសនោះឯង ។ បទថា* **សន្ថរំ បញ្ញាបេហិ** *អធិប្បាយថា អ្នកចូរក្រាលអាសនៈដែលត្រូវក្រាល ។ បទថា* **សន្ថរំ បញ្ញាបេត្វា** *សេចក្តីថា ក្រាលសំពត់សម្រាប់ក្រាលដេកលើគ្រែដែលជាកប្បិយ ។ ការឈានកន្លង ឈ្មោះថា បរិញ្ញា ក្នុងបទថា* **កាមានំ បរិញ្ញំ បញ្ញាបេតិ** *នេះ ព្រោះដូច្នោះ ទើបសាស្តាពួកខ្លះ បញ្ញត្តការឈានកន្លងកាមទាំងឡាយថា ជាបឋមជ្ឈាន ។ បទថា* **ន រូបានំ បរិញ្ញំ** *សេចក្តីថា មិនបញ្ញត្តធម៌ដែលជាហេតុឈានកន្លងនូវរូបថា ជាអរូបាវចរសមាបត្តិ ។ បទថា* **ន វេទនានំ បរិញ្ញំ** *សេចក្តីថា មិនបញ្ញត្តិការឈានកន្លងវេទនាថាជានិព្វាន គតិ គឺការសម្រេច ឈ្មោះថា* **និដ្ឋា** *។ បទថា* **ឧទាហុ បុថុ** *សេចក្តីថា ឬផ្សេងគ្នា ។៤*

## អដ្ឋកថា ភរណ្ឌុសូត្រទី ៤ ចប់

# សុត្តន្តបិដក

## ហត្ថកសូត្រទី ៥

[ ១២៩ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រាកាលរាត្រីកន្លងបឋមយាម ទេវបុត្រឈ្មោះហត្ថកៈ មានសម្បុរល្អ ធ្វើវត្តជេតពនទាំងមូលឲ្យភ្លឺច្បាស់ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏គិតថា អញនឹងឈរក្នុងទីចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ ដូច្នេះហើយ ត្រឡប់អន្ទុយស្រពាប អន្ទុយរាបវិញ មិនអាចនឹងឈរនៅបានឡើយ ។ ទឹកដោះថ្លា ឬប្រេងដែលគេចាក់ស្រោចទៅក្នុងដីខ្សាច់ រមែងជ្រួតជ្រាបលិចចុះបាត់ទៅ មិនដក់នៅ យ៉ាងណាមិញ ហត្ថកទេវបុត្រគិតថា អញនឹងឈរក្នុងទីចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ ដូច្នេះហើយ ត្រឡប់អន្ទុយស្រពាប អន្ទុយរាបវិញ មិនអាចឈរនៅបាន ក៏យ៉ាងនោះឯង ។ វេលានោះ ព្រះដ៏មានព្រះភាគត្រាស់បង្គាប់ហត្ថកទេវបុត្រដូច្នេះថា ម្នាលហត្ថកៈ អ្នកចូរនិម្មិតនូវអត្តភាពឲ្យធំសម្បើម ។ ហត្ថកទេវបុត្រ បានទទួលព្រះតម្រាស់ព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ដូច្នេះហើយ និម្មិតអត្តភាពឲ្យធំសម្បើម ថ្វាយបង្គំព្រះមានព្រះភាគ រួចឈរក្នុងទីដ៏សមគួរ ។ លុះហត្ថកទេវបុត្រ ឈរក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគត្រាស់សួរដូច្នេះថា ម្នាលហត្ថកៈ ធម៌ណាដែលអ្នកកាលកើតជាមនុស្សក្នុងភពមុន បានប្រព្រឹត្តហើយ តើធម៌ទាំងនោះអ្នកបានប្រព្រឹត្តក្នុងកាលឥឡូវនេះដែរឬទេ ។ ហត្ថកទេវបុត្រក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ណា ដែលខ្ញុំព្រះអង្គកាលកើតជាមនុស្ស ក្នុង

កពមុនបានប្រព្រឹត្តហើយ ធម៌ទាំងនោះ ខ្ញុំព្រះអង្គបានប្រព្រឹត្តក្នុងកាលឥឡូវនេះដែរ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ណាដែលខ្ញុំព្រះអង្គ កាលកើតជាមនុស្សក្នុងកពមុន មិនបានប្រព្រឹត្តទេ ធម៌ទាំងនោះ ក៏ខ្ញុំព្រះអង្គប្រព្រឹត្តក្នុងកាលឥឡូវនេះដែរ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគទ្រង់គង់ប្រឡូកប្រឡំដោយភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ស្តេច អាមាត្យធំរបស់ស្តេច តិរ្ថិយ និងសាវកនៃតិរ្ថិយទាំងឡាយ ក្នុងកាលឥឡូវនេះ យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គក៏យ៉ាងនោះដែរ តែងនៅប្រឡូកប្រឡំដោយទេវបុត្រទាំងឡាយ បពិត្រព្រះអង្គដ៏ចម្រើន ទេវបុត្រទាំងឡាយ តែងមកអំពីទីឆ្ងាយ ដោយបំណងថា យើងនឹងស្តាប់ធម៌ក្នុងសម្នាក់ហត្ថកទេវបុត្រ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនឆ្អែត មិនរួញរា នឹងធម៌ទាំង ៣ ត្រាតែធ្វើមរណកាល ។ ធម៌ ៣ ដូចម្តេចខ្លះ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនឆ្អែត មិនរួញរានឹងការមើលមើលព្រះដ៏មានព្រះភាគ ត្រាតែធ្វើមរណកាល ១ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនឆ្អែត មិនរួញរានឹងការស្តាប់ព្រះសទ្ធម្ម ត្រាតែធ្វើមរណកាល ១ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនឆ្អែត មិនរួញរានឹងការបម្រើសង្ឃ ត្រាតែធ្វើមរណកាល ១ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនឆ្អែត មិនរួញរានឹងធម៌ទាំង ៣ នេះឯង ត្រាតែធ្វើមរណកាល ។

( ការឆ្អែត ៣ យ៉ាង ) គឺឆ្អែតនឹងការមើលព្រះដ៏មាន
ព្រះភាគ ១ ឆ្អែតនឹងការបម្រើព្រះសង្ឃ ១ ឆ្អែតនឹងការ

ស្តាប់ព្រះសទ្ធម្ម ១ មានក្នុងកាលម្តងៗ តែប៉ុណ្ណោះ ។ ហត្ថកទេវបុត្រ កាលសិក្សានូវអធិសីល ត្រេកអរក្នុងការស្តាប់ព្រះសទ្ធម្ម មិនឆ្អែតនឹងធម៌ ៣ ប្រការ ក៏បានទៅកើតក្នុងអវិហាព្រហ្មលោក ។

# អដ្ឋកថា

## ហត្ថកសូត្រ

[ ១២៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងហត្ថកសូត្រទី ៥ ដូចតទៅនេះថា **អភិក្កន្ត** សព្ទ ក្នុងបទថា **អភិក្កន្តាយ រត្តិយា** នេះ ប្រាកដក្នុងអត្ថទាំងឡាយ មានអស់ទៅ ល្អ ស្អាត និងការត្រេកអរក្រៃលែងជាដើម ។ ក្នុងអត្ថទាំងនោះ **អភិក្កន្ត** សព្ទ ដែលប្រាកដក្នុងអត្ថថាអស់ទៅ ដូចក្នុងប្រយោគជាដើមថា **អភិក្កន្តា ភន្តេ រត្តិ និក្ខន្តោ បឋមោ យាមោ ចិរនិសិន្នោ ភិក្ខុសង្ឃោ** បពិត្រព្រះអង្គដ៏ចម្រើន វេលារាត្រីបឋមយាមកន្លងទៅហើយ ភិក្ខុសង្ឃអង្គុយចាំយូរហើយ ។ ប្រាកដក្នុងអត្ថថា ល្អ ដូចក្នុងប្រយោគជាដើមថា **អយំ ឥមេសំ ចតុន្នំ បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ច** បណ្តាបុគ្គលទាំង ៤ ពួកនេះ បុគ្គលនេះចាត់ថា ល្អជាងផង ប្រសើរជាងផង ។ ប្រាកដក្នុងអត្ថថា ស្អាត ដូចក្នុងប្រយោគជាដើមថា

**កោ មេ វន្ទតិ បាទានិ ឥទ្ធិយា យសសា ជលំ អភិក្កន្តេន វណ្ណេន សព្វា ឱភាសយំ ទិសា** អ្នកណាហ្ន៎ រុងរឿងដោយឫទ្ធិ និងយស មានសម្បុរល្អ ញុំាងទិសទាំងពួងឲ្យភ្លឺ មកថ្វាយបង្គំបាទានៃតថាគត ។ ប្រាកដក្នុងអត្ថថា ត្រេកអរក្រៃលែង ដូចក្នុងប្រយោគជាដើមថា **អភិក្កន្តំ ភន្តេ** បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គ ច្បាស់ណាស់ តែក្នុងបទថា **អភិក្កន្តាយ រត្តិយា** នេះ **អភិក្កន្ត** សព្ទ ប្រាកដក្នុងអត្ថថា ល្អ ។ ដោយហេតុនោះ ទើបលោកពោលពង្រីកសេចក្តីថា បទថា **អភិក្កន្តាយ រត្តិយា** សេចក្តីថា ក្នុងរាត្រីដែលគួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត ។ **ភិក្កន្ត** សព្ទ ក្នុងបទថា **អភិក្កន្តវណ្ណា** នេះ ប្រាកដក្នុងអត្ថថា ស្អាត ។

ឯ **វណ្ណ** សព្ទ ប្រាកដក្នុងអត្ថ មានជាដើមថា ពណ៌សម្បុរ គួរសរសើរ ពួកត្រកូល ហេតុ សណ្ឋាន ប្រមាណ និងរូបាយតនៈ ។ ក្នុងអត្ថទាំងនោះ **វណ្ណ** សព្ទ ប្រាកដក្នុងអត្ថថា ពណ៌សម្បុរ ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា **សុវណ្ណវណ្ណោសិ ភគវា** បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គមានពណ៌សម្បុរដូចមាស ។ ប្រាកដក្នុងអត្ថថា គួរសរសើរ ដូចក្នុងប្រយោគជាដើមនេះថា **កទា សញ្ញូឡ្ហា បន តេ គហបតិ សមណស្ស គោតមស្ស វណ្ណា** នៃគហបតី ក្នុងកាលណា ពណ៌សម្បុររបស់ព្រះសមណគោតម ដែលលោកគួរសរសើរ ។ ប្រាកដក្នុងអត្ថថា ពួកត្រកូល ដូចក្នុងប្រយោគជាដើមថា **ចត្តារោ មេ ភោ គោតម វណ្ណា** បពិត្រព្រះគោតមដ៏ចម្រើន ត្រកូលទាំង ៤ នេះ ។ ប្រាកដក្នុងអត្ថថា ហេតុ ដូច

ក្នុងប្រយោគជាដើមថា **អថ កេន នុ វណ្ណេន គន្ធថេនោតិ វុច្ចតិ** កាលបើដូច្នេះ ព្រោះហេតុអ្វីហ្ន៎ ទើបអ្នកពោលថា ល្អចក្ខិន ។ ប្រាកដក្នុងអត្ថថា សណ្ឋាន ដូចក្នុងប្រយោគជាដើមថា **មហន្តំ ហត្ថិរាជវណ្ណំ អភិនិម្មិនិត្វា** និម្មិតសណ្ឋានជាស្តេចដំរីធំ ។ ប្រាកដក្នុងអត្ថថា ប្រមាណ ដូចក្នុងប្រយោគជាដើមថា **តយោ បត្តស្ស វណ្ណា** បាត្រ ៣ ខ្នាត ។ ប្រាកដក្នុងរូបាយតនៈ ដូចក្នុងប្រយោគជាដើមថា **វណ្ណោ គន្ធោ រសោ ឱជា** រូបាយតនៈ គន្ធាយតនៈ រសាយតនៈ និងផោដ្ឋព្វាយតនៈ **វណ្ណ** នោះ ក្នុងទីនេះ គប្បីជ្រាបថា បានដល់ពណ៌សម្បុរ ដោយហេតុនោះ ទើបលោកពោលពង្រីកសេចក្តីថា បទថា **អភិក្កន្តវណ្ណា** សេចក្តីថា មានពណ៌សម្បុរស្អាត មានពណ៌សម្បុរគួរប្រាថ្នា មានពណ៌សម្បុរគួរពេញចិត្ត ។

**កេវល** សព តបទថា **កេវលកប្បំ** នេះ មានអត តិចដូចជាមិនមានចំណែកសេសសល់ ច្រើន មិនមានលាយឡំ មិនលើស តម្កល មិនប្រកប ពិតយ៉ាងនោះ **កេវល** សព្ទនោះ មានអត្ថមិនមានសេសសល់ ដូចក ប្រយោគជាដើមថា **កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ** ទ្រង ប្រកាសព្រហ្មចរិយ ដ៏ពេញ បរិបូណ៌បរិសុទ ង អស ។ មក ក អត ដោយច្រើន ដូចក ប្រយោគជាដើមថា **កេវលកប្បា ច អង្គមគធា បហូតំ ខាទនីយំ ភោជនីយំ អាទាយ អភិក្កមិតុកាមា ហោន្តិ** ព្រោះថា ជនអ ទៅក ដែនអង្គៈ និងមគធៈទាំងអស ប្រាថ ងនាំយកខាទនីយភោជនីយាហារ មានប្រមាណច្រើន ចូលមកបូជា ។ មកក អត មិនមានលាយឡំ ដូច

*ក្នុងប្រយោគជាដើមថា* **កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ** *សេចក្តីកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងមានយ៉ាងនេះឯង ។ មកក្នុងអត្ថថា មិនលើស ដូចក្នុងប្រយោគជាដើមថា* **កេវលំ សទ្ធាមត្តកំ នូន អយមាយស្មា** *ព្រោះអាស្រ័យនូវគុណធម៌ ត្រឹមតែសទ្ធាប៉ុណ្ណោះដោយពិត ។ មកក្នុងអត្ថថា តម្កល់មាំ ដូចក្នុងប្រយោគជាដើមថា* **កេវលកប្បំ សង្ឃ-ភេទាយ ឋិតោ** *សទ្ធិវិហារិករបស់អនុរុទ្ធមានអាយុ ឈ្មោះវាហិយៈ នៅតែទទូចដើម្បីបំបែកឃ្លាងមុតមាំ ។ មកក្នុងអត្ថថា បែកគ្នា ដូចក្នុងប្រយោគជាដើមថា* **កេវលី វុសិតវា ឧត្តមបុរិសោតិ វុច្ចតិ** *ម្នាលភិក្ខុទាំងឡាយ ភិក្ខុលះអង្គ ៥ ប្រកបដោយអង្គ ៥ ហៅថា ជាឧត្តមបុរស មានគុណគ្រប់គ្រាន់ ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងធម្មវិន័យនេះ ដូច្នេះ ។ មានអត្ថថា មិនប្រកប ដូចក្នុងពាក្យជាដើមថា* **កេវលី វុសិត្វា ឧត្តមបុរិសោតិ វុច្ចតិ** *តថាគតពោលថាជាបុរសឧត្តម មានកិច្ចបានធ្វើអស់ហើយ មានព្រហ្មចរិយធម៌នៅរួចហើយ ។ តែក្នុងទីនេះ លោកបំណងយកអត្ថថា មិនមានចំណែកសេសសល់ ជាអត្ថរបស់* **កេវល** *សព្ទនោះ ។*

*ចំណែក* **កប្ប** *មានអត្ថច្រើនយ៉ាង ដូចជាការជឿយ៉ាងក្រៃលែង វោហារ កាលបរិច្ឆេទ ការកាត់ វិកប្ប លេស ដោយជុំវិញ ។ មានអធិប្បាយថា* **កប្ប** *សព្ទ មកក្នុងអត្ថថា ការជឿយ៉ាងក្រៃលែង ដូចក្នុងប្រយោគជាដើមថា* **ឱកប្ប ឆីយមេតំ ភោតោ គោតមស្ស យថា តំ អរហតោ សម្មាសម្ពុទ្ធស្ស** *ពាក្យរបស់ព្រះគោតមដ៏ចម្រើន ដែលជាអរហន្តសម្មាសម្ពុទ្ធនេះ ជាពាក្យគួរជឿពិតហើយ ។ មកក្នុងអត្ថថា វោហារ*

ដូចក្នុងប្រយោគជាដើមថា **អនុជានាមិ ភិក្ខវេ បញ្ចហិ សមណកប្បេហិ ផលំ បរិភុញ្ជិតុំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់ផ្លែឈើ ដោយសមណកប្ប ៥ យ៉ាង ។ មកក្នុងអត្ថថា កាល ដូចក្នុងប្រយោគជាដើមថា **យេន សុទំ និច្ចកប្បំ វិហរាមិ** តថាគតនោះឯង តែងនៅអស់កាលជានិច្ច ។ មកក្នុងអត្ថថា បញ្ញត្តិ ដូចក្នុងប្រយោគជាដើមថា **ឥច្ចាយស្មា កប្បោ** កប្បមាណពដ៏មានអាយុទូលសួរថា ។ មកក្នុងអត្ថថា កាត់ ដូចក្នុងប្រយោគជាដើមថា **អលង្កតោ មាលធរោ សុវត្ថោ សុក្កុណ្ឌលី កប្បិតកេសមស្សុ** អង្គមានខ្លួនប្រដាប់ហើយ ទ្រទ្រង់នូវកម្រងផ្កា ស្លៀកដណ្ដប់ល្អមានប្រដាប់ត្រចៀកល្អមានសក់និងពុកចង្កាកាត់ចោលហើយ ។ មកក្នុងអត្ថថា វិកប្ប ដូចក្នុងប្រយោគជាដើមថា **កប្បតិ ទ្វង្គុលកប្បោ** កំណត់ដោយស្រមោលព្រះអាទិត្យប្រែទៅប្រមាណពីរធ្នាប់ គួរ ។ មកក្នុងអត្ថថា លេស ដូចក្នុងប្រយោគជាដើមថា **អត្ថិ កប្បោ និបជ្ជិតុំ** បើដូច្នោះអាត្មាអញដេកសិន ។ មកក្នុងអត្ថថា ដោយជុំវិញ ដូចក្នុងប្រយោគជាដើមថា **កេវលកប្បំ ជេតវនំ ឱភាសេត្វា** ញុំាងវត្តជេតពនឲ្យភ្លឺស្វាងដោយជុំវិញ ។ តែក្នុងទីនេះ លោកបំណងយកអត្ថថា ដោយជុំវិញ ជាអត្ថរបស់ **កប្ប** សព្ទនោះ ។ ព្រោះដូច្នោះ ក្នុងបទថា **កេវលកប្បំ ជេតវនំ** នេះ ទើបមានអត្ថថា ញុំាងវត្តជេតពនឲ្យភ្លឺស្វាងដោយជុំវិញ មិនមានសេសសល់ ។

បទថា **ឱភាសេត្វា** បានដល់ ផ្សាយរស្មីទៅ ។ បទថា **វាលុកាយ** បានដល់ខ្សាច់ល្អិត ។ បទថា **ន សណ្ឋាតិ** សេចក្ដីថា មិនឈរ ។ បទថា **ឱឡារិកំ** សេចក្ដីថា ព្រោះក្នុងកាលដែលព្រហ្ម និងទេវតាឈររត្រង់ផែនដី

គួរនិម្មិតអត្តភាពឲ្យគ្រោតគ្រាត ឬនិម្មិតផែនដី ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះ ដោយបទថា **ធម្មា** នេះ ទ្រង់សម្ដែងដល់ព្រះពុទ្ធវចនៈដែលហត្ថកទេវបុត្រធ្លាប់រៀនមកក្នុងកាលមុន ។ បទថា **ធម្ម-វត្តិនោ អហេសុំ** សេចក្ដីថា ធម៌ទាំងឡាយបានវិនាសទៅចាកការពោលរបស់បុគ្គលដែលមិនស្ទាធ្យាយ ។ បទថា **អប្បដិវាណោ** សេចក្ដីថា មិនវិលត្រឡប់ គឺមិនអផ្សុក ។ បទថា **ទស្សនស្ស** សេចក្ដីថា ចំពោះការឃើញចក្ខុវិញ្ញាណ ។ បទថា **ឧបដ្ឋានស្ស** សេចក្ដីថា ចំពោះការទំនុកបម្រុងដោយបច្ច័យ ៤ ។ បទថា **អធិសីលំ** បានដល់ សីល ១០ ។ ព្រោះថា សីល ១០ នោះ ព្រះមានព្រះភាគត្រាស់ហៅថា អធិសីល ព្រោះប្រៀបធៀបនឹងបញ្ចសីល ។ ដោយបទថា **អវិហំ គតោ** ហត្ថកទេវបុត្រសម្ដែងថា ខ្ញុំព្រះអង្គកើតហើយ ក្នុងព្រហ្មលោកជាន់អវិហា ។៙

## អដ្ឋកថាហត្ថកសូត្រទី ៥ ចប់

# សុត្តន្តបិដក

## កដុវិយសូត្រទី ៦

[ ១៣០ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។ គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់ស្បង់ ប្រដាប់បាត្រ និងចីវរក្នុងវេលាបុព្វណ្ហសម័យ ទ្រង់ចូលទៅកាន់ក្រុងពារាណសី ដើម្បីបិណ្ឌបាត ។ កាលព្រះដ៏មានព្រះភាគទ្រង់ស្តេចទៅបិណ្ឌបាតក្នុងសម្នាក់ នៃមិលក្ខជន អ្នកលក់គោ ទ្រង់បានឃើញភិក្ខុមួយរូប មានសេចក្តីត្រេកអរ តិច មានសេចក្តីត្រេកអរខាងក្រៅ ប្រាសចាកសតិ មិនមានប្រាជ្ញា មានចិត្ត មិនតាំងមាំ មានចិត្តវើវវាយ មានឥន្ទ្រិយជាប្រក្រតី ( មិនរក្សាឥន្ទ្រិយ ) លុះទតឃើញហើយ ទ្រង់មានព្រះវាចានឹងភិក្ខុនោះ ដូច្នេះថា ម្នាលភិក្ខុ អ្នក កុំធ្វើខ្លួនឲ្យស្អុយឡើយ ម្នាលភិក្ខុ ពួករុយនឹងមិនចោមរោមតាម នឹងមិនតាម ចោមស៊ីនូវខ្លួនដែលធ្វើឲ្យស្អុយ ដែលប្រឡាក់វត្ថុ មានក្លិនឆ្អេះឆ្អាបនោះ ហេតុនុ៎ះ មិនមានទេ ។ លំដាប់នោះឯង ភិក្ខុនោះ លុះព្រះដ៏មានព្រះភាគ ទូន្មានដោយឱវាទនេះហើយ ក៏ដល់នូវសេចក្តីសំវេគ ( បានជាសោតាបន្នបុគ្គល ) ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្តេចទៅដើម្បីបិណ្ឌបាត ក្នុងក្រុងពារាណសី លុះស្តេចត្រឡប់មកអំពីបិណ្ឌបាតក្នុងវេលាខាងក្រោយ ភត្ត ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ក្នុងទីឯណោះ តថាគតបានស្លៀកស្បង់ ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយ ចូលទៅកាន់ក្រុងពារាណសី ដើម្បីបិណ្ឌបាត ម្នាលភិក្ខុទាំងឡាយ កាល តថាគតត្រាច់ទៅដើម្បីបិណ្ឌបាត ក្នុងសម្នាក់នៃមិលក្ខជន អ្នកលក់គោ ក៏បាន

ឃើញភិក្ខុមួយរូប មានសេចក្តីត្រេកអរតិច មានសេចក្តីត្រេកអរខាងក្រៅ ប្រាសចាកសតិ មិនមានប្រាជ្ញា មានចិត្តមិនតាំងមាំ មានចិត្តរវើរវាយ មានឥន្ទ្រិយជាប្រក្រតី លុះបានឃើញហើយ និយាយនឹងភិក្ខុនោះដូច្នេះថា ម្នាលភិក្ខុ អ្នកកុំធ្វើខ្លួនឲ្យស្អុយឡើយ ម្នាលភិក្ខុ ពួករុយនឹងមិនចោមរោមតាម មិនតាមរោមស៊ីនូវខ្លួន ដែលធ្វើឲ្យស្អុយ ដែលប្រឡាក់វត្ថុ មានក្លិនឆ្អេះឆ្អាប នោះ ហេតុនុ៎ះ មិនមានទេ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ភិក្ខុនោះ លុះតថាគតទូន្មានដោយឱវាទនេះហើយ ក៏ដល់នូវសេចក្តីសំវេគ ។ កាលព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុមួយរូបបានក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ ជារបស់ស្អុយ អ្វីជារបស់មានក្លិនឆ្អេះឆ្អាប អ្វីជារុយ ។ ម្នាលភិក្ខុ អភិជ្ឈា ជារបស់ស្អុយ ព្យាបាទជារបស់មានក្លិនឆ្អេះឆ្អាប អកុសលវិតក្កដ៏លាមកជាតួរុយ ។ ម្នាលភិក្ខុ ពួករុយនឹងមិនចោមរោមតាម នឹងមិនតាមចោមស៊ីនូវខ្លួន ដែលធ្វើឲ្យស្អុយ ដែលប្រឡាក់វត្ថុ មានក្លិនឆ្អេះឆ្អាបនោះ ហេតុនុ៎ះ មិនមានទេ ។

ពួករុយ គឺសេចក្តីត្រិះរិះដែលអាស្រ័យនូវរាគៈ នឹងតាមរោមនូវបុគ្គលដែលមិនគ្រប់គ្រងក្នុងចក្ខុទ្វារ និងសោតទ្វារ មិនសង្រួមក្នុងឥន្ទ្រិយ ។ ភិក្ខុដែលធ្វើខ្លួនឲ្យស្អុយ ប្រឡាក់វត្ថុមានក្លិនឆ្អេះឆ្អាប ជាអ្នកឆ្ងាយអំពីព្រះនិព្វាន មានចំណែកនៃសេចក្តីចង្អៀតចង្អល់ចិត្តតែម្យ៉ាង ។ បុគ្គលពាល អប្បឥតប្រាជ្ញា ដែលពួករុយ

តាមរោម ( នោះ ) មិនបានប្រព្រឹត្តនូវធម៌ ដ៏ស្មោះ
ស្មើដើម្បីខ្លួនក្នុងស្រុក ឬក្នុងព្រៃឡើយ ។ ចំណែក
ខាងជនណា បរិបូណ៌ដោយសីល និងបញ្ញា ត្រេកអរ
ក្នុងធម៌ជាគ្រឿងរម្ងាប់នូវកិលេស ជាអ្នកស្ងប់ស្ងាត់
ជននោះ រមែងដេកជាសុខ ទាំងពួករុយ ក៏មិនបាន
ហើរតាមស៊ីជននោះឡើយ ។

# អដ្ឋកថា

## កដុវិយសូត្រ

[ ១៣០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកដុវិយសូត្រទី ៦ ដូចតទៅនេះ បទថា **គោយោគមិលក្ខុស្មឹ** សេចក្ដីថា ក្នុងសម្នាក់នៃមនុស្សព្រៃ ដែលប្រាកដខ្លួនក្នុងផ្សារ លក់ដូរគោ ។ បទថា **រិត្តស្សាទំ** សេចក្ដីថា ដាច់នូវការត្រេកអរ ព្រោះមិនមានសេចក្ដីសុខដែលកើតអំពីឈាន ។ បទថា **ពាហិ-រស្សាទំ** សេចក្ដីថា មានការត្រេកអរក្នុងសេចក្ដីសុខខាងក្រៅ ដោយអំណាចសេចក្ដីសុខ ដែលកើតអំពីកាមគុណ ។ បទថា **កដុវិយំ** បានដល់ របស់ដែលគេបោះចោលហើយ ។ បទថា **អាមគន្ធេ** សេចក្ដីថា មានក្លិនធ្លាបឆ្អេះពោល គឺសេចក្ដីក្រោធ ។ បទថា **អវស្សុតំ** សេចក្ដីថា សើមហើយ ។ រុយ

*ពោល គឺកិលេស ឈ្មោះថា* **មក្ខិកា** ។ *បទថា* **ឆានុបតិស្សន្តិ** *សេចក្តីថា នឹងមិនហើរតាមទៅ ។ បទថា* **ឆាន្វាស្សវិស្សន្តិ** *សេចក្តីថា នឹងមិនតាមទៅបោមពោម ។ បទថា* **សំវេគមាចាធិ** *បានដល់ ជាព្រះសោតាបន្ន ។ បទថា* **កដុវិយការោ** *សេចក្តីថា ធ្វើឲ្យជារបស់ខូច ។ បទថា* **អារកា** **ហោតិ** *សេចក្តីថា មានក្នុងទីឆ្ងាយ ។ បទថា* **វិឃាតស្សេវ** **ភាគវា** *សេចក្តីថា មានចំណែកនៃទុក្ខនោះឯង ។ បទថា* **ចរេ** *ប្រែថា រមែងត្រាច់ទៅ ។ បទថា* **ធុម្មេធោ** *បានដល់ ជាអ្នកមានបញ្ញាថោកថយ ។ ក្នុងព្រះសូត្រនេះ ត្រាស់វដ្ដៈតែម្យ៉ាងប៉ុណ្ណោះ ។ តែក្នុងគាថាទាំងឡាយ ត្រាស់វដ្ដៈផង និងវិវដ្ដៈផង ។*

## អដ្ឋកថា កដុវិយសូត្រទី ៦ ចប់

# សុត្តន្តបិដក

## អន្ធុរុទ្ធសូត្រទី ៧

[ ១៣១ ] គ្រានោះ ព្រះអនុរុទ្ធដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអនុរុទ្ធដ៏មានអាយុ គង់ក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់ចក្ខុជារបស់មនុស្សធម្មតា ឃើញមាតុគ្រាម ដែលបែកធ្លាយរាងកាយស្លាប់ទៅ ច្រើនតែទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ។ បពិត្រព្រះអង្គដ៏ចម្រើន មាតុគ្រាមប្រកបដោយធម៌ប៉ុន្មានយ៉ាង លុះបែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ។ ព្រះដ៏មានព្រះភាគត្រាស់តបថា ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៣ យ៉ាង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ។ ប្រកបដោយធម៌ ៣ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលអនុរុទ្ធ ក្នុងលោកនេះ មាតុគ្រាមរមែងមានចិត្តត្រូវមន្ទិល គឺសេចក្តីកំណាញ់រួបរឹត នៅគ្រប់គ្រងផ្ទះ ក្នុងបុព្វណ្ហសម័យ ១ រមែងមានចិត្តត្រូវឥស្សារួបរឹត នៅគ្រប់គ្រងផ្ទះ ក្នុងមជ្ឈន្តិកសម័យ ១ រមែងមានចិត្តត្រូវកាមរាគៈរួបរឹត នៅគ្រប់គ្រងផ្ទះ ក្នុងសាយណ្ហសម័យ ១ ។ ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៣ យ៉ាងនេះឯង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ។

# អដ្ឋកថា

## អនុរុទ្ធសូត្រ

ក្នុងអនុរុទ្ធសូត្រទី ៧ ទ្រង់ត្រាស់វគ្គៈតែម្យ៉ាង ។

អដ្ឋកថាបឋមអនុរុទ្ធសូត្រទី ៧ ចប់

# សុត្តន្តបិដក

## ទុតិយអនុរុទ្ធសូត្រទី ៨

[ ១៣២ ] គ្រានោះ ព្រះអនុរុទ្ធដ៏មានអាយុ ចូលទៅរកព្រះសារីបុត្រដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះសារីបុត្រដ៏មានអាយុ លុះបញ្ចប់ពាក្យគួររីករាយ និងពាក្យគួររឭកហើយ គង់ក្នុងទីសមគួរ ។ លុះព្រះអនុរុទ្ធដ៏មានអាយុ គង់ក្នុងទីសមគួរហើយ ក៏ពោលទៅនឹងព្រះសារីបុត្រដ៏មានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្រ ខ្ញុំតែងឃើញសត្វលោកជាច្រើន ដោយចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុជារបស់មនុស្សធម្មតា មួយទៀត សេចក្តីព្យាយាមដែលខ្ញុំប្រារព្ធហើយ មិនបានរួញរាឡើយ សតិដែលខ្ញុំបានតាំងស៊ប់ហើយ ក៏មិនបានវង្វេងភ្លេច កាយរបស់ខ្ញុំដែលស្ងប់រម្ងាប់ហើយ ក៏មិនបានក្រវល់ក្រវាយ ចិត្តដែលខ្ញុំតម្កល់ខ្ជាប់ហើយ ក៏ជាចិត្តមានអារម្មណ៍មូលតែមួយ កាលបើដូច្នេះ ចិត្តរបស់ខ្ញុំក៏មិនរួចចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ។ ព្រះសារីបុត្រតបថា

ម្នាលអាវុសោអនុរុទ្ធ ត្រង់ពាក្យដែលអ្នកនិយាយយ៉ាងនេះថា ខ្ញុំតែងឃើញសត្វលោកជាច្រើន ដោយចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់ចក្ខុជារបស់មនុស្សធម្មតាដូច្នេះ នេះជាមានះរបស់អ្នក ម្នាលអាវុសោអនុរុទ្ធ មួយទៀត ត្រង់ពាក្យដែលអ្នកនិយាយយ៉ាងនេះថា សេចក្តីព្យាយាមដែលខ្ញុំប្រារព្ធហើយ មិនរួញរាឡើយ សតិដែលខ្ញុំបានតាំងស៊ប់ហើយ ក៏មិនបានវង្វេងភ្លេច កាយរបស់ខ្ញុំដែលស្ងប់រម្ងាប់ហើយ ក៏មិនបានក្រវល់ក្រវាយ ចិត្តដែលខ្ញុំតម្កល់ខ្ជាប់ហើយ ក៏ជាចិត្តមានអារម្មណ៍មូលតែមួយដូច្នេះ នេះជាឧទ្ធច្ចៈរបស់អ្នកទេ ម្នាលអាវុសោអនុរុទ្ធ មួយទៀត ត្រង់ពាក្យដែលអ្នកនិយាយយ៉ាងនេះថា កាលបើដូច្នេះ ចិត្តរបស់ខ្ញុំក៏មិនរួចចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ នេះជាកុក្កុច្ចៈរបស់អ្នក ខ្ញុំសូមរម្ល៉ឹក សូមអនុរុទ្ធដ៏មានអាយុលះបង់ធម៌ទាំង ៣ នេះចេញ កុំធ្វើទុកក្នុងចិត្តនូវធម៌ទាំង ៣ នេះ សូមប្រមូលចិត្តមកក្នុងអមតធាតុវិញ ។ សម័យតមក ព្រះអនុរុទ្ធដ៏មានអាយុ បានលះបង់ធម៌ទាំង ៣ នេះ ហើយមិនធ្វើទុកក្នុងចិត្ត នូវធម៌ទាំង ៣ នេះ ហើយប្រមូលចិត្តក្នុងអមតធាតុ ។ លំដាប់នោះ ព្រះអនុរុទ្ធដ៏មានអាយុតែមួយអង្គឯងចៀសចេញចាកពួកមិនមានសេចក្តីប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ពួកកុលបុត្តចេញចាកផ្ទះ ចូលកាន់ផ្នួសដោយប្រពៃ ដើម្បីអនុត្តរធម៌ណា មិនយូរប៉ុន្មាន លោកក៏បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវអនុត្តរធម៌នោះ ដែលមានព្រហ្មចរិយៈជាទីបំផុត ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន បានដឹងច្បាស់ថា ជាតិអស់

ហើយ មគ្គព្រហ្មចរិយធម៌ អញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះអនុរុទ្ធដ៏មានអាយុក៏ជាព្រះអរហន្តមួយអង្គដែរ ។

# អដ្ឋកថា

## ទុតិយអនុរុទ្ធសូត្រ

[ ១៣២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយអនុរុទ្ធសូត្រទី ៨ ដូចតទៅនេះ បទថា **ឥទន្តេ មានស្មឹ** សេចក្តីថា នេះជាមានះ ដែលចម្រើនហើយដោយចំណែក ៩ <u>របស់លោក</u> ។ បទថា **ឥទន្តេ ឧទ្ធច្ចស្មឹ** សេចក្តីថា នេះជាការរាយមាយរបស់លោក គឺការដែលចិត្តរបស់លោករាយមាយ ។ បទថា **ឥទន្តេ កុក្កុច្ចស្មឹ** សេចក្តីថា នេះជាការក្តៅក្រហាយស្តាយក្រោយរបស់លោក ។

**អដ្ឋកថា ទុតិយអនុរុទ្ធសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## បដិច្ឆន្នសូត្រទី ៩

[ ១៣៣ ] ម្នាលភិក្ខុទាំងឡាយ វត្ថុ ៣ យ៉ាងនេះ បិទបាំងទើបប្រសើរ បើកផ្សាយមិនប្រសើរ ។ វត្ថុ ៣ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ គឺមាតុគ្រាមបិទបាំងទើបប្រសើរ បើកផ្សាយ មិនប្រសើរ ១ ម្នាលភិក្ខុទាំងឡាយ មន្តរបស់ពួកព្រាហ្មណ៍ លាក់ទើបប្រសើរ បើកផ្សាយ មិនប្រសើរ ១ ម្នាលភិក្ខុទាំងឡាយ មិច្ឆាទិដ្ឋិ បិទបាំងទើបប្រសើរ បើកផ្សាយ មិនប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ វត្ថុ ៣ យ៉ាងនេះឯង បិទបាំង ទើបប្រសើរ បើកផ្សាយមិនប្រសើរទេ ។ ម្នាលភិក្ខុទាំងឡាយ វត្ថុ ៣ យ៉ាងនេះ បើកទើបរុងរឿង បិទមិនរុងរឿងទេ ។ វត្ថុ ៣ យ៉ាងគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ គឺមណ្ឌលព្រះចន្ទបើកទើបរុងរឿង បិទមិនរុងរឿង ១ ម្នាលភិក្ខុទាំងឡាយ មណ្ឌលព្រះអាទិត្យ បើកទើបរុងរឿង បិទមិនរុងរឿង ១ ម្នាលភិក្ខុទាំងឡាយ ធម្មវិន័យដែលតថាគតសម្តែងហើយ បើកទើបរុងរឿង បិទមិនរុងរឿង ១ ។ ម្នាលភិក្ខុទាំងឡាយ វត្ថុ ៣ យ៉ាងនេះឯង បើកទើបរុងរឿង បិទមិនរុងរឿងទេ ។

# អដ្ឋកថា

## បដិច្ឆន្នសូត្រ

[ ១៣៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបដិច្ឆន្នសូត្រទី ៩ ដូចតទៅនេះ បទថា **វហន្តិ** ប្រែថា រមែងនាំទៅ ។ បទថា **បដិច្ឆន្នោ វហតិ** សេចក្តីថា បិទបាំងហើយ ទើបចេញទៅ ។ ក្នុងបទថា **វិវដោ វិរោចតិ** គប្បីជ្រាបការដែលត្រូវបើកផ្សារដោយចំណែក ៤ យ៉ាង គឺបើកផ្សារដោយចំណែកមួយ ១ បើកផ្សារដោយចំណែកពីរ ១ បើកផ្សារដោយចំណែកផ្ទាល់ខ្លួន ១ បើកផ្សារដោយទូទៅ ១ ។ ក្នុងបណ្តាវត្ថុដែលត្រូវបើកផ្សារ ៤ យ៉ាងនោះ សិក្ខាបទដែលមិនទូទៅដល់ភិក្ខុ និងភិក្ខុនី ឈ្មោះថា បើកផ្សារដោយចំណែកមួយ ។ សិក្ខាបទដែលទូទៅដល់ឧភតោវិភង្គ ឈ្មោះថា បើកផ្សារដោយចំណែកពីរ គុណធម៌ដែលបានត្រាស់ដឹងហើយ ឈ្មោះថា បើកផ្សារចំពោះខ្លួន ។ ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក ឈ្មោះថា វត្ថុដែលបើកផ្សារដោយទូទៅ ៕៚

**អដ្ឋកថា បដិច្ឆន្នសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## លេខសូត្រទី ៣០

[ ១៣៤ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ មានប្រាកដក្នុងលោក ។ បុគ្គល ៣ ពួក ដូចម្តេចខ្លះ ។ គឺបុគ្គលប្រៀបដូចគំនូសថ្ម ១ បុគ្គលប្រៀបដូចគំនូសផែនដី ១ បុគ្គលប្រៀបដូចគំនូសទឹក ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលប្រៀបដូចគំនូសថ្ម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងក្រោធរឿយៗ ឯសេចក្តីក្រោធរបស់គេនោះ រមែងដេកត្រាំនៅអស់កាលយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ គំនូសថ្ម រមែងមិនចាប់រលុបដោយខ្យល់ ឬដោយទឹកទេ ជាគំនូសតាំងនៅអស់កាលយូរ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងក្រោធរឿយៗ ឯសេចក្តីក្រោធរបស់គេនោះ រមែងដេកត្រាំនៅអស់កាលយូរអង្វែង ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលប្រៀបដូចគំនូសថ្ម ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលប្រៀបដូចគំនូសផែនដី តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងក្រោធរឿយៗ តែសេចក្តីក្រោធរបស់គេនោះ មិនបានដេកត្រាំនៅអស់កាលយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ គំនូសផែនដី រមែងចាប់លុបដោយខ្យល់ ឬដោយទឹក ជាគំនូសមិនតាំងនៅអស់កាលយូរ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងក្រោធរឿយៗ តែសេចក្តីក្រោធរបស់គេនោះ មិនបានដេកត្រាំនៅអស់កាលយូរអង្វែង ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ

នេះហៅថា បុគ្គលប្រៀបដូចស្នាមគំនូសផែនដី ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលប្រៀបដូចគំនូសទឹក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ដែលគេនិយាយពាក្យរឹងរូសក្តី និយាយពាក្យអាក្រក់ក្តី និយាយពាក្យមិនជាទីគាប់ចិត្តក្តី តែងឆាប់និយាយតបតទៅវិញ ឆ្លើយឆ្លងស្រួលវិញ រីករាយរកវិញ ។ ម្នាលភិក្ខុទាំងឡាយ គំនូសទឹក រមែងរលុបឆាប់ មិនតាំងនៅអស់កាលយូរ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលគេនិយាយពាក្យរឹងរូសក្តី និយាយពាក្យអាក្រក់ក្តី និយាយពាក្យមិនជាទីគាប់ចិត្តក្តី រមែងឆាប់និយាយតបតទៅវិញ ឆ្លើយឆ្លងស្រួលវិញ រីករាយរកវិញ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលប្រៀបដូចគំនូសទឹក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះឯង មានប្រាកដក្នុងលោក ។

កុសិនារវគ្គទី ៣ ចប់

## ឧទ្ទាននៃកុសិនារវគ្គនោះ គឺ

និយាយអំពីព្រះដ៏មានព្រះភាគ គង់ជិតក្រុងកុសិនារា ១
អំពីពួកភិក្ខុបង្កហេតុ ទាស់ទែងគ្នា ១ អំពីព្រះដ៏មាន
ព្រះភាគ គង់នៅក្នុងគោតមកចេតិយ ១ អំពីករណ្ឌុ-
កាលាមតាបស ១ អំពីហត្ថកទេវបុត្ត ១ អំពីភិក្ខុធ្វើ
ខ្លួនឲ្យស្មុយ ១ អំពីព្រះអនុរុទ្ធ ២ លើក អំពីវត្ថុដែល
បិទបាំង ១ អំពីគំនូស ១ រួបរួមត្រូវជា ១០ ។

# អដ្ឋកថា

## លេខសូត្រ

[ ១៣៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងលេខសូត្រទី ១០ ដូចតទៅនេះ បទថា **អភិណ្ហំ** សេចក្តីថា ជានិច្ច គឺជានិច្ចនិរន្តរ ។ បទថា **អគាឡ្ហេន** សេចក្តីថា ដោយពាក្យធ្ងន់ គឺពាក្យគ្រោតគ្រាត ។ បទថា **ផរុសេន** សេចក្តីថា ដោយពាក្យគ្រោតគ្រាត អធិប្បាយថា ត្រូវប្រកែកយ៉ាងធ្ងន់ យ៉ាងគ្រោតគ្រាត ដូច្នេះ ។ បទថា **អមនាបេន** សេចក្តីថា ដោយពាក្យដែលមិនគាប់ចិត្ត គឺមិនត្រេកអរនៃចិត្ត ។ បទថា **សន្ធិយតិយេវ** សេចក្តីថា នៅធ្វើឲ្យជាប់គ្នា ។ បទថា **សំសន្ទតិយេវ** សេចក្តីថា នៅដូចក្នុងកាលមុននោះឯង ។ បទថា **សម្មោទតិយេវ** សេចក្តីថា ដល់នូវភាពតែមួយ ជាមួយគ្នានោះឯង ។ ពាក្យដ៏សេស ក្នុងបទទាំងពួង ងាយយល់ហើយ ដូច្នេះ ៕

អដ្ឋកថា លេខសូត្រទី ១០ ចប់

កុសិនារវគ្គទី ៣ ចប់

# សុត្តន្តបិដក

# យោធាជីវវគ្គទី ៤

## យោធសូត្រទី ១

[ ១៣៥ ] ម្នាលភិក្ខុទាំងឡាយ យោធាជីវៈ ( អ្នករស់នៅដោយឋានៈជាទាហាន ) ប្រកបដោយអង្គ ៣ ទើបគួរជាយោធាជីវៈរបស់ព្រះរាជា អ្នកបម្រើរបស់ព្រះរាជា ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជា ។ ប្រកបដោយអង្គ ៣ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈក្នុងលោកនេះ ជាអ្នកបាញ់បានឆ្ងាយ ១ ជាអ្នកបាញ់មិនខុស ១ ជាអ្នកទម្លាយគំនរធំៗ បាន ១ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈប្រកបដោយអង្គ ៣ នេះឯងទើបគួរជារបស់ព្រះរាជា ជាអ្នកបម្រើនៃព្រះរាជា ដល់នូវការរាប់ថា ជាអង្គរបស់ព្រះរាជា ។ ម្នាលភិក្ខុទាំងឡាយ ចំណែកភិក្ខុប្រកបដោយធម៌ ៣ យ៉ាង ទើបជាអ្នកគួរទទួលនូវទានដែលគេនាំមកបូជា ។បេ។ ជាស្រែបុណ្យដ៏ប្រសើររបស់សត្វលោក ក៏យ៉ាងនោះដែរ ។ ប្រកបដោយធម៌ ៣ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកបាញ់បានឆ្ងាយ ១ ជាអ្នកបាញ់មិនខុស ១ ជាអ្នកទម្លាយគំនរធំៗ បាន ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបាញ់បានឆ្ងាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ រូបណាមួយជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី រូបណាជិតក្តី ឆ្ងាយក្តី ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវរូបទាំងអស់នុ៎ះ ដោយបញ្ញាដ៏ប្រពៃ តាមសេចក្តីពិត យ៉ាងនេះថា

នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ វេទនាណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី វេទនាណា ជិតក្តី ឆ្ងាយក្តី ភិក្ខុពិចារណាឃើញនូវវេទនាទាំងអស់នុ៎ះ ដោយបញ្ញាដ៏ប្រពៃ តាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ សញ្ញាណាមួយជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី សញ្ញាណា ជិតក្តី ឆ្ងាយក្តី ភិក្ខុពិចារណាឃើញនូវសញ្ញាទាំងអស់នុ៎ះ ដោយបញ្ញាដ៏ប្រពៃ តាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ សង្ខារទាំងឡាយណាមួយជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី សង្ខារទាំងឡាយណា ជិតក្តី ឆ្ងាយក្តី ភិក្ខុពិចារណាឃើញនូវសង្ខារទាំងអស់នុ៎ះ ដោយបញ្ញាដ៏ប្រពៃ តាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ វិញ្ញាណណាមួយជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី វិញ្ញាណណា ជិតក្តី ឆ្ងាយក្តី ភិក្ខុពិចារណាឃើញនូវវិញ្ញាណទាំងអស់នុ៎ះ ដោយបញ្ញាដ៏ប្រពៃ តាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបាញ់បានឆ្ងាយ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបាញ់

មិនខុស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាសេចក្តីរលត់ទុក្ខ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាសេចក្តីប្រតិបត្តិ ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបាញ់មិនខុស យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកទម្លាយគំនរធំៗ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទម្លាយគំនរនៃអវិជ្ជាដ៏ធំបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកទម្លាយគំនរធំៗ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាងនេះឯង ទើបជាអ្នកគួរទទួលនូវទានដែលបុគ្គលនាំមកបូជា ។បេ។ ជាស្រែបុណ្យដ៏ប្រសើររបស់សត្វលោក ។

# អដ្ឋកថា

# យោធាជីវវគ្គទី ៤

## យោធសូត្រ

[ ១៣៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងយោធសូត្រទី ១ នៃយោធជីវវគ្គទី ៤ ដូចតទៅ បុគ្គលដែលចូលទៅអាស្រ័យការច្បាំងដើម្បីចិញ្ចឹមជីវិត ឈ្មោះថា **យោធាជីវោ** ។ បទថា **រាជារហោ** សេចក្តីថា គួរដល់ព្រះរាជា ។ បទថា **រាជាភោគ្គោ** សេចក្តីថា ជាបុគ្គលដែលព្រះរាជាគប្បីប្រើប្រាស់ ។ បទថា **អង្គន្តេវ សង្ខ្យំ គច្ឆតិ** សេចក្តីថា រមែងរាប់ថា ជាអង្គប្រកប ព្រោះចាំបាច់ដោយពិត ដូចដៃ និងជើង ។ បទថា **ទូរេ បាតី ហោតិ** សេចក្តីថា បាញ់ព្រួញទៅបានឆ្ងាយយ៉ាងនេះ គឺក្នុងទីកចម្ងាយប្រមាណមួយឧសភៈ លើគោកចម្ងាយប្រមាណ ៨ ឧសភៈ ឬឆ្ងាយជាងនោះ ។ ពិតហើយ ទាហានរបស់ព្រះបាទទុដ្ឋគាមណិអភ័យ យិតផ្ទុបាញ់បានចម្ងាយ ៩ ឧសភៈ ។ ក្នុងភពចុងក្រោយ ព្រះពោធិសត្វបាញ់បានចម្ងាយ ១ យោជន៍ ។ បទថា **អក្ខណវេធី** បានដល់ បាញ់មិនខុស ម្យ៉ាងទៀត អធិប្បាយថា អាចបាញ់បានរហ័សទាន់ផ្លេកបន្ទោរ ។ បទថា **មហតោ កាយស្ស បទាលេតា** អធិប្បាយថា អាចបាញ់ទម្លុះបន្ទះក្តារ ១០០ បន្ទះដែលតម្រួតគ្នាខ្លះ បន្ទះស្បែកក្របី ១០០ បន្ទះដែលតម្រួតគ្នាខ្លះ បន្ទះកោហៈកម្រាស់ប្រមាណមេដៃខ្លះ បន្ទះក្តារដែលធ្វើដោយឈើផ្ចង់កម្រាស់ ៤ ធ្នាប់ខ្លះ បន្ទះក្តារដែលធ្វើដោយដើមល្វាកម្រាស់ ១

*ធ្លាប់ខ្លះ រទេះដែលដាក់ខ្សាច់បានទម្លុះតាមបណ្តោយខ្លះ ។ បទថា* **យន្តិញ្ចិ រូបំ** *ជាដើម បានឲ្យពិស្តារហើយ ក្នុងគម្ពីរឈ្មោះវិសុទ្ធិមគ្គនោះឯង ។ បទថា* **នេតំ មម** *ជាដើម ព្រះមានព្រះភាគត្រាស់ដោយអំណាចនៃការហាមតណ្ហា មានះ និងទិដ្ឋិ ។ បទថា* **សម្មប្បញ្ញាយ បស្សតិ** *សេចក្តីថា ពិចារណាឃើញដោយមគ្គបញ្ញា មួយអន្លើដោយវិបស្សនាដោយប្រពៃ គឺដោយហេតុដោយការណ៍ ។ បទថា* **បទាលេតិ** *សេចក្តីថា រមែងទម្លាយដោយអរហត្តមគ្គ ៗ។*

**អដ្ឋកថា យោធសូត្រទី ១ ចប់**

# សុត្តន្តបិដក

## បរិសាសូត្រទី ២

*[ ១៣៦ ] ម្នាលភិក្ខុទាំងឡាយ បរិសទ្យនេះ មាន ៣ ពួក ។ បរិសទ្យ ៣ ពួក គឺអ្វីខ្លះ ។ គឺបរិសទ្យដែលសិក្សាផ្តេសផ្តាស ១ បរិសទ្យដែលសាកសួររួច ទើបសិក្សា ១ បរិសទ្យដែលសិក្សាតាមកំណត់ ១ ។ ម្នាលភិក្ខុទាំងឡាយ បរិសទ្យមាន ៣ ពួកនេះឯង ។*

# អដ្ឋកថា

## បរិសាសូត្រ

[ ១៣៦ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងបរិសាសូត្រទី ២ ដូចតទៅនេះ បទថា* **ឧក្កាចិតវិនីតា** *បានដល់ បរិស័ទដែលដឹកនាំដោយមិនបានសាកសួរ គឺបរិស័ទដែលទូន្មានបានលំបាក ។ បទថា* **បដិបុច្ឆាវិនីតា** *បានដល់ បរិស័ទដែលណែនាំដោយសាកសួរ គឺបរិស័ទដែលទូន្មានបានងាយ ។ បទថា* **យាវតជ្ឈាវិនីតា** *បានដល់ បរិស័ទដែលណែនាំដោយគោលដែលគួរណែនាំល្មមប្រមាណ អធិប្បាយថា បានដល់ បរិស័ទដែលត្រូវទូន្មានដោយដឹងប្រមាណ ។ អត្ថនៃព្រះបាលីថា* **យាវតជ្ឈា** *ស្មើគ្នានឹង* **យាវ អជ្ឈាសយា** *ប្រែថា គ្រប់គ្រាន់ដល់អធ្យាស្រ័យ អធិប្បាយថា បរិស័ទដែលបានទទួលការទូន្មានដោយដឹងអធ្យាស្រ័យ ។*

**អដ្ឋកថា បរិសាសូត្រទី ២ ចប់**

# សុត្តន្តបិដក

## មិត្តសូត្រទី ៣

[ ១៣៧ ] ម្នាលភិក្ខុទាំងឡាយ មិត្តប្រកបដោយអង្គ ៣ គួរសេពគប់ ។ ប្រកបដោយអង្គ ៣ គឺអ្វីខ្លះ ។ គឺមិត្តឲ្យវត្ថុដែលគេឲ្យបានដោយក្រ ១ ធ្វើនូវអំពើដែលគេធ្វើបានដោយក្រ ១ អត់ធន់នូវហេតុដែលគេអត់ធន់បានដោយក្រ ១ ។ ម្នាលភិក្ខុទាំងឡាយ មិត្តប្រកបដោយអង្គ ៣ នេះឯង គួរសេពគប់ ។

## អដ្ឋកថា

### មិត្តសូត្រ

ក្នុងមិត្តសូត្រទី ៣ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាមិត្តសូត្រទី ៣ ចប់

# សុត្តន្តបិដក

## ឧប្បាទសូត្រទី ៤

[ ១៣៨ ] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគតទាំងឡាយកើតឡើងក្តី ព្រះតថាគតទាំងឡាយ មិនទាន់កើតឡើងក្តី ធាតុនោះ ធម្មដ្ឋិតិនោះ ធម្មនិយាមនោះ តែងស្ថិតនៅជាធម្មតា គឺថាសង្ខារទាំងឡាយទាំងពួងមិនទៀង ។ ព្រះតថាគតត្រាស់ដឹង យល់ច្បាស់នូវធាតុជាដើមនោះ លុះត្រាស់ដឹងយល់ច្បាស់ហើយ ក៏ប្រាប់ សម្តែង បញ្ញត្ត តាំងផ្តើម បើកបង្ហើប ចែករំលែក ធ្វើឲ្យរាក់ថា សង្ខារទាំងពួងមិនទៀង ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគតទាំងឡាយកើតឡើងក្តី ព្រះតថាគតទាំងឡាយមិនទាន់កើតឡើងក្តី ធាតុនោះ ធម្មដ្ឋិតិនោះ ធម្មនិយាមនោះ តែងស្ថិតនៅជាធម្មតា គឺថាសង្ខារទាំងពួងជាទុក្ខ ។ ព្រះតថាគតរមែងត្រាស់ដឹង យល់ច្បាស់នូវធាតុជាដើមនោះ លុះត្រាស់ដឹង យល់ច្បាស់ហើយ ក៏ប្រាប់សម្តែង បញ្ញត្ត តាំងផ្តើម បើកបង្ហើប ចែករំលែក ធ្វើឲ្យរាក់ថា សង្ខារទាំងពួងជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគតទាំងឡាយកើតឡើងក្តី ព្រះតថាគតទាំងឡាយមិនទាន់កើតឡើងក្តី ធាតុនោះ ធម្មដ្ឋិតិនោះ ធម្មនិយាមនោះ តែងស្ថិតនៅជាធម្មតា គឺថាធម៌ទាំងឡាយទាំងពួងជាអនត្តា ។ ព្រះតថាគតត្រាស់ដឹង យល់ច្បាស់នូវធាតុជាដើមនោះ លុះត្រាស់ដឹង យល់ច្បាស់ហើយ ក៏ប្រាប់ សម្តែង បញ្ញត្ត តាំងផ្តើម បើកបង្ហើប ចែករំលែក ធ្វើឲ្យរាក់ថា ធម៌ទាំងឡាយ ទាំងពួងជាអនត្តា ។

# អដ្ឋកថា

## ឧប្បាទសូត្រ

[ ១៣៨ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងឧប្បាទសូត្រទី ៤ ដូចតទៅនេះ បទថា* **ធម្មដ្ឋិតតា** *បានដល់ ភាវៈដែលទ្រទ្រង់បានឯង តាមសភាវៈ ។ បទថា* **ធម្មនិយាមតា** *បានដល់ ពិតប្រាកដដោយសភាវៈ ។ បទថា* **សព្វេ សង្ខារា** *បានដល់ សង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ បទថា* **អនិច្ចា** *សេចក្ដីថា ឈ្មោះថា អនិច្ចា ដោយអត្ថថា មានហើយ ត្រឡប់ជាមិនមាន ។ បទថា* **ទុក្ខា** *សេចក្ដីថា ឈ្មោះថា ទុក្ខ ព្រោះអត្ថថា គ្របសង្កត់ជានិច្ច ។ បទថា* **អនត្តា** *សេចក្ដីថា ឈ្មោះថា អនត្តា ព្រោះអត្ថថា មិនប្រព្រឹត្តទៅតាមអំណាច ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់លក្ខណៈទាំង ៣ លាយគ្នា ដូចពណ៌នាមក ដូច្នេះ ៕*

### អដ្ឋកថា ឧប្បាទសូត្រទី ៤ ចប់

# សុត្តន្តបិដក

## កេសកម្ពលសូត្រទី ៥

[ ១៣៩ ] ម្នាលភិក្ខុទាំងឡាយ សំពត់ទាំងឡាយណាមួយ ដែលគេត្បាញដោយតម្បាញ សំពត់កម្ពលដែលគេត្បាញដោយសក់មនុស្ស ប្រាកដជាអាក្រក់បំផុតជាងសំពត់ទាំងនោះ ម្នាលភិក្ខុទាំងឡាយ សំពត់កម្ពលដែលគេត្បាញដោយសក់មនុស្ស ត្រជាក់ក្នុងពេលត្រជាក់ ក្តៅក្នុងពេលក្តៅ មានសម្បុរអាក្រក់ មានក្លិនអាក្រក់ មានសម្ផស្សអាក្រក់ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ វាទៈនៃសមណៈច្រើននាក់ណាមួយ វាទៈនៃគ្រូឈ្មោះមក្ខលិ ប្រាកដជាអាក្រក់ជាងវាទៈនៃសមណៈទាំងនោះ ក៏យ៉ាងនោះដែរ ម្នាលភិក្ខុទាំងឡាយ មក្ខលិ ជាមោឃបុរស មានសេចក្តីប្រកាន់យ៉ាងនេះ មានការយល់ឃើញយ៉ាងនេះថា កម្មមិនមាន អំពើដែលត្រូវធ្វើមិនមាន សេចក្តីព្យាយាមមិនមាន ។ ម្នាលភិក្ខុទាំងឡាយ ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយណា ក្នុងអតីតកាល ព្រះអរហន្តសម្មាសម្ពុទ្ធដ៏មានព្រះភាគទាំងនោះ ជាកម្មវាទផង ជាកិរិយវាទផង ជាវិរិយវាទផង ។ ម្នាលភិក្ខុទាំងឡាយ មក្ខលិជាមោឃបុរស ហាមឃាត់នូវព្រះអរហន្តសម្មាសម្ពុទ្ធនោះថា កម្មមិនមាន អំពើដែលត្រូវធ្វើមិនមាន សេចក្តីព្យាយាមមិនមាន ។ ម្នាលភិក្ខុទាំងឡាយ ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយណា ក្នុងអនាគតកាល ព្រះអរហន្តសម្មា-សម្ពុទ្ធដ៏មានព្រះភាគទាំងនោះ ជាកម្មវាទផង ជាកិរិយវាទផង ជាវិរិយវាទផង ។ ម្នាលភិក្ខុទាំងឡាយ មក្ខលិជាមោឃបុរស ឈ្មោះថា ហាមឃាត់នូវ

ព្រះអរហន្តសម្មាសម្ពុទ្ធទាំងនោះថា កម្មមិនមាន អំពើដែលត្រូវធ្វើមិនមាន សេចក្តីព្យាយាមមិនមាន ។ ម្នាលភិក្ខុទាំងឡាយ សូម្បីតថាគត ដែលជាអរហន្តសម្មាសម្ពុទ្ធក្នុងកាលឥឡូវនេះ ជាកម្មវាទ ជាកិរិយវាទ ជាវិរិយវាទដែរ ។ ម្នាលភិក្ខុទាំងឡាយ មក្ខលិ ជាមោឃបុរស ហាមឃាត់នូវតថាគតដែរថា កម្មមិនមាន អំពើដែលត្រូវធ្វើមិនមាន សេចក្តីព្យាយាមមិនមាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដាក់លបក្នុងមាត់ស្ទឹង ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដើម្បីសេចក្តីមិនចម្រើន ដើម្បីសេចក្តីវិនាសដល់ត្រីជាច្រើន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ មក្ខលិ ជាមោឃបុរស កើតឡើងក្នុងលោក ដូចជាលបសម្រាប់ដាក់មនុស្ស ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដើម្បីសេចក្តីមិនចម្រើន ដើម្បីសេចក្តីវិនាស ដល់សត្វមានប្រមាណច្រើន ក៏យ៉ាងនោះដែរ ។

# អដ្ឋកថា

## កេសកម្ពលសូត្រ

[ ១៣៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកេសកម្ពលសូត្រទី ៥ ដូចតទៅនេះ បទថា **តន្តាវុតានំ វត្ថានំ** ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃបឋមាវិភត្តិ អធិប្បាយថា បានដល់ សំពត់ដែលត្បាញដោយអំបោះ ។ សំពត់កម្ពលដែលត្បាញ

ដោយសក់មនុស្ស ឈ្មោះថា **កេសកម្ពលោ** ។ បទថា **បរាធានំ** នេះ ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃបឋមាវិភត្តិ ។ បទថា **បដិកិដ្ឋោ** សេចក្ដីថា លទ្ធិក្រោយអាក្រក់ ។ បទថា **មោឃបុរិសោ** ប្រែថា បុរសទទេ គឺបុរសដែលវង្វេង ។ បទថា **បដិពាហាតិ** ប្រែថា បដិសេធ ។ បទថា **ខិបំ ឧឌ្ឌេយ្យ** បានដល់ ដាក់លប ។ល។

**អដ្ឋកថា កេសកម្ពលសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## សម្បទាសូត្រទី៦

[ ១៤០ ] ម្នាលភិក្ខុទាំងឡាយ សម្បទានេះមាន ៣ យ៉ាង ។ សម្បទា ៣ យ៉ាង ដូចម្ដេចខ្លះ ។ គឺសទ្ធាសម្បទា ១ សីលសម្បទា ១ បញ្ញាសម្បទា ១ ។ ម្នាលភិក្ខុទាំងឡាយ សម្បទាមាន ៣ យ៉ាងនេះឯង ។

# អដ្ឋកថា

## សម្បទាសូត្រ

ក្នុងសម្បទាសូត្រទី ៦ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាសម្បទាសូត្រទី ៦ ចប់

# សុត្តន្តបិដក

## វុឌ្ឍិសូត្រទី ៧

[ ១៤១ ] ម្នាលភិក្ខុទាំងឡាយ វុឌ្ឍិ ( សេចក្តីចម្រើន ) នេះមាន ៣ យ៉ាង ។ វុឌ្ឍិ ៣ យ៉ាង ដូចម្តេចខ្លះ ។ គឺសទ្ធាវុឌ្ឍិ ១ សីលវុឌ្ឍិ ១ បញ្ញាវុឌ្ឍិ ១ ។ ម្នាលភិក្ខុទាំងឡាយ វុឌ្ឍិមាន ៣ យ៉ាងនេះឯង ។

# អដ្ឋកថា

## វុឌ្ឍិសូត្រ

ក្នុងវុឌ្ឍិសូត្រទី ៧ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាវុឌ្ឍិសូត្រទី ៧ ចប់

# សុត្តន្តបិដក

## បឋមអស្សសូត្រទី ៨

[ ១៤២ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវគោត្រនៃសេះ ៣ យ៉ាង នូវគោត្រនៃបុរស ៣ យ៉ាង ចូរអ្នកទាំងឡាយស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ក៏ទទួលព្រះតម្រាស់នៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះគោត្រនៃសេះ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គោត្រនៃសេះខ្លះ ក្នុងលោកនេះ ជាវាហនៈ បរិបូណ៌ដោយល្បឿន តែមិនបរិបូណ៌ដោយសម្បុរ មិនបរិបូណ៌ដោយកម្ពស់ និងមាឌ ១ ម្នាលភិក្ខុទាំងឡាយ គោត្រនៃសេះខ្លះ ក្នុងលោកនេះ ជាវាហនៈ បរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង តែមិនបរិបូណ៌ដោយកម្ពស់ និងមាឌ ១ ម្នាលភិក្ខុទាំងឡាយ គោត្រនៃសេះខ្លះ ក្នុងលោកនេះ ជាវាហនៈ បរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង បរិបូណ៌ដោយកម្ពស់ និងមាឌផង ១ ។ ម្នាលភិក្ខុទាំងឡាយ គោត្រនៃសេះមាន ៣ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះគោត្រនៃបុរស ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គោត្រនៃបុរស ក្នុងលោកនេះ ជាអ្នកបរិបូណ៌ដោយល្បឿន តែមិនបរិបូណ៌ដោយសម្បុរ មិនបរិបូណ៌ដោយកម្ពស់ និងមាឌ ១ ម្នាលភិក្ខុទាំងឡាយ គោត្រនៃបុរសខ្លះ ក្នុងលោកនេះ ជាអ្នកបរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង តែមិនបរិបូណ៌ដោយ

កម្ពស់ និងមាឌ ១ ម្នាលភិក្ខុទាំងឡាយ គោត្រនៃបុរសខ្លះ ក្នុងលោកនេះ ជាអ្នកបរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង បរិបូណ៌ដោយកម្ពស់ និងមាឌផង ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះគោត្រនៃបុរស ជាអ្នកបរិបូណ៌ដោយល្បឿន តែមិនបរិបូណ៌ដោយសម្បុរ មិនបរិបូណ៌ដោយកម្ពស់ និងមាឌ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។បេ។ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាបដិបទា ជាដំណើរទៅកាន់សេចក្តីរលត់ទុក្ខ ។ តថាគតហៅថា នេះជាល្បឿនរបស់ភិក្ខុនោះ ។ តែបើភិក្ខុនោះ ត្រូវគេសាកសួរប្រស្នាក្នុងអភិធម្ម ក្នុងអភិវិន័យ រមែងស្ងៀមស្ងាត់ ដោះស្រាយមិនរួច ។ តថាគតហៅថា នេះមិនមែនជាសម្បុររបស់ភិក្ខុនោះ ។ ទាំងភិក្ខុនោះក៏ជាអ្នកថ្នែងលាភ ចំពោះចីវរ បិណ្ឌបាត សេនាសនៈ និងបរិក្ខារ គឺថ្នាំជាបច្ច័យដល់អ្នកជំងឺ ។ តថាគតហៅថា នេះមិនមែនជាកម្ពស់ និងមាឌរបស់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ គោត្រនៃបុរស ជាអ្នកបរិបូណ៌ដោយល្បឿន តែមិនបរិបូណ៌ដោយសម្បុរ មិនបរិបូណ៌ដោយកម្ពស់ និងមាឌយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះគោត្រនៃបុរស ជាអ្នកបរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង តែមិនបរិបូណ៌ដោយកម្ពស់ និងមាឌ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។បេ។ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ តថាគតហៅថា នេះជាល្បឿនរបស់ភិក្ខុនោះ ។ ភិក្ខុនោះកាលបើគេសាកសួរ

ប្រស្នាក្នុងអភិធម្ម ក្នុងអភិវិន័យ រមែងដោះស្រាយរួច មិនស្ទៀមស្ទាត់ ។ តថាគតហៅថា នេះជាសម្បុររបស់ភិក្ខុនោះ ។ តែភិក្ខុនោះ ជាអ្នកថ្នែងលាភ ចំពោះចីវរ បិណ្ឌបាត សេនាសនៈ និងបរិក្ខារ គឺថ្នាំជាបច្ច័យដល់អ្នកជំងឺ ។ តថាគតហៅថា នេះមិនមែនជាកម្ពស់ និងមាឌរបស់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ គោត្រនៃបុរស ជាអ្នកបរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង តែមិនបរិបូណ៌ដោយកម្ពស់ និងមាឌយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះគោត្រនៃបុរស ជាអ្នកបរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង បរិបូណ៌ដោយកម្ពស់ និងមាឌផង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។បេ។ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ តថាគតហៅថា នេះជាល្បឿនរបស់ភិក្ខុនោះ ។ ភិក្ខុនោះកាលបើគេសាកសួរប្រស្នាក្នុងអភិធម្ម ក្នុងអភិវិន័យ រមែងដោះស្រាយរួច មិនស្ទៀមស្ទាត់ ។ តថាគតហៅថា នេះជាសម្បុររបស់ភិក្ខុនោះ ។ ទាំងភិក្ខុនោះក៏ជាអ្នកស្ទាក់លាភ ចំពោះចីវរ បិណ្ឌបាត សេនាសនៈ និងបរិក្ខារ គឺថ្នាំជាបច្ច័យដល់អ្នកជំងឺ ។ តថាគតហៅថា នេះជាកម្ពស់ និងមាឌរបស់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ គោត្រនៃបុរស ជាអ្នកបរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង បរិបូណ៌ដោយកម្ពស់ និងមាឌផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ គោត្រនៃបុរស មាន ៣ យ៉ាងនេះឯង ។

# អដ្ឋកថា

## បឋមអស្សសូត្រ

[ ១៤២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមអស្សសូត្រទី ៨ ដូចតទៅនេះ បទថា **អស្សខលុង្កោ** បានដល់ ពូជសេះខ្ចក ។ បទថា **ឥធមស្ស ជវស្មឹ វទាមិ** សេចក្តីថា តថាគតពោលថា នេះជាសម្ទុះ គឺញាណរបស់ភិក្ខុនោះ ។ បទថា **ឥធមស្ស វណ្ណស្មឹ វទាមិ** សេចក្តីថា តថាគតពោលថា នេះជាពណ៌ គឺគុណរបស់ភិក្ខុនោះ ។ បទថា **ឥធមស្ស អារោហបរិណាហស្មឹ** សេចក្តីថា តថាគតពោលថា នេះជាកម្ពស់ ការស្រស់ស្អាតរបស់ភិក្ខុនោះ ដូច្នេះឯង ៕

### អដ្ឋកថា បឋមអស្សសូត្រទី ៨ ចប់

# សុត្តន្តបិដក

## ទុតិយអស្សសូត្រទី ៩

[ ១៤៣ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំម្តែងនូវសេះរាបសា ៣ ពួកផង នូវបុរសរាបសា ៣ ពួកផង ចូរអ្នកទាំងឡាយស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្ត ដោយប្រពៃចុះ តថាគតនឹងសំម្តែង ។ ភិក្ខុទាំងនោះ ទទួលព្រះតម្រាស់នៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះដ៏

មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះសេះរាបសា ៣ ពួក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេះរាបសាខ្លះ ក្នុងលោកនេះ បរិបូណ៌ដោយល្បឿន តែមិនបរិបូណ៌ដោយសម្បុរ មិនបរិបូណ៌ដោយកម្ពស់ និងមាឌ ១ ម្នាលភិក្ខុទាំងឡាយ សេះរាបសាខ្លះ ក្នុងលោកនេះ បរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង តែមិនបរិបូណ៌ដោយកម្ពស់ និងមាឌ ១ ម្នាលភិក្ខុទាំងឡាយ សេះរាបសាខ្លះ ក្នុងលោកនេះ បរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង បរិបូណ៌ដោយកម្ពស់ និងមាឌផង ១ ។ ម្នាលភិក្ខុទាំងឡាយ សេះរាបសា មាន ៣ ពួកនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ ចុះបុរសរាបសា ៣ ពួក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុរសរាបសាខ្លះ ក្នុងលោកនេះ ជាអ្នកបរិបូណ៌ដោយល្បឿន តែមិនបរិបូណ៌ដោយសម្បុរ មិនបរិបូណ៌ដោយកម្ពស់ និងមាឌ ១ ម្នាលភិក្ខុទាំងឡាយ បុរសរាបសាខ្លះ ក្នុងលោកនេះ បរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង តែទាស់មិនបរិបូណ៌ដោយកម្ពស់ និងមាឌ ១ ម្នាលភិក្ខុទាំងឡាយ បុរសរាបសាខ្លះ ក្នុងលោកនេះ បរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង បរិបូណ៌ដោយកម្ពស់ និងមាឌផង ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសរាបសា ជាអ្នកបរិបូណ៌ដោយល្បឿន តែមិនបរិបូណ៌ដោយសម្បុរ មិនបរិបូណ៌ដោយកម្ពស់ និងមាឌ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាឱបបាតិកកំណើត ( កើតក្នុងសុទ្ធាវាស ) បរិនិព្វានក្នុងសុទ្ធាវាសនោះ មានសភាពមិនត្រឡប់ចាកលោកនោះមកវិញឡើយ ព្រោះ

អស់ទៅនៃឱរម្ភាគិយសញ្ញោជនៈ ៥ តថាគតហៅថា នេះជាល្បឿនរបស់ភិក្ខុនោះ ។ តែបើភិក្ខុនោះត្រូវគេសាកសួរប្រស្នាក្នុងអភិធម្ម ក្នុងអភិវិន័យ រមែងស្ទៀមស្ទាត់ ដោះស្រាយមិនរួច ។ តថាគតហៅថា នេះមិនមែនជាសម្បុររបស់ភិក្ខុនោះ ។ ទាំងភិក្ខុនោះ ជាអ្នកថ្នែងលាភ ចំពោះចីវរ បិណ្ឌបាត សេនាសនៈ និងបរិក្ខារ គឺថ្នាំជាបច្ច័យដល់អ្នកជំងឺ ។ តថាគតហៅថា នេះមិនមែនកម្ពស់ និងមាឌរបស់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ បុរសាភបសា ជាអ្នកបរិបូណ៌ដោយល្បឿន តែមិនបរិបូណ៌ដោយសម្បុរ មិនបរិបូណ៌ដោយកម្ពស់ និងមាឌ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសាភបសា ជាអ្នកបរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង តែមិនបរិបូណ៌ដោយកម្ពស់ និងមាឌ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាឱបបាតិកកំណើត ( កើតក្នុងសុទ្ធាវាស ) បរិនិព្វានក្នុងសុទ្ធាវាសនោះ មានសភាពមិនត្រឡប់ចាកលោកនោះមកវិញឡើយ ព្រោះអស់ទៅនៃឱរម្ភាគិយសញ្ញោជនៈ ៥ ។ តថាគតហៅថា នេះជាល្បឿនរបស់ភិក្ខុនោះ ។ ភិក្ខុនោះ បើត្រូវគេសាកសួរប្រស្នាក្នុងអភិធម្ម ក្នុងអភិវិន័យ រមែងដោះស្រាយរួច មិនស្ទៀមស្ទាត់ ។ តថាគតហៅថា នេះជាសម្បុររបស់ភិក្ខុនោះ ។ តែភិក្ខុនោះឯង ជាអ្នកថ្នែងលាភ ចំពោះចីវរ បិណ្ឌបាត សេនាសនៈ និងបរិក្ខារ គឺថ្នាំជាបច្ច័យដល់អ្នកជំងឺ ។ តថាគតហៅថា នេះមិនមែនជាកម្ពស់និងមាឌរបស់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ បុរសាភបសា ជាអ្នកបរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង តែទាស់មិនបរិបូណ៌ដោយ

កម្ពស់ និងមាឌ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសរាបសា ជាអ្នកបរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង បរិបូណ៌ដោយកម្ពស់និងមាឌផង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាឱបបាតិកកំណើត ( កើតក្នុងសុទ្ធាវាស ) បរិនិព្វានក្នុងសុទ្ធាវាសនោះ មានសភាពមិនត្រឡប់ចាកលោកនោះមកវិញឡើយ ព្រោះអស់ទៅនៃឱរម្ភាគិយសញ្ញោជនៈ ៥ ។ តថាគតហៅថា នេះជាល្បឿនរបស់ភិក្ខុនោះ ។ ភិក្ខុនោះ បើត្រូវគេសាកសួរប្រស្នាក្នុងអភិធម្ម ក្នុងអភិវិន័យ រមែងដោះស្រាយរួច មិនស្ងៀមស្ងាត់ ។ តថាគតហៅថា នេះជាគុណរបស់ភិក្ខុនោះ ។ ទាំងភិក្ខុនោះជាអ្នកស្វាក់លាភ ចំពោះចីវរ បិណ្ឌបាត សេនាសនៈ និងបរិក្ខារ គឺថ្នាំជាបច្ច័យដល់អ្នកជំងឺ ។ តថាគតហៅថា នេះជាកម្ពស់ និងមាឌរបស់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ បុរសរាបសា ជាអ្នកបរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង បរិបូណ៌ដោយកម្ពស់ និងមាឌផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុរសរាបសា មាន ៣ ពួកនេះឯង ។

# អដ្ឋកថា

## ទុតិយអស្សសូត្រ

[ ១៨៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយអស្សសូត្រទី ៩ ដូចតទៅនេះ បទថា **អស្សសទស្សេ** សេចក្តីថា ក្នុងសេះល្អ ក្នុងចំនួនសេះទាំងឡាយ បទថា **បុរិសសទស្សេ** សេចក្តីថា ក្នុងបុគ្គលដែលដូចគ្នានឹងសេះល្អ ក្នុងបុរសទាំងឡាយ អធិប្បាយថា បានដល់ សុភាពបុរស ក្នុងព្រះសូត្រនេះ ត្រាស់មគ្គផល ៣ យ៉ាង ។ ក្នុងបណ្តាបុគ្គល ៣ ប្រភេទនោះ បុគ្គលល្អនេះ គប្បីជ្រាបថា ដល់ព្រមដោយសមុះ គឺញាណដោយមគ្គ ៣ ។៚

**អដ្ឋកថាទុតិយអស្សសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## តតិយអស្សសូត្រទី ១០

[ ១៨៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវសេះអាជានេយ្យដ៏ល្អ ៣ ពួកផង នូវបុរសអាជានេយ្យដ៏ល្អ ៣ ពួកផង ចូរអ្នកទាំងឡាយស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ទទួលព្រះតម្រាស់នៃព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ចុះសេះអាជានេយ្យដ៏ល្អ ៣ ពួក តើ

ដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អខ្លះ ក្នុងលោកនេះ ។បេ។ ជាវាហនៈ បរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង បរិបូណ៌ដោយកម្ពស់ និងមាឌផង ១ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អមាន ៣ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសអាជានេយ្យ ៣ ពួកតើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ល្អខ្លះ ក្នុងលោកនេះ ។បេ។ បរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង បរិបូណ៌ដោយកម្ពស់ និងមាឌផង ១ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសអាជានេយ្យដ៏ល្អជាអ្នកបរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង បរិបូណ៌ដោយកម្ពស់ និងមាឌផង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈព្រោះអស់អាសវៈដោយបញ្ញាដ៏ឧត្ដម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តនៅ ។ តថាគតហៅថា នេះជាល្បឿនរបស់ភិក្ខុនោះ ។ ភិក្ខុនោះ បើគេសាកសួរប្រស្នា ក្នុងអភិធម្ម ក្នុងអភិវិន័យ រមែងដោះស្រាយរួច មិនស្ទៀមស្ទាត់ ។ តថាគតហៅថា នេះជាសម្បុររបស់ភិក្ខុនោះ ។ ទាំងភិក្ខុនោះជាអ្នកស្ទាក់លាភ ចំពោះចីវរ បិណ្ឌបាត សេនាសនៈ និងបរិក្ខារ គឺថ្នាំជាបច្ច័យដល់អ្នកជំងឺ ។ តថាគតហៅថា នេះជាកម្ពស់ និងមាឌរបស់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ល្អ ជាអ្នកបរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង បរិបូណ៌ដោយកម្ពស់ និងមាឌផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ល្អមាន ៣ ពួកនេះឯង ។

# អដ្ឋកថា

## តតិយអស្សសូត្រ

[ ១៨៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតតិយអស្សសូត្រទី ១០ ដូចតទៅនេះ បទថា **ភព្វេ** បានដល់ សេះអាជានេយ្យដ៏ចម្រើន ។ សេះដែលដឹងហេតុគួរ និងមិនគួរ ឈ្មោះថា សេះអាជានេយ្យ សូម្បីក្នុងបុរសអាជានេយ្យក៏មានន័យនេះដូចគ្នា ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់អរហត្តផល ។ បណ្តាបុគ្គល ៣ ប្រភេទ បុរសអាជានេយ្យ គប្បីជ្រាបថា ជាអ្នកសម្បូរដោយសមុះ គឺញាណ ព្រោះអរហត្តមគ្គ ។៚

**អដ្ឋកថា តតិយអស្សសូត្រទី ១០ ចប់**

# សុត្តន្តបិដក

## បឋមមោរនិវាបសូត្រទី ១១

[ ១៨៥ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងបរិញ្វជការាម ជាមោរនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលព្រះតម្រាស់នៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាង

ឈ្មោះថា ជាអ្នកមានសេចក្ដីចូលចិត្តដាច់ស្រេច មានសេចក្ដីក្សេមចាកយោគៈដាច់ស្រេច មានព្រហ្មចរិយៈដាច់ស្រេច មានទីបំផុតដាច់ស្រេច ប្រសើរបំផុតជាងទេវតា និងមនុស្សទាំងឡាយ ។ ប្រកបដោយធម៌ ៣ យ៉ាង គឺអ្វីខ្លះ ។ គឺប្រកបដោយអសេក្ខសីលក្ខន្ធ ១ អសេក្ខសមាធិក្ខន្ធ ១ អសេក្ខ-បញ្ញាខន្ធ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាងនេះឯង ឈ្មោះថាជាអ្នកមានសេចក្ដីចូលចិត្តដាច់ស្រេច មានសេចក្ដីក្សេមចាកយោគៈដាច់ស្រេច មានព្រហ្មចរិយៈដាច់ស្រេច មានទីបំផុតដាច់ស្រេច ជាអ្នកប្រសើរបំផុតជាងទេវតា និងមនុស្សទាំងឡាយ ។

# អដ្ឋកថា

## បឋមមោរនិវាបសូត្រ

[ ១៤៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមមោរនិវាបសូត្រទី ១១ ដូចតទៅ បទថា **អច្ចន្តនិដ្ឋោ** សេចក្ដីថា សម្រេចដោយការឈានកន្លងទីបំផុតនៃទុក្ខ អធិប្បាយថា សម្រេចអកុប្បធម៌ ( ធម៌មិនញាប់ញ័រ ) ។ ពាក្យដ៏សេស ក៏ដូចគ្នានឹងពាក្យដែលពោលហើយនោះឯង ។

**អដ្ឋកថាបឋមមោរនិវាបសូត្រទី ១១ ចប់**

# សុត្តន្តបិដក

## ទុតិយមោរនិវាបសូត្រទី ១២

[ ១៨៦ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាង ឈ្មោះថាជាអ្នកមានសេចក្តីចូលចិត្តដាច់ស្រេច មានសេចក្តីក្សេមចាកយោគៈដាច់ស្រេច មានព្រហ្មចរិយៈដាច់ស្រេច មានទីបំផុតដាច់ស្រេច ជាអ្នកប្រសើរបំផុត ជាងទេវតានិង មនុស្សទាំងឡាយ ។ ប្រកបដោយធម៌ ៣ យ៉ាង គឺអ្វីខ្លះ ។ គឺប្រកបដោយឥទ្ធិប្បាដិហារ្យ ១ អាទេសនាបាដិហារ្យ ១ អនុសាសនីបាដិហារ្យ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាងនេះឯង ឈ្មោះថាជាអ្នកមានសេចក្តីចូលចិត្តដាច់ស្រេច មានព្រហ្មចរិយៈដាច់ស្រេច មានទីបំផុតដាច់ស្រេច ជាអ្នកប្រសើរបំផុត ជាងទេវតានិងមនុស្សទាំងឡាយ ។

# អដ្ឋកថា

## ទុតិយមោរនិវាបសូត្រ

[ ១៨៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយមោរនិវាបសូត្រទី ១២ ដូច្នេះ បទថា **ឥទ្ធិប្បាដិហារិយេន** បានដល់ ដោយការសម្តែងឫទ្ធិដ៏អស្ចារ្យ ។ បទថា **អាទេសនាបាដិហារិយេន** បានដល់ ដោយការពោលចន្លុលបង្ហាញអាងដល់ដ៏អស្ចារ្យ ៕

**អដ្ឋកថា ទុតិយមោរនិវាបសូត្រទី ១២ ចប់**

# សុត្តន្តបិដក

## តតិយមោរនិវាបសូត្រទី ១៣

[ ១៤៧ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាង ឈ្មោះថា ជាអ្នកមានសេចក្តីចូលចិត្តដាច់ស្រេច មានសេចក្តីក្សេមចាកយោគៈដាច់ស្រេច មានព្រហ្មចរិយៈដាច់ស្រេច មានទីបំផុតដាច់ស្រេច ជាអ្នកប្រសើរបំផុតជាងទេវតា និងមនុស្សទាំងឡាយ ។ ប្រកបដោយធម៌ ៣ យ៉ាងគឺអ្វីខ្លះ ។ គឺប្រកបដោយសម្មាទិដ្ឋិ ( ការយល់ប្រពៃ ) ១ សម្មាញាណ ( ការដឹងប្រពៃ ) ១ សម្មាវិមុត្តិ ( ការរួចចាកកិលេសដោយប្រពៃ ) ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាងនេះឯង ឈ្មោះថា ជាអ្នកមានសេចក្តីចូលចិត្តដាច់ស្រេច មានសេចក្តីក្សេមចាកយោគៈដាច់ស្រេច មានព្រហ្មចរិយៈដាច់ស្រេច មានទីបំផុតដាច់ស្រេច ជាអ្នកប្រសើរបំផុត ជាងទេវតា និងមនុស្សទាំងឡាយ ។

យោធាជីវវគ្គទី ៤ ចប់

### ឧទ្ទាននៃយោធាជីវវគ្គនោះ គឺ

និយាយអំពីយោធាជីវៈ ១ អំពីបរិសទ្យ ១ អំពីមិត្ត ១ អំពីព្រះតថាគតកើតឡើង ១ អំពីសំពត់កម្ពលដែលត្បាញដោយសក់មនុស្ស ១ អំពីសម្បទាមានសទ្ធាជាដើម ១ អំពីវុឌ្ឍិ ១ អំពីសេះមាន ៣ លើក ១ អំពីព្រះដ៏មានបុណ្យនៅក្នុងបរិព្វាជការាម ជាមោរនិវាបស្ថាន មាន ៣ លើក ១ ។

# អដ្ឋកថា

## តតិយមោរនិវាបសូត្រ

[ ១៤៧ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងតតិយមោរនិវាបសូត្រទី ១៣ ដូច្នេះ បទថា* **សម្មាទិដ្ឋិយា** *បានដល់ ដោយសម្មាទិដ្ឋិដែលកើតអំពីវិបស្សនា ដើម្បីជាប្រយោជន៍ដល់ផលសមាបត្តិ ។ បទថា* **សម្មាញាណេន** *បានដល់ ដោយផលញ្ញាណ ។ បទថា* **សម្មាវិមុត្តិយា** *បានដល់ ធម៌ គឺផល-សមាបត្តិដ៏សេស ។ ក្នុងសូត្រទាំង ៣ នេះ ព្រះមានព្រះភាគត្រាស់សំដៅដល់ព្រះខីណាស្រពតែម្យ៉ាង ដូច្នេះឯង ។*

**អដ្ឋកថា តតិយមោរនិវាបសូត្រទី ១៣ ចប់**

**យោធាជីវវគ្គទី ៤ ចប់**

# សុត្តន្តបិដក

## មង្គលវគ្គទី ៥

### អកុសលសូត្រទី ១

[ ១៤៨ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាង រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៣ យ៉ាង គឺអ្វីខ្លះ ។ គឺប្រកបដោយកាយកម្មជាអកុសល ១ វចីកម្មជាអកុសល ១ មនោកម្មជាអកុសល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាងនេះឯង រមែងទៅកើតក្នុងនរក ដូចគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។ ប្រកបដោយធម៌ ៣ យ៉ាង គឺអ្វីខ្លះ ។ គឺប្រកបដោយកាយកម្មជាកុសល ១ វចីកម្មជាកុសល ១ មនោកម្មជាកុសល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាងនេះឯង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។

# អដ្ឋកថា

# មង្គលវគ្គទី ៥

## អកុសលសូត្រ

[ ១៤៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអកុសលសូត្រទី ១ នៃមង្គលវគ្គទី ៥ ដូចតទៅ បទថា **យថាភតំ និក្ខិត្តោ** សេចក្តីថា តាមដែលនាំមកវក្យា ។ល។

**អដ្ឋកថា អកុសលសូត្រទី ១ ចប់**

# សុត្តន្តបិដក

## សាវជ្ជសូត្រទី ២

[ ១៤៩ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាង ។បេ។ គឺកាយកម្មប្រកបដោយទោស ១ វចីកម្មប្រកបដោយទោស ១ មនោកម្មប្រកបដោយទោស ១ ។បេ។ គឺកាយកម្មមិនមានទោស ១ វចីកម្មមិនមានទោស ១ មនោកម្មមិនមានទោស ១ ។បេ។

# អដ្ឋកថា

## សាវជ្ជសូត្រ

[ ១៤៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសាវជ្ជសូត្រទី ២ ដូចតទៅនេះ បទថា **សាវជ្ជេន** បានដល់ កម្មដែលមានទោស ។ល។

**អដ្ឋកថា សាវជ្ជសូត្រទី ២ ចប់**

# សុត្តន្តបិដក

## វិសមសូត្រទី ៣

[ ១៥០ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាង ។បេ។ គឺកាយកម្មមិនរាបសា ១ វចីកម្មមិនរាបសា ១ មនោកម្មមិនរាបសា ១ ។បេ។

# អដ្ឋកថា

## វិសមសូត្រ

[ ១៥០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវិសមសូត្រទី ៣ ដូចតទៅនេះ បទថា **វិសមេន** បានដល់ ដោយកម្មដែលមានការក្ដាំងក្ដាត់ ។ បទថា **សមេន** បានដល់ ដោយកម្មដែលប្រាសចាកសេចក្ដីក្ដាំងក្ដាត់ ។ល។

**អដ្ឋកថា វិសមសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## អសុចិសូត្រទី ៤

[ ១៥១ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាង ។បេ។ គឺកាយកម្មមិនស្អាត ១ វចីកម្មមិនស្អាត ១ មនោកម្មមិនស្អាត ១ ។បេ។ គឺកាយកម្មស្អាត ១ វចីកម្មស្អាត ១ មនោកម្មស្អាត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាងនេះឯង រមែងទៅកើតក្នុងស្ថានសួគ៌ដូចជាគេនាំយកទៅតម្កល់ទុក ។

## អដ្ឋកថា

## អសុចិសូត្រ

[ ១៥១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអសុចិសូត្រទី ៤ ដូចតទៅនេះ បទថា **អសុចិនា** បានដល់ ដោយកម្មដែលមិនស្អាត ដូចគ្នានឹងលាមក ។ បទថា **សុចិនា** បានដល់ ដោយកម្មដែលស្អាត ៕

**អដ្ឋកថា អសុចិសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## បឋមខតសូត្រទី ៩

[ ១៥២ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល ជាអ្នកមិនឆ្លៀវឆ្លាស ជាអសប្បុរស ប្រកបដោយធម៌ ៣ យ៉ាង រមែងរក្សាខ្លួនដែលខូចគាស់រម្លើងផ្តាច់ផ្តិល ( នូវគុណ ) ជាអ្នកប្រកបដោយទោសផង ប្រកបដោយដំណៀលរបស់អ្នកប្រាជ្ញផង រមែងបាននូវបាបជាច្រើនផង ។ ប្រកបដោយធម៌ ៣ យ៉ាង គឺអ្វីខ្លះ ។ គឺប្រកបដោយកាយកម្មជាអកុសល ១ វចីកម្មជាអកុសល ១ មនោកម្មជាអកុសល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល ជាអ្នកមិនឆ្លៀវឆ្លាស ជាអសប្បុរស ប្រកបដោយធម៌ ៣ យ៉ាងនេះឯង រមែងរក្សាខ្លួនដែលខូចគាស់រម្លើងផ្តាច់ផ្តិល ( នូវគុណ ) ជាអ្នកប្រកបដោយទោសផង ប្រកបដោយដំណៀលរបស់អ្នកប្រាជ្ញផង រមែងបាននូវបាបជាច្រើនផង ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតជាអ្នកឆ្លៀវឆ្លាស ជាសប្បុរស ប្រកបដោយធម៌ ៣ យ៉ាង រមែងរក្សាខ្លួនដែលមិនគាស់រម្លើង មិនផ្តាច់ផ្តិល ( នូវគុណ ) ជាអ្នកមិនមានទោសផង មិនមានដំណៀលរបស់អ្នកប្រាជ្ញផង រមែងបាននូវបុណ្យជាច្រើនផង ។ ប្រកបដោយធម៌ ៣ យ៉ាង គឺអ្វីខ្លះ ។ គឺប្រកបដោយកាយកម្មជាកុសល ១ វចីកម្មជាកុសល ១ មនោកម្មជាកុសល ១ ។បេ។

# អដ្ឋកថា

## បឋមខតសូត្រ

[ ១៥២ ] ក្នុងបឋមខតសូត្រទី ៥ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាបឋមខតសូត្រទី ៥ ចប់

# សុត្តន្តបិដក

## ទុតិយខតសូត្រទី ៦

[ ១៥៣ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលប្រកបដោយធម៌ ៣ យ៉ាង ។បេ។ គឺកាយកម្មប្រកបដោយទោស ១ វចីកម្មប្រកបដោយទោស ១ មនោកម្មប្រកបដោយទោស ១ ។បេ។ គឺកាយកម្មមិនមានទោស ១ វចីកម្មមិនមានទោស ១ មនោកម្មមិនមានទោស ១ ។បេ។

# អដ្ឋកថា

## ទុតិយខតសូត្រ

[ ១៥៣ ] ក្នុងទុតិយខតសូត្រទី ៦ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាទុតិយខតសូត្រទី ៦ ចប់

# សុត្តន្តបិដក

## តតិយខតសូត្រទី ៧

[ ១៥៤ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលប្រកបដោយធម៌ ៣ យ៉ាង ។បេ។ គឺកាយកម្មមិនរាបសា ១ វចីកម្មមិនរាបសា ១ មនោកម្មមិនរាបសា ១ ។បេ។ គឺកាយកម្មរាបសា ១ វចីកម្មរាបសា ១ មនោកម្មរាបសា ១ ។បេ។

# អដ្ឋកថា

## តតិយខតសូត្រ

[ ១៥៤ ] ក្នុងតតិយខតសូត្រទី ៧ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាតតិយខតសូត្រទី ៧ ចប់

# សុត្តន្តបិដក

## ចតុត្ថខតសូត្រទី ៨

[ ១៥៥ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាង ។បេ។ គឺកាយកម្មមិនស្អាត ១ វចីកម្មមិនស្អាត ១ មនោកម្មមិនស្អាត ១ ។បេ។ គឺកាយកម្មស្អាត ១ វចីកម្មស្អាត ១ មនោកម្មស្អាត ១ ។ ម្នាលភិក្ខុទាំងឡាយ

បណ្ឌិតជាអ្នកឆ្លៀវឆ្លាស ជាសប្បុរស ប្រកបដោយធម៌ ៣ យ៉ាងនេះឯង រមែងរក្សាខ្លួនដែលមិនបានគាស់រម្លើង មិនផ្តាច់ផ្តិល ( នូវគុណ ) ជាអ្នកមិនមានទោសផង មិនមានដំណៀលរបស់អ្នកប្រាជ្ញផង រមែងបាននូវបុណ្យជាច្រើនផង ។

# អដ្ឋកថា

## ចតុត្ថខតសូត្រ

[ ១៥៥ ] ក្នុងចតុត្ថខតសូត្រទី ៨ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាចតុត្ថខតសូត្រទី ៨ ចប់

# សុត្តន្តបិដក

## វន្ទនាសូត្រទី ៩

[ ១៥៦ ] ម្នាលភិក្ខុទាំងឡាយ ការថ្វាយបង្គំនេះមាន ៣ យ៉ាង ។ ការថ្វាយបង្គំ ៣ យ៉ាង ដូចម្តេចខ្លះ ។ គឺថ្វាយបង្គំដោយកាយ ១ ដោយវាចា ១ ដោយចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ការថ្វាយបង្គំមាន ៣ យ៉ាងនេះឯង ។

## អដ្ឋកថា

### វន្ទនាសូត្រ

[ ១៥៦ ] ក្នុងវន្ទនាសូត្រទី ៩ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាវន្ទនាសូត្រទី ៩ ចប់

# សុត្តន្តបិដក

## សុបុព្វណ្ហសូត្រទី ១០

[ ១៥៧ ] ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយណា ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ក្នុងបុព្វណ្ហសម័យ ម្នាលភិក្ខុទាំងឡាយ សត្វទាំងនោះ ឈ្មោះថាមានបុព្វណ្ហសម័យដ៏ល្អ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយណា ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ក្នុងមជ្ឈន្តិកសម័យ ម្នាលភិក្ខុទាំងឡាយ សត្វទាំងនោះ ឈ្មោះថា មានមជ្ឈន្តិកសម័យដ៏ល្អ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយណា ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ក្នុងសាយណ្ហសម័យ ម្នាលភិក្ខុទាំងឡាយ សត្វទាំងនោះ ឈ្មោះថា មានសាយណ្ហសម័យដ៏ល្អ ។

ពេលណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយ
វាចាចិត្ត ពេលនោះ ឈ្មោះថា នក្ខត្តឫក្សល្អ មង្គលល្អ

ពេលភ្លឺស្វាងល្អ ពេលនៃអរុណរះឡើងល្អ ខណៈល្អ យាមល្អ ( ទានដែលបុគ្គលបូជា ) ដល់ព្រហ្មចារីបុគ្គលទាំងឡាយ ( ក្នុងពេលនោះ ) ឈ្មោះថាជាគ្រឿងបូជាល្អ ( ក្នុងថ្ងៃនោះ ) កាយកម្មឈ្មោះថា នាំឲ្យមានសេចក្តីចម្រើន វចីកម្ម ក៏ឈ្មោះថា នាំឲ្យមានសេចក្តីចម្រើន មនោកម្ម ក៏ឈ្មោះថា នាំឲ្យមានសេចក្តីចម្រើន សេចក្តីប្រាថ្នាទាំងឡាយ របស់អ្នកទាំងនោះ ក៏ឈ្មោះថានាំឲ្យមានសេចក្តីចម្រើន បុគ្គលដែលបានធ្វើនូវកាយកម្ម វចីកម្ម មនោកម្ម គួរដល់សេចក្តីចម្រើនហើយ រមែងបាននូវប្រយោជន៍ដ៏ចម្រើនទាំងឡាយ ។ អ្នកទាំងឡាយនោះ ចូរបាននូវប្រយោជន៍ បាននូវសេចក្តីសុខ ចូរចម្រើនក្នុងព្រះពុទ្ធសាសនា ចូរកុំឲ្យមានរោគ ឲ្យបាននូវសេចក្តីសុខ ព្រមទាំងញាតិទាំងឡាយគ្រប់គ្នា ។

**មង្គលវគ្គទី ៥ ចប់**

## ឧទ្ទាននៃមង្គលវគ្គនោះ គឺ

និយាយអំពីបុគ្គលដែលប្រកបដោយកម្មជាអកុសល ១ អំពីកម្មប្រកបដោយទោស ១ ព្រមទាំងកម្មមិនរាបស្មា ១ កម្មមិនស្អាត ១ អំពីបុគ្គលរក្សាខ្លួន ដែលគាស់

រមើង ( គុណ ) ៤ លើក ១ អំពីការថ្វាយបង្គំ ១

អំពីបុញ្ញសម័យល្អ ១ ត្រូវជា ១០ ។

**តតិយបណ្ណាសក ចប់**

# អដ្ឋកថា

## សុបុព្វណ្ហសូត្រ

[ ១៥៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសុបុព្វណ្ហសូត្រទី ១០ ដូចតទៅនេះ ក្នុងពាក្យជាដើមថា **សុនក្ខត្តំ** ថ្ងៃដែលមនុស្សទាំងឡាយបំពេញសុចរិតធម៌ទាំង ៣ ឲ្យបរិបូណ៌ ឈ្មោះថា ជាថ្ងៃដែលបាននូវការប្រកបនក្ខត្តឫក្ស ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ថ្ងៃនោះ មានឫក្សល្អគ្រប់កាល ។ ថ្ងៃនោះឯង ឈ្មោះថា ជាថ្ងៃធ្វើមង្គលហើយ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ថ្ងៃនោះ មានមង្គលល្អគ្រប់កាល ។ ថ្ងៃដែលមានពន្លឺពេញមួយថ្ងៃ ឈ្មោះថា **សុបភាតំ** មានការភ្លឺជាប្រចាំ ។ សូម្បីការក្រោកឡើងអំពីការដេកនៃថ្ងៃនោះ ក៏ឈ្មោះថា **សុហុដ្ឋិតំ** គឺក្រោកឡើងដោយល្អ ។ ខណៈនៃថ្ងៃនោះ ក៏ឈ្មោះថា **សុក្ខណោ** គឺខណៈល្អ ។ យាមនៃថ្ងៃនោះ ក៏ឈ្មោះថា **សុមុហុត្តោ** គឺយាមល្អ ។

ក្នុងបទថា **សុមុហុត្តោ** នេះ គប្បីជ្រាបការចែកពេលដូច្នេះ វេលា

ប្រមាណ ១០ ផ្ទាប់ ឈ្មោះថា ខណៈ វេលា ១០ ផ្ទាប់ដោយខណៈនោះ ឈ្មោះថា **លយ** វេលា ១០ លយៈ ដោយលយៈនោះ ឈ្មោះថា **ខណ-លយ** ។ វេលា ១០ ដង ដោយខណៈលយៈនោះ ឈ្មោះថា **មុហុត្ត** ។ វេលា ១០ ដងដោយមុហុត្តនោះ ឈ្មោះថា **ខណមុហុត្ត** ។

បទថា **សុយិដ្ឋំ ព្រហ្មចារិសុ** សេចក្តីថា ទានដែលបុគ្គលឲ្យក្នុងអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ក្នុងថ្ងៃដែលបំពេញសុចរិត ៣ ឲ្យបរិបូណ៌ហើយ ឈ្មោះថា **សុយិដ្ឋំ** ។ បទថា **បទក្ខិណំ កាយកម្មំ** សេចក្តីថា កាយកម្មដែលបុគ្គលធ្វើហើយក្នុងថ្ងៃនោះ ឈ្មោះថា ជាកាយកម្មប្រកបដោយសេចក្តីចម្រើនក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា **បទក្ខិណានិ កត្វាន** សេចក្តីថា កាលធ្វើកាយកម្មជាដើមដែលប្រកបដោយសេចក្តីចម្រើនហើយ ។ បទថា **លភន្តត្ថេ បទក្ខិណេ** សេចក្តីថា នឹងបានប្រយោជន៍ដែលជាប្រទក្សិណ គឺប្រយោជន៍ដែលប្រកបដោយសេចក្តីចម្រើននោះឯង ។ អត្ថដ៏សេសក្នុងព្រះសូត្រនេះ ងាយយល់ទាំងអស់ហើយ ដូច្នេះ ៕

**អដ្ឋកថាសុបុព្វណ្ហសូត្រទី ១០ ចប់**

**មង្គលវគ្គទី ៥ ចប់**

**តតិយបណ្ណាសក ចប់**

# សុត្តន្តបិដក

## សូត្រមិនសង្គ្រោះចូលក្នុងបណ្ណាសក

[ ១៥៨ ] ម្នាលភិក្ខុទាំងឡាយ បដិបទានេះមាន ៣ យ៉ាង ។ បដិបទា ៣ យ៉ាង គឺអ្វីខ្លះ ។ គឺអាគាឡ្ហប្បដិបទា ( ប្រតិបត្តិគ្រោតគ្រាត ) ១ និជ្ឈាមប្បដិបទា ( ប្រតិបត្តិដុតកម្ដៅខ្លួនហួសហេតុ ) ១ មជ្ឈិមប្បដិបទា ( ប្រតិបត្តិយ៉ាងកណ្ដាល ) ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះអាគាឡ្ហប្បដិបទា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្ដីប្រកាន់យ៉ាងនេះ មានសេចក្ដីយល់ឃើញយ៉ាងនេះថា ទោសក្នុងកាមទាំងឡាយមិនមាន ដូច្នេះ បុគ្គលនោះ រមែងដល់នូវសភាពជាអ្នកធ្លាក់ចុះក្នុងកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាគាឡ្ហប្បដិបទា ។ ម្នាលភិក្ខុទាំងឡាយ ចុះនិជ្ឈាមប្បដិបទា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ គ្មានសំពត់ ( អាក្រាត ) លះបង់មារយាទល្អ ស៊ីលិទ្ធដៃ ឬជម្រះឧច្ចារៈដោយម្រាមដៃ បើគេអញ្ជើញថា ចូរមក ក៏មិនមក គេឃាត់ថា ឈប់ ក៏មិនឈប់ មិនត្រេកអរនឹងភត្តដែលគេនាំមកមុន មិនត្រេកអរនឹងភត្តដែលគេនាំមកចំពោះខ្លួន មិនត្រេកអរនឹងការនិមន្ត បុគ្គលនោះមិនទទួលភត្តអំពីមាត់ឆ្នាំង មិនទទួលភត្តអំពីមាត់កញ្ជើ មិនទទួលភត្តដែលគេនាំមកកន្លងធរណីទ្វារ មិនទទួលភត្តដែលគេនាំមក កន្លងកំណាត់ឈើ មិនទទួលភត្តដែលគេនាំមក កន្លងអង្រែ មិនទទួលភត្តរបស់មនុស្សពីរនាក់ ដែលកំពុងបរិភោគ មិនទទួលភត្តរបស់ស្ត្រីមានគភ៌ មិនទទួលភត្ត

របស់ស្ត្រីដែលកំពុងបំបៅកូន មិនទទួលភត្តរបស់ស្ត្រីដែលកំពុងនៅរួមនឹងបុរស មិនទទួលភត្តក្នុងទីដែលពួកគ្នាឯងណែនាំ មិនទទួលភត្តក្នុងទីដែលមានឆ្កែនៅចាំ មិនទទួលភត្តក្នុងទីដែលមានរុយរោម មិនស៊ីត្រី មិនស៊ីសាច់ មិនផឹកសុរា មិនផឹកមេរ័យ មិនផឹកទឹកត្រាំថ្នាំ បុគ្គលនោះ ទទួលភត្តចំពោះតែក្នុងផ្ទះមួយ ញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយដុំបាយមួយពំនូតខ្លះ ទទួលភត្តចំពោះតែក្នុងផ្ទះពីរ ញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយដុំបាយពីរពំនូតខ្លះ ទទួលភត្តចំពោះតែក្នុងផ្ទះ ៧ ញុំាំងអត្តភាពឲ្យប្រព្រឹតតទៅដោយដុំបាយ ៧ ពំនូតខ្លះ ញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយភត្តក្នុងភាជន៍ ១ ខ្លះ ញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយភត្តក្នុងភាជន៍ ២ ខ្លះ ... ញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយភត្តក្នុងភាជន៍ ៧ ខ្លះ ... ស៊ីអាហាររំលង ១ ថ្ងៃខ្លះ ស៊ីអាហាររំលង ២ ថ្ងៃខ្លះ ... ស៊ីអាហាររំលង ៧ ថ្ងៃខ្លះ បុគ្គលនោះប្រកបដោយសេចក្តីព្យាយាម ក្នុងការផ្លាស់ប្តូរនូវការបរិភោគភត្ត រំលងកន្លះខែមានសភាពដូច្នេះឯង ។ បុគ្គលនោះមានបន្លែស្រស់ជាអាហារខ្លះ មានអង្ករស្រងែជាអាហារខ្លះ មានស្កួយជាអាហារខ្លះ មានកម្ទេចស្បែកជាអាហារខ្លះ មានជ័រជាអាហារខ្លះ មានស្មៅ ឬសារាយជាអាហារខ្លះ មានកន្ទក់ជាអាហារខ្លះ មានបាយក្តាំងជាអាហារខ្លះ មានម្សៅជាអាហារខ្លះ មានស្មៅជាអាហារខ្លះ មានអាចម៍គោជាអាហារខ្លះ មានមើមឈើ និងផ្លែឈើ ក្នុងព្រៃជាអាហារខ្លះ បរិភោគតែផ្លែឈើដែលជ្រុះស្រាប់ខ្លះ បុគ្គលនោះស្លៀក ដណ្តប់សំពត់សម្បកធ្មៃខ្លះ ស្លៀកដណ្តប់សំពត់ដែលគេត្បាញលាយគ្នាខ្លះ ស្លៀកដណ្តប់សំពត់

ដែលបកចេញអំពីសាកសពខ្លះ ស្លៀកដណ្តប់សំពត់បង្សុកូលខ្លះ ស្លៀកដណ្តប់សម្បកឈើខ្លះ ស្លៀកដណ្តប់ស្បែកខ្លាខ្លះ ស្លៀកដណ្តប់ស្បែកខ្លាទាំងក្រចកខ្លះ ស្លៀកដណ្តប់ស្បូវក្តាំងខ្លះ ស្លៀកដណ្តប់សំពត់ត្បាញដោយសម្បកក្រចៅខ្លះ ស្លៀកដណ្តប់ចម្រៀកក្តារខ្លះ ស្លៀកដណ្តប់សំពត់កម្ពលដែលត្បាញដោយសក់មនុស្សខ្លះ ស្លៀកដណ្តប់សំពត់កម្ពលដែលត្បាញដោយរោមកន្ទុយសត្វខ្លះ ស្លៀកដណ្តប់សំពត់ដែលត្បាញដោយស្លាបមៀមខ្លះ ទុកសក់ និងពុកមាត់ ប្រព្រឹត្តកាន់វត្តក្នុងការព្យាយាមទុកសក់ និងពុកមាត់ខ្លះ ឈរសម្រឹងហាមឃាត់នូវអាសនៈខ្លះ អង្គុយច្រហោង ប្រព្រឹត្តកាន់វត្តក្នុងការព្យាយាមអង្គុយច្រហោងខ្លះ ដេកលើបន្លា សម្រេចការដេកលើបន្លាខ្លះ ប្រព្រឹត្តកាន់វត្តចុះត្រាំទឹក ១ ថ្ងៃ ៣ ដង គឺព្រឹក ថ្ងៃត្រង់ ល្ងាចខ្លះ បុគ្គលនោះប្រព្រឹត្តកាន់វត្តកម្តៅកាយជាច្រើន មានសភាពយ៉ាងនេះ ដោយប្រការដូច្នេះឯង ម្នាលភិក្ខុទាំងឡាយ នេះហៅថា និជ្ឈាមប្បដិបទា ។ ម្នាលភិក្ខុទាំងឡាយ ចុះមជ្ឈិមប្បដិបទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានប្រាជ្ញាស្មារតី បន្ទោបង់នូវអភិជ្ឈា និងទោមនស្ស ក្នុងលោកក្នុងវេទនាទាំងឡាយ ... ក្នុងចិត្ត ... ពិចារណានូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានប្រាជ្ញាស្មារតី បន្ទោបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា មជ្ឈិមប្បដិបទា ។ ម្នាលភិក្ខុទាំងឡាយ បដិបទាមាន ៣ យ៉ាងនេះឯង ។

[ ១៥៩ ] ម្នាលភិក្ខុទាំងឡាយ បដិបទានេះមាន ៣ យ៉ាង ។ បដិបទា ៣ យ៉ាង គឺអ្វីខ្លះ ។ គឺអាគាឡ្ហប្បដិបទា ១ និជ្ឈាមប្បដិបទា ១ មជ្ឈិម-ប្បដិបទា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះអាគាឡ្ហប្បដិបទាដូចម្តេច ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាគាឡ្ហប្បដិបទា ។ ម្នាលភិក្ខុទាំងឡាយ ចុះនិជ្ឈាមប្បដិបទា តើដូចម្តេច ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា និជ្ឈាមប្បដិបទា ។ ម្នាលភិក្ខុទាំងឡាយ ចុះមជ្ឈិមប្បដិបទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បណ្តុះឆន្ទៈឲ្យកើត ព្យាយាម ប្រារព្ធសេចក្តីព្យាយាម ផ្គងតម្កល់ចិត្តទុក ដើម្បីញុំាងអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង បណ្តុះឆន្ទៈឲ្យកើត ព្យាយាមប្រារព្ធ សេចក្តីព្យាយាម ផ្គងតម្កល់ចិត្តទុក ដើម្បីលះបង់អកុសលធម៌ដ៏លាមកដែល កើតឡើងហើយ បណ្តុះឆន្ទៈឲ្យកើត ព្យាយាមប្រារព្ធសេចក្តីព្យាយាម ផ្គង តម្កល់ចិត្តទុក ដើម្បីញុំាងកុសលធម៌ដែលមិនទាន់កើត ឲ្យកើតឡើង បណ្តុះ ឆន្ទៈឲ្យកើតឡើង ព្យាយាមប្រារព្ធសេចក្តីព្យាយាម ផ្គងតម្កល់ចិត្តទុក ដើម្បី ស្ថិតស្ថេរ ដើម្បីមិនវិនាស ដើម្បីលូតលាស់ ដើម្បីធំទូលាយ ដើម្បីចម្រើន ឡើង ដើម្បីបរិបូណ៌នៃកុសលធម៌ដែលកើតឡើងហើយ ... ចម្រើនឥទ្ធិបាទ ដែលប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ចម្រើនឥទ្ធិបាទដែលប្រកប ដោយវីរិយសមាធិ និងបធានសង្ខារ ចម្រើនឥទ្ធិបាទដែលប្រកបដោយចិត្ត-សមាធិ និងបធានសង្ខារ ចម្រើនឥទ្ធិបាទដែលប្រកបដោយវីមំសាសមាធិ និងបធានសង្ខារ ... ចម្រើនសទ្ធិន្ទ្រិយ ចម្រើនវីរិយិន្ទ្រិយ ចម្រើនសតិន្ទ្រិយ

ចម្រើនសមាធិន្ទ្រិយ ចម្រើនបញ្ញិន្ទ្រិយ ... ចម្រើនសទ្ធាពល ចម្រើនវីរិយពល ចម្រើនសតិពល ចម្រើនសមាធិពល ចម្រើនបញ្ញាពល ... ចម្រើនសតិ-សម្ពោជ្ឈង្គ ចម្រើនធម្មវិចយសម្ពោជ្ឈង្គ ចម្រើនវីរិយសម្ពោជ្ឈង្គ ចម្រើនបីតិសម្ពោជ្ឈង្គ ចម្រើនបស្សទ្ធិសម្ពោជ្ឈង្គ ចម្រើនសមាធិសម្ពោជ្ឈង្គ ចម្រើនឧបេក្ខាសម្ពោជ្ឈង្គ ... ចម្រើនសម្មាទិដ្ឋិ ចម្រើនសម្មាសង្កប្បៈ ចម្រើនសម្មាវាចា ចម្រើនសម្មាកម្មន្តៈ ចម្រើនសម្មាអាជីវៈ ចម្រើនសម្មាវាយាមៈ ចម្រើនសម្មាសតិ ចម្រើនសម្មាសមាធិ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា មជ្ឈិមប្បដិបទា ។ ម្នាលភិក្ខុទាំងឡាយ បដិបទាមាន ៣ យ៉ាងនេះឯង ។

( អចេលកវគ្គទី ៦ ចប់

## ឧទ្ទាននៃអចេលកវគ្គនោះ គឺ

និយាយអំពីសតិប្បដ្ឋាន ១ ឥទ្ធិបាទ ១ ឥន្ទ្រិយ ១ ពល ១ ពោជ្ឈង្គ ១ មគ្គ ១ ដែលលោកប្រកបហៅថាបដិបទា ( ផ្លូវប្រតិបត្តិ ) ។ )

[ ១៦០ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាង រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៣ យ៉ាង គឺអ្វីខ្លះ ។ គឺបុគ្គលជាអ្នកសម្លាប់សត្វដោយខ្លួនឯង ១ ជីកនាំបុគ្គលដទៃក្នុងការសម្លាប់សត្វ ១ ពេញចិត្តក្នុងការសម្លាប់សត្វ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាងនេះឯង រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាង

រមែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។ ប្រកបដោយធម៌ ៣ យ៉ាង គឺអ្វីខ្លះ ។ គឺបុគ្គលវៀរចាកការសម្លាប់សត្វដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការវៀរចាកការសម្លាប់សត្វ ១ ពេញចិត្តក្នុងការវៀរចាកការសម្លាប់សត្វ ១ ។បេ។ កាន់យកទ្រព្យដែលគេមិនបានឲ្យដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ ពេញចិត្តក្នុងការកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ ... ជាអ្នកវៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការវៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ ពេញចិត្តក្នុងការវៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ ... ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ជាអ្នកពេញចិត្តក្នុងការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ... ជាអ្នកវៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការវៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ជាអ្នកត្រេកអរក្នុងការវៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ... ជាអ្នកពោលពាក្យកុហកដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការពោលពាក្យកុហក ១ ជាអ្នកពេញចិត្តក្នុងការពោលពាក្យកុហក ១ ... ជាអ្នកវៀរចាកការពោលពាក្យកុហកដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការវៀរចាកការពោលពាក្យកុហក ១ ជាអ្នកពេញចិត្តក្នុងការវៀរចាកការពោលពាក្យកុហក ១ ... ជាអ្នកពោលពាក្យញុះញង់ដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការពោលពាក្យញុះញង់ ១ ជាអ្នកពេញចិត្តក្នុងការ

ពោលពាក្យញុះញង់ ១ ... ជាអ្នកវៀរចាកការពោលពាក្យញុះញង់ដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការវៀរចាកការពោលពាក្យញុះញង់ ១ ជាអ្នកពេញចិត្តក្នុងការវៀរចាកការពោលពាក្យញុះញង់ ១ ... ជាអ្នកពោលពាក្យអាក្រក់ដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការពោលពាក្យអាក្រក់ ១ ជាអ្នកពេញចិត្តក្នុងការពោលពាក្យអាក្រក់ ១ ... ជាអ្នកវៀរចាកការនិយាយពាក្យអាក្រក់ ១ ដឹកនាំបុគ្គលដទៃក្នុងការវៀរចាកការនិយាយពាក្យអាក្រក់ ១ ជាអ្នកពេញចិត្តក្នុងការវៀរចាកការនិយាយពាក្យអាក្រក់ ១ ... ជាអ្នកនិយាយពាក្យឥតប្រយោជន៍ដោយដោយខ្លួនឯង ១ ជាអ្នកដឹកនាំបុគ្គលដទៃក្នុងការនិយាយពាក្យឥតប្រយោជន៍ ១ ជាអ្នកពេញចិត្តក្នុងការនិយាយពាក្យឥតប្រយោជន៍ ១ ... ជាអ្នកវៀរចាកការនិយាយពាក្យឥតប្រយោជន៍ដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការវៀរចាកការនិយាយពាក្យឥតប្រយោជន៍ ១ ជាអ្នកពេញចិត្តក្នុងការវៀរចាកការនិយាយពាក្យឥតប្រយោជន៍ ១ ... ជាអ្នកសម្លឹងរំពៃនូវទ្រព្យបុគ្គលដទៃដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការសម្លឹងរំពៃនូវទ្រព្យបុគ្គលដទៃ ១ ជាអ្នកពេញចិត្តក្នុងការសម្លឹងរំពៃនូវទ្រព្យបុគ្គលដទៃ ១ ... ជាអ្នកមិនសម្លឹងរំពៃនូវទ្រព្យបុគ្គលដទៃដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការមិនសម្លឹងរំពៃទ្រព្យបុគ្គលដទៃ ១ ជាអ្នកពេញចិត្តក្នុងការមិនសម្លឹងរំពៃទ្រព្យបុគ្គលដទៃ ១ ... ជាអ្នកមានចិត្តគុំកួនដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការគុំកួន ១ ជាអ្នកពេញចិត្តក្នុងការគុំកួន ១ ... ជាអ្នកមិនមានចិត្តគុំកួនដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការមិនគុំកួន ១ ជាអ្នក

ពេញចិត្តក្នុងការមិនគុំកួន ១ ... ជាអ្នកមានសេចក្ដីយល់ខុសដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការយល់ខុស ១ ជាអ្នកពេញចិត្តក្នុងការយល់ខុស ១ ... ជាអ្នកមានសេចក្ដីយល់ត្រូវដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងសេចក្ដីយល់ត្រូវ ១ ជាអ្នកពេញចិត្តក្នុងសេចក្ដីយល់ត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាងនេះឯង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។

( កម្មបថបេយ្យាល ចប់

## ឧទ្ទាននៃកម្មបថបេយ្យាលនោះ គឺ

និយាយអំពីការសម្លាប់សត្វ ១ កាន់យកទ្រព្យដែលគេមិនឲ្យ ១ ប្រព្រឹត្តខុសក្នុងកាម ១ និយាយកុហក ១ និយាយញុះញង់ ១ និយាយអាក្រក់ ១ និយាយពាក្យឥតប្រយោជន៍ ១ សម្លឹងរំពៃចំពោះទ្រព្យបុគ្គលដទៃ ១ សេចក្ដីគុំកួន ១ សេចក្ដីយល់ខុស ១ បណ្ឌិតគប្បីបញ្ចូលកម្មបថទាំងឡាយ ឲ្យគ្រប់ជា ៣ ត្រង់បេយ្យាលផងចុះ ។ )

[ ១៦១ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាង បុគ្គលគប្បីចម្រើនដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៣ យ៉ាង ដូចម្ដេច ។ គឺសុញ្ញតសមាធិ ១ អនិមិត្តសមាធិ ១ អប្បណិហិតសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយធម៌ ៣ យ៉ាងនេះឯង បុគ្គលគប្បីចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ម្នាលភិក្ខុទាំងឡាយ

ធម៌ ៣ យ៉ាងនេះ បុគ្គលគប្បីចម្រើន ដើម្បីកំណត់ដឹង ។បេ។ ដើម្បីអស់រលីង ដើម្បីលះបង់ ដើម្បីអស់ទៅ ដើម្បីសូន្យទៅ ដើម្បីវិនាស ដើម្បីរលត់ ដើម្បីផ្តាច់បង់ ដើម្បីរលាស់ចោលនូវរាគៈ ។ ធម៌ ៣ យ៉ាងនេះ បុគ្គលគប្បីចម្រើន ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់រលីង ដើម្បីលះបង់ ដើម្បីអស់ទៅ ដើម្បីសូន្យទៅ ដើម្បីវិនាស ដើម្បីរលត់ ដើម្បីផ្តាច់បង់ ដើម្បីរលាស់ ចោលនូវទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ បមាទៈ ។

ពួកសូត្រដែលមិនសង្គ្រោះក្នុងបណ្ណាសក ចប់

## ឧទ្ទាននៃរាគបេយ្យាលនោះ គឺ

និយាយអំពីធម៌ ដែលអាស្រ័យនៅក្នុងរាគបេយ្យាល ដែលលោកពោលហើយថា មាន ១៧ គឺរាគៈ ១ ទោសៈ ១ មោហៈ ១ កោធៈ ១ ឧបនាហៈ ១ ជាគម្រប់ ៥ មក្ខៈ ១ បឡាសៈ ១ ឥស្សា ១ មច្ឆរិយៈ ១ មាយា ១ សាឋេយ្យៈ ១ ថម្ភៈ ១ សារម្ភៈ ១ មានះ ១ អតិមានះ ១ មទៈ ១ បមាទៈ ១ ។ អំពីសមាធិ ៣ យ៉ាង គឺសុញ្ញតសមាធិ ១ អនិមិត្តសមាធិ ១ អប្បណិហិតសមាធិ ១ ដែលលោកកំណត់ទុកក្នុងសមាធិមូលកាបេយ្យាល ដោយហេតុជាជំនួយដែល

ប្រកបដោយសេចក្តីឧបមា ដើម្បីដឹងច្បាស់ ១ ដើម្បីកំណត់ដឹង ១ ដើម្បីអស់រលីង ១ ដើម្បីលះបង់ ១ ដើម្បីអស់ទៅ ១ ដើម្បីសូន្យទៅ ១ ដើម្បីវិនាស ១ ដើម្បីរលត់ ១ ដើម្បីផ្តាច់បង់ ១ ដើម្បីរលាស់ចោល ១ រួមត្រូវជា ១០ ។

**តិកនិបាត ចប់**

# អដ្ឋកថា

## សូត្រដែលមិនសង្គ្រោះចូលក្នុងបណ្ណាសក

ក្នុងសូត្រទាំងឡាយ បន្ទាប់អំពីនេះទៅ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ១៥៨ ] បទថា **អាគាឡ្ហា បដិបទា** បានដល់ បដិបទាដែលធូរថយ គឺធូរលុង បានដល់ ប្រកាន់ដ៏មាំដោយអំណាចលោភៈ ។ បទថា **និជ្ឈាមា** បានដល់ បដិបទាដែលតឹងពេក គឺដុតខ្លួន ធ្វើខ្លួនឲ្យក្តៅ ដោយអំណាចនៃអត្តកិលមថានុយោគ ។ បទថា **មជ្ឈិមា** បានដល់ បដិបទាដែលមិនធូរថយ មិនតឹង នៅត្រង់កណ្តាល ។

បទថា **អចេលកោ** គឺមិនមានសំពត់ បានដល់ ជាមនុស្សអាក្រាត ។ បទថា **មុត្តាចារោ** បានដល់ លះបង់អាចារៈ ។ បុគ្គលនោះវៀរចាកអាចារៈរបស់កុលបុត្រ ក្នុងផ្លូវលោកៈ ក្នុងកិច្ចផ្តាល់ខ្លួនទាំងឡាយ មានការបន្ទោបង់ឧច្ចារៈជាដើម ឈរបន្ទោបង់ឧច្ចារៈ ឈរបន្ទោបង់បស្សាវៈ ឈរទំពា ឈរបរិភោគ ។ បទថា **ហត្ថាវលេខនោ** សេចក្តីថា កាលដុំបាយក្នុងដៃអស់ហើយ អ្នកបួសអាក្រាត ដែលបដិបត្តិតឹងនោះ ក៏ប្រើអណ្តាតលិទ្ធដៃ ឬបើមិនដូច្នោះទេ បន្ទោបង់ឧច្ចារៈហើយ ជាអ្នកមានសេចក្តីសម្គាល់ក្នុងដៃនោះឯងថាជាទឹក យកដៃជូតសម្អាត ។ អ្នកបួសអាក្រាត ឈ្មោះថា **ន ឯហិភទន្តិកោ** ព្រោះអត្ថថា កាលមហាជនពោលថា អ្នកដ៏ចម្រើន សូមអ្នកមកដើម្បីភិក្ខាចារ ដូច្នេះ ក៏មិនមក អ្នកបួសអាក្រាត ឈ្មោះថា **ន តិដ្ឋភទន្តិកោ** ព្រោះអត្ថថា កាលមហាជនពោលថា បើយ៉ាងនោះ និមន្តឈរចាំសិន ក៏

*មិនព្រមឈរ ។ បានឮថា អ្នកបួសអាក្រាតនោះ មិនព្រមធ្វើទាំងការមក និងការឈប់ឈរទាំង ២ នោះ ព្រោះខ្លាច និងជាការធ្វើតាមពាក្យរបស់និគ្រន្ថនោះ ។ បទថា* **អភិហដំ** *បានដល់ ភិក្ខាដែលបុគ្គលនោះកាន់មកឲ្យមុនខ្លួនទៅដល់ ។ បទថា* **ឧទ្ទិស្សកតំ** *បានដល់ ភិក្ខាដែលបុគ្គលនោះប្រាប់ថា មនុស្សទាំងនេះធ្វើឧទ្ទិសដល់ពួកអ្នក ។ បទថា* **និមន្តនំ** *សេចក្តីថា អ្នកបួសអាក្រាតត្រូវគេនិមន្តយ៉ាងនេះថា សូមនិមន្តចូលទៅកាន់ត្រកូល វិថី ឬភូមិឈ្មោះនោះ ក៏មិនត្រេកអរ គឺមិនទទួលភិក្ខា ។ បទថា* **ន កុម្ភិមុខា** *បានដល់ មិនទទួលភិក្ខាដែលគេដួសអំពីឆ្នាំងមកឲ្យ ។ បទថា* **កឡោបិ** *ក្នុងពាក្យថា* **ន កឡោបិមុខា** *បានដល់ ឆ្នាំងបាយ ឬល្អី ។ អ្នកបួសអាក្រាតមិនទទួលភិក្ខាហារអំពីឆ្នាំង ឬល្អីនោះ សួរថា ព្រោះហេតុអ្វី ទើបមិនទទួល ។ ឆ្លើយថា ព្រោះគិតថា ឆ្នាំង និងល្អី អាស្រ័យអាត្មាអញ ទើបប៉ះខ្ទប់ជាមួយវែក ។ បទថា* **ន ឯឡកមន្តរំ** *សេចក្តីថា មិនទទួលភិក្ខាដែលបុគ្គលឈរត្រង់ធរណីទ្វារឲ្យ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា បុគ្គលនេះ អាស្រ័យអញហើយ ទើបបាននូវការឈរត្រង់ធរណីទ្វារ ។ ក្នុងកំណាត់ឈើ និងអង្រែ ក៏មានន័យនេះឯង ។*

*បទថា* **ទ្វិន្នំ** *សេចក្តីថា កាលបុគ្គល ២ នាក់កំពុងបរិភោគ កាលមនុស្សម្នាក់ក្រោកឡើងឲ្យ ក៏មិនទទួល ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះគិតថា មានអន្តរាយអំពីដុំបាយ ។ ចំណែកក្នុងបទថា* **ន គព្ភិនិយា** *ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ សម្រាប់ស្រីមានគភ៌ ទារកដែលនៅ*

ក្នុងផ្ទៃបានទទួលការប៉ះទង្គិច ។ សម្រាប់ស្រីដែលកំពុងឲ្យកូនបៅដោះ អន្តរាយដោយការបៅដោះ នឹងមានដល់ទារក សម្រាប់ស្រីដែលនៅជាមួយបុរសដទៃ អន្តរាយនៃតម្រេកនឹងមាន ព្រោះហេតុដូចពោលមកនេះ ទើបអ្នកបួសអាក្រាត មិនទទួលភិក្ខាអំពីស្រីទាំងនេះ ។ បទថា **ន សង្កិត្តីសុ** បានដល់ក្នុងភត្តដែលគេប្រារព្ធឲ្យធ្វើ ។

បានឮថា ក្នុងសម័យស្រូវអង្ករ រកបានដោយលំបាក សាវ័ករបស់អចេលក៍ ក៏ប្រមូលយកអង្ករជាដើមអំពីទីនោះៗ មកចម្អិនជាបាយ ដើម្បីជាប្រយោជន៍ដល់អចេលក៍ទាំងឡាយ អចេលក៍ដែលរង្កៀស ក៏មិនព្រមទទួលអំពីភត្តនោះ ។ បទថា **ន យត្ថ សា** សេចក្តីថា ក្នុងទីណាឆ្កែប្រាកដខ្លួនដោយសង្ឃឹមថា នឹងបានដុំបាយ ក្នុងទីនោះ អចេលក៍ក៏មិនព្រមទទួលភិក្ខាដែលមិនទាន់បានឲ្យដល់ឆ្កែនោះ ហើយនាំមកឲ្យខ្លួន សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះគិតថា អន្តរាយនៃដុំបាយ នឹងមានដល់ឆ្កែនោះ ។ បទថា **សណ្ឌសណ្ឌចារិនី** បានដល់ រុយហើរទៅជាក្រុមៗ ។ អធិប្បាយថា មនុស្សទាំងឡាយឃើញអចេលក៍ហើយ ចូលទៅកាន់រោងបាយ ដោយគិតថា ឲ្យដល់អចេលក៍នេះ កាលបុគ្គលទាំងនោះចូលទៅ រុយដែលទំគ្រង់មាត់ល្អីជាដើម ក៏ហើរឡើងទៅជាក្រុមៗ អចេលក៍មិនទទួលភិក្ខា ដែលនាំមកអំពីទីដែលរុយហើរឡើងនោះ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះគិតថា អន្តរាយក្នុងទីរកស៊ីរបស់រុយ កើតព្រោះអាស្រ័យអាត្មាអញ ។ បទថា **ន ថុសោទកំ** បានដល់ ទឹកផឹកដែលធ្វើដោយគ្រឿងផ្សំ គឺស្រូវគ្រប់ប្រភេទ ។

ក្នុងទីនេះ ការផឹកស្រាប៉ុណ្ណោះមានទោស ។ តែអចេលក៍នេះ មានការសម្គាល់ក្នុងទឹកផឹកគ្រប់ប្រភេទថា មានទោស ។ អចេលក៍ណាទទួលភិក្ខាក្នុងផ្ទះមួយហើយត្រឡប់ អចេលក៍នោះ ឈ្មោះថា **ឯកាគារិក** អចេលក៍ចិញ្ចឹមអត្តភាពដោយបាយមួយដុំប៉ុណ្ណោះ អចេលក៍នោះ ឈ្មោះថា **ឯកាលោបិក** ក្នុងអចេលក៍ប្រភេទ **ទ្វាគារិក** ជាដើម ក៏មានន័យនេះឯង ។

បទថា **ឯកិស្សាបិ ទត្តិយា** បានដល់ ក្នុងថាសមួយ ឈ្មោះថា **ទត្តិ** បានដល់ ថាសតូចៗ មួយ ដែលបុគ្គលដាក់ភិក្ខាដ៏ប្រណីត ។ បទថា **ឯកាហិកំ** បានដល់ អាហារដែលវៀរការបរិភោគមួយពេល ។ បទថា **អឌ្ឍមាសិកំ** បានដល់ អាហារដែលវៀរការទទួលទានកន្លះខែ ។ បទថា **បរិយាយភត្តភោជនំ** បានដល់ បរិភោគភត្តដែលគេឲ្យតាមវារៈ គឺការបរិភោគភត្តដែលគេនាំមកឲ្យតាមវារៈនៃគ្នាយ៉ាងនេះ គឺតាមវារៈ ១ ថ្ងៃ តាមវារៈ ២ ថ្ងៃ តាមវារៈ ៧ ថ្ងៃ តាមវារៈកន្លះខែ ។ បទថា **សាកភក្ខោ** ជាដើម មានអត្ថដូចពោលហើយនេះឯង ។ បទថា **ឧព្ភដ្ឋកោ** ប្រែថា ជាអ្នកឈរនៅខាងលើ ។ បទថា **ឧក្កុដិកប្បធានមនុយុត្តោ** បានដល់ ប្រកបសេចក្តីព្យាយាម ក្នុងឥរិយាបថអង្គុយច្រហោង កាលបរិភោគ ដើរទៅ ក៏ច្រហោង គឺលោតទៅ ។ បទថា **កណ្ដកាបស្សយិកោ** សេចក្តីថា បោះបន្ទាដែក ឬបន្ទាធម្មជាតិក្នុងដី ហើយក្រាលបន្ទះស្បែកលើបន្ទានោះ ធ្វើការកម្រើកឥរិយាបថ មានការឈរ និងការចង្ក្រមជាដើម ។ បទថា **សេយ្យំ** បានដល់ កាលដេកក៏សម្រេចការដេកតែម្យ៉ាងដូចគ្នា ។ បទថា **សាយត-**

**តិយាមកំ** បានដល់ ប្រកបសេចក្ដីព្យាយាមចុះងូតទឹកមានពេលល្ងាចជាគម្រប់ ៣ គឺមួយថ្ងៃ ៣ ដង ពេលព្រឹក ពេលថ្ងៃ និងពេលល្ងាច ដោយគិតថា អាត្មាអញនឹងបន្សាត់នូវបាប ។

បទថា **កាយេ កាយានុបស្សី** ជាដើម គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងអដ្ឋកថាឯកនិបាតខាងដើម ។ បទថា **អយំ វុច្ចតិ ភិក្ខវេ មជ្ឈិមប្បដិបទា** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ បដិបទានេះមិនចូលទៅកៀកកិតនឹងអន្តធម៌ ២ យ៉ាង គឺកាមសុខល្លិកានុយោគ និងអត្តកិលមថានុយោគ ។ ម្យ៉ាងទៀត បដិបទាដែលផុតអំពីអន្តធម៌ គឺសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ គប្បីជ្រាបថា មជ្ឈិមប្បដិបទា ។

[ ១៦០ ] បទថា **សមនុញ្ញោ** បានដល់ មានអធ្យាស្រ័យស្មើគ្នា ។

[ ១៦១ ] បទថា **រាគស្ស** បានដល់ រាគៈទាក់ទងក្នុងបញ្ចកាមគុណ ។ បទថា **អភិញ្ញាយ** ប្រែថា ដើម្បីដឹងក្រៃលែង ។ វិបស្សនា ព្រះមានព្រះភាគត្រាស់ដោយសមាធិទាំង ៣ មានបទថា **សុញ្ញតោ សមាធិ** ជាដើម ។ ពិតហើយ វិបស្សនាបានឈ្មោះទាំងនេះ ក៏ព្រោះមិនមានការប្រកាន់ថាទៀង និមិត្តថាទៀង និងសេចក្ដីប្រាថ្នាថាទៀង ។ បទថា **បរិញ្ញាយ** ប្រែថា ដើម្បីកំណត់ដឹង ។ ក្នុងបទដ៏សេស ក៏មានន័យនេះឯង ៕

**តិកនិបាតវណ្ណនា ក្នុងអដ្ឋកថាអង្គុត្តរនិកាយ**

**ឈ្មោះមនោរថបូរណី ចប់**

# សុត្តន្តបិដក
# អង្គុត្តរនិកាយ ចតុក្កនិបាត
# តតិយភាគ

*សូមនមស្ការព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ*

## បឋមបណ្ណាសក
## ភណ្ឌគ្គាមវគ្គទី ១
### អនុពុទ្ធសូត្រទី ១

[ ១ ] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងភណ្ឌគ្រាម ក្នុងដែនវជ្ជី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ កាលដែលតថាគតក្តី អ្នកទាំងឡាយក្តី អន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលដ៏វែងយ៉ាងនេះ ព្រោះមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវធម៌ ៤ ។ ធម៌ ៤ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កាលដែលតថាគតក្តី អ្នកទាំងឡាយក្តី អន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលដ៏វែងយ៉ាងនេះ ព្រោះមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវ*

អរិយសីល ( សីលដ៏ប្រសើរ ) ១ ម្នាលភិក្ខុទាំងឡាយ កាលដែលតថាគតក្តី អ្នកទាំងឡាយក្តី អន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលដ៏វែងយ៉ាងនេះ ព្រោះមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយសមាធិ ( សមាធិដ៏ប្រសើរ ) ១ ម្នាលភិក្ខុទាំងឡាយ កាលដែលតថាគតក្តី អ្នកទាំងឡាយក្តី អន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលដ៏វែងយ៉ាងនេះ ព្រោះមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយបញ្ញា ( បញ្ញាដ៏ប្រសើរ ) ១ ម្នាលភិក្ខុទាំងឡាយ កាលដែលតថាគតក្តី អ្នកទាំងឡាយក្តី អន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលដ៏វែងយ៉ាងនេះ ព្រោះមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយវិមុត្តិ ( វិមុត្តិដ៏ប្រសើរ ) ១ ។ ម្នាលភិក្ខុទាំងឡាយ អរិយសីលនោះ តថាគតក្តី អ្នកទាំងឡាយក្តី បានត្រាស់ដឹងហើយ ចាក់ធ្លុះហើយ អរិយ-សមាធិក៏បានត្រាស់ដឹងហើយ ចាក់ធ្លុះហើយ អរិយបញ្ញាក៏បានត្រាស់ដឹងហើយ ចាក់ធ្លុះហើយ អរិយវិមុត្តិក៏បានត្រាស់ដឹងហើយ ចាក់ធ្លុះហើយ សេចក្តីប្រាថ្នាក្នុងភពក៏បានកាត់ចោលហើយ តណ្ហាជាគ្រឿងនាំទៅក្នុងភពក៏អស់ហើយ ឥឡូវនេះ ការកើតតទៅទៀតមិនមានឡើយ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នូវពាក្យនេះ លុះព្រះសុគតជាសាស្តា ទ្រង់ត្រាស់នូវពាក្យនេះរួចហើយ ទើបទ្រង់ត្រាស់នូវព្រះគាថានេះតទៅទៀតថា

សីល សមាធិ បញ្ញា និងវិមុត្តិជាធម៌រកគុណជាតិដទៃប្រសើរ
ជាងគ្មាន ធម៌ទាំងអម្បាលនេះ ព្រះគោតមមានយសបានត្រាស់
ដឹងហើយ ។ ព្រះពុទ្ធសម្តែងធម៌ដល់ភិក្ខុទាំងឡាយ ព្រោះត្រាស់

ដឹងច្បាស់ដោយប្រការដូច្នេះ សាស្តាមានចក្ខុធ្វើនូវទីបំផុតនៃទុក្ខហើយ ចេញចាក់វានៈ គឺតណ្ហាហើយ ។

# អដ្ឋកថា

# អង្គុត្តរនិកាយ ឈ្មោះ មនោរថបូរណី

## ចតុក្កនិបាត

## បឋមបណ្ណាសក

## ភណ្ឌគ្គាមវគ្គទី ១

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

### អនុពុទ្ធសូត្រ

[ ១ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងអនុពុទ្ធសូត្រទី ១ នៃចតុក្កនិបាតដូច្នេះ ក្នុងបទថា* **អននុពោធា** *បានដល់ ព្រោះមិនដឹង ព្រោះមិនជ្រាប ។ បទថា* **អប្បដិវេធា** *បានដល់ ព្រោះមិនចាក់ធ្លុះ គឺព្រោះមិនធ្វើឲ្យប្រចក្ស ។ បទថា* **ទីឃមទ្ធានំ** *ប្រែថា អស់កាលយូរ ។ បទថា* **សន្ធាវិតំ** *បានដល់ ស្ទុះទៅ ដោយទៅអំពីភព ។ បទថា* **សំសរិតំ** *បានដល់ អន្ទោលទៅ ដោយមិនមករឿយៗ ។ បទថា* **មមញ្ចេវ តុម្ហាកញ្ច** *ប្រែថា ដែលតថាគត និងអ្នកទាំងឡាយ ។ម្យ៉ាងទៀត ក្នុងបទថា* **សន្ធាវិតំ សំសរិតំ** *នេះ គប្បីជ្រាបអត្ថយ៉ាងនេះថា ការស្ទុះទៅ ការអន្ទោលទៅ មានហើយដល់តថាគត និងអ្នកទាំងឡាយ ។ បទថា* **អរិយស្ស** *បានដល់ មិនមានទោស ។ ធម៌ទាំង*

៣ គឺសីល សមាធិ និងបញ្ញា គប្បីជ្រាបថា សម្បយុត្តដោយមគ្គនិងផល ។ ផលប៉ុណ្ណោះ លោកសម្ដែងដោយ ឈ្មោះថា វិមុត្តិ ។ បទថា **ភវតណ្ហា** បានដល់ តណ្ហាក្នុងភពទាំងឡាយ ។ បទថា **ភវនេត្តិ** បានដល់ តណ្ហាដូចខ្សែចងសត្វទុកក្នុងភព ។ បទនោះ ជាឈ្មោះរបស់តណ្ហានោះឯង ។ ពិតហើយ តណ្ហានោះ នាំសត្វទាំងឡាយទៅកាន់ភពនោះៗ ដូចចង-កគោ ព្រោះដូច្នោះ ទើបតណ្ហានោះ លោកហៅថា **ភវនេត្តិ** ។ បទថា **អនុត្តរោ** បានដល់ លោកុត្តរ ។ បទថា **ទុក្ខស្សន្តករោ** បានដល់ ទ្រង់ធ្វើទីបំផុតនៃវដ្ដទុក្ខ ។ បទថា **ចក្ខុមា** បានដល់ ទ្រង់មានចក្ខុដោយចក្ខុទាំង ៥ ។ បទថា **បរិនិព្វុតោ** បានដល់ បរិនិព្វានហើយ ដោយកិលេសបរិនិព្វាន ។ ទ្រង់បញ្ចប់ទេសនាតាមលំដាប់អនុសន្ធិថា នេះជាបរិនិព្វានលើកទី ១ របស់ព្រះសាស្ដា ត្រង់ពោធិមណ្ឌលដ្ឋាន ។ តែខាងក្រោយ ទ្រង់បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ រម្ងត់ខន្ធ ត្រង់ចន្លោះដើមរាំងទាំងគូ ដូច្នេះ ៕

## អដ្ឋកថា អនុពុទ្ធសូត្រទី ១ ចប់

# សុត្តន្តបិដក

## បបតិតសូត្រទី ២

[ ២ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនបានប្រកបដោយធម៌ ៤ យ៉ាង តថាគតហៅថា ឃ្លាតចាកធម្មវិន័យនេះ ។ ធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនបានប្រកបដោយអរិយសីល តថាគតហៅថា ឃ្លាតចាកធម្មវិន័យនេះ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនបានប្រកបដោយអរិយសមាធិ តថាគតហៅថាឃ្លាតចាកធម្មវិន័យនេះ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនបានប្រកបដោយអរិយបញ្ញា តថាគតហៅថា ឃ្លាតចាកធម្មវិន័យនេះ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនបានប្រកបដោយអរិយវិមុត្តិ តថាគតហៅថាឃ្លាតចាកធម្មវិន័យនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនបានប្រកបដោយធម៌ ៤ យ៉ាងនេះឯង តថាគតហៅថាឃ្លាតចាកធម្មវិន័យនេះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង ទើបតថាគតហៅថា មិនឃ្លាតចាកធម្មវិន័យនេះ ។ ធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយអរិយសីល តថាគតហៅថា មិនឃ្លាតចាកធម្មវិន័យនេះ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយអរិយសមាធិ តថាគតហៅថា មិនឃ្លាតចាកធម្មវិន័យនេះ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយអរិយបញ្ញា តថាគតហៅថា មិនឃ្លាតចាកធម្មវិន័យនេះ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយអរិយវិមុត្តិ តថាគតហៅថា មិនឃ្លាតចាកធម្មវិន័យនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះឯង តថាគតហៅថា មិនឃ្លាតចាកធម្មវិន័យនេះ ។

បុគ្គលដែលឃ្លាតចាក ( ធម្មវិន័យ ) រមែងធ្លាក់ចុះ បុគ្គលដែលធ្លាក់ចុះ ជាអ្នកជាប់ជំពាក់ដោយរាគៈ រមែងមក ( កាន់ជាតិ ជរា ព្យាធិ មរណៈ ) ម្តងទៀត ( បើ ) កិច្ច ( ដោយមគ្គទាំង ៤ ) បុគ្គលនោះបានធ្វើស្រេចហើយ បានត្រេកអរហើយ ក្នុងគុណជាតដែលបុគ្គលគប្បីត្រេកអរ សេចក្តីសុខបានមក ដោយសេចក្តីសុខ ( រមែងមានដល់បុគ្គលនោះ ) ។

# អដ្ឋកថា

## បបតិតសូត្រ

[ ២ ] បទថា គប្បីជ្រាបវិនិច្ឆ័យក្នុងបបតិតសូត្រទី ២ ដូចតទៅនេះ **បបតិតោ** បានដល់ ដែលឃ្លាតទៅ ។ បទថា **អប្បបតិតោ** បានដល់ ដែលតាំងនៅហើយ ។ បណ្តាបុគ្គលទាំងនោះ លោកិយមហាជន ឈ្មោះថា ធ្លាក់ទៅទាំងអស់ ។ ព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើម ឈ្មោះថា ធ្លាក់ទៅក្នុងខណៈកើតកិលេស ។ ព្រះខីណាស្រព ឈ្មោះថា តាំងនៅហើយដោយចំណែកមួយ ។ បទថា **ចុតា បតន្តិ** សេចក្តីថា ជនពួកណាឃ្លាតទៅ ជនទាំងនោះ ឈ្មោះថា ធ្លាក់ ។ បទថា **បតិតា** សេចក្តីថា ជនទាំងឡាយណាធ្លាក់ទៅ ជនទាំងនោះ ឈ្មោះថា ឃ្លាតទៅ ។ អធិប្បាយថា

ឈ្មោះថា ធ្លាក់ ព្រោះឃ្លាតទៅ ឈ្មោះថា ឃ្លាតទៅ ព្រោះធ្លាក់ ដូច្នេះ ។ បទថា **គិទ្ធា** បានដល់ បុគ្គលដែលតម្រេកព្រោះរាគៈ ។ បទថា **បុនរាគតា** សេចក្ដីថា រមែងឈ្មោះថាជាអ្នកមកកាន់ជាតិ ជរា ព្យាធិ មរណៈទៀត ។ បទថា **កតកិច្ចំ** សេចក្ដីថា ធ្វើកិច្ចដែលគួរធ្វើដោយមគ្គ ៤ ។ បទថា **រតំ រម្មំ** សេចក្ដីថា ត្រេកអរហើយក្នុងគុណជាតដែលគួរត្រេកអរ ។ បទថា **សុខេនាន្វាគតំ សុខំ** សេចក្ដីថា អំពីសេចក្ដីសុខមកតាម គឺដល់ព្រមនូវសុខ អធិប្បាយថា អំពីសុខរបស់មនុស្សមកដល់ គឺសម្រេចសុខទិព្វ អំពីសុខក្នុងឈាន មកដល់សុខក្នុងវិបស្សនា អំពីសុខក្នុងវិបស្សនា មកដល់សុខក្នុងមគ្គ អំពីសុខក្នុងមគ្គ មកដល់សុខក្នុងផល អំពីសុខក្នុងផល ក៏មកដល់សុខក្នុងនិព្វាន ។ល។

**អដ្ឋកថា បបតិតសូត្រទី ២ ចប់**

# សុត្តន្តបិដក

## បឋមខតសូត្រទី ៣

[ ៣ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលមិនឈ្លាសវៃ ជាអសប្បុរស ប្រកបដោយធម៌ ៤ យ៉ាង រមែងរក្សាខ្លួនដែលខ្លួនជីកគាស់កម្ចាត់គុណចោលហើយ ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្ដីតិះដៀលរបស់អ្នក

ប្រាជ្ញទាំងឡាយផង បាននូវបាបដ៏ច្រើនផង ។ ធម៌ ៤ យ៉ាងតើដូចម្តេចខ្លះ ។ គឺបុគ្គលនោះ មិនបានពិចារណា ស្ទាបស្ទង់មើល ហើយពោលសរសើរបុគ្គលដែលគួរតិះដៀល ១ មិនបានពិចារណា ស្ទាបស្ទង់មើល ហើយពោលតិះដៀលបុគ្គលដែលគួរសរសើរ ១ មិនបានពិចារណា ស្ទាបស្ទង់មើលហើយ កើតសេចក្តីជ្រះថ្លាក្នុងហេតុដែលមិនគួរជ្រះថ្លា ១ មិនបានពិចារណា ស្ទាបស្ទង់មើលហើយ កើតសេចក្តីមិនជ្រះថ្លាក្នុងហេតុដែលគួរជ្រះថ្លា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលមិនឈ្លាសវៃ ជាអសប្បុរសប្រកបដោយធម៌ទាំង ៤ យ៉ាងនេះឯង រមែងរក្សាខ្លួន ដែលខ្លួនជីកគាស់កម្ចាត់គុណាចោលហើយ ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង រមែងបាននូវបាបដ៏ច្រើនផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាបណ្ឌិត ឈ្លាសវៃ ជាសប្បុរសប្រកបដោយធម៌ ៤ យ៉ាង រមែងរក្សាខ្លួនដែលខ្លួនមិនបានជីកគាស់ មិនបានកម្ចាត់គុណាចោល ជាអ្នកមិនមានទោសផង មិនមានសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបុណ្យដ៏ច្រើនផង ។ ធម៌ ៤ តើដូចម្តេចខ្លះ ។ គឺបុគ្គលនោះ ពិចារណាស្ទាបស្ទង់មើល រួចហើយ ទើបពោលតិះដៀលបុគ្គលដែលគួរតិះដៀល ១ ពិចារណា ស្ទាបស្ទង់មើលរួចហើយ ទើបពោលសរសើរបុគ្គលដែលគួរសរសើរ ១ ពិចារណាស្ទាបស្ទង់មើលរួចហើយ ទើបកើតសេចក្តីមិនជ្រះថ្លាក្នុងហេតុដែលមិនគួរជ្រះថ្លា ១ ពិចារណាស្ទាបស្ទង់មើលរួចហើយ ទើបកើតសេចក្តីជ្រះថ្លាក្នុងហេតុដែលគួរជ្រះថ្លា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជា

បណ្ឌិតឈ្លាសវៃ ជាសប្បុរសប្រកបដោយធម៌ ៤ យ៉ាងនេះឯង រមែងរក្សាខ្លួនដែលខ្លួនមិនបានជីកគាស់ មិនបានកម្ចាត់គុណចោល ជាអ្នកមិនមានទោសផង មិនមានសេចក្ដីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបុណ្យដ៏ច្រើនផង ។

បុគ្គលណាសរសើរបុគ្គលដែលគួរតិះដៀលក្ដី តិះដៀលបុគ្គលដែលគួរសរសើរក្ដី បុគ្គលនោះឈ្មោះថាជ្រើសរើសយកកំហុសដោយមាត់ពាក្យ រមែងមិនបានសេចក្ដីសុខ ព្រោះកំហុសនោះឡើយ ។ ការចាញ់ដោយទ្រព្យណា ព្រមទាំងទ្រព្យរបស់ខ្លួនក្ដី ទាំងខ្លួនក្ដី ព្រោះល្បែងភ្នាល់ ការចាញ់ដោយទ្រព្យនេះ ជាកំហុសមានប្រមាណតិចទេ បុគ្គលណាញុំាងចិត្តឲ្យប្រទូស្តក្នុងពួកបុគ្គល ដែលស្រុះស្រួលមូលមិត្រគ្នា កំហុសរបស់បុគ្គលនោះឯង ទើបធំជាង បុគ្គលដែលតម្កល់វាចានិងចិត្តដ៏លាមក តិះដៀលព្រះអរិយៈ រមែងទៅកើតក្នុងនរកអស់ ១ សែននិរព្វុទៈ និង ៣៦ និរព្វុទៈផង និង ៥ អព្វុទៈ ផង ។

# អដ្ឋកថា

## បឋមខតសូត្រ

[ ៣ ] *បឋមខតសូត្រទី ៣ ពោលក្នុងអដ្ឋកថាទុកនិបាតហើយ ។ ឯក្នុងគាថា គប្បីជ្រាបវិនិច្ឆ័យដូច្នេះ បទថា* **និន្ទិយំ** *បានដល់ បុគ្គលដែលគួរនិន្ទា។ បទថា* **និន្ទតិ** *បានដល់ រមែងតិះដៀល ។ បទថា* **បសំសិយោ** *បានដល់ បុគ្គលគួរសរសើរ ។ បទថា* **វិចិណាតិ មុខេន សោ កលឹ** *សេចក្តីថា បុគ្គលនោះប្រព្រឹត្តយ៉ាងនេះហើយ ឈ្មោះថា រមែងជ្រើសរើសដោយមាត់នោះ ។ បទថា* **កលិនា តេន សុខំ ន វិន្ទតិ** *សេចក្តីថា បុគ្គលនោះរមែងមិនបាននូវសេចក្តីសុខ ព្រោះទោសនោះ ។ បទថា* **សព្វស្សាបិ សហាបិ អត្តនា** *សេចក្តីថា ការចាក់ភ្នាល់ ខូចទាំងទ្រព្យរបស់ខ្លួនគ្រប់យ៉ាងផង ទាំងខ្លួនឯងផង ឈ្មោះថា ជាទោសប្រមាណតិចតួច ។ បទថា* **យោ សុគតេសុ** *សេចក្តីថា ឯបុគ្គលណា គប្បីធ្វើចិត្តគិតប្រទូស្តក្នុងបុគ្គលទាំងឡាយ ដែលប្រព្រឹត្តទៅដោយប្រពៃហើយ ការមានចិត្តប្រទូស្តរបស់បុគ្គលនោះឯង មានទោសច្រើនជាងទោសនោះ ។ ឥឡូវនេះ កាលទ្រង់សម្តែងការមានចិត្តប្រទូស្តនោះ មានទោសច្រើនជាង ទើបត្រាស់ថា* **សតំ សហស្សានំ** *ជាដើម ។ បណ្តាបទទាំងនោះ បទថា* **សតំ សហស្សានំ** *បានដល់ អស់សែនដោយការរាប់តាមនិរព្វុទៈ ។ បទថា* **ឆត្តឹសតិ** *បានដល់ ៣៦ និរព្វុទៈ ។ បទថា* **បញ្ច ច** *គឺ ៥ អព្វុទៈ ដោយការរាប់តាមអព្វុទៈ ។ បទថា* **យមរិយំ គរហិ** *សេចក្តីថា បុគ្គលកាលតិះដៀលព្រះអរិយៈទាំង-ឡាយ រមែងចូលដល់នរកណា ក្នុងនរកនោះ ប្រមាណអាយុមានប៉ុណ្ណោះ ។*

# សុត្តន្តបិដក

## ទុតិយខតសូត្រទី ៤

[ ៤ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលមិនឈ្លាសវៃ ជាអសប្បុរស កាលប្រតិបត្តិខុសក្នុងបុគ្គល ៤ ពួក ឈ្មោះថា រក្សាខ្លួនដែលខ្លួនជីកគាស់កម្ចាត់គុណចោលហើយ ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង បាននូវបាបដ៏ច្រើនផង ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល មិនឈ្លាសវៃ ជាអសប្បុរស កាលបើប្រតិបត្តិខុសក្នុងមាតា ឈ្មោះថា រក្សាខ្លួនដែលខ្លួនជីកគាស់កម្ចាត់គុណចោលហើយ ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង តែងបានបាបដ៏ច្រើនផង ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលពាលប្រតិបត្តិខុសក្នុងបិតា ។បេ។ ម្នាលភិក្ខុទាំង-ឡាយ កាលប្រតិបត្តិខុសក្នុងព្រះតថាគត ។បេ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលមិនឈ្លាសវៃ ជាអសប្បុរស កាលប្រតិបត្តិខុសក្នុងសាវ័ករបស់ព្រះតថាគត ឈ្មោះថា រក្សាខ្លួនដែលខ្លួនជីកគាស់កម្ចាត់គុណចោលហើយ ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំង-ឡាយផង តែងបាននូវបាបដ៏ច្រើនផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលមិនឈ្លាសវៃ ជាអសប្បុរស កាលប្រតិបត្តិខុសក្នុងបុគ្គល ៤ ពួកនេះឯង ឈ្មោះថា រក្សាខ្លួនដែលខ្លួនជីកគាស់កម្ចាត់គុណចោលហើយ ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបាបដ៏ច្រើនផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាបណ្ឌិត ឈ្លាសវៃ

ជាសប្បុរស កាលប្រតិបត្តិត្រូវក្នុងបុគ្គល ៤ ពួក ឈ្មោះថា រក្សាខ្លួនដែលខ្លួនមិនបានជីកគាស់ មិនបានកម្ចាត់គុណចោល ជាអ្នកមិនមានទោសផង មិនមានសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបុណ្យដ៏ច្រើនផង ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ គឺបុគ្គលជាបណ្ឌិតឈ្លាសវៃ ជាសប្បុរស កាលប្រតិបត្តិត្រូវក្នុងមាតា ឈ្មោះថារក្សាខ្លួនដែលខ្លួនមិនបានជីកគាស់ មិនបានកម្ចាត់គុណចោល ជាអ្នកមិនមានទោសផង មិនមានសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបុណ្យដ៏ច្រើនផង ម្នាលភិក្ខុទាំងឡាយ កាលប្រតិបត្តិត្រូវក្នុងបិតា ។បេ។ ម្នាលភិក្ខុទាំងឡាយ កាលប្រតិបត្តិត្រូវក្នុងព្រះតថាគត ។បេ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលជាបណ្ឌិតឈ្លាសវៃ ជាសប្បុរស កាលប្រតិបត្តិត្រូវក្នុងសាវកនៃព្រះតថាគត ឈ្មោះថា រក្សាខ្លួនដែលខ្លួនមិនបានជីកគាស់ មិនបានកម្ចាត់គុណចោល ជាអ្នកមិនមានទោសផង មិនមានសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបុណ្យដ៏ច្រើនផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាបណ្ឌិតឈ្លាសវៃ ជាសប្បុរស កាលប្រតិបត្តិត្រូវក្នុងបុគ្គល ៤ ពួកនេះឯង ឈ្មោះថា រក្សាខ្លួនដែលខ្លួនមិនបានជីកគាស់ មិនបានកម្ចាត់គុណចោល ជាអ្នកមិនមានទោសផង មិនមានសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបុណ្យដ៏ច្រើនផង ។

ជនណាប្រតិបត្តិខុសក្នុងមាតា ១ ក្នុងបិតា ១ ក្នុងព្រះតថាគត
ជាសម្ពុទ្ធ ១ ក្នុងសាវករបស់ព្រះតថាគតនោះ ១ ជនដូច្នោះនោះ

រមែងបាននូវបាបដ៏ច្រើន ។ ក្នុងលោកនេះ បណ្ឌិតទាំងឡាយ រមែងតិះដៀលបុគ្គលនោះ លុះបុគ្គលនោះទៅកាន់លោកខាងមុខហើយ រមែងទៅកាន់អបាយទៀត ព្រោះការប្រព្រឹត្តមិនត្រូវតាមធម៌នោះ ក្នុងមាតា និងបិតាទាំងឡាយ ។ ជនណាប្រតិបត្តិត្រូវក្នុងមាតា ១ ក្នុងបិតា ១ ក្នុងព្រះតថាគតជាសម្ពុទ្ធ ១ ក្នុងសាវករបស់ព្រះតថាគតនោះ ១ ជនដូច្នោះនោះ រមែងបាននូវបុណ្យដ៏ច្រើន ។ ក្នុងលោកនេះ បណ្ឌិតទាំងឡាយ រមែងសរសើរ ជននោះ លុះជននោះទៅកាន់លោកខាងមុខហើយ រមែងរីករាយក្នុងស្ថានសួគ៌ ព្រោះការប្រព្រឹត្តត្រូវតាមធម៌នោះ ចំពោះមាតា និងបិតាទាំងឡាយ ។

# អដ្ឋកថា

## ទុតិយខតសូត្រ

[ ៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយខតសូត្រទី ៤ ដូចតទៅនេះ បទថា **មាតរិ បិតរិ ច** ជាដើម នាយមិត្តវិន្ទុកៈ ឈ្មោះថា បដិបត្តិខុសក្នុងមាតា ។ ព្រះបាទអជាតសត្តុ ឈ្មោះថា បដិបត្តិខុសក្នុងបិតា ។ ទេវទត្ត ឈ្មោះថា បដិបត្តិខុសក្នុងព្រះតថាគត ។ កោកាលិកៈ ឈ្មោះថា បដិបត្តិខុសក្នុងសាវករបស់ព្រះតថាគត ។ បទថា **ពហុញ្ច** ប្រែថា ច្រើន ។ បទថា **បសវតិ**

ប្រែថា រមែងបាន ។ បទថា **ញាយ** សេចក្តីថា ដោយការប្រព្រឹត្តធម៌ ពោល គឺបដិបត្តិខុសនោះ ។ បទថា **ឥតោ** គឺទៅអំពីលោកនេះ ។ បទថា **អញ្ញតរ គច្ឆតិ** គឺបុគ្គលកាលកើតឡើងក្នុងនរកជាដើមណាមួយ ។ ឯក្នុងសុក្កបក្ខ ក៏មានន័យដូចគ្នា ។ល។

**អដ្ឋកថា ទុតិយខតសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## អនុសោតសូត្រទី ៥

[ ៥ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះរមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលមានដំណើរទៅបណ្តោយតាមខ្សែទឹក ១ បុគ្គលមានដំណើរទៅច្រាសខ្សែទឹក ១ បុគ្គលមានសភាពជាអ្នកឈរនៅ ១ បុគ្គលបានឆ្លងទៅដល់ត្រើយនាយហើយ ជាព្រាហ្មណ៍ឋិតនៅលើគោក ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានដំណើរទៅបណ្តោយតាមខ្សែទឹក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ តែងសេពកាមទាំងឡាយផង តែងធ្វើអំពើអាក្រក់ផង ។ ម្នាលភិក្ខុទាំងឡាយនេះហៅថា បុគ្គលមានដំណើរទៅបណ្តោយតាមខ្សែទឹក ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលមានដំណើរទៅច្រាសខ្សែទឹក តើដូចម្តេច ។ ម្នាលភិក្ខុទាំង-

ឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនសេពកាមទាំងឡាយផង មិនធ្វើអំពើអាក្រក់ផង តែជាអ្នកប្រកបដោយទុក្ខ និងទោមនស្ស មានមុខទទឹកដោយទឹកភ្នែក ទួញយំ ខំប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិបូណ៌បរិសុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានដំណើរទៅប្រាសខ្សែទឹក ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានសភាពជាអ្នកឈរនៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាឱបបាតិកបរិនិព្វានក្នុងលោកនោះ មានការមិនបានត្រឡប់ចាកលោកនោះជាធម្មតា ព្រោះអស់ទៅនៃឱរម្ភាគិយ-សំយោជនៈទាំង ៥ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានសភាពជាអ្នកស្ថិតនៅ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលបានឆ្លងទៅដល់ត្រើយនាយជាព្រាហ្មណ៍ ស្ថិតនៅលើគោក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង ហើយសម្រេចសម្រាន្តនៅក្នុងបច្ចុប្បន្ននេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលបានឆ្លងទៅដល់ត្រើយនាយហើយ ជាព្រាហ្មណ៍ ស្ថិតនៅលើគោក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះឯង រមែងមានទៅក្នុងលោក ។

ជនទាំងឡាយណានីមួយ មិនសង្រួមក្នុងកាមទាំងឡាយ មិន
បានប្រាសចាករាគៈ ជាអ្នកបរិភោគកាមក្នុងលោកនេះ ជន
ទាំងនោះឯង តែងចូលទៅកាន់ជាតិ និងជរាជារឿយៗ ត្រូវ

តណ្ហាគ្របសង្កត់ ឈ្មោះថា ជាអ្នកមានដំណើរទៅបណ្តោយតាមខ្សែទឹក ។ ព្រោះហេតុនោះ បុគ្គលអ្នកមានប្រាជ្ញាក្នុងលោកនេះ ជាអ្នកមានសតិតម្កល់ខ្ជាប់ មិនសេពកាមទាំង-ឡាយផង មិនធ្វើនូវអំពើអាក្រក់ទាំងឡាយផង តែជាអ្នកប្រកបដោយទុក្ខ លះបង់កាម ទើបអ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គលនោះថា ជាអ្នកមានដំណើរទៅច្រាសខ្សែទឹក។ ជនណាលះបង់នូវកិលេសទាំង ៥ មានការសិក្សាបរិបូណ៌ហើយ មានសភាពមិនបានសាបសូន្យ ជាអ្នកដល់នូវការស្ទាត់ជំនាញដោយចិត្ត មានឥន្ទ្រិយតម្កល់មាំ ជននោះឯង ហៅថា មានសភាពជាអ្នកស្ថិតនៅ ។ ធម៌ទាំងឡាយ ដ៏ឧត្តម និងលាមកដែលខ្លួនបានត្រាស់ដឹងហើយ បានកម្ចាត់ចោលហើយ ដល់នូវសេចក្តីវិនាសទៅ មិនមានដល់បុគ្គលណា បុគ្គលនោះហៅថា អ្នកចេះចប់នូវត្រៃវេទ មានមគ្គព្រហ្មចរិយៈ នៅស្រេចហើយ ដល់នូវទីបំផុតនៃត្រៃលោក ដល់នូវត្រើយហើយ ។

# អដ្ឋកថា

## អនុសោតសូត្រ

[ ៥ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងអនុសោតសូត្រទី ៥ ដូចតទៅនេះ បុគ្គលឈ្មោះថា **អនុសោតគាមី** ព្រោះទៅតាមក្រសែ ។ ឈ្មោះថា **បដិសោតគាមី** ព្រោះទៅច្រាស់ក្រសែ គឺកិលេស ដោយបដិបត្តិដែលជាសត្រូវ ។ បទថា **ឋិតត្តោ** គឺមានការតាំងខ្លួនបានហើយ ។ បទថា **តិណ្ណោ** បានដល់ ឆ្លងឱឃៈតាំងនៅហើយ ។ បទថា **បារគតោ** បានដល់ ដល់នូវត្រើយដទៃ ។ បទថា **ថលេ តិដ្ឋតិ** បានដល់ នៅលើគោក គឺ និព្វាន ។ បទថា **ព្រាហ្មណោ** បានដល់ ជាបុគ្គលប្រសើរ មិនមានទោស ។ បទថា **ឥធ** ប្រែថា ក្នុងលោកនេះ ។ បទថា **កាមេ ច បដិសេវតិ** បានដល់ សេពវត្ថុកាម ដោយកិលេសកាម ។ បទថា **បាបញ្ច កម្មំ ករោតិ** បានដល់ រមែងធ្វើកម្ម មានបាណាតិបាតជាដើម ដែលជាបាប ។ បទថា **បាបញ្ច កម្មំ ន ករោតិ** បានដល់ មិនធ្វើកម្ម គឺពៀរ ៥ ។ បទថា **អយំ វុច្ចតិ ភិក្ខវេ ឋិតត្តោ** សេចក្តីថា អនាគាមិបុគ្គលនោះ ឈ្មោះថា តម្កល់ខ្លួនបានហើយ ដោយអំណាចការមិនត្រឡប់អំពីលោកនោះ ដោយកាន់យកបដិសន្ធិទៀត ។ បទថា **តណ្ហាធិបន្នា** សេចក្តីថា ពួកជនដែលត្រូវតណ្ហាគ្របសង្កត់ គឺគ្របសង្កត់ ឬចូលដល់ គឺឈមចុះកាន់តណ្ហា ។ បទថា **បរិបុណ្ណសេក្ខោ** បានដល់ តាំងនៅក្នុងភាពបរិបូណ៌ដោយសិក្ខា ។ បទថា **អបរិហានធម្មោ** បានដល់ មានការមិនវិនាសជាសភាវៈ ។ បទថា **ចេតោវសិប្បត្តោ** បានដល់ ជាអ្នក

ជំនាញផ្លូវចិត្ត ។ បុគ្គលបែបនេះ រមែងជាព្រះខីណាស្រព ។ តែក្នុងសេចក្តីនេះ ត្រាស់ដល់អនាគាមិបុគ្គល ។ បទថា **សមាហិតិន្ទ្រិយោ** បានដល់ ដែលមានឥន្ទ្រិយមាំទាំហើយ ។ បទថា **បរោបរា** បានដល់ ធម៌យ៉ាងឧត្តម និងធម៌យ៉ាងថោកទាប អធិប្បាយថា កុសលធម៌ និងអកុសលធម៌ ។ បទថា **សមេច្ច** បានដល់ មកព្រមគ្នាដោយញាណ ។ បទថា **វិធូបិតា** បានដល់ ដែលលោកកម្ចាត់ ឬដុតហើយ ។ បទថា **វុសិតព្រហ្មចរិយោ** សេចក្តីថា នៅចប់មគ្គព្រហ្មចរិយៈ ។ បទថា **លោកន្តគូ** សេចក្តីថា ដល់នូវទីបំផុតនៃលោកទាំង ៣ ។ បទថា **ចារគតោ** សេចក្តីថា ជាអ្នកដល់នូវត្រើយដោយអាការ ៦ ។ ក្នុងសេចក្តីនេះ ត្រាស់តែព្រះខីណាស្រពប៉ុណ្ណោះ តែវដ្តៈ និងវិវដ្តៈ គឺលោកិយ និងលោកុត្តរ ត្រាស់ក្នុងសូត្រផង ក្នុងគាថាផង ដោយប្រការដូច្នេះ ។ល។

**អដ្ឋកថា អនុសោតសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## អប្បសុតសូត្រទី ៦

[ ៦ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលចេះដឹងតិច មិនបាន

ប្រកបដោយការចេះដឹង ១ មានសេចក្តីចេះដឹងតិច បានប្រកបដោយការចេះដឹង ១ មានសេចក្តីចេះដឹងច្រើន មិនបានប្រកបដោយការចេះដឹង ១ មានសេចក្តីចេះដឹងច្រើន ហើយបានប្រកបដោយការចេះដឹង ១ ។ ម្នាលភិក្ខុទាំង-ឡាយ ចុះបុគ្គលមានសេចក្តីចេះដឹងតិច មិនបានប្រកបដោយការចេះដឹង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពុទ្ធវចនៈ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ មានតិចដល់បុគ្គលពួកខ្លះ ក្នុងលោកនេះ បុគ្គលនោះមិនចេះអដ្ឋកថា មិនចេះបាលីនៃពុទ្ធវចនៈ មានប្រមាណតិចនោះ មិនប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ។ ម្នាលភិក្ខុទាំង-ឡាយ យ៉ាងនេះឯង ឈ្មោះថា បុគ្គលមានសេចក្តីចេះដឹងតិច មិនបានប្រកបដោយការចេះដឹង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានសេចក្តីចេះដឹងតិច បានប្រកបដោយការចេះដឹង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពុទ្ធវចនៈ គឺសុត្តៈ គេយ្យៈ ។បេ។ វេទល្លៈ មានតិចដល់បុគ្គលពួកខ្លះ ក្នុងលោកនេះ បុគ្គលនោះចេះអដ្ឋកថា ចេះបាលីនៃពុទ្ធវចនៈ មានប្រមាណតិចនោះ ប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងឈ្មោះថា បុគ្គលមានសេចក្តីចេះដឹងតិច បានប្រកបដោយការចេះដឹង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានសេចក្តីចេះដឹងច្រើន តែមិនបានប្រកបដោយការចេះដឹង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពុទ្ធវចនៈ គឺសុត្តៈ គេយ្យៈ ។បេ។ វេទល្លៈ មានច្រើនដល់បុគ្គលពួកខ្លះក្នុងលោកនេះ បុគ្គលនោះមិនចេះអដ្ឋកថា មិនចេះបាលីនៃពុទ្ធវចនៈ មានប្រមាណច្រើននោះ មិនប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ។

ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងឈ្មោះថា បុគ្គលមានសេចក្តីចេះដឹងច្រើន តែមិនបានប្រកបដោយការចេះដឹង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានសេចក្តីចេះច្រើន ប្រកបដោយការចេះដឹង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពុទ្ធវចនៈ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ មានច្រើនដល់បុគ្គលពួកខ្លះ ក្នុងលោកនេះ បុគ្គលនោះចេះអដ្ឋកថា ចេះបាលីនៃពុទ្ធវចនៈ មានប្រមាណច្រើននោះ ហើយប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា បុគ្គលមានសេចក្តីចេះដឹងច្រើន ប្រកបដោយការចេះដឹង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះឯង រមែងមាននៅក្នុងលោក ។

បើបុគ្គលមានសេចក្តីចេះដឹងតិច ទាំងមិនបានស្ថិតនៅក្នុងសីលទាំងឡាយ អ្នកប្រាជ្ញទាំងឡាយ រមែងតិះដៀលបុគ្គលនោះដោយហេតុទាំង ២ គឺសីល ១ សេចក្តីចេះដឹង ១ ។ បើបុគ្គលមានសេចក្តីចេះដឹងតិច តែស្ថិតនៅខ្ជាប់ខ្ជួនក្នុងសីលទាំងឡាយ អ្នកប្រាជ្ញទាំងឡាយ តែងសរសើរបុគ្គលនោះតែដោយសីល ប៉ុន្តែសេចក្តីចេះ ដឹងមិនសម្រេចដល់បុគ្គលនោះទេ ។ បើបុគ្គលមានសេចក្តីចេះដឹងច្រើន តែមិនស្ថិតនៅក្នុងសីលទាំងឡាយទេ អ្នកប្រាជ្ញទាំងឡាយ រមែងតិះដៀលបុគ្គលនោះដោយសីល ប៉ុន្តែសេចក្តីចេះដឹង តែងសម្រេចដល់បុគ្គលនោះ ។ បើបុគ្គលមានសេចក្តីចេះដឹងច្រើន ទាំងតាំងនៅខ្ជាប់ខ្ជួន ក្នុងសីលទាំងឡាយ

អ្នកប្រាជ្ញទាំងឡាយ រមែងសរសើរបុគ្គលនោះ ដោយហេតុទាំង ២ គឺសីល ១ សេចក្តីចេះដឹង ១ ។ អ្នកណាគួរនិន្ទាបុគ្គលអ្នកមានសេចក្តីចេះដឹងច្រើន ទ្រទ្រង់នូវធម៌ ប្រកបដោយបញ្ញា ជាពុទ្ធសាវកនោះ ដែលដូចជាដុំនៃមាសជម្ពូនទបាន ទេវតា និងមនុស្សទាំងឡាយ រមែងសរសើរបុគ្គលនោះ សូម្បីព្រហ្មក៏សរសើរដែរ ។

# អដ្ឋកថា

## អប្បស្សុតសូត្រ

## អធិប្បាយ សុត្តៈ និងគេយ្យៈជាដើម

[ ៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអប្បស្សុតសូត្រទី ៦ ដូចតទៅនេះ បទថា **អនុបបន្នោ** ប្រែថា មិនចូលដល់ ។ ក្នុងបទថា **សុត្តំ** ជាដើមនេះ ឧភតោវិភង្គ និទ្ទេស ខន្ធកៈ បរិវារ សុត្តនិបាត មង្គលសូត្រ រតនសូត្រ នាលកសូត្រ តុវដ្ដកសូត្រ ព្រះតម្រាស់របស់ព្រះតថាគតដទៃ មានឈ្មោះថាសូត្រ គប្បីជ្រាបថា **សុត្ត** ។ ព្រះសូត្រដែលមានគាថាទាំងអស់ គប្បីជ្រាបថា គេយ្យៈ ។ ដោយចំពោះយ៉ាងក្រៃលែង ក្នុងសំយុត្តនិកាយ សគាថវគ្គទាំងអស់ អភិធម្មបិដកទាំងអស់ សូត្រដែលមិនមានគាថា ព្រះពុទ្ធវចនៈដទៃ

ដែលមិនសង្គ្រោះនឹងអង្គ ៨ ដទៃ គប្បីជ្រាបថា វេយ្យាករណ៍ ។ ធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ មិនមានឈ្មោះព្រះសូត្រ ក្នុងសុត្តនិបាត គប្បីជ្រាបថា ជាគាថា ។ ព្រះសូត្រ ៨២ ដែលប្រកបដោយគាថា ដែលសម្រេចមកអំពីសោមនស្សញ្ញាណ គប្បីជ្រាបថា ឧទាន ។ ព្រះសូត្រ ១១០ ដែលប្រព្រឹត្តទៅដោយន័យជាដើមថា **វុត្តមិទំ ភគវតា** ដូច្នេះ គប្បីជ្រាបថា ជា **ឥតិវុត្តក** ។ ជាតក ៥៥០ មានអបណ្ណកជាតកជាដើម គប្បីជ្រាបថា ជាតក ។ ព្រះសូត្រដែលប្រកបដោយធម៌ដែលគួរអស្ចារ្យ មិនធ្លាប់មានទាំងអស់ ដែលប្រព្រឹត្តទៅដោយន័យជាដើមថា **ចត្តារោ មេ ភិក្ខវេ អច្ឆរិយា អព្ភុតធម្មា អានន្ទេ** គប្បីជ្រាបថា អព្ភុតធម៌ ។ ព្រះសូត្រទាំងពួងដែលសួរហើយ បាននូវការចេះដឹង និងការត្រេកអរ មានចូឡវេទល្លសូត្រ មហាវេទល្លសូត្រ និងសម្មាទិដ្ឋិសូត្រ សក្កបញ្ហសូត្រ សង្ខារភាជនីយសូត្រ មហាបុណ្ណមសូត្រជាដើម គប្បីជ្រាបថា វេទល្ល ។

បទថា **ន អត្ថមញ្ញាយ ធម្មញ្ញាយ** សេចក្តីថា មិនដឹងអដ្ឋកថា និងបាលី ។

បទថា **ធម្មានុធម្មប្បដិបន្នោ** សេចក្តីថា រមែងមិនបដិបត្តិធម៌សមគួរដល់លោកុត្តរធម៌ ៩ គឺបដិបទាខាងដើម មួយអន្លើដោយសីល ។ គប្បីជ្រាបអត្ថក្នុងវារៈទាំងអស់ដោយឧបាយនេះ ។ ឯវារៈទី ១ ក្នុងព្រះសូត្រនេះ ត្រាស់ដល់បុគ្គលដែលមានសុតតិច ទុស្សីល ក្នុងវារៈទី ២ ត្រាស់ដល់បុគ្គលដែលមានសុតតិច តែជាព្រះខីណាស្រព ក្នុងវារៈទី ៣ ត្រាស់ដល់

បុគ្គលដែលមានសុតច្រើន តែទ្រុស្តសីល ក្នុងវារៈទី ៤ ត្រាស់ដល់បុគ្គលដែលមានសុតច្រើនផង ជាព្រះខីណាស្រពផង ។ បទថា **សីលេសុ អសមាហិតោ** សេចក្តីថា មិនធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ។ បទថា **សីលតោ ច សុតេន ច** សេចក្តីថា អ្នកប្រាជ្ញទាំងឡាយ រមែងតិះដៀលបុគ្គលនោះ ដោយចំណែកនៃសីលផង ដោយចំណែកសុតផង យ៉ាងនេះថា បុគ្គលនេះ ទ្រុស្តសីល មានសុតតិច ។ បទថា **តស្ស សម្បជ្ជតេ សុតំ** សេចក្តីថា សុតៈនៃបុគ្គលនោះ ឈ្មោះថា សម្បូរ ព្រោះហេតុដែលកិច្ច គឺសុតៈដែលបុគ្គលនោះ ធ្វើហើយដោយសុតៈនោះ ។ បទថា **ណាស្ស សម្បជ្ជតេ** សេចក្តីថា សុតកិច្ច ឈ្មោះថា មិនសម្បូរ ព្រោះកិច្ច គឺសុតៈដែលបុគ្គលមិនបានធ្វើ ។ បទថា **ធម្មធរំ** បានដល់ ជាបុគ្គលទ្រទ្រង់នូវធម៌ដែលស្តាប់ហើយបាន ។ បទថា **សប្បញ្ញំ** បានដល់ មានបញ្ញាល្អ ។ បទថា **នេក្ខំ ជម្ពោនទស្សេវ** សេចក្តីថា មាសតាមធម្មជាតិ គេហៅថា ជម្ពូនុទ ដូចដុំនៃជម្ពូនុទនោះ គឺដូចមាសទឹក ៥ ។

## អដ្ឋកថា អប្បស្សុតសូត្រទី ៦ ចប់

# សុត្តន្តបិដក

## សង្ឃសោភណសូត្រទី ៧

[ ៧ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលឆ្លៀវឆ្លាសវាងវៃ ក្លៀវក្លា ជាអ្នកចេះដឹងច្រើន ទ្រទ្រង់នូវធម៌ ប្រតិបត្តិធម៌ដ៏សមគួរដល់ឋានៈនៃបុគ្គល ៤ ពួកនេះ រមែងញុំាំងសង្ឃឲ្យរុងរឿង ។ បុគ្គល ៤ ពួក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឆ្លៀវឆ្លាស វាងវៃ ក្លៀវក្លា ជាអ្នកចេះដឹងច្រើន ទ្រទ្រង់នូវធម៌ ប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ រមែងញុំាំងសង្ឃឲ្យរុងរឿង ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី ។បេ។ ម្នាលភិក្ខុទាំងឡាយ ឧបាសក ។បេ។ ម្នាលភិក្ខុទាំងឡាយ ឧបាសិកា ឆ្លៀវឆ្លាស វាងវៃ ក្លៀវក្លា ជាអ្នកចេះដឹងច្រើន ទ្រទ្រង់នូវធម៌ ប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ រមែងញុំាំងសង្ឃឲ្យរុងរឿង ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលឆ្លៀវឆ្លាស វាងវៃ ក្លៀវក្លា ជាអ្នកចេះដឹងច្រើន ទ្រទ្រង់នូវធម៌ ប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ទាំង ៤ ពួកនេះឯង រមែងញុំាំងសង្ឃឲ្យរុងរឿង ។

បុគ្គលណា ឆ្លៀវឆ្លាស ក្លៀវក្លា ជាអ្នកចេះដឹងច្រើន ទ្រទ្រង់
នូវធម៌ ជាអ្នកប្រព្រឹត្តធម៌ដ៏សមគួរដល់ធម៌ បុគ្គលប្រាកដដូច្នោះ
នោះ ឈ្មោះថា ញុំាំងសង្ឃឲ្យរុងរឿង ។ គឺភិក្ខុបរិបូណ៌ដោយ
សីល ១ ភិក្ខុនី មានសេចក្តីចេះដឹងច្រើន ១ ឧបាសកមាន
សទ្ធា ១ ឧបាសិកាមានសទ្ធា ១ បុគ្គលទាំងអម្បាលនេះឯង
រមែងញុំាំងសង្ឃឲ្យរុងរឿង ព្រោះថា បុគ្គលទាំងនេះ ជាអ្នក
ធ្វើសង្ឃឲ្យរុងរឿង ។

# អដ្ឋកថា

## សង្ឃសោភណសូត្រ

[ ៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសង្ឃសោភណសូត្រទី ៧ ដូចតទៅនេះ បទថា **វិយត្តា** បានដល់ បុគ្គលដែលប្រកបដោយបញ្ញាក្លៀវក្លា ។ បទថា **វិនីតា** សេចក្តីថា បុគ្គលចូលដល់វិន័យដែលលោកទូន្មានល្អ ។ បទថា **វិសារទា** សេចក្តីថា ប្រកបដោយសេចក្តីក្លាហាន គឺញាណសហគតៈដោយសោមនស្ស ។ បទថា **ធម្មធរា** គឺទ្រទ្រង់នូវធម៌ដែលស្តាប់មកហើយបាន ។ បទថា **ភិក្ខុ ច សីលសម្បន្នោ** សេចក្តីថា ក្នុងគាថាត្រាស់គុណតែម្យ៉ាងដល់បុគ្គលមួយក៏ពិត តែគុណធម៌ទាំងពួង ក៏រមែងគួរទាំងអស់ដល់លោកទាំងនោះ ។ល។

**អដ្ឋកថា សង្ឃសោភណសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## វេសារជ្ជសូត្រទី ៨

[ ៨ ] ម្នាលភិក្ខុទាំងឡាយ តថាគតប្រកបដោយវេសារជ្ជញាណ ( ប្រាជ្ញាក្លៀវក្លា ) បែបណា តែងប្ដេជ្ញានូវទីដ៏ប្រសើរ បន្លឺនូវសីហនាទក្នុងពួកបរិស័ទ ញ៉ាំងព្រហ្មចក្រ ( ចក្រ គឺធម៌ដ៏ប្រសើរ ) ឲ្យប្រព្រឹត្តទៅបាន

វេសារជ្ជញ្ញាណនេះ របស់តថាគតមាន ៤ យ៉ាង ។ វេសារជ្ជញ្ញាណ ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញនូវនិមិត្ត គឺធម៌ ឬបុគ្គលទុំះថា សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី បុគ្គលណាមួយក្នុងលោកក្តី នឹងចោទតថាគតដោយពាក្យប្រកបដោយធម៌ក្នុងហេតុនោះថា លោកប្តេជ្ញាខ្លួនថាជាអ្នកត្រាស់ដឹងឯងដោយប្រពៃ ប៉ុន្តែ ធម៌ទាំងអម្បាលនេះ លោកមិនបានត្រាស់ដឹងទេ ម្នាលភិក្ខុទាំងឡាយ កាលតថាគតមិនឃើញនូវនិមិត្តទុំះឯង ទើបដល់នូវសេចក្តីក្សេម ដល់នូវភាពជាអ្នកមិនមានភ័យ ដល់នូវភាពជាអ្នកក្លៀវក្លា ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញនូវនិមិត្ត គឺធម៌ ឬបុគ្គលទុំះថា សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី បុគ្គលណាមួយក្នុងលោកក្តី នឹងចោទតថាគតដោយពាក្យប្រកបដោយធម៌ក្នុងហេតុនោះថា លោកប្តេជ្ញាខ្លួនថាជាអ្នកអស់អាសវៈហើយ ប៉ុន្តែអាសវៈទាំងអម្បាលនេះ មិនទាន់អស់ទេ ម្នាលភិក្ខុទាំងឡាយ កាលតថាគតមិនឃើញនូវនិមិត្តទុំះឯង ទើបដល់នូវសេចក្តីក្សេម ដល់នូវភាពជាអ្នកមិនមានភ័យ ដល់នូវភាពជាអ្នកក្លៀវក្លា ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញនូវនិមិត្ត គឺធម៌ ឬបុគ្គលទុំះថា សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី បុគ្គលណាមួយក្នុងលោកក្តី នឹងចោទតថាគតដោយពាក្យប្រកបដោយធម៌ក្នុងហេតុនោះថា ធម៌ទាំងឡាយណាដែលលោកពោលថា ធម៌ជាគ្រឿងធ្វើនូវអន្តរាយ ធម៌ទាំងអម្បាលនោះ មិនអាចធ្វើអន្តរាយដល់បុគ្គលអ្នកសេពបានទេ ម្នាលភិក្ខុទាំងឡាយ កាលតថាគតមិន

ឃើញនូវនិមិត្តនុ៎ះឯង ទើបដល់នូវសេចក្តីក្សេម ដល់នូវភាពជាអ្នកមិនមានភ័យ ដល់នូវភាពជាអ្នកក្លៀវក្លា ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញនូវនិមិត្ត គឺធម៌ ឬបុគ្គលនុ៎ះថា សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី បុគ្គលណាមួយក្នុងលោកក្តី នឹងចោទតថាគតដោយពាក្យប្រកបដោយធម៌ក្នុងហេតុនោះថា ធម៌ដែលលោកសម្តែងហើយ ដើម្បីប្រយោជន៍ដល់គុណវិសេសណា គុណវិសេសនោះមិនអាចស្រោចស្រង់ ដើម្បីឲ្យអស់ទៅនៃទុក្ខដោយប្រពៃ ដល់អ្នកធ្វើតាមនូវធម៌នោះទេ ម្នាលភិក្ខុទាំងឡាយ កាលតថាគតឃើញនូវនិមិត្តនុ៎ះឯង ទើបដល់នូវសេចក្តីក្សេម ដល់នូវភាពជាអ្នកមិនមានភ័យ ដល់នូវភាពជាអ្នកក្លៀវក្លា ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតប្រកបដោយវេសារជ្ជញាណណា តែងប្តេជ្ញានូវទីដ៏ប្រសើរ បន្លឺនូវសីហនាទ ក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅបាន វេសារជ្ជញាណនោះរបស់តថាគត មាន ៤ យ៉ាងនេះឯង ។

គន្លងនៃពាក្យណានីមួយដ៏ច្រើន ដែលគេរៀបរៀងទុកហើយក្តី
ពួកសមណព្រាហ្មណ៍ ដែលអាស្រ័យនូវគន្លងនៃពាក្យណាក្តី
គន្លងពាក្យទាំងនោះ លុះមកដល់ព្រះតថាគត ដែលជាអ្នក
មានសេចក្តីក្លៀវក្លា គ្របសង្កត់នូវគន្លងនៃពាក្យហើយ ក៏រមែង
វិនាសសាបសូន្យទៅ ព្រះតថាគតណា គ្របសង្កត់នូវធម៌
ទាំងអស់ មានសេចក្តីអនុគ្រោះដល់សត្វទាំងអស់ ហើយ
ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ពួកសត្វតែងថ្វាយបង្គំនូវព្រះ

*តថាគត ប្រាកដដូច្នោះនោះ ព្រះអង្គប្រសើរជាងទេវតា និង មនុស្ស ទ្រង់ចូលដល់ត្រើយនៃភព ។*

# អដ្ឋកថា

## វេសារជ្ជសូត្រ

*[ ៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវេសារជ្ជសូត្រទី ៨ ដូចតទៅនេះ បទថា* **វេសារជ្ជានិ** *នេះ ធម៌ដែលជាបដិបក្ខចំពោះការខ្លាច ឈ្មោះថា វេសារជ្ជៈ គឺ ញាណជាហេតុឲ្យអង់អាច ។ វេសារជ្ជៈនេះ ជាឈ្មោះនៃសោមនស្សញាណ ដែលកើតឡើងដល់ព្រះតថាគត បុគ្គលពិចារណាឃើញការមិនមាននូវការ អង់អាចនោះក្នុងឋានៈ ៤ ។ បទថា* **អាសភណ្ឋានំ** *សេចក្តីថា ឋានៈដ៏ ប្រសើរ គឺឋានៈដ៏ឧត្តមក្តី ព្រះពុទ្ធទាំងឡាយក្នុងកាលមុន ជាអ្នកអង់អាចក្តី ។ ឋានៈរបស់ព្រះពុទ្ធទាំងឡាយនោះ ។ ន័យម្យ៉ាងទៀត មេហ្វូងនៃគោ ១០០ ឈ្មោះថា* **ឧសភៈ** *មេហ្វូងនៃគោ ១០០០ ឈ្មោះថា* **វសភៈ** *ឬគោឧសភៈ ជាមេក្រោលគោ ១០០ ក្រោល គោវសភៈ ជាមេក្រោលគោ ១០០០ ក្រោល គោនិសភៈ ប្រសើរបំផុតនៃគោទាំងអស់ អត់ធន់ចំពោះអន្តរាយគ្រប់យ៉ាង ជាគោ-សគួរស្រឡាញ់ នាំការៈទៅបានច្រើនផង មិនញាប់ញ័រដោយសំឡេង រន្ទះ ១០០ ផង ១០០០ ផងផង គោនិសភៈនោះ លោកបំណងយកគោឧសភៈ*

ក្នុងទីនេះ នេះជាពាក្យហៅគោឧសភៈ នោះដោយបរិយាយ ។ ឈ្មោះថា អាសភៈ ព្រោះឋានៈនេះជារបស់គោឧសភៈ ។ បទថា **ឋានំ** បានដល់ការយកជើងទាំង ៤ កាយផែនដីឈរ ។ ឯឋានៈនេះ ឈ្មោះថា អាសភៈ ព្រោះដូចការឈររបស់គោឧសភៈ ។ គោឧសភៈដែលរាប់ថា គោនិសភៈ យកជើង ៤ កាយផែនដី ហើយឈរដោយមិនញាប់ញ័រ យ៉ាងណា តថាគតក៏កាយនូវផែនដី គឺបរិស័ទ ៨ ដោយព្រះបាទ គឺវេសារជ្ជញ្ញាណ ៤ មិនញាប់ញ័រដោយសត្រូវ និងបច្ចាមិត្រណាមួយក្នុងលោក ព្រមទាំងទេវលោក ឈរដោយមិនញាប់ញ័រ ក៏ដូច្នោះ ។ តថាគតកាលឈរយ៉ាងនេះ ទើបប្តេជ្ញាឋានៈរបស់បុគ្គលអង់អាចចូលដល់ មិនសម្តែងត្រឡប់លើកឡើងទុកក្នុងព្រះកាយ ដោយហេតុនោះ ទើបត្រាស់ថា **អាសភណ្ឋានំ បដិជានាតិ** ដូច្នេះ ។

បទថា **បរិសាសុ** បានដល់ ក្នុងបរិស័ទទាំង ៨ ។ បទថា **សីហនាទំ នទតិ** សេចក្តីថា បន្លឺសំឡេងសម្តែងអំណាចដ៏ប្រសើរបំផុត សំឡេងសម្តែងអំណាចរបស់រាជសីហ៍ ឬបន្លឺសំឡេងសម្តែងអំណាច ដូចការបន្លឺសីហនាទនៃរាជសីហ៍ ។ សេចក្តីនេះ គប្បីសម្តែងដោយសីហនាទសូត្រ ។ រាជសីហ៍ហៅថា សីហៈ ព្រោះអត់ធន់ និងព្រោះចាប់ចំណី យ៉ាងណា តថាគតក៏ដូច្នោះ ហៅថា សីហៈ ព្រោះទ្រង់អត់ធន់នូវលោកធម៌ទាំងឡាយ និងព្រោះទ្រង់កម្ចាត់លទ្ធិដទៃ ។ ការបន្លឺរបស់សីហៈដែលលោកពោលយ៉ាងនេះ ហៅថា សីហនាទ ។ ក្នុងសីហនាទនោះ រាជសីហ៍ ប្រកបដោយកម្លាំងរបស់រាជសីហ៍ ក្លាហាន ក្នុងទីទាំងពួង ប្រាសចាកការព្រឺរោម ព្រឺស្បែក បន្លឺសីហនាទ

យ៉ាងណា សីហៈ គឺតថាគតក៏ដូច្នោះ ប្រកបដោយកម្លាំងរបស់តថាគត ជាអ្នកក្លាហានក្នុងបរិស័ទទាំង ៨ ប្រាសចាកការព្រឺរោម រមែងបន្លឺសីហនាទដែលប្រកបដោយលម្អនៃទេសនា នៃបែបផ្សេងៗ ដោយន័យជាដើមថា យ៉ាងនេះរូប ។ ដោយហេតុនោះ ទើបត្រាស់ថា **បរិសាសុ សីហនាទំ នទតិ** ដូច្នេះ ។

បទថា **ព្រហ្មំ** ក្នុងបទថា **ព្រហ្មចក្កំ បវត្តេតិ** នេះ បានដល់ ចក្រដ៏ប្រសើរឧត្តមដ៏បរិសុទ្ធ **ចក្ក** សព្ទនេះ រមែងប្រើក្នុងអត្ថថា សម្បត្តិ លក្ខណៈ ចំណែកនៃរថ ឥរិយាបថ ទាន រតនចក្រ ធម្មចក្ក និងខុរចក្រ បហរចក្រ អសនិមណ្ឌលជាដើម ក្នុងទីនេះ ប្រើក្នុងអត្ថថា **ធម្មចក្ក** គប្បីធ្វើធម្មចក្កឲ្យជាក់ច្បាស់ ចែកជា ២ ប្រការ ។

ពិតហើយ **ចក្ក** សព្ទនេះ រមែងប្រាកដក្នុងសម្បត្តិ ដូចក្នុងប្រយោគទាំងឡាយថា **ចត្តារិមានិ ភិក្ខវេ ចក្កានិ យេហិ សមន្នាគតានំ ទេវ-មនុស្សានំ** ម្នាលភិក្ខុទាំងឡាយ ចក្កនេះមាន ៤ យ៉ាង ចក្កនេះ តែងប្រព្រឹត្តទៅដល់ពួកទេវតា និងមនុស្សដែលប្រកបព្រមដោយចក្ក ... ។ ប្រើក្នុងអត្ថថា លក្ខណៈ ដូចក្នុងប្រយោគជាដើមថា **បាទតលេសុ ចក្កានិ ជាតានិ** ចក្កទាំងឡាយកើតមានត្រង់ផ្ទៃព្រះបាទានៃព្រះរាជកុមារនេះ ។ ប្រើក្នុងអត្ថថា អង្គនៃរថ ដូចក្នុងប្រយោគជាដើមថា **ចក្កំវ វហតោ បទំ** ដូចកង់រទេះវិលតាមជានជើងគោ ដែលកំពុងអូសទៅ ។ ប្រើក្នុងអត្ថថា ឥរិយាបថ ដូចក្នុងប្រយោគជាដើមថា **ចតុចក្កំ នវទ្វារំ** សរីរៈមានចក្ក ៤ មានទ្វារ ៩ ។ ប្រើ

ក្នុងអត្ថថា ទាន ដូចក្នុងប្រយោគជាដើមថា **ទានំ កុញ្ច ច មា ច បមាទោ ចក្កំ បវត្តយ សព្វបាណីនំ** សូមព្រះអង្គទ្រង់ឲ្យទាន ហើយសឹមទ្រង់សោយ សូមព្រះអង្គកុំប្រមាទ ( ក្នុងបុណ្យទាំងឡាយ ) សូមព្រះអង្គញុំាងចក្កធម៌ឲ្យប្រព្រឹត្តទៅ ។ ប្រើក្នុងអត្ថថា រតនចក្ក ដូចក្នុងប្រយោគជាដើមថា **ទិព្វំ ចក្ករតនំ បាតុរហោសិ** ចក្ករ័តន៍ជាទិព្វមានកាំ ១០០០ ព្រមទាំងខ្នង និងដុំបរិបូណ៌ដោយអាការទាំងពួង ក៏កើតប្រាកដហើយ ។ ប្រើក្នុងអត្ថថា ធម្មចក្ក ដូចក្នុងប្រយោគជាដើមថា **មយា បវត្តិតំ ចក្កំ** ញុំាងធម្មចក្ក ជាចក្កដ៏ប្រសើរដែលតថាគតឲ្យប្រព្រឹត្តទៅហើយ ។ ប្រើក្នុងអត្ថថា ខុរចក្ក ដូចក្នុងប្រយោគជាដើមថា **ឥច្ឆាហតស្ស បោសស្ស ចក្កំ មតិ មត្ថកេ** ចក្កវិលកិនអំបែងក្បាលបុគ្គលដែលតស្សាគ្របសង្កត់ហើយ ។ ប្រើក្នុងអត្ថថា បហរចក្ក ដូចក្នុងប្រយោគជាដើមថា **ខុរបរិយន្តេន ចេបិ ចក្កេន** ដោយគ្រឿងចក្ក មានខ្នងកង់ដ៏មុត ដូចជាកាំបិតកោរ ។ ប្រើក្នុងអត្ថថា អសនិមណ្ឌល ដូចក្នុងប្រយោគជាដើមថា **អសនិវិចក្កំ** ( ម្នាលភិក្ខុទាំងឡាយ ) កម្ពុរន្ទះធ្លាក់ចំលើបុគ្គលណា ។ តែសព្ទ **ចក្ក** នេះ ក្នុងទីនេះ លោកសំដៅយកធម្មចក្ក ។ ធម្មចក្កនេះមាន ២ គឺបដិវេធញ្ញាណ ១ ទេសនាញ្ញាណ ១ ។ បណ្តាធម្មចក្ក ២ នោះ ញាណដែលបញ្ញាអប់រំ នាំអរិយផលមកឲ្យខ្លួនឯង ឈ្មោះថា **បដិវេធញ្ញាណ** ។ ញាណដែលករុណាអប់រំ នាំអរិយផលមកឲ្យសាវ័កទាំងឡាយ ឈ្មោះថា **ទេសនាញ្ញាណ** ។ បណ្តាញាណ ២ យ៉ាងនោះ បដិវេធញ្ញាណមាន ២ គឺដែលកំពុងកើតឡើង ១ ដែលកើតឡើងហើយ ១ ។

បដិវេធញ្ញាណនោះ ឈ្មោះថា កំពុងកើតឡើង រាប់តាំងអំពីទ្រង់ចេញបួស រហូតដល់អរហត្តមគ្គ ឈ្មោះថា កើតឡើងហើយក្នុងខណៈនៃអរហត្តផល ។ ម្យ៉ាងទៀត ឈ្មោះថា កំពុងកើតឡើង រាប់តាំងអំពីកាលនៅក្នុងតុសិតពិភព រហូតដល់អរហត្តមគ្គ ក្នុងមហាពោធិបល្ល័ង្ក ឈ្មោះថា កើតឡើងហើយ ក្នុងខណៈនៃអរហត្តផល ។ ម្យ៉ាងទៀត ឈ្មោះថា កំពុងកើតឡើង រាប់តាំងអំពីព្រះពុទ្ធទីបង្ករ រហូតដល់អរហត្តមគ្គ នាពោធិបល្ល័ង្ក ឈ្មោះថា កើតឡើងហើយ ក្នុងខណៈនៃអរហត្តផល ។ ទេសនាញាណក៏មាន ២ គឺដែលកំពុងប្រព្រឹត្តទៅ ១ ដែលប្រព្រឹត្តទៅហើយ ១ ។ ទេសនាញាណនោះ ឈ្មោះថា កំពុងប្រព្រឹត្តទៅហើយ រហូតដល់សោតាបត្តិមគ្គ របស់ព្រះអញ្ញាកោណ្ឌញ្ញៈ ឈ្មោះថា ប្រព្រឹត្តទៅហើយ ក្នុងខណៈនៃសោតាបត្តិផល ។ បណ្តាញាណទាំង ២ បដិវេធញ្ញាណជាលោកុត្តរ ទេសនាញាណជាលោកិយ ។ ញាណទាំង ២ នោះ មិនទូទៅដល់សាវកដទៃឡើយ ជាឱរសញ្ញាណ ធ្វើឲ្យកើតឱរស គឺសាវក សម្រាប់ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ ។

បទថា **សម្មាសម្ពុទ្ធស្ស តេ បដិជានតោ** សេចក្តីថា លោកប្តេជ្ញាយ៉ាងនេះថា អាត្មាអញជាសម្មាសម្ពុទ្ធ ធម៌ទាំងឡាយទាំងពួង អាត្មាអញត្រាស់ដឹងហើយ ដូច្នេះ ។ បទថា **អនភិសម្ពុទ្ធា** សេចក្តីថា ធម៌ទាំងឡាយនេះ លោកមិនទាន់ដឹងឡើយ ។ បទថា **តត្រ វត** គឺក្នុងធម៌ដែលលោកសម្តែងនោះយ៉ាងនេះថា **អនភិសម្ពុទ្ធា** ។ បទថា **សហធម្មេន** បានដល់ ដោយពាក្យសម្តី ព្រមទាំងដោយហេតុ ដោយការណ៍ ។ បុគ្គលក្តី ធម៌ក្តី លោក

បំណងថាជានិមិត្ត ក្នុងបទថា **និមិត្តមេតំ** នេះ ។ ក្នុងសេចក្ដីនេះ មានអត្ថដូច្នេះថា បុគ្គលណាចោទតថាគតៗ ក៏មិនទាន់ឃើញបុគ្គលនោះ បុគ្គលសម្ដែងធម៌ណាហើយ នឹងចោទតថាគតថា ធម៌ឈ្មោះនេះ លោកមិនទាន់ដឹងឡើយ ដូច្នេះ តថាគតក៏មិនទាន់ឃើញធម៌នោះ ។ បទថា **ខេមប្បត្តោ** បានដល់ ដល់នូវភាពក្សេម ។ ពីរបទដ៏សេស ក៏ជាវេវចនៈនៃបទនេះឯង ។ ពាក្យទាំងអស់ ទ្រង់ត្រាស់សំដៅដល់វេសារជ្ជញ្ញាណតែម្យ៉ាង ។ ដ្បិតថា ព្រះទសពល កាលទ្រង់មិនឃើញបុគ្គលដែលចោទ ឬធម៌ដែលមិនដឹង ជាហេតុឲ្យចោទថា ធម៌នេះ លោកមិនទាន់ដឹង ដូច្នេះ ពិចារណាឃើញថា តថាគតដឹងតាមសេចក្ដីពិតហើយ ទើបពោលថា តថាគតជាព្រះពុទ្ធ ដូច្នេះ ទើបកើតសោមនស្សដែលមានកម្លាំងជាឧញាណ ដែលប្រកបដោយសោមនស្សនោះ ឈ្មោះថា វេសារជ្ជៈ ។ ទ្រង់សំដៅដល់វេសារជ្ជញ្ញាណនោះ ទើបត្រាស់ពាក្យជាដើមថា **ខេមប្បត្តោ** ដូច្នេះ ។ ក្នុងបទទាំងអស់ គប្បីជ្រាបអត្ថយ៉ាងនេះ ។

ក្នុងបទថា **អន្តរាយិកា ធម្មា** នេះ ឈ្មោះថា អន្តរាយិកធម៌ ព្រោះធ្វើនូវអន្តរាយ ។ អន្តរាយិកធម៌ទាំងនេះ ដោយអត្ថ ក៏បានដល់អាបត្តិ ៧ កងដែលដាក់ចិត្តប្រព្រឹត្តល្មើស ។ សេចក្ដីពិត ទោសដែលក្លែងល្មើសដោយហោច សូម្បីត្រឹមអាបត្តិទុក្កដ និងទុព្ភាសិត ក៏រមែងធ្វើអន្តរាយដល់មគ្គ និងផលបាន ។ តែក្នុងទីនេះ បំណងយកមេថុនធម្ម ។ ព្រោះថា កាលភិក្ខុរូបណាមួយសេពមេថុនធម្ម រមែងជាអន្តរាយចំពោះមគ្គ និងផល ដោយ

ចំណែកមួយ ។ បទថា **យស្ស ខោ បន តេ អត្ថាយ** សេចក្តីថា ដើម្បីប្រយោជន៍ដល់ធម៌ឯណា ក្នុងបណ្តាធម៌ដែលជាទីអស់រាគៈជាដើម ។ បទថា **ធម្មា ទេសិតោ** សេចក្តីថា លោកពោលធម៌ មានអសុភភាវនាជាដើម ។ បទថា **តត្រ វត មំ** គឺក្នុងធម៌ដែលមិននាំសត្វចេញចាកទុក្ខនោះ ។ បទដ៏សេស គប្បីជ្រាបដោយន័យដែលពោលក្នុងវិន័យ ។

បទថា **វាទបថា** គឺគន្លងនៃវាទៈទាំងឡាយនោះឯង ។ បទថា **បុថុ** ប្រែថា ច្រើន ។ បទថា **សិតា** គឺបុគ្គលដែលចងបញ្ហាឡើង ។ម្យ៉ាងទៀត បទថា **បុថុស្សិតា** បានដល់ វាទៈដែលត្រៀម គឺរៀបចំច្រើន ។ ម្យ៉ាងទៀត ឈ្មោះថា **បុថុស្សិតា** ព្រោះសមណព្រាហ្មណ៍ជាច្រើនចង ។ បទថា **យំ និស្សិតា** សេចក្តីថា ឥឡូវនេះ សមណព្រាហ្មណ៍អាស្រ័យនូវគន្លងវាទៈណា ។ បទថា **ន តេ ភវន្តិ** សេចក្តីថា គន្លងវាទៈទាំងនោះ រមែងមិនមាន គឺវិនាសទៅ ។ បទថា **ធម្មចក្កំ** នោះ ជាឈ្មោះរបស់ទេសនាញាណក៏មាន បដិវេធញ្ញាណក៏មាន ។ បណ្តាញាណទាំង ២ នោះ ទេសនាញាណជាលោកិយ បដិវេធញ្ញាណជាលោកុត្តរ ។ បទថា **កេវលី** បានដល់ ទ្រង់ដល់ព្រមដោយលោកុត្តរ ដោយឥតសេសសល់ ។ បទថា **តាទិសំ** គឺលោកជាបុគ្គលយ៉ាងនោះ ៗ៚

## អដ្ឋកថាវេសារជ្ជសូត្រទី ៨ ចប់

# សុត្តន្តបិដក

## តណ្ហាសូត្រទី ៩

[ ៩ ] ម្នាលភិក្ខុទាំងឡាយ តណ្ហាកាលកើតឡើងដល់ភិក្ខុ រមែងកើតឡើងព្រោះបច្ច័យណា បច្ច័យនោះឈ្មោះថា ជាទីកើតឡើងនៃតណ្ហាមាន ៤ យ៉ាងនេះ ។ បច្ច័យជាទីកើតឡើងនៃតណ្ហា ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តណ្ហាកាលកើតឡើងដល់ភិក្ខុ រមែងកើតឡើងព្រោះហេតុចីវរ ១ ម្នាលភិក្ខុទាំងឡាយ តណ្ហាកាលកើតឡើងដល់ភិក្ខុ រមែងកើតឡើងព្រោះហេតុបិណ្ឌបាត ១ ម្នាលភិក្ខុទាំងឡាយ តណ្ហាកាលកើតឡើងដល់ភិក្ខុ រមែងកើតឡើងព្រោះហេតុសេនាសនៈ ១ ម្នាលភិក្ខុទាំងឡាយ តណ្ហាកាលកើតឡើងដល់ភិក្ខុ រមែងកើតឡើង ព្រោះហេតុភេសជ្ជៈឧត្តម និងថ្លៃថ្លាដូច្នេះៗ ១ ។ ម្នាលភិក្ខុទាំងឡាយ តណ្ហាកាលកើតឡើងដល់ភិក្ខុ រមែងកើតឡើងព្រោះបច្ច័យណា បច្ច័យនោះ ឈ្មោះថា ជាទីកើតឡើងនៃតណ្ហាមាន ៤ យ៉ាង ប៉ុណ្ណេះ ។

បុរសមានតណ្ហាជាគម្រប់ពីរ អន្ទោលទៅ ( ក្នុងសង្សារវដ្ត )
អស់កាលដ៏វែង រមែងមិនប្រព្រឹត្តកន្លងនូវសង្សារ គឺខន្ធ
ធាតុ អាយតនៈ ដែលមានក្នុងអត្តភាពនេះ និងខាងមុខ ។
លុះភិក្ខុដឹងច្បាស់នូវតណ្ហានេះ ថាជាទោស ជាដែនកើត
ព្រមនៃទុក្ខហើយ ជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្តី
ប្រកាន់មាំ មានស្មារតី នៅគ្រប់ឥរិយាបថ ។

# អដ្ឋកថា

## តណ្ហាសូត្រ

[ ៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតណ្ហាសូត្រទី ៩ ដូចតទៅនេះ ឈ្មោះថា **ឧប្បាទា** ព្រោះជាទីកើតឡើងនៃតណ្ហាទាំងនោះ ។ សួរថា អ្វីកើត ។ ឆ្លើយថា តណ្ហា ។ ការកើតឡើងនៃតណ្ហា ឈ្មោះថា **តណ្ហុប្បាទា** អធិប្បាយថា វត្ថុនៃតណ្ហា ហេតុនៃតណ្ហា ។ បទថា **ចីវរហេតុ** សេចក្តីថា តណ្ហារមែងកើត ព្រោះមានចីវរជាហេតុថា អាត្មាអញនឹងបានចីវរដែលគួរពេញចិត្តក្នុងទីណា ។ សព្ទថា **ឥតិ** ក្នុងបទថា **ឥតិភវាភវហេតុ** នេះ ជានិបាត ចុះក្នុងអត្ថថា ឧទាហរណ៍ អធិប្បាយថា តណ្ហារមែងកើតឡើង ព្រោះការមានតិច មានច្រើនជាហេតុ ដូចកើតឡើងព្រោះមានចីវរជាដើមជាហេតុ ឯក្នុងបទថា **ភវាភវោ** នេះ បំណងយកសប្បិ និងនវនីតជាដើមដែលប្រណីត និងប្រណីតជាងគ្នា ។ អាចារ្យពួកខ្លះពោលថា ភពដែលប្រណីតជាង និងប្រណីតបំផុត ក្នុងសម្បត្តិភព ដូច្នេះក៏មាន ។

បទថា **តណ្ហាទុតិយោ** សេចក្តីថា សត្វនេះ អន្ទោលទៅក្នុងសង្សារវដ្ត ដែលសត្វខ្លួនឯងមិនដឹងទីបញ្ចប់ មិនមែនអន្ទោលទៅតាមទំនើងប៉ុណ្ណោះ តែនៅបានតណ្ហាជាសម្លាញ់អន្ទោលទៅផង ដោយហេតុនោះ ទើបត្រាស់ថា **តណ្ហា ទុតិយោ** ដូច្នេះ ។ ក្នុងបទថា **ឥត្ថភាវញ្ញថាភាវំ** នេះ បានដល់ អត្តភាពនេះ ឈ្មោះថា ឥត្ថភាវៈយ៉ាងនេះ អត្តភាពក្នុងអនាគត ឈ្មោះថា អញ្ញថាភាវៈដទៃ ម្យ៉ាងទៀត អត្តភាពដទៃយ៉ាងនេះ ឈ្មោះថា

ឥត្ថភាវៈយ៉ាងនេះ ដែលមិនមែនយ៉ាងនេះ ឈ្មោះថា អញ្ញថាភាវៈដទៃ ៗ ដែលជាយ៉ាងនេះ និងយ៉ាងដទៃ ៗ បទថា **សំសារំ** បានដល់ លំដាប់ខន្ធ ធាតុ អាយតនៈ ។ បទថា **នាតិវត្តតិ** ប្រែថា មិនកន្លងផុតទៅ ។ បទថា **ឯតមាទីនវំ ញត្វា** សេចក្ដីថា ភិក្ខុដឹងដល់ទោស ក្នុងខន្ធដែលជាអតីត អនាគត បច្ចុប្បន្នយ៉ាងនេះហើយ ។ បទថា **តណ្ហំ ទុក្ខស្ស សម្ភវំ** សេចក្ដីថា ដឹងដល់តណ្ហាយ៉ាងនេះថា តណ្ហានេះជាហេតុកើត ជាដែនកើត ជាហេតុនៃវដ្ដទុក្ខ ។ កាលដែលភិក្ខុនេះចម្រើនវិបស្សនា ហើយសម្រេចអរហត្ត ទ្រង់សម្ដែងដោយហេតុប្រមាណប៉ុណ្ណេះ ។ ឥឡូវនេះ កាលទ្រង់សរសើរភិក្ខុខីណាស្រពនោះ ទើបត្រាស់ថា **វីតតណ្ហោ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **អនាទានោ** បានដល់ មិនប្រកាន់មាំ ។ បទថា **សតោ ភិក្ខុ បរិព្វជេ** សេចក្ដីថា ភិក្ខុដែលជាខីណាស្រព ដល់នូវការបរិបូណ៌ដោយសតិសម្បជញ្ញៈ គប្បីមានសតិសម្បជញ្ញៈត្រាច់ទៅ ។ ដូច្នោះ ក្នុងសូត្រត្រាស់ដល់វដ្ដៈ ក្នុងគាថាត្រាស់ដល់វដ្ដៈផង វិវដ្ដៈផង ដោយប្រការដូច្នេះ ។៚

## អដ្ឋកថា តណ្ហាសូត្រទី ៩ ចប់

# សុត្តន្តបិដក

## យោគសូត្រទី ១០

[ ១០ ] ម្នាលភិក្ខុទាំងឡាយ យោគៈ ( កិលេសជាគ្រឿងប្រកបសត្វទុកក្នុងវដ្តៈ ) នេះ មាន ៤ យ៉ាង ។ យោគៈ ៤ យ៉ាង តើដូចម្តេច ។ គឺកាមយោគៈ ១ ភវយោគៈ ១ ទិដ្ឋិយោគៈ ១ អវិជ្ជាយោគៈ ១ ។ ម្នាលភិក្ខុទាំងឡាយ កាមយោគៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ មិនដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវកាមទាំង-ឡាយ កាលបើបុគ្គលនោះ មិនដឹងច្បាស់តាមពិតនូវហេតុជាទីកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវកាមទាំងឡាយ ក៏កើតមានតម្រេកក្នុងកាម សេចក្តីរីករាយក្នុងកាម សេចក្តីស្នេហាក្នុងកាម សេចក្តីងប់នៅក្នុងកាម សេចក្តីស្រេកឃ្លានក្នុងកាម សេចក្តីអន្ទះអន្ទែងព្រោះកាម សេចក្តីជ្រុលជ្រប់ក្នុងកាម សេចក្តីប្រាថ្នាក្នុងកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កាមយោគៈ ។ កាមយោគៈដូច្នេះឯង ។ ភវយោគៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវភពទាំងឡាយ កាលបើបុគ្គលនោះ មិនដឹងច្បាស់តាមពិតនូវហេតុជាទីកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវភពទាំងឡាយ ក៏កើតមានតម្រេក

*ក្នុងភព សេចក្ដីរីករាយក្នុងភព សេចក្ដីស្នេហាក្នុងភព សេចក្ដីងប់នៅក្នុងភព សេចក្ដីស្រេកឃ្លានក្នុងភព សេចក្ដីអន្ទះអន្ទែងព្រោះភព សេចក្ដីជ្រុលជ្រប់ក្នុងភព សេចក្ដីប្រាថ្នាក្នុងភព ក្នុងភពទាំងឡាយ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភវយោគៈ ។ កាមយោគៈ និងភវយោគៈ ដូច្នេះឯង ។ ទិដ្ឋិយោគៈតើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនដឹងច្បាស់តាមពិតនូវហេតុជាទីកើតឡើងផង សេចក្ដីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវទិដ្ឋិទាំងឡាយ កាលបើបុគ្គលនោះមិនដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង សេចក្ដីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវទិដ្ឋិទាំងឡាយ ក៏កើតមានតម្រេកក្នុងទិដ្ឋិ សេចក្ដីរីករាយក្នុងទិដ្ឋិ សេចក្ដីស្នេហាក្នុងទិដ្ឋិ សេចក្ដីងប់នៅក្នុងទិដ្ឋិ សេចក្ដីស្រេកឃ្លានក្នុងទិដ្ឋិ សេចក្ដីអន្ទះអន្ទែងព្រោះទិដ្ឋិ សេចក្ដីជ្រុលជ្រប់ក្នុងទិដ្ឋិ សេចក្ដីប្រាថ្នាក្នុងទិដ្ឋិ ក្នុងទិដ្ឋិទាំងឡាយ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទិដ្ឋិយោគៈ ។ កាមយោគៈ ភវយោគៈ និងទិដ្ឋិយោគៈ ដូច្នេះឯង ។ អវិជ្ជាយោគៈ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ មិនដឹងច្បាស់តាមពិតនូវហេតុជាទីកើតឡើងផង សេចក្ដីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវផស្សាយតនៈទាំង ៦ កាលបើបុគ្គលនោះមិនដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង សេចក្ដីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវផស្សាយតនៈទាំង ៦ ក៏កើតមានសេចក្ដីល្ងង់ មិនដឹងក្នុងផស្សាយតនៈទាំង ៦ ម្នាលភិក្ខុទាំង-*

ឡាយ នេះហៅថា អវិជ្ជាយោគៈ ។ កាមយោគៈ ភវយោគៈ ទិដ្ឋិយោគៈ និងអវិជ្ជាយោគៈ ដូច្នេះឯង ។ បុគ្គលប្រកបដោយអកុសលធម៌ដ៏លាមក ជាគ្រឿងសៅហ្មង ជាគ្រឿងនាំឲ្យកើតក្នុងភពថ្មីទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាវិបាក ជាគ្រឿងនាំឲ្យកើតជាតិ ជរា មរណៈតទៅ ព្រោះហេតុនោះ ( បុគ្គលនោះ ) ហៅថា ជាអ្នកមិនមានសេចក្តីក្សេមចាកយោគៈទេ ។ ម្នាលភិក្ខុទាំងឡាយ យោគៈមាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ការមិនប្រកបដោយយោគៈនេះ មាន ៤ យ៉ាង ។ ៤ យ៉ាងតើដូចម្តេចខ្លះ ។ គឺការមិនប្រកបដោយកាមយោគៈ ១ ការមិនប្រកបដោយភវយោគៈ ១ ការមិនប្រកបដោយទិដ្ឋិយោគៈ ១ ការមិនប្រកបដោយអវិជ្ជាយោគៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះការមិនប្រកបដោយកាមយោគៈតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដឹងច្បាស់តាមពិតនូវហេតុជាទីកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវកាមទាំងឡាយ កាលបើបុគ្គលនោះដឹងច្បាស់តាមពិតនូវហេតុជាទីកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវកាមទាំងឡាយ ក៏មិនកើតមានតម្រេកក្នុងកាម សេចក្តីរីករាយក្នុងកាម សេចក្តីស្នេហាក្នុងកាម សេចក្តីងប់នៅក្នុងកាម សេចក្តីស្រេកឃ្លានក្នុងកាម សេចក្តីអន្ទះអន្ទែងព្រោះកាម សេចក្តីជ្រុលជ្រប់ក្នុងកាម សេចក្តីប្រាថ្នាក្នុងកាម ក្នុងកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការមិនប្រកបដោយកាមយោគៈ ។ ការមិនប្រកបដោយកាមយោគៈ

ដូច្នេះឯង ។ ចុះការមិនប្រកបដោយភវយោគៈ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង សេចក្ដីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវភពទាំងឡាយ កាលបើបុគ្គលនោះដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង សេចក្ដីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវភពទាំងឡាយ ក៏មិនកើតមានតម្រេកក្នុងភព សេចក្ដីរីករាយក្នុងភព សេចក្ដីស្នេហាក្នុងភព សេចក្ដីងប់នៅក្នុងភព សេចក្ដីស្រេកឃ្លានក្នុងភព សេចក្ដីអន្ទះអន្ទែងព្រោះភព សេចក្ដីជ្រុលជ្រប់ក្នុងភព សេចក្ដីប្រាថ្នាក្នុងភព ក្នុងភពទាំងឡាយ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការមិនប្រកបដោយភវយោគៈ ។ ការមិនប្រកបដោយកាមយោគៈ និងការមិនប្រកបដោយភវ-យោគៈ ដូច្នេះឯង ។ ចុះការមិនប្រកបដោយទិដ្ឋិយោគៈ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដឹងច្បាស់តាមពិតនូវហេតុជាទីកើតឡើងផង សេចក្ដីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវទិដ្ឋិទាំងឡាយ កាលបើបុគ្គលនោះដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង សេចក្ដីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវទិដ្ឋិទាំងឡាយ ក៏មិនកើត មានតម្រេកក្នុងទិដ្ឋិ សេចក្ដីរីករាយក្នុងទិដ្ឋិ សេចក្ដីស្នេហាក្នុងទិដ្ឋិ សេចក្ដីងប់នៅក្នុងទិដ្ឋិ សេចក្ដីស្រេកឃ្លានក្នុងទិដ្ឋិ សេចក្ដីអន្ទះអន្ទែងព្រោះទិដ្ឋិ សេចក្ដីជ្រុលជ្រប់ក្នុងទិដ្ឋិ សេចក្ដីប្រាថ្នាក្នុងទិដ្ឋិ ក្នុងទិដ្ឋិទាំងឡាយ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការមិនប្រកបដោយទិដ្ឋិ

យោគៈ ។ ការមិនប្រកបដោយកាមយោគៈ ការមិនប្រកប ដោយភវយោគៈ និងការមិនប្រកបដោយទិដ្ឋិយោគៈ ដូច្នេះឯង ។ ចុះការមិនប្រកបដោយអវិជ្ជាយោគៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវផស្សាយតនៈទាំង ៦ កាលបើបុគ្គលនោះដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវផស្សាយតនៈទាំង ៦ ក៏មិនមានសេចក្តីល្ងង់ សេចក្តីមិនដឹងក្នុងផស្សាយតនៈទាំង ៦ ឡើយ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការមិនប្រកបដោយអវិជ្ជាយោគៈ ។ ការមិនប្រកបដោយកាមយោគៈ ការមិនប្រកបដោយភវយោគៈ ការមិនប្រកបដោយទិដ្ឋិ-យោគៈ និងការមិនប្រកបដោយអវិជ្ជាយោគៈ ដូច្នេះឯង ។ បុគ្គលប្រាសចាកអកុសលធម៌ដ៏លាមក ជាគ្រឿងសៅហ្មង ជាហេតុនាំឲ្យកើតក្នុងភពថ្មីទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាវិបាក ជាហេតុនាំឲ្យកើតជាតិ ជរា មរណៈតទៅ ព្រោះហេតុនោះ ( បុគ្គលនោះ ) ទើបហៅ ថា ជាអ្នកមានសេចក្តីក្សេមចាកយោគៈ ។ ម្នាលភិក្ខុទាំងឡាយ ការមិនប្រកបដោយយោគៈ មាន ៤ យ៉ាងប៉ុណ្ណេះ ។

ពួកសត្វប្រកបដោយកាមយោគៈ និងភវយោគៈទាំង ២
ប្រកបដោយទិដ្ឋិយោគៈ ត្រូវអវិជ្ជាយោគៈចោមរោម ជា
អ្នកមានដំណើរទៅកាន់ជាតិ ( ជរា ) និងមរណៈជា

ប្រក្រតី រមែងអន្ទោលទៅរកសង្សារ ។ ចំណែកពួកជន ណា បានកំណាត់ដឹងនូវកាមយោគៈផង ភវយោគៈដោយ អាការទាំងពួងផង ដកឡើងនូវទិដ្ឋិយោគៈផង លះបង់នូវ អវិជ្ជាយោគៈផង ជាអ្នកប្រាសចាកយោគៈទាំងពួង ជន ទាំងនោះ ឈ្មោះថា ជាអ្នកប្រាជ្ញកន្លងផុតនូវយោគៈ ។

កណ្ឌគ្គាមវគ្គទី ១ ចប់

## ឧទ្ទាននៃកណ្ឌគ្គាមវគ្គនោះគឺ

និយាយអំពីការត្រាស់ដឹងធម៌ ៤ យ៉ាង ១ អំពីភិក្ខុជាអ្នក ធ្លាក់ចុះចាកធម្មវិន័យ ១ អំពីការជីករំលើងគុណមាន ២ លើក ១ ជាគម្រប់ ៥ និងបុគ្គលមានដំណើរទៅតាមខ្សែ ទឹក ១ អំពីបុគ្គលមានសេចក្ដីចេះដឹងតិច ១ អំពីបុគ្គល ញុំាងសង្ឃឲ្យរុងរឿង ១ ( អំពីវេសារជ្ជញាណ ) អំពី ការកើតឡើងនៃតណ្ហា ១ និងយោគៈ ១ ទៀតជា ១០ ។

# អដ្ឋកថា

## យោគសូត្រ

[ ១០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងយោគសូត្រទី ១០ ដូចតទៅនេះ កិលេសឈ្មោះថា **យោគា** ព្រោះចងសត្វទុកក្នុងវដ្តៈ ។ ក្នុងបទថា **កាមយោគោ** ជាដើម ការត្រេកប្រកបដោយកាមគុណ ៥ ឈ្មោះថា **កាមយោគ** ។ តម្រេកដោយអំណាចការពេញចិត្តក្នុងរូបភព និងអរូបភព ឈ្មោះថា **ភវយោគោ**។ ការជាប់ចិត្តក្នុងឈានក៏យ៉ាងនោះ ។ រាគៈប្រកបដោយសស្សតទិដ្ឋិ និងទិដ្ឋិ ៦២ ឈ្មោះថា **ទិដ្ឋិយោគ**។ ការមិនដឹងក្នុងសច្ចៈ ៤ ឈ្មោះថា **អវិជ្ជាយោគោ** ។ម្យ៉ាងទៀត ឈ្មោះថា **កាមយោគោ** ព្រោះប្រកបសត្វក្នុងកាម ។ ឈ្មោះថា **ភវយោគោ** ព្រោះប្រកបសត្វក្នុងភព ឈ្មោះថា **ទិដ្ឋិយោគោ** ព្រោះប្រកបសត្វក្នុងទិដ្ឋិ ។ ឈ្មោះថា **អវិជ្ជាយោគោ** ព្រោះប្រកបសត្វក្នុងអវិជ្ជា ។ ពាក្យដូចពោលមកនេះ ជាឈ្មោះរបស់ធម៌ ដែលបានពោលហើយខាងដើម ។ ឥឡូវនេះ កាលទ្រង់សម្តែងពង្រីកធម៌ទាំងនោះឲ្យពិស្តារ ទើបត្រាស់ថា **កតមោ ច ភិក្ខវេ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **សមុទយំ** គឺការកើត ។ បទថា **អដ្ឋង្គមំ** គឺការរលត់ ។ បទថា **អស្សាទំ** គឺត្រេកអរ ។ បទថា **អាទីនវំ** គឺទោសដែលមិនត្រេកអរ ។ បទថា **និស្សរណំ** គឺការចេញទៅ ។

បទថា **កាមេសុ** គឺក្នុងវត្ថុកាម ។ បទថា **កាមរាគោ** គឺរាគៈកើតព្រោះប្រារព្ធកាម ។ ក្នុងបទដ៏សេស ក៏មានន័យនេះឯង ។ បទថា **អនុសេតិ**

*គឺកើតឡើង ។ គប្បីជ្រាបអត្ថក្នុងបទគ្រប់យ៉ាង យ៉ាងនេះថា បទថា* **អយំ វុច្ចតិ ភិក្ខវេ កាមយោគោ** *សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ នេះហៅថា ហេតុនៃការប្រកបគ្រឿងចងសត្វក្នុងកាម ។ បទថា* **ឆន្នំ ផស្សាយតនានំ** *បានដល់ ហេតុ មានចក្ខុសម្ផស្សជាដើម សម្រាប់អាយតនៈទាំងឡាយ មានចក្ខុជាដើម ។ បទថា* **អវិជ្ជា អញ្ញាណំ** *សេចក្ដីថា អវិជ្ជា គឺការមិនដឹង ព្រោះជាបដិបក្ខចំពោះការដឹង ។* **ឥតិ** *សព្ទ ក្នុងបទនេះថា* **ឥតិ កាមយោគោ** *គប្បីប្រកបជាមួយយោគៈទាំង ៤ ថា* **កាមយោគ** *ដូច្នេះ* **ភវយោគ** *ដូច្នេះជាដើម ។*

*បទថា* **សម្បយុត្តោ** *បានដល់ ដែលចោមរោមហើយ ។ បទថា* **បាបកេហិ** *បានដល់ ដែលលាមក ។ បទថា* **អកុសលេហិ** *បានដល់ កើតអំពីការមិនឈ្លាស ។ បទថា* **សង្កិលេសិកេហិ** *គឺមានការសៅហ្មង អធិប្បាយថា ប្រទូស្តនឹងការបរិសុទ្ធនៃចិត្តដែលបរិសុទ្ធហើយ ។ បទថា* **បោនោព្ភវិកេហិ** *បានដល់ ជាហេតុឲ្យកើតក្នុងភពថ្មី ។ បទថា* **សទរេហិ** *បានដល់ មានការក្ដៅក្រហាយ ។ បទថា* **ទុក្ខវិបាកេហិ** *បានដល់ ឲ្យទុក្ខកើតឡើងក្នុងពេលឲ្យផល ។ បទថា* **អាយតឹជាតិ ជរាមរណិកេហិ** *បានដល់ ឲ្យកើតជាតិ ជរា មរណៈក្នុងអនាគតរឿយៗ ។ បទថា* **តស្មា អយោគក្ខេមីតិ វុច្ចតិ** *សេចក្ដីថា ព្រោះហេតុដែលបុគ្គលលះយោគៈមិនទាន់បាន រមែងជាបុគ្គលប្រកបដោយធម៌ទាំងនោះ ដូច្នោះ ទើបតថាគតហៅថា* **អាយោគក្ខេមី** *ព្រោះបុគ្គលមិនសម្រេចព្រះនិព្វានដែលក្សេមចាក*

*យោគៈ ទាំង ៤ នោះ ។*

*បទថា* **វិសំយោគា** *គឺហេតុនៃការប្រាសចាកយោគ ។ បទថា* **កាម-យោគវិសំយោគោ** *គឺហេតុនៃការប្រាសចាកកាមយោគ ។ ក្នុងបទដ៏សេសក៏មានន័យនេះឯង ។ បណ្ដាបទទាំងនោះ ការសម្លឹងអសុភកម្មដ្ឋាន ជាការប្រាសចាកកាមយោគៈ អនាគាមិមគ្គ ធ្វើអសុភជ្ឈាននោះឲ្យជាបាទហើយសម្រេច ឈ្មោះថា ប្រាសចាកកាមយោគៈដោយចំណែកមួយ ។ អរហត្តមគ្គឈ្មោះថា ប្រាសចាកភវយោគៈ សោតាបត្តិមគ្គ ឈ្មោះថា ប្រាសចាកទិដ្ឋិយោគៈ អរហត្តមគ្គ ឈ្មោះថា ប្រាសចាកអវិជ្ជាយោគៈ ។ ឥឡូវនេះកាលទ្រង់សម្ដែងពង្រីកវិសំយោគធម៌ទាំងនោះ ឲ្យពិស្ដារ ទើបត្រាស់ថា* **កតមោ ច ភិក្ខវេ** *ជាដើម ។ សេចក្ដីនៃព្រះតម្រាស់នោះ គប្បីជ្រាបដោយន័យដែលពោលហើយ ។ បទថា* **ភវយោគេន ចូភយំ** *សេចក្ដីថា ចងដោយភវយោគៈ និងចងដោយភវយោគៈ ទិដ្ឋិយោគៈទាំង ២ ក្រៃលែងឡើង គឺប្រកបដោយយោគៈណាមួយ ។ បទថា* **បុរក្ខតា** *បានដល់ ត្រូវនាំទៅខាងមុខ ឬត្រូវចោមរោម ។ បទថា* **កាមេ បរិញ្ញាយ** *បានដល់កំណត់ដឹងកាមទាំង ២ ។ បទថា* **ភវយោគញ្ច សព្វសោ** *បានដល់កំណត់ដឹងភវយោគៈទាំងអស់នោះឯង ។ បទថា* **សមូហច្ច** *បានដល់ ដកចោលអស់ហើយ ។ បទថា* **វិរាជយំ** *បានដល់ កំពុងប្រាសចាក ឬប្រាសចាកហើយ ។ កាលពោលថា* **វិរាជេន្តោ** *ក៏ឈ្មោះថា ពោលដល់មគ្គ កាលពោលថា* **វិរាជេត្វា** *ក៏ឈ្មោះថា ពោលដល់ផល ។ បទថា* **មុនិ**

បានដល់ ព្រះមុនី គឺព្រះខីណាស្រព ។ ដូច្នោះ ក្នុងសូត្រនេះក្តី ក្នុងគាថាក្តី ទើបត្រាស់ទាំងវដ្តៈ ទាំងវិវដ្តៈ ៕

## អដ្ឋកថា យោគសូត្រទី ១០ ចប់

## ភណ្ឌគាមវគ្គទី ១ ចប់

# សុត្តន្តបិដក

## ចរវគ្គទី ២

### ចរសូត្រទី ១

[ ១១ ] ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកាមវិតក្កក្តី ព្យាបាទវិតក្កក្តី វិហឹសាវិតក្កក្តី កើតឡើងដល់ភិក្ខុកំពុងដើរទៅ បើភិក្ខុតាំងចិត្តទទួលមិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យអស់ទៅ មិនឲ្យដល់នូវសេចក្តីវិនាស នូវវិតក្កទាំងនោះទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលដើរទៅមានសភាពយ៉ាងនេះ ហៅថា មិនមានព្យាយាមដុតកម្តៅកិលេស មិនខ្លាចពាក្យតិះដៀល ខ្ជិលច្រអូស មានព្យាយាមថោកថយជានិច្ចនិរន្តរ៍ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកាម-វិតក្កក្តី ព្យាបាទវិតក្កក្តី វិហឹសាវិតក្កក្តី កើតឡើងដល់ភិក្ខុកំពុងឈរ បើភិក្ខុតាំងចិត្តទទួល មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យអស់ទៅ មិនឲ្យដល់នូវសេចក្តីវិនាសនូវវិតក្កទាំងនោះទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលឈរមានសភាពយ៉ាងនេះ ហៅថា មិនមានព្យាយាមដុតកម្តៅកិលេស មិនខ្លាចពាក្យតិះដៀល ខ្ជិលច្រអូស មានព្យាយាមថោកថយជានិច្ចនិរន្តរ៍ ។ ម្នាលភិក្ខុទាំង-ឡាយ ប្រសិនបើកាមវិតក្កក្តី ព្យាបាទវិតក្កក្តី វិហឹសាវិតក្កក្តី កើតឡើងដល់ភិក្ខុកំពុងអង្គុយ បើភិក្ខុតាំងចិត្តទទួល មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យអស់ទៅ មិនឲ្យដល់នូវសេចក្តីវិនាស នូវវិតក្កទាំងនោះទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលអង្គុយមានសភាពយ៉ាងនេះ ហៅថា មិនមានព្យាយាម

ដុតកម្តៅកិលេស មិនខ្លាចពាក្យតិះដៀល ខ្ជិលច្រអូស មានព្យាយាមថោកថយជានិច្ចនិរន្តរ៍ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកាមវិតក្កក្តី ព្យាបាទ-វិតក្កក្តី វិហឹសាវិតក្កក្តី កើតឡើងដល់ភិក្ខុកំពុងដេក កំពុងភ្ញាក់រឭក បើភិក្ខុតាំងចិត្តទទួល មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យអស់ទៅ មិនឲ្យដល់នូវសេចក្តីវិនាសនូវវិតក្កទាំងនោះទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលដេក ភ្ញាក់រឭកមានសភាពយ៉ាងនេះ ហៅថា មិនមានព្យាយាមដុតកម្តៅកិលេស មិនខ្លាចពាក្យតិះដៀល ខ្ជិលច្រអូស មានព្យាយាមថោកថយជានិច្ចនិរន្តរ៍ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកាមវិតក្កក្តី ព្យាបាទវិតក្កក្តី វិហឹសាវិតក្កក្តី កើតឡើងដល់ភិក្ខុកំពុងដើរ បើភិក្ខុមិនបានតាំងចិត្តទទួល ខំលះបង់ បន្ទោបង់ចេញ ធ្វើឲ្យអស់ទៅ ឲ្យដល់នូវសេចក្តីវិនាស នូវវិតក្កទាំងនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលដើរមានសភាពយ៉ាងនេះ ហៅថា មានព្យាយាមដុតកម្តៅកិលេស មានសេចក្តីខ្លាចពាក្យតិះដៀល មានព្យាយាមប្រារព្ធហើយមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានជានិច្ចនិរន្តរ៍ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកាមវិតក្កក្តី ព្យាបាទវិតក្កក្តី វិហឹសាវិតក្កក្តី កើតឡើងដល់ភិក្ខុកំពុងឈរ បើភិក្ខុមិនបានតាំងចិត្តទទួល ខំលះបង់ បន្ទោបង់ ធ្វើឲ្យអស់ទៅ ឲ្យដល់នូវសេចក្តីវិនាសនូវវិតក្កទាំងនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈរមានសភាពយ៉ាងនេះ ហៅថា មានព្យាយាមដុតកម្តៅកិលេស មានសេចក្តីខ្លាចពាក្យតិះដៀល មានព្យាយាមប្រារព្ធហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានជានិច្ចនិរន្តរ៍ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកាមវិតក្កក្តី ព្យាបាទវិតក្កក្តី

វិហឹសាវិតក្កក្តី កើតឡើងដល់ភិក្ខុកំពុងអង្គុយ បើភិក្ខុមិនបានតាំងចិត្តទទួល ខំលះបង់ បន្ទោបង់ ធ្វើឲ្យអស់ទៅ ឲ្យដល់នូវសេចក្តីវិនាស នូវវិតក្កទាំង នោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអង្គុយមានសភាពយ៉ាងនេះ ហៅថា មាន ព្យាយាមដុតកម្តៅកិលេស មានសេចក្តីខ្ជិចពាក្យតិះដៀល មានព្យាយាម ប្រារព្ធហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានជានិច្ចនិរន្តរ៍ ។ ម្នាលភិក្ខុទាំង-ឡាយ ប្រសិនបើកាមវិតក្កក្តី ព្យាបាទវិតក្កក្តី វិហឹសាវិតក្កក្តី កើតឡើងដល់ ភិក្ខុកំពុងដេក កំពុងភ្ញាក់រឭក បើភិក្ខុមិនបានតាំងចិត្តទទួល ខំលះបង់ បន្ទោ បង់ ធ្វើឲ្យអស់ទៅ ឲ្យដល់នូវសេចក្តីវិនាស នូវវិតក្កទាំងនោះ ម្នាលភិក្ខុ ទាំងឡាយ ភិក្ខុកាលដេក ភ្ញាក់រឭកមានសភាពយ៉ាងនេះ ហៅថា មាន ព្យាយាមដុតកម្តៅកិលេស មានសេចក្តីខ្ជិចពាក្យតិះដៀល មានព្យាយាម ប្រារព្ធហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានជានិច្ចនិរន្តរ៍ ។

ភិក្ខុណាកាលដើរក្តី ឈរក្តី អង្គុយក្តី ដេកក្តី តែងត្រិះរិះនូវ
វិតក្ក ដែលអាស្រ័យនូវផ្ទះ គឺកិលេសដ៏លាមក ភិក្ខុប្រាកដ
ដូច្នោះនោះ ឈ្មោះថា ដើរទៅកាន់ផ្លូវដែលបណ្ឌិតគប្បីខ្ពើម
ជ្រប់នៅក្នុងអារម្មណ៍ជាគ្រឿងវង្វេង មិនអាចពាល់ត្រូវនូវ
ញាណជាគ្រឿងត្រាស់ដឹងដ៏ឧត្តមទេ ។ ភិក្ខុណាកាលដើរក្តី
ឈរក្តី អង្គុយក្តី ដេកក្តី បានរម្ងាប់នូវវិតក្ក ត្រេកអរក្នុង
ធម៌ ជាគ្រឿងរម្ងាប់នូវវិតក្ក ភិក្ខុប្រាកដដូច្នោះនោះ ទើប
អាចពាល់ត្រូវនូវញាណ ជាគ្រឿងត្រាស់ដឹងដ៏ឧត្តមបាន ។

# អដ្ឋកថា
# ចរវគ្គទី២

## ចរសូត្រ

[ ១១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចរសូត្រទី ១ នៃចរវគ្គទី ២ ដូច្នេះ ក្នុងបទថា **អធិវាសេតិ** បានដល់ លើកឡើងឲ្យនៅក្នុងចិត្ត ។ បទថា **នប្បជហតិ** បានដល់ មិនលះបង់ ។ បទថា **ន វិនោទេតិ** បានដល់ មិននាំចេញ ។ បទថា **ន ព្យន្តីករោតិ** បានដល់ មិនធ្វើឲ្យអស់ គឺកាត់ផ្លូវ ។ បទថា **ន អនភាវំ គមេតិ** បានដល់ មិនធ្វើឲ្យដល់នូវការមិនចម្រើន គឺដល់នូវសេចក្តីលំបាក ។ បទថា **ចរម្បិ** គឺកំពុងដើរ ។ បទថា **អនាតាបី** គឺមិនមានសេចក្តីព្យាយាម ។ បទថា **អនោត្តាបី** គឺវៀរចាកសេចក្តីខ្លាចនូវការតិះដៀល ។ បទថា **សតតំ** គឺជានិច្ច ។ បទថា **សមិតំ** គឺមិនមានចន្លោះ អ្នកសិក្សាជ្រាបអត្ថក្នុងបទទាំងអស់យ៉ាងនេះហើយ គប្បីជ្រាបតាមបរិយាយដែលពោលហើយ ក្នុងសុក្កបក្ខ គឺធម៌ចំណែក-ស ។

ក្នុងគាថា គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **គេហនិស្សិតំ** បានដល់ អាស្រ័យកិលេស ។ បទថា **មោហនេយ្យេសុ** បានដល់ ក្នុងអារម្មណ៍ដែលឲ្យកើតសេចក្តីវង្វេង ។ បទថា **អភព្វោ** បានដល់ មិនដូចភាជនៈដែលទទួលទ្រ ។ បទថា **ផុដ្ឋុំ សម្ពោធិមុត្តមំ** បានដល់ ដើម្បីពាល់ត្រូវឧត្តមញ្ញាណ ពោល គឺអរហត្ត ៕

**អដ្ឋកថា ចរសូត្រទី ១ ចប់**

# សុត្តន្តបិដក

## សីលសូត្រទី ២

[ ១២ ] ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយ បរិបូណ៌ដោយសីល បរិបូណ៌ដោយបាតិមោក្ខ សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈ និងគោចារ ឃើញភ័យក្នុងទោស សូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ បរិបូណ៌ដោយសីល បរិបូណ៌ដោយបាតិមោក្ខ សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈ និងគោចារ ឃើញភ័យក្នុងទោសសូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ តើគប្បីមានកិច្ចអ្វី ដែលគួរធ្វើឲ្យក្រៃលែងឡើងទៀត ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុកាលដើរមានអភិជ្ឈា ... មានព្យាបាទទៅប្រាសហើយ មានសេចក្តីងងុយ និងងោកងក់ ... មានសេចក្តីរវើរវាយ និងសេចក្តីរំខានចិត្ត ... មានសេចក្តីសង្ស័យលះបង់ហើយ មានព្យាយាមប្រារព្ធហើយ មិនបានរួញរា មានស្មារតីប្រុងខ្ជាប់ មិនបានវង្វេងភ្លេច មានកាយស្ងប់រម្ងាប់ មិនបានក្រវល់ក្រវាយ មានចិត្តតម្កល់មាំនៅក្នុងអារម្មណ៍តែមួយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលដើរ មានសភាពយ៉ាងនេះ ហៅថា មានព្យាយាមដុតកម្តៅកិលេស មានសេចក្តីខ្លាចពាក្យតិះដៀល មានព្យាយាមប្រារព្ធហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានជានិច្ចនិរន្តរ៍ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុឈរ ... ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុអង្គុយ ... ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុកំពុងដេក កំពុងភ្ញាក់រឭក

មានអភិជ្ឈា ... មានព្យាបាទទៅប្រាសហើយ មានសេចក្ដីធន់ធ្មុយ និងងោកងក់ ... មានសេចក្ដីរវើរវាយ និងសេចក្ដីរំខានចិត្ត ... មានសេចក្ដីសង្ស័យលះបង់ហើយ មានព្យាយាមប្រារព្ធហើយ មិនបានរួញរា មានស្មារតីប្រុងខ្ជាប់ មិនបានវង្វេងភ្លេច មានកាយស្ងប់រម្ងាប់ហើយ មិនបានក្រវល់ក្រវាយ មានចិត្តតម្កល់មាំ នៅក្នុងអារម្មណ៍តែមួយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលដេក ភ្ញាក់រឭកមានសភាពដូច្នេះ ហៅថា មានព្យាយាមដុតកម្ដៅកិលេស មានសេចក្ដីខ្លាចពាក្យតិះដៀល មានព្យាយាមប្រារព្ធហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានជានិច្ចនិរន្តរ៍ ។

ភិក្ខុគប្បីដើរសង្រួម គប្បីឈរសង្រួម គប្បីអង្គុយសង្រួម
គប្បីដេកសង្រួម គប្បីបត់ ( នូវអវយវៈតូចធំ ) សង្រួម
គប្បីលានូវអវយវៈតូចធំទុំៈសង្រួម គតិនៃសត្វលោកទាំង
ខាងលើ កណ្ដាល និងខាងក្រោម មានកំណត់ត្រឹមណា
អ្នកប្រាជ្ញទាំងឡាយ ពិចារណាឃើញនូវកិរិយាកើតឡើង
និងវិនាសទៅនៃធម៌ គឺខន្ធទាំងឡាយ មានកំណត់ត្រឹមណោះ
ទើបពោលថា ភិក្ខុមានសភាពដូច្នោះ ជាអ្នកសិក្សានូវបដិបទា
ដ៏សមគួរដល់នូវសេចក្ដីស្ងប់រម្ងាប់ចិត្ត មានសតិសព្វកាល
ឈ្មោះថា ជាអ្នកមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានជានិច្ច ។

# អដ្ឋកថា

## សីលសូត្រ

[ ១២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសីលសូត្រទី ២ ដូចតទៅនេះ បទថា **សម្បន្នសីលា** បានដល់ អ្នកទាំងឡាយមានសីលបរិបូណ៌ ។ បទថា **សម្បន្នបាតិមោក្ខា** បានដល់ មានបាតិមោក្ខបរិបូណ៌ ។ បទថា **បាតិមោក្ខសំវរសំវុតា** សេចក្ដីថា អ្នកទាំងឡាយ ចូរជាអ្នកសង្រួម ប្រកប ដោយបាតិមោក្ខសំវរសីលចុះ ។ បទថា **អាចារគោចរសម្បន្នា** សេចក្ដីថា អ្នកទាំងឡាយ ចូរជាអ្នកដល់ព្រម គឺប្រកបដោយអាចារៈ និងគោចរចុះ ។ បទថា **អណុមត្តេសុ វជ្ជេសុ** បានដល់ ក្នុងទោសទាំងឡាយមានប្រមាណ តិច បទថា **ភយទស្សាវិនោ** សេចក្ដីថា ជាអ្នកមានប្រក្រតីឃើញទោស ដែលមានប្រមាណតិចទាំងនោះ ដោយជាភ័យ ។ បទថា **សមាទាយ សិក្ខថ សិក្ខាបទេសុ** សេចក្ដីថា អ្នកទាំងឡាយ ចូរសមាទាន កាន់យក សិក្ខាបទដែលគួរសមាទាននោះៗ ក្នុងចំណែកនៃសិក្ខាទាំងអស់ សិក្សា ។ កាលទ្រង់ដឹកនាំ និងត្រាស់សរសើរក្នុងគុណដែលបានហើយ ដោយការ ត្រាស់ធម៌ប្រមាណប៉ុណ្ណេះថា **សម្បន្នសីលានំ ។បេ។ សិក្ខាបទេសុ** ឥឡូវ នេះ កាលទ្រង់សម្ដែងប្រយោជន៍ដែលគប្បីធ្វើឲ្យក្រៃលែងឡើង ទើបត្រាស់ ថា **កិមស្ស** ដូច្នេះជាដើម ។ ក្នុងបទនោះ បទថា **កិមស្ស** ប្រែថា គប្បី មានអ្វីហ្ន៎ ។

បទថា **យតំ ចរេ** សេចក្ដីថា ភិក្ខុគប្បីដើរ គឺដើរសង្រួម ។ ក្នុងបទ

ទាំងពួងក៏មានន័យដូច្នេះ ។ បទថា **អច្ចេ** ប្រែថា គប្បីអង្គុយ ។ បទថា **យតមេតំ បសារយេ** សេចក្ដីថា គប្បីលាអវយវៈតូចធំ ដោយសង្រួម គឺរៀបរយ ។ បទថា **ឧទ្ធំ** ប្រែថា ខាងលើ ។ បទថា **តិរិយំ** ប្រែថា ត្រង់កណ្ដាល ។ បទថា **អធាចីនំ** ប្រែថា ខាងក្រោម ។ បញ្ចក្ខន្ធ ទោះអតីតក្ដី បច្ចុប្បន្នក្ដី អនាគតក្ដី ត្រាស់ដោយហេតុប្រមាណប៉ុណ្ណេះ ។ ពាក្យថា **យាវតា** ជាពាក្យដែលសម្ដែងការកំណត់ ។ បទថា **ជគតោ គតិ** បានដល់ ការសម្រេចនៃលោក ។ បទថា **សមវេក្ខិតា ច ធម្មានំ ខន្ធានំ ឧទយព្វយំ** សេចក្ដីថា ពិចារណាមើលការកើតឡើង ការវិនាសទៅនៃធម៌ គឺបញ្ចក្ខន្ធ មានអតីតជាដើមនោះ ក្នុងលោកទាំងពួង គឺបានពិចារណាឃើញដោយប្រពៃដោយលក្ខណៈ ៥០ ដែលពោលថា កាលឃើញការកើតនៃបញ្ចក្ខន្ធ ក៏ពិចារណាឃើញលក្ខណៈ ២៥ បាន ។ កាលឃើញការវិនាសក៏ពិចារណាឃើញលក្ខណៈ ២៥ បាន ។ បទថា **ចេតោសមថសាមីចឹ** បានដល់ បដិបទាដែលសមគួរដល់ការស្ងប់ចិត្ត ។ បទថា **សិក្ខមានំ** សេចក្ដីថា កាលបដិបត្តិ គឺបំពេញ ។ បទថា **បហិតត្តោ** បានដល់ មានចិត្តឯក ។ បទថា **អហុ** ប្រែថា ពោល ។ បទដ៏សេសក្នុងសូត្រនេះ ងាយយល់ហើយ ក្នុងសូត្រនេះ ត្រាស់លាយឡំគ្នានឹងសីល ក្នុងគាថាត្រាស់ដល់ភិក្ខុដែលជាខីណាស្រព ។៙

**អដ្ឋកថាសីលសូត្រទី ២ ចប់**

# សុត្តន្តបិដក

## បធានសូត្រទី ៣

[ ១៣ ] ម្នាលភិក្ខុទាំងឡាយ សម្មប្បធាន ( សេចក្តីព្យាយាមប្រពៃ ) នេះមាន ៤ យ៉ាង ។ សម្មប្បធាន ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងអកុសលធម៌ដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ១ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីលះបង់នូវអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ១ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងកុសលធម៌ ដែលមិនទាន់កើតឡើងឲ្យកើតឡើង ១ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងកុសលធម៌ ដែលកើតឡើងហើយ ឲ្យស្ថិតនៅ មិនឲ្យរេចរឹលទៅ ឲ្យចម្រើនដ៏ទូលាយ បរិបូណ៌ក្រៃលែងឡើង ១ ម្នាលភិក្ខុទាំងឡាយ សម្មប្បធានមាន ៤ យ៉ាងប៉ុណ្ណេះ ។

ព្រះខីណាស្រពទាំងនោះ ជាអ្នកមានព្យាយាមដោយប្រពៃ
គ្របសង្កត់នូវមារ គឺវដ្តៈបាន ជាអ្នកមិនបានអាស្រ័យ ជា
អ្នកដល់ត្រើយនៃភ័យ គឺជាតិ និងមរណៈ ត្រេកអរបាន
ឈ្នះនូវមារ ព្រមទាំងវាហនៈ គឺសេនារបស់មារ ព្រះ
ខីណាស្រពនោះ មិនបានញាប់ញ័រដោយតណ្ហា កន្លងបង់
នូវពលនៃមារទាំងអស់បាន ( លោកដល់នូវសេចក្តីសុខ

ហើយ ) ។

# អដ្ឋកថា

## បធានសូត្រ

[ ១៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបធានសូត្រទី ៣ ដូចតទៅនេះ បទថា **សម្មប្បធានានិ** បានដល់ ការត្រេកអរ គឺការព្យាយាមដ៏ខ្ពង់ខ្ពស់ ។ បទថា **សម្មប្បធានា** បានដល់ ព្រះខីណាស្រពដែលមានសេចក្ដីព្យាយាមបរិបូណ៌ ។ បទថា **មារធេយ្យាភិភូតា** សេចក្ដីថា ព្រះខីណាស្រពទាំងនោះ គ្របសង្កត់ធ្វងនូវដែនមារ គឺតេភូមិកវដ្ដ ។ បទថា **តេ អសិតា** បានដល់ ព្រះខីណា-ស្រពទាំងឡាយដែលជាអ្នកមានកិលេសមិនអាស្រ័យហើយ ។ បទថា **ជាតិ-មរណភយស្ស** បានដល់ ភ័យដែលកើតឡើង ព្រោះអាស្រ័យការកើតនិងការស្លាប់ ឬភ័យ ពោល គឺការកើត និងការស្លាប់ ។ បទថា **បារគូ** ប្រែថា ដល់នូវត្រើយ ។ បទថា **តេ តុសិតា** សេចក្ដីថា ព្រះខីណាស្រពទាំងនោះ ឈ្មោះថា ត្រេកអរហើយ ។ បទថា **ជេត្វា មារំ សវាហនំ** បានដល់ ឈ្នះមារ មួយអន្លើនឹងកងទ័ពហើយ ។ បទថា **តេ អនេជា** សេចក្ដីថា ព្រះខីណាស្រពទាំងនោះមិនញាប់ញ័រ ដោយការញាប់ញ័រ គឺតណ្ហា ឈ្មោះថា មិនញាប់ញ័រ ។ បទថា **នមុចិពលំ** ប្រែថា ពលរបស់

មារ ។ បទថា **ឧចាតិវត្តា** ប្រែថា ឈានកន្លង ។ បទថា **តេ សុខិតា** បានដល់ ព្រះខីណាស្រពទាំងនោះ ឈ្មោះថា មានសេចក្ដីសុខ ដោយលោកុត្តរសុខ ។ ដោយហេតុនោះ ទើបលោកពោលថា

**សុខិនោវត អរហន្តោ តណ្ហា តេសំ ន វិជ្ជតិ**
**អស្មិមានោ សមុច្ឆិន្នោ មោហជាលំ បទាលិតំ។**

ពួកអរហន្តមានសេចក្ដីសុខណាស់ ពួកអរហន្តទាំងនោះ
មិនមានតណ្ហាទេ អស្មិមានះ លោកផ្ដាច់បង់ហើយ
បណ្ដាញ គឺមោហៈ លោកទម្លាយចោលហើយ ។

**អដ្ឋកថា បធានសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## សំវរសូត្រទី ៤

[ ១៤ ] ម្នាលភិក្ខុទាំងឡាយ បធាន ( សេចក្ដីព្យាយាម ) នេះ មាន ៤ យ៉ាង ។ បធានទាំង ៤ យ៉ាង តើដូចម្ដេច ។ គឺសំវរប្បធាន ១ បហានប្បធាន ១ ភាវនាបធាន ១ អនុរក្ខនាបធាន ១ ។ ម្នាលភិក្ខុទាំង-ឡាយ សំវរប្បធាន តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយភ្នែកហើយ មិនបានកាន់យកនូវនិមិត្ត មិនបានកាន់យកនូវ

អនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវបុគ្គល ដែលមិនបានសង្រួមនូវចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួមនូវចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក ... ធុំក្លិនដោយច្រមុះ ... ជញ្ជាបរសដោយអណ្តាត ... ពាល់ត្រូវនូវផ្សព្វដោយកាយ ... ដឹងនូវធម្មារម្មណ៍ដោយចិត្ត មិនបានកាន់យកនូវនិមិត្ត មិនបានកាន់យកនូវអនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវបុគ្គលដែលមិនបានសង្រួមនូវមនិន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួមនូវមនិន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវមនិន្ទ្រិយនោះ រក្សានូវមនិន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងមនិន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សំវរប្បធាន ។ ម្នាលភិក្ខុទាំងឡាយ បហានប្បធាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនបានតាំងចិត្តទទួល ខំលះបង់ បន្ទោបង់ ធ្វើឲ្យអស់ទៅ ឲ្យដល់នូវសេចក្តីវិនាស នូវកាមវិតក្កដែលកើតឡើងហើយ ព្យាបាទវិតក្កដែលកើតឡើងហើយ ... វិហឹសាវិតក្កដែលកើតឡើងហើយ ... មិនបានតាំងចិត្តទទួល ខំលះបង់ បន្ទោបង់ ធ្វើឲ្យអស់ទៅ ឲ្យដល់នូវសេចក្តីវិនាស នូវអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ កើតឡើងហើយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បហានប្បធាន ។ ម្នាលភិក្ខុទាំងឡាយ ភាវនាបធាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្តី

ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវសេចក្តីរលត់ មានកិរិយាបង្អោនទៅដើម្បីលះបង់ ចម្រើននូវធម្មវិចយសម្ពោជ្ឈង្គ ... ចម្រើននូវវីរិយសម្ពោជ្ឈង្គ ... ចម្រើននូវបីតិសម្ពោជ្ឈង្គ ... ចម្រើននូវបស្សទ្ធិសម្ពោជ្ឈង្គ ... ចម្រើននូវសមាធិសម្ពោជ្ឈង្គ ... ចម្រើននូវឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្តីស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវសេចក្តីរលត់ មានកិរិយាបង្អោនទៅដើម្បីលះបង់ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភាវនាបធាន ។ ម្នាលភិក្ខុទាំងឡាយ អនុរក្ខនាបធាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រក្សាទុកនូវសមាធិនិមិត្ត គឺអដ្ឋិកសញ្ញា បុឡវកសញ្ញា វិនីលកសញ្ញា វិបុព្វកសញ្ញា វិច្ឆិទ្ទកសញ្ញា ឧទ្ធុមាតកសញ្ញាដ៏ល្អ ដែលកើតឡើងហើយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អនុរក្ខនាបធាន ។ ម្នាលភិក្ខុទាំងឡាយ បធានមាន ៤ យ៉ាងប៉ុណ្ណេះ ។

សំវរប្បធាន ១ បហានប្បធាន ១ ភាវនាបធាន ១ អនុ-
រក្ខនាបធាន ១ បធានទាំង ៤ យ៉ាងនេះ ព្រះពុទ្ធជា
ផៅពង្សនៃព្រះអាទិត្យ ទ្រង់សម្តែងហើយ ដែលភិក្ខុក្នុង
សាសនានេះ មានព្យាយាមដុតកម្តៅកិលេស បានដល់នូវ
អរហត្ត ជាធម៌អស់ទៅនៃទុក្ខ ។

# អដ្ឋកថា

## សំវរសូត្រ

[ ១៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសំវរសូត្រទី ៤ ដូចតទៅនេះ សេចក្ដីព្យាយាម ឈ្មោះថា **បធាន** ។ សេចក្ដីព្យាយាមដែលកើតឡើងដល់អ្នកសង្រួមចក្ខុជាដើម ឈ្មោះថា **សំវរប្បធាន** ។ សេចក្ដីព្យាយាមដែលកើតឡើងដល់បុគ្គលដែលលះកាមវិតក្កជាដើម ឈ្មោះថា **បហានប្បធាន** ។ សេចក្ដីព្យាយាមដែលកើតឡើងដល់បុគ្គលដែលចម្រើនសម្ពោជ្ឈង្គ ឈ្មោះថា **ភាវនាបធាន** ។ សេចក្ដីព្យាយាមដែលកើតឡើងដល់ភិក្ខុដែលតាមរក្សាសមាធិនិមិត្ត ឈ្មោះថា **អនុរក្ខនាបធាន** ។ ក្នុងបទថា **វិវេកនិស្សិតំ** ជាដើម មានវិនិច្ឆ័យដូច្នេះថា បទទាំង ៣ គឺវិវេក វិរាគ និរោធ ជាឈ្មោះរបស់និព្វាន ពិតហើយ និព្វាន ឈ្មោះថា **វិវេក** ព្រោះស្ងាត់ចាកឧបធិ ឈ្មោះថា **វិរាគ** ព្រោះរាគៈជាដើម អាស្រ័យនិព្វាននោះ ទើបប្រាសទៅ ។ ឈ្មោះថា **និរោធ** ព្រោះរាគៈជាដើមអាស្រ័យនិព្វាននោះ ក៏រលត់ទៅ ព្រោះដូច្នោះ ក្នុងបទថា **វិវេកនិស្សិតំ** ជាដើម ទើបមានអត្ថថា អាស្រ័យនិព្វាន ដោយជាអារម្មណ៍ខ្លះ ដោយជាធម៌ដែលគប្បីសម្រេចខ្លះ ។

ក្នុងបទថា **វោស្សគ្គបរិណាមី** នេះ វោស្សគ្គមាន ២ គឺបរិច្ចាគវោស្សគ្គ ១ បក្ខន្ទនវោស្សគ្គ ១ ។ ក្នុង ២ យ៉ាងនោះ វិបស្សនា ឈ្មោះថា **បរិច្ចាគ-វោស្សគ្គ** ព្រោះលះបង់រាគៈក្នុងកិលេស និងខន្ធ ដោយអំណាចតទង្គប្បហាន មគ្គ ឈ្មោះថា **បក្ខន្ទនវោស្សគ្គ** ព្រោះស្ទុះទៅកាន់និព្វាន ដោយអំណាច

អារម្មណ៍ ។ ព្រោះដូច្នោះ ក្នុងបទថា **វោស្សគ្គបរិណាមឹ** នេះ ទើបមានអត្ថដូច្នេះថា សតិសម្ពោជ្ឈង្គដែលភិក្ខុចម្រើនដោយប្រការណា រមែងបង្អោនទៅដើម្បីលះបង់ រមែងដល់វិបស្សនាភាវនា និងមគ្គភាវនា ភិក្ខុរមែងចម្រើនសតិសម្ពោជ្ឈង្គនោះ ដោយប្រការនោះ ក្នុងបទដ៏សេសក៏មានន័យនេះឯង ។ បទថា **ភទ្ទកំ** បានដល់ ដែលបានហើយ ។ សមាធិដែលបានហើយ ដោយអំណាចអដ្ឋិកសញ្ញាជាដើម ហៅថា **សមាធិនិមិត្ត** ។ បទថា **អនុរក្ខតិ** បានដល់ ដែលជាធម៌ធ្វើរាគៈ ទោសៈ មោហៈ ដែលជាសត្រូវចំពោះសមាធិឲ្យរីងស្ងួតទៅរក្សាទុក ។ សញ្ញា ៥ មានអដ្ឋិកសញ្ញាជាដើម ត្រាស់ក្នុងសេចក្តីនេះ តែក្នុងទីនេះ គប្បីពោលអសុភសញ្ញា ១០ ឲ្យពិស្តារផងដែរ ។ សេចក្តីពិស្តាររបស់អសុភសញ្ញានោះ ពោលហើយក្នុងវិសុទ្ធិមគ្គ ។

ក្នុងគាថា លោកពោលសេចក្តីព្យាយាមតែម្យ៉ាងដែលឲ្យសម្រេចសំវរៈជាដើម ដោយឈ្មោះ ឈ្មោះថា **សំវរ** ។ បទថា **ខយំ ទុក្ខស្ស បាបុណេ** គឺគប្បីសម្រេចអរហត្ត ពោល គឺធម៌ជាទីអស់ទៅនៃទុក្ខ ។

## អដ្ឋកថាសំវរសូត្រទី ៤ ចប់

# សុត្តន្តបិដក

## បញ្ញត្តិសូត្រទី ៥

[ ១៥ ] ម្នាលភិក្ខុទាំងឡាយ អគ្គប្បញ្ញត្តិ ( បញ្ញត្តិដ៏ប្រសើរ ) នេះ មាន ៤ យ៉ាង ។ អគ្គប្បញ្ញត្តិ ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ រាហុអសុរិន្ទនេះ ធំលើសជាងពួកសត្វមានអត្តភាព ១ ម្នាលភិក្ខុទាំងឡាយ ព្រះបាទមន្ធាតុនេះ ប្រសើរជាងបុគ្គលអ្នកបរិភោគកាមទាំងឡាយ ១ ម្នាលភិក្ខុទាំងឡាយ មារមានចិត្តបាបនេះ ប្រសើរជាងពួកសត្វដែលមានតំណែងធំៗ ១ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ប្រាកដជាប្រសើរក្នុងមនុស្សលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ១ ។ ម្នាលភិក្ខុទាំងឡាយ អគ្គប្បញ្ញត្តិមាន ៤ យ៉ាងប៉ុណ្ណេះ ។ រាហុធំលើសពួកសត្វដែលមានអត្តភាព ស្តេចមន្ធាតុប្រសើរជាងបុគ្គលអ្នកបរិភោគកាមទាំងឡាយ មារប្រសើរជាងពួកសត្វ ដែលមានតំណែងធំៗ ជាអ្នករុងរឿងដោយឫទ្ធិ គឺការសម្រេចដោយទិព្វសម្បត្តិ និងដោយយសបរិវារ គតិនៃសត្វលោកមានកំណត់ត្រឹមណា ទោះជាន់ខាងលើក្តី កណ្តាលក្តី ខាងក្រោមក្តី ព្រះពុទ្ធដែលអ្នកប្រាជ្ញទាំងឡាយពោលថា ប្រសើរជាងមនុស្សលោក ព្រមទាំងទេវលោក មានកំណត់ត្រឹមណោះ ។

# អដ្ឋកថា

## បញ្ញត្តិសូត្រ

[ ១៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបញ្ញត្តិសូត្រទី ៥ ដូចតទៅនេះ បទថា **អគ្គប្បញ្ញត្តិយោ** បានដល់ ការបញ្ញត្តិដ៏ឧត្តម ។ បទថា **អត្តភាវីនំ** បានដល់ មានអត្តភាពទាំងឡាយ ។ បទថា **យទិទំ រាហុ អសុរិន្ទោ** បានដល់ អសុរិន្ទរាហុនេះ ឈ្មោះថាជាកំពូល ។ បានឮថា ក្នុងសេចក្តីនេះ អសុរិន្ទរាហុកម្ពស់ ៤៨០០ យោជន៍ ចន្លោះដើមដៃ ១២០០ យោជន៍ បាតដៃ បាតជើង ទំហំ ៣០០ យោជន៍ ថ្នាំងម្រាមដៃ ៥០ យោជន៍ ចន្លោះចិញ្ចើមម្ខាងទៅម្ខាង ៥០ យោជន៍ ថ្ងាស់ទំហំ ៣០០ យោជន៍ ក្បាលទំហំ ៩០០ យោជន៍ ។

បទថា **កាមភោគីនំ យទិទំ រាជា មន្ធាតា** សេចក្តីថា ព្រះបាទមន្ធាតុនេះ ឈ្មោះថា ជាកំពូលរបស់សត្វដែលបរិភោគកាមរបស់ទិព្វផង ជារបស់មនុស្សផង ។ ពិតហើយ ព្រះបាទមន្ធាតុនោះ កើតក្នុងមនុស្សទាំងឡាយ មានអាយុមួយអសង្ខេយ្យ ធ្វើភ្លៀងឲ្យធ្លាក់ចុះជាប្រាក់ ក្នុងខណៈដែលប្រាថ្នាបរិភោគកាមដែលជារបស់មនុស្សអស់កាលដ៏យូរ ។ ឯក្នុងទេវលោក ក៏បរិភោគកាមដ៏ប្រណីត រហូតដល់ព្រះឥន្ទអស់អាយុ ៣៦ អង្គ ព្រោះដូច្នោះ ទើបលោកឈ្មោះថា ជាកំពូលនៃបុគ្គលដែលបរិភោគកាមទាំងឡាយ ។ បទថា **អធិបតេយ្យានំ** សេចក្តីថា នៃបណ្តាបុគ្គលដែលគ្រប់គ្រងតំណែងអធិបតី គឺតំណែងជាប្រធាន ។ បទថា **តថាគតោ អគ្គមក្ខាយតិ**

សេចក្តីថា អ្នកប្រាជ្ញហៅព្រះតថាគតថាជាអគ្គបុគ្គលដោយគុណ ដែលជាលោកិយ និងលោកុត្តរ ។

បទថា **ឥទ្ធិយា យសសា ជលំ** សេចក្តីថា បុគ្គលរុងរឿងដោយសេចក្តីសម្រេចនៃទិព្វសម្បត្តិ និងដោយយស ពោល គឺបរិវារ ។ បទថា **ឧទ្ធំ តិរិយំ អបាចីនំ** បានដល់ ក្នុងខាងលើ កណ្តាល និងខាងក្រោម ។ បទថា **យាវតា ជគតោ គតិ** បានដល់ ភូមិសម្រេចនៃលោកត្រឹមប៉ុណ្ណា ៕

## អដ្ឋកថា បញ្ញត្តិសូត្រទី ៥ ចប់

# សុត្តន្តបិដក

## សោខុម្មសូត្រទី ៦

[ ១៦ ] ម្នាលភិក្ខុទាំងឡាយ ញាណជាគ្រឿងចាក់ធ្លុះនូវលក្ខណៈដ៏ល្អិតនេះ មាន ៤ យ៉ាង ។ ញាណជាគ្រឿងចាក់ធ្លុះនូវលក្ខណៈដ៏ល្អិត ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ប្រកបដោយញាណជាគ្រឿងកំណត់នូវលក្ខណៈដ៏ល្អិត ក្នុងរូបក្រៃលែង ប៉ុន្តែមិនពិចារណាឃើញនូវញាណជាគ្រឿងកំណត់ នូវលក្ខណៈដ៏ល្អិត ក្នុងរូបដទៃទៀត ដែលលើសលុបជាង ឬថ្លៃថ្លាជាងញាណ ជាគ្រឿងកំណត់នូវលក្ខណៈដ៏ល្អិត ក្នុងរូបនោះ ទាំងមិនបានប្រាថ្នានូវញាណ ជាគ្រឿងកំណត់

នូវលក្ខណៈដ៏ល្អិត ក្នុងរូបដទៃទៀត ដែលលើសលុបជាង ឬថ្លៃថ្លាជាង ញាណជាគ្រឿងកំណត់នូវលក្ខណៈដ៏ល្អិត ក្នុងរូបនោះឯង ១ ប្រកបដោយញាណជាគ្រឿងកំណត់នូវលក្ខណៈដ៏ល្អិតក្នុងវេទនា ១ ប្រកបដោយញាណជាគ្រឿងកំណត់នូវលក្ខណៈដ៏ល្អិតក្នុងសញ្ញា ១ ប្រកបដោយញាណជាគ្រឿងកំណត់នូវលក្ខណៈដ៏ល្អិតក្នុងសង្ខារដ៏ក្រៃលែង ប៉ុន្តែមិនពិចារណាឃើញនូវញាណជាគ្រឿងកំណត់នូវលក្ខណៈដ៏ល្អិតក្នុងសង្ខារដទៃ ដែលលើសលុបជាង ឬថ្លៃថ្លាជាងញាណជាគ្រឿងកំណត់នូវលក្ខណៈដ៏ល្អិតក្នុងសង្ខារនោះទាំងមិនបានប្រាថ្នានូវញាណ ជាគ្រឿងកំណត់នូវលក្ខណៈដ៏ល្អិត ក្នុងសង្ខារដទៃទៀតដែលលើសលុបជាង ឬថ្លៃថ្លាជាងញាណជាគ្រឿងកំណត់នូវលក្ខណៈដ៏ល្អិតក្នុងសង្ខារនោះឯង ១ ។ ម្នាលភិក្ខុទាំងឡាយ ញាណជាគ្រឿងចាក់ធ្លុះនូវលក្ខណៈដ៏ល្អិត មាន ៤ យ៉ាងប៉ុណ្ណេះ ។

ភិក្ខុណាដឹងសភាពដ៏ល្អិត នូវរូបក្ខន្ធផង នូវហេតុជាដែនកើតឡើងនៃវេទនាខន្ធផង សញ្ញាខន្ធតាំងឡើងដោយហេតុណា ដល់នូវការរលត់ទៅក្នុងទីណា ( ដឹងច្បាស់នូវហេតុនោះ ដឹងទីនោះ ) ផង ដឹងនូវសង្ខារក្ខន្ធថា ជារបស់អ្នកដទៃ គឺមិនទៀង ជាទុក្ខ មិនមែនជារបស់ខ្លួនផង ភិក្ខុនោះឈ្មោះថាឃើញដោយប្រពៃ ជាអ្នកស្ងប់រម្ងាប់ ត្រេកអរក្នុងសន្តិបទ គឺព្រះនិព្វាន បានឈ្នះនូវមារ ព្រមទាំងវាហនៈ គឺសេនា ហើយ រមែងទ្រទ្រង់ទុកនូវរាងកាយ ក្នុងភពជាទីបំផុត ។

# អដ្ឋកថា

## សោខុម្មសូត្រ

[ ១៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសោខុម្មសូត្រទី ៦ ដូចតទៅនេះ បទថា **សោខុម្មានិ** បានដល់ ញាណដែលជាគ្រឿងចាក់ធ្លុះបានរហូត ។ បទថា **រូបសោខុម្មេន សមន្នាគតោ ហោតិ** បានដល់ ជាអ្នកប្រកបដោយញាណដែលកំណត់ដឹងលក្ខណៈសុខុម ល្អិតក្នុងរូប ។ បទថា **បរមេន** បានដល់ ឧត្តម ។ បទថា **តេន ច រូបសោខុម្មេន** សេចក្តីថា ដោយញាណដែលកំណត់ដឹងសុខុមលក្ខណៈ រហូតដល់អនុលោមញ្ញាណនោះ ។ បទថា **ន សមនុបស្សតិ** បានដល់ មិនពិចារណាឃើញដោយការមិនមាន ។ បទថា **ន បត្ថេតិ** បានដល់ មិនប្រាថ្នាដោយការមិនមាន ។ ក្នុងវេទនាដែលសុខុមជាដើម ក៏មានន័យដូចគ្នា ។

បទថា **រូបសោខុម្មតំ ញត្វា** សេចក្តីថា កិច្ចដឹងរូបក្ខន្ធដែលជារបស់សុខុម ដោយញាណជាគ្រឿងកំណត់សុខុមលក្ខណៈដែលល្អិត ។ បទថា **វេទនានញ្ច សម្ភវំ** សេចក្តីថា ដឹងដល់ដែនកើតនៃវេទនាខន្ធ ។ បទថា **សញ្ញា យតោ សមុទេតិ** សេចក្តីថា ដឹងហេតុដែលសញ្ញាខន្ធកើត គឺកើតឡើង ។ បទថា **អត្ថំ គច្ឆតិ យត្ថ ច** សេចក្តីថា ដឹងដល់សញ្ញាខន្ធរលត់ ។ បទថា **សង្ខារេ បរតោ ញត្វា** សេចក្តីថា ដឹងដល់សង្ខារក្ខន្ធដែលប្រែប្រួលទៅជាដទៃ ដោយអំណាចការទ្រុឌទ្រោម ព្រោះជារបស់មិនទៀង ។ អនិច្ចានុ-បស្សនា ត្រាស់ដោយបទនេះ ។ ត្រាស់ទុក្ខានុបស្សនា និងអនត្តានុបស្សនា

ដោយបទនេះថា **ឧក្កុដោ ឆោ ច អត្ថតោ** ។ បទថា **សន្តោ** សេចក្តីថា ឈ្មោះថា ស្ងប់ ព្រោះកិលេសស្ងប់ ។ បទថា **សន្តិបទេ រតោ** បានដល់ ត្រេកអរក្នុងព្រះនិព្វាន ។ ក្នុងសូត្រនេះ ត្រាស់វិបស្សនាក្នុងឋានៈ ៤ ប៉ុណ្ណោះ ក្នុងគាថា ត្រាស់លោកុត្តរធម៌ផងដែរ ៕

**អដ្ឋកថា សោខុម្មសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## បឋមអគតិសូត្រទី ៧

[ ១៧ ] ម្នាលភិក្ខុទាំងឡាយ ការលុះអគតិ ( សេចក្តីលម្អៀង ) នេះមាន ៤ យ៉ាង ។ អគតិ ៤ យ៉ាង តើដូចម្តេច ។ គឺលុះអគតិព្រោះសេចក្តីស្រឡាញ់ ១ លុះអគតិព្រោះសេចក្តីស្អប់ ១ លុះអគតិព្រោះសេចក្តីល្ងង់ ១ លុះអគតិព្រោះសេចក្តីខ្លាច ១ ។ ម្នាលភិក្ខុទាំងឡាយ ការលុះអគតិមាន ៤ យ៉ាងប៉ុណ្ណោះ ។

បុគ្គលណាកន្លងនូវសុចរិតធម៌ ព្រោះសេចក្តីស្រឡាញ់ សេចក្តីស្អប់ សេចក្តីខ្លាច សេចក្តីល្ងង់ យសរបស់បុគ្គលនោះ រមែងសាបសូន្យទៅ ដូចជាព្រះចន្ទ្រក្នុងកាឡបក្ស គឺខាងរនោច ។

# អដ្ឋកថា

## បឋមអគតិសូត្រ

[ ១៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមអគតិសូត្រទី ៧ ដូចតទៅនេះ បទថា **អគតិគមនានិ** បានដល់ សេចក្ដីលម្អៀង ។ បទថា **ឆន្ទាគតឹ គច្ឆតិ** សេចក្ដីថា បុគ្គលលម្អៀង ព្រោះពេញចិត្ត គឺធ្វើវត្ថុដែលមិនគួរធ្វើ ។ ក្នុងបទដ៏សេសក៏ន័យនេះឯង ។

បទថា **ឆន្ទា ទោសា ភយា មោហា** សេចក្ដីថា បុគ្គលធ្វើនូវសេចក្ដីលម្អៀង ព្រោះការពេញចិត្ត ព្រោះស្អប់ ព្រោះខ្លាច ព្រោះល្ងង់ ។ បទថា **អតិវត្តតិ** បានដល់ ល្មើសក្នុងធម៌ ៕

### អដ្ឋកថា បឋមអគតិសូត្រទី ៧ ចប់

# សុត្តន្តបិដក

## ទុតិយអគតិសូត្រទី ៨

[ ១៨ ] ម្នាលភិក្ខុទាំងឡាយ ការមិនលុះអគតិនេះមាន ៤ យ៉ាង ។ ឯការមិនលុះអគតិ ៤ យ៉ាង តើដូចម្ដេចខ្លះ ។ គឺមិនលុះអគតិព្រោះសេចក្ដីស្រឡាញ់ ១ មិនលុះអគតិព្រោះសេចក្ដីស្អប់ ១ មិនលុះអគតិព្រោះសេចក្ដីល្ងង់ ១ មិនលុះអគតិព្រោះសេចក្ដីខ្លាច ១ ។ ម្នាលភិក្ខុទាំងឡាយ ការមិន

លុះអគតិ មាន ៤ យ៉ាងប៉ុណ្ណេះ ។

បុគ្គលណាមិនបានកន្លងនូវសុចរិតធម៌ ព្រោះសេចក្តីស្រឡាញ់ សេចក្តីស្អប់ សេចក្តីខ្លាច សេចក្តីល្ងង់ យសរបស់បុគ្គលនោះ រមែងពេញបរិបូណ៌ ដូចជាព្រះចន្ទ្រក្នុងសុក្កបក្ស គឺខាងខ្នើត ។

# អដ្ឋកថា

## ទុតិយអគតិសូត្រ

ក្នុងទុតិយអគតិសូត្រទី ៨ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាទុតិយអគតិសូត្រទី ៨ ចប់

# សុត្តន្តបិដក

## តតិយអគតិសូត្រទី ៩

[ ១៩ ] ម្នាលភិក្ខុទាំងឡាយ ការលុះអគតិនេះមាន ៤ យ៉ាង ។ ការលុះអគតិ ៤ យ៉ាង តើដូចម្តេច ។ គឺលុះអគតិព្រោះសេចក្តីស្រឡាញ់ ១ លុះអគតិព្រោះសេចក្តីស្អប់ ១ លុះអគតិព្រោះសេចក្តីល្ងង់ ១ លុះអគតិព្រោះសេចក្តីខ្លាច ១ ។ ម្នាលភិក្ខុទាំងឡាយ ការលុះអគតិ ៤ យ៉ាងប៉ុណ្ណេះ ។

បុគ្គលណាកន្លងនូវសុចរិតធម៌ ព្រោះសេចក្ដីស្រឡាញ់ សេចក្ដី
ស្អប់ សេចក្ដីខ្លាច សេចក្ដីល្ងង់ យសរបស់បុគ្គលនោះ រមែង
សាបសូន្យទៅ ដូចជាព្រះចន្ទ្រក្នុងកាឡបក្ស ។

[ ២០ ] ម្នាលភិក្ខុទាំងឡាយ ការមិនលុះអគតិនេះមាន ៤ យ៉ាង ។ ការមិនលុះអគតិ ៤ យ៉ាង តើដូចម្ដេច ។ គឺមិនលុះអគតិព្រោះសេចក្ដីស្រឡាញ់ ១ មិនលុះអគតិព្រោះសេចក្ដីស្អប់ ១ មិនលុះអគតិព្រោះសេចក្ដីល្ងង់ ១ មិនលុះអគតិព្រោះសេចក្ដីខ្លាច ១ ។ ម្នាលភិក្ខុទាំងឡាយ ការមិនលុះអគតិ មាន ៤ យ៉ាងប៉ុណ្ណេះ ។

បុគ្គលណា មិនប្រព្រឹត្តកន្លងនូវសុចរិតធម៌ ព្រោះសេចក្ដី
ស្រឡាញ់ សេចក្ដីស្អប់ សេចក្ដីខ្លាច សេចក្ដីល្ងង់ យសរបស់
បុគ្គលនោះ រមែងពេញបរិបូណ៌ដូចព្រះចន្ទ្រក្នុងសុក្កបក្ស ។

# អដ្ឋកថា

## តតិយអគតិសូត្រ

[ ១៩-២០ ] តតិយអគតិសូត្រទី ៩ ត្រាស់ដោយន័យទាំង ២ ដោយអំណាចនៃបុគ្គលដែលត្រាស់ដឹងដូចគ្នា ។

**អដ្ឋកថា តតិយអគតិសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ភត្តុទ្ទេសកសូត្រទី ១០

[ ២១ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាភត្តុទ្ទេសកៈ ( អ្នកសម្តែងនូវភត្ត ) ប្រកបដោយធម៌ ៤ យ៉ាង រមែងធ្លាក់ចុះទៅក្នុងនរក ដូចជាគេនាំទៅទម្លាក់ចោល ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច ។ គឺលុះអគតិព្រោះសេចក្តីស្រឡាញ់ ១ លុះអគតិព្រោះសេចក្តីស្អប់ ១ លុះអគតិព្រោះសេចក្តីល្ងង់ ១ លុះអគតិព្រោះសេចក្តីខ្លាច ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាភត្តុទ្ទេសកៈ ប្រកបដោយធម៌ ៤ យ៉ាងនេះឯង រមែងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ចោល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាភត្តុទ្ទេសកៈ ប្រកបដោយធម៌ ៤ យ៉ាង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច ។ គឺមិនលុះអគតិព្រោះសេចក្តីស្រឡាញ់ ១ មិនលុះអគតិព្រោះសេចក្តីស្អប់ ១ មិនលុះអគតិព្រោះសេចក្តីល្ងង់ ១ មិនលុះអគតិព្រោះសេចក្តីខ្លាច ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាភត្តុទ្ទេសកៈ ប្រកបដោយធម៌ ៤ យ៉ាងនេះ រមែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។

ជនណានីមួយមិនសង្រួមក្នុងកាម មិនប្រកបដោយធម៌
មិនគោរពក្នុងធម៌ លុះអគតិព្រោះសេចក្តីស្រឡាញ់
សេចក្តីស្អប់ សេចក្តីខ្លាច ( សេចក្តីល្ងង់ ) ជននោះ
ហៅថាជាមនុស្សក្រាកក្នុងបរិស័ទ ព្រោះព្រះពុទ្ធសមណៈ

អ្នកត្រាស់ដឹង ទ្រង់សម្តែងទុកយ៉ាងនេះ ព្រោះហេតុនោះ ជនទាំងឡាយណា ស្ថិតនៅក្នុងធម៌ មិនធ្វើអំពើលាមក មិនលុះអគតិព្រោះសេចក្តីស្រឡាញ់ សេចក្តីស្អប់ សេចក្តីខ្លាច ( សេចក្តីល្ងង់ ) ជនទាំងនោះ ជាសប្បុរស ដែលអ្នកប្រាជ្ញគប្បីសរសើរ ។ ជននោះហៅថាជាអ្នកផូរផង់ក្នុងបរិស័ទ ព្រោះព្រះពុទ្ធសមណៈអ្នកត្រាស់ដឹង ទ្រង់សម្តែងទុកហើយយ៉ាងនេះ ។

**ចរវគ្គទី ២ ចប់**

## ឧទ្ទាននៃចរវគ្គនោះ គឺ

និយាយអំពីការដើរជាដើម ១ អំពីសីល ១ អំពីសេចក្តីព្យាយាម ១ អំពីសេចក្តីសង្រួម ១ អគ្គប្បញ្ញត្តិ ១ ទៀតជាគម្រប់ ៥ អំពីញាណជាគ្រឿងកំណត់ដឹងនូវលក្ខណៈដ៏ល្អិត ១ អំពីអគតិមាន ៣ លើក និងភិក្ខុជាអ្នកសម្តែងនូវភត្តមួយទៀត ត្រូវជា ១០ ។

# អដ្ឋកថា

## ភត្តុទ្ទេសកសូត្រ

[ ២១ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងភត្តុទ្ទេសកសូត្រទី ១០ ដូចតទៅនេះ បទថា* **ភត្តុទ្ទេសកោ** *បានដល់ ភិក្ខុអ្នកចែកសលាកភត្តជាដើម ។ បទថា* **កាមេសុ អសញ្ញតា** *សេចក្តីថា ពួកជនដែលមានកិលេសកាមមិនសង្រួមក្នុងវត្ថុកាមទាំងឡាយ ។ បទថា* **បរិសាកសដោ ច បនេស វុច្ចតិ** *សេចក្តីថា បរិស័ទបែបនេះ ឈ្មោះថា បរិស័ទកាកសំណល់ ។ បទថា* **សមណេន** *បានដល់ ព្រះពុទ្ធសមណៈដែលជាអ្នកត្រាស់ដឹង ។ បទថា* **បរិសាយ មណ្ឌោ ច បនេស វុច្ចតិ** *សេចក្តីថា បរិស័ទបែបនេះ ហៅថា ជាអ្នកផូរផង់ក្នុងបរិស័ទ ព្រោះការបរិសុទ្ធ ។*

**អដ្ឋកថា ភត្តុទ្ទេសកសូត្រទី ១០ ចប់**

**ចរវគ្គទី ២ ចប់**

# សុត្តន្តបិដក

# ឧរុវេលវគ្គទី ៣

## បឋមឧរុវេលសូត្រទី ១

[ ២២ ] *សម័យមួយ ព្រះដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះ ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ សម័យមួយ តថាគតបានត្រាស់ដឹងជាដំបូង ហើយនៅក្រោមដើមអជបាលនិគ្រោធ ក្បែរឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលានិគមឯណោះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ សម្ងំនៅក្នុងទីស្ងាត់តែម្នាក់ឯង មានចិត្តត្រិះរិះយ៉ាងនេះថា បុគ្គលមិនមានសេចក្តីគោរពកោតក្រែង រមែងនៅបានទាំងលំបាកណាស់ តថាគតគួរចូលទៅធ្វើសក្ការៈ ធ្វើសេចក្តីគោរពសមណៈ ឬព្រាហ្មណ៍ណាហ្ន៎ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះថា តថាគតគប្បីចូលទៅធ្វើសក្ការៈ ធ្វើសេចក្តីគោរពសមណៈ ឬព្រាហ្មណ៍ឯទៀត ដើម្បីបំពេញនូវសីលក្ខន្ធរបស់តថាគតដែលមិនទាន់ពេញ តែក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស តថាគតមិនឃើញសមណៈ ឬព្រាហ្មណ៍ឯទៀត ដែលបរិបូណ៌ដោយសីលជាងតថាគត គួរឲ្យតថាគតចូលទៅធ្វើសក្ការៈ ធ្វើសេចក្តី*

គោរពបានឡើយ នូវសមាធិក្ខន្ធរបស់តថាគតដែលមិនទាន់ពេញ ... នូវបញ្ញាខន្ធ ... តថាគតគួរចូលទៅធ្វើសក្ការៈ ធ្វើសេចក្តីគោរពសមណៈ ឬព្រាហ្មណ៍ឯទៀត ដើម្បីបំពេញវិមុត្តិក្ខន្ធ តែក្នុងលោក ព្រមទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស តថាគតមិនឃើញសមណៈ ឬព្រាហ្មណ៍ឯទៀត ឲ្យបរិបូណ៌ដោយវិមុត្តិជាងតថាគត ល្មមឲ្យតថាគតចូលទៅធ្វើសក្ការៈ ធ្វើសេចក្តីគោរពបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះថា បើដូច្នោះ គួរតែតថាគតចូលទៅធ្វើសក្ការៈ ធ្វើសេចក្តីគោរពធម៌ ដែលតថាគតត្រាស់ដឹងហើយនោះ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង សហម្បតិព្រហ្ម បានដឹងសេចក្តីត្រិះរិះក្នុងចិត្តរបស់តថាគត ក៏បាត់អំពីព្រហ្មលោក មកប្រាកដក្នុងទីចំពោះមុខតថាគត ដូចជាបុរសមានកម្លាំងលាដៃដែលខ្ជួនបត់ ឬបត់ដៃដែលខ្ជួនលាចេញ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ សហម្បតិព្រហ្មបង់កសំពត់ឆៀងស្មាម្ខាង លុតជង្គង់ខាងស្តាំលើប្រឹថពី ប្រណម្យអញ្ជលីចំពោះតថាគត និយាយនឹងតថាគត យ៉ាងនេះថា បពិត្រព្រះដ៏មានព្រះភាគ ការនុ៎ះយ៉ាងនេះហើយ បពិត្រព្រះសុគត ការនុ៎ះយ៉ាងនេះហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធទាំងឡាយណាមានហើយ ក្នុងកាលអតីតក្តី ព្រះដ៏មានព្រះភាគទាំងឡាយនោះ ចូលទៅធ្វើសក្ការៈ ធ្វើសេចក្តីគោរពចំពោះធម៌តែប៉ុណ្ណោះ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធទាំងឡាយ

ណា នឹងមានក្នុងកាលអនាគតក្តី ព្រះដ៏មានព្រះភាគទាំងនោះ នឹងចូលទៅធ្វើសក្ការៈ ធ្វើសេចក្តីគោរពចំពោះព្រះធម៌ដែរ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ក្នុងកាលឥឡូវនេះ ចូលទៅធ្វើសក្ការៈ ធ្វើសេចក្តីគោរពចំពោះព្រះធម៌ដែរចុះ ។ សហម្បតិព្រហ្ម បានពោលពាក្យនេះហើយ លុះពោលពាក្យនេះហើយ ក៏ពោលពាក្យជាគាថាព័ន្ធយ៉ាងនេះតទៅទៀតថា

ព្រះសម្ពុទ្ធទាំងឡាយណា ក្នុងកាលជាអតីតក្តី ព្រះសម្ពុទ្ធទាំងឡាយណា ក្នុងកាលអនាគតក្តី ព្រះសម្ពុទ្ធណា ក្នុងកាលឥឡូវនេះក្តី ព្រះអង្គបានញុំាងសេចក្តីសោករបស់ពួកជនច្រើនឲ្យវិនាស ព្រះសម្ពុទ្ធគ្រប់អង្គនោះ គោរពព្រះសទ្ធម្មហើយផងកំពុងគោរពព្រះសទ្ធម្មផង និងគោរពព្រះសទ្ធម្មផង នេះជាធម្មតារបស់ព្រះពុទ្ធទាំងឡាយ ហេតុនោះបុគ្គលអ្នកត្រូវការប្រយោជន៍ផ្ទាល់ខ្លួន ប្រាថ្នានូវភាវៈនៃខ្លួនជាធំ កាលរឭកពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ត្រូវតែគោរពព្រះសទ្ធម្ម ។

ម្នាលភិក្ខុទាំងឡាយ សហម្បតិព្រហ្មបាននិយាយពាក្យនេះ លុះនិយាយពាក្យនេះហើយ ក៏ថ្វាយបង្គំតថាគត រួចធ្វើប្រទក្សិណហើយបាត់ពីទីនោះទៅ ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានដឹងច្បាស់នូវការនិមន្តន៍របស់

សហម្បតិព្រហ្មផង នូវការដ៏សមគួរដល់តថាគតផង ក្នុងទីឯណោះហើយ ក៏ធ្វើសក្ការៈ ធ្វើសេចក្តីគោរពចំពោះធម៌ ដែលតថាគតត្រាស់ដឹងហើយនោះ ម្នាលភិក្ខុទាំងឡាយ បើសង្ឃដែលប្រកបដោយគុណដ៏ធំក្នុងកាលណា កាលនោះ តថាគតមានសេចក្តីគោរពចំពោះសង្ឃដែរ ។

# អដ្ឋកថា

# ឧរុវេលវគ្គទី ៣

## បឋមឧរុវេលសូត្រ

[ ២២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមឧរុវេលសូត្រទី ១ នៃឧរុវេលវគ្គទី ៣ ដូចតទៅ បទថា **ឧរុវេលា** ក្នុងបទថា **ឧរុវេលាយំ** នេះ បានដល់ ទីដែលមានខ្សាច់គំនរធំ អធិប្បាយថា គំនរខ្សាច់ធំ ។ ម្យ៉ាងទៀត គប្បីឃើញអត្ថក្នុងសេចក្តីនេះយ៉ាងនេះថា ខ្សាច់ ហៅថា **ឧរុ** ព្រំដែន ហៅថា **វេលា**។ ខ្សាច់ដែលពួកតាបសជញ្ជូនមក ព្រោះល្មើសនឹងកតិកាជាហេតុ ឈ្មោះថា **ឧរុវេលា** ។ បានឮថា ក្នុងអតីតកាល កាលព្រះពុទ្ធមិនទាន់កើតឡើង កុលបុត្រមួយម៉ឺននាក់បួសជាតាបសនៅក្នុងទីនោះ ថ្ងៃមួយ ប្រជុំព្រមគ្នាហើយបានតាំងកតិកាគ្នាថា ឈ្មោះថា កាយកម្ម វចីកម្ម រមែងប្រាកដដល់ជនដទៃបាន ឯមនោកម្មមិនប្រាកដ ព្រោះដូច្នោះ បុគ្គលណាត្រិះរិះដល់កាមវិតក្កព្យាបាទវិតក្ក ឬវិហិង្សាវិតក្ក បុគ្គលដទៃ ឈ្មោះថា ដាស់តឿនបុគ្គលនោះមិនមាន បុគ្គលនោះត្រូវដាស់តឿនខ្លួនដោយខ្លួនឯង ត្រូវយកស្លឹកឈើខ្ចប់ខ្សាច់ នាំមកគរក្នុងទីនេះ នេះចាត់ជាទណ្ឌកម្មរបស់បុគ្គលនោះ ។ តាំងអំពីនោះមក បុគ្គលណាត្រិះរិះនូវវិតក្កដូច្នោះ បុគ្គលនោះយកស្លឹកឈើខ្ចប់ខ្សាច់មកចាក់ក្នុងទីនោះ ទើបកើតជាគំនរខ្សាច់ធំដោយលំដាប់ក្នុងទីនោះ ដោយប្រការដូច្នេះ បន្ទាប់មក ពួកបុគ្គលដែលកើតខាងក្រោយ ទើបព័ទ្ធគំនរខ្សាច់នោះ ធ្វើឲ្យជាចេតិយដ្ឋាន លោកសំដៅដល់ចេតិយដ្ឋាននោះ ទើបពោលថា

**ឧរុវេលាតិ មហាវេលា មហាវាលិការាសីតិ អត្ថោ** ដូច្នេះ លោកសំដៅដល់សេចក្ដីនោះឯង ទើបពោលម្យ៉ាងទៀត គប្បីឃើញអត្ថក្នុងសេចក្ដីនេះយ៉ាងនេះថា ខ្សាច់ លោកហៅថា **ឧរុ** ព្រំដែន ហៅថា **វេលា** ខ្សាច់ដែលគេនាំមក ព្រោះហេតុកន្លងល្មើសកតិកាជាហេតុ ឈ្មោះ **ឧរុវេលា** ។ ដោយបទថា **នជ្ជា នេរញ្ជរាយ តីរេ** សេចក្ដីថា តថាគតអាស្រ័យឧរុ-វេលគាម នៅសម្រាកទៀបឆ្នេរស្ទឹងនេរញ្ជរា ។ បទថា **អជបាលនិគ្រោធេ** សេចក្ដីថា ពួកអ្នកចិញ្ចឹមពពែអង្គុយខ្លះ ឈរខ្លះ ក្នុងម្លប់របស់ដើមនិគ្រោធនោះ ព្រោះហេតុនោះ ទើបដើមនិគ្រោធនោះ ហៅថា អជបាលនិគ្រោធ ។ អធិប្បាយថា ខាងក្រោមដើមអជបាលនិគ្រោធនោះ ។

បទថា **បឋមាភិសម្ពុទ្ធោ** សេចក្ដីថា ជាអ្នកត្រាស់ដឹងដំបូង ។ បទថា **ឧទបាទិ** សេចក្ដីថា វិតក្កនេះកើតក្នុងសប្ដាហ៍ទី ៥ សួរថា ព្រោះហេតុអ្វី ទើបកើតឡើង ឆ្លើយថា ព្រោះជាអាចិណាបដិបត្តិ និងអាសេវនប្បច្ច័យជាតិមុនរបស់ព្រះពុទ្ធគ្រប់អង្គ ក្នុងហេតុនោះ គប្បីនាំតិត្តិរជាតកមកសម្ដែងដើម្បីប្រកាសអាសេវនៈ ការសេពក្នុងជាតិមុន បានឮថា សត្វទទា ស្វា និងដំរី កាលនៅក្នុងប្រទេសមួយ ទើបបង្ហាញដើមព្រៃ បណ្ដាពួកយើង បុគ្គលណាជាអ្នកចាស់ យើងទាំងឡាយនឹងគោរពក្នុងបុគ្គលនោះ ។ ពិចារណាថយក្រោយថា បណ្ដាពួកយើង បុគ្គលណាហ្ន៎ជាអ្នកចាស់ ។ ដឹងថា សត្វទទាជាបុគ្គលចាស់ ទើបធ្វើការឱនលំទោនចំពោះទទានោះ ជាអ្នកព្រមព្រៀងត្រេកអរដល់គ្នានិងគ្នា ក៏មានស្ថានសួគ៌ជាទីទៅខាងមុខ ។ ទេវតាដែលស្ថិត

នៅក្នុងដើមឈើ ជ្រាបហេតុនោះ ទើបពោលគាថានេះថា

**យេ វុឌ្ឍមបចាយន្តិ នរា ធម្មស្ស កោវិទា**
**ទិដ្ឋេ ធម្មេ ច បាសំសា សម្បរាយោ ច សុគ្គតិ ។**

ពួកជនណា ជាអ្នកឈ្លាសក្នុងធម៌ ប្រព្រឹត្តកោតក្រែង ចំពោះបុគ្គលដែលចម្រើនហើយ ពួកជននោះ អ្នកផង គប្បីសរសើរ ក្នុងបច្ចុប្បន្នផង សម្បរលោក គឺសុគតិ ក៏កើត ( ដល់ពួកជននោះ ) ផង ។

ព្រះតថាគតកើតក្នុងកំណើតអហេតុកតិរច្ឆានយ៉ាងនេះ គង់ពេញចិត្ត ដោយការនៅក្នុងការមានសេចក្តីគោរព ឥឡូវនេះ ហេតុអ្វី ទ្រង់មិនពេញព្រះ ហឫទ័យនោះ ។ បទថា **អគារវោ** គឺវៀរការគោរពក្នុងបុគ្គលដទៃ ។ អធិប្បាយថា មិនតាំងបុគ្គលណាក្នុងឋានៈគួរគោរព ។ បទថា **អប្បតិស្សោ** គឺវៀរការកោតក្រែង អធិប្បាយថា មិនតាំងបុគ្គលណាក្នុងឋានៈដែលជាធំ ។ ក្នុងបទថា **សមណំ វា ព្រាហ្មណំ វា** នេះ លោកបំណងយកសមណៈ និងព្រាហ្មណ៍ដែលស្ងប់បាប ដែលបន្សាត់បាបហើយប៉ុណ្ណោះ ។

បទថា **សក្កត្វា គរុំ កត្វា** សេចក្តីថា ធ្វើសក្ការៈ និងចូលទៅតាំង ការគោរព ។ ក្នុងបទថា **សទេវកេ លោកេ** ជាដើម គប្បីជ្រាបវិនិច្ឆ័យ ដូច្នេះថា **សទេវក** ប្រែថា ព្រមជាមួយទេវតាទាំងឡាយ បណ្តាមារ និង ព្រហ្មទាំងឡាយ ដែលទ្រង់កាន់យកដោយ **ទេវ** សព្ទ ក្នុងបទនេះ ឈ្មោះថា មារ អ្នកមានអំណាច រមែងប្រើអំណាចលើសត្វទាំងពួង ឈ្មោះថា មហា-

ព្រហ្ម ជាអ្នកមានអានុភាពធំ រមែងផ្សាយពន្លឺទៅក្នុងចក្រវាលមួយដោយម្រាមដៃ ១ ក្នុងចក្រវាល ២ ដោយម្រាមដៃ ២ រមែងផ្សាយពន្លឺទៅក្នុងចក្រវាលមួយម៉ឺន ដោយម្រាមដៃទាំង ១០ ទើបទ្រង់ត្រាស់ញែកថា **សមារកេ សព្រហ្មកេ** ដោយព្រះតម្រិះថា ជនទាំងឡាយកុំពោលថា បុគ្គលនោះ ជាអ្នកមានសីល សម្បូរជាងដោយសីលនេះ ។ ឈ្មោះថា សមណៈទាំងឡាយក៏ដូចគ្នា ជាពហូសូត ដោយអំណាច ១ និកាយជាដើម មានសីល ជាបណ្ឌិត ។ សូម្បីព្រាហ្មណ៍ទាំងឡាយជាពហូសូត ដោយអំណាចវិជ្ជាមើលផែនដីជាដើម ជាបណ្ឌិត ទើបត្រាស់ថា **សស្សមណ-ព្រាហ្មណិយា បជាយ** ដោយទ្រង់ព្រះតម្រិះថា ជនទាំងឡាយកុំបីពោលថា សមណៈ និងព្រាហ្មណ៍ទាំងនោះ ជាអ្នកមានសីលសម្បូរជាង ដោយសីលនេះ ។ ចំណែកបទថា **សទេវមនុស្សាយ** នេះ ទ្រង់កាន់យកដើម្បីទ្រង់សម្តែងមិនឲ្យសេសសល់ កាលទ្រង់កាន់យកហើយ ទើបត្រាស់ម្យ៉ាងទៀត ក្នុងពាក្យនេះ បីបទដំបូង ត្រាស់ដោយអំណាចលោក ពីរបទក្រោយត្រាស់ដោយអំណាចពួកសត្វ ។ បទថា **សីលសម្បន្នតរំ** សេចក្តីថា បុគ្គលសម្បូរជាង គឺក្រៃលែងជាងដោយសីល ក្នុងសេចក្តីនេះ ធម៌ ៤ មានសីលជាដើម ត្រាស់ទាំងលោកិយ ទាំងលោកុត្តរ ។

វិមុត្តិញាណទស្សនៈ និងបច្ចវេក្ខណញ្ញាណជាលោកិយតែម្យ៉ាង ។ បទថា **ធាតុរហោសិ** សេចក្តីថា សហម្បតីព្រហ្មគិតថា ព្រះសាស្តានេះ កាលទ្រង់មិនឃើញបុគ្គលដែលក្រៃលែងជាងទ្រង់ដោយសីលជាដើម តាំង

អំពីអវិចី រហូតដល់ភវគ្គព្រហ្ម ត្រង់ត្រិះរិះថា តថាគតនឹងធ្វើសក្ការៈដល់លោកុត្តរធម៌ ៩ ដែលតថាគតត្រាស់ដឹងហើយ ចូលអាស្រ័យ ព្រះមានព្រះភាគទ្រង់ត្រិះរិះដល់ហេតុ ទ្រង់ត្រិះរិះដល់ប្រយោជន៍ គុណវុឌ្ឍិពិសេសចាំអាត្មាអញនឹងទៅធ្វើឧស្សាហ៍ឲ្យកើតដល់ព្រះអង្គ ដូច្នេះ ទើបប្រាកដក្នុងទីចំពោះព្រះភក្ត្រ ។ អធិប្បាយថា បានឈរនៅចំពោះព្រះភក្ត្រ ។ ក្នុងបទថា **វិហាំសុ វិហារន្តិ ច** នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ បុគ្គលណាគប្បីពោលថា ព្រះពុទ្ធទាំងឡាយដ៏ច្រើនក្នុងបច្ចុប្បន្ន ព្រោះព្រះបាលីថា **វិហារន្តិ** ដូច្នេះ បុគ្គលនោះ គប្បីត្រូវជំទាស់ដោយបាលីនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ជាព្រះអរហន្តសម្មាសម្ពុទ្ធក្នុងកាលឥឡូវនេះ ដូច្នេះ ។ គប្បីសម្តែងការមិនមានព្រះពុទ្ធទាំងឡាយដទៃដល់បុគ្គលនោះ ដោយសូត្រទាំងឡាយជាដើមថា

**ន មេ អាចរិយោ អត្ថិ សទិសោ មេ ន វិជ្ជតិ**
**សទេវកស្មិំ លោកស្មឹ នត្ថិ មេ បដិបុគ្គលោ។**

តថាគតមិនមានអាចារ្យទេ មិនមានបុគ្គលដទៃ ស្មើនឹង
តថាគតក្នុងលោកនេះ ព្រមទាំងទេវលោក មិនមាន
បុគ្គលប្រៀបផ្ទឹមនឹងតថាគតបានឡើយ ។

បទថា **តស្មា** សេចក្តីថា ព្រោះដូច្នោះ ទើបព្រះពុទ្ធព្រះអង្គទ្រង់សម្តែងសេចក្តីគោរពព្រះសទ្ធម្ម ។ បទថា **មហត្តមភិកង្ខតា** សេចក្តីថា ប្រាថ្នានូវភាពជាធំ ។ បទថា **សរំ ពុទ្ធាន សាសនំ** សេចក្តីថា កាលមារឭកដល់

ពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។ បទថា **យតោ** ប្រែថា ក្នុងកាលណា ។ បទថា **មហត្តេន សមន្នាគតោ** សេចក្តីថា សូម្បីសង្ឃប្រកបដោយភាពជាធំ ៤ យ៉ាង គឺភាពជាធំដោយរត្តញ្ញូ គឺអ្នកដឹងរាត្រីយូរ ១ ភាពជាធំដោយភាពបរិបូណ៌ ១ ភាពជាធំដោយព្រហ្មចរិយៈ ១ ភាពជាធំដោយភាពជាកំពូលដោយលាភ ១ ។ បទថា **អថ មេ សង្ឃេបិ គារវោ** សេចក្តីថា កាលនោះតថាគតក៏កើតសេចក្តីគោរពក្នុងសង្ឃ ។ សួរថា ព្រះមានព្រះភាគទ្រង់ធ្វើសេចក្តីគោរពក្នុងសង្ឃក្នុងកាលណា ។ ឆ្លើយថា ក្នុងកាលព្រះនាងបជាបតីថ្វាយគូនៃសំពត់ ។ ពិតហើយ ក្នុងកាលនោះ ព្រះមានព្រះភាគ កាលត្រាស់ដល់គូនៃសំពត់ ដែលព្រះនាងមហាបជាបតីបង្អោនចូលទៅថ្វាយដល់ព្រះអង្គថា នៃនាងគោតមី ចូរនាងថ្វាយដល់សង្ឃចុះ កាលព្រះនាងថ្វាយក្នុងសង្ឃហើយ តថាគតផង សង្ឃផង ឈ្មោះថា នាងបូជាហើយ ឈ្មោះថា ទ្រង់ធ្វើសេចក្តីគោរពក្នុងសង្ឃ ។ល។

## អដ្ឋកថាបឋមឧរុវេលសូត្រទី ១ ចប់

# សុត្តន្តបិដក

## ទុតិយឧរុវេលសូត្រទី ២

[ ២៣ ] ម្នាលភិក្ខុទាំងឡាយ សម័យមួយ កាលតថាគតទើបនឹងបាន ត្រាស់ដឹងជាដំបូង នៅក្រោមដើមអជបាលនិគ្រោធ ក្បែរឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាឯណោះ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ពួកព្រាហ្មណ៍ ច្រើនគ្នា ចាស់គ្រាំគ្រា ព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅយូរឆ្នាំមកហើយ មានអាយុក៏ជ្រុលចូលមកក្នុងបច្ឆិមវ័យហើយ បានចូលទៅរកតថាគត លុះ ចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងតថាគត លុះបញ្ចប់ពាក្យ ដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះពួកព្រាហ្មណ៍ទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ បាននិយាយនឹងតថាគតដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន យើងខ្ញុំបានឮ យ៉ាងនេះថា ព្រះសមណគោតមមិនសំពះ មិនក្រោកទទួលពួកព្រាហ្មណ៍ ដែលចាស់គ្រាំគ្រា ព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានអាយុក៏ជ្រុលចូលមកក្នុងបច្ឆិមវ័យហើយ ទោះបីគ្រាន់តែអញ្ជើញហៅរក នូវព្រាហ្មណ៍ទាំងនោះ ឲ្យអង្គុយលើអាសនៈ ( ព្រះអង្គក៏មិនធ្វើផង ) បពិត្រព្រះគោតមដ៏ចម្រើន ពាក្យដែលយើងខ្ញុំបានឮមកនោះជាប្រាកដថា ព្រះគោតមដ៏ចម្រើន មិនសំពះ មិនក្រោកទទួលពួកព្រាហ្មណ៍ដែលចាស់ គ្រាំគ្រា ព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅយូរឆ្នាំមកហើយ មានអាយុ ក៏ជ្រុលចូលមកក្នុងបច្ឆិមវ័យហើយថា សូម្បីត្រឹមតែអញ្ជើញ ហៅរកពួក

ព្រាហ្មណ៍ទាំងនោះ ឲ្យអង្គុយលើអាសនៈ ( ព្រះអង្គក៏មិនធ្វើ ) បពិត្រព្រះគោតមដ៏ចម្រើន កិច្ចមានការមិនសំពះជាដើមនោះ ជាទំនងពុំសមគួរឡើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះដូច្នេះថា អ្នកដ៏មានអាយុទាំងឡាយនេះ មិនស្គាល់នូវបុគ្គលចាស់ផង នូវធម៌ទាំងឡាយដែលធ្វើខ្លួនឲ្យជាបុគ្គលចាស់ផង ម្នាលភិក្ខុទាំងឡាយ បើបុគ្គលចម្រើនដោយវ័យតាំងពីកើតមក មានអាយុ ៨០ ឆ្នាំក្តី ៩០ ឆ្នាំក្តី ១០០ ឆ្នាំក្តី តែបុគ្គលនោះជាអ្នកនិយាយខុសកាល និយាយពាក្យមិនពិត និយាយពាក្យឥតប្រយោជន៍ និយាយពាក្យមិនមែនធម៌ និយាយពាក្យមិនមែនវិន័យ និយាយពាក្យដែលមិនគួរ ឲ្យតម្កល់ទុកក្នុងហឫទ័យខុសកាល ប្រាសចាកគ្រឿងអាង ជាពាក្យមិនមានទីបំផុត មិនប្រកបដោយប្រយោជន៍ កាលបើដូច្នោះ បុគ្គលពាលនោះក៏ដល់នូវការរាប់ថា ជាបុគ្គលចាស់ខ្ចៅ ម្នាលភិក្ខុទាំងឡាយ បុគ្គលនៅក្មេងកំលោះ ជំទង់ មានសក់ខ្មៅ ប្រកបដោយវ័យចម្រើន គឺបឋមវ័យមែន តែបុគ្គលនោះជាអ្នកនិយាយពាក្យត្រូវកាល និយាយពាក្យពិត និយាយពាក្យជាប្រយោជន៍ និយាយពាក្យជាធម៌ និយាយពាក្យជាវិន័យ និយាយសម្តីគួរតម្កល់ទុកក្នុងហឫទ័យ ត្រូវតាមកាល មានគ្រឿងអាង មានទីបំផុត ប្រកបដោយប្រយោជន៍ កាលបើដូច្នោះ បុគ្គលនោះ ក៏រាប់ថាជាចាស់ ចេះដឹង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៤ នេះ ជាធម៌សម្រាប់ធ្វើឲ្យជាថេរៈ ( បុគ្គលចាស់ ) ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ

បរិបូណ៌ដោយអាចារៈ និងគោចរ ឃើញភ័យក្នុងទោសគ្រាន់តែបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ជាពហុស្សូត ទ្រទ្រង់សុតៈ មិនភ្លេច សន្សំទុកនូវសុតៈ ពួកធម៌ណាមានលម្អបទខាងដើម លម្អបទកណ្ដាល លម្អបទចុង ប្រកាសនូវព្រហ្មចារ្យដ៏បរិសុទ្ធបរិបូណ៌ទាំងអស់ ប្រកបដោយអត្ថ ព្រមទាំងព្យញ្ជនៈ ធម៌ទាំងឡាយមានសភាពដូច្នោះ ភិក្ខុនោះចេះចាំច្រើន ទ្រទ្រង់រត់មាត់ ពិចារណាបានតាមចិត្ត ដឹងដោយប្រពៃដោយទិដ្ឋិគឺបញ្ញា ១ ជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយមិនខុសវេលា នូវឈានទាំង ៤ ដែលកើតក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ១ ជាអ្នកធ្វើឲ្យជាក់ច្បាស់ បានដល់ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ បញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៤ នេះ ជាធម៌ធ្វើឲ្យបានឋានៈជាថេរៈ ។

អ្នកណាមានចិត្តអណ្ដែតអណ្ដូង ច្រើនតែនិយាយពាក្យឥតប្រយោជន៍ មានគំនិតមិនតម្កល់ស៊ប់សួន មិនត្រេកអរនឹងព្រះសទ្ធម្ម ប្រហែលគ្នានឹងសត្វម្រឹគ អ្នកដែលមានទិដ្ឋិដ៏លាមក មិនមានសេចក្ដីអើពើនោះ ( តែងតែ ) ឆ្ងាយចាកសភាវៈមាំទាំ ។ បើអ្នកណាបរិបូណ៌ដោយសីល មានសុតៈ មានសេចក្ដីឆ្លៀវឆ្លាស ប្រកបក្នុងធម៌ទាំងឡាយ ដែលធ្វើឲ្យជាថេរៈ ឃើញច្បាស់នូវសេចក្ដីនៃសច្ចៈទាំង ៤ ដោយ

មគ្គបញ្ញា ព្រមទាំងវិបស្សនា ជាអ្នកច្នៃផុតនូវធម៌ទាំងអស់ ( មានខន្ធជាដើម ) បានមានចិត្តមិនជាប់ជំពាក់ ( មានការមិនជាប់ជំពាក់ព្រោះរាគៈជាដើម ) បរិបូណ៌ដោយសេចក្តីជ្រះថ្លា ។ អ្នកណាលះបង់ជាតិ និងមរណៈបានហើយ មានព្រហ្មចារ្យគ្រប់គ្រាន់ តថាគតហៅអ្នកនោះថា ជាថេរៈ ភិក្ខុណាមិនមានអាសវៈទាំងឡាយ ព្រោះអស់អាសវៈទាំង-ឡាយ តថាគតហៅភិក្ខុនោះថា ជាថេរៈ ។

# អដ្ឋកថា

## ទុតិយឧរុវេលសូត្រ

[ ២៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយឧរុវេលសូត្រទី ២ ដូចតទៅនេះ បទថា **សម្ពហុលា** គឺព្រាហ្មណ៍ដ៏ច្រើន ។ បទថា **ព្រាហ្មណា** សេចក្តីថា ពួកព្រាហ្មណ៍មកហើយ ព្រមគ្នានឹងព្រាហ្មណ៍ដែលជាអ្នកពោលពាក្យគ្រោតគ្រាត ។ បទថា **ជិណ្ណា វុឌ្ឍា** បានដល់ ជាអ្នកគ្រាំគ្រាដោយជរា ចម្រើនដោយវ័យ ។ បទថា **មហល្លកា** បានដល់ ចាស់ដោយជាតិ ។ បទថា **អទ្ធគតា** បានដល់ កន្លងកាល កន្លងវ័យទាំង ៣ ទៅហើយ ។ បទថា **សុតំ មេតំ** បានដល់ សេចក្តីនេះ ពួកយើងស្តាប់មកហើយ ។ បទថា **តយិទំ**

**ភោ គោតម តថេវ** សេចក្ដីថា បពិត្រព្រះគោតម សេចក្ដីនេះ ពួកខ្ញុំព្រះអង្គស្ដាប់មកហើយ ការណ៍ក៏ពិតយ៉ាងនោះ ។ បទថា **តយិទំ ភោ គោតម ន សម្បន្នមេវ** សេចក្ដីថា ការមិនធ្វើអភិវាទជាដើមនេះមិនសមគួរឡើយ ។

ក្នុងបទជាដើមថា **អកាលវាទី** មានវិនិច្ឆ័យដូច្នេះ ឈ្មោះថា **អកាលវាទី** ព្រោះពោលមិនស្គាល់កាល ។ ឈ្មោះថា **អភូតវាទី** ព្រោះនិយាយតែរឿងដែលមិនពិត ។ ឈ្មោះថា **អនត្ថវាទី** ព្រោះពោលតែរឿងដែលមិនជាប្រយោជន៍ មិនពោលរឿងដែលជាប្រយោជន៍ ។ ឈ្មោះថា **អធម្មវាទី** ព្រោះពោលមិនជាធម៌ មិនពោលជាធម៌ ។ ឈ្មោះថា **អវិនយវាទី** ព្រោះពោលមិនជាវិន័យ មិនពោលជាវិន័យ ។ បទថា **អនិធានវតី វាចំ ភាសិតា** បានដល់ មិនពោលវាចាដែលគួរចាំទុកក្នុងហទយៈ ។ បទថា **អកាលេន** បានដល់ ដោយកាលមិនគួរពោល ។ បទថា **អនបទេសំ** បានដល់ ពោលមិនមានគោលអាង គឺមិនមានហេតុផល ។ បទថា **អបរិយន្តវតី** បានដល់ និយាយមិនចេះចប់ ពោលមិនមានកំណត់ ។ បទថា **អនត្ថសញ្ហិតំ** បានដល់ មិនសម្ដែងឲ្យអាស្រ័យប្រយោជន៍ដែលជាលោកិយ និងលោកុត្តរ ។ បទថា **ពាលោ ថេរោត្វេវ សង្ខំ គច្ឆតិ** សេចក្ដីថា រាប់បានថាជាថេរៈអន្ធពាល គឺបុគ្គលល្ងង់ខ្លៅ ខ្វាក់ងងឹត ។ បទជាដើមថា **កាលវាទី** គប្បីជ្រាបដោយអំណាចនៃធម៌ ដែលផ្ទុយគ្នាដែលពោលមកហើយ ។

បទថា **បណ្ឌិតោ ថេរោត្វេវ សង្ខំ គច្ឆតិ** សេចក្ដីថា ឈ្មោះថា បណ្ឌិត ព្រោះប្រកបដោយការឈ្លាស ឈ្មោះថា ថេរៈ ព្រោះដល់នូវភាពជា

អ្នកមាំទាំ ។ បទថា **ពហុស្សុតោ ហោតិ** សេចក្តីថា ភិក្ខុនោះមានសុតៈច្រើន អធិប្បាយថា នវង្គសត្ថុសាសនៈដែលភិក្ខុនោះរៀនហើយ ដោយអំណាចខាងដើម និងខាងចុងនៃបាលី និងអនុសន្ធិ ។ បទថា **សុតធរោ** បានដល់ ជាអ្នកទ្រទ្រង់នូវសុតៈបាន ។ ពិតហើយ ព្រះពុទ្ធវចនៈដែលភិក្ខុណារៀនតែបាលីបទេសនេះ សាបសូន្យទៅចាកបាលីបទេសនេះ មិនគង់នៅដូចទឹកក្នុងឆ្នាំងធ្លុះ លោកមិនអាចពោល ឬប្រាប់សូត្រ ឬជាតកណាមួយក្នុងកណ្តាលបរិស័ទបាន ភិក្ខុនេះ ឈ្មោះថា ទ្រទ្រង់នូវសុតៈក៏មិនមែន ។ ឯព្រះពុទ្ធវចនៈដែលភិក្ខុបានរៀនហើយ រមែងដូចជាពេលដែលខ្លួនរៀនមកហើយនោះឯង កាលលោកមិនធ្វើការស្វាធ្យាយអស់ ១០ ឆ្នាំក្តី ២០ ឆ្នាំក្តី ក៏មិនភ្លេចភ្លាំង ភិក្ខុនេះ ឈ្មោះថា ជាអ្នកទ្រទ្រង់នូវសុតៈ ។ បទថា **សុតសន្និចយោ** បានដល់ ជាអ្នកសន្សំសុតៈ ។ សុតៈដែលភិក្ខុណាសន្សំទុកក្នុងប្រអប់ គឺហទយៈ រមែងតាំងនៅដូចគំនូសចារឹកត្រង់ថ្ម និងដូចខ្លាញ់រាជសីហ៍ដែលគេដាក់ក្នុងភាជន៍មាស ភិក្ខុនេះឈ្មោះថា សន្សំសុតៈ ។ បទថា **ធតា** គឺទ្រទ្រង់ចាំបានស្ទាត់ជំនាញ ។ ពិតហើយ ព្រះពុទ្ធវចនៈដែលភិក្ខុរូបខ្លះរៀនហើយ មិនទ្រទ្រង់ចាំឲ្យស្ទាត់ជំនាញ មិនធ្វូន់ក្នុងចិត្ត កាលអ្នកដទៃពោលថា សូមលោកម្ចាស់ពោលសូត្រនោះ ជាតកនោះ ដូច្នេះ លោកក៏ពោលថា អាត្មានឹងស្វាធ្យាយសាកល្បងពិចារណាសិន សឹមដឹងព្រះពុទ្ធវចនៈដែលភិក្ខុរូបខ្លះទ្រទ្រង់ស្ទាត់ជំនាញហើយ ប្រៀបដូចភវង្គសោត កាលបុគ្គលត្រូវពោលថា សូមលោកម្ចាស់ពោលសូត្រ ឬជាតកនោះ ដូច្នេះ លោកនឹងលើក

ឡើងពោលសូត្រ ឬជាតកនោះបានភ្លាម ។ ទ្រង់ត្រាស់ថា **ធតា** ព្រោះសំដៅដល់សេចក្តីនោះ ។ បទថា **វចសា បរិចិតា** បានដល់ ស្វាធ្យាយដោយវាចាបាននូវសូត្រ ១០ វគ្គ ១០ បណ្ណាសក ១០ ។ បទថា **មនសានុបេក្ខិតា** បានដល់ សម្លឹងដោយចិត្ត ។ ព្រះពុទ្ធវចនៈដែលភិក្ខុណាស្វាធ្យាយហើយដោយវាចា ប្រាកដច្បាស់ក្នុងទីនោះៗ ដល់បុគ្គលដែលជាប់ដោយចិត្ត ដូចរូបប្រាកដច្បាស់ដល់បុគ្គលដែលឈរអុជប្រទីបធំ ដូច្នោះ ។ ទ្រង់សំដៅយកព្រះពុទ្ធវចនៈនៃភិក្ខុ ទើបត្រាស់ពាក្យនេះ ។ បទថា **ទិដ្ឋិយា សុប្បដិវិទ្ធា** បានដល់ ប្រើក្នុងបញ្ញាដែលបែកធ្លុះធ្លាយ ទាំងហេតុ ទាំងផល ។

បទថា **អភិចេតសិកានំ** សេចក្តីថា ចិត្តដែលបរិសុទ្ធ គួរប្រាថ្នា ឬអធិចិត្ត លោកហៅថា **អភិចេត** ឈាន ៤ កើតក្នុងអភិចិត្ត ឈ្មោះថា **អភិចេតសិក**ម្យ៉ាងទៀត ឈាន ៤ អាស្រ័យអភិចេត ហេតុនោះ ទើបឈ្មោះថា **អភិចេតសិក** ។ បទថា **ទិដ្ឋធម្មសុខវិហារានំ** បានដល់ ដែលជាធម៌គ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ។ អត្តភាពដែលប្រចក្ស លោកហៅថា ទិដ្ឋធម៌ ។ អធិប្បាយថា ជាគ្រឿងនៅជាសុខក្នុងទិដ្ឋធម៌នោះ ពាក្យនេះជាឈ្មោះរបស់រូបាវចរជ្ឈានទាំងឡាយ ។ ពិតហើយ បុគ្គលបានឈាន អង្គុយចូលឈានទាំងនោះ រមែងបាននេក្ខម្មសុខដែលមិនសៅហ្មង ក្នុងអត្តភាពនេះឯង ។ ព្រោះដូច្នោះ ទើបត្រាស់ថា **ទិដ្ឋធម្មសុខវិហារានំ** ដូច្នេះ ។ បទថា **និកាមលាភី** បានដល់ បានតាមត្រូវការ បានតាមអំណាចការប្រាថ្នារបស់ខ្លួន លោកអធិប្បាយថា អាចចូលឈានបានក្នុងខណៈដែលប្រាថ្នាហើយ ។

បទថា **អកិច្ឆលាភី** លោកអធិប្បាយថា អាចសង្កត់ធម៌ដែលជាសត្រូវ ហើយចូលឈានបានដោយស្រួល ។ បទថា **អកសិរលាភី** បានដល់ បាននូវការមិនលំបាក គឺស្ទាត់ជំនាញ លោកអធិប្បាយថា អាចចេញអំពីឈានបានតាមកំណត់ ។ ពិតហើយ បុគ្គលខ្លះបានឈានប៉ុណ្ណោះ មិនអាចចូលបានក្នុងខណៈដែលប្រាថ្នា ។ បុគ្គលខ្លះអាចចូលយ៉ាងនោះបាន តែក៏សង្កត់សង្កិនធម៌ដែលធ្វើអន្តរាយបានដោយលំបាក ។ បុគ្គលខ្លះអាចចូលបានយ៉ាងនោះផង សង្កត់ធម៌ដែលធ្វើអន្តរាយបានផង ដោយមិនលំបាកឡើយ តែក៏មិនអាចចេញអំពីឈានបានតាមកំណត់ ដូចនាឡិកាយន្ត ។ សម្បទា ៣ យ៉ាងនេះ មានដល់បុគ្គលណា បុគ្គលនោះលោកហៅថា **អកសិរលាភី** ដូច្នេះ ។

បទជាដើមថា **អាសវានំ ខយា** មានអត្ថដូចពោលមកហើយនោះឯង ។ ក្នុងទីនេះ សូម្បីសីលក៏ត្រាស់ដល់សីលរបស់ព្រះខីណាស្រពប៉ុណ្ណោះ សូម្បីពាហុសច្ចៈ ក៏ត្រាស់ពាហុសច្ចៈរបស់ព្រះខីណាស្រពប៉ុណ្ណោះ សូម្បីឈាន ក៏ត្រាស់ឈានដែលប្រើសម្រាប់ព្រះខីណាស្រពប៉ុណ្ណោះ ។ ចំណែកអរហត្ត ត្រាស់ដោយបទជាដើមថា **អាសវានំ ខយា** ដូច្នេះ ។ តែកិច្ចរបស់មគ្គក្នុងទីនេះ គប្បីជ្រាបថា ទ្រង់ប្រកាសដោយផល ។

បទថា **ឧទ្ធតេន** បានដល់ ប្រកបដោយឧទ្ធច្ចៈ ។ បទថា **សម្ផញ្ញ** បានដល់ ពាក្យរោយរាយ ។ បទថា **អសមាហិតសង្កប្បោ** បានដល់ មានការត្រិះរិះមិនតាំងមាំ ។ បទថា **មគោ** បានដល់ ដូចម្រឹគ ។ បទថា **អារា** ប្រែថា ក្នុងទីឆ្ងាយ ។ បទថា **ថាវរេយ្យម្ហា** បានដល់ ចាកការមាំទាំ ។

បទថា **បាបទិដ្ឋិ** បានដល់ ការយល់ឃើញអាក្រក់ ។ បទថា **អនាទរោ** បានដល់ វៀរចាកការអើពើ ។ បទថា **សុតវា** បានដល់ ចូលដល់ដោយសូត្រ ។ បទថា **បដិភាណវា** សេចក្តីថា បុគ្គលប្រកបដោយបដិភាណ ២ យ៉ាង ។ បទថា **បញ្ញាយត្ថំ វិបស្សតិ** សេចក្តីថា រមែងឃើញទូលំទូលាយនូវអត្ថសច្ចៈ ៤ ដោយមគ្គប្បញ្ញា មួយអន្លើដោយវិបស្សនា ។ បទថា **បារគូ សព្វធម្មានំ** សេចក្តីថា ដល់នូវត្រើយនៃធម៌ មានខន្ធជាដើម ជាអ្នកដល់នូវត្រើយ គឺទីបំផុតនៃធម៌ទាំងពួង ដោយការដល់ត្រើយ ៦ យ៉ាង គឺត្រើយនៃអភិញ្ញា ១ ត្រើយនៃបរិញ្ញា ១ ត្រើយនៃភាវនា ១ ត្រើយនៃបហាន ១ ត្រើយនៃសច្ឆិកិរិយា ១ ត្រើយនៃសមាបត្តិ ១ ។ បទថា **អខិលោ** បានដល់ វៀរចាកបង្គោល មានរាគៈជាដើម ។ បទថា **បដិភាណវា** បានដល់ប្រកបដោយបដិភាណ ២ យ៉ាង ។ បទថា **ព្រហ្មចរិយស្ស កេវលី** បានដល់ នៅចប់ព្រហ្មចរិយៈ ។ ពាក្យដ៏សេស ក្នុងសូត្រនេះ ងាយយល់ទាំងអស់ហើយ ៕

## អដ្ឋកថា ទុតិយឧរុវេលសូត្រទី ២ ចប់

# សុត្តន្តបិដក

## លោកសូត្រទី ៣

[ ២៤ ] ម្នាលភិក្ខុទាំងឡាយ លោក ( គឺទុក្ខសច្ច ) តថាគតបានត្រាស់ដឹងហើយ តថាគតផុតចាកលោក ( គឺទុក្ខសច្ច ) ហើយ ម្នាលភិក្ខុទាំងឡាយ លោកសមុទយៈ តថាគតបានត្រាស់ដឹងហើយ លោកសមុទយៈ តថាគតបានលះបង់ហើយ ម្នាលភិក្ខុទាំងឡាយ លោកនិរោធ តថាគតបានត្រាស់ដឹងហើយ លោកនិរោធតថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ ម្នាលភិក្ខុទាំងឡាយ លោកនិរោធគាមិនីបដិបទា តថាគតបានត្រាស់ដឹងហើយ លោកនិរោធគាមិនីបដិបទា តថាគតបានចម្រើនហើយ ។ ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណា ដែលលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ដែលពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសឃើញ ឮ ពាល់ត្រូវ ដឹងច្បាស់ បានដល់ ស្វែងរក ត្រាច់រង្គាត់រកអារម្មណ៍នោះ តថាគតបានដឹងជាក់ស្តែងហើយ ដោយសារចិត្ត ព្រោះហេតុនោះ បានជាគេហៅថា តថាគត ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានត្រាស់ក្នុងរាត្រីណា បរិនិព្វានក្នុងរាត្រីណា តែងពោលចរចា សម្តែងចេញនូវវាចាណាក្នុងចន្លោះនោះ កិច្ចមានការត្រាស់ដឹងជាដើមទាំងនោះ ដូច្នោះមែន មិនមែនជាមិនមែនទេ ព្រោះហេតុនោះ បានជាគេហៅថា តថាគត ។ ម្នាលភិក្ខុទាំងឡាយ តថាគតថាយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ថាយ៉ាងនេះ ថាយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ថាយ៉ាងនោះ ហេតុនោះ

ទើបបានជាគេហៅថា តថាគត ។ ម្នាលភិក្ខុទាំងឡាយ តថាគតជាអ្នកគ្របសង្កត់ អង់អាច ជាអ្នកឃើញពិត មានអំណាចគ្របសង្កត់លោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណ-ព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសបាន ហេតុនោះ បានជាគេហៅថា តថាគត ។

បុគ្គលណាដឹងច្បាស់នូវលោកទាំងអស់ ដឹងច្បាស់ក្នុងលោកទាំងអស់តាមពិត ផុតចាកលោកទាំងអស់ មិនមានការកពូនក្នុងលោកទាំងអស់ បុគ្គលនោះឯងជាអ្នកប្រាជ្ញ គ្របសង្កត់នូវអារម្មណ៍ទាំងអស់បាន ជាអ្នករួចចាកគន្ថៈទាំងអស់ ព្រះនិព្វានបុគ្គលនោះពាល់ត្រូវហើយ ព្រះនិព្វានមិនមានភ័យមកពីណាទេ បុគ្គលនោះជាខីណាសវៈ បានត្រាស់ដឹងហើយ ជាអ្នកមិនមានទុក្ខ អ្នកផ្ដាច់នូវសេចក្ដីសង្ស័យហើយ ដល់នូវការអស់ទៅនៃកម្មទាំងអស់ រួចស្រឡះ ( ដោយផលវិមុត្តិដែលមានអា-រម្មណ៍ ) ក្នុងធម៌ជាគ្រឿងអស់ទៅនៃឧបធិក្កិលេស បុគ្គលនោះ ជាភគវន្ត អ្នកត្រាស់ដឹង បុគ្គលនេះ ជាសីហៈ មិនមានបុគ្គលដទៃស្មើ ញ៉ាំងចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅក្នុងលោកព្រមទាំងទេវលោក ដោយប្រការដូច្នេះឯង ។ ពួកទេវតា និងពួកមនុស្ស ដែលបានដល់ព្រះពុទ្ធជាទីរឭក តែងនាំគ្នាមកនមស្ការព្រះតថាគតនោះ អ្នកមានគុណធំ ប្រាសចាកសេចក្ដី

ញាញើតញាញើម ។ តថាគតមានខ្លួនទូន្មានល្អហើយ ប្រសើរជាងពួកបុគ្គលអ្នកទូន្មានខ្លួន ពុទ្ធឥសីដែលមានចិត្តស្ងប់រម្ងាប់ហើយ ប្រសើរជាងពួកបុគ្គលអ្នកទូន្មានខ្លួន តថាគតមានចិត្តផុតស្រឡះហើយ ខ្ពង់ខ្ពស់ជាងពួកបុគ្គលអ្នកមានចិត្តផុតស្រឡះហើយ តថាគតឆ្លងផុតហើយ ប្រសើរជាងពួកបុគ្គលអ្នកឆ្លង ពួកទេវតា និងមនុស្សតែងនាំគ្នាមកនមស្ការ តថាគតនោះមានគុណដ៏ធំ ប្រាសចាកសេចក្តីញាញើតញាញើម ដោយប្រការដូច្នេះ ។ ក្នុងលោកនេះ ព្រមទាំងទេវលោក មិនមានបុគ្គលប្រៀបនឹងតថាគតបានទេ ។

# អដ្ឋកថា

## លោកសូត្រ

[ ២៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងលោកសូត្រទី ៣ ដូចតទៅនេះ បទថា **លោកោ** បានដល់ ទុក្ខសច្ច ។ បទថា **អភិសម្ពុទ្ធោ** បានដល់ ធ្វើឲ្យប្រចក្សហើយដោយញាណ ។ បទថា **លោកស្មា** បានដល់ ចាកទុក្ខសច្ច ។ បទថា **បហីនោ** បានដល់ លះបានហើយ ដោយអរហត្តមគ្គញាណ ត្រង់មហាពោធិមណ្ឌល ។ បទថា **តថាគតស្ស ភាវិតា** ប្រែថា ដែលតថាគត

ធ្វើឲ្យមានហើយ ។

ព្រះមានព្រះភាគ កាលត្រាស់កាពដែលទ្រង់ជាពុទ្ធៈ ដោយសច្ចៈ ៤ ដោយឋានៈមានប្រមាណប៉ុណ្ណោះយ៉ាងនេះហើយ ឥឡូវនេះ ទើបត្រាស់ពាក្យជាដើមថា **យំ ភិក្ខវេ** ដើម្បីត្រាស់កាពដែលទ្រង់ជាតថាគត ។ ក្នុងបទទាំងនោះ បទថា **ទិដ្ឋំ** បានដល់ រូបាយតនៈ ។ បទថា **សុតំ** បានដល់ សទ្ទាយតនៈ ។ បទថា **មុតំ** បានដល់ អាយតនៈ គឺក្លិន រស ផោដ្ឋព្វៈ ព្រោះជាអារម្មណ៍ដែលមកដល់ហើយ ទទួលទុក ។ បទថា **វិញ្ញាតំ** បានដល់ ធម្មារម្មណ៍ មានសុខ និងទុក្ខជាដើម ។ បទថា **បត្តំ** បានដល់ ស្វែងរក ឬមិនស្វែងរក ក៏មកដល់ហើយ ។ បទថា **បរិយេសិតំ** សេចក្ដីថា មកដល់ ឬមិនមកដល់ ក៏ស្វែងរកហើយ ។ បទថា **អនុវិចរិតំ មនសា** បានដល់ គិតគ្នេរដោយចិត្ត ។ ដោយបទថា **តថាគតេន អភិសម្ពុទ្ធំ** នេះ ទ្រង់សម្ដែងសេចក្ដីនេះថា រូបារម្មណ៍ជាដើម មានពណ៌ខៀវ ពណ៌លឿងឯណាប្រាកដក្នុងចក្ខុទ្វាររបស់លោក ព្រមទាំងទេវលោកនេះ ក្នុងលោកធាតុដែលមិនមានប្រមាណ តថាគតត្រាស់ដឹងរូបារម្មណ៍ទាំងឡាយនោះ យ៉ាងនេះថា សត្វនេះឃើញរូបារម្មណ៍នេះ ក្នុងខណៈនេះហើយ កើតចិត្តត្រេកអរខ្លះ ទោមនស្សខ្លះ ជាកណ្ដាលខ្លះ ដូច្នេះ ។ ម្យ៉ាងទៀត សទ្ទារម្មណ៍ជាដើម មានសំឡេងស្គរ ប្រាកដក្នុងសោតទ្វាររបស់លោក ព្រមទាំងទេវលោកនេះ ក្នុងលោកធាតុដែលមិនមានប្រមាណក៏ដូចគ្នា គន្ធារម្មណ៍ជាដើម មានក្លិនឫស ក្លិនសម្បក ប្រាកដក្នុងឃានទ្វារ រសារម្មណ៍ជាដើម មានរសឫស

រសជាដើម ប្រាកដក្នុងជិវ្ហាទ្វារ ផោដ្ឋព្វារម្មណ៍ មានធាតុដី ធាតុភ្លើង ធាតុខ្យល់ជាដើមថា រឹង ទន់ ប្រាកដក្នុងកាយទ្វារ តថាគតត្រាស់ដឹងនូវផោដ្ឋព្វារម្មណ៍ទាំងអស់នោះ យ៉ាងនេះថា សត្វនេះពាល់ត្រូវផោដ្ឋព្វារម្មណ៍នេះ ក្នុងខណៈនេះហើយ កើតចិត្តត្រេកអរខ្លះ ទោមនស្សខ្លះ ជាកណ្តាលខ្លះ ដូច្នេះ ។ ម្យ៉ាងទៀត ធម្មារម្មណ៍ មានសុខ និងទុក្ខជាដើម ប្រាកដក្នុងមនោទ្វាររបស់សត្វលោក ព្រមទាំងទេវលោក ក្នុងលោកធាតុ ដែលមិនមានប្រមាណ តថាគតត្រាស់ដឹងធម្មារម្មណ៍ទាំងអស់នោះ យ៉ាងនេះថា សត្វនេះដឹងធម្មារម្មណ៍នេះ ក្នុងខណៈនេះហើយ កើតចិត្តត្រេកអរខ្លះ ទោមនស្សខ្លះ ជាកណ្តាលខ្លះ ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ឯណា ដែលសត្វទាំងនេះឃើញហើយ បានឮហើយ ជ្រាបហើយ រឭកហើយ ក្នុងអារម្មណ៍នោះ តថាគតមិនឃើញ មិនបានឮ មិនជ្រាប និងមិនដឹង មិនមាន ឯអារម្មណ៍ដែលមហាជននេះស្វែងរកហើយ តែមិនដល់ក៏មាន មិនស្វែងរកហើយ មិនដល់ក៏មាន ស្វែងរកហើយដល់ក៏មាន មិនស្វែងរកហើយ តែដល់ក៏មាន អារម្មណ៍ទាំងអស់ ឈ្មោះថា មិនដល់ដល់តថាគត តថាគតមិនធ្វើឲ្យជាក់ច្បាស់ដោយញាណ មិនមាន ។ បទថា **តស្មា តថាគតោតិ វុច្ចតិ** សេចក្តីថា ហៅថា តថាគត ព្រោះលោកទៅយ៉ាងណា តថាគតក៏ទៅយ៉ាងនោះឯង ។

ឯក្នុងបាលី លោកពោលថា **អភិសម្ពុទ្ធំ** បទនោះ ក៏មានអត្ថតែម្យ៉ាងនឹង **តថាគត** សព្ទនោះឯង ។ គប្បីជ្រាបអត្ថនៃពាក្យនិគមចុងក្រោយថា

**តថាគតោ** ក្នុងវារៈទាំងអស់ដោយន័យនេះ ។ យុត្តិ គឺការពាល់ត្រូវនៃ **តថាគត** សព្ទនោះ ពោលដោយពិស្តារនៃ **តថាគត** សព្ទ ក្នុងអដ្ឋកថាដែលពោលដោយឯកបុគ្គល ។ម្យ៉ាងទៀត ក្នុងសេចក្តីនេះ សព្ទថា **អញ្ញ-ទត្ថុ** ជានិបាត ចុះក្នុងអត្ថថា ចំណែកមួយ ។ ឈ្មោះថា **ទស** ព្រោះឃើញ ។ ឈ្មោះថា **វសវត្តិ** ព្រោះប្រើអំណាច ។

បទថា **សព្វលោកំ អភិញ្ញាយ** សេចក្តីថា ដឹងនូវលោកសន្និវាសដែលជាត្រៃធាតុ គឺធាតុ ៣ ។ បទថា **សព្វលោកេ យថាតថំ** សេចក្តីថា វត្ថុណាមួយ គប្បីដឹងបានក្នុងលោកសន្និវាសដែលជាធាតុ ៣ នោះ ទ្រង់ដឹងវត្ថុនោះតាមពិត មិនវិបរិត ។ បទថា **វិសំយុត្តោ** សេចក្តីថា ប្រាសចាកយោគៈ ព្រោះទ្រង់លះយោគៈ ៤ បាន ។ បទថា **អនុស្សយោ** សេចក្តីថា វៀរបង់នូវតណ្ហា ទិដ្ឋិ និងឧស្សយោ គឺសេចក្តីប្រណែន ។ បទថា **សព្វាភិភូ** សេចក្តីថា ជាអ្នកគ្របសង្កត់អារម្មណ៍ទាំងពួង មានរូបជាដើមបានហើយ ។ បទថា **ធីរោ** គឺដែលដល់ព្រមដោយធិតប្បញ្ញា ។ បទថា **សព្វគន្ថប្ប-មោចនោ** សេចក្តីថា ដោះនូវកិលេស ដែលជាគ្រឿងចង ៤ យ៉ាងបាន ។ បទថា **ផុដ្ឋស្ស** កាត់បទជា **ផុដ្ឋា អស្ស** ។ បទនេះជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃតតិយាវិភត្តិ ។ បទថា **បរមា សន្តិ** បានដល់ និព្វាន ។ ពិតហើយ និព្វាននោះ ធីរជនពាល់ត្រូវដោយការពាល់ត្រូវដោយញាណនោះ ដោយហេតុនោះ ទើបលោកពោលថា **និព្វានំ អកុតោ ភយំ** ដូច្នេះ ។ ម្យ៉ាងទៀត បទថា **បរមាសន្តិ** បានដល់ ឧត្តមសន្តិ ។ សួរថា សន្តិដ៏ឧត្តមនោះ

គឺអ្វី ។ ឆ្លើយថា បរមសន្តិនោះឯង គឺនិព្វាន ។ ពិតហើយ ព្រោះហេតុក្នុងនិព្វាន មិនមានភ័យអំពីណា ដូច្នោះ ទើបនិព្វាននោះលោកហៅថា មិនមានភ័យអំពីទីណាឡើយ ។ បទថា **វិមុត្តោ ឧបធិសង្ខយេ** សេចក្តីថា រួចផុតហើយ ព្រោះនិព្វាន ពោលគឺ ធម៌ដែលជាទីបំផុតឧបធិ ដោយផលវិមុត្តិដែលមាននិព្វាននោះជាអារម្មណ៍ ។ បទថា **សីហោ អនុត្តរោ** សេចក្តីថា តថាគត ឈ្មោះថា សីហៈ គឺបុគ្គលកំពូល ព្រោះអត្ថថា អត់សង្កត់នូវអន្តរាយទាំងឡាយ និងព្រោះអត្ថថា កម្ចាត់កិលេសទាំងឡាយ ។ បទថា **ព្រហ្មំ** ប្រែថា ប្រសើរ ។ បទថា **ឥតិ** សេចក្តីថា ដឹងគុណរបស់តថាគតយ៉ាងនេះ ។ បទថា **សង្គម្ម** បានដល់ មកប្រជុំគ្នាហើយ ។ បទថា **តំ** គឺព្រះតថាគត ។ បទថា **នមស្សន្តិ** សេចក្តីថា ទេវតា និងមនុស្សទាំងនោះដល់នូវព្រះតថាគតនោះជាសរណៈ ហើយនមស្ការ ។ ឥឡូវនេះ ដើម្បីទ្រង់សម្តែងដល់បុគ្គលដែលទេវតា និងមនុស្សនមស្ការពោលដល់ ទើបត្រាស់ពាក្យជាដើមថា **ទន្តោ** ដូច្នេះ ។ ពាក្យនោះ មានអត្ថងាយយល់ទាំងអស់ហើយ ។៚

## អដ្ឋកថាលោកសូត្រទី ៣ ចប់

# សុត្តន្តបិដក

## កាឡកសូត្រទី ៤

[ ២៤ ] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកាឡការាម ជិតក្រុងសាកេត ។ ក្នុងទីនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណា ដែលលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក និងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ និងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស បានឃើញ ឮ ពាល់ត្រូវ ដឹងច្បាស់ បានដល់ ស្វែងរក ពិចារណារឿយៗ ដោយចិត្ត តថាគតដឹងច្បាស់នូវអារម្មណ៍នោះ ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណា ដែលលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក និងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ និងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស បានឃើញ ឮ ពាល់ត្រូវ ដឹងច្បាស់ បានដល់ ស្វែងរក ពិចារណារឿយៗ ដោយចិត្ត តថាគតដឹងច្បាស់នូវអារម្មណ៍នោះ ឯអារម្មណ៍នោះ តថាគតដឹងប្រាកដហើយ អារម្មណ៍នោះមិនស្ថិតនៅក្នុងតថាគតទេ ។ ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណា ដែលលោក ព្រមទាំងទេវលោក ... បានឃើញ ឮ ពាល់ត្រូវ ដឹងច្បាស់ បានដល់ ស្វែងរក ពិចារណារឿយៗ ដោយចិត្ត ប្រសិនបើតថាគតពោលថា អាត្មាអញដឹងនូវអារម្មណ៍នោះ ពាក្យនោះ គប្បីជាពាក្យកុហករបស់តថាគត ...

ប្រសិនបើតថាគតពោលថា អាត្មាអញដឹងខ្លះ មិនដឹងខ្លះនូវ អារម្មណ៍នោះ ពាក្យនោះ គប្បីជាពាក្យកុហកដែរ ... ប្រសិនបើតថាគតពោលថា អាត្មាអញមិនមែនដឹង មិនមែនជាមិនដឹងនូវអារម្មណ៍នោះ ពាក្យនោះ គប្បីជាទោសរបស់តថាគត ម្នាលភិក្ខុទាំងឡាយ តថាគតមិនសម្គាល់នូវអារម្មណ៍ដែលមហាជនឃើញហើយថា គួរឃើញ ព្រោះបានឃើញ មិនសម្គាល់នូវអារម្មណ៍ដែលមហាជនមិនឃើញ មិនសម្គាល់នូវអារម្មណ៍ដែលមហាជនគប្បីឃើញ មិនសម្គាល់នូវបុគ្គលអ្នកឃើញ មិនសម្គាល់នូវសំឡេងដែលមហាជនឮហើយ ថាគួរឮ ព្រោះបានឮ មិនសម្គាល់នូវសំឡេងដែលមហាជនមិនបានឮហើយ មិនសម្គាល់នូវសំឡេងដែលមហាជនត្រូវឮ មិនសម្គាល់នូវបុគ្គលអ្នកឮសំឡេង មិនសម្គាល់នូវអារម្មណ៍ដែលមហាជនពាល់ត្រូវហើយ ថាគួរពាល់ត្រូវ ព្រោះបានពាល់ត្រូវ មិនសម្គាល់នូវអារម្មណ៍ដែលមហាជនមិនពាល់ត្រូវហើយ មិនសម្គាល់នូវអារម្មណ៍ដែលមហាជនគប្បីពាល់ត្រូវ មិនសម្គាល់នូវបុគ្គលអ្នកពាល់ត្រូវ មិនសម្គាល់នូវអារម្មណ៍ដែលមហាជនដឹងច្បាស់ហើយ ថាគួរដឹងច្បាស់ ព្រោះបានដឹងច្បាស់ មិនសម្គាល់នូវអារម្មណ៍ដែលមហាជនមិនដឹងច្បាស់ មិនសម្គាល់នូវអារម្មណ៍ដែលមហាជនត្រូវដឹងច្បាស់ មិនសម្គាល់នូវបុគ្គលអ្នកដឹងច្បាស់ ម្នាលភិក្ខុទាំងឡាយ តថាគតជាតាទិបុគ្គលប្រាកដដូចនោះ ក្នុងធម៌ គឺអារម្មណ៍ទាំងឡាយ ដែលមហាជនត្រូវឃើញ ឮ ពាល់ត្រូវ ដឹងច្បាស់ តថាគតហៅថា តាទិបុគ្គលឯទៀត មិនថ្លៃថ្នូរផង មិនវិសេសវិសាលផង

ជាងតថាគតជាតាទិបុគ្គលនោះ ដោយប្រការដូច្នេះឡើយ ។

អារម្មណ៍ណាមួយ ដែលពួកជនបានឃើញក្តី បានឮក្តី បានពាល់ត្រូវក្តី ដឹងច្បាស់ក្តី អារម្មណ៍នោះ ពួកជនដទៃសម្គាល់ថាជារបស់ពិតហើយប្រកាន់មាំ ។ បណ្តាពួកជនសង្រួមដោយខ្លួនឯង ព្រះតថាគតជាតាទិបុគ្គល មិនគប្បីជឿពាក្យដទៃដែលពិតក្តី មិនពិតក្តី ។ ពួកសត្វឃើញសរ គឺទិដ្ឋិនោះមុនបំផុត ហើយជ្រុលជ្រប់ជាប់នៅក្នុងអារម្មណ៍ណា តថាគតដឹងច្បាស់ ឃើញច្បាស់នូវសរ គឺអារម្មណ៍នោះ ដូច្នោះ សេចក្តីជ្រុលជ្រប់ ( ដោយសរ គឺទិដ្ឋិ ) នោះ មិនមានដល់ព្រះតថាគតទាំងឡាយឡើយ ។

# អដ្ឋកថា

## កាឡកសូត្រ

[ ២៤ ] កាឡកសូត្រទី ៤ តាំងឡើងព្រោះអត្ថុប្បត្តិហេតុ សួរថាអត្ថុប្បត្តិហេតុដូចម្តេច ។ ឆ្លើយថា ព្រោះរឿងព្រះគុណរបស់ព្រះទសពល ។

បានឮថា នាងចូឡសុភទ្ទាកូនស្រីរបស់អនាថបិណ្ឌិក មានបំណងនឹងទៅជាមេផ្ទះរបស់កូនប្រុសកាឡកសេដ្ឋី ក្នុងនគរសាកេត ទើបចូលទៅគាល់

ព្រះសាស្តា ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងទៅមានស្វាមីក្នុងត្រកូលរបស់បុគ្គលមិច្ឆាទិដ្ឋិ បើខ្ញុំម្ចាស់បានទទួលការរាប់អានក្នុងត្រកូលនោះ កាលនឹងបញ្ជូនបុរសម្នាក់មក ក៏នឹងយឺតយូរ បពិត្រព្រះមានព្រះភាគ សូមទ្រង់មេត្តានឹកដល់ខ្ញុំម្ចាស់ខ្លះ ដូច្នេះ បានទទួលការជានាហើយក៏ទៅ កាឡកសេដ្ឋីគិតថា កូនប្រសាស្រីរបស់អញមកហើយ កាលនឹងរៀបមង្គល ទើបបានរៀបចំរបស់បរិភោគ និងរបស់ទំពាដ៏ច្រើន បានអញ្ជើញអ្នកបួសអាក្រាត ៥០០ នាក់មក អ្នកបួសអាក្រាតទាំងនោះអង្គុយហើយ ទើបលោកសេដ្ឋីបញ្ជូនមនុស្សទៅប្រាប់នាងចូឡសុភទ្ទាថា កូនស្រី ចូរមកថ្វាយបង្គំព្រះអរហន្ត ។ អរិយសាវិកាដែលសម្រេចផលហើយ គ្រាន់តែគេពោលថា ព្រះអរហន្តប៉ុណ្ណោះ ក៏ក្រោកឡើងដោយគិតថា លាភរបស់អញហ្ន៎ ។ លុះបានឃើញអ្នកបួសអាក្រាតមិនមានសិរីទាំងនោះ ទើបពោលថា បពិត្រលោកឪពុក ធម្មតាសមណៈទាំងឡាយ មិនមែនមិនមានហិរិខាងក្នុង មិនមែនមិនមានឱត្តប្បៈខាងក្រៅឡើយ គិតថា ជនទាំងនេះ មិនមែនសមណៈ ទើបស្តោះទឹកមាត់ ដើរត្រឡប់ទៅកាន់កន្លែងរបស់ខ្លួន ។

គ្រានោះ ពួកអ្នកបួសអាក្រាតពោលថា នែលោកសេដ្ឋី ស្រីកាឡកណ្ណីបែបនេះ លោកបានមកអំពីណា ក្នុងជម្ពូទ្វីប មិនមានស្រីដទៃឬ ហើយនាំគ្នាជេរសេដ្ឋី ។ ទើបលោកសេដ្ឋីសំណូមពរថា បពិត្រលោកអាចារ្យ កម្មដែលខ្ញុំដឹង ឬមិនដឹង ក៏បានធ្វើទៅហើយ ខ្ញុំនឹងដឹងរឿងនោះ ដូច្នេះ បញ្ជូនពួកអ្នកបួសអាក្រាតទៅហើយ ក៏បានទៅរកនាងសុភទ្ទា សួរថា នែនាង

ហេតុអ្វី ទើបនាងធ្វើយ៉ាងនេះ ហេតុអ្វី ទើបធ្វើឲ្យព្រះអរហន្តអាប់មុខមាត់ ។ នាងឆ្លើយថា បពិត្រលោកឪពុក ធម្មតាព្រះអរហន្តមិនមែនយ៉ាងនេះ ។ គ្រានោះ ទើបលោកសេដ្ឋីពោលនឹងនាងថា សមណៈរបស់នាងដូចម្ដេច ទើបនាងសរសើរលោកពន់ពេក សមណៈរបស់នាងមានសីលដូចម្ដេច មានមារយាទដូចម្ដេច នាងកាលបើយើងសួរហើយ ចូរប្រាប់សេចក្ដីនោះដល់យើង ។ នាងសុភទ្ទាពោលថា លោកមានឥន្ទ្រិយស្ងប់ ចិត្តស្ងប់ តាំងនៅក្នុងមគ្គ មានគុណដ៏ស្ងប់ មានភ្នែកដាក់ចុះ និយាយតែល្មមប្រមាណ សមណៈរបស់កូនយ៉ាងនេះ សមណៈទាំងនោះ កាត់នូវចំណង ចូលកាន់ព្រៃនៅតាមទំនើង មិនមានសម្ងាញ់ ដូចដំរីកាត់នូវចំណង សមណៈរបស់កូនដូច្នេះឯង ។

កាលពោលយ៉ាងនេះហើយ ទើបឈរពោលគុណរបស់ព្រះរតនត្រ័យចំពោះមុខសេដ្ឋី ។ សេដ្ឋីស្ដាប់ពាក្យរបស់នាងហើយ ទើបពោលថា បើយ៉ាងនោះ យើងនឹងនាំសមណៈរបស់នាងមកធ្វើមង្គល ដូច្នេះ ។ នាងសួរថា លោកឪពុកនឹងធ្វើក្នុងកាលណា ។ សេដ្ឋីគិតថា កាលអញប្រាប់ថា ២-៣ ថ្ងៃ នាងក៏បញ្ជូនទូតទៅឲ្យហៅមក ដូច្នេះ កាលបើដូច្នោះ ទើបពោលនឹងនាងថា នៃកូន ក្នុងថ្ងៃស្អែកនេះឯង ។ ក្នុងពេលល្ងាច នាងឡើងប្រាសាទជាន់លើកាន់ភាជនៈធំ ដាក់ផ្កាឈើ រឭកដល់ព្រះគុណរបស់ព្រះសាស្ដាហើយ ទើបបាចផ្កា ៨ ក្ដាប់ទៅ ដើម្បីព្រះទសពល ហើយផ្គងអញ្ជលី ឈរនមស្ការ ។ នាងបានពោលយ៉ាងនេះថា ស្អែកនេះ សូមទ្រង់ទទួលកិច្ចការរបស់ខ្ញុំម្ចាស់

មួយអន្លើដោយភិក្ខុសង្ឃ ៥០០ រូប ។ ផ្កាទាំងនោះ បានទៅប្រតិស្ឋានជាពិតានខាងលើព្រះទសពល ។ ព្រះសាស្តាកាលទ្រង់នឹកដល់ ក៏បានឃើញហេតុនោះ ក្នុងវេលាចប់ព្រះធម្មទេសនា អនាថបិណ្ឌិកមហាសេដ្ឋី នមស្ការព្រះទសពល ហើយទូលថា បពិត្រព្រះអង្គដ៏ចម្រើន ស្អែកនេះ សូមទ្រង់ទទួលភិក្ខាក្នុងផ្ទះរបស់ខ្ញុំព្រះអង្គ មួយអន្លើដោយភិក្ខុ ៥០០ រូប ។ ព្រះសាស្តាត្រាស់ថា លោកសេដ្ឋី តថាគតទទួលនិមន្តនាងចូឡសុភទ្ទាហើយ លោកសេដ្ឋីទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនឃើញអ្នកណាមក ។ ព្រះសាស្តាត្រាស់ថា ត្រូវហើយលោកសេដ្ឋី ឧបាសិកាដែលជាសប្បុរស នៅចម្ងាយ សូម្បី ១០០០ យោជន៍ ក៏រមែងប្រាកដបានដូចភ្នំហិមពាន្ត ទើបត្រាស់គាថានេះថា

ពួកសប្បុរស រមែងប្រាកដក្នុងទីឆ្ងាយ ដូចភ្នំហិមពាន្តដូច្នោះ
ពួកអសប្បុរស ( ទុកជាឋិតនៅ ) ក្នុងទីជិត ក៏រមែងមិន
ប្រាកដ ដូចព្រួញដែលបុគ្គលបាញ់ក្នុងវេលាយប់ ។

អនាថបិណ្ឌិកទូលថា សូមទ្រង់មេត្តាសង្គ្រោះធីតារបស់ខ្ញុំព្រះអង្គចុះដូច្នេះ ថ្វាយបង្គំហើយ ត្រឡប់ទៅ ។

ព្រះសាស្តាត្រាស់នឹងព្រះអានន្ទថា អានន្ទ តថាគតនឹងទៅនគរសាកេតអ្នកចូរឲ្យស្លាកដល់ភិក្ខុ ៥០០ តែកាលឲ្យ គប្បីឲ្យដល់ពួកភិក្ខុដែលបានអភិញ្ញា ៦ ប៉ុណ្ណោះ ។ ព្រះថេរៈក៏បានធ្វើយ៉ាងនោះ ។ ក្នុងពេលយប់ជ្រៅនៃរាត្រី នាងចូឡសុភទ្ទាគិតថា ធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់មានកិច្ចច្រើន

ទ្រង់មានករណីច្រើន ទ្រង់កំណត់ ឬទ្រង់មិនកំណត់ក៏មិនដឹង អញនឹងធ្វើដូចម្ដេចហ្ន៎ ។ ខណៈនោះ ស្ដេចវេស្សវណ្ណមហារាជបានពោលនឹងនាងចូឡសុភទ្ទាថា នែនាងសុភទ្ទា នាងកុំគិតថ្វីឡើយ កុំទោមនស្សឡើយ ព្រះមានព្រះភាគ និងភិក្ខុសង្ឃ ទ្រង់ទទួលនិមន្តដើម្បីសោយភត្តក្នុងថ្ងៃស្អែកនេះហើយ នាងក៏ត្រេកអរ ត្រៀមរៀបចំទានតែម្យ៉ាង ។ សក្កទេវរាជ ទ្រង់ហៅវិស្សកម្មមកត្រាស់ថា នែបា ព្រះទសពលនឹងយាងទៅកាន់សម្នាក់របស់នាងចូឡសុភទ្ទា ឯនគរសាកេត អ្នកចូរធ្វើផ្ទះកំពូល ៥០០ ។ វិស្សកម្មទេវបុត្រនោះក៏បានធ្វើតាមទេវបង្គាប់ ។ ព្រះសាស្ដាដែលភិក្ខុអ្នកបានអភិញ្ញា ៦ ចំនួន ៥០០ រូប ចោមរោមហើយ បានទៅកាន់នគរសាកេត ដោយកូដាគារ យានមានផ្ទះកំពូល ហាក់ដូចគូសនូវអាកាស មានពណ៌ដូចកែវមណី ។

នាងចូឡសុភទ្ទា ថ្វាយទានដល់ព្រះភិក្ខុសង្ឃ មានព្រះសម្ពុទ្ធជាប្រធាន ថ្វាយព្រះបង្គំព្រះសាស្ដា ទូលថា ចំណែកឪពុកក្មេករបស់ខ្ញុំម្ចាស់ ជាមិច្ឆាទិដ្ឋិ សូមទ្រង់ត្រាស់ធម៌ដែលសមគួរដល់ជនទាំងនោះផងចុះ ។ ព្រះសាស្ដា ទ្រង់សម្ដែងធម៌ហើយ ។ កាឡកសេដ្ឋីក៏បានជាសោតាបន្នបុគ្គល បានថ្វាយឧទ្យានរបស់ខ្លួនដល់ព្រះទសពល ។ ពួកអ្នកបួសអាក្រាតមិនប្រាថ្នានឹងចេញទៅ ដោយគិតថា លោកសេដ្ឋីឲ្យដល់ពួកយើងមុនហើយ ដូច្នេះ សេដ្ឋីបញ្ជាឲ្យនាំពួកអ្នកបួសអាក្រាតទាំងអស់ចេញទៅ ដោយពោលថា ពួកអ្នកចូរទៅនាំពួកអ្នកអាក្រាតទាំងនោះទៅ ដោយវិធីការដែលគប្បីនាំចេញទៅឲ្យខាងតែបាន ដូច្នេះហើយ ទើបឲ្យសាងវិហារក្នុងទីត្រង់នោះឯង ហើយប្រូចទឹក

ធ្វើឲ្យជាព្រហ្មទេយ្យឧទ្ទិសថ្វាយ ទើបវិហារនោះ ឈ្មោះថា កាឡការាម ព្រោះកាឡកសេដ្ឋីបានឲ្យសាង ។ សម័យនោះ ព្រះមានព្រះភាគប្រថាប់នៅក្នុងកាឡការាមនោះ ដោយហេតុនោះ ទើបលោកពោលថា **សាកេតេ វិហរតិ កាឡការាមេ** ដូច្នេះ ។

បទថា **ភិក្ខូ អាមន្តេសិ** បានដល់ ព្រះមានព្រះភាគត្រាស់ហៅភិក្ខុ ៥០០ រូបមក ។ បានឮថា ភិក្ខុទាំងនោះ ជាកុលបុត្រអ្នកនគរសាកេត ស្តាប់ធម្មទេសនារបស់ព្រះសាស្តាហើយ បួសក្នុងសម្នាក់ព្រះសាស្តា អង្គុយក្នុងសាលា ដែលគាល់ពោលគុណរបស់ព្រះទសពលថា ឱ ! ឈ្មោះថាគុណរបស់ព្រះពុទ្ធទាំងឡាយ ធំពិតហ្ន៎ ព្រះសាស្តាទ្រង់ដោះកាឡកសេដ្ឋី ដែលជាមិច្ឆាទិដ្ឋិបែបនេះចេញអំពីមិច្ឆាទិដ្ឋិ គឺការឃើញខុសបាន ឲ្យសម្រេចសោតាបត្តិផល ទ្រង់ធ្វើនគរទាំងមូលឲ្យដូចជាស្ថានទេវលោក ព្រះសាស្តាទ្រង់ពិនិត្យពិចារណាដល់ចិត្ត របស់ភិក្ខុពោលសរសើរទាំងនោះ ទើបទ្រង់ត្រិះរិះថា កាលតថាគតទៅ ទេសនាកណ្ឌធំនឹងតាំងឡើង វេលាចប់ទេសនា ភិក្ខុទាំង ៥០០ រូបនេះ តាំងនៅក្នុងអរហត្ត ផែនដីធំនឹងញាប់ញ័រដល់ទឹកទ្រផែនដី ដូច្នេះ ទ្រង់ចូលកាន់ធម្មសភា ប្រថាប់គង់លើបវរពុទ្ធាសនៈ ដែលគេរៀបចំថ្វាយ ទ្រង់ធ្វើភិក្ខុទាំងនោះឲ្យជាខាងដើមហើយ ទើបទ្រង់ផ្តើមទេសនានេះថា **យំ ភិក្ខវេ សទេវកស្ស លោកស្ស** ដូច្នេះ ។ សូត្រនេះគប្បីជ្រាបថា តាំងឡើងព្រោះរឿងព្រះគុណ ដោយប្រការដូច្នេះ ។ ចប់ទេសនា ផែនដីធំបានញាប់ញ័រដល់ទឹកទ្រផែនដីហើយ ។

បទថា **អត្តញ្ញាសឹ** បានដល់ បានដឹងដោយបញ្ញាដ៏ក្រៃលែង អធិប្បាយថា ត្រាស់ដឹងហើយ ។ បទថា **វិទិតំ** បានដល់ ដឹងហើយ ធ្វើឲ្យប្រាកដបាន ។ ដោយបទនេះ ទ្រង់សម្តែងសេចក្តីនេះថា ជនដទៃដឹងតែម្យ៉ាង តែអាត្មាអញដឹងហើយ ធ្វើឲ្យប្រាកដផងដែរ ។ ឈ្មោះថា ភូមិនៃព្រះសព្វញ្ញុតញ្ញាណ ត្រាស់ដោយបទទាំង ៣ នេះ ។ បទថា **តំ តថាគតេន ន ឧបដ្ឋាសិ** សេចក្តីថា អារម្មណ៍ដែលប្រព្រឹត្តទៅក្នុងទ្វារ ៦ នោះ មិនប្រាកដ គឺមិនចូលទៅដល់តថាគតដោយតណ្ហា ឬដោយទិដ្ឋិ ។ ពិតហើយ ព្រះមានព្រះភាគអង្គនេះ ទ្រង់ឃើញរូបដោយចក្ខុ ព្រះមានព្រះភាគ ទ្រង់មិនមានឆន្ទរាគៈ ព្រះមានព្រះភាគអង្គនោះ ទ្រង់មានចិត្តរួចផុតល្អហើយ ព្រះមានព្រះភាគ ទ្រង់ស្តាប់សំឡេងដោយសោតៈ ទ្រង់ហិតក្លិនដោយឃានៈ ទ្រង់លិទ្ធរសដោយជិវ្ហា ទ្រង់ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ទ្រង់ដឹងធម៌ដោយមនសៈ ព្រះមានព្រះភាគទ្រង់មិនមានឆន្ទរាគៈ គឺតម្រេកដោយអំណាចការពេញចិត្ត ព្រះមានព្រះភាគអង្គនោះ ទ្រង់មានចិត្តរួចផុតល្អហើយ ដោយហេតុនោះ ទើបត្រាស់ថា **តំ តថាគតេន ន ឧបដ្ឋាសិ** ដូច្នេះ ។ ឯភូមិនៃព្រះខីណាស្រព គប្បីជ្រាបថា ត្រាស់ដោយបទនេះ ។ បទថា **តំ មមស្ស មុសា** សេចក្តីថា ពាក្យនោះឯង គប្បីឈ្មោះថា មុសាវាទ ។ បទថា **តំ បិស្ស តាទិសមេវ** សេចក្តីថា ពាក្យនោះ គប្បីជាមុសាវាទ ។ បទថា **តំ មមស្ស កលិ** សេចក្តីថា ពាក្យនោះ គប្បីជាទោសដល់យើង ។ ឈ្មោះថា សច្ចភូមិ គប្បីជ្រាបថា ត្រាស់ដោយហេតុមានប្រមាណប៉ុណ្ណេះ ។

បទថា **ទិដ្ឋា ទិដ្ឋព្វំ** បានដល់ ឃើញរូបដែលឃើញ ហើយគួរឃើញ ។ បទថា **ទិដ្ឋំ ន មញ្ញតិ** សេចក្តីថា រមែងមិនសម្គាល់អាយតនៈ គឺរូបដែលឃើញហើយនោះ ដោយតណ្ហា មានះ ទិដ្ឋិថា អញក៏ឃើញរូបដែលមហាជនឃើញហើយដូចគ្នា ។ បទថា **អទិដ្ឋំ ន មញ្ញតិ** សេចក្តីថា រមែងមិនសម្គាល់ដោយតណ្ហាជាដើមយ៉ាងនេះថា អាត្មាអញឃើញរូបនោះ ដែលមហាជនមិនទាន់ឃើញ ។ បទថា **ទិដ្ឋព្វំ ន មញ្ញតិ** សេចក្តីថា រមែងមិនសម្គាល់ដោយការសម្គាល់ទាំងនោះយ៉ាងនេះថា អាត្មាអញក៏ឃើញរូបដែលមហាជនឃើញហើយ ដូច្នេះ ។ សេចក្តីពិត រូបដែលគួរឃើញ ជារូបដែលមហាជនឃើញហើយនោះឯង ។ ពាក្យបែបនេះ អ្នកសិក្សារមែងរកបានក្នុងកាលទាំង ៣ ។ អត្ថនៃពាក្យទាំងនោះ ត្រាស់ហើយ ដោយបទនោះ ។ បទថា **ទិដ្ឋារំ ន មញ្ញតិ** សេចក្តីថា រមែងមិនសម្គាល់បុគ្គលឃើញនេះ ឈ្មោះថា សត្វម្នាក់ ដោយការសម្គាល់ទាំងនោះ ។ សូម្បីក្នុងឋានៈដ៏សេស ក៏គប្បីជ្រាបអត្ថដោយន័យនេះឯង ។ ឈ្មោះថា សុញ្ញតាភូមិ គឺការទទេ ក៏ត្រាស់ដោយឋានៈប្រមាណប៉ុណ្ណេះ ។

បទថា **ឥតិ ខោ ភិក្ខវេ** ប្រែថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ។ បទថា **តាទិសោវ តាទី** សេចក្តីថា ភាពហាក់ដូចតែមួយ ឈ្មោះថា **តាទិ** ។

ពិតហើយ ព្រះតថាគត យ៉ាងណា ក្នុងឥដ្ឋារម្មណ៍ មានលាភជាដើម ក្នុងអនិដ្ឋារម្មណ៍ មានការវិនាសលាភជាដើម ក៏មានន័យដូច្នោះ ។ ដោយហេតុនោះ ទើបលោកពោលថា តថាគតជាតាទិបុគ្គលទាំងក្នុងលាភ ទាំងក្នុង

ការវិនាសលាភ ជាតាទិបុគ្គលក្នុងយស និងក្នុងការវិនាសយស ជាតាទិ-បុគ្គលក្នុងនិន្ទាផង ក្នុងសរសើរផង ជាតាទិបុគ្គលក្នុងសុខផង ក្នុងទុក្ខផង ដូច្នេះ ។ តថាគត ឈ្មោះថា **តាទិ** ដូច្នោះ ក៏ព្រោះភាពជាតាទិបុគ្គលនេះ ។ បទថា **តម្ហា ច បន តាទិម្ហា** សេចក្តីថា ឈ្មោះថា ភូមិនៃតាទិបុគ្គល ត្រាស់ដោយពាក្យប្រមាណប៉ុណ្ណេះថា មិនមានតាទិបុគ្គលដទៃក្រៃលែងជាង ឬប្រណីតជាងតាទិបុគ្គលរបស់តថាគត ដូច្នេះ ។ ព្រះមានព្រះភាគ កាលទ្រង់ពង្រីកទេសនាដោយភូមិទាំង ៥ នេះ មហាប្រឹថពីក៏បានញាប់ញ័រជាបន្ទាល់ក្នុងឋានៈ ៥ ។ វេលាចប់ទេសនា សត្វ គឺទេវតា និងមនុស្សចំនួន ៨៤០០០ មកដល់ទីនោះ រួមទាំងកុលបុត្រ ៥០០ ដែលបួសថ្មីទាំងនោះ ជាដើម ក៏នាំគ្នាផឹកទឹកបាន គឺអមតធម៌ហើយ ។

ព្រះមានព្រះភាគ ទ្រង់បញ្ចប់ព្រះសូត្រហើយ កាលទ្រង់កាន់យកកំពូលធម៌ ដោយគាថាទាំងឡាយ ទើបត្រាស់ថា **យង្កិញ្ចិ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **អជ្ឈោសិតំ សច្ចមុតំ បរេសំ** សេចក្តីថា វត្ថុដែលបានឃើញជាដើម ដែល បុគ្គលដទៃសម្គាល់ថាពិត ហើយជាប់ចិត្តដោយការជឿ ដែលប្រព្រឹត្តតាមអ្នកដទៃ គឺលេបយកសព្វយ៉ាង ។ បទថា **សយសំវុតេសុ** សេចក្តីថា ក្នុងការកាន់យកវត្ថុដែលខ្លួនរវាំងប្រយ័ត្ននោះឯង គឺប្រព្រឹត្តកាន់យកហើយ អធិប្បាយថា ក្នុងបុគ្គលដែលមានទិដ្ឋិជាគតិ ។ ដ្បិតពួកបុគ្គលដែលមានទិដ្ឋិជាគតិ ក៏ហៅបុគ្គលនោះថា **សយំសំវុតា** គឺដែលសង្រួមនោះឯង ។ បទថា **សច្ចំ មុសា វាបិ បរំ ទហេយ្យ** សេចក្តីថា

តថាគតជាតាទិបុគ្គល ក្នុងបុគ្គលដែលមានទិដ្ឋិជាគតិ ពោល គឺដែលខ្ជនរវាំងប្រយ័ត្នទាំងនោះឯង មិនគប្បីកាន់យក មិនគប្បីជឿ មិនគប្បីប្រព្រឹត្តតាមពាក្យនៃបុគ្គលទាំងនោះថា ពិត ឬមិនពិត ឲ្យប្រាប់ទៅ គឺឲ្យឧត្តុង្គឧត្តមយ៉ាងនេះថា នេះប៉ុណ្ណោះពិត ដទៃមិនពិត ដូច្នេះ ។ បទថា **ឯតញ្ច សល្លំ** គឺតថាគតឃើញព្រួញ គឺទិដ្ឋិនេះ ។ បទថា **បដិកច្ច ទិស្វា** សេចក្តីថា តថាគតឃើញមកអំពីមុនក្នុងមណ្ឌលពោធិព្រឹក្ស ។ បទថា **វិសត្តា** សេចក្តីថា ប្រជាជនជាប់ជំពាក់រួបរឹត ។ ក្នុងបទថា **ជានាមិ បស្សាមិ តថេវ ឯតំ** នេះ សេចក្តីថា ពួកសត្វនេះជាប់ចិត្តលេបនូវវត្ថុសព្វយ៉ាង ក៏ជាប់ជំពាក់ដល់គ្នានិងគ្នា សូម្បីតថាគតក៏បានដឹង ឃើញវត្ថុទាំងនោះ វត្ថុនោះក៏ដូចដែលពួកសត្វនេះប្រកាន់គ្នា តែតថាគតទាំងឡាយ មិនជាប់ជំពាក់យ៉ាងនោះ ។ ៚

## អដ្ឋកថាកាឡកសូត្រទី ៤ ចប់

# សុត្តន្តបិដក

## ព្រហ្មចរិយសូត្រទី ៨

[ ២៦ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងប្រព្រឹត្តព្រហ្មចរិយធម៌នេះ ដើម្បីកុហកមហាជនក៏ទេ ដើម្បីល្បួងលួងមហាជនក៏ទេ ដើម្បីលាភសក្ការៈ និងសេចក្តីសរសើរជាអានិសង្សក៏ទេ ដើម្បីបានអានិសង្ស ព្រោះការដោះនូវពាក្យជនដទៃ ដូច្នេះ ដូច្នោះថា មហាជនចូរស្គាល់នូវតថាគតដូច្នេះក៏ទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតប្រព្រឹត្តព្រហ្មចារ្យនេះ ដើម្បីសង្រួម ដើម្បីលះ ដើម្បីប្រាសចាករាគៈ ដើម្បីរម្ងត់ទុក្ខតែប៉ុណ្ណោះឯង ។

ព្រះដ៏មានព្រះភាគនោះ ទ្រង់បានសម្តែងនូវព្រហ្មចារ្យ មិនបានជឿអ្នកដទៃ ដើម្បីសង្រួម ដើម្បីលះបង់ ជាដំណើរទៅក្នុងព្រះនិព្វាន ផ្លូវហ្នឹង ដែលព្រះពុទ្ធជាចម្បងយាត្រាទៅ ។ បើពួកជនណា ដើរតាមផ្លូវដែលព្រះពុទ្ធសម្តែងហើយនោះ បើពួកជននោះ ធ្វើតាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តានោះ ទើបនឹងធ្វើទីបំផុតទុក្ខបាន ។

# អដ្ឋកថា

## ព្រហ្មចរិយសូត្រ

[ ២៦ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងព្រហ្មចរិយសូត្រទី ៥ ដូចតទៅនេះ បទថា **ជនកុហានត្ថំ** សេចក្តីថា ដើម្បីការបោកបញ្ឆោតបុគ្គល ដោយរឿងកុហនវត្ថុ ៣ យ៉ាង ។ បទថា **ន ជនលបនត្ថំ** បានដល់ មិនមែនដើម្បីល្បួងលួងបុគ្គល ។ បទថា **ន លាភសក្ការសិលោកានិសំសត្ថំ** បានដល់ មិនមែនដើម្បីលាភសក្ការៈ មានចីវរជាដើម និងពាក្យសរសើរឡើយ ។ បទថា **ន ឥតិវាទប្បមោក្ខានិសំសត្ថំ** បានដល់ មិនមែនដើម្បីអានិសង្សជាមេលទ្ធិ ដោយហេតុនោះៗ មិនមែនដើម្បីអានិសង្ស និងដោះនូវលទ្ធិ ។ បទថា **ន ឥតិ មំ ជនោ ជានាតុ** បានដល់ មិនមែនដើម្បីឲ្យអ្នកដទៃស្គាល់ថា បានឮថា ភិក្ខុនោះយ៉ាងនេះ ។ បទថា **សំវរត្ថំ** បានដល់ ដើម្បីការសង្រួមដោយសំវរៈ ៥ ។ បទថា **បហានត្ថំ** បានដល់ ដើម្បីលះដោយបហាន ៣ ។ បទថា **វិរាគត្ថំ** បានដល់ ដើម្បីប្រាសចាកកិលេស មានរាគៈជាដើម ។ បទថា **និរោធត្ថំ** បានដល់ ដើម្បីរម្ងត់កិលេសទាំងនោះឯង ។ បទថា **អនីតិហំ** បានដល់ វៀរឥតិហាសៈ ដែលពោលតាមគ្នាមកតាមបវេណី មិនដើរតាមអ្នកដទៃ ។ បទថា **និព្វានោគធគាមិនំ** សេចក្តីថា ជាផ្លូវឈមចុះកាន់ខាងក្នុងព្រះនិព្វាន ។ សេចក្តីពិត មគ្គព្រហ្មចរិយៈ ធ្វើនិព្វានឲ្យជាអារម្មណ៍ តែងប្រព្រឹត្តទៅ គឺប្រព្រឹត្តទៅខាងក្នុងនិព្វាននោះឯង ។ បទថា **បដិបជ្ជន្តិ** បានដល់ ដើរតាមផ្លូវទាំង ២ ។ ក្នុងព្រះសូត្រនេះត្រាស់

វឌ្ឍៈផង វិវឌ្ឍៈផង ក្នុងគាថាត្រាស់វិវឌ្ឍៈតែម្យ៉ាង ។

## អដ្ឋកថា ព្រហ្មចរិយសូត្រទី ៥ ចប់

# សុត្តន្តបិដក

## កុហសូត្រទី ៦

[ ២៧ ] ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា ជាអ្នកកុហក រឹងរូស រវេរវាយ មានកិលេសលេចឡើងប្រាកដដូចជាស្នែង ជំទើងមានះ មានចិត្តមិននឹងធឹង ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុទាំងនោះ មិនមែនជាអ្នករាប់អានតថាគតទេ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុទាំងនោះ ជាអ្នកប្រាសចាកធម្មវិន័យនេះ ពួកភិក្ខុទាំងនោះមិនដល់នូវសេចក្តីចម្រើន ដុះដាលធំទូលាយក្នុងធម៌-វិន័យនេះបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា ជាអ្នកមិនកុហក មិនរវេរវាយ ជាអ្នកខ្ជាប់ខ្ជួន មិនរឹងរូស មានចិត្តនឹងធឹង ម្នាលភិក្ខុទាំង-ឡាយ ពួកភិក្ខុទាំងនោះ ឈ្មោះថា ជាអ្នករាប់អានតថាគតផង ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុទាំងនោះ មិនប្រាសចាកធម្មវិន័យនេះផង ពួកភិក្ខុទាំងនោះ តែងដល់នូវសេចក្តីចម្រើន ដុះដាលធំទូលាយ ក្នុងធម្មវិន័យនេះផង ។

ពួកភិក្ខុណាកុហក រឹងរូស រវេរវាយ មានកិលេសលេចឡើង
ប្រាកដដូចជាស្នែង ជំទើងមានះ មានចិត្តមិននឹងធឹង ភិក្ខុទាំង

នោះ រមែងមិនដុះដាលក្នុងធម៌ ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងហើយទេ ។ ភិក្ខុណាជាអ្នកមិនកុហក មិនរឡេះរឡោះ ជាអ្នកខ្ជាប់ខ្ជួន មិនរឹងរូស មានចិត្តនឹងធឹង ភិក្ខុទាំងនោះ ទើបដុះដាលក្នុងធម៌ ដែលព្រះសម្មាសម្ពុទ្ធសម្តែងហើយ ។

# អដ្ឋកថា

## កុហសូត្រ

[ ២៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកុហសូត្រទី ៦ ដូចតទៅនេះ បទថា **កុហា** ប្រែថា បោកបញ្ឆោត ។ បទថា **ថទ្ធា** បានដល់ រឹងរូស ដោយសេចក្តីក្រោធ និងមានះ ។ បទថា **លបា** បានដល់ និយាយរឡេះរឡោះ ។ បទថា **សិង្គី** សេចក្តីថា ជាអ្នកប្រកបដោយកិលេសដែលប្រាកដដូចស្នែងសត្វ ដែលលោកពោលយ៉ាងនេះថា បណ្តាធម៌ទាំងនោះ កិលេសជាតដូចស្នែង តើដូចម្តេច ។ កិលេសជាតដូចស្នែង សេចក្តីស្រឡាញ់ ការឈ្លាសវៃ ការឆ្លៀវឈ្លាស ការបិនប្រសប់ សេចក្តីបិនប្រសប់ណា នេះហៅថា កិលេសជាតដូចស្នែង ។

បទថា **ឧន្នឡា** សេចក្តីថា ដូចដើមបបុសដែលខំលូតឡើង គឺលើក

មានះតាំងឡើង ។ បទថា **អសមាហិតា** សេចក្ដីថា មិនបានត្រឹមតែឯកគ្គតាចិត្ត ។ បទថា **ន មេ តេ ភិក្ខវេ ភិក្ខូ មាមកា** សេចក្ដីថា ភិក្ខុទាំងនោះរបស់តថាគត មិនមែនជាសម្បត្តិរបស់តថាគត ។ បទថា របស់តថាគត ត្រាស់ ព្រោះបួសឧទ្ទិសព្រះសាស្ដា ។ បទថា **តេ ខោ មេ ភិក្ខវេ ភិក្ខូ មាមកា** សេចក្ដីថា ត្រាស់ព្រោះបួសឧទ្ទិសខ្លួនក្នុងសាសនានេះ តែត្រាស់ថា **មាមកា** ព្រោះជាអ្នកបដិបត្តិប្រពៃ ។ បទថា **វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ អាបជ្ជន្តិ** សេចក្ដីថា ភិក្ខុទាំងនោះ រមែងដល់នូវការចម្រើន ព្រោះចម្រើនដោយសីលាទិគុណ ការដុះដាល ព្រោះមិនញាប់ញ័រ ការបរិបូណ៌ ព្រោះផ្សាយទៅក្នុងទីគ្រប់ស្ថាន ។ ភិក្ខុទាំងនេះ រមែងដុះដាលរហូតដល់អរហត្តមគ្គ កាលសម្រេចអរហត្តផលហើយ ឈ្មោះថា ដុះដាល ។ ទាំងក្នុងព្រះសូត្រនេះ ទាំងក្នុងគាថា ត្រាស់ទាំងវដ្ដៈ ទាំងវិវដ្ដៈ ដោយប្រការដូច្នេះ ។ល។

**អដ្ឋកថា កុហសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## សន្តុដ្ឋិសូត្រទី ៧

[ ២៨ ] ម្នាលភិក្ខុទាំងឡាយ វត្ថុ ៤ យ៉ាងនេះ ជារបស់តិចផង បានដោយងាយផង មិនមានទោសផង ។ វត្ថុ ៤ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាចីវរទាំងឡាយ បំសុកូលចីវរជារបស់តិចផង បានដោយងាយផង មិនមានទោសផង ១ ម្នាលភិក្ខុទាំងឡាយ បណ្តាភោជនទាំងឡាយ ដុំបាយដែលភិក្ខុបានដោយកម្លាំងនៃកំភួនជើង ជារបស់តិចផង បានដោយងាយផង មិនមានទោសផង ១ ម្នាលភិក្ខុទាំងឡាយ បណ្តាសេនាសនៈទាំងឡាយ រុក្ខមូលសេនាសនៈជារបស់តិចផង បានដោយងាយផង មិនមានទោសផង ១ ម្នាលភិក្ខុទាំងឡាយ បណ្តាភេសជ្ជៈទាំងឡាយ បូតិមុត្តភេសជ្ជៈជារបស់តិចផង បានដោយងាយផង មិនមានទោសផង ១ ។ ម្នាលភិក្ខុទាំងឡាយ វត្ថុទាំង ៤ នេះជារបស់តិចផង បានដោយងាយផង មិនមានទោសផង ម្នាលភិក្ខុទាំងឡាយ កាលណាភិក្ខុជាអ្នកសន្តោសដោយវត្ថុតិចផង បានដោយងាយផង តថាគតហៅថា នេះជាអង្គរបស់សមណៈដ៏ប្រសើរ ។

សេចក្តីចង្អៀតចង្អល់ចិត្ត តែងមិនមានដល់ភិក្ខុអ្នកត្រេកអរ
ដោយរបស់មិនមានទោសផង តិចផង បានដោយងាយផង
ព្រោះប្រារព្ធនូវសេនាសនៈផង ចីវរផង ភេសជ្ជៈផង
ភោជនផង ទាំងទិសក៏មិនបៀតបៀន ( ភិក្ខុនោះ ) ។

មួយទៀត ពួកធម៌ណា ដែលតថាគតសម្ដែងហើយ ជាធម៌សមគួរដល់សមណភាព ធម៌នោះតាំងនៅខាងក្នុង ( ចិត្ត ) របស់ភិក្ខុអ្នកមានសេចក្ដីសន្ដោស អ្នកមិនប្រមាទនោះ ។

# អដ្ឋកថា

## សន្តុដ្ឋិសូត្រ

[ ២៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសន្តុដ្ឋិសូត្រទី ៧ ដូចតទៅនេះ បទថា **អប្បានិ** ប្រែថា របស់តិចតួច ។ បទថា **សុលភានិ** ប្រែថា គប្បីបានដោយងាយ គឺបុគ្គលណាក៏អាចបានក្នុងទីណាមួយ ។ បទថា **អនវជ្ជានិ** ប្រែថា មិនមានទោស ។ បទថា **បិណ្ឌិយាលោបភោជនំ** បានដល់អាហារដែលគ្រាច់ទៅដោយកម្លាំងស្មង បានមក គ្រាន់តែជាដុំបាយ ។ បទថា **បូតិមុត្តំ** បានដល់ ទឹកមូត្រណាមួយ ។ កាយសូម្បីមានពណ៌ដូចមាស ក៏ហៅថា កាយស្អុយ យ៉ាងណា ទឹកមូត្រ សូម្បីថ្មោងថ្មី ក៏ហៅថា ទឹកមុត្រស្អុយ ដូច្នោះ ។ បទថា **វិឃាតោ** បានដល់ ការចង្អៀតចង្អល់ អធិប្បាយថា ចិត្តមិនមានទុក្ខ ( មិនប្រាស់ប្រាល់ ) ។ បទថា **ទិសា នប្បដិហញ្ញតិ** សេចក្ដីថា ភិក្ខុណាកើតការគិតឡើងថា អាត្មាអញទៅទីឈ្មោះនោះ នឹងបានចីវរជាដើម ចិត្តរបស់ភិក្ខុនោះ ឈ្មោះថា រមែងក្ដៅក្រហាយ សព្វទិស ។

ភិក្ខុណាមិនកើតការគិតយ៉ាងនោះ ចិត្តរបស់ភិក្ខុនោះ ឈ្មោះថា មិនក្តៅក្រហាយ សព្វទិស ។ បទថា **ធម្មា** គឺបដិបត្តិធម៌ ។ បទថា **សាមញ្ញស្សានុលោមិកា** បានដល់ សមគួរដល់សមណធម៌ ។ បទថា **អជ្ឈត្តហិតា** សេចក្តីថា ធម៌ទាំងអស់នោះ រមែងឈ្មោះថា ភិក្ខុដែលមានចិត្តសន្តោស កំណត់នៅខាងក្នុង មិនទៅខាងក្រៅ ។ល។

**អដ្ឋកថា សន្តុដ្ឋិសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## អរិយវង្សសូត្រទី ៨

[ ២៩ ] ម្នាលភិក្ខុទាំងឡាយ អរិយវង្ស ៤ យ៉ាងនេះ ជាច្បាប់ទម្លាប់ដឹងអស់រាត្រីដ៏វែង ជាបវេណី ជាច្បាប់ចាស់ មិនច្រឡូកច្រឡំ មិនដែលច្រឡូកច្រឡំ មិនរោតរាតរាយ មិនរាត់រាយ ដែលសមណព្រាហ្មណ៍ទាំងឡាយ ជាអ្នកប្រាជ្ញមិនអាចតិះដៀលបាន ។ ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកសន្តោសដោយចីវរ តាមមានតាមបាន ជាអ្នកសរសើរគុណនៃសេចក្តីសន្តោសដោយចីវរ តាមមានតាមបាន មិនដល់នូវការស្វែងរកដ៏មិនសមគួរ ព្រោះហេតុតែចីវរ មិនប្រាស់ប្រាល់ព្រោះមិនបានចីវរ បានចីវរហើយ មិនរីករាយ មិនជ្រុលជ្រប់ មិនទម្រន់

ឲ្យតណ្ហាគ្របសង្កត់ចិត្ត ជាអ្នកឃើញទោសជាប្រក្រតី មានប្រាជ្ញាជាគ្រឿងរលាស់ចេញ បរិភោគមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់បុគ្គលដទៃ ព្រោះតែសេចក្តីសន្តោសដោយចីវរ តាមមានតាមបាននោះ ។ មែនពិត ភិក្ខុណាឈ្លាសវៃ មិនខ្ជិលច្រអូស ជាអ្នកដឹងខ្លួន មានស្មារតីតម្កល់មាំក្នុងសេចក្តីសន្តោសនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា អ្នកតាំងនៅក្នុងអរិយវង្ស ជាច្បាប់ទម្លាប់ចាស់ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកសន្តោសដោយបិណ្ឌបាតតាមមានតាមបាន ជាអ្នកសរសើរគុណនៃសេចក្តីសន្តោសដោយបិណ្ឌបាត មិនដល់នូវការស្វែងរកដ៏មិនសមគួរ ព្រោះហេតុតែបិណ្ឌបាត មិនប្រាស់ប្រាល់ព្រោះតែមិនបានចង្ហាន់បិណ្ឌបាត បានចង្ហាន់បិណ្ឌបាតហើយ មិនរីករាយ មិនជ្រុលជ្រប់ មិនទម្រន់ឲ្យតណ្ហាគ្របសង្កត់ ឃើញទោសជាប្រក្រតី មានប្រាជ្ញាជាគ្រឿងរលាស់ចេញ បរិភោគ មិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់បុគ្គលដទៃ ព្រោះតែសេចក្តីសន្តោសដោយបិណ្ឌបាត តាមមានតាមបាននោះឡើយ ។ ពិតហើយ ភិក្ខុណាឈ្លាសវៃ មិនខ្ជិលច្រអូស ជាអ្នកដឹងខ្លួន មានស្មារតីតម្កល់មាំក្នុងសេចក្តីសន្តោសនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា អ្នកតាំងនៅក្នុងអរិយវង្ស ជាច្បាប់ទម្លាប់ចាស់ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកសន្តោសដោយសេនាសនៈតាមមានតាមបាន ជាអ្នកសរសើរគុណនៃសេចក្តីសន្តោសដោយសេនាសនៈ តាមមាន តាមបាន មិនដល់នូវការស្វែងរកដ៏មិនសមគួរ ព្រោះហេតុតែសេនាសនៈ មិនប្រាស់ប្រាល់ ព្រោះតែ

មិនបានសេនាសនៈ បានសេនាសនៈហើយ ក៏មិនរីករាយ មិនជ្រុលជ្រប់ មិនទម្រន់ឲ្យតណ្ហាគ្របសង្កត់ ឃើញទោសជាប្រក្រតី មានប្រាជ្ញាជាគ្រឿងរលាស់ចេញ បរិភោគមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់បុគ្គលដទៃ ព្រោះតែសេចក្តីសន្តោសដោយសេនាសនៈ តាមមានតាមបាននោះឡើយ ។ មែនពិត ភិក្ខុណាឈ្លាសវៃ មិនខ្ជិលច្រអូស ជាអ្នកដឹងខ្លួន មានស្មារតីតម្កល់មាំក្នុងសេចក្តីសន្តោសនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា អ្នកតាំងនៅក្នុងអរិយវង្សជាច្បាប់ទម្លាប់ចាស់ ១ ។ ម្នាលភិក្ខុទាំង-ឡាយ មួយទៀត ភិក្ខុជាអ្នកមានការចម្រើន ជាទីត្រេកអរ ជាអ្នកត្រេកអរក្នុងការចម្រើន មានការលះបង់កិលេសទាំងពួង ជាទីត្រេកអរ ជាអ្នកត្រេកអរក្នុងការលះ មិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់បុគ្គលដទៃ ព្រោះតែការចម្រើនជាទីត្រេកអរ ត្រេកអរក្នុងការចម្រើន មានការលះជាទីត្រេកអរ ត្រេកអរក្នុងការលះនោះឡើយ ។ មែនពិត ភិក្ខុណាឈ្លាសវៃ មិនខ្ជិសច្រអូស ជាអ្នកដឹងខ្លួន មានស្មារតីតាំងមាំក្នុងការត្រេកអរនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា អ្នកតាំងនៅក្នុងអរិយវង្សជាច្បាប់ទម្លាប់ចាស់ ១ ។ ម្នាលភិក្ខុទាំងឡាយ អរិយវង្ស ៤ យ៉ាងនេះ ជាច្បាប់ទម្លាប់ ដឹងអស់រាត្រីដ៏វែង ជាបវេណី ជាច្បាប់ចាស់ មិនច្រឡូកច្រឡំ មិនដែលច្រឡូកច្រឡំ មិនរតាត់រតាយ មិនរាត់រាយ ដែលសមណព្រាហ្មណ៍ទាំងឡាយ ជាអ្នកប្រាជ្ញមិនអាចតិះដៀលបាន ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុបរិបូណ៌ដោយអរិយវង្សទាំង ៤ នេះ ទុកណាជានៅក្នុងបុរត្ថិមទិស ភិក្ខុនោះឯង អាចអត់

សង្កត់នូវសេចក្តីអផ្សុកបាន សេចក្តីអផ្សុក ក៏មិនអាចគ្របសង្កត់ភិក្ខុនោះបានឡើយ ទុកណាជានៅក្នុងបច្ឆិមទិស ... ទុកណាជានៅក្នុងឧត្តរទិស ... ទុកណាជានៅក្នុងទក្ខិណទិស ភិក្ខុនោះឯង អាចគ្របសង្កត់នូវសេចក្តីអផ្សុក សេចក្តីអផ្សុក ក៏មិនគ្របសង្កត់ភិក្ខុនោះបានឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុជាអ្នកខ្ជាប់ខ្ជួន អាចអត់សង្កត់នូវសេចក្តីអផ្សុក និងសេចក្តីត្រេកអរ ( ក្នុងកាមគុណទាំង ៥ ) បាន ។

សេចក្តីអផ្សុកមិនអាចគ្របសង្កត់ នូវភិក្ខុអ្នកខ្ជាប់ខ្ជួនបាន ទាំងសេចក្តីអផ្សុក មិនអាចគ្របសង្កត់ភិក្ខុអ្នកខ្ជាប់ខ្ជួនបាន ភិក្ខុអ្នកខ្ជាប់ខ្ជួន ក៏អាចគ្របសង្កត់នូវសេចក្តីអផ្សុកបាន ភិក្ខុអ្នកខ្ជាប់ខ្ជួន គ្របសង្កត់នូវសេចក្តីអផ្សុកបាន ។ រាគៈ ទោសៈ ដូចម្តេច ឃាត់នូវបុគ្គលអ្នកលះបង់នូវកម្មទាំងពួង អ្នកបន្ទោបង់នូវកិលេសទាំងឡាយបាន អ្នកណាគួរនឹងនិន្ទា នូវបុគ្គលដែលប្រាកដស្មើដោយគ្រឿង នៃមាសជម្ពូនទនោះបាន ពួកទេវតា និងមនុស្សក៏សរសើរ សូម្បីតែព្រហ្មក៏សរសើរបុគ្គលនោះដែរ ។

# អដ្ឋកថា

## អរិយវង្សសូត្រ

[ ២៩ ] អរិយវង្សសូត្រទី ៨ តាំងឡើង មានអធ្យាស្រ័យរបស់ព្រះអង្គជាអត្ថុប្បត្តិហេតុ ។ បានឮថា ព្រះមានព្រះភាគប្រថាប់គង់លើបវរពុទ្ធាសនៈ ដែលគេរៀបចំថ្វាយក្នុងធម្មសភាជេតពនមហាវិហារ ត្រាស់ហៅភិក្ខុ ៤ ម៉ឺនរូប ដែលអង្គុយចោមរោមថា **ភិក្ខវេ** ដូច្នេះហើយ ទើបទ្រង់ផ្តើមមហាអរិយវង្សសូត្រនេះថា **ចត្តារោមេ ភិក្ខវេ អរិយវំសា** ជាដើម ដោយអំណាចអធ្យាស្រ័យរបស់ទ្រង់ផង របស់បុគ្គលដទៃផង ។ ក្នុងបទទាំងនោះ បទថា **អរិយវំសា** គឺវង្សរបស់ព្រះអរិយៈទាំងឡាយ ។ អរិយ-វង្សទី ៨ នេះ ជាខ្សែស្រឡាយរបស់ព្រះអរិយៈ ឈ្មោះថា ជាបវេណីរបស់ព្រះអរិយៈ ដូចខត្តិយវង្ស ព្រាហ្មណវង្ស វេស្សវង្ស សុទ្ទវង្ស សមណវង្ស កុលវង្ស រាជវង្ស ដូច្នោះ ។ វង្សនេះ លោកពោលថា ជាកំពូលនៃវង្សទាំងនោះ ដូចក្លិនក្លាំពាក់ជាដើម ជាកំពូលនៃឈើដែលមានក្លិនកើតអំពីឫសជាដើម ។

សួរថា បុគ្គលពួកណា គឺអរិយៈ វង្សរបស់អរិយៈ ។ ឆ្លើយថា ព្រះសម្ពុទ្ធទាំងឡាយ ព្រះបច្ចេកពុទ្ធទាំងឡាយ និងសាវករបស់ព្រះតថាគតទាំងឡាយ លោកហៅថា ព្រះអរិយៈ វង្សរបស់ព្រះអរិយៈទាំងនោះ ទើបរួមហៅថា អរិយវង្ស ។ មុនអំពីកាលនេះទៅ ក្នុងទីបំផុត ៤ អសង្ខេយ្យ និងមួយសែនកប្ប ព្រះពុទ្ធកើតឡើង ៤ អង្គ គឺព្រះតណ្ហង្ករ ១ មេធង្ករ ១

សារណង្ករ ១ ទីបង្ករ ១ ដូច្នេះ ។ វង្សរបស់ព្រះអរិយៈទាំងនោះ ឈ្មោះថា អរិយវង្ស ។ ខាងក្រោយអំពីបរិនិព្វានរបស់ព្រះពុទ្ធទាំងនោះ កន្លងទៅមួយអសង្ខេយ្យ មានព្រះពុទ្ធព្រះនាមកោណ្ឌញ្ញៈ ។បេ។ ក្នុងកប្បនេះ ព្រះពុទ្ធកើតឡើង ៤ អង្គ គឺព្រះកកុសន្ធៈ ១ ព្រះកោនាគមនៈ ១ ព្រះកស្សបៈ ១ ព្រះមានព្រះភាគគោតមនៃពួកយើង ១ ដូច្នេះ វង្សរបស់ព្រះអរិយៈទាំងនោះរួមឈ្មោះថា អរិយវង្ស ។ម្យ៉ាងទៀត វង្សរបស់ព្រះអរិយៈទាំងឡាយ គឺព្រះពុទ្ធគ្រប់អង្គ បច្ចេកពុទ្ធ និងពុទ្ធសាវក ទាំងអតីត អនាគត និងបច្ចុប្បន្នឈ្មោះថា អរិយវង្ស ។

វង្សនៃព្រះអរិយៈទាំងនោះ ឈ្មោះថា **អគ្គញ្ញា** បានដល់ គប្បីដឹងថាប្រសើរក្រៃលែង ។ ឈ្មោះថា **រត្តញ្ញា** បានដល់ គប្បីដឹងថា ប្រព្រឹត្តមកយូរហើយ ។ ឈ្មោះថា **វំសញ្ញា** បានដល់ គប្បីដឹងថា ជាវង្ស គឺខ្សែស្រឡាយ ។ ឈ្មោះថា **បោរាណា** បានដល់ មិនមែនកើតឡើងឥឡូវនេះឡើយ ។ ឈ្មោះថា **អសំកិណ្ណា** បានដល់ មិនមែនខ្ចាត់ខ្ចាយ មិនមែនត្រូវបោះបោល ។ បទថា **អសំកិណ្ណាបុព្វា** បានដល់ មិនធ្លាប់ខ្ចាត់ខ្ចាយ ព្រះពុទ្ធក្នុងអតីតមិនធ្លាប់បោះបង់ ដោយយល់ថា ប្រយោជន៍អ្វី ដោយអរិយវង្សទាំងនេះ ។ បទថា **ន សំកីយន្តិ** បានដល់ ឥឡូវនេះ លោកទាំងនោះក៏មិនបោះបង់ ។ បទថា **ន សំកីយិស្សន្តិ** បានដល់ ព្រះពុទ្ធក្នុងអនាគត ក៏មិនបោះបង់ ។ សមណព្រាហ្មណ៍ពួកណា ជាអ្នកចេះដឹងក្នុងលោក អរិយវង្សទាំងនេះ ដែលសមណព្រាហ្មណ៍ទាំងនោះ មិនជំទាស់ហើយ គឺសមណ-

ព្រាហ្មណ៍ដែលជាអ្នកប្រាជ្ញ មិននិន្ទា មិនតិះដៀលហើយ ។

បទថា **សន្តុដ្ឋោ ហោតិ** សេចក្តីថា ជាអ្នកសន្តោសដោយបច្ច័យសន្តោស ។ បទថា **ឥតរីតរេន** សេចក្តីថា ជាអ្នកសន្តោសដោយបច្ច័យគ្រោតគ្រាត ល្អិត សៅហ្មង ប្រណីត ថាវរៈ និងចាស់ណាមួយ ។ ដោយពិត ភិក្ខុរមែងជាអ្នកសន្តោសដោយបច្ច័យតាមដែលបានហើយជាដើមតាមមានតាមបាន គឺយ៉ាងណានីមួយ ក្នុងចីវរសន្តោស មាន ៣ គឺយថាលាភសន្តោស ១ យថាពលសន្តោស ១ យថាសារុប្បសន្តោស ១ ។ ក្នុងបិណ្ឌបាតជាដើម ក៏ន័យនេះដូចគ្នា ។ រឿងពិស្តារនៃសន្តោសទាំងនោះ គប្បីជ្រាបដោយន័យដែលលោកពោលហើយ ក្នុងព្រះសូត្រនេះថា ម្នាលភិក្ខុទាំងឡាយ កុសលធម៌ ដែលមិនទាន់កើតឡើង រមែងកើតឡើង ដល់ភិក្ខុដែលសន្តោស ដូច្នេះជាដើម ។

ដូច្នោះ លោកសំដៅដល់សន្តោស ៣ យ៉ាងនេះ ទើបពោលថា ភិក្ខុជាអ្នកសន្តោសដោយចីវរតាមមានតាមបាន គឺជាអ្នកសន្តោសដោយចីវរតាមដែលបានពោលហើយជាដើមឯណានីមួយ ដូច្នេះ ។ ចីវរសន្តោសនេះ ភិក្ខុគប្បីស្គាល់ចីវរ គប្បីស្គាល់ខេត្តចីវរ គប្បីស្គាល់បង្សុកូលចីវរ គប្បីស្គាល់សន្តោសដោយចីវរ គប្បីស្គាល់ធុតង្គដែលទាក់ទងជាមួយចីវរ ក្នុងសេចក្តីនោះ ពាក្យថា គប្បីស្គាល់ចីវរ បានដល់ គប្បីស្គាល់កប្បិយចីវរ ១២ ប្រភេទ គឺចីវរ ៦ ដែលធ្វើដោយសម្បកឈើជាដើម និងចីវរដែលអនុលោម ៦ ដែលធ្វើដោយសំពត់សាច់ល្អជាដើម ។ និងគប្បីស្គាល់អកប្បិយចីវរ

ជាដើមយ៉ាងនេះ គឺចីវរដែលធ្វើដោយក្រងសម្បកឈើ ចីវរដែលធ្វើដោយផ្លែ ចីវរដែលធ្វើដោយក្រងបន្ទះឈើ សំពត់កម្ពលដែលធ្វើដោយសក់មនុស្ស សំពត់ដែលធ្វើដោយស្លឹករីត ស្បែកខ្លា ស្លាបមៀម និងសំពត់ធ្វើដោយដើមឈើ សំពត់ធ្វើដោយវល្លិ សំពត់ធ្វើដោយដើមរំទឹក សំពត់ធ្វើដោយដើមចេក សំពត់ធ្វើដោយឫស្សី ។

ពាក្យថា គប្បីស្គាល់ខេត្តនៃចីវរ បានដល់ គប្បីស្គាល់ខេត្ត ៦ ដោយការកើតឡើងយ៉ាងនេះ គឺកើតដោយសង្ឃខ្លះ គណៈខ្លះ ញាតិខ្លះ មិត្រខ្លះ ទ្រព្យរបស់ខ្លួនខ្លះ បង្សុកូលខ្លះ និងគប្បីស្គាល់ខេត្ត ៨ ដោយមាតិកា ៨ ។ ពាក្យថា គប្បីស្គាល់បង្សុកូលចីវរ បានដល់ គប្បីដឹងក្នុងសំពត់បង្សុកូល ២៣ យ៉ាង គឺសំពត់ដែលគេចោលក្នុងព្រៃខ្មោច ១ សំពត់ដែលគេចោលក្នុងផ្សារ ១ សំពត់ដែលគេចោលតាមផ្លូវរថ ១ សំពត់ដែលគេចោលក្នុងគំនរសំរាម ១ សំពត់ជូតមន្ទិលគភ៌របស់ស្រីដែលកើតកូន ១ សំពត់ជូតទឹក ១ សំពត់ដែលគេចោលតាមកំពង់ជូតទឹក ឬកំពង់ធ្លង ១ សំពត់ដែលគេរុំអ្នកស្លាប់ទៅព្រៃខ្មោច ហើយនាំត្រឡប់មក ១ សំពត់ដែលត្រូវភ្លើងឆេះហើយគេចោល ១ សំពត់ដែលគោទំពាហើយគេចោល ១ សំពត់ដែលកណ្តៀរកាត់ហើយគេចោល ១ សំពត់ដែលកណ្តុរកាត់ហើយគេចោល ១ សំពត់ដែលដាច់ជុំវិញហើយគេចោល ១ សំពត់ដាច់ជាយហើយគេចោល ១ សំពត់ដែលគេធ្វើជាទង់ ១ សំពត់ដែលគេបូជាត្រង់ជំបូក ១ សំពត់របស់ភិក្ខុផងគ្នា ១ សំពត់ដែលរលកបក់ឡើងមកលើច្រាំង ១ សំពត់ក្នុងទីដែលគេចងក្នុងទី

រាជាភិសេក ១ សំពត់ដែលធ្លាក់នៅក្នុងផ្លូវ ១ សំពត់ដែលត្រូវខ្យល់ក្តួចទៅ ១ សំពត់ដែលសម្រេចដោយឫទ្ធិ ១ សំពត់ដែលទេវតាប្រគេន ១ ក្នុងរឿងសំពត់ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **សោត្ថិយំ** គឺសំពត់ដែលគេខ្ចប់មន្ទិលគភ៌ចោល ១ ។ បទថា **គតបច្ចាគតំ** សេចក្តីថា សំពត់ដែលគេរុំអ្នកស្លាប់នាំទៅកាន់ព្រៃហើយនាំត្រឡប់មក ។ បទថា **ធជាហដំ** គឺសំពត់ដែលគេឲ្យលើកជាទង់ឡើងហើយនាំត្រឡប់មកអំពីទីនោះ ។ បទថា **ថូបំ** គឺសំពត់ដែលបូជាត្រង់ដំបូក ។ បទថា **សាមុទ្ទិយំ** គឺសំពត់ដែលរលកបក់ឡើងលើច្រាំង ។ បទថា **បថិកំ** គឺសំពត់ដែលពួកមនុស្សអ្នកដើរផ្លូវវាយដោយដុំថ្ម ដណ្តប់ទៅ ព្រោះខ្លាចចោរ ។ បទថា **ឥទ្ធិមយំ** គឺចីវររបស់ឯហិភិក្ខុ ។ បទដ៏សេសជាក់ច្បាស់ហើយ ដូច្នេះ ។

ពាក្យថា គប្បីស្គាល់ចីវរសន្តោស សេចក្តីថា សន្តោសក្នុងចីវរ ២០ គឺសន្តោសដោយការត្រិះរិះ ១ សន្តោសដោយការដើរផ្លូវ ១ សន្តោសដោយការស្វែងរក ១ សន្តោសដោយការបាន ១ សន្តោសដោយការទទួលល្មមប្រមាណ ១ សន្តោសដោយការវៀរចាកការឡេះឡោះ ១ សន្តោសតាមមានតាមបាន ១ សន្តោសតាមកម្លាំង ១ សន្តោសតាមសមគួរ ១ សន្តោសដោយទឹក ១ សន្តោសដោយការបោកគក់ ១ សន្តោសដោយការធ្វើ ១ សន្តោសដោយការប៉ាន់ប្រមាណ ១ សន្តោសដោយអំបោះ ១ សន្តោសដោយការដេរ ១ សន្តោសដោយការជ្រលក់ ១ សន្តោសដោយការធ្វើកប្ប ១ សន្តោសដោយការប្រើប្រាស់ ១ សន្តោសដោយការវៀរ

ចាកការសន្សំ ១ សន្តោសដោយការលះបង់ ១ ។

ក្នុងសន្តោស ២០ នោះ ភិក្ខុដែលត្រេកអរនៅចាំវស្សាអស់ត្រៃមាស ហើយ ត្រិះរិះត្រឹមមួយខែក៏គួរ ព្រោះថា លោកបវារណាហើយ រមែងធ្វើចីវរ ក្នុងខែដែលកើតចីវរ ។ ភិក្ខុដែលសមាទានសំពត់បង្សុកូលជាវត្ត រមែងធ្វើ បានក្នុងកន្លះខែប៉ុណ្ណោះ ការត្រិះរិះអស់កាលមួយខែ ឬកន្លះខែ ដោយប្រការ ដូច្នេះ ឈ្មោះថា វិតក្កសន្តោស ។ ភិក្ខុដែលត្រេកអរដោយវិតក្កសន្តោស គប្បីដូចព្រះថេរៈដែលសមាទានសំពត់បង្សុកូលជាវត្ត នៅត្រង់បាចីនខណ្ឌ-រាជិវិហារ ។

បានឮថា ព្រះថេរៈមកដោយបំណងថា នឹងថ្វាយបង្គំព្រះចេតិយ ក្នុង ចេតិយបព៌តវិហារ ថ្វាយបង្គំព្រះចេតិយហើយ គិតថា ចីវររបស់អាត្មាអញ ចាស់ អញនឹងបានក្នុងលំនៅរបស់ភិក្ខុច្រើនរូប លោកទៅកាន់មហាវិហារ ជួបព្រះសង្ឃត្ថេរហើយ ទើបសួរដល់ទីសម្រាក ហើយនៅក្នុងវិហារនោះ ក្នុងថ្ងៃស្អែកឡើង ទើបកាន់ចីវរមកថ្វាយបង្គំព្រះថេរៈ ព្រះថេរៈពោលថា មានការអ្វីអាវុសោ ។ លោកឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំនឹងទៅកាន់ទ្វារ ស្រុក ។ ព្រះថេរៈពោលថា អាវុសោ ខ្ញុំក៏ទៅ ។ លោកទទួលថា សាធុ លោកម្ចាស់ ហើយទើបដើរទៅឈរ នៅត្រង់ខ្លោងទ្វារនៃមហាពោធិ៍ គិតថា អាត្មាអញនឹងបានចីវរដែលពេញចិត្ត ក្នុងលំនៅរបស់អ្នកមានបុណ្យទាំង-ឡាយ ហើយគិតថា ការត្រិះរិះរបស់អាត្មាអញ មិនបរិសុទ្ធ ទើបត្រឡប់ អំពីទីនោះឯង ក្នុងថ្ងៃស្អែកឡើង ទៅកាន់ទីជិតទួលឈ្មោះបេននម្ពនៈ ក្នុង

ថ្ងៃស្អែកឡើង ត្រឡប់អំពីខាងទ្វារទិសខាងជើងនៃមហាចេតិយយ៉ាងនោះដូចគ្នា ក្នុងថ្ងៃទី ៤ ក៏បានទៅកាន់សម្នាក់ព្រះថេរៈៗ គិតថា ការត្រិះរិះរបស់ភិក្ខុនេះ នឹងមិនបរិសុទ្ធ ដូច្នេះហើយ កាន់យកចីវរសួរបញ្ហា ចូលទៅកាន់ស្រុកជាមួយភិក្ខុនោះឯង ក្នុងរាត្រីនោះ មនុស្សម្នាក់ឈឺបន្ទោបង់ឧច្ចារៈ ហើយបន្ទោបង់ឧច្ចារៈលើសំពត់ ទើបចោលសំពត់នោះក្នុងគំនរសំរាម ព្រះថេរៈអ្នកសមាទានបង្សុកូលជាវត្ត ឃើញសំពត់នោះ ដែលពួកដង្កូវក្បាលខៀវចោមរោម ទើបផ្គងអញ្ជលី ព្រះថេរៈសួរថា អាវុសោ ហេតុអ្វី ទើបលោកផ្គងអញ្ជលីដល់គំនរសំរាម ។ ព្រះថេរៈនោះឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំមិនមែនផ្គងអញ្ជលីដល់គំនរសំរាម ខ្ញុំផ្គងអញ្ជលីដល់ព្រះទសពលបិតារបស់ខ្ញុំ ព្រះទសពលទ្រង់កាន់យកសំពត់ដែលគេរុំសពនាងបុណ្ណទាសី ហើយធ្វើជាសំពត់បង្សុកូល ទ្រង់រលាស់សត្វតូចៗ ប្រមាណមួយតុម្ពហើយទ្រង់កាន់យកអំពីព្រៃខ្មោច ទ្រង់ធ្វើកិច្ចដែលធ្វើបានលំបាកហើយ ។ ព្រះមហាថេរៈគិតថា ការត្រិះរិះរបស់ព្រះថេរៈអ្នកសមាទានសំពត់បង្សុកូលជាវត្តបរិសុទ្ធហើយ សូម្បីព្រះថេរៈដែលសមាទានសំពត់បង្សុកូលជាវត្ត ក៏ឈរនៅក្នុងទីនោះឯង ចម្រើនវិបស្សនា សម្រេចផលទាំង ៣ ហើយ កាន់យកសំពត់នោះ ធ្វើជាចីវរដណ្តប់ ហើយទៅកាន់បាចីនខណ្ឌរាជិវិហារ បានសម្រេចអរហត្តដែលជាអគ្គផលហើយ ។

ការដែលភិក្ខុកាលទៅដើម្បីចីវរ មិនគិតថា អាត្មាអញនឹងបានក្នុងទីណាទៅដោយមានកម្មដ្ឋានជាធំប៉ុណ្ណោះ ឈ្មោះថា **គមនសន្តោស** គឺសន្តោស

ដោយការទៅ ។ បើភិក្ខុស្វែងរកចីវរ មិនស្វែងរកជាមួយភិក្ខុធម្មតា នាំភិក្ខុដែលមានការខ្មាស គួរស្រឡាញ់ទៅស្វែងរក ឈ្មោះថា **បរិយេសន-សន្តោស** គឺសន្តោសដោយការស្វែងរក ។ ការដែលភិក្ខុស្វែងរកយ៉ាងនេះ ឃើញចីវរដែលទាយកនាំមកអំពីចម្ងាយ មិនត្រិះរិះយ៉ាងនេះថា ចីវរនោះនឹងគួរពេញចិត្ត ចីវរនោះនឹងគួរពេញចិត្ត ហើយត្រេកអរដោយចីវរដែលគ្រោតគ្រាត ឬល្អិតជាដើម តាមដែលខ្លួនបានហើយប៉ុណ្ណោះ ឈ្មោះថា **បដិលាភ-សន្តោស** គឺការសន្តោសដោយការបាន ។ ភិក្ខុកាលកាន់យកចីវរដែលខ្លួនបានហើយយ៉ាងនេះ ត្រេកអរដោយចីវរត្រឹមតែគួរដល់ខ្លួនឯងថា សំពត់ទាំងនេះ នឹងជាចីវរ ២ ជាន់ សំពត់ទាំងនេះ នឹងជាចីវរ ១ ជាន់ ដូច្នេះប៉ុណ្ណោះ ឈ្មោះថា **មត្តបដិគ្គហណសន្តោស** គឺសន្តោសដោយការទទួលយកល្មមប្រមាណ ។ ម្យ៉ាងទៀត ការដែលភិក្ខុស្វែងរកចីវរ មិនគិតថា អាត្មាអញនឹងបានចីវរដែលគួរពេញចិត្តត្រង់ទ្វារផ្ទះរបស់បុគ្គលនោះ ហើយត្រាច់ទៅតាមលំដាប់ទ្វារ ឈ្មោះថា **លោលុប្បវិវជ្ជនសន្តោស** គឺសន្តោសដោយការវៀរបង់នូវការឡេះឡោះ ។

ភិក្ខុអាចញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយចីវរដែលសៅហ្មង ឬប្រណីតណាមួយ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយចីវរដែលខ្លួនបានហើយយ៉ាងនោះឯង ឈ្មោះថា **យថាលាភសន្តោស** គឺសន្តោសដោយបច្ច័យតាមបាន ។ ការស្គាល់កម្លាំងរបស់ខ្លួន ហើយញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរដែលអាចឲ្យប្រព្រឹត្តទៅបាន ឈ្មោះថា **យថាពលសន្តោស** គឺសន្តោស

ដោយបច្ច័យតាមកម្លាំង ។ ការដែលភិក្ខុប្រគេនចីវរដែលគាប់ចិត្តដល់ភិក្ខុដទៃ ហើយ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយចីវរណាមួយរបស់ខ្លួន ឈ្មោះថា **យថាសារុប្បសន្តោស** គឺសន្តោសដោយបច្ច័យតាមសមគួរ ។

ការមិនជ្រើសរើសថា ទឹកក្នុងទីណាពេញចិត្ត ក្នុងទីណាមិនពេញចិត្ត ដូច្នេះហើយ បោកចីវរដោយទឹកដែលសមគួរបានណាមួយ ឈ្មោះថា **ឧទក-សន្តោស** គឺសន្តោសដោយទឹក ។ ភិក្ខុគួរវៀរទឹកដែលល្អក់ដោយដីក្រហម ជ័រឈើ និងស្លឹកឈើស្អុយ ។ ឯការដែលភិក្ខុបោកចីវរ មិនវាយដោយដំបង ជាដើម ញីដោយដៃ ឈ្មោះថា **ធោវនសន្តោស** គឺសន្តោសដោយការបោក ។ ម្យ៉ាងទៀត នឹងបោកចីវរដែលមិនស្អាតដោយទឹកដែលថ្លា ដាក់ស្លឹកឈើស្ងោរឲ្យក្ដៅក៏គួរ ការដែលភិក្ខុអ្នកបោកចីវរធ្វើយ៉ាងនេះ ក៏មិនញុំាងចិត្តឲ្យកម្រើកថា ចីវរនេះគ្រោតគ្រាត ចីវរនេះល្អិត ដូច្នេះហើយ ធ្វើដោយវិធីដែលឲ្យត្រឹមតែល្មមប្រមាណប៉ុណ្ណោះ ឈ្មោះថា **ករណសន្តោស** គឺសន្តោសដោយការធ្វើ ។ ការធ្វើចីវរល្មមបិទមណ្ឌល ៣ ប៉ុណ្ណោះ ឈ្មោះថា **បរិមាណ-សន្តោស** គឺសន្តោសដោយប្រមាណ ។ ម្យ៉ាងទៀត ការដែលមិនត្រាច់ទៅដោយគិតថា អញនឹងស្វែងរកអំបោះដែលពេញចិត្ត ដើម្បីធ្វើចីវរ ហើយកាន់យកអំបោះប្រភេទណាមួយនោះឯង ដែលបុគ្គលនាំមកទុកត្រង់ផ្លូវជាដើម ឬត្រង់ទេវស្ថានក្ដី ដែលគេនាំមកទុកទៀបបាតជើងក្ដី ហើយធ្វើ ឈ្មោះថា **សុត្តសន្តោស** គឺសន្តោសដោយអំបោះ ។

ក្នុងពេលភ្ជាប់សំពត់កុសិ គប្បីដេរ ៧ ជង់ ក្នុងទីមានប្រមាណ ១

ផ្លាប់ ព្រោះថា កាលបើលោកធ្វើយ៉ាងនេះ ភិក្ខុណាមិនមានសម្លាញ់ ភិក្ខុនោះ ក៏មិនខូចទំនៀម ។ តែក្នុងទីប្រមាណ ៣ ផ្លាប់ ក៏គួរដេរ ៧ ដង ។ កាលភិក្ខុធ្វើយ៉ាងនេះ សូម្បីភិក្ខុអ្នកដើរផ្លូវ ក៏គប្បីជាសម្លាញ់ពិត ។ ភិក្ខុណាមិនជាសម្លាញ់ ភិក្ខុនោះ រមែងខូចទំនៀម នេះឈ្មោះថា **សិព្វនសល្លេខ** គឺសន្លោសដោយការដេរ ។ ភិក្ខុដែលជ្រលក់ចីវរ មិនគួរស្វែងរកទឹកជ្រលក់អំពីដើមជ្រៃខ្មៅជាដើមឡើយ លោកបានទឹកជ្រលក់ដែលធ្វើអំពីដើមសោមពក្កលជាដើមណាមួយ ក៏គប្បីជ្រលក់ដោយទឹកជ្រលក់នោះ ។ កាលមិនបានយ៉ាងនោះ គប្បីកាន់យកទឹកជ្រលក់ថ្មី ដែលពួកអ្នកស្រុកកាន់យក រួចទុកក្នុងព្រៃ ឬកាកទឹកជ្រលក់ដែលពួកភិក្ខុស្ងោរចោល ហើយទើបជ្រលក់ នេះឈ្មោះថា **រជនសល្លេខ** គឺសន្លោសដោយការជ្រលក់ ។ ការដែលភិក្ខុកាន់យកពណ៌ខៀវ ពណ៌ភក់ ពណ៌ខ្មៅ និងពណ៌ខ្មៅជាំណាមួយ ធ្វើកប្ប គឺពិន្ទុ ដែលប្រាកដច្បាស់ដល់បុគ្គលដែលអង្គុយនៅលើខ្នងដំរី ឈ្មោះថា **កប្បសល្លេខ** គឺសន្លោសដោយកប្ប ។

ការប្រើប្រាស់ គ្រាន់តែបិទបាំងអវយវៈដែលធ្វើសេចក្តីខ្មាសឲ្យកម្រើកប៉ុណ្ណោះ ឈ្មោះថា **បរិភោគសល្លេខ** គឺសន្លោសដោយការប្រើប្រាស់ ។ ព្រះមហាសិវត្ថេរពោលថា ភិក្ខុបានសំពត់ហើយ តែមិនទាន់បានអំបោះក្តី ម្ជុលក្តី អ្នកធ្វើក្តី រក្សាទុកក៏គួរ តែកាលបានម្ជុលជាដើម រក្សាទុកមិនគួរ សូម្បីចីវរដែលធ្វើហើយ បើលោកបំណងនឹងឲ្យដល់សហធម្មិក មានអន្តេវាសិកជាដើម តែអន្តេវាសិកទាំងនោះមិននៅព្រមគ្នា រក្សាទុករង់ចាំការមក

ក៏គួរ កាលអន្តេវាសិកជាដើមមកដល់ហើយ គួរឲ្យនោះឯង បើមិនអាចឲ្យ គួរអធិដ្ឋានទុក កាលត្រៃចីវរជទៃមាន ទោះអធិដ្ឋានជាសំពត់ក្រាលដេកក៏គួរ ព្រោះថា ចីវរដែលមិនអធិដ្ឋាននោះឯង រមែងជាសន្និធិពិត ចីវរដែល អធិដ្ឋានហើយ មិនជាសន្និធិឡើយ នេះឈ្មោះថា **សន្និធិបរិវជ្ជនសល្លេខ** គឺសន្តោសដោយការវៀរនូវការសន្សំ ។ ម្យ៉ាងទៀត ភិក្ខុកាលលះបង់ មិន គួរឲ្យព្រោះយល់មុខ គប្បីតាំងនៅក្នុងសារាណីយធម៌ ហើយលះបង់ឲ្យ ដូច្នេះនេះ ឈ្មោះថា **វិសជ្ជនសល្លេខ** សន្តោសដោយការលះបង់ ។ ពាក្យ ថា គប្បីស្គាល់ធុតង្គទាំងឡាយដែលទាក់ទងដោយចីវរ បានដល់ **បំសុ-កូលិកង្គ** អង្គនៃភិក្ខុដែលទ្រទ្រង់សំពត់បង្សុកូលជាវត្ត និង **តេចីវរិកង្គ** នៃ ភិក្ខុអ្នកទ្រទ្រង់ចីវរ ៣ ជាវត្ត គប្បីជ្រាបរឿងពិស្តារនៃធុតង្គទាំងនោះក្នុងគម្ពីរ វិសុទ្ធិមគ្គ ភិក្ខុកាលបំពេញមហាអរិយវង្ស ដែលទាក់ទងដោយចីវរសន្តោស ឈ្មោះថា រមែងរក្សាធុតង្គ ២ នេះបាន កាលរក្សាធុតង្គទាំងនេះ រមែងជា បុគ្គលសន្តោសដោយមហាអរិយវង្ស គឺចីវរសន្តោស ដោយប្រការដូច្នេះ ។

បទថា **វណ្ណវាទី** សេចក្តីថា ភិក្ខុមួយរូបជាអ្នកសន្តោស តែមិន ពោលសរសើរសន្តោស ។ ភិក្ខុមួយរូបមិនសន្តោស តែពោលសរសើរ សន្តោស មួយរូបមិនសន្តោសផង មិនពោលសរសើរសន្តោសផង ។ ភិក្ខុ មួយរូបជាអ្នកសន្តោសផង ពោលសរសើរសន្តោសផង កាលទ្រង់សម្តែង សន្តោសនោះ ទើបត្រាស់ថា **ឥតរីតរចីវរសន្តុដ្ឋិយា ច វណ្ណវាទី** ដូច្នេះ ។

បទថា **អនេសនំ** សេចក្តីថា មិនធ្វើការស្វែងរកដែលមិនសមគួរច្រើន

ប្រការ មានការធ្វើទូត គឺទទួលបម្រើដោយនាំដំណឹង ។ បទថា **អប្បដិរូបំ** ប្រែថា មិនសមគួរ ។ បទថា **អលទ្ធា ច** ប្រែថា មិនបានហើយ ។ ភិក្ខុរូបខ្លះគិតថា អញនឹងបានចីវរដូចម្ដេចហ្ន៎ នៅរួមជាមួយពួកភិក្ខុដែលមានបុណ្យទាំងឡាយ ធ្វើនូវការបោកបញ្ឆោត រមែងតក់ស្លុត យ៉ាងណា ភិក្ខុជាអ្នកសន្ដោស មិនបានចីវរ រមែងមិនតក់ស្លុត យ៉ាងនោះ ។ បទថា **លទ្ធា ច** សេចក្ដីថា បានដោយធម៌ ដោយស្មោះស្មើ ។ បទថា **អគធិតោ** គឺប្រាសចាកគ្រឿងជាប់ក្រង គឺលោភៈ ។ បទថា **អមុច្ឆិតោ** សេចក្ដីថា មិនដល់នូវការងប់ជ្រប់ដោយតណ្ហា ដែលមានប្រមាណក្រៃលែង ។ បទថា **អនជ្ឈាបន្នោ** សេចក្ដីថា ជាបុគ្គលដែលតណ្ហាមិនគ្របសង្កត់ មិនបានជាប់ក្រង ។ បទថា **អាទីនវទស្សាវី** សេចក្ដីថា ឃើញទោសក្នុងអាបត្តិដែលទាក់ទងដោយអនេសនា និងការបរិភោគលាភដែលជាប់ជំពាក់ ។ បទថា **និស្សរណាបញ្ញោ** សេចក្ដីថា ដឹងច្បាស់ដល់ឧបាយដែលដកខ្លួនចេញ ដែលលោកពោលថា ត្រឹមតែដើម្បីកម្ចាត់បង់នូវរងាប៉ុណ្ណោះ ។

បទថា **ឥតរីតរចីវរសន្តុដ្ឋិយា** សេចក្ដីថា ព្រោះសន្ដោសដោយចីវរណាមួយ ។ បទថា **នេវត្តានុក្កំសេតិ** សេចក្ដីថា រមែងមិនលើកខ្លួនថាអាត្មាអញ ទ្រទ្រង់សំពត់បង្សុកូលជាប្រក្រតី អាត្មាអញជាតំណាងរបស់ភិក្ខុដែលទ្រទ្រង់សំពត់បង្សុកូលជាប្រក្រតី ក្នុងរោងឧបសម្បទា បុគ្គលណាហ្ន៎ស្មើនឹងអាត្មាអញ ដូច្នេះ ។ បទថា **នោ បរំ វម្ភេតិ** សេចក្ដីថា មិនសង្កត់សង្កិនអ្នកដទៃយ៉ាងនេះថា ភិក្ខុដទៃទាំងនេះ មិនទ្រទ្រង់បង្សុកូលិក ឬ

ថា ភិក្ខុទាំងនោះ មិនមានសូម្បីត្រឹមតែទ្រទ្រង់សំពត់បង្សុកូល ។ បទថា **យោ ហិ តត្ថ ឧក្ខោ** សេចក្តីថា ភិក្ខុណាមានទុក្ខៈ គឺការឈ្លោះ អាច ក្នុងការៈពោលសរសើរជាដើមក្នុងជីវរសន្តោសនោះ ។ បទថា **អនលសោ** សេចក្តីថា វៀរនូវការខ្ជិលច្រអូសដោយការធ្វើជាប់តគ្នា ។ បទថា **សម្ប-ជានោ បតិស្សតោ** សេចក្តីថា ប្រកបដោយបញ្ញា គឺសម្បជញ្ញៈ និង សតិ ។ បទថា **អរិយវំសេ ឋិតោ** បានដល់ តាំងមាំហើយក្នុងអរិយវង្ស ។

បទថា **ឥតរីតរេន បិណ្ឌបាតេន** គឺដោយបិណ្ឌបាតណាមួយ ។ ក្នុង បិណ្ឌបាតសន្តោសនេះ ភិក្ខុគប្បីស្គាល់បិណ្ឌបាត គប្បីស្គាល់ខេត្តរបស់ បិណ្ឌបាត គប្បីស្គាល់សន្តោសដោយបិណ្ឌបាត គប្បីស្គាល់ធុតង្គដែល ទាក់ទងដោយបិណ្ឌបាត។ ក្នុងសេចក្តីទាំងនោះ ពាក្យថា បិណ្ឌបាត បានដល់ បិណ្ឌបាត ១៦ គឺបាយ នំស្រស់ សត្តុ ត្រី សាច់ ទឹកដោះស្រស់ ទឹកដោះជូរ សប្បិ នវនីត ប្រេង ទឹកឃ្មុំ ទឹកអំពៅ បបរ របស់គួរទំពា របស់គួរលិឍ របស់គួរភ្លក្ស ។

ពាក្យថា ខេត្តរបស់បិណ្ឌបាត បានដល់ ខេត្តរបស់បិណ្ឌបាត ១៥ គឺ សង្ឃភត្ត ១ ឧទ្ទេសភត្ត ១ និមន្តនភត្ត ១ សលាកភត្ត ១ បក្ខិកភត្ត ១ ឧបោសថិកភត្ត ១ បាដិបទិកភត្ត ១ អាគន្តុកភត្ត ១ គមិកភត្ត ១ គិលានភត្ត ១ គិលានុបដ្ឋាកភត្ត ១ ធុរភត្ត ១ កុដិភត្ត ១ វារកភត្ត ១ វិហារភត្ត ១ ។

ពាក្យថា **បិណ្ឌបាតសន្តោស** បានដល់ សន្តោសក្នុងបិណ្ឌបាត ១៥

គឺវិតក្កសន្ដោស ១ គមនសន្ដោស ១ បរិយេសនសន្ដោស ១ បដិលាភសន្ដោស ១ បដិគ្គហនសន្ដោស ១ មត្តបដិគ្គហនសន្ដោស ១ លោលុប្បវិសជ្ជនសន្ដោស ១ យថាសន្ដោស ១ យថាពលសន្ដោស ១ យថាសារុប្បសន្ដោស ១ ឧបការសន្ដោស ១ បរិមាណសន្ដោស ១ បរិភោគសន្ដោស ១ សន្និធិបរិវជ្ជនសន្ដោស ១ វិសជ្ជនសន្ដោស ១ ។

ក្នុងសន្ដោសទាំងនោះ ភិក្ខុដែលត្រេកអរ លុបមុខស្រេចហើយ ទើបត្រិះរិះ ។ ឯបិណ្ឌបាតិកភិក្ខុ ទៅព្រមដោយគណៈក្នុងពេលបម្រើព្រះថេរៈក្នុងពេលល្ងាច គិតប៉ុណ្ណោះថា ស្អែកនេះនឹងត្រាច់ទៅបិណ្ឌបាតក្នុងទីណាក្នុងស្រុកនោះ ដូច្នេះហើយ មិនគប្បីត្រិះរិះបន្ដអំពីនោះ ។ ភិក្ខុដែលត្រាច់ទៅមួយរូប គប្បីឈរត្រិះរិះក្នុងរោងវិតក្ក ។ កាលត្រិះរិះបន្ទាប់អំពីនោះ ឈ្មោះថា ឃ្លាតឆ្ងាយអំពីអរិយវង្ស នេះឈ្មោះថា **វិតក្កសន្ដោស** គឺសន្ដោសដោយការត្រិះរិះ ។

កាលចូលទៅដើម្បីបិណ្ឌបាត ក៏មិនគិតថា អញនឹងបានក្នុងទីណា គប្បីទៅដោយប្រាថ្នាកម្មដ្ឋានជាធំ នេះឈ្មោះថា **គមនសន្ដោស** គឺសន្ដោសដោយការទៅ ។ កាលស្វែងរកក៏មិននាំភិក្ខុចម្មតាទៅ គប្បីនាំភិក្ខុដែលខ្មាសគួរស្រឡាញ់ប៉ុណ្ណោះទៅស្វែងរក នេះឈ្មោះថា **បរិយេសនសន្ដោស** គឺសន្ដោសដោយការស្វែងរក ។ លោកឃើញបិណ្ឌបាតដែលគេនាំមកអំពីចម្ងាយ មិនគប្បីកើតចិត្តគិតថា នុ៎ះរបស់គាប់ចិត្ត មិនគាប់ចិត្ត ដូច្នេះ នេះឈ្មោះថា **បដិលាភសន្ដោស** គឺសន្ដោសដោយការបាន ។ លោកមិនគិតថា

អញនឹងទទួលវត្ថុនេះដែលពេញចិត្ត នឹងមិនទទួលវត្ថុ ដែលមិនពេញចិត្ត ដូច្នេះហើយ គប្បីទទួលណាមួយ ដែលល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅប៉ុណ្ណោះ នេះឈ្មោះថា **បដិគ្គហណសន្តោស** គឺសន្តោសដោយការទទួល ។ ក្នុងបដិគ្គហនសន្តោសប្បច្ច័យនេះ ទេយ្យធម៌មានច្រើន ទាយកបំណងនឹងប្រគេនតិច លោកគប្បីទទួលតិច ទេយ្យធម៌មានច្រើន ទាយកក៏បំណងឲ្យច្រើន គប្បីទទួលល្មមប្រមាណប៉ុណ្ណោះ ។ ទេយ្យធម៌មិនមានច្រើនផង ទាយកបំណងនឹងឲ្យតិចផង លោកគប្បីទទួលតែបន្តិច ។ ទេយ្យធម៌មិនមានច្រើន ចំណែកទាយកបំណងនឹងប្រគេនច្រើន លោកគប្បីទទួលដោយប្រមាណ ។ ដ្បិតថា ភិក្ខុដែលមិនដឹងប្រមាណក្នុងការទទួល រមែងទម្លាយនូវសេចក្ដីជ្រះថ្លារបស់ពួកមនុស្ស ញ៉ាំងសទ្ធាទេយ្យឲ្យធ្លាក់ចុះ ។ មិនធ្វើតាមពាក្យប្រៀនប្រដៅ រមែងមិនអាចទាញចិត្ត សូម្បីរបស់មាតាបានឡើយ ។ លោកស្គាល់ប្រមាណហើយ គប្បីទទួលដោយអាការយ៉ាងនេះឯង នេះឈ្មោះថា **មត្តបដិគ្គហណសន្តោស** គឺសន្តោសដោយការទទួលល្មមប្រមាណ ។ ភិក្ខុមិនទៅចំពោះត្រកូលស្ដុកស្ដម្ភប៉ុណ្ណោះ ដើរទៅតាមលំដាប់ទ្វារ នេះឈ្មោះថា **លោលុប្បវិវជ្ជនសន្តោស** គឺសន្តោសដោយការវៀរចាកការខ្វេះខ្វាះ ។ យថាលាភសន្តោសជាដើម មានន័យដូចពោលក្នុងចីវរហើយ ។

ការបរិភោគបិណ្ឌបាតហើយ ដឹងនូវឧបការៈយ៉ាងនេះថា អាត្មាអញនឹងរក្សាសមណធម៌ ដូច្នេះ បរិភោគ ឈ្មោះថា **ឧបការសន្តោស** គឺសន្តោសដោយឧបការៈ ។ លោកមិនគប្បីទទួលបាត្រដែលបុគ្គលដាក់ពេញមកប្រគេន

កាលអនុបសម្បន្នមាន គប្បីឲ្យអនុបសម្បន្ននោះទទួល កាលមិនមាន លោកឲ្យបុគ្គលនោះយកចេញខ្លះ ទទួលតែល្មមទទួលបាន នេះឈ្មោះថា **បរិមាណសន្តោស** គឺសន្តោសដោយប្រមាណ ។ ការបរិភោគដោយគិតយ៉ាងនេះថា ជាការបន្ទោបង់នូវការឃ្លាន នេះជាឧបាយបន្ទោបង់ក្នុងការឃ្លាននេះ នេះឈ្មោះថា **បរិភោគសន្តោស** គឺសន្តោសដោយការបរិភោគ ។ លោកមិនគប្បីរក្សាទុកបរិភោគ នេះឈ្មោះថា **សន្និធិបរិវជ្ជនសន្តោស** គឺសន្តោសដោយការវៀរចាកការសន្សំ ។ លោកមិនយល់មុខ តាំងនៅក្នុងសារណីយធម៌ គប្បីលះបង់ នេះឈ្មោះថា **វិសជ្ជនសន្តោស** គឺសន្តោសដោយការលះបង់ ។ ឯធុតង្គ ៥ ដែលទាក់ទងដោយបិណ្ឌបាត គឺបិណ្ឌបាតិកង្គ សបទានចារិកង្គ ឯកាសាសនិកង្គ បត្តបិណ្ឌិកង្គ ខលុបច្ឆាភត្តិកង្គ ។ ធុតង្គទាំងនោះមានរឿងពិស្តារ បានពោលហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។ ភិក្ខុបំពេញមហាអរិយវង្ស ទាក់ទងដោយបិណ្ឌបាតសន្តោស រមែងរក្សាធុតង្គ ៥ នេះ កាលរក្សាធុតង្គ ៥ នេះ ឈ្មោះថាជាអ្នកសន្តោសដោយអរិយវង្ស ទាក់ទងដោយបិណ្ឌបាតសន្តោស ។ បទថា **វណ្ណវាទី** ដូច្នេះជាដើម គប្បីជ្រាបដោយន័យដែល ពោលហើយ ។

ក្នុងបទថា **សេនាសនេន** នេះ គប្បីស្គាល់សេនាសនៈ គប្បីស្គាល់ខេត្តសេនាសនៈ គប្បីស្គាល់សន្តោសដោយសេនាសនៈ គប្បីស្គាល់ធុតង្គដែលទាក់ទងដោយសេនាសនៈ ក្នុងសេចក្តីទាំងនោះ ពាក្យថា **សេនាសន** បានដល់ សេនាសនៈទាំងឡាយ ១៥ គឺគ្រែ ១ តាំង ១ ពូក ១ ខ្នើយ ១

វិហារ ១ អឌ្ឍយោគ ១ ប្រាសាទ ១ ប្រាសាទជំបូលត្រនិល ១ គុហា ១ លេណា ( ទីសម្ងំ ) ១ ប៉ម ១ បង្ហា ១ គុម្ពឫស្សី ១ គល់ឈើ ១ ឬទីដែលពួកភិក្ខុចៀសចេញទៅ ១ ។

ពាក្យថា ខេត្តនៃសេនាសនៈ បានដល់ ខេត្ត ៦ គឺដោយសង្ឃក្តី គណៈក្តី ញាតិក្តី មិត្រក្តី ទ្រព្យរបស់ខ្លួនក្តី សំពត់បង្សុកូលក្តី ។

ពាក្យថា សេនាសនសន្តោស បានដល់ សន្តោសក្នុងសេនាសនៈ ១៥ មានវិតក្កសន្តោសជាដើម ។ សន្តោសទាំងនោះ គប្បីជ្រាបដោយន័យដែលពោលហើយក្នុងបិណ្ឌបាត ។ ឯធុតង្គ ៥ ដែលទាក់ទងដោយសេនាសនៈ គឺអារញ្ញិកង្គ ១ រុក្ខមូលិកង្គ ១ អព្ភោកាសិកង្គ ១ សោសានិកង្គ ១ យថាសណ្ឋតិកង្គ ១ ។ រឿងពិស្តាររបស់លធុតង្គទាំងនោះបានពោលហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។ ភិក្ខុដែលបំពេញមហាអរិយវង្ស ទាក់ទងដោយសេនាសនសន្តោស រមែងរក្សាធុតង្គទាំង ៥ នេះបាន កាលរក្សាធុតង្គទាំងនេះ រមែងឈ្មោះថាជាអ្នកសន្តោសដោយមហាអរិយវង្ស ដែលទាក់ទងដោយសេនាសនសន្តោស ឯគិលានប្បច្ច័យ ក៏នៅក្នុងបិណ្ឌបាតនោះឯង ។ ភិក្ខុគប្បីត្រេកអរក្នុងគិលានប្បច្ច័យនោះ ដោយយថាលាភសន្តោស យថាពលសន្តោស យថាសារុប្បសន្តោសប៉ុណ្ណោះ ។ នេសជ្ជិកង្គ រមែងចាត់ចូលក្នុងអរិយវង្ស គឺត្រេកអរក្នុងភាវនា ដោយប្រការដូច្នេះ សមដូចលោកពោលថា

**បញ្ច សេនាសនេ វុត្តា បញ្ច អាហារនិស្សិតា**

**ឯកោ វីរិយសញ្ញុត្តោ ទ្វេ ច ចីវរនិស្សិតា ។**

ធុតង្គ ៥ យ៉ាង លោកពោលទុកក្នុងសេនាសនៈ អាស្រ័យអាហារ ៥ យ៉ាង ប្រកបដោយសេចក្តីព្យាយាម ១ និងអាស្រ័យចីវរ ២ យ៉ាង ដូច្នេះ ។

ព្រះមានព្រះភាគ ត្រាស់អរិយវង្ស គឺចីវរសន្តោសដោយប្រការដំបូង ដូចទ្រង់ក្រាលផែនដី ដូចទ្រង់ធ្វើមហាសមុទ្រឲ្យពេញ ដូចទ្រង់ពង្រីកអាកាសឲ្យទូលាយចេញហើយ ទើបត្រាស់បិណ្ឌបាតសន្តោសជាលំដាប់ទី ២ ដូចទ្រង់ឲ្យព្រះចន្ទរះឡើង និងដូចទ្រង់ធ្វើព្រះអាទិត្យឲ្យរះឡើង ត្រាស់អរិយវង្ស គឺសេនាសនសន្តោសជាប្រការទី ៣ ដូចទ្រង់លើកភ្នំសិនេរុឡើង ឥឡូវនេះ កាលត្រាស់អរិយវង្ស គឺត្រេកអរក្នុងភាវនាជាប្រការទី ៤ ដែលប្រកបដោយន័យ ១០០០ ទ្រង់ផ្តើមទេសនាថា **បុន ច បរំ ភិក្ខវេ ភិក្ខុ ភាវនារាមោ ហោតិ** ជាដើម ។

ក្នុងបទថា **ភាវនារាមោ** នោះ សេចក្តីត្រេកអរ ឈ្មោះថា **អារាម** អធិប្បាយថា ត្រេកអរក្រៃលែង ។ ឈ្មោះថា **ភាវនារាម** ព្រោះភិក្ខុនោះត្រេកអរក្នុងភាវនា ឈ្មោះថា **ភាវនារត** ព្រោះត្រេកអរហើយក្នុងភាវនា ។ ដែលឈ្មោះថា **បហានារាម** ព្រោះត្រេកអរក្នុងបហាន គឺការលះ ៥ យ៉ាង ម្យ៉ាងទៀត ឈ្មោះថា **ភាវនារាម** ព្រោះចម្រើន ទើបត្រេកអរ ឈ្មោះថា **បហានារាម** ព្រោះលះបង់ ទើបត្រេកអរ ។ ក្នុងភាវនា និងបហាននេះ

គប្បីជ្រាបយ៉ាងនេះថា ។ ពិតហើយ ភិក្ខុនេះចម្រើនសតិប្បដ្ឋាន ៤ រមែងត្រេកអរ អធិប្បាយថា រមែងបាននូវការត្រេកអរ ចម្រើនសម្មប្បធាន ៤ ក៏ដូចគ្នា កាលចម្រើនឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ អនុបស្សនា ៧ មហាវិបស្សនា ១៨ ពោធិបក្ខិយធម៌ ៣៧ ចម្រើនការបែកអារម្មណ៍ ៣៨ រមែងត្រេកអរ រមែងបាននូវការត្រេកអរ ។ម្យ៉ាងទៀត លះកិលេស មានកាមច្ឆន្ទៈជាដើម ក៏ត្រេកអរ បាននូវការត្រេកអរ ។ ឯក្នុងអរិយវង្ស ៤ នេះ វិនយបិដកទាំងមូល ជាការត្រាស់ដោយធុតង្គ ១៣ និងសន្តោសដោយបច្ច័យ ៤ ដោយអរិយវង្សប្រការដំបូង បិដក ២ ដ៏សេសត្រាស់ដោយអរិយវង្ស គឺការត្រេកអរក្នុងភាវនា ។ ភិក្ខុកាលពោលអរិយវង្ស គឺការត្រេកអរក្នុងភាវនានេះ គប្បីពោលដោយនេក្ខម្មបាលី ក្នុងបដិសម្ភិទាមគ្គ គប្បីពោលដោយបរិយាយនៃទសុត្តរសូត្រ ក្នុងទីឃនិកាយ គប្បីពោលដោយបរិយាយនៃសតិប្បដ្ឋានសូត្រ ក្នុងមជ្ឈិមនិកាយ គប្បីពោលដោយបរិយាយនៃនិទ្ទេសក្នុងអភិធម្ម ។

បណ្តាពាក្យទាំងនោះ ពាក្យថា គប្បីពោលដោយនេក្ខម្មបាលី ក្នុងបដិសម្ភិទាមគ្គ បានដល់ គប្បីពោលតាមនេក្ខម្មបាលី ក្នុងបដិសម្ភិទាមគ្គយ៉ាងនេះថា លោកកាលចម្រើននេក្ខម្មៈក៏ត្រេកអរ លះកាមច្ឆន្ទៈក៏ត្រេកអរ កាលចម្រើនអព្យាបាទក៏ត្រេកអរ លះព្យាបាទក៏ត្រេកអរ កាលចម្រើនអាលោកសញ្ញាក៏ត្រេកអរ លះថីនមិទ្ធៈក៏ត្រេកអរ កាលចម្រើនការមិនអណ្តែតអណ្តូងក៏ត្រេកអរ លះឧទ្ធច្ចៈក៏ត្រេកអរ កាលចម្រើនការកំណត់នូវ

ធម៌ក៏ត្រេកអរ លះវិចិកិច្ឆាក៏ត្រេកអរ កាលចម្រើនញាណក៏ត្រេកអរ លះអវិជ្ជាក៏ត្រេកអរ កាលចម្រើនបាមុជ្ជក៏ត្រេកអរ លះអរតិក៏ត្រេកអរ កាលចម្រើនបឋមជ្ឈានក៏ត្រេកអរ លះនីវរណៈក៏ត្រេកអរ កាលចម្រើនទុតិយជ្ឈានក៏ត្រេកអរ លះវិតក្ក និងវិចារក៏ត្រេកអរ កាលចម្រើនតតិយជ្ឈានក៏ត្រេកអរ លះបីតិក៏ត្រេកអរ កាលចម្រើនចតុត្ថជ្ឈានក៏ត្រេកអរ លះសុខនិងទុក្ខក៏ត្រេកអរ កាលចម្រើនអាកាសានញ្ចាយតនសមាបត្តិក៏ត្រេកអរ លះរូបសញ្ញា បដិឃសញ្ញា នានត្តសញ្ញាក៏ត្រេកអរ កាលចម្រើនវិញ្ញាណញ្ចាយតនសមាបត្តិ ។បេ។ នេវសញ្ញានាសញ្ញាយតនសមាបត្តិក៏ត្រេកអរ លះអាកិញ្ចញ្ញាយតនសមាបត្តិក៏ត្រេកអរ ។

កាលចម្រើនអនិច្ចានុបស្សនាក៏ត្រេកអរ លះនិច្ចសញ្ញាក៏ត្រេកអរ កាលចម្រើនទុក្ខានុបស្សនាក៏ត្រេកអរ លះសុខសញ្ញាក៏ត្រេកអរ កាលចម្រើនអនត្តានុបស្សនាក៏ត្រេកអរ លះអត្តសញ្ញាក៏ត្រេកអរ កាលចម្រើននិព្វិទានុបស្សនាក៏ត្រេកអរ លះនន្ទិក៏ត្រេកអរ កាលចម្រើនវិរាគានុបស្សនាក៏ត្រេកអរ លះរាគៈក៏ត្រេកអរ កាលចម្រើននិរោធានុបស្សនាក៏ត្រេកអរ លះសមុទយៈក៏ត្រេកអរ កាលចម្រើនបដិនិស្សគ្គានុបស្សនាក៏ត្រេកអរ លះការប្រកាន់មាំក៏ត្រេកអរ កាលចម្រើនខយានុបស្សនាក៏ត្រេកអរ លះសេចក្ដីសម្គាល់ថាជាប់នៅរឹងប៉ឹងក៏ត្រេកអរ កាលចម្រើនវយានុបស្សនាក៏ត្រេកអរ លះការប្រមូលមកក៏ត្រេកអរ កាលចម្រើនវិបរិណាមានុបស្សនាក៏ត្រេកអរ លះការសម្គាល់ថាមាំមួនក៏ត្រេកអរ កាលចម្រើនអនិមិត្តានុបស្សនាក៏ត្រេកអរ

លះការកំណត់ថាទៀងក៏ត្រេកអរ កាលចម្រើនអប្បណិហិតានុបស្សនាក៏ត្រេកអរ លះសេចក្តីប្រាថ្នាក៏ត្រេកអរ កាលចម្រើនសុញ្ញតានុបស្សនាក៏ត្រេកអរ លះសេចក្តីប្រកាន់ក៏ត្រេកអរ កាលចម្រើនអធិប្បញ្ញា និងធម្មវិបស្សនាក៏ត្រេកអរ លះសេចក្តីប្រកាន់មាំ និងការប្រកាន់ស្អិត ថាមានខ្លឹមក៏ត្រេកអរ កាលចម្រើនយថាភូតញ្ញាណទស្សនៈក៏ត្រេកអរ លះសេចក្តីប្រកាន់ដោយការវង្វេងខ្វាំងក៏ត្រេកអរ កាលចម្រើនអាទីនវានុបស្សនាក៏ត្រេកអរ លះសេចក្តីប្រកាន់ដោយអាល័យក៏ត្រេកអរ កាលចម្រើនបដិសង្ខានុបស្សនាក៏ត្រេកអរ លះការមិនពិចារណាក៏ត្រេកអរ កាលចម្រើនវិវដ្តានុបស្សនាក៏ត្រេកអរ លះសេចក្តីប្រកាន់ដោយការប្រកប ក៏ត្រេកអរ កាលចម្រើនសោតាបត្តិមគ្គក៏ត្រេកអរ លះកិលេសទាំងឡាយដែលឋិតនៅក្នុងទីតែមួយជាមួយ និងទិដ្ឋិក៏ត្រេកអរ កាលចម្រើនសកទាគាមិមគ្គក៏ត្រេកអរ លះកិលេសទាំងឡាយដ៏គ្រោតគ្រាតក៏ត្រេកអរ កាលចម្រើនអនាគាមិមគ្គក៏ត្រេកអរ លះកិលេសទាំងឡាយដ៏ល្អិតក៏ត្រេកអរ កាលចម្រើនអរហត្តមគ្គក៏ត្រេកអរ លះកិលេសទាំងអស់ក៏ត្រេកអរ ដូច្នេះ ។[១]

ពាក្យថា ដោយបរិយាយនៃទសុត្តរសូត្រ ក្នុងទីឃនិកាយ បានដល់ គប្បីពោលដោយបរិយាយនៃទសុត្តរសូត្រ ក្នុងទីឃនិកាយយ៉ាងនេះថា កាលចម្រើនធម៌មួយក៏ត្រេកអរ លះធម៌មួយក៏ត្រេកអរ ។បេ។ កាលចម្រើនធម៌

១- បិដក ៦៩ ឃ្នាប ៧៣ ។ តែក្នុងទីនេះ លោកគ្រាន់តែកាន់យកន័យហើយលើកយកមកប៉ុណ្ណោះ ។

១០ ក៏ត្រេកអរ លះធម៌ ១០ ក៏ត្រេកអរ កាលចម្រើនធម៌ ១ ក៏ត្រេកអរ តើដូចម្តេច គឺកាយគតាសតិដែលប្រកបដោយសេចក្តីត្រេកអរ ( សេចក្តីសុខ ) ឈ្មោះថា ចម្រើនធម៌ ១ ក៏ត្រេកអរ កាលលះបង់ធម៌ ១ ក៏ត្រេកអរ តើដូចម្តេច គឺអស្មិមានះ ឈ្មោះថា លះធម៌ ១ ក៏ត្រេកអរ កាលចម្រើនធម៌ ២ ក៏ត្រេកអរ តើដូចម្តេច ។បេ។ កាលចម្រើនធម៌ ១០ ក៏ត្រេកអរ តើដូចម្តេច គឺកសិណាយតនៈ ១០ ។ ឈ្មោះថា ចម្រើនធម៌ ១០ ទាំងនេះក៏ត្រេកអរ ។ កាលលះធម៌ ១០ ក៏ត្រេកអរ តើដូចម្តេច គឺសភាពដែលខុស ១០ យ៉ាង ឈ្មោះថា លះធម៌ ១០ ទាំងនេះក៏ត្រេកអរ ភិក្ខុជាអ្នកមានភាវនាជាទីត្រេកអរយ៉ាងនេះឯង ។[១]

ពាក្យថា គប្បីពោលដោយបរិយាយនៃសតិប្បដ្ឋានសូត្រ ក្នុងមជ្ឈិមនិកាយ បានដល់ គប្បីពោលដោយបរិយាយនៃសតិប្បដ្ឋានសូត្រ ក្នុងមជ្ឈិមនិកាយយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ផ្លូវ គឺសតិប្បដ្ឋានទាំង ៤ ជាផ្លូវមូលតែមួយ ។បេ។ ល្មមតែកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ភិក្ខុនោះមានចិត្តមិនអាស្រ័យ ( តណ្ហានិស្ស័យ និងទិដ្ឋិនិស្ស័យ ) គ្រប់ឥរិយាបថទាំង ៤ មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលជាបុគ្គលមានភាវនាជាទីត្រេកអរត្រេកអរហើយ ក្នុងភាវនាយ៉ាងនេះឯង ។ ជាអ្នកមានបហានជាទីត្រេកអរ

---

១- ក្នុងទីនេះ លោកមិនបានលើកយកទសុត្តរសូត្រទាំងស្រុងនោះឡើយ លោកលើកយកតែន័យមកប៉ុណ្ណោះ ។

ត្រេកអរហើយក្នុងបហាន ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុនោះ ដើរក្តី ក៏ដឹងច្បាស់ថា អាត្មាអញកំពុងដើរ ។បេ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុគប្បីឃើញសរីរៈស្លាប់ ដែលគេចោលក្នុងព្រៃស្មសាន ។បេ។ នៅសល់តែរាងឆ្អឹងទទេ ពុកផុយខ្ទិចខ្ទី ផុយជាលម្អិតតូចលម្អិតធំ ។ ភិក្ខុនោះ ( បង្អោនសរីរៈស្លាប់នោះ ) មកប្រៀបផ្ទឹមនឹងកាយនេះឯងថា សូម្បីកាយនេះសោត ក៏គង់នឹងសភាពជារបស់គួរខ្ពើមយ៉ាងនោះ គង់នឹងមានប្រភេទក្លាយទៅជាយ៉ាងនោះ នឹងកន្លងចាកសភាពយ៉ាងនោះពុំបានឡើយ ។ ភិក្ខុពិចារណារឿយៗ នូវកាយក្នុងកាយជាខាងក្នុង ។បេ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុជាអ្នកមានការនាជាទីត្រេកអរ យ៉ាងនេះ ។

ពាក្យថា គប្បីពោលដោយបរិយាយនៃនិទ្ទេសក្នុងអភិធម្ម បណ្ឌិតគប្បីពោលដោយបរិយាយនៃនិទ្ទេសយ៉ាងនេះថា លោកកាលឃើញសង្ខ-តធម៌ទាំងពួង ដោយភាពជាវត្ថុមិនទៀង ជាទុក្ខ ជារោគ ជាបូស ។បេ។ មានគ្រឿងសៅហ្មងជាធម្មតា រមែងត្រេកអរ ។ ភិក្ខុដែលជាអ្នកមានការនាជាទីត្រេកអរយ៉ាងនេះឯង ។

បទថា **នេវត្តានុក្កំសេតិ** សេចក្តីថា ភិក្ខុរមែងមិនធ្វើការលើកខ្លួនយ៉ាងនេះថា កាលអាត្មាអញ ធ្វើកម្មក្នុងវិបស្សនាថាមិនទៀង ជាទុក្ខ ជាអនត្តាមកអស់កាល ៦០-៧០ ឆ្នាំ សូម្បីបច្ចុប្បន្ននេះ បុគ្គលណាហ្ន៎ ដែលជាអ្នកស្មើអាត្មាអញ ដូច្នេះ ។ បទថា **នោ បរំ វម្ភេតិ** សេចក្តីថា រមែងមិនធ្វើការសង្កត់អ្នកដទៃយ៉ាងនេះថា សូម្បីត្រឹមវិបស្សនាថាមិនទៀង ជាទុក្ខ ដូច្នេះ ក៏

មិនមាន ហេតុអ្វី ទើបជនទាំងនេះរំលងកម្មដ្ឋានត្រាច់ទៅ ដូច្នេះ ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។

បទថា **ឥមេ ខោ ភិក្ខវេ ចត្តារោ អរិយវំសា** សេចក្ដីថា ព្រះមានព្រះភាគទ្រង់បញ្ជាក់ព្រះសូត្រថា ម្នាលភិក្ខុទាំងឡាយ អរិយវង្ស ទាំងឡាយ ៤ ជាវង្សរបស់ព្រះអរិយៈ ជាខ្សែស្រឡាយរបស់ព្រះអរិយៈ ជាផ្លូវរបស់ព្រះអរិយៈ ជាគន្លងរបស់ព្រះអរិយៈ ដូច្នេះ ។ ឥឡូវនេះ កាលទ្រង់សម្ដែងឥស្សរៈ ដោយភិក្ខុដែលជាអ្នកបំពេញមហាអរិយវង្ស ទើបត្រាស់ថា **ឥមេហិ ច បន ភិក្ខវេ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **សោវ អរតឹ សហតិ** សេចក្ដីថា អ្នកប៉ុណ្ណោះ រមែងគ្របសង្កត់បាននូវការមិនត្រេកអរ ការមិនត្រេកអរក្រៃលែង ការធុញទ្រាន់ចេញបាន ។ បទថា **ន តំ អរតិ សហតិ** សេចក្ដីថា ឈ្មោះថា ការមិនត្រេកអរ ក្នុងការចម្រើនអធិកុសល ក្នុងសេនាសនៈដ៏ស្ងាត់នោះឯណា ការមិនត្រេកអរនោះ រមែងមិនអាចគ្របសង្កត់ភិក្ខុនោះបាន ។ បទថា **អរតិរតិសហោ** សេចក្ដីថា ភិក្ខុអ្នកមានបញ្ញាបំបាក់បង់ អាចគ្របសង្កត់នូវការមិនត្រេកអរ និងការត្រេកអរក្នុងកាមគុណ ៥ ។

បុគ្គលនេះ កាលទ្រង់កាន់យកកំពូលធម៌ដោយគាថាទាំងឡាយ ទើបត្រាស់ពាក្យថា **នារតី** ជាដើម ។ ក្នុងបទទាំងនោះ បទថា **ធីរំ** គឺជាអ្នកមានសេចក្ដីព្យាយាម ។ បទថា **នារតី ធីរសំហតិ** នេះ ជាពាក្យពោលហេតុនៃបទដំបូង ។ ព្រោះហេតុដែលការមិនត្រេកអរ មិនញាំញីភិក្ខុដែល

មានបញ្ញា គឺរមែងមិនអាចញ៉ាំញី គឺគ្របសង្កត់ភិក្ខុដែលមានបញ្ញាបាន ដូច្នោះ ទើបការមិនត្រេកអរមិនញ៉ាំញីភិក្ខុដែលមានបញ្ញាឡើយ ។ បទថា **ធីរោ ហិ អរតីសហោ** សេចក្តីថា ព្រោះហេតុដែលភិក្ខុជាអ្នកសង្កត់សង្កិន ការមិនត្រេកអរបាន ឈ្មោះថា ជាអ្នកមានបញ្ញា ព្រោះសង្កត់ការមិនត្រេកអរ បាន ដូច្នោះ ទើបលោកសង្កត់ការមិនត្រេកអរបាន ។ បទថា **សព្វកម្ម-វិហាយិនំ** សេចក្តីថា ភិក្ខុលះនូវកម្ម ប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងពួងហើយ គឺកាត់ផ្តាច់ផ្លូវជុំវិញហើយ ។ បទថា **បនុណ្ណំ កោ និវារយេ** សេចក្តីថា រាគៈក្តី ទោសៈក្តី អ្វីនឹងមកការពាំងបុគ្គលដែលបន្ទោបង់កិលេសទាំងឡាយបាន ហើយ ។ បទថា **នេក្ខំ ជម្ពោនទស្សេវ កោ តំ និន្ទិតុមរហតិ** សេចក្តីថា បុគ្គលណាហ្ន៎នឹងតិះដៀលបុគ្គលនោះ ដែលរួចផុតចាកទោស ដែលគប្បី តិះដៀល ដូចដុំមាសធម្មជាតិ ដែលហៅថា ជម្ពូនុទ ។ បទថា **ព្រហ្មុនាបិ បសំសិតោ** សេចក្តីថា សូម្បីព្រហ្មក៏សរសើរបុគ្គលនោះ ។ ក្នុងវេលាចប់ទេសនា ភិក្ខុ ៤ ម៉ឺនរូបក៏តាំងនៅក្នុង ព្រះអរហត្ត ។

**អដ្ឋកថាអរិយវង្សសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## ធម្មបទសូត្រទី ៩

[ ៣០ ] ម្នាលភិក្ខុទាំងឡាយ ធម្មបទ ៤ យ៉ាងនេះ ជាច្បាប់ទម្លាប់ គប្បីដឹងអស់រាត្រីដ៏វែង ជាបវេណី ជាច្បាប់ចាស់ មិនបានច្រឡូកច្រឡំ មិនដែលច្រឡូកច្រឡំ មិនរគាត់រគាយ មិនរាត់រាយ ដែលពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញមិនអាចតិះដៀលបាន ។ ធម្មបទ ៤ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ គឺអនភិជ្ឈា ជាធម្មបទ ជាច្បាប់ទម្លាប់ គប្បីដឹងអស់រាត្រីដ៏វែង ជាបវេណី ជាច្បាប់ចាស់ មិនច្រឡូកច្រឡំ មិនដែលច្រឡូកច្រឡំ មិនរគាត់រគាយ មិនរាត់រាយ ដែលសមណព្រាហ្មណ៍ទាំងឡាយ ជាអ្នកប្រាជ្ញ មិនអាចតិះដៀលបាន ១ ម្នាលភិក្ខុទាំងឡាយ អព្យាបាទជាធម្មបទ ... ម្នាលភិក្ខុទាំងឡាយ សម្មាសតិជាធម្មបទ ... ម្នាលភិក្ខុទាំងឡាយ សម្មាសមាធិជាធម្មបទ ជាច្បាប់ទម្លាប់ គប្បីដឹងអស់រាត្រីដ៏វែង ជាបវេណី ជាច្បាប់ចាស់ មិនច្រឡូកច្រឡំ មិនដែលច្រឡូកច្រឡំ មិនរគាត់រគាយ មិនរាត់រាយ ដែលពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញ មិនអាចតិះដៀលបាន ១ ។ ម្នាលភិក្ខុទាំងឡាយ ធម្មបទ ៤ យ៉ាងនេះឯង ជាច្បាប់ទម្លាប់ គប្បីដឹងអស់រាត្រីដ៏វែង ជាបវេណី ជាច្បាប់ចាស់ មិនច្រឡូកច្រឡំ មិនដែលច្រឡូកច្រឡំ មិនរគាត់រគាយ មិនរាត់រាយ ដែលពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញ មិនអាចតិះដៀលបានឡើយ ។

ភិក្ខុ គប្បីជាអ្នកមិនមានអភិជ្ឈា មានចិត្តមិនប្រកបដោយព្យាបាទ បរិបូណ៌ដោយស្មារតី មានចិត្តតាំងនៅនឹងក្នុងអារម្មណ៍ តែមួយ មានចិត្តតាំងនៅមាំជាកណ្ដាល ។

# អដ្ឋកថា

## ធម្មបទសូត្រ

[ ៣០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងធម្មបទសូត្រទី ៩ ដូចតទៅនេះ បទថា **ធម្មបទានិ** គឺចំណែកនៃធម៌ ។ ក្នុងបទថា **អនភិជ្ឈា** ជាដើម គប្បីជ្រាបអនភិជ្ឈានដោយជាសត្រូវរបស់អភិជ្ឈា ។ **អព្យាបាទ** ដោយជាសត្រូវរបស់ព្យាបាទ **សម្មាសតិ** ដោយជាសត្រូវរបស់មិច្ឆាសតិ គប្បីជ្រាប **សម្មាសមាធិ** ដោយជាសត្រូវរបស់មិច្ឆាសមាធិ ។

បទថា **អនភិជ្ឈាលុ** គឺមិនមានតណ្ហា ។ បទថា **អព្យាបន្នេន ចេតសា** សេចក្ដីថា មានចិត្តមិនលះប្រក្រតីភាពអស់កាលទាំងពួង ។ បទថា **សតោ ឯកគ្គចិត្តស្ស** សេចក្ដីថា បុគ្គលប្រកបដោយសតិ មានចិត្តពិតប្រាកដក្នុងអារម្មណ៍តែមួយ ។ បទថា **អជ្ឈត្តំ សុសមាហិតោ** សេចក្ដីថា បុគ្គលមានចិត្តតាំងមាំដោយល្អក្នុងខាងក្នុងពិតប្រាកដ ។ ទ្រង់ត្រាស់វដ្ដៈនិងវិវដ្ដៈទុកក្នុងព្រះសូត្រផង ក្នុងគាថាផង ។

# សុត្តន្តបិដក

## បរិព្វាជកសូត្រទី ១០

[ ៣១ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ សម័យនោះ ពួកបរិព្វាជកដ៏ច្រើន ជាអ្នកចេះដឹងអាស្រ័យនៅក្នុងអារាមនៃបរិព្វាជក ក្បែរឆ្នេរស្ទឹងឈ្មោះសិប្បិនី បរិព្វាជកទាំងនោះ គឺអន្នភារបរិព្វាជក ១ វរធរបរិព្វាជក ១ សកុលុទាយិបរិព្វាជក ១ និងពួកបរិព្វាជកជាអ្នកចេះដឹងឯទៀត ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ចេញអំពីទីសម្ងំ ក្នុងវេលាថ្ងៃរសៀល ក៏យាងចូលទៅឯអារាមនៃបរិព្វាជក ក្បែរឆ្នេរស្ទឹង ឈ្មោះសិប្បិនី លុះយាងចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេតាក់តែងថ្វាយ ។ លុះព្រះដ៏មានព្រះភាគគង់រួចហើយ បានត្រាស់នឹងពួកបរិព្វាជកទាំងនោះដូច្នេះថា ម្នាលបរិព្វាជកទាំងឡាយ ធម្មបទ ៤ យ៉ាងនេះ ជាច្បាប់ទម្លាប់ គប្បីដឹងអស់រាត្រីដ៏យូរ ជាបវេណី ជាច្បាប់ចាស់ មិនច្រឡូកច្រឡំ មិនដែលច្រឡូកច្រឡំ មិនរតាត់រតាយ មិនរាត់រាយ ដែលពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញមិនអាចតិះដៀលបាន ។ ធម្មបទ ៤ តើដូចម្ដេច ។ ម្នាលបរិព្វាជកទាំងឡាយ អនភិជ្ឈាជាធម្មបទ ជាច្បាប់ទម្លាប់ គប្បីដឹងអស់រាត្រីដ៏យូរ ជាបវេណី ជាច្បាប់ចាស់ មិនច្រឡូកច្រឡំ មិនដែលច្រឡូកច្រឡំ មិនរតាត់រតាយ មិនរាត់រាយ ដែលពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ មិនអាចតិះដៀលបាន ១ ។ ម្នាលបរិព្វាជកទាំងឡាយ អព្យាបាទជាធម្មបទ ... ម្នាលបរិព្វាជកទាំងឡាយ សម្មាសតិជាធម្មបទ ... ម្នាល

បរិព្វាជកទាំងឡាយ សម្មាសមាធិជាធម្មបទ ... ជាច្បាប់ទម្លាប់ គប្បីដឹងអស់រាត្រីដ៏យូរ ជាបវេណី ជាច្បាប់ចាស់ មិនច្រឡូកច្រឡំ មិនដែលច្រឡូកច្រឡំ មិនរតាត់រតាយ មិនរាត់រាយ ដែលពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញមិនអាចតិះដៀលបាន ១ ។ ម្នាលបរិព្វាជក ធម្មបទទាំងឡាយ ៤ យ៉ាងនេះ ជាច្បាប់ទម្លាប់ គប្បីដឹងអស់រាត្រីដ៏យូរ ជាបវេណី ជាច្បាប់ចាស់ មិនច្រឡូកច្រឡំ មិនដែលច្រឡូកច្រឡំ មិនរតាត់រតាយ មិនរាត់រាយ ដែលពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញ ក៏មិនអាចតិះដៀលបាន ។ ម្នាលបរិព្វាជកទាំងឡាយ អ្នកណាគប្បីនិយាយយ៉ាងនេះថា អាត្មាអញនឹងឃាត់ហាមនូវអនភិជ្ឈាជាធម្មបទនុ៎ះ ហើយបញ្ញត្តបុគ្គលអ្នកមានអភិជ្ឈា អ្នកមានតម្រេកដ៏ក្លៀវក្លាក្នុងកាមទាំងឡាយ ថាជាសមណៈ ឬព្រាហ្មណ៍ កាលបើអ្នកនោះនិយាយដូច្នេះហើយ តថាគតត្រូវនិយាយនឹងអ្នកនោះ ចំពោះហេតុនោះយ៉ាងនេះថា អ្នកចូរមក ចូរនិយាយដោះស្រាយទៅមើល តថាគតនឹងមើលអានុភាពរបស់អ្នក ម្នាលបរិព្វាជកទាំងឡាយ អ្នកនោះ នឹងឃាត់ហាមនូវអនភិជ្ឈា ជាធម្មបទហើយ បញ្ញត្តបុគ្គលណាមួយ ដែលមានអភិជ្ឈា អ្នកមានតម្រេកដ៏ក្លៀវក្លាក្នុងកាមទាំងឡាយ ថាជាសមណៈ ឬព្រាហ្មណ៍ ដូច្នេះ ហេតុនោះ មិនមានឡើយ ។ ម្នាលបរិព្វាជកទាំងឡាយ អ្នកណាគប្បីនិយាយយ៉ាងនេះថា អាត្មាអញនឹងឃាត់ហាមនូវអព្យាបាទ ជាធម្មបទនុ៎ះហើយ បញ្ញត្តបុគ្គលណាមួយ អ្នកមានចិត្តព្យាបាទ មានគំនិតដែលទោសប្រទូស្ត ហើយ ថាជាសមណៈ ឬព្រាហ្មណ៍ កាលបើអ្នកនោះនិយាយដូច្នេះហើយ

តថាគតត្រូវនិយាយនឹងអ្នកនោះ ចំពោះហេតុនោះ យ៉ាងនេះថា អ្នកចូរមក ចូរនិយាយដោះស្រាយទៅមើល តថាគតនឹងមើលអានុភាពរបស់អ្នក ។ ម្នាលបរិព្វាជកទាំងឡាយ អ្នកនោះឯងនឹងឃាត់ហាមនូវអព្យាបាទ ជាធម្មបទ ហើយបញ្ញត្តបុគ្គលណាមួយ អ្នកមានចិត្តព្យាបាទ អ្នកមានគំនិតដែលទោសប្រទូស្តហើយ ថាជាសមណៈ ឬព្រាហ្មណ៍ដូច្នេះ ហេតុនុ៎ះមិនមានឡើយ ។ ម្នាលបរិព្វាជកទាំងឡាយ អ្នកណាគប្បីនិយាយយ៉ាងនេះថា អាត្មាអញនឹងឃាត់ហាមនូវសម្មាសតិ ជាធម្មបទនោះហើយ បញ្ញត្តបុគ្គលណាមួយដែលមិនមានសតិ មិនមានសម្បជញ្ញៈ ថាជាសមណៈ ឬព្រាហ្មណ៍ កាលបើអ្នកនោះនិយាយដូច្នេះហើយ តថាគតត្រូវនិយាយនឹងអ្នកនោះ ចំពោះហេតុនុ៎ះ យ៉ាងនេះថា អ្នកចូរមក ចូរនិយាយដោះស្រាយទៅមើល តថាគតនឹងមើលអានុភាពរបស់អ្នក ។ ម្នាលបរិព្វាជកទាំងឡាយ អ្នកនោះឯងនឹងឃាត់ហាមនូវសម្មាសតិ ជាធម្មបទ ហើយបញ្ញត្ត បុគ្គលណាមួយ ដែលមិនមានសតិ មិនមានសម្បជញ្ញៈ ថាជាសមណៈ ឬព្រាហ្មណ៍ដូច្នេះ ហេតុនុ៎ះមិនមានឡើយ ។ ម្នាលបរិព្វាជកទាំងឡាយ អ្នកណាគប្បីនិយាយយ៉ាងនេះថា អាត្មាអញនឹងឃាត់ហាមសម្មាសមាធិ ជាធម្មបទនុ៎ះ ហើយបញ្ញត្តបុគ្គលណាមួយ ដែលមិនមានចិត្តតម្កល់មាំ ដែលមានចិត្តរវើរវាយ ថាជាសមណៈ ឬព្រាហ្មណ៍ កាលបើអ្នកនោះនិយាយដូច្នេះហើយ តថាគតត្រូវនិយាយចំពោះហេតុនុ៎ះ យ៉ាងនេះថា អ្នកចូរមក ចូរនិយាយដោះស្រាយទៅមើល តថាគតនឹងមើលអានុភាពរបស់អ្នក ។ ម្នាលបរិព្វាជកទាំងឡាយ អ្នកនោះឯងឃាត់ហាម

សម្មាសមាធិ ជាធម្មបទ ហើយបញ្ញត្តបុគ្គលណាមួយ ដែលមិនមានចិត្ត តម្កល់មាំ ដែលមានចិត្តរវើរវាយ ថាជាសមណៈ ឬព្រាហ្មណ៍ ដូច្នេះ ហេតុនុ៎ះមិនមានឡើយ ។ ម្នាលបរិព្វាជកទាំងឡាយ អ្នកណាគប្បីសម្គាល់នូវធម្មបទទាំង ៤ នេះថា ជារបស់ដែលគួរតិះដៀល គួរឃាត់ហាមគន្ធនៃពាក្យប្រកបដោយហេតុទាំង ៤ យ៉ាង ក៏មកកាន់ហេតុដែលគេគួរតិះដៀលចំពោះអ្នកនោះក្នុងបច្ចុប្បន្ន ។ ធម្មបទ ៤ តើដូចម្តេច ។ បើអ្នកដ៏ចម្រើនតិះដៀលឃាត់ហាមអនភិជ្ឈា ជាធម្មបទថា សមណៈ ឬព្រាហ្មណ៍ទាំងឡាយណា ជាអ្នកប្រកបដោយតណ្ហា អ្នកមានតម្រេកដ៏ក្រាសក្នុងកាមទាំងឡាយ សមណៈ ឬព្រាហ្មណ៍ទាំងឡាយនោះ ជាទីបូជារបស់អ្នកដ៏ចម្រើន សមណៈ ឬព្រាហ្មណ៍ទាំងឡាយនោះ ជាទីសរសើររបស់អ្នកដ៏ចម្រើន ១ ។ បើអ្នកដ៏ចម្រើនតិះដៀលឃាត់ហាមអព្យាបាទ ជាធម្មបទថា សមណៈ ឬព្រាហ្មណ៍ទាំងឡាយណា មានចិត្តព្យាបាទ មានគំនិតដែលទោសប្រទូស្តហើយ សមណៈ ឬព្រាហ្មណ៍ទាំងឡាយនោះ ជាទីបូជារបស់អ្នកដ៏ចម្រើន សមណៈ ឬព្រាហ្មណ៍ទាំងឡាយនោះ ជាទីសរសើររបស់អ្នកដ៏ចម្រើន ១ ។ បើអ្នកដ៏ចម្រើនតិះដៀលឃាត់ហាមសម្មាសតិ ជាធម្មបទថា សមណៈ ឬព្រាហ្មណ៍ទាំងឡាយណា ជាអ្នកភ្លេចស្មារតី មិនមានសម្បជញ្ញៈ សមណៈ ឬព្រាហ្មណ៍ទាំងឡាយនោះ ជាទីបូជារបស់អ្នកដ៏ចម្រើន សមណៈ ឬព្រាហ្មណ៍ទាំងឡាយនោះ ជាទីសរសើររបស់អ្នកដ៏ចម្រើន ១ ។ បើអ្នកដ៏ចម្រើនតិះដៀល ឃាត់ហាមសម្មាសមាធិជាធម្មបទថា សមណៈ ឬព្រាហ្មណ៍ទាំង-

ឡាយណា មានចិត្តមិនតម្កល់មាំ មានចិត្តរវើរវាយ សមណៈ ឬព្រាហ្មណ៍ទាំងឡាយនោះ ជាទីបូជារបស់អ្នកដ៏ចម្រើន សមណៈ ឬព្រាហ្មណ៍ទាំង-ឡាយនោះ ជាទីសរសើររបស់អ្នកដ៏ចម្រើន ១ ។ ម្នាលបរិព្វាជកទាំងឡាយ អ្នកណាគប្បីសម្គាល់នូវធម្មបទទាំង ៤ នេះថា ជារបស់ដែលគេគួរតិះដៀល គួរឃាត់ហាមគន្ទង់នៃពាក្យប្រកបដោយហេតុទាំង ៤ នេះ ក៏មកកាន់ហេតុដែលគេគួរតិះដៀលចំពោះអ្នកនោះក្នុងបច្ចុប្បន្ននេះ ។ ម្នាលបរិព្វាជកទាំង-ឡាយ ជនទាំងឡាយពីរនាក់ គឺវស្សៈ ១ ភញ្ញៈ ១ ជាអ្នកនៅក្នុងឧក្កល-ជនបទ ជាអហេតុកវាទ អកិរិយវាទ និងនត្ថិកវាទ ក៏ជនទាំងពីរនាក់នោះបានសម្គាល់នូវធម្មបទទាំង ៤ នេះថា ជារបស់ដែលមិនត្រូវតិះដៀល ថាជារបស់ដែលមិនត្រូវហាមឃាត់ឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះខ្លាចគេនិន្ទា ពេបជ្រាយ តិះដៀលដល់ខ្លួន ។

បុគ្គលអ្នកមិនមានចិត្តព្យាបាទ មានស្មារតីគ្រប់កាល មានចិត្តតម្កល់មាំ ប្រព្រឹត្តទៅក្នុងខាងក្នុង សិក្សាក្នុងការបន្ទោបង់នូវអភិជ្ឈា តថាគត ហៅថា អ្នកមិនប្រមាទ ។

**ឧរុវេលវគ្គទី ៣ ចប់**

## ឧទ្ទាននៃឧរុវេលវគ្គនោះ គឺ

ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងឧរុវេលនិគមពីរដង ១ លោក គឺទុក្ខជាដើម ដែលព្រះតថាគតត្រាស់ដឹងហើយ ១ ព្រះអង្គ

គង់ក្នុងកាឡកាម ១ ព្រហ្មចរិយធម៌ជាគម្រប់ប្រាំ ១ ពួកកុហកជាដើម ១ សេចក្តីសន្ទោស ១ អរិយវង្ស ១ ធម្មបទ ( ជាច្បាប់ចាស់ ) ១ ធម្មបទ ទ្រង់សម្តែងចំពោះពួកបរិព្វាជក ១ ។

# អដ្ឋកថា

## បរិព្វាជកសូត្រ

[ ៣១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបរិព្វាជកសូត្រទី ១០ ដូចតទៅនេះ បទថា **អភិញ្ញាតា** បានដល់ បុគ្គលមានឈ្មោះដែលស្គាល់ គឺប្រាកដ ។ បទថា **អន្នភារោ** ជាដើម ជាឈ្មោះរបស់បរិព្វាជកទាំងនោះ ។ បទថា **បដិសល្លានា វុដ្ឋិតោ** បានដល់ ព្រះមានព្រះភាគទ្រង់ចេញអំពីផលសមាបត្តិ ។ ផលសមាបត្តិនោះ លោកបំណងយកថា ជាទីសម្ងំក្នុងទីនេះ ។ បទថា **បចុក្កាយ** គឺជំទាស់ ។ បទថា **អភិជ្ឈាលុំ** គឺបុគ្គលមានតណ្ហា ។ បទថា **កាមេសុ តិព្វសារាគំ** សេចក្តីថា បុគ្គលមានរាគៈ ត្រេកអរ ច្រើនក្នុងវត្ថុកាម ។ បទថា **តមហំ តត្ថ ឯវំ វទេយ្យំ** សេចក្តីថា កាលបុគ្គលពោលពាក្យនោះ ព្រោះពោលយ៉ាងនេះក្នុងហេតុនោះ ។ បទថា **បដិក្កោសិតព្វំ មញ្ញេយ្យ** សេចក្តីថា បុគ្គលណាសម្គាល់ថា គួរជំទាស់ គឺ

គួរឃាត់ ។ បទថា **សហធម្មិកា** បានដល់ ព្រមទាំងហេតុ ។ បទថា **វាទានុបាតា** សេចក្ដីថា ជាអ្នកបៀតបៀនវាទៈដែលប្រកបដោយធម៌ ក៏ធ្លាក់ទៅតាមវាទៈដែលមិនប្រកបដោយធម៌ អធិប្បាយថា ប្រព្រឹត្តតាមវាទៈ ។ បទថា **គារយ្ហា ឋានា** គឺបច្ច័យដែលគួរតិះដៀល ។ បទថា **អាគច្ឆន្តិ** គឺរមែងចូលដល់ ។

បទថា **ឧក្កលា** គឺអ្នកជនបទឧក្កលៈ ។ បទថា **វស្សភញ្ញា** គឺបរិព្វាជក ២ នាក់ ឈ្មោះថា វស្សៈ និងភញ្ញៈ ។ បទថា **អហេតុកវាទា** សេចក្ដីថា ទាំង ២ នាក់ ជាអ្នកមានវាទៈជាដើមយ៉ាងនេះថា ហេតុមិនមាន បច្ច័យមិនមាន ដើម្បីការបរិសុទ្ធនៃសត្វទាំងឡាយ ដូច្នេះ ។ បទថា **អកិរិយវាទា** សេចក្ដីថា បុគ្គលមានវាទៈបដិសេធកិរិយវាទៈយ៉ាងនេះថា កាលបុគ្គលធ្វើបាប មិនឈ្មោះថា បុគ្គលធ្វើ ដូច្នេះ ។ បទថា **នត្ថិកវាទា** សេចក្ដីថា បុគ្គលមានវាទៈជាដើមយ៉ាងនេះថា ទានដែលទាយកឲ្យហើយមិនមានផល ដូច្នេះ ។ បុគ្គលទាំង ២ នោះ ជាអ្នកមុជចុះក្នុងទស្សនៈទាំង ៣ នេះ ។ សួរថា ក្នុងអ្នកទាំងនោះ កំណត់បានដូចម្ដេច ។ ឆ្លើយថា បុគ្គលណាកាន់យកលទ្ធិបែបនេះ អង្គុយស្វាធ្យាយពិចារណា ក្នុងទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ មិច្ឆាសតិរបស់បុគ្គលនោះ រមែងតាំងមាំក្នុងអារម្មណ៍នោះថា ហេតុមិនមាន បច្ច័យមិនមាន កាលបុគ្គលធ្វើបាប រមែងមិនឈ្មោះថា បុគ្គលធ្វើ ។បេ។ ទានដែលទាយកឲ្យហើយ មិនមានផល ។បេ។ ព្រោះកាយបែកធ្លាយ រមែងដាច់សូន្យ ដូច្នេះ ចិត្តរមែងចុះស៊ប់

ជវនចិត្តទាំងឡាយ រមែងស្ទុះទៅក្នុងជវនចិត្តទី ១ បុគ្គលនោះនៅកែបាន ក្នុងជវនចិត្តទី ២ ជាដើម ក៏យ៉ាងនោះ ក្នុងជវនចិត្តទី ៧ បុគ្គលនោះ សូម្បីព្រះពុទ្ធទាំងឡាយ ក៏កែមិនបាន មិនត្រឡប់មក រមែងដូចគ្នានឹង អរិដ្ឋភិក្ខុ និងកណ្ដកសាមណេរ ។ បណ្ដាទស្សនៈ ៣ យ៉ាងនោះ បុគ្គល ខ្លះឈមចុះកាន់ទស្សនៈ ១ បុគ្គលខ្លះឈមចុះកាន់ទស្សនៈ ២ បុគ្គលខ្លះ ឈមចុះកាន់ទស្សនៈ ៣ បុគ្គលនោះ រមែងឈ្មោះថា និយតមិច្ឆាទិដ្ឋិក ទាំងអស់ បុគ្គលទាំងនោះត្រូវឃាត់សួគ៌ និងឃាត់ព្រះនិព្វាន មិនគួរទៅកាន់ ស្ថានសួគ៌ក្នុងលំដាប់នៃអត្តភាពនោះ នឹងពោលថ្វីដល់ព្រះនិព្វាននោះ ។ អធិប្បាយថា សត្វនេះ ជាអ្នកយាមផែនដី ឈ្មោះថា ជាដង្កត់ក្នុងវដ្ដៈ ។ ដោយច្រើន សត្វបែបនេះ មិនចេញអំពីភព សូម្បីវស្សៈ និងកញ្ញបរិព្វាជក ក៏ដូច្នេះ ។ បទថា **និន្ទាព្យារោសឧបារម្ភភយា** សេចក្ដីថា ព្រោះខ្លួនខ្លាច នូវសេចក្ដីនិន្ទា ខ្លាចសេចក្ដីស្អប់ខ្ពើម និងខ្លាចបុគ្គលពោលអាក្រក់ ដូច្នេះ ។ បទថា **អភិជ្ឈាវិនយេ សិក្ខំ** សេចក្ដីថា អរហត្ត ហៅថា ធម៌ជាគ្រឿង កម្ចាត់អភិជ្ឈា អ្នកសិក្សាក្នុងព្រះអរហត្ត ហៅថា ជាអ្នកមិនប្រមាទ ដូច្នេះ ។ ត្រាស់ទាំងវដ្ដៈ ទាំងវិវដ្ដៈ ក្នុងព្រះសូត្រហើយ ទើបត្រាស់ផលសមាបត្តិ ក្នុងព្រះគាថា ដោយប្រការដូច្នេះ ។

## អដ្ឋកថា បរិព្វាជកសូត្រទី ១០ ចប់

## ឧរុវេលវគ្គទី ៣ ចប់

# សុត្តន្តបិដក

# ចក្កវគ្គទី ៤

## ចក្កសូត្រទី ១

[ ៣២ ] ម្នាលភិក្ខុទាំងឡាយ ចក្កនេះមាន ៤ ចក្ក ៤ តែងប្រព្រឹត្តទៅ ( ដើម្បីជាប្រយោជន៍ ) ដល់ពួកទេវតា និងមនុស្ស ដែលប្រកបដោយចក្ក ពួកទេវតា និងមនុស្សដែលប្រកបដោយចក្កហើយ មិនយូរប៉ុន្មាន ក៏បានដល់នូវភាពនៃខ្លួនជាធំទូលាយ ក្នុងភោគៈទាំងឡាយ ។ ចក្ក ៤ ដូចម្តេចខ្លះ ។ គឺការនៅក្នុងប្រទេសដ៏សមគួរ ១ ការចូលទៅសេពគប់នឹងពួកសប្បុរស ១ ការតម្កល់ទុកខ្លួនដោយល្អ ១ បុណ្យដែលបានធ្វើទុកហើយក្នុងកាលមុន ១ ។ ម្នាលភិក្ខុទាំងឡាយ ចក្កនេះមាន ៤ យ៉ាង ចក្ក ៤ នេះតែងប្រព្រឹត្តទៅដល់ពួកទេវតា និងមនុស្ស ដែលប្រកបព្រមដោយចក្ក ពួកទេវតា និងមនុស្ស ដែលប្រកបដោយចក្កហើយ មិនយូរប៉ុន្មាន គង់បានដល់នូវភាវៈនៃខ្លួនជាធំទូលាយក្នុងភោគៈទាំងឡាយ ។

ជនណានៅក្នុងប្រទេសដ៏សមគួរ សេពគប់នូវមិត្តដ៏ប្រសើរ
ប្រកបដោយការតម្កល់ទុកនូវខ្លួនដោយល្អ បានធ្វើបុណ្យទុក
ក្នុងកាលមុន ធញ្ញជាត ទ្រព្យយស សេចក្តីសរសើរសុខ
តែងឃុំគ្រងនូវជននុ៎ះ ។

# អដ្ឋកថា

# ចក្កវគ្គទី ៤

## ចក្កសូត្រ

[ ៣២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចក្កសូត្រទី ១ នៃចក្កវគ្គទី ៤ ដូចតទៅនេះ បទថា **ចក្កានិ** គឺសម្បត្តិ ។ បទថា **ចតុច្ចក្កំ វត្តតិ** សេចក្ដីថា ចក្រគឺសម្បត្តិ ៤ រមែងវិល គឺបន្តគ្នាទៅ ។ បរិស័ទ ៤ រមែងប្រាកដព្រម ក្នុងទឹកដីណា កាលនៅក្នុងទឹកដីដ៏សមគួរបែបនោះ ឈ្មោះថា **បដិរូបទេសវាស** គឺការនៅក្នុងប្រទេសដ៏សមគួរ ។ ការសេពគប់សប្បុរស មានព្រះពុទ្ធជាដើម ឈ្មោះថា **សប្បុរិសូបស្សយ** គឺការសេពគប់សប្បុរស ។ ការតាំងខ្លួនប្រពៃ គឺបើជាបុគ្គលប្រកបដោយការមិនមានសទ្ធាជាដើមអំពីមុន ការលះនូវការមិនមានសទ្ធាទាំងនោះចេញ ហើយតាំងនៅក្នុងសទ្ធាជាដើម ឈ្មោះថា **អត្ត-សម្មាបណិធិ** គឺការតាំងខ្លួនទុកប្រពៃ ។ ភាពជាបុគ្គលមានកុសលសន្សំក្នុងកាលមុន ឈ្មោះថា **បុព្វេ ច កតបុញ្ញតា** ភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន ។ សេចក្ដីនេះឯង កាន់យកជាប្រមាណក្នុងចក្ក ៤ នេះ ។ ព្រោះថា កុសលកម្មប៉ុណ្ណោះ ដែលបុគ្គលណាធ្វើដោយចិត្ត ដែលសម្បយុត្តដោយញាណឯណា កុសលចិត្តនោះឯង រមែងនាំបុគ្គលនោះ ចូលទៅក្នុងទឹកដីដែលសមគួរឲ្យបុគ្គលនោះ គប់រកសប្បុរស បុគ្គលនោះ ឈ្មោះថា តាំងខ្លួនប្រពៃដោយអាការយ៉ាងនេះ ។ បទថា **បុញ្ញកតោ** ប្រែថា បានធ្វើ

បុណ្យទុកហើយ ។ បទថា **សុខញ្ចាតំ អធិវត្តតិ** សេចក្តីថា សេចក្តីសុខ រមែងឃុំគ្រង គឺផ្សាយចុះមកកាន់បុគ្គលនោះ ដូច្នេះ ៕

**អដ្ឋកថា ចក្កសូត្រទី ១ ចប់**

# សុត្តន្តបិដក

## សង្គហសូត្រទី ២

[ ៣៣ ] ម្នាលភិក្ខុទាំងឡាយ សង្គហវត្ថុនេះមាន ៤ ។ សង្គហវត្ថុ ៤ តើដូចម្តេចខ្លះ ។ គឺការឲ្យទាន ១ ការពោលពាក្យគួរស្រឡាញ់បាន ១ ការប្រព្រឹត្តជាប្រយោជន៍ ១ ភាពនៃបុគ្គលអ្នកមានខ្លួនស្មើ ១ ។ ម្នាលភិក្ខុទាំងឡាយ សង្គហវត្ថុមាន ៤ យ៉ាងនេះឯង ។

ការឲ្យទាន ១ ការពោលពាក្យគួរស្រឡាញ់បាន ១ ការ
ប្រព្រឹត្តជាប្រយោជន៍ ១ ភាពនៃបុគ្គលអ្នកមានខ្លួនស្មើ ១
ដែលមានក្នុងលោកនេះ តាមសមគួរក្នុងធម៌ទាំងឡាយនោះៗ
បើសង្គហវត្ថុទាំងឡាយនេះ មានក្នុងលោក ដូចជាភ្លៅរបស់
រថ ដែលអាចវិលទៅបាន ។ បើពួកសង្គហៈនេះ មិនមានទេ
មាតាមិនគួរបាននូវសេចក្តីរាប់អាន ឬការបូជាអំពីបុត្រ បិតា
ក៏មិនគួរបាននូវសេចក្តីរាប់អាន ឬការបូជាអំពីបុត្រ ( ប្រុស

ស្រី ) ឡើយ ព្រោះហេតុណា ហេតុនោះ បានជាបណ្ឌិតទាំង-ឡាយ តែងសម្លឹងមើលនូវសង្គហៈទាំងឡាយនេះ បណ្ឌិតទាំងឡាយនោះ ក៏បានដល់នូវភាពនៃខ្លួនជាធំផង ជាបុគ្គលគួរសរសើរផង ។

# អដ្ឋកថា

## សង្គហសូត្រ

[ ៣៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសង្គហសូត្រទី ២ ដូចតទៅនេះ បទថា **សង្គហវត្ថូនិ** គឺហេតុនៃការសង្គ្រោះគ្នា ។ ក្នុងបទថា **ទានញ្ច** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូច្នេះ បុគ្គលពួកខ្លះ គួរទទួលសង្គ្រោះដោយទានតែម្យ៉ាង គប្បីឲ្យទានតែម្យ៉ាងដល់បុគ្គលនោះ ។ បទថា **បេយ្យវជ្ជំ** គឺពោលពាក្យគួរស្រឡាញ់ ។ ពិតហើយ បុគ្គលខ្លះពោលថា បុគ្គលនេះឲ្យវត្ថុដែលគួរឲ្យតែដោយពាក្យមួយ បុគ្គលនោះក៏ពោលលុប ធ្វើឲ្យវិនាសទៅ បុគ្គលនោះឲ្យធ្វើអ្វី ដូច្នេះ បុគ្គលខ្លះពោលថា បុគ្គលនេះមិនឲ្យទានក៏ពិត តែបុគ្គលនោះក៏ពោលបានអើល ដូចយកប្រេងលាប ។ បុគ្គលនោះទោះឲ្យក្តី មិនឲ្យក្តី តែពាក្យរបស់បុគ្គលនោះ រមែងមានតម្លៃរាប់ពាន់ ។ បុគ្គលបែបនេះ រមែងមិនទន្ទឹងនូវការឲ្យ រមែងទន្ទឹងតែពាក្យដែលគួរស្រឡាញ់តែម្យ៉ាង គួរពោល

តែពាក្យស្រឡាញ់ដល់បុគ្គលនោះប៉ុណ្ណោះ ។ បទថា **អត្ថចរិយា** គឺពោលតែរឿងដែលជាប្រយោជន៍ និងធ្វើនូវសេចក្តីចម្រើន ។ ពិតហើយ បុគ្គលខ្លះមិនមែនបំណងតែការឲ្យ មិនមែនបំណងតែបិយវាចា ពាក្យដែលគួរស្រឡាញ់ ត្រូវការតែពាក្យដែលជាប្រយោជន៍ ការពោលដែលធ្វើនូវការចម្រើនដល់ខ្លួនតែម្យ៉ាង ។ គប្បីពោលតែរឿងបំពេញប្រយោជន៍ដល់បុគ្គលបែបនោះ យ៉ាងនេះថា អ្នកគួរធ្វើកិច្ចនេះ មិនគួរធ្វើកិច្ចនេះ បុគ្គលនេះ គួរគប់រក បុគ្គលនេះ មិនគួរគប់រក ។ បទថា **សមានត្តតា** គឺភាពជាអ្នកមានសេចក្តីសុខ មានទុក្ខស្មើគ្នា ។ បុគ្គលពួកខ្លះ រមែងមិនទទួលសង្គហវត្ថុមានទានជាដើម សូម្បីតែមួយ បើទទួលនូវការរួមសុខ រួមទុក្ខយ៉ាងនេះ គឺអង្គុយលើអាសនៈ ១ ដេកលើគ្រែ ១ បរិភោគរួមគ្នា ១ ។ បើបុគ្គលនោះជាគ្រហស្ថ រមែងស្មើគ្នាដោយជាតិ បព្វជិតរមែងស្មើគ្នាដោយសីល ការជាក់ខ្លួនស្មើនេះ គួរធ្វើដល់បុគ្គលនោះ ។

បទថា **តត្ថ តត្ថ យថារហំ** សេចក្តីថា ដាក់ខ្លួនស្មើក្នុងធម៌នោះៗ តាមសមគួរ ។ បទថា **រថស្សាណីវ យាយតោ** សេចក្តីថា សង្គហធម៌ទាំងនេះ រមែងទាញយកនូវលោកបាន ដូចគន្លឹះត្រង់ផ្លូវរមែងទាញរថដែលស្ទុះទៅ គឺរមែងទាញយានបាន ដូច្នោះ ។ បទថា **ន មាតា បុត្តការណា** សេចក្តីថា បើមាតាមិនគប្បីធ្វើការសង្គ្រោះដល់បុត្រសោត លោកក៏មិនគប្បីបានទទួលនូវការរាប់អាន ឬបូជា ព្រោះបុត្រជាហេតុ ។ បទថា **សង្គហា ឯតេ** ជាបឋមាវិភត្តិ ប្រើក្នុងអត្ថទុតិយាវិភត្តិ ម្យ៉ាងទៀត បាឋៈថា **សង្គហោ ឯតេ**

ក៏មាន ។ បទថា **សមវេក្ខន្តិ** គឺរមែងពិចារណាឃើញដោយប្រពៃ ។ បទថា **ចាសំសា ច ភវន្តិ** គឺរមែងជាបុគ្គលគួរសរសើរ ។ល។

**អដ្ឋកថាសង្គហសូត្រទី ២ ចប់**

# សុត្តន្តបិដក

## សីហសូត្រទី ៣

[ ៣៤ ] ម្នាលភិក្ខុទាំងឡាយ វេលាថ្ងៃរសៀល សត្វសីហៈជាស្តេចម្រឹគ រមែងចេញអំពីជំណោក លុះចេញអំពីជំណោកហើយ ក៏មីតពត់ខ្លួន លុះមីតពត់ខ្លួនហើយ ក៏ក្រឡេកមៀងមើលទិសទាំង ៤ ជុំវិញ លុះក្រឡេកមៀងមើលទិសទាំង ៤ ជុំវិញ រួចក៏បន្លឺសីហនាទ ៣ ដង លុះបន្លឺសីហនាទ ៣ ដងហើយ ទើបដើរចេញទៅរកចំណី ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វតិរច្ឆានណា ឮសំឡេងសត្វសីហៈ ជាស្តេចម្រឹគកំពុងបន្លឺ ពួកសត្វតិរច្ឆាននោះ ក៏ភិតភ័យ សង្វេគ ញ័រចំប្រប់រាល់គ្នា ពួកសត្វនៅក្នុងរូង រមែងស្ទុះចូលទៅកាន់រូង ពួកសត្វអាស្រ័យនៅនឹងទឹក ក៏ស្ទុះទៅរកទឹក ពួកសត្វអាស្រ័យនៅក្នុងព្រៃ ក៏ចូលព្រៃ ពួកសត្វបក្សីហើរទៅឯអាកាស ។ ម្នាលភិក្ខុទាំងឡាយ ពួកដំរីណារបស់ស្តេច ដែលគេចងដោយចំណងព្រ័ត្រដ៏មាំក្នុងស្រុក និគម និងរាជធានីទាំងឡាយ ក៏ពួកដំរីទាំងនោះ ស្ទុះផ្តាច់ចំណងទាំង

អម្បាលនោះហើយ ភិតភ័យរាកនោម រាកអាចម៍ ប្រោលប្រាសទៅខាងណោះខ្វះ ខាងណោះខ្វះ ។ ម្នាលភិក្ខុទាំងឡាយ សត្វសីហៈជាស្តេចនៃម្រឹគ មានឫទ្ធិច្រើនយ៉ាងនេះ មានយសសក្តិធំយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ជាងពួកសត្វតិរច្ឆាន មានឧបមាយ៉ាងណា ។ ម្នាលភិក្ខុទាំងឡាយ កាលណាព្រះតថាគតបានត្រាស់ឡើងក្នុងលោក ជាអ្នកឆ្ងាយចាកកិលេស ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ បរិបូណ៌ដោយវិជ្ជា និងចរណៈ មានដំណើរល្អ ជ្រាបច្បាស់នូវត្រៃលោក ប្រសើរដោយសីលាទិគុណ រកបុគ្គលដទៃប្រៀបផ្ទឹមមិនបាន ជាអ្នកទូន្មាននូវបុរស ដែលគួរទូន្មានបាន ជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ បានត្រាស់ដឹងនូវអរិយសច្ចធម៌ លែងវិលត្រឡប់មកកាន់ភពថ្មីទៀត ព្រះតថាគតនោះ ទ្រង់សម្តែងធម៌ថា សក្កាយដូច្នេះ ការកើតនៃសក្កាយ ដូច្នេះ ការរលត់នៃសក្កាយ ដូច្នេះ បដិបទាដំណើរទៅកាន់ទីរលត់នៃសក្កាយ ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ពួកទេវតាណា ដែលមានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន ឋិតនៅលើវិមានទាំងឡាយ ដ៏ខ្ពស់អស់កាលយូរ ពួកទេវតាទាំងនោះ បានស្តាប់នូវធម៌ទេសនារបស់ព្រះតថាគតហើយ ច្រើនតែភិតភ័យ សង្វេគ ញ័រចំប្រប់គ្រប់គ្នាថា ម្នាលអ្នកដ៏ចម្រើន ពួកយើងមិនទៀងទេតើ តែពួកយើង សម្គាល់ថាទៀង ម្នាលអ្នកដ៏ចម្រើន ពួកយើងមិនមាំមួនទេតើ តែពួកយើង សម្គាល់ថាមាំមួន ម្នាលអ្នកដ៏ចម្រើន ពួកយើងមិនស្ថិតស្ថេរទេតើ តែពួកយើងសម្គាល់ថាស្ថិតស្ថេរ ម្នាលអ្នកដ៏ចម្រើន ពួកយើងមិនទៀង មិនមាំមួន មិន

ស្ថិតស្ថេរទេ ( ព្រោះ ) រាប់បញ្ចូលក្នុងសក្កាយ គឺខន្ធទាំង ៥ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត មានឫទ្ធិច្រើនយ៉ាងនេះ មានយសសក្តិធំយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ជាងសត្វលោក ព្រមទាំងទេវលោក ក៏មានឧបមេយ្យយ៉ាងនោះដែរ ។

កាលព្រះពុទ្ធបានត្រាស់ដឹងហើយ ទ្រង់ធ្វើធម្មចក្កឲ្យប្រព្រឹត្តទៅដល់សត្វលោក ព្រមទាំងទេវលោក ជាសាស្តា មិនមានបុគ្គលដទៃប្រៀបផ្ទឹមស្មើបាន ទ្រង់សម្តែងនូវសក្កាយផង នូវសេចក្តីរលត់ទៅនៃសក្កាយផង នូវហេតុជាទីកើតឡើងនៃសក្កាយផង នូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ជាដំណើរទៅកាន់ទីរលត់ទុក្ខផង ពួកទេវតាដែលមានអាយុវែង មានសម្បុរល្អ មានយសសក្តិ ដែលមិនទាន់ផុតអំពីសក្កាយ លុះឮព្រះពុទ្ធដីការបស់ព្រះអរហន្តជាតាទិបុគ្គល ដែលរួចស្រឡះ (ចាកអកុសលធម៌ ) ហើយក៏ភិតភ័យដល់នូវសេចក្តីតក់ស្លុត ថាពួកយើងមិនទៀងទេតើ ដូចពួកម្រឹគដទៃខ្លាចសីហៈ ។

# អដ្ឋកថា

## សីហសូត្រ

[ ៣៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសីហសូត្រទី ៣ ដូចតទៅនេះ បទថា **សីហោ** បានដល់ រាជសីហ៍ ៤ ប្រភេទ គឺតិណរាជសីហ៍ ១ កាឡរាជសីហ៍ ១ បណ្ឌុរាជសីហ៍ ១ កេសររាជសីហ៍ ១ ។ ក្នុងរាជសីហ៍ទាំងនោះ តិណរាជសីហ៍ ស៊ីស្មៅដូចគ្នានឹងមេគោ មានពណ៌ដូចសត្វព្រាប កាឡរាជសីហ៍ ដូចគ្នានឹងមេគោខ្មៅ ។ បណ្ឌុរាជសីហ៍ ស៊ីសាច់ មានពណ៌ដូចមេគោពណ៌ស្លឹកឈើទុំ កេសរសីហៈប្រកបដោយមុខ ចុងកន្ទុយ និងចុងជើងទាំង ៤ ដែលធម្មជាតិតាក់តែងដោយល័ខ តាំងអំពីក្បាលរបស់កេសរសីហៈនោះ ស្នាម ៣ ធ្នូត ដូចគេគូរដោយល័ខ ត្រង់កណ្ដាលខ្នង ជាក្រយៅនៅត្រង់គល់ក្លៅ ។ ចំណែកត្រង់ករបស់វា មានកេសរស្រដៀងនឹងវង្វង់ដែលគេចង ដោយសំពត់កម្ពលក្រហមមានតម្លៃរាប់សែន ។ ឯអវយវៈដ៏សេស មានខ្លួនដូចដុំស្រូវសាលីសុទ្ធ ឬដូចដុំលម្អិតនៃខ្យងស័ង្ខ ក្នុងរាជសីហ៍ ៤ នេះ លោកបំណងយកកេសរសីហៈក្នុងទីនេះ ។

បទថា **មិគរាជា** ជាស្ដេចនៃហ្វូងម្រឹគទាំងអស់ ។ បទថា **អាសយា** បានដល់ ចេញអំពីលំនៅ ។ លោកអធិប្បាយថា រមែងចេញអំពីគុហាមាស ឬគុហាប្រាក់ គុហាកែវមណី គុហាកែវផលិក ឬគុហាមនោសិលា ។ កាលនឹងចេញ រមែងចេញដោយហេតុ ៤ គឺកាលងងឹតគ្របសង្កត់ ចេញដើម្បីពន្លឺ ១ ឈឺបន្ទោបង់ឧច្ចារបស្សាវៈ ចេញដើម្បីបន្ទោបង់ឧច្ចារបស្សាវៈ ១ ត្រូវ

សេចក្តីឃ្លានគ្របសង្កត់ ចេញដើម្បីរកចំណី ១ ត្រូវការបន្តពូជគ្របសង្កត់ ចេញដើម្បីមេថុន ១ តែក្នុងទីនេះ សំដៅយកចេញដើម្បីរកចំណី ។ បទថា **វិជម្ភតិ** សេចក្តីថា រាជសីហ៍ លាតជើងទាំង ២ ឲ្យស្មើគ្នា លើផ្ទៃគុហាមាស ឬលើផ្ទៃគុហាប្រាក់ គុហាកែវមណី គុហាកែវផលិក ឬគុហាមនោសិលាណាមួយ សណ្តូកជើងមុខត្រង់ទៅមុខ ធ្វើជង្គង់ខ្លួនខាងក្រោយឲ្យត្រង់ បន្ទន់ចំណែកខាងមុខ បង្អោនខ្នង អើត-កឡើង រលាស់នូវធូលីដែលជាប់នៅត្រង់ខ្លួន រលាស់ហាក់បីដូចសំឡេងរន្ទះ ។ ចំណែកធូលី រមែងវិលលើផែនដីដែលរលាស់ ដូចកូនគោជំទង់ ចំណែកធូលីនោះ ដែលកំពុងវិលប្រាកដដូចគ្នានឹងភ្លើងដែលវិលនៅក្នុងទីងងឹត ។ បទថា **អនុវិលោកេតិ** សួរថា ព្រោះហេតុអ្វី ទើបរាជសីហ៍សម្លឹងមើល ។ ឆ្លើយថា ព្រោះអាណិតសត្វដទៃ ។ បានឮថា កាលរាជសីហ៍បញ្ចេញសំឡេង សត្វទាំងឡាយមានដំរី គោ ក្របីជាដើម ដើរក្បែរជ្រោះ ឬអណ្តូងក៏ធ្លាក់ទៅក្នុងជ្រោះខ្លះក្នុងអណ្តូងខ្លះ ទើបក្រឡេកមើល ព្រោះការអាណិតអាសូរសត្វទាំងនោះ ។ សួរថា រាជសីហ៍ជាសត្វកាច ស៊ីសាច់របស់សត្វដទៃ នៅមានការអាណិតអាសូរឬ ។ ឆ្លើយថា មាន ។ ពិតហើយ រាជសីហ៍មិនចាប់សត្វតូចៗ ដើម្បីជាអាហាររបស់ខ្លួន ដោយគិតថា ប្រយោជន៍អ្វីរបស់អញដោយសត្វជាច្រើនដែលត្រូវសម្លាប់ ដូច្នេះ ។ រាជសីហ៍ធ្វើការអាណិតអាសូរ ដោយអាការយ៉ាងនេះ ។ សេចក្តីនោះ សមដូចលោកពោលថា អាត្មាអញកុំសម្លាប់សត្វតូចតាចដែលនៅក្នុងទីមិនរាបស្មើឡើយ ។

បទថា **សីហនាទំ នទតិ** សេចក្តីថា គ្រាដំបូង បញ្ចេញសំឡេងដែលសត្វខ្លាច ៣ ដង ។ កាលរាជសីហ៍ឈរលើទីសម្រាប់រលាស់ បន្លឺសំឡេង សំឡេងកងរំពងតែម្យ៉ាង ដោយជុំវិញអស់ទីប្រមាណ ៣ យោជន៍ ពួកសត្វជើង ២ និងជើង ៤ ដែលនៅខាងក្នុងទី ៣ យោជន៍ បានឮសំឡេងកងរំពងរបស់រាជសីហ៍ហើយ រមែងឈរក្នុងទីដើមមិនបាន ។ បទថា **គោចរាយ បក្កមតិ** បានដល់ រមែងចេញទៅដើម្បីរកចំណី ។ សួរថា ចេញទៅដូចម្តេច ។ ឆ្លើយថា រាជសីហ៍ឈរលើទីសម្រាប់រលាស់ខ្លួន លោតទៅខាងស្តាំ ខាងឆ្វេង ខាងក្រោយ រមែងស្ទុះទៅអស់ទីប្រមាណ ១ ឧសភៈ កាលនឹងលោតខ្ពស់ ក៏លោតបាន ៤ ឧសភៈខ្លះ ៨ ឧសភៈខ្លះ កាលរត់ទៅក្នុងទីរាបស្មើ ក៏រត់ទៅបានរហូតចម្ងាយប្រមាណ ១៦ ឧសភៈខ្លះ ២០ ឧសភៈខ្លះ កាលរត់ចុះអំពីទីទួល ឬភ្នំ ក៏រត់បាន អស់ទីប្រមាណ ៦០ ឧសភៈខ្លះ ៨០ ឧសភៈខ្លះ ឃើញដើមឈើ ឬភ្នំក្នុងចន្លោះផ្លូវ ក៏គេចដើមឈើ ឬភ្នំនោះចៀសទៅទីកម្ពស់ប្រមាណ ១ ឧសភៈ ខាងស្តាំខ្លះ ខាងឆ្វេងខ្លះ រាជសីហ៍បន្លឺសំឡេងលើកទី ៣ រមែងប្រាកដខ្លួនក្នុងទី ៣ យោជន៍ មួយអន្លើដោយសំឡេងនោះ រាជសីហ៍ទៅបាន ៣ យោជន៍ ត្រឡប់មកឈរ គង់បានឮនូវសំឡេងកងរំពងរបស់ខ្លួននោះឯង ។ រាជសីហ៍ រមែងស្ទុះទៅដោយកម្លាំងជើងដ៏រហ័សយ៉ាងនេះ ។

បទថា **យេភុយ្យេន** ប្រែថា ដោយច្រើន ។ បទថា **ភយំ សន្តាសំ សំវេគំ** គ្រប់បទ ជាឈ្មោះរបស់ការភ័យខ្លាចនៃចិត្តដូចគ្នា ។ ពិតហើយ

សត្វ និងមនុស្សបានឮសំឡេងរបស់រាជសីហ៍ ចំណែកច្រើន ជាអ្នកខ្លាច ចំណែកតិច ជាអ្នកមិនខ្លាច ។ សួរថា សត្វមានចំនួនតិចទាំងនោះ គឺនរណា ឆ្លើយថា គឺរាជសីហ៍ដែលមានជាតិស្មើគ្នា ដំរីអាជានេយ្យ សេះអាជានេយ្យ គោឧសភអាជានេយ្យ បុរសអាជានេយ្យ ព្រះខីណាស្រព ។ សួរថា ព្រោះហេតុអ្វី ទើបសត្វ និងមនុស្សទាំងនោះមិនខ្លាច ។ ឆ្លើយថា ជាដំបូង រាជសីហ៍ដែលស្មើគ្នា រមែងមិនខ្លាច ព្រោះគិតថា អញស្មើគ្នាដោយជាតិ គោត្រ ត្រកូល និងសេចក្ដីអង់អាច ។ ដំរីអាជានេយ្យជាដើមមិនខ្លាច ព្រោះថា ខ្លួនមានសក្កាយទិដ្ឋិជាកម្លាំង ព្រះខីណាស្រពមិនខ្លាច ព្រោះលះសក្កាយ-ទិដ្ឋិបានហើយ ។ បទថា **ពិលាសយា** បានដល់ សត្វដែលដេកនៅក្នុងរន្ធ ក្នុងរូង មានពស់ ស្ការ និងទន្សងជាដើម ។ បទថា **ឧទកាសយា** បានដល់ សត្វក្នុងទឹក មានត្រី និងអណ្ដើកជាដើម ។ បទថា **វនាសយា** បានដល់ សត្វក្នុងព្រៃ មានដំរី សេះ គោ ម្រឹគជាដើម ។ បទថា **បរិសន្តិ** សេចក្ដីថា សត្វទាំងឡាយសម្លឹងមើលផ្លូវដោយគិតថា ឥឡូវនេះ អ្នកណានឹងមកចាប់ ដូច្នេះ ទើបចូលទៅ ។ បទថា **ឧឡ្ហេហិ** គឺដែលមាំទាំ ។ បទថា **វរត្តេហិ** គឺដោយខ្សែស្បែក ។ ក្នុងបទថា **មហិទ្ធិកោ** ជាដើម គប្បីជ្រាបថា ការដែលរាជសីហ៍មានឫទ្ធិច្រើន ដោយអំណាចឈរក្នុងទីសម្រាប់លោតខ្លួន លោតបាន ១ ឧសភៈ ទៅខាងស្ដាំជាដើម លោតត្រង់ទៅមុខបានប្រមាណ ២០ ឧសភៈជាដើម ។ គប្បីជ្រាបភាពដែលសត្វមានសក្តិធំព្រោះជាម្ចាស់ ជាធំជាងម្រឹគដ៏សេស ។ គប្បីជ្រាបភាពដែលរាជសីហ៍មាន

អានុភាពច្រើន ដោយអំណាចនៃសត្វទាំងឡាយ បានពួសំឡេងក្នុងទី ៣ យោជន៍ដោយជុំវិញ ហើយនាំគ្នាគេចទៅ ។

បទថា **ឯវមេវ ខោ** សេចក្តីថា ព្រះមានព្រះភាគត្រាស់ដល់ព្រះអង្គ ក្នុងព្រះសូត្រនោះៗ ដោយប្រការនោះៗ ត្រាស់ដល់ព្រះអង្គ ប្រៀបដូចរាជ-សីហ៍ក្នុងព្រះសូត្រនេះថា ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា សត្វសីហៈនេះ ជាឈ្មោះរបស់ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ។ ប្រៀបដូចគ្រូពេទ្យ ក្នុងព្រះសូត្រនេះថា ម្នាលសុនក្ខត្តៈទាំងឡាយ ពាក្យថា ភិសក្កៈ ( គ្រូពេទ្យវះកាត់ ) នោះ ឈ្មោះរបស់តថាគតជាអរហន្តសម្មាសម្ពុទ្ធ ដូច្នេះ ។ លោកប្រដូចនឹងព្រាហ្មណ៍ ដូចក្នុងព្រះសូត្រនេះថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រាហ្មណ៍ ( អ្នកបន្សាត់បង់នូវបាប ) នេះ ជាឈ្មោះរបស់តថាគត ជាអរហន្តសម្មាសម្ពុទ ដូច្នេះ ។ ប្រៀបដូចបុគ្គលដែលនាំផ្លូវ ក្នុងសូត្រនេះថា ម្នាលតិស្សៈ ពាក្យថា បុរសស្ទាត់ក្នុងផ្លូវនោះ ជាឈ្មោះរបស់ព្រះតថាគត-អរហន្តសម្មាសម្ពុទ្ធ ដូច្នេះ ។ ប្រដូចនឹងព្រះរាជា ក្នុងសូត្រនេះថា ម្នាលសេលព្រាហ្មណ៍ តថាគតជាស្តេចព្រោះធម៌ ដូច្នេះ ។ ក្នុងព្រះសូត្រនេះ ទ្រង់ប្រៀបព្រះអង្គដូចរាជសីហ៍ ទើបត្រាស់យ៉ាងនោះ ។

ក្នុងពាក្យនេះ មានការប្រៀបដូច្នេះ ពេលដែលព្រះតថាគតបំពេញនូវអភិនីហារទៀបបាទមូលរបស់ព្រះពុទ្ធទីបង្ករ ទ្រង់បំពេញបារមីទាំងឡាយអស់កាលកំណត់រាប់មិនបាន ធ្វើម៉ឺនលោកធាតុឲ្យញាប់ញ័រ ដោយបដិសន្ធិ និងដោយការប្រសូតិចាកគភ៌របស់មាតាក្នុងភពចុងក្រោយ ទ្រង់ចម្រើនវ័យហើយ

សោយសម្បត្តិដូចទិព្វសម្បត្តិ ប្រថាប់នៅក្នុងប្រាសាទទាំង ៣ គប្បីជ្រាប ដូចកាលរាជសីហ៍ នៅក្នុងកាញ្ចនគុហាជាដើម ។ ពេលដែលតថាគតឡើង ផែលសេះកណ្ឋកៈ មាននាយឆន្នជាសម្លាញ់ ស្តេចយាងចេញតាមទ្វារដែល បើក ក្នុងវេលាមានព្រះជន្មាយុ ២៩ វស្សា ឈានកន្លងរាជសម្បត្តិទាំង ៣ ( ៣ នគរ ) ទ្រង់គ្រងសំពត់កាសាវពស្ត្រ ដែលព្រហ្មថ្វាយនាឆ្នេរស្ទឹង អនោមា ទ្រង់ព្រះផ្នួសហើយ ក៏យាងទៅកាន់ក្រុងរាជគ្រឹះ ក្នុងថ្ងៃទី ៧ ត្រាច់ បិណ្ឌបាតក្នុងក្រុងរាជគ្រឹះនោះ ទ្រង់ធ្វើកត្តកិច្ចត្រង់ញកភ្នំបណ្ឌវៈ រហូតទ្រង់ ថ្វាយបដិញ្ញាដល់ព្រះបាទពិម្ពិសារថា ទ្រង់សម្រេចព្រះសម្មាសម្ពោធិញ្ញាណ ហើយ នឹងយាងមកដែនមគធៈមុនទីដទៃ គប្បីជ្រាបដូចកាលរាជសីហ៍ចេញ អំពីកាញ្ចនគុហាជាដើម ។

កាលព្រះតថាគត ទ្រង់ថ្វាយបដិញ្ញាហើយ ទ្រង់យាងចូលទៅរក អាឡារតាបសកាលាមគោត្រជាដើម រហូតដល់សោយមធុបាយាស ៤៩ ពំនូត ដែលនាងសុជាតាថ្វាយ គប្បីជ្រាបដូចពេលរាជសីហ៍រលាស់ខ្លួន ។

ការដែលព្រះតថាគត ទ្រង់ទទួលស្មៅ គឺស្បា ៨ ក្តាប់ដែលព្រាហ្មណ៍ ឈ្មោះថាសោត្ថិយៈថ្វាយក្នុងវេលាល្ងាច ទេវតាក្នុងម៉ឺនចក្រវាលសរសើរបូជា ដោយគ្រឿងក្រអូបជាដើម ទ្រង់ធ្វើប្រទក្សិណពោធិព្រឹក្ស ៣ ជុំ ហើយឡើង កាន់ពោធិមណ្ឌលដ្ឋាន ទ្រង់ក្រាលកម្រាលស្មៅ គឺស្បាក្នុងទីកម្ពស់ ១៤ ហត្ថ ប្រថាប់គង់អធិដ្ឋានសេចក្តីព្យាយាមដែលមានអង្គ ៤ ទ្រង់កម្ចាត់មារ និង ពលមារក្នុងខណៈនោះឯង ទ្រង់ជម្រះវិជ្ជា ៣ ក្នុងយាមទាំង ៣ ទ្រង់កូរទូវ

មហាសមុទ្រ គឺបដិច្ចសមុប្បាទ ទាំងអនុលោម ទាំងបដិលោម ដោយឈើសម្រាប់កូរ គឺយមកញ្ញាណ គឺព្រះញាណដែលប្រព្រឹត្តទៅជាគូៗ កាលទ្រង់សម្រេចសព្វញ្ញុតញ្ញាណហើយ លោកធាតុទាំងមួយម៉ឺនក៏ញាប់ញ័រ ដោយអានុភាពព្រះសព្វញ្ញុតញ្ញាណនោះ គប្បីជ្រាបដូចការកម្ចាត់ធូលីក្នុងខ្លួនរបស់រាជសីហ៍ ។

ការដែលព្រះតថាគត ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណ នៅប្រថាប់ក្នុងពោធិមណ្ឌលដ្ឋាន ៧ សប្តាហ៍ សោយមធុបាយាសជាព្រះក្រយាហារ ទ្រង់ទទួលអារាធនាសម្តែងធម៌របស់មហាព្រហ្ម នាគល់អជបាលនិគ្រោធប្រថាប់នៅក្នុងទីនោះ ក្នុងថ្ងៃទី ១១ ទ្រង់រំពឹងថា ស្អែកនេះ ជាថ្ងៃអាសាឡ្ហបុណ្ណមី ក្នុងវេលាទៀបភ្លឺ ទ្រង់ប្រមើលមើលថា តថាគតគប្បីសម្តែងធម៌ដល់បុគ្គលណាមុនហ្ន៎ ទ្រង់ជ្រាបថា អាឡារតាបស និងឧទកតាបសអស់ជីវិតហើយ ទ្រង់ឃើញបញ្ចវគ្គិយសមគួរទទួលព្រះធម្មទេសនាមុន គប្បីឃើញដូចការក្រឡេកមើលក្នុងទិសទាំង ៤ របស់រាជសីហ៍ ។

វេលាដែលព្រះតថាគត ទ្រង់កាន់យកបាត្រ និងចីវររបស់ព្រះអង្គ ទ្រង់ក្រោកអំពីដើមអជបាលនិគ្រោធ យាងទៅអស់ទីចម្ងាយ ១៨ យោជន៍ ខាងក្រោយសោយព្រះក្រយាហារ ដោយព្រះហឫទ័យបំណងប្រកាសធម្មចក្រដល់បញ្ចវគ្គិយ គប្បីជ្រាបដូចកាលរាជសីហ៍ចេញរកចំណី ទៅបាន ៣ យោជន៍ ។

កាលទ្រង់ទៅអស់ចម្ងាយផ្លូវ ១៨ យោជន៍ ទ្រង់ធ្វើបញ្ចវគ្គិយភិក្ខុឲ្យ

យល់ច្បាស់ ហើយប្រថាប់គង់លើអចលបល្ល័ង្ក ដែលពួកទេវតាប្រជុំព្រមគ្នាក្នុងម៉ឺនចក្រវាលចោមរោមហើយ ទើបប្រកាសធម្មចក្រ ដោយន័យជាដើមថា អន្តធម៌ ២ ដែលអ្នកបួសមិនគួរសេព ដូច្នេះ គប្បីជ្រាបដូចកាលរាជសីហ៍បន្លឺសីហនាទ ។ កាលព្រះតថាគតទ្រង់សំដែងធម្មចក្រនេះ សំឡេងឧគ្ឃោសនៃធម៌របស់រាជសីហ៍ គឺព្រះតថាគត ក៏គ្របដណ្តប់នូវម៉ឺនលោកធាតុខាងក្រោមដល់អវិចី ខាងលើទល់ភវគ្គព្រហ្ម ។ កាលព្រះតថាគតទ្រង់សំដែងលក្ខណៈ ៣ ត្រាស់ធម៌ចែកសច្ចៈ ៤ ព្រមដោយអាការ ១៦ រហូតដល់ពាន់ន័យ ពួកទេវតាដែលមានអាយុវែង ក៏កើតតក់ស្លុតដោយញាណ គប្បីជ្រាបដូចកាលពួកសត្វតូចៗ តក់ស្លុត ព្រោះសំឡេងរបស់រាជសីហ៍ ។

ម្យ៉ាងទៀត ព្រះតថាគតទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណ ដូចរាជសីហ៍ពេលដែលទ្រង់ចេញចាកព្រះគន្ធកុដិ ដូចរាជសីហ៍ចេញចាកគុហាមាស ដែលនៅអាស្រ័យ កាលទ្រង់ចូលទៅកាន់ធម្មសភា ដូចរាជសីហ៍រលាស់ខ្លួន ទ្រង់សម្លឹងមើលបរិស័ទ ដូចការសម្លឹងមើលទិស ពេលទ្រង់សំដែងធម៌ ដូចការបន្លឺសីហនាទ ការយាងទៅបង្ក្រាបលទ្ធិដទៃ ដូចការចេញរកចំណី ។

ម្យ៉ាងទៀត ព្រះតថាគតដូចរាជសីហ៍ ការចេញអំពីផលសមាបត្តិ ដែលអាស្រ័យនិព្វានដោយអារម្មណ៍ ក៏ដូចការចេញអំពីកាញ្ចនគុហា ដែលអាស្រ័យហិនវន្តបពិត បច្ចវេក្ខណញ្ញាណ ដូចការរលាស់ខ្លួន កាលប្រមើលមើលវេនេយ្យសត្វ ក៏ដូចការសម្លឹងមើលទិស ការសំដែងធម៌ដល់បរិស័ទដែលមកដល់ហើយ ក៏ដូចការបន្លឺសីហនាទ ការចូលទៅរកវេនេយ្យសត្វ

ដែលមកមិនទាន់ដល់ គប្បីជ្រាបដូចការចេញទៅរកចំណី ។

បទថា **យទា** ប្រែថា ក្នុងកាលណា ។ បទថា **តថាគតោ** បានដល់ឈ្មោះថា តថាគតដោយហេតុ ៨ ដែលពោលហើយខាងដើម ។ បទថា **លោកេ** គឺក្នុងសត្វលោក ។ បទថា **ឧប្បជ្ជតិ** សេចក្ដីថា តថាគតឈ្មោះថា កំពុងកើតឡើង តាំងអំពីអភិនីហារបំពេញមក រហូតដល់ពោធិបល្ល័ង្ក ឬ អរហត្តមគ្គញ្ញាណ តែកាលសម្រេចអរហត្តផល ឈ្មោះថា កើតឡើងហើយ ។ បទថា **អរហំ សម្មាសម្ពុទ្ធោ** ជាដើម លោកពង្រីកពិស្ដារហើយក្នុងនិទ្ទេស ពោលដោយពុទ្ធានុស្សតិ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។

បទថា **ឥតិ សក្កាយោ** សេចក្ដីថា នេះជាសក្កាយ គឺប្រមាណប៉ុណ្ណោះ ជាសក្កាយក្រៅលែងជាងនេះមិនមាន ឧបាទានក្ខន្ធ ៥ ទាំងពួងឈ្មោះថា លោកសម្ដែងហើយ ដោយសភាវៈ ដោយកិច្ច ដោយទីបំផុតដោយកំណត់ ដោយផ្លូវជុំវិញ ដោយហេតុប្រមាណប៉ុណ្ណោះ ។ បទថា **ឥតិ សក្កាយស្ស សមុទយោ** បានដល់ នេះឈ្មោះសក្កាយសមុទយៈ ។ ពាក្យថា ព្រោះអាហារកើត ទើបរូបកើត ដូច្នេះជាដើម ឈ្មោះថា លោកសម្ដែងហើយ ដោយហេតុ មានប្រមាណប៉ុណ្ណោះ ។ បទថា **ឥតិ សក្កាយស្ស អត្ថង្គមោ** សេចក្ដីថា នេះជាសក្កាយនិរោធ គឺការរលត់សក្កាយ ។ ពាក្យថា ព្រោះអាហាររលត់ ទើបរូបរលត់ដូច្នេះជាដើមទាំងអស់ ឈ្មោះថា លោកសម្ដែងហើយដោយបទនេះ ។ បទថា **វណ្ណវន្តោ** បានដល់ បុគ្គលមានវណ្ណៈស្អាត ដោយវណ្ណៈនៃសរីរៈ ។ បទថា **ឧច្ចាវចំ សុត្វា** សេចក្ដីថា

ទេវតាទាំងនោះ បានស្តាប់ព្រះធម្មទេសនារបស់ព្រះតថាគត ដែលប្រដាប់ដោយលក្ខណៈ ៥០ ក្នុងបញ្ចក្ខន្ធ ។ បទថា **យេភុយ្យេន** សេចក្តីថា សួរថា វៀរទេវតាពួកណាក្នុងទីនេះ ។ ឆ្លើយថា វៀរទេវតាដែលជាអរិយសាវក ។ ព្រោះទេវតាដែលជាអរិយសាវកទាំងនោះ មិនកើតត្រឹមតែការខ្លាច ដោយការខ្លាចនៃចិត្ត ព្រោះលោកអស់អាសវៈហើយ សេចក្តីសង្វេគដោយញាណរមែងកើតឡើងដល់បុគ្គលដែលសង្វេគហើយ ព្រោះលោកសម្រេចធម៌ដែលគប្បីសម្រេច ដោយសេចក្តីព្យាយាម ដោយឧបាយក៏មាន សេចក្តីខ្លាចដោយការខ្លាចនៃចិត្តតែងកើតឡើងដល់ទេវតាពួកនេះ បុគ្គលធ្វើទុកក្នុងចិត្តដោយការមិនទៀងក៏មាន ការខ្លាចដោយញាណ រមែងកើតឡើងក្នុងកាលវិបស្សនាមានកម្លាំងក៏មាន ។ បទថា **ភោ** នោះ ត្រឹមតែជាពាក្យហៅដោយធម៌ ។ បទថា **សក្កាយ បរិយាបន្នា** បានដល់ ទាក់ទងក្នុងខន្ធ ៥ ។ ដូច្នោះ កាលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងទោសក្នុងវដ្តៈហើយ ទ្រង់សម្តែងធម៌នាំត្រៃលក្ខណ៍មក ទេវតាទាំងនោះ ក៏កើតនូវការសង្វេគដោយញាណដោយប្រការដូច្នេះ ។

បទថា **អភិញ្ញាយ** គឺទ្រង់ដឹងហើយ ។ បទថា **ធម្មចក្កំ** បានដល់ បដិវេធញ្ញាណខ្លះ ទេសនាញាណខ្លះ ។ ព្រះពុទ្ធប្រថាប់គង់ក្នុងពោធិបល្ល័ង្កទ្រង់ចាក់ធ្លុះសច្ចៈ ៤ ព្រមដោយអាការ ១៦ រហូតដល់ ១០០០ ន័យ ដោយព្រះញាណណា ព្រះញាណនោះ ឈ្មោះថា បដិវេធញ្ញាណ ។ ទ្រង់ប្រកាសធម្មចក្រមានបរិវដ្តៈ ៣ អាការ ១២ ដោយព្រះញាណណា ព្រះញាណនោះ

ឈ្មោះថា ទេសនាញាណ ។ ញាណទាំង ២ យ៉ាងនោះ ជាញាណដែលកើតក្នុងគ្រាដំបូងរបស់ព្រះទសពល ។ ក្នុងញាណទាំង ២ នោះ គួរកាន់យកធម្មទេសនាញាណ ធម្មទេសនាញាណនោះ ឈ្មោះថា រមែងប្រព្រឹត្តទៅដរាបសោតាបត្តិផល ដែលមិនទាន់កើតឡើងដល់ព្រះអញ្ញាកោណ្ឌញ្ញត្ថេរ មួយអន្លើដោយព្រហ្ម ១៨ កោដិ កាលសោតាបត្តិផលនោះកើតឡើងហើយ គប្បីជ្រាបថា ធម្មទេសនាញាណ ឈ្មោះថា ប្រព្រឹត្តទៅហើយ ដូច្នេះ ។ បទថា **អប្បដិបុគ្គលោ** គឺវៀរបុគ្គលដែលអាចប្រៀបផ្ទឹម ។ បទថា **យសស្សិនោ** គឺដល់ព្រមដោយបរិវារ ។ បទថា **តាទិនោ** គឺបុគ្គលដែលនឹងធឹង ជាមួយលោកធម៌ មានលាភជាដើម ។៚

**អដ្ឋកថាសីហសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## អគ្គប្បសាទសូត្រទី ៤

[ ៣៥ ] ម្នាលភិក្ខុទាំងឡាយ អគ្គប្បសាទ ( សេចក្ដីជ្រះថ្លាដ៏ប្រសើរ ) នេះ មាន ៤ ។ អគ្គប្បសាទ ៤ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វទាំងប៉ុន្មាន ដែលឥតជើងក្ដី មានជើង ២ ក្ដី មានជើង ៤ ក្ដី មានជើងច្រើនក្ដី មានរូបក្ដី គ្មានរូបក្ដី មានសញ្ញាក្ដី គ្មានសញ្ញាក្ដី មិនមែន

ជាមិនមានសញ្ញាក្តី ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ប្រាកដជាប្រសើរលើសជាងពួកសត្វទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វណាជ្រះថ្លាក្នុងព្រះពុទ្ធ ពួកសត្វទាំងនោះ ឈ្មោះថា ជ្រះថ្លាក្នុងបុគ្គលប្រសើរ ផលដ៏ប្រសើរតែងមានដល់ពួកសត្វអ្នកជ្រះថ្លាក្នុងបុគ្គលប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកសង្ខតធម៌ ធម៌ដែលបច្ច័យតាក់តែងទាំងប៉ុន្មាន មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ប្រាកដជាប្រសើរជាងពួកសង្ខតធម៌ទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វណាជ្រះថ្លា ក្នុងមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ពួកសត្វនោះ ឈ្មោះថា ជ្រះថ្លាក្នុងព្រះធម៌ដ៏ប្រសើរ ផលដ៏ប្រសើរតែងមានដល់ពួកសត្វ អ្នកជ្រះថ្លាក្នុងធម៌ដ៏ប្រសើរ ១ ។ ម្នាលភិក្ខុទាំង-ឡាយ ធម៌ទាំងប៉ុន្មាន ជាសង្ខតធម៌ក្តី អសង្ខតធម៌ក្តី វិរាគធម៌ ប្រាកដជាប្រសើរជាងពួកធម៌ទាំងនោះ ព្រោះថា វិរាគធម៌នេះ ជាធម៌សម្រាប់បន្ទោបង់នូវសេចក្តីស្រវឹង ជាធម៌កម្ចាត់បង់នូវសេចក្តីស្រេកឃ្លាន ជាធម៌អាចដកនូវសេចក្តីអាល័យ ជាធម៌ផ្តាច់បង់នូវវដ្តៈ ជាធម៌អស់ទៅនៃតណ្ហា ជាធម៌ប្រាសចាកតម្រេក ជាធម៌រលត់ ជាធម៌មិនមានគ្រឿងចាក់ស្រែះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វណាជ្រះថ្លាក្នុងវិរាគធម៌ ពួកសត្វនោះ ឈ្មោះថា ជ្រះថ្លាក្នុងធម៌ដ៏ប្រសើរ ផលដ៏ប្រសើរ តែងមានដល់ពួកសត្វ អ្នកជ្រះថ្លាក្នុងធម៌ដ៏ប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃក្តី គណៈក្តី ទាំងប៉ុន្មាន សង្ឃ-សាវកនៃតថាគត បើរាប់ជាគូបាន ៤ គូ បើរាប់រៀងជាបុរសបុគ្គលមាន ៨ នេះជាសង្ឃសាវករបស់ព្រះដ៏មានព្រះភាគ គួរទទួលរបស់ដែលគេនាំមកបូជា

គួរទទួលនូវអាគន្តុកទាន គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលីកម្មដែលសត្វលោកគប្បីធ្វើ ជាស្រែបុណ្យដ៏ប្រសើរ នៃសត្វលោក ប្រាកដជាប្រសើរជាងសង្ឃ ឬគណៈទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វណាជ្រះថ្លាក្នុងព្រះសង្ឃ ពួកសត្វនោះ ឈ្មោះថា ជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរ ផលដ៏ប្រសើរតែងមានដល់ពួកសត្វ អ្នកជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ អគ្គប្បសាទ ( សេចក្តីជ្រះថ្លាដ៏ប្រសើរ ) មាន ៤ យ៉ាងនេះឯង ។

បុណ្យដ៏ប្រសើរផង អាយុដ៏ប្រសើរផង វណ្ណៈដ៏ប្រសើរផង យសដ៏ប្រសើរផង សេចក្តីសរសើរដ៏ប្រសើរផង សេចក្តីសុខដ៏ប្រសើរផង កម្លាំងដ៏ប្រសើរផង រមែងចម្រើនដល់បុគ្គលទាំងឡាយ អ្នកជ្រះថ្លាចំពោះវត្ថុដ៏ប្រសើរ ដឹងច្បាស់នូវធម៌ដ៏ប្រសើរ ជ្រះថ្លាក្នុងព្រះពុទ្ធដ៏ប្រសើរ ជាទក្ខិណេយ្យ-បុគ្គល មិនមានបុគ្គលដទៃលើស ជ្រះថ្លាក្នុងព្រះធម៌ដ៏ប្រសើរ ជាធម៌រម្ងាប់រាគៈ នាំមកនូវសេចក្តីសុខ ជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរ ជាស្រែបុណ្យ មិនមានស្រែដទៃលើស ឲ្យនូវទានចំពោះបុគ្គលដ៏ប្រសើរ ។ អ្នកប្រាជ្ញដែលមានចិត្តតម្កល់មាំក្នុងធម៌ដ៏ប្រសើរ ជាអ្នកឲ្យនូវទាន ដល់បុគ្គលដ៏ប្រសើរ ទោះកើតជាទេវតាក្តី ជាមនុស្សក្តី តែងដល់នូវភាវៈដ៏ប្រសើររមែងរីករាយ ។

# អដ្ឋកថា

## អគ្គប្បសាទសូត្រ

[ ៣៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបសាទសូត្រទី ៤ ដូចតទៅនេះ បទថា **អគ្គប្បសាទ** ព្រោះអគ្គថា ជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរ ឬការជ្រះថ្លាដ៏លើស ។ បទថា **យាវតា** គឺប្រមាណប៉ុនណា ។ បទថា **អបទា** បានដល់ ពួកសត្វដែលមិនមានជើង មានពស់ និងត្រីជាដើម ។ បទថា **ទ្វិបទា** បានដល់ពួកសត្វជើង ២ មានមនុស្ស និងបក្សីជាដើម ។ បទថា **ចតុប្បទា** បានដល់សត្វជើង ៤ មានដំរី និងសេះជាដើម ។ បទថា **ពហុប្បទា** បានដល់ ពួកសត្វជើងច្រើន មានក្អែបជាដើម ។ បទថា **នេវសញ្ញិនាសញ្ញិនោ** បានដល់ពួកសត្វដែលកើតក្នុងភវគ្គព្រហ្ម ។ បទថា **អគ្គមក្ខាយតិ** សេចក្តីថា ព្រះតថាគតដ៏ជាអ្នកប្រាជ្ញពោលថា ជាកំពូល គឺប្រសើរបំផុតដោយគុណទាំង-ឡាយ ។ បទថា **អសង្ខតា** សេចក្តីថា លោកពោលកាន់យកព្រះនិព្វានប៉ុណ្ណោះ ។ បទជាដើមថា **វិរាគោ** ជាឈ្មោះរបស់ព្រះនិព្វានពិត ព្រោះថា មកដល់ព្រះនិព្វាននោះហើយ កិលេសទាំងឡាយ ក៏រលាយទៅអស់ ការស្រវឹងទាំងឡាយ មានការស្រវឹងព្រោះរាគៈជាដើម ក៏ឈប់ស្រវឹងទៅ គឺមិនមាន ការស្រេកទាំងឡាយក៏ប្រាសទៅ អាល័យទាំងឡាយក៏ដកទៅ វដ្តៈទាំងឡាយក៏ដាច់ តណ្ហាក៏អស់ វដ្តទុក្ខក៏រលត់ ការក្តៅទាំងពួង ក៏រលត់ទៅ ព្រោះដូច្នោះ ទើបនិព្វានមានឈ្មោះទាំងនោះ ។ បទដ៏សេស ក្នុងសូត្រនេះងាយយល់ទាំងអស់ហើយ ។ល។

**អដ្ឋកថាអគ្គប្បសាទសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## វស្សការសូត្រទី ៥

[ ៣៦ ] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះ វស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ទើបអង្គុយក្នុងទីសមគួរ ។ លុះវស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន យើងខ្ញុំតែងបញ្ញត្តនូវជនដែលមានបញ្ញាច្រើន ប្រកបដោយធម៌ទាំង ៤ ថា ជាមហាបុរស ។ ប្រកបដោយធម៌ទាំង ៤ តើដូចម្តេច ។ បពិត្រព្រះគោតមដ៏ចម្រើន ជនជាពហុស្សូតក្នុងលោកនេះ រមែងដឹងច្បាស់នូវសេចក្តីនៃអ្នកចេះនោះៗ ១ នៃភាសិតនោះៗ ថា នេះជាសេចក្តីនៃភាសិតនេះ នេះជាសេចក្តីនៃភាសិតនេះ ១ ជនជាអ្នកមានស្មារតីតែងនឹករឭករឿយៗ នូវកិច្ចដែលខ្លួនធ្វើយូរហើយផង នូវពាក្យដែលពោលយូរហើយផង ១ កិច្ចការទាំងឡាយណា ជារបស់គ្រហស្ថ ក៏ជាអ្នកឈ្លាសវៃក្នុងកិច្ចការទាំងឡាយនោះ មិនខ្ជិល ប្រកបដោយបញ្ញាដែលជាឧបាយក្នុងកិច្ចនោះថា គួរធ្វើ គួរចាត់ចែង ១ ។ បពិត្រព្រះគោតមដ៏ចម្រើន យើងខ្ញុំតែងបញ្ញត្តនូវជនដែលមានបញ្ញាច្រើន ប្រកបដោយធម៌ទាំង ៤ នេះឯង ថាជាមហាបុរស ។ បពិត្រព្រះគោតមដ៏ចម្រើន បើព្រះអង្គ

សព្វព្រះពុទ្ធហឫទ័យនឹងពាក្យខ្ញុំ សូមព្រះគោតមដ៏ចម្រើន អនុមោទនាដល់ខ្ញុំចុះ បពិត្រព្រះគោតមដ៏ចម្រើន បើព្រះអង្គត្រូវការហាមឃាត់ពាក្យរបស់ខ្ញុំ សូមព្រះគោតមដ៏ចម្រើន ហាមឃាត់ពាក្យរបស់ខ្ញុំចុះ ។ ម្នាលព្រាហ្មណ៍ តថាគតមិនទទួលអនុមោទនា មិនហាមឃាត់ពាក្យរបស់អ្នកទេ ។ ម្នាលព្រាហ្មណ៍ តថាគតក៏តែងបញ្ញត្តនូវបុគ្គលដែលមានបញ្ញាច្រើន ប្រកបដោយធម៌ ៤ ថា ជាមហាបុរសដែរ ។ ប្រកបដោយធម៌ ៤ តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ បុគ្គលក្នុងលោកនេះ ជាអ្នកប្រតិបត្តិដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ពួកជនច្រើនគ្នាបានតម្កល់ហើយ ក្នុងផ្លូវដ៏ប្រសើរ គឺកល្យាណធម៌ និងកុសលធម៌ បុគ្គលនោះ ប្រាថ្នាដើម្បីត្រិះរិះនូវវិតក្កណា ក៏ត្រិះរិះនូវវិតក្កនោះបាន មិនប្រាថ្នាដើម្បីត្រិះរិះនូវវិតក្កណា ក៏មិនត្រិះរិះនូវវិតក្កនោះ ប្រាថ្នាដើម្បីសម្រេចនូវគំនិតណា ក៏សម្រេចនូវគំនិតនោះ មិនប្រាថ្នាដើម្បីសម្រេចនូវគំនិតណា ក៏មិនសម្រេចនូវគំនិតនោះឡើយ ។ បុគ្គលជាអ្នកបានដល់នូវចេតោវសី ក្នុងផ្លូវវិតក្កទាំងឡាយ ជាអ្នកបានមិនបាច់ប្រាថ្នា បានដោយមិនលំបាក បានដោយមិនក្រ មិនខុសវេលាកំណត់នូវឈានទាំង ៤ ដែលកើតក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយក្នុងបច្ចុប្បន្ននេះ ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង ។ ម្នាលព្រាហ្មណ៍ តថាគតមិនអនុមោទនា មិនហាមឃាត់ពាក្យរបស់អ្នកទេ ។ ម្នាលព្រាហ្មណ៍ តថាគតតែងបញ្ញត្តនូវជនដែលមានបញ្ញាច្រើន

ប្រកបដោយធម៌ទាំង ៤ នេះឯង ថាជាមហាបុរស ។ បពិត្រព្រះគោតមដ៏ចម្រើន ហេតុនេះ អស្ចារ្យណាស់ បពិត្រព្រះគោតមដ៏ចម្រើន ហេតុនេះមិនដែលមានទេ ព្រោះថា ពាក្យដែលព្រះគោតមដ៏ចម្រើនសម្តែងហើយនេះជាពាក្យសុភាសិត ។ ខ្ញុំព្រះអង្គសូមចាំទុកនូវព្រះគោតមដ៏ចម្រើន ដែលប្រកបដោយធម៌ទាំង ៤ នេះថា ព្រះគោតមដ៏ចម្រើនប្រតិបត្តិដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើនមែន ជនច្រើននាក់បានតម្កល់ហើយក្នុងផ្លូវដ៏ប្រសើរ គឺកល្យាណធម៌ និងកុសលធម៌ ព្រះគោតមដ៏ចម្រើនប្រាថ្នាដើម្បីត្រិះរិះនូវវិតក្កណា តែងត្រិះរិះនូវវិតក្កនោះបាន មិនប្រាថ្នាដើម្បីត្រិះរិះនូវវិតក្កណា ក៏មិនត្រិះរិះនូវវិតក្កនោះ ប្រាថ្នាដើម្បីសម្រេចនូវគំនិតណា ក៏សម្រេចនូវគំនិតនោះ មិនប្រាថ្នាដើម្បីសម្រេចនូវគំនិតណា ក៏មិនសម្រេចនូវគំនិតនោះឡើយ ព្រះគោតមដ៏ចម្រើន ដល់នូវចេតោវសីក្នុងផ្លូវវិតក្កទាំងឡាយ ព្រះគោតមដ៏ចម្រើន បានមិនបាច់ប្រាថ្នា បានដោយមិនលំបាក បានដោយមិនក្រនូវឈានទាំង ៤ ដែលកើតក្នុងព្រះហឫទ័យដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ព្រះគោតមដ៏ចម្រើន បានធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។ ម្នាលព្រាហ្មណ៍ សម្តីនាំឲ្យចង្អៀតចង្អល់ ដែលអ្នកនិយាយហើយទាំងប៉ុន្មានតថាគតនឹងព្យាករនូវសម្តីនោះឲ្យអ្នកស្តាប់ ម្នាលព្រាហ្មណ៍ តថាគតប្រតិបត្តិហើយ ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន

ពួកជនច្រើនគ្នាបានតម្កល់នៅក្នុងផ្លូវដ៏ប្រសើរ គឺកល្យាណធម៌ និងកុសល-ធម៌ ម្នាលព្រាហ្មណ៍ តថាគតប្រាថ្នាដើម្បីត្រិះរិះនូវវិតក្កណា ទើបត្រិះរិះនូវវិតក្កនោះ មិនប្រាថ្នាដើម្បីត្រិះរិះនូវវិតក្កណា ក៏មិនត្រិះរិះនូវវិតក្កនោះ តថាគតប្រាថ្នាដើម្បីសម្រេចនូវគំនិតណា ក៏សម្រេចនូវគំនិតនោះបាន មិនប្រាថ្នាសម្រេចនូវគំនិតណា ក៏មិនសម្រេចនូវគំនិតនោះឡើយ ម្នាលព្រាហ្មណ៍ តថាគតដល់នូវចេតោវសីក្នុងផ្លូវវិតក្កទាំងឡាយ ម្នាលព្រាហ្មណ៍ តថាគតបានមិនបាច់ប្រាថ្នា បានដោយមិនលំបាក បានដោយមិនក្រនូវឈានទាំង ៤ ដែលកើតក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្នហើយ ម្នាលព្រាហ្មណ៍ តថាគតបានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញា-វិមុត្តិដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។

បុគ្គលណាជាអ្នកដឹងនូវឧបាយ ជាគ្រឿងរួចអំពីអន្ទាក់នៃមច្ចុមារ
របស់ពួកសត្វទាំងពួង ប្រកាសនូវញេយ្យធម៌ជាប្រយោជន៍ដល់
ទេវតា និងមនុស្សទាំងឡាយ ជនច្រើនបានឃើញ បានស្តាប់
បុគ្គលណាហើយ ជ្រះថ្លា បុគ្គលណា ជាអ្នកឈ្លាសវៃនូវមគ្គ និង
មិនមែនមគ្គ មានសោឡសកិច្ចធ្វើស្រេចហើយ មិនមានអាសវៈ
ដឹងនូវសច្ចៈទាំង ៤ មានសរីរៈតាំងនៅក្នុងទីបំផុត តថាគត
ហៅបុគ្គលនោះថា ជាមហាបុរស ។

# អដ្ឋកថា

## វស្សការសូត្រ

[ ៣៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវស្សការសូត្រទី ៥ ដូចតទៅនេះ បទថា **អនុស្សរិតា** បានដល់ តាមរឭកដល់ ។ អធិប្បាយថា ជាអ្នកអាចរឭកដល់រឿងបន្តៗ គ្នាមកបាន ។ បទថា **ទក្ខោ** គឺជាអ្នកឈ្លាស ។ បទថា **តត្រុ-បាយាយ** សេចក្តីថា ជាអ្នកប្រកបដោយបញ្ញាដែលជាឧបាយក្នុងកិច្ចនោះៗ បានយ៉ាងនេះថា ក្នុងវេលានេះ គួរធ្វើកិច្ចនេះ ដូច្នេះ ។ បទថា **អនុមោ-ទិតុំ** បានដល់ គួរទ្រង់ត្រេកអរ ។ បទថា **បដិក្កោសិតុំ** បានដល់ ការជំទាស់ ។ បទថា **នេវ ខោ ត្យាហំ** បានដល់ តថាគតមិនអនុមោទនាដល់អ្នក ។ សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ ទ្រង់មិនត្រេកអរ ទ្រង់មិនជំទាស់ក្នុងសេចក្តីនោះ ។ ឆ្លើយថា ទ្រង់មិនត្រេកអរ ព្រោះជាលោកិយ ទ្រង់មិនជំទាស់ ព្រោះទាញយកតែប្រយោជន៍ដែលជាលោកិយ ។ បទថា **ពហុស្សជនតា** កាត់បទជា **ពហុ អស្ស ជនតា** ប្រែថា ប្រជុំជនដ៏ច្រើន ។ បទនេះ គប្បីជ្រាបថា ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថតតិយាវិភត្តិ ។ បទថា **អរិយេ ញាយេ** គឺក្នុងមគ្គ មួយអន្លើដោយវិបស្សនា ។ បទថា **កល្យាណធម្មតា កុសលធម្មតា** ជាឈ្មោះរបស់មគ្គទាំងនោះ ។ បទថា **យំ វិតក្កំ** សេចក្តីថា ត្រិះរិះនូវបណ្តានេក្ខម្មវិតក្កជាដើមណាមួយ ។ បទថា **ន តំ វិតក្កំ វិតក្កេតិ** សេចក្តីថា មិនត្រិះរិះបណ្តាកាមវិតក្កជាដើម សូម្បីតែវិតក្ក ១ បទក្រៅអំពីនេះ ជាវេវចនៈនៃបទថា **វិតក្កំ** នោះឯង វិតក្កក្នុងបទថា **វិតក្កបថេសុ** នេះ

បានដល់ គន្ធវិតក្ក ។ ក្នុងបទថា **អហំ ហិ ព្រាហ្មណា** ជាដើម គប្បីជ្រាបថា ដោយន័យទី ១ លោកពោលដល់សីល និងពហុសច្ចរបស់ព្រះខីណាស្រព ដោយន័យទី ២-៣ លោកពោលដល់កិរិយវិតក្ក វិតក្កដែលកើតអំពីកិរិយា និងកិរិយជ្ឈាន គឺឈានដែលកើតអំពីកិរិយារបស់ព្រះខីណាស្រព ដោយន័យទី ៤ លោកពោលដល់ភាពជាព្រះខីណាស្រព ដូច្នេះ ។

បទថា **មច្ចុធាសា បមោចនំ** គឺផ្លូវដែលរួចផុតចាកអន្ទាក់នៃមច្ចុ ។ បទថា **ញាយំ ធម្មំ** គឺមគ្គ ព្រមដោយវិបស្សនា ។ បទថា **ទិស្វា ច សុត្វា ច** សេចក្តីថា បានឃើញ និងបានស្តាប់ហើយ ដោយញាណនោះឯង បទដ៏សេស ក្នុងសូត្រនេះ ងាយយល់ទាំងអស់ហើយ ៕

**អដ្ឋកថាវស្សការសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ទោណសូត្រទី ៦

[ ៣៧ ] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់ផ្លូវឆ្ងាយ ក្នុងចន្លោះឧក្កដ្ឋនគរ និងសេតព្យនគរ ។ ចំណែកទោណព្រាហ្មណ៍ក៏ដើរទៅកាន់ផ្លូវឆ្ងាយ ក្នុងចន្លោះឧក្កដ្ឋនគរ និងសេតព្យនគរដែរ ។ ទោណព្រាហ្មណ៍

ក៏បានឃើញកង់ចក្រទាំងឡាយមួយពាន់ ក្នុងស្នាមព្រះបាទទាំងគូរបស់ព្រះដ៏មានព្រះភាគ ដែលប្រកបដោយខ្នងកង់ និងដុំ បរិបូណ៌ដោយអាការគ្រប់យ៉ាង លុះឃើញហើយ មានសេចក្តីត្រិះរិះដូច្នេះថា ឃើអើ អស្ចារ្យណាស់ហ្ន៎ ឃើអើ មិនដែលមានទេ ស្នាមជើងទាំងពីរនេះ មិនដែលមានដល់មនុស្សធម្មតាទេ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ក៏ទ្រង់យាងបែរចេញអំពីផ្លូវ ហើយទ្រង់គង់ផ្គត់ព្រះភ្នែន តម្កល់ព្រះកាយឲ្យត្រង់ តម្រង់ព្រះស្មារតីឲ្យនឹង ក្រោមម្លប់ឈើមួយ ។ ឯទោណព្រាហ្មណ៍ ដើរទៅតាមស្នាមព្រះបាទព្រះដ៏មានព្រះភាគ ក៏បានឃើញព្រះដ៏មានព្រះភាគគួរជាទីជ្រះថ្លា ជាទីរីករាយ មានព្រះឥន្ទ្រិយស្ងប់រម្ងាប់ មានព្រះហឫទ័យស្ងប់ស្ងាត់ បានដល់នូវអរហត្តមគ្គ និងអរហត្តមគ្គសមាធិដ៏ឧត្តម ស្រគត់ស្រគំ រម្យទម មានឥន្ទ្រិយរក្សាហើយ ជាបុគ្គលដ៏ប្រសើរ គង់ក្រោមម្លប់ឈើមួយ លុះឃើញហើយ ក៏ចូលទៅរកព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា លោកដ៏ចម្រើននឹងកើតជាទេវតា ។ ព្រះអង្គតបថា ម្នាលព្រាហ្មណ៍ តថាគតនឹងមិនកើតជាទេវតាទេ ។ លោកដ៏ចម្រើននឹងកើតជាគន្ធព្វ ។ ម្នាលព្រាហ្មណ៍ តថាគតនឹងមិនកើតជាគន្ធព្វទេ ។ លោកដ៏ចម្រើននឹងកើតជាយក្ខ ។ ម្នាលព្រាហ្មណ៍ តថាគតនឹងមិនកើតជាយក្ខទេ ។ លោកដ៏ចម្រើននឹងកើតមនុស្សឬ ។ ម្នាលព្រាហ្មណ៍ តថាគតនឹងមិនកើតជាមនុស្សទេ ។ ទោណព្រាហ្មណ៍ពោលថា កាលខ្ញុំសួរថា លោកដ៏ចម្រើននឹងកើតជាទេវតាឬ លោកពោលថា ម្នាលព្រាហ្មណ៍ តថាគតនឹងមិនកើត

ជាទេវតាទេ កាលខ្ញុំសួរថា លោកដ៏ចម្រើន នឹងកើតជាគន្ធព្វឬ លោកពោលថា ម្នាលព្រាហ្មណ៍ តថាគតនឹងមិនកើតជាគន្ធព្វទេ កាលខ្ញុំសួរថា លោកដ៏ចម្រើននឹងកើតជាយក្ខឬ លោកពោលថា ម្នាលព្រាហ្មណ៍ តថាគតនឹងមិនកើតជាយក្ខទេ កាលខ្ញុំសួរថា លោកដ៏ចម្រើន នឹងកើតជាមនុស្សឬ លោកពោលថា ម្នាលព្រាហ្មណ៍ តថាគតនឹងមិនកើតជាមនុស្សទេ កាលបើដូច្នេះ តើលោកដ៏ចម្រើន នឹងទៅកើតជាអ្វីទៅ ។ ម្នាលព្រាហ្មណ៍ បើតថាគតកើតជាទេវតា ព្រោះថា តថាគតមិនបានលះបង់អាសវៈទាំងឡាយណា អាសវៈទាំងឡាយនោះ តថាគតបានលះបង់ស្រឡះហើយ បានគាស់រម្លើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ម្នាលព្រាហ្មណ៍ បើតថាគតកើតជាគន្ធព្វ ព្រោះតថាគតមិនទាន់បានលះបង់នូវអាសវៈទាំងឡាយណា ... បើកើតជាយក្ខ ... បើកើតជាមនុស្ស អាសវៈទាំងឡាយនោះ តថាគតបានលះបង់ស្រឡះហើយ បានគាស់រម្លើងឫសគល់អស់ហើយ ធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។ ម្នាលព្រាហ្មណ៍ ផ្កាព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី កើតឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក ដុះផុតអំពីទឹក មិនជាប់ដោយទឹកវិញទេ យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ តថាគតដែលកើតឡើងក្នុងលោក ចម្រើនឡើងក្នុងលោក រមែងគ្របសង្កត់នូវលោក មិនបានជាប់ជំពាក់ ដោយលោកវិញក៏យ៉ាងនោះដែរ ម្នាលព្រាហ្មណ៍ អ្នកចូរ

ចំណាំតថាគតថា ព្រះពុទ្ធដូច្នេះចុះ ។

តថាគតគប្បីកើតជាទេវតា ឬកើតជាគន្ធព្វ ត្រាច់ទៅតាមអាកាស ព្រោះអាសវៈណាក្តី គប្បីដល់នូវភាពនៃខ្លួនជាយក្ខ និងដួប ប្រទះនូវភាពនៃខ្លួនជាមនុស្ស ព្រោះអាសវៈណាក្តី អាសវៈទាំង អស់នោះ របស់តថាគតអស់ហើយ បានកម្ចាត់បង់ហើយ ធ្វើ ឲ្យរបួតចំណាងហើយ ។ ផ្កាឈូកសដុះឡើងផុត ( ពីទឹក ) មិន ជាប់ដោយទឹក យ៉ាងណា តថាគតមិនជាប់ដោយលោកយ៉ាង នោះ ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ តថាគតជាព្រះពុទ្ធ ។

# អដ្ឋកថា

## ទោណសូត្រ

[ ៣៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទោណសូត្រទី ៦ ដូចតទៅនេះ បទថា **អន្តរា ច ឧក្កដ្ឋំ អន្តរា ច សេតព្យំ** នេះ បទថា **ឧក្កដ្ឋា** បានដល់ នគរដែលគេស្គាល់យ៉ាងនោះ ព្រោះគេអុជគប់ភ្លើងសាងហើយ ។ បទថា **សេតព្យំ** បានដល់ នគរដែលកើតរបស់ព្រះកស្សបសម្មាសម្ពុទ្ធ ក្នុងអតីត-កាល ។ ឯ **អន្តរា** សព្ទ ប្រើក្នុងអត្ថថា ហេតុ ខណៈ ចិត្ត ត្រង់កណ្តាល និងចន្លោះ ប្រើក្នុងអត្ថថា ហេតុ ដូចក្នុងបាលីជាដើមថា **តទនន្តរំ កោ**

**ជានេយ្យ អញ្ញត្រ តថាគតេន** *អ្នកណាគប្បីដឹងបាននូវហេតុនោះកើត លើកលែងតែព្រះតថាគតចេញ និងថា* **ឯឆា សង្គម្ម មន្តេន្តិ មញ្ច តញ្ច កិមន្តរំ** *ជនទាំងឡាយមកប្រជុំនិយាយគ្នា ទៀបធ្មេរស៊ីងទាំងឡាយផង ... ហើយនិយាយចំពោះខ្ញុំផង ចំពោះលោកផង តើព្រោះហេតុអ្វី ។ ប្រើក្នុងអត្ថថា ឋានៈ ដូចក្នុងបាលីជាដើមថា* **អទ្ទសា ខោ មំ ភន្តេ អញ្ញតរា ឥត្ថី វិជ្ជន្តរិកាយ ភាជនំ ធោវន្តី** *បពិត្រព្រះអង្គដ៏ចម្រើន ស្រីម្នាក់កំពុងលាងភាជនៈ បានឃើញខ្ញុំព្រះអង្គ ក្នុងខណៈមានផ្លេកបន្ទោរដូច្នេះ ។ ប្រើក្នុងអត្ថថា ចិត្ត ដូចក្នុងបាលីជាដើម* **យស្សន្តរតោ ន សន្តិ កោបា** *សេចក្តីក្រោធមិនមានក្នុងចិត្តរបស់បុគ្គលណា .... ដូច្នេះ ។ ប្រើក្នុងអត្ថថា កណ្តាល ដូចក្នុងបាលីជាដើមថា* **អន្តរា វោសានមាបាទិ** *ដល់នូវការបញ្ចប់ ( បន្ធូរបន្ថយសេចក្តីព្យាយាម ) ត្រង់កណ្តាលដូច្នេះ ។ ប្រើក្នុងអត្ថថា ចន្លោះ ដូចក្នុងបាលីជាដើមថា* **អបិចាយំ ភិក្ខវេ តបោទា ទ្វិន្នំ មហានិរយានំ អន្តរិកាយ អាគច្ឆតិ** *ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែស្ទឹងតបោទានេះ មកតាមចន្លោះនៃមហានរកទាំងពីរ ដូច្នេះ ។* **អន្តរា** *សព្ទនេះ ក្នុងទីនេះ ប្រើក្នុងអត្ថថា ចន្លោះ ព្រោះដូច្នោះ គប្បីឃើញអត្ថក្នុងពាក្យនេះយ៉ាងនេះថា ក្នុងចន្លោះឧក្កដ្ឋនគរ និងសេតព្យនគរ ដូច្នេះ ។ លោកធ្វើជាទុតិយាវិភត្តិ ព្រោះប្រកបដោយ* **អន្តរា** *សព្ទ ។ ឯពួកអាចារ្យអ្នកលេងអក្ខរៈ ក្នុងឋានៈដូច្នេះ រមែងប្រកប* **អន្តរា** *សព្ទណាមួយ ក្នុងពាក្យយ៉ាងនេះថា* **អន្តរា គាមញ្ច នគរញ្ច យាតិ** *បុគ្គលដើរទៅក្នុងចន្លោះស្រុក និងស្ទឹង ដូច្នេះ* **អន្តរា** *សព្ទ*

នោះ គប្បីប្រកបដោយបទទី ២ កាលមិនប្រកប ក៏មិនសម្រេចជាទុតិយា-វិភត្តិ តែក្នុងទីនេះ លោកប្រកបហើយ ទើបពោលយ៉ាងនេះ ។

បទថា **អទ្ធានមគ្គប្បដិបន្នោ ហោតិ** គឺទ្រង់ដើរផ្លូវឆ្ងាយ អធិប្បាយថា ផ្លូវវែង ។ សួរថា ទ្រង់ដើរផ្លូវឆ្ងាយ ព្រោះហេតុអ្វី ។ ឆ្លើយថា បានឮថា ក្នុងថ្ងៃនោះ ព្រះមានព្រះភាគទ្រង់បានឃើញហេតុនេះថា កាលតថាគតដើរទៅផ្លូវនោះ ទោណព្រាហ្មណ៍ឃើញចេតិយ គឺស្នាមជើងរបស់តថាគត ក៏នឹងដើរតាមដល់ទីដែលតថាគតអង្គុយ ហើយសួរបញ្ហា កាលបើដូច្នោះ តថាគតនឹងសម្តែងសច្ចធម៌ដល់ទោណយ៉ាងនេះ ព្រាហ្មណ៍នឹងចាក់ធ្លុះសាមញ្ញផល ៣ ហើយនឹងពណ៌នាគុណ ឈ្មោះទោណគជ្ជិត ១២០០០ បទ កាលតថាគតបរិនិព្វានហើយ នឹងរម្ងាប់ការវិវាទដ៏ធំ ដែលកើតឡើងក្នុងជម្ពូទ្វីប ហើយទើបចែកព្រះធាតុទាំងឡាយ ដូច្នេះ ទើបទ្រង់ធ្វើដំណើរដោយហេតុនេះ ។

បទថា **ទោណោបិ សុទំ ព្រាហ្មណោ** សេចក្តីថា ទោណព្រាហ្មណ៍ជំនាញក្នុងត្រៃវេទ កាលបង្រៀនសិប្បៈដល់ពួកមាណព ៥០០ នាក់ ក្នុងថ្ងៃនោះ ក្រោកឡើងអំពីព្រលឹម ធ្វើកិច្ចផ្ទាល់ខ្លួនស្រេចហើយ ស្លៀកសំពត់តម្លៃ ១០០ ប្រើរបស់មានតម្លៃ ៥០០ ជំនាញដោយយញ្ញ ពាក់ស្បែកជើងខៀវក្រហម មានមនុស្ស ៥០០ ចោមរោម បានដើរទៅតាមផ្លូវនោះដូចគ្នា ។ ពាក្យនេះ លោកពោលសំដៅដល់សេចក្តីនោះ ។ បទថា **ធាតេសុ** បានដល់ដោយស្នាមដែលទ្រង់ជាន់ដោយព្រះបាទ ។ បទថា **ចក្កានិ** បានដល់ ចក្ក-

លក្ខណៈ គឺរូបចក្រ សួរថា កាលព្រះមានព្រះភាគទ្រង់យាងទៅ ស្នាមព្រះបាទប្រាកដក្នុងទីដែលទ្រង់ជាន់ឬ ។ ឆ្លើយថា មិនប្រាកដទេ ។ ព្រោះហេតុអ្វី ព្រោះស្នាមព្រះបាទល្អិត មានកម្លាំងច្រើន និងព្រោះអនុគ្រោះមហាជន ។

ពិតហើយ ព្រោះព្រះពុទ្ធទាំងឡាយ ទ្រង់មានឆវីវណ្ណល្អិត ទីដែលទ្រង់ជាន់ ដូចទីដែលសំឡីតាំងនៅ ទើបស្នាមព្រះបាទមិនប្រាកដ ។ ស្នាមដែលព្រះតថាគតទ្រង់ជាន់ ក៏ត្រឹមតែជាន់ប៉ុណ្ណោះ ទើបស្នាមព្រះបាទមិនប្រាកដក្នុងទីនោះ ព្រោះទ្រង់ជាអ្នកមានកម្លាំងច្រើន ដូចស្នាមជើងរបស់សេះសិន្ធពដែលមានកម្លាំងជើងរហ័សដូចខ្យល់ ជាន់លើស្លឹកឈូករបស់គុម្ពបទុម ក៏ត្រឹមតែជាន់ប៉ុណ្ណោះ ដូច្នោះ ។ ឯពួកមហាជនដើរតាមស្នាមព្រះបាទរបស់ព្រះពុទ្ធទាំងឡាយទៅ កាលមហាជននោះ ឃើញស្នាមព្រះបាទរបស់ព្រះសាស្តា ក៏មិនអាចជាន់ពីលើ គប្បីដើរចៀសចេញ ព្រោះដូច្នោះ ស្នាមព្រះបាទណា គប្បីមានក្នុងទីដែលទ្រង់ជាន់ហើយ ស្នាមព្រះបាទនោះ ក៏បាត់ទៅភ្លាម ចំណែកទោណព្រាហ្មណ៍ឃើញបាន ដោយអំណាចអធិដ្ឋានរបស់ព្រះតថាគត សូម្បីព្រះមានព្រះភាគទ្រង់បំណងសម្តែងចេតិយ គឺព្រះបាទដល់បុគ្គលណា ប្រារព្ធដល់បុគ្គលនោះ ទ្រង់អធិដ្ឋានថា បុគ្គលឈ្មោះនោះ ចូរឃើញដូច្នេះ ព្រោះដូច្នោះ ព្រាហ្មណ៍នេះ បានឃើញដោយអំណាចការអធិដ្ឋានរបស់ព្រះតថាគត ដូចមាគណ្ឌិយព្រាហ្មណ៍ដែរ ។

បទថា **ចាសាទិកំ** គឺឲ្យកើតសេចក្តីជ្រះថ្លា ។ បទក្រៅអំពីនេះ ជាវេវចនៈនៃបទថា **ចាសាទិកំ** នោះឯង ។ ក្នុងបទថា **ឧត្តមទមថសមថ-**

**មនុប្បត្តំ** នេះ គប្បីជ្រាបដូច្នេះ អរហត្តមគ្គ ឈ្មោះថា ការទូន្មានយ៉ាងឧត្តម អរហត្ត មគ្គសមាធិ ឈ្មោះថា ការស្ងប់ដ៏ឧត្តម អធិប្បាយថា ទ្រង់សម្រេច ទាំង ២ យ៉ាងនោះ ។ បទថា **ឆន្ទំ** គឺអស់នូវព្យសន៍ ។ បទថា **គុត្តំ** គឺរក្សា ឃុំគ្រង ។ បទថា **យតិន្ទ្រិយំ** គឺរក្សាឥន្ទ្រិយ ។ បទថា **នាគំ** សេចក្តីថា ឈ្មោះថា នាគ ព្រោះហេតុ ៤ គឺព្រោះមិនដល់អគតិ មានឆន្ទាគតិជាដើម ១ ព្រោះមិនត្រឡប់មកកាន់កិលេសដែលលះបានហើយ ១ ព្រោះមិនធ្វើបាប ១ ព្រោះអត្តថា មានកម្លាំង ១ ។ ក្នុងបទថា **ទេវោ នោ ភវំ ភវិស្សតិ** នេះ ការសួរគប្បីចប់ដោយពាក្យប្រមាណប៉ុណ្ណោះថា លោកដ៏ចម្រើន ជាទេវតាឬ ដូច្នេះ តែព្រាហ្មណ៍នេះ សួរដោយអនាគត កាលថា ព្រះអង្គនឹងជាទេវរាជ មួយអង្គដែលមានសក្តិធំក្នុងអនាគតកាលទេដឹង ដូច្នេះ ទើបពោលយ៉ាងនោះ ព្រះមានព្រះភាគ កាលត្រាស់ដោយប្រពៃ ដោយពាក្យសួររបស់ព្រាហ្មណ៍ នោះ ទើបត្រាស់ថា ម្នាលព្រាហ្មណ៍ តថាគតមិនមែនជាទេវតាទេ ។ ក្នុងបទ ទាំងអស់ក៏មានន័យដូច្នេះ ។ បទថា **អាសវានំ** បានដល់ អាសវៈ ៤ មាន កាមាសវៈជាដើម ។ បទថា **បហីនា** សេចក្តីថា អាសវៈទាំងនោះ តថាគត លះបានហើយ ដោយការសម្រេចសព្វញ្ញុតញ្ញាណនាពោធិបល្ល័ង្ក ។ បទថា **អនុបលិត្តោ លោកេន** សេចក្តីថា លោក គឺសង្ខារលោកចូលមកជ្រាប ចូលក្នុងចិត្តរបស់តថាគតមិនបាន ព្រោះតថាគតលះគ្រឿងលាប គឺតណ្ហា និងទិដ្ឋិចេញហើយ ។ បទថា **ពុទ្ធោ** សេចក្តីថា អ្នកចូរស្គាល់តថាគតថាជា **ពុទ្ធ** ព្រោះត្រាស់ដឹងសច្ចៈ ៤ ដូច្នេះ ។

បទថា **យេន** គឺព្រោះអាសវៈណា ។ បទថា **ទេវូបបត្យស្ស** សេចក្តីថា តថាគតគប្បីបានកំណើតជាទេវតា ។ បទថា **វិហង្គមោ** បានដល់ ទេវតាប្រភេទគន្ធព្វ ព្រោះហោះហើរបាន ។ បទថា **វិទ្ធស្តា** ប្រែថា ទម្លាយហើយ ។ បទថា **វិនឡីកតា** បានដល់ ធ្វើឲ្យប្រាសចាកគ្រឿងផ្សារភ្ជាប់ គឺប្រាសចាកគ្រឿងចង ។ បទថា **តោយេន នុបលិប្បតិ** សេចក្តីថា ផ្កាឈូកសដែលផុសឡើងផុតអំពីទឹកមួយហត្ថ ដែលធ្វើឲ្យស្រស់ស្អាត ធ្វើហ្វូងកមរឲ្យត្រេកអរ ទឹកជ្រាបចូលមិនបាន ។ បទថា **តស្មា ពុទ្ធោស្មិ ព្រាហ្មណា** សេចក្តីថា ចប់ទេសនា ព្រាហ្មណ៍សម្រេចផល ៣ ទើបពោលគុណឈ្មោះថា **ទោណគជ្ជិត** គឺសំឡេងគ្រហឹមរបស់ទោណព្រាហ្មណ៍ ដោយគាថា ១២០០០ បទ ។ កាលព្រះតថាគតបរិនិព្វានហើយ ទោណព្រាហ្មណ៍រម្ងាប់នូវជម្លោះយ៉ាងធំដែលកើតឡើង ពេញផ្ទៃជម្ពូទ្វីបហើយ ទើបបានចែកនូវព្រះធាតុទាំងឡាយដល់គ្នា ដូចពណ៌នាមកនេះ ។

## អដ្ឋកថាទោណសូត្រទី ៦ ចប់

# សុត្តន្តបិដក

## អបរិហានិសូត្រទី ៧

[ ៣៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយធម៌ ៤ យ៉ាងមិនគួរសាបសូន្យ តែងនៅក្នុងទីជិតនៃព្រះនិព្វាន ។ ប្រកបដោយធម៌ ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីលបរិបូណ៌ ១ ជាអ្នកមានទ្វារគ្រប់គ្រងហើយក្នុងឥន្ទ្រិយទាំងឡាយ ១ ជាអ្នកដឹងប្រមាណក្នុងភោជន ១ ជាអ្នកប្រកបរឿយៗ នូវការភ្ញាក់រឭក ១ ។ ម្នាលភិក្ខុទាំង-ឡាយ ចុះភិក្ខុមានសីលបរិបូណ៌ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈ និងគោចរ អ្នកឃើញនូវភ័យក្នុងទោសគ្រាន់តែបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសីលបរិបូណ៌យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកមានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានឃើញរូបដោយចក្ខុហើយ មិនកួចកាន់នូវនិមិត្ត មិនកួចកាន់នូវអនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្សដែលជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវភិក្ខុដែលមិនបានសង្រួមចក្ខុន្ទ្រិយ ព្រោះហេតុមិនបានសង្រួមនូវចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ បានឮសំឡេងដោយត្រចៀក ... បានហិតក្លិនដោយច្រមុះ ... បានទទួលរសដោយអណ្តាត ... ពាល់ត្រូវផោដ្ឋព្វៈ

ដោយកាយ ... ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ជាអ្នកមិនកួចកាន់នូវនិមិត្ត មិនកួចកាន់នូវអនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្សជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវភិក្ខុដែលមិនបានសង្រួមមនិន្ទ្រិយ ព្រោះហេតុមិនបានសង្រួមនូវមនិន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវមនិន្ទ្រិយនោះ រក្សានូវមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានទ្វារគ្រប់គ្រងហើយ ក្នុងឥន្ទ្រិយទាំងឡាយ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអ្នកដឹងប្រមាណក្នុងភោជន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយនៃបញ្ញា នឹងបរិភោគនូវអាហារដើម្បីលេងក៏ទេ ដើម្បីស្រវឹងក៏ទេ ដើម្បីប្រដាប់តាក់តែងរាងកាយក៏ទេ ដើម្បីឲ្យផូរផង់សម្បុរក៏ទេ ដើម្បីនឹងឲ្យតាំងនៅនៃកាយនេះ ដើម្បីនឹងញ៉ាំងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់បង់នូវសេចក្តីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចារ្យប៉ុណ្ណោះឯង អាត្មាអញនឹងឃាត់បង់នូវវេទនាចាស់ផង មិនឲ្យវេទនាថ្មីកើតឡើងផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្តី សេចក្តីមិនមានទោសក្តី កិរិយានៅសប្បាយក្តីនឹងមានដល់អាត្មាអញផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកដឹងប្រមាណក្នុងភោជនយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកប្រកបរឿយៗ នូវការភ្ញាក់រឭក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅចង្ក្រមក្នុងវេលាថ្ងៃ សម្អាតចិត្តចាកអាវរណីយធម៌ទាំងឡាយ ចូលទៅចង្ក្រមអស់បឋមយាមនៃរាត្រី សម្អាតចិត្តចាកអាវរណីយធម៌ទាំងឡាយ សម្រេចសីហសេយ្យា

ដោយបង្អៀងខាងស្តាំអស់មជ្ឈិមយាមនៃរាត្រី តម្រួតជើងលើជើង មានស្មារតី ជាអ្នកដឹងខ្លួន ធ្វើទុកក្នុងចិត្តនូវឧដ្ឋានសញ្ញាដល់បច្ឆិមយាមនៃរាត្រី ក្រោកឡើងចូលទៅចង្ក្រម សម្អាតចិត្តចាកអាវរណីយធម៌ទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រកបរឿយៗ នូវការភ្ញាក់រឮកយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយធម៌ទាំង ៤ នេះ មិនគួរសាបសូន្យ តែងនៅក្នុងទីជិតនៃព្រះនិព្វាន ។ ភិក្ខុឋិតនៅក្នុងសីលផង សង្រួមក្នុងឥន្ទ្រិយទាំងឡាយផង ដឹងប្រមាណក្នុងភោជនផង ប្រកបរឿយៗ ក្នុងការភ្ញាក់រឮកផង កាលភិក្ខុប្រកបដោយសេចក្តីព្យាយាម មិនខ្ជិលច្រអូសទាំងថ្ងៃទាំងយប់ ចម្រើននូវកុសលធម៌ ដើម្បីដល់នូវព្រះនិព្វាន ជាទីក្សេមចាកយោគៈ យ៉ាងនេះ ភិក្ខុដែលមានសេចក្តីត្រេកអរ ក្នុងសេចក្តីមិនប្រមាទ ឬឃើញភ័យក្នុងសេចក្តីប្រមាទ មិនគួរដើម្បីសាបសូន្យ តែងនៅក្នុងទីជិតនៃព្រះនិព្វាន ។

# អដ្ឋកថា

## អបរិហានិសូត្រ

[ ៣៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអបរិហានិសូត្រទី ៧ ដូចតទៅនេះ បទថា **និព្វានស្សេវ សន្តិកេ** សេចក្តីថា ភិក្ខុប្រព្រឹត្តក្នុងទីជិតព្រះនិព្វាននោះឯង ។ បទថា **សីលេ បតិដ្ឋិតោ** បានដល់ ភិក្ខុតាំងនៅក្នុងបាតិមោក្ខ-

សីល ។ បទថា **ឃរិហារី** ប្រែថា កាលនៅយ៉ាងនេះ ។ បទថា **អាតាបី** គឺប្រកបដោយសេចក្តីព្យាយាម ។ បទថា **យោគក្ខេមស្ស** សេចក្តីថា ដើម្បីសម្រេចគុណដ៏ក្សេមចាកយោគៈ គឺព្រះនិព្វាន ។ បទថា **បមាទេ ភយ-ទស្សិ វា** បានដល់ ឃើញការប្រមាទថា ជាភ័យ ។៚

## អដ្ឋកថា អបរិហានិសូត្រទី ៧ ចប់

# សុត្តន្តបិដក

## បដិលីនសូត្រទី ៨

[ ៣៩ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលតថាគតហៅថា អ្នកមានបច្ចេកសច្ចៈបន្ទោបង់ហើយ ១ មានការស្វែងរកលះបង់ហើយដោយបរិបូណ៌ ១ មានកាយសង្ខារស្ងប់រម្ងាប់ ១ ជាអ្នកពួនសម្ងំ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកមានបច្ចេកសច្ចៈបន្ទោបង់ហើយ តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ ពួកបច្ចេកសច្ចៈដ៏ច្រើនណារបស់ពួកសមណៈ និងព្រាហ្មណ៍ដ៏ច្រើនដោយយល់ថា លោកទៀងដូច្នេះក៏មាន លោកមិនទៀងដូច្នេះក៏មាន លោកមានទីបំផុតដូច្នេះក៏មាន លោកមិនមានទីបំផុតដូច្នេះក៏មាន ជីវិតនោះគឺសរីរៈនោះដូច្នេះក៏មាន ជីវិតដទៃ សរីរៈដទៃដូច្នេះក៏មាន សត្វស្លាប់ទៅកើតទៀតដូច្នេះក៏មាន សត្វស្លាប់ទៅមិនកើតទៀតដូច្នេះក៏មាន សត្វស្លាប់ទៅកើតទៀត

ខ្វះ មិនកើតទៀតខ្វះដូច្នេះក៏មាន សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក៏មាន ពួកបច្ចេកសច្ចៈទាំងអស់នោះ ភិក្ខុក្នុងសាសនានេះ បន្ទោបង់ហើយ កម្ចាត់បង់ហើយ លះបង់ហើយ ខ្ជាក់ចោលហើយ ប្បូតចេញហើយ បណ្តេញបង់ហើយ បំបាត់បង់ហើយ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុជាអ្នកមានបច្ចេកសច្ចៈបន្ទោបង់ហើយ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអ្នកមានការស្វែងរកលះបង់ហើយដោយបរិបូណ៌ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកកាម ភិក្ខុក្នុងសាសនានេះលះបង់ហើយ ( ដោយអនាគាមិមគ្គ ) ការស្វែងរកភព ភិក្ខុលះបង់ហើយ ( ដោយអរហត្តមគ្គ ) ការស្វែងរកព្រហ្មចារ្យ ភិក្ខុបានរម្ងាប់ហើយ ( ដោយអរហត្តមគ្គ ) ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានការស្វែងរក លះបង់ហើយដោយបរិបូណ៌យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអ្នកមានកាយ-សង្ខារស្ងប់រម្ងាប់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់សុខផង ព្រោះលះបង់ទុក្ខផង ព្រោះរលត់សោមនស្សទោម-នស្សក្នុងកាលមុនផង ដល់នូវចតុត្ថជ្ឈាន មិនទុក្ខមិនសុខ មានឧបេក្ខា និងសតិដ៏បរិសុទ្ធ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានកាយសង្ខារស្ងប់រម្ងាប់ហើយយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអ្នកពួនសម្ងំ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អស្មិមានះ ភិក្ខុក្នុងសាសនានេះលះបង់ហើយ គាស់រម្លើងឫសចោលហើយ ធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។ ម្នាលភិក្ខុទាំង-

ឡាយ ភិក្ខុជាអ្នកពួនសម្ងំយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែល តថាគតហៅថា មានបច្ចេកសច្ចៈបន្ទោបង់ហើយ មានការស្វែងរកលះបង់ ហើយដោយបរិបូណ៌ មានកាយសង្ខារស្ងប់រម្ងាប់ ជាអ្នកពួនសម្ងំយ៉ាង នេះឯង ។

ការប្រកាន់ថា ពិតដូច្នេះៗ នឹងជាទីតាំងនៃទិដ្ឋិ ភិក្ខុដកចោល ហើយ ការស្វែងរក គឺការស្វែងរកកាម ស្វែងរកភព ព្រម ទាំងការស្វែងរកព្រហ្មចារ្យ និងទីតាំងនៃទិដ្ឋិ ភិក្ខុអ្នកប្រាស ចាកតម្រេក ក្នុងរាគៈទាំងពួង អ្នករួចផុតស្រឡះ ព្រោះអស់ ទៅនៃតណ្ហា បានលះបង់ហើយ បានដកចោលហើយ ភិក្ខុ នោះឯងជាអ្នកស្ងប់រម្ងាប់ មានស្មារតី មានកាយ និងចិត្តស្ងប់ រម្ងាប់ មិនចាញ់កិលេស ជាអ្នកដឹងនូវសច្ចៈ ព្រោះស្គាល់ ច្បាស់នូវមានះ តថាគតហៅថា ជាអ្នកពួនសម្ងំ ។

# អដ្ឋកថា

## បដិលីនសូត្រ

[ ៣៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបដិលីនសូត្រទី ៨ ដូចតទៅនេះ បទថា **បនុណ្ណប្បច្ចេកសច្ចោ** បានដល់ ភិក្ខុឈ្មោះថា ជាអ្នកមានបច្ចេកសច្ចៈដែល

ដកបានហើយ ព្រោះថា ទិដ្ឋិសច្ចៈ ពោល គឺការឃើញតែម្យ៉ាង ព្រោះទាញយកនូវការឃើញតែម្យ៉ាង យ៉ាងនេះថា ការឃើញនេះ ប៉ុណ្ណោះពិត លោកដក គឺកម្ចាត់បានហើយ ។ ក្នុងបទថា **សមវយសដ្ឋេសនោ** នេះ បទថា **សមវយ** ប្រែថា មិនខ្វះខាត ។ បទថា **សដ្ឋា** ប្រែថា លះបង់ហើយ ។ ឈ្មោះថា **សមវយសដ្ឋេសនោ** ព្រោះលះការស្វែងរកដោយឥតសេសសល់ អធិប្បាយថា បុគ្គលដែលលះការស្វែងរកគ្រប់យ៉ាង ដោយប្រពៃ ។ បទថា **បដិលីនោ** ប្រែថា ជាអ្នកពួនសម្ងំ គឺនៅម្នាក់ឯង ។ បទថា **បុថុស្ស-មណាព្រាហ្មណានំ** បានដល់ សមណៈ និងព្រាហ្មណ៍ដ៏ច្រើន ក្នុងពាក្យថា **សមណាព្រាហ្មាណានំ** នេះ បុគ្គលដែលចូលទៅបួស ឈ្មោះថា សមណៈ បុគ្គលដែលពោលថា **ភោ** អ្នកដ៏ចម្រើន ឈ្មោះថា ព្រាហ្មណ៍ ។

បទថា **បុថុប្បច្ចេកសច្ចានិ** បានដល់ សច្ចៈតែម្យ៉ាងដ៏ច្រើន ។ បទថា **នុណ្ណានិ** ប្រែថា នាំចេញហើយ ។ បទថា **បនុណ្ណានិ** ប្រែថា នាំចេញល្អហើយ ។ បទថា **ចត្តានិ** ប្រែថា រលាស់ហើយ ។ បទថា **វន្តានិ** ប្រែថា ខ្ជាក់ចេញហើយ ។ បទថា **មុត្តានិ** គឺធ្វើគ្រឿងចងឲ្យដាច់ហើយ ។ បទថា **បហីនានិ** ប្រែថា លះបានហើយ ។ បទថា **បដិនិស្សដ្ឋានិ** ប្រែថា លះចោលហើយ ដោយមិនដុះឡើងក្នុងចិត្តទៀត ។ បទទាំងអស់ ជាពាក្យប្រើជំនួសការលះបង់នូវការប្រកាន់ដែលប្រកាន់ហើយ ។ បទថា **កាមេសនា បហីនា ហោតិ** បានដល់ ការស្វែងរកកាម ដែលលះបានហើយ ដោយអនាគាមិមគ្គ ។ ឯការស្វែងរកភព ឈ្មោះថា កំពុងលះដោយអរហត្តមគ្គ

ការស្វែងរកព្រហ្មចរិយៈ គឺអធ្យាស្រ័យដែលប្រព្រឹត្តទៅហើយយ៉ាងនេះថា អញនឹងស្វែងរកព្រហ្មចរិយៈ ដូច្នេះ ក៏ស្ងប់រម្ងាប់ទៅដោយអរហត្តមគ្គនោះឯង ។ ឯការស្វែងរកទិដ្ឋិព្រហ្មចរិយៈ ក៏គប្បីពោលបានថា រមែងរម្ងាប់ទៅដោយសោតាបត្តិមគ្គតែម្យ៉ាង ។ បទថា **ឯវំ ខោ ភិក្ខវេ** សេចក្ដីថា កាយសង្ខាររម្ងាប់ហើយដោយចតុត្ថជ្ឈានយ៉ាងនេះ ក៏ឈ្មោះថា ខ្យល់អស្សាសបស្សាសៈស្ងប់ហើយ ។ បទថា **អស្មិមានោ** បានដល់ មានះ ៩ យ៉ាង ដែលកើតឡើងថា ជាអញ ។

គាថាទាំងឡាយ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ការស្វែងរកមាន ២ គឺការស្វែងកាម ១ ការស្វែងរកភព ១ ។ បទថា **ព្រហ្មចរិយេសនា សហា** សេចក្ដីថា ការស្វែងរកនោះជា ៣ គឺស្វែងរកព្រហ្មចរិយៈ រួមទាំងការស្វែងរក ២ នោះ គប្បីបញ្ជាក់ក្នុងទីនេះ ហើយប្រកបសេចក្ដីនឹងបទនេះថា **ឯសនា បដិនិស្សដ្ឋា** លះបង់ការស្វែងរក ។ បទថា **ឥតិ សច្ចបរាមាសោ ទិដ្ឋិដ្ឋានា សមុស្សយា** សេចក្ដីថា កាលប្រកាន់ថា នេះពិត នេះពិត នឹងទីតាំងនៃទិដ្ឋិ ពោល គឺទិដ្ឋិនោះឯង ដែលហៅថា **សមុស្សយ** ព្រោះកាយត្រូវធាតុ ៤ សាងឡើង គឺលើកឡើង តម្កល់ទុកគ្រប់យ៉ាង ។ គប្បីបញ្ជាក់ទីនេះ ហើយប្រកបសេចក្ដីជាមួយបទនេះថា **ទិដ្ឋិដ្ឋានា សមូហតា** ដកនូវកាយដែលជាទីតាំងនៃទិដ្ឋិ សួរថា បុគ្គលណាវៀរនូវការស្វែងរកទាំងនោះ និងបុគ្គលណាដកទីតាំងនៃទិដ្ឋិទាំងនោះបានហើយ ។ ឆ្លើយថា ភិក្ខុដែលប្រាសចាកតម្រេកទាំងពួងហើយ បាននូវវិមុត្តិ ព្រោះអស់តណ្ហា ដ្បិតថា

ភិក្ខុណាប្រាសចាកតម្រេកហើយ ចាករាគៈទាំងពួង ជាអ្នកប្រកបដោយអរហត្តផលវិមុត្តិ ដែលប្រព្រឹត្តទៅ ព្រោះអស់តណ្ហា គឺព្រោះរលត់ដោយឥតសេសសល់ ភិក្ខុនោះលះបង់នូវការស្វែងរកបានហើយ និងជកកាយដែលជាទីតាំងនៃទិដ្ឋិបានហើយ ។ បទថា **ស វេ សន្តោ** សេចក្តីថា ភិក្ខុនោះ គឺភិក្ខុបែបនេះ ឈ្មោះថា ស្ងប់ ព្រោះកិលេសស្ងប់ ។ បទថា **បស្សទ្ធោ** បានដល់ រម្ងាប់ហើយ ដោយកាយបស្សទ្ធិ និងចិត្តបស្សទ្ធិទាំង ២ ។ បទថា **អបរាជិតោ** សេចក្តីថា ឈ្មោះថា ដែលបុគ្គលណាមួយធ្វើឲ្យចាញ់មិនបាន ព្រោះឈ្នះកិលេសសព្វយ៉ាងហើយ ។ បទថា **មានាភិសមយា** គឺព្រោះលះមានះបាន ។ បទថា **ពុទ្ធោ** សេចក្តីថា ជាអ្នកត្រាស់ដឹងសច្ចៈទាំង ៤ តាំងនៅ ។ ដោយហេតុនោះ ក្នុងសូត្រក្តី ក្នុងគាថាក្តី ទើបទ្រង់ត្រាស់តែបុគ្គលដែលអស់អាសវៈតែម្យ៉ាង ៕

**អដ្ឋកថា បដិលីនសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## ឧជ្ជយសូត្រទី ៩

[ ៤០ ] គ្រានោះ ឧជ្ជយព្រាហ្មណ៍ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះ

បញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះឧជ្ជយព្រាហ្មណ៍អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគថា ព្រះគោតមដ៏ចម្រើន សរសើរការបូជារបស់យើងដែរឬទេ ។ ម្នាលព្រាហ្មណ៍ តថាគតមិនសរសើរការបូជាទាំងអស់ទេ ម្នាលព្រាហ្មណ៍ តែតថាគតមិនមែនជាមិនសរសើរការបូជាទាំងអស់ទេ ។ ម្នាលព្រាហ្មណ៍ គេសម្លាប់គោទាំងឡាយ សម្លាប់ពពែ និងចៀមទាំងឡាយ សម្លាប់មាន់ និងជ្រូកទាំងឡាយ សត្វទាំងឡាយផ្សេងៗ ក៏ដល់នូវសេចក្តីស្លាប់ ព្រោះការបូជាមានសភាពយ៉ាងណា ម្នាលព្រាហ្មណ៍ តថាគតមិនសរសើរការបូជាប្រកបដោយសេចក្តីអន្តរាយយ៉ាងនោះឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលព្រាហ្មណ៍ ព្រោះថា ព្រះអរហន្តទាំងឡាយក្តី បុគ្គលទាំងឡាយអ្នកដល់នូវអរហត្តមគ្គក្តី មិនដើរទៅជិតការបូជាប្រកបដោយសេចក្តីអន្តរាយ មានសភាពយ៉ាងនេះឡើយ ។ ម្នាលព្រាហ្មណ៍ គេមិនសម្លាប់គោទាំងឡាយ មិនសម្លាប់ពពែនិងចៀមទាំងឡាយ មិនសម្លាប់មាន់ និងជ្រូកទាំងឡាយ សត្វទាំងឡាយផ្សេងៗ ក៏មិនស្លាប់ ព្រោះការបូជាមានសភាពយ៉ាងណា ម្នាលព្រាហ្មណ៍ តថាគតតែងសរសើរការបូជា ដែលមិនប្រកបដោយសេចក្តីអន្តរាយ មានសភាពយ៉ាងនេះ គឺនិច្ចទាន និងការបូជាតាមលម្អានត្រកូល ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលព្រាហ្មណ៍ ព្រោះថាព្រះអរហន្តទាំងឡាយក្តី បុគ្គលទាំងឡាយអ្នកដល់នូវអរហត្តមគ្គក្តី តែងពេញចិត្តការបូជាដែលមិនប្រកបដោយសេចក្តីអន្តរាយ មានសភាពយ៉ាងនេះ ។

ការបូជាធំ មានកិច្ចដែលត្រូវធ្វើច្រើន គឺការសម្លាប់សេះ សម្លាប់បុរស ការទុកដាក់មនុស្សដោយប្រពៃ ការពោលពាក្យជាទីស្រឡាញ់ ផ្ទះមិនបាច់មានគន្លឹះទ្វារ ការបូជាធំទាំងនោះ មិនមានផលឡើយ គេសម្លាប់ពពែ និងចៀមក្តី គោទាំងឡាយក្តី ពួកសត្វផ្សេងៗ ក្តី ព្រោះការបូជាណា ពួកបុគ្គលអ្នកដល់នូវអរហត្តមគ្គ និងបុគ្គលអ្នកស្វែងរកនូវគុណដ៏ធំ ( ព្រះអរហន្ត ) តែងមិននិយមនូវការបូជានោះទេ ។ ពួកជនបូជាសព្វកាល នូវយញ្ញណាដែលមិនប្រកបដោយសេចក្តីអន្តរាយ តាមលម្អាននៃត្រកូលក្តី គេមិនសម្លាប់ពួកពពែ និងចៀម ឬពួកគោ ឬក៏ពួកសត្វផ្សេងៗ ព្រោះការបូជាណាក្តី ពួកបុគ្គលអ្នកដល់នូវអរហត្តមគ្គ និងបុគ្គលអ្នកស្វែងរកនូវគុណដ៏ធំ ( ព្រះអរហន្ត ) ទើបពេញចិត្តការបូជានោះៗ ។ អ្នកប្រាជ្ញត្រូវបូជាយ៉ាងនេះ ការបូជានុ៎ះមានផលច្រើន ។ ក៏កាលបុគ្គលបូជាយ៉ាងនេះ ទើបប្រសើរ មិនមានបាប ការបូជាឈ្មោះថា មានផលច្រើនផង ទេវតាទាំងឡាយតែងជ្រះថ្លាផង ។

# អដ្ឋកថា

## ឧជ្ជយសូត្រ

[ ៤០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧជ្ជយសូត្រទី ៩ ដូចតទៅនេះ បទថា **សង្ឃាតំ អាបជ្ជន្តិ** សេចក្តីថា សត្វទាំងឡាយរមែងត្រូវសម្លាប់ គឺស្លាប់ ។ បទថា **និច្ចទានំ** បានដល់ សលាកភត្ត ។ បទថា **អនុកុលយញ្ញំ** សេចក្តីថា យញ្ញ គឺទានដែលបុគ្គលគប្បីបូជា គឺគប្បីឲ្យដោយអំណាចបន្តគ្នា មកតាមត្រកូលយ៉ាងនេះ ព្រោះបុព្វបុរសយើងទាំងឡាយឲ្យមកហើយ ។

ក្នុងបទថា **អស្សមេធំ** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូច្នេះ យញ្ញ ឈ្មោះថា **អស្សមេធ** ព្រោះក្នុងយញ្ញនេះ គេសម្លាប់សេះ ពាក្យនោះជាឈ្មោះរបស់យញ្ញ ដែលនឹងឲ្យសម្បត្តិគ្រប់យ៉ាង មិនមានសល់ វៀរលែងតែផែនដី និងមនុស្សទាំងឡាយ ដែលមានបង្គោលបូជា ២១ បង្គោល គប្បីបូជាដោយបរិយញ្ញ ២ ។ យញ្ញ ឈ្មោះថា **បុរិសមេធ** ព្រោះក្នុងយញ្ញនេះ គេសម្លាប់មនុស្ស ពាក្យនោះ ជាឈ្មោះរបស់យញ្ញ ដែលនឹងឲ្យសម្បត្តិដែលពោលហើយ ក្នុងអស្សមេធ មួយអន្លើដោយផែនដី ដែលគប្បីបូជាដោយបរិយញ្ញ ៤ ។ ឈ្មោះថា **សម្មាបាស** ព្រោះក្នុងយញ្ញនេះ គេបោះអន្ទាក់ទៅ ពាក្យនោះ ជាឈ្មោះរបស់យញ្ញទាំងអស់ ដែលគេធ្វើទេន បូជាបោះអន្ទាក់ ត្រង់ឱកាសដែលអន្ទាក់នោះធ្លាក់ ហើយដើរថយក្រោយ តាំងអំពីឱកាសដែលមុជចុះក្នុងស្ទឹងសរស្សវតី គប្បីបូជាដោយបង្គោលជាដើម ដែលលើកទៅបានរៀងរាល់ថ្ងៃ ។ ឈ្មោះថា **វាជបេយ្យ** ព្រោះក្នុងឥឡូវនេះ បុគ្គលផឹកវាជៈ

ពាក្យនោះ ជាឈ្មោះរបស់យញ្ញដែលឲ្យសម្បត្តិ ១៧ ពួក ដែលមានបង្គោលបូជា ធ្វើដោយដើមក្ទៅ ដែលគប្បីបូជាដោយសត្វចិញ្ចឹម ១៧ ប្រភេទ ដោយបរិយញ្ញ ១ ។ ឈ្មោះថា **និរគ្គឡ** ព្រោះក្នុងយញ្ញនេះ មិនមានស្នៀតបោះ ពាក្យនោះ ជាឈ្មោះរបស់យញ្ញ ដែលកំណត់ក្នុងអស្សមេធ ហៅឈ្មោះម៉្យាងទៀតថា **សព្វមេធ** ដែលឲ្យសម្បត្តិដូចពោលហើយក្នុងអស្សមេធ មួយអន្លើដោយផែនដី និងមនុស្សទាំងឡាយដែលគប្បីបូជាដោយបរិយញ្ញ ៩ ។

បទថា **មហារម្ភា** បានដល់ មានកិច្ចច្រើន មានករណីច្រើន ម៉្យាងទៀត ឈ្មោះថា មានការចាប់ផ្ដើមធំ ក៏ព្រោះការចាប់ផ្ដើមដោយបាណាតិបាតច្រើន ។ ក្នុងបទថា **ន តេ ហោន្តិ មហប្ផលា** នេះ លោកសរុបផលរបស់យញ្ញ ដែលមានចំណែកសល់ ក្នុងអត្ថថា មិនមានចំណែកសល់ ព្រោះដូច្នោះ ទើបមានអធិប្បាយថា ពោលដោយផលដែលគួរប្រាថ្នា ក៏មិនមានផលឡើយ ។ ក្នុងសេចក្ដីនេះ លោកពោលសំដៅដល់ការផ្ដើមដោយបាណាតិបាតនោះឯង ។ ចំណែកទានណា ដែលគេឲ្យក្នុងចន្លោះយញ្ញនោះ ទាននោះ រមែងមានផលមិនច្រើន ព្រោះត្រូវការចាប់ផ្ដើមនេះចូលទៅកម្ចាត់ហើយ អធិប្បាយថា មានផលតិច ។ បទថា **ហញ្ញរេ** គឺរមែងសម្លាប់ ។ បទថា **យជន្តិ អនុកុលំ សទា** សេចក្ដីថា ជនពួកណា រមែងបូជាយញ្ញតាមត្រកូល សូម្បីជនទាំងនោះកើតខាងក្រោយ ក៏គង់បូជាតាម ព្រោះបុព្វបុរសទាំងឡាយបានបូជាមកហើយ ។ បទថា **សេយ្យោ ហោតិ** ប្រែថា

រមែងវិសេសពិត ។ បទថា ន ធាមិយោ បានដល់ មិនអាក្រក់អ្វីឡើយ ។

អដ្ឋកថា ឧជ្ជយសូត្រទី ៩ ចប់

# សុត្តន្តបិដក

## ឧទាយិសូត្រទី ១០

[ ៤១ ] គ្រានោះ ឧទាយិព្រាហ្មណ៍ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ អង្គុយក្នុងទីសមគួរ ។ លុះឧទាយិព្រាហ្មណ៍អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគថា ព្រះគោតមដ៏ចម្រើន សរសើរការបូជារបស់យើងដែរឬទេ ។ ម្នាលព្រាហ្មណ៍ តថាគតមិនសរសើរការបូជាទាំងអស់ទេ ម្នាលព្រាហ្មណ៍ ប៉ុន្តែតថាគតមិនមែនជាមិនសរសើរការបូជាទាំងអស់ទេ ។ ម្នាលព្រាហ្មណ៍ គេសម្លាប់គោទាំងឡាយ សម្លាប់ពពែ និងចៀមទាំងឡាយ សម្លាប់មាន់ និងជ្រូកទាំងឡាយ សត្វទាំងឡាយផ្សេងៗ ស្លាប់ ព្រោះការបូជាមានសភាពយ៉ាងណា ម្នាលព្រាហ្មណ៍ តថាគតមិនសរសើរការបូជាប្រកបដោយសេចក្តីអន្តរាយ មានសភាពយ៉ាងនោះឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលព្រាហ្មណ៍ ព្រោះថា ព្រះអរហន្តទាំងឡាយក្តី បុគ្គលទាំងឡាយអ្នកដល់

នូវអរហត្តមគ្គក្តី មិននិយមការបូជាប្រកបដោយសេចក្តីអន្តរាយ មានសភាពយ៉ាងនេះឡើយ ។ ម្នាលព្រាហ្មណ៍ គេមិនសម្លាប់គោទាំងឡាយ មិនសម្លាប់ពពែ និងចៀមទាំងឡាយ មិនសម្លាប់មាន់ និងជ្រូកទាំងឡាយ សត្វទាំងឡាយផ្សេងៗ មិនស្លាប់ ព្រោះការបូជាមានសភាពយ៉ាងណា ម្នាលព្រាហ្មណ៍ តថាគតតែងសរសើរការបូជា មិនប្រកបដោយសេចក្តីអន្តរាយមានសភាពយ៉ាងនេះ គឺនិច្ចទាន និងការបូជាតាមលម្អាននៃត្រកូល ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលព្រាហ្មណ៍ ព្រោះថា ព្រះអរហន្តទាំងឡាយក្តី បុគ្គលទាំងឡាយអ្នកដល់នូវអរហត្តមគ្គក្តី តែងចូលទៅជិតការបូជា ដែលមិនប្រកបដោយសេចក្តីអន្តរាយ មានសភាពយ៉ាងនេះ ។

> យញ្ញដែលគេតាក់តែងហើយ មិនប្រកបដោយសេចក្តីអន្តរាយគួរតាមកាល ពួកព្រហ្មចារីបុគ្គល ជាអ្នកសង្រួមតែងចូលទៅជិតនូវយញ្ញ ប្រាកដដូច្នោះ ព្រះពុទ្ធទាំងឡាយ មានកិលេសដូចជាគ្រឿងប្រក់បើកហើយក្នុងលោក បានប្រព្រឹត្តកន្លងនូវវដ្តត្រកូល និងវដ្តគតិ ព្រះអង្គឆ្លៀវឆ្លាសក្នុងបុណ្យ ទ្រង់សរសើរនូវការបូជានុ៎ះ បុគ្គលមានចិត្តជ្រះថ្លា ធ្វើនូវគ្រឿងបូជាដ៏សមគួរ ទោះក្នុងយញ្ញ គឺបកតិទានក្តី ទោះក្នុងការបូជាដោយសទ្ធា គឺមតកទានក្តី ហើយបូជាចំពោះព្រហ្មចារីបុគ្គលទាំងឡាយ ជាស្រែបុណ្យដ៏ល្អ យញ្ញណាដែលជនធ្វើហើយចំពោះទក្ខិណេយ្យបុគ្គលទាំងឡាយ ( យញ្ញនោះ ) ឈ្មោះថា

បូជាហើយដោយប្រពៃ បូជាហើយដោយល្អ សម្រេចហើយដោយស្រួល ឈ្មោះថា យញ្ញមានផលច្រើនផង ទេវតាទាំងឡាយតែងជ្រះថ្លាផង ។ បណ្ឌិតជាមេធាវី មានសទ្ធា មានចិត្តលះ ( ទ្រព្យ ) បូជាយ៉ាងនេះហើយ រមែងចូលទៅកាន់លោក ជាសុខ មិនមានការបៀតបៀន ។

**ចក្កវគ្គទី ៤ ចប់**

## ឧទ្ទាននៃចក្កវគ្គនោះ គឺ

និយាយអំពីចក្កធម៌ ១ សង្គហវត្ថុ ១ ប្រៀបដោយសត្វសីហៈ ១ ការជ្រះថ្លា ១ វស្សការព្រាហ្មណ៍ ១ ជាតម្រប់ ៥ ទោណព្រាហ្មណ៍ ១ ការមិនសាបសូន្យ ( ចាកព្រះនិព្វាន ) ១ ភិក្ខុមានការស្ងប់ស្ងាត់ ១ ឧជ្ជយព្រាហ្មណ៍ ១ ឧទាយិព្រាហ្មណ៍ ១ រួមទាំងអស់ត្រូវជា ១០ ។

# អដ្ឋកថា

## ឧទាយិសូត្រ

[ ៤១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧទាយិសូត្រទី ១០ ដូចតទៅនេះ បទថា **អភិសង្ខតំ** គឺធ្វើឲ្យជាគំនរ ។ បទថា **និរារម្ភំ** គឺវៀរនូវការប្រារព្ធសត្វ ។ បទថា **យញ្ញំ** គឺទេយ្យធម៌ ។ សេចក្តីពិត ទេយ្យធម៌នោះ ហៅថា យញ្ញ

ព្រោះបុគ្គលគប្បីបូជា ។ បទថា **កាលេន** គឺតាមកាលដ៏គួរ គឺសមគួរ ។ បទថា **ឧបសំយន្តិ** គឺរមែងចូលទៅដល់ ។ បទថា **កុលំ គតឹ** សេចក្ដីថា បុគ្គលឈានកន្លងហើយនូវត្រកូលក្នុងវដ្ដៈ និងគតិក្នុងវដ្ដៈ។ បទថា **បុញ្ញស្ស កោវិទា** សេចក្ដីថា ការឈ្លាសក្នុងបុណ្យដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ បទថា **យញ្ញោ** គឺក្នុងទានតាមប្រក្រតី ។ បទថា **សទ្ធេ** គឺក្នុងទានឧទ្ទិស ដើម្បីអ្នកស្លាប់ ។ បទថា **ហុញ្ញំ កត្វា** សេចក្ដីថា រៀបចំទេយ្យធម៌ឲ្យជារបស់គួរបូជា ។ បទថា **សុក្ខេត្តេ ព្រហ្មចារិសុ** សេចក្ដីថា ក្នុងស្រែដែលល្អ ពោល គឺប្រព្រឹត្តព្រហ្មចរិយៈ ។ បទថា **សម្បន្នំ** គឺដល់ល្អហើយ ។ បទថា **ទក្ខិណេយ្យេសុ យំ កតំ** សេចក្ដីថា យញ្ញដែលសម្រេចក្នុងទក្ខិណេយ្យ-បុគ្គលដែលសមគួរ ដែលបុគ្គលបូជា បួងសួងល្អហើយ ។ បទថា **សទ្ធោ** សេចក្ដីថា ឈ្មោះថា ជាអ្នកមានសទ្ធា ព្រោះជឿក្នុងគុណរបស់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។ បទថា **មុត្តេន ចេតសា** បានដល់ មានចិត្តលះបង់ហើយ លោកសម្ដែងការបរិច្ចាគដោយទឹកចិត្តលះបង់ ដោយបទនេះឯង ។

**អដ្ឋកថាឧទាយិសូត្រទី ១០ ចប់**

**ចក្កវគ្គទី ៤ ចប់**

# សុត្តន្តបិដក

## រោហិតស្សវគ្គទី ៥

### សមាធិសូត្រទី ១

[ ៤២ ] ម្នាលភិក្ខុទាំងឡាយ សមាធិភាវនានេះ មាន ៤ យ៉ាង ។ សមាធិភាវនា ៤ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សមាធិភាវនា ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ ប្រព្រឹត្តទៅដើម្បីនៅជាសុខ ក្នុងបច្ចុប្បន្ន ១ ម្នាលភិក្ខុទាំងឡាយ សមាធិភាវនាដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ ប្រព្រឹត្តទៅដើម្បីបាននូវញាណទស្សនៈ ១ ម្នាលភិក្ខុទាំងឡាយ សមាធិភាវនាដែលបុគ្គលចម្រើន បានធ្វើឲ្យរឿយៗ ហើយ ប្រព្រឹត្តទៅដើម្បីសតិ និងសម្បជញ្ញៈ ១ ម្នាលភិក្ខុទាំងឡាយ សមាធិភាវនា ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ ប្រព្រឹត្តទៅដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសមាធិភាវនាដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ ប្រព្រឹត្តទៅដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកធម៌ជាអកុសលទាំងឡាយហើយ បានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្ក ប្រកបដោយវិចារ មានបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ជាអារម្មណ៍ សម្រេចសម្រាន្តនៅ ព្រោះរម្ងាប់នូវវិតក្ក និងវិចារ ក៏ចូលទៅកាន់ទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តាន

នៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារ មានតែបីតិ និងសុខ កើតអំពីសមាធិ គឺបឋមជ្ឈាន សម្រេចសម្រាន្តនៅ ព្រោះប្រាសចាកបីតិផង ជាបុគ្គលព្រងើយកន្តើយផង មានសតិ និងសម្បជញ្ញៈផង ទទួលយកនូវសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយតែងសរសើរនូវបុគ្គល ដែលបាននូវតតិយជ្ឈាននោះថា ប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខ ដូច្នេះ ព្រោះតតិយជ្ឈានណា ក៏បានដល់នូវតតិយជ្ឈាននោះ សម្រេចសម្រាន្តនៅ ព្រោះលះបង់នូវសេចក្តីសុខផង លះបង់នូវសេចក្តីទុក្ខផង មានសោមនស្ស និងទោមនស្សអស់ទៅក្នុងកាលមុនផង ក៏បានដល់នូវចតុត្ថជ្ឈាន ជាធម្មជាតមានអារម្មណ៍ មិនមែនជាទុក្ខមិនមែនជាសុខ គឺជាឧបេក្ខា មានសតិដ៏បរិសុទ្ធដោយឧបេក្ខា សម្រេចសម្រាន្តនៅ ។ ម្នាលភិក្ខុទាំងឡាយ នេះជាសមាធិ-ភាវនា ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ ប្រព្រឹត្តទៅដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ ចុះសមាធិភាវនាដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ ប្រព្រឹត្តទៅដើម្បីបាននូវញាណ-ទស្សនៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ធ្វើទុកក្នុងចិត្តនូវអាលោកសញ្ញា ( សេចក្តីសម្គាល់ក្នុងពន្លឺ ) អធិដ្ឋាននូវទិវាសញ្ញា ( សេចក្តីសម្គាល់ក្នុងវេលាថ្ងៃ ) គឺថា ក្នុងវេលាថ្ងៃយ៉ាងណា វេលាយប់ក៏យ៉ាងនោះ ក្នុងវេលាយប់យ៉ាងណា វេលាថ្ងៃក៏យ៉ាងនោះដែរ ។ ភិក្ខុមានចិត្តស្ងប់ស្ងាត់ មិនមានកិលេសជាគ្រឿងរួបរឹត តែងចម្រើនចិត្តដែលប្រកបដោយ

ពន្ធ័ ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ នេះជាសមាធិភាវនាដែល បុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ តែងប្រព្រឹត្តទៅដើម្បីបាននូវ ញាណទស្សនៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះសមាធិភាវនា ដែលបុគ្គលបាន ចម្រើន បានធ្វើឲ្យរឿយៗ ហើយ ប្រព្រឹត្តទៅដើម្បីសតិ និងសម្បជញ្ញៈ តើ ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ វេទនាទាំងឡាយរបស់ភិក្ខុក្នុងសាសនានេះ តែងកើតឡើងប្រាកដ តែងស្ថិតនៅប្រាកដ តែងដល់នូវសេចក្តីអស់ទៅវិញ ប្រាកដសញ្ញា ... ប្រាកដវិតក្កទាំងឡាយ តែងកើតឡើងប្រាកដ តែងស្ថិត នៅប្រាកដ តែងដល់នូវសេចក្តីអស់ទៅវិញប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ នេះជាសមាធិភាវនា ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ ប្រព្រឹត្ត ទៅដើម្បីសតិ និងសម្បជញ្ញៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះសមាធិភាវនាដែល បុគ្គលបានចម្រើនហើយ បានធ្វើឲ្យរឿយៗ ហើយ ប្រព្រឹត្តទៅដើម្បីអស់ទៅ នៃអាសវៈទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនា នេះ ពិចារណាឃើញរឿយៗ នូវទីកើត និងទីរលត់ក្នុងឧបាទានក្ខន្ធទាំង ៥ ថា រូបដូច្នេះ ការកើតឡើងនៃរូបដូច្នេះ សេចក្តីអស់ទៅនៃរូបដូច្នេះ វេទនា ដូច្នេះ ការកើតឡើងនៃវេទនាដូច្នេះ សេចក្តីអស់ទៅនៃវេទនាដូច្នេះ សញ្ញា ដូច្នេះ ការកើតឡើងនៃសញ្ញាដូច្នេះ សេចក្តីអស់ទៅនៃសញ្ញាដូច្នេះ សង្ខារ ទាំងឡាយដូច្នេះ ការកើតឡើងនៃសង្ខារទាំងឡាយដូច្នេះ សេចក្តីអស់ទៅនៃ សង្ខារទាំងឡាយដូច្នេះ វិញ្ញាណដូច្នេះ ការកើតឡើងនៃវិញ្ញាណដូច្នេះ សេចក្តី អស់ទៅនៃវិញ្ញាណដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ នេះជាសមាធិភាវនា ដែល

បុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ ប្រព្រឹត្តទៅដើម្បីអស់នៃអាសវៈទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ សមាធិភាវនាមាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ តថាគតបានពោលហើយ ក្នុងបុណ្ណកប្បញ្ហា ត្រង់បរាយនវគ្គ ព្រោះសំដៅយកសមាធិភាវនានុ៎ះ ។

បុគ្គលបានពិចារណា នូវសភាពធម៌ដ៏ថោកទាប និងឧត្តមក្នុងលោក សេចក្តីរំភើបចិត្តបន្តិចបន្តួចរបស់បុគ្គលណា មិនមានក្នុងលោក តថាគតពោលថា បុគ្គលនោះ ជាអ្នករម្ងាប់ ( នូវសឹកសត្រូវ គឺកិលេស ) មិនមានផ្សែង គឺសេចក្តីក្រោធ មិនមានទុក្ខ មិនមានសេចក្តីប្រាថ្នា ឈ្មោះថា ឆ្លងនូវជាតិ និងជរាបាន ។

# អដ្ឋកថា

# រោហិតស្សវគ្គទី ៥

## សមាធិសូត្រ

[ ៤២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសមាធិសូត្រទី ១ នៃរោហិតស្សវគ្គទី ៥ ដូចតទៅ បទថា **ញាណទស្សនប្បដិលាភាយ** សេចក្តីថា ដើម្បីបាន ញាណទស្សនៈ គឺទិព្វចក្ខុ ។ បទថា **ទិវា សញ្ញំ អធិដ្ឋាតិ** សេចក្តីថា រមែងតាំងនូវការកំណត់សម្គាល់យ៉ាងនេះថា ពេលថ្ងៃដូច្នេះ ។ បទថា **យថា ទិវា តថា រត្តឹ** សេចក្តីថា មនសិការដល់អាលោកសញ្ញា គឺការកំណត់សម្គាល់ថា ពន្លឺក្នុងពេលថ្ងៃយ៉ាងណា រមែងមនសិការដល់អាលោកសញ្ញានោះ សូម្បីក្នុងពេលយប់ក៏ដូច្នោះឯង ។ ក្នុងបទទី ២ ក៏មានន័យនេះដូចគ្នា ។ បទថា **សប្បភាសំ** បានដល់ មានពន្លឺ គឺទិព្វចក្ខុញាណ សូម្បីធ្វើចិត្តឲ្យដូចជាពន្លឺ បានហើយក៏ពិត តែបណ្ឌិតគប្បីកំណត់អត្ថយ៉ាងនេះ ។ តែក្នុងទីនេះ លោកបំណងយកពន្លឺ គឺទិព្វចក្ខុញាណ ។ បទថា **វិទិតា** បានដល់ ប្រាកដហើយ ។ សួរថា សេចក្តីនេះដូចម្តេច វេទនាដែលដឹងហើយ ឈ្មោះថា កើតឡើងដែលដឹងហើយ ឈ្មោះថា រលត់ទៅឬ ។ ឆ្លើយថា ភិក្ខុក្នុងធម្មវិន័យនេះ រមែងកំណត់វត្ថុ រមែងកំណត់អារម្មណ៍ ព្រោះភិក្ខុនោះ កំណត់វត្ថុនិងអារម្មណ៍ហើយ វេទនាដែលដឹងយ៉ាងនេះថា វេទនាកើតឡើងយ៉ាងនេះ តាំងនៅយ៉ាងនេះ រលត់ទៅយ៉ាងនេះ ឈ្មោះថា កើតឡើង ដែលដឹងហើយ

ឈ្មោះថា តាំងនៅ ដែលដឹងហើយ ឈ្មោះថា រលត់ទៅ ។ សូម្បីក្នុងសញ្ញា និងវិតក្កក៏ន័យនេះដូចគ្នា ។ បទថា **ឧទយព្វយានុបស្សី** ប្រែថា ពិចារណា ឃើញការកើត និងការវិនាស ។ បទថា **ឥតិ រូបំ** សេចក្ដីថា រូបយ៉ាងនេះ រូបមានប៉ុណ្ណេះ រូបដទៃក្រៅអំពីនេះមិនមាន ។ បទថា **ឥតិ រូបស្ស សមុទយោ** សេចក្ដីថា ការកើតឡើងនៃរូបយ៉ាងនេះ ។ ឯបទថា **អដ្ឋង្គមោ** លោកសំដៅដល់ការបែកធ្លាយ ។ ក្នុងវេទនាជាដើមក៏ន័យនេះដូចគ្នា ។

បទថា **ឥទញ្ច បន មេតំ ភិក្ខវេ សន្ធាយ ភាសិតំ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ពាក្យជាដើមថា **សង្ខាយ លោកស្មិំ** ណា ខ្ញុំពោលហើយក្នុងបុណ្ណកបញ្ហា ពាក្យនោះ តថាគតពោលសំដៅដល់ផលសមាបត្តិនេះ ។ ក្នុងបទទាំងនោះ បទថា **សង្ខាយ** បានដល់ ដឹងដោយញាណ ។ បទថា **លោកស្មិំ** បានដល់ ក្នុងលោក គឺពួកសត្វ ។ បទថា **បរោបរានិ** បានដល់ ការក្រៃលែង និងធូរថយ គឺខ្ពស់ និងទាប ។ បទថា **ឥញ្ជិតំ** បានដល់ ការញាប់ញ័រ ។ បទថា **នត្ថិ កុហិញ្ចិ លោកេ** សេចក្ដីថា ការញាប់ញ័ររបស់បុគ្គលណា ក្នុងទីណាមួយ ទោះក្នុងខន្ធ ១ ក្ដី អាយតនៈ ១ ក្ដី ធាតុ ១ ក្ដី អារម្មណ៍ ១ ក្ដី រមែងមិនមានក្នុងលោក ។ បទថា **សន្តោ** សេចក្ដីថា បុគ្គលនោះជាបុគ្គលស្ងប់ ព្រោះស្ងប់កិលេសដែលជាសត្រូវ ។ បទថា **វិធូមោ** សេចក្ដីថា ជាអ្នកប្រាសចាកកិលេសដូចផ្សែង ព្រោះផ្សែង គឺសេចក្ដីក្រោធ ។ ក្នុងព្រះសូត្រនេះ ត្រាស់ដល់ឯកគ្គតាក្នុងមគ្គ ក្នុងគាថា ត្រាស់ផលសមាបត្តិតែម្យ៉ាង ដោយប្រការដូច្នេះឯង ។៕

# សុត្តន្តបិដក

## បញ្ហាសូត្រទី ២

[ ៤៣ ] ម្នាលភិក្ខុទាំងឡាយ បញ្ហាព្យាករណ៍ ( ការឆ្លើយប្រស្នា ) នេះមាន ៤ យ៉ាង ។ បញ្ហាព្យាករណ៍ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បញ្ហាដែលគួរឆ្លើយទៅតែម្តង ១ ម្នាលភិក្ខុទាំងឡាយ បញ្ហាដែលគួរឆ្លើយចែករំលែកឲ្យពិស្តារ ១ ម្នាលភិក្ខុទាំងឡាយ បញ្ហាដែលគួរសួរតបទៅវិញ ហើយទើបឆ្លើយ ១ ម្នាលភិក្ខុទាំងឡាយ បញ្ហាដែលគួរបញ្ឈប់ទុក ១ ។ ម្នាលភិក្ខុទាំងឡាយ បញ្ហាព្យាករណ៍ មាន ៤ យ៉ាងនេះឯង ។

បញ្ហាទី ១ ជាពាក្យគួរឆ្លើយទៅតែម្តង បញ្ហាដទៃ ( ទី ២ )
ជាពាក្យគួរឆ្លើយចែករំលែកឲ្យពិស្តារ បញ្ហាទី ៣ ជាពាក្យគួរ
សួរតបទៅវិញហើយ ទើបឆ្លើយ ចំណែកបញ្ហាទី ៤ ជាពាក្យ
គួរបញ្ឈប់ទុក ។ ភិក្ខុណាដឹងនូវបញ្ហាព្យាករណ៍ទាំងនោះ ដ៏
សមគួរតាមធម៌ក្នុងទីនោះៗ អ្នកប្រាជ្ញទាំងឡាយ តែងពោល
នូវភិក្ខុបែបនោះថា ជាអ្នកឈ្លាសវៃក្នុងបញ្ហាទាំង ៤ យ៉ាង ។
មួយទៀត ភិក្ខុដែលគេបៀតបៀនបានដោយកម្រ គ្របសង្កត់
បានដោយកម្រ មានធម៌ដ៏ជ្រាលជ្រៅ ដែលគេកម្ចាត់បង់បាន
ដោយកម្រ ជាអ្នកឈ្លាសវៃក្នុងប្រយោជន៍ទាំងពីរ គឺសេចក្តី
ចម្រើន ១ សេចក្តីមិនចម្រើន ១ ។ ភិក្ខុជាបណ្ឌិត តែងវៀរ
បង់នូវសេចក្តីមិនចម្រើន កាន់យកតែសេចក្តីចម្រើន ទើបហៅ

*ថាជាអ្នកប្រាជ្ញ មានប្រាជ្ញាជាគ្រឿងទ្រទ្រង់ ព្រោះដឹងនូវប្រយោជន៍( ទាំងពីរប្រការនោះ ) ។*

# អដ្ឋកថា

## បញ្ញាសូត្រ

[ ៤៣ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងបញ្ញាសូត្រទី ២ ដូចតទៅនេះ បទថា* **យោ ច នេសំ តត្ថ តត្ថ ជានាតិ អនុធម្មតំ** *សេចក្តីថា ភិក្ខុណាដឹងការពោលស្រាយបញ្ហាទាំងនោះ ក្នុងឋានៈនោះៗ ។ បទថា* **ចតុប្បញ្ហស្ស កុសលោ អាហុ ភិក្ខុំ តថាវិធំ** *សេចក្តីថា លោកហៅភិក្ខុបែបនោះយ៉ាងនេះថា ជាអ្នកឈ្លាសក្នុងបញ្ហាទាំង ៤ ។ បទថា* **ទុរាសទោ ទុប្បសហោ** *សេចក្តីថា ដែលបុគ្គលណាមួយ មិនអាចប៉ះខ្ទប់ ឬសង្កត់សង្កិនបាន ។ បទថា* **គម្ភីរោ** *សេចក្តីថា ជាបុគ្គលជ្រាលជ្រៅ ដូចមហាសមុទ្រសីទន្តរ ៧ ។ បទថា* **ទុប្បធំសិយោ** *បានដល់ បុគ្គលដែលអ្នកណាម្នាក់ដោះបានលំបាក អធិប្បាយថា បុគ្គលណាមួយមិនអាចឲ្យបុគ្គលនោះដោះនូវការប្រកាន់ក្នុងអ្វីដែលបុគ្គលនោះ ប្រកាន់ហើយបានឡើយ ។ បទថា* **អត្ថេ អនត្ថេ ច** *បានដល់ ក្នុងការចម្រើន និងក្នុងការវិនាស ។ បទថា* **អត្ថាភិសមយា** *បានដល់ ព្រោះប្រមូលយកការចម្រើនបាន ។ បទថា* **ធីរោ បណ្ឌិតោតិ**

**បវុច្ចតិ** សេចក្តីថា បុគ្គលប្រកបដោយបញ្ញា គេហៅថា បុគ្គលនេះជាបណ្ឌិត ដូច្នេះ ។ល។

## អដ្ឋកថា បញ្ញាសូត្រទី ២ ចប់

# សុត្តន្តបិដក

## បឋមកោធសូត្រទី ៣

[ ៤៤ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ មានទៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលជាអ្នកធ្ងន់ក្នុងសេចក្តីក្រោធ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ជាអ្នកធ្ងន់ក្នុងសេចក្តីលុបគុណ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ជាអ្នកធ្ងន់ក្នុងលាភ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ជាអ្នកធ្ងន់ក្នុងសក្ការៈ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះឯង មានទៅក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះមានទៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ គឺបុគ្គលជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងសេចក្តីក្រោធ ១ ជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងសេចក្តីលុបគុណ ១ ជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងលាភ ១ ជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងសក្ការៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះឯង មានទៅក្នុងលោក ។

ភិក្ខុណាជាអ្នកធ្ងន់ក្នុងសេចក្ដីក្រោធ និងសេចក្ដីលុបគុណ ជាអ្នកធ្ងន់ក្នុងលាភសក្ការៈ ភិក្ខុទាំងនោះ រមែងមិនចម្រើនក្នុងព្រះសទ្ធម្ម ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងឡើយ ។ ភិក្ខុទាំងឡាយណា ជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម នៅហើយផង នៅឥឡូវនេះផង ភិក្ខុទាំងនោះ រមែងចម្រើនក្នុងព្រះសទ្ធម្ម ដែលព្រះសម្មាសម្ពុទ្ធ ត្រាស់សម្ដែងហើយ ។

# អដ្ឋកថា

## បឋមកោធសូត្រ

[ ៤៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមកោធសូត្រទី ៣ ដូចតទៅនេះ បទថា **កោធគរុ ន សទ្ធម្មគរុ** សេចក្ដីថា បុគ្គលកាន់យកសេចក្ដីក្រោធជាសំខាន់ មិនកាន់យកព្រះសទ្ធម្ម រមែងកាន់យកព្រះសទ្ធម្ម តែធ្វើឲ្យមិនសំខាន់ ។ ក្នុងបទដ៏សេស ក៏ន័យនេះដូចគ្នា ។ បទថា **វិរូហន្តិ** បានដល់ រមែងចម្រើន ឬរមែងតាំងមាំ មិនញាប់ញ័រ ដោយសទ្ធាដែលជាមូល កើតព្រមហើយ ៕

**អដ្ឋកថា បឋមកោធសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ទុតិយកោធសូត្រទី ៤

[ ៤៥ ] ម្នាលភិក្ខុទាំងឡាយ អសទ្ធម្មទាំងឡាយនេះមាន ៤ យ៉ាង ។ អសទ្ធម្ម ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺភាពនៃបុគ្គលជាអ្នកធ្ងន់ក្នុងសេចក្តីក្រោធ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ភាពនៃបុគ្គលជាអ្នកធ្ងន់ក្នុងសេចក្តីលុបគុណ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ភាពនៃបុគ្គលជាអ្នកធ្ងន់ក្នុងលាភ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ភាពនៃបុគ្គលជាអ្នកធ្ងន់ក្នុងសក្ការៈ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ អសទ្ធម្មមាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រះសទ្ធម្មទាំងឡាយនេះមាន ៤ យ៉ាង ។ ព្រះសទ្ធម្ម ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺភាពនៃបុគ្គលជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងសេចក្តីក្រោធ ១ ភាពនៃបុគ្គលជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងសេចក្តីលុបគុណ ១ ភាពនៃបុគ្គលជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងលាភ ១ ភាពនៃបុគ្គលជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងសក្ការៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រះសទ្ធម្មមាន ៤ យ៉ាងនេះឯង ។

ភិក្ខុជាអ្នកធ្ងន់ក្នុងសេចក្តីក្រោធ និងសេចក្តីលុបគុណ ជាអ្នក
ធ្ងន់ក្នុងលាភ ក្នុងសក្ការៈ រមែងមិនដុះដាលឡើង ក្នុងព្រះ
សទ្ធម្មបានឡើយ ដូចជាពូជដែលគេព្រោះក្នុងស្រែមិនល្អ ។
ចំណែកភិក្ខុទាំងឡាយណា ជាអ្នកធ្ងន់ក្នុងព្រះសទ្ធម្ម នៅ
ហើយផង នៅឥឡូវនេះផង ភិក្ខុទាំងនោះឯង តែងចម្រើន

ក្នុងព្រះធម៌ ដូចជា ពូជតែងដុះឡើង ព្រោះអាស្រ័យទឹក ដូច្នោះ ។

# អដ្ឋកថា

## ទុតិយកោធសូត្រ

[ ៤៥ ] ក្នុងទុតិយកោធសូត្រទី ៤ បទថា **កោធគរុតា** ប្រែថា ជាអ្នកធ្ងន់ ក្នុងសេចក្ដីក្រោធ ។ ក្នុងបទទាំងពួងក៏ន័យនេះឯង ៗ។

**អដ្ឋកថា ទុតិយកោធសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## បឋមរោហិតស្សសូត្រទី ៥

[ ៤៦ ] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ លំដាប់នោះឯង រោហិតស្ស-ទេវបុត្ត កាលវេលារាត្រី ( បឋមយាម ) កន្លងទៅហើយ មានពន្លឺដ៏រុងរឿង ញាំងវត្តជេតពនទាំងមូលឲ្យភ្លឺស្វាង ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះ

ចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយស្ថិតនៅក្នុងទីសមគួរ ។ លុះរោហិតស្សទេវបុត្តស្ថិតនៅក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិ ក្នុងឱកាសនៃចក្រវាលលោកណា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលអាចដើម្បីដឹង ដើម្បីឃើញ ឬដើម្បីដល់នូវទីបំផុតនៃលោក ( នោះ ) ដោយកិរិយាដើរទៅ ( ដោយជើង ) បានដែរឬ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលអាវុសោ បុគ្គលមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិ ក្នុងសង្ខារលោកណា តថាគតមិនបានពោលថា បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់នូវទីបំផុតនៃសង្ខារលោកនោះ ដោយកិរិយាដើរទៅ ( ដោយជើង ) បានឡើយ ។ រោហិតស្សទេវបុត្ត ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះតម្រាស់នេះ ដែលព្រះដ៏មានព្រះភាគត្រាស់ប្រពៃហើយថា ម្នាលអាវុសោ បុគ្គលមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិ ក្នុងសង្ខារលោកណា តថាគតមិនពោលថា បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់នូវទីបំផុតនៃសង្ខារលោកនោះ ដោយកិរិយាដើរទៅ ( ដោយជើង ) បានឡើយ បពិត្រព្រះអង្គដ៏ចម្រើន កាលពីព្រេងនាយមក ខ្ញុំព្រះអង្គធ្លាប់កើតជាឥសីឈ្មោះរោហិតស្សៈ ជាបុត្ររបស់ព្រានព្រៃ មានឫទ្ធិទៅដោយអាកាសវេហាស៍បាន ។ បពិត្រព្រះអង្គដ៏ចម្រើន សម្ទុះមានសភាពយ៉ាងនេះ បានកើតដល់ខ្ញុំព្រះអង្គនោះ ប្រៀបដូចនាយខ្មាន់ធ្នូ

មានធនុធមិដ៏មាំ បានសិក្សាដោយប្រពៃហើយ មានដៃដ៏ស្ទាត់ មានការបាញ់ ដ៏ស្ទាត់ បានយកព្រួញដ៏ស្រាល ( បាញ់ ) ឲ្យឆ្លងរំលងនូវទីងស្រមោលដើម ត្នោត ដោយមិនលំបាក ជំហានឈានដើរទៅដោយជើង មានសភាពយ៉ាង នេះ បានកើត ( ដល់ខ្ញុំព្រះអង្គ ) ប្រៀបដូចសមុទ្ទទិសខាងលិច ( ឆ្ងាយ អំពី ) សមុទ្ទទិសខាងកើត ។ បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គនោះ ប្រកបដោយសម្ទុះមានសភាពយ៉ាងនេះ ដោយការឈានដើរទៅ ( ដោយ ជើង ) មានសភាពយ៉ាងនេះហើយ សេចក្ដីប្រាថ្នាមានសភាពយ៉ាងនេះ ក៏ កើតឡើងថា អាត្មាអញនឹងដល់នូវទីបំផុតនៃលោក ដោយការដើរទៅ ( ដោយ ជើង ) បាន ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ លើកលែងតែពេល ស៊ីផឹក ទំពាហុតស្រូប ( នូវអាហារជាដើម ) លើកលែងតែពេលធ្វើនូវឧច្ចារៈ និងបស្សាវៈ លើកលែងតែពេលដេក និងបន្ទោបង់នូវសេចក្ដីទុក្ខលំបាក ទាំងប្រកបដោយអាយុ ១០០ ឆ្នាំ មានជីវិតរស់នៅបាន ១០០ ឆ្នាំ ដើរទៅ អស់ ១០០ ឆ្នាំ ក៏គង់មិនដល់នូវទីបំផុតនៃលោកបានឡើយ ធ្វើមរណកាល ក្នុងចន្លោះនោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យពេកណាស់ បពិត្រ ព្រះអង្គដ៏ចម្រើន ចម្លែកពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះ តម្រាស់នេះ ដែលព្រះដ៏មានព្រះភាគត្រាស់ប្រពៃហើយថា ម្នាលអាវុសោ បុគ្គលមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិក្នុងសង្ខារលោក ណា តថាគតមិនបានពោលថា បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់នូវទី បំផុតនៃសង្ខារលោកនោះ ដោយកិរិយាដើរទៅ ( ដោយជើង ) បានឡើយ ។

ម្នាលអាវុសោ បុគ្គលមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិ ក្នុងសង្ខារលោកណា តថាគតមិនបានពោលថា បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់នូវទីបំផុតនៃលោកនោះ ដោយកិរិយាដើរទៅ ( ដោយជើង ) បានឡើយ ម្នាលអាវុសោ មួយទៀត បើតថាគតមិនបានដល់នូវទីបំផុតនៃសង្ខារលោកហើយ ក៏មិនបានពោលនូវកិរិយាធ្វើនូវទីបំផុតនៃទុក្ខឡើយ ។ ម្នាលអាវុសោ មួយទៀត តថាគតតែងបញ្ញត្តនូវលោក គឺទុក្ខផង លោកសមុទយៈផង លោកនិរោធផង លោកនិរោធគាមិនីបដិបទាផង ក្នុងអត្តភាពប្រមាណ ១ ព្យាមនេះឯង ដែលប្រកបដោយសញ្ញាផង ប្រកបដោយចិត្តផង ។

ទីបំផុតនៃលោក បុគ្គលមិនគប្បីដល់ ដោយការដើរទៅ
( ដោយជើង ) ក្នុងកាលណាម្តងឡើយ មួយទៀត ការមិន
ទាន់ដល់នូវទីបំផុតនៃលោក ឈ្មោះថា មិនបានរួចចាកទុក្ខ
ឡើយ ។ ព្រោះហេតុនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាប
ច្បាស់នូវលោក ទ្រង់មានបញ្ញាល្អ ទ្រង់ដល់នូវទីបំផុតនៃ
លោក ទ្រង់ប្រព្រឹត្តចប់ព្រហ្មចរិយៈហើយ ។ ទ្រង់មានបាប
រម្ងាប់បង់ហើយ ទ្រង់ជ្រាបច្បាស់នូវទីបំផុតនៃលោកហើយ
មិនប្រាថ្នានូវលោកនេះ និងលោកខាងមុខឡើយ ។

# អដ្ឋកថា

## បឋមរោហិតស្សសូត្រ

[ ៤៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមរោហិតស្សសូត្រទី ៥ ដូច្នេះ បទថា **យត្ថ** សេចក្តីថា ផែនដីក្នុងឱកាសមួយរបស់លោកក្នុងចក្រវាល ។ បទថា **ន ចវតិ ន ឧបបជ្ជតិ** នេះ ទ្រង់កាន់យកហើយ ដោយអំណាចចុតិ និងបដិសន្ធិបន្តគ្នាទៅ ។ បទថា **គមនេន** គឺដោយការប្រើជើងដើរទៅ ។ បទថា **លោកស្ស អន្តំ** សេចក្តីថា ព្រះសាស្តា ត្រាស់សំដៅទីបំផុតរបស់សង្ខារលោក ។ ក្នុងបទថា **ញាតេយ្យំ** ជាដើម សេចក្តីថា ដែលបុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់ ។ ដោយហេតុនោះ ទេវបុត្រទូលសួរទីបំផុតនៃលោកក្នុងចក្រវាល ព្រះសាស្តាក៏ត្រាស់ឆ្លើយទីបំផុតនៃសង្ខារលោក ។ ឯទេវបុត្រនោះ ត្រេកអរក្នុងបញ្ហាថា ការពោលដោះស្រាយរបស់ព្រះសាស្តាសមនឹងបញ្ហារបស់ខ្លួន ដូច្នេះ ទើបទូលថា **អច្ឆរិយំ** ដូច្នេះជាដើម ។

បទថា **ទឡ្ហធម្មោ** បានដល់ ជាអ្នកស៊កធ្នូដ៏មាំ គឺប្រកបដោយធ្នូមានទំហំដ៏កំពូល ។ បទថា **ធនុគ្គហោ** បានដល់ អាចារ្យដែលបង្ហឹកធ្នូ ។ បទថា **សុសិក្ខិតោ** គឺជាអ្នកបានសិក្សាសិប្បៈធ្នូមក ១២ ឆ្នាំ ។ បទថា **កតហត្ថោ** សេចក្តីថា មានថ្វីដៃជំនាញហើយ អាចបាញ់ចុងរោមទ្រាយក្នុងចម្ងាយមួយឧសភៈបាន ។ បទថា **កតូបាសនោ** បានដល់ អ្នកបាញ់ធ្នូជំនាញបានសម្តែងសិប្បៈធ្នូមកហើយ ។ បទថា **អសនេន** គឺព្រួញ ។ បទថា **អតិបាតេយ្យ** គឺឆ្លងទៅ ។ ទេវបុត្រសម្តែងសម្បត្តិ គឺសម្ទុះរបស់ខ្លួនថា

ខ្ញុំចូលចក្រវាលមួយទៅ ស្មើគ្នានឹងព្រួញនោះចូលស្រមោលដើមត្នោតទៅ ។

បទថា **បុរត្ថិមា សមុទ្ទា បច្ឆិមោ** សេចក្តីថា ទេវបុត្រពោលថា ការឈានជើងមួយទៅបានក្នុងទីឆ្ងាយ ដូចសមុទ្រទិសខាងលិច ឆ្ងាយអំពីសមុទ្រទិសខាងកើតដូច្នោះ ។ បានឮថា ឥសីនោះឈរត្រង់កណ្តាប់ចក្រវាលទិសខាងកើត បោះជំហានចូលកណ្តាប់ចក្រវាលនៃទិសខាងលិច បោះជើងទី ២ ទៅទៀត ចូលកណ្តាប់ចក្រវាលដទៃ ។ បទថា **ឥច្ឆាគតំ** ប្រែថា ការប្រាថ្នានោះឯង ។ បទថា **អញ្ញត្រេវ** គឺលោកសម្តែងការមិនយឺតយូរ ។ បានឮថា ក្នុងពេលភិក្ខាចារ ឥសីនោះ ទំពាឈើស្ទន់នាគលតា លុបមុខក្នុងអនោ-តត្តស្រះ កាលបានពេល ក៏ត្រាច់បិណ្ឌបាត ក្នុងឧត្តរកុរុទ្វីប អង្គុយត្រង់ក្នុំកណ្តាប់ចក្រវាល ធ្វើភត្តកិច្ច ។ ឈប់សម្រាកក្នុងទីនោះមួយស្របក់ ក៏ធ្វើដំណើរទៅទៀត ។ បទថា **វស្សសតាយុកោ** សេចក្តីថា យុគនោះ ជាសម័យដែលមនុស្សមានអាយុវែង ។ ឥសីនេះ ដើរក្នុងកាលអាយុនៅសល់ ១០០ ឆ្នាំ ។ បទថា **វស្សសតជីវី** សេចក្តីថា គាត់មានជីវិត ១០០ ឆ្នាំ ដោយមិនមានអន្តរាយ ។ បទថា **អន្តរាយេវ កាលកតោ** សេចក្តីថា មិនទាន់ដល់ទីបំផុតនៃលោកក្នុងចក្រវាលក៏ស្លាប់មុនក្នុងចន្លោះ ។ តែគាត់ធ្វើកាល-កិរិយាក្នុងទីនោះហើយ ទើបមកកើតក្នុងចក្រវាលនេះ ។

បទថា **អប្បត្វា** សេចក្តីថា មិនទាន់ដល់ទីបំផុតនៃសង្ខារលោក ។ បទថា **ទុក្ខស្ស** គឺវដ្តទុក្ខ ។ បទថា **អន្តកិរិយំ** គឺធ្វើទីបំផុត ។ បទថា **កឡេវរេ** គឺក្នុងអត្តភាព ។ បទថា **សសញ្ញម្ហិ សមនកេ** គឺមានសញ្ញា

មានចិត្ត ។ បទថា **លោកំ** គឺទុក្ខសច្ច ។ បទថា **លោកសមុទយំ** គឺសមុទយសច្ច ។ បទថា **លោកនិរោធំ** គឺនិរោធសច្ច ។ បទថា **បដិបទំ** គឺមគ្គសច្ច ព្រះមានព្រះភាគទ្រង់សម្ដែងថា អាវុសោ តថាគតរមែងមិនបញ្ញត្តសច្ចៈ ៤ នេះចូលក្នុងស្មៅ និងឈើជាដើមឡើយ តែតថាគតរមែងបញ្ញត្តចូលក្នុងកាយនេះ ដែលមានមហាភូត ៤ ប៉ុណ្ណោះ ។ បទថា **សមិតាវិ** បានដល់ មានបាបស្ងប់ហើយ ។ បទថា **ឆាសីសតិ** គឺរមែងមិនប្រាថ្នា ៕

**អដ្ឋកថា បឋមរោហិតស្សសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ទុតិយរោហិតស្សសូត្រទី ៦

[ ៤៧ ] លុះកន្លងរាត្រីនោះហើយ ព្រះដ៏មានព្រះភាគ បានត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ក្នុងរាត្រីនេះ រោហិតស្សទេវបុត្តកាលដែលវេលារាត្រី ( បឋមយាម ) កន្លងទៅហើយ មានពន្លឺដ៏រុងរឿងញុំាងវត្តជេតពនទាំងមូលឲ្យភ្លឺស្វាង ក៏ចូលមករកតថាគត លុះចូលមកដល់ក៏ថ្វាយបង្គំតថាគត ហើយស្ថិតនៅក្នុងទីសមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះរោហិតស្សទេវបុត្ត អង្គុយក្នុងទីសមគួរហើយ បាននិយាយនឹងតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិន

បដិសន្ធិក្នុងឱកាសនៃចក្រវាលលោកណា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលអាចដើម្បីដឹង ដើម្បីឃើញ ឬដើម្បីដល់នូវទីបំផុតនៃលោកនោះ ដោយកិរិយាដើរទៅ ( ដោយជើង ) បានដែរឬ ។ ម្នាលភិក្ខុទាំងឡាយ កាលរោហិតស្សទេវបុត្តពោលនឹងតថាគតយ៉ាងនេះហើយ តថាគតបានពោលទៅនឹងរោហិតស្សទេវបុត្តថា ម្នាលអាវុសោ បុគ្គលមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិក្នុងសង្ខារលោកណា តថាគតមិនបានពោលថា បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់នូវទីបំផុតនៃសង្ខារលោកនោះ ដោយកិរិយាដើរទៅ ( ដោយជើង ) បានឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលតថាគតពោលយ៉ាងនេះហើយ រោហិតស្សទេវបុត្ត បាននិយាយនឹងតថាគតដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះតម្រាស់នេះ ដែលព្រះដ៏មានព្រះភាគ ត្រាស់ប្រពៃហើយថា ម្នាលអាវុសោ បុគ្គលមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិក្នុងសង្ខារលោកណា តថាគតមិនបានពោលថា បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់នូវទីបំផុតនៃសង្ខារលោកនោះ ដោយកិរិយាដើរទៅ ( ដោយជើង ) បានឡើយ បពិត្រព្រះអង្គដ៏ចម្រើន កាលពីព្រេងនាយមក ខ្ញុំព្រះអង្គធ្លាប់កើតជាឥសីឈ្មោះរោហិតស្សៈ ជាបុត្ររបស់ព្រានព្រៃ មានឫទ្ធិទៅដោយអាកាសវេហាស៍បាន ។ បពិត្រព្រះអង្គដ៏ចម្រើន សម្ទុះមានសភាពយ៉ាងនេះ បានកើតដល់ខ្ញុំព្រះអង្គនោះ ប្រៀបដូចនាយខ្មាន់ធ្នូមានធនុធម៌ដ៏មាំ បានសិក្សាដោយប្រពៃហើយ មានដៃដ៏ស្ទាត់

មានការបាញ់ដ៏ស្ទាត់ បានយកព្រួញដ៏ស្រាល ( បាញ់ ) ឲ្យឆ្លងរំលងទទឹង ស្រមោលដើមត្នោត ដោយមិនលំបាក ជំហានឈានដើរទៅដោយជើង មាន សភាពយ៉ាងនេះ បានកើតដល់ខ្ញុំព្រះអង្គនោះ ប្រៀបដូចសមុទ្ទទិសខាងលិច ( ឆ្ងាយ ) អំពីសមុទ្ទទិសខាងកើត ។ បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះ អង្គនោះ ប្រកបដោយសម្ទុះមានសភាពយ៉ាងនេះ ដោយការឈានដើរទៅ ( ដោយជើង ) មានសភាពយ៉ាងនេះហើយ សេចក្តីប្រាថ្នាមានសភាពយ៉ាង នេះ ក៏កើតឡើងថា អាត្មាអញនឹងដល់នូវទីបំផុតនៃលោក ដោយកិរិយាដើរ ទៅ ( ដោយជើង ) បាន ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ លើក លែងតែពេលស៊ីផឹក ទំពាហុតស្រូប ( នូវអាហារជាដើម ) លើកលែងតែ ពេលធ្វើនូវឧច្ចារៈ និងបស្សាវៈ លើកលែងតែពេលដេក និងបន្ទោបង់នូវ សេចក្តីទុក្ខលំបាក ទាំងប្រកបដោយអាយុ ១០០ ឆ្នាំ មានជីវិតរស់នៅបាន ១០០ ឆ្នាំ ទាំងដើរទៅអស់ ១០០ ឆ្នាំ ក៏គង់មិនដល់នូវទីបំផុតនៃលោក បានឡើយ ក៏ធ្វើមរណកាលក្នុងចន្លោះនោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកណាស់ បពិត្រព្រះអង្គដ៏ ចម្រើន ព្រោះថា ព្រះតម្រាស់នេះ ដែលព្រះដ៏មានព្រះភាគ ត្រាស់ប្រពៃ ហើយថា ម្នាលអាវុសោ បុគ្គលមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិក្នុងសង្ខារលោកណា តថាគតមិនបានពោលថា បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់នូវទីបំផុតនៃសង្ខារលោកនោះ ដោយកិរិយាដើរទៅ ( ដោយជើង ) បានឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលរោហិតស្សទេវបុត្ត

ពោលយ៉ាងនេះហើយ តថាគត បានពោលទៅនឹងរោហិតស្សទេវបុត្តថា ម្នាលអាវុសោ បុគ្គលមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិ ក្នុងសង្ខារលោកណា តថាគតមិនបានពោលថា បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់នូវទីបំផុតនៃសង្ខារលោកនោះ ដោយកិរិយាដើរទៅ ( ដោយជើង ) បានឡើយ ។ ម្នាលអាវុសោ មួយទៀត បើតថាគតមិនបានដល់នូវទីបំផុតនៃសង្ខារលោកហើយ ក៏មិនបានពោលនូវកិរិយាធ្វើនូវទីបំផុតនៃទុក្ខឡើយ ម្នាលអាវុសោ មួយទៀត តថាគតតែងបញ្ញត្តនូវលោកផង លោកសមុទយៈផង លោកនិរោធផង លោកនិរោធគាមិនីបដិបទាផង ក្នុងអត្តភាពប្រមាណ ១ ព្យាមនេះឯង ដែលប្រកបដោយសញ្ញាផង ប្រកបដោយចិត្តផង ។

> ទីបំផុតនៃលោក បុគ្គលមិនគប្បីដល់ដោយការដើរទៅ ( ដោយជើង ) ក្នុងកាលណាមួយឡើយ មួយទៀត ការមិនទាន់ដល់នូវទីបំផុតនៃលោក ឈ្មោះថា មិនបានរួចចាកទុក្ខឡើយ ។ ព្រោះហេតុនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់មានបញ្ញាល្អ ទ្រង់ដល់នូវទីបំផុតនៃលោក ទ្រង់ប្រព្រឹត្តចប់ព្រហ្មចរិយៈហើយ ។ ទ្រង់មានបាបរម្ងាប់បង់ហើយ ទ្រង់ជ្រាបច្បាស់នូវទីបំផុតនៃលោកហើយ មិនប្រាថ្នានូវលោកនេះ និងលោកខាងមុខឡើយ ។

# អដ្ឋកថា

## ទុតិយរោហិតស្សសូត្រ

[ ៤៧ ] ក្នុងទុតិយរោហិតស្សសូត្រទី ៦ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាទុតិយរោហិតស្សសូត្រទី ៦ ចប់

# សុត្តន្តបិដក

## សុវិទូរសូត្រទី ៧

[ ៤៨ ] ម្នាលភិក្ខុទាំងឡាយ របស់ដែលឆ្ងាយក្រៃលែងឆ្ងាយនេះ មាន ៤ យ៉ាង ។ របស់ដែលឆ្ងាយក្រៃលែងឆ្ងាយ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ មេឃ និងផែនដី នេះជារបស់ឆ្ងាយក្រៃលែងឆ្ងាយទី ១ ម្នាលភិក្ខុទាំងឡាយ ត្រើយសមុទ្រខាងអាយ និងត្រើយសមុទ្រខាងនាយ នេះជារបស់ឆ្ងាយក្រៃលែងឆ្ងាយទី ២ ម្នាលភិក្ខុទាំងឡាយ ព្រះអាទិត្យរះឡើងអំពីទិសណា អស្តង្គតទៅក្នុងទិសណា នេះជារបស់ឆ្ងាយក្រៃលែងឆ្ងាយទី ៣ ម្នាលភិក្ខុទាំងឡាយ ធម៌របស់ពួកសប្បុរស និងធម៌របស់ពួកអសប្បុរស នេះជារបស់ឆ្ងាយក្រៃលែងឆ្ងាយទី ៤ ។ ម្នាលភិក្ខុទាំងឡាយ របស់ដែលឆ្ងាយក្រៃលែងឆ្ងាយ មាន ៤ យ៉ាងនេះឯង ។

មេឃ និងដីរមែងឆ្ងាយអំពីគ្នា ត្រើយសមុទ្រនោះ លោកពោល

ថា ឆ្ងាយអំពីគ្នា ព្រះអាទិត្យជាអ្នកធ្វើនូវពន្លឺរះឡើងអំពីទិសណា អស្តង្គតទៅវិញក្នុងទិសណា រមែងឆ្ងាយអំពីគ្នា បណ្ឌិតទាំងឡាយពោលថា ធម៌របស់ពួកសប្បុរស និងធម៌របស់ពួកអសប្បុរស ឆ្ងាយក្រៃលែងឆ្ងាយជាងនោះទៅទៀត ។ សមាគមរបស់ពួកសប្បុរស មិនបានព្រាត់ប្រាសចាកគ្នា សមាគមរបស់ពួកសប្បុរស ស្ថិតនៅដរាបណា ធម៌របស់ពួកសប្បុរសក៏មាននៅដរាបនោះ ។ សមាគមរបស់ពួកអសប្បុរស រមែងព្រាត់ប្រាសទៅឆាប់ ព្រោះហេតុនោះ ធម៌ទាំងឡាយរបស់ពួកសប្បុរស ទើបឈ្មោះថា ឆ្ងាយអំពីធម៌របស់ពួកអសប្បុរស ។

# អដ្ឋកថា

## សុវិទូរសូត្រ

[ ៤៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសុវិទូរសូត្រទី ៧ ដូចតទៅនេះ បទថា **សុវិទូរវិទូរានិ** សេចក្តីថា មិនជិតគ្នាដោយបរិយាយណាមួយ គឺដ៏ឆ្ងាយនោះឯង ។ បទថា **នភញ្ច ភិក្ខវេ បឋវី ច** បានដល់ អាកាស និងផែនដីធំ ។ ក្នុង ២ យ៉ាងនោះ ឈ្មោះថា អាកាសមិនឆ្ងាយអំពីផែនដី សូម្បីប្រមាណ ២ ធ្នាប់ តែលោកក៏នៅពោលដ៏ឆ្ងាយ ព្រោះមិនជាប់គ្នានិងគ្នា ។

បទថា **វេរោចនោ** គឺព្រះអាទិត្យ ។ បទថា **សតញ្ច ភិក្ខវេ ធម្មោ** សេចក្តីថា ពោធិបក្ខិយធម៌ ៣៧ មានសតិប្បដ្ឋាន ៤ ជាដើម ។ បទថា **អសតញ្ច ធម្មោ** សេចក្តីថា អសទ្ធម្ម មានទិដ្ឋិ ៦២ ជាដើម ។ បទថា **បភង្ករោ** គឺព្រះអាទិត្យ ។ បទថា **អព្យាយិកោ ហោតិ** បានដល់ មិនសាបរលាបទៅជាសភាវៈ ។ បទថា **សតំ សមាគមោ** សេចក្តីថា ការសមាគមរបស់បណ្ឌិត ដោយអំណាចការចងភ្ជាប់នូវមិត្រ ។ បទថា **យាវម្បិ តិដ្ឋេយ្យ** សេចក្តីថា គប្បីតាំងនៅយូរប៉ុនណា ។ បទថា **តថេវ ហោតិ** សេចក្តីថា ទីលំនៅនោះគង់នៅមិនលះប្រក្រតី ។ បទថា **ខិប្បញ្ហិ វេតិ** គឺ សាបរលាបឆាប់រហ័ស ។

**អដ្ឋកថា សុវិទូរសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## វិសាខសូត្រទី ៨

[ ៤៩ ] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះវិសាខ-បញ្ចាលីបុត្រ ( វិសាខភិក្ខុកូននៃនាងព្រាហ្មណី ឈ្មោះបញ្ចាលី ) ដ៏មានអាយុ ពន្យល់ភិក្ខុទាំងឡាយ ឲ្យយល់ច្បាស់ ឲ្យកាន់យកដោយល្អ ឲ្យអាចហ៊ាន ឲ្យ

រីករាយ ដោយធម្មីកថាក្នុងរោងធាន់ ប្រកបដោយសម្ដីជារបស់អ្នកក្រុង ជាវាចាច្បាស់លាស់ ប្រាសចាកទោស អាចញុំាងអ្នកស្ដាប់ ឲ្យចូលចិត្តសេចក្ដីជាក់លាក់បាន រាប់បញ្ចូលក្នុងវិវដ្ដៈ មិនបានអាស្រ័យនូវវដ្ដសង្សារ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ចេញអំពីទីពួនសម្ងំ ក្នុងសាយណ្ហសម័យហើយ ស្ដេចចូលទៅកាន់រោងធាន់ លុះចូលទៅដល់ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគ ទ្រង់គង់ស្រេចហើយ បានត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ នរណាហ្ន៎ ពន្យល់ភិក្ខុទាំងឡាយឲ្យយល់ច្បាស់ ឲ្យកាន់យកដោយល្អ ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាក្នុងរោងធាន់ ប្រកបដោយសម្ដីជារបស់អ្នកក្រុង ជាវាចាច្បាស់លាស់ ប្រាសចាកទោស អាចញុំាងអ្នកស្ដាប់ ឲ្យចូលចិត្តសេចក្ដីជាក់លាក់បាន រាប់បញ្ចូលក្នុងវិវដ្ដៈ មិនបានអាស្រ័យនូវវដ្ដសង្សារ ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះវិសាខបញ្ចាលីបុត្រដ៏មានអាយុ ពន្យល់ភិក្ខុទាំងឡាយឲ្យយល់ច្បាស់ ឲ្យកាន់យកដោយល្អ ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ក្នុងរោងធាន់ ប្រកបដោយសម្ដីជារបស់អ្នកក្រុង ជាវាចាច្បាស់លាស់ ប្រាសចាកទោស អាចញុំាងអ្នកស្ដាប់ ឲ្យចូលចិត្តសេចក្ដីជាក់លាក់ រាប់បញ្ចូលក្នុងវិវដ្ដៈ មិនបានអាស្រ័យនូវវដ្ដសង្សារ ។ លំដាប់នោះ ព្រះមានព្រះភាគ បានត្រាស់ទៅនឹងព្រះវិសាខបញ្ចាលីបុត្ត ដ៏មានអាយុថា ម្នាលវិសាខៈ ប្រពៃណាស់ហើយ ម្នាលវិសាខៈ ប្រពៃណាស់ហើយ អ្នកពន្យល់ភិក្ខុទាំងឡាយឲ្យយល់ច្បាស់ ឲ្យកាន់យកដោយល្អ ឲ្យអាចហ៊ាន ឲ្យ

រីករាយដោយធម្មីកថា ប្រកបដោយសម្ដីជារបស់អ្នកក្រុង ជាវាចាច្បាស់លាស់ ប្រាសចាកទោស អាចញុំាងអ្នកស្ដាប់ឲ្យចូលចិត្តសេចក្ដីជាក់លាក់បាន រាប់បញ្ចូលក្នុងវិវដ្ដៈ មិនបានអាស្រ័យនូវវដ្ដសង្សារ ។

បណ្ឌិតដែលនៅច្រឡំដោយពួកបុគ្គលពាល កាលបើមិនទាន់និយាយទេ ជនទាំងឡាយក៏មិនស្គាល់ថា ( ជាបណ្ឌិតឡើយ ) លុះតែបណ្ឌិតបាននិយាយ ឬសម្ដែងនូវចំណែកនៃព្រះនិព្វានទើបជនទាំងឡាយស្គាល់បាន ។ បណ្ឌិតគួរសម្ដែង គួរបំភ្លឺ គួរលើកតម្កើងនូវព្រះនវលោកុត្តរធម៌ ដែលជាទង់ជ័យរបស់ពួកឥសី ពួកឥសី ( គឺព្រះអរិយបុគ្គល មានព្រះពុទ្ធជាដើម ) មានសុភាសិតជាទង់ជ័យ ព្រោះថា ព្រះនព្វលោកុត្តរធម៌ ជាទង់ជ័យរបស់ពួកឥសី ។

# អដ្ឋកថា

## វិសាខសូត្រ

[ ៤៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវិសាខសូត្រទី ៨ ដូចតទៅនេះ បទថា **បញ្ចាលិបុត្តោ** គឺជាកូនរបស់ព្រាហ្មណី ឈ្មោះបញ្ចាលី ។ បទថា **පោរិយា វាចាយ** គឺដោយវាចាដែលបរិបូណ៌ ។ បទថា **វិស្សដ្ឋាយ** គឺអណ្ដាតមិន

ជាប់ ។ បទថា **អនេឡគលាយ** សេចក្តីថា មិនមានទោស មិនជាក់ជុប ព្យញ្ជនៈមិនប្រែប្រួល ។ បទថា **បរិយាបន្នាយ** គឺទាក់ទងក្នុងវដ្តៈ ។ បទថា **អនិស្សិតាយ** គឺមិនអាស្រ័យវដ្តៈ ។ អធិប្បាយថា ពោលពាក្យឲ្យអាស្រ័យវិវដ្តៈប៉ុណ្ណោះ មិនពោលពាក្យឲ្យអាស្រ័យវដ្តៈឡើយ ។

បទថា **ធាភាសមានំ** គឺមិនពោលក៏មិនមានបុគ្គលណាស្គាល់ ។ បទថា **អមតំ បទំ** បានដល់ បទ គឺព្រះនិព្វាន ។ បទថា **ភាសយេ** បានដល់ គប្បីធ្វើឲ្យច្បាស់លាស់ ។ បទថា **ជោតយេ** ជាវេវចនៈនៃបទថា **ភាសយេ** នុ៎ះឯង ។ បទថា **បគ្គណ្ហេ ឥសីនំ ធជំ** សេចក្តីថា លោកុត្តរធម៌ ៩ យ៉ាង ហៅថា ទង់ជ័យរបស់ពួកឥសី ព្រោះអត្ថថា ផ្សាយខ្ពរខ្ពាយទៅ អធិប្បាយថា គប្បីលើកតម្កើងលោកុត្តរធម៌នោះ គឺគប្បីពោលលើកឲ្យខ្ពស់ ។ ពួកឥសីឈ្មោះថា មានសុភាសិតជាទង់ ព្រោះអត្ថថា មានសុភាសិតដែលសម្តែងលោកុត្តរធម៌ ៩ ជាទង់ ។ បទថា **ឥសិយោ** បានដល់ ព្រះអរិយៈទាំងឡាយមានព្រះពុទ្ធជាដើម ។ បទថា **ធម្មោ ហិ ឥសីនំ ធជោ** សេចក្តីថា លោកុត្តរធម៌ ឈ្មោះថា ជាទង់របស់ពួកឥសី ដោយន័យដែលពោលហើយខាងដើមនោះឯង ។ល។

## អដ្ឋកថាវិសាខសូត្រទី ៨ ចប់

# សុត្តន្តបិដក

## វិបល្លាសសូត្រទី ៩

[ ៥០ ] ម្នាលភិក្ខុទាំងឡាយ សញ្ញាវិបល្លាស ចិត្តវិបល្លាស និងទិដ្ឋិវិបល្លាសទាំងឡាយនេះមាន ៤ យ៉ាង ។ វិបល្លាស ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាវិបល្លាស ចិត្តវិបល្លាស និងទិដ្ឋិវិបល្លាសថាទៀងក្នុងរបស់ដែលមិនទៀង ១ ម្នាលភិក្ខុទាំងឡាយ សញ្ញាវិបល្លាស ចិត្តវិបល្លាស និងទិដ្ឋិវិបល្លាសថា ជាសុខក្នុងរបស់ដែលជាទុក្ខ ១ ម្នាលភិក្ខុទាំងឡាយ សញ្ញាវិបល្លាស ចិត្តវិបល្លាស និងទិដ្ឋិវិបល្លាសថា ខ្លួន ក្នុងរបស់ដែលមិនមែនខ្លួន ១ ម្នាលភិក្ខុទាំងឡាយ សញ្ញាវិបល្លាស ចិត្តវិបល្លាស និងទិដ្ឋិ-វិបល្លាសថា ស្អាត ក្នុងរបស់ដែលមិនស្អាត ១ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាវិបល្លាស ចិត្តវិបល្លាស និងទិដ្ឋិវិបល្លាស មាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាមិនវិបល្លាស ចិត្តមិនវិបល្លាស និងទិដ្ឋិមិនវិបល្លាសនេះ មាន ៤ យ៉ាង ។ មិនវិបល្លាស ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាមិនវិបល្លាស ចិត្តមិនវិបល្លាស និងទិដ្ឋិមិនវិបល្លាសថា មិនទៀង ក្នុងរបស់ដែលមិនទៀង ១ ម្នាលភិក្ខុទាំងឡាយ សញ្ញាមិនវិបល្លាស ចិត្តមិនវិបល្លាស និងទិដ្ឋិមិនវិបល្លាសថា ជាទុក្ខ ក្នុងរបស់ដែលជាទុក្ខ ១ ម្នាលភិក្ខុទាំងឡាយ សញ្ញាមិនវិបល្លាស ចិត្តមិនវិបល្លាស និងទិដ្ឋិមិនវិបល្លាសថា មិនមែនខ្លួន ក្នុងរបស់ដែលមិនមែនខ្លួន ១ ម្នាលភិក្ខុទាំងឡាយ សញ្ញាមិនវិបល្លាស ចិត្តមិនវិបល្លាស និងទិដ្ឋិមិន

វិបល្លាសថា មិនស្អាត ក្នុងរបស់ដែលមិនស្អាត ១ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាមិនវិបល្លាស ចិត្តមិនវិបល្លាស និងទិដ្ឋិមិនវិបល្លាស មាន ៤ យ៉ាង នេះឯង ។

សត្វទាំងឡាយ ដែលមិច្ឆាទិដ្ឋិបៀតបៀនហើយ ជាអ្នកមាន ចិត្តរវើរវាយ មានសញ្ញាទៅប្រាសហើយ រមែងមានសេចក្តី សម្គាល់ថាទៀង ក្នុងរបស់ដែលមិនទៀង មានសេចក្តីសម្គាល់ ថាសុខ ក្នុងរបស់ដែលជាទុក្ខ មានសេចក្តីសម្គាល់ថាខ្លួន ក្នុង របស់ដែលមិនមែនខ្លួន មានសេចក្តីសម្គាល់ថាល្អ ក្នុងរបស់ ដែលមិនល្អ ជនទាំងនោះ ឈ្មោះថា ជាអ្នកប្រកបក្នុងយោគៈ របស់មារ មិនដល់នូវព្រះនិព្វាន ជាទីក្សេមចាកយោគៈបាន ឡើយ សត្វទាំងឡាយ តែងមានប្រក្រតី ដល់នូវជាតិ និង មរណៈ រមែងទៅកាន់សង្សារវដ្ត លុះព្រះពុទ្ធទាំងឡាយ ទ្រង់ កើតឡើងក្នុងលោកវេលាណា ក៏ទ្រង់ធ្វើនូវពន្លឺ ។ ព្រះពុទ្ធ ទាំងនោះ ទ្រង់សម្តែងនូវព្រះធម៌ គឺសច្ចៈ ៤ នេះ ដែលជា ធម៌ប្រព្រឹត្តទៅកាន់ទីរម្ងាត់ទុក្ខ ពួកសត្វដែលប្រកបដោយប្រាជ្ញា លុះបានស្តាប់ព្រះធម៌ របស់ព្រះពុទ្ធទាំងនោះហើយ ក៏ត្រឡប់ ផាកចិត្តរបស់ខ្លួន បានឃើញនូវរបស់ដែលមិនទៀង ថាមិន ទៀង ឃើញនូវរបស់ដែលជាទុក្ខ ថាជាទុក្ខ បានឃើញថា មិនមែនខ្លួន ក្នុងរបស់ដែលមិនមែនខ្លួន បានឃើញរបស់ដែល

មិនល្អ ថាមិនល្អ ( ជនទាំងនោះ ) ជាអ្នកសមាទាននូវ
សម្មាទិដ្ឋិ បានរួចចាកទុក្ខទាំងពួង ។

# អដ្ឋកថា

## វិបល្លាសសូត្រ

[ ៥០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវិបល្លាសសូត្រទី ៩ ដូចតទៅនេះ បទថា **សញ្ញាវិបល្លាសា** សេចក្ដីថា មានសញ្ញា គឺការសម្គាល់ឃ្លៀងឃ្លាត អធិប្បាយថា មានសញ្ញាវិបរិត ៤ ។ ក្នុង ២ បទដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា **អនិច្ចេ ភិក្ខវេ និច្ចន្តិ សញ្ញាវិបល្លាសោ** សេចក្ដីថា កើតនូវការសម្គាល់ គឺប្រកាន់យ៉ាងនេះថា ទៀង ក្នុងរបស់ដែលមិនទៀង ឈ្មោះថា សញ្ញាវិបល្លាស ។ បណ្ឌិតគប្បីជ្រាបអត្ថគ្រប់បទដោយន័យនេះ ។

បទថា **អនត្តនិ ច អត្តា** សេចក្ដីថា បុគ្គលអ្នកមានសេចក្ដីសម្គាល់យ៉ាងនេះថា ជាអត្តាក្នុងវត្ថុដែលជាអនត្តា ។ បទថា **មិច្ឆាទិដ្ឋិហតា** សេចក្ដីថា សត្វនឹងសម្គាល់តែម្យ៉ាងប៉ុណ្ណោះក៏មិនមែន នៅមានមិច្ឆាទិដ្ឋិ គឺការយល់ខុស ដែលកំពុងកើតឡើង នាំទៅហើយ ដូចសញ្ញាវិបល្លាស ។ បទថា **ចិត្តចិត្តា** សេចក្ដីថា ប្រកបដោយចិត្តរាយមាយ ដែលកំពុងកើតឡើង ដូចសញ្ញាវិបល្លាស និងទិដ្ឋិវិបល្លាស ។ បទថា **វិសញ្ញិនោ** នោះ ត្រឹមតែជា

ទេសនា ។ អធិប្បាយថា ជាសញ្ញា ចិត្ត និងទិដ្ឋិដែលវិបរិត ។ បទថា **តេ យោគយុត្តា មារស្ស** សេចក្តីថា សត្វទាំងនោះ ឈ្មោះថា ប្រកបនៅក្នុងគ្រឿងចងរបស់មារ ។ បទថា **អយោគក្ខេមិនោ** សេចក្តីថា ជាបុគ្គលមិនដល់នូវការក្សេមចាកយោគៈ ៤ គឺព្រះនិព្វាន ។ បទថា **សត្តា** គឺបុគ្គលទាំងឡាយ ។ បទថា **ពុទ្ធា** គឺបុគ្គលត្រាស់ដឹងសច្ចៈ ៤ ។ បទថា **ឥមំ ធម្មំ** គឺសច្ចៈ ៤ ។ បទថា **សចិត្តំ បច្ចលទ្ធា** បានដល់ ត្រឡប់បាននូវការគិតខ្លួនឯង ។ បទថា **អនិច្ចតោ ទុក្ខំ** បានដល់ បានឃើញដោយភាពជារបស់មិនទៀងពិត ។ បទថា **អសុភតទ្ទសុំ** បានដល់ បានឃើញដោយភាពជា របស់មិនស្អាតពិត ។ បទថា **សម្មាទិដ្ឋិ សមាទានា** បានដល់ ជាបុគ្គលទាញយក សម្មាទស្សនៈ ។ បទថា **សព្វំ ទុក្ខំ ឧបច្ចគុំ** សេចក្តីថា កន្លងផុតវដ្តទុក្ខទាំងមូលបាន ៕

## អដ្ឋកថា វិបល្លាសសូត្រទី ៩ ចប់

# សុត្តន្តបិដក

## ឧបក្កិលេសសូត្រទី ១០

[ ៥១ ] ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទ្រ និងព្រះអាទិត្យសៅហ្មងដោយឧបក្កិលេសទាំងឡាយណា រមែងមិនក្តៅ មិនភ្លឺ មិនរុងរឿង ឧបក្កិលេសរបស់ព្រះចន្ទ្រ និងព្រះអាទិត្យទាំងឡាយនេះមាន ៤ យ៉ាង ។ ឧបក្កិលេស ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទ្រ និងព្រះអាទិត្យសៅហ្មង ព្រោះឧបក្កិលេសណា រមែងមិនក្តៅ មិនភ្លឺ មិនរុងរឿង ឧបក្កិលេសរបស់ព្រះចន្ទ្រ និងព្រះអាទិត្យទាំងឡាយនោះ គឺពពក ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទ្រ និងព្រះអាទិត្យសៅហ្មង ព្រោះឧបក្កិលេសណា រមែងមិនក្តៅ មិនភ្លឺ មិនរុងរឿង ឧបក្កិលេសរបស់ព្រះចន្ទ្រ និងព្រះអាទិត្យទាំងនោះ គឺទឹកសន្សើម ១ ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទ្រ និងព្រះអាទិត្យសៅហ្មងព្រោះឧបក្កិលេសណា រមែងមិនក្តៅ មិនភ្លឺ មិនរុងរឿង ឧបក្កិលេសរបស់ព្រះចន្ទ្រ និងព្រះអាទិត្យទាំងឡាយនោះ គឺផ្សែង ឬធូលី ១ ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទ្រ និងព្រះអាទិត្យ សៅហ្មងព្រោះឧបក្កិលេសណា រមែងមិនក្តៅ មិនភ្លឺ មិនរុងរឿង ឧបក្កិលេសរបស់ព្រះចន្ទ្រ និងព្រះអាទិត្យទាំងឡាយនោះ គឺរាហុអសុរិន្ទ ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទ្រ និងព្រះអាទិត្យសៅហ្មងព្រោះឧបក្កិលេសទាំងឡាយណា រមែងមិនក្តៅ មិនភ្លឺ មិនរុងរឿង ឧបក្កិលេសរបស់ព្រះចន្ទ្រ និងព្រះអាទិត្យទាំងឡាយមាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ទាំងឡាយពួកមួយ

សៅហ្មងព្រោះឧបក្កិលេសទាំងឡាយណា រមែងមិនក្តៅ មិនភ្លឺ មិនរុងរឿង ឧបក្កិលេសទាំងឡាយ របស់ពួកសមណព្រាហ្មណ៍មាន ៤ យ៉ាងនោះដែរ ។ ឧបក្កិលេស ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ទាំងឡាយពួកមួយ ផឹកនូវសុរា និងមេរ័យ មិនវៀរចាកការផឹកនូវសុរា និងមេរ័យឡើយ ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ទាំងឡាយពួកមួយ សៅហ្មងព្រោះឧបក្កិលេសណា តែងមិនក្តៅ មិនភ្លឺ មិនរុងរឿង នេះជាឧបក្កិលេសរបស់ពួកសមណព្រាហ្មណ៍ទី ១ ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ទាំងឡាយពួកមួយ សេពនូវមេថុនធម្ម មិនវៀរចាកការសេពមេថុនធម្មឡើយ ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ពួកមួយ សៅហ្មងដោយឧបក្កិលេសណា តែងមិនក្តៅ មិនភ្លឺ មិនរុងរឿង នេះជាឧបក្កិលេសរបស់សមណព្រាហ្មណ៍ទី ២ ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ទាំងឡាយពួកមួយ ត្រេកអរនូវមាស និងប្រាក់ មិនវៀរចាកការទទួលនូវមាស និងប្រាក់ឡើយ ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ទាំងឡាយពួកមួយ សៅហ្មងព្រោះឧបក្កិលេសណា តែងមិនក្តៅ មិនភ្លឺ មិនរុងរឿង នេះជាឧបក្កិលេសរបស់ពួកសមណព្រាហ្មណ៍ទី ៣ ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ពួកមួយ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ មិនវៀរចាកមិច្ឆាជីវៈឡើយ ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ពួកមួយ សៅហ្មងព្រោះឧបក្កិលេសណា តែងមិនក្តៅ មិនភ្លឺ មិនរុងរឿង នេះជាឧបក្កិលេសរបស់ពួកសមណព្រាហ្មណ៍ទី ៤ ។ ម្នាលភិក្ខុទាំងឡាយ សម-

ណព្រាហ្មណ៍ពួកមួយ សៅហ្មងព្រោះឧបក្កិលេសទាំងឡាយណា តែងមិនក្តៅ មិនភ្លឺ មិនរុងរឿង ឧបក្កិលេសរបស់ពួកសមណព្រាហ្មណ៍មាន ៤ យ៉ាងនេះឯង ។

សមណព្រាហ្មណ៍ ពួកមួយ ជាអ្នកសៅហ្មងដោយរាគៈ និងទោសៈ ត្រូវអវិជ្ជារួបរឹតហើយ មានប្រក្រតីរីករាយចំពោះរូបជាទីស្រឡាញ់ ជាជនល្ងង់ រមែងផឹកនូវសុរា និងមេរ័យ សេពនូវមេថុនធម្ម ត្រេកអរចំពោះប្រាក់ និងមាស ។ សមណព្រាហ្មណ៍ ពួកមួយ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ សមណព្រាហ្មណ៍ ពួកមួយ មិនស្អាត ប្រកបដោយធូលី រមែងមិនក្តៅ មិនភ្លឺ ព្រោះឧបក្កិលេសទាំងឡាយណា ឧបក្កិលេសទាំងនុ៎ះ ព្រះសម្ពុទ្ធជាផៅពង្សនៃព្រះអាទិត្យ បានត្រាស់ទុកហើយ ពួកសត្វត្រូវសេចក្តីងងឹតគ្របសង្កត់ហើយ ជាខ្ញុំនៃតណ្ហា ប្រព្រឹត្តទៅតាមខ្សែនៃតណ្ហា ញុំាងអត្តភាពដ៏ក្លៀវក្លាឲ្យចម្រើនឡើង តែងកាន់យកនូវភពថ្មី ។

រោហិតស្សវគ្គទី ៥ ចប់

# ឧទ្ទាននៃរោហិតស្សវគ្គនោះ គឺ

និយាយអំពីសមាធិភាវនា ១ អំពីបញ្ហាព្យាករណ៍ ១ អំពីបុគ្គលជួន់ក្នុងសេចក្តីក្រោធមាន ២ លើក អំពីរោហិតស្សទេវបុត្រដទៃ

២ លើកទៀត អំពីរបស់ដែលធ្លាយក្រៃលែងធ្លាយ ១ អំពីបញ្ចាលីបុត្រ ឈ្មោះវិសាខៈ ១ អំពីវិបល្លាស ១ អំពីឧបក្កិលេស ១ រួមត្រូវជា ១០ ។

# អដ្ឋកថា

## ឧបក្កិលេសសូត្រ

[ ៥១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧបក្កិលេសសូត្រទី ១០ ដូចតទៅនេះ បទថា **ឧបក្កិលេសា** សេចក្តីថា ឈ្មោះថា ឧបក្កិលេស ព្រោះធ្វើនូវការសៅហ្មង មិនឲ្យផូរផង់ ។ បទថា **មហិយា** គឺពពក ។ បទថា **ធូមរជោ** បានដល់ ផ្សែង និងធូលី ។ បទថា **រាហុ** សេចក្តីថា ពពក ផ្សែង និងផង់ធូលីទាំង ៣ ខាងដើម ជាឧបក្កិលេសដែលមិនដល់ព្រះចន្ទ និងព្រះអាទិត្យ ចំណែករាហុ គប្បីជ្រាបថា លោកពោលដោយអំណាចឧបក្កិលេសដែលដល់ព្រះចន្ទ និងព្រះអាទិត្យ ។ បទថា **សមណព្រាហ្មណា ន តបន្តិ ន ភាសន្តិ ន វិរោចន្តិ** សេចក្តីថា រមែងមិនស្អាត ដោយការស្អាតដោយគុណ មិនផូរផង់ដោយការស្រស់ថ្លានៃគុណ រមែងមិនរុងរឿង ដោយការរុងរោចន៍ដោយគុណ ។ បទថា **សុរាមេរយបានា អប្បដិវិរតា** សេចក្តីថា មិនវៀរចាកការផឹកសុរា ៥ យ៉ាង និងមេរ័យ ៤ យ៉ាង ។

បទថា **អវិជ្ជានិវុតា** សេចក្ដីថា ជាបុគ្គលត្រូវអវិជ្ជារិតរុំហើយ គឺបិទបាំងហើយ ។ បទថា **បិយរូបាភិនន្ទិនោ** សេចក្ដីថា ត្រេកត្រអាល ត្រេកអរនូវបិយរូប គឺវត្ថុដែលជាទីត្រេកអរ ។ បទថា **សាទិយន្តិ** គឺរមែងទទួល ។ បទថា **អវិទ្ទសុ** គឺ អន្ធពាល ។ បទថា **សនេត្តិកា** សេចក្ដីថា នាំទៅដោយខ្សែ គឺ តណ្ហា ។ បទថា **កដសឹ** គឺ អត្តភាព ។ បទថា **ឃោរំ** គឺ កាច ។ ក្នុងសូត្រក្ដី ក្នុងគាថាក្ដី ទ្រង់ត្រាស់វដ្ដៈតែម្យ៉ាង ។ល។

**អដ្ឋកថា ឧបក្កិលេសសូត្រទី ១០ ចប់**

**រោហិតស្សវគ្គទី ៥ ចប់**

**បឋមបណ្ណាសក ចប់**

# សុត្តន្តបិដក ចាលីប្រែ -៤៣

## សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ

### ព្រាហ្មណវគ្គ


បឋមជនសូត្រទី ១ ...... ...... ...... ...... ២
អដ្ឋកថាបឋមជនសូត្រ ...... ...... ...... ...... ៤
ទុតិយជនសូត្រទី ២ ...... ...... ...... ...... ៦
អដ្ឋកថាទុតិយជនសូត្រ ...... ...... ...... ...... ៨
ព្រាហ្មណសូត្រទី ៣ ...... ...... ...... ...... ៩
អដ្ឋកថាព្រាហ្មណសូត្រ ...... ...... ...... ...... ១១
បរិញ្វជកសូត្រទី ៤ ...... ...... ...... ...... ១២
អដ្ឋកថាបរិញ្វជកសូត្រ ...... ...... ...... ...... ១៥
និព្វុតសូត្រទី ៥ ...... ...... ...... ...... ១៥
អដ្ឋកថានិព្វុតសូត្រ ...... ...... ...... ...... ១៧
បលោកសូត្រទី ៦ ...... ...... ...... ...... ១៨
អដ្ឋកថាបលោកសូត្រ ...... ...... ...... ...... ២០
ជប្បសូត្រទី ៧ ...... ...... ...... ...... ២២
អដ្ឋកថាជប្បសូត្រ ...... ...... ...... ...... ២៦
តិកណ្ណសូត្រទី ៨ ...... ...... ...... ...... ៣០
អដ្ឋកថាតិកណ្ណសូត្រ ...... ...... ...... ...... ៣៦
អធិប្បាយវិជ្ជា ៣ ...... ...... ...... ...... ៤២
ជានុស្សោណិសូត្រទី ៩ ...... ...... ...... ...... ៤៩
អដ្ឋកថាជានុស្សោណិសូត្រ ...... ...... ...... ...... ៥៣

សង្ខារវសូត្រទី ១០ ...... ...... ...... ...... ៥៤
អដ្ឋកថាសង្ខារវសូត្រ ...... ...... ...... ...... ៦៤

## មហាវគ្គ

តិត្ថាយតនសូត្រទី ១ ...... ...... ...... ...... ៧៥
អដ្ឋកថាតិត្ថាយតនសូត្រ ...... ...... ...... ...... ៨៥
អត្តរបស់អាយតនសព្វ ...... ...... ...... ...... ៨៥
អាពាធ ៨ យ៉ាង ...... ...... ...... ...... ៨៩
ភយសូត្រទី ២ ...... ...... ...... ...... ១០៧
អដ្ឋកថាភយសូត្រ ...... ...... ...... ...... ១១១
វេនាគសូត្រទី ៣ ...... ...... ...... ...... ១១៤
អដ្ឋកថាវេនាគសូត្រ ...... ...... ...... ...... ១២៣
សរភសូត្រទី ៤ ...... ...... ...... ...... ១៤០
អដ្ឋកថាសរភសូត្រ ...... ...... ...... ...... ១៤៦
កេសបុត្តសូត្រទី ៥ ...... ...... ...... ...... ១៦៣
អដ្ឋកថាកាលាមសូត្រ ( សូត្រនេះមានឈ្មោះពីរ ) ..... ..... ...... ១៧៤
សាឡ្ហសូត្រទី ៦ ...... ...... ...... ...... ១៧៨
អដ្ឋកថាសាឡ្ហសូត្រ ...... ...... ...... ...... ១៨៦
កថាវត្ថុសូត្រទី ៧ ...... ...... ...... ...... ១៨៨
អដ្ឋកថាកថាវត្ថុសូត្រ ...... ...... ...... ...... ១៩៣
តិត្ថិយសូត្រទី ៨ ...... ...... ...... ...... ២០៣
អដ្ឋកថាតិត្ថិយសូត្រ ...... ...... ...... ...... ២០៧
រឿងស្រីសម្លាប់ប្តី ...... ...... ...... ...... ២០៩
មូលសូត្រទី ៩ ...... ...... ...... ...... ២១៣

អដ្ឋកថាមូលសូត្រ ...... ...... ...... ...... ២២១

ឧបោសថសូត្រទី ១០ ...... ...... ...... ...... ២២៥

អដ្ឋកថាឧបោសថសូត្រ ...... ...... ...... ...... ២៤៦


### អានន្ទវគ្គ


ឆន្នសូត្រទី ១ ...... ...... ...... ...... ២៦២

អដ្ឋកថាឆន្នសូត្រ ...... ...... ...... ...... ២៦៦

អាជីវកសូត្រទី ២ ...... ...... ...... ...... ២៦៨

អដ្ឋកថាអាជីវកសូត្រ ...... ...... ...... ...... ២៧២

មហានាមសក្កសូត្រទី ៣ ...... ...... ...... ...... ២៧៣

អដ្ឋកថាមហានាមសក្កសូត្រ ...... ...... ...... ...... ២៧៥

និគណ្ឋនាដសូត្រទី ៤ ...... ...... ...... ...... ២៧៦

អដ្ឋកថានិគណ្ឋនាដសូត្រ ...... ...... ...... ...... ២៧៩

សមាទបកសូត្រទី ៥ ...... ...... ...... ...... ២៨៣

អដ្ឋកថាសមាទបកសូត្រ ...... ...... ...... ...... ២៨៥

នវសូត្រទី ៦ ...... ...... ...... ...... ២៨៧

អដ្ឋកថានវសូត្រ ...... ...... ...... ...... ២៨៨

កវសូត្រទី ៧ ...... ...... ...... ...... ២៨៩

អដ្ឋកកវសូត្រ ...... ...... ...... ...... ២៩១

សីលព្វតសូត្រទី ៨ ...... ...... ...... ...... ២៩១

អដ្ឋកថាសីលព្វតសូត្រ ...... ...... ...... ...... ២៩៣

គន្ធសូត្រទី ៩ ...... ...... ...... ...... ២៩៤

អដ្ឋកថាគន្ធសូត្រ ...... ...... ...... ...... ២៩៧

ចូឡូណិសូត្រទី ១០ ...... ...... ...... ...... ២៩៩

អដ្ឋកថាចូឡណីសូត្រ ...... ...... ...... ...... ៣០៤

### សមណវគ្គ

សមណសូត្រទី ១ ...... ...... ...... ...... ៣២០
អដ្ឋកថាសមណសូត្រ ...... ...... ...... ...... ៣២១
គទ្រភសូត្រទី ២ ...... ...... ...... ...... ៣២២
អដ្ឋកថាគទ្រភសូត្រ ...... ...... ...... ...... ៣២៣
ខេត្តសូត្រទី ៣ ...... ...... ...... ...... ៣២៤
អដ្ឋកថាខេត្តសូត្រ ...... ...... ...... ...... ៣២៥
វជ្ជិបុត្តសូត្រទី ៤ ...... ...... ...... ...... ៣២៦
អដ្ឋកថាវជ្ជិបុត្តសូត្រ ...... ...... ...... ...... ៣២៧
បឋមសេក្ខសូត្រទី ៥ ...... ...... ...... ...... ៣២៩
អដ្ឋកថាបឋមសេក្ខសូត្រ ...... ...... ...... ...... ៣៣០
ទុតិយសេក្ខសូត្រទី ៦ ...... ...... ...... ...... ៣៣១
អដ្ឋកថាទុតិយសេក្ខសូត្រ ...... ...... ...... ...... ៣៣៤
តតិយសេក្ខសូត្រទី ៧ ...... ...... ...... ...... ៣៣៧
អដ្ឋកថាតតិយសេក្ខសូត្រ ...... ...... ...... ...... ៣៣៩
ចតុត្ថសេក្ខសូត្រទី ៨ ...... ...... ...... ...... ៣៤៤
អដ្ឋកថាចតុត្ថសេក្ខសូត្រ ...... ...... ...... ...... ៣៤៦
បឋមសិក្ខាសូត្រទី ៩ ...... ...... ...... ...... ៣៤៧
អដ្ឋកថាបឋមសិក្ខាសូត្រ ...... ...... ...... ...... ៣៤៨
ទុតិយសិក្ខាសូត្រទី ១០ ...... ...... ...... ...... ៣៤៨
អដ្ឋកថាទុតិយសិក្ខាសូត្រ ...... ...... ...... ...... ៣៥០
បំកធាសូត្រទី ១១ ...... ...... ...... ...... ៣៥២

អដ្ឋកថាបំកជាសូត្រ ...... ...... ...... ...... ៣៥៨

លោណផលវគ្គ

អច្ចាយិកសូត្រទី ១ ...... ...... ...... ...... ៣៦១

អដ្ឋកថាអច្ចាយិកសូត្រ ...... ...... ...... ...... ៣៦៣

វិវិត្តសូត្រទី ២ ...... ...... ...... ...... ៣៦៤

អដ្ឋកថាវិវិត្តសូត្រ ...... ...... ...... ...... ៣៦៨

សរទសូត្រទី ៣ ...... ...... ...... ...... ៣៧១

អដ្ឋកថាសរទសូត្រ ...... ...... ...... ...... ៣៧២

បរិសាសូត្រទី ៤ ...... ...... ...... ...... ៣៧៣

អដ្ឋកថាបរិសាសូត្រ ...... ...... ...... ...... ៣៧៥

បឋមអាជានីយសូត្រទី ៥ ...... ...... ...... ...... ៣៧៨

អដ្ឋកថាបឋមអាជានីយសូត្រ ...... ...... ...... ...... ៣៨០

ទុតិយអាជានីយសូត្រទី ៦ ...... ...... ...... ...... ៣៨១

អដ្ឋកថាទុតិយអាជានីយសូត្រ ...... ...... ...... ...... ៣៨៣

តតិយអាជានីយសូត្រទី ៧ ...... ...... ...... ...... ៣៨៣

អដ្ឋកថាតតិយអាជានីយសូត្រ ...... ...... ...... ...... ៣៨៥

នវសូត្រទី ៨ ...... ...... ...... ...... ៣៨៦

អដ្ឋកថានវសូត្រ ...... ...... ...... ...... ៣៩១

លោណកសូត្រទី ៩ ...... ...... ...... ...... ៣៩២

អដ្ឋកថាលោណកសូត្រ ...... ...... ...... ...... ៣៩៨

សង្ឃសូត្រទី ១០ ...... ...... ...... ...... ៤០៣

អដ្ឋកថាសង្ឃសូត្រ ...... ...... ...... ...... ៤០៩

សូត្រសមុគ្គតសូត្រទី ១១ ...... ...... ...... ...... ៤១២

អដ្ឋកថាសមុគ្គតសូត្រ ...... ...... ...... ...... ៤១៦

# តតិយបណ្ណាសក

## សម្ពោធិវគ្គ

បុព្វសូត្រទី ១ ...... ...... ...... ...... ៤១៩
អដ្ឋកថាបុព្វសូត្រ ...... ...... ...... ...... ៤២១
មនុស្សសូត្រទី ២ ...... ...... ...... ...... ៤២៣
អដ្ឋកថាមនុស្សសូត្រ ...... ...... ...... ...... ៤២៤
អស្សាទសូត្រទី ៣ និងអដ្ឋកថា ...... ...... ...... ...... ៤២៥
សមណសូត្រទី ៤ និងអដ្ឋកថា ...... ...... ...... ...... ៤២៦
រោណសូត្រទី ៥ ...... ...... ...... ...... ៤២៨
អដ្ឋកថារោណសូត្រ ...... ...... ...... ...... ៤២៩
អតិត្តសូត្រទី ៦ ...... ...... ...... ...... ៤៣០
អដ្ឋកថាអតិត្តសូត្រ ...... ...... ...... ...... ៤៣១
បឋមកូដសូត្រទី ៧ ...... ...... ...... ...... ៤៣១
អដ្ឋកថាបឋមកូដសូត្រ ...... ...... ...... ...... ៤៣៣
ទុតិយកូដសូត្រទី ៨ ...... ...... ...... ...... ៤៣៤
អដ្ឋកថាទុតិយកូដសូត្រ ...... ...... ...... ...... ៤៣៥
បឋមនិទានសូត្រទី ៩ ...... ...... ...... ...... ៤៣៦
អដ្ឋកថាបឋមនិទានសូត្រ ...... ...... ...... ...... ៤៣៨
ទុតិយនិទានសូត្រទី ១០ ...... ...... ...... ...... ៤៣៩
អដ្ឋកថាទុតិយនិទានសូត្រ ...... ...... ...... ...... ៤៤២

## អាបាយិកវគ្គ

អាបាយិកសូត្រទី ១ ...... ...... ...... ...... ៤៤៤
អដ្ឋកថាអាបាយិកសូត្រ ...... ...... ...... ...... ៤៤៥
ទុល្លភសូត្រសូត្រទី ២ ...... ...... ...... ...... ៤៤៦
អដ្ឋកថាទុល្លភសូត្រ ...... ...... ...... ...... ៤៤៦
អប្បមេយ្យសូត្រទី ៣ ...... ...... ...... ...... ៤៤៧
អដ្ឋកថាអប្បមេយ្យសូត្រ ...... ...... ...... ...... ៤៤៨
អានេញ្ជសូត្រទី ៤ ...... ...... ...... ...... ៤៤៩
អដ្ឋកថាអានេញ្ជសូត្រ ...... ...... ...... ...... ៤៥២
អយសូត្រទី ៥ ...... ...... ...... ...... ៤៥៣
អដ្ឋកថាអយសូត្រ ...... ...... ...... ...... ៤៥៦
អបណ្ណកសូត្រទី ៦ ...... ...... ...... ...... ៤៥៧
អដ្ឋកថាអបណ្ណកសូត្រ ...... ...... ...... ...... ៤៦០
កម្មន្តសូត្រទី ៧ ( មិនមានអដ្ឋកថា ) ...... ...... ...... ...... ៤៦១
បឋមសោចេយ្យសូត្រទី ៨ ...... ...... ...... ...... ៤៦៣
អដ្ឋកថាបឋមសោចេយ្យសូត្រ ...... ...... ...... ...... ៤៦៣
ទុតិយសោចេយ្យសូត្រទី ៩ ...... ...... ...... ...... ៤៦៥
អដ្ឋកថាទុតិយសោចេយ្យសូត្រ ...... ...... ...... ...... ៤៦៨
មោនេយ្យសូត្រទី ១០ ...... ...... ...... ...... ៤៦៩
អដ្ឋកថាមោនេយ្យសូត្រ ...... ...... ...... ...... ៤៧០

## កុសិនារវគ្គ

កុសិនារសូត្រទី ១ ...... ...... ...... ...... ៤៧២
អដ្ឋកថាកុសិនារសូត្រ ...... ...... ...... ...... ៤៧៥
កណ្ឌនសូត្រទី ២ ...... ...... ...... ...... ៤៧៧

អដ្ឋកថាកណ្ហនសូត្រ ...... ...... ...... ...... ៤៧៩
គោតមចេតិយសូត្រទី ៣ ...... ...... ...... ...... ៤៧៩
អដ្ឋកថាគោតមចេតិយសូត្រ ...... ...... ...... ...... ៤៨០
ករណ្ឌុសូត្រសូត្រទី ៤ ...... ...... ...... ...... ៤៨៤
អដ្ឋកថាករណ្ឌុសូត្រ ...... ...... ...... ...... ៤៨៧
ហត្ថកសូត្រទី ៥ ...... ...... ...... ...... ៤៨៩
អដ្ឋកថាហត្ថកសូត្រ ...... ...... ...... ...... ៤៩១
កដុវិយសូត្រទី ៦ ...... ...... ...... ...... ៤៩៧
អដ្ឋកថាកដុវិយសូត្រ ...... ...... ...... ...... ៤៩៩
អនុរុទ្ធសូត្រទី ៧ ...... ...... ...... ...... ៥០១
អដ្ឋកថាអនុរុទ្ធសូត្រ ...... ...... ...... ...... ៥០២
ទុតិយអនុរុទ្ធសូត្រទី ៨ ...... ...... ...... ...... ៥០២
អដ្ឋកថាទុតិយអនុរុទ្ធសូត្រ ...... ...... ...... ...... ៥០៤
បដិច្ឆន្នសូត្រទី ៩ ...... ...... ...... ...... ៥០៥
អដ្ឋកថាបដិច្ឆន្នសូត្រ ...... ...... ...... ...... ៥០៦
លេខសូត្រទី ១០ ...... ...... ...... ...... ៥០៧
អដ្ឋកថាលេខសូត្រ ...... ...... ...... ...... ៥០៩

## យោធាជីវវគ្គ

យោធសូត្រទី ១ ...... ...... ...... ...... ៥១០
អដ្ឋកថាយោធសូត្រ ...... ...... ...... ...... ៥១៣
បរិសាសូត្រសូត្រទី ២ ...... ...... ...... ...... ៥១៤
អដ្ឋកថាបរិសាសូត្រ ...... ...... ...... ...... ៥១៥
មិត្តសូត្រទី ៣ និងអដ្ឋកថា ...... ...... ...... ...... ៥១៦

ឧប្បាទសូត្រទី ៤ ...... ...... ...... ...... ៥១៧
អដ្ឋកថាឧប្បាទសូត្រ ...... ...... ...... ...... ៥១៨
កេសកម្ពលសូត្រទី ៥ ...... ...... ...... ...... ៥១៩
អដ្ឋកថាកេសកម្ពលសូត្រ ...... ...... ...... ...... ៥២០
សម្បទាសូត្រទី ៦ និងអដ្ឋកថា ...... ...... ...... ...... ៥២១
វុឌ្ឍិសូត្រទី ៧ និងអដ្ឋកថា ...... ...... ...... ...... ៥២២
បឋមអស្សសូត្រទី ៨ ...... ...... ...... ...... ៥២៣
អដ្ឋកថាបឋមអស្សសូត្រ ...... ...... ...... ...... ៥២៦
ទុតិយអស្សសូត្រទី ៩ ...... ...... ...... ...... ៥២៦
អដ្ឋកថាទុតិយអស្សសូត្រ ...... ...... ...... ...... ៥៣០
តតិយអស្សសូត្រទី ១០ ...... ...... ...... ...... ៥៣០
អដ្ឋកថាតតិយអស្សសូត្រ ...... ...... ...... ...... ៥៣២
បឋមមោរនិវាបសូត្រទី ១១ ...... ...... ...... ...... ៥៣២
អដ្ឋកថាបឋមមោរនិវាបសូត្រ ...... ...... ...... ...... ៥៣៣
ទុតិយមោរនិវាបសូត្រទី ១២ ...... ...... ...... ...... ៥៣៤
អដ្ឋកថាទុតិយមោរនិវាបសូត្រ ...... ...... ...... ...... ៥៣៤
តតិយមោរនិវាបសូត្រទី ១៣ ...... ...... ...... ...... ៥៣៥
អដ្ឋកថាតតិយមោរនិវាបសូត្រ ...... ...... ...... ...... ៥៣៦

## មង្គលវគ្គ

អកុសលសូត្រទី ១ និងអដ្ឋកថា ...... ...... ...... ...... ៥៣៧
សាវជ្ជសូត្រទី ២ និងអដ្ឋកថា ...... ...... ...... ...... ៥៣៨
វិសមសូត្រទី ៣ និងអដ្ឋកថា ...... ...... ...... ...... ៥៣៩

អសុចិសូត្រទី ៤ និងអដ្ឋកថា ...... ...... ...... ...... ៥៤០
បឋមខតសូត្រទី ៥ និងអដ្ឋកថា ...... ...... ...... ...... ៥៤១
ទុតិយខតសូត្រទី ៦ និងអដ្ឋកថា ...... ...... ...... ...... ៥៤២
តតិយខតសូត្រទី ៧ និងអដ្ឋកថា ...... ...... ...... ...... ៥៤៣
ចតុត្ថខតសូត្រទី ៨ និងអដ្ឋកថា ...... ...... ...... ...... ៥៤៣
វន្ទនាសូត្រទី ៩ និងអដ្ឋកថា ...... ...... ...... ...... ៥៤៥
សុបុព្វណ្ហសូត្រទី ១០ ...... ...... ...... ...... ៥៤៥
អដ្ឋកថាសុបុព្វណ្ហសូត្រ ...... ...... ...... ...... ៥៤៧
សូត្រមិនសង្គ្រោះចូលក្នុងបណ្ណាសក ...... ...... ...... ...... ៥៤៩
អដ្ឋកថាសូត្រមិនសង្គ្រោះចូលក្នុងបណ្ណាសក ...... ...... ...... ...... ៥៥៩

# សុត្តន្តបិដក ចាលីប្រែ -៤២

## ភណ្ឌគ្គាមវគ្គ

អនុពុទ្ធសូត្រទី ១ ...... ...... ...... ...... ៥៦៤
អដ្ឋកថាអនុពុទ្ធសូត្រ ...... ...... ...... ...... ៥៦៧
បបតិតសូត្រទី ២ ...... ...... ...... ...... ៥៦៩
អដ្ឋកថាបបតិតសូត្រ ...... ...... ...... ...... ៥៧០
បឋមខតសូត្រទី ៣ ...... ...... ...... ...... ៥៧១
អដ្ឋកថាបឋមខតសូត្រ ...... ...... ...... ...... ៥៧៤
ទុតិយខតសូត្រទី ៤ ...... ...... ...... ...... ៥៧៥
អដ្ឋកថាទុតិយខតសូត្រ ...... ...... ...... ...... ៥៧៧
អនុសោតសូត្រទី ៥ ...... ...... ...... ...... ៥៧៨
អដ្ឋកថាអនុសោតសូត្រ ...... ...... ...... ...... ៥៨១

អប្បស្សុតសូត្រទី ៦ ...... ...... ...... ...... ៥៨២
អដ្ឋកថាអប្បស្សុតសូត្រ ...... ...... ...... ...... ៥៨៥
អធិប្បាយសុត្តៈ និងគេយ្យៈជាដើម ...... ...... ...... ...... ៥៨៥
សង្ឃសោភណសូត្រទី ៧ ...... ...... ...... ...... ៥៨៨
អដ្ឋកថាសង្ឃសោភណសូត្រ ...... ...... ...... ...... ៥៨៩
វេសារជ្ជទី ៨ ...... ...... ...... ...... ៥៨៩
អដ្ឋកថាវេសារជ្ជសូត្រ ...... ...... ...... ...... ៥៩២
អត្ថរបស់ចក្កសព្ទ ...... ...... ...... ...... ៥៩៤
តណ្ហាសូត្រទី ៩ ...... ...... ...... ...... ៥៩៩
អដ្ឋកថាតណ្ហាសូត្រ ...... ...... ...... ...... ៦០០
យោគសូត្រទី ១០ ...... ...... ...... ...... ៦០២
អដ្ឋកថាយោគសូត្រ ...... ...... ...... ...... ៦០៨

ចរវគ្គ

ចរសូត្រទី ១ ...... ...... ...... ...... ៦១២
អដ្ឋកថាចារសូត្រ ...... ...... ...... ...... ៦១៥
សីលសូត្រទី ២ ...... ...... ...... ...... ៦១៦
អដ្ឋកថាសីលសូត្រ ...... ...... ...... ...... ៦១៨
បធានសូត្រទី ៣ ...... ...... ...... ...... ៦២០
អដ្ឋកថាបធានសូត្រ ...... ...... ...... ...... ៦២១
សំវរសូត្រទី ៤ ...... ...... ...... ...... ៦២២
អដ្ឋកថាសំវរសូត្រ ...... ...... ...... ...... ៦២៥
បញ្ញត្តិសូត្រទី ៥ ...... ...... ...... ...... ៦២៧
អដ្ឋកថាបញ្ញត្តិសូត្រ ...... ...... ...... ...... ៦២៨
សោខុម្មសូត្រទី ៦ ...... ...... ...... ...... ៦២៩

អដ្ឋកថាសោខុម្មសូត្រ ...... ...... ...... ...... ៦៣១
បឋមអគតិសូត្រទី ៧ ...... ...... ...... ...... ៦៣២
អដ្ឋកថាបឋមអគតិសូត្រ ...... ...... ...... ...... ៦៣៣
ទុតិយអគតិសូត្រទី ៨ និងអដ្ឋកថា ...... ...... ...... ...... ៦៣៣
តតិយអគតិសូត្រទី ៩ និងអដ្ឋកថា ...... ...... ...... ...... ៦៣៤
កត្តុទ្ទេសកសូត្រទី ១០ ...... ...... ...... ...... ៦៣៦
អដ្ឋកថាកត្តុទ្ទេសកសូត្រ ...... ...... ...... ...... ៦៣៨

### ឧរុវេលវគ្គ

បឋមឧរុវេលសូត្រទី ១ ...... ...... ...... ...... ៦៣៩
អដ្ឋកថាបឋមឧរុវេលសូត្រ ...... ...... ...... ...... ៦៤៣
ទុតិយឧរុវេលសូត្រទី ២ ...... ...... ...... ...... ៦៤៩
អដ្ឋកថាទុតិយឧរុវេលសូត្រ ...... ...... ...... ...... ៦៥២
លោកសូត្រទី ៣ ...... ...... ...... ...... ៦៥៨
អដ្ឋកថាលោកសូត្រ ...... ...... ...... ...... ៦៦០
កាឡកសូត្រទី ៤ ...... ...... ...... ...... ៦៦៥
អដ្ឋកថាកាឡកសូត្រ ...... ...... ...... ...... ៦៦៧
ព្រហ្មចរិយសូត្រទី ៥ ...... ...... ...... ...... ៦៧៧
អដ្ឋកថាព្រហ្មចរិយសូត្រ ...... ...... ...... ...... ៦៧៨
កុហសូត្រទី ៦ ...... ...... ...... ...... ៦៧៩
អដ្ឋកថាកុហសូត្រ ...... ...... ...... ...... ៦៨០
សន្តុដ្ឋិសូត្រទី ៧ ...... ...... ...... ...... ៦៨២
អដ្ឋកថាសន្តុដ្ឋិសូត្រ ...... ...... ...... ...... ៦៨៣
អរិយវង្សសូត្រទី ៨ ...... ...... ...... ...... ៦៨៤
អដ្ឋកថាអរិយវង្សសូត្រ ...... ...... ...... ...... ៦៨៨

ធម្មបទសូត្រទី ៩ ...... ...... ...... ...... ៧១៣
អដ្ឋកថាធម្មបទសូត្រ ...... ...... ...... ...... ៧១៤
បរិព្វាជកសូត្រទី ១០ ...... ...... ...... ...... ៧១៥
អដ្ឋកថាបរិព្វាជកសូត្រ ...... ...... ...... ...... ៧២០

## ចក្កវគ្គ

ចក្កសូត្រទី ១ ...... ...... ...... ...... ៧២៣
អដ្ឋកថាចក្កសូត្រ ...... ...... ...... ...... ៧២៤
សង្គហសូត្រទី ២ ...... ...... ...... ...... ៧២៥
អដ្ឋកថាសង្គហសូត្រ ...... ...... ...... ...... ៧២៦
សីហសូត្រទី ៣ ...... ...... ...... ...... ៧២៨
អដ្ឋកថាសីហសូត្រ ...... ...... ...... ...... ៧៣១
អគ្គប្បសាទសូត្រទី ៤ ...... ...... ...... ...... ៧៤១
អដ្ឋកថាអគ្គប្បសាទសូត្រ ...... ...... ...... ...... ៧៤៤
វស្សការសូត្រទី ៥ ...... ...... ...... ...... ៧៤៥
អដ្ឋកថាវស្សការសូត្រ ...... ...... ...... ...... ៧៤៩
ទោណសូត្រទី ៦ ...... ...... ...... ...... ៧៥០
អដ្ឋកថាទោណសូត្រ ...... ...... ...... ...... ៧៥៣
អបរិហានិសូត្រទី ៧ ...... ...... ...... ...... ៧៥៩
អដ្ឋកថាអបរិហានិសូត្រ ...... ...... ...... ...... ៧៦១
បដិលីនសូត្រទី ៨ ...... ...... ...... ...... ៧៦២
អដ្ឋកថាបដិលីនសូត្រ ...... ...... ...... ...... ៧៦៤
ឧជ្ជយសូត្រទី ៩ ...... ...... ...... ...... ៧៦៧
អដ្ឋកថាឧជ្ជយសូត្រ ...... ...... ...... ...... ៧៧០
ឧទាយិសូត្រទី ១០ ...... ...... ...... ...... ៧៧២

អដ្ឋកថាឧទាយិសូត្រ ...... ...... ...... ...... ៧៧៤

## ពោហិតស្សវគ្គ

សមាធិសូត្រទី ១ ...... ...... ...... ...... ៧៧៦
អដ្ឋកថាសមាធិសូត្រ ...... ...... ...... ...... ៧៨០
បញ្ហាសូត្រទី ២ ...... ...... ...... ...... ៧៨២
អដ្ឋកថាបញ្ហាសូត្រ ...... ...... ...... ...... ៧៨៣
បឋមកោធសូត្រទី ៣ ...... ...... ...... ...... ៧៨៤
អដ្ឋកថាបឋមកោធសូត្រ ...... ...... ...... ...... ៧៨៥
ទុតិយកោធសូត្រទី ៤ និងអដ្ឋកថា ...... ...... ...... ...... ៧៨៧
បឋមរោហិតស្សសូត្រទី ៥ ...... ...... ...... ...... ៧៨៧
អដ្ឋកថាបឋមរោហិតស្សសូត្រ ...... ...... ...... ...... ៧៩១
ទុតិយរោហិតស្សសូត្រទី ៦ និងអដ្ឋកថា ...... ...... ...... ...... ៧៩៣
សុវិទូរសូត្រទី ៧ ...... ...... ...... ...... ៧៩៧
អដ្ឋកថាសុវិទូរសូត្រ ...... ...... ...... ...... ៧៩៨
វិសាខសូត្រទី ៨ ...... ...... ...... ...... ៧៩៩
អដ្ឋកថាវិសាខសូត្រ ...... ...... ...... ...... ៨០១
វិបល្លាសសូត្រទី ៩ ...... ...... ...... ...... ៨០៣
អដ្ឋកថាវិបល្លាសសូត្រ ...... ...... ...... ...... ៨០៥
ឧបក្កិលេសសូត្រទី ១០ ...... ...... ...... ...... ៨០៧
អដ្ឋកថាឧបក្កិលេសសូត្រ ...... ...... ...... ...... ៨១០